# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៤៧

បាលីប្រែ ៥៨ - ៥៩

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# ជាតកដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ជាតក

## សត្តមភាគ ~ អដ្ឋមភាគ

# ៤៧

## បាលីប្រែ ៥៨-៥៩



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៤៧

# ចតុក្កនិបាត ជាតក កាលិង្គវគ្គ

## ចុល្លកាលិង្គជាតក

[ ៥០២ ] ( នន្ទិសេនាមាត្យពោលថា ) អ្នកទាំងឡាយ ចូរបើកទ្វារ ថ្វាយព្រះរាជធីតាទាំង ៤ ព្រះអង្គនេះ ដើម្បីស្តេចចូលទៅខាងក្នុងព្រះនគរ ដែលខ្ញុំជាអាមាត្យឈ្មោះនន្ទិសេន ជាបុរសសីហៈរបស់ព្រះបាទអរុណដែល អាចារ្យប្រៀនប្រដៅល្អ រក្សាល្អហើយ ។

[ ៥០៣ ] ( ព្រះបាទកាលិង្គពោលថា ) ម្នាលព្រហ្មចារិតាបស អ្នក ពោលយ៉ាងនេះថា ជំនះនឹងមានដល់ពួកកាលិង្គៈ ដែលជាអ្នកអត់ធន់ចំពោះ ទុក្ខភ័យដែលគេអត់ធន់មិនបាន បរាជ័យនឹងមានដល់ពួកអស្សកៈដូច្នេះ ជន ទាំងឡាយអ្នកមានសន្តានស្លូតត្រង់ មិនពោលនូវពាក្យមិនពិតឡើយ ។

[ ៥០៤ ] ( តាបសពោធិសត្វពោលថា ) បពិត្រសក្កទេវរាជ ពួក ទេវតាប្រព្រឹត្តកន្លងហើយនូវមុសាវាទ ព្រះអង្គគួរធ្វើនូវពាក្យពិតដ៏ទៀងទាត់ យ៉ាងក្រៃលែង បពិត្រមឃវទេវរាជជាធំលើផែនដី មួយ៉ាងទៀត ព្រះអង្គ អាស្រ័យហេតុអ្វី ទើបពោលនូវពាក្យមុសាវាទនោះ ។

[ ៥០៥ ] ( ព្រះឥន្ទ្រពោលថា ) បពិត្រព្រាហ្មណ៍ ក្រែងលោកបានឮពាក្យ គេនិយាយថា ពពួកទេវតា មិនប្រណែនចំពោះសេចក្តីព្យាយាមរបស់បុរស ទេ ការទូន្មានខ្លួន ១ ការតម្កល់មាំមិនបែកចិត្ត ១ ការមិនបន្ធូរបន្ថយការ ប្រឹងប្រែងក្នុងការគួរ ១ ព្យាយាមដ៏មាំ ១ ការសង្វាតរបស់បុរស ១ ( មាន

ដល់ពួកអស្សុរៈ ) ហេតុនោះបានជាជ័យជម្នះមានហើយដល់ពួកអស្សុរៈ ។

ចប់ ចុល្លកាលិង្គជាតកទី ១ ។

# ចតុក្កនិបាតជាតក

## កាលិង្គវគ្គ

### អដ្ឋកថា ចុល្លកាលិង្គជាតក

[ ៥០២-៥០៥ ] ព្រះសាស្តា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធបព្វជ្ជារបស់បរិព្វាជិកា ៤ នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វិវរថ ឥមាសំ ទ្វារំ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរវេសាលី មានស្តេចលិច្ឆវី ៧៧០៧ អង្គ ប្រថាប់នៅ ។ ក្សត្រលិច្ឆវីទាំងនោះ បានជាអ្នកមានព្រះតម្រិះក្នុងការសួរនិងការដេញដោល កាលនោះនិគ្រន្ថធ្លាតវៃក្នុងវាទៈ ៥០០ វាទៈ មកដល់នគរវេសាលី ស្តេចលិច្ឆវីទាំងនោះ ទ្រង់បានធ្វើការសង្គ្រោះនិគ្រន្ថនោះ ។ មាននិគ្រន្ថស្រី ជាអ្នកឈ្លាសវៃបែបនោះម្នាក់ទៀត ក៏មកដល់នគរវេសាលី ទើបក្សត្រទាំងឡាយឲ្យជនទាំងពីរលើកវាទៈដល់គ្នានឹងគ្នា ។ ជនទាំងពីរសុទ្ធតែជាអ្នកឈ្លាសវៃដូចគ្នា ។ លំដាប់នោះ ស្តេចលិច្ឆវីទាំងឡាយមានព្រះតម្រិះថា កូនដែលកើតឡើង ព្រោះអាស្រ័យជនទាំងពីរនេះ នឹងបានជាអ្នកឈ្លាសវៃក្រៃលែង ទើបធ្វើវិវាហមង្គលដល់ជនទាំងពីរនោះ ហើយឲ្យជនទាំងពីរនៅរួមគ្នា ។ សម័យ

តមក ព្រោះអាស្រ័យការនៅរួមគ្នា របស់និគ្រន្ថទាំងពីរនោះ ទើបកើតបាន ទារិកា ៤ នាក់ និងទារក ១ នាក់ដោយលំដាប់ ។ មាតាបិតាបានដាក់ ឈ្មោះទារិកាទាំង ៤ នាក់ថា សច្ចា ១ លោលា ១ អវវាទិកា ១ បដិច្ឆ-ទា ១ ហើយដាក់ ឈ្មោះទារកថា សច្ចកៈ ។ ជនទាំង ៥ នោះដឹងក្តីហើយ នាំគ្នារៀនវាទៈទាំង ១ ពាន់ គឺរៀនអំពីមាតា ៥០០ អំពីបិតា ៥០០ មាតា បិតាបានឲ្យឱវាទដល់ទារិកាទាំង ៤ យ៉ាងនេះថា បើអ្នកណាទម្លាយវាទៈ របស់ពួកនាងបាន បើជាគ្រហស្ថ នាងគប្បីជាបាទបរិចារិការបស់បុរសនោះ បើជាបព្វជិតទម្លាយបាន ក៏គួរបួសក្នុងសម្នាក់របស់បព្វជិតនោះ ។ ក្នុងកាល តមក មាតាបិតាក៏ធ្វើកាលកិរិយាទៅ ។ កាលមាតាបិតាធ្វើកាលកិរិយាទៅ ហើយ និគ្រន្ថប្រុសដែលជាកូនពៅ បង្រៀនសិប្បៈដល់ស្តេចលិច្ឆវីក្នុងនគរ វេសាលីនោះឯង ចំណែកបងស្រីទាំង ៤ កាន់មែកព្រីង ចេញអំពីនគរនេះ ទៅនគរនោះដើម្បីលើកវាទៈ រហូតដល់នគរសាវត្ថី ទើបដោតមែងព្រីងទុក ក្បែរទ្វារនគរហើយពោលដល់ក្មេងៗថា អ្នកណាជាគ្រហស្ថក្តី បព្វជិតក្តីអាច លើកវាទៈជាមួយពួកយើងបាន បុគ្គលនោះ ចូរយកជើងច្រឹះគំនរដីនេះឲ្យខ្ចាត់ ខ្ចាយ ហើយជាន់មែកព្រីងដោយជើងនោះឯង ហើយនាំគ្នាទៅកាន់ព្រះនគរ ដើម្បីភិក្ខាហារ ។ ក្នុងកាលនោះ ព្រះសារីបុត្តបោសទីដែលមិនទាន់បានបោស ដងទឹកដាក់ក្អមទទេ ប្រតិបត្តិភិក្ខុឈឺ ទើបចូលទៅបិណ្ឌបាតក្នុងនគរសាវត្ថី យឺតយូរបន្តិច ឃើញមែកព្រីងនោះ ទើបសួរទារកទាំងឡាយ ។ ទារកទាំង ឡាយប្រាប់ការប្រព្រឹត្តទៅនោះ ព្រះថេរៈឲ្យទារកទាំងនោះផ្តួលមែកព្រីងយក

ដើងជាន់ ហើយប្រាប់ពួកទារកថា បុគ្គលដែលដោតមែកព្រីងនេះទុក ធ្វើកត្តកិច្ច ត្រឡប់មកហើយ ចូរមកជួបអាត្មាត្រង់ខ្លោងទ្វារវិហារជេតពន ប្រាប់ហើយក៏ចូលទៅកាន់ព្រះនគរ ធ្វើកត្តកិច្ចស្រេចហើយ បានឈរត្រង់ខ្លោងទ្វារវិហារ ។ ចំណែកបរិព្វាជិកាទាំងនោះ ត្រាច់ភិក្ខាចារហើយត្រឡប់មក ឃើញមែកព្រីងត្រូវជាន់ ទើបពោលថា អ្នកណាជាន់មែកព្រីងនេះ ពួកក្មេងប្រាប់ថាព្រះសារីបុត្តត្ថេរជាន់ ហើយពោលថា បើអ្នកនាងម្ចាស់ទាំងឡាយត្រូវការលើកវាទៈ ចូរទៅកាន់ខ្លោងទ្វារព្រះវិហារ ។ ទើបនាំគ្នាត្រឡប់ចូលទៅក្នុងព្រះនគរវិញ ប្រាប់មហាជនឲ្យប្រជុំគ្នាហើយ ទៅកាន់ខ្លោងទ្វារព្រះវិហារ សួរវាទៈ ១០០០ ជាមួយព្រះថេរៈ ។ ព្រះថេរៈដោះស្រាយ ហើយសួរថា ពួកនាងចេះអ្វីទៀតដែរឬទេ បរិព្វាជិកាទាំងនោះពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំមិនចេះអ្វីដទៃទៀតឡើយ ទើបព្រះថេរៈពោលថា យើងនឹងសួរសំណួរមួយដល់ពួកនាង បរិព្វាជិកាទាំងនោះពោលថា សូមលោកម្ចាស់សួរចុះ បើពួកខ្ញុំដឹងនឹងឆ្លើយ ព្រះថេរៈសួរថា **ឯកំ ណាម កឹ** អ្វីឈ្មោះថា ១ បរិព្វាជិកាទាំងនោះមិនជ្រាប ទើបព្រះថេរៈវិសជ្ជនាឲ្យស្តាប់ បរិព្វាជិកាទាំងនោះពោលថា បពិត្រលោកម្ចាស់ បរាជ័យជារបស់ពួកខ្ញុំ ជ័យជម្នះជារបស់លោកម្ចាស់ ព្រះថេរៈសួរថា ឥឡូវនេះពួកនាងនឹងធ្វើដូចម្តេច បរិព្វាជិកាទាំង ៤ ឆ្លើយថា មាតាបិតារបស់ខ្ញុំបានឲ្យឱវាទនេះទុកថា បើគ្រហស្ថទម្លាយវាទៈរបស់ពួកនាងបាន ពួកនាងរមែងជាបជាបតីរបស់បុរសនោះ បើបព្វជិតទម្លាយបាន ក៏ចូរនាំគ្នាបួសក្នុងសម្នាក់របស់បព្វជិតនោះ ព្រោះហេតុនោះ សូមលោកម្ចាស់ឲ្យនូវ

បព្វជ្ជាដល់ពួកខ្ញុំចុះ ។ ព្រះថេរៈពោលថា សាធុ ហើយឲ្យនាងបួសក្នុងសម្នាក់របស់ព្រះនាងឧប្បលវណ្ណាថេរី មិនយូរប៉ុន្មាន ជនទាំងនោះបានសម្រេចអរហត្ត ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសារីបុត្តត្រូវជាទីពឹងអាស្រ័យរបស់បរិព្វាជិកាទាំង ៤ បានឲ្យនាងទាំងនោះសម្រេចអរហត្ត ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន សារីបុត្តក៏បានជាទីពឹងអាស្រ័យរបស់បរិព្វាជិកាទាំងនេះ ក្នុងកាលឥឡូវនេះបានឲ្យបព្វជ្ជាភិសេក តែក្នុងកាលមុនបានឲ្យតាំងនៅក្នុងតំណែងជាអគ្គមហេសីរបស់ព្រះរាជា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទកាលិង្គរាជ សោយរាជសម្បត្តិក្នុងនគរទន្តបុរៈ ដែនកាលិង្គៈ ។ ព្រះរាជាព្រះនាមថាអស្សកៈ គ្រងរាជសម្បត្តិក្នុងនគរ បាដលិក្នុងដែនអស្សកៈ ។ ព្រះបាទកាលិង្គៈទ្រង់សម្បូរដោយរេហ៍ពល និងពាហនៈ ព្រះអង្គក៏មានកម្លាំងដូចដំរីសារ មិនឃើញមានបុគ្គលដែលអាចប្រយុទ្ធជាមួយទ្រង់បាន ទ្រង់ជាបុគ្គលមានបំណងក្នុងការធ្វើចម្បាំង ទើបត្រាស់ប្រាប់ដល់អាមាត្យទាំងឡាយថា យើងមានសេចក្តីត្រូវការនឹងច្បាំង តែមិនឃើញបុគ្គលដែលអាចច្បាំងជាមួយយើង យើងនឹងធ្វើដូចម្តេច ។ អាមាត្យទាំង

ឡាយក្រាបទូលថា បពិត្រមហារាជ មានឧបាយមួយ ព្រះរាជធីតាទាំង ៤ របស់ទ្រង់មានរូបឆោមដ៏ឧត្តម សូមទ្រង់ប្រដាប់តាក់តែងព្រះរាជធីតាទាំងនោះ ហើយឲ្យអង្គុយក្នុងយានដែលបិទជិត ចោមរោមដោយរេហ៍ពល ហើយត្រាច់ទៅក្នុងគាមនិគម និងរាជធានីទាំងឡាយប្រកាសថា ព្រះរាជាអង្គណា មានបំណងនឹងទទួលយក ( ព្រះរាជធីតា ) ដើម្បីខ្លួន ពួកយើងនឹងធ្វើការច្បាំងជាមួយព្រះរាជាអង្គនោះ ទើបព្រះរាជាទ្រង់ធ្វើយ៉ាងនោះ ។ ក្នុងទីដែលព្រះរាជធីតាទាំងនោះយាងទៅហើយ ព្រះរាជាទាំងឡាយមិនព្រមឲ្យព្រះរាជធីតាទាំងនោះចូលព្រះនគរព្រោះភ័យខ្លាច នាំគ្នាបញ្ជូនគ្រឿងបណ្ណាការ ចេញទៅហើយឲ្យប្រថាប់នៅខាងក្រៅព្រះនគរ ។ ព្រះរាជធីតាទាំងនោះត្រាច់ទៅពេញជម្ពូទ្វីបដោយអាការៈយ៉ាងនេះ រហូតដល់ព្រះនគរបោដលិដែនអស្សកៈចំណែកព្រះបាទអស្សកៈ ទ្រង់ឲ្យបិទទ្វារព្រះនគរ ហើយទ្រង់បញ្ជូនបណ្ណាការទៅថ្វាយ ។ អាមាត្យរបស់ព្រះបាទអស្សកៈ ឈ្មោះនន្ទិសេន ជាបណ្ឌិតឈ្លាសវៃក្នុងឧបាយ នន្ទិសេនអាមាត្យនោះគិតថា បានឮថា រាជធីតារបស់ព្រះបាទកាលិង្គទាំងនេះ ត្រាច់ទៅពេញជម្ពូទ្វីប ក៏មិនមានអ្នកណាហ៊ានច្បាំង កាលបើយ៉ាងនេះ ជម្ពូទ្វីប ក៏បានឈ្មោះថាសាបសូន្យទទេចាកអ្នកចម្បាំង អញនឹងច្បាំងជាមួយព្រះបាទកាលិង្គ ។ នន្ទិសេនអាមាត្យនោះ ក៏ទៅកាន់ទ្វារព្រះនគរ ហៅអ្នករក្សាទ្វារមកដើម្បីឲ្យគេបើកទ្វារដល់ព្រះរាជធីតាទាំងនោះ ទើបពោលគាថាទី ១ ថា

អ្នកទាំងឡាយចូរបើកទ្វារថ្វាយព្រះរាជធីតាទាំង ៤ ព្រះអង្គ

នេះ ដើម្បីស្តេចចូលទៅខាងក្នុងព្រះនគរ ដែលខ្ញុំជាអាមាត្យ ឈ្មោះ នន្ទិសេនជាបុរសសីហៈរបស់ព្រះបាទ អរុណ ដែលអាចារ្យប្រៀនប្រដៅល្អ រក្សាល្អហើយ ដូច្នេះ ។

បណ្ដាបទថាទាំងនោះ បទថា **អរុណរាជស្ស** សេចក្ដីថា ព្រះរាជាអន្ធនោះ ក្នុងកាលតាំងនៅក្នុងរាជសម្បត្តិ ព្រះនាមថាអស្សកៈ ដោយអំណាចនៃឈ្មោះរបស់ដែន តែព្រះនាមថាអរុណៈ ជាព្រះនាមដែលរាជត្រកូលប្រទានដល់ព្រះរាជានោះ ដោយហេតុនោះ ទើបនន្ទិសេនអាមាត្យពោលថា **អរុណរាជស្ស** ដូច្នេះ ។ បទថា **សីហេន** បានដល់ ជាបុរសដូចរាជសីហ៍ ។ បទថា **សុសិដ្ឋេន** បានដល់ ដែលអាចារ្យទាំងឡាយទូន្មានល្អហើយ ។ បទថា **នន្ទិសេនេន** សេចក្ដីថា ដែលខ្ញុំឈ្មោះថានន្ទិសេន ។

កាលនោះនន្ទិសេនអាមាត្យពោលយ៉ាងនេះហើយ ទើបឲ្យបើកទ្វារទទួលព្រះរាជធីតាទាំង ៤ ទៅថ្វាយព្រះបាទអស្សកៈ ហើយក្រាបទូលថា សូមទ្រង់កុំខ្លាចរអាឡើយ បើមានការច្បាំងទូលបង្គំជានា សូមទ្រង់ធ្វើព្រះរាជធីតាដែលមានរូបឆោមដ៏ល្អទាំងនេះ ជាអគ្គមហេសីចុះ ហើយអភិសេកដល់ព្រះរាជធីតាទាំងនោះ ហើយបញ្ជូនរាជបុរសដែលមកជាមួយព្រះធីតាទាំងនោះត្រឡប់ទៅដោយពោលថា អ្នកទាំងឡាយចូរក្រាបទូលព្រះរាជារបស់អ្នក ដល់ភាពដែលព្រះបាទអស្សកៈទ្រង់តាំងព្រះរាជធីតាទាំង ៤ ទុកក្នុងតំណែងអគ្គមហេសី ។ រាជបុរសទាំងនោះ ទៅក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះបាទកាលិង្គទ្រង់ពោលថា ស្តេចអស្សកៈនោះប្រហែលជាមិនដឹងកម្លាំងរបស់យើងពិតប្រា

កជ ទើបយាងចេញទៅដោយសេនាធំក្នុងខណៈនោះមួយរំពេច ។ នន្ទិសេន អាមាត្យជ្រាបការយាងមក របស់ព្រះបាទកាលិង្គៈ ទើបបញ្ជូនសាសន៍ទៅថា សូមព្រះបាទកាលិង្គ នៅក្នុងរាជសីមារបស់ទ្រង់ប៉ុណ្ណោះ កុំកន្លងរាជសីមា របស់ព្រះរាជាទូលបង្គំមកឡើយ ការច្បាំងនឹងមានក្នុងរវាងដែនទាំងពីរ ។ ព្រះបាទកាលិង្គស្តាប់សាសន៍នោះហើយ ទ្រង់ក៏ឈប់ បោះជំរុំទ័ពទុកខាងក្នុង រាជអាណាខេត្តរបស់ទ្រង់ ។ ចំណែកព្រះបាទអស្សកៈ ក៏ទ្រង់បញ្ឈប់កងទ័ព ខាងចុងរាជអាណាខេត្តរបស់ទ្រង់ដូចគ្នា ។

គ្រានោះ ព្រះពោធិសត្វបួសជាឥសី នៅត្រង់បណ្ណសាលាក្នុងចន្លោះអា-ណាខេត្តនៃព្រះរាជាទាំងពីរនោះ ។ ព្រះបាទកាលិង្គ ទ្រង់ព្រះតម្រិះថា ធម្មតា សមណៈទាំងឡាយរមែងដឹងរបស់ណាមួយ អ្នកណាដឹងថា តើអ្វីនឹងមាន ជ័យជម្នះឬបរាជ័យ នឹងមានដល់អ្នកណា អញនឹងសួរតាបសមើល ដូច្នេះ ហើយ ទើបចូលទៅរកព្រះពោធិសត្វ ដោយភេទដែលគេមិនស្គាល់ ថ្វាយ បង្គំហើយអង្គុយក្នុងចំណែកម្ខាង ធ្វើបដិសណ្ឋារៈហើយសួរថា បពិត្រលោក ម្ចាស់ ព្រះបាទកាលិង្គៈច្បាំងនឹងព្រះបាទអស្សកៈ នាំគ្នាតាំងកងទ័ពក្នុងរាជ សីមារៀងៗខ្លួន ក្នុងព្រះរាជាទាំងពីរអង្គនោះ អ្នកណាឈ្នះអ្នកណាចាញ់ ។ តាបសពោធិសត្វក្រាបទូលថា នែអ្នកមានបុណ្យច្រើន អាត្មាមិនដឹងថាអង្គណា ឈ្នះអង្គណាចាញ់ទេ តែសក្កទេវរាជមកក្នុងទីនេះ អាត្មានឹងសួរសក្កទេវរាជ នោះ ហើយទើបប្រាប់ឲ្យដឹង ស្អែកនេះចូរអ្នកមកស្តាប់ចុះ ។ សក្កទេវរាជ យាងមកកាន់ទីបម្រើរបស់ព្រះពោធិសត្វ ហើយប្រថាប់គង់ ។ ពេលនោះ

ទើបព្រះពោធិសត្វទូលសួរសេចក្តីនោះនឹងសក្កទេវរាជ សក្កទេវរាជព្យាករថា បពិត្រលោកម្ចាស់ ព្រះបាទកាលិង្គមានជ័យជម្នះ ព្រះបាទអស្សកៈបរាជ័យ ម្យ៉ាងទៀត បុព្វនិមិត្តនេះនឹងប្រាកដ ក្នុងថ្ងៃស្អែកឡើង ព្រះបាទកាលិង្គយាង មកសួរ ព្រះពោធិសត្វទូលដល់ព្រះបាទកាលិង្គនោះ ព្រះបាទកាលិង្គមិនត្រាស់ សួរថា បុព្វនិមិត្តអ្វីនឹងប្រាកដ ទ្រង់ក្រោកឡើង លីលាចេញទៅដោយព្រះ ហឫទ័យត្រេកអរថា អញនឹងមានជ័យជម្នះ ។ រឿងនោះបានល្បីទៅហើយ ព្រះបាទអស្សកៈទ្រង់បានស្តាប់រឿងនោះ ទើបហៅនន្ទិសេនាមាត្យ ហើយប្រាប់ ថា បានឮថាខាងព្រះបាទកាលិង្គជាអ្នកឈ្នះ ខាងយើងនឹងចាញ់ យើងគួរ ធ្វើដូចម្តេច នន្ទិសេនាមាត្យនោះក្រាបទូលថា បពិត្រមហារាជ អ្នកណាជ្រាប សេចក្តីនោះបានថា ជ័យជម្នះឬបរាជ័យជារបស់អ្នកណា សូមទ្រង់កុំគិតថ្វី ឡើយ កាលក្រាបទូលឲ្យព្រះរាជាស្ងប់ចិត្តហើយ ទើបចូលទៅរកព្រះពោធិ សត្វ ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាងសួរថា បពិត្រលោកម្ចាស់ អ្នក ណាឈ្នះ អ្នកណាចាញ់ ព្រះពោធិសត្វពោលថា ព្រះបាទកាលិង្គៈឈ្នះ ព្រះ បាទអស្សកៈចាញ់ អាមាត្យនន្ទិសេនសួរថា បពិត្រលោកម្ចាស់ បុព្វនិមិត្តអ្វី មានដល់អ្នកឈ្នះ បុព្វនិមិត្តអ្វីមានដល់អ្នកចាញ់ ព្រះពោធិសត្វពោលថាអ្នក មានបុណ្យច្រើន អារក្ខទេវតារបស់អ្នកឈ្នះ គឺជាគោដែលមានពណ៌សសុទ្ធ អារក្ខទេវតារបស់អ្នកចាញ់ជាគោដែលមានពណ៌ខ្មៅសុទ្ធ អារក្ខទេវតាទាំងពីរ ចំណែកច្បាំងគ្នាហើយនឹងធ្វើនូវការមានជ័យជម្នះនិងបរាជ័យ ។ នន្ទិសេនា មាត្យបានស្តាប់ពាក្យនោះ ទើបក្រោកឡើង លាតាបសទៅ នាំទាហានធំ

ប្រមាណមួយពាន់នាក់ដែលជាសម្លាញ់របស់ព្រះរាជា ឡើងទៅកាន់ភ្នំដែលមិនឆ្ងាយប៉ុន្មាន ហើយសួរថា អ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកអាចថ្វាយជីវិតដល់ព្រះរាជារបស់ពួកយើងបានដែរឬទេ ទាហានធំទាំងនោះពោលថា ពួកខ្ញុំអាចថ្វាយបាន ។ នន្ទិសេនាមាត្យ ពោលថា បើយ៉ាងនោះ ពួកអ្នកចូរលោតទៅក្នុងជ្រោះនេះ ។ ទាហានធំទាំងនោះបានត្រៀមខ្លួន ដើម្បីលោត ទើបនន្ទិសេនាមាត្យឃាត់ទាហានធំទាំងនោះហើយពោលថា កុំលោតឡើយ អ្នកទាំងឡាយជាអ្នកមានចិត្តល្អ ជាអ្នកមិនថយក្រោយ ជួយគ្នាច្បាំងដើម្បីថ្វាយជីវិតដល់ព្រះរាជារបស់យើងទាំងឡាយចុះ ។ ទាហានធំទាំងនោះទទួលពាក្យហើយ ។ កាលសង្គ្រាមប្រឈមមុខគ្នា ព្រះបាទកាលិង្គទ្រង់សប្បាយព្រះហឫទ័យថា បានឮថាពួកយើងនឹងឈ្នះ ទើបបន្ធូរបន្ថយព្យាយាម សូម្បីពលនិកាយរបស់ព្រះអង្គ ក៏នាំគ្នាដាក់ចិត្តថា ពួកយើងនឹងមានជ័យជម្នះ ដូច្នេះហើយ ទើបបន្ធូរបន្ថយព្យាយាម មិនចងគ្នាជាពួក នាំគ្នាជៀសចេញទៅតាមគាប់ចិត្ត ក្នុងពេលនឹងធ្វើសេចក្ដីព្យាយាមក៏មិនធ្វើ ។ ចំណែកព្រះរាជាទាំងពីរអង្គ ទ្រង់ឡើងលើខ្នងសេះចូលទៅរកគ្នានឹងគ្នាដោយបំណងថានឹងច្បាំង ។ អារក្ខទេវតារបស់ព្រះរាជាទាំងពីរចេញទៅខាងមុខ អារក្ខទេវតារបស់ព្រះបាទកាលិង្គៈជាគោសសុទ្ធ អារក្ខទេវតារបស់ព្រះបាទអស្សកៈជាគោខ្មៅសុទ្ធ គោទាំងនោះ ក៏ចូលទៅរកគ្នានឹងគ្នា សម្ដែងអាការៈប្រយុទ្ធ ។ គោទាំងនោះរមែងប្រាកដដល់ព្រះរាជាទាំងពីរអង្គប៉ុណ្ណោះ មិនប្រាកដដល់អ្នកដទៃ ។ នន្ទិសេនាមាត្យទូលសួរព្រះបាទអស្សកៈថា បពិត្រមហារាជ អារក្ខទេវតាប្រាកដ

ដល់ទ្រង់ហើយឬនៅ ព្រះបាទអស្សកៈត្រាស់ថា អើប្រាកដ នន្ទិសេនាមាត្យសួរថាប្រាកដដោយអាការៈដូចម្តេច ព្រះបាទអស្សកៈពោលថា អារក្ខទេវតារបស់ព្រះបាទកាលិង្គ ប្រាកដជាគោសសុទ្ធ អារក្ខទេវតារបស់យើង ប្រាកដជាគោខ្មៅសុទ្ធកំពុងជួបសេចក្តីលំបាក នន្ទិសេនាមាត្យក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំខ្លាចឡើយ ពួកយើងនឹងឈ្នះ ព្រះបាទកាលិង្គៈនឹងចាញ់ សូមទ្រង់ចុះពីលើខ្នងសេះ កាន់លំពែងនេះ យកព្រះហស្តឆ្វេងទះត្រង់ពោះសេះសន្ធពដែលសិក្សាល្អហើយ ប្រញាប់ទៅមួយអន្លើដោយបុរសមួយពាន់នាក់នេះ យកលំពែងប្រហារអារក្ខទេវតារបស់ព្រះបាទកាលិង្គៈឲ្យដួលចុះ បន្ទាប់អំពីនោះ ពួកទូលបង្គំប្រមាណមួយពាន់នាក់នឹងប្រហារដោយលំពែង មួយពាន់ដើម កាលធ្វើយ៉ាងនេះ អារក្ខទេវតារបស់ព្រះបាទកាលិង្គៈនឹងវិនាស បន្ទាប់អំពីនោះ ព្រះបាទកាលិង្គៈនឹងចាញ់ ពួកយើងនឹងឈ្នះ ព្រះរាជាទ្រង់ទទួលថា សាធុ ហើយយាងទៅ យកលំពែងចាក់តាមសញ្ញាដែលនន្ទិសេនាមាត្យថ្វាយ ចំណែកអ្នកចម្បាំងដែលក្លៀវក្លាទាំងឡាយ ក៏ចាក់ដោយលំពែងមួយពាន់ ។ អារក្ខទេវតារបស់ព្រះបាទកាលិង្គៈ ក៏ដល់នូវការស្លាប់ក្នុងទីនោះឯង ។ រំពេចនោះ ព្រះបាទកាលិង្គៈទ្រង់ក៏ចាញ់គេចទៅ ។ អាមាត្យទាំងឡាយ ១ ពាន់នាក់ ឃើញព្រះបាទកាលិង្គៈគេចទៅ ក៏នាំគ្នាស្រែកថា ព្រះបាទកាលិង្គរត់ទៅហើយ ។ ព្រះបាទកាលិង្គៈទ្រង់ខ្លាចចំពោះមរណភ័យ យាងគេចទៅ កាលទ្រង់ជេរតាបសនោះ ទើបពោលគាថាទី ២ ថា

ម្នាលព្រហ្មចារីតាបស អ្នកពោលយ៉ាងនេះថា ជម្នះនឹងមាន

ដល់ពួកកាលិង្គៈ ដែលជាអ្នកអត់ធន់ចំពោះទុក្ខភ័យ ដែលគេអត់ធន់មិនបាន បរាជ័យនឹងមានដល់ពួកអស្សកៈដូច្នេះ ជនទាំងឡាយអ្នកមានសន្តានស្លូតត្រង់ មិនពោលនូវពាក្យមិនពិតឡើយ ដូច្នេះ ។

បណ្ដាបទថាទាំងនោះ បទថា **អសយ្ហសាហិនំ** បានដល់ អាចញ៉ាំញីបុគ្គលដែលបុគ្គលណាមួយញ៉ាំញីមិនបាន គឺញ៉ាំញីបានដោយក្រ ។ បទថា **ឥច្ចេវំ តេ ភាសិតំ** សេចក្ដីថា នែតាបសកោង អ្នកទទួលយកថ្លៃឈ្នួលហើយពោលយ៉ាងនេះនឹងព្រះរាជាអ្នកចាញ់ថា នឹងឈ្នះ ពោលនឹងព្រះរាជាដែលឈ្នះថា នឹងចាញ់ ។ បទថា **ន ឧជុភូតា** សេចក្ដីថា ជនទាំងឡាយណា ជាអ្នកស្មោះត្រង់ដោយកាយ វាចានិងចិត្ត ជនទាំងនោះរមែងមិនពោលកុហកយ៉ាងនេះ ។

ព្រះបាទកាលិង្គនោះ កាលជេរតាបសយ៉ាងនេះហើយ ក៏យាងគេចទៅកាន់នគររបស់ព្រះអង្គ មិនអាចងាកមកក្រឡេកមើល ។ បន្ទាប់អំពីនោះ កាលកន្លងទៅ ២-៣ ថ្ងៃ សក្កទេវរាជបានយាងមកកាន់ទីបម្រើរបស់តាបស ។ តាបសកាលនឹងទូលដល់សក្កទេវរាជ ទើបពោលគាថាទី ៣ ថា

បពិត្រសក្កទេវរាជ ពួកទេវតាប្រព្រឹត្តកន្លងហើយនូវមុសាវាទ ព្រះអង្គ គួរធ្វើនូវពាក្យពិតដ៏ទៀងទាត់យ៉ាងក្រៃលែង បពិត្រមឃវទេវរាជ ជាធំលើផែនដី ម្យ៉ាងទៀត ព្រះអង្គអាស្រ័យហេតុអ្វី ទើបពោលនូវពាក្យមុសាវាទនោះ ដូច្នេះ ។

បណ្ដាបទថាទាំងនោះ បទថា **តណ្ឌ មុសា ភាសិតំ** សេចក្ដីថា ពាក្យណាព្រះអង្គត្រាស់ទុកដល់អាត្មា ពាក្យនោះទ្រង់ធ្វើមុសាវាទ ដែលកាច់បំបាក់នូវប្រយោជន៍ ទ្រង់ត្រាស់ពាក្យកុហក ទ្រង់អាស្រ័យហេតុអ្វីទើបត្រាស់ពាក្យនោះយ៉ាងនេះ ។ សក្កទេវរាជស្ដាប់ពាក្យនោះហើយទើបត្រាស់គាថាទី ៤ ថា

បពិត្រព្រាហ្មណ៍ ក្រែងលោកបានឮពាក្យគេនិយាយថា ពពួក
ទេវតាមិនប្រណែនចំពោះសេចក្ដីព្យាយាមរបស់បុរសទេ ការ
ទូន្មានខ្លួន ១ ការតម្កល់មាំមិនបែកចិត្ត ១ ការមិនបន្ទរបន្ទយ
ការប្រឹងប្រែងក្នុងការគួរ ១ ព្យាយាមដ៏មាំ ១ ការសង្វាត
របស់បុរស ១ ( មានដល់ពួកអស្សកៈ ) ហេតុនោះបានជា
ជ័យជម្នះមានហើយដល់ពួកអស្សកៈ ដូច្នេះ ។

គាថាទី ៤ នោះ មានអធិប្បាយដូច្នេះថា នែព្រាហ្មណ៍ កាលគេពោលក្នុងទីនោះៗ លោកមិនធ្លាប់បានឮពាក្យនេះឬថា ទេវតាទាំងឡាយរមែងមិនប្រណែន មិនឫស្យាក្នុងការព្យាយាមរបស់កូនប្រុស រមែងសង្កត់ចិត្ត ពោលគឺការទូន្មានខ្លួន ដូចជាការធ្វើសេចក្ដីព្យាយាមរបស់ព្រះបាទអស្សកៈ ការមានចិត្តមិនបែកគ្នា មានសាមគ្គីគ្នា ការត្រេកអរតាំងមាំមិនបែកខ្ញែកគ្នា ការមិនប្រណាំងប្រជែងគ្នាក្នុងពេលធ្វើសេចក្ដីព្យាយាម នៃពួកសម្លាញ់របស់ព្រះបាទអស្សកៈ ការមិនរួញរា ( ដែលផ្ទុយគ្នានឹង ) មនុស្សរបស់ព្រះបាទកាលិង្គៈ ដែលបែកគ្នាជាពួកៗ រួញរាដូច្នោះ ម្យ៉ាងទៀត សេចក្ដីព្យាយាមនិងការប្រឹងប្រែងនៃបុរសរបស់បុគ្គលដែលមានចិត្តបែកខ្ញែកគ្នា បានជាគុណធម៌

ដែលមាំទាំ ព្រោះជាអ្នកមានការសាមគ្គីគ្នា ព្រោះហេតុនោះឯង ទើបជ័យជម្នះមានដល់ពួកស្តេចអស្សក: ។

កាលព្រះបាទកាលិង្គគេចទៅហើយ ព្រះបាទអស្សកៈ បានបោសសម្អាតឈើយទិងយុទ្ធភណ្ឌ ហើយយាងចូលទៅកាន់ព្រះនគររបស់ព្រះអង្គ អាមាត្យនន្ទិសេន បញ្ជូនសាសន៍ទៅថ្វាយព្រះបាទកាលិង្គថា សូមទ្រង់បញ្ជូនមតិកមកថ្វាយព្រះរាជធីតាទាំង ៤ អង្គនេះ បើទ្រង់មិនបញ្ជូនមក ពួកយើងនឹងដឹងកិច្ចដែលត្រូវធ្វើក្នុងរឿងនេះ ។ ព្រះបាទកាលិង្គទ្រង់ស្ដាប់សាសន៍នោះហើយ ខ្លាចផង តក់ស្លុតផង ទើបបញ្ជូនរាជទ្រព្យមតិកដែលរាជធីតាទាំងនោះគប្បីបាន មកឲ្យ ។ ចាប់តាំងពីនោះមក ព្រះរាជាទាំងពីរ រស់នៅដោយសាមគ្គីគ្នា ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជធីតារបស់ព្រះបាទកាលិង្គក្នុងកាលនោះ បានមកជាភិក្ខុនីទាំងនេះក្នុងកាលឥឡូវនេះ អាមាត្យនន្ទិសេនក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចុល្លកាលិង្គជាតក ចប់

# មហាអស្សារោហជាតក

[ ៥០៦ ] ( ព្រះរាជាពោធិសត្វត្រាស់ថា ) បុគ្គលណា កាលឲ្យចំពោះជនទាំងឡាយ ដែលមិនដែលឲ្យ ( ដល់ខ្លួន ) មិនឲ្យចំពោះជនទាំងឡាយដែលធ្លាប់ឲ្យ បុគ្គលនោះបានដល់នូវសេចក្តីវិនាស មិនបាននូវមិត្តសំឡាញ់ក្នុងគ្រាមានសេចក្តីអន្តរាយទាំងឡាយ ។

[ ៥០៧ ] បុគ្គលណា មិនឲ្យទានចំពោះជនទាំងឡាយដែលមិនដែលឲ្យ បានឲ្យចំពោះជនទាំងឡាយដែលឲ្យ បុគ្គលនោះក៏ដល់នូវសេចក្តីវិនាស មិនបាននូវសំឡាញ់ក្នុងកាលមានសេចក្តីអន្តរាយទាំងឡាយ ។

[ ៥០៨ ] ការសម្តែងនូវសេចក្តីស្និទ្ធស្នាលនិងការបរិភោគរួមឲ្យវិសេសក្នុងពួកជនអ្នកមានធម៌មិនប្រសើរ ជាអ្នកអួតអាង ក៏រមែងវិនាស ម្យ៉ាងទៀត សូម្បីទានបន្តិចបន្តួចដែលបុគ្គលធ្វើហើយចំពោះពួកព្រះអរិយផង ចំពោះពួកបុគ្គលអ្នកមានចិត្តស្លូតត្រង់ផង ជាទានមានផលច្រើន ។

[ ៥០៩ ] បុគ្គលណា បានធ្វើឧបការៈដ៏ល្អទុកហើយក្នុងកាលមុនបុគ្គលនេះឈ្មោះថា បានធ្វើអំពើដែលគេធ្វើបានដោយក្រក្រៃពេកក្នុងលោក លុះដល់កាលជាខាងក្រោយ បុគ្គលនោះធ្វើ ( គុណានីមួយដទៃទៀតក្តី ) មិនធ្វើក្តី ក៏ឈ្មោះថាជាបុគ្គលគួរដល់កិរិយាបូជាដោយពិត ។

**ចប់ មហាអស្សារោហជាតកទី ២ ។**

# អដ្ឋកថា
# មហាអស្សារោហជាតក

[ ៥០៦-៥០៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អយោឃរស្មិ ធមំ ធានំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន បានពោលទុកហើយខាងដើមនោះឯង ។ ក្នុងជាតកនេះ ព្រះសាស្ដាត្រាស់ថា បុរាណកបណ្ឌិតទាំងឡាយ ក៏បានធ្វើហើយដោយអំណាចឧបការៈដល់ខ្លួន ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះពោធិសត្វជាព្រះរាជាក្នុងនគរពារាណសី ទ្រង់គ្រងរាជដោយធម៌ ឲ្យទានរក្សាសីល ។ ព្រះបាទពារាណសីនោះ ទ្រង់ព្រះតម្រិះថានឹងបង្ក្រាបជាយដែន ដែលបះបោរឲ្យស្ងប់ ទើបទ្រង់ចោមរោមដោយពលយោធាយាងទៅ ទ្រង់ចាញ់ ទើបទ្រង់ឡើងសេះគេចទៅដល់បច្ចន្តគាមជាយដែនមួយកន្លែង ។ ជន ៣០ នាក់ដែលជាសេវកៈ នៅក្នុងបច្ចន្តគាមនោះ ។ មនុស្សទាំងនោះប្រជុំគ្នាត្រង់កណ្ដាលស្រុកអំពីព្រលឹម ធ្វើកិច្ចការក្នុងស្រុក ។ ខណៈនោះ ព្រះរាជាទ្រង់ឡើងសេះដែលហ្វឹកហើយ ទ្រង់ប្រដាប់តាក់តែងដោយគ្រឿងសឹក យាងចូលទៅក្នុងស្រុក តាមទ្វារស្រុក ។ មនុស្សទាំងនោះគិតថា នេះអ្វីហ្ន៎ ទើបខ្លាចនាំគ្នាគេចចូលផ្ទះរៀងៗខ្លួន ។ ក្នុងមនុស្សទាំងនោះ មានបុរសម្នាក់មិនគេចចូលផ្ទះ ធ្វើការទទួលព្រះរាជា ហើយសួរថា ខ្ញុំបានឮថា ព្រះរាជាយាងទៅបច្ចន្តជនបទ តើលោកជានរណា ជារាជបុរស ឬចារបុរស ព្រះរាជាត្រាស់ថា នែសម្លាញ់ ខ្ញុំជារាជបុរស ។ មនុស្សនោះពោល

ថា បើយ៉ាងនោះ សូមលោកមកចុះ ហើយនាំព្រះរាជាទៅកាន់ផ្ទះ ឲ្យអង្គុយលើតាំងរបស់ខ្លួន ហើយពោលថា នែនាងដ៏ចម្រើន ចូរនាងមកលាងជើងរបស់សម្លាញ់ កាលឲ្យកិរិយាលាងជើងរបស់ព្រះរាជានោះហើយ ឲ្យអាហារតាមសមគួរដល់កម្លាំងរបស់ខ្លួន ហើយក្រាលទីដេកដោយពោលថា សូមលោកសម្រាកមួយស្របក់ ព្រះរាជាក៏ផ្ទំហើយ ។ ចំណែកបុរសម្ចាស់ផ្ទះ ដោះគ្រឿងក្រោះរបស់សេះចេញដើម្បីឲ្យដើរបានស្រួល ឲ្យផឹកទឹក យកប្រេងលាបខ្នងហើយឲ្យស្មៅ ។ បុរសនោះ បដិបត្តិព្រះរាជាយ៉ាងនេះបាន ៣-៤ ថ្ងៃ ព្រះរាជាត្រាស់ថា សម្លាញ់ខ្ញុំនឹងទៅ ទើបធ្វើកិច្ចសមគួរទាំងពួង ដែលគប្បីធ្វើដល់ព្រះរាជានិងសេះម្តងទៀត ។ ព្រះរាជាត្រេកអរហើយ កាលនឹងយាងទៅបានត្រាស់ថា នែសម្លាញ់ ខ្ញុំឈ្មោះមហាអស្សារោហៈ ផ្ទះរបស់ខ្ញុំនៅកណ្តាលព្រះនគរ បើឯងមកកាន់ព្រះនគរដោយកិច្ចណាមួយ ចូរឈរត្រង់ទ្វារទិសទក្សិណ ហើយពោលនឹងអ្នកយាមទ្វារថា បុរសឈ្មោះមហាអស្សា-រោហៈនៅផ្ទះមួយណា ហើយគប្បីនាំអ្នកយាមទ្វារទៅកាន់ផ្ទះរបស់ខ្ញុំ ត្រាស់ដូច្នេះហើយ ក៏យាងជៀសចេញទៅ ។ ចំណែកពួកពលយោធាមិនឃើញព្រះរាជាទើបបោះព្រះពន្លាខាងក្រៅព្រះនគរ កាលឃើញព្រះរាជាហើយ ក៏នាំគ្នាក្រោកទទួល ចោមរោម ព្រះរាជាកាលយាងចូលព្រះនគរ បានប្រថាប់ឈរត្រង់រវាងទ្វារត្រាស់ឲ្យហៅទ្វារបាលមក ឲ្យមហាជនថយចេញ ហើយត្រាស់ថា នែបា អ្នកស្រុកបច្ចន្តគាមម្នាក់មានបំណងមកជួបយើង មកហើយនឹងសួរអ្នកថា ផ្ទះរបស់នាយមហាអស្សារោហៈនៅឯណា ឯងគប្បីចាប់ដៃគេទុក

ហើយនាំមកបង្ហាញយើងឲ្យគេឃើញ ក្នុងកាលនោះ អ្នកនឹងបានទ្រព្យមួយពាន់ ។ ចំណែកបុរសនោះ ក៏មិនមកគាល់ កាលបុរសនោះមិនមកគាល់ព្រះរាជា ទើបព្រះរាជាឲ្យបន្ថែមពលីក្នុងស្រុកដែលបុរសនោះនៅ កាលបន្ថែមពលីហើយ បុរសនោះក៏នៅតែមិនមក ។ កាលបើយ៉ាងនោះ ទើបទ្រង់ឲ្យបន្ថែមពលីលើកទី ២ លើកទី ៣ បុរសនោះនៅតែមិនមកនោះឯង ។ លំដាប់នោះទើបអ្នកស្រុកទាំងឡាយប្រជុំគ្នា ហើយនិយាយនឹងបុរសនោះថា នែអ្នកតាំងពីនាយអស្សារោហៈសម្លាញ់របស់អ្នកមក ពួកយើងត្រូវបៀតបៀនដោយពលីរហូតមិនអាចងើបក្បាលរួច ចូរអ្នកទៅ ចូរប្រាប់ដល់នាយមហាអស្សារោហៈសម្លាញ់របស់អ្នក ឲ្យជួយដោះពលីរបស់ពួកយើងផង ។ បុរសនោះពោលថា សាធុ ខ្ញុំនឹងទៅ តែខ្ញុំមិនអាចមានដៃទទេទៅឡើយ សម្លាញ់របស់ខ្ញុំមានកូន ២ នាក់ អ្នកទាំងឡាយចូររៀបចំគ្រឿងស្លៀកដណ្ដប់ និងគ្រឿងប្រដាប់ដើម្បីក្មេង ២ នាក់នោះ ដើម្បីភរិយារបស់គេនិងដើម្បីសម្លាញ់របស់ខ្ញុំ ។ អ្នកស្រុកទាំងនោះពោលថា បាន ពួកយើងនឹងរៀបចំឲ្យ ហើយនាំគ្នាចាត់ចែងគ្រឿងបណ្ណាការគ្រប់យ៉ាង បុរសនោះកាន់យកគ្រឿងបណ្ណាការនោះនិងនំដែលចៀនដោយខ្លាញ់ក្នុងផ្ទះរបស់ខ្លួនទៅ កាលដល់ទ្វារទិសខាងត្បូងទើបសួរទ្វារបាលថា រ៉ៃយសម្លាញ់ ផ្ទះរបស់នាយមហាអស្សារោហៈនៅឯណា ទ្វារបាលនោះពោលថា ចូរអ្នកមក ខ្ញុំនឹងបង្ហាញដល់អ្នក ហើយដឹកដៃនាំទៅកាន់ទ្វារព្រះរាជនិវេសន៍ បញ្ជូនដំណឹងឲ្យទ្រង់ជ្រាបថា នាយទ្វារបាលនាំបុរសអ្នកបច្ចន្តគាមម្នាក់មកហើយ ។ ព្រះរាជាគ្រាន់តែបានស្ដាប់ ក៏ក្រោកឡើងអំពី

អាសនៈត្រាស់ថា សម្លាញ់របស់យើងចូរមកជាមួយនាយទ្វារប៉ុណ្ណោះ ហើយទ្រង់ធ្វើបដិសណ្ឋារៈ គ្រាន់តែទ្រង់បានឃើញប៉ុណ្ណោះ ទ្រង់រក់ទាក់បុរសនោះ ហើយត្រាស់សួរថា កិរិយាសម្លាញ់និងកូនៗរបស់យើង មិនមានរោគទេឬ ហើយទ្រង់ចាប់ដៃនាំឡើងប្រាសាទ ឲ្យអង្គុយលើអាសនៈ ខាងក្រោមស្វេតឆត្រ ត្រាស់ហៅអគ្គមហេសីមកហើយ ត្រាស់ថា នែនាងដ៏ចម្រើន ចូរនាងលាងជើងសម្លាញ់របស់យើង អគ្គមហេសីនោះបានលាងជើងបុរសនោះ ព្រះរាជាទ្រង់ស្រោចទឹកដោយព្រះសុវណ្ណភិង្គារ ព្រះទេវីទ្រង់លាងជើង ហើយលាបដោយប្រេងក្រអូប ។ ព្រះរាជាត្រាស់សួរថា នែ សម្លាញ់ របស់ទំពាសម្រាប់ពួកយើងណាមួយមានខ្លះដែរឬ បុរសនោះពោលថា មាន ហើយនាំយកនំមកអំពីបង្វេច ។ ព្រះរាជាទ្រង់ទទួលដោយចានមាស កាលនឹងធ្វើការសង្គ្រោះលើកទឹកចិត្តទើបត្រាស់ថា អ្នកទាំងឡាយ ចូរទំពាស៊ីនំដែលសម្លាញ់យើងនាំមក ហើយប្រទានដល់ព្រះទេវីនិងអាមាត្យទាំងឡាយ សូម្បីព្រះអង្គឯងក៏ទ្រង់សោយ ។ ចំណែកបុរសនោះ ក៏បង្ហាញគ្រឿងបណ្ណាការដទៃថ្វាយ កាលទ្រង់សង្គ្រោះបុរសនោះ ទើបព្រះរាជាទ្រង់ដោះសំពត់កាសិកព័ស្ត្រ ហើយទ្រង់ស្លៀកគូសំពត់ដែលនាំមកថ្វាយ ចំណែកព្រះទេវី ក៏ដោះសំពត់កាសិកសាដកនិងគ្រឿងអាភរណៈទាំងឡាយចេញ ហើយព្រះនាងស្លៀកសំពត់សាដកដែលបុរសនោះនាំមក ហើយប្រដាប់គ្រឿងអាភរណៈ ។ លំដាប់នោះ ព្រះរាជាឲ្យបុរសសម្លាញ់នោះបរិភោគភោជន ដែលគួរដល់ព្រះរាជា ហើយទ្រង់បញ្ជាអាមាត្យម្នាក់ថា ចូរអ្នកឲ្យជាងធ្វើការកោរពុកមាត់ដល់បុរសនេះ តាម

ទំនងដែលធ្វើដល់យើងនោះឯង ហើយឲ្យងូតដោយទឹកក្រអូប ស្លៀកសំពត់កាសិកព័ស្ត្រដែលមានតម្លៃមួយសែន ឲ្យប្រដាប់ដោយគ្រឿងអលង្ការសម្រាប់ព្រះរាជា ហើយចូរនាំមក អាមាត្យនោះបានធ្វើយ៉ាងនោះ ។ ព្រះរាជាត្រាស់ឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ឲ្យអាមាត្យទាំងឡាយប្រជុំគ្នាហើយឲ្យសំយុងអំបោះក្រហមកណ្តាលស្វេតឆត្រ ព្រះរាជទានរាជសម្បត្តិពាក់កណ្តាលដល់បុរសសម្លាញ់នោះ ។ តាំងអំពីកាលនោះ ព្រះរាជាទាំងពីរនោះ ក៏រួមសោយរួមផឹក រួមផ្ទំជាមួយគ្នា ការស្និទ្ធស្នាល ក៏បានមាំមួនដែលបុគ្គលណាមួយមិនអាចបំបែកបាន ។ លំដាប់នោះ ព្រះរាជាត្រាស់ឲ្យហៅបុត្ត និងកិរិយារបស់សម្លាញ់នោះមក ឲ្យសាងនិវេសន៍ខាងក្នុងព្រះរាជនគរព្រះរាជទានដល់បុរសនោះ ។ ព្រះរាជាទាំងពីរនោះ សាមគ្គីគ្នា ជាអ្នកត្រេកអរកគ្នា គ្រងរាជសម្បត្តិ ។ តមកអាមាត្យទាំងឡាយ នាំគ្នាក្រោធនឹងព្រះបាទពារាណសីនោះ ទើបទូលព្រះរាជឱរសថា បពិត្ររាជបុត្ត ព្រះរាជាទ្រង់បានប្រទានរាជសម្បត្តិពាក់កណ្តាលដល់គហបតីនេះ រួមសោយរួមផឹក ជាមួយគហបតីនោះ ឲ្យពួកក្មេងៗថ្វាយបង្គំ ទូលបង្គំទាំងឡាយមិនដឹងដល់កម្មដែលគហបតីនេះធ្វើ ព្រះរាជាទ្រង់ធ្វើអ្វី ទូលបង្គំទាំងឡាយនឹកខ្មាស សូមទ្រង់ទូលព្រះរាជាផងចុះ ។ ព្រះរាជឱរសនោះ ទទួលពាក្យហើយ ទើបក្រាបទូលរឿងនោះដល់ព្រះរាជាហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំធ្វើយ៉ាងនេះឡើយ ។ ព្រះបាទពារាណសីត្រាស់ថា នែបា បិតាចាញ់ចម្បាំងក្នុងកាលនោះ បាននៅក្នុងទីណា បុត្តជ្រាបដែរឬទេ ព្រះរាជឱរសក្រាបទូលថា ទូលបង្គំមិនជ្រាប ព្រះ

រាជាត្រាស់ថា បិតានៅក្នុងផ្ទះរបស់គហបតីនេះផុតភ័យហើយ ត្រឡប់មកគ្រងរាជសម្បត្តិ កាលបើដូច្នេះ ព្រោះហេតុអ្វីទើបបិតាមិនឲ្យសម្បត្តិដល់អ្នកមានឧបការៈដល់យើងនោះ ។ ព្រះពោធិសត្វកាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់ថា នែបា បុគ្គលណាឲ្យដល់បុគ្គលដែលមិនគួរឲ្យ មិនឲ្យដល់បុគ្គលដែលគួរឲ្យ បុគ្គលនោះដល់នូវភ័យអន្តរាយ នឹងមិនបានឧបការៈអ្វីឡើយកាលទ្រង់សម្តែងតទៅ ទើបត្រាស់គាថាទាំងនេះថា

បុគ្គលណា កាលឲ្យចំពោះជនទាំងឡាយដែលមិនដែលឲ្យ ( ដល់ខ្លួន ) មិនឲ្យចំពោះជនទាំងឡាយដែលធ្លាប់ឲ្យ បុគ្គលនោះបានដល់នូវសេចក្តីវិនាស មិនបាននូវមិត្តសំឡាញ់ ក្នុងគ្រាមានសេចក្តីអន្តរាយទាំងឡាយ ។

បុគ្គលណា មិនឲ្យទានចំពោះជនទាំងឡាយដែលមិនដែលឲ្យ បានឲ្យចំពោះជនទាំងឡាយដែលឲ្យ បុគ្គលនោះ ក៏ដល់នូវសេចក្តីវិនាស មិនបាននូវសំឡាញ់ ក្នុងកាលមានសេចក្តីអន្តរាយទាំងឡាយ ។

ការសម្តែងនូវសេចក្តីស្និទ្ធស្នាល និងការបរិភោគរួមឲ្យវិសេសក្នុងពួកជនអ្នកមានធម៌មិនប្រសើរ ជាអ្នកអួតអាង ក៏រមែងវិនាស មា៉្យងទៀត សូម្បីទានបន្តិចបន្តួចដែលបុគ្គលធ្វើហើយ ចំពោះពួកព្រះអរិយផង ចំពោះពួកបុគ្គលអ្នកមានចិត្តស្លូតត្រង់ផង ជាទានមានផលច្រើន ។

បុគ្គលណា បានធ្វើឧបការៈដ៏ល្អទុកហើយ ក្នុងកាលមុន
បុគ្គលនេះឈ្មោះថា បានធ្វើអំពើដែលគេធ្វើបានដោយក្រក្រៃ
ពេកក្នុងលោក លុះដល់កាលជាខាងក្រោយ បុគ្គលនោះធ្វើ
( គុណានីមួយដទៃទៀតក្តី ) មិនធ្វើក្តី ក៏ឈ្មោះថាជាបុគ្គល
គួរដល់កិរិយាបូជាដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនេយ្យេសុ** បានដល់ បុគ្គលមិនធ្លាប់ធ្វើឧប-ការៈមកអំពីមុន ។ បទថា **នេយ្យេសុ** បានដល់ អ្នកធ្វើឧបការៈមកហើយ ។ បទថា **នប្បវេច្ឆតិ** បានដល់ មិនបន្ថែមឲ្យទៅ គឺមិនឲ្យ ។ បទថា **អាបទាសុ** បានដល់ ក្នុងកាលមានអន្តរាយ ។ បទថា **ព្យសនំ** បានដល់ សេចក្តីទុក្ខ ។ បទថា **សញ្ញោគសម្ភោគវិសេសទស្សនំ** សេចក្តីថា ការសម្តែងនូវភាពវិ-សេស គឺការសម្តែងគុណរបស់ការស្និទ្ធស្នាលគ្នា និងការបរិភោគរួមគ្នា ដែលមិត្តធ្វើទុកទាំងអស់នេះថា បុគ្គលនេះធ្វើល្អដល់យើងហើយ រមែងវិនាស គឺអន្តរាយទៅក្នុងជនដែលឈ្មោះថា **អនរិយ** ព្រោះជាបុគ្គលមានធម៌មិនបរិ-សុទ្ធ ។ ឈ្មោះថា **សឋេ** ព្រោះភាពជាបុគ្គលបោកបញ្ឆោត ។ បទថា **អរិ-យេ** បានដល់ ឈ្មោះថា **អរិយេ** គឺបុគ្គលបរិសុទ្ធ ព្រោះដឹងនូវគុណដែលគេធ្វើទុកដល់ខ្លួន ។ បទថា **អជ្ជវេ** បានដល់ ឈ្មោះថា **អជ្ជវេ** គឺមិនវៀចវេរ ព្រោះហេតុនោះ ទុ៎ះឯង ។ បទថា **អណុម្បិ** បានដល់ មានប្រមាណតិច ។ បទថា **តាទិសុ** សេចក្តីថា វត្ថុដែលធ្វើក្នុងបុគ្គលប្រសើរ បុគ្គលស្មោះត្រង់ដូច្នោះ សូម្បីតិចក៏មានផលច្រើន ដូចពូជដែលព្រោះក្នុងស្រែល្អ រមែងមាន

ផលរុងរឿង ផ្សាយវិសាលទៅ តែវត្ថុដែលធ្វើក្នុងបុគ្គលលាមកក្រៅអំពីនេះ ទោះបីច្រើន ក៏រមែងវិនាស ដូចពូជដែលព្រោះក្នុងភ្លើងដូច្នោះ ។ សមដូចលោកពោលទុក ( ក្នុងនិគ្រោធជាតក ) ថា

ពូជ ( ដែលដាក់ ) ក្នុងភ្លើងរមែងឆេះ មិនដុះយ៉ាងណាមិញ ឧបការគុណដែលបុគ្គលធ្វើហើយក្នុងអសប្បុរស រមែងវិនាស មិនលូតលាស់យ៉ាងនោះដែរ ។

ឧបការគុណដែលបុគ្គលធ្វើហើយក្នុងបុរសជាកតញ្ញូ មានសីលធម៌ មានសេចក្តីប្រព្រឹត្តប្រសើរនោះ រមែងមិនវិនាសទេ ដូចពូជ ( ដែលព្រោះ ) ក្នុងស្រែល្អ ដូច្នេះ ។

បណ្តាបទថាទាំងនោះ បទថា **បុព្វេ កតកល្យាណោ** បានដល់ អ្នកធ្វើឧបការៈទុកមុន ។ បទថា **អកា** បានដល់ បានធ្វើហើយ អធិប្បាយថា បុគ្គលនេះបានធ្វើវត្ថុដែលឈ្មោះថាធ្វើបានដោយលំបាកក្នុងលោក ។ បទថា **បច្ឆា កយិរា** សេចក្តីថា បុគ្គលនោះបានធ្វើឬមិនបានធ្វើគុណណាមួយដទៃក្នុងកាលជាខាងក្រោយ ឈ្មោះថាបុគ្គលគួរបូជាដោយពិត ព្រោះគុណដែលធ្វើទុកមុននោះឯង ។ បុគ្គលនោះរមែងគួរធ្វើសក្ការៈរាប់អានគ្រប់យ៉ាង ។

ពួកអាមាត្យនិងរាជឱរសបានស្តាប់ដូច្នេះហើយ ក៏មិនបានពោលពាក្យណាទៀតឡើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា បុរសអ្នកស្រុកបច្ចន្តគាមក្នុងកាលនោះ បានមកជាអានន្ទ

ក្នុងកាលឥឡូវនេះ ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាមហាអស្សារោហជាតក ចប់

# ឯកករាជជាតក

[ ៥១០ ] ( ព្រះបាទទុព្ភិសេនទ្រង់ត្រាស់ថា ) បពិត្រព្រះអង្គជាឯករាជ កាលពីដើម ព្រះអង្គនៅសោយកាមគុណទាំងឡាយជារបស់ស្តុកស្តម្ភ រកអ្វីប្រសើរជាងគ្មាន ឥឡូវនេះ ព្រះអង្គនោះ គេបោះទៅក្នុងរណ្ដៅក្រហេងក្រហូងហើយ នៅតែមិនលះបង់នូវពណ៌សម្បុរនិងកម្លាំងពីដើម ។

[ ៥១១ ] ( ព្រះបាទពារាណសីពោលថា ) បពិត្រព្រះបាទទុព្ភិសេន សេចក្ដីអត់ធន់ក្ដី សេចក្ដីប្រព្រឹត្តតបៈក្ដី ខ្ញុំមានបំណងទុកហើយពីមុន បពិត្រមហារាជ ឥឡូវនេះ ខ្ញុំបានសម្រេចនូវសេចក្ដីប្រាថ្នានោះហើយ តើគប្បីលះបង់នូវពណ៌សម្បុរនិងកម្លាំងពីដើមដូចម្ដេចកើត ។

[ ៥១២ ] ( ទាន សីល ឧបោសថកម្ម ) ទាំងអស់របស់ខ្ញុំសម្រេចហើយ បពិត្រព្រះអង្គមានយស មានប្រាជ្ញារកនរណាគ្របសង្កត់មិនកើត ខ្ញុំបានយសដ៏ធំ ជាយសដែលខ្ញុំមិនធ្លាប់បានក្នុងកាលពីដើមហើយ ទើបខ្ញុំមិនលះបង់ពណ៌សម្បុរនិងកម្លាំងពីដើម ។

[ ៥១៣ ] បពិត្រព្រះជនិន្ទ្រ ពួកសប្បុរសបន្ទោបង់នូវរជ្ជសុខដោយទុក្ខ បន្ទោបង់នូវសេចក្ដីទុក្ខដែលបុគ្គលគ្របសង្កត់មិនបាននោះ ដោយសារឈានសុខ ជាអ្នកមានចិត្តត្រជាក់ស្មើក្នុងសេចក្ដីសុខនិងទុក្ខទាំង ២ យ៉ាង ។

**ចប់ ឯកករាជជាតកទី ៣ ។**

# អដ្ឋកថា

## ឯករាជជាតក

[ ៥១០-៥១៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេវកៈ ក្នុងសម្នាក់របស់ព្រះបាទកោសលម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អនុត្តរេ កាមគុណេ សមិទ្ធេ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្ន បានពោលទុកហើយក្នុងសេយ្យជាតក ខាងដើមនោះឯង ។ ក្នុងជាតកនេះព្រះសាស្តាត្រាស់ថា មិនមែនអ្នកប៉ុណ្ណោះដែលនាំយកប្រយោជន៍មក ដោយអំពើដែលមិនជាប្រយោជន៍ សូម្បីបុរាណកបណ្ឌិតទាំងឡាយ ក៏បាននាំយកប្រយោជន៍មកដោយអំពើដែលមិនជាប្រយោជន៍ដល់ខ្លួនដូចគ្នា ហើយទើបទ្រង់នាំយកអតីតនិទានមកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាល អាមាត្យជាឧបដ្ឋាករបស់ព្រះបាទពារាណសី ប្រទូស្តក្នុងរាជសម្នាក់ ព្រះរាជាទ្រង់ឃើញទោសរបស់អាមាត្យនោះដោយប្រចក្ស ទើបទ្រង់បណ្តេញសេវកៈនោះចេញអំពីដែន ទើបសេវកៈនោះទៅឧបដ្ឋាកព្រះបាទកោសល ព្រះនាមទុព្ភិសេនៈ ។ ហេតុការណ៍ទាំងពួង បានពោលហើយក្នុងមហាសីលវជាតកនោះឯង ។ ក្នុងជាតកនេះ ព្រះបាទទុព្ភិសេនៈឲ្យចាប់ព្រះបាទពារាណសីដែលប្រថាប់គង់ក្នុងកណ្តាលអាមាត្យ នាផ្ទៃប្រាសាទ ហើយដាក់សង្រែកព្យួរសំយុងព្រះសិរសាចុះក្រោមលើធរណីទ្វារ ។ ព្រះបាទពារាណសី ទ្រង់ចម្រើនមេត្តាប្រារព្ធចោររាជ ធ្វើកសិណបរិកម្ម ញុំាងឈានឲ្យកើតហើយ ចំណងក៏ដាច់ ។ តាំងអំពីនោះ ព្រះរាជាទ្រង់ប្រថាប់គង់សមាធិក្នុងអាកាស ។ ការក្តៅក្រហាយកើតឡើងក្នុងរាងកាយរបស់ចោររាជ ទ្រង់

ស្រែកថា ក្តៅ ក្តៅ ហើយបម្រះនទៀលទៅមកលើផែនដី ។ កាលចោររាជ ត្រាស់យ៉ាងនេះថា នេះហេតុអ្វីហ្ន៎ ទើបអាមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ ទ្រង់ធ្វើព្រះរាជាដែលតាំងនៅក្នុងធម៌ ដែលមិនមានកំហុសបែបនេះ ឲ្យព្យួរសិរសាខាងលើធរណីទ្វារ ចោររាជត្រាស់ថា បើយ៉ាងនោះពួកអ្នកចូរប្រញាប់ទៅដោះព្រះរាជាអង្គនោះ ។ រាជបុរសទាំងឡាយទៅហើយ បានឃើញព្រះរាជាទ្រង់គង់ពត់ភ្នែនក្នុងអាកាស ទើបត្រឡប់មកក្រាបទូលដល់ព្រះបាទទុព្ភិសេន ។ ព្រះបាទទុព្ភិសេននោះ ប្រញាប់យាងទៅថ្វាយបង្គំព្រះបាទពារាណសីនោះ ឲ្យទ្រង់អត់ទោស ហើយត្រាស់គាថាទី ១ ថា

បពិត្រព្រះអង្គជាឯករាជ កាលពីដើម ព្រះអង្គនៅសោយកាម
គុណទាំងឡាយ ជារបស់ស្អុកស្អុករកអ្វីប្រសើរជាងគ្មានឥឡូវ
នេះ ព្រះអង្គនោះ គេបោះទៅក្នុងរណ្តៅក្រហេងក្រហូងហើយ
នៅតែមិនលះបង់នូវពណ៌សម្បុរនិងកម្លាំងពីដើម ដូច្នេះ ។

បណ្តាបទថាទាំងនោះ បទថា **វសិ** បានដល់ នៅហើយ ព្រះបាទទុព្ភិសេនត្រាស់ហៅព្រះពោធិសត្វដោយព្រះនាមថា ឯករាជ ។ បទថា **សោធានិ** កាត់បទជា **សោ ត្វំ ឥធានិ** ប្រែថា ឥឡូវនេះព្រះអង្គនោះ ។ បទថា **ទុគ្គេ** បានដល់ មិនស្មើ ។ បទថា **នរកម្ហិ** បានដល់ ក្នុងរណ្តៅ ពាក្យនេះ លោកពោលសំដៅយកទីដែលត្រូវព្យួរ ។ បទថា **នប្បជ្ជហោ វណ្ណពលំ បុរាណំ** នេះ ព្រះបាទទុព្ភិសេនត្រាស់សួរថា ទ្រង់សូម្បីត្រូវបោះទៅក្នុងទីដែលមិនស្មើបែបនេះ ក៏ទ្រង់មិនបានលះបង់ឆវីវណ្ណនិងកម្លាំងកាយដែលមានអំពីមុន ។

ព្រះពោធិសត្វទ្រង់បានស្តាប់ដូច្នោះ ទើបត្រាស់គាថាដ៏សេសថា

បពិត្រព្រះបាទទុដ្ឋិសេន សេចក្តីអត់ធន់ក្តី សេចក្តីប្រព្រឹត្ត តបៈក្តី ខ្ញុំមានបំណងទុកហើយពីមុន បពិត្រមហារាជ ឥឡូវនេះ ខ្ញុំបានសម្រេចនូវសេចក្តីប្រាថ្នានោះហើយ តើគប្បីលះបង់នូវពណ៌សម្បុរនិងកម្លាំងពីដើមដូចម្តេចកើត ។

( ទាន សីល ឧបោសថកម្ម ) ទាំងអស់របស់ខ្ញុំសម្រេចហើយ បពិត្រព្រះអង្គមានយស មានប្រាជ្ញា រកនរណាគ្រប សង្កត់មិនកើត ខ្ញុំបានយសដ៏ធំ ជាយសដែលខ្ញុំមិនធ្លាប់បាន ក្នុងកាលពីដើមហើយ ទើបខ្ញុំមិនលះបង់ពណ៌សម្បុរនិងកម្លាំង ពីដើម ។

បពិត្រព្រះជនិន្ទ្រ ពួកសប្បុរស បន្ទោបង់នូវជួសុខដោយទុក្ខ បន្ទោបង់នូវសេចក្តីទុក្ខ ដែលបុគ្គលគ្របសង្កត់មិនបាន នោះដោយសារឈានសុខ ជាអ្នកមានចិត្តត្រជាក់ស្មើក្នុងសេចក្តីសុខនិងទុក្ខទាំង ២ យ៉ាង ដូច្នេះ ។

បណ្តាបទទាំងនោះបទថា **ខន្តី** បានដល់ អធិវាសនខន្តិ ។ បទថា **តបោ** បានដល់ ការប្រព្រឹត្តតបៈ ។ បទថា **សម្បដ្ឋិតា** បានដល់ ប្រាថ្នាហើយ គឺប្រាថ្នាចំពោះហើយ ។ ព្រះបាទពារាណសី ត្រាស់ហៅចោររាជនោះ ដោយព្រះនាមថា ទុដ្ឋិសេន ។ បទថា **តន្ទានិ លទ្ធាន** សេចក្តីថា ឥឡូវនេះ ខ្ញុំបានសេចក្តីប្រាថ្នានោះហើយ ។ បទថា **ជហេ** សេចក្តីថា ព្រោះហេតុអ្វីយើង

នឹងលះ ។ លោកសម្តែងសេចក្តីថា ព្រោះបុគ្គលដែលមានសេចក្តីទុក្ខក្តី ទោមនស្សក្តី នឹងត្រូវលះទុក្ខឬទោមនស្សនោះ ។ ព្រះបាទពារាណសី កាលសម្តែងសម្បត្តិរបស់ទ្រង់ តាមដែលទ្រង់បានស្តាប់តាមគ្នាមក ទើបត្រាស់ថា **សព្វា កិរេវំ បរិនិដ្ឋិតានិ** ដូច្នេះ ។ លោកពោលអធិប្បាយទុកថា កិច្ចដែលខ្ញុំគប្បីធ្វើគ្រប់យ៉ាង គឺការឲ្យទាន ការរក្សាសីល ចម្រើនភាវនា និងការរក្សាឧបោសថ ខ្ញុំធ្វើស្រេចហើយក្នុងកាលមុននេះឯង ។ បទថា **យសស្សិនំ បញ្ញវន្តំ វិសយ្ហ** សេចក្តីថា ឈ្មោះថា **យសស្សិនំ** ព្រោះដល់ព្រមដោយបរិវារសម្បត្តិ ឈ្មោះថា **បញ្ញវន្តំ** ព្រោះដល់ព្រមដោយបញ្ញា ឈ្មោះថា **វិសយ្ហ** ព្រោះជាបុគ្គលដែលបុគ្គលណាមួយ មិនអាចសង្កត់សង្កិនបាន ។ កាលបើយ៉ាងនេះ បទទាំង ៣ នេះ ទើបជាអាលបនៈ គឺពាក្យសម្រាប់ហៅទាំងអស់ ។ សព្ទថា **ឆំ** ក្នុងគាថានេះ ជានិបាត និងចុះនិគ្គហិតត្រង់ **ត** សព្ទ គឺចុះ **តំ** សព្ទ ដោយធ្វើព្យញ្ជនៈ ឲ្យពីរោះរណ្តំ ។ បទថា **យសោ ច** គឺយស នោះឯង ។ បទថា **លទ្ធា បុរិមំ** បានដល់ បានយសដែលមិនធ្លាប់បានមកអំពីមុន គឺក្នុងកាលមុន ។ បទថា **ឧឡារំ** បានដល់ ធំ ។ ព្រះបាទពារាណសី ត្រាស់សំដៅយកការកើតនៃឈានដោយមេត្តាភាវនា ដែលជាគ្រឿងសង្កត់កិលេស ។ បទថា **ឆប្បជ្ជហោ** សេចក្តីថា បានយសបែបនេះហើយ ព្រោះហេតុអ្វីនឹងលះពណ៌សម្បុរ និងកម្លាំងកាយដែលមានអំពីមុន ។ បទថា **ទុក្ខេន** សេចក្តីថា បន្ទោបង់នូវសុខក្នុងរាជសម្បត្តិរបស់ខ្ញុំ ដោយសេចក្តីទុក្ខ ព្រោះត្រូវបោះទៅក្នុងនរកដែលទ្រង់ធ្វើឲ្យកើតឡើង ។ បទថា **សុខេន វា តំ ទុក្ខំ** បានដល់

បន្ទោបង់នូវទុក្ខនោះដោយសុខដែលកើតអំពីឈាន ។ បទថា **ឧភយត្ថ សន្តោ** សេចក្តីថា សប្បុរសទាំងឡាយដូចជាខ្ញុំនោះមានសភាវៈស្ងប់ត្រជាក់ក្រៃលែង គឺមានខ្លួនជាកណ្តាលក្នុងចំណែកទាំងពីរនេះរមែងជាបុគ្គលទៀងត្រង់ គឺរមែងដូចគ្នា មិនមានអាការៈខុសគ្នាឡើយក្នុងសុខនិងទុក្ខ ។

ព្រះបាទទុព្ភិសេន ទ្រង់បានស្តាប់ដូច្នេះហើយ ទើបសូមឲ្យព្រះពោធិសត្វអត់ទោសហើយត្រាស់ថា ទ្រង់ប៉ុណ្ណោះ ចូរគ្រងរាជសម្បត្តិរបស់ទ្រង់ ខ្ញុំនឹងសុំការពារពួកចោរដល់ទ្រង់ ហើយដាក់អាជ្ញាដល់អាមាត្យដែលប្រទូស្តនោះ ហើយចៀសចេញទៅ ។ ចំណែកព្រះពោធិសត្វ ទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់អាមាត្យទាំងឡាយហើយបួសជាឥសី មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបាទទុព្ភិសេនក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ឯករាជជាតក ចប់**

## ឧទ្ទុរជាតក

[ ៥១៤ ] ( នាគឈ្មោះចុល្លទទ្ទុរៈពោលថា ) បពិត្រមហាទទ្ទុរៈ ពាក្យអាក្រក់ទាំងឡាយនេះក្នុងមនុស្សលោកធ្វើខ្ញុំឲ្យក្តៅក្រហាយ ឯពួកក្មេងទាំង-ឡាយនេះ មិនមានពិសសោះ ប៉ុន្តែហាំនជេរខ្ញុំ ដែលមានពិសថា ជាអ្នកស៊ីកង្កែបផង នៅក្នុងទឹកផង ។

[ ៥១៥ ] ( នាគឈ្មោះមហាទទ្ទុរៈនិយាយតបទៅវិញថា ) បុគ្គលដែលគេបំបរបង់ចេញចាកដែនរបស់ខ្លួនហើយទៅកាន់ជនបទឯទៀត ត្រូវធ្វើជង្រុកឲ្យធំដើម្បីដាក់នូវពាក្យអាក្រក់ទាំងឡាយចុះ ។

[ ៥១៦ ] ពួកជនមិនដឹងនូវបុរសដោយជាតិ ឬដោយវិន័យ គឺគុណសម្បត្តិក្នុងទីណា បុគ្គលកាលនៅក្នុងសំណាក់នៃពួកជន ដែលខ្លួនមិនស្គាល់មិនត្រូវធ្វើសេចក្តីប្រកាន់ក្នុងទីនោះឡើយ ។

[ ៥១៧ ] បុគ្គលប្រកបដោយប្រាជ្ញា ( សូម្បីមានអានុភាព ) ស្មើដោយភ្លើង កាលនៅក្នុងប្រទេសដទៃ ត្រូវតែអត់សង្កត់ពាក្យ ទោះបីមនុស្សជាខ្ញុំគេគម្រាមក៏ដោយ ។

**ចប់ ទទ្ទុរជាតកទី ៤ ។**

## អដ្ឋកថា

## ទទ្ទរជាតក

[ ៥១៤-៥១៧ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនដោយសេចក្ដីក្រោធមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឥមានិ មំ ទទ្ទរ តាបយន្តិ** ដូច្នេះជាដើម ។

រឿងនេះបានពោលទុកហើយខាងដើមនោះឯង ។ កាលនោះ កាលភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នា ដោយរឿងដែលភិក្ខុនោះជាបុគ្គលច្រើនដោយសេចក្ដីក្រោធ ក្នុងធម្មសភា ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ឲ្យហៅភិក្ខុនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកច្រើនដោយសេចក្ដីក្រោធពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ជាបុគ្គលក្រោធដូចគ្នា ព្រោះភាពជាបុគ្គលច្រើនដោយសេចក្ដីក្រោធ បុរាណកបណ្ឌិតទាំងឡាយ តាំងនៅក្នុងភាពជានាគរាជបរិសុទ្ធ ក៏បាននៅក្នុងទីកដីដែលប្រឡាក់លាមក ដែលពេញទៅដោយលាមកអស់ ៣ ឆ្នាំ ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតជាឱរសរបស់ព្រះបាទទទ្ទរនាគរាជ គ្រប់គ្រងរាជសម្បត្តិក្នុងទទ្ទរនាគភពដែលមាននៅនាជើងភ្នំទទ្ទរបព៌ត ក្នុងហិមវន្តប្បទេស មាន

ឈ្មោះថាមហាទទ្ទរៈ ចំណែកប្អូនប្រុសរបស់មហាទទ្ទរនាគរាជនោះ ឈ្មោះថាចុល្លទទ្ទរៈ ។ ចុល្លទទ្ទរនាគរាជនោះច្រើនដោយសេចក្តីក្រោធ គ្រោតគ្រាតត្រាច់ជេរ ត្រាច់ប្រហារនាគមាណព ស្តេចនាគដឹងថា ចុល្លទទ្ទរនាគរាជនោះជាសត្វគ្រោតគ្រាត ទើបបញ្ជាឲ្យនាំចុល្លទទ្ទរនាគរាជនោះចេញអំពីនាគភព ។ តែមហាទទ្ទរនាគរាជ សូមឲ្យបិតាអត់ទោសហើយឃាត់ទុក ។ ក្នុងលើកទី ២ ស្តេចនាគក្រេវក្រោធចំពោះចុល្លទទ្ទរនាគរាជនោះ សូម្បីលើកទី ២ មហាទទ្ទរនាគរាជនោះ ក៏ទូលសូមឲ្យអត់ទោស ។ តែក្នុងវារៈទី ៣ ស្តេចនាគដែលជាបិតាត្រាស់ថា ឯងឃាត់មិនឲ្យយើងដេញសត្វដែលប្រព្រឹត្តអនាចារចូរឯងទាំងពីរទៅចុះ ចូរចេញអំពីនាគភពនេះ ទៅកាន់ទីដែលប្រឡាក់លាមកក្នុងនគរពារាណសីអស់ ៣ ឆ្នាំ ហើយអួសចេញអំពីនាគពិភព ។ នាគរាជ ២ នាក់បងប្អូននោះ ក៏ទៅនៅត្រង់ទីដែលប្រឡាក់លាមក ក្នុងក្រុងពារាណសីនោះ ។ កាលនោះ ពួកក្មេងអ្នកស្រុកឃើញនាគបងប្អូនទាំងពីរនោះស្វែងរកចំណីត្រង់ជាយទឹក ក្បែរទីដែលប្រឡាក់លាមក ទើបនាំគ្នាប្រហារគ្រវែងដោយអង្កត់ឧសនិងដុំដីជាដើម នាំគ្នាជេរដោយពាក្យគ្រោតគ្រាតថា នេះសត្វអ្វីក្បាលធំ កន្ទុយដូចម្ជុល នៅតែក្នុងទឹក មានកន្ទែបកូនក្អាត់ជាកិក្ខាជាដើម ចុល្លទទ្ទរនាគរាជ អត់ធ្មត់នឹងការ មើលងាយរបស់ពួកក្មេងអ្នកស្រុកទាំងនោះមិនបាន ព្រោះខ្លួនជាអ្នកកាច ទើបពោលថា បពិត្របង ពួកក្មេងទាំងនេះមើលងាយពួកយើង មិនដឹងថាពួកយើងជាអ្នកមានពិសដ៏ពន្លឹក ខ្ញុំមិនអាចអត់ធ្មត់ក្នុងការមើលងាយរបស់ពួកវាបានទេ ខ្ញុំនឹងធ្វើពួកវាឲ្យវិនាសដោយខ្យល់

ប្រមុះ កាលចរចានឹងបងប្រុសទើបពោលគាថាទី ១ ថា

បពិត្រមហាទទ្ទរៈ ពាក្យអាក្រក់ទាំងឡាយនេះ ក្នុងមនុស្សលោក ធ្វើខ្ញុំឲ្យក្តៅក្រហាយ ឯពួកក្មេងទាំងឡាយនេះ មិនមានពិសសោះ ប៉ុន្តែហៅនជេរខ្ញុំដែលមានពិសថា ជាអ្នកស៊ីកង្កែបផង នៅក្នុងទឹកផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តាបយន្តិ** បានដល់ រមែងធ្វើឲ្យលំបាក ។ បទថា **មណ្ឌូកភក្ខា ឧទកន្តសេវី** សេចក្តីថា ពួកក្មេងអ្នកស្រុកដែលមិនមានឫទ្ធិតេជះទាំងនោះពោលថា សត្វស៊ីកង្កែប ស៊ីក្អាត់ និងថាជាសត្វទឹក ជេរយើងជាសត្វមានពិសដ៏ពន្លឹក ។ មហាទទ្ទរនាគរាជ បានស្តាប់ពាក្យរបស់ចុល្លទទ្ទរនាគរាជជាប្អូននោះហើយ បានពោលគាថាដ៏សេសថា

បុគ្គលដែលគេបំបរបង់ចេញចាកដែនរបស់ខ្លួន ហើយទៅកាន់ជនបទឯទៀតត្រូវធ្វើជង្រុកឲ្យធំ ដើម្បីដាក់នូវពាក្យអាក្រក់ទាំងឡាយចុះ ។

ពួកជនមិនដឹងនូវបុរសដោយជាតិ ឬដោយវិន័យ គឺគុណសម្បត្តិក្នុងទីណា បុគ្គលកាលនៅក្នុងសំណាក់នៃពួកជនដែលខ្លួនមិនស្គាល់ មិនត្រូវធ្វើសេចក្តីប្រកាន់ក្នុងទីនោះឡើយ ។

បុគ្គលប្រកបដោយប្រាជ្ញា (សូម្បីមានអានុភាព) ស្មើដោយភ្លើង កាលនៅក្នុងប្រទេសដទៃ ត្រូវតែអត់សង្កត់ពាក្យ ទោះបីមនុស្សជាខ្ញុំគេគម្រាមក៏ដោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទុបានំ ពិជេតវេ** សេចក្តីថា ជនទាំងឡាយសាងនូវជង្រុកជំទុកដើម្បីដាក់ស្រូវ ធ្វើជង្រុកឲ្យពេញ កាលកិច្ចកើតឡើង ក៏ប្រើប្រាស់ស្រូវយ៉ាងណា បុរសដែលជាបណ្ឌិត ក៏យ៉ាងនោះដូចគ្នា ទៅកាន់ទឹកដីដទៃ គប្បីធ្វើជង្រុកជំទុកខាងក្នុងហទយៈ ដើម្បីដាក់នូវពាក្យគ្រោតគ្រាត កាលដាក់នូវពាក្យគ្រោតគ្រាតទាំងនោះទុកក្នុងហទយៈនោះហើយ នឹងធ្វើកិច្ចដែលគួរធ្វើក្នុងពេលដែលសមគួរដល់ខ្លួន ។ បទថា **ជាតិយា វិនយេន វា** សេចក្តីថា ក្នុងទីណាជនទាំងឡាយរមែងស្គាល់ខ្លួនដោយជាតិ ឬដោយវិន័យថា បុគ្គលនេះជាក្សត្រ បុគ្គលនេះជាព្រាហ្មណ៍ ឬថាជាអ្នកមានសីល ជាពហុស្សូត ជាអ្នកដល់ព្រមដោយគុណធម៌ ។ បទថា **មានំ** សេចក្តីថា មិនគប្បីធ្វើការប្រកាន់ខ្លួនថា គេហៅយើងបែបនេះដោយវោហារដ៏លាមក មិនធ្វើសក្ការៈ មិនគោរព ។ បទថា **វសំ អញ្ញាតកេ ជនេ** សេចក្តីថា នៅក្នុងសម្នាក់របស់បុគ្គលដែលមិនស្គាល់ជាតិនិងគោត្តរបស់ខ្លួន ។ បទថា **វសេ-តោ** កែជា **វសតា** ប្រែថា នៅ ។ម្យ៉ាងទៀត បាលីក៏ជា **វសតា** ដូច្នេះ ដូចគ្នា ។ នាគបងប្អូននោះ នៅក្នុងទីនោះអស់កាលកំណត់ ៣ ឆ្នាំ ដោយអាការៈយ៉ាងនេះ ។ លំដាប់នោះ ស្តេចនាគបិតា ឲ្យហៅនាគបងប្អូនទាំងពីរនោះមក ។ តាំងអំពីនោះមក នាគបងប្អូននោះ ក៏អស់នូវមានះ ការប្រកាន់ខ្លួន ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុដែលច្រើនដោយសេចក្តី

ក្រោធ តាំងនៅក្នុងអនាគាមិផល ហើយទ្រង់ប្រជុំជាតកថា ចុល្លទទ្ទរនាគរាជ ក្នុងកាលនោះ បានមកជាភិក្ខុដែលច្រើនដោយ សេចក្តីក្រោធក្នុងកាលឥឡូវនេះ ចំណែកមហាទទ្ទរនាគរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទទ្ទរជាតក ចប់

# សីលវីមំសជាតក

[ ៥១៨ ] ( មាណពពោធិសត្វពោលថា ) ធម្មតាសេចក្តីស្ងាត់កំបាំង របស់បុគ្គលអ្នកធ្វើអំពើអាក្រក់មិនមានក្នុងលោកទេ ពួកភូតដែលនៅក្នុងព្រៃ គង់គេឃើញបាន បុគ្គលពាលរមែងសម្គាល់នូវអំពើអាក្រក់ ដែលធ្វើនោះថា ស្ងាត់កំបាំង ។

[ ៥១៩ ] ខ្ញុំមិនឃើញថា ស្ងាត់កំបាំងទេ ឬទីដែលសូន្យ ( ចាកសត្វ ) ក៏មិនមាន ខ្ញុំមិនឃើញថាសូន្យក្នុងទីណា ទីនោះក៏មិនសូន្យអំពីខ្ញុំទេ ។

[ ៥២០ ] ( ព្រះសាស្តាត្រាស់ថា ) ពួកមាពណា គឺទុជ្ជច្ចៈ ១ សុជច្ចៈ ១ នន្ទៈ ១ សុខវច្ឆនៈ ១ វជ្ឈៈ ១ អធុវសីលៈ ១ ( ជាដើម ) នោះ ជាអ្នកត្រូវការ ( ដោយស្ត្រី ) ក៏សាបសូន្យចាកសភាវៈ ( ការបាននូវស្ត្រី ) ។

[ ៥២១ ] ចំណែកព្រាហ្មណ៍ណា ដែលមានប្រាជ្ញា មានព្យាយាមក្នុងសច្ចៈ បានរក្សានូវធម៌ទុក ព្រាហ្មណ៍នោះ ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង តើគប្បីសាបសូន្យ ( ចាកការបាននូវស្ត្រី ) ដូចម្តេចកើត ។

**ចប់ សីលវីមំសជាតកទី ៥ ។**

# អដ្ឋកថា
# សីលវីមំសជាតក

[ ៥១៨-៥២១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាយជាគ្រឿងសង្កត់កិលេស ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នត្ថិ លោកេ រហោ នាម** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានច្បាស់ក្នុងបានីយជាតក ឯកាទសកនិបាត ។ ចំណែកក្នុងជាតកនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា

ភិក្ខុប្រមាណ ៥០០ រូប នៅក្នុងជេតពនវិហារ នាំគ្នាត្រិះរិះកាមវិតក្កៈក្នុងលំដាប់មជ្ឈិមយាម ។ ព្រះសាស្តា ទ្រង់ប្រមើលមើលភិក្ខុទាំងឡាយជានិច្ចកាល ក្នុងកាលទាំងពួង ទាំងពេលយប់និងពេលថ្ងៃ ទាំង ៦ ដង ដូចបុគ្គលរក្សាភ្នែកដែលមានតែម្ខាង និងដូចបុគ្គលមានបុត្តតែមួយរក្សាបុត្ត និងចាមរីជាតិរក្សារោមកន្ទុយដោយសេចក្តីមិនប្រមាទដូច្នោះ ។ ក្នុងកាលដែលជាចំណែករាត្រី ទ្រង់ប្រមើលមើលវត្តជេតពនវិហារដោយទិព្វចក្ខុ ទ្រង់ឃើញភិក្ខុទាំងនោះ ហាក់បីដូចចោរដែលកើតឡើងខាងក្នុងនិវេសន៍របស់ស្តេចចក្រពត្តិ ទើបទ្រង់បើកព្រះគន្ធកុដិ ហៅព្រះអានន្ទត្ថេរមក ហើយត្រាស់ថា អានន្ទ ចូរអ្នកឲ្យភិក្ខុទាំងឡាយ ខាងក្នុងវត្តជេនពនប្រជុំគ្នា ហើយចូរក្រាលអាសនៈត្រង់ទ្វារព្រះគន្ធកុដិ ។ ព្រះអានន្ទត្ថេរនោះ បានធ្វើយ៉ាងនោះហើយ ក្រាបទូលព្រះសាស្តាឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាគង់លើអាសនៈដែលព្រះអានន្ទក្រាល ហើយទ្រង់ដាស់តឿនភិក្ខុទាំងឡាយ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរាណកបណ្ឌិតទាំងឡាយ មិនធ្វើបាបដោយគិតថា ឈ្មោះថា ទីកំបាំងក្នុង

ការធ្វើបាបមិនមាន កាលភិក្ខុទាំងឡាយនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយ បានជាប្រធាននៃពួកមាណព ៥០០ នាក់ រៀនសិល្បសាស្ត្រក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ក្នុងនគរពារាណសីនោះឯង អាចារ្យមានធីតាកំពុងចម្រើនវ័យទើបគិតថា អញនឹងសាកល្បងសីលរបស់មាណពទាំងនេះ ហើយនឹងឲ្យធីតាដល់មាណពដែលសម្បូរដោយសីលប៉ុណ្ណោះ ។ ថ្ងៃមួយអាចារ្យទិសាបាមោក្ខនោះ ហៅមាណពទាំងឡាយមកហើយពោលថា បាទាំងឡាយ កូនស្រីរបស់យើងចម្រើនវ័យហើយ យើងនឹងធ្វើវិវាហមង្គល ( តែ ) គួរនឹងបានសំពត់ និងគ្រឿងអលង្ការ អ្នកទាំងឡាយចូរទៅ កាលពួកញាតិរបស់ខ្លួនមិនឃើញ ចូរលួចយកសំពត់និងគ្រឿងអលង្ការហើយនាំមក សំពត់និងគ្រឿងអលង្ការ ដែលបុគ្គលណាមួយមិនឃើញប៉ុណ្ណោះ ទើបយើងទទួលយក សំពត់និងគ្រឿងអលង្ការដែលបុគ្គលណាមួយឃើញ ហើយនាំយកមក យើងមិនទទួល ។ មាណពទាំងនោះ ទទួលពាក្យរបស់អាចារ្យ ចាប់តាំងពីនោះមក កាលពួកញាតិមិនឃើញ ទើបនាំយកសំពត់និងគ្រឿងប្រដាប់ទាំងឡាយមក ។ អាចារ្យក៏ដាក់វត្ថុដែលពួកមាណពនាំមកទុកផ្សេងៗគ្នា ។ ព្រះពោធិសត្វមិននាំអ្វីមកឡើយ ។ ពេលនោះអាចារ្យពោលនឹងព្រះពោធិសត្វនោះថា នែបា អ្នកមិនទៅនាំយកអ្វីមកទេឬ ព្រះពោធិសត្វពោលថា ពិតហើយលោកអាចារ្យ ។ អាចារ្យសួរថា

ព្រោះហេតុអ្វី ព្រះពោធិសត្វពោលថា លោកអាចារ្យមិនទទួលរបស់ដែលយកមកកាលមានបុគ្គលណាឃើញ ខ្ញុំក៏មិនឃើញទីកំបាំងក្នុងការធ្វើបាប កាលនឹងសម្តែងសេចក្តីនោះ ទើបពោលគាថា ២ ថា

ធម្មតាសេចក្តីស្ងាត់កំបាំង របស់បុគ្គលអ្នកធ្វើអំពើអាក្រក់
មិនមានក្នុងលោកទេ ពួកភូតដែលនៅក្នុងព្រៃគង់គេឃើញបាន
បុគ្គលពាលរមែងសម្គាល់នូវអំពើអាក្រក់ដែលធ្វើនោះថាស្ងាត់
កំបាំង ។

ខ្ញុំមិនឃើញថាស្ងាត់កំបាំងទេ ឬទីដែលសូន្យ (ចាកសត្វ )
ក៏មិនមាន ខ្ញុំមិនឃើញថាសូន្យក្នុងទីណា ទីនោះក៏មិនសូន្យអំពី
ខ្ញុំទេ ដូច្នេះ ។

បណ្តាបទថាទាំងនោះ បទថា **រហោ** បានដល់ ទីកំបាំង ។ បទថា **វនភូតានិ** បានដល់ ភូតទាំងឡាយដែលកើតផង មាននៅក្នុងព្រៃផង ។ បទថា **តំ ពាលោ** សេចក្តីថា បុគ្គលពាលរមែងសម្គាល់នូវបាបកម្មនោះថា យើងធ្វើក្នុងទីស្ងាត់ ។ ដោយបទថា **សុញ្ញំ វាបិ** នេះ ព្រះពោធិសត្វពោលថា ទីទទេចាកសត្វទាំងឡាយមិនមាន ។

អាចារ្យជ្រះថ្លាចំពោះព្រះពោធិសត្វនោះ ទើបពោលថា នែបា ក្នុងផ្ទះរបស់យើងមិនមានទ្រព្យអ្វីឡើយ តែយើងមានបំណងនឹងឲ្យធីតារបស់យើងដល់បុគ្គលដែលសម្បូរដោយសីល កាលនឹងសាកល្បងមាណពទាំងឡាយនេះ ទើបធ្វើយ៉ាងនេះ ធីតារបស់យើងសមគួរដល់អ្នកប៉ុណ្ណោះ ហើយប្រដាប់តាក់

តែងធីតា ប្រគល់ឲ្យដល់ព្រះពោធិសត្វ ហើយពោលនឹងមាណពទាំងឡាយ ក្រៅអំពីនេះថា វត្ថុដែលពួកអ្នកនាំមកហើយ ចូរនាំទៅកាន់ផ្ទះរបស់អ្នកទាំងឡាយចុះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មាណពអ្នកទ្រុស្តសីលទាំងនោះ មិនបាននូវស្ត្រីនោះ ព្រោះភាពដែលខ្លួនជាអ្នកទ្រុស្តសីល មាណពដែលជាបណ្ឌិតប៉ុណ្ណោះបាន ព្រោះជាអ្នកដល់ព្រមដោយសីល ដោយប្រការដូច្នេះ ទ្រង់ត្រាស់ដឹងព្រមចំពោះហើយ ទើបត្រាស់គាថា ២ ក្រៅអំពីនេះថា

ពួកមាពណ គឺទុជ្ជច្ចះ ១ សុជច្ចះ ១ នន្ទះ ១ សុខវច្ឆនះ ១ វជ្ឈះ ១ អធុវសីលះ ១ ( ជាដើម ) នោះ ជាអ្នកត្រូវការ ( ដោយស្ត្រី ) ក៏សាបសូន្យចាកសភាវះ ( ការបាននូវស្ត្រី ) ។

ចំណែកព្រាហ្មណ៍ណា ដែលមានប្រាជ្ញា មានព្យាយាមក្នុងសច្ចះ បានរក្សានូវធម៌ទុក ព្រាហ្មណ៍នោះ ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង តើគប្បីសាបសូន្យ ( ចាកការបាននូវស្ត្រី ) ដូចម្តេចកើត ដូច្នេះ ។

ក្នុងគាថានោះ ព្រះសាស្តាទ្រង់កាន់យកឈ្មោះរបស់មាណពដែលជាធំ ៦ នាក់ មានទុជច្ចមាណពជាដើមដូច្នេះ ។ ទ្រង់មិនប្រារព្ធឈ្មោះរបស់មាណពទាំងឡាយដ៏សេស ទើបត្រាស់ដោយសរុបនោះឯងថា មាណពទាំងនោះមានសេចក្តីត្រូវការធីតារបស់អាចារ្យ នាំគ្នាលះធម៌ចោលដូច្នេះ ។ បណ្តាបទទាំង

នោះ បទថា **តេ** បានដល់ មាណពទាំងនោះ ។ បទថា **ធម្មំ** បានដល់ សភាវៈ គឺការបានចំពោះស្ត្រី ។ បទថា **ជហាមត្ថិកា** កាត់បទជា **ជហុំ អត្ថិកា** ប្រែដូចក្នុងគាថា ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ ចំណែក **ម** អក្ខរៈ លោកពោលដោយអំណាចការភ្ជាប់ព្យញ្ជនៈ ។ លោកពោលអធិប្បាយទុកថា មាណពទាំងនោះ ជាអ្នកត្រូវការធីតារបស់អាចារ្យប៉ុណ្ណោះ នាំគ្នាលះសភាវៈ គឺការបានចំពោះស្ត្រីនោះ ព្រោះភាពដែលខ្លួនជាអ្នកទ្រុស្តសីល ។ បទថា **ព្រាហ្មណោ ច** សេចក្តីថា ចំណែកព្រាហ្មណ៍ដែលសម្បូរដោយសីល ក្រៅអំពីនេះ ។ បទថា **កថំ ជហេ** សេចក្តីថា ព្រោះហេតុអ្វីនឹងលះការបានស្ត្រីនោះ ។ បទថា **សព្វធម្មានំ** សេចក្តីថា ក្នុងទីនេះ សីល ៥ សីល ៨ សុចរិត ៣ ដែលជាលោកិយៈ ឈ្មោះថាធម៌ទាំងពួង ។ ព្រាហ្មណមាណពនោះ ដល់ត្រើយនៃធម៌ទាំងពួងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **ចារគូ** ។ បទថា **ធម្មំ** បានដល់ ធម៌ដែលមានប្រការដូចពោលហើយនោះឯង ទើបព្រាហ្មណមាណព គ្រប់គ្រង គឺរក្សា ។ បទថា **ធិតិមា** បានដល់ ដែលប្រកបដោយបញ្ញារក្សាសីល ។ បទថា **សច្ចនិក្កមោ** បានដល់ ជាអ្នកមានសច្ចៈជាសភាវៈ គឺប្រកបដោយសេចក្តីព្យាយាម ជាគ្រឿងឈានទៅក្នុងសីលធម៌តាមដែលពោលហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុ ៥០០ រូបតាំងនៅក្នុងអរហត្ត ហើយទ្រង់ប្រជុំជាតកថា អាចារ្យក្នុងកាលនោះ បានមកជាសារីបុត្ត

ក្នុងកាលឥឡូវនេះ ចំណែកមាណពជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សីលវីមំសជាតក ចប់

# សុជាតាជាតក

[ ៥២២ ] ( នាងសុជាតាទេវីសួរថា ) បពិត្រព្រះទេវៈ នេះផ្លែអ្វី មូល រលីងមានពណ៌ក្រហមដូចជាឈាមដែលដាក់ក្នុងភាជន៍មាសខ្ញុំម្ចាស់សួរហើយ សូមព្រះអង្គប្រាប់ឲ្យទាន ។

[ ៥២៣ ] ( ព្រះបាទពារាណសីទ្រង់ត្រាស់ថា ) ម្នាលទេវី ក្នុងកាល មុន នាងមានក្បាលរលីង ស្លៀកកំណាត់សំពត់ចាស់ មានដៃក្នុងថ្នក់ ហើយ បេះនូវផ្លែឈើទាំងឡាយណា ( នេះ ) គឺផ្លែពុទ្រារបស់នាងនោះហើយ ។

[ ៥២៤ ] ស្ត្រីថោកទាបរមែងក្តៅក្រហាយ មិនត្រេកអរ ( ក្នុងរាជ ត្រកូល ) កោគៈរបស់ស្តេចទាំងឡាយរមែងលះបង់នូវស្ត្រីឥតបុណ្យនោះ ស្ត្រី ថោកទាប បេះនូវផ្លែពុទ្រាក្នុងទីណា អ្នកទាំងឡាយចូរនាំស្ត្រីនោះទៅក្នុងទី នោះចុះ ។

[ ៥២៥ ] ( អាមាត្យពោធិសត្វទូលថា ) បពិត្រមហារាជ ទោសខុស ព្រោះសេចក្តីប្រមាទទាំងនេះ រមែងមានដល់នាងនារី ដែលដល់នូវយសសក្តិ បពិត្រព្រះទេវៈ សូមព្រះអង្គអត់ទោសដល់ព្រះនាងសុជាតាទេវី បពិត្រព្រះ អង្គប្រសើរក្នុងរថ សូមព្រះអង្គកុំទ្រង់ព្រះពិរោធ ចំពោះព្រះនាងសុជាតាទេវី នេះឡើយ ។

**ចប់ សុជាតាជាតកទី ៦ ។**

# អដ្ឋកថា
# សុជាតាជាតក

[ ៥២២-៥២៥ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កឹ អណ្ឌកា ឥមេ ទេវ** ដូច្នេះជាដើម ។

បានឮមកថា ថ្ងៃមួយព្រះរាជាទ្រង់មានវិវាទ ឈ្លោះប្រកែកគ្នាក្នុងរឿងសិរីជាមួយព្រះនាងមល្លិកាទេវី អាចារ្យពួកខ្លះពោលថា ទ្រង់ឈ្លោះរឿងទីបន្ទំដូច្នេះក៏មាន ។ ព្រះរាជាទ្រង់ក្រេវក្រោធ រហូតទ្រង់មិនដាក់ព្រះទ័យថា ព្រះនាងមាន ។ ចំណែកព្រះនាងមល្លិកាទេវីព្រះតម្រិះថា ព្រះសាស្ដាប្រហែលជាទ្រង់មិនជ្រាបថា ព្រះរាជាទ្រង់ពិរោធជាមួយអាត្មាអញឡើយ ។ សូម្បីព្រះសាស្ដាក៏ទ្រង់ជ្រាប ទ្រង់ព្រះតម្រិះថានឹងធ្វើព្រះរាជានិងព្រះទេវីឲ្យរួបរួមគ្នា ។ ក្នុងពេលព្រឹកទ្រង់ស្លៀកដណ្ដប់ហើយ កាន់បាត្រនិងចីវរ មានភិក្ខុ ៥០០ រូបជាបរិវារ ទ្រង់ចូលទៅកាន់នគរសាវត្ថី ហើយបានយាងទៅកាន់ទ្វារព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ទទួលបាត្ររបស់ព្រះតថាគត ហើយនិមន្តឲ្យចូលព្រះរាជនិវេសន៍ ឲ្យគង់លើអាសនៈដែលគេក្រាលទុកហើយ ទ្រង់ថ្វាយទក្ខិណោទកដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទ្រង់នាំបបរ និងរបស់គួរទំពាមកប្រគេន ។ ព្រះសាស្ដា ទ្រង់យកព្រះហស្តបិទបាត្រហើយត្រាស់ថា មហាបពិត្រ ព្រះទេវីយាងទៅណា ព្រះរាជាទូលថា បពិត្រព្រះអង្គ ប្រយោជន៍អ្វីដោយព្រះទេវីនោះដែលស្រវឹងដោយយសរបស់ខ្លួន ។ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ទ្រង់ប្រទានយសដល់មាតុគ្រាម ដោយព្រះអង្គឯង

ហើយទ្រង់មិនអត់ទោសកំហុសដែលព្រះទេវីនោះធ្វើមិនសមគួរ ។ ព្រះរាជាទ្រង់ស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាហើយ ទើបត្រាស់ឲ្យហៅព្រះទេវីមក ព្រះទេវីយាងមកអង្គាសព្រះសាស្តា ព្រះសាស្តាទ្រង់ត្រាស់ថា គួរទ្រង់ទាំងពីរស្រុះស្រួលគ្នានឹងគ្នា ហើយទ្រង់បានត្រាស់ពណ៌នានូវសាមគ្គីរស ហើយចៀសចេញទៅ ។ ចាប់តាំងពីនោះ ព្រះរាជានិងព្រះទេវីទាំងពីរ ក៏ទ្រង់នៅដោយសាមគ្គីព្រមព្រៀងគ្នា ។

ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់បានធ្វើព្រះរាជានិងព្រះទេវីទាំងពីរអង្គ ឲ្យស្មុគ្រស្មាគមដល់គ្នានឹងគ្នា ដោយព្រះតម្រាស់តែមួយដងប៉ុណ្ណោះ ។ ព្រះសាស្តាយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ អ្នកទាំងឡាយ អង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បានធ្វើជនទាំងពីរនេះ ឲ្យព្រមព្រៀងត្រូវរូវគ្នា ដោយឱវាទត្រឹមតែម្តងប៉ុណ្ណោះ ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបានជាអាមាត្យទូន្មានអត្ថនិងធម៌ដល់ព្រះបាទព្រហ្មទត្តនោះ ថ្ងៃមួយ ព្រះរាជាទ្រង់បើកមហាបង្អួច ប្រថាប់ទតត្រង់លានព្រះរាជវាំង ។ ខណៈនោះ ធីតារបស់អ្នកបេះបន្លែម្នាក់ មានរូបស្អាតតាំងនៅក្នុងបឋមវ័យ ឈ្មោះ

សុជាតា ទូលល្អីពុទ្រាលើក្បាល ដើរពពាយនាយលក់ទៅតាមលានព្រះរាជវាំងថា ចូរកាន់យកផ្លែពុទ្រា ចូរកាន់យកផ្លែពុទ្រា ព្រះរាជាទ្រង់បានស្តាប់សំឡេងរបស់នាងហើយ ទ្រង់មានចិត្តប្រតិព័ទ្ធ ទ្រង់ជ្រាបថានាងមិនទាន់មានប្តីទើបឲ្យហៅមកហើយ ទ្រង់តាំងស្ត្រីនោះទុកក្នុងតំណែងអគ្គមហេសី ហើយបានប្រទានយសធំដល់នាង ។ ស្រីនោះបានជាទីពេញព្រះហឫទ័យរបស់ព្រះរាជា ។ ថ្ងៃមួយព្រះរាជាប្រថាប់គង់ លូកផ្លែពុទ្រាក្នុងចានមាសសោយ ព្រះនាងសុជាតាទេវីបានឃើញព្រះរាជាសោយពុទ្រា កាលទូលសួរថា បពិត្រមហារាជ ទ្រង់សោយផ្លែអ្វី ទើបត្រាស់គាថាទី ១ ថា

បពិត្រព្រះទេវៈ នេះផ្លែអ្វី មូលរលីងមានពណ៌ក្រហមដូចជា
ឈាមដែលដាក់ក្នុងភាជន៍មាស ខ្ញុំម្ចាស់សួរហើយ សូមព្រះ
អង្គប្រាប់ឲ្យទាន ដូច្នេះ ។

បទថា **កឹ អណ្ឌកា** នេះ ក្នុងគាថានោះ ព្រះនាងសុជាតាទេវីទូលសួរថា នេះឈ្មោះផ្លែអ្វីដូចជាស៊ុត ដ្បិតមានរាងមូល ។ បទថា **កំសមល្លកេ** បានដល់ ក្នុងចានមាស ។ បទថា **ឧបលោហិតកា** បានដល់ មានពណ៌ក្រហម ។ បទថា **វគ្គូ** បានដល់ ល្អ គឺមិនមានមន្ទិល ។

ព្រះរាជាទ្រង់ពិរោធត្រាស់ថា នាងឈ្មួញពុទ្រា កូនអ្នកបេះបន្លែ ធ្វើជាមិនស្គាល់ សូម្បីផ្លែពុទ្រាដែលជារបស់ប្រចាំត្រកូលនៃខ្លួន ហើយទើបត្រាស់គាថា ២ ថា

ម្នាលទេវី ក្នុងកាលមុននាងមានក្បាលរលីងស្បៀកកំណាត់

សំពត់ចាស់ មានដៃក្នុងថ្នក់ ហើយ បេះនូវផ្លែឈើទាំងឡាយណា ( នេះ ) គឺផ្លែពុទ្រារបស់នាងនោះហើយ ។

ស្ត្រីថោកទាបរមែងក្តៅក្រហាយ មិនត្រេកអរ ( ក្នុងរាជត្រកូល ) ភោគៈរបស់ស្តេចទាំងឡាយ រមែងលះបង់នូវស្ត្រីឥតបុណ្យនោះ ស្ត្រីថោកទាបបេះនូវផ្លែពុទ្រាក្នុងទីណា អ្នកទាំងឡាយចូរនាំស្ត្រីនោះទៅក្នុងទីនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភណ្ឌុ** បានដល់ អ្នកមានក្បាលទំពែក ។ បទថា **ឆន្នកាសិនី** បានដល់ ស្លៀកសំពត់ចាស់ ។ បទថា **ឱច្ឆង្គហត្ថាបចិនាសិ** សេចក្តីថា នាងចូលព្រៃយកតម្កក់ទាញមែកឈើចុះមក យកដៃបេះផ្លែដែលជ្រើសរើសហើយ ជាអ្នកចាប់ថ្នក់ដាក់ចូលទៅក្នុងថ្នក់យកទៅ ។ បទថា **តស្សា តេ កោលិយំ ផលំ** សេចក្តីថា កាលនាងកំពុងបេះយ៉ាងនេះ ឥឡូវនេះយើងស៊ីផ្លែឈើណា ផ្លែឈើនោះជាផ្លែឈើប្រចាំត្រកូល គឺជាផ្លែឈើដែលត្រកូលឲ្យនាង ។ បទថា **ឱឧយ្ហតេ ឧ រមតិ** សេចក្តីថា ស្រីថោកទាបនេះ កាលនៅក្នុងរាជត្រកូលនេះ រមែងក្តៅក្រហាយ មិនត្រេកអរ ដូចត្រូវបោះក្នុងលោហកុម្ភីនរកដូច្នោះ ។ បទថា **ភោគា** បានដល់ រាជភោគទ្រព្យរមែងលះបង់ស្រីនេះដែលមិនមានបុណ្យ ។ ដោយបទថា **យត្ថ កោលំ បចិស្សតិ** នេះ ព្រះរាជាត្រាស់ថា ស្រីនេះទៅក្នុងទីណា បេះផ្លែពុទ្រានោះឯងលក់ដូរចិញ្ចឹមជីវិតទៀត អ្នកទាំងឡាយចូរនាំស្រីនេះទៅក្នុងទីនោះឯង ។

ព្រះពោធិសត្វគិតថា វៀរអាត្មាអញហើយ អ្នកដទៃនឹងធ្វើជនទាំងពីរនេះ

ឲ្យត្រូវរូវគ្នាមិនមានឡើយ អញនឹងទូលព្រះរាជាឲ្យទ្រង់យល់ព្រម ហើយមិនឲ្យដេញព្រះទេវីនេះទៅ ទើបពោលគាថាទី ៤ ថា

បពិត្រមហារាជ ទោសខុសព្រោះសេចក្តីប្រមាទទាំងនេះរមែងមានដល់នាងនារីដែលដល់នូវយសសក្តិ បពិត្រព្រះទេវៈ សូមព្រះអង្គអត់ទោស ដល់ព្រះនាងសុជាតាទេវី បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំទ្រង់ព្រះពិរោធ ចំពោះព្រះនាងសុជាតាទេវីនេះឡើយ ដូច្នេះ ។

គាថានេះមានអធិប្បាយថា បពិត្រមហារាជ ទោសព្រោះការប្រមាទទាំងនេះ គឺបែបនេះ រមែងមានដល់នារីដែលបានទទួលយស ការតែងតាំងព្រះនាងទុកក្នុងតំណែងខ្ពង់ខ្ពស់បែបនេះ ហើយទ្រង់មិនអត់ទោសកំហុសមានប្រមាណប៉ុណ្ណេះ ក្នុងកាលឥឡូវនេះមិនសមគួរដល់ទ្រង់ឡើយ បពិត្រព្រះសម្មតិទេព ព្រោះហេតុនោះ សូមទ្រង់អត់ទោសដល់ព្រះនាងសុជាតា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ គឺជាធំក្នុងពលរថ សូមទ្រង់កុំព្រះពិរោធដល់ព្រះនាងសុជាតាទេវីនេះ ។

ព្រះរាជា ទ្រង់អត់សង្កត់នូវកំហុសនោះដល់ព្រះទេវី ព្រោះពាក្យរបស់ព្រះពោធិសត្វនោះ ទើបទ្រង់តែងតាំងក្នុងតំណែងដើមនោះឯង ។ តាំងអំពីនោះមក ព្រះរាជានិងព្រះទេវីទាំងពីរអង្គ ទ្រង់នៅដោយសាមគ្គីគ្នានឹងគ្នា ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាព្រះបាទកោ-

សល ក្នុងកាលឥឡូវនេះ ព្រះនាងសុជាតាក្នុងកាលនោះ បានមកជានាងមល្លិកា ចំណែកអាមាត្យ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុជាតាជាតក ចប់

# បលាសជាតក

[ ៥២៦ ] ( រុក្ខទេវតាពោធិសត្វពោលថា ) ម្នាលព្រាហ្មណ៍ អ្នកដឹងថាដើមចារនេះជាឈើឥតចេតនា ឥតចេះស្តាប់ ឥតដឹងអ្វីទេ ជាអ្នកប្រាជ្ញព្យាយាមមិនប្រហែសធ្វេសជានិច្ច ហេតុអ្វី ក៏សួររកការដេកជាសុខ ( របស់ដើមឈើ ) ។

[ ៥២៧ ] ( ព្រាហ្មណ៍ពោលថា ) ដើមឈើ ប្រាកដក្នុងទីដ៏ឆ្ងាយផង ធំផង ដុះនៅក្នុងទី ( ទួល ) មានសភាពជាទីនៅរបស់ភូត ហេតុនោះបានជាខ្ញុំថ្វាយបង្គំដើមចារនេះ ពួកភូតណា នៅអាស្រ័យលើដើមឈើនេះ ( ខ្ញុំថ្វាយបង្គំ ) ពួកភូតនោះ ព្រោះហេតុតែទ្រព្យ ។

[ ៥២៨ ] ( រុក្ខទេវតាពោលថា ) ម្នាលព្រាហ្មណ៍ ខ្ញុំនោះឯងកាលសម្លឹងឃើញនូវការដឹងគុណ ដែលអ្នកធ្វើហើយ ខ្ញុំនឹងធ្វើនូវការតបគុណដល់អ្នក តាមសមគួរដល់អានុភាព ការដែលអ្នកមកខ្វល់ខ្វាយ ក្នុងសំណាក់សប្បុរស នឹងជារបស់សោះសូន្យដូចម្តេចកើត ។

[ ៥២៩ ] ដើមល្វៀបណា ដុះនៅខាងមុខដើមទន្ទាប់ យញ្ញដែលគេធ្វើហើយក្នុងកាលមុនច្រើន ជាកំណាប់ដែលគេកប់ព័ទ្ធជុំវិញក្បែរគល់ល្វៀបនោះឯង ជាកំណាប់មិនមានអ្នកទទួល អ្នកចូរទៅគាស់យកកំណាប់ទ្រព្យនោះចុះ ។

**ចប់ បលាសជាតកទី ៧ ។**

# អដ្ឋកថា

## បលាសជាតក

[ ៥២៦-៥២៩ ] ព្រះសាស្តាទ្រង់ផ្ទំលើព្រះទែនសម្រាប់បរិនិព្វាន ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អចេតនំ ព្រាហ្មណា អស្សុណន្តំ** ដូច្នេះជាដើម ។

បានឮថា អាវុសោអង្គនោះ ដឹងថាក្នុងបច្ចូសសម័យថ្ងៃជិតរះនៃរាត្រីនោះ ព្រះសាស្តានឹងបរិនិព្វាន ក៏នឹកគិតដល់ខ្លួនថា អាត្មាអញនៅជាសេក្ខបុគ្គល មានកិច្ចដែលត្រូវធ្វើ តែព្រះសាស្តារបស់អញនឹងបរិនិព្វាន ការឧបដ្ឋាកដែលអញធ្វើដល់ព្រះសាស្តាអស់កាល ២៥ ឆ្នាំហេតុអ្វីក៏ឥតផល ត្រូវសេចក្តីសោកគ្របសង្កត់ ទើបឈរតោងត្រដោកទ្វារបន្ទប់តូច ក្នុងឧទ្យានទ្រហោយំ ។ ព្រះដ៏មានព្រះភាគទ្រង់មិនឃើញព្រះអានន្ទទើបត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អានន្ទទៅណា កាលទ្រង់ស្តាប់ដូច្នេះហើយ ទើបត្រាស់ឲ្យហៅព្រះអានន្ទមកប្រទានឱវាទថា ម្នាលអានន្ទ អ្នកបានធ្វើបុណ្យទុកហើយ ចូរប្រកបសេចក្តីព្យាយាម អ្នកនឹងអស់អាសវៈដោយឆាប់រួសរាន់ អ្នកកុំទោមនស្សឡើយ ការឧបដ្ឋាកដែលអ្នកធ្វើដល់តថាគតក្នុងកាលឥឡូវនេះ នឹងឥតផលដូចម្តេចកើត ការឧបដ្ឋាកដែលអ្នកធ្វើដល់តថាគតក្នុងកាលមុន សូម្បីកាលដែលតថាគតនៅមានរាគៈជាដើម ក៏គង់មានផល ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតាត្រង់ដើមចារ ក្នុងទីមិនឆ្ងាយអំពីនគរពារាណសី

ក្នុងកាលនោះ អ្នកនគរពារាណសីនាំគ្នាគោរពទេវតាជាមង្គល ទើបខ្វល់ខ្វាយធ្វើពលីកម្មជាដើមជានិច្ចកាល ។ កាលណោះ មានព្រាហ្មណ៍ទុគ៌តម្នាក់គិតថា អញនឹងប្រណិប័តន៍ទេវតាមួយអង្គ ទើបធ្វើគល់ចារធំមួយដើម ដែលដុះត្រង់ដីខ្ពស់ឲ្យរាបស្មើប្រាសចាកស្មៅហើយព័ទ្ធរបង យកខ្សាច់មករោយហើយប្រោះដោយគ្រឿងក្រអូបត្រង់ដើមឈើ បូជាដោយផ្កា គ្រឿងក្រអូបនិងធូមគន្ធអុជប្រទីប ហើយពោលថា សូមលោកនៅជាសុខ ហើយធ្វើប្រទក្សិណដើមឈើជៀសចេញទៅ ។ ព្រលឹមថ្ងៃទី ២ ព្រាហ្មណ៍នោះទៅសួរដល់ការដេកជាសុខសប្បាយ ។ ថ្ងៃមួយរុក្ខទេវតាគិតថា ព្រាហ្មណ៍នេះបដិបត្តិអញក្រៃលែង អញនឹងពិសោធព្រាហ្មណ៍នេះមើល គាត់ប្រណិប័តន៍អញដោយហេតុណា អញនឹងឲ្យហេតុនោះ ដូច្នេះហើយ ទេវតានោះ កាលព្រាហ្មណ៍នោះមកបោសគល់ឈើ ទើបឈរក្បែរៗដោយភេទរបស់ព្រាហ្មណ៍ចាស់ ហើយពោលគាថាទី ១ ថា

> ម្នាលព្រាហ្មណ៍ អ្នកដឹងថាដើមចារនេះជាឈើឥតចេតនា ឥតចេះស្តាប់ ឥតដឹងអ្វីទេ ជាអ្នកប្រារព្ធព្យាយាម មិនប្រហែសធ្វេសជានិច្ច ហេតុអ្វីក៏សួររកការដេកជាសុខ ( របស់ដើមឈើ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អស្សុណន្តំ** បានដល់ ឈ្មោះថា **អស្សុណន្តំ** ព្រោះមិនមានចេតនា ។ បទថា **ជានោ** បានដល់ លោកជាអ្នកដឹង ។ បទថា **ធុវំ អប្បមត្តោ** បានដល់ ជាអ្នកមិនប្រមាទជានិច្ច ។

ព្រាហ្មណ៍បានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

ដើមឈើប្រាកដក្នុងទីដ៏ឆ្ងាយផង ធំផង ដុះនៅក្នុងទី ( ទួល ) មានសភាពជាទីនៅរបស់ភូត ហេតុនោះ បានជាខ្ញុំថ្វាយបង្គំដើមចារនេះ ពួកភូតណា នៅអាស្រ័យលើដើមឈើនេះ ( ខ្ញុំថ្វាយបង្គំ ) ពួកភូតនោះ ព្រោះហេតុតែទ្រព្យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទូរេ សុតោ** សេចក្តីថា នែព្រាហ្មណ៍ ដើមឈើនេះប្រាកដក្នុងទីឆ្ងាយ មិនមែនប្រាកដក្នុងទីជិតៗ ។ បទថា **ព្រហា ច** បានដល់ ធំ ។ បទថា **តេសេ ឋិតោ** បានដល់ តាំងនៅក្នុងទីខ្ពស់ រាបស្មើ ។ បទថា **ភូតនិវាសរូបោ** បានដល់ មានសភាវៈជាទីអាស្រ័យរបស់ទេវតា គឺទេវតាដែលមានសក្តិធំអាស្រ័យនៅត្រង់ដើមចារនេះពិត ។ បទថា **តេ ច ធនស្ស ហេតុ** សេចក្តីថា ខ្ញុំសូមថ្វាយបង្គំដើមឈើនេះ និងទេវតាដែលឋិតនៅត្រង់ដើមឈើនេះ ព្រោះហេតុនៃទ្រព្យ មិនមែនមិនមានហេតុ ។

រុក្ខទេវតាបានស្តាប់ដូច្នោះ មានចិត្តជ្រះថ្លាក្នុងព្រាហ្មណ៍ ទើបលួងលោមព្រាហ្មណ៍ឲ្យល្ហែល្ហើយចិត្តថា នែព្រាហ្មណ៍ យើងជាទេវតាកើតត្រង់ដើមឈើនេះ អ្នកកុំខ្លាចឡើយ យើងនឹងឲ្យទ្រព្យដល់អ្នក បានឈរក្នុងអាកាស ត្រង់ទ្វារវិមានរបស់ខ្លួនដោយទេវានុភាពធំ បានពោលគាថា ២ ដទៃថា

ម្នាលព្រាហ្មណ៍ ខ្ញុំនោះឯង កាលសម្លឹងឃើញនូវការដឹងគុណដែលអ្នកធ្វើហើយ ខ្ញុំនឹងធ្វើនូវការតបគុណដល់អ្នកតាមសមគួរដល់អានុភាព ការដែលអ្នកមកខ្វល់ខ្វាយក្នុងសំណាក់

សប្បុរស នឹងជារបស់សោះសូន្យដូចម្តេចកើត ។

ដើមលៀបណា ដុះនៅខាងមុខដើមទន្ទាប់ យញ្ញដែលគេធ្វើហើយក្នុងកាលមុនច្រើន ជាកំណប់ ដែលគេកប់ព័ទ្ធជុំវិញក្បែរគល់លៀបនោះឯង ជាកំណប់មិនមានអ្នកទទួល អ្នកចូរទៅគាស់យកកំណប់ទ្រព្យនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថានុភាវំ** បានដល់ តាមអំណាច គឺតាមកម្លាំង ។ បទថា **កតញ្ញុតំ** សេចក្តីថា ដឹងគុណដែលអ្នកធ្វើដល់ខ្ញុំ ឈ្មោះថា សម្លឹងនូវភាពកតញ្ញូដែលមានក្នុងខ្លួននោះ ។ បទថា **អាគម្ម** បានដល់ មកហើយ ។ បទថា **សតំ សកាសេ** បានដល់ ក្នុងសម្នាក់របស់សប្បុរសទាំងឡាយ ។ បទថា **មោឃានិ តេ អស្សុ បរិជប្បិតានិ** សេចក្តីថា ខ្វល់ខ្វាយដោយវាចាដោយការសួរដល់ការដេកជាសុខសប្បាយ និងខ្នះខ្នែងដោយការបោសសម្អាតជាដើម នឹងមិនមែនជាផលដល់អ្នកដូចម្តេចកើត ។ បទថា **យោ តិន្ទុរុក្ខស្ស បរោ បិលក្ខោ** សេចក្តីថា រុក្ខទេវតាឈរត្រង់ទ្វារវិមាននោះឯង លាដៃចង្អុលថា ដើមលៀបនោះតាំងនៅខាងមុខដើមទន្ទាប់ ។ ក្នុងបទថា **បរិវារិតោ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា ត្រង់គល់លៀបនោះ ដើមលៀបនេះ ឈ្មោះថា **បរិវារិតោ** ព្រោះ គេកប់ទ្រព្យទុកជុំវិញគល់ឈើនោះ ឈ្មោះថា **បុព្វយញ្ញោ** ព្រោះទ្រព្យកើតឡើងដល់ពួកម្ចាស់ទ្រព្យដំបូងដោយអំណាចយញ្ញដែលគេបូជាហើយក្នុងកាលមុន ឈ្មោះថា **ឧឡារោ** ព្រោះជាដើមឈើធំ ដោយមានផ្ទាំងកំណប់មិនមែនតិច ឈ្មោះថា **និខាតោ** ព្រោះ

គេជីកដីកប់ទុក ឈ្មោះថា **អនាយានោ** ព្រោះឥឡូវនេះ ម្ចាស់ទាំងឡាយមិនមាន លោកពោលអធិប្បាយទុកថា កំណាប់ទ្រព្យធំនេះ ខ្ញុំកប់ទុកដោយឆ្នាំងទ្រព្យ កឆ្នាំងជាប់តៗគ្នាជុំវិញគល់ឈើនេះ មិនមានម្ចាស់ ចូរអ្នកទៅជីកទ្រព្យនោះៗចុះ ។ ទេវតានោះ កាលពោលយ៉ាងនេះហើយ ទើបឲ្យឱវាទដល់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ អ្នកជីកកំណាប់ទ្រព្យនោះទៅ នឹងលំបាកហត់នឿយ ចូរអ្នកទៅចុះ យើងនឹងនាំទ្រព្យនោះទៅកាន់ផ្ទះរបស់អ្នក ហើយនឹងកប់ទុកក្នុងទីនោះនិងទីនោះ ចូរអ្នកប្រើប្រាស់ទ្រព្យនោះដល់អស់ជីវិត ចូរឲ្យទានរក្សាសីលចុះ ។ ហើយញុំាងទ្រព្យនោះឲ្យប្រតិស្ឋានក្នុងផ្ទះរបស់ព្រាហ្មណ៍នោះដោយអានុភាពរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បលាសជាតក ចប់

# ជវសកុណជាតក

[ ៥៣០ ] ( សត្វត្រសេះពោលថា ) កម្លាំងណារបស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើងត្រូវបានសាច់បន្តិចបន្តួចខ្លះ ។

[ ៥៣១ ] ( រាជសីហ៍ឆ្លើយតបថា ) អ្នកឯងចូលទៅតាមចន្លោះនៃធ្មេញរបស់ខ្ញុំ ដែលជាអ្នកស៊ី ( សាច់ ) និងឈាម ធ្វើនូវអំពើអាក្រក់ទាំងឡាយជានិច្ច រស់នៅដោយសាច់ណា សាច់នោះមានច្រើន ។

[ ៥៣២ ] ( ត្រសេះឆ្លើយតបថា ) សេចក្តីដឹងគុណដែលគេធ្វើហើយ មិនមានក្នុងបុគ្គលណា ការសេពគប់នឹងបុគ្គលអ្នកមិនដឹងគុណ ដែលគេធ្វើហើយ មិនធ្វើ ( គុណនឹងអ្នកណា ) មិនតបស្នងសងគុណដល់អ្នកដែលធ្វើគុណហើយដល់ខ្លួននោះ ជាការឥតប្រយោជន៍ ។

[ ៥៣៣ ] បណ្ឌិតមិនបានមិត្តធម៌ ដោយសារគុណដែលខ្លួនសន្សំហើយក្នុងទីចំពោះមុខបុគ្គលណា បណ្ឌិតមិនត្រូវប្រស្សា មិនត្រូវជេរ ត្រូវតែគេចចេញចាកបុគ្គលនោះ ដោយសន្សឹមៗ ។

**ចប់ ជវសកុណជាតកទី ៨ ។**

# អដ្ឋកថា

# ជវសកុណជាតក

[ ៥៣០-៥៣៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអកតញ្ញូរបស់ទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អកម្មរាជ តេ កិច្ចំ** ដូច្នេះជាដើម ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ជាអកតញ្ញូដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាសត្វត្រសេះក្នុងហិមវន្តប្បទេស ។ កាលនោះ រាជសីហ៍មួយស៊ីសាច់ ឆ្អឹងក៏ជាប់ករហូតហើម ។ មិនអាចចាប់ចំណីបរិភោគបាន វេទនាដ៏ខ្លាំងក្លាប្រព្រឹត្តទៅ ។ លំដាប់នោះ បក្សីនោះត្រាច់ស្វែងរកចំណី បានឃើញរាជសីហ៍នោះ ក៏ទំត្រង់មែកឈើសួរថា អើសម្លាញ់ ឯងកើតទុក្ខព្រោះរឿងអ្វី រាជសីហ៍ក៏ប្រាប់សេចក្តីនោះ ។ បក្សីនោះពោលថា សម្លាញ់ ខ្ញុំនឹងនាំឆ្អឹងនោះចេញអំពីករបស់អ្នក តែខ្ញុំមិនអាចចូលទៅក្នុងមាត់របស់អ្នក ព្រោះខ្លាចអ្នកស៊ីខ្ញុំ ។ រាជសីហ៍ពោលថា សម្លាញ់កុំខ្លាចឡើយ ខ្ញុំមិនស៊ីឯងឡើយ ចូរឯងឲ្យជីវិតខ្ញុំចុះ ។ បក្សីនោះទទួលពាក្យថា សាធុ ហើយឲ្យរាជសីហ៍នោះដេកផ្អៀងហើយគិតថា អ្នកណានឹងដឹងថាអ្វីកើតឡើងដល់អញ ទើបដាក់កំណាត់ឈើខ្វាស់ទុកត្រង់បបូរមាត់ខាងលើនិងខាងក្រោមរបស់រាជសីហ៍នោះ ដោយមិនអាចឲ្យរាជសីហ៍បិទមាត់បាន ហើយចូលទៅក្នុងមាត់ យកចំពុះចឹកចុងឆ្អឹង

ឆ្អឹងក៏ធ្លាក់ចូលទៅ ។ លុះធ្វើឆ្អឹងឲ្យធ្លាក់ទៅហើយ កាលនឹងចេញអំពីមាត់របស់រាជសីហ៍ ទើបយកចំពុះចឹកកំណាត់ឈើឲ្យធ្លាក់ទៅ ហើយហើរចេញទៅទំត្រង់មែកឈើ រាជសីហ៍ជាសះស្បើយហើយ ។ ថ្ងៃមួយ រាជសីហ៍សម្លាប់ក្របីព្រៃមួយហើយទំពាស៊ី បក្សីគិតថា អញនឹងសាកល្បងរាជសីហ៍នោះមើល ទើបទំត្រង់មែកឈើខាងលើរាជសីហ៍នោះ កាលចរចានឹងរាជសីហ៍នោះ ទើបពោលគាថាទី ១ ថា

កម្លាំងណា របស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាម
កម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើង
ត្រូវបានសាច់បន្តិចបន្តួចខ្លះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អករម្ហាស តេ កិច្ចំ** សេចក្តីថា សីហៈដ៏ចម្រើន ខ្ញុំបានធ្វើកិច្ចមួយដល់អ្នក ។ បទថា **យំ ពលំ អហុវម្ហសេ** សេចក្តីថា កម្លាំងណាមានដល់ខ្ញុំ ខ្ញុំមិនបានធ្វើអ្វីមួយឲ្យវិនាសចាកកិច្ចនោះ បានធ្វើហើយដោយកម្លាំងនោះឯង ។ រាជសីហ៍បានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

អ្នកឯង ចូលទៅតាមចន្លោះនៃធ្មេញរបស់ខ្ញុំ ដែលជាអ្នក
ស៊ី ( សាច់ ) និងឈាម ធ្វើនូវអំពើអាក្រក់ទាំងឡាយជានិច្ច
រស់នៅដោយសាច់ណា សាច់នោះមានច្រើន[១]ដូច្នេះ ។

---

១-ពាក្យថា ពហុំ យម្បិ ជីវសិ នេះ គួរប្រែថា អ្នករួចជីវិតបាន នោះជាគុណច្រើន ( ណាស់ទៅ ) ហើយ ។

បក្សីស្តាប់ដូច្នោះ ទើបពោលគាថា ២ ក្រៅអំពីនេះថា

សេចក្តីដឹងគុណដែលគេធ្វើហើយ មិនមានក្នុងបុគ្គលណា

ការសេពគប់នឹងបុគ្គលអ្នកមិនដឹងគុណដែលគេធ្វើហើយ មិន

ធ្វើ ( គុណនឹងអ្នកណា ) មិនតបស្នងសងគុណដល់អ្នកដែល

ធ្វើគុណហើយដល់ខ្លួននោះ ជាការឥតប្រយោជន៍ ។

បណ្ឌិតមិនបានមិត្តធម៌ដោយសារគុណដែលខ្លួនសន្សំហើយ

ក្នុងទីចំពោះមុខបុគ្គលណា បណ្ឌិតមិនត្រូវប្រួស្បា មិនត្រូវជេរ

ត្រូវតែគេចចេញចាកបុគ្គលនោះ ដោយសន្សឹមៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អកតញ្ញុំ** បានដល់ ជាអ្នកមិនដឹងគុណដែលគេធ្វើហើយ ។ បទថា **អកត្តារំ** បានដល់ ដែលមិនធ្វើកិច្ចណាមួយ ។ បទថា **សម្មុខចិណ្ណេន** សេចក្តីថា ដោយគុណដែលធ្វើទុកចំពោះមុខ ។ បទថា **អនុសូយមនក្កោសំ** សេចក្តីថា បណ្ឌិតកុំប្រណែន កុំជេរបុគ្គលនោះ គប្បីជៀសចេញឲ្យឆ្ងាយសន្សឹមៗអំពីបាបបុគ្គលនោះ ។

កាលពោលយ៉ាងនេះហើយ បក្សីនោះក៏ហើរជៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា រាជសីហ៍ក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកបក្សីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ជវសកុណជាតក ចប់**

## ឆវជាតក

[ ៥៣៤ ] ( ពោធិសត្វក្រាបទូលព្រះបាទពារាណសីថា ) កិច្ចដែលយើងទាំង ៣ នាក់ធ្វើហើយ ទាំងអស់នេះជាកិច្ចលាមក បុគ្គលណា ( អង្គុយក្នុងទីទាប ) បង្ហាញមន្ត ១ បុគ្គលណា ( អង្គុយក្នុងទីខ្ពស់ ) រៀននូវមន្ត ១ បុគ្គលទាំង ២ នាក់ ( នោះ ) មិនឃើញនូវបុរាណធម៌ផង បុគ្គលទាំង ២ នាក់ ( នោះ ) ឃ្លាតចាកប្រក្រតីផង ។

[ ៥៣៥ ] ( ព្រាហ្មណបុរោហិតឆ្លើយតបថា ) ខ្ញុំបរិភោគបាយស្រូវសាលីស្អាត ( របស់ស្តេចនេះ ) លាយដោយសាច់ ហេតុនោះបានជាខ្ញុំមិនសេពគប់នូវធម៌ដែលពួកឥសីសេពគប់ហើយនោះទេ ។

[ ៥៣៦ ] ( ពោធិសត្វពោលថា ) អ្នកចូរចៀសចេញពីទីនេះទៅ លោកនេះក៏ធំទូលាយ ពួកសត្វឯទៀតតែងស្ងោរដណ្តាំដែរ អ្នកកុំប្រព្រឹត្តអធម៌ ដូចជាថ្មដែលបំបែកនូវឆ្នាំងឡើយ ។

[ ៥៣៧ ] ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលនូវការបានយសនឹងបានទ្រព្យ ព្រោះការប្រព្រឹត្តបំផ្លាញខ្លួន ឬដោយកិរិយាប្រព្រឹត្តអធម៌ ។

**ចប់ ឆវជាតកទី ៩ ។**

# អដ្ឋកថា

## ឆវជាតក

[ ៥៣៤-៥៣៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វំ ឥទញ្ច មរិកតំ** ដូច្នេះជាដើម ។

រឿងមានមកហើយដោយពិស្តារក្នុងព្រះវិន័យនោះឯង ។ ចំណែកក្នុងជាតកនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ព្រះសាស្តា ត្រាស់ឲ្យហៅភិក្ខុឆព្វគ្គិយមកហើយសួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកអង្គុយលើអាសនៈទាប ហើយសម្តែងធម៌ដល់អ្នកអង្គុយលើអាសនៈខ្ពស់ពិតឬ កាលឆព្វគ្គិយភិក្ខុក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់តិះដៀលភិក្ខុទាំងនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលពួកអ្នកមិនធ្វើសេចក្តីគោរពក្នុងធម៌របស់តថាគតមិនសមគួរ ដ្បិតថាបុរាណកបណ្ឌិតទាំងឡាយ បានតិះដៀលអាចារ្យដែលអង្គុយលើអាសនៈ ប្រាប់មន្តដល់ជនក្រៅសាសនា ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលចណ្ឌាល លុះចម្រើនវ័យហើយ ក៏តម្កល់ខ្លួនបាន ។ ភរិយារបស់បុរសចណ្ឌាលនោះចាញ់ផ្ទៃចង់បរិភោគស្វាយទើបពោលថា នែអ្នក ខ្ញុំចង់បរិភោគស្វាយ ។ ប្តីពោលថា នែនាង ក្នុងរដូវកាលនេះស្វាយមិនមាន អញនឹងនាំផ្លែឈើជូរដទៃមកឲ្យ ភរិយាពោលថា នែអ្នក ខ្ញុំចង់បានផ្លែស្វាយប៉ុណ្ណោះ នឹងមានជីវិតរស់នៅបាន បើមិនបានជីវិតក៏មិនមាន ។

ប្តីនោះជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងភរិយានោះ ទើបគិតថា អញនឹងបានស្វាយអំពីណាហ្ន៎ ។ សម័យនោះឯង ក្នុងព្រះរាជឧទ្យានរបស់ព្រះបាទពារាណសី មានស្វាយមានផ្លែជាប្រចាំ ទើបបុរសចណ្ឌាលគិតថា អញនឹងនាំផ្លែស្វាយចាស់អំពីព្រះរាជឧទ្យាននោះ មករម្ងាប់ការចាញ់ផ្លែរបស់ភរិយានេះ លុះដល់កណ្តាលយប់ ទើបទៅកាន់រាជឧទ្យាន ឡើងដើមស្វាយហើយលាក់ខ្លួនរកមើលស្វាយត្រង់មែកផ្សេងៗ ។ កាលបុរសចណ្ឌាលនោះ ធ្វើយ៉ាងនេះឯង រាត្រីក៏អស់ គាត់គិតថា អញនឹងចុះទៅក្នុងកាលឥឡូវនេះ ឧទ្យានបាលនឹងឃើញអញ ចាប់អញថាជាចោរ អញនឹងទៅក្នុងពេលយប់ ទើបឡើងទៅកាន់ប្រគាបមួយហើយពួនសម្ងំ ។ កាលណោះ ព្រះបាទពារាណសីទ្រង់ព្រះតម្រិះថា នឹងរៀនមន្តក្នុងសម្នាក់បុរោហិត ទើបទ្រង់យាងចូលកាន់រាជឧទ្យាន ប្រថាប់គង់លើអាសនៈខ្ពស់ត្រង់គល់ស្វាយ ឲ្យអាចារ្យអង្គុយលើអាសនៈទាបហើយរៀនមន្ត ។ ព្រះពោធិសត្វពួនខាងលើគិតថា ព្រះរាជានេះ ប្រថាប់គង់លើអាសនៈខ្ពស់រៀនមន្ត ទ្រង់មិនមានធម៌ សូម្បីព្រាហ្មណ៍អ្នកអង្គុយលើអាសនៈទាបបង្រៀនមន្ត ក៏មិនមានធម៌ អញដែលមិនអើពើដល់ជីវិត មកលួចស្វាយព្រោះហេតុនៃមាតុគ្រាម ក៏ជាអ្នកមិនមានធម៌ ។ ព្រះពោធិសត្វនោះកាលនឹងចុះអំពីដើមស្វាយ ទើបចាប់មែកដែលទោរទន់មួយ ហក់ចុះមកឈរក្នុងទីចំពោះមុខជនទាំងពីរគឺព្រះរាជា និងបុរោហិតនោះ ហើយក្រាបទូលថា បពិត្រមហារាជ ទូលបង្គំជាមនុស្សវិនាសហើយ ទ្រង់ជាបុគ្គលល្ងង់ខ្លៅ បុរោហិតជាបុគ្គលដែលស្លាប់ហើយ ត្រូវព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើប

ពោលគាថាទី ១ ថា

កិច្ចដែលយើងទាំង ៣ នាក់ធ្វើហើយ ទាំងអស់នេះជាកិច្ចលាមក បុគ្គលណា ( អង្គុយក្នុងទីទាប ) បង្ហាញមន្ត ១ បុគ្គលណា ( អង្គុយក្នុងទីខ្ពស់ ) រៀននូវមន្ត ១ បុគ្គលទាំង ២ នាក់ ( នោះ ) មិនឃើញនូវបុរាណធម៌ផង បុគ្គលទាំង ២ នាក់ ( នោះ ) ឃ្លាតចាកប្រក្រតីផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វំ ឥទញ្ច មរិកតំ** សេចក្ដីថា កិច្ចទាំងអស់ដែលយើងទាំងឡាយ គឺដែលជនទាំង ៣ ធ្វើជាកិច្ចលាមក គឺឥតមារយាទមិនជាធម៌ ។ ព្រះពោធិសត្វតិះដៀលភាពដែលខ្លួនជាចោរ និងភាពដែលព្រះរាជានិងបុរោហិតទាំងនោះ មិនគោរពក្នុងមន្តទាំងឡាយហើយ កាលនឹងតិះដៀលចំពោះជនទាំងពីរគឺព្រះរាជានិងបុរោហិត ( ដោយពាកក្រៅ ) អំពីនេះទើបពោលពាក្យជាដើមថា បុគ្គលទាំង ២ នាក់ ( នោះ ) មិនឃើញនូវបុរាណធម៌ផង ដូច្នេះ ។ បណ្ដាបទថាទាំងនោះ បទថា **ឧភោ** សេចក្ដីថា ជនទាំងពីររមែងមិនឃើញបុរាណកធម៌ដែលគួរដល់ការធ្វើសេចក្ដីគោរព និងជាអ្នកឃ្លៀងឃ្លាតចាកប្រក្រតីក្នុងធម៌នោះ ពិតហើយ ធម៌ឈ្មោះថាប្រក្រតីព្រោះកើតឡើងមុន សមដូចលោកពោលទុក ( ក្នុងធម្មទេវបុត្តជាតក ) ថា ធម៌បានកើតមុន អធម៌កើតក្រោយក្នុងលោក ... ដូច្នេះ ។ បណ្ដាបទទាំងនោះបទថា **យោ ចាយំ** សេចក្ដីថា បុរោហិតនេះអង្គុយលើអាសនៈទាប ឲ្យទន្ទេញមន្ត ព្រះរាជានេះអង្គុយលើអាសនៈខ្ពស់បានរៀនយក ។ ព្រាហ្មណ៍

បានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

ខ្ញុំបរិភោគបាយស្រូវសាលីស្អាត ( របស់ស្តេចនេះ ) លាយ
ដោយសាច់ ហេតុនោះបានជាខ្ញុំមិនសេពគប់នូវធម៌ ដែលពួក
ឥសីសេពគប់ហើយនោះទេ ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអធិប្បាយថា អ្នកដ៏ចម្រើន ខ្ញុំបរិភោគបាយនៃស្រូវសាលីដែលជារបស់នៃព្រះរាជានេះ ជាបាយស្អាតលាយដោយសាច់បង់ដោយសេប្រភេទនៃសាច់មានប្រការផ្សេងៗ ព្រោះហេតុនោះ ទើបខ្ញុំជាបុគ្គលជាប់ចំពាក់ក្នុងផ្ទៃ ទើបមិនសេពនូវធម៌នេះ ដែលពួកឥសីទាំងឡាយស្វែងរកគុណសេពហើយ ។ ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបពោលគាថា ២ ថា

អ្នកចូរចៀសចេញពីទីនេះទៅ លោកនេះក៏ធំទូលាយ ពួក
សត្វឯទៀត តែងស្ងួដណ្តាំដែរ អ្នកកុំប្រព្រឹត្តអធម៌ ដូចជាថ្ម
ដែលបំបែកនូវឆ្នាំងឡើយ ។

ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលនូវការបានយស និង
បានទ្រព្យព្រោះការប្រព្រឹត្តបំផ្លាញខ្លួន ឬដោយកិរិយាប្រព្រឹត្ត
អធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិព្វជ** សេចក្តីថា អ្នកចូរចៀសចេញអំពីទីនេះទៅទីដទៃ ។ បទថា **មហា** សេចក្តីថា លោកនេះ ឈ្មោះថា ធំទូលាយ ។ បទថា **បចន្តញ្ញេបិ** សេចក្តីថា មនុស្សដទៃៗក្នុងជម្ពូទ្វីបនេះ ក៏ដណ្តាំស្ល មិន

មែនព្រះ រាជាមួយអង្គនេះប៉ុណ្ណោះ ។ បទថា **អស្មា កុម្ភមិវាភិទា** សេចក្ដីថា ដូចថ្មបំបែកឆ្នាំងដូច្នោះ ។ លោកពោលពាក្យអធិប្បាយទុកថា អ្នកមិនទៅទីដទៃ នៅប្រព្រឹត្តអធម៌ក្នុងទីនេះ អធម៌ដែលអ្នកប្រព្រឹត្តហើយយ៉ាងនោះ កុំបំផ្លាញនូវអ្នកឡើយ ដូចដុំថ្មបំបែកឆ្នាំងដូច្នោះ ។ ពាក្យថា **ធិរត្ថុ** ជាដើម មានសេចក្ដីសង្ខេបដូចតទៅនេះថា នៃព្រាហ្មណ៍ ខ្ញុំតិះដៀល គឺនិន្ទាការបានយសនិងទ្រព្យរបស់អ្នកយ៉ាងនេះ ព្រោះហេតុអ្វី ព្រោះលាភដែលអ្នកបានហើយនេះ និងការដល់ព្រមដោយហេតុជាគ្រឿងឲ្យធ្លាក់ទៅ ក្នុងអបាយទាំងឡាយតទៅ ឈ្មោះថាជាការចិញ្ចឹមជីវិតមិនប្រកបដោយធម៌ ប្រយោជន៍អ្វីដោយការចិញ្ចឹមជីវិត ដែលសម្រេចដោយការធ្វើខ្លួន ឲ្យធ្លាក់ចុះយ៉ាងនេះ ឬដោយការប្រព្រឹត្តមិនប្រកបដោយធម៌នេះ ហេតុនោះ ទើបខ្ញុំពោលយ៉ាងនេះនឹងអ្នក ។

លំដាប់នោះ ព្រះរាជាទ្រង់ជ្រះថ្លា ក្នុងធម្មកថារបស់ព្រះពោធិសត្វនោះ ត្រាស់សួរថា នៃបុរសដ៏ចម្រើន អ្នកមានជាតិជាអ្វី ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំជាចណ្ឌាល ព្រះរាជាត្រាស់ថា អ្នកដ៏ចម្រើន បើអ្នកសម្បូរដោយជាតិសោត យើងនឹងឲ្យរាជសម្បត្តិដល់អ្នក តែតាំងអំពីនេះទៅ យើងនឹងធ្វើជាព្រះរាជាក្នុងពេលថ្ងៃ ចូរអ្នកធ្វើជាព្រះរាជាក្នុងពេលយប់ ហើយព្រះរាជទានកម្រងផ្កា គ្រឿងប្រដាប់ករបស់ទ្រង់ ឲ្យប្រដាប់កព្រះពោធិសត្វនោះ ហើយទ្រង់ធ្វើព្រះពោធិសត្វឲ្យជាអ្នកគ្រប់គ្រងព្រះនគរ ។ នេះជាទំនៀមនៃការប្រដាប់កម្រងផ្កាពណ៌ក្រហមត្រង់ក របស់អ្នកគ្រប់គ្រងព្រះនគរ ។

តាំងអំពីនោះមក ព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វនោះ ទ្រង់ធ្វើសេចក្ដីគោរពក្នុងឋានៈជាអាចារ្យ ប្រថាប់គង់លើអាសនៈទាបហើយទ្រង់រៀនមន្ត ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់បានប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ចំណែកកូនចណ្ឌាលក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឆវជាតក ចប់

## សយ្ហជាតក

[ ៥៣៨ ] ( តាបសពោធិសត្វពោលថា ) បុគ្គលមិនគប្បីប្រាថ្នានូវផែនដីដែលមានសណ្ឋានដូចកុណ្ឌល ក្នុងកណ្ដាលសាគរ មានសមុទ្រព័ទ្ធជុំវិញមួយអន្លើដោយពាក្យនិន្ទាឡើយ ម្នាលសយ្ហាមាត្យ ចូរអ្នកដឹងយ៉ាងនេះចុះ ។

[ ៥៣៩ ] ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលការបានយសនឹងការបានទ្រព្យព្រោះការប្រព្រឹត្តបំផ្លាញខ្លួន ឬដោយការប្រព្រឹត្តអធម៌ ។

[ ៥៤០ ] សូវអាត្មាជាអ្នកមិនមានផ្ទះសម្បែង ប្រព្រឹត្តកាន់បាត្រ ( សូមគេ ) ការចិញ្ចឹមជីវិតនោះឯង ប្រសើរជាជាងការស្វែងរកមិនប្រកបដោយធម៌ ។

[ ៥៤១ ] សូវអាត្មាជាអ្នកមិនមានផ្ទះសម្បែង ប្រព្រឹត្តកាន់បាត្រ មិនបៀតបៀននូវសត្វដទៃក្នុងលោក ការប្រព្រឹត្តនោះ ប្រសើរជាជាងរាជសម្បត្តិទៅទៀត ។

**ចប់ សយ្ហជាតកទី ១០ ។**

**ចប់ កាលិង្គវគ្គទី ១ ។**

### ឧទ្ទាននៃកាលិង្គវគ្គនោះគឺ

និយាយអំពីការបើកទ្វារ ១ ជនមិនឲ្យ ១ កាមគុណដ៏មាំមួន ១ នាគឈ្មោះទទ្ទរៈ ១ អំពើបាបមិនមានស្ងាត់កំបាំង ១ ផ្លែពុទ្រា ១ ដើមចារ ១ ការធ្វើអំពើដ៏ប្រសើរ ១ អំពើលាមក ១ ផែនដីមានសមុទ្រព័ទ្ធជុំវិញ ១ ត្រូវជា ១០ ។

# អដ្ឋកថា

## សេយ្យជាតក

[ ៥៣៨-៥៤១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សសមុទ្ទបរិយាយំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី ឃើញស្ត្រីដែលតាក់តែងកាយ មានរូបល្អត្រកាលម្នាក់ បានជាអ្នកអផ្សុកមិនត្រេកអរក្នុងសាសនា លំដាប់នោះទើបភិក្ខុទាំងឡាយនាំគ្នាបង្ហាញភិក្ខុនោះដល់ព្រះមានព្រះភាគ ភិក្ខុនោះកាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថាអ្នកអផ្សុកពិតឬ ទើបក្រាបទូលថា ករុណាព្រះអង្គ ។ កាលព្រះសាស្តាត្រាស់ថា អ្នកណាធ្វើឲ្យអ្នកអផ្សុក ទើបក្រាបទូលសេចក្តីនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខបែបនេះ ព្រោះហេតុអ្វីទើបអ្នកអផ្សុក បណ្ឌិតទាំងឡាយក្នុងកាលមុន សូម្បីបានតំណែងជាបុរោហិត ក៏គង់បដិសេធតំណែងនោះហើយទៅបួស កាលត្រាស់ហើយទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរ ពារាណសី ព្រះពោធិសត្វកើតក្នុងឧទរព្រាហ្មណីរបស់បុរោហិត ប្រសូតក្នុងថ្ងៃតែមួយជាមួយព្រះឱរសនៃព្រះរាជា ។ ព្រះរាជាត្រាស់សួរអាមាត្យទាំងឡាយថា អ្នកណាកើតក្នុងថ្ងៃជាមួយឱរសរបស់យើង មានដែរឬហ្ន៎ អាមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ មាន គឺបុត្តរបស់បុរោហិត ។ ទើបព្រះរាជា

ទ្រង់បញ្ជាឲ្យយកបុត្តរបស់បុរោហិតនោះមកប្រគល់ឲ្យមេដោះទាំងឡាយ ឲ្យថែទាំរួមជាមួយព្រះរាជឱរស ។ គ្រឿងប្រដាប់និងគ្រឿងផឹក គ្រឿងបរិភោគរបស់កុមារទាំងពីរដូចគ្នានោះឯង ។ ព្រះរាជកុមារនិងកុមារចម្រើនវ័យហើយទៅកាន់នគរតក្កសិលា រៀនសិប្បៈទាំងពួងរួមគ្នា ហើយត្រឡប់មក ។ ព្រះរាជាទ្រង់បានប្រទានតំណែងឧបរាជដល់ព្រះរាជឱរស ព្រះពោធិសត្វមានយសធំ ។ តាំងអំពីកាលនោះមក ព្រះពោធិសត្វនិងព្រះរាជឱរស ក៏បរិភោគរួមគ្នា ផឹករួមគ្នា ដេករួមគ្នា វិសាសៈ គឺការស្និទ្ធស្នាលរវាងគ្នានឹងគ្នា ក៏មាំទាំឡើង ។ ក្នុងកាលតមក កាលព្រះរាជបិតាសោយទិវង្គតហើយ ព្រះរាជឱរសបានតាំងនៅក្នុងរាជសម្បត្តិ ទ្រង់សោយសម្បត្តិធំ ។ ព្រះពោធិសត្វគិតថា សម្លាញ់របស់អញបានគ្រងរាជ្យខណៈដែលទ្រង់កំណត់តំណែងនោះឯងគង់នឹងប្រទានតំណែងបុរោហិតដល់អញ ប្រយោជន៍អ្វី ដោយការគ្រប់គ្រងផ្ទះ អញនឹងបួស ចម្រើននូវវិវេក ។ ព្រះពោធិសត្វថ្វាយបង្គំមាតាបិតា សូមឲ្យលោកអនុញ្ញាត បព្វជ្ជាហើយ លះបង់មហាសម្បត្តិ ម្នាក់ឯងប៉ុណ្ណោះចេញទៅកាន់ហិមវន្តប្បទេស ធ្វើសាលាស្លឹកនៅត្រង់បទេសដែលគួររីករាយ បួសជាឥសី បានធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតឡើងហើយ ជាអ្នកលេងឈាន ។ ក្នុងកាលនោះ ព្រះរាជាទ្រង់នឹករឭកដល់ព្រះពោធិសត្វទើបសួរថា សម្លាញ់របស់យើងមិនប្រាកដ តើគេទៅណា ។ អាមាត្យទាំងឡាយទូលដល់ភាពដែលព្រះពោធិសត្វនោះបួសហើយ ក្រាបទូលថា បានឮថា សម្លាញ់របស់ទ្រង់នៅក្នុងដងព្រៃគួរជាទីត្រេកអរ ។ ព្រះរាជាត្រាស់សួរទីលំនៅរបស់ព្រះ

ពោធិសត្វនោះហើយ ត្រាស់នឹងសយ្ហអាមាត្យថា ចូរអ្នកនាំសម្លាញ់របស់យើងមក យើងនឹងឲ្យតំណែងបុរោហិតដល់សម្លាញ់របស់យើងនោះ ។ សយ្ហអាមាត្យទទួលព្រះតម្រាស់ហើយ ចេញអំពីនគរពារាណសី ទៅដល់បច្ចន្តគាមដោយលំដាប់ ហើយបោះជុំរុំក្នុងបច្ចន្តគាមនោះ ទៅកាន់លំនៅរបស់ព្រះពោធិសត្វជាមួយពួកព្រានព្រៃ ឃើញព្រះពោធិសត្វ អង្គុយត្រង់ទ្វារបណ្ណសាលា ដូចរូបបដិមាមាស ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ធ្វើបដិសណ្ឋារៈហើយពោលថា បពិត្រលោកម្ចាស់ ព្រះរាជាមានបំណងនឹងព្រះរាជទានតំណែងបុរោហិតដល់លោកម្ចាស់ ទ្រង់ទន្ទឹងការត្រឡប់មក ព្រះពោធិសត្វពោលថា តំណែងបុរោហិតចូរលើកទុកចុះ ខ្ញុំបានរាជសម្បត្តិក្នុងដែនកាសី ដែនកោសល ក្នុងជម្ពូទ្វីបទាំងមូលនិងសិរីនៃស្តេចចក្រពត្តិក៏មិនប្រាថ្នា បណ្ឌិតទាំងឡាយរមែងមិនត្រឡប់កាន់យកកិលេសទាំងឡាយ ដែលលះហើយម្តងទៀត ព្រោះវត្ថុដែលលះម្តងហើយ ដូចជាដុំទឹកមាត់ដែលស្តោះទៅហើយ ទើបពោលគាថាទាំងនេះថា

បុគ្គលមិនគប្បីប្រាថ្នានូវផែនដីដែលមានសណ្ឋានដូចកុណ្ឌល
ក្នុងកណ្តាលសាគរ មានសមុទ្ទព័ទ្ធជុំវិញមួយអន្ទើដោយពាក្យ
និន្ទាឡើយ ម្នាលសយ្ហាមាត្យ ចូរអ្នកដឹងយ៉ាងនេះចុះ ។

ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលការបានយសនឹងការ
បានទ្រព្យ ព្រោះការប្រព្រឹត្តបំផ្លាញខ្លួន ឬដោយការប្រព្រឹត្ត
អធម៌ ។

សូវអាត្មា ជាអ្នកមិនមានផ្ទះសម្បែង ប្រព្រឹត្តកាន់បាត្រ ( សូមគេ ) ការចិញ្ចឹមជីវិតនោះឯង ប្រសើរជាជាងការស្វែងរកមិនប្រកបដោយធម៌ ។

សូវអាត្មាជាអ្នកមិនមានផ្ទះសម្បែង ប្រព្រឹត្តកាន់បាត្រ មិនបៀតបៀននូវសត្វដទៃក្នុងលោក ការប្រព្រឹត្តនោះ ប្រសើរជាជាងរាជសម្បត្តិទៅទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរិយាយ** ក្នុងបទថា **សសមុទ្ទបរិយាយំ** សេចក្ដីថា បរិវារ លោកហៅថា **បរិយាយ** ជាមួយបរិវារ ពោលគឺសមុទ្រមួយអន្ទើដោយក្នុំកណ្ដាប់ចក្កវាឡ ដែលព័ទ្ធជុំវិញសមុទ្រ ។ បទថា **សាគរកុណ្ឌលំ** សេចក្ដីថា ដូចកុណ្ឌលរបស់សាគរនោះ ព្រោះតាំងនៅជាកោះត្រង់កណ្ដាលសាគរ ។ បទថា **និក្ខាយ** បានដល់ ដោយការនិទ្ទាដូច្នេះថា លះនូវការបួសដែលសម្បូរដោយសុខក្នុងឈាន កាន់យកឥស្សរិយយស ។ ព្រះពោធិសត្វហៅអាមាត្យនោះដោយឈ្មោះថា សយ្ហៈ ។ បទថា **វិជានហិ** បានដល់ ចូរអ្នកដឹងធម៌ ។ បទថា **យា វុត្តិ វិនិបាតេន** សេចក្ដីថា ការបានយស ការបានទ្រព្យនិងការចិញ្ចឹមជីវិតឯណា ដែលអញបានដោយការប្រាថ្នាធំរមែងមានដោយការធ្វើខ្លួនឲ្យថោកទាប គឺការញ៉ាំងខ្លួនឲ្យធ្លាក់ទៅចាកសេចក្ដីសុខក្នុងឈានឬដោយការទៅអំពីទីនេះហើយ ប្រព្រឹត្តមិនជាធម៌នៃអាត្មាអញដែលស្រវឹងដោយសេចក្ដីស្រវឹងក្នុងយស យើងតិះដៀលការចិញ្ចឹមជីវិតបែបនោះ ។ បទថា **បត្តមាធាយ** បានដល់ កាន់ភាជនៈដើម្បីភិក្ខា ។ បទថា

**អនាគារោ** សេចក្តីថា យើងជាអ្នកវៀរចាកផ្ទះត្រាច់ទៅក្នុងត្រកូលអ្នកដទៃ ។ បទថា **សាធុ ជីវិកា** សេចក្តីថា ការរស់នៅរបស់យើងនោះឯង ប្រសើរជាង គឺប្រសើរក្រៃលែងជាង ។ បទថា **យា ចាធម្មេន** បានដល់ ការស្វែងរកដោយមិនជាធម៌ឯណា លោកពោលអធិប្បាយថា ការរស់នៅនោះឯងល្អជាងការស្វែងរកដោយមិនប្រកបដោយធម៌នោះ ។ បទថា **អហឹសយំ** បានដល់ មិនបៀតបៀន ។ បទថា **អបិ រជ្ជេន** សេចក្តីថា យើងកាន់អំបែងសម្រេចនូវការចិញ្ចឹមជីវិតដោយមិនបៀតបៀនអ្នកដទៃយ៉ាងនេះ ប្រសើរ គឺឧត្តមជាងភាពជាព្រះរាជា ។

ព្រះពោធិសត្វហាមប្រាមសយ្ហាមាត្យ ដែលអង្វររឿយៗ ដោយប្រការដូច្នេះ ។ ចំណែកសយ្ហាមាត្យ កាលព្រះពោធិសត្វមិនយល់ព្រម ទើបថ្វាយបង្គំព្រះពោធិសត្វ ហើយមកក្រាបទូលដល់ព្រះរាជា ដល់ភាពដែលព្រះពោធិសត្វនោះមិនត្រឡប់មក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបប្រកាសសច្ចទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល មហាជនដទៃទៀតបានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលជាដើម ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ សយ្ហាមាត្យក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកកូនបុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា សេយ្ហជាតក ចប់

កាលិង្គវគ្គ ចប់

# បុចិមន្ទវគ្គ

## បុចិមន្ទជាតក

[ ៥៤២ ] ( និម្ពរុក្ខទេវតាពោលថា ) ម្នាលចោរ អ្នកចូរក្រោកឡើង អ្នកដេកធ្វើអ្វី ប្រយោជន៍អ្វីដោយការដេកលក់របស់អ្នក កុំឲ្យរាជបុរសទាំងឡាយ ចាប់អ្នកដែលធ្វើកម្មអាក្រក់ក្នុងស្រុកឡើយ ។

[ ៥៤៣ ] ( អស្សត្ថទេវតានិយាយថា ) រាជបុរសទាំងឡាយនឹងចាប់តែចោរដែលធ្វើកម្មអាក្រក់ក្នុងស្រុកទេតើ ប្រយោជន៍អ្វីដល់បុចិមន្ទទេវតាដែលស្ថិតនៅក្នុងព្រៃនោះ ។

[ ៥៤៤ ] ( បុចិមន្ទទេវតាពោលថា ) ម្នាលអស្សត្ថទេវតាអ្នកមិនដឹងនូវទោសនៃខ្ញុំផង នៃចោរផង ពួករាជបុរសចាប់បានចោរអ្នកធ្វើអំពើអាក្រក់ក្នុងស្រុក ហើយដោតចោរនោះដោយមែកស្ដៅស្រួច ខ្ញុំរង្កៀសចិត្តក្នុងហេតុនោះ ។

[ ៥៤៥ ] ( អស្សត្ថទេវតាពោលថា ) អ្នកប្រាជ្ញគប្បីរង្កៀសនូវហេតុដែលគួររង្កៀស គប្បីរក្សានូវភ័យដែលមិនទាន់មកដល់ អ្នកប្រាជ្ញតែងសម្លឹងមើលនូវលោកទាំង ២ ព្រោះអនាគតភ័យ ។

**ចប់ បុចិមន្ទជាតក ទី ១ ។**

# បុចិមន្ទវគ្គ

## អដ្ឋកថា បុចិមន្ទជាតក

[ ៥៤២-៥៤៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាមោគ្គល្លាន ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧដ្ឋេហិ ចោរ កឹ សេសិ** ដូច្នេះជាដើម ។

បានឮថា កាលព្រះថេរៈចូលទៅអាស្រ័យនគររាជគ្រឹះ នៅក្នុងកុដិដែលសាងក្នុងព្រៃ មានចោរម្នាក់កាត់ទីតក្នុងផ្ទះមួយខ្នង ក្នុងស្រុកក្បែរទ្វារក្រុង កាន់យកទ្រព្យដែលជាសារៈល្មមកាន់យកទៅបាន គេចទៅចូលបរិវេណកុដិរបស់ព្រះថេរៈ ហើយដេកត្រង់យ៉មុខនៃបណ្ណសាលារបស់ព្រះថេរៈ ដោយគិតថាក្នុងទីនេះនឹងគ្រប់គ្រងរក្សាអញបាន ។ ព្រះថេរៈដឹងថាចោរនោះ ដេកត្រង់យ៉មុខ ទើបធ្វើសេចក្តីរង្កៀសក្នុងចោរនោះគិតថា ធម្មតាការទាក់ទងជាមួយចោររមែងមិនគួរ ទើបចេញមកដេញថា នែឯងកុំមកដេកទីនេះ ទើបចោរចេញអំពីទីនោះ បន្សល់ទុកតែស្នាមជើងហើយគេចទៅ ។ មនុស្សទាំងឡាយកាន់គប់ភ្លើងមកក្នុងទីនោះតាមស្នាមជើងចោរ ឃើញទីមក ទីឈរ និងទីដេករបស់ចោរនោះ ទើបនិយាយគ្នាថា ចោរមកផ្លូវនេះ ឈរទីនេះ អង្គុយទីនេះ គេចទៅផ្លូវនេះ តែពួកយើងមិនឃើញចោរ នាំគ្នាស្ទុះទៅខាងនោះខាងនេះ ក៏មិនឃើញទើបនាំគ្នាត្រឡប់ ។ ស្អែកឡើង ពេលព្រឹក ព្រះថេរៈត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់អំពីបិណ្ឌបាត ហើយទើបទៅកាន់វេឡុវ័នវិហារ ក្រាបទូលរឿងនោះដល់ព្រះសាស្តា ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន

មិនមែនតែអ្នកប៉ុណ្ណោះ ដែលវៀរវៀសក្នុងវត្ថុដែលគួរវៀរវៀស សូម្បីបុរាណក បណ្ឌិតទាំងឡាយក៏វៀរវៀសហើយ កាលព្រះថេរៈអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតា អាស្រ័យនៅត្រង់ដើមស្ពៅក្នុងព្រៃដែលជាព្រៃខ្មោចមួយកន្លែងក្បែរព្រះនគរ ។ ថ្ងៃមួយចោរម្នាក់ធ្វើចោរកម្មក្នុងស្រុកក្បែរទ្វារក្រុង ហើយចូលទៅកាន់ព្រៃខ្មោចនោះ ។ ក្នុងកាលណោះ មានដើមឈើធំក្នុងព្រៃខ្មោចនោះ ២ ដើម គឺដើមស្ពៅនិងដើមអស្សត្ថព្រឹក្ស ។ ចោរទុកដាក់កញ្ចប់ភណ្ឌៈត្រង់គល់ស្ពៅ ហើយដេក តែក្នុងពេលដទៃ មនុស្សទាំងឡាយចាប់ពួកចោរដោតដោយឈើអណ្តោតដែលធ្វើដោយមែកស្ពៅ ។ ក្នុងកាលនោះ ទេវតានោះគិតថា បើពួកមនុស្សមកចាប់ចោរនេះ នឹងនាំគ្នាកាប់មែកស្ពៅនេះឯងសម្រួចដោតចោរនេះ កាលបើយ៉ាងនេះដើមឈើនឹងវិនាសណ្ហើយ ចុះអញនឹងនាំចោរនោះចេញអំពីទីនេះ ។ ទេវតានោះ កាលចរចាប្រាស្រ័យនឹងចោរនោះទើបពោលគាថាទី ១ ថា

ម្នាលចោរ អ្នកចូរក្រោកឡើង អ្នកដេកធ្វើអ្វី ប្រយោជន៍អ្វី
ដោយការដេកលក់របស់អ្នក កុំឲ្យរាជបុរសទាំងឡាយ ចាប់
អ្នក ដែលធ្វើកម្មអាក្រក់ក្នុងស្រុកឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាជានោ** លោកពោលសំដៅយកពួករាជបុរស ។ បទថា **កិព្វិសការកំ** បានដល់ ដែលធ្វើចោរកម្មដ៏ទារុណ ។

ទេវតាកាលពោលនឹងចោរនោះដូច្នេះហើយ ទើបធ្វើឲ្យខ្លាចគេចទៅ ដោយពោលថា ចូរទៅកាន់ទីដទៃដរាបទាន់រាជបុរសមិនទាន់មកចាប់ ។ កាលចោរនោះទៅហើយ ទេវតាដែលអាស្រ័យត្រង់អស្សត្ថព្រឹក្សក៏ពោលគាថាទី ២ ថា

រាជបុរសទាំងឡាយ នឹងចាប់តែចោរដែលធ្វើកម្មអាក្រក់ ក្នុងស្រុកទេតើ ប្រយោជន៍អ្វីដល់បុចិមន្ទទេវតាដែលស្ថិតនៅក្នុងព្រៃនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វនេ ជាតស្ស តិដ្ឋតោ** សេចក្ដីថា ដើមស្ដៅដែលដុះនិងតាំងនៅក្នុងព្រៃ ។ អស្សត្ថព្រឹក្សទេវតា ហៅបុចិមន្ទទេវតាដោយចំពោះ គឺហៅឈ្មោះដើមឈើ ព្រោះបុចិមន្ទទេវតានោះ កើតត្រង់ដើមស្ដៅនោះ ។ និម្ពទេវតាបានស្ដាប់ដូច្នោះទើបពោលគាថាទី ៣ ថា

ម្នាលអស្សត្ថទេវតា អ្នកមិនដឹងនូវទោសនៃខ្ញុំផង នៃចោរផង ពួករាជបុរសចាប់បានចោរអ្នកធ្វើអំពើអាក្រក់ក្នុងស្រុក ហើយដោតចោរនោះដោយមែកស្ដៅស្រួច ខ្ញុំរង្កៀសចិត្តក្នុងហេតុនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្សត្ថ** នេះ ទេវតាដែលកើតត្រង់ដើមស្ដៅនោះ ហៅដោយន័យមុននោះឯង ។ បទថា **មម ចោរស្ស ចន្តរំ** បានដល់ហេតុដែលយើងនិងចោរនៅរួមគ្នាមិនបាន ។ បទថា **អច្ចេន្តិ និម្ពស្មូលស្មឹ** សេចក្ដីថា ពេលនេះរាជបុរសទាំងឡាយនឹងដោតចោរទុកលើឈើស្រួច ដែលធ្វើអំពីមែកស្ដៅ ។ បទថា **តស្មឹ មេ សង្កតេ មនោ** សេចក្ដីថា ចិត្តរបស់ខ្ញុំ

វង្វៀសក្នុងហេតុនោះថាបើពួករាជបុរសចាប់ចោរនេះដោតដោយឈើអណ្តោតស្រោត វិមានរបស់យើងនឹងវិនាស បើមិនធ្វើយ៉ាងនោះ នឹងព្យួរចោរទុកត្រង់មែកស្ងោ វិមានរបស់យើងនឹងមានក្លិនស្អុយដោយសាកសព ហេតុនោះទើបយើងឲ្យចោរនោះគេចទៅ ។

កាលទេវតាទាំងនោះ ចរចាប្រាស្រ័យគ្នានឹងគ្នាយ៉ាងនេះឯង ពួកម្ចាស់ទ្រព្យកាន់គប់ភ្លើងមកតាមគន្លងជើង ឃើញទីចោរដេកទើបពោលថា អ្នកដ៏ចម្រើនទាំងឡាយ អំបាញ់មិញនេះ ចោរក្រោកគេចទៅហើយ ពួកយើងចាប់ចោរមិនបាន បើពួកយើងចាប់ចោរបានស្រោត នឹងដោតចោរនោះដោយឈើអណ្តោតមែកស្ងោនេះ ឬព្យួរទុកត្រង់មែកស្ងោហើយនឹងទៅ ថាហើយស្ទុះទៅក្នុងទីផ្សេងៗ មិនជួបចោរទើបត្រឡប់ទៅ ។ អស្សត្ថទេវតា បានស្តាប់ពាក្យរបស់បុគ្គលទាំងនោះ ទើបពោលគាថាទី ៤ ថា

អ្នកប្រាជ្ញគប្បីវង្វៀសនូវហេតុដែលគួរវង្វៀស គប្បីរក្សានូវភ័យ
ដែលមិនទាន់មកដល់ អ្នកប្រាជ្ញតែងសម្លឹងមើលនូវលោកទាំង
២ ព្រោះអនាគតភ័យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រក្ខេយ្យានាគតំ ភយំ** សេចក្តីថា អនាគតភ័យមាន ២ យ៉ាង គឺភ័យដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ ១ ភ័យដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ១ ក្នុងអនាគតភ័យ ២ យ៉ាងនោះ បណ្ឌិតកាលវៀរបាបមិត្ត ឈ្មោះថាការពារនូវភ័យដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ កាលវៀរទុច្ចរិត ៣ ឈ្មោះថាការពារនូវភ័យ ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព ។ បទថា

**អនាគតភយា** សេចក្ដីថា កាលវៀរស្មក្នុងភ័យនោះ ព្រោះអនាគតភ័យ ។ បទថា **ធីរោ** សេចក្ដីថា បុរសដែលជាបណ្ឌិតរមែងមិនធ្វើការប្រឡូកប្រឡំជាមួយបាបមិត្ត រមែងមិនប្រព្រឹត្តទុច្ចរិតដោយទ្វារទាំង ៣ ។ បទថា **ឧភោលោកេ** សេចក្ដីថា ព្រោះបណ្ឌិតនោះ កាលខ្លាចយ៉ាងនេះ រមែងពិចារណាឃើញ គឺរមែងឃើញលោកទាំងពីរ ពោលគឺលោកនេះ និងលោកខាងមុខ កាលវៀរស រមែងលះបាបមិត្ត ព្រោះខ្លាចភ័យក្នុងលោកនេះ រមែងមិនធ្វើបាបកម្មព្រោះខ្លាចភ័យក្នុងលោកខាងមុខ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា ទេវតាដែលកើតត្រង់ដើមអស្សត្ថព្រឹក្សក្នុងកាលនោះ បានមកជាសារីបុត្ត ក្នុងកាលឥឡូវនេះ ចំណែកទេវតាដែលកើតក្នុងដើមស្ដៅក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា បុចិមន្ទជាតក ចប់

# កស្សបមន្ទិយជាតក

[ ៥៤៦ ] ( តាបសពោធិសត្វពោលថា ) បពិត្រកស្សបជាបិតា បើក្មេងតូចជេរឬវាយ ព្រោះវាជាក្មេង បណ្ឌិតអ្នកមានប្រាជ្ញាតែងអត់សង្កត់នូវកំហុសទាំងអស់នោះ ។

[ ៥៤៧ ] ប្រសិនបើសប្បុរសទាំងឡាយទាស់ទែងគ្នា សប្បុរសរមែងតបានវិញយ៉ាងឆាប់ ឯក្មេងពាលទាំងឡាយ រមែងបែកគ្នាដូចបាត្រដី ក្មេងពាលទាំងនោះ មិនដល់នូវការស្ងប់រម្ងាប់ឡើយ ។

[ ៥៤៨ ] ជនណាដឹងនូវទោសដែលខ្លួនធ្វើឲ្យកន្លងហួសទៅហើយផង ជនណាដឹងនូវការសម្តែងនូវទោសផង ជនទាំង ២ ពួកនោះ ( បើទុកជាបែកគ្នាហើយ ) ច្រើនរួបរួមគ្នាវិញបាន ការតមិត្តរបស់ជនទាំង ២ ពួកនោះ មិនរលុបរលាយឡើយ ។

[ ៥៤៩ ] ជនណា គួរតនូវមិត្តភាពរបស់ពួកជនដទៃដែលទោសគ្របសង្កត់ហើយ ដោយខ្លួនឯងបាន ជននោះជាមនុស្សខ្ពង់ខ្ពស់លើសលុប ជាមនុស្សនាំទៅនូវភារៈបាន ជាមនុស្សទ្រទ្រង់នូវធុរៈបាន ។

**ចប់ កស្សបមន្ទិយជាតកទី ២ ។**

# អដ្ឋកថា

# កស្សបមន្ទិយជាតក

[ ៥៤៦-៥៤៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់មួយរូបទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **អបិ កស្សបមន្ទិយា** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានកុលបុត្តម្នាក់ ឃើញទោសក្នុងកាមទាំងឡាយ ទើបបួសក្នុងសម្នាក់របស់ព្រះសាស្តា ប្រកបរឿយៗក្នុងកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។ ចំណេរកាលតមក មាតារបស់ភិក្ខុនោះបានធ្វើកាលកិរិយា ។ កាលមាតាធ្វើកាលកិរិយាទៅហើយ ទើបភិក្ខុនោះឲ្យបិតានិងប្អូនប្រុសបួស ហើយនៅក្នុងវត្តជេតពន ។ ក្នុងវស្សូបនាយិកសម័យថ្ងៃជិតចូលវស្សា បានឮថា បច្ច័យគឺចីវររកបានងាយ ទើបទៅកាន់អាវាសក្នុងស្រុកមួយកន្លែងទាំង ៣ រូប ចាំវស្សាក្នុងអាវាសប្រចាំក្នុងស្រុកនោះ ចេញវស្សាហើយទើបត្រឡប់មកកាន់វត្តជេតពនដូចមុន ។ ទើបភិក្ខុកំលោះប្រាប់សាមណេរដែលជាប្អូនប្រុសក្បែរវត្តជេតពនថា សាមណេរ ចូរអ្នកឲ្យព្រះថេរៈចាស់សម្រាកហើយសឹមនាំមក ខ្ញុំទៅមុនដើម្បីចាត់ចែងបរិវេណ ហើយក៏ចូលទៅកាន់វត្តជេតពន ។ ព្រះថេរៈចាស់ដើរសន្សឹមៗមក ។ សាមណេរធ្វើហាក់ដូចជាយកក្បាលរុញរឿយៗ នាំលោកទៅដោយកម្លាំងថា បពិត្រលោកម្ចាស់សូមលោកនិមន្តទៅចុះ ។ ព្រះថេរៈពោលថា លោករុញមក ដោយអំណាចខ្លួន ទើបវិលត្រឡប់ទៅជាថ្មី ហើយដើរមកតាំងអំពីចុងផ្លូវ ។ កាលព្រះថេរៈនិងសាមណេរធ្វើនូវការឈ្លោះគ្នាយ៉ាងនេះឯង ព្រះអាទិត្យក៏អស្តង្គត

ងងឹតអន្ធការក៏កើតឡើង ។ ចំណែកភិក្ខុក្រៅអំពីនេះ ក៏បោសបរិវេណតម្កល់ទឹកទុក កាលមិនឃើញការមករបស់ព្រះថេរៈនិងសាមណេរនោះ ទើបកាន់យកគប់ភ្លើងទៅ រង់ចាំទទួល បានឃើញព្រះថេរៈនិងសាមណេរកំពុងមកទើបសួរថា ហេតុអ្វីទើបយឺតយូរ ព្រះថេរៈចាស់ក៏ប្រាប់ហេតុនោះ ភិក្ខុកំលោះនោះឲ្យព្រះថេរៈនិងសាមណេរនោះសម្រាកហើយនាំសន្សឹមៗមក ។ ថ្ងៃនោះ មិនបានឱកាសឧបដ្ឋាកព្រះសម្មាសម្ពុទ្ធ ។ ក្នុងថ្ងៃទីពីរ ភិក្ខុកំលោះនោះមកកាន់ទីឧបដ្ឋាកព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយអង្គុយ ព្រះសាស្ដា ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមកពីអង្កាល់ណា ភិក្ខុកំលោះក្រាបទូលថា បពិត្រព្រះអង្គ មកពីម្សិលមិញ ព្រះសាស្ដាត្រាស់ថា អ្នកមកតាំងពីម្សិលមិញ តែមកឧបដ្ឋាកក្នុងថ្ងៃនេះ ភិក្ខុកំលោះក្រាបទូលថា ករុណាព្រះអង្គ ហើយក្រាបទូលសេចក្ដីនោះ ។ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលព្រះថេរៈចាស់ ហើយត្រាស់ថា ភិក្ខុចាស់រូបនេះ ធ្វើកម្មបែបនេះក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានធ្វើហើយ តែឥឡូវនេះ ព្រះថេរៈចាស់នោះធ្វើអ្នកឲ្យលំបាក តែក្នុងកាលមុន បានធ្វើបណ្ឌិតឲ្យលំបាក កាលភិក្ខុនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាសីនិគម កាលព្រះពោធិសត្វនោះចម្រើនវ័យហើយ មាតាបានធ្វើកាលកិរិយា ព្រះពោធិសត្វនោះធ្វើឈាបនកិច្ចសរីរៈរបស់មាតាហើយ លុះកន្លងទៅបានកន្លះខែ បានឲ្យទ្រព្យដែល

មានក្នុងផ្ទះជាទាន ហើយនាំបិតានិងប្អូនប្រុសទៅ កាន់យកសំពត់សម្បកឈើ ដែលទេវតាឲ្យ ហើយបួសជាឥសីក្នុងហិមវន្តប្បទេស ញុំាងអត្តភាពឲ្យប្រ-ព្រឹត្តទៅដោយមើមដំឡូងនិងផ្លែឈើ ដោយការត្រាច់ស្វែងរកក្នុងដងព្រៃដែលគួរត្រេកអរ ។ ក្នុងព្រៃហិមពាន្តក្នុងរដូវភ្លៀង ភ្លៀងធ្លាក់មិនដាច់គ្រាប់ មិនអាចជីកដំឡូង ផ្លែឈើនិងស្លឹកឈើក៏ជ្រុះ ។ ដោយច្រើន តាបសទាំងឡាយ នាំគ្នាមកអំពីហិមវន្តប្បទេស មកកាន់ដែនដីមនុស្ស ។ ក្នុងកាលនោះ ព្រះពោធិសត្វ ក៏នាំបិតានិងប្អូនប្រុស មកកាន់ដែនដីមនុស្ស ។ កាលហិមវន្តប្បទេសដើមឈើទាំងឡាយ ចេញផ្កាចេញផ្លែទៀត ទើបនាំជនទាំងពីរ គឺបិតានិងប្អូនប្រុសនោះមកកាន់អាស្រមបទរបស់ខ្លួនក្នុងហិមវន្តប្បទេស ។ ក្នុងទីមិនឆ្ងាយអំពីអាស្រម កាលព្រះអាទិត្យអស្តង្គតហើយទើបពោលថា លោកទាំងឡាយដើរមកបណ្តើរៗចុះ ខ្ញុំទៅមុនដើម្បីរៀបចំអាស្រម ហើយក៏លាតាបសទាំងពីរនោះធ្វើដំណើរទៅ ។ តាបសជាប្អូន ដើរសន្សឹមៗទៅជាមួយបិតា ក៏យកក្បាលរុញបិតាត្រង់ចង្កេះនាំទៅដោយពោលថា ដើរៗ ។ តាបសចាស់ពោលថា ឯងនាំយើងមកតាមគាប់ចិត្តរបស់ខ្លួន ហើយទើបដើរត្រឡប់ទៅក្រោយដើរមកជាថ្មី ។ កាលតាបស ឪកូនទាំងនោះ ធ្វើនូវការឈ្លោះគ្នានឹងគ្នាយ៉ាងនោះ ងងឹតក៏មកដល់ ។ ព្រះពោធិសត្វបោសសម្អាតបណ្ណសាលា តម្កល់ទឹកប្រើ ទឹកឆាន់ ហើយកាន់គប់ភ្លើងដើរបញ្ច្រាស់ផ្លូវមក ឃើញតាបសឪពុកនិងកូននោះទើបពោលថា លោកម្ចាស់ទាំងឡាយរវល់ធ្វើអ្វី អស់កាលមានប្រមាណប៉ុណ្ណោះ ។ ទើបតាបសជាប្អូននោះប្រាប់ហេតុដែលបិតាធ្វើ ។ ព្រះ

ពោធិសត្វនាំតាបសទាំងពីរនោះមកឃើតៗ ឲ្យទុកដាក់បរិក្ខារ ឲ្យបិតាងូតទឹក ធ្វើនូវការលាងជើង លាបជើងនិងគក់ខ្នង ដាក់អំបែងរងើកភ្លើង ហើយចូលទៅអង្គុយជិតបិតា ដែលរម្ងាប់កាពចុករួយហើយ ទើបពោលថា បពិត្របិតា ធម្មតាក្មេងកំលោះទាំងឡាយ ដូចគ្នានឹងភាជនៈដី រមែងបែកបានមួយរំពេចប៉ុណ្ណោះ តាំងអំពីបែកហើយ មិនអាចតគ្នាបានវិញ ក្មេងកំលោះទាំងនោះ ជេរក្តី បរិភាសក្តី អ្នកជំគួរអត់ធន់ កាលឲ្យឱវាទដល់បិតាទើបពោលគាថាទាំងនេះថា

បពិត្រកស្សបជាបិតា បើក្មេងតូចជេរប្រវាយ ព្រោះវាជាក្មេង បណ្ឌិតអ្នកមានប្រាជ្ញាតែងអត់សង្កត់នូវកំហុសទាំងអស់នោះ ។

ប្រសិនបើសប្បុរសទាំងឡាយទាស់ទែងគ្នា សប្បុរសរមែងតបានវិញយ៉ាងឆាប់ ឯក្មេងពាលទាំងឡាយ រមែងបែកគ្នាដូចបាត្រដី ក្មេងពាលទាំងនោះ មិនដល់នូវការស្ងប់រម្ងាប់ឡើយ ។

ជនណា ដឹងនូវទោស ដែលខ្លួនធ្វើឲ្យកន្លងហួសទៅហើយផង ជនណា ដឹងនូវការសម្តែងនូវទោសផង ជនទាំង ២ ពួកនោះ ( បើទុកជាបែកគ្នាហើយ ) ច្រើនរួបរួមគ្នាវិញបាន ការតមិត្តរបស់ជនទាំង ២ ពួកនោះ មិនរលុបរលាយឡើយ ។

ជនណា គួរតនូវមិត្តភាពរបស់ពួកជនដទៃដែលទោសគ្របសង្កត់ហើយ ដោយខ្លួនឯងបាន ជននោះ ជាមនុស្សខ្ពង់ខ្ពស់

លើសលុប ជាមនុស្សនាំទៅនូវភារៈបាន ជាមនុស្សទ្រទ្រង់នូវ
ធុរៈបាន ដូច្នេះ ។

ព្រះពោធិសត្វហៅបិតាដោយឈ្មោះថា កស្សបៈ ក្នុងកាលនោះ ។ បទថា **មន្តិយា** បានដល់ ដោយភាពជាបុគ្គលកំលោះ ដោយភាពជាអ្នកមានបញ្ញាតិច ។ បទថា **យុវា សុបតិ ហន្តិ វា** សេចក្តីថា ក្មេងកំលោះជេរក្តី ប្រហារក្តី ។ ដោយបទថា **ធីរោ** នេះ លោកហៅបុគ្គលដែលប្រាសចាកបាបថា ជាអ្នកមានសេចក្តីព្យាយាម អធិប្បាយថា ជាអ្នកប្រកបដោយបញ្ញា ដូច្នេះក៏មាន ។ ចំណែកបទថា **បណ្ឌិតោ** ជាវេវចនៈរបស់បទថា **ធីរោ** នេះប៉ុណ្ណោះ ។ សូម្បីដោយបទទាំងពីរ លោកសម្តែងថា បណ្ឌិតជាអ្នកមានបញ្ញាច្រើនរមែងអត់ធ្មត់ គឺអត់ធន់នូវកំហុសដែលពួកក្មេងអ្នកមានបញ្ញាទន់ធ្វើហើយទាំងអស់ ។ បទថា **សន្ធិយរេ** សេចក្តីថា រមែងបង្រួបបង្រួមគ្នា គឺតមិត្តភាពបានទៀត ។ បទថា **ពាលា បត្តាវ** សេចក្តីថា ចំណែកបុគ្គលពាលទាំងឡាយ រមែងបែកគ្នារហូត ដូចភាជនៈដីដែលបែកហើយ តគ្នាមិនបានដូច្នោះ ។ បទថា **ន តេ សមថមជ្ឈគូ** សេចក្តីថា បុគ្គលពាលទាំងនោះ ធ្វើនូវជម្លោះសូម្បីមានប្រមាណតិច រមែងមិនបាន គឺមិនជួបនូវការស្ងប់ពៀរ ។ បទថា **ឯតេ ភិយ្យោ** សេចក្តីថា ជនទាំងពីរនោះ សូម្បីបែកគ្នាហើយ រមែងត្រូវរូវគ្នាវិញបាន ។ បទថា **សន្ធិ** បានដល់ ផ្សះផ្សាដោយភាពជាមិត្ត ។ បទថា **តេសំ** សេចក្តីថា ការតជាប់គ្នារបស់ជនទាំងពីរនោះប៉ុណ្ណោះ រមែងមិនប្រែប្រួល ។ បទថា **យោ ចាធិបន្នំ** សេចក្តីថា បុគ្គលណារមែងដឹងទោសកំហុស

ដែលធ្វើទុកក្នុងអ្នកដទៃដែលខ្លួនត្រូវហើយ គឺកន្លងល្មើសហើយ ។ បទថា **ធេសធំ** សេចក្តីថា បុគ្គលណា រមែងដឹងទីទទួលនូវការសម្តែងទោស ដែលបុគ្គលនោះដឹងទោសខ្លួនសម្តែងហើយ ។ បទថា **យោ បរេសាធិបន្នានំ** សេចក្តីថា បុគ្គលណា កាលអ្នកដទៃកន្លងល្មើស គឺត្រូវទោសគ្របសង្កត់ ធ្វើនូវកំហុស ។ បទថា **សយំ សន្ធាតុមរហាតិ** សេចក្តីថា កាលមនុស្សទាំងនោះមិនសូមខមាទោស ខ្លួនឯងអាចធ្វើសេចក្តីស្និទ្ធស្នាល គឺភ្ជាប់មិត្តភាពយ៉ាងនេះថា អ្នកមានមុខស្អាតមកចុះ ចូររៀនឧទ្ទេស ចូរស្តាប់អដ្ឋកថា ចូរប្រឹងប្រែងប្រកបភាវនា ព្រោះហេតុអ្វីទើបលោកឆ្ងាយ បុគ្គលនេះ គឺបុគ្គលបែបនេះ ជាអ្នកមានប្រក្រតីនៅដោយមេត្តា ជាអ្នកប្រសើរក្រៃលែង រមែងដល់នូវការរាប់ថា ជាអ្នកនាំភារៈនិងទ្រទ្រង់នូវធុរៈទុក ព្រោះនាំភារៈនិងធុរៈរបស់មិត្តទៅ ។

ព្រះពោធិសត្វ បានឲ្យឱវាទដល់តាបសជាបិតាយ៉ាងនេះ ចាប់តាំងពីនោះមក តាបសជាបិតានោះ ក៏បានទូន្មានខ្លួនល្អហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា តាបសជាបិតាក្នុងកាលនោះ បានមកជាព្រះថេរៈចាស់ក្នុងកាលឥឡូវនេះ តាបសជាប្អូនក្នុងកាលនោះ បានមកជាសាមណេរ ចំណែកព្រះពោធិសត្វអ្នកឲ្យឱវាទដល់តាបសជាបិតាក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាកស្សបមន្ទិយជាតក ចប់**

## ខន្តិវាទិជាតក

[ ៥៥០ ] ( សេនាបតីពោលថា ) បពិត្រលោកមានព្យាយាមធំ ព្រះរាជាណាកាត់ព្រះហស្តទាំង ២ ក្តី កាត់ព្រះបាទទាំង ២ ក្តី កាន់ត្រចៀកនិងច្រមុះក្តី របស់លោក សូមលោកខ្ញាល់ចំពោះបុគ្គលនោះចុះ សូមលោកកុំញុំាងដែននេះឲ្យវិនាសឡើយ ។

[ ៥៥១ ] ( តាបសពោធិសត្វពោលថា ) ព្រះរាជាណា កាត់ដៃទាំង ២ ក្តី កាត់ជើងទាំង ២ ក្តី កាត់ត្រចៀកនិងច្រមុះក្តី របស់អាត្មា សូមឲ្យព្រះរាជានោះទ្រង់មានព្រះជន្មយឺនយូរពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មាមិនខឹងឡើយ ។

[ ៥៥២ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) សមណៈជាអ្នកសម្តែងនូវខន្តីមានហើយក្នុងអតីតកាល ព្រះបាទកាសី ទ្រង់ត្រាស់ឲ្យចោរឃាតកបុរសសម្លាប់សមណៈនោះអ្នកតាំងនៅក្នុងខន្តី ។

[ ៥៥៣ ] ព្រះបាទកាសី តាំងនៅក្នុងនរក សោយនូវផលនៃកម្មណាផលនៃកម្មអាក្រក់នោះ ជាផលក្តៅក្រហាយ ។

**ចប់ ខន្តិវាទិជាតកទី ៣ ។**

## អដ្ឋកថា

## ខន្តិវាទិជាតក

[ ៥៥០-៥៥៣ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុច្រើនដោយសេចក្តីក្រោធមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យ

ផ្ដើមថា **យោ តេ ហត្ថេ ច ចាទេ ច** ដូច្នេះជាដើម ។

រឿងបានពោលទុកហើយខាងដើមនោះឯង ក្នុងទីនេះ ព្រះសាស្ដាត្រាស់នឹងភិក្ខុនោះថា អ្នកបួសក្នុងសាសនារបស់ព្រះពុទ្ធដែលជាអ្នកមិនក្រោធព្រោះហេតុអ្វីទើបធ្វើសេចក្ដីក្រោធ បុរាណកបណ្ឌិតទាំងឡាយ កាលគ្រឿងប្រហារមួយពាន់ធ្លាក់លើរាងកាយ កាលត្រូវគេកាត់ដៃ ជើង ត្រចៀក និងច្រមុះ ក៏មិនធ្វើសេចក្ដីក្រោធដល់អ្នកដទៃ ហើយទ្រង់នាំយកអតីតនិទាន មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមថា កលាបុ ទ្រង់គ្រងរាជសម្បត្តិក្នុងនគរពារាណសី ។ កាលនោះព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិ ៨០ កោដិ ជាមាណពឈ្មោះថា កុណ្ឌលកុមារ ចម្រើនវ័យហើយបានរៀនសិប្បៈគ្រប់យ៉ាង ក្នុងនគរតក្កសិលា ហើយប្រមូលទ្រព្យសម្បត្តិតម្កល់ខ្លួនបាន កាលមាតាបិតាអនិច្ចកម្មទៅ សម្លឹងមើលគំនរទ្រព្យហើយគិតថា ញាតិទាំងឡាយរបស់អញធ្វើទ្រព្យឲ្យកើតឡើងហើយ ហេតុអ្វីមិនកាន់យកទៅ អញគួរកាន់យកទ្រព្យនោះទៅ ទើបចាត់ចែងទ្រព្យទាំងអស់ឲ្យទានដល់បុគ្គលដែលគួរឲ្យ ដោយអំណាចនៃការឲ្យទាន ចូលទៅកាន់ព្រៃហិមពាន្តបួស ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយផលាផល រស់នៅអស់កាលយូរដើម្បីត្រូវការសេជូរប្រៃទើបមកកាន់ដែនដីមនុស្ស ដល់នគរពារាណសីដោយលំដាប់ ហើយសម្រាកនៅក្នុងព្រះរាជឧទ្យាន ។ ស្អែកឡើង ព្រះពោធិសត្វត្រាច់ភិក្ខាចារទៅក្នុងនគរដល់ទ្វារនិវេសន៍របស់សេនាបតី ។ សេនាបតីជ្រះ

ថ្វាក្នុងឥរិយាបថរបស់ព្រះពោធិសត្វនោះ ទើបនិមន្តឲ្យចូលកាន់ផ្ទះដោយលំដាប់ ឲ្យឆាន់ភោជនដែលគេរៀបចំដើម្បីខ្លួន ឲ្យទទួលបដិញ្ញាហើយ ឲ្យនៅក្នុងព្រះរាជឧទ្យាននោះឯង ។ ថ្ងៃមួយព្រះបាទកលាបុ ទ្រង់ស្រវឹងទឹកច័ណ្ឌ មានស្រីស្នំដែលឈ្លាសចោមរោម យាងទៅកាន់ព្រះរាជឧទ្យានដោយព្រះឥស្សរិយយសដ៏ធំ បានក្រាលព្រះបន្ទំលើផ្ទាំងថ្ម ដែលជាមង្គល ហើយផ្ទំលើភ្លៅរបស់ស្រីស្នំដែលទ្រង់ប្រោសប្រាណម្នាក់ អ្នករបាំទាំងឡាយ ជាអ្នកប៉ិនប្រសប់ក្នុងការច្រៀង ការប្រគំ និងការរាំ ក៏ប្រកបការច្រៀងជាដើម ។ ព្រះបាទកលាបុ មានសម្បត្តិដូចសក្កទេវរាជ ទ្រង់ផ្ទំលក់ទៅ ។ លំដាប់នោះ ស្រីទាំងនោះនាំគ្នាពោលថា ពួកយើងប្រកបការច្រៀង ការរាំជាដើម ដើម្បីប្រយោជន៍ដល់ព្រះរាជាអង្គណា ព្រះរាជាអង្គនោះទ្រង់ផ្ទំលក់ទៅហើយ នឹងមានប្រយោជន៍អ្វីដល់ពួកយើងដោយការច្រៀងជាដើម ទើបដាក់គ្រឿងតូរ្យតន្ត្រី មានពិណជាដើមទុកក្នុងទីនោះៗឯង ចៀសចេញទៅកាន់ព្រះរាជឧទ្យាន ត្រូវផ្កា ផ្លែឈើ និងស្លឹកឈើជាដើមលួងលោមចិត្ត ទើបត្រេកអរក្នុងព្រះរាជឧទ្យាន ។ ក្នុងកាលនោះ ព្រះពោធិសត្វអង្គុយដូចដំរីចុះប្រេងដ៏ប្រសើរ ញុំាងកាលឲ្យកន្លងទៅដោយសេចក្តីសុខក្នុងបព្វជ្ជាត្រង់គល់សាលព្រឹក្ស មានផ្ការីកស្គុសស្គាយក្នុងព្រះរាជឧទ្យាននោះ ។ លំដាប់នោះ ស្រីទាំងនោះ កាលចៀស ( អំពីព្រះរាជា ) ទៅកាន់ព្រះរាជឧទ្យានហើយត្រាច់ទៅ បានឃើញព្រះពោធិសត្វទើបពោលថា មកអ្នកទាំងឡាយ លោកម្ចាស់របស់ពួកយើងជាបព្វជិត អង្គុយត្រង់គល់ឈើមួយដើម ពួកយើងនឹងអង្គុយស្តាប់ពាក្យណាមួយ ក្នុងសម្នាក់

របស់លោកម្ចាស់នោះ ទម្រាំព្រះរាជាភ្ញាក់ពីផ្ទំ ទើបបានទៅថ្វាយបង្គំចោម រោមហើយពោលថា សូមលោកម្ចាស់ពោលនូវពាក្យណាមួយដែលគួរពោល ដល់ពួកខ្ញុំចុះ ព្រះពោធិសត្វ ក៏ពោលធម៌ដល់ស្រីទាំងនោះ ។ កាលនោះ ស្រីនោះអង្រួនភ្លៅឲ្យព្រះរាជាភ្ញាក់ ព្រះរាជាទ្រង់តើនហើយមិនឃើញស្រីទាំង នោះ ទើបត្រាស់ថា ពួកស្រីថោកទាបទាំងនោះទៅណា ស្រីដែលជាទីប្រោស ប្រាណនោះក្រាបទូលថា បពិត្រមហារាជ ស្រីទាំងនោះ ទៅចោមរោមតា- បសមួយរូប ។ ព្រះរាជាទ្រង់ពិរោធ កាន់ព្រះខ័នប្រញាប់យាងទៅ ដោយ តាំងព្រះហឫទ័យថា អញនឹងឲ្យជដិលកោងនោះសិក្សា ។ លំដាប់នោះ ស្រី ទាំងនោះឃើញព្រះរាជាទ្រង់ពិរោធ កំពុងយាងមក ក្នុងបណ្តាស្រីទាំងនោះ ស្រីដែលជាទីប្រោសប្រាណ ( ម្នាក់ ) ដណ្តើមយកដាវអំពីព្រះហស្តរបស់ ព្រះរាជា ឲ្យព្រះរាជាស្ងប់រម្ងាប់ ។ ព្រះរាជានោះ ចូលទៅប្រថាប់ឈរក្នុង សម្នាក់ព្រះពោធិសត្វ ហើយត្រាស់សួរថា សមណ: ឯងមានវាទ:ដូចម្តេច ព្រះពោធិសត្វទូលថា មហាបពិត្រ អាត្មាមានខន្តិជាវាទ: គឺពោលសរសើរ ខន្តី ព្រះរាជាត្រាស់ថា ដែលហៅថាខន្តីនោះគឺអ្វី ព្រះពោធិសត្វទូលថា គឺ ការមិនក្រោធក្នុងកាលដែលគេជេរ ប្រហារ និងចំអកឡកឡឺយ ។ ព្រះរាជា ត្រាស់ថា ឥឡូវនេះ យើងនឹងឃើញការមានខន្តីរបស់ឯង ត្រាស់ឲ្យហៅ ពេជ្ឈឃាដអ្នកសម្លាប់ចោរមក ។ ពេជ្ឈឃាដនោះកាន់ពូថៅ ខ្សែតីតាមចារិត របស់ខ្លួន ស្លៀកសំពត់កាសាវ: ពាក់កម្រងផ្កាក្រហមមកថ្វាយបង្គំព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំនឹងធ្វើអ្វី ព្រះរាជាត្រាស់ថា ចូរ

ចាប់តាបសអាក្រក់ដូចចោរនេះ ទាញឲ្យដួលចុះលើផែនដី ហើយយកខ្សែតី វាយពីរពាន់រំពាត់ក្នុងទីទាំង ៤ គឺខាងមុខខាងក្រោយ និងត្រង់ចំហៀងទាំងសងខាង ពេជ្ឈឃាដនោះ បានធ្វើតាមព្រះរាជតម្រាស់ ។ សម្បុរថ្ងៃនិងស្បែករបស់ព្រះពោធិសត្វបែកខ្ទេចខ្ទី សាច់ក៏ដាច់ ឈាមក៏ហូរ ។ ព្រះរាជាត្រាស់សួរថា ឯងមានវាទៈដូចម្ដេច ព្រះពោធិសត្វទូលថា មហាបពិត្រ អាត្មាមានវាទៈសរសើរខន្តី ទ្រង់សម្គាល់ថាខន្តីមានក្នុងរវាងស្បែករបស់អាត្មាឬ ខន្តីមិនមានក្នុងរវាងស្បែករបស់អាត្មាឡើយ មហាបពិត្រ ខន្តីរបស់អាត្មា តាំងនៅចំពោះខាងក្នុងហទយៈដែលទ្រង់មិនអាចឃើញ ។ ពេជ្ឈឃាដទូលសួរទៀតថា បពិត្រព្រះអង្គ ទូលបង្គំនឹងធ្វើអ្វីទៀត ព្រះរាជាត្រាស់ថា ចូរកាត់ដៃទាំងពីររបស់តាបសកោងនេះ ។ ពេជ្ឈឃាដនោះ ឆារពូថៅកាប់ដៃទាំងពីរត្រឹមកដៃ ។ ពេលនោះព្រះរាជាត្រាស់នឹងពេជ្ឈឃាដនោះថា ចូរកាត់ជើងទាំងពីរ ពេជ្ឈឃាដក៏កាប់ជើងទាំងពីរ ។ ឈាមហូរចេញអំពីចុងដៃនិងចុងជើង ដូចទឹកល័ក្តដែលហូរចេញអំពីឆ្នាំងធ្លុះដូច្នោះ ។ ព្រះរាជាត្រាស់សួរទៀតថា ឯងមានវាទៈដូចម្ដេច ព្រះពោធិសត្វទូលថា មហាបពិត្រ អាត្មាមានវាទៈសរសើរខន្តី ទ្រង់សម្គាល់ថាខន្តីនៅត្រង់ចុងដៃចុងជើងរបស់អាត្មាឬ ខន្តីនោះមិនមាននៅក្នុងទីនេះ ព្រោះខន្តីរបស់អាត្មា តាំងនៅក្នុងហទយៈដ៏ជ្រៅ ។ ព្រះរាជាត្រាស់ថា ចូរកាត់ត្រចៀក និងច្រមុះតាបសនេះ ។ ពេជ្ឈឃាដក៏កាត់ត្រចៀក និងច្រមុះ ។ សកលកាយទាំងមូល ពោរពេញដោយឈាម ។ ព្រះរាជាត្រាស់សួរទៀតថា ឯងមានវាទៈដូចម្ដេច ព្រះពោធិសត្វទូលថា មហា

បពិត្រ អាត្មាមានវាទៈសរសើរនូវខន្តី ទ្រង់សម្គាល់ថាខន្តីតាំងនៅត្រង់ចុង ត្រចៀកចុងច្រមុះឬ ខន្តីរបស់អាត្មាតាំងនៅក្នុងហទយៈដ៏ជ្រៅ ។ ព្រះរាជា ត្រាស់ថា ជដិលកោង ចូរឯងអង្គុយសរសើរខន្តីរបស់ឯងចុះ ហើយយកជើង ជាក់ត្រង់ទ្រូងរបស់ព្រះពោធិសត្វចៀសចេញទៅ ។ កាលព្រះរាជានោះយាង ទៅហើយ សេនាបតីជូតឈាមអំពីរាងកាយរបស់ព្រះពោធិសត្វ ប្រមូលចុង ដៃចុងជើង ត្រចៀកនិងច្រមុះទុកក្នុងសំពត់សាដក គ្រាប់ឲ្យព្រះពោធិសត្វ អង្គុយហើយថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ក្រោធ គួរក្រោធព្រះរាជាដែលធ្វើខុស ក្នុងលោកម្ចាស់ មិនគួរ ក្រោធអ្នកដទៃឡើយ កាលអង្វរ ទើបពោលគាថាទី ១ ថា

> បពិត្រលោកមានព្យាយាមធំ ព្រះរាជាណាកាត់ព្រះហស្តទាំង
> ២ ក្តី កាត់ព្រះបាទទាំង ២ ក្តី កាត់ត្រចៀកនិងច្រមុះក្តី របស់
> លោក សូមលោកខ្ញាល់ចំពោះបុគ្គលនោះចុះ សូមលោកកុំ
> ញុំាំងដែននេះឲ្យវិនាសឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មហាវីរ** បានដល់ អ្នកមានសេចក្តីព្យាយាម ធំ ។ បទថា **មា រដ្ឋំ វិនស្ស ឥទំ** សេចក្តីថា លោកកុំធ្វើកាសិករដ្ឋដែលមិន មានកំហុសនេះឲ្យវិនាសឡើយ ។ ព្រះពោធិសត្វស្តាប់ដូច្នោះ ក៏ពោលគាថា ទី ២ ថា

> ព្រះរាជាណា កាត់ដៃទាំង ២ ក្តី កាត់ជើងទាំង ២ ក្តី កាត់
> ត្រចៀកនិងច្រមុះក្តីរបស់អាត្មា សូមឲ្យព្រះរាជានោះទ្រង់មាន

ព្រះជន្មយឺនយូរ ពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មា មិនខឹងឡើយ

ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាទិសា** សេចក្តីថា បណ្ឌិតទាំងឡាយដែលប្រកបដោយកម្លាំងនៃខន្តីដូចអាត្មា រមែងមិនក្រោធថា បុគ្គលនេះជេរបរិភាសប្រហារអញ កាត់អវយវៈទម្លាយនូវអញ ។

ក្នុងកាលព្រះរាជាយាងចេញអំពីព្រះរាជឧទ្យាន ផុតគន្លងចក្ខុ របស់ព្រះពោធិសត្វប៉ុណ្ណោះ មហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ក៏ញែកចេញពីគ្នា ដូចសំពត់សាដកដែលធំផង រឹងផងញែកចេញដូច្នោះ ។ អណ្តាតភ្លើងអំពីអវីចិមហានរក លៀនចេញមកទទួលព្រះរាជា ដូចដណ្តប់ដោយសំពត់កម្ពលក្រហម ដែលត្រកូលប្រគល់ឲ្យ ព្រះរាជាចូលកាន់ផែនដីត្រង់ទ្វារព្រះរាជឧទ្យាននោះឯង ហើយតាំងនៅក្នុងអវីចិមហានរក ។ ព្រះពោធិសត្វបានធ្វើកាលកិរិយា ក្នុងថ្ងៃនោះឯង ។ រាជបុរសនិងអ្នកនគរទាំងឡាយកាន់យកគ្រឿងក្រអូប ផ្កាកម្រងនិងផ្សែងក្រអូបមកធ្វើឈាបនកិច្ចសរីរៈរបស់ព្រះពោធិសត្វ ។ ចំណែកកេចិអាចារ្យពោលថា ព្រះពោធិសត្វ ត្រឡប់ទៅកាន់ហិមវន្តប្បទេសនោះឯង ពាក្យរបស់កេចិអាចារ្យទាំងនោះមិនពិត ។ ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយ ទ្រង់ត្រាស់អភិសម្ពុទ្ធគាថា ២ គាថាថា

សមណៈជាអ្នកសម្តែងនូវខន្តី មានហើយ ក្នុងអតីតកាល

ព្រះបាទកាសីទ្រង់ត្រាស់ឲ្យចោរឃាតកបុរស សម្លាប់សមណៈ

នោះ អ្នកតាំងនៅក្នុងខន្តី ។

ព្រះបាទកាសី តាំងនៅក្នុងនរក សោយនូវផលនៃកម្មណា
ផលនៃកម្មអាក្រក់នោះ ជាផលក្តៅក្រហាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អតីតមទ្ធានំ** បានដល់ ក្នុងអតីតកាលដ៏យូរលង់ ។ បទថា **ខន្តិទីបនោ** បានដល់ ដែលពណ៌នានូវអធិវាសនខន្តី ។ បទថា **អច្ឆេទយិ** បានដល់ ត្រាស់ឲ្យសម្លាប់ ។ តែព្រះថេរៈពួកខ្លះពោលថា ដៃជើងរបស់ព្រះពោធិសត្វតជាប់គ្នាវិញ ពាក្យនោះមិនពិតដូចគ្នា ។ បទថា **សមប្បិតោ** បានដល់ តាំងនៅចំពោះហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអ្នកខឹងក្រោធ សម្រេចអនាគាមិផល ហើយទ្រង់ប្រជុំជាតកថា ព្រះបាទកាសីព្រះនាមថាកលាបុក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ សេនាបតីក្នុងកាលនោះបានមកជាសារីបុត្ត ចំណែកតាបសដែលសរសើរខន្តីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាខន្តិវាទីជាតក ចប់

# លោហកុម្ភិជាតក

[ ៥៥៤ ] ( សត្វនរកម្នាក់ពោលថា ) ពួកយើងដែលមិនបានឲ្យទាន បានជាពួកយើងរស់នៅដោយត្រដាបត្រដួស កាលភោគៈទាំងឡាយមាន ពួកយើងមិនបានធ្វើនូវទីពឹងបម្រុងខ្លួនសោះ ។

[ ៥៥៥ ] ( សត្វនរកម្នាក់ទៀតពោលថា ) ពួកយើងដែលឆេះក្នុងនរកគ្រប់ជា ៦ ម៉ឺនឆ្នាំដោយអាការទាំងពួងហើយ កាលណានឹងមានទីបំផុត ( នៃទុក្ខ ) ។

[ ៥៥៦ ] ( សត្វនរកម្នាក់ទៀតពោលថា ) ម្នាលអ្នកស្មើនឹងខ្ញុំ ទីបំផុត ( នៃទុក្ខយើង ) មិនមានទេ ទីបំផុតនឹងមានមកពីណា ទីបំផុតនឹងមិនប្រាកដទេ ព្រោះថា ខ្ញុំនិងអ្នកបានធ្វើបាបក្នុងកាលនោះ ។

[ ៥៥៧ ] ( សត្វនរកម្នាក់ទៀតពោលថា ) ខ្ញុំនោះ លុះទៅអំពីទីនេះបានកំណើតជាមនុស្ស ចាប់អំពីដឹងក្តីទៅ សូមជាអ្នកបរិបូណ៌ដោយសីលធ្វើកុសលឲ្យច្រើន ។

**ចប់ លោហកុម្ភិជាតកទី ៤ ។**

# អដ្ឋកថា

# លោហកុម្ភិជាតក

[ ៥៥៤-៥៥៧ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទកោសល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ទុជ្ជីវិតមជីវិម្ហ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ព្រះបាទកោសលទ្រង់ស្ដាប់សំឡេងរបស់សត្វនរក ៤ នាក់ក្នុងកណ្ដាលរាត្រី គឺសត្វនរកម្នាក់ពោលចំពោះ **ទុ** អក្ខរៈប៉ុណ្ណោះ ម្នាក់ពោលថា **ស** អក្ខរៈ ម្នាក់ពោល **ន** អក្ខរៈ ម្នាក់ពោល **សោ** អក្ខរៈ ។

បានឮថា ក្នុងអតីតកព សត្វនរកទាំងនោះ បានជាព្រះរាជឱរស ធ្វើបរទារកកម្មក្នុងនគរសាវត្ថីនេះឯង ។ ព្រះរាជឱរសទាំងនោះ ខុសក្នុងមាតុគ្រាមទាំងឡាយដែលអ្នកដទៃរក្សាគ្រប់គ្រង ជាអ្នកភ្លើតភ្លើន ធ្វើនូវបាបកម្មច្រើន ត្រូវកងចក្ក គឺសេចក្ដីស្លាប់កាត់ជីវិតហើយ កើតក្នុងលោហកុម្ភី ៤ រណ្ដៅ ក្នុងទីជិតនគរសាវត្ថី ឆេះក្នុងលោហកុម្ភីនោះ ៦ ម៉ឺនឆ្នាំ ផុសឡើងមក ឃើញកណ្ដាប់មាត់លោហកុម្ភី ទាំង ៤ នាក់ នាំគ្នាស្រែកតាមលំដាប់ ដោយសំឡេងខ្លាំងៗថា កាលណាហ្ន៎ ពួកយើងនឹងផុតទុក្ខនេះ ។ ព្រះរាជាទ្រង់ស្ដាប់សំឡេងសត្វនរកទាំងនោះ ទ្រង់ខ្លាចចំពោះមរណភ័យ ប្រថាប់គង់នោះឯងរហូតដល់អរុណរះ ។ លុះអរុណរះហើយ ព្រាហ្មណ៍ទាំងឡាយមកគាល់ ទូលសួរព្រះរាជាដល់សេចក្ដីសុខក្នុងការដេកលក់ ព្រះរាជាត្រាស់ថា អាចារ្យទាំងឡាយ យើងដេកជាសុខមកអំពីណា ថ្ងៃនេះ យើងបានឮសំឡេងគួរស្ញៀវខ្លាច ៤ មាត់បែបនេះ ព្រាហ្មណ៍ទាំងឡាយនាំគ្នារលាស់ដៃ ។ ព្រះរាជាត្រាស់

សួរថា លោកអាចារ្យ មានហេតុអ្វីឬ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ សំឡេងគ្រោតគ្រាតពន់ពេក ព្រះរាជាត្រាស់ថា កែខៃបានដែរឬទេ ពួកព្រាហ្មណ៍ក្រាបទូលថា បើកែខៃមិនបាន ពួកទូលបង្គំឈ្មោះថា មិនសិក្សាមកល្អឡើយ ។ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយនឹងធ្វើអ្វីទើបរារាំងបាន ពួកព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំមិនអាចធ្វើពិធីកម្មហាមឃាត់ទាំងស្រុងបានទេ តែពួកទូលបង្គំនឹងបូជាយញ្ញប្រកបដោយវត្ថុគ្រប់យ៉ាងមួយមុខ ៤ ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះ អ្នកទាំងឡាយចូរប្រញាប់ចាប់សត្វដែលមានជីវិត មួយមុខ ៤ តាំងអំពីសត្វប្រចៀចឡើងទៅ គឺដំរី ៤ សេះ ៤ គោឈ្មោល ៤ មនុស្ស ៤ ហើយបូជាយញ្ញប្រកបដោយវត្ថុទាំងពួងមួយមុខ ៤ ធ្វើសួស្តីដល់យើងចុះ ។ ព្រាហ្មណ៍ទាំងឡាយ ទទួលព្រះតម្រាស់ថា សាធុមហារាជ ។ ហើយកាន់យករបស់ដែលត្រូវការ ទៅជីករណ្តៅយញ្ញ នាំសត្វជាច្រើនទៅចងទុកត្រង់បង្គោល ដល់នូវឧស្សាហៈ ថាពួកយើងនឹងស៊ីសាច់ ស៊ីត្រីជាច្រើន នឹងបានទ្រព្យច្រើន ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព បានវត្ថុនេះគួរ បានវត្ថុនេះគួរ ត្រាច់ខ្វាត់ខ្វែងទៅមក ។ ព្រះនាងមល្លិកាទេវី ចូលទៅគាល់ព្រះរាជា ហើយក្រាបទូលសួរថា បពិត្រមហារាជ ហេតុអ្វីហ្ន៎ ទើបពួកព្រាហ្មណ៍ត្រេកអរពន់ពេក ត្រាច់ទៅ ។ ព្រះរាជាត្រាស់ថា នែទេវី ប្រយោជន៍អ្វីដោយរឿងនេះដល់នាង នាងប្រមាទស្រវឹងដោយយសរបស់ខ្លួន ចំណែកសេចក្តីទុក្ខធ្លាក់ដល់យើងប៉ុណ្ណោះ ។ ព្រះនាងមល្លិកាទូលសួរថា បពិត្រមហារាជ តើមានរឿងអ្វី ។ ព្រះរាជាត្រាស់ថា

នៃទេវី យើងបានឮសំឡេងដែលមិនធ្លាប់បានឮបែបនេះ បន្ទាប់អំពីនោះទើប សួរព្រាហ្មណ៍ទាំងឡាយថា ព្រោះបានឮសំឡេងទាំងនេះ ហេតុកេទអ្វីនឹងកើត មាន ពួកព្រាហ្មណ៍នាំគ្នាពោលថា បពិត្រមហារាជ អន្តរាយនៃរាជសម្បត្តិ នៃភោគទ្រព្យ ឬនៃជីវិតនឹងប្រាកដដល់ទ្រង់ ពួកទូលបង្គំនឹងបូជាយញ្ញដោយ វត្ថុទាំងពួងមួយមុខ ៤ ហើយនឹងធ្វើសួស្តីឲ្យ ព្រាហ្មណ៍ទាំងនោះ ទទួល បញ្ជារបស់យើងហើយ ធ្វើរណ្តៅយញ្ញហើយនាំគ្នាមក ព្រោះហេតុនៃរបស់ ដែលត្រូវការនោះ ។ ព្រះនាងមល្លិកាក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ទូលសួរព្រាហ្មណ៍ដែលជាកំពូលនៃលោកព្រមទាំងទេវលោក ដល់ការ សម្រេចផលនៃសំឡេងនោះហើយឬ ព្រះរាជាត្រាស់ថា នៃទេវី អគ្គព្រាហ្មណ៍ ក្នុងលោកនិងទេវលោកនុ៎ះជាអ្នកណា ព្រះនាងមល្លិកាក្រាបទូលថា ព្រះគោតម សម្មាសម្ពុទ្ធ ។ ព្រះរាជាត្រាស់ថា នៃទេវី យើងមិនទាន់បានទូលសួរព្រះមាន ព្រះភាគឡើយ ។ ព្រះនាងមល្លិកាក្រាបទូលថា បើយ៉ាងនោះសូមទ្រង់យាង ទៅទូលសួរព្រះអង្គចុះ ។ ព្រះរាជា ជឿពាក្យរបស់ព្រះនាងមល្លិកានោះ សោយ ព្រះក្រយាហារព្រឹកហើយ ទ្រង់ឡើងរថដ៏ប្រសើរ យាងទៅកាន់ជេតពនមហា វិហារ ថ្វាយបង្គំព្រះសាស្តា ហើយទូលសួរថា បពិត្រព្រះអង្គ ក្នុងកណ្តាល យប់ ខ្ញុំព្រះអង្គបានឮសំឡេង ៤ សួរពួកព្រាហ្មណ៍ហើយ ពួកព្រាហ្មណ៍ ប្រាប់ថា នឹងបូជាយញ្ញដោយរបស់ទាំងពួងមួយមុខ ៤ ហើយនឹងធ្វើសួស្តីឲ្យ ហើយធ្វើកម្មក្នុងរណ្តៅយញ្ញ ព្រោះបានឮសំឡេងទាំងនោះ ហេតុណាមួយ កើតមានដល់ខ្ញុំព្រះអង្គដែរឬទេ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ហេតុ

ណាមួយមិនមានដល់ទ្រង់ឡើយ សត្វនរកទាំងឡាយសោយទុក្ខ ទើបស្រែក យ៉ាងនេះ សំឡេងទាំងនេះទ្រង់បានស្តាប់យ៉ាងនេះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន ព្រះរាជាក្នុងកាលមុន ក៏បានស្តាប់មកហើយដូចគ្នា ទ្រង់មានព្រះបំណងនឹងធ្វើយញ្ញដោយការសម្លាប់បសុសត្វ ព្រោះត្រាស់សួរពួកព្រាហ្មណ៍ តែទ្រង់មិនធ្វើព្រោះបានស្តាប់ពាក្យរបស់បណ្ឌិតទាំងឡាយ បណ្ឌិតទាំងឡាយ ពោលពាក្យដែលជាមូលនៃសំឡេងទាំងនោះ បានឲ្យដោះលែងមហាជន ធ្វើនូវសួស្តីឲ្យហើយ កាលព្រះរាជានោះទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍នាកាសិកគាមមួយកន្លែង ចម្រើនវ័យ ហើយឃើញទោសក្នុងកាមទាំងឡាយ ក៏លះកាមទាំងឡាយបួសជាឥសី ធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ជាអ្នកលេងឈានក្នុងដងព្រៃ ដែលគួរជាទីត្រេកអរក្នុងហិមវន្តប្បទេស ។ ក្នុងកាលនោះ ព្រះបាទពារាណសី បានស្តាប់សំឡេង ៤ ប្រការនេះរបស់សត្វនរក ៤ នាក់ ទ្រង់តក់ស្លុតក្នុងព្រះហឫទ័យ កាលព្រាហ្មណ៍ទាំងឡាយក្រាបទូលដោយទំនងនេះឯងថា អន្តរាយ ៣ យ៉ាង ឯណានីមួយនឹងកើតឡើង ទូលបង្គំទាំងឡាយ នឹងធ្វើអន្តរាយនោះ ឲ្យស្ងប់ដោយយញ្ញប្រកបដោយវត្ថុទាំងពួងមួយមុខ ៤ ទើបទ្រង់យល់ព្រម ។ បុរោហិតមួយអន្លើដោយពួកព្រាហ្មណ៍ ឲ្យជីករណ្តៅសម្រាប់បូជាយញ្ញ ។ មហាជនត្រូវនាំចូលទៅកាន់បង្គោល ។ ក្នុងកាលនោះ ព្រះពោធិសត្វធ្វើមេត្តាភាវនា

ឲ្យជាបុរេចារិក ពិនិត្យមើលលោកដោយទិព្វចក្ខុ បានឃើញហេតុនោះហើយ គិតថា ថ្ងៃនេះ អញគួរនឹងទៅធ្វើសួស្តីឲ្យដល់មហាជន ទើបហោះទៅកាន់អាកាស ដោយកម្លាំងឫទ្ធិ ចុះត្រង់ព្រះរាជឧទ្យាន របស់ព្រះបាទពារាណសី អង្គុយត្រង់ផ្ទាំងថ្មដូចបដិមាមាស ។ ក្នុងកាលនោះ សិស្សច្បងរបស់បុរោហិត ចូលទៅរកអាចារ្យហើយពោលថា លោកអាចារ្យ ក្នុងវេទរបស់ពួកយើង ឈ្មោះថាការសម្លាប់អ្នកដទៃហើយធ្វើនូវសួស្តីរមែងមិនមាន មិនមែនឬ ។ បុរោហិតឃាត់អន្តេវាសិកនោះថា ចូរឯងពេញចិត្តក្នុងរាជទ្រព្យ យើងនឹងបានស៊ីមច្ឆមំសាហារដ៏ច្រើននិងបានទ្រព្យ ចូរឯងនៅស្ងៀមចុះ ។ អន្តេវាសិកនោះគិតថា អញមិនជាសម្លាញ់ក្នុងរឿងនេះឡើយ ទើបចេញទៅកាន់ព្រះរាជឧទ្យាន ឃើញព្រះពោធិសត្វហើយ ទើបថ្វាយបង្គំ ធ្វើបដិសណ្ឋារៈហើយ អង្គុយក្នុងចំណែកម្ខាង ។ ព្រះពោធិសត្វសួរថា នែមាណព ព្រះរាជាគ្រងរាជសម្បត្តិដោយធម៌ដែរឬ អន្តេវាសិកនោះពោលថា បពិត្រលោកម្ចាស់ ព្រះរាជាទ្រង់គ្រងរាជសម្បត្តិដោយធម៌ តែក្នុងកណ្តាលយប់ទ្រង់បានស្តាប់សំឡេង ៤ ប្រការ ទើបត្រាស់សួរព្រាហ្មណ៍ទាំងឡាយ ពួកព្រាហ្មណ៍ក្រាបទូលថា ពួកទូលបង្គំនឹងបូជាយញ្ញដោយវត្ថុទាំងពួងមួយមុខ ៤ ហើយនឹងធ្វើសួស្តីឲ្យព្រះរាជា ទ្រង់បំណងធ្វើកម្ម គឺសម្លាប់បសុសត្វ ហើយធ្វើនូវសួស្តីដល់ខ្លួន មហាជនត្រូវនាំចូលទៅចងទុកត្រង់បង្គោល បពិត្រលោកម្ចាស់ អ្នកមានសីលដូចលោកម្ចាស់នឹងប្រាប់សេចក្តីសម្រេចផលនៃសំឡេងនោះ ហើយដោះលែងមហាជនអំពីមាត់មច្ចុរាជមិនគួរឬហ្ន៎ ។ ព្រះពោធិសត្វពោលថា មាណព ព្រះ

រាជាទ្រង់មិនស្គាល់អាត្មា សូម្បីអាត្មាក៏មិនស្គាល់ព្រះរាជាអង្គនោះ តែអាត្មាដឹងសេចក្តីសម្រេចផល នៃសំឡេងទាំងនេះ បើព្រះរាជាយាងមករកអាត្មាហើយសួរ អាត្មានឹងទូលថ្វាយព្រះរាជាឲ្យអស់សង្ស័យ ។ អន្តេវាសិកនោះពោលថា បពិត្រលោកម្ចាស់ បើយ៉ាងនោះ សូមលោកម្ចាស់នៅទីនេះ មួយអន្ទាំស្ងា ខ្ញុំនឹងនាំព្រះរាជាមក ព្រះពោធិសត្វពោលថា សាធុ មាណព ។ អន្តេវាសិកនោះ ទៅក្រាបទូលរឿងនោះដល់ព្រះរាជា ហើយនាំព្រះរាជាយាងមក ។ ព្រះរាជាទ្រង់ថ្វាយបង្គំព្រះពោធិសត្វហើយ គង់ក្នុងចំណែកម្ខាង ត្រាស់សួរថា បានឮថា លោកម្ចាស់ដឹងការសម្រេចផលនៃសំឡេងដែលខ្ញុំបានស្តាប់មកពិតឬ ព្រះពោធិសត្វក្រាបទូលថា ថ្វាយព្រះពរមហាបពិត្រ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់ ព្រះពោធិសត្វក្រាបទូលថា មហាបពិត្រ ក្នុងកាលមុនសត្វនរកទាំងនេះ ដល់នូវការប្រព្រឹត្តក្នុងទារៈទាំងឡាយដែលអ្នកដទៃរក្សាគ្រប់គ្រង ទើបកើតក្នុងលោហកុម្ភីទាំង ៤ រណ្តៅក្នុងទីជិតនគរពារាណសី ត្រូវស្ងោរម្ញាស់រហូតកាយក្លាយជាពពុះក្នុងទឹកទង់ដែង ស្រុះទៅខាងក្រោមរហូតដល់បាតអស់កាល ៦ ម៉ឺនឆ្នាំ ផុសឡើងខាងលើបានឃើញមាត់លោហកុម្ភី ដោយកាល ៣ ម៉ឺនឆ្នាំដូចគ្នា បានសម្លឹងទៅខាងក្រៅទាំង ៤ នាក់ បំណងនឹងពោលគាថា ៤ ឲ្យគ្រប់បរិបូណ៌ តែមិនអាចធ្វើយ៉ាងនោះបាន ពោលបានត្រឹមតែអក្ខរមួយប៉ុណ្ណោះ ហើយលិចចុះក្នុងលោហកុម្ភីវិញ ក្នុងសត្វនរក ៤ នាក់នោះ សត្វដែលពោលថា ទុ អក្ខរៈហើយលិចចុះទៅ ជាអ្នកបំណងពោលយ៉ាងនេះថា

ពួកយើងដែលមិនបានឲ្យទាន បានជាពួកយើងរស់នៅដោយត្រជាបត្រជួស កាលភោគៈទាំងឡាយមាន ពួកយើងមិនបានធ្វើនូវទីពឹងបម្រុងខ្លួនសោះ ដូច្នេះ ។

តែមិនអាចពោលគាថានោះឲ្យបរិបូណ៌បាន ហើយព្រះពោធិសត្វបានពោលគាថានោះឲ្យគ្រប់បរិបូណ៌ ដោយញាណរបស់ខ្លួន ។ សូម្បីក្នុងគាថាដ៏សេសក៏មានន័យនេះដូចគ្នា ។

បណ្ដាសត្វទាំងនោះ គាថារបស់សត្វដែលពោលថា **ស** អក្ខរៈ នឹងពោលតទៅ មានដូច្នេះថា

ពួកយើងដែលឆេះក្នុងនរកគ្រប់ជា ៦ ម៉ឺនឆ្នាំ ដោយអាការទាំងពួងហើយកាលណានឹងមានទីបំផុត ( នៃទុក្ខ ) ដូច្នេះ ។

គាថារបស់សត្វដែលពោលតែ **ន** អក្ខរៈ ហើយប្រាថ្នានឹងពោលតទៅមានដូច្នេះថា

ម្នាលអ្នកស្មើនឹងខ្ញុំ ទីបំផុត ( នៃទុក្ខយើង ) មិនមានទេ ទីបំផុតនឹងមានមកពីណា ទីបំផុតនឹងមិនប្រាកដទេ ព្រោះថា ខ្ញុំនិងអ្នកបានធ្វើបាបក្នុងកាលនោះ ដូច្នេះ ។

គាថារបស់សត្វដែលពោលតែ **សោ** អក្ខរៈ ហើយនឹងពោលតទៅ មានដូច្នេះថា

ខ្ញុំនោះ លុះទៅអំពីទីនេះ បានកំណើតជាមនុស្ស ចាប់អំពីដឹងក្ដីទៅ សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឲ្យច្រើន

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុជ្ជីវិតំ** សេចក្ដីថា កាលប្រព្រឹត្តទុច្ចរិត ៣ ឈ្មោះថារមែងរស់នៅអាក្រក់ គឺរស់នៅលាមក ។ សត្វទាំងនោះ ក៏សំដៅយកការរស់នៅអាក្រក់នោះឯង ទើបពោលថា រស់នៅដោយត្រដាបត្រដួស ដូច្នេះ ។ បទថា **យេសន្តោ ន ទទម្ហសេ** សេចក្ដីថា កាលទេយ្យធម៌និងបដិគ្គាហកៈមាននោះឯង យើងទាំងឡាយមិនបានឲ្យទាន ។ បទថា **ទីបំ នាកម្ហ** សេចក្ដីថា មិនធ្វើទីពឹងដល់ខ្លួន ។ បទថា **បរិបុណ្ណានិ** បានដល់ មិនខ្វះមិនលើស ។ បទថា **សព្វសោ** បានដល់ ដោយអាការៈទាំងពួង ។ បទថា **បច្ចមានានំ** បានដល់ កាលយើងទាំងឡាយឆេះនៅក្នុងនរកនេះ ។ បទថា **នត្ថិ អន្តោ** សេចក្ដីថា មិនមានកំណត់កាលយ៉ាងនេះថា យើងទាំងឡាយនឹងផុតក្នុងកាលឈ្មោះនោះ ។ បទថា **កុតោ អន្តោ** សេចក្ដីថា ព្រោះហេតុអ្វីទីបំផុតនឹងប្រាកដ ។ បទថា **ន អន្តោ** សេចក្ដីថា ទីបំផុតនៃទុក្ខ នឹងមិនប្រាកដដល់យើងទាំងឡាយ ដែលជាអ្នកប្រាថ្នានឹងឃើញទីបំផុត ។ បទថា **តទា ហិ បកតំ** សេចក្ដីថា អ្នកនិទ្ទុក្ខទាំងឡាយ ក្នុងកាលនោះ ខ្ញុំនឹងអ្នកបានធ្វើបាបកម្មទុកច្រើននោះឯង គឺធ្វើទុកយ៉ាងឧក្រិដ្ឋក្រៃលែង ។ បាលីថា **តថា ហិ បកតំ** ក្នុងកាលនោះ ខ្ញុំនឹងអ្នក ធ្វើបាបកម្មទុកច្រើន ដូច្នេះក៏មានអធិប្បាយថា ព្រោះហេតុដែលធ្វើបាបកម្មនោះទុក ទើបមិនអាចឃើញទីបំផុតនៃទុក្ខនោះ ។ បទថា **មារិស** បានដល់ បុគ្គលដូចជាពួកយើង ។ ពាក្យថា **មារិស** នេះជាពាក្យហៅដោយសេចក្ដីស្រឡាញ់ ។ សព្ទថា **ន្ហ** ជានិបាត

ចុះក្នុងអត្ថថា ពិតប្រាកដ ។ ក្នុងសេចក្តីនេះមានពាក្យអធិប្បាយដូច្នេះថា ខ្ញុំ ទុំះទៅអំពីនេះហើយ បាននូវកំណើតមនុស្សនឹងជាអ្នកដឹងនូវពាក្យស្មូមសម្បូរ ដោយសីលនឹងធ្វើកុសលឲ្យច្រើនដោយចំណែកមួយពិត ។

ព្រះពោធិសត្វ កាលពោលគាថានីមួយៗដោយប្រការដូច្នេះហើយ ឲ្យព្រះរាជាទ្រង់ជ្រាបច្បាស់ថា មហាបពិត្រ សត្វនរកនោះបំណងនឹងពោលគាថានេះឲ្យគ្រប់បរិបូណ៌ តែមិនអាចធ្វើយ៉ាងនោះបាន ព្រោះភាពដែលបាបរបស់ខ្លួនធ្ងន់ពេក ដូច្នោះសត្វនរកនោះ កាលបានសោយវិបាកនៃកម្មរបស់ខ្លួន ទើបស្រែក ឈ្មោះថាអន្តរាយ ព្រោះហេតុបច្ច័យដែលស្តាប់សំឡេងនេះរមែងមិនមាន សូមទ្រង់កុំខ្លាចឡើយ ។ ព្រះរាជាត្រាស់ឲ្យលែងមហាជន ហើយឲ្យត្រាច់វាយស្គរស្មុវណ្ណភេរី ប្រកាសឲ្យទម្លាយរណ្តៅយញ្ញ ។ ព្រះពោធិសត្វធ្វើនូវសួស្តីដល់មហាជនហើយ ស្នាក់នៅ ២-៣ ថ្ងៃ ទើបទៅកាន់ហិមវន្តប្បទេសនោះឯង ជាអ្នកមានឈានមិនសាបសូន្យ ទើបកើតក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា មាណពរបស់បុរោហិតក្នុងកាលនោះ បានមកជាសារីបុត្តក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា លោហកុម្ភិជាតក ចប់

# មំសជាតក

[ ៥៥៨ ] ( ព្រះនរិន្ទទ្រង់ត្រាស់ផ្សេងៗ ) ( ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្តទី ១ ថា ) វាចារបស់អ្នកអាក្រក់ណាស់ អ្នកជាអ្នកសុំសាច់ តែវាចាប្រហែលនឹងវាវ នៃសំឡាញ់ យើងនឹងឲ្យវាវដល់អ្នក ។

[ ៥៥៩ ] ( ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្តទី ២ ថា ) ជនជាបងប្អូន គេទុកជាអវយវៈរបស់មនុស្សទាំងឡាយក្នុងលោក វាចារបស់អ្នក ប្រហែលនឹងអវយវៈ នៃសំឡាញ់ យើងនឹងឲ្យសាច់អវយវៈដល់អ្នក ។

[ ៥៦០ ] ( ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្តទី ៣ ថា ) កូនកាលហៅបិតាថា ឪពុក ឪពុក ដូច្នេះ រមែងធ្វើបេះដូងបិតាឲ្យកម្រើក វាចារបស់អ្នក ប្រហែលនឹងបេះដូង នៃសំឡាញ់ យើងនឹងឲ្យបេះដូងដល់អ្នក ។

[ ៥៦១ ] ( ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្តទី ៤ ថា ) សំឡាញ់របស់បុរសណា មិនមានក្នុងស្រុក លំនៅរបស់បុរសនោះក្នុងស្រុកនោះឯង ដូចព្រៃ វាចារបស់អ្នកប្រហែលនឹងសម្បត្តិទាំងពួង នៃសំឡាញ់ យើងនឹងឲ្យសាច់ទាំងអស់ដល់អ្នក ។

**ចប់ មំសជាតកទី ៥ ។**

# អដ្ឋកថា

# មំសជាតក

[ ៥៥៨-៥៦១ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបិណ្ឌបាតមានរសឆ្ងាញ់ដែលព្រះសារីបុត្តត្រេឡាឲ្យដល់ភិក្ខុទាំងឡាយ ដែលផឹកថ្នាំបញ្ចុះ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ផរុសា វត តេ វាចា** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ភិក្ខុពួកខ្លះក្នុងវត្តជេតពន នាំគ្នាផឹកថ្នាំបញ្ចុះដែលផ្សំដោយជ័រ ទើបភិក្ខុទាំងនោះមានសេចក្ដីត្រូវការដោយបិណ្ឌបាតដែលមានរស ។ ភិក្ខុដែលជាគិលានុបដ្ឋាកទាំងឡាយគិតថា នឹងនាំភត្តាហារដែលមានរសមក ទើបចូលទៅកាន់នគរសាវត្ថី ត្រាច់បិណ្ឌបាតតាមវិថីដែលមានផ្ទះសម្បូរដោយបាយ ក៏មិនបានភត្តាហារដែលមានរស ទើបនាំគ្នាត្រឡប់ ។ ព្រះថេរៈចូលទៅបិណ្ឌបាតយឺតយូរជាងភិក្ខុទាំងនោះ ទើបសួរថា អាវុសោទាំងឡាយ ហេតុអ្វីទើបត្រឡប់យឺតយូរ ភិក្ខុទាំងនោះក៏ប្រាប់សេចក្ដីនោះ ។ ព្រះថេរៈពោលថា បើយ៉ាងនោះអ្នកទាំងឡាយចូរមក ហើយនាំភិក្ខុទាំងនោះទៅកាន់វិថីនោះឯង ។ មនុស្សទាំងឡាយបានប្រគេនភត្តាហារ ដែលមានរសពេញបាត្រ ។ ពួកភិក្ខុដែលជាគិលានុបដ្ឋាក នាំមកហើយបានប្រគេនដល់ពួកភិក្ខុឈឺ ភិក្ខុឈឺទាំងនោះបានបរិភោគរសដែលជាទីត្រេកអរ ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថាឧបដ្ឋាករបស់ពួកភិក្ខុដែលផឹកថ្នាំបញ្ចុះ មិនបានភត្តាហារដែលមានរស ទើបត្រឡប់ចេញមក ព្រះថេរៈក៏នាំ ត្រាច់ទៅក្នុងផ្លូវដែលមានផ្ទះសម្បូរដោយ

បាយ បញ្ចូនបិណ្ឌបាតដែលមានរសជាច្រើនមកឲ្យ ។ ព្រះសាស្ដាយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តបានសាច់ដ៏ប្រសើរ ( តែឯង ) ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយអ្នកមានវាចាទន់ភ្លន់ឈ្លាសក្នុងពាក្យសម្ដីជាទីស្រឡាញ់ក៏បានហើយដូចគ្នា ហើយទ្រង់នាំយកអតីតនិទាន មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី ។ ថ្ងៃមួយព្រានម្នាក់បានសាច់មកជាច្រើនដាក់ពេញយានតូច មកកាន់នគរដោយបំណងនឹងលក់ ។ ក្នុងកាលនោះ កូនសេដ្ឋី ៤ នាក់ដែលជាអ្នកក្រុងពារាណសី ចេញអំពីនគរហើយ អង្គុយសន្ទនាគ្នាដល់រឿងដែលបានឃើញបានឮបានស្ដាប់មកឯណានីមួយ ក្នុងទីដែលមានផ្លូវមកប្រសព្វគ្នា សេដ្ឋីបុត្ត ៤ នាក់នោះ សេដ្ឋីបុត្តម្នាក់ឃើញព្រានម្រឹគនោះដឹកសាច់មកទើបពោលថា យើងនឹងឲ្យព្រាននោះនាំជុំសាច់មក សេដ្ឋីបុត្តទាំងនោះពោលថា ចូរឯងទៅនាំមកចុះ ។ សេដ្ឋីបុត្តនោះចូលទៅរកព្រានម្រឹគហើយពោលថា វ៉ៃយ ព្រាន ចូរឲ្យដុំសាច់ដល់អញ ។ ព្រានពោលថា ធម្មតាអ្នកសូមរបស់ណាមួយជាមួយអ្នកដទៃ ត្រូវជាបុគ្គលដែល មានវាចាគួរស្រឡាញ់ អ្នកនឹងបានដុំសាច់សមគួរដល់វាចាដែលអ្នកពោល ហើយបាន

ពោលគាថាទី ១ ថា

វាចារបស់អ្នកអាក្រក់ណាស់ អ្នកជាអ្នកសុំសាច់ តែវាចា
ប្រហែលនឹងរាវ នៃសំឡាញ់ យើងនឹងឲ្យរាវដល់អ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិលោមសទិសី** សេចក្ដីថា ឈ្មោះថា ដូចគ្នានឹងរាវ ព្រោះជាវាចាគ្រោតគ្រាត ។ បទថា **កិលោមំ សម្ម ទម្មិ តេ** សេចក្ដីថា ព្រានពោលថា ណ្ហើយចុះ អ្នកចូរកាន់យក ខ្ញុំនឹងឲ្យរាវនេះដែលដូចគ្នានឹងវាចារបស់អ្នក ហើយលើករាវដែលមិនមានរសប្រាសចាកសាច់និងឈាមឲ្យទៅ ។

លំដាប់នោះ សេដ្ឋីបុត្តម្នាក់ទៀត សួរសេដ្ឋីបុត្តនោះថា ឯងនិយាយដូចម្ដេចហើយទើបសូម សេដ្ឋីបុត្តនោះពោលថា គ្នានិយាយថា វ៉ៃយ ហើយទើបសូម ។ សេដ្ឋីបុត្តទាំងនោះពោលថា សូម្បីយើងក៏នឹងសូម ហើយទៅ ពោលថា បងប្រុស សូមបងឲ្យដុំសាច់ដល់ខ្ញុំខ្លះ នាយព្រានពោលថា អ្នកនឹងបានដុំសាច់ដែលសមគួរដល់វាចារបស់អ្នក ហើយពោលគាថាទី ២ ថា

ជនជាបងប្អូន គេទុកជាអវយវៈរបស់មនុស្សទាំងឡាយ ក្នុង
លោក វាចារបស់អ្នកប្រហែលនឹងអវយវៈ នៃសំឡាញ់ យើង
នឹងឲ្យសាច់អវយវៈដល់អ្នក ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយដូច្នេះថា ពាក្យថា បងប្អូនប្រុសឬបងប្អូនស្រីនេះ ឈ្មោះថាជាចំណែកប្រកប ព្រោះដូចគ្នានឹងអវយវៈរបស់មនុស្សក្នុងលោកនេះ ព្រោះដូច្នោះវាចារបស់អ្នកដូចគ្នានឹងអវយវៈ ខ្ញុំនឹងឲ្យ

ដុំសាច់ប៉ុណ្ណោះ ដែលសមគួរដល់វាចារបស់អ្នក ។

កាលពោលយ៉ាងនេះហើយ ទើបព្រានលើកយកសាច់ដែលជាអវយវៈចំណែកប្រកបឲ្យទៅ ។ សេដ្ឋីបុត្តម្នាក់ទៀតសួរសេដ្ឋីបុត្តនោះថា ឯងនិយាយដូចម្តេចហើយទើបសូម សេដ្ឋីបុត្តនោះពោលថា គ្នានិយាយថាបងប្រុសហើយទើបសូម ។ សេដ្ឋីបុត្តនោះពោលថា ខ្ញុំក៏នឹងសូម ហើយទៅពោលថា បពិត្រលោកឪពុក សូមលោកឲ្យដុំសាច់ដល់ខ្ញុំខ្លះ ព្រានពោលថា អ្នកនឹងបានដុំសាច់ដែលសមគួរដល់វាចារបស់អ្នក ហើយទើបពោលគាថាទី ៣ ថា

កូនកាលហៅបិតាថា ឪពុក ឪពុក ដូច្នេះ រមែងធ្វើបេះដូង
បិតាឲ្យកម្រើក វាចារបស់អ្នកប្រហែលនឹងបេះដូងនៃសំឡាញ់
យើងនឹងឲ្យបេះដូងដល់អ្នក ដូច្នេះ ។

កាលពោលយ៉ាងនេះហើយ ទើបលើកយកសាច់ដែលឆ្ងាញ់ ព្រមទាំងសាច់បេះដូងឲ្យទៅ ។ សេដ្ឋីបុត្តទី ៤ សួរសេដ្ឋីបុត្តនោះថា ឯងពោលដូចម្តេចហើយទើបសូម សេដ្ឋីបុត្តនោះពោលថា គ្នាពោលថា បពិត្រលោកឪពុកហើយទើបសូម ។ សេដ្ឋីបុត្តទី ៤ នោះពោលថា ខ្ញុំក៏នឹងសូម ហើយទើបចូលទៅ ពោលថា សម្លាញ់ សូមអ្នកឲ្យដុំសាច់ដល់ខ្ញុំខ្លះ ព្រានពោលថា អ្នកនឹងបានដុំសាច់ដែលសមគួរដល់វាចារបស់អ្នក ហើយពោលគាថាទី ៤ ថា

សំឡាញ់របស់បុរសណាមិនមានក្នុងស្រុក លំនៅរបស់បុរស
នោះក្នុងស្រុកនោះឯងដូចព្រៃ វាចារបស់អ្នក ប្រហែលនឹង
សម្បត្តិទាំងពួង នៃសំឡាញ់ យើងនឹងឲ្យសាច់ទាំងអស់ដល់

អ្នក ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា ក្នុងផ្ទះរបស់បុរសណាមិនមានសម្លាញ់ ពោលគឺ ឈ្មោះថាសម្លាញ់ ព្រោះទៅរួមគ្នាក្នុងសុខនិងទុក្ខ ទីកន្លែងនោះរបស់បុរសនោះដូចគ្នានឹងព្រៃមិនមានមនុស្សដូច្នោះ វាចារបស់អ្នកដូចគ្នានឹងសម្បត្តិទាំងអស់ គឺដូចគ្នានឹងសម្បត្តិដែលជារបស់ខ្លួនទាំងអស់ ព្រោះហេតុនោះ ខ្ញុំនឹងឲ្យយានដែលផ្ទុកសាច់របស់ខ្ញុំនេះ ទាំងអស់ដល់អ្នក ។

កាលពោលយ៉ាងនោះហើយ ទើបនាយព្រានពោលថា មកសម្លាញ់ ខ្ញុំនឹងនាំយានដែលដឹកសាច់ទាំងអស់នេះ ទៅកាន់ផ្ទះរបស់ឯងចុះ សេដ្ឋីបុត្តឲ្យនាយព្រានបរយានទៅកាន់ផ្ទះរបស់ខ្លួនឲ្យជញ្ជូនសាច់ចុះ ធ្វើសក្ការៈរាប់អានដល់នាយព្រាន ឲ្យហៅបុត្តនិងកិរិយារបស់នាយព្រាននោះមក ឲ្យឈប់ប្រព្រឹត្តកម្មគ្រោតគ្រាត ឲ្យនៅក្នុងកណ្ដាលគំនរទ្រព្យសម្បត្តិរបស់ខ្លួន ជាសម្លាញ់ដែលមាំទាំជាមួយនាយព្រាននោះ រស់នៅសាមគ្គីគ្នាដរាបដល់អស់ជីវិត ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា នាយព្រានក្នុងកាលនោះ បានសារីបុត្តក្នុងកាលឥឡូវនេះ ចំណែកសេដ្ឋីបុត្តអ្នកបានសាច់ទាំងអស់ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មំសជាតក ចប់

# សសបណ្ឌិតជាតក

[ ៥៦២ ] ( ភេទនិយាយនឹងឥន្ទព្រាហ្មណ៍ថា ) ខ្ញុំមានត្រីក្ដិន ៧ ដែលព្រានសន្ទូចស្រង់ឡើងពីទឹកដាក់លើគោក ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ។

[ ៥៦៣ ] ( ចចកនិយាយនឹងឥន្ទព្រាហ្មណ៍ថា ) កត្តរបស់អ្នករក្សាស្រែឯណោះ គឺសាច់ពីរជ្រនួចផង ទន្សងមួយផង ដបទធិមួយផង ខ្ញុំបាននាំមកក្នុងវេលាយប់ ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ។

[ ៥៦៤ ] ( ស្វានិយាយនឹងឥន្ទព្រាហ្មណ៍ថា ) ផ្លែស្វាយទុំ ទឹកត្រជាក់ ទីមានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ។

[ ៥៦៥ ] ( ទន្សាយនិយាយនឹងឥន្ទព្រាហ្មណ៍ថា ) ទន្សាយ មិនមានល្ង មិនមានសណ្ដែក មិនមានអង្ករទេ អ្នកចូរបរិភោគនូវខ្ញុំដែលឆ្អិនដោយភ្លើងនេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ។

**ចប់ សសបណ្ឌិតជាតកទី ១ ។**

# អដ្ឋកថា

# សសបណ្ឌិតជាតក

[ ៥៦២-៥៦៥ ] *ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការថ្វាយបរិក្ខារគ្រប់យ៉ាង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **សត្ត មេ រោហិតា មច្ឆា** *ដូច្នេះជាដើម ។*

*បានឮថា ក្នុងនគរសាវត្ថីមានកុដុម្ពិកៈម្នាក់ ត្រៀមការថ្វាយបរិក្ខារគ្រប់យ៉ាងដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យសាងមណ្ឌបត្រង់ទ្វារផ្ទះហើយនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យគង់លើបវរអាសនៈក្នុងមណ្ឌបដែលបានចាត់ចែងទុកល្អហើយ ថ្វាយទានដ៏ប្រណីតមានរសប្រសើរផ្សេងៗហើយនិមន្តឲ្យឆាន់អស់កាល ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ បានថ្វាយបរិក្ខារទាំងពួងដល់ភិក្ខុ ៥០០ មានព្រះពុទ្ធជាប្រធាន ក្នុងកាលសម្រេចភត្តកិច្ច ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនា ទើបត្រាស់ថា ម្នាលឧបាសក អ្នកគួរធ្វើបីតិសោមនស្ស ។ ឈ្មោះថាទាននេះ ជាវង្សរបស់បុរាណកបណ្ឌិតទាំងឡាយ ដ្បិតថាបុរាណកបណ្ឌិតទាំងឡាយ បានបរិច្ចាគជីវិតដល់ពួកយាចក ដែលមកដល់ចំពោះមុខសូម្បីតែសាច់របស់ខ្លួន ក៏បានឲ្យហើយ កាលឧបាសកនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា*

*ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតទន្សាយក្នុងព្រៃ ។ ព្រៃនោះនៅត្រង់ជើងភ្នំ ស្ទឹង និងបច្ចន្តគាមមកប្រសព្វគ្នាតែមួយកន្លែង ។ មានសត្វដទៃ ៣ ទៀតគឺ ស្វា*

ចចកនិងកេ បានជាសម្លាញ់របស់ទន្សាយនោះ ។ សត្វទាំង ៤ នោះជាបណ្ឌិត នៅរួមគ្នា កាន់យកចំណីដែលជាទីគោចរៀងៗខ្លួន ហើយមកប្រជុំគ្នាក្នុងពេលល្ងាច ។ សសបណ្ឌិតសម្តែងធម៌ដោយការឲ្យឱវាទដល់សត្វទាំង ៣ ថា អ្នកទាំងឡាយគប្បីឲ្យទាន គប្បីរក្សាសីល គប្បីធ្វើឧបោសថកម្ម ។ សត្វទាំង ៣ នោះទទួលឱវាទរបស់សសបណ្ឌិតនោះហើយ ចូលទៅកាន់គុម្ពឈើដែលជាលំនៅរៀងៗខ្លួន ។ ពេលវេលាកន្លងទៅយ៉ាងនេះ ថ្ងៃមួយព្រះពោធិសត្វសម្លឹងមើលអាកាសឃើញព្រះចន្ទ ដឹងថាស្អែកនេះជាថ្ងៃឧបោសថទើបពោលនឹងសត្វទាំង ៣ ក្រៅអំពីនេះថា ស្អែកនេះជាថ្ងៃឧបោសថ អ្នកទាំង ៣ ចូរសមាទានសីលរក្សាឧបោសថ ទានដែលតាំងនៅក្នុងសីល ហើយឲ្យ រមែងមានផលច្រើន ព្រោះហេតុនោះ កាលយាចកមកដល់ អ្នកទាំងឡាយគប្បីឲ្យអាហារដែលគួរបរិភោគ ហើយសឹមបរិភោគខ្លួនឯង ។ សត្វទាំង ៣ នោះទទួលថា សាធុ ហើយនាំគ្នាសម្រាកក្នុងលំនៅរៀងៗខ្លួន ។ ស្អែកឡើង ក្នុងសត្វទាំងនោះ ភេគិតថា អញនឹងស្វែងរកចំណីអំពីព្រលឹម ទើបទៅកាន់ឆ្នេរស្ទឹងគង្គា ។ កាលនោះ ព្រានសន្ទូចម្នាក់ ចាប់ត្រីក្ដិនបាន ៧ យកវល្លិ៍ដោតកាយខ្សាច់ត្រង់ឆ្នេរស្ទឹង ( កប់ត្រី ) ហើយយកខ្សាច់លប់ កាលចាប់ត្រីទៀត ទើបទៅកាន់ត្រើយខាងត្បូងស្ទឹងគង្គា ។ ភេហិតក្លិន បានទូវក្លិនត្រីទើបកាយខ្សាច់ឃើញត្រី នាំចេញមកគិតថា ម្ចាស់របស់ត្រីនេះមានឬទេហ្ន៎ ទើបប្រកាស ៣ ដង កាលមិនឃើញម្ចាស់ ទើបពាំចុងវល្លិ៍នាំទៅរក្សាទុកក្នុងគុម្ពឈើដែលជាលំនៅរបស់ខ្លួនគិតថា អញនឹងទំពាស៊ីកាលដល់វេលា ដូច្នេះ

ហើយ ទើបដេកពិចារណាដល់សីលរបស់ខ្លួន ចំណែកចចក ចេញស្វែងរកចំណី បានឃើញសាច់អាំង ២ ច្រនួច ទន្សងមួយនិងទឹកដោះជូរមួយដបក្នុងខ្ទមរបស់អ្នកចាំស្រែម្នាក់ គិតថាម្ចាស់របស់ទាំងនេះមានឬហ្ន៎ទើបប្រកាស ៣ ដង មិនឃើញម្ចាស់ទើបសឹកខ្សែដបទឹកដោះជូរត្រង់ក យកមាត់ពាំសាច់អាំងនិងទន្សង នាំទៅរក្សាទុកក្នុងគុម្ពឈើដែលជាលំនៅរបស់ខ្លួន គិតថានឹងស៊ីសាច់កាលដល់វេលា ទើបដេកពិចារណាដល់សីលរបស់ខ្លួន ។ ចំណែកស្វាចេញអំពីលំនៅចូលទៅកាន់ដងព្រៃ នាំយកចង្កោមផ្លែស្វាយមករក្សាទុកត្រង់គុម្ពឈើដែលជាលំនៅរបស់ខ្លួន គិតថា អញនឹងស៊ីក្នុងកាលដល់ពេលវេលា ទើបដេកពិចារណាដល់សីលរបស់ខ្លួន ។ ចំណែកព្រះពោធិសត្វគិតថា ចាំដល់ពេលនឹងចេញទៅស៊ីស្បូវក្លាំងនិងស្មៅទាំងឡាយ ដូច្នេះហើយ ទើបដេកក្នុងគុម្ពឈើដែលជាលំនៅរបស់ខ្លួននោះឯង គិតថា អញមិនអាចឲ្យស្មៅដល់ពួកយាចកដែលមកកាន់សម្នាក់របស់អញ សូម្បីល្ងនិងអង្ករជាដើមរបស់អញក៏មិនមាន បើយាចកមកកាន់សម្នាក់របស់អញសោត អញនឹងឲ្យសាច់ក្នុងរាងកាយរបស់អញ ។ ដោយតេជះនៃសីលរបស់ព្រះពោធិសត្វនោះ បណ្ឌុកម្ពលសិលារបស់សក្កទេវរាជបានសម្តែងអាការៈក្តៅ ។ ( បណ្ឌុកម្ពលសិលានោះក្តៅព្រោះសក្កទេវរាជអស់អាយុឬអស់បុណ្យ ឬកាលសត្វដទៃដែលមានអានុភាពច្រើនប្រាថ្នាទីកន្លែងនោះ ឬដោយតេជះនៃសីលរបស់សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ក្នុងកាលនោះ បណ្ឌុកម្ពលសិលារបស់សក្កទេវរាជបានក្តៅ ព្រោះតេជះនៃសីល ) ។ សក្កទេវរាជនោះទ្រង់រំពឹងមើល ជ្រាបហេតុនោះ

ហើយ ទើបត្រិះរិះថា អញនឹងសាកល្បងស្តេចទន្សាយមើល ជាបឋមទ្រង់យាងទៅកាន់លំនៅរបស់កេ កាឡាខ្លួនជាព្រាហ្មណ៍ហើយឈរ ។ កាលកេពោលថា នែព្រាហ្មណ៍ អ្នកមកឈរដើម្បីត្រូវការអ្វី ទើបត្រាស់ថា អ្នកបណ្ឌិត បើខ្ញុំគប្បីបានអាហារខ្លះ នឹងជាអ្នករក្សាឧបោសថ សម្ងំនៅ ។ កេនោះពោលថា សាធុ ខ្ញុំនឹងឲ្យអាហារដល់អ្នក កាលនឹងចរចាជាមួយសក្កទេវរាជនោះ ទើបពោលគាថាទី ១ ថា

ខ្ញុំមានត្រីច្អិន ៧ ដែលព្រានសន្ទូចស្រង់ឡើងពីទឹកដាក់លើ
គោក ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ
ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ថលមុព្ភតា** សេចក្តីថា ដែលព្រានសន្ទូចលើកឡើងអំពីទឹកដាក់លើគោក ។ បទថា **ឯតំ ភុត្វា** សេចក្តីថា ចូរអ្នកអាំងមច្ឆាហារដែលជារបស់ខ្ញុំនេះបរិភោគ អង្គុយត្រង់គល់ឈើដែលជាទីរីករាយធ្វើសមណធម៌ក្នុងព្រៃចុះ ។

ព្រាហ្មណ៍ពោលថា រឿងនេះចូរលើកទុកចុះ ខ្ញុំនឹងដឹងក្នុងកាលជាក្រោយហើយទៅកាន់សម្នាក់របស់ចចក កាលចចកពោលថា អ្នកឈរដើម្បីត្រូវការអ្វី ក៏បានពោលយ៉ាងនោះឯង ចចកពោលថា សាធុ ខ្ញុំនឹងឲ្យ កាលចរចានឹងសក្កទេវរាជនោះ ទើបពោលគាថាទី ២ ថា

ភត្តរបស់អ្នករក្សាស្រែឯណោះ គឺសាច់ពីរជ្រនួចផង ទន្សង
មួយផង ដបទធិមួយផង ខ្ញុំបាននាំមកក្នុងវេលាយប់ ម្នាល

ព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ
( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធស្ស មេ** សេចក្ដីថា របស់អ្នកយាមស្រែក្នុងទីមិនឆ្ងាយអំពីខ្ញុំនោះ គឺក្នុងទីឯណោះ ។ បទថា **អបាភតំ** បានដល់នាំមកហើយ គឺនាំមករក្សាទុក ។ បទថា **មំសសូលា ច ទ្វេ គោធា** សេចក្ដីថា សាច់អាំង ២ ជន្ទួចដែលឆ្អិនលើរងើកភ្លើងនិងទន្សង ១ ។ បទថា **ឧធិវារកំ** បានដល់ ដបទឹកដោះជូរ ។ បទថា **ឥទំ** ជាដើម មានសេចក្ដីថា ខ្ញុំមានវត្ថុនេះ គឺមានប្រមាណប៉ុណ្ណេះ សូមលោកអាំងរបស់ទាំងអស់នេះឲ្យឆ្អិនតាមគាប់ចិត្ត ហើយបរិភោគ ជាអ្នករក្សាឧបោសថ អង្គុយត្រង់គល់ឈើដែលជាទីត្រេកអរ ធ្វើសមណធម៌ក្នុងព្រៃចុះ ។

ព្រាហ្មណ៍ពោលថា រឿងនេះចូរលើកទុកចុះ ខ្ញុំនឹងដឹងឯក្រោយ ហើយទៅកាន់សម្នាក់របស់ស្វា កាលស្វានោះពោលថា អ្នកឈរដើម្បីត្រូវការអ្វី ទើបពោលយ៉ាងនោះឯង ។ ស្វាពោលថា សាធុខ្ញុំនឹងឲ្យ កាលចរចាជាមួយសក្កទេវរាជនោះ ទើបពោលគាថាទី ៣ ថា

ផ្លែស្វាយទុំ ទឹកត្រជាក់ ទីមានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ម្នាល
ព្រាហ្មណ៍នេះរបស់ខ្ញុំអ្នកចូរបរិភោគរបស់នេះហើយ ( ចម្រើន
សមណធម៌ ) នៅក្នុងព្រៃចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អម្ពបក្កំ** បានដល់ ស្វាយទុំដ៏ឆ្ងាញ់ ។ បទថា **ឧទកំ សីតំ** បានដល់ ទឹកក្នុងស្ទឹងគង្គាត្រជាក់ ។ បទថា **ឯតំ កុត្វា**

សេចក្តីថា នែព្រាហ្មណ៍ ចូរអ្នកបរិភោគផ្លែស្វាយនេះ ហើយផឹកទឹកត្រជាក់ អង្គុយត្រង់គល់ឈើដែលជាទីត្រេកអរតាមគាប់ចិត្ត ហើយធ្វើសមណធម៌ក្នុងព្រៃចុះ ។

ព្រាហ្មណ៍ពោលថា រឿងនេះចូរលើកទុកសិនចុះ ខ្ញុំនឹងដឹងក្នុងកាលជាខាងក្រោយ ហើយទៅកាន់សម្នាក់របស់សសបណ្ឌិត កាលសសបណ្ឌិតពោលថា អ្នកមកដើម្បីអ្វី ក៏ពោលយ៉ាងនោះឯង ។ ព្រះពោធិសត្វបានស្តាប់ដូច្នោះ ក៏មានសេចក្តីត្រេកអរសោមនស្សពោលថា នែព្រាហ្មណ៍ អ្នកមកកាន់សម្នាក់របស់ខ្ញុំដើម្បីត្រូវការអាហារ បានធ្វើល្អហើយ ថ្ងៃនេះខ្ញុំនឹងឲ្យទានដែលមិនធ្លាប់ឲ្យ ឯអ្នកជាអ្នកមានសីល មិនធ្វើបាណាតិបាត ចូរអ្នកប្រមូលឧសច្រើនប្រភេទ មកបង្កាត់ឲ្យឆេះជាភ្លើង ហើយចូរប្រាប់ខ្ញុំ ខ្ញុំនឹងលះបង់ខ្លួនលោតចូលក្នុងភ្លើង កាលរាងកាយរបស់ខ្ញុំឆ្អិនហើយ អ្នកគប្បីបរិភោគសាច់ហើយធ្វើសមណធម៌ កាលចរចានឹងសក្កទេវរាជនោះ ទើបពោលគាថាទី ៤ ថា

> ទន្សាយ មិនមានល្ង មិនមានសណ្តែក មិនមានអង្ករទេ អ្នកចូរបរិភោគនូវខ្ញុំដែលឆ្អិនដោយភ្លើងនេះ ហើយ ( ចម្រើនសមណធម៌ ) នៅក្នុងព្រៃចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មមំ ភុត្វា** សេចក្តីថា ចូរអ្នកបរិភោគខ្ញុំដែលឆ្អិនដោយភ្លើង ដែលខ្ញុំប្រាប់ឲ្យអ្នកបង្កាត់ឡើងនេះ ហើយចូរនៅក្នុងព្រៃនេះ ធម្មតារាងកាយរបស់ទន្សាយមួយ រមែងល្មមញុំាងជីវិតរបស់បុរសម្នាក់ ឲ្យ

ប្រព្រឹត្តទៅបាន ។

សក្កទេវរាជ បានស្តាប់វាចារបស់សសបណ្ឌិតនោះហើយ ទើបនិម្មិតរងើកភ្លើងមួយគំនរដោយអានុភាពរបស់ខ្លួន ហើយប្រាប់ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វនោះក្រោកឡើងចាកដំណេកស្បូវភ្លាំងហើយ ទៅកាន់ត្រង់គំនររងើកភ្លើងគិតថា បើសត្វតូចៗក្នុងរវាងរោមរបស់អញមាន សត្វទាំងនោះ កុំស្លាប់ជាមួយឡើយ ហើយរលាស់ខ្លួន ៣ ដង តម្កល់រាងកាយទាំងមូលក្នុងទានមុខ គឺផ្លូវរបស់ទាន មានចិត្តរីករាយលោតចូលក្នុងភ្លើង ដូចស្តេចហង្សលោតចូលក្នុងស្រះឈូកដូច្នោះ ។ តែភ្លើងនោះមិនអាចធ្វើនូវការក្តៅ សូម្បីត្រឹមតែរន្ធរោមក្នុងរាងកាយរបស់ព្រះពោធិសត្វ ដូចជាចូលទៅក្នុងបន្ទប់ដែលមានសន្សើម ដូច្នោះ ។ លំដាប់នោះ ព្រះពោធិសត្វហៅសក្កទេវរាជ មកពោលថា នែព្រាហ្មណ៍ ភ្លើងដែលអ្នកបង្កាត់ត្រជាក់ពន់ពេក មិនអាចធ្វើឲ្យក្តៅត្រឹមតែរន្ធរោមក្នុងរាងកាយរបស់ខ្ញុំ នេះជាអ្វី ។ សក្កទេវរាជត្រាស់ថា បណ្ឌិត ខ្ញុំមិនមែនព្រាហ្មណ៍ ខ្ញុំជាសក្កទេវរាជ មកដើម្បីសាកល្បងអ្នកទើបព្រះពោធិសត្វបន្លឺសីហនាទថា បពិត្រសក្កៈ សូមទ្រង់ផ្អាកសិនចុះ បើលោកសន្និវាសទាំងមូលគប្បីសាកល្បងខ្ញុំ ដោយទានសោត មិនគប្បីឃើញភាពដែលខ្ញុំមិនបំណងនឹងឲ្យទានឡើយ ។ លំដាប់នោះ សក្កទេវរាជត្រាស់នឹងព្រះពោធិសត្វនោះថា ម្នាលសសបណ្ឌិត គុណរបស់អ្នកចូរប្រាកដអស់កប្បទាំងមូលចុះ ហើយទ្រង់ច្របាច់បព៌ត កាន់យកចំណែករាវរបស់បព៌ត គូរលក្ខណៈរបស់ទន្សាយទុកក្នុងព្រះចន្ទ ហើយនាំព្រះពោធិសត្វ មកឲ្យដេកលើ

ស្បូវក្លាំងខ្ចីក្នុងគុម្ពឈើក្នុងព្រៃនោះឯង ហើយយាងទៅកាន់ទេវលោករបស់ទ្រង់វិញ ។ បណ្ឌិតទាំង ៤ នោះ ព្រមព្រៀងត្រេកអរនឹងគ្នា នាំគ្នាបំពេញសីល ឲ្យទាន រក្សាឧបោសថ ហើយទៅតាមយថាកម្ម ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ គហបតីអ្នកថ្វាយបរិក្ខារគ្រប់យ៉ាង តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ភេក្កុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចចកក្នុងកាលនោះ បានមកជាមោគ្គល្លាន ស្វាក្នុងកាលនោះ បានមកជាសារីបុត្ត សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ ចំណែកសសបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សសបណ្ឌិតជាតក ចប់

## មតរោទនជាតក

[ ៥៦៦ ] ( សេដ្ឋីពោធិសត្វពោលថា ) អ្នកទាំងឡាយ យំរកបុគ្គលស្លាប់ទៅហើយ ៗ តែម្យ៉ាង បុគ្គលណាបម្រុងស្លាប់អ្នកទាំងឡាយមិនយំរកបុគ្គលនោះសោះ ពួកសត្វទាំងអស់ ជាអ្នកទ្រទ្រង់នូវសរីរៈតែងលះបង់នូវជីវិតតាមលំដាប់ ។

[ ៥៦៧ ] ពួកទេវតា មនុស្ស សត្វជើង ៤ ពួកសត្វស្លាប និងពួកពស់ប្រកបដោយក្អែន មិនជាធំក្នុងសរីរៈឡើយ តែងលះបង់ជីវិត ទាំងកំពុងត្រេកអរ ( ក្នុងឋានៈដែលខ្លួនកើតហើយ ) ។

[ ៥៦៨ ] សុខនឹងទុក្ខជាធម្មជាតិកម្រើក មិនតាំងនៅយ៉ាងនេះ បុគ្គលគួរមើលមើលក្នុងពួកមនុស្ស ការកន្ទក់កន្ទេញ ការយំសោក ជារបស់មិនមានប្រយោជន៍ទេ ព្រោះហេតុអ្វី ក៏គំនរនៃសេចក្ដីសោក គ្របសង្កត់អ្នកទាំងឡាយ ។

[ ៥៦៩ ] ពួកជនណា ជាអ្នកលេង ជាអ្នកស្រវឹង មិនធ្វើ ( សេចក្ដីចម្រើន ) ជាមនុស្សពាល ក្លៀវក្លា មិនមានសេចក្ដីព្យាយាម មិនឈ្លាសក្នុងធម៌ ពួកជននោះ តែងសម្គាល់នូវអ្នកប្រាជ្ញ ( ដែលមិនយំសោកជាដើម ) ថាជាមនុស្សពាលទៅវិញ ។

**ចប់ មតរោទនជាតកទី ៧ ។**

# អដ្ឋកថា

# មតរោទនជាតក

[ ៥៦៦-៥៦៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈក្នុងនគរសាវត្ថីម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មតមតមេវ រោទថ** ដូច្នេះជាដើម ។

បានឮថា បងប្រុសរបស់កុដុម្ពិកៈនោះ បានធ្វើកាលកិរិយា កុដុម្ពិកៈជាប្អូន ត្រូវសេចក្តីសោកគ្របសង្កត់ព្រោះកាលកិរិយារបស់កុដុម្ពិកៈជាបងនោះ មិនងូតទឹក មិនបរិភោគអាហារ មិនលាបស្រឡាប ទៅព្រៃខ្មោចអំពីព្រលឹមដល់នូវសេចក្តីសោកទ្រហោយំ ។

ព្រះសាស្តា ទ្រង់ប្រមើលមើលលោកសន្និវាសក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់ប្អូនប្រុសនៃកុដុម្ពិកៈនោះ ទើបទ្រង់ព្រះតម្រិះថា តថាគតគួរនាំអតីតហេតុមករម្ងាប់សេចក្តីសោក ហើយនឹងឲ្យនូវសោតាបត្តិផលដល់កុដុម្ពិកៈនេះ វៀរតថាគតហើយបុគ្គលណាមួយដែលអាចរម្ងែងមិនមាន តថាគតជាទីពឹងអាស្រ័យរបស់កុដុម្ពិកៈនេះទើបគួរ ។ ស្អែកឡើងទ្រង់យាងត្រឡប់អំពីបិណ្ឌបាតខាងក្រោយកត្តហើយ ទ្រង់នាំបច្ឆាសមណៈទៅកាន់ទ្វារផ្ទះរបស់កុដុម្ពិកៈជាប្អូននោះ កុដុម្ពិកៈបានឮថាព្រះសាស្តាយាងមកទើបឲ្យក្រាលអាសនៈពោលថា អ្នកទាំងឡាយ ចូរនិមន្តឲ្យទ្រង់ចូលមក ។ ព្រះសាស្តាក៏យាងចូលទៅហើយគង់លើអាសនៈដែលគេក្រាលទុក ។ ចំណែកកុដុម្ពិកៈមកថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងកុដុម្ពិកៈនោះថា ម្នាលកុដុម្ពិកៈ អ្នកគិតអ្វីឬ កុដុម្ពិកៈក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គទោមនស្សតាំងអំពីបងប្រុសស្លាប់ទៅ ។ ព្រះសាស្តាត្រាស់ថា ម្នាលកុដុម្ពិកៈ សង្ខារទាំងឡាយមិនទៀង វត្ថុដែលគួរបែកធ្លាយ ក៏បែកធ្លាយទៅ មិនគួរគិតក្នុងរឿងនេះឡើយ សូម្បីបុរាណកបណ្ឌិតទាំងឡាយ កាលបងប្រុសស្លាប់ទៅក៏មិនទោមនស្ស ដ្បិតថា វត្ថុដែលគួរបែកធ្លាយ បានបែកធ្លាយទៅហើយ ។ កាលកុដុម្ពិកៈនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋីមានទ្រព្យ ៨០ កោដិ កាលព្រះពោធិសត្វចម្រើនវ័យហើយ មាតាបិតាក៏បានធ្វើកាលកិរិយាទៅ ។ កាលមាតាបិតានោះធ្វើកាលកិរិយាហើយ បងប្រុសរបស់ព្រះពោធិសត្វ ក៏បានចាត់ចែងទ្រព្យសម្បត្តិជំនួស ។ ព្រះពោធិសត្វអាស្រ័យបងប្រុសនោះរស់នៅ ។ ក្នុងកាលតមក បងប្រុសនោះក៏បានធ្វើកាលកិរិយាដោយជំងឺបែបនោះ ។ ញាតិមិត្តនិងសម្លាញ់ទាំងឡាយ នាំគ្នាផ្គងដើមដៃកន្ទក់កន្ទេញ សូម្បីតែម្នាក់ក៏មិនអាចតាំងនៅដោយធម្មតារបស់ខ្លួនបាន ចំណែកព្រះពោធិសត្វ មិនកន្ទក់កន្ទេញ មិនយំ មនុស្សទាំងឡាយនាំគ្នាតិះដៀលព្រះពោធិសត្វថា មើលចុះអ្នកដ៏ចម្រើនទាំងឡាយ កាលបងប្រុសស្លាប់ទៅហើយ អាការៈសូម្បីត្រឹមតែមុខស្រពោនក៏មិនមាន បុរសនេះមានចិត្តរឹងត្អឹងក្រៃពេក ប្រហែលជាចង់ឲ្យបងប្រុសស្លាប់ដោយគិតថា អញម្នាក់ឯងនឹងប្រើប្រាស់ទ្រព្យសម្បត្តិទាំងពីរចំណែក ។ ញាតិ

ទាំងឡាយ តិះដៀលព្រះពោធិសត្វនោះថា កាលបងប្រុសស្លាប់ហេតុអ្វីក៏ឯង មិនយំ ។ ព្រះពោធិសត្វនោះបានស្តាប់ពាក្យរបស់ញាតិទាំងនោះក៏ពោលថា អ្នកទាំងឡាយមិនស្គាល់លោកធម៌ ៨ ប្រការ ព្រោះភាពដែលខ្លួនជាបុគ្គល ល្ងង់ខ្លៅទើបនាំគ្នាយំថា បងប្រុសរបស់អញស្លាប់ សូម្បីខ្ញុំក៏ត្រូវស្លាប់ ព្រោះ ហេតុអ្វីអ្នកទាំងឡាយក៏មិនយំឲ្យដល់ខ្ញុំខ្លះថា បុគ្គលនេះក៏នឹងស្លាប់ សូម្បីអ្នក ទាំងឡាយក៏ស្លាប់ ហេតុម្តេចក៏មិនយំឲ្យខ្លួនឯងថា សូម្បីយើងទាំងឡាយក៏ នឹងស្លាប់ សូម្បីយើងទាំងឡាយក៏នឹងស្លាប់ សង្ខារទាំងពួងជារបស់មិនទៀងមាន ហើយក៏រលត់ទៅវិញ សង្ខារណាមួយដែលអាចតាំងនៅតាមសភាវៈ នោះឯង រមែងមិនមាន អ្នកទាំងឡាយជាបុគ្គលខ្វាក់ងងឹត មិនស្គាល់លោកធម៌ ៨ ប្រការ ទើបនាំគ្នាយំព្រោះការមិនដឹង ខ្ញុំយំដើម្បីអ្វី ហើយពោលគាថាទាំងនេះថា

អ្នកទាំងឡាយ យំរកបុគ្គលស្លាប់ទៅហើយ ៗ តែម្យ៉ាង
បុគ្គលណាបម្រុងស្លាប់ អ្នកទាំងឡាយ មិនយំរកបុគ្គលនោះ
សោះ ពួកសត្វទាំងអស់ជាអ្នកទ្រទ្រង់នូវសរីរៈ តែងលះបង់
នូវជីវិតតាមលំដាប់ ។

ពួកទេវតា មនុស្ស សត្វជើង ៤ ពួកសត្វស្លាប និងពួក
ពស់ប្រកបដោយភ្នែន មិនជាធំក្នុងសរីរៈឡើយ តែងលះបង់
ជីវិតទាំងកំពុងត្រេកអរ ( ក្នុងឋានៈដែលខ្លួនកើតហើយ ) ។

សុខនឹងទុក្ខជាធម្មជាតិកម្រើក មិនតាំងនៅយ៉ាងនេះបុគ្គល
គួរមិលមើលក្នុងពួកមនុស្ស ការកន្ទក់កន្ទេញ ការយំសោក

ជារបស់មិនមានប្រយោជន៍ទេ ព្រោះហេតុអ្វីក៏គំនរនៃសេចក្ដីសោក គ្របសង្កត់អ្នកទាំងឡាយ ។

ពួកជនណា ជាអ្នកលេង ជាអ្នកស្រវឹង មិនធ្វើ ( សេចក្ដីចម្រើន ) ជាមនុស្សពាល ក្លៀវក្លា មិនមានសេចក្ដីព្យាយាម មិនឈ្លាសក្នុងធម៌ ពួកជននោះ តែងសម្គាល់នូវអ្នកប្រាជ្ញ ( ដែលមិនយំសោកជាដើម ) ថា ជាមនុស្សពាលទៅវិញដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មតមតមេវ** បានដល់ ស្លាប់ទៅហើយស្លាប់ទៅហើយនោះឯង ។ បទថា **អនុបុព្វេន** សេចក្ដីថា កាលជួបនូវការស្លាប់របស់ខ្លួន សត្វទាំងឡាយរមែងលះបង់ជីវិតទៅដោយលំដាប់ៗ គឺសត្វទាំងពួង មិនមែននាំគ្នាស្លាប់ព្រមគ្នា បើស្លាប់ព្រមគ្នាយ៉ាងនោះ ការប្រព្រឹត្តទៅរបស់លោកសន្និវាស ក៏ត្រូវដាច់សូន្យ ។ បទថា **ភោគិនោ** បានដល់ ដែលប្រកបដោយទំហំរាងកាយធំ ។ បទថា **រមមានា** សេចក្ដីថា សត្វទាំងឡាយមានទេវតាជាដើមនេះ សូម្បីទាំងអស់កើតក្នុងភពនោះៗ ដល់នូវការត្រេកអរ គឺមិនក្ដៅក្រហាយខ្វឹកខ្វួលក្នុងទីដែលកើតរៀងៗខ្លួន ក៏រមែងលះបង់ជីវិតទៅ ។ បទថា **ឃរំ ចលិតំ** សេចក្ដីថា សុខទុក្ខ ឈ្មោះថាប្រែប្រួលទៅមិនតាំងនៅ ព្រោះមិនមានការឈប់ស្ងៀមនិងការតាំងមាំនៅក្នុងភពទាំង ៣ យ៉ាងនោះ ។ បទថា **កឹ វោ សោកគណាភិកិរេ** សេចក្ដីថា ព្រោះហេតុអ្វី ទើបគំនរនៃសេចក្ដីសោកគ្របសង្កត់ គឺលិចលង់អ្នកទាំងឡាយ ។ បទថា **ធុត្តា សោ-**

**ឈ្នា ច អកតា** សេចក្តីថា អ្នកលេងស្រី អ្នកលេងស្រា អ្នកលេងល្បែងភ្នាល់ អ្នកផឹក អ្នកស៊ីជាដើម ជាអ្នកមិនធ្វើសេចក្តីចម្រើនផង ដាច់នូវការសិក្សាផង ។ បទថា **ពាលា** បានដល់ ប្រកបដោយការល្ងង់ខ្លៅ គឺជាអ្នកមិនដឹង ។ បទថា **ស្វាភា អយោគិនោ** សេចក្តីថា ឈ្មោះថា **ស្វាភា** ព្រោះមិនដាក់ចិត្តដោយឧបាយ ឈ្មោះថា **អយោគិនោ** ព្រោះភាពជាអ្នកមិនប្រកបព្យាយាម ។ បាលីថា **អយោធិនោ** ដូច្នេះក៏មាន អធិប្បាយថា ជាអ្នកមិនអាចច្បាំងនឹងកិលេសមារ ។ បទថា **ធីរំ មញ្ញន្តិ ពាលោតិ យេ ធម្មស្ស អកោវិទា** សេចក្តីថា ពួកអ្នកលេងជាដើមបែបនោះ ជាអ្នកមិនដឹងនូវលោកធម៌ ៨ ប្រការ កាលទុក្ខធម៌មានប្រមាណតិចតួចកើតឡើងហើយ ក៏ទោមនស្ស ខ្សឹកខ្សួលទ្រហោយំ ព្រោះមិនដឹងលោកធម៌ ៨ តាមសេចក្តីពិត ទើបសម្គាល់អ្នកប្រាជ្ញគឺបណ្ឌិតដូចខ្ញុំ ដែលមិនសោកខ្សឹកខ្សួលក្នុងការស្លាប់របស់ញាតិជាដើម ថាបុគ្គលនេះ ជាបុគ្គលពាលមិនយំសោក ។

ព្រះពោធិសត្វ កាលសម្តែងធម៌ដល់ញាតិទាំងនោះ ដោយប្រការយ៉ាងនេះហើយ បានធ្វើញាតិទាំងអស់នោះឲ្យស្បើយនូវសោកហើយ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈ តាំងនៅក្នុងសោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា បណ្ឌិតដែលសម្តែងធម៌ដល់មហាជន ហើយធ្វើឲ្យប្រាសចាកសេចក្តីសោកក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មតភេទនជាតក ចប់**

## កណវេរជាតក

[ ៥៧០ ] ( ពួករបាំច្រៀងថា ) អ្នកឱបរឹតនាងសាមាណា ដោយដើមដៃក្បែរគុម្ពច្បាទាំងឡាយមានផ្កាក្រហម ដូចពន្លឺព្រះអាទិត្យក្នុងវសន្តសម័យ ( ហើយរត់ទៅឥឡូវនេះ ) នាងសាមានោះ ប្រាប់មកអ្នក ( ថានាង ) មិនមានរោគទេ ។

[ ៥៧១ ] ( ពោធិសត្វពោលថា ) នៃនាងដ៏ចម្រើន បានឮថា ខ្យល់បក់ផាត់ភ្នំ ដោយហេតុណា ខ្ញុំមិនគប្បីជឿនូវហេតុនោះទេ បើខ្យល់បក់ផាត់ភ្នំបាន បក់ផាត់ផែនដីទាំងមូលក៏បានដែរ នាងសាមាណា ស្លាប់ទៅហើយ អ្នកពោលថានាងសាមានោះមិនមានរោគ ( ខ្ញុំមិនគប្បីជឿទេ ) ។

[ ៥៧២ ] ( ពួករបាំច្រៀងថា ) នាងសាមានោះ មិនស្លាប់ផង នាងមិនចង់បានបុរសដទៃផង ឮថា នាងសាមាមានប្ដីតែមួយ នាងចង់បានតែប្ដីនោះឯង ។

[ ៥៧៣ ] ( ព្រះពោធិសត្វពោលថា ) នាងសាមាប្ដូរយកខ្ញុំ ដែលមិនធ្លាប់ស្និទ្ធស្នាល ដោយប្ដីដែលស្និទ្ធស្នាល អស់កាលយូរ ប្ដូរយកខ្ញុំ ជាប្ដីមិនពិតប្រាកដ ដោយប្ដីពិតប្រាកដ នាងសាមា មុខតែប្ដូរយកបុរសដទៃ ខ្ញុំនឹងទៅកាន់ទីឆ្ងាយលើសពីនេះទៅទៀត ។

**ចប់ កណវេរជាតកទី ៨ ។**

## អដ្ឋកថា

## កណវេរជាតក

[ ៥៧០-៥៧៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោម របស់ភរិយាចាស់នៃភិក្ខុមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យន្តំ វសន្តសមយេ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានច្បាស់ក្នុងឥន្ទ្រិយជាតក ចំណែកក្នុងទីនេះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ កាលមុនអ្នកអាស្រ័យស្រីនេះទើបបានទទួលការកាត់ក្បាលដោយដាវ ទើបទ្រង់នាំយកអតីតនិទានមក សាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតចំបូកចោរ ក្នុងផ្ទះរបស់គហបតីម្នាក់ ក្នុងកាសិកគាម ។ លុះចម្រើនវ័យហើយ ធ្វើចោរកម្មចិញ្ចឹមជីវិតរហូតប្រាកដក្នុងលោក ជាអ្នកក្លាហាន មានកម្លាំងដូចដំរីសារ មិនមានអ្នកណាអាចចាប់ព្រះពោធិសត្វនោះបានឡើយ ។ ថ្ងៃមួយព្រះពោធិសត្វកាត់ទីតផ្ទះក្នុងផ្ទះរបស់សេដ្ឋីម្នាក់ លួចយកទ្រព្យជាច្រើន អ្នកនគរនាំគ្នាចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រព្រះសម្មតិទេព មហាចោរម្នាក់ប្លន់ព្រះនគរ សូមទ្រង់ចាប់ចោរនោះ ។ ព្រះរាជាប្រើឲ្យភ្នាក់ងាររក្សាព្រះនគរចាប់មហាចោរនោះ ។ ក្នុងពេលយប់ ភ្នាក់ងាររក្សាព្រះនគរបានដាក់មនុស្សជាក្រុមៗក្នុងទីនោះៗ ចាប់មហាចោរនោះបានមួយអន្ទើដោយកស្តុតាង ហើយក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាត្រាស់នឹងភ្នាក់ងាររក្សាព្រះនគរនោះឯងថា ចូរកាត់ក្បាលចោរនេះ ភ្នាក់ងារអ្នករក្សា

ព្រះនគរចងដៃមហាចោរនោះទៅក្រោយ ដោយចំណងដ៏មាំ ហើយពាក់កម្រង ផ្កាច្បារពណ៌ក្រហម ត្រង់ករបស់មហាចោរនោះ ហើយរោយកម្ទេចឥដ្ឋដាក់ លើក្បាល វាយមហាចោរនោះដោយផ្តៅម្តង ៤ រំពាត់ហើយនាំទៅកាន់ផ្លូវ បែកជា ៤ ដោយស្គរតូចដែលមានសំឡេងខ្លាំង នាំទៅកាន់ទីសម្លាប់ ។ អ្នក នគរទាំងមូលបានតោឡោថា បានឮថា ចោរដែលធ្វើការប្លន់ក្នុងនគរ នេះ ត្រូវចាប់បានហើយ ។ កាលនោះ ក្នុងនគរពារាណសី មានស្រីគណិកាម្នាក់ ឈ្មោះ សាមា មានតម្លៃខ្លួន ១០០០ ជាទីប្រោសប្រាណរបស់ព្រះរាជា មាន វណ្ណទាសី ៥០០ ជាបរិវារ ។ នាងសាមានោះ ឈរបើកបង្អួចលើផ្ទៃប្រា សាទ ឃើញចោរនោះកំពុងត្រូវនាំទៅ ចោរនោះជាអ្នកមានរូបស្អាតគួរស្នេហា ដល់នូវលម្អស្អាតក្រៃលែង មានពណ៌សម្បុរដូចទេវតា ប្រាកដច្បាស់ជាង មនុស្សទាំងពួង ។ នាងសាមាឃើញក៏មានចិត្តប្រតិព័ទ្ធ គិតថា អញនឹងធ្វើ បុរសនេះ ឲ្យមកជាប្តីរបស់អញ បានដោយឧបាយណាហ្ន៎ ឃើញថាមាន ឧបាយមួយ ទើបដាក់ទ្រព្យមួយពាន់ក្នុងដៃអ្នកបម្រើម្នាក់ ដែលជាអ្នកធ្វើតាម សេចក្តីត្រូវការរបស់ខ្លួនបាន ដើម្បីយកទៅឲ្យភ្នាក់ងារអ្នករក្សាព្រះនគរ ដោយ ប្រាប់ថា ចោរនេះជាបងប្រុសរបស់នាងសាមា វៀរនាងសាមាហើយ អ្នកដទៃ ជាទីអាស្រ័យរបស់ចោរនេះមិនមាន សូមលោកទទួលយកទ្រព្យ មួយពាន់ ហើយលែងចោរនេះ អ្នកបម្រើនោះបានធ្វើយ៉ាងនោះ ។ ភ្នាក់ងារអ្នករក្សាព្រះ នគរពោលថា ចោរនេះល្បីល្បាញណាស់ យើងមិនអាចលែងបាន តែបើ បានអ្នកដទៃជំនួស យើងអាចឲ្យចោរនេះអង្គុយក្នុងយានដែលបិទជិត ហើយ

បញ្ជូនទៅបាន ។ អ្នកបម្រើទើបប្រាប់ដល់នាងសាមានោះ ។ កាលនោះ សេដ្ឋីបុត្តម្នាក់ មានចិត្តប្រតិព័ទ្ធនឹងនាងសាមា ឲ្យទ្រព្យមួយថ្ងៃមួយពាន់រាល់ថ្ងៃ ។ ថ្ងៃនោះសេដ្ឋីបុត្តនោះបានយកទ្រព្យមួយពាន់ទៅកាន់ផ្ទះនោះ ក្នុងពេលព្រះអាទិត្យអស្តង្គត ។ ចំណែកនាងសាមា ទទួលទ្រព្យមួយពាន់ ហើយដាក់ត្រង់ភ្លៅអង្គុយយំ កាលសេដ្ឋីបុត្តនោះពោលថា នែនាង តើមានរឿងអ្វី ទើបពោលថា បពិត្រអ្នក ចោរនេះជាបងប្រុសខ្ញុំ គាត់មិនមកកាន់សម្នាក់ខ្ញុំដោយគិតថា អញធ្វើកម្មគ្រោតគ្រាត កាលខ្ញុំបញ្ជូនដំណឹងដល់អ្នករក្សាព្រះនគរ អ្នករក្សាព្រះនគរ បញ្ជូនដំណឹងមកថា យើងបានទ្រព្យមួយពាន់ ទើបលែង ឥឡូវនេះ ខ្ញុំបានទ្រព្យមួយពាន់នេះហើយ តែមិនបានឱកាសទៅកាន់សម្នាក់របស់ភ្នាក់ងារអ្នករក្សានគរ ។ ព្រោះមានចិត្តប្រតិព័ទ្ធក្នុងនាង សេដ្ឋីបុត្តនោះ ក៏ពោលថា ខ្ញុំនឹងយកទៅឲ្យ ។ នាងសាមាពោលថា បើយ៉ាងនោះ សូមអ្នកកាន់ទ្រព្យដែលនាំមកនោះឯងទៅចុះ ។ សេដ្ឋីបុត្តនោះកាន់យកទ្រព្យមួយពាន់នោះ ទៅកាន់ផ្ទះភ្នាក់ងារអ្នករក្សាព្រះនគរ ។ អ្នករក្សាព្រះនគរនោះឃាត់សេដ្ឋីបុត្តនោះទុកក្នុងទីដែលបិទជិត ហើយឲ្យចោរអង្គុយក្នុងយានដែលបិទជិតបញ្ជូនទៅឲ្យនាងសាមា ហើយធ្វើការអះអាងថា ចោរនេះជាចោរល្បីល្បាញក្នុងដែន ត្រូវរង់ចាំឲ្យងងឹតសិន សឹមយើងសម្លាប់ចោរនោះ ក្នុងពេលដែលគ្មានមនុស្ស ហើយបញ្ឈប់មួយស្របក់ កាលអស់មនុស្សហើយ ទើបនាំសេដ្ឋីបុត្តទៅកាន់ទីសម្លាប់ ដោយការរក្សាយ៉ាងតឹងរឹង ហើយយកដាវកាត់ក្បាល ដោតដោយលំពែងហើយទៅកាន់ព្រះនគរ ។

តាំងអំពីនោះមក នាងសាមាមិនបានទទួលរបស់ណាមួយអំពីដៃអ្នកដទៃ អភិរម្យជាមួយចោរនោះឯង ។ ចោរនោះគិតថា បើស្រីនេះមានចិត្តប្រតិព័ទ្ធក្នុងប្រុសដទៃសោត សូម្បីអញក៏នាងធ្វើដូចសេដ្ឋីបុត្ត ហើយអភិរម្យនឹងប្រុសដទៃនោះប៉ុណ្ណោះ ស្រីនេះទ្រុស្តមិត្តដោយចំណែកមួយ អញមិនគួរនៅក្នុងទីនេះ គួរប្រញាប់ទៅកាន់ទីដទៃ តែកាលទៅមិនគួរទៅដៃទទេ នឹងយកគ្រឿងអាភរណៈរបស់ស្រីនេះទៅដែរ ។ ថ្ងៃមួយទើបបបួលនាងសាមាថា នាងដ៏ចម្រើន យើងទាំងឡាយនៅតែក្នុងផ្ទះ ដូចមាន់នៅក្នុងទ្រុង ពួកយើងនឹងទៅលេងក្នុងឧទ្យានមួយថ្ងៃ ។ នាងសាមានោះទទួលថា សាធុ ហើយចាត់ចែងរបស់ទាំងពួង មានរបស់ទំពានិងរបស់បរិភោគជាដើម ប្រដាប់ដោយអាភរណៈទាំងពួង អង្គុយក្នុងយានដែលបិទជិត ជាមួយចោរនោះ ហើយទៅកាន់ឧទ្យាន ។ ចោរនោះលេងជាមួយនាងសាមានោះក្នុងឧទ្យាននោះ ក៏គិតថា អញគួរគេចទៅក្នុងឥឡូវនេះ ទើបធ្វើដូចជាត្រូវការរួមអភិរម្យដោយកិលេសជាមួយនាងសាមានោះ ក៏នាំចូលទៅរវាងគុម្ពច្បារមួយកន្លែង ធ្វើជាឱបនាងសាមានោះ ហើយទើបចាប់សង្កត់ធ្វើឲ្យសន្លប់ ហើយដោះគ្រឿងអាភរណៈទាំងពួង យកសំពត់ដណ្តប់របស់នាងនោះឯង ចងជាបង្វេច មានកណ្ឋៈទុកត្រង់ក លោតផ្លោះរបងឧទ្យានគេចទៅ ។ ចំណែកនាងសាមានោះបាននូវស្មារតី ក្រោកឡើងមកកាន់សម្នាក់របស់ពួកស្រីបម្រើហើយសួរថា អយ្យបុត្តទៅណា ពួកស្រីបម្រើពោលថា ពួកខ្ញុំមិនដឹងឡើយ ។ នាងសាមាគិតថា ប្តីរបស់អញសម្គាល់ថាអញស្លាប់ទើបខ្លាចហើយរត់គេចទៅ កើតទោមនស្ស

ក្នុងចិត្ត ទើបចេញអំពីឧទ្យាននោះឯង ទៅកាន់ផ្ទះគិតថា តាំងអំពីកាលដែលអញមិនបានជួបប្តីជាទីស្រឡាញ់ អញនឹងមិនដេកលើដំណេក ដែលប្រដាប់តាក់តែង ដេកតែត្រង់ផ្ទៃខាងក្រោម ។ តាំងអំពីនោះមក នាងមិនស្លៀកសំពត់សាដកដែលគាប់ចិត្ត មិនបរិភោគអាហារពីរពេល មិនប៉ះរបស់ក្រអូបនិងកម្រងផ្កាជាដើម គិតថា អញនឹងស្វែងរកអយ្យបុត្តដោយឧបាយណាមួយហើយឲ្យហៅត្រឡប់មក ទើបហៅអ្នករបាំមកឲ្យទ្រព្យមួយពាន់ កាលពួកអ្នករបាំពោលថា បពិត្រអ្នកនាង ពួកខ្ញុំនឹងធ្វើអ្វី ទើបនាងពោលថា ឈ្មោះថាទីដែលពួកអ្នកមិនបានទៅ មិនមាន អ្នកទាំងឡាយកាលត្រាច់ទៅកាន់គាមនិគមនិងរាជធានីសម្តែងសិល្បៈ គប្បីច្រៀងបទនេះមុន ក្នុងមណ្ឌលសម្រាប់លេង កាលឲ្យពួកអ្នករបាំសិក្សាទើបពោលគាថាទី ១ ប្រាប់ថា កាលពួកអ្នកច្រៀងបទនេះ បើមានបុរសម្នាក់នៅខាងក្នុងបរិស័ទនោះ គាត់នឹងពោលជាមួយអ្នក កាលបើដូច្នោះ គប្បីប្រាប់ដល់ភាពដែលខ្ញុំ សុខសប្បាយហើយនាំគាត់មក បើគាត់មិនមក ពួកអ្នកគប្បីឲ្យដំណឹងមក ដូច្នេះ ហើយប្រគល់ស្បៀងសម្រាប់ធ្វើដំណើរឲ្យ ហើយបញ្ជូនពួកអ្នករបាំទៅ ។ ពួកអ្នករបាំទាំងនោះចេញអំពីនគរពារាណសី លេងក្នុងទីនោះៗ បានទៅដល់បច្ចន្តគ្រាមមួយ ។ ចោរនោះក៏គេចទៅនៅក្នុងបច្ចន្តគ្រាមនោះ ពួកអ្នករបាំទាំងនោះ កាលសម្តែងនូវការលេងក្នុងទីនោះ ទើបនាំគ្នាច្រៀងបទនេះមុនដោយសេចក្តីថា

អ្នកឱបរឹតនាងសាមាណា ដោយដើមដៃក្បែរគុម្ពច្បាទាំងឡាយ

មានផ្កាក្រហម ដូចពន្លឺព្រះអាទិត្យក្នុងវសន្តសម័យ ( ហើយ

រត់ទៅ ឥឡូវនេះ ) នាងសាមានោះប្រាប់មកអ្នក ( ថានាង )
មិនមានរោគទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កណវេរេសុ** គឺ **ករវីរេសុ** ប្រែថា ផ្កាច្បា ។ បទថា **ភាណុសុ** បានដល់ សម្បុរដោយពណ៌ក្រហមនៃផ្កាក្រហម ។ បទថា **សាមំ** បានដល់ ដែលមានឈ្មោះយ៉ាងនោះ ។ បទថា **បីឡេសិ** សេចក្ដីថា អ្នកឱបរឹត ដូចបុគ្គលបំណងនឹងរួមអភិរម្យដោយកិលេស គឺឱបដូច្នោះ ។ បទថា **សា តំ** សេចក្ដីថា នាងសាមានោះមិនមានរោគ តែអ្នកសម្គាល់ថានាងស្លាប់ ទើបខ្លាចគេចទៅ នាងបានពោល គឺប្រាប់ដល់ការដែលនាងមិនមានរោគ ។

ចោរបានស្ដាប់ចម្រៀងនោះ ទើបចូលទៅរកអ្នករបាំហើយពោលថា អ្នកពោលថា សាមាមានជីវិតតែខ្ញុំមិនជឿឡើយ កាលចរចានឹងអ្នករបាំនោះ ទើបពោលគាថាទី ២ ថា

នៃនាងដ៏ចម្រើន បានឮថា ខ្យល់បក់ផាត់ភ្នំ ដោយហេតុណា
ខ្ញុំមិនគប្បីជឿនូវហេតុនោះទេ បើខ្យល់បក់ផាត់ភ្នំបាន បក់ផាត់
ផែនដីទាំងមូលក៏បានដែរ នាងសាមាណា ស្លាប់ទៅហើយ អ្នក
ពោលថា នាងសាមានោះ មិនមានរោគ ( ខ្ញុំមិនគប្បីជឿទេ )
ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអត្ថថា នៃអ្នករបាំដ៏ចម្រើន បានឮថា ខ្យល់បក់ភ្នំ ដូចស្មៅនិងស្លឹកឈើនេះ បុគ្គលណាក៏មិនជឿ បើខ្យល់គប្បីបក់ភ្នំទៅ

បាន ផែនដីទាំងមូលក៏គង់បក់ទៅបាន សេចក្តីនេះបុគ្គលណាមួយមិនគប្បីជឿ ដូចយើងមិនជឿដំណឹងនាងសាមានោះ ។ បទថា **យត្ថ សាមា កាលកតា** សេចក្តីថា នាងសាមាធ្វើកាលកិរិយាទៅហើយ នឹងសួរការមិនមានរកេគដល់យើងបានឯង ។ សួរថា ព្រោះហេតុអ្វីទើបមិនជឿ ឆ្លើយថា ព្រោះធម្មតាអ្នកដែលស្លាប់ហើយ នឹងឲ្យដំណឹងដល់បុគ្គលណាមួយមិនបាន ។

អ្នករបាំបានស្តាប់ពាក្យចោរនោះហើយ ក៏ពោលគាថាទី ៣ ថា

នាងសាមានោះ មិនស្លាប់ផង នាងមិនចង់បានបុរសដទៃផង
ឮថានាងសាមាមានប្តីតែមួយ នាងចង់បានតែប្តីនោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមេវ អភិកង្ខតិ** សេចក្តីថា នាងមិនប្រាថ្នាប្រុសដទៃ ទន្ទឹង គឺត្រូវការ ប្រាថ្នាចំពោះលោកប៉ុណ្ណោះ ។ ចោរបានស្តាប់ដូច្នោះទើបពោលថា ទោះនាងមានជីវិតក្តី មិនមានជីវិតក្តី យើងមិនត្រូវការនាងទេ ហើយពោលគាថាទី ៤ ថា

នាងសាមាប្តូរយកខ្ញុំ ដែលមិនធ្លាប់ស្និទ្ធស្នាល ដោយប្តីដែល
ស្និទ្ធស្នាលអស់កាលយូរ ប្តូរយកខ្ញុំជាប្តីមិនពិតប្រាកដ ដោយ
ប្តីពិតប្រាកដ នាងសាមាមុខតែប្តូរយកបុរសដទៃ ខ្ញុំនឹងទៅកាន់
ទីឆ្ងាយ លើសពីនេះទៅទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសន្ថុតំ** បានដល់ ដែលមិនទាន់បានធ្វើនូវការស្និទ្ធស្នាល ។ បទថា **ចិរសន្ថុតេន** បានដល់ បុរសដែលបានធ្វើសេចក្តីស្និទ្ធស្នាលមកអស់កាលយូរ ។ បទថា **និមិនិ** ប្រែថា ដោះដូរ ។

បទថា **អច្ឆរំ ធុវេន** សេចក្ដីថា នាងសាមាបានឲ្យទ្រព្យមួយពាន់ដល់អ្នករក្សានគរ ហើយទទួលយកយើងមក ដើម្បីជួរយើងដែលមិនធ្លាប់ជាប្ដីនោះ ។ បទថា **មយាបិ សាមា និមិនេយ្យ អញ្ញំ** សេចក្ដីថា នាងសាមាគប្បីដូរយើងយកប្ដីដទៃ ។ ដោយបទថា **ឥតោ អហំ ទូរតរំ** នេះ ចោរពោលថា យើងនឹងទៅឲ្យឆ្ងាយដែលមិនអាចបានឮដំណើងឬការ ប្រព្រឹត្តទៅរបស់នាងសាមានោះ ព្រោះហេតុនោះ អ្នកទាំងឡាយចូរប្រាប់កាពដែលយើងទៅអំពីទីនេះទៅកាន់ទីដទៃ ដល់នាងសាមានោះ កាលអ្នករបាំទាំងនោះកំពុងឃើញនោះឯង បានស្លៀកសំពត់យ៉ាងខ្ជាប់ ហើយប្រញាប់គេចទៅ ។ អ្នករបាំទាំងឡាយ បានមកប្រាប់អាការៈកិរិយាដែលចោរនោះធ្វើដល់នាងសាមានោះ ។ នាងជាអ្នកមានវិប្បដិសារៈក្ដៅក្រហាយចិត្ត ទើបញ៉ាំងកាលវេលាឲ្យកន្លងទៅដោយប្រក្រតីរបស់ខ្លួននោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកនឹកដល់ភរិយាចាស់ក៏តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា សេដ្ឋីបុត្តក្នុងកាលនោះ បានមកជាភិក្ខុរូបនេះក្នុងកាលឥឡូវនេះ នាងសាមាក្នុងកាលនោះ បានមកជាភរិយាចាស់ ចំណែកចោរក្នុងកាលនោះ គឺតថាគតនេះឯង ។

### អដ្ឋកថា កណវេរជាតក ចប់

# តិត្តិរជាតក

[ ៥៧៤ ] ( សត្វទទាសួរតាបសពោធិសត្វថា ) ខ្ញុំរស់នៅជាសុខសប្បាយណាស់ ទាំងបានបរិភោគ ( ដោយស្រួល ) តែខ្ញុំឋិតនៅក្នុងសេចក្ដីអន្តរាយ បពិត្រលោកដ៏ចម្រើន តើគតិរបស់ខ្ញុំដូចម្ដេច ។

[ ៥៧៥ ] ( ព្រះពោធិសត្វឆ្លើយថា ) ម្នាលចៅបក្សី បើចិត្តរបស់អ្នកមិនបង្អោនទៅរកអំពើបាបទេ បាបក៏មិនប្រឡាក់នូវអ្នកដ៏ចម្រើនដែលជាអ្នកមិនខ្វល់ខ្វាយឡើយ ។

[ ៥៧៦ ] ( ទទាពោលថា ) សត្វទទាជាច្រើនមក ព្រោះគិតថា ញាតិយើងទំនៅ ( ត្រង់ទីនោះ ) ព្រានប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យខ្ញុំ ចិត្តរបស់ខ្ញុំក៏រង្កៀសក្នុងរឿងនោះ ។

[ ៥៧៧ ] ( ពោធិសត្វពោលថា ) ព្រានមិនប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យអ្នកទេ បើចិត្តអ្នកមិនប្រទូស្ត បាបមិនប្រឡាក់នូវអ្នកដ៏ចម្រើនដែលមិនមានសេចក្ដីខ្វល់ខ្វាយឡើយ ។

**ចប់ តិត្តិរជាតកទី ៩ ។**

# អដ្ឋកថា
# តិត្តិរជាតក

[ ៥៧៤-៥៧៧ ] ព្រះសាស្តាកាលគង់នៅក្នុងនគរកោសម្ពី នាពទរិការាម ទ្រង់ប្រារព្ធព្រះរាហុលត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សុ-សុខំ វត ជីវាមិ** ដូច្នេះជាដើម ។

រឿងបានពណ៌នាទុកពិស្តារហើយ ក្នុងតិបល្លត្ថជាតកខាងដើមនោះឯង ។ តែក្នុងទីនេះ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាដល់គុណរបស់ព្រះរាហុលត្ថេរក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះរាហុលជាអ្នកប្រាថ្នាចំពោះការសិក្សា មានសេចក្តីរង្កៀសក្នុងបាបកម្ម អត់ធន់ចំពោះឱវាទ ។ ព្រះសាស្តា យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន រាហុលក៏ស្រឡាញ់ចំពោះការសិក្សារង្កៀសក្នុងបាបកម្ម អត់ធន់ចំពោះឱវាទ ដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយ ក៏រៀនសិប្បៈទាំងពួងក្នុងនគរតក្កសិលា ហើយចេញបួសជាឥសីក្នុងហិមវន្តប្បទេស បានធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតហើយ ជាអ្នកលេងឈានក្នុងដងព្រៃដែលគួរជាទីត្រេកអរ លុះត្រូវការសេពរស់ជូរប្រៃ បានទៅកាន់បច្ចន្តគាមមួយកន្លែង ។

មនុស្សទាំងឡាយក្នុងបច្ចន្តគាម ឃើញព្រះពោធិសត្វហើយ កាលជ្រះថ្លាទើប សាងបណ្ណសាលាក្នុងព្រៃមួយកន្លែង ហើយនិមន្តឲ្យនៅ ទំនុកបម្រុងដោយបច្ច័យទាំងឡាយ ។ កាលនោះមាននាយព្រានម្នាក់ក្នុងស្រុកនោះ ចាប់សត្វទទាដែលជាទទាឈ្មោលបានមួយ ឲ្យសិក្សាយ៉ាងល្អហើយចិញ្ចឹមទុក ។ ព្រាននោះ តែងនាំទទាឈ្មោលនោះទៅព្រៃ ហើយចាប់ពួកទទាដែលនាំគ្នាមក ព្រោះសំឡេងទទាឈ្មោលនោះ លក់ដូរចិញ្ចឹមជីវិត ។ គ្រានោះ ទទានោះគិតថា ញាតិរបស់អញជាច្រើនវិនាស ព្រោះអាស្រ័យអញនេះឯង នុ៎ះជាបាបរបស់អញ ដូច្នេះហើយ ទើបមិនរងាវ ។ ព្រានដឹងថាទទាឈ្មោលនោះមិនរងាវ ទើបយកមែកឬស្សីវាយក្បាលទទាឈ្មោលនោះ ទទាក៏យំព្រោះក្តៅក្រហាយដោយសេចក្តីទុក្ខ ។ ព្រានព្រៃនោះអាស្រ័យទទានោះ ចាប់ទទាទាំងឡាយចិញ្ចឹមជីវិតដោយប្រការយ៉ាងនោះ ។ លំដាប់នោះ ទទានោះគិតថា អញមិនមានចេតនាថា ទទាទាំងនេះចូរស្លាប់ តែបដិច្ចកម្ម ( កម្មដែលអាស្រ័យ ) គង់ពាល់ត្រូវលើអញ បើអញមិនយំសត្វទាំងនេះ ក៏មិនមក លុះណាតែអញយំទើបមក ព្រានព្រៃចាប់ញាតិអញដែលមកហើយសម្លាប់ ក្នុងសេចក្តីនេះ បាបមានដល់អញដែរឬហ្ន៎ ។ ចាប់តាំងអំពីនោះ សត្វទទានោះគិតថា នរណាហ្ន៎នឹងកាត់សង្ស័យនេះរបស់អញបាន ដូច្នេះហើយ ទើបពិចារណារកបណ្ឌិតបែបនេះ ។ ថ្ងៃមួយព្រានបក្សីនោះចាប់ទទាបានជាច្រើនដាក់ពេញទ្រុង គិតថា អញនឹងផឹកទឹក ទើបទៅកាន់អាស្រមរបស់ព្រះពោធិសត្វ ដាក់ទ្រុងទទាឈ្មោលនោះ ក្នុងសម្នាក់របស់ព្រះពោធិសត្វ ផឹកទឹកហើយដេកត្រង់ដីខ្សាច់លក់ទៅ ។ ទទាដឹងថាព្រានដេក

លក់ ក៏គិតថា អញនឹងសួរសេចក្តីសង្ស័យរបស់អញនឹងតាបសនេះបើលោក ដឹងនឹងប្រាប់អញ ដូច្នេះហើយ ទំក្នុងទ្រុងនោះឯង កាលនឹងសួរតាបសនោះ ទើបពោលគាថាទី ១ ថា

ខ្ញុំរស់នៅជាសុខ សប្បាយណាស់ ទាំងបានបរិភោគ ( ដោយ ស្រួល ) តែខ្ញុំឋិតនៅក្នុងសេចក្តីអន្តរាយ បពិត្រលោកដ៏ចម្រើន តើគតិរបស់ខ្ញុំដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុសុខំ វត** សេចក្តីថា បពិត្រលោកដ៏ចម្រើន ខ្ញុំអាស្រ័យព្រានបក្សីនេះរស់នៅជាសុខសប្បាយ ។ បទថា **លភាមិ ចេវ** សេចក្តីថា ខ្ញុំបានបរិភោគរបស់គួរទំពា គួរបរិភោគតាមគាប់ចិត្ត ។ បទថា **បរិបន្ថេវ តិដ្ឋាមិ** សេចក្តីថា តែញាតិទាំងឡាយរបស់ខ្ញុំដែលនាំគ្នាមកហើយ ដោយសំឡេងរបស់ខ្ញុំរមែងវិនាសទៅព្រោះអន្តរាយណា ខ្ញុំតាំងនៅក្នុងអន្តរាយ នោះ ។ ដោយបទថា **កា នុ ភន្តេ** នេះ សត្វទទាសួរថា លោកដ៏ចម្រើន គតិរបស់ខ្ញុំដូចម្តេចហ្ន៎ គឺការសម្រេចផលអ្វីនឹងមានដល់ខ្ញុំ ។

ព្រះពោធិសត្វ កាលនឹងឆ្លើយបញ្ហារបស់សត្វទទានោះ ទើបពោលគាថា ទី ២ ថា

ម្នាលចៅបក្សី បើចិត្តរបស់អ្នក មិនបង្អោនទៅរកអំពើបាបទេ បាបក៏មិនប្រឡាក់នូវអ្នកដ៏ចម្រើន ដែលជាអ្នកមិនខ្វល់ខ្វាយ ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាបស្ស កម្មុនោ** សេចក្តីថា បើចិត្តរបស់

អ្នកមិនបង្អោនទៅដើម្បីប្រយោជន៍ដល់បាបកម្ម គឺមិនបង្អោនទៅក្នុងការធ្វើបាប ។ បទថា **អចាវជស្ស** សេចក្តីថា កាលបើដូច្នោះបាបរមែងមិនប្រឡាក់ គឺមិនជាប់បុគ្គលដែលមិនខ្វល់ខ្វាយ គឺមិនដល់នូវការខ្វល់ខ្វាយដើម្បីធ្វើបាបកម្ម ជាបុគ្គលបរិសុទ្ធនោះឯង ។ សត្វទទាបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ៣ ថា

សត្វទទាជាច្រើនមក ព្រោះគិតថា ញាតិយើងទំនៅ ( ត្រង់
ទីនោះ ) ព្រានប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យខ្ញុំ
ចិត្តរបស់ខ្ញុំ ក៏រង្កៀសក្នុងរឿងនោះ ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអធិប្បាយថា លោកដ៏ចម្រើន បើខ្ញុំមិនធ្វើសំឡេង សត្វទទាទាំងនេះនឹងមិនមក តែកាលខ្ញុំធ្វើសំឡេង សត្វទទាជាច្រើននេះ មកដោយគិតថា ញាតិរបស់អញទំក្នុងទីនោះ នាយព្រានចាប់ទទាដែលមកនោះសម្លាប់ ឈ្មោះថារមែងពាល់ត្រូវ គឺបានជួបនូវកម្ម គឺបាណាតិបាតនេះ ព្រោះអាស្រ័យខ្ញុំ ព្រោះហេតុនោះ ទើបចិត្តរបស់ខ្ញុំរង្កៀស គឺដល់នូវការរង្កៀស យ៉ាងនេះថា នាយព្រានធ្វើបាបព្រោះអាស្រ័យខ្ញុំ បាបនេះនឹងមានដល់ខ្ញុំដែរឬហ្ន៎ ។ ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបពោលគាថាទី ៤ ថា

ព្រានមិនប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យអ្នកទេ
បើចិត្តអ្នកមិនប្រទូស្ត[១]បាបមិនប្រឡាក់នូវអ្នកដ៏ចម្រើន ដែល
មិនមានសេចក្តីខ្វល់ខ្វាយឡើយ ដូច្នេះ ។

---

១-គួរប្រែថា បើចិត្តអ្នកមិនប្រទូស្ត បាណាតិបាតកម្ម ដែលព្រានអាស្រ័យអ្នកធ្វើហើយ រមែងមិនប៉ះពាល់អ្នកទេ ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បើចិត្តរបស់អ្នកមិនប្រទូស្ត ព្រោះកិរិយាធ្វើបាប គឺមិនបង្អោន មិនទោរទន់ មិនឈមទៅក្នុងការធ្វើបាបនោះ កាលបើដូច្នោះ កម្មដែលនាយព្រានអាស្រ័យអ្នកធ្វើរមែងមិនពាល់ត្រូវ គឺមិនប្រឡាក់អ្នកព្រោះបាបនោះ រមែងមិនប្រឡាក់ គឺមិនជាប់ចិត្តរបស់អ្នកដែលមានសេចក្តីខ្វល់ខ្វាយតិច គឺមិនមានការជាប់ជំពាក់ក្នុងការធ្វើបាប អ្នកចម្រើនជាអ្នកបរិសុទ្ធ ព្រោះអ្នកមិនមានចេតនាក្នុងបាណាតិបាត ។

ព្រះពោធិសត្វ ធ្វើសត្វទទាឲ្យយល់ហើយដោយប្រការយ៉ាងនេះចំណែកសត្វទទានោះ ក៏បានជាអ្នកអស់សេចក្តីរង្កៀសសង្ស័យ ព្រោះអាស្រ័យព្រះមហាសត្វនោះ ។ ព្រាហ្មណ៍ក្រាក់អំពីដំណេកហើយ ថ្វាយបង្គំព្រះពោធិសត្វកាន់យកទ្រុងទទាហើយចៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា សត្វទទាក្នុងកាលនោះ បានមកជារាហុលក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តិត្តិរជាតក ចប់

# សុចជជាតក

[ ៥៧៨ ] ( នាងទេវីពោលថា ) ព្រះរាជាកាលមិនប្រទានភ្នំ (សូម្បី) ដោយព្រះវាចា ឈ្មោះថា មិនលះបង់នូវរបស់ដែលគួរលះបង់ដោយងាយទេ ( ប្រសិនបើ ) ព្រះរាជាបានប្រទានភ្នំ ( សូម្បី ) ដោយព្រះវាចា ព្រះរាជានោះ ( ដែលខ្ញុំសូមហើយ ) គង់លះបង់វត្ថុខ្លះ ។

[ ៥៧៩ ] ( ព្រះរាជាត្រាស់ថា ) បុគ្គលធ្វើអំពើណា គប្បីនិយាយអំពើនោះ មិនធ្វើអំពើណាមិនគប្បីនិយាយអំពើនោះ ពួកបណ្ឌិតរមែងកំណត់ដឹងនូវបុគ្គលដែលមិនធ្វើ ( គ្រាន់តែ ) និយាយ ។

[ ៥៨០ ] ( ព្រះនាងទេវីពោលថា ) បពិត្រព្រះរាជបុត្ត ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ដែលឋិតនៅក្នុងវចីសច្ចផង ក្នុងសភាវធម៌ផង សូម្បីដល់នូវសេចក្ដីវិនាស ក៏ព្រះហឫទ័យរបស់ព្រះអង្គនៅតែត្រេកអរក្នុងសច្ចៈ ។

[ ៥៨១ ] ( ព្រះពោធិសត្វ សម្ដែងគុណរបស់ព្រះនាងទេវីថា ) ភរិយាណា របស់ប្ដីអ្នកទាល់ក្រ ក៏ជាស្រីទាល់ក្រដែរ របស់ប្ដីអ្នកស្ដុកស្ដម្ភ ក៏ជាស្រីស្ដុកស្ដម្ភ មានកេរ្តិ៍ឈ្មោះដែរ ភរិយានោះឈ្មោះថា ជាភរិយាដ៏ឧត្ដមរបស់ប្ដីនោះ ស្រីទាំងឡាយរបស់អ្នកមានប្រាក់ ( ក៏ដូច្នោះដែរ ) ។

**ចប់ សុចជជាតកទី ១០ ។**

**ចប់ បុចិមន្ទវគ្គទី ២ ។**

### ឧទ្ទាននៃបុចិមន្ទវគ្គនោះគឺ

និយាយអំពីចោរ ១ កស្សបតាបស ១ តាសបខន្តិវាទី ១ ការរស់នៅអាក្រក់ ១ សំដីអាក្រក់ ១ ទន្សាយ ១ បុគ្គលស្លាប់ ១ វសន្តកាល ១ ការរស់នៅជាសុខ ១ ព្រះរាជាមិនលះបង់នូវរបស់ដែលលះបង់ឆាយ ១ ត្រូវជា ១០ ។

## អដ្ឋកថា

## សុចជជាតក

[ ៥៧៨-៥៨១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សុច្ចជំ វត ឆច្ចជិ** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈនោះគិតថានឹងទារបំណុលក្នុងស្រុក ទើបទៅក្នុងស្រុកនោះ មួយអន្លើដោយភរិយា កាលជម្រះបំណុលហើយគិតថា អញនឹងនាំរទេះមកជញ្ជូនតាមក្រោយ ទើបផ្ញើទុកក្នុងត្រកូលមួយ ត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញ បានឃើញភ្នំមួយក្នុងរវាងផ្លូវ ។ កាលនោះភរិយាពោលនឹងកុដុម្ពិកៈនោះថា នៃអ្នក បើភ្នំនេះគប្បីជាមាសសោត អ្នកនឹងឲ្យអ្វីខ្ញុំ កុដុម្ពិកៈពោលថា នាងជានណាដែលខ្ញុំនឹងឲ្យអ្វីនោះ ។ ចំណែកភរិយាតូចចិត្តថា ប្តីរបស់អញនេះ មានចិត្តរឹងត្អឹងណាស់ បានឮថា កាលភ្នំកើតជាមាសក៏គង់មិនឲ្យអ្វីដល់អញ ។ ស្វាមីភរិយាទាំងពីរដើរទៅជិតវត្តជេតពន គិតថានឹងផឹកទឹក ទើប

ចូលទៅកាន់ព្រះវិហារផឹកទឹក ។ ក្នុងបច្ចូសសម័យថ្ងៃនោះឯង ព្រះទសពល ទ្រង់បានឃើញឧបនិស្ស័យនៃសោតាបត្តិផល របស់ជនទាំងពីរនោះ កាល ទ្រង់រង់ចាំការមក ទើបគង់ក្នុងបរិវេណព្រះគន្ធកុដិ ទ្រង់បញ្ចេញព្រះធពណ្ណ- រង្សី ។ ចំណែកជនទាំងពីរគឺស្វាមីភរិយានោះ ផឹកទឹកហើយក៏មកថ្វាយបង្គំ ព្រះសាស្តា ហើយអង្គុយ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈដល់ជនទាំងពីរគឺ ស្វាមីភរិយានោះ ហើយត្រាស់សួរថា អ្នកទាំងពីរទៅណាមកណា កាល ជនទាំងពីរគឺស្វាមីភរិយាក្រាបទូលថា ខ្ញុំព្រះអង្គមកពីទារបំណុល ក្នុងស្រុក ( ឯណោះ ) ។ ព្រះសាស្តាសួរភរិយាបុរសនោះថា ឧបាសិកា ប្តីរបស់នាង ប្រាថ្នាប្រយោជន៍ដល់នាង ធ្វើឧបការៈដល់នាងដែរឬ ភរិយារបស់កុដុម្ពិកៈ ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មានសេចក្តីស្នេហាក្នុងស្វាមីនេះ តែ ស្វាមីនេះ មិនស្រឡាញ់ក្នុងខ្ញុំម្ចាស់ ថ្ងៃនេះកាលខ្ញុំម្ចាស់ឃើញភ្នំហើយពោល ថា បើភ្នំនេះក្លាយជាមាស អ្នកឲ្យអ្វីដល់ខ្ញុំខ្លះដែរឬ គាត់បែរជាពោលថា នាង ជាអ្នកណា យើងមិនឲ្យអ្វីដល់នាងឡើយ ប្តីនេះ ជាមនុស្សមានចិត្តអាក្រក់ យ៉ាងនេះ ។ ព្រះសាស្តាត្រាស់ថា ឧបាសិកា កុដុម្ពិកៈនេះរមែងពោលយ៉ាង នេះឯង តែក្នុងកាលណាគេនឹកដល់គុណ គឺសេចក្តីល្អរបស់នាង ក្នុងកាល នោះ គេនឹងប្រគល់ភាពជាធំទាំងអស់ កាលភរិយារបស់កុដុម្ពិកៈនោះទូលអា- រាធនាថា សូមទ្រង់ត្រាស់ប្រាប់ចុះ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចត ទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី

ព្រះពោធិសត្វបានជាអាមាត្យ សម្រេចរាជកិច្ចទាំងអស់របស់ព្រះបាទព្រហ្មទត្ត នោះ ។ ថ្ងៃមួយ ព្រះរាជាទ្រង់ឃើញព្រះរាជឱរសដែលជាឧបរាជ មកកាន់ទីគាល់ ទ្រង់ត្រិះរិះថា កូននេះទ្រទ្រង់នូវយស នឹងប្រទូសរ៉ាយខាងក្នុងដល់អញ ទើបហៅព្រះរាជឱរសនោះមកត្រាស់ថា នៃកូន ដរាបណាបិតានៅមានជីវិត បាកុំនៅក្នុងព្រះនគរ ចូរនៅក្នុងទីដទៃ អំណឹះតតពីអញទៅហើយ សឹមមកគ្រងរាជសម្បត្តិចុះ ។ ព្រះរាជឱរសទទួលរាជបញ្ជាហើយ ថ្វាយបង្គំព្រះរាជបិតា មួយអន្លើដោយព្រះជេដ្ឋជាយា ចេញអំពីព្រះនគរទៅកាន់ជាយដែនសាងបណ្ណសាលាក្នុងព្រៃ ញុំាងព្រះជន្មឲ្យប្រព្រឹត្តទៅដោយមូលផលាផលក្នុងព្រៃ ។ ចំណេរកាលតមកព្រះរាជាទ្រង់សោយទិវង្គត ឧបរាជដែលជាឱរសទ្រង់មើលនូវផ្កាយនក្ខត្តឫក្ស ដឹងថាព្រះរាជបិតាសោយទិវង្គតហើយ ទើបមកកាន់នគរពារាណសី ក្នុងរវាងផ្លូវបានឃើញភ្នំមួយ ។ លំដាប់នោះ ព្រះជាយាត្រាស់នឹងព្រះរាជឱរសនោះថា បពិត្រទេវៈ បើភ្នំនេះក្លាយជាមាសទ្រង់ប្រទានអ្វីដល់ខ្ញុំម្ចាស់ខ្លះ ព្រះរាជឱរសត្រាស់ថា នាងជាអ្នកណា យើងចាំបាច់ឲ្យអ្វីដល់នាង ។ ព្រះជាយានោះតូចចិត្តថា អញមិនអាចលះបង់ព្រោះស្រឡាញ់ក្នុងព្រះស្វាមីនេះ ទើបទៅកាន់ព្រៃជាមួយ តែស្វាមីនេះត្រាស់យ៉ាងនេះ ជាអ្នកមានព្រះហឫទ័យអាក្រក់ពន់ពេក ស្វាមីនេះ បានជាព្រះរាជាហើយនឹងធ្វើសេចក្ដីល្អដល់អញដូចម្ដេចកើត ។ ព្រះរាជឱរសនោះ យាងមកហើយ តាំងនៅក្នុងរាជសម្បត្តិ ហើយតាំងព្រះជាយានោះក្នុងតំណែងអគ្គមហេសី បានប្រទានត្រឹមយសនេះប៉ុណ្ណោះ ចំណែកការរាប់អាន ការលើកតម្កើងមិនមាន ។

សូម្បីព្រះនាងមានក៏មិនដាក់ព្រះទ័យ ។ ព្រះពោធិសត្វគិតថា ព្រះទេវីមានឧបការៈច្រើនដល់ព្រះរាជា ព្រះនាងមិនបានអើពើដល់សេចក្ដីលំបាក កាលយាងទៅនៅក្នុងព្រៃ តែព្រះរាជានេះមិនបាននឹកដល់ព្រះទេវីឡើយ ត្រាច់អភិរម្យតែនឹងស្ត្រីដទៃៗ អញនឹងធ្វើដោយប្រការដែលព្រះទេវី បាននូវឥស្សរិយយសទាំងពួង ។ ថ្ងៃមួយចូលទៅគាល់ព្រះទេវី ហើយក្រាបទូលថា បពិត្រមហាទេវី ទូលបង្គំមិនបានសូម្បីត្រឹមតែដុំបាយអំពីសម្នាក់ព្រះនាង ព្រោះហេតុអ្វីទើបនាងលះបង់ទូលបង្គំ មានទឹកព្រះហឫទ័យអាក្រក់ពន់ពេក ។ ព្រះទេវីត្រាស់ថា បពិត្រលោកឪពុក បើខ្លួនខ្ញុំបាន ខ្ញុំក៏នឹងឲ្យលោក តែខ្ញុំក៏មិនបាននឹងឲ្យលោកបានដូចម្ដេច មកទល់ឥឡូវនេះ ព្រះរាជានឹងប្រទានដល់ខ្ញុំដូចម្ដេចកើត បពិត្រលោកឪពុក ក្នុងរវាងផ្លូវ កាលខ្ញុំពោលថា បើក្អំនេះក្លាយជាមាសទ្រង់ប្រទានអ្វីដល់ខ្ញុំម្ចាស់ខ្លះ ព្រះរាជានោះត្រាស់ថា នាងជាអ្នកណាយើងមិនឲ្យអ្វីដល់នាងឡើយ សូម្បីរបស់ដែលបរិច្ចាគបានងាយៗ ទ្រង់ក៏មិនបរិច្ចាគ ។ ព្រះពោធិសត្វក្រាបទូលថា តើព្រះនាងអាច ត្រាស់រឿងនេះក្នុងទីចំពោះព្រះភក្ត្រព្រះរាជាបានឬទេ ព្រះទេវីត្រាស់ថា រឿងអ្វីដែលមិនបាននោះព្រះពោធិសត្វបានក្រាបទូលថា បើយ៉ាងនោះកាលណាទូលបង្គំនៅក្នុងសម្នាក់របស់ព្រះរាជា ហើយទូលសួរព្រះនាង សូមព្រះនាង ត្រាស់រឿងនេះចុះ ។ ព្រះទេវីទទួលថា សាធុ ។ ក្នុងពេលដែលព្រះទេវី យាងទៅគាល់ព្រះរាជាហើយប្រថាប់ឈរ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះនាង ទូលបង្គំមិនបានអ្វីអំពីសម្នាក់ព្រះនាងសោះមិនមែនឬ ព្រះទេវីត្រាស់ថា បពិត្រលោកឪ

ពុក បើខ្ញុំមិនបាន តើនឹងឲ្យលោកបានដូចម្តេច ឥឡូវនេះ ព្រះរាជានឹងឲ្យខ្ញុំដូចម្តេចកើត ព្រោះថា ក្នុងវេលាមកអំពីព្រៃ ព្រះរាជាទ្រង់ឃើញក្អំមួយកាលខ្ញុំទូលថា បើក្អំនេះក្លាយជាមាស ទ្រង់នឹងប្រទានអ្វីដល់ខ្ញុំម្ចាស់ខ្លះ ព្រះអង្គគង់ត្រាស់ថា នាងជាអ្នកណា យើងមិនឲ្យអ្វីនាងឡើយ សូម្បីរបស់ដែលលះបង់បានងាយ ៗ ក៏ទ្រង់មិនលះបង់ កាលព្រះនាងសម្តែងសេចក្តីនេះ ទើបត្រាស់គាថាទី ១ ថា

ព្រះរាជាកាលមិនប្រទានក្អំ (សូម្បី) ដោយព្រះវាចា ឈ្មោះ
ថា មិនលះបង់នូវរបស់ដែលគួរលះបង់ដោយងាយទេ ( ប្រ-
សិនបើ ) ព្រះរាជាបានប្រទានក្អំ ( សូម្បី ) ដោយព្រះវាចា
ព្រះរាជានោះ ( ដែលខ្ញុំសូមហើយ ) គង់លះបង់វត្ថុខ្លះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុច្ចជំ វត** សេចក្តីថា ឈ្មោះថាទ្រង់មិនលះសូម្បីវត្ថុដែលលះបានដោយងាយ ។ បទថា **អទទំ** បានដល់ មិនព្រះរាជទានក្អំដោយគ្រាន់តែវាចា ។ បទថា **កិញ្ចិ តស្ស ចជន្តស្ស** សេចក្តីថា កាលព្រះរាជានោះដែលខ្ញុំទូលសូមហើយ ទ្រង់បានលះក្អំនោះ ឈ្មោះថាទ្រង់លះអ្វីខ្លះ ។ បទថា **វាចាយ អទទំ បព្វតំ** សេចក្តីថា បើព្រះរាជានេះ កាលខ្ញុំទូលសូមហើយ បានព្រះរាជទានក្អំនោះ ដែលជាមាសតាមពាក្យរបស់ខ្ញុំដោយវាចា គឺបានព្រះរាជទាន ដោយត្រឹមតែព្រះតម្រាស់ ។ ព្រះរាជាបានស្តាប់ដូច្នេះ ក៏ត្រាស់គាថាទី ២ ថា

បុគ្គលធ្វើអំពើណា គប្បីនិយាយអំពើនោះ មិនធ្វើអំពើណា

មិនគប្បីនិយាយអំពើនោះពួកបណ្ឌិតរមែងកំណត់ដឹងនូវបុគ្គល
ដែលមិនធ្វើ ( គ្រាន់តែ ) និយាយ ដូច្នេះ ។

ពាក្យដែលជាគាថានោះមានសេចក្តីថា បុគ្គលដែលជាបណ្ឌិតធ្វើវត្ថុណាដោយកាយ គប្បីពោលដល់វត្ថុនោះដោយវាចា សូម្បីវត្ថុណាមិនបានធ្វើ ក៏រមែងមិនពោលវត្ថុនោះ អធិប្បាយថា បំណងនឹងឲ្យក៏គួរពោលថាឲ្យ មិនបំណងនឹងឲ្យមិនគួរពោលថាឲ្យ ព្រោះហេតុអ្វី ព្រោះបុគ្គលណា សូម្បីពោលថាឲ្យ ខាងក្រោយមិនបានឲ្យ បណ្ឌិតទាំងឡាយរមែងកំណត់ដឹង បុគ្គលនោះថាមិនធ្វើ គឺល្អតែពាក្យប៉ុណ្ណោះ អធិប្បាយថា បុគ្គលពោលត្រឹមតែវាចាថាយើងនឹងឲ្យ តែមិនបានឲ្យ តែថាវត្ថុណា ទោះបីមិនបានឲ្យដោយកាយ តែឲ្យត្រឹមតែវាចាប៉ុណ្ណោះ វត្ថុនោះឈ្មោះថា យកជាការបានដូចម្តេច បណ្ឌិតទាំងឡាយរមែងដឹងថា បុគ្គលនោះជាអ្នកពោលកុហកដោយប្រការដូចពោលនេះ តែបុគ្គលល្ងង់ខ្លៅទាំងឡាយ រមែងត្រេកអរត្រឹមតែវាចាប៉ុណ្ណោះ ។ ព្រះទេវីបានស្តាប់ដូច្នោះ ក៏ផ្គងអញ្ជលីចំពោះព្រះរាជា ហើយត្រាស់គាថាទី ៣ ថា

បពិត្រព្រះរាជបុត្ត ខ្ញុំសូមថ្វាយបង្គំព្រះអង្គដែលឋិតនៅក្នុងវិថី
សច្ចផង ក្នុងសភាវធម៌ផង សូម្បីដល់នូវសេចក្តីវិនាស ក៏ព្រះ
ហឫទ័យរបស់ព្រះអង្គនៅតែត្រេកអរក្នុងសច្ចៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សច្ចេ ធម្មេ** បានដល់ ក្នុងវិថីសច្ចៈ និងសភាវធម៌ ។ បទថា **ព្យសនំ បត្តោ** សេចក្តីថា ព្រះហឫទ័យរបស់ទ្រង់ទោះបីដល់នូវសេចក្តីវិនាស ពោលគឺត្រូវបណ្តេញអំពីដែន ក៏នៅតែត្រេកអរក្នុង

សច្ចៈនោះឯង ។

ព្រះពោធិសត្វ បានស្តាប់ព្រះសវនីយ៍របស់ព្រះទេវី ដែលត្រាស់គុណរបស់ព្រះរាជាយ៉ាងនោះ កាលប្រកាសគុណរបស់ព្រះទេវី ក៏ពោលគាថាទី ៤ ថា

កិរិយាណា របស់ប្តីអ្នកទាល់ក្រ ក៏ជាស្រីទាល់ក្រដែរ របស់
ប្តីអ្នកស្តុកស្តម្ភ ក៏ជាស្រីស្តុកស្តម្ភ មានកេរ្តិ៍ឈ្មោះដែរ កិរិយា
នោះឈ្មោះថា ជាកិរិយាដ៏ឧត្តមរបស់ប្តីនោះ ស្រីទាំងឡាយ
របស់អ្នកមានប្រាក់ ( ក៏ដូច្នោះដែរ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិត្តិមា** សេចក្តីថា ដល់ព្រមដោយកិត្តិយស ។ បទថា **សា ហិស្ស បរមា** សេចក្តីថា ស្រីណា ក្នុងកាលប្តីជាអ្នកក្រីក្រ សូម្បីខ្លួនឯងជាអ្នកក្រីក្រក៏មិនលះបង់ប្តីនោះ ។ បទថា **អឌ្ឍស្ស** សេចក្តីថា កាលប្តីស្តុកស្តម្ភក៏ជាអ្នកស្តុកស្តម្ភ អនុវត្តតាមប្តី ជាអ្នករួមសុខរួមទុក្ខជាមួយ ។ ស្រីនោះឯងឈ្មោះថាជាកិរិយាដ៏កំពូលរបស់បុរសនោះ ។ បទថា **សហិរញ្ញស្ស** សេចក្តីថា កាលប្តីមានប្រាក់ តាំងនៅក្នុងភាពជាធំ ស្រីកិរិយាទាំងឡាយក៏រមែងមានប្រាក់ដែរ នោះមិនគួរអស្ចារ្យឡើយ ។

ឯព្រះពោធិសត្វកាលពោលយ៉ាងនេះហើយ ទើបពោលគុណរបស់ព្រះទេវីថា បពិត្រមហារាជ ព្រះទេវីនេះ កាលទ្រង់មានទុក្ខ ព្រះនាងក៏រួមទុក្ខក្នុងព្រៃ ទ្រង់គួរធ្វើនូវការលើកតម្កើងព្រះទេវីនេះ ។ ព្រះរាជាទ្រង់រឭកដល់គុណរបស់ព្រះទេវីព្រោះវាចារបស់ព្រះពោធិសត្វនោះ ទើបត្រាស់ថា ម្នាលបណ្ឌិត

យើងរឭកដល់គុណរបស់ព្រះទេវីបានព្រោះពាក្យរបស់អ្នក ទើបព្រះរាជទាន ឥស្សរិយយសទាំងពួងដល់ព្រះទេវីនោះហើយត្រាស់ថា អ្នកធ្វើឲ្យខ្ញុំរឭកដល់គុណរបស់ព្រះទេវី ទើបទ្រង់ធ្វើសក្ការៈយ៉ាងធំដល់ព្រះពោធិសត្វ ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយក្នុងកាលចប់សច្ចៈ ជនទាំងពីរគឺស្វាមីនិងភរិយាតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាកុដុម្ពិកៈក្នុងកាលឥឡូវនេះ ព្រះទេវីក្នុងកាលនោះ បានមកជាឧបាសិកា ចំណែកអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុចជជាតក ចប់

## បុចិមន្ទវគ្គ ចប់

# កុដិទូសកវគ្គ

## កុដិទូសកជាតក

[ ៥៨២ ] ( គ្រលេងគ្រលោងពោលថា ) នែពានរ ក្បាល ដៃនិងជើងរបស់អ្នកដូចជាមនុស្សដែរ តែព្រោះហេតុអ្វី បានជាផ្ទះរបស់អ្នកគ្មាន ។

[ ៥៨៣ ] ( ពានរឆ្លើយថា ) នែគ្រលេងគ្រលោង ក្បាល ដៃនិងជើងរបស់ខ្ញុំ ដូចមនុស្សមែនហើយ តែប្រាជ្ញាណាដែលបោរាណាចារ្យពោលថា ប្រសើរក្នុងពួកមនុស្ស ប្រាជ្ញានោះរបស់ខ្ញុំមិនមានទេ ។

[ ៥៨៤ ] ( គ្រលេងគ្រលោងពោលថា ) ធម្មតាអ្នកមានចិត្តមិននឹងនួន មានចិត្តរបិលរប៉ូច ជាអ្នកប្រទូស្តចំពោះមិត្ត មានមារយាទមិនទៀងជានិច្ចតែងមិនមានសេចក្តីសុខ ។

[ ៥៨៥ ] នែពានរ អ្នកនោះចូរធ្វើនូវអានុភាព ( ឲ្យកើតបញ្ញា ) ចូរផ្លាស់មារយាទចេញ ចូរធ្វើខ្ទមជាគ្រឿងការពារនូវត្រជាក់និងខ្យល់ ។

**ចប់ កុដិទូសកជាតកទី ១ ។**

# កុដិទូសកវគ្គ

## អដ្ឋកថា កុដិទូសកជាតក

[ ៥៨២-៥៨៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះ ដុតបណ្ណសាលារបស់ព្រះមហាកស្សបត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មនុស្សស្សេវ តេ សីសំ** ដូច្នេះជាដើម ។

រឿងកើតឡើងក្នុងនគររាជគ្រឹះ ។ បានឮថា ក្នុងកាលនោះ ព្រះថេរៈអាស្រ័យនគររាជគ្រឹះក្នុងអរញ្ញកុដិ ភិក្ខុកំលោះពីររូបឧបដ្ឋាកព្រះថេរៈ ។ ក្នុងភិក្ខុកំលោះពីររូបនោះ មួយរូបជាអ្នកមានឧបការៈដល់ព្រះថេរៈ ចំណែកមួយរូបទៀត ជាភិក្ខុប្រដៅក្រ ធ្វើកិច្ចវត្តដែលភិក្ខុក្រៅអំពីនេះធ្វើ ថាដូចជាខ្លួនឯងធ្វើ កាលភិក្ខុនោះតម្កល់ទឹកខ្ពុរមាត់ជាដើម ខ្លួនឯងទៅកាន់សម្នាក់របស់ព្រះថេរៈ ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ ទឹកខ្ញុំតម្កល់ទុកហើយ សូមលោកម្ចាស់លុបមុខចុះ ។ កាលបរិវេណកុដិដែលភិក្ខុនោះ ក្រោកឡើងអំពីព្រលឹមបោសសម្អាតហើយ ក្នុងពេលព្រះថេរៈចេញមក ខ្លួនឯងបរិហារខាងនេះខាងនោះ ធ្វើបរិវេណទាំងមូលឲ្យដូចជាខ្លួនបោសទុក ។ ភិក្ខុដែលសម្បូរដោយវត្តគិតថា លោកម្ចាស់វិលខូចរូបនេះ យកកិច្ចវត្តដែលអញធ្វើស្រេចថាដូចជាខ្លួនឯងធ្វើ អញនឹងធ្វើកម្មរបស់ភិក្ខុបោកប្រាស់នេះ ឲ្យប្រាកដ ។ កាលភិក្ខុវិលខូចនោះឆាន់ក្នុងស្រុកហើយ មកដេកលើគ្រែរបស់ខ្លួននោះឯង ភិក្ខុដែលសម្បូរដោយវត្ត ក៏ដាំទឹកសម្រាប់ងូតឲ្យក្តៅហើយចាក់ទុកខាងក្រោយបន្ទប់ទឹក ហើយដាំទឹកដទៃប្រមាណកន្ទះនាឡិទុកលើជើងចង្ក្រាន ។ ភិក្ខុវិលខូច ភ្ញាក់អំពីដេកហើយឃើញចំហាយទឹកហុយឡើងគិតថា ភិក្ខុនោះដាំទឹកឲ្យក្តៅហើយ ទើបទៅកាន់សម្នាក់របស់ព្រះថេរៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំតម្កល់ទឹកក្នុងបន្ទប់សម្រាប់ងូតហើយ សូមលោកម្ចាស់ស្រង់ចុះ ។ ព្រះថេរៈពោលថា ខ្ញុំនឹងងូត ហើយមកជាមួយភិក្ខុវិលខូចនោះ មិនឃើញទឹកក្នុងបន្ទប់ទើបសួរថា ទឹកនៅឯណា ទឹកនៅឯណា ទើបភិក្ខុនោះប្រញាប់ទៅកាន់

រោងភ្លើង លូកប៉ោយចូលក្នុងផ្ទាំងទទេ ប៉ោយប៉ះនឹងបាតផ្ទាំងឮសូរ តតៈ ។ តាំងអំពីនោះមកទើបភិក្ខុនោះមានឈ្មោះថា ឧឡុង្កសទ្ទកៈ ( សំឡេងប៉ោយ ) ខណៈនោះ ភិក្ខុដែលសម្បូរដោយវត្ត ទើបនាំទឹកអំពីទីដែលខ្លួនរក្សាទុកហើយ ពោលថា សូមលោកម្ចាស់ស្រង់ចុះ ។ ព្រះថេរៈស្រង់ហើយ ពិចារណាថា បានឮថា ឧឡុង្កសទ្ទកៈ ជាមនុស្សខិលខូច ទើបទូន្មានឧឡុង្កសទ្ទកៈនោះ ដែលមកកាន់ទីឧបដ្ឋាកក្នុងពេលល្ងាចថា អាវុសោ ធម្មតាសមណៈពោល វត្តដែលខ្លួនធ្វើប៉ុណ្ណោះថា អញធ្វើទើបគួរ ពោលដោយប្រការដទៃ រមែង ជាសម្បជានមុសាវាទ គឺកុហកទាំងដឹងខ្លួន តាំងអំពីនេះទៅ ចូរអ្នកកុំធ្វើកម្ម បែបនេះ ។ ព្រះឧឡុង្កសទ្ទកៈនោះខឹងនឹងព្រះថេរៈ ។ ស្អែកឡើងមិនចូលទៅ កាន់ស្រុកដើម្បីបិណ្ឌបាតជាមួយព្រះថេរៈ ព្រះថេរៈ ក៏ចូលទៅបិណ្ឌបាតជា មួយភិក្ខុមួយអង្គទៀត ។ ចំណែក ព្រះឧឡុង្កសទ្ទកៈ បានទៅកាន់ត្រកូល ឧបដ្ឋាករបស់ព្រះថេរៈ កាលជនទាំងនោះពោលថា ព្រះថេរៈទៅណា ក៏ ពោលថា ព្រះថេរៈអង្គុយក្នុងវិហារនោះឯង ព្រោះមានជំងឺ កាលអ្នកស្រុក ពោលថា បានអ្វីទើបគួរ ទើបពោលថា ចូរឲ្យវត្ថុនេះនិងវត្ថុនេះ ហើយកាន់ យកទៅតាមគាប់ចិត្តរបស់ខ្លួន ឆាន់ហើយ បានទៅកាន់វិហារ ។ ស្អែកឡើង ព្រះថេរៈទៅកាន់ត្រកូលនោះ ហើយគង់ ។ ជនទាំងឡាយ ក៏ពោលថា បពិត្រលោកម្ចាស់ ក្រែងលោកម្ចាស់មានជំងឺឬ បានឮថា ម្សិលមិញលោក ម្ចាស់អង្គុយតែក្នុងវិហារប៉ុណ្ណោះ ពួកខ្ញុំ បញ្ជូនអាហារទៅប្រគេនក្នុងដៃភិក្ខុ កំលោះឈ្មោះនោះ លោកម្ចាស់បានឆាន់អាហារដែរឬ ។ ព្រះថេរៈបាននៅ

ស្បៀម ធ្វើភត្តកិច្ចហើយ ទៅកាន់វិហារ ហៅព្រះឧឡ្លុក្កសទ្ទកៈដែលមកក្នុង ពេលបម្រើព្រះថេរៈ ក្នុងពេលល្ងាចថា អាវុសោ បានឮថា អ្នកសូមក្នុង ត្រកូលឈ្មោះនោះក្នុងផ្ទះឈ្មោះនោះថា ការបានវត្ថុនេះនិងវត្ថុនេះ រមែងគួរ ដល់ព្រះថេរៈ ហើយបរិភោគខ្លួនឯង ហើយពោលបន្តថា ឈ្មោះថាការសូម រមែងមិនគួរ លោកកុំប្រព្រឹត្តអនាចារបែបនេះទៀត ។ ព្រះឧឡ្លុក្កសទ្ទកៈចង អាឃាតក្នុងព្រះថេរៈដោយហេតុមានប្រមាណប៉ុណ្ណេះ គិតថា ម្សិលមិញនេះ ព្រះថេរៈនេះធ្វើនូវជម្លោះជាមួយអញ ព្រោះហេតុត្រឹមតែទឹក ឥឡូវនេះលោក អត់ធន់មិនបានថា អញបរិភោគភត្តមួយក្តាប់ក្នុងផ្ទះរបស់ឧបដ្ឋាកលោក ទើប ឈ្លោះនឹងអញទៀត អញនឹងដឹងកិច្ចដែលគួរធ្វើដល់ព្រះថេរៈនេះ ។ ស្អែក ឡើង កាលព្រះថេរៈចូលទៅបិណ្ឌបាត ទើបកាន់យកដំបងវាយភាជនៈគ្រឿង ប្រើប្រាស់ទាំងឡាយ ដុតបណ្ណសាលា ហើយចៀសចេញទៅ ។ ព្រះឧឡ្លុក្ក សទ្ទកៈនោះ នៅមានជីវិតនោះឯង តែជាមនុស្សប្រេត ស្គមស្មេកស្មាំង ធ្វើ កាលកិរិយាហើយ បានទៅកើតក្នុង អវិចិមហានរក ។ អនាចារដែលព្រះ ឧឡ្លុក្កសទ្ទកៈនោះធ្វើ បានប្រាកដទៅក្នុងកណ្តាលមហាជន ។ គ្រានោះ ភិក្ខុ មួយពួកចេញអំពីនគររាជគ្រឹះ មកកាន់នគរសាវត្ថី ទុកដាក់បាត្រនិងចីវរក្នុងទី ដែលជាសភាគៈគ្នា ក្នុងទីដែលមកដល់ ហើយទៅកាន់សម្នាក់ របស់ព្រះ សាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរ ។ ព្រះសាស្តា ទ្រង់ធ្វើបដិ សណ្ឋារៈជាមួយភិក្ខុទាំងនោះ ហើយត្រាស់សួរថា ពួកអ្នកមកអំពីណា ភិក្ខុ ទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំមកអំពីនគររាជគ្រឹះ ព្រះ

សាស្តាត្រាស់សួរថា អ្នកណាជាអាចារ្យឲ្យឱវាទក្នុងទីនោះ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ គឺព្រះមហាកស្សបត្ថេរ ។ ព្រះសាស្តាត្រាស់សួរថា កស្សបៈសុខទេឬ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ព្រះថេរៈសុខទេ តែសទ្ធិវិហារិករបស់លោក ក្រោធក្នុងឱវាទដែលលោកប្រៀនប្រដៅ ( កាលព្រះថេរៈចូលទៅបិណ្ឌបាត ក៏កាន់យកដំបងវាយភាជនៈ និងគ្រឿងប្រើប្រាស់ទាំងឡាយ ) ដុតបណ្ណសាលារបស់ព្រះថេរៈ ហើយគេចទៅ ។ ព្រះសាស្តាទ្រង់បានស្តាប់ដូច្នោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះនៃកស្សបៈ ប្រសើរជាងការត្រាច់ទៅជាមួយបុគ្គលពាលបែបនេះ ហើយទ្រង់ត្រាស់គាថាក្នុងធម្មបទថា

> បុគ្គលកាលស្វះស្វែងរកល្បាណមិត្ត បើមិនបានមិត្តដ៏ប្រសើរ
> ជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង
> ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណមិនមានក្នុងបុគ្គល
> ពាលឡើយ ដូច្នេះ ។

កាលត្រាស់គាថានេះហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយនោះ ត្រាស់ទៀតថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះប្រទូស្តកុដិក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាអ្នកប្រទូស្តកុដិមកហើយដូចគ្នា រមែងក្រោធអ្នកឲ្យឱវាទតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ក្រោធហើយដូចគ្នា កាលភិក្ខុទាំងនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាសត្វគ្រលេងគ្រលោង ចម្រើនវ័យហើយ ធ្វើសម្បុកដែលភ្លៀងលិចមិនបាន ជាទីគាប់ចិត្តរបស់ខ្លួន ក្នុងហិមវន្តប្បទេស កាលនោះ ស្វាមួយ កាលភ្លៀងធ្លាក់មិនដាច់គ្រាប់ក្នុងរដូវវស្សា ត្រូវរងារគ្រប សង្កត់ អង្គុយរណ្តំធ្មេញក្នុងទីមិនឆ្ងាយអំពីព្រះពោធិសត្វ ។ ព្រះពោធិសត្វ ឃើញស្វានោះលំបាកយ៉ាងនោះ កាលនឹងចរចាជាមួយស្វានោះ ក៏ពោលគាថា ទី ១ ថា

នៃពានរ ក្បាល ដៃនិងជើងរបស់អ្នក ដូចជាមនុស្សដែរ តែ
ព្រោះហេតុអ្វីបានជាផ្ទះរបស់អ្នកគ្មាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វណ្ណោឆ** បានដល់ ព្រោះហេតុ ។ ដោយ បទថា **អគារំ** នេះ គ្រលេងគ្រលោងសួរថា ព្រោះហេតុអ្វីផ្ទះជាទីនៅអាស្រ័យ របស់អ្នកមិនមាន ស្វាបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ២ ថា

នៃគ្រលេងគ្រលោង ក្បាល ដៃនិងជើងរបស់ខ្ញុំ ដូចមនុស្ស
មែនហើយ តែប្រាជ្ញាណាដែលបោរាណាចារ្យពោលថាប្រសើរ
ក្នុងពួកមនុស្ស ប្រាជ្ញានោះរបស់ខ្ញុំមិនមានទេ ដូច្នេះ ។

ក្នុងគាថានោះ ស្វាហៅបក្សីនោះដោយឈ្មោះថា **សិង្គិល** ។ បទថា **យា-ហុ សេដ្ឋា មនុស្សេសុ** សេចក្តីថា វិចារណប្បញ្ញារបស់ខ្ញុំ ដែលបណ្ឌិត ទាំងឡាយ ពោលថាប្រសើរបំផុតក្នុងពួកមនុស្ស រមែងមិនមាន ក្បាល ដៃ ជើងនិងកម្លាំងកាយ ( ជាដើម ) មិនជាប្រមាណក្នុងលោក វិចារណប្បញ្ញា

ប៉ុណ្ណោះ ប្រសើរបំផុត វិចារណប្បញ្ញានោះ មិនមានដល់ខ្ញុំ ព្រោះហេតុនោះ ទើបផ្ទះរបស់ខ្ញុំមិនមាន ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះ ក៏ពោលគាថា ២ ក្រៅអំពីនេះថា

ធម្មតាអ្នកមានចិត្តមិននឹងនួន មានចិត្តរបុិលរប៉ូច ជាអ្នកប្រទូស្តចំពោះមិត្ត មានមារយាទមិនទៀងជានិច្ច តែងមិនមានសេចក្តីសុខ ។

នែពានរ អ្នកនោះចូរធ្វើនូវអានុភាព ( ឲ្យកើតបញ្ញា ) ចូរផ្លាស់មារយាទចេញ ចូរធ្វើខ្ទមជាគ្រឿងការពារនូវត្រជាក់ និងខ្យល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនវដ្ឋិតចិត្តស្ស** បានដល់ ជាអ្នកមានចិត្តមិនតាំងមាំចំពោះហើយ ។ បទថា **ទុត្ភិនោ** បានដល់ ដែលមានប្រក្រតីទ្រុស្តមិត្ត ។ បទថា **អទ្ធុវសីលស្ស** បានដល់ ដែលរក្សាប្រក្រតីទុកសព្វកាលមិនបាន ។ បទថា **សោ ករស្សុ អានុភាវំ** សេចក្តីថា នែស្វាសម្លាញ់ អ្នកនុ៎ះឯងធ្វើឧបាយនៃកម្លាំង ដើម្បីធ្វើប្រយោជន៍ឲ្យកើតឡើង ឲ្យប្រាកដឡើង ។ បទថា **វីតិវត្តស្សុ សីលិយំ** សេចក្តីថា ចូរអ្នកឈានកន្លងនូវប្រក្រតី គឺភាពជាអ្នកទ្រុស្តសីល ចូរជាអ្នកមានសីល ។ បទថា **កុដិកំ** សេចក្តីថា ចូរធ្វើខ្ទម គឺសម្បុក បានដល់ ផ្ទះជាទីលំនៅមួយរបស់ខ្លួនដែលអាចការពារនូវរងា និងខ្យល់ ។

ស្វាគិតថា ជាបឋម បក្សីនេះជេរអញ ព្រោះភាពដែលខ្លួនទំក្នុងទីដែល

ភ្លៀងមិនប៉ះពាល់ អញនឹងមិនឲ្យវាទំក្នុងសម្បុកនេះ ។ លំដាប់នោះ ស្វាបំណង នឹងចាប់ព្រះពោធិសត្វទើបស្ទុះមក ព្រះពោធិសត្វក៏ហើរទៅទីដទៃ ស្វាក៏បោច សម្បុក ធ្វើឲ្យល្អិតជាកម្ទេចតូចធំ ហើយចៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើប ទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះ បានមកជាភិក្ខុដែលដុតកុដិក្នុងកាលឥឡូវ នេះ ចំណែកក្រលេងក្រលោងក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កុដិទូសកជាតក ចប់

## ទុទ្ទុភាយជាតក

[ ៥៨៦ ] ( ទន្សាយនិយាយថា ) សូមសេចក្តីចម្រើនមានដល់លោកចុះ ខ្ញុំនៅក្នុងប្រទេសណា ប្រទេសនោះធ្វើសំឡេងឮទុទ្ទុភ: តែខ្ញុំមិនដឹងនូវប្រទេសនុ៎ះថា អ្វីនេះ ធ្វើសំឡេងឮទុទ្ទុភ: ។

[ ៥៨៧ ] ( ព្រះសាស្តាទ្រង់សំម្តែងថា ) ទន្សាយឮស្លឹកព្នៅជ្រុះ ថាទុទ្ទុភ: ដូច្នេះ ក៏ស្ទុះបោលប្រេច ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយ ក៏ភ័យតក់ស្លុត ។

[ ៥៨៨ ] ពួកជនពាលនោះ មិនទាន់សម្រេចនូវចំណែកនៃសោតវិញ្ញាណ ឮសំឡេងនៃជនដទៃ មានសេចក្តីប្រហែលធ្វេសដ៏ក្រៃលែង ជនពាលទាំងនោះ រមែងលុះតាមពាក្យជនដទៃ ។

[ ៥៨៩ ] ចំណែកពួកជនណា បរិបូណ៌ដោយសីលនិងបញ្ញា ត្រេកអរក្នុងការស្ងប់រម្ងាប់ ជាធីរជនអ្នកឆ្ងាយ អ្នកវៀរចាកបាប ធីរជននោះ មិនលុះតាមពាក្យជនដទៃទេ ។

**ចប់ ទុទ្ទុភាយជាតកទី ២ ។**

## អដ្ឋកថា

## ទុទ្ទុភាយជាតក

[ ៥៨៦-៥៨៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកតិរ្ថិយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទុទ្ទុភាយតិ**

**ភទ្ទន្តេ** ដូច្នេះជាដើម ។

បានឮថា តិរ្ថិយទាំងឡាយសម្រេចការដេកលើបន្លា ដុតធ្វើឲ្យក្តៅក្នុងទី ៥ កន្លែង ( ៥ ភ្នក់ ) ប្រព្រឹត្តមិច្ឆាតបៈ មានប្រការផ្សេងៗ នៅក្នុងទីនោះ ក្នុងទីមិនឆ្ងាយអំពីជេតពនវិហារ ។ គ្រានោះ ភិក្ខុជាច្រើននាំគ្នាត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី ហើយបានត្រឡប់មកកាន់វិហារជេតពន ក្នុងរវាងផ្លូវបានឃើញតិរ្ថិយទាំងនោះ ទើបនាំគ្នាទៅគាល់ព្រះសាស្តាហើយទូលសួរថា បពិត្រព្រះអង្គ សារៈក្នុងការសមាទានវត្តរបស់សមណព្រាហ្មណ៍ដែលជាតិរ្ថិយមានឬ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ខ្លឹមសារឬភាពវិសេសក្នុងការសមាទានវត្តរបស់ពួកតិរ្ថិយទាំងនោះរមែងមិនមានឡើយ ព្រោះវត្តនោះកាលស្ទាបស្ទង់មើល ក៏ដូចគ្នានឹងផ្លូវដែលពេញដោយសំរាម និងដូចទន្សាយផ្អើលសំឡេងខ្ទាំង កាលភិក្ខុទាំងនោះទូលអារាធនាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គទាំងឡាយ មិនជ្រាបភាពដែលវត្តនោះប្រព្រឹត្តទៅដូចទន្សាយខ្លាចសំឡេងខ្ទាំង សូមទ្រង់ត្រាស់ប្រាប់ចុះ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតរាជសីហ៍ ចម្រើនវ័យហើយ អាស្រ័យក្នុងព្រៃ ក្នុងកាលនោះ មានព្រៃត្នោតលាយនឹងដើមព្នៅ ក្នុងទីជិតសមុទ្ទទិសខាងលិច ។ ក្នុងព្រៃត្នោតនោះ មានទន្សាយមួយនៅក្រោមដើមត្នោតមួយគុម្ពក្បែរគល់ព្នៅ ។ ថ្ងៃមួយទន្សាយនោះដើររកអាហារ ហើយមកដេកក្រោមស្លឹក

ត្នោត គិតថា បើផែនដីនេះស្រុត អញនឹងទៅក្នុងទីណាហ្ន៎ ខណៈនោះឯង ផ្លែត្នោតមួយ ជ្រុះលើស្លឹកត្នោត ។ ព្រោះសំឡេងស្លឹកត្នោតនោះ ទន្សាយនោះក៏គិតថា ផែនដីស្រុតមែន ទើបលោតគេចទៅមិនមើលក្រោយ ទន្សាយដទៃឃើញទន្សាយនុ៎ះ ខ្លាចមរណភ័យដែលកំពុងរត់គេច ទើបសួរថា នែអ្នកដ៏ចម្រើន អ្នកខ្លាចអ្វីខ្លាំងម្ល៉េះទើបរត់មក ទន្សាយនោះពោលថា អ្នកដ៏ចម្រើនកុំសួរឡើយ ទន្សាយនោះក៏រត់តាមទៅពីខាងក្រោយ ព្រមទាំងស្រែកសួរថា អ្នកដ៏ចម្រើន អ្នកខ្លាចអ្វី អ្នកដ៏ចម្រើន អ្នកខ្លាចអ្វី ។ ទន្សាយនោះ មិនមើលក្រោយឡើយពោលថា ផែនដីស្រុតត្រង់ទីនោះ ។ សូម្បីទន្សាយនោះក៏រត់តាមក្រោយទន្សាយដែលប្រាប់នោះទៅ ។ កាលបើយ៉ាងនោះ ទន្សាយដទៃបានឃើញដូច្នោះ ក៏រត់តាមៗគ្នាទៅ សេចក្តីថា ទន្សាយរាប់ពាន់ បាននាំគ្នាគេចទៅ ។ ម្រឹគមួយពួកឃើញទន្សាយទាំងនោះ ក៏នាំគ្នារត់ទៅដែរ ពួកជ្រូកមួយពួក ទ្រាយមួយពួក ក្របីមួយពួក គោមួយពួក រមាសមួយពួក ខ្លាធំមួយពួក សីហៈមួយពួក ដំរីមួយពួកឃើញក៏សួរថា តើមានរឿងអ្វី សត្វទាំងនោះ ពោលថា ត្រង់នោះផែនដីស្រុត ទើបរត់ទៅទាំងអស់គ្នា ។ ក្នុងទីប្រមាណមួយយោជន៍ មានពួកសត្វតិរច្ឆានច្រើនឡើងៗដោយលំដាប់ដោយអាការៈយ៉ាងនេះ ។ ក្នុងកាលនោះ ព្រះពោធិសត្វឃើញពួកសត្វទាំងនោះកំពុងរត់ទើបសួរថា តើមានរឿងអ្វី កាលបានឮថា ក្នុងទីនោះផែនដីស្រុតទើបគិតថា ធម្មតាផែនដីស្រុត រមែងមិនមានក្នុងកាលណាឡើយ សត្វទាំងនោះនឹងឃើញអ្វីមួយពិតប្រាកដ បើអញមិនជួយខ្វល់ខ្វាយ សត្វទាំងពួងនឹង

វិនាស អញនឹងឲ្យជីវិត ដល់សត្វទាំងនេះ កាលគិតហើយ ទើបរត់ទៅកាន់ជើងភ្នំមុនដោយកម្លាំងរាជសីហ៍ ហើយបន្លឺសីហនាទ ៣ ដងត្រង់ជើងភ្នំនោះ ។ សត្វទាំងនោះ កាលរាជសីហ៍គំរាមក៏ខ្លាច ទើបត្រឡប់មកឈរជាក្រុមសួរគ្នាថា តើមានរឿងអ្វី ។ រាជសីហ៍បានចូលទៅក្នុងរវាងសត្វទាំងនោះហើយសួរថា ពួកអ្នករត់រឿងអ្វី សត្វទាំងនោះពោលថា ផែនដីស្រុត រាជសីហ៍សួរថា អ្នកណាឃើញផែនដីស្រុត សត្វទាំងនោះពោលថា ដំរីជាអ្នកដឹង រាជសីហ៍ក៏សួរដំរីជាដើមទៅ ដំរីពោលថា ពួកខ្ញុំមិនដឹង ពួកសីហៈដឹង ពួកសីហៈទាំងឡាយក៏ពោលថា ពួកខ្ញុំមិនដឹង ពួកខ្លាធំទាំងឡាយដឹង សូម្បីពួកខ្លាធំទាំងឡាយ ក៏ពោលថា ពួកខ្ញុំមិនដឹង ពួករមាសដឹង សូម្បីពួករមាសទាំងឡាយក៏ពោលថា ពួកគោដឹង ពួកគោក៏ពោលថា ក្របីទាំងឡាយដឹង ក្របីទាំងឡាយក៏ពោលថា ពួកខ្ទីងដឹង សូម្បីខ្ទីងទាំងឡាយក៏ពោលថា ពួកជ្រូកដឹង សូម្បីពួកជ្រូកទាំងឡាយក៏ពោលថា ពួកម្រឹគដឹង សូម្បីពួកម្រឹគក៏ពោលពួកខ្ញុំមិនដឹង ពួកទន្សាយដឹង កាលទន្សាយ ត្រូវសួរ ទើបទន្សាយទាំងឡាយបង្ហាញទន្សាយនោះថា ទន្សាយនេះនិយាយ ។ លំដាប់នោះ រាជសីហ៍សួរទន្សាយនោះថា សម្លាញ់ បានឮថា ឯងឃើញយ៉ាងនោះឬថាផែនដីស្រុត ទន្សាយនោះ ពោលថា បាទខ្ញុំឃើញ រាជសីហ៍សួរថា អ្នកឃើញក្នុងទីណា ទន្សាយនោះពោលថា ខ្ញុំនៅក្នុងព្រៃត្នោតដែលមានដើមព្នៅដុះលាយ ជិតសមុទ្ទទិសខាងលិច ព្រោះថាខ្ញុំដេកក្រោមស្លឹកត្នោត ក្រោមដើមត្នោតក្បែរគល់ព្នៅ ក្នុងព្រៃត្នោតនោះ គិតថា បើផែនដីស្រុតអញនឹងទៅក្នុងទីណា ខណៈ

នោះឯង ខ្ញុំក៏បានឮសំឡេងផែនដីស្រុត ក៏បានរត់គេចទៅ ។ រាជសីហ៍គិតថា ផ្លែព្នៅទុំជ្រុះលើស្លឹកត្នោតនោះ ធ្វើសំឡេងខ្លាំងពិត ទន្សាយនេះបានឮសំឡេងនោះ ទើបធ្វើសេចក្ដីសម្គាល់ឲ្យកើតឡើងថា ផែនដីស្រុត ទើបគេចទៅ អញនឹងពិនិត្យមើលឲ្យដឹងពិតប្រាកដ ។ រាជសីហ៍កាន់យកទន្សាយនោះទុក លួងលោមពួកសត្វឲ្យធូរស្បើយហើយ ពោលថា យើងនឹងដឹងផែនដីត្រង់ទីដែលទន្សាយនេះឃើញតើស្រុតឬមិនស្រុតដោយពិតហើយនឹងត្រឡប់មក ពួកអ្នកចូរនៅក្នុងទីនេះ ទម្រាំខ្ញុំមក ហើយលើកទន្សាយឡើងដាក់លើខ្នង ស្ទុះទៅដោយកម្លាំងរាជសីហ៍ ដាក់ទន្សាយចុះត្រង់ព្រៃត្នោតហើយពោលថា មក ចូរអ្នកប្រាប់ទីដែលអ្នកបានឃើញ ទន្សាយពោលថា ខ្ញុំមិនហ៊ានទៅឡើយ ។ រាជសីហ៍ពោលថា មក អ្នកកុំខ្លាចឡើយ ។ ទន្សាយនោះមិនអាចចូលទៅជិតដើមព្នៅ ក៏ឈរក្នុងទីមិនឆ្ងាយហើយពោលថា នេះជាទីដែលមានសំឡេងខ្លាំង ហើយពោលគាថាទី ១ ថា

> សូមសេចក្ដីចម្រើនមានដល់លោកចុះ ខ្ញុំនៅក្នុងប្រទេសណា
> ប្រទេសនោះធ្វើសំឡេងឮទុទ្ទុកៈ តែខ្ញុំមិនដឹងនូវប្រទេសនុ៎ះថា
> អ្វីនេះ ធ្វើសំឡេងឮទុទ្ទុកៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុទ្ទុភាយតិ** បានដល់ ធ្វើសំឡេងថា ទុទ្ទុកៈ គឺសំឡេងខ្លាំងរំពង ។ បទថា **ភទ្ទន្តេ** សេចក្ដីថា សូមសេចក្ដីចម្រើនមានដល់លោក ។ បទថា **កិមេតំ** សេចក្ដីថា ក្នុងប្រទេសដែលខ្ញុំនៅ មានសំឡេងខ្លាំងរំពង សូម្បីខ្ញុំក៏មិនដឹងថាសំឡេងកងរំពងនេះជាអ្វី ឬព្រោះហេតុអ្វីទើប

មានសំឡេងកងរំពង ខ្ញុំបានឮសំឡេងខ្លាំងតែម្យ៉ាង ។

កាលទន្សាយពោលយ៉ាងនេះហើយ រាជសីហ៍ក៏ទៅកាន់គល់ព្នៅ ឃើញទីដែលទន្សាយដេកក្រោមស្លឹកត្នោត និងផ្លែព្នៅដែលជ្រុះលើស្លឹកត្នោត ដឹងជាផែនដីមិនស្រុតពិតប្រាកដហើយ ទើបលើកទន្សាយដាក់លើខ្នង មកកាន់សម្នាក់របស់ម្រឹគដោយឆាប់រហ័សដោយសម្ទុះនៃរាជសីហ៍ ប្រាប់ការប្រព្រឹត្តទៅទាំងពួង ហើយពោលថា អ្នកទាំងឡាយកុំខ្លាចឡើយ ធ្វើពួកម្រឹគឲ្យធូរស្បើយហើយឲ្យទៅ ។ បើក្នុងកាលនោះមិនមានព្រះពោធិសត្វសោត សត្វទាំងពួងនឹងរត់ចុះក្នុងសមុទ្ទ នាំគ្នាវិនាសអស់ តែព្រោះអាស្រ័យព្រះពោធិសត្វ សត្វទាំងពួងក៏បាននូវជីវិតរស់នៅ ។

ព្រះសាស្តាទ្រង់ត្រាស់ដឹងហើយ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថា ៣ គាថានេះថា

ទន្សាយឮស្នូរផ្លែព្នៅជ្រុះថា ទុទ្ទុភៈ ដូច្នេះ ក៏ស្ទុះបោលប្រេច ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយ ក៏ភ័យតក់ស្លុត ។

ពួកជនពាលនោះ មិនទាន់សម្រេចនូវចំណែក នៃសោតវិញ្ញាណ ឮសំឡេងនៃជនដទៃ មានសេចក្តីប្រហែលធ្វេសដ៏ក្រៃលែង ជនពាលទាំងនោះ រមែងលុះតាមពាក្យជនដទៃ ។

ចំណែកពួកជនណា បរិបូណ៌ដោយសីលនឹងបញ្ញា ត្រេកអរក្នុងការស្ងប់រម្ងាប់ ជាធីរជនអ្នកឆ្ងាយ អ្នកវៀរចាកបាប ធីរជននោះ មិនលុះតាមពាក្យជនដទៃទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វេលុវំ** បានដល់ ផ្លែព្នៅទុំ ។ បទថា **ធុធុកំ** បានដល់ មានសំឡេងយ៉ាងនោះ ។ បទថា **សន្តត្តា** បានដល់ តក់ស្លុត ។ បទថា **មិគវាហិនី** បានដល់ ពួកម្រឹគ គឺម្រឹគសេនាច្រើនពាន់ ។ បទថា **បតវិញ្ញាណំ** សេចក្ដីថា មិនទាន់សម្រេចដល់វិញ្ញាណបទ គឺកោដ្ឋាសនៃសោតវិញ្ញាណ ។ បទថា **តេ ហោន្តិ បរបត្តិយា** សេចក្ដីថា អន្ធពាលបុថុជ្ជនទាំងនោះ អនុលោមតាមសំឡេងបុគ្គលដទៃ សម្គាល់ការឮ ពោលគឺសំឡេងអ្នកដទៃនោះប៉ុណ្ណោះថាជាសំខាន់ ទើបជាអ្នកជឿចំពោះអ្នកដទៃប៉ុណ្ណោះ ព្រោះមិនដល់វិញ្ញាណបទ ផ្លូវនៃការដឹងច្បាស់ គឺជឿពាក្យរបស់អ្នកដទៃហើយធ្វើតាមគ្នាទៅ ។ បទថា **សីលេន** បានដល់ ប្រកបដោយសីលដែលមកដោយអរិយមគ្គ ។ បទថា **បញ្ញាយុបសមេ រតា** សេចក្ដីថា ត្រេកអរក្នុងការស្ងប់រម្ងាប់កិលេសដោយបញ្ញាដែលមកដោយមគ្គដូចគ្នា ។

សេចក្ដីអធិប្បាយដូច្នេះក៏មានថា ប្រកបដោយបញ្ញា ដូចប្រកបដោយសីល ត្រេកអរក្នុងការស្ងប់កិលេស ។ បទថា **អារកា វិរតា ធីរា** សេចក្ដីថា ជាបណ្ឌិត វៀរឆ្ងាយចាកការធ្វើបាប ។ បទថា **ន ហោន្តិ** សេចក្ដីថា ជនទាំងនោះ គឺបែបនោះ ជាព្រះសោតាបន្ន មានធម៌ដែលដឹងច្បាស់ហើយដោយមគ្គញាណភាវៈ ១ ដោយជាអ្នកវៀរចាកបាប និងត្រេកអរក្នុងការស្ងប់កិលេស រមែងមិនជឿចំពោះអ្នកដទៃដែលពោល ។ ព្រោះហេតុអ្វី ព្រោះបានជាក់ច្បាស់ចំពោះខ្លួនឯង ។ ដោយហេតុនោះ ទើបព្រះសាស្ដាត្រាស់ទុក ( ក្នុងខុទ្ទកនិកាយធម្មបទ ) ថា

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងតតឹងផង មានឱកាសកម្ចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា រាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទុទ្ទុភាយជាតក ចប់

# ព្រហ្មទត្តជាតក

[ ៥៩០ ] ( តាបសពោធិសត្វពោលថា ) បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសូម រមែងបានផលពីរយ៉ាង គឺការមិនបានទ្រព្យ ១ ការបានទ្រព្យ ១ ព្រោះថា ការសូមមានយ៉ាងនេះជាធម្មតា ។

[ ៥៩១ ] បពិត្រព្រះអង្គជាឥស្សរលើរថនៃដែនបញ្ចាល អ្នកប្រាជ្ញទាំងឡាយ បានពោលនូវការសុំថាជាការយំ បុគ្គលណាឃាត់នូវការសុំ អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថា ជាអ្នកមានការយំតប ។

[ ៥៩២ ] កុំឲ្យពួកជនអ្នកដែនបញ្ចាលមកប្រជុំគ្នា ឃើញអាត្មាភាពកំពុងយំ ឬព្រះអង្គកំពុងយំតបឡើយ ព្រោះហេតុនោះ បានជាអាត្មាភាពត្រូវការទីស្ងាត់ ។

[ ៥៩៣ ] ( ព្រះបាទព្រហ្មទត្តទ្រង់ត្រាស់ថា ) បពិត្រព្រាហ្មណ៍ ខ្ញុំនឹងឲ្យគោញីសម្បុរក្រហម ១ ពាន់ ព្រមទាំងគោឈ្មោលដល់លោក ព្រោះថា អរិយជន បានស្តាប់នូវគាថាប្រកបដោយធម៌របស់លោកជាអរិយៈ មិនគប្បីឲ្យដូចម្តេចកើត ។

**ចប់ ព្រហ្មទត្តជាតកទី ៣ ។**

# អដ្ឋកថា

# ព្រហ្មទត្តជាតក

[ ៥៩០-៥៩៣ ] ព្រះសាស្តា កាលអាស្រ័យនៅក្នុងក្រុងអាឡវី ត្រង់អគ្គាឡវចេតិយ ទ្រង់ប្រារព្ធកុដិការសិក្ខាបទ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ទ្វយំ យាចនកោ រាជ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានមកហើយក្នុងមណិកណ្ឋជាតកខាងដើមនោះឯង ។ តែក្នុងរឿងនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកច្រើនទៅដោយការសូម ច្រើនទៅដោយការធ្វើវិញ្ញត្តិពិតឬ កាលភិក្ខុទាំងនោះក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់តិះដៀលភិក្ខុទាំងនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បោរាណកបណ្ឌិតទាំងឡាយ សូម្បីព្រះរាជាជាធំក្នុងផែនដីបវារណាទុក ប្រាថ្នានឹងសូមឆត្រស្លឹកឈើ និងស្បែកជើងមួយជាន់ ១ គូ ក៏មិនសូមក្នុងកណ្តាលមហាជន ព្រោះមានហិរិឱត្តប្បៈ ទើបពោលសូមក្នុងទីកំបាំង ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទបញ្ចាលរាជ សោយរាជសម្បត្តិក្នុងឧត្តរបញ្ចាលនគរ កបិលរដ្ឋ ។ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ក្នុងតំបន់មួយ លុះចម្រើនវ័យហើយទៅកាន់តក្កសិលានគរ រៀនសិល្បសាស្ត្រទាំងពួង បន្ទាប់មកបានបួសជាតាបស ចិញ្ចឹមជីវិតដោយមូលផលាផលក្នុងព្រៃ ដោយការស្វែងរកក្នុងហិមវន្តប្បទេស អស់កាលយូរ ។ កាលត្រាច់ទៅកាន់ដែនដីមនុស្សដើម្បីបរិភោគរសជូរប្រៃ ទើបទៅកាន់ឧត្តរបញ្ចាលនគរ សម្រាកនៅក្នុងព្រះរាជឧទ្យាន ស្អែកឡើង កាលស្វែងរកភិក្ខាហារ ទើបចូលទៅកាន់

ព្រះនគរ ដល់ទ្វាព្រះរាជវាំង ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងអាចារៈនិងវិហារធម៌របស់តាបសនោះទើបនិមន្តឲ្យគង់ក្នុងផ្ទៃប្រាសាទ ឲ្យឆាន់ភោជនដែលគួរដល់ព្រះរាជា កាន់យកបដិញ្ញាហើយឲ្យនៅក្នុងព្រះរាជឧទ្យាននោះឯង ។ តាបសនោះឆាន់តែក្នុងព្រះរាជមន្ទីរនោះឯងជាប្រចាំ កាលផុតរដូវភ្លៀងហើយ មានបំណងនឹងទៅកាន់ហិមវន្តប្បទេសវិញ គិតថា បើអញធ្វើដំណើរទៅ គួរបានស្បែកជើងមួយជាន់ ១ គូ និងឆត្រស្លឹកឈើមួយ អញនឹងទូលសូមព្រះរាជា ។ ថ្ងៃមួយតាបសនោះឃើញព្រះរាជាយាងមកកាន់ព្រះរាជឧទ្យានថ្វាយបង្គំហើយប្រថាប់គង់ ទើបគិតថា នឹងទូលសូមស្បែកជើងនិងឆត្រ ក៏គិតទៀតថា បុគ្គលកាលសូមអ្នកដទៃថា សូមអ្នកឲ្យរបស់ឈ្មោះនេះ ឈ្មោះថារមែងយំ ចំណែកអ្នកដទៃ ( ម្ចាស់ទ្រព្យ ) ដែលពោលថា មិនមាន ឈ្មោះថា រមែងយំតប មហាជនកុំឃើញអញយំ កុំឃើញព្រះរាជាយំតបឡើយ ដូច្នោះ សូម្បីយើងទាំងពីរយំក្នុងទីស្ងាត់កំបាំងនឹងជាអ្នកនៅស្ងៀម ។ លំដាប់នោះ ទើបតាបសក្រាបទូលព្រះរាជានោះថា បពិត្រមហារាជ អាត្មារង់ចាំចំពោះទីកំបាំង ។ ព្រះរាជាបានស្តាប់ដូច្នោះ ទើបត្រាស់ឲ្យពួករាជបុរសថយចេញទៅ ។ ព្រះពោធិសត្វគិតថា បើអញទូលសូម ព្រះរាជាមិនប្រទានសោត មេត្រីភាពរបស់អញនឹងបែកធ្លាយទៅ ព្រោះហេតុនោះ អញនឹងមិនទូលសូម ក្នុងថ្ងៃនោះកាលមិនអាចប្រារព្ធឈ្មោះ ក៏ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់យាងសិនចុះ អាត្មានឹងដឹងក្នុងថ្ងៃមួយទៀត ។ ក្នុងកាលដែលព្រះរាជាយាងមក ព្រះរាជឧទ្យានម្តងទៀត ក៏ក្រាបទូលយ៉ាងនោះ មួយថ្ងៃទៀត ក៏ក្រាបទូលយ៉ាងនោះ

ឯង សេចក្តីថា កាលព្រះពោធិសត្វមិនអាចទូលយ៉ាងនេះ ពេលវេលាកន្លង ទៅអស់ ១២ ឆ្នាំ ។ លំដាប់នោះ ព្រះរាជាត្រិះរិះថា លោកម្ចាស់របស់អញ ពោលថា រង់ចាំឱកាសស្ងាត់ កាលបរិស័ទថយចេញទៅហើយ ក៏មិនអាច ពោលពាក្យណាមួយ កាលលោកម្ចាស់បំណងពោលប៉ុណ្ណោះ ពេលវេលាកន្លង ទៅអស់ ១២ ឆ្នាំ ម្យ៉ាងទៀត លោកម្ចាស់ប្រព្រឹត្តព្រហ្មចរិយៈមកយូរ ប្រហែល ជាលោកនឿយណាយ ប្រាថ្នានឹងបរិភោគសម្បត្តិ បំណងចំពោះរាជសម្បត្តិ ទេដឹង កាលលោកមិនអាចប្រារព្ធឈ្មោះរាជសម្បត្តិ ទើបបាននៅស្ងៀម ថ្ងៃ នេះអញនឹងដឹងគ្នា លោកប្រាថ្នាវត្ថុណា អញនឹងឲ្យវត្ថុនោះ ចាប់តាំងអំពីរាជ សម្បត្តិឡើងទៅ ។ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់នមស្ការហើយ ប្រថាប់គង់ កាលព្រះពោធិសត្វក្រាបទូលថា អាត្មាទន្ទឹងឱកាសកំបាំង កាល បរិស័ទត្រឡប់ថយទៅហើយ ទើបត្រាស់នឹងព្រះពោធិសត្វដែលមិនអាចទូល ពាក្យណាមួយថា លោកម្ចាស់ពោលថា រង់ចាំឱកាសកំបាំង សូម្បីបានឱកាស កំបាំងហើយ ក៏មិនអាចពោលអ្វីអស់កាល ១២ ឆ្នាំ ខ្ញុំសូមបវារណាវត្ថុទាំង ពួង មានរាជសម្បត្តិជាដើមចំពោះលោកម្ចាស់ សូមលោកម្ចាស់កុំភ័យខ្លាច សូមលោកម្ចាស់ សុំតាមគាប់ចិត្តចុះ ។ ព្រះពោធិសត្វក៏ទូលថា ថ្វាយព្រះ ពរមហាបពិត្រ ទ្រង់ប្រទានវត្ថុដែលអាត្មាសូមឬ ព្រះរាជាត្រាស់ថា បពិត្រ លោកម្ចាស់ ខ្ញុំនឹងឲ្យ ។ ព្រះពោធិសត្វទូលថា ថ្វាយព្រះពរមហាបពិត្រ កាល អាត្មាធ្វើដំណើរទៅ គួរបានស្បែកជើងមួយជាន់ ១ គូ ឆត្រស្លឹកឈើមួយ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ទ្រព្យមានប្រមាណប៉ុណ្ណេះ លោកម្ចាស់

មិនអាចសូមអស់កាល ១២ ឆ្នាំឬ ព្រះពោធិសត្វទូលថា ពិតហើយ ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វីទើបលោកម្ចាស់ធ្វើយ៉ាងនេះ ព្រះពោធិសត្វទូលថា មហាបពិត្រ បុគ្គលដែលសូមថា ចូរឲ្យរបស់នេះដល់ខ្ញុំ ឈ្មោះថាយំ បុគ្គលដែលពោលថាមិនមាន ឈ្មោះថាយំតប បើទ្រង់ត្រូវអាត្មាទូលសូម មិនប្រទានសោត មហាជនកុំបានឃើញទីដែលអាត្មាភាពយំ និងទ្រង់យំតបនោះ ព្រោះដូច្នោះ ទើបអាត្មាភាពរង់ចាំឱកាសស្ងាត់ដើម្បីប្រយោជន៍នេះ ហើយពោលគាថា ៣ ដូច្នេះថា

បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសូម រមែងបានផលពីរ
យ៉ាងគឺ ការមិនបានទ្រព្យ ១ ការបានទ្រព្យ ១ ព្រោះថា
ការសូម មានយ៉ាងនេះជាធម្មតា ។

បពិត្រព្រះអង្គជាឥស្សរលើរថ នៃដែនបញ្ចាល អ្នកប្រាជ្ញ
ទាំងឡាយ បានពោលនូវការសុំថាជាការយំ បុគ្គលណាឃាត់
នូវការសុំ អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថា ជាអ្នកមាន
ការយំតប ។

កុំឲ្យពួកជនអ្នកដែនបញ្ចាលមកប្រជុំគ្នា ឃើញអាត្មាភាព
កំពុងយំ ឬព្រះអង្គកំពុងយំតបឡើយ ព្រោះហេតុនោះ បាន
ជាអាត្មាភាពត្រូវការទីស្ងាត់ ដូច្នេះ ។

ក្នុងគាថាទាំងនោះ ព្រះពោធិសត្វហៅព្រះរាជាដោយបទទាំងពីរថា **រាជព្រហ្មទត្ត** ។ បទថា **និគច្ឆតិ** បានដល់ រមែងបានចំពោះ គឺរមែងជួប

ប្រសព្វ ។ បទថា **ឯវំធម្មា** បានដល់ មានយ៉ាងនេះជាសភាវៈ ( ធម្មតា ) ។ បទថា **អាហុ** សេចក្តីថា បណ្ឌិតទាំងឡាយរមែងពោល ។ បទថា **បញ្ចាលានំ រថេសភ** បានដល់ ប្រសើក្នុងរថនិងជាអ្នកជំក្នុងដែនបញ្ចាល ។ បទថា **យោ យាចនំ បច្ចក្ខាតិ** សេចក្តីថា បុគ្គលណារមែងបដិសេធចំពោះសេចក្តីនោះថា មិនមាន ។ បទថា **តមាហុ** សេចក្តីថា បណ្ឌិតទាំងឡាយពោលហើយ គឺរមែងពោលការបដិសេធនោះថា ជាការយំតប ។ បទថា **មំ មាទ្ទសំសុ** សេចក្តីថា អ្នកបញ្ចាលដែលនៅក្នុងដែនរបស់ព្រះអង្គ មកប្រជុំគ្នាហើយ កុំបានឃើញអាត្មាភាពយំឡើយ ។

ព្រះរាជាទ្រង់ជ្រះថ្លាក្នុងលក្ខណៈនៃការគោរពរបស់ព្រះពោធិសត្វ កាលទ្រង់ឲ្យពរ ទើបត្រាស់គាថាទី ៤ ថា

> បពិត្រព្រាហ្មណ៍ ខ្ញុំនឹងឲ្យគោញីសម្បុរក្រហម ១ ពាន់ ព្រមទាំងគោឈ្មោលដល់លោក ព្រោះថា អរិយជន បានស្តាប់នូវគាថាប្រកបដោយធម៌របស់លោកជាអរិយៈ មិនគប្បីឲ្យដូចម្តេចកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រោហិណីនំ** បានដល់ មានពណ៌ក្រហម ។ បទថា **អរិយោ** បានដល់ ដែលសម្បូរដោយអាចារៈ គឺមារយាទ ។ បទថា **អរិយស្ស** បានដល់ ដែលសម្បូរដោយអាចារៈ គឺមារយាទ ។ បទថា **កថំ ន ទជ្ជា** សេចក្តីថា មិនគប្បីឲ្យដូចម្តេចកើត ។ បទថា **ធម្មយុត្តា** បានដល់ ប្រកបដោយហេតុ ។

ចំណែកព្រះពោធិសត្វក្រាបទូលថា មហាបពិត្រ អាត្មាមិនត្រូវការវត្ថុកាម សូមទ្រង់ប្រទានវត្ថុដែលអាត្មាសូម ហើយទទួលយកស្បែកជើងមួយជាន់ ឆត្រ ១ ទូន្មានព្រះរាជាថា មហាបពិត្រ សូមទ្រង់កុំប្រមាទ ចូររក្សាសីល ចូរធ្វើឧបោសថកម្មចុះ កាលព្រះរាជាកំពុងអង្វរនោះឯង បានទៅកាន់ហិមវន្តប្បទេស ធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតក្នុងទីនោះហើយ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ព្រហ្មទត្តជាតក ចប់

## ចម្មសាដកជាតក

[ ៥៩៤ ] ( ចម្មសាកដបរិញ្វជកពោលថា ) ឱ ពពែដ៏ប្រសើរនេះ ជាសត្វជើង ៤ មានសភាពល្អ ដ៏ចម្រើនល្អ មានមារយាទ ជាទីស្រឡាញ់ មានយស តែងគោរពព្រាហ្មណ៍ អ្នកបរិបូណ៌ដោយជាតិនិងមន្ត ។

[ ៥៩៥ ] ( បណ្ឌិតពាណិជពោធិសត្វពោលថា ) ម្នាលព្រាហ្មណ៍ អ្នកកុំស្និទ្ធស្នាលនឹងសត្វជើង ៤ ដោយការឃើញមួយរំពេចឡើយ ដ្បិតសត្វពពែនេះ ប្រាថ្នានឹងធ្វើនូវការប្រហារដ៏មាំ បានជាថយក្រោយ នឹងព្រលែងនូវការប្រហារឲ្យងាយ ។

[ ៥៩៦ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ឆ្អឹងភ្លៅរបស់ព្រាហ្មណ៍ក៏បាក់ អម្រែករបស់ព្រាហ្មណ៍ក៏ធ្លាក់ចុះ ទ្រព្យទាំងអស់របស់ព្រាហ្មណ៍ក៏បែកហើយ ព្រាហ្មណ៍លើកដៃទាំងពីរឡើងកន្ទក់កន្ទេញថា ពពែស្ទុះមកសម្លាប់ព្រហ្មចារីបុគ្គល ។

[ ៥៩៧ ] ( បរិញ្វជកនិយាយតទៅទៀតថា ) ខ្ញុំជាមនុស្សឥតប្រាជ្ញា ត្រូវពពែបុះសម្លាប់ក្នុងថ្ងៃនេះយ៉ាងណា បុគ្គលណាសរសើរបុគ្គលដែលមិនគួរបូជា បុគ្គលនោះត្រូវគេសម្លាប់ដេកនៅ ( ក្នុងទីនេះ ) យ៉ាងនោះដែរ ។

**ចប់ ចម្មសាដកជាតកទី ៤ ។**

# អដ្ឋកថា

# ចម្មសាដកជាតក

[ ៥៩៤-៥៩៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបរិព្វាជកឈ្មោះចម្មសាដកៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កល្យាណរូបោ វតាយំ** ដូច្នេះជាដើម ។

បានឮថា បរិព្វាជកនោះ មានស្បែកប៉ុណ្ណោះជាគ្រឿងស្លៀក និងគ្រឿងដណ្ដប់ ។ ថ្ងៃមួយបរិព្វាជកនោះ ចេញអំពីអារាមរបស់បរិព្វាជក ត្រាច់ភិក្ខាទៅក្នុងនគរសាវត្ថី ដល់ទីដែលពួកពពែជល់គ្នា ។ ពពែឃើញបរិព្វាជកនោះមានបំណងនឹងជល់ទើបថយ ។ បរិព្វាជកមិនចៀសចេញដោយគិតថា ពពែនេះសម្ដែងនូវការគោរពអញ ។ ពពែស្ទុះមកដោយរហ័សជល់បរិព្វាជកនោះត្រង់ភ្លៅធ្វើឲ្យដួលចុះ ។ ហេតុដែលគាត់សរសើរពពែនោះ ដែលមិនមែនជាសប្បុរស បានប្រាជកដល់ពួកភិក្ខុ ។ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ចម្មសាដកបរិព្វាជក ធ្វើនូវការសរសើរអសប្បុរសដល់នូវសេចក្ដីវិនាស ។ ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន បរិព្វាជកនេះក៏បានសរសើរអសប្បុរសហើយ ក៏ដល់នូវសេចក្ដីវិនាសដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកជំនួញមួយ ចម្រើនវ័យហើយ ធ្វើនូវការជួញដូរ ។ ក្នុងកាលនោះ មានចម្មសាដកបរិព្វាជកម្នាក់ ត្រាច់កិក្ខាទៅក្នុងនគរពារាណសី ដល់ស្ថានទីដែលពួកពពែជល់គ្នា ឃើញពពែមួយបន្ទាបខ្លួនក៏មិនចៀសចេញទៅ ដោយសម្គាល់ថា ពពែធ្វើសេចក្តីគោរពក្នុងអញ គិតថា ក្នុងរវាងពួកមនុស្សមានប្រមាណប៉ុណ្ណេះ ពពែមួយគង់ដឹងគុណរបស់អញ ទើបឈរប្រណម្យដៃពោលគាថាទី ១ ថា

ឱ ពពែដ៏ប្រសើរនេះ ជាសត្វជើង ៤ មានសភាពល្អ ដ៏ចម្រើនល្អ មានមារយាទជាទីស្រឡាញ់ មានយស តែងគោរពព្រាហ្មណ៍អ្នកបរិបូណ៌ដោយជាតិនិងមន្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កល្យាណរូបោ** បានដល់ មានជាតិកំណើតល្អ ។ បទថា **សុបេសលោ** បានដល់ មានសីលជាទីស្រឡាញ់ដោយល្អ ។ បទថា **ជាតិមន្តូបបន្នំ** បានដល់ សម្បូរដោយជាតិ និងមន្តទាំងឡាយ ។ បទថា **យសស្សី** នេះ ជាបទពោលដល់គុណ ។

ខណៈនោះ ឈ្មួញជាបណ្ឌិតអង្គុយនៅត្រង់ផ្សារ កាលនឹងឃាត់បរិព្វាជកនោះ ទើបពោលគាថាទី ២ ថា

ម្នាលព្រាហ្មណ៍ អ្នកកុំស្និទ្ធស្នាលនឹងសត្វជើង ៤ ដោយការឃើញមួយរំពេចឡើយ ដ្បិតសត្វពពែនេះ ប្រាថ្នានឹងធ្វើនូវការប្រហារដ៏មាំ បានជាថយក្រោយ នឹងព្រលែងនូវការប្រ-

ហារឲ្យឆ្ងាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥត្តរទស្សនេន** សេចក្ដីថា ត្រឹមតែឃើញមួយរំពេច ។

កាលឈ្មួញជាបណ្ឌិត កំពុងពោលនោះឯង ពពែស្ទុះមកដោយរហ័សដល់ត្រង់ភ្លៅឲ្យបរិព្វាជកនោះដួលក្នុងទីនោះឯង ធ្វើឲ្យបានទទួលទុក្ខវេទនា ។ បរិព្វាជកនោះ ដេកបរិទេវនាការ ។

ព្រះសាស្ដាកាលទ្រង់ប្រកាសហេតុនោះ ទើបត្រាស់គាថាទី ៣ ថា

ឆ្អឹងភ្លៅរបស់ព្រាហ្មណ៍ក៏បាក់ អម្រែករបស់ព្រាហ្មណ៍ក៏ធ្លាក់
ចុះ ទ្រព្យទាំងអស់របស់ព្រាហ្មណ៍ ក៏បែកហើយ ព្រាហ្មណ៍
លើកដៃទាំងពីរឡើងកន្ទក់កន្ទេញថា ពពែស្ទុះមកសម្លាប់ព្រហ្ម
ចារីបុគ្គល ដូច្នេះ ។

អត្ថនៃពាក្យដែលជាគាថានោះ មានដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឆ្អឹងភ្លៅរបស់បរិព្វាជកនោះក៏បាក់អម្រែកបរិក្ខារក៏ធ្លាក់ចុះកាលបរិព្វាជកនោះរមៀលទៅ កណ្ឌៈជាគ្រឿងឧបករណ៍របស់ព្រាហ្មណ៍នោះក៏បែកអស់ ។ ព្រាហ្មណ៍លើកដៃទាំងពីរឡើងពោលសំដៅយកបរិស័ទដែលឈរថា ជួយផង ពពែជល់ព្រហ្មចារីដូច្នេះ កន្ទក់កន្ទេញទ្រហោយំ បរិទេវនាការ ហើយពោលគាថាទី ៤ ថា

ខ្ញុំជាមនុស្សឥតប្រាជ្ញា ត្រូវពពែបុះសម្លាប់ក្នុងថ្ងៃនេះយ៉ាងណា
បុគ្គលណាសរសើរបុគ្គលដែលមិនគួរបូជា បុគ្គលនោះត្រូវគេ

សម្លាប់ជេកនៅ ( ក្នុងទីនេះ ) យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អប្បត្តំ** បានដល់ ដែលមិនគួរបូជា ។ បទថា **យថាហមជ្ជ** សេចក្ដីថា ដូចយើងឈរសរសើរអសប្បុរស ត្រូវពពែបុះដ៏ខ្លាំងរហូតស្លាប់ក្នុងទីនេះ ក្នុងថ្ងៃនេះឯង ។ បទថា **ទុម្មតិ** បានដល់ មិនមានបញ្ញា អធិប្បាយថា បុគ្គលដទៃណា ធ្វើការសរសើរនូវអសប្បុរស បុគ្គលនោះរមែងសោយសេចក្ដីទុក្ខដូចខ្ញុំដូច្នោះ ។

បរិព្វាជកកន្ទក់កន្ទេញដោយប្រការដូច្នេះ ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រជុំជាតកថា បរិព្វាជកឈ្មោះចម្មសាដកក្នុងកាលនោះ បានមកជាបរិព្វាជកចម្មសាដកក្នុងកាលឥឡូវនេះ ចំណែកពាណិជ្ជ ដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ចម្មសាដកជាតក ចប់**

# គោធជាតក

[ ៥៩៨ ] ( ទន្សងពោធិសត្វនិយាយនឹងតាបសថា ) ខ្ញុំស្មានអ្នកថាជាសមណៈ បានចូលទៅរកអ្នក ជាអ្នកមិនសង្រួម អ្នកនោះប្រហារខ្ញុំដោយដំបងដូចមនុស្សមិនមែនជាសមណៈដែរ ។

[ ៥៩៩ ] ម្នាលតាបសកម្លៅ ប្រយោជន៍អ្វីដោយផ្នួងសក់របស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ខាងក្នុងរបស់អ្នកស្មុគស្មាញដោយកិលេស អ្នកបោសរំលីងតែសរីរៈខាងក្រៅ ។

[ ៦០០ ] ( តាបសនិយាយថា ) នែទន្សង ឯងចូរមកណេះ ឯងត្រឡប់មកវិញ ចូរបរិភោគបាយស្រូវសាលីចុះ ប្រេងនិងអំបិលរបស់អញក៏មាន ដីប្លីរបស់អញក៏មានច្រើន ។

[ ៦០១ ] ( ទន្សងឆ្លើយថា ) ខ្ញុំនោះនឹងចូលទៅរកដំបូក ជម្រៅ ១០០ ជួរបុរសយ៉ាងក្រៃលែង ថ្វីបើអ្នកឯងមានប្រេងនិងអំបិល ដីប្លីរបស់អ្នកមិនជាប្រយោជន៍ដល់ខ្ញុំឡើយ ។

**ចប់ គោធជាតកទី ៥ ។**

# អដ្ឋកថា

# គោធជាតក

[ ៥៩៨-៦០១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **សមណាន្តំ មញ្ញមានោ** ដូច្នេះជាដើម ។

រឿងបានឲ្យពិស្តារហើយខាងដើមនោះឯង ។ សូម្បីក្នុងរឿងនេះ ភិក្ខុទាំងឡាយក៏នាំភិក្ខុនោះមកបង្ហាញដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុនេះជាអ្នកកុហក ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏កុហកដូចគ្នា ហើយទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតទន្សង លុះចម្រើនវ័យ ដល់ព្រមដោយកម្លាំងកាយនៅក្នុងព្រៃ ។ តាបសទ្រុស្តសីលម្នាក់ សាងសាលាស្លឹកមិនឆ្ងាយអំពីទីដែលព្រះពោធិសត្វរស់នៅនោះ ហើយសម្រេចការនៅ ។ ព្រះពោធិសត្វស្វែងរកចំណី បានឃើញបណ្ណសាលានោះ ហើយគិតថា ជាបណ្ណសាលារបស់តាបសអ្នកមានសីល ទើបទៅក្នុងទីនោះថ្វាយបង្គំតាបស ហើយទៅកាន់លំនៅរបស់ខ្លួន ។ ថ្ងៃមួយតាបសកោងនោះ បានសាច់ឆ្ងាញ់ដែលគេចម្អិនស្រេចហើយក្នុងត្រកូលឧបដ្ឋាកទាំងឡាយទើបសួរថា នេះជាសាច់អ្វី បានឮថា ជាសាច់ទន្សង ជាអ្នកត្រូវចំណង់ក្នុងរសគ្របសង្កត់ គិតថា អញនឹង

សម្លាប់ទន្សោងដែលមកកាន់អាស្រមបទរបស់អញជាប្រចាំ ហើយស្ងួស៊ីតាមគាប់ចិត្ត ទើបកាន់យកសប្បិ ទធិ និងកណ្ឌៈជាគ្រឿងក្តៅជាដើម ទៅកាន់អាស្រមបទនោះ យកសំពត់កាសាវៈបិទបាំងដំបងទុក ហើយអង្គុយរង់ចាំការមករបស់ព្រះពោធិសត្វ ធ្វើអាកប្បកិរិយាស្ងប់ស្ងាត់ពន់ពេក ត្រង់ទ្វារបណ្ណសាលា ព្រះពោធិសត្វនោះមកហើយ ឃើញតាបសមានអាកប្បកិរិយាចំឡែកគិតថា តាបសនេះនឹងបានស៊ីសាច់សត្វដែលមានជាតិដូចអញ អញនឹងឃ្លាំមើលតាបសនោះ ទើបឈរក្នុងទីក្រោមខ្យល់ បានទូវក្លិនខ្លួនដឹងថាតាបសបរិភោគសាច់សត្វដែលមានជាតិស្មើនឹងខ្លួន ទើបមិនចូលទៅរកតាបសបានថយចេញទៅហើយ ។ ចំណែកតាបសនោះ ដឹងអាការៈដែលព្រះពោធិសត្វមិនចូលមក ទើបគ្រវែងដំបងទៅ ។ ដំបងមិនត្រូវត្រង់ខ្លួនព្រះពោធិសត្វ តែត្រូវត្រង់ចុងកន្ទុយ ។ តាបសពោលថាទៅចុះ អញគ្រវែងខុសហើយ ។ ព្រះពោធិសត្វពោលថា ខាងដើមលោកគ្រវែងខ្ញុំខុស តែមិនខុសក្នុងអបាយទាំង ៤ ហើយគេចចូលទៅក្នុងដំបូកដែលតាំងនៅខាងចុងទីចង្រ្កម អើតក្បាលចេញមកតាមរន្ធដទៃ កាលនឹងចរចាជាមួយតាបសនោះ បានពោលគាថា ២ ថា

ខ្ញុំស្មានអ្នកថាជាសមណៈ បានចូលទៅរកអ្នក ជាអ្នកមិនសង្រួម អ្នកនោះប្រហារខ្ញុំដោយដំបង ដូចមនុស្សមិនមែនជាសមណៈដែរ ។

ម្នាលតាបសកម្លៅ ប្រយោជន៍អ្វីដោយផ្នួងសក់ របស់អ្នក

ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំ របស់អ្នក ខាងក្នុងរបស់អ្នក
សាំញ៉ាំដោយកិលេស អ្នកបោសរំលីងតែសរីរៈ ខាងក្រៅ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសញ្ញតំ** សេចក្ដីថា ខ្ញុំសម្គាល់លោកអ្នក មិនសង្រួមផ្លូវកាយជាដើម គឺដែលមិនជាសមណៈថា ឈ្មោះថាជាសមណៈ ព្រោះជាអ្នកស្ងប់រម្ងាប់ ដោយភាពជាអ្នកស្ងប់រម្ងាប់បាប ដោយគិតថា បុគ្គល នេះជាសមណៈ ទើបចូលទៅរក ។ បទថា **ចាហាសិ** បានដល់ គ្រវែង ហើយ ។ បទថា **អជិនសាដិយា** សេចក្ដីថា ប្រយោជន៍អ្វីដល់លោកដោយ ស្បែកខ្លាដែលចៀងស្នា ។ បទថា **អព្ភន្តរន្តេ** សេចក្ដីថា ខាងក្នុងរាងកាយ របស់លោកសាំញ៉ាំដោយកិលេស ដូចឃ្លោកពេញដោយថ្នាំពិស ដូចរណ្ដៅ ពេញដោយលាមក ដូចដំបូកពេញដោយអាសិរពិស ។ បទថា **ពាហិរំ** សេចក្ដីថា រាងកាយខាងក្រៅប៉ុណ្ណោះរលោងរលាំ គឺរមែងដូចជាលាមកដំរី លាមក សេះ ព្រោះខាងក្នុងគ្រោតគ្រាត ខាងក្រៅរលោង ។ តាបសបានស្ដាប់ដូច្នោះ ក៏ពោលគាថាទី ៣ ថា

នែទទង្វេង ឯងចូរមកណេះ ឯងត្រឡប់មកវិញ ចូរបរិភោគ
បាយស្រូវសាលីចុះ ប្រេងនិងអំបិលរបស់អញក៏មាន ដីប្លី
របស់អញ ក៏មានច្រើន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បហុតំ មយ្ហំ បិប្ផលិ** សេចក្ដីថា មិនមែន មានតែបាយនៃស្រូវសាលី ប្រេងនិងអំបិលតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីគ្រឿង

ទេស ដូចជាហិង្គុ ក្រវាញ ខ្ញី ខ្ទឹម ម្រេច និងជីរីរបស់យើងក៏មានច្រើន ចូរអ្នកបរិភោគបាយនៃស្រូវសាលី ដែលចម្អិនដោយគ្រឿងទេសនោះ ។ ព្រះពោធិសត្វបានស្តាប់ដូច្នោះ ទើបពោលគាថាទី ៤ ថា

ខ្ញុំនោះនឹងចូលទៅរកដំបូកជម្រៅ ១០០ ជួរបុរស យ៉ាងក្រៃលែង ថ្វីបើអ្នកឯងមានប្រេងនិងអំបិល ជីរីរបស់អ្នកមិនជាប្រយោជន៍ដល់ខ្ញុំឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បវេក្ខាមិ** បានដល់ នឹងចូលទៅ ។ បទថា **អហិតំ** សេចក្តីថា ជីរី ពោលគឺគ្រឿងទេសរបស់លោកនោះមិនជាប្រយោជន៍ គឺមិនជាទីសប្បាយសម្រាប់ខ្ញុំ ។

ឯព្រះពោធិសត្វ កាលពោលយ៉ាងនោះហើយ ទើបគំរាមតាបសកោងនោះថា វ៉ឺយជដិលកោង បើឯងនៅក្នុងទីនេះ យើងនឹងឲ្យពួកមនុស្សក្នុងគោចរគាមចាប់ឯងថា បុគ្គលនេះជាចោរ ហើយឯងនឹងដល់នូវវិការៈ ចូរឯងគេចទៅដោយឆាប់ ។ ជដិលកោងក៏គេចទៅអំពីទីនោះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ជដិលកោងក្នុងកាលនោះ បានមកជាភិក្ខុកុហករូបនេះក្នុងកាលឥឡូវនេះ ចំណែកស្តេចទន្សងក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា គោធជាតក ចប់**

## កណ្ណារុជាតក

[ ៦០២ ] ( ទេវបុត្តជាធំពោលថា ) បុគ្គលណាមិនលួចទ្រព្យគេដោយកាយ មិននិយាយកុហកដោយវាចា បានយសសក្តិហើយមិនស្រវឹង បុគ្គលនោះឯង គួរប្រដាប់ផ្កាត្រឡាចជាទិព្វទាំងឡាយ ។

[ ៦០៣ ] ( ទេវបុត្តទី ២ ពោលថា ) បុគ្គលណាស្វះស្វែងរកទ្រព្យដោយធម៌ មិននាំយកទ្រព្យគេដោយបោកប្រាស់ បានទ្រព្យទាំងឡាយហើយមិនស្រវឹង បុគ្គលនោះឯង ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន ។

[ ៦០៤ ] ( ទេវបុត្តទី ៣ ពោលថា ) បុគ្គលណាមានចិត្តមិនដាច់ហើរដូចរមៀត មានសទ្ធាមិនរសាយ មិនបរិភោគវត្ថុមានរសឆ្ងាញ់តែម្នាក់ឯង បុគ្គលនោះ ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន ។

[ ៦០៥ ] ( ទេវបុត្តទី ៤ ពោលថា ) បុគ្គលណា មិនជេរប្រទេចពួកសប្បុរសក្នុងទីចំពោះមុខឬកំបាំងមុខ ជាអ្នកនិយាយយ៉ាងណា ធ្វើយ៉ាងនោះ បុគ្គលនោះ ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន ។

**ចប់ កណ្ណារុជាតកទី ៦ ។**

## អដ្ឋកថា

## កណ្ណារុជាតក

[ ៦០២-៦០៥ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាយេន យោ**

**ឆាវហារ** ដូច្នេះជាដើម ។

បានឮថា កាលទេវទត្តនោះបំបែកសង្ឃហើយយ៉ាងនោះ កាលបរិស័ទចៀសចេញទៅជាមួយអគ្គសាវក លោហិតដ៏ក្តៅបានហូរចេញអំពីមាត់ ។ លំដាប់នោះ ភិក្ខុទាំងឡាយ បានសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តពោលមុសាវាទបំបែកសង្ឃ ឥឡូវនេះមានជំងឺសោយទុក្ខវេទនាច្រើន ព្រះសាស្តាយាងមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នក អង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តនេះ ក៏បានជាអ្នកពោលកុហកដូចគ្នា ម្យ៉ាងទៀត ទេវទត្តនេះពោលមុសាវាទបំបែកសង្ឃហើយមានជំងឺបានសោយទុក្ខច្រើនក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានសោយទុក្ខច្រើនហើយដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាទេវបុត្តមួយអង្គក្នុងឋានតាវត្តិង្ស ។ សម័យនោះឯងនគរពារាណសីមានលេងមហោស្រពធំ ពួកនាគ គ្រុឌនិងភុម្មដ្ឋកទេវតាជាច្រើននាំគ្នាមកមើលមហោស្រព ។ ទេវបុត្ត ៤ អង្គមកអំពីតាវត្តិង្ស ក៏ប្រដាប់មកុដដែលធ្វើដោយកម្រងផ្កាទិព្វ ឈ្មោះកក្ការុ នាំគ្នាមកកាន់ទីមើលមហោស្រព ។ ព្រះនគរប្រមាណ ១២ យោជន៍មានក្លិនតែមួយ គឺក្លិនផ្កាទាំងនោះ ។ មនុស្ស

ទាំងឡាយត្រាច់សាកសួរថា អ្នកណាប្រដាប់ផ្កាទាំងនេះ ។ ទេវបុត្តទាំងនោះដឹងថា មនុស្សស្មើបសួររកពួកខ្លួន ទើបហោះទៅកាន់លានព្រះរាជវាំង ឈរក្នុងអាកាសដោយទេវានុភាពធំ ។ មហាជនប្រជុំគ្នា ព្រះរាជាក្តី ឧបរាជជា-ដើមក្តី ក៏នាំគ្នាមក ។ ពេលនោះ ទើបព្រះរាជានិងឥស្សរជនទាំងនោះ នាំគ្នាសួរទេវបុត្តទាំងនោះថា បពិត្រលោកទាំងឡាយ លោកមកអំពីទេវលោកជាន់ណា ទេវបុត្តពោលថា ខ្ញុំមកអំពីទេវលោកជាន់តាវត្តិង្ស ពួកមនុស្សទាំងឡាយសួរថា ពួកលោកមកដោយកិច្ចអ្វី ទេវបុត្តពោលថា មកដោយបំណងមើលមហោស្រព ពួកមនុស្សសួរថា នេះឈ្មោះថាជាផ្កាអ្វី ទេវបុត្តពោលថា នេះជាផ្កាត្រឡាចទិព្វ ។ មនុស្សទាំងឡាយពោលថា លោកទាំងឡាយចូរប្រដាប់ផ្កាដទៃក្នុងទេវលោកចុះ សូមឲ្យផ្កាត្រឡាចទិព្វនេះដល់ពួកយើង ។ ទេវបុត្តទាំងឡាយពោលថា ផ្កាត្រឡាចទិព្វនេះមានអានុភាពច្រើន សមគួរដល់ទេវតាទាំងឡាយប៉ុណ្ណោះ មិនសមគួរដល់បុគ្គលថោកថយអប្បឥតប្រាជ្ញា មានអធ្យាស្រ័យបង្អោនទៅក្នុងផ្លូវថោកទាប ទ្រុស្តសីលក្នុងមនុស្សលោក តែសមគួរដល់មនុស្សទាំងឡាយដែលប្រកបដោយគុណនេះៗ ។ កាលពោលយ៉ាងនេះហើយ ទេវបុត្តជាធំក្នុងទេវបុត្ត ៤ អង្គនោះពោលគាថាទី ១ ថា

> បុគ្គលណា មិនលួចទ្រព្យគេដោយកាយ មិននិយាយកុហក
> ដោយវាចា បានយសសក្តិហើយមិនស្រវឹង បុគ្គលនោះឯង
> គួរប្រដាប់ផ្កាត្រឡាចជាទិព្វទាំងឡាយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុគ្គលណាមិនលួច សូម្បី

ត្រឹមតែស្មៅ របស់អ្នកដទៃដោយកាយ សូម្បីលះជីវិតក៏មិនពោលមុសាវាទ ដោយវាចា ។ ពាក្យនេះត្រឹមតែជាមាតិកាទេសនាប៉ុណ្ណោះ ។ ក្នុងពាក្យនេះ មានអធិប្បាយដូច្នេះថា បុគ្គលណា មិនធ្វើអកុសលកម្មបថទាំង ១០ ដោយ កាយទ្វារ វចីទ្វារនិងមនោទ្វារ ។ បទថា **យសោ លទ្ធា** សេចក្ដីថា បុគ្គល ណា បានភាពជាធំហើយ មិនស្រវឹងក្នុងភាពជាធំ មិនធ្វើនូវកម្មលាមក ព្រោះ លះបង់ស្មារតី បុគ្គលប្រកបដោយគុណទាំងនេះនោះឯង រមែងគួរដល់ផ្កាទិព្វ នេះ ព្រោះហេតុនោះ បុគ្គលណា ប្រកបដោយគុណទាំងនេះ បុគ្គលនោះរមែង គួរសូមផ្កាទាំងនេះ ពួកយើងនឹងឲ្យដល់បុគ្គលនោះ ។

បុរោហិតស្ដាប់ដូច្នោះគិតថា អញមិនមានគុណទាំងនេះ សូម្បីតែមួយតែ អញនឹងពោលមុសាវាទ ទទួលយកផ្កានេះមកប្រដាប់ កាលបើយ៉ាងនេះ មហាជននឹងដឹងអញថា ជាអ្នកសម្បូរដោយគុណ ។ បុរោហិតនោះក៏ពោល ថា យើងជាអ្នកប្រកបដោយគុណទាំងនេះ ទើបឲ្យនាំផ្កាទាំងនោះមកប្រដាប់ ហើយបានអង្វរទេវបុត្តអង្គទី ២ ទេវបុត្តអង្គទី ២ នោះក៏ពោលគាថាទី ២ ថា

> បុគ្គលណា ស្វះស្វែងរកទ្រព្យដោយធម៌ មិននាំយកទ្រព្យគេ
> ដោយបោកប្រាស់បានទ្រព្យទាំងឡាយហើយមិនស្រវឹងបុគ្គល
> នោះឯង ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុគ្គលគប្បីស្វែងរកទ្រព្យមាន មាសនិងប្រាក់ជាដើមដោយធម៌ គឺដោយអាជីវៈបរិសុទ្ធ មិនគប្បីស្វែងរកដោយ ការបោកបញ្ឆោត គឺមិនគប្បីនាំយកទៅដោយការបោកបញ្ឆោត បាននូវភោគៈ

ទាំងឡាយ មានសំពត់ និងអាភរណៈជាដើម មិនគប្បីស្រវឹងដោយសេចក្តីប្រមាទ បុគ្គលបែបនេះរមែងគួរដល់ផ្កាទាំងនេះ ។

បុរោហិតពោលថា យើងជាបុគ្គលប្រកបដោយគុណទាំងនេះ ហើយឲ្យនាំផ្កាទិព្វមកប្រដាប់ ទើបអង្វរទេវបុត្តអង្គទី ៣ ទេវបុត្តអង្គទី ៣ ក៏ពោលគាថាទី ៣ ថា

បុគ្គលណា មានចិត្តមិនដាច់ហើរដូចរមៀត មានសទ្ធាមិន
រសាយ មិនបរិភោគវត្ថុមានរសឆ្ងាញ់តែម្នាក់ឯង បុគ្គលនោះ
ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុគ្គលមានចិត្តមិនដាច់ហើរដូចជារមៀត គឺមិនដាច់សាបពណ៌ដូចជ្រលក់ដោយរមៀត បានដល់ មានសេចក្តីស្រឡាញ់មាំទាំ និងមានសទ្ធាមិនប្រែប្រួល គឺបានស្តាប់ពាក្យអ្នកជឿកម្មឬវិបាករបស់កម្ម ហើយជឿមិនប្រែប្រួល មិនបែកធ្លាយដោយហេតុត្រឹមបន្តិចបន្តួច បុគ្គលណា មិនរារាំងយាចក ឬអ្នកដទៃដែលគួរដល់ការឲ្យខាងក្រៅ មិនបរិភោគភោជនដែលមានរសល្អតែឯង គឺចែកឲ្យដល់ជនទាំងនោះហើយ ទើបបរិភោគ បុគ្គលនោះរមែងគួរដល់ផ្កាទាំងនោះ ។

បុរោហិតពោលថា យើងជាបុគ្គលប្រកបដោយគុណទាំងនេះ ទើបឲ្យនាំផ្កាទាំងនោះមកប្រដាប់ ហើយអង្វរទេវបុត្តទី ៤ ទេវបុត្តទី ៤ នោះក៏ពោលគាថាទី ៤ ថា

បុគ្គលណា មិនជេរប្រទេចពួកសប្បុរស ក្នុងទីចំពោះមុខ ឬ

កំបាំងមុខ ជាអ្នកនិយាយយ៉ាងណាធ្វើយ៉ាងនោះ បុគ្គលនោះ
ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បុគ្គលណាមិនជេរមិនបរិភាសសប្បុរស គឺបុរសដែលជាឧត្តមបណ្ឌិតដែលប្រកបដោយគុណ មានសីលជាដើមក្នុងទីចំពោះមុខ ឬទីកំបាំងមុខ ពោលដល់វត្ថុណាដោយវាចា រមែងធ្វើវត្ថុនោះឯងដោយកាយ បុគ្គលនោះ រមែងគួរដល់ផ្កាទាំងនេះ ។

បុរោហិតពោលថា យើងជាអ្នកប្រកបដោយគុណទាំងនេះ ហើយឲ្យនាំផ្កាទាំងនោះមកប្រដាប់ ។ ទេវបុត្តទាំង ៤ អង្គបានឲ្យមកុដផ្កាទាំង ៤ ដល់បុរោហិត ហើយនាំគ្នាត្រឡប់ទៅកាន់ទេវលោក ។ ក្នុងកាលដែលទេវបុត្តទាំងនោះទៅហើយ វេទនាក៏ខ្លាំងក្រៃលែងកើតឡើងត្រង់ក្បាលបុរោហិត ក្បាលដូចត្រូវចាក់ដោយកំពូលភ្នំស្រួច និងដូចត្រូវចងរឹតដោយបន្ទះដែកដូច្នោះ ។ បុរោហិតបានទទួលទុក្ខវេទនា បម្រះនទៀលទៅមក ស្រែកដោយសំឡេងខ្លាំង កាលមហាជនសួរថា តើអ្នកកើតអ្វី ក៏ពោលថា ខ្ញុំពោលមុសាវាទក្នុងគុណដែលមិនមានខាងក្នុងថាមាន ហើយសូមផ្កាទាំងនេះនឹងទេវបុត្តទាំងនោះ អ្នកទាំងឡាយ ជួយនាំយកផ្កាទាំងនេះចេញអំពីក្បាលខ្ញុំផងចុះ ។ ទោះជនទាំងឡាយ នាំគ្នាជួយដោះ ក៏មិនអាចដោះបាន ដូចជាត្រូវចងដោយបន្ទះដែកលំដាប់នោះ ជនទាំងឡាយក៏សែងបុរោហិតនោះទៅផ្ទះ ។ កាលបុរោហិតនោះស្រែកក្នុងផ្ទះអស់កាល ៧ ថ្ងៃ ព្រះរាជាហៅអាមាត្យទាំងឡាយមកហើយត្រាស់ថា ព្រាហ្មណ៍ទ្រុស្តសីលនឹងស្លាប់ តើយើងនឹងធ្វើដូចម្តេច អាមាត្យទាំង

ឡាយនោះទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ឲ្យលេងមហោស្រពម្តង ទៀតចុះ ទេវបុត្តទាំងឡាយនឹងមកទៀត ។ ទើបព្រះរាជាឲ្យលេងមហោស្រព ម្តងទៀត ទេវបុត្តទាំងឡាយក៏មកទៀត បានធ្វើនគរទាំងមូលឲ្យមានក្លិនក្រអូប តែមួយដោយក្លិនផ្កា ហើយឈរត្រង់លានព្រះរាជវាំងដូចមុន ។ មហាជន ប្រជុំគ្នា ហើយនាំព្រាហ្មណ៍ទ្រុស្តសីលមកឲ្យ ដេកផ្ងារក្នុងទីចំពោះមុខនៃទេវ បុត្តទាំងនោះ ព្រាហ្មណ៍បុរោហិតនោះបានអង្វរទេវបុត្តទាំងឡាយថា នៃអ្នក សូមអ្នកទាំងឡាយ ឲ្យជីវិតដល់ខ្ញុំចុះ ទេវបុត្តទាំងនោះ តិះដៀលព្រាហ្មណ៍ បុរោហិតក្នុងកណ្តាលមហាជនថា ផ្កាទាំងនេះមិនសមគួរដល់អ្នកដែលជាបុគ្គល លាមកទ្រុស្តសីល មានបាបធម៌ អ្នកបានសម្គាល់ថា នឹងបញ្ឆោតទេវបុត្តទាំង នេះ គួរអាសូរ អ្នកបានទទួលផលនៃមុសាវាទរបស់ខ្លួនហើយ លុះតិះដៀល ហើយ ក៏ដោះមកុដផ្កាចេញអំពីក្បាល ឲ្យឱវាទដល់មហាជន ហើយបានទៅ កាន់ឋានរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើប ទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាល ឥឡូវនេះ បណ្តាទេវបុត្តទាំងនោះ ទេវបុត្តមួយអង្គ បានមកជាកស្សបៈ ទេវបុត្តមួយអង្គ បានមកជាមោគ្គល្លាន ទេវបុត្តមួយអង្គ បានមកជាសារីបុត្ត ចំណែកទេវបុត្តដែលជាប្រធានក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កក្ការុជាតក ចប់**

## កាកាតិជាតក

[ ៦០៦ ] ( នដកុវេរគន្ធព្វច្រៀងថា ) ស្ត្រីជាទីស្រឡាញ់របស់ទូលព្រះបង្គំ នៅក្នុងទីណា ក្លិនក្រអូបនេះក៏បក់មកអំពីទីនោះ ចិត្តរបស់ទូលព្រះបង្គំត្រេកអរក្នុងស្ត្រីណា ស្ត្រីនោះឈ្មោះនាងកាកាតិ ទៅនៅក្នុងទីឆ្ងាយអំពីទីនេះ ។

[ ៦០៧ ] ( ស្តេចគ្រុឌពោលថា ) អ្នកបានឆ្លងសមុទ្រដោយឧបាយដូចម្តេច បានឆ្លងទន្លេឈ្មោះកេបុកៈដោយឧបាយដូចម្តេច បានឆ្លងសមុទ្រទាំង ៧ ជាន់ដោយឧបាយដូចម្តេច បានឡើងដើមរកា ( ជាលំនៅរបស់យើង ) ដោយឧបាយដូចម្តេច ។

[ ៦០៨ ] ( នដកុវេរគន្ធព្វឆ្លើយតបថា ) ខ្ញុំបានឆ្លងសមុទ្រជាមួយនឹងលោក បានឆ្លងទន្លេឈ្មោះកេបុកៈជាមួយនឹងលោក បានឆ្លងសមុទ្រទាំង ៧ ជាន់ជាមួយនឹងលោក បានឡើងដើមរកាជាមួយនឹងលោក ។

[ ៦០៩ ] ( ស្តេចគ្រុឌពោលថា ) អញនាំមកទាំងនាំទៅនូវសហាយរបស់ប្រពន្ធ ហេតុណា ហេតុនោះ គួរតិះដៀលខ្លួនអញ មានកាយធំ គួរតិះដៀលខ្លួនអញដែលមិនមានគំនិត ។

**ចប់ កាកាតិជាតកទី ៧ ។**

## អដ្ឋកថា

## កាកាតិជាតក

[ ៦០៦-៦០៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **វាតិ ចាយំ តតោ គន្ធោ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ព្រោះហេតុអ្វីទើបអ្នកអផ្សុក ភិក្ខុនោះក្រាបទូលថា ព្រោះអំណាចកិលេស ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ធម្មតាមាតុគ្រាម បុគ្គលណាមួយក៏រក្សាមិនបាន បុគ្គលណាមួយ ក៏មិនអាចរក្សា បុរាណកបណ្ឌិតទាំងឡាយក្នុងកាលមុន សូម្បីលើកមាតុគ្រាមដាក់លើវិមានដើមរកាក្នុងកណ្ដាលមហាសមុទ្រក៏មិនអាចរក្សាទុកបាន ទើបទ្រង់នាំយកអតីតនិទាន មកសាធក: ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងព្រះឧទរអគ្គមហេសីនៃព្រះរាជាអង្គនោះ លុះចម្រើនវ័យហើយ កាលព្រះរាជបិតាសោយទិវង្គត ក៏គ្រងរាជសម្បត្តិ ។ អគ្គមហេសីរបស់ព្រះពោធិសត្វនោះព្រះនាមថាកាកវតី មានព្រះរូបឆោមលោមពណ៌ស្អាតដូចទេពអប្សរ នេះជាសេចក្ដីសង្ខេបក្នុងជាតកនេះ ចំណែករឿងអតីតៈដោយពិស្ដារ មានជាក់ច្បាស់ក្នុងកុណាលជាតក ។ ក្នុងកាលនោះ ស្ដេចគ្រុឌមួយកាឡាខ្លួនជាមនុស្ស លេងបាស្កាជាមួយព្រះរាជា មានចិត្តប្រតិព័ទ្ធក្នុងនាងកា

កវតីអគ្គមហេសី ទើបនាំនាងទៅកាន់សុបណ្ណភព គឺឋានគ្រុឌ ហើយរួម អភិរម្យជាមួយព្រះនាងនោះ ។ ព្រះរាជាកាលមិនឃើញព្រះទេវី ទើបត្រាស់ នឹងគន្ធព្វឈ្មោះនដកុវេរៈថា ចូរអ្នកស្វែងរកព្រះទេវី ។ គន្ធព្វនោះ ទើប កំណត់យកស្តេចគ្រុឌនោះ ក៏ដេកក្នុងព្រៃរទឹកក្នុងស្រះមួយកន្លែង ក្នុងពេល ស្តេចគ្រុឌនោះទៅអំពីស្រះនោះ បានតោងក្នុងរវាងស្លាបទៅដល់សុបណ្ណភព ហើយចេញអំពីរវាងស្លាប ធ្វើការបេបោសអង្អែលដោយកិលេសជាមួយ ព្រះ ទេវីនោះ ហើយតោងក្នុងរវាងស្លាបរបស់គ្រុឌត្រឡប់មកវិញ ។ ក្នុងកាល ស្តេចគ្រុឌលេងបាស្កាជាមួយព្រះរាជា ទើបកាន់យកពិណរបស់ខ្លួន មកកាន់ កន្លែងលេងបាស្កា ឈរក្នុងរាជសម្នាក់ ហើយច្រៀងគាថាទី ១ ថា

ស្ត្រីជាទីស្រឡាញ់របស់ទូលព្រះបង្គំ នៅក្នុងទីណា ក្លិនក្រអូប នេះ ក៏បក់មកអំពីទីនោះ ចិត្តរបស់ទូលព្រះបង្គំត្រេកអរក្នុង ស្ត្រីណា ស្ត្រីនោះឈ្មោះនាងកាកាតិ ទៅនៅក្នុងទីឆ្ងាយអំពីទី នេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គន្ធោ** បានដល់ ក្លិននៃរាងកាយរបស់នាង លាបដោយក្លិនទិព្វ ។ បទថា **យត្ថ មេ** សេចក្តីថា ស្រីជាទីស្រឡាញ់របស់ ខ្ញុំ នៅក្នុងសុបណ្ណភពណា អធិប្បាយថា ព្រះនាងធ្វើការបេបោសអង្អែលកាយ ជាមួយស្តេចគ្រុឌនេះ ក្លិនរបស់នាងជាប់មកតាមរាងកាយរបស់ស្តេចគ្រុឌនេះ ទើបឈ្មោះថា បក់មកអំពីទីនោះ ។ បទថា **ទូរេ ឥតោ** បានដល់ ក្នុងទី ឆ្ងាយអំពីទីនេះ ។ **ហិ** អក្ខរៈ ត្រឹមតែជានិបាត ។ បទថា **កាកាវតី** បាន

ដល់ ព្រះទេវីព្រះនាមថាកាកវតី ។ បទថា **យត្ថ មេ** សេចក្តីថា ចិត្តរបស់ខ្ញុំ ត្រេកអរ គឺត្រេកអរក្រៃលែងហើយចំពោះស្ត្រីណា ។ ស្តេចគ្រុឌបានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

អ្នកបានឆ្លងសមុទ្រ ដោយឧបាយដូចម្តេច បានឆ្លងទន្លេឈ្មោះ
កេបុកៈ ដោយឧបាយដូចម្តេច បានឆ្លងសមុទ្រទាំង ៧ ជាន់
ដោយឧបាយដូចម្តេច បានឡើងដើមរកា ( ជាលំនៅរបស់
យើង ) ដោយឧបាយដូចម្តេច ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអត្ថថា អ្នកឆ្លងសមុទ្រក្នុងជម្ពូទ្វីបនេះនិងទន្លេឈ្មោះកេបុកៈបន្ទាប់អំពីសមុទ្រនោះទៅ និងសមុទ្រទាំង ៧ ដែលតាំងនៅក្នុងរវាងភ្នំទាំងឡាយបានដូចម្តេច គឺឆ្លងដោយឧបាយអ្វី ហើយអ្នកឡើងដើមរកាដែលជាកពរបស់យើងដែលតាំងនៅហួសសមុទ្រទាំង ៧ បានដូចម្តេច ។ នដកុវេរៈបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ៣ ថា

ខ្ញុំបានឆ្លងសមុទ្រជាមួយនឹងលោក បានឆ្លងទន្លេឈ្មោះកេបុកៈ ជា
មួយនឹងលោក បានឆ្លងសមុទ្រទាំង ៧ ជាន់ ជាមួយនឹងលោក
បានឡើងដើមរកា ជាមួយនឹងលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តយា** សេចក្តីថា ខ្ញុំតោងក្នុងរវាងស្លាបរបស់អ្នក ធ្វើកិច្ចទាំងពួងនេះ ព្រោះអ្នកជាហេតុ ។ លំដាប់នោះ ស្តេចគ្រុឌក៏ពោលគាថាទី ៤ ថា

អញនាំមកទាំងនាំទៅនូវសហាយរបស់ប្រពន្ធហេតុណាហេតុ

នោះ គួរតិះដៀលខ្លួនអញមានកាយធំ គួរតិះដៀលខ្លួនអញ
ដែលមិនមានគំនិត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធិរត្ថុ មំ** សេចក្ដីថា ស្ដេចគ្រុឌកាល តិះដៀលខ្លួនឯង ទើបពោលទុក ។ បទថា **អចេតនំ** បានដល់ ឈ្មោះថា **អចេតនំ** ព្រោះមិនដឹងការចូនំនិងការស្រោល ព្រោះភាពជាអ្នកមានរាងកាយធំ ។ បទថា **យត្ថ** កែជា **យស្មា** ប្រែថា ព្រោះហេតុណា ។ លោកពោលពាក្យអធិប្បាយទុកថា ព្រោះហេតុដែលយើងនាំគន្ធព្វនេះ ដែលជាសហាយរបស់ប្រពន្ធខ្លួន ដែលតោងត្រង់រវាងស្លាបមក ឈ្មោះថានាំមក កាលនាំទៅ ឈ្មោះថានាំទៅ ដូច្នោះគួរតិះដៀលខ្លួនយើង ។ ស្ដេចគ្រុឌនោះ បាននាំព្រះនាងកាកវតីនោះមកថ្វាយព្រះរាជា ហើយមិនបានមកលេងបាស្កាទៀតឡើយ ។

ព្រះសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់បានប្រជុំជាតកថា នដកុវេរៈក្នុងកាលនោះ បានមកជាភិក្ខុអផ្សុកក្នុងកាលឥឡូវនេះ ចំណែកព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កាកាតិជាតក ចប់

# អននុសោចិយជាតក

[ ៦១០ ] ( តាបសពោធិសត្វពោលថា ) នាងសម្មិល្លហាសិនី ជាស្រីដ៏ចម្រើន មានក្នុងចន្លោះពួកសត្វដ៏ច្រើន ដែលស្លាប់ហើយ ពួកសត្វដែលស្លាប់ហើយនោះ នឹងមានប្រយោជន៍អ្វីដល់ខ្ញុំ ហេតុនោះ បានជាខ្ញុំមិនសោកស្តាយនាងសម្មិល្លហាសិនី ជាទីស្រឡាញ់ទុំរះឡើយ ។

[ ៦១១ ] វត្ថុណាៗ មិនមានដល់សត្វនោះ បើសត្វគប្បីសោកស្តាយចំពោះវត្ថុដែលគ្មាននោះៗ គប្បីសោកស្តាយចំពោះខ្លួនឯង ដែលលុះក្នុងអំណាចនៃមច្ចុគ្រប់កាលផង ។

[ ៦១២ ] អាយុសង្ខារ មិនទៅតាមសត្វណាមួយ ដែលឈរ អង្គុយ ដេក ដើរទៅមកឡើយ សត្វបើកភ្នែក ធ្មេចភ្នែក ដរាបណា វ័យរបស់សត្វតែងវិកិលទៅដរាបនោះ ។

[ ៦១៣ ] កាលបើសេចក្តីព្រាត់ប្រាសក្នុងខ្លួន ជាផ្លូវឥតសង្ស័យនោះហើយ បុគ្គលគប្បីអាណិតសត្វរស់នៅដ៏សេសសល់ មិនគួរសោយសោកចំពោះសត្វដែលច្យុតហើយទេ ។

**ចប់ អននុសោចិយជាតកទី ៨ ។**

# អដ្ឋកថា

# អននុសោចិយជាតក

[ ៦១០-៦១៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ដែលមានភរិយាស្លាប់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ពហូនំ វិជ្ជតី ភោតី** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈនោះ កាលភរិយាស្លាប់ហើយ មិនងូតទឹក មិនផឹក មិនលាបស្រឡាប មិនទទួលទានបាយ មិនប្រកបការងារ ត្រូវសេចក្តីសោកគ្របសង្កត់ ទៅកាន់ឈាបនដ្ឋាន ត្រាច់បរិទេវនាការតែម្យ៉ាង ។ តែឧបនិស្ស័យនៃសោតាបត្តិមគ្គ ឆេះសន្ធោសន្ធៅខាងក្នុងរបស់កុដុម្ពិកៈនោះ ដូចប្រទីបដែលឆេះក្នុងឆ្នាំងដូច្នោះ ។ ក្នុងពេលទៀបភ្លឺ ព្រះសាស្តាទ្រង់ ប្រមើលមើលលោក បានទតឃើញកុដុម្ពិកៈនោះ ទ្រង់ព្រះតម្រិះថា វៀរតថាគតហើយ អ្នកដទៃដែលនឹងនាំសេចក្តីសោកចេញ ហើយឲ្យនូវសោតាបត្តិមគ្គ ដល់កុដុម្ពិកៈនេះមិនមាន តថាគតនឹងជាទីពឹងអាស្រ័យរបស់កុដុម្ពិកៈនោះ ដូច្នេះ កាលត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត ទ្រង់នាំបច្ឆាសមណៈទៅកាន់ទ្វារផ្ទះរបស់កុដុម្ពិកៈនោះ ជាអ្នកដែលកុដុម្ពិកៈបានឮការយាងមក ទ្រង់មានសក្ការៈ មានការក្រាកទទួលជាដើមដែលកុដុម្ពិកៈធ្វើហើយ គង់លើអាសនៈដែលគេក្រាលទុក ត្រាស់សួរកុដុម្ពិកៈ ដែលមកថ្វាយបង្គំអង្គុយក្នុងទីសមគួរក្នុងចំណែកម្ខាងថា ឧបាសក អ្នកគិតរឿងអ្វីឬ កាលកុដុម្ពិកៈនោះក្រាបទូលថា បពិត្រព្រះអង្គ ភរិយារបស់ខ្ញុំព្រះអង្គស្លាប់ ខ្ញុំព្រះអង្គសោកដល់នាងទើប

គិត ។ ព្រះសាស្តាត្រាស់ថា ឧបាសក ឈ្មោះថារបស់ដែលមានការបែក ជាធម្មតារមែងបែកទៅ កាលរបស់នោះបែកហើយ មិនគួរគិត សូម្បីបុរាណកបណ្ឌិតទាំងឡាយ កាលភរិយាស្លាប់ហើយក៏គង់មិនគិត ( ជ្រួត ) ថា របស់ដែលមានការបែកជាធម្មតា បានបែកទៅហើយ កាលកុដុម្ពិកៈនោះទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

រឿងក្នុងអតីតៈមានច្បាស់ក្នុងចុល្លពោធិជាតក ក្នុងទសកនិបាត ចំណែកក្នុងទីនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយបានរៀនសិល្បសាស្ត្រទាំងពួងក្នុងនគរតក្កសិលា ហើយត្រឡប់មកកាន់សម្នាក់មាតាបិតា ។ ក្នុងជាតកនេះព្រះពោធិសត្វជាព្រហ្មចារី តាំងអំពីកុមារ ។ លំដាប់នោះ មាតាបិតារបស់ព្រះពោធិសត្វប្រាប់ថា យើងនឹងស្វែងរកភរិយាឲ្យដល់ឯង ព្រះពោធិសត្វពោលថា កូនមិនមានសេចក្តីត្រូវការគ្រប់គ្រងផ្ទះ កាលលោកទាំងឡាយស្លាប់ទៅហើយ ខ្ញុំនឹងបួស ត្រូវមាតាបិតារំអុករឿយៗ ទើបឲ្យជាងធ្វើរូបមាសមួយ ហើយពោលថា បើបានកុមារិកាបែបនេះ ទើបនៅគ្រប់គ្រងផ្ទះ ។ មាតាបិតារបស់ព្រះពោធិសត្វ ក៏ឲ្យលើករូបមាសនោះ ឡើងលើយាន ហើយបិទជិត បញ្ជូនមនុស្សទាំងឡាយ ព្រមទាំងបរិវារជាច្រើនទៅ ដោយប្រាប់ថា ពួកអ្នកចូរទៅ ចូរត្រាច់ពេញជម្ពូទ្វីប ឃើញកុមារិកាដែលជាព្រាហ្មណីស្អាតបែបនេះក្នុងទីណា អ្នកទាំងឡាយចូរឲ្យរូបមាសនេះ ក្នុងទី

នោះ ហើយនាំព្រាហ្មណីកុមារិកានោះមក ។ ក្នុងកាលនោះ សត្វមានបុណ្យម្នាក់ ចុតិអំពីព្រហ្មលោក មកកើតជាកុមារិកា ក្នុងផ្ទះព្រាហ្មណ៍ដែលមានសម្បត្តិ ៨០ កោដិ ក្នុងដែនកាសីនោះឯង មាតាបិតា បានដាក់ឈ្មោះកុមារិកានោះថា សម្មិល្លហាសិនី ។ កុមារិកានោះ មានអាយុ ១៦ ឆ្នាំ ជាអ្នកមានរូបស្អាតគួរសរសើរ ប្រៀបដូចទេពអប្សរ បរិបូណ៌ដោយសព៌ាង្គកាយ ។ ឈ្មោះថាការគិតដោយអំណាចកិលេស មិនធ្លាប់កើតឡើងដល់នាងឡើយនាងជាស្ត្រីព្រហ្មចារិនីដោយពិត ។ ជនទាំងឡាយនាំរូបមាសនោះ ទៅដល់ស្រុកនោះ មនុស្សទាំងឡាយ ក្នុងស្រុកនោះ ឃើញរូបមាសនោះហើយ នាំគ្នាពោលថា ព្រោះហេតុអ្វី នាងសម្មិល្លហាសិនីធីតារបស់ព្រាហ្មណ៍ឈ្មោះនោះមកឈរក្នុងទីនេះ មនុស្សទាំងឡាយ បានស្តាប់ដូច្នោះ ទៅកាន់ត្រកូលព្រាហ្មណ៍ ស្តីដណ្តឹងនាងសម្មិល្លហាសិនីនោះ ។ ទើបនាងបញ្ជូនដំណឹងដល់មាតាបិតាថា បើលោកទាំងពីរស្លាប់ហើយ ខ្ញុំនឹងបួស ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះទេ ។ មាតាបិតានោះពោលថា កុមារិកានឹងធ្វើអ្វីបាន ហើយទទួលយករូបមាស បញ្ជូននាងទៅ ដោយបរិវារជាច្រើន កាលព្រះពោធិសត្វ និងនាងសម្មិល្លហាសិនីទាំងពីរនាក់មិនប្រាថ្នាសោះ មាតាបិតាក៏ធ្វើការមង្គល គឺរៀបការឲ្យ ។ ជនទាំងពីរនោះ អង្គុយក្នុងបន្ទប់ជាមួយគ្នា សូម្បីដេកក៏ដេកក្នុងគ្រែតែមួយ មិនបានមើលគ្នាដោយអំណាចកិលេស នៅក្នុងទីជាមួយគ្នាដូចភិក្ខុពីររូប និងដូចព្រហ្មពីរអង្គនៅក្នុងទីតែមួយដូច្នោះ ។ ចំណេរកាលកន្លងមក មាតាបិតារបស់ព្រះពោធិសត្វ បានធ្វើកាលកិរិយា ព្រះពោធិសត្វធ្វើ

ឈាបនកិច្ចសរីរៈរបស់មាតាបិតាហើយ ហៅនាងសម្មិល្លហាសិនីមកពោល ថា នែនាង ចូរនាងត្រកអរក្នុងទ្រព្យនេះមានប្រមាណប៉ុណ្ណោះ គឺទ្រព្យ ៨០ កោដិដែលជារបស់ត្រកូលខ្ញុំ និងទ្រព្យ ៨០ កោដិ ដែលជារបស់ត្រកូលនាង ហើយគ្រប់គ្រងទ្រព្យសម្បត្តិនេះចុះ ខ្ញុំនឹងបួស ។ នាងសម្មិល្លហាសិនីពោល ថា បពិត្រអយ្យបុត្ត បើអ្នកបួស ខ្ញុំក៏នឹងបួស ខ្ញុំមិនអាចបោះបង់អ្នកបាន បើ ដូច្នោះចូរមក ។ ជនទាំងពីរនោះ ក៏លះទ្រព្យសម្បត្តិទាំងអស់ឲ្យទៅជាទាន លះបង់ទ្រព្យសម្បត្តិ ដូចលះបង់ដុំទឹកមាត់ ចូលទៅកាន់ហិមវន្តប្បទេសទាំង ពីរនាក់ បួសជាឥសី មានមើមឈើនិងផ្លែឈើក្នុងព្រៃជាអាហារ នៅក្នុង ហិមវន្តប្បទេសនោះអស់កាលយូរ កាលត្រូវការសេជូរប្រៃ ទើបមកអំពី ហិមវន្តប្បទេស ដល់នគរពារាណសីដោយលំដាប់ នៅក្នុងព្រះរាជឧទ្យាន ។ កាលតាបសនិងតាបសិនីទាំងពីរនោះ នៅក្នុងព្រះរាជឧទ្យាននោះ បរិព្វាជិកា ជាសុខុមាលជាតិ បរិភោគកត្តដែលលាយឡំប្រាសចាកឱជៈ ក៏កើតអាពាធ ចុះលោហិត នាងមិនបានកេសជ្ជៈដែលជាសប្បាយ ក៏ខ្សោយកម្លាំង ក្នុងពេល ភិក្ខាចារ ព្រះពោធិសត្វគ្រាហ៍នាងទៅកាន់ទ្វារព្រះនគរ ហើយឲ្យដេកលើបន្ទះ ក្ដារក្នុងសាលាមួយខ្នង ចំណែកខ្លួនចូលទៅភិក្ខាចារ ។ នាងកាលព្រះពោធិ សត្វមិនទាន់ត្រឡប់មក ក៏ធ្វើកាលកិរិយាទៅ ។ មហាជនឃើញរូបសម្បត្តិ របស់បរិព្វាជិកា នាំគ្នាចោមរោមទ្រហោយំ ។ ព្រះមហាសត្វត្រាច់ភិក្ខាត្រឡប់ មកដឹងថានាងស្លាប់ហើយ ត្រិះរិះថា របស់ណាដែលបែកធ្លាយទៅជាធម្មតា រមែងបែកទៅ សង្ខារទាំងពួងមិនទៀងហ្ន៎ មានគតិយ៉ាងនេះឯង ហើយអង្គុយ

លើបទុះក្ការដែលនាងដេកនោះឯង បរិភោគភោជនដែលលាយគ្នា ហើយខ្ពុរមាត់ ។ មហាជនឈរចោមរោមសួរថា លោកដ៏ចម្រើន បរិញ្ចាជិកានេះត្រូវជាអ្វីនឹងលោក ព្រះពោធិសត្វពោលថា កាលជាគ្រហស្ថនាងជាបាទបរិចារិការបស់ខ្ញុំ មហាជនពោលថា បពិត្រលោកម្ចាស់ ពួកយើងគង់អត់ធន់មិនបាននាំគ្នាស្រែកយំ ព្រោះហេតុអ្វីទើបលោកមិនយំ ព្រះពោធិសត្វពោលថា បរិញ្ចាជិកានេះ កាលនៅមានជីវិតរមែងជាញាតិនឹងយើង ឥឡូវនេះមិនជាញាតិនឹងគ្នាឡើយ ព្រោះនាងទៅកាន់បរលោក ទៅកាន់អំណាចរបស់សេចក្ដីស្លាប់ ខ្ញុំយំព្រោះអ្វី កាលនឹងសម្ដែងធម៌ដល់មហាជន ទើបពោលគាថាទាំងនេះថា

នាងសម្មិល្លហាសិនី ជាស្រីដ៏ចម្រើន មានក្នុងចន្លោះពួក
សត្វដ៏ច្រើនដែលស្លាប់ហើយ ពួកសត្វដែលស្លាប់ហើយនោះ
នឹងមានប្រយោជន៍អ្វីដល់ខ្ញុំ ហេតុនោះ បានជាខ្ញុំមិនសោក
ស្ដាយនាងសម្មិល្លហាសិនីជាទីស្រឡាញ់ទុះឡើយ ។

វត្ថុណាៗ មិនមានដល់សត្វនោះ បើសត្វគប្បីសោកស្ដាយ
ចំពោះវត្ថុដែលគ្មាននោះៗ គប្បីសោកស្ដាយចំពោះខ្លួនឯងដែល
លុះក្នុងអំណាចនៃមច្ចុគ្រប់កាលផង ។

អាយុសង្ខារ មិនទៅតាមសត្វណាមួយដែលឈរ អង្គុយ
ដេក ដើរទៅមកឡើយ សត្វបើកភ្នែក ធ្មេចភ្នែក ដរាបណា
វ័យរបស់សត្វ តែងរំកិលទៅដរាបនោះ ។

កាលបើសេចក្ដីព្រាត់ប្រាសក្នុងខ្លួន ជាផ្លូវឥតសង្ស័យនោះ

ហើយ បុគ្គលគប្បីអាណិតសត្វរស់នៅដ៏សេសសល់ មិនគួរ
សោយសោកចំពោះសត្វដែលច្យុតហើយទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហូនំ វិជ្ជតី** សេចក្តីថា ស្រីនេះ ចោល យើងហើយ ឥឡូវនេះ មាន គឺកើតក្នុងរវាងពួកសត្វដែលស្លាប់ដទៃជាច្រើន ។ បទថា **តេហិ មេ កឹ ភវិស្សតិ** សេចក្តីថា ឥឡូវនេះ នាងប្រព្រឹត្តទៅជាមួយពួកសត្វ ដែលស្លាប់ហើយនោះ នឹងជាអ្វីជាមួយខ្ញុំ ឬថានាងនឹងជាអ្វីដល់ខ្ញុំ ដោយអំណាចការទាក់ទងក្នុងសត្វដែលស្លាប់ហើយទាំងនោះ គឺនាងជានរណា ជាកិរិយាឬប្អូនស្រី ។ បាលីថា **តេហិ មេកំ** ដូច្នេះក៏មាន អធិប្បាយបាលីនោះថា កឡេវរកាយនេះ ដូចគ្នានឹងកាយសត្វដែលស្លាប់ហើយទាំងនោះ ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលនាងសម្មិល្លហាសិនីនេះស្លាប់ហើយ សមាគមនឹងមនុស្សដែលស្លាប់ហើយ ជាអ្វីដល់ខ្ញុំ ព្រោះដូច្នោះ ទើបខ្ញុំមិនសោយសោកដល់នាងសម្មិល្លហាសិនីនេះ ។ បទថា **យំ យំ តស្ស** សេចក្តីថា វត្ថុណាមួយរមែងមិនមានដល់សត្វដែលសោយសោកនោះ បានដល់សេចក្តីស្លាប់ គឺការរលត់ បើនឹងសោយសោកដល់វត្ថុនោះៗ ។ បាលីថា **យស្ស** ដូច្នេះក៏មាន ។ សេចក្តីនៃបាលីនោះថា វត្ថុណាមួយរមែងមិនមានដល់បុគ្គលណា បើបុគ្គលនោះសោយសោកដល់វត្ថុនោះៗ ។ បទថា **មច្ចុវសំ បត្តំ** សេចក្តីថា កាលបើយ៉ាងនោះ បុគ្គលគួរសោយសោកដល់ខ្លួនដែលដល់ គឺដែលនឹងទៅកាន់អំណាចរបស់មច្ចុជានិច្ចនោះឯង ព្រោះហេតុនោះ បុគ្គលនោះ មិនមានពេលសោយសោកឡើយ ។

ក្នុងគាថាទី ៣ មានវិនិច្ឆ័យ ដូចតទៅនេះថា អ្នកសិក្សាគប្បីនាំបាលីដ៏សេសមកភ្ជាប់ចូលគ្នា សេចក្តីថា អាយុសង្ខាររមែងទៅតាមសត្វ ណាមួយក៏បាន មិនមែនអ្នកឈរ អង្គុយ ដេក ឬដើរប៉ុណ្ណោះឡើយ ។ បណ្តាបទទាំងនោះ បទថា **បត្តគុំ** បានដល់ ដែលត្រាច់ទៅមកៗ អធិប្បាយថា សត្វទាំងនេះប្រមាទក្នុងឥរិយាបថទាំង ៤ ចំណែកអាយុសង្ខារ មិនប្រមាទក្នុងឥរិយាបថទាំងពួង ទាំងពេលយប់និងពេលថ្ងៃរមែងធ្វើកម្ម គឺដល់នូវការអស់ទៅរបស់ខ្លួនប៉ុណ្ណោះ ។ បទថា **យាវុប្បត្តិ និមិស្សតិ** សេចក្តីថា នេះជាវោហារហៅកាលវេលានោះ ។ លោកអធិប្បាយថា វ័យរបស់សត្វទាំងនេះរមែងសាបសូន្យទៅ សូម្បីខណៈបិទភ្នែកនិងបើកភ្នែក គឺក្នុងខណៈមានប្រមាណតិចតួចយ៉ាងនេះ គឺវ័យដែលសល់ក្នុងវ័យទាំង ៣ រមែងវិនាស គឺមិនចម្រើន ។ បទថា **តត្តត្តនិ វតប្បន្តេ** បានដល់ ក្នុងខ្លួនដែលជាផ្លូវអន្តរាយនោះ ។ លោកអធិប្បាយថា កាលវ័យនោះ វិនាសទៅយ៉ាងនេះ អត្តភាពដែលដល់នូវការរាប់ថា នេះជាអត្តា រមែងជាផ្លូវអន្តរាយ គឺត្រូវចងដោយវ័យ ( អន្ទាក់ ) ចូលទៅពាក់កណ្តាលមិនពេញបរិបូណ៌ ។ កាលបើយ៉ាងនោះខ្លួនដែលជាផ្លូវអន្តរាយនេះ ត្រូវមានការព្រាត់ប្រាសអំពីគ្នានៃសត្វទាំងឡាយដែលកើតក្នុងកពនោះៗដោយឥតសង្ស័យ គឺអស់សង្ស័យ សត្វដែលសេសសល់មិនទាន់ស្លាប់ គឺសត្វដែលសល់នោះនៅរស់ គឺមានជីវិត គួរអាណិតដល់គ្នានឹងគ្នា គឺគួរមេត្តាដល់គ្នា គប្បីចម្រើនមេត្តាក្នុងសត្វនោះយ៉ាងនេះថា សូមសត្វទាំងនេះកុំបីមានរោគ កុំបៀតបៀនគ្នា ចំណែកសត្វដែលចុតិទៅហើយ

គឺស្លាប់ហើយ មិនគួរសោយសោកដល់ គឺមិនគួរតាមសោយសោកដល់ ។

ព្រះមហាសត្វកាលសម្តែងអាការៈមិនទៀង ដោយគាថា ៤ យ៉ាងនេះ សម្តែងធម៌ហើយ ។ មហាជន នាំគ្នាធ្វើឈាបនកិច្ចសរីរៈរបស់បរិញ្ញជិកាហើយ ។ ព្រះពោធិសត្វចូលទៅកាន់ហិមវន្តប្បទេស ធ្វើឈានទិងអភិញ្ញាឲ្យកើតឡើង មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តាទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈបានតាំងនៅក្នុងសោតាបត្តិផលហើយទ្រង់បានសមោធានជាតកថា នាងសម្មិល្លហាសិនីក្នុងកាលនោះ បានមកជារាហុលមាតាក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អននុសោចិយជាតក ចប់

# កាឡពាហុជាតក

[ ៦១៤ ] ( សេកឈ្មោះបោដ្ឋបាទជាប្អូននិយាយថា ) កាលពីដើម យើងបានបាយនិងទឹកណាអំពីសម្នាក់នៃស្តេចនោះ ឥឡូវនេះ បាយនិងទឹកនោះ បានទៅស្វាវិញហើយ បពិត្របងរាធៈ ឥឡូវនេះ យើងនឹងនាំគ្នាទៅព្រៃវិញ ព្រោះព្រះបាទធនញ្ជ័យ លែងរាប់អានយើងហើយ ។

[ ៦១៥ ] ( សេកពោធិសត្វឈ្មោះរាធៈជាបង និយាយតបថា ) លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី លោកធម៌ទាំង ៨ នោះ មិនទៀងក្នុងមនុស្សសត្វទាំងឡាយទេ ម្នាលបោដ្ឋបាទ អ្នកកុំសោកស្តាយឡើយ អ្នកនឹងសោកស្តាយធ្វើអ្វី ។

[ ៦១៦ ] ( សេកឈ្មោះបោដ្ឋបាទនិយាយថា ) បពិត្របងរាធៈ បងជាអ្នកប្រាជ្ញមែនពិតហើយ បងដឹងនូវប្រយោជន៍ដែលមិនទាន់មានមក តើយើងនឹងឃើញស្វាដ៏លាមកដែលត្រូវគេបណ្តេញអំពីរាជត្រកូលដោយឧបាយដូចម្តេចហ្ន៎ ។

[ ៦១៧ ] ( រាធៈនិយាយតបថា ) ស្វាខ្មៅឈ្មោះកាឡពាហុ ញាក់ត្រចៀក ធ្វើមុខក្រញូវ គង់ធ្វើឲ្យព្រះរាជកុមារភិតភ័យ ដោយការសង្ឃ្រកថា មុហុំមុហុំ វាមុខជានឹងឋិតនៅឆ្ងាយអំពីបាយនិងទឹក ដោយហេតុណា វានឹងធ្វើនូវហេតុនោះដោយខ្លួនឯងពុំលែងឡើយ ។

**ចប់ កាឡពាហុជាតក ទី ៩ ។**

# អដ្ឋកថា

# កាឡពាហុជាតក

[ ៦១៤-៦១៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តដែលវិនាសចាកលាភសក្ការៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យំ អន្នធានស្ស** ដូច្នេះជាដើម ។

កាលទេវទត្តចងសេចក្ដីក្រោធ ដែលមិនគួរក្នុងព្រះតថាគត ហើយប្រកបនាយខ្មាន់ធ្នូ ទោសកំហុសរបស់ទេវទត្តនោះបានប្រាកដ ព្រោះលែងដំរីនាឡាគិរី ។ លំដាប់នោះ មនុស្សទាំងឡាយក៏នាំគ្នាផ្ដាច់ធុវភត្តជាដើម ដែលផ្ដើមតាំងទុកដល់ទេវទត្ត ព្រះរាជាក៏ទ្រង់មិនសម្លឹងមើលទេវទត្តនោះ ។ ទេវទត្តវិនាសលាភសក្ការៈ ទើបត្រាច់សូមក្នុងត្រកូលទាំងឡាយបរិភោគ ។ ភិក្ខុទាំងឡាយក៏អង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តគិតថា នឹងញ៉ាំងលាភសក្ការៈឲ្យកើតឡើង តែលាភសក្ការៈដែលកើតឡើងហើយ ក៏មិនអាចធ្វើឲ្យគង់វង់ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏បានជាអ្នកវិនាសចាកលាភសក្ការៈ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទធនញ្ជ័យសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ យោនយកកំណើតជាសត្វសេក ឈ្មោះរាធៈ មានរាងកាយធំ

មាំមួន ចំណែកសេកជាប្អូនរបស់ព្រះពោធិសត្វនោះ ឈ្មោះថាបោដ្ឋបាទ ។ ព្រានព្រៃម្នាក់ ចាប់សេកបងប្អូនទាំងពីរនោះបាន ទើបនាំទៅថ្វាយព្រះបាទពារាណសី ។ ព្រះរាជាឲ្យដាក់សេកទាំងពីរក្នុងទ្រុងមាស ឲ្យបរិភោគលាជលាយដោយទឹកឃ្មុំ ក្នុងភាជន៍មាស ឲ្យផឹកទឹកដែលលាយដោយស្ករក្រាមចិញ្ចឹមទុក បានធ្វើសក្ការៈច្រើនសន្ធឹកសន្ធាប់ ។ សេកទាំងពីរនោះ បានជាអ្នកដល់ព្រមដោយលាភនិងយសដ៏ក្រៃលែង ។ តមកព្រានព្រៃម្នាក់ បាននាំយកស្វាខ្មៅដ៏ធំមួយ ឈ្មោះថាកាឡពាហុ មកថ្វាយព្រះរាជា ។ កាឡពាហុនោះមកឯក្រោយ ទើបមានលាភសក្ការៈច្រើនជាង លាភសក្ការៈរបស់សេកទាំងពីរថមថយទៅ ។ ព្រះពោធិសត្វមិនបាននិយាយអ្វីឡើយ ព្រោះប្រកបដោយលក្ខណៈនៃអ្នកមិនញាប់ញ័រ តែសេកជាប្អូន ព្រោះមិនមានលក្ខណៈជាអ្នកមិនញាប់ញ័រ ទើបអត់ធន់លាភសក្ការៈរបស់ស្វាកាឡពាហុមិនបាន ក៏ពោលនឹងបងប្រុសថា បពិត្របង កាលមុនក្នុងរាជត្រកូលនេះ រមែងឲ្យរបស់ស៊ីមានរសល្អជាដើមដល់ពួកយើង តែឥឡូវនេះ ពួកយើងមិនបាន គេនាំទៅឲ្យស្វាកាឡពាហុប៉ុណ្ណោះ ពួកយើងកាលមិនបានលាភសក្ការៈអំពីសម្នាក់របស់ព្រះបាទធនញ្ជ័យ នឹងធ្វើអ្វីក្នុងទីនេះ មកពួកយើងទៅព្រៃចុះ កាលចរចាជាមួយសេកជាបង ក៏ពោលគាថាទី ១ ថា

កាលពីដើម យើងបានបាយនិងទឹកណា អំពីសម្នាក់នៃស្តេច
នោះ ឥឡូវនេះបាយនឹងទឹកនោះបានទៅស្វាវិញហើយ បពិត្រ
បងរាធៈ ឥឡូវនេះ យើងនឹងនាំគ្នាទៅព្រៃវិញ ព្រោះព្រះបាទ

ធនញ្ជ័យលែងរាប់អានយើងហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យំ អន្នទានស្ស** សេចក្ដីថា បាយនិងទឹកណា អំពីសម្នាក់របស់ព្រះរាជានោះ ។ម្យ៉ាងទៀត បទថា **អន្នទានស្ស** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថរបស់ទុតិយាវិភត្តិ ។ បទថា **ធនញ្ជយាយ** ជាចតុត្ថីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា ពួកយើងជាបុគ្គល ដែលព្រះបាទធនញ្ជ័យមិនធ្វើសក្ការៈអើពើហើយ មិនបានបាយនិងទឹក ជាសត្វដែលព្រះបាទធនញ្ជ័យនេះឯងទ្រង់មិនអើពើហើយ ។ សេកឈ្មោះរាធៈបានស្ដាប់ដូច្នោះ ក៏ពោលគាថាទី ២ ថា

លាភក្ដី អលាភក្ដី យសក្ដី អយសក្ដី និន្ទាក្ដី បសំសាក្ដី
សុខក្ដី ទុក្ខក្ដី លោកធម៌ទាំង ៨ នោះ មិនទៀងក្នុងមនុស្ស
សត្វទាំងឡាយទេ ម្នាលពោដ្ឋបាទ អ្នកកុំសោកស្ដាយឡើយ
អ្នកនឹងសោកស្ដាយធ្វើអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យសោ** បានដល់ ឥស្សរិយយស និងបរិវារយស ។ បទថា **អយសោ** បានដល់ ការមិនមានឥស្សរិយយស និងបរិវារយសនោះ ។ បទថា **ឯតេ** សេចក្ដីថា លោកធម៌ទាំង ៨ ប្រការនេះ ជារបស់មិនទៀង ក្នុងពួកមនុស្ស ដែលដល់នូវភាពជាបុគ្គលដ៏លើសដោយលាភនិងយស ។ សម័យតមករមែងជាអ្នកមានលាភតិច សក្ការៈតិច ឈ្មោះថាជាអ្នកមានលាភជានិច្ចកាលរមែងមិនមាន ។ សូម្បីក្នុងយសជាដើមក៏មានន័យនេះដូចគ្នា ។

សេកឈ្មោះបោដ្ឋបាទបានស្តាប់ដូច្នោះ កាលមិនអាចធ្វើសេចក្តីប្រណែនក្នុងស្វាកាឡពាហុឲ្យបាត់ទៅបាន ទើបពោលគាថាទី ៣ ថា

បពិត្របងរាធៈ បងជាអ្នកប្រាជ្ញមែនពិតហើយ បងដឹងនូវ
ប្រយោជន៍ ដែលមិនទាន់មានមក តើយើងនឹងឃើញស្វាដ៏
លាមក ដែលត្រូវគេបណ្តេញអំពីរាជត្រកូល ដោយឧបាយ
ដូចម្តេចហ្ន៎ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កថំ នុ ខោ** បានដល់ ដោយឧបាយដូចម្តេចហ្ន៎ ។ បទថា **ឧក្ខាម** បានដល់ នឹងឃើញ ។ បទថា **និច្ឆាមិតំ** បានដល់ ត្រូវអូសចេញទៅ គឺត្រូវទាញចេញទៅ ។ បទថា **ជម្មំ** បានដល់បុគ្គលលាមក ។ សេកឈ្មោះរាធៈបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ៤ ថា

ស្វាខ្មៅឈ្មោះកាឡពាហុ ញាក់ត្រចៀក ធ្វើមុខក្រញូវ គង់ធ្វើ
ឲ្យព្រះរាជកុមារកិតភ័យ ដោយការសន្សំកថា មុហុំមុហុំ វា
មុខជា នឹងឋិតនៅឆ្ងាយអំពីបាយនិងទឹក ដោយហេតុណា វា
នឹងធ្វើនូវហេតុនោះដោយខ្លួនឯងពុំលែងឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាយតេ កុមារេ** សេចក្តីថា រមែងធ្វើព្រះរាជកុមារឲ្យភ័យខ្លាច ។ បទថា **យេនារកា ឋស្សតិ អន្នបាន** សេចក្តីថា ខ្លួនវានោះឯង នឹងធ្វើហេតុចាំបាច់ដែលនៅឆ្ងាយអំពីបាយនិងទឹកនេះ ឯងកុំប្រណែនចំពោះស្វានោះឡើយ ។

ចំណែកស្វាកាឡពាហុ លុះកន្លងទៅបាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏ញាក់

ត្រចៀកជាដើមចំពោះមុខព្រះរាជកុមារទាំងឡាយ ធ្វើឲ្យព្រះរាជកុមារទាំងឡាយខ្លាច ។ ព្រះរាជកុមារទាំងឡាយនោះភិតភ័យហើយ នាំគ្នាស្រែកយំ ។ ព្រះរាជាត្រាស់សួរថា តើមានរឿងអ្វី ទ្រង់បានស្តាប់រឿងនោះហើយត្រាស់ថា ចូរដេញវាចេញទៅ ហើយឲ្យដេញស្វាកាឡពាហុនោះចេញទៅ លាភសក្ការៈរបស់សេកទាំងពីរ ក៏បានជាប្រក្រតីឡើងវិញ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ស្វាកាឡពាហុក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ សេកបោដ្ឋបាទក្នុងកាលនោះ បានមកជាអានន្ទ ចំណែកសេករាធៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កាឡពាហុជាតក ចប់

# សីលវីមំសជាតក

[ ៦១៨ ] ( បុរោហិតពោធិសត្វនិយាយថា ) បានឮមកថា សីលជាគុណជាតិដ៏ល្អ សីលជាគុណជាតិដ៏ប្រសើរក្រៃលែងក្នុងលោក សូមព្រះអង្គទតមើលចុះ ដូចយ៉ាងនាគ ជាសត្វមានពិសដ៏ខ្លាំងពន្លឹក មិនហ៊ានបៀតបៀនដោយយល់ថា បុគ្គលនេះមានសីល ។

[ ៦១៩ ] ( ពោធិសត្វពោលថា ) ដុំសាច់បន្តិចបន្តួច នៅមានដល់ខ្លែងនោះដរាបណា ពួកប្រមង់ក្នុងលោក ចោមចឹកខ្លែងនោះ ដរាបនោះ ដែរ សត្វបក្សីដ៏សេស មិនបានបៀតបៀនខ្លែងដែលមិនមានសាច់ជាគ្រឿងកង្វល់នោះ ។

[ ៦២០ ] បុគ្គលដេកលក់ជាសុខ ព្រោះមិនមានសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាដែលមានលទ្ធផលដ៏ជាសុខ នាងបិង្គលាទាសី បានធ្វើនូវសេចក្តីប្រាថ្នាឲ្យគ្មានសេចក្តីប្រាថ្នាវិញ ក៏ដេកលក់ជាសុខដែរ ។

[ ៦២១ ] ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី មិនមានធម៌ដទៃប្រសើរជាងសមាធិឡើយ ( ព្រោះ ) បុគ្គលអ្នកតាំងនៅក្នុងសមាធិហើយ រមែងមិនបៀតបៀនបុគ្គលដទៃផង មិនបៀតបៀនខ្លួនឯងផង ។

**ចប់ សីលវីមំសជាតក ទី ១០ ។**

**ចប់ កុដិទូសកវគ្គទី ៣ ។**

## ឧទ្ទាននៃកុដិទូសកវគ្គនោះគឺ

និយាយអំពីក្បាលនិងដៃជើងរបស់ស្វាដូចមនុស្ស ១ ប្រទេសធ្វើនូវសំឡេងថាទុំទុំកៈ ១ បុគ្គលអ្នកសូម ១ សត្វពពៃប្រសើរ ១ សត្វទទ្រើងប្រសើរ ១ ការមិនល្អដោយកាយ ១ ទន្ទេរឈ្មោះកេបុកៈ ១ ស្តេចម្រើនប្រសើរ ១ សេកឈ្មោះរាធៈ ១ សីលប្រសើរ ១ ត្រូវជា ១០ ។

# អដ្ឋកថា

# សីលវីមំសជាតក

[ ៦១៨-៦២១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍សាកល្បងសីល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សីលំ កិរេវ កល្យាណំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន និទានទាំងពីររឿង បានពោលទុកហើយខាងដើមនោះឯង ចំណែកក្នុងជាតកនេះ ព្រះពោធិសត្វបានជាបុរោហិតរបស់ព្រះបាទពារាណសី កាលព្រះពោធិសត្វនោះ ពិសោធសីលរបស់ខ្លួន ទើបកាន់យកកហាបណៈអំពីបន្ទះក្តារ សម្រាប់រាប់ប្រាក់អស់កាល ៣ ថ្ងៃ ពួករាជបុរសទាំងឡាយក៏ចាប់ព្រះពោធិសត្វថ្វាយដល់ព្រះរាជាថាជាចោរ ។ ព្រះពោធិសត្វនោះឈរក្នុងសម្នាក់របស់ព្រះរាជា ពណ៌នាសីលដោយគាថាទី ១ ថា

បានឮមកថា សីលជាគុណជាតិដ៏ល្អ សីលជាគុណជាតិដ៏
ប្រសើរក្រៃលែង ក្នុងលោក សូមព្រះអង្គទតមើលចុះ ដូច
យ៉ាងនាគ ជាសត្វមានពិសដ៏ខ្លាំងពន្លឹក មិនហ៊ានបៀតបៀន
ដោយយល់ថា បុគ្គលនេះមានសីល ដូច្នេះ ។

ហើយទូលសូមឲ្យព្រះរាជាទ្រង់អនុញ្ញាតដើម្បីបួស ហើយក៏បួស ។ គ្រានោះ ខ្លែងធាបយកដុំសាច់ក្នុងរានលក់សាច់មួយកន្លែង ហើរទៅក្នុងអាកាស សត្វដទៃចោមរោមប្រហារខ្លែងនោះដោយក្រចកនិងចំពុះជាដើម ខ្លែងនោះមិនអាចអត់ធន់ចំពោះសេចក្តីទុក្ខនោះបាន ទើបចោលដុំសាច់ សត្វដទៃក៏ពាំយកទៅ ។ សូម្បីសត្វនោះ ក៏ត្រូវសត្វដទៃបៀតបៀនយ៉ាងនោះ ក៏ចោលដុំ

សាច់នោះ ។ ពេលនោះ សត្វដទៃៗ ក៏ពាំយកទៅ រួមសេចក្ដីថា សត្វណា ពាំយកទៅ សត្វទាំងឡាយក៏ដេញតាមសត្វនោះៗ ។ សត្វណាចោល សត្វ នោះ ក៏មានសេចក្ដីសុខ ។ ព្រះពោធិសត្វឃើញដូច្នោះ ទើបគិតថា ឈ្មោះ ថា កាមទាំងឡាយប្រៀបដូចដុំសាច់ កាលបើយ៉ាងនោះ បុគ្គលដែលប្រកាន់ ក្នុងកាមប៉ុណ្ណោះទើបកើតទុក្ខ កាលលះបង់បាន ក៏ជាសុខ ហើយពោលគា ថាទី ២ ថា

ដុំសាច់បន្តិចបន្តួច នៅមានដល់ខ្លែងនោះ ដរាបណា ពួក ប្រមង់ក្នុងលោក ចោមចឹកខ្លែងនោះ ដរាបនោះដែរ សត្វបក្សី ដ៏សេស មិនបានបៀតបៀនខ្លែងដែលមិនមានសាច់ជាគ្រឿង កង្វល់នោះ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា ដុំសាច់បន្តិចបន្តួចដែលយក មាត់ពាំ នៅមានដល់ខ្លែងនោះដរាបណា សត្វប្រមង់ទាំងឡាយក្នុងលោកនេះ ក៏នាំគ្នាចោមចឹកខ្លែងនោះដរាបនោះ តែកាលណាខ្លែងនោះលែងនូវដុំសាច់នោះ សត្វដ៏សេស ក៏រមែងមិនបៀតបៀនសត្វនោះ ដែលមិនមានសេចក្ដីកង្វល់ គឺ មិនមានបលិពោធ ។ ព្រះពោធិសត្វនោះ ចេញអំពីព្រះនគរហើយ ក្នុងពេល ល្ងាចបានដេកក្នុងផ្ទះរបស់បុរសម្នាក់ ផ្ទះនោះនៅក្នុងរវាងផ្លូវ ។ ទាសីក្នុងផ្ទះ នោះឈ្មោះបិង្គលា បានណាត់នឹងបុរសម្នាក់ថា គប្បីមកក្នុងវេលាឈ្មោះនោះ នាងលាងជើងរបស់ចៅហ្វាយទាំងឡាយហើយ កាលចៅហ្វាយទាំងឡាយដេក ហើយ អង្គុយទន្ទឹងមើលការមករបស់បុរសនោះត្រង់ធរណីទ្វារ គិតថា គេ

នឹងមកឥឡូវនេះ គេនឹងមកឥឡូវនេះ រហូតកន្លងបឋមយាមនិងមជ្ឈិមយាម ក្នុងពេលទៀបភ្លឺ នាងអស់សង្ឃឹមថាបុរសនោះគង់មិនមកពិត ក៏ដេកលក់ទៅ ព្រះពោធិសត្វឃើញហេតុការណ៍នេះគិតថា ទាសីនេះអង្គុយអស់កាល មានប្រមាណប៉ុណ្ណេះ ដោយសង្ឃឹមថាបុរសនោះនឹងមក ដឹងថាឥឡូវនេះ បុរសនោះមិនមក ក៏អស់ប្រាថ្នា ដេកលក់យ៉ាងសប្បាយ ឈ្មោះថាការប្រាថ្នាក្នុងកិលេសទាំងឡាយជាទុក្ខ ការមិនមានប្រាថ្នាប៉ុណ្ណោះជាសុខ ក៏ពោលគាថាទី ៣ ថា

បុគ្គលដេកលក់ជាសុខ ព្រោះមិនមានសេចក្ដីប្រាថ្នា សេចក្ដីប្រាថ្នាដែលមានលទ្ធផលដ៏ជាសុខ នាងបិង្គលាទាសី បានធ្វើនូវសេចក្ដីប្រាថ្នា ឲ្យគ្មានសេចក្ដីប្រាថ្នាវិញ ក៏ដេកលក់ជាសុខដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ផលវតី** សេចក្ដីថា ការប្រាថ្នាដែលបានផលនោះ ឈ្មោះថាជាសុខ ព្រោះផលនោះជាសុខ ។ បទថា **និរាសំ កត្វាន** សេចក្ដីថា ធ្វើឲ្យអស់ប្រាថ្នា អធិប្បាយថា កាត់ចោលគឺលះចោល ។ បទថា **បិង្គលា** សេចក្ដីថា ឥឡូវនេះ នាងបិង្គលាទាសីនោះ ដេកលក់ជាសុខ ។

ស្អែកឡើង ព្រះពោធិសត្វនោះ ចេញអំពីស្រុកនោះចូលទៅកាន់ព្រៃ ឃើញតាបសម្នាក់អង្គុយចូលឈានក្នុងព្រៃគិតថា សេចក្ដីសុខដែលក្រៃលែងជាងសេចក្ដីសុខក្នុងឈានរមែងមិនមានក្នុងលោកនេះ និងលោកខាងមុខទើប

ពោលគាថាទី ៤ ថា

ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី មិនមានធម៌ដទៃប្រសើរ

ជាងសមាធិឡើយ ( ព្រោះ ) បុគ្គលអ្នកតាំងនៅក្នុងសមាធិ

ហើយ រមែងមិនបៀតបៀនបុគ្គលដទៃផង មិនបៀតបៀនខ្លួន

ឯងផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមាធិបរោ** សេចក្តីថា ឈ្មោះថាធម៌ គឺសេចក្តីសុខខាងក្រៅ គឺដទៃអំពីសមាធិ រមែងមិនមាន ។

ព្រះពោធិសត្វកាលចូលព្រៃហើយ បួសជាឥសី ធ្វើឈាននិងអភិញ្ញាឲ្យកើតឡើង មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា បុរោហិតក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សីលវីមំសជាតក ចប់**

**កុដិទូសកវគ្គ ចប់**

# កោកិលវគ្គ

## កោកាលិកជាតក

[ ៦២២ ] ( អាមាត្យពោធិសត្វពោលថា ) បុគ្គលណានិយាយហួសប្រមាណ ក្នុងកាលដែលមិនសម្រេច ( លទ្ធផល ) បុគ្គលនោះត្រូវគេកម្ចាត់ចេញ ដេកនៅតែម្នាក់ឯង ដូចកូនតាវៅ ( ដែលមេក្អែកចឹកកម្ចាត់ចេញ ) ។

[ ៦២៣ ] កាំបិតទុកជាគេសំលៀងមុតហើយ ឬថ្នាំពិសដ៏ក្លាខ្លាំង ក៏មិនទាញបុគ្គលឲ្យធ្លាក់ចុះ ដូចវាចាជាទុព្ភាសិតទេ ។

[ ៦២៤ ] ហេតុនោះ អ្នកប្រាជ្ញគួររក្សាវាចាទុក ក្នុងកាលដែលគួរនិងកាលមិនគួរ មិនគួរនិយាយហួសប្រមាណ សូម្បីចំពោះបុគ្គលដែលស្មើនឹងខ្លួន ។

[ ៦២៥ ] ចំណែកបុគ្គលណាមានគំនិតគិតទុកមុន មានប្រាជ្ញាជាគ្រឿងពិចារណា និយាយល្មមប្រមាណក្នុងកាលគួរ បុគ្គលនោះ អាចចាប់សត្រូវទាំងពួងបាន ដូចគ្រុឌចាប់នាគដូច្នោះ ។

**ចប់ កោកាលិកជាតកទី ១ ។**

# កោកិលវគ្គ

## អដ្ឋកថា កោកលិកជាតក

[ ៦២២-៦២៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកោកាលិកៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ វេ កា-**

**លេ អសម្បត្តេ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន បានឲ្យពិស្តារហើយក្នុងតក្ការិយជាតក ចំណែករឿងក្នុងអតីតៈ មានដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ បានជាអាមាត្យអ្នកថ្វាយឱវាទចំពោះព្រះបាទពារាណសីនោះ ព្រះរាជា ជាអ្នកមានព្រះតម្រាស់ច្រើន ព្រះពោធិសត្វគិតថា នឹងឃាត់ការនិយាយច្រើនរបស់ព្រះរាជានោះ ដូច្នេះហើយ ទើបគិតរកឧបមាឯណាមួយ ។ ថ្ងៃមួយព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យានហើយប្រថាប់គង់លើមង្គលសិលា ខាងលើថ្មនោះមានស្វាយមួយដើម ។ ក្នុងទីនោះ តាវ៉ៅញី ពងក្នុងសម្បុកក្អែកមួយលើដើមស្វាយនោះ ហើយក៏ទៅ ។ ក្អែកញីក៏ក្រាបពងតាវ៉ៅនោះ ។ ចំណេរកាលតមក កូនតាវ៉ៅក៏ញាស់ ។ ក្អែកញីសម្គាល់ថាជាកូនរបស់ខ្លួន ទើបនាំអាហារមកដោយចំពុះ ប្រតិបត្តិកូនតាវ៉ៅនោះ ។ កូនតាវ៉ៅនោះរោមស្លាបមិនទាន់ដុះ ក៏បន្លឺសំឡេងជាសត្វតាវ៉ៅ ក្នុងកាលដែលមិនគួរយំឡើយ ក្អែកញីគិតថា កូននេះយំជាសំឡេងសត្វដទៃ តាំងពីឥឡូវនេះ កាលវាធំឡើងនឹងធ្វើដូចម្ដេច ទើបចឹកដោយចំពុះឲ្យស្លាប់ ទម្លាក់អំពីសម្បុក ។ កូនតាវ៉ៅធ្លាក់ទៀបបាទាព្រះរាជា ព្រះរាជាសួរព្រះពោធិសត្វថា នែសម្លាញ់ នេះជាសត្វអ្វី ព្រះពោធិសត្វគិតថា អញស្វែងរកហេតុដើម្បីប្រៀបធៀប ដើម្បីនឹងហាមព្រះរាជា ឥឡូវនេះ អញបានហេតុប្រៀបធៀបនេះហើយ ទើបក្រាបទូលថា បពិត្រមហារាជ ឈ្មោះថាបុគ្គលមាត់រឹង និយាយច្រើនក្នុងកាល

មិនគួរនិយាយ រមែងបានទុក្ខបែបនេះ បពិត្រមហារាជ កូនតាវៅនេះចម្រើន ធំធាត់បានព្រោះក្អែកញី ពេមស្លាបមិនទាន់ដុះ ក៏យំជាសំឡេងតាវៅក្នុងកាលដែលមិនគួរយំ ក្អែកដឹងថាកូនតាវៅមិនមែនជាកូនរបស់ខ្លួន ទើបចឹកដោយចំពុះឲ្យស្លាប់ ធ្លាក់ចុះមកអំពីសម្បុក មនុស្សក្តី សត្វតិរច្ឆានក្តី និយាយច្រើនក្នុងកាលមិនគួរនិយាយ រមែងបាននូវទុក្ខបែបនេះ ហើយបានពោលគាថាទាំងនេះថា

បុគ្គលណា និយាយហួសប្រមាណ ក្នុងកាលដែលមិនសម្រេច ( លទ្ធផល ) បុគ្គលនោះត្រូវគេកម្ចាត់ចេញ ដេកនៅតែម្នាក់ឯងដូចកូនតាវៅ ( ដែលមេក្អែកចឹកកម្ចាត់ចេញ ) ។

កាំបិតទុកជាគេសំលៀងមុតហើយ ឬថ្នាំពិសដ៏ក្លាខ្លាំង ក៏មិនទាញបុគ្គលឲ្យធ្លាក់ចុះ ដូចវាចាជាទុព្ភាសិតទេ ។

ហេតុនោះ អ្នកប្រាជ្ញគួររក្សាវាចាទុក ក្នុងកាលដែលគួរនិងកាលមិនគួរ មិនគួរនិយាយហួសប្រមាណ សូម្បីចំពោះបុគ្គលដែលស្មើនឹងខ្លួន ។

ចំណែកបុគ្គលណា មានគំនិតគិតទុកមុន មានប្រាជ្ញាជាគ្រឿងពិចារណា និយាយល្មមប្រមាណក្នុងកាលគួរ បុគ្គលនោះ អាចចាប់សត្រូវទាំងពួងបាន ដូចគ្រុឌចាប់នាគដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **កាលេ អសម្បត្តេ** បានដល់ កាលដែលគួរពោលរបស់ខ្លួនមិនទាន់មកដល់ ។ បទថា **អតិវេលំ** សេចក្តីថា រមែង

ពោលលើសប្រមាណ ធ្វើឲ្យហួសកាលវេលា ។ បទថា **ហលាហលម្ហិវ** កាត់បទជា **ហលាហលំ ឥវ** ប្រែថា ដូចថ្នាំពិសដ៏ខ្លាំងក្លា ។ បទថា **ឆិក្កាលេ** បានដល់ ក្នុងខណៈនោះឯង គឺក្នុងកាលដែលមិនទាន់មកដល់ ។ បទថា **តស្មា** បានដល់ ព្រោះហេតុដែលពាក្យទុព្ភាសិតប៉ុណ្ណោះរមែងទម្លាយរបស់ជាងសស្ត្រាដែលសំលៀងមុតនិងថ្នាំពិសដ៏ពន្លឹក ។ បទថា **កាលេ អកាលេ ច** សេចក្តីថា បណ្ឌិតគប្បីរក្សាវាចាទាំងក្នុងកាល និងមិនមែនកាលដែលគួរពោល អធិប្បាយថា មិនគួរពោលហួសវេលា សូម្បីជាមួយបុគ្គលដែលស្មើនឹងខ្លួន គឺសូម្បីនឹងបុគ្គលដែលមានការធ្វើមិនផ្សេងគ្នា ។ បទថា **មតិ-បុព្វោ** បានដល់ ឈ្មោះថាមានការគិតជាខាងមុខ ព្រោះធ្វើការគិតឲ្យជាបុរេចារិកខាងមុខ ហើយទើបពោល ។ បទថា **វិចក្ខណោ** សេចក្តីថា បុគ្គលដែលពិចារណាដោយញាណ ហើយបានប្រយោជន៍ ឈ្មោះថាជាអ្នកមានបញ្ញាឃើញច្បាស់ ។ បទថា **ឱរគាមិវ** កាត់បទជា **ឱរគំ ឥវ** ប្រែថា ដូចសត្វដែលទៅដោយទ្រូង គឺពស់ ។ លោកពោលអធិប្បាយទុកដូច្នេះថា គ្រុឌធ្វើទឹកសមុទ្ទឲ្យបែកជាពីរ ហើយចាប់យកនាគដែលមានខ្លួនធំ កាលចាប់បានហើយ រំពេចនោះឯងក៏លើកពស់នោះ ឡើងកាន់ដើមរកាស៊ីសាច់យ៉ាងណា បុគ្គលមានការគិតកើតឡើងជាខាងមុខ មានបញ្ញា ជាគ្រឿងឃើញប្រច័ក្ស ពោលល្មមប្រមាណក្នុងកាលដែលគួរពោល ក៏យ៉ាងនោះដូចគ្នារមែងកាន់យក គឺចាប់ពួកអមិត្តទាំងអស់បាន គឺធ្វើឲ្យនៅក្នុងអំណាចរបស់ខ្លួនបាន ។ ព្រះរាជាកាលទ្រង់ស្តាប់ធម្មទេសនារបស់ព្រះពោធិសត្វហើយ តាំងអំពីនោះមក ក៏បាន

ជាអ្នកមានព្រះតម្រាស់ល្មមប្រមាណ ហើយទ្រង់ដំឡើងបុណ្យសក្តិ ព្រះរាជទានដល់ព្រះពោធិសត្វនោះឲ្យធំជាងមុន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា កូនតាវៅក្នុងកាលនោះ បានមកជាកោលិកៈក្នុងឥឡូវនេះ ចំណែកអាមាត្យជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កោកាលិកជាតក ចប់

# វេលដ្ឋិជាតក

[ ៦២៦ ] ( អាមាត្យពោធិសត្វពោលថា ) បពិត្រព្រះរាជា បុគ្គលខ្លះប្រហារខ្លួនដោយខ្លួនឯង ហើយនិយាយថា គេប្រហារក៏មាន ផ្ចាញ់គេហើយនិយាយថាគេផ្ចាញ់ខ្លួនក៏មាន អ្នកប្រាជ្ញកុំគប្បីជឿពាក្យនៃអ្នកនិយាយមុនដោយដាច់ខាតឡើយ ។

[ ៦២៧ ] ហេតុនោះ បណ្ឌិតជាតិ គួរស្តាប់ពាក្យរបស់បុគ្គលក្រៅពីនេះផង លុះស្តាប់ពាក្យរបស់ជនទាំង ២ នាក់ហើយ គប្បីធ្វើតាមពាក្យច្បាប់ចុះ ។

[ ៦២៨ ] គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូសមិនប្រពៃ អ្នកបួសមិនសង្រួមមិនប្រសើរ ព្រះរាជាមិនពិចារណាហើយធ្វើមិនប្រសើរបណ្ឌិតដែលជាអ្នកច្រើនក្រោធ ក៏ពុំប្រសើរ ។

[ ៦២៩ ] បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រគប្បីពិចារណាហើយសឹមធ្វើ បើមិនទាន់ពិចារណាមិនត្រូវធ្វើទេ យសក្តិ កិត្តិសព្ទក្តី រមែងចម្រើនដល់ព្រះរាជាដែលពិចារណាហើយទើបធ្វើ ។

**ចប់ វេលដ្ឋិជាតកទី ២ ។**

# អដ្ឋកថា

# វេឡុជាតក

[ ៦២៦-៦២៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុរោហិតរបស់ព្រះបាទកោសល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អបិ ហន្ត្វា ហតោ ព្រូតិ** ដូច្នេះជាដើម ។

បានឮថា បុរោហិតនោះ ទៅកាន់ស្រុកស្នួយរបស់ខ្លួនដោយរថ បររថទៅក្នុងផ្លូវចង្អៀត ជួបក្រុមរទេះមួយក្រុមក៏ពោលថា ពួកអ្នកចូរចៀសរទេះរបស់ពួកអ្នក ដូច្នេះហើយក៏ទៅ កាលអ្នកបររទេះមិនទាន់ចៀស ក៏ក្រោធទើបយកដងជន្ទញវាយនឹមរបស់អ្នករទេះដែលបរមុខគេ ដងជន្ទញនោះចំនឹមរទេះ ក៏ខ្ទាតត្រឡប់មកត្រូវថ្ងាសរបស់ខ្លួនឯង ថ្ងាសរបស់គាត់ក៏ប៉ោងឡើងបុរោហិតនោះក៏ត្រឡប់ទៅក្រាបទូលដល់ព្រះរាជាថា ពួកអ្នករទេះវាយ ទើបព្រះរាជាក៏ត្រាស់ឲ្យចៅក្រមវិនិច្ឆ័យ ពួកចៅក្រមក៏ហៅពួកអ្នករទេះមក ហើយវិនិច្ឆ័យ ឃើញតែទោសកំហុសរបស់បុរោហិតប៉ុណ្ណោះ ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា បុរោ-ហិតរបស់ព្រះរាជាចោទគេថា ពួកអ្នករទេះវាយខ្លួន តែខ្លួនឯងសោះជាអ្នកធ្វើខុស ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថាបពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន បុរោហិតនេះក៏ធ្វើកម្មបែបនេះដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបានជាអាមាត្យអ្នកវិនិច្ឆ័យក្តី របស់ព្រះបាទពារាណសីនោះឯង សេចក្តីទាំងអស់មានដូច្នេះថា កាលនោះ បុរោហិតរបស់ព្រះរាជា បានទៅកាន់ស្រុកសួយរបស់ខ្លួនដោយរថ ដូច្នេះជាដើម ដូចគ្នានឹងសេចក្តីដែលមានហើយខាងដើមនោះឯង ។ តែក្នុងជាតកនេះ កាលបុរោហិតនោះក្រាបទូលព្រះរាជាហើយ ព្រះរាជាប្រថាប់គង់ក្នុងរោងវិនិច្ឆ័យដោយព្រះអង្គឯង ត្រាស់ឲ្យហៅពួកអ្នករទេះមក មិនបានជម្រះក្តីឲ្យជាក់ច្បាស់ ត្រាស់ថា ពួកអ្នកវាយបុរោហិតរបស់យើងធ្វើថ្វាសឲ្យពកឡើង ហើយត្រាស់ថា អ្នកទាំងឡាយចូរពិន័យពួកអ្នករទេះទាំងនោះ ។ លំដាប់នោះ ព្រះពោធិសត្វក្រាបទូលព្រះរាជាថា បពិត្រមហារាជ ទ្រង់មិនបានជម្រះការធ្វើឲ្យជាក់ច្បាស់ឡើយ ទ្រង់ឲ្យពិន័យពួករទេះទាំងនោះ ដ្បិតថា បុគ្គលពួកខ្លះ ប្រហារខ្លួនដោយខ្លួនឯងក៏ពោលថាត្រូវអ្នកដទៃប្រហារ ព្រោះដូច្នោះការមិនវិនិច្ឆ័យ ហើយសម្រេចមិនគួរ ធម្មតាព្រះរាជាគ្រងរាជសម្បត្តិ ពិចារណាហើយទើបដាក់រាជបញ្ជាគួរ ហើយបានពោលគាថាទាំងនេះថា

បពិត្រព្រះរាជា បុគ្គលខ្លះ ប្រហារខ្លួនដោយខ្លួនឯង ហើយ
និយាយថា គេប្រហារក៏មាន ផ្ចាញ់គេ ហើយនិយាយថា គេ
ផ្ចាញ់ខ្លួនក៏មាន អ្នកប្រាជ្ញកុំគប្បីជឿពាក្យនៃអ្នកនិយាយ មុន
ដោយដាច់ខាតឡើយ ។

ហេតុនោះ បណ្ឌិតជាតិ គួរស្តាប់ពាក្យរបស់បុគ្គលក្រៅពីនេះ

ផង លុះស្តាប់ពាក្យរបស់ជនទាំង ២ នាក់ហើយ គប្បីធ្វើតាមពាក្យច្បាប់ចុះ ។

គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូស មិនប្រពៃ អ្នកបួសមិនសង្រួមមិនប្រសើរ ព្រះរាជាមិនពិចារណាហើយធ្វើមិនប្រសើរ បណ្ឌិតដែលជាអ្នកច្រើនក្រោធក៏ពុំប្រសើរ ។

បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រគប្បីពិចារណាហើយសឹមធ្វើ បើមិនទាន់ពិចារណាមិនត្រូវធ្វើទេ យសក្តី កិត្តិសព្ទក្តី រមែងចម្រើនដល់ព្រះរាជាដែលពិចារណា ហើយទើបធ្វើដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ ហន្ត្វា** សេចក្តីថា បុគ្គលពួកខ្លះប្រទូស្តខ្លួនឯងដោយខ្លួនឯង គង់និយាយ គឺពោលបង្កាច់ថា ត្រូវអ្នកដទៃប្រទូស្ត ។ បទថា **ចេត្វា ជិតោ** សេចក្តីថា ឬខ្លួនឯងផ្ចាញ់អ្នកដទៃហើយពោលចោទថា ខ្ញុំត្រូវផ្ចាញ់ ។ បទថា **អញ្ញនត្ថុ** សេចក្តីថា បពិត្រមហារាជ បុគ្គលមិនគួរជឿពាក្យរបស់ដើមចោទដែលទៅកាន់រាជត្រកូល ហើយនិយាយមុន គឺមិនគប្បីជឿពាក្យរបស់ដើមចោទដោយចំណែកមួយ ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលមិនគួរជឿពាក្យរបស់បុគ្គលដែលមកពោលមុនដោយចំណែកមួយ ។ បទថា **យថា ធម្មោ** សេចក្តីថា សភាវៈ គឺគោលការណ៍វិនិច្ឆ័យតាំងទុកយ៉ាងណា គប្បីធ្វើយ៉ាងនោះ ។ បទថា **អសញ្ញតោ** បានដល់ ដែលមិនសង្រួមកាយជាដើម គឺជាអ្នកទ្រុស្តសីល ។ បទថា **តំ ន សាធុ** សេច

ក្តីថា សេចក្តីក្រោធ ពោលគឺការអាក់អន់ ដែលមាំទាំដោយការប្រកាន់អស់កាលយូរ របស់បណ្ឌិត គឺបុគ្គលដែលមានការដឹងនោះ មិនល្អ ។ បទថា **ឆានិសម្ម** បានដល់ ទ្រង់មិនពិចារណាហើយ មិនគួរធ្វើ ។ បទថា **ធិសម្បតិ** សេចក្តីថា បពិត្រមហារាជ បុគ្គលជាធំនៃទិសទាំងឡាយ ។ បទថា **យសោកិត្តិ ច** សេចក្តីថា បរិវារ គឺភាពជាធំ និងកិត្តិសព្ទ រមែងចម្រើន ។

ព្រះរាជាបានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ទ្រង់វិនិច្ឆ័យកាត់ក្តីដោយធម៌ កាលទ្រង់វិនិច្ឆ័យដោយធម៌ ទោសកំហុសមានដល់ព្រាហ្មណ៍ប៉ុណ្ណោះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាព្រាហ្មណ៍នេះក្នុងកាលឥឡូវនេះ ចំណែកអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វេឡុជាតក ចប់

# គោធជាតក

[ ៦៣០ ] ( នាងទេវីក្រាបបង្គំទូលថា ) ព្រះអង្គណា ដែលមានព្រះ ខ័នសៀត ទ្រង់ស្និតស្នាងហើយ ទ្រទ្រង់នូវសំពត់គីរីជិ ទ្រង់មានទទ្បងធ្នូរ បានបោលទៅអំពីមែកអស្សត្ថព្រឹក្ស ព្រះអង្គនោះ ទ្រង់ប្រសើរក្នុងរថ គឺខ្ញុំ ដឹងច្បាស់ហើយក្នុងកណ្ដាលព្រៃក្នុងកាលនោះឯង ។

[ ៦៣១ ] ( ពោធិសត្វពោលថា ) បុគ្គលគប្បីសំពះបុគ្គលអ្នកសំពះ ខ្លួន គប្បីសេពគប់បុគ្គលអ្នកសេពគប់ខ្លួន គប្បីធ្វើកិច្ចរបស់បុគ្គលដែលជួយ ធ្វើកិច្ចខ្លួន មិនគប្បីធ្វើនូវសេចក្ដីចម្រើន ដល់បុគ្គលអ្នកប្រាថ្នាសេចក្ដីវិនាស មិនគប្បីគប់រកនូវបុគ្គលដែលមិនគប់រក ( ខ្លួននោះឡើយ ) ។

[ ៦៣២ ] គប្បីលះបង់នូវបុគ្គលដែលលះបង់ខ្លួន មិនគប្បីធ្វើនូវសេច ក្ដីស្រឡាញ់ដោយតណ្ហា ( ក្នុងបុគ្គលនោះ ) មិនគប្បីគប់រកនូវបុគ្គលដែល មានចិត្តរវើរវាយ ដូចសត្វបក្សីដឹងថា ឈើមានផ្លែអស់ហើយ ( ហើរទៅរក ដើមឈើដែលមានផ្លែបរិបូណ៌ ) គប្បីរមិលមើលបុគ្គលដទៃ ព្រោះថាលោក សន្និវាសធំណាស់ ។

[ ៦៣៣ ] ( ព្រះរាជាត្រាស់ថា ) យើងនោះជាក្សត្រ កាលឃើញនូវ ភាពនៃកតញ្ញូនឹងធ្វើតបដល់នាងតាមសមត្ថភាព យើងនឹងឲ្យឥស្សរិយយស ទាំងអស់ដល់នាង នាងចង់បានរបស់ណា យើងនឹងឲ្យរបស់នោះដល់នាង ។

**ចប់ គោធជាតកទី ៣ ។**

# អដ្ឋកថា

## គោធជាតក

[ ៦៣០-៦៣៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **តមេវ មេ តុំ** ដូច្នេះ ។

រឿងបច្ចុប្បន្ន បានឲ្យពិស្តារហើយខាងដើមនោះឯង តែក្នុងជាតកនេះ កាលស្វាមីភរិយាទាំងពីរនោះ ទារបំណុលស្រេចហើយ ត្រឡប់មកតាមផ្លូវ ព្រានព្រៃម្នាក់បានឲ្យទន្សងអាំងមួយ ដោយពោលថា សូមអ្នកទាំងពីរបរិភោគចុះ ។ បុរសជាប្តីនោះ បានប្រើភរិយាឲ្យទៅដងទឹក ហើយស៊ីសាច់ទន្សងអស់ ក្នុងពេលភរិយានោះត្រឡប់មកក៏ពោលថា នែនាង ទន្សងគេចទៅហើយ ។ ភរិយាពោលថា សាធុ បើទន្សងអាំងគេចទៅហើយខ្ញុំនឹងធ្វើដូចម្ដេច ។ ភរិយានោះផឹកទឹកក្នុងវត្តជេតពនហើយ អង្គុយក្នុងសម្នាក់របស់ព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា ឧបាសិកា ប្តីរបស់នាងប្រាថ្នាប្រយោជន៍ មានសេចក្តីស្រឡាញ់ល្អ ( ធ្វើ ) ឧបការៈដល់នាងដែរឬ នាងក៏ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់មានសេចក្តីប្រាថ្នាប្រយោជន៍ មានសេចក្តីស្រឡាញ់ក្នុងប្តីនេះ តែប្តីមិនមានសេចក្តីស្រឡាញ់ក្នុងខ្ញុំម្ចាស់ឡើយ ព្រះសាស្តាត្រាស់ថា ណ្ហើយចុះនាងកុំគិតប្តីឡើយ ប្តីនេះរមែងធ្វើយ៉ាងនេះ កាលណារឭកដល់គុណរបស់នាងបាន កាលនោះនឹងឲ្យភាពជាធំទាំងអស់ចំពោះនាងប៉ុណ្ណោះ កាលជនទាំងពីរគឺស្វាមីភរិយាទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

សូម្បីរឿងក្នុងអតីតៈ ក៏ដូចគ្នានឹងរឿងដែលពោលហើយខាងដើមនោះឯង តែក្នុងជាតកនេះ កាលព្រះរាជបុត្តនិងព្រះជាយានោះយាងត្រឡប់ ក្នុងរវាងផ្លូវ ព្រានព្រៃទាំងឡាយឃើញការអស់កម្លាំងរបស់ជនទាំងពីរ ទើបឲ្យសាច់ទន្សងអាំងមួយប្រាប់ថា សូមអ្នកទាំងពីរបរិភោគចុះ ។ ព្រះរាជធីតា យកវល្លិចងទន្សងនោះហើយ កាន់ធ្វើដំណើរទៅ ។ ជនទាំងពីរនោះ ជួបស្រះទឹកមួយកន្លែង ទើបគេចចេញអំពីផ្លូវ អង្គុយត្រង់ដើមអស្សត្ថព្រឹក្ស ។ ព្រះរាជបុត្តត្រាស់ថា នែនាង ចូរនាងទៅដងទឹកអំពីស្រះមកដោយស្លឹកឈូក យើងនឹងបរិភោគសាច់ទាំងអស់គ្នា ។ ព្រះរាជធីតានោះ ព្យួរទន្សងទុកត្រង់មែកឈើ ហើយទៅដើម្បីដងទឹក ។ ចំណែកព្រះរាជបុត្ត សោយសាច់ទន្សងអស់ហើយ ទ្រង់អង្គុយបែរព្រះភក្ត្រចាប់កន្ទុយទន្សង ។ រាជបុត្តនោះ កាលព្រះរាជធីតាសោយទឹកឆ្អែត ត្រឡប់មកទើបត្រាស់ថា នាងដ៏ចម្រើន ទន្សងចុះអំពីមែកឈើ ចូលទៅកាន់ដំបូក យើងរត់ដេញចាប់កន្ទុយបាន តែខ្លួនវាដាច់ចូលដំបូកទៅហើយ សល់ត្រឹមតែកន្ទុយដែលចាប់ក្នុងដៃប៉ុណ្ណោះ ព្រះរាជធីតាទូលថា ណ្ហើយចុះព្រះអង្គ កាលទន្សងអាំងគេចទៅបានខ្ញុំម្ចាស់នឹងធ្វើដូចម្តេច មកយើងទៅ ។ ជនទាំងពីរនោះផឹកទឹកហើយ ទៅដល់នគរពារាណសី រាជបុត្តបានរាជសម្បត្តិ ហើយតាំងព្រះរាជធីតានោះទុកត្រឹមតែជាតំណែងអគ្គមហេសី ចំណែកសក្ការៈនិងការរាប់អានមិនមានដល់ព្រះនាងឡើយ ។ ព្រះពោធិសត្វបំណងនឹងឲ្យព្រះរាជាធ្វើសក្ការៈដល់ព្រះនាង ទើបឈរក្នុងសម្នាក់របស់ព្រះរាជាហើយទូលថា បពិត្រព្រះនាង ទូលបង្គំគួរបានរបស់អ្វីមួយអំពី

សម្អាក់ព្រះនាងមិនមែនឬ ហេតុអ្វីព្រះនាងមិនសម្លឹងមើលទូលបង្គំសោះ ព្រះទេវីត្រាស់ថា បពិត្រលោកឪពុក ខ្ញុំក៏មិនបានអ្វីអំពីសម្អាក់ព្រះរាជា ខ្ញុំនឹងមានអ្វីឲ្យលោកនោះ មកទល់ឥឡូវនេះ ព្រះរាជាប្រទានដល់ខ្ញុំដូចម្តេចកើតសូម្បីក្នុងកាលមកអំពីព្រៃ ទ្រង់សោយសាច់ទន្សងអាំងតែមួយអង្គឯង ។ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះនាង ព្រះអង្គទ្រង់ជាបុគ្គលប្រសើរ ទ្រង់នឹងមិនធ្វើដូច្នោះពិត ព្រះនាងកុំត្រាស់យ៉ាងនេះឡើយ ។ លំដាប់នោះ ព្រះទេវីត្រាស់នឹងព្រះពោធិសត្វថា បពិត្រលោកឪពុករឿងនោះមិនប្រាកដដល់លោក ប្រាកដចំពោះព្រះរាជានិងខ្ញុំប៉ុណ្ណោះ ទើបត្រាស់គាថាទី ១ ថា

ព្រះអង្គណា ដែលមានព្រះខ័នសៀត ទ្រង់ស្អិតស្អាងហើយ
ទ្រទ្រង់នូវសំពត់គីរីដិ ទ្រង់មានទន្សងឆ្អើរ បានបោលទៅអំពី
មែកអស្សត្ថព្រឹក្ស ព្រះអង្គនោះ ទ្រង់ប្រសើរក្នុងរថ គឺខ្ញុំដឹង
ច្បាស់ហើយក្នុងកណ្តាលព្រៃ ក្នុងកាលនោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តទេវ** សេចក្តីថា ក្នុងកាលនោះឯង ខ្ញុំជ្រាបទ្រង់បានយ៉ាងនេះថា ព្រះរាជានេះមិនប្រទានអ្វីដល់ខ្ញុំ តែអ្នកដទៃរមែងមិនដឹងសភាវៈរបស់ទ្រង់ ។ បទថា **ខគ្គពទ្ធស្ស** បានដល់ ទ្រង់សៀតព្រះខ័ន ។ បទថា **គីរីដិនោ** សេចក្តីថា ក្នុងពេលទ្រង់ស្លៀកព្រះកូសាសម្បកឈើយាងមកតាមផ្លូវ ។ បទថា **បក្កា** សេចក្តីថា ទន្សងអាំងលើរងើកភ្លើងគេចទៅហើយ ។

ព្រះទេវីត្រាស់ទោសដែលព្រះរាជាទ្រង់ធ្វើឲ្យប្រាកដ ក្នុងកណ្តាលបរិស័ទ

ដោយប្រការយ៉ាងនេះ ។ ព្រះពោធិសត្វបានស្តាប់ដូច្នោះ ក្រាបទូលថា បពិត្រព្រះនាង ព្រោះការធ្វើមិនផាសុកឲ្យដល់ទ្រង់ទាំងពីរអង្គ ចាប់តាំងពីពេលមិនជាទីប្រោសប្រាណរបស់ព្រះរាជាដ៏ប្រសើរ ព្រះនាងប្រថាប់នៅក្នុងទីនេះព្រោះអ្វី ហើយបានពោលគាថា ២ ថា

បុគ្គលគប្បីសំពះបុគ្គលអ្នកសំពះខ្លួន គប្បីសេពគប់បុគ្គលអ្នកសេពគប់ខ្លួន គប្បីធ្វើកិច្ចរបស់បុគ្គលដែលជួយធ្វើកិច្ចខ្លួន មិនគប្បីធ្វើនូវសេចក្តីចម្រើន ដល់បុគ្គលអ្នកប្រាថ្នាសេចក្តីវិនាស មិនគប្បីគប់រកនូវបុគ្គលដែលមិនគប់រក ( ខ្លួននោះឡើយ ) ។

គប្បីលះបង់នូវបុគ្គលដែលលះបង់ខ្លួន មិនគប្បីធ្វើនូវសេចក្តីស្រឡាញ់ដោយតណ្ហា ( ក្នុងបុគ្គលនោះ ) មិនគប្បីគប់រកនូវបុគ្គលដែលមានចិត្តរវើរវាយ ដូចសត្វបក្សីដឹងថាឈើមានផ្លែអស់ហើយ ( ហើរទៅរកដើមឈើដែលមានផ្លែបរិបូណ៌ ) គប្បីរមិលមើលបុគ្គលដទៃ ព្រោះថាលោកសន្និវាសធំណាស់ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នមេ នមន្តស្ស** សេចក្តីថា បុគ្គលណាសំពះខ្លួនដោយចិត្តទន់ភ្លន់ គប្បីសំពះតបបុគ្គលនោះប៉ុណ្ណោះ ។ បទថា **កិច្ចានុកុព្វស្ស** បានដល់ អ្នកជួយធ្វើកិច្ចដែលកើតឡើងដល់ខ្លួនប៉ុណ្ណោះ ។ បទថា **នានត្ថកាមស្ស** បានដល់ បុគ្គលមិនត្រូវការសេចក្តីចម្រើន ។ បទថា

**វជេថ ឆ កាយិកា** សេចក្តីថា មិនគប្បីធ្វើនូវសេចក្តីស្នេហា ដោយអំណាចតណ្ហាក្នុងបុគ្គលដែលលះបង់នោះ ។ បទថា **អបេតចិត្តេន** បានដល់ ដែលមានចិត្តឆ្ងាយ គឺមានចិត្តនឿយណាយ ។ បទថា **ន សម្ភជេយ្យ** បានដល់ មិនគប្បីសមាគម ។ បទថា **អញ្ញំ សមេក្ខេយ្យ** បានដល់ គប្បីសម្លឹងមើលអ្នកដទៃ អធិប្បាយថា បក្សីដឹងថាដើមឈើឥតផ្លែ រមែងទៅកាន់ដើមឈើដទៃដែលមានផ្លែយ៉ាងណា បុគ្គលក៏យ៉ាងនោះ ដឹងថាបុរសអស់សេចក្តីស្រឡាញ់ហើយ គប្បីទៅរកអ្នកដទៃ ដែលគេស្រឡាញ់ខ្លួនដោយល្អ ។

ព្រះរាជាកាលព្រះពោធិសត្វកំពុងពោលនោះឯង រឭកដល់គុណព្រះទេវីបានទើបត្រាស់ថា នាងដ៏ចម្រើន យើងមិនបានកំណត់គុណរបស់នាងអស់កាលមានប្រមាណប៉ុណ្ណេះ យើងកំណត់បានចំពោះពាក្យរបស់បណ្ឌិតនេះឯង នឹងឲ្យរាជសម្បត្តិនេះដល់នាងដែលអត់សង្កត់នូវកំហុសរបស់យើងបាន ទើបត្រាស់គាថាទី ៤ ថា

> យើងនោះជាក្សត្រ កាលឃើញនូវភាពនៃកតញ្ញូនឹងធ្វើតបដល់
> នាងតាមសមត្ថភាព យើងនឹងឲ្យឥស្សរិយយសទាំងអស់ដល់
> នាង នាងចង់បានរបស់ណា យើងនឹងឲ្យរបស់នោះដល់នាង
> ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ** ប្រែថា យើងនោះ ។ បទថា **យថានុភាវំ** បានដល់ តាមសមត្ថភាព ។ បទថា **យស្សិច្ឆសិ** សេចក្តីថា នាងចង់បានដើម្បីឲ្យ ដល់បុគ្គលណា យើងនឹងឲ្យវត្ថុដែលនាងចង់បាន ចាប់តាំងអំពី

រាជសម្បត្តិនេះទៅ ដើម្បីបុគ្គលនោះ ។

ព្រះរាជា កាលត្រាស់យ៉ាងនោះហើយ បានប្រទានភាពជាធំទាំងពួងដល់ព្រះទេវី កាលទ្រង់ព្រះតម្រិះថា បណ្ឌិតនេះ ធ្វើឲ្យអញរឭកដល់គុណរបស់ព្រះទេវី ក៏ប្រទានឥស្សរិយយសធំដល់បណ្ឌិតនោះផង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ប្តីប្រពន្ធទាំងពីរ តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់សមោធានជាតកថា ភរិយាស្វាមីក្នុងកាលនោះ បានជាប្តីប្រពន្ធក្នុងកាលឥឡូវនេះ ចំណែកអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គោធជាតក ចប់

## រាជោវាទជាតក

[ ៦៣៤ ] ( ព្រះពោធិសត្វពោលថា ) កាលដែលពួកគោញីឆ្លងដើរ ទៅ បើគោមេហ្វូងដើរវៀច ពួកគោញីក៏ដើរវៀចតាមដែរ ព្រោះគោមេហ្វូង ដើរវៀចនោះ ។

[ ៦៣៥ ] ក្នុងពួកមនុស្ស ក៏យ៉ាងនោះដែរ មនុស្សណាដែលគេសន្មត ជាប្រសើរជាងគេ បើមនុស្សនោះប្រព្រឹត្តអធម៌នឹងបាច់និយាយទៅថ្វីដល់ប្រ-ជាជនឯទៀត បើព្រះរាជាជាអ្នកប្រព្រឹត្តអធម៌ រាស្ត្រទាំងអស់រមែងដេកជា ទុក្ខ ។

[ ៦៣៦ ] កាលដែលពួកគោញីដើរឆ្លងទៅ បើគោមេហ្វូងដើរត្រង់ ពួក គោញីទាំងអស់ក៏ដើរត្រង់ដែរ កាលបើគោមេហ្វូងនាំដើរទៅត្រង់ ។

[ ៦៣៧ ] ក្នុងពួកមនុស្សក៏យ៉ាងនោះដែរ មនុស្សណាដែលគេសន្មត ជាប្រសើរជាងគេ បើមនុស្សនោះប្រព្រឹត្តធម៌នឹងបាច់និយាយទៅថ្វីដល់ប្រជា-ជនក្រៅនេះ បើព្រះរាជាជាអ្នកប្រព្រឹត្តធម៌រាស្ត្រទាំងអស់ក៏ដេកជាសុខ ។

**ចប់ រាជោវាទជាតកទី ៤ ។**

# អដ្ឋកថា

## រាជោវាទជាតក

[ ៦៣៤-៦៣៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធរាជោវាទៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **គវំ ចេ តរមានានំ** ដូច្នេះ ជាដើម ។

រឿងបច្ចុប្បន្នមានច្បាស់ក្នុងតេសកុណជាតក ចំណែកក្នុងជាតកនេះ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រះរាជាក្នុងកាលមុន ទ្រង់ស្តាប់ពាក្យរបស់បណ្ឌិតទាំងឡាយហើយ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ បំពេញផ្លូវទៅកាន់ឋានសួគ៌ឲ្យបរិបូណ៌ហើយ កាលព្រះរាជាទ្រង់អារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយ រៀនសិប្បៈទាំងឡាយស្រេចហើយ បួសជាឥសី ធ្វើអភិញ្ញានិងសមាបត្តិ ឲ្យកើតឡើង មានឫសឈើនិងផ្លែឈើក្នុងព្រៃជាអាហារ នៅក្នុងហិមវន្តប្បទេសដ៏ជាទីរីករាយ ។ ក្នុងកាលនោះ ព្រះរាជាទ្រង់រង្កៀសទោសដែលមិនមែនជាគុណ ទ្រង់ព្រះតម្រិះថា បុគ្គលណាដែលពោលទោសមិនមែនគុណរបស់អាត្មាអញមានឬ ទើបទ្រង់ស្វែងរក មិនបានឃើញបុគ្គលណាមួយដែលពោលទោសរបស់ទ្រង់ ទាំងក្នុងអន្តោជននិងពាហិរជន ទាំងខាងក្នុងព្រះនគរនិងខាងក្រៅព្រះនគរ ទ្រង់ព្រះតម្រិះថា ក្នុងអ្នកជនបទតើដូចម្តេចដែរហ្ន៎ ទើបក្លែងភេទយាងទៅតាមជនបទ សូម្បីក្នុងជនបទ ក៏ទ្រង់មិនបានឃើញអ្នកដែលពោលទោស ទ្រង់បាន

ស្តាប់តែពាក្យសរសើរគុណរបស់ទ្រង់ប៉ុណ្ណោះ ទើបព្រះតម្រិះថា ក្នុងហិមវន្តប្បទេសដូចម្ដេចដែរហ្ន៎ ហើយយាងចូលទៅកាន់ព្រៃ រហូតដល់អាស្រមរបស់ព្រះពោធិសត្វ ទ្រង់អភិវាទព្រះពោធិសត្វហើយ ធ្វើបដិសណ្ឋារៈប្រថាប់គង់ក្នុងចំណែកម្ខាង ។ កាលណោះព្រះពោធិសត្វ នាំផ្លែនិគ្រោធ ( ជ្រៃ ) ទុំអំពីព្រៃមកបរិភោគ ផ្លែនិគ្រោធទុំទាំងនោះផ្អែមមានឱជៈ មានរសស្មើដោយលម្អិតស្ករក្រាម ។ ព្រះពោធិសត្វនោះ យាងព្រះរាជាថា អ្នកមានបុណ្យច្រើនអញ្ជើញលោកបរិភោគផ្លែនិគ្រោធទុំនេះ ហើយបរិភោគទឹក ។ ព្រះរាជាទ្រង់ធ្វើយ៉ាងនោះ ហើយត្រាស់សួរព្រះពោធិសត្វថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វីហ្ន៎ ទើបផ្លែនិគ្រោធនេះផ្អែមល្អពិត ។ ព្រះពោធិសត្វពោលថា អ្នកមានបុណ្យច្រើន ព្រះរាជាគ្រងរាជសម្បត្តិដោយធម៌ស្មើពិត ព្រោះហេតុនោះទើបផ្លែនិគ្រោធទុំនេះផ្អែម ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ក្នុងកាលដែលព្រះរាជាមិនតាំងនៅក្នុងធម៌ ផ្លែឈើទុំមិនផ្អែមឬ ព្រះពោធិសត្វទូលថា ពិតហើយអ្នកមានបុណ្យច្រើន កាលព្រះរាជាទាំងឡាយ មិនតាំងនៅក្នុងធម៌ ប្រេង ទឹកឃ្មុំ ស្ករអំពៅក្តី ឬសឈើនិងផ្លែឈើក្នុងព្រៃក្តី រមែងមិនផ្អែមអស់នូវឱជៈ ម្យ៉ាងទៀត មិនមែនតែរបស់ទាំងនេះតែម្យ៉ាងទេ សូម្បីរដ្ឋទាំងមូលក៏អស់ឱជៈ គ្មានតម្លៃ តែកាលព្រះរាជាទាំងឡាយទ្រង់តាំងនៅក្នុងធម៌ សូម្បីវត្ថុទាំងនោះ ក៏រមែងផ្អែមមានឱជៈ រដ្ឋទាំងមូលក៏មានឱជៈដូចគ្នា ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ គង់នឹងជាយ៉ាងនោះ ។ ព្រះរាជាទ្រង់មិនឲ្យដឹងព្រះអង្គថាជាព្រះរាជាឡើយ ទ្រង់ថ្វាយបង្គំព្រះពោធិសត្វ ហើយយាងមក

កាន់នគរពារាណសី ទ្រង់ព្រះតម្រិះថា នឹងសាកល្បងពាក្យរបស់តាបសទើប ទ្រង់គ្រងរាជ្យមិនប្រកបដោយធម៌ ទ្រង់ព្រះតម្រិះថា នឹងដឹងសេចក្តីពិតក្នុងកាលឥឡូវនេះ ទើបឲ្យពេលវេលាកន្លងទៅបន្តិចបន្តួច ហើយយាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះទៀត ទ្រង់ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង ។ ចំណែកព្រះពោធិសត្វក៏ពោលយ៉ាងនោះឯង ហើយបានថ្វាយផ្លែនិគ្រោធទុំដល់ព្រះរាជានោះ ផ្លែនិគ្រោធទុំនោះក៏មានរសល្វីងដល់ព្រះរាជា ។ ព្រះរាជាទ្រង់ដឹងថាមិនផ្អែម ប្រាសចាករស ទើបស្តោះចោលមួយអន្លើដោយទឹកមាត់ហើយពោលថា ល្វីងលោកម្ចាស់ ។ ព្រះពោធិសត្វទូលថា អ្នកមានបុណ្យច្រើន ព្រះរាជាមិនបានប្រព្រឹត្តធម៌ដោយពិត ព្រោះកាលព្រះរាជាទាំងឡាយមិនប្រព្រឹត្តធម៌ របស់ទាំងអស់ តាំងអំពីផ្លែឈើក្នុងព្រៃ រមែងមិនមានឱជៈ ហើយបានពោលគាថាទាំងនេះថា

កាលដែលពួកគោញីឆ្លងដើរទៅ បើគោមេហ្វូងដើរវៀច ពួក
គោញី ក៏ដើរវៀចតាមដែរ ព្រោះគោមេហ្វូងដើរវៀចនោះ ។
ក្នុងពួកមនុស្សក៏យ៉ាងនោះដែរ មនុស្សណាដែលគេសន្មត
ថាប្រសើរជាងគេបើមនុស្សនោះប្រព្រឹត្តអធម៌នឹងបាច់និយាយ
ទៅថ្វីដល់ប្រជាជនឯទៀត បើព្រះរាជា ជាអ្នកប្រព្រឹត្តអធម៌
រាស្ត្រទាំងអស់រមែងដេកជាទុក្ខ ។
កាលដែលពួកគោញីដើរឆ្លងទៅ បើគោមេហ្វូងដើរត្រង់ពួក
គោញីទាំងអស់ ក៏ដើរត្រង់ដែរ កាលបើគោមេហ្វូងនាំដើរ

ទៅត្រង់ ។

ក្នុងពួកមនុស្សក៏យ៉ាងនោះដែរ មនុស្សណាដែលគេសន្មត ថាប្រសើរជាងគេ បើមនុស្សនោះប្រព្រឹត្តធម៌នឹងបាច់និយាយ ទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាជាអ្នកប្រព្រឹត្តធម៌រាស្ត្រ ទាំងអស់ក៏ដេកជាសុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គវំ** បានដល់ គោ ។ បទថា **តរមានានំ** សេចក្តីថា កាលគោទាំងឡាយឆ្លងស្ទឹង ។ បទថា **ជិម្ហំ** បានដល់ វៀច គឺ កោង ។ បទថា **នេត្តេ** សេចក្តីថា កាលគោដែលជាមេហ្វូង គឺគោម្ចាស់ហ្វូង ដែលជាអ្នកនាំមុខគោ នាំទៅ គឺនាំមុខទៅ ។ បទថា **បគេវ ឥតរា បជា** សេចក្តីថា សត្វទាំងឡាយក្រៅអំពីនេះ ក៏រមែងប្រព្រឹត្តអធម៌តាមៗគ្នា ។ បទថា **ទុក្ខំ សេតិ** សេចក្តីថា មិនមែនទៅជាទុក្ខតែម្យ៉ាង រមែងបានជួបនូវទុក្ខ ក្នុងឥរិយាបថទាំង ៤ ផងដែរ ។ បទថា **អធម្មិកោ** សេចក្តីថា បើព្រះរាជា ប្រព្រឹត្តមិនជាធម៌ ដោយលុះក្នុងអគតិ មានឆន្ទាគតិជាដើម ។ បទថា **សុខំ សេតិ** សេចក្តីថា បើព្រះរាជាមិនលុះក្នុងអំណាចអគតិ តាំងនៅក្នុងធម៌ រដ្ឋ ទាំងអស់នឹងដល់នូវសេចក្តីសុខតែម្យ៉ាងក្នុងឥរិយាបថទាំង ៤ ។

ព្រះរាជាទ្រង់ស្តាប់ធម៌របស់ព្រះពោធិសត្វ ទើបទ្រង់ឲ្យដឹងថា ព្រះអង្គជាព្រះរាជា ហើយត្រាស់ថា បពិត្រលោកម្ចាស់ កាលមុនខ្ញុំឯងធ្វើផ្លែនិគ្រោធ ឲ្យផ្អែម ហើយបានធ្វើឲ្យល្វីង ឥឡូវនេះ នឹងធ្វើឲ្យផ្អែមរហូតទៅ ហើយទ្រង់ ថ្វាយបង្គំព្រះពោធិសត្វ ត្រឡប់ទៅកាន់នគរ គ្រងរាជសម្បត្តិដោយធម៌ ទ្រង់

បានធ្វើវត្ថុទាំងពួងឲ្យក្លាយជាប្រក្រតីដូចដើម ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា រាជោវាទជាតក ចប់

# ជម្ពុកជាតក

[ ៦៣៨ ] ( រាជសីហ៍និយាយថា ) នែចចក ដំរីនោះធំណាស់ មានកាយក៏ខ្ពស់ មានភ្លុកក៏វែង ពួកសត្វកើតក្នុងត្រកូលរាជសីហ៍ណា រមែងចាប់ដំរីបាន អ្នកឯងមិនមែនកើតក្នុងត្រកូលរាជសីហ៍នោះទេ ។

[ ៦៣៩ ] សត្វណា មិនមែនជារាជសីហ៍ ក្លែងខ្លួនដោយមានះថា អញជារាជសីហ៍ សត្វនោះរមែងដេកថ្ងូរលើផែនដី ដូចជាចចកមកកាន់ដំរី ( ត្រូវដំរីជាន់ ) ។

[ ៦៤០ ] ចចកនេះ មិនដឹងកម្លាំងកាយ កម្លាំងប្រាជ្ញា និងកំណើតរបស់សីហៈដែលជាសត្វមានយស ជាសត្វឧត្តម ជាសត្វមានខ្លួនមាំមួន ជាសត្វមានកម្លាំងខ្លាំងសោះ ទើបត្រូវដំរីជាន់ស្លាប់ ។

[ ៦៤១ ] ក្នុងលោកនេះ បុគ្គលណា បានពិចារណាឲ្យដឹងច្បាស់នូវកម្លាំងកាយ និងកម្លាំងប្រាជ្ញា ក្នុងខ្លួន ជាអ្នកកំណត់ដោយការស្វាធ្យាយដោយការប្រឹក្សា ដោយសុភាសិត ( ជាមុន ) ទើបធ្វើការងារ បុគ្គលនោះឈ្មោះថា ឈ្នះនូវប្រយោជន៍ធំ គឺមិនសាបសូន្យប្រយោជន៍ ។

**ចប់ ជម្ពុកជាតកទី ៥ ។**

# អដ្ឋកថា

# ជម្ពុកជាតក

[ ៦៣៨-៦៤១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធហេតុដែលទេវទត្តយកតម្រាប់ព្រះសុគត ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ព្រហា បវឌ្ឍកាយោ សោ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន បានឲ្យពិស្តារហើយខាងដើមនោះឯង ចំណែកក្នុងជាតកនេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ព្រះសាស្តាត្រាស់សួរថា ម្នាលសារីបុត្ត ទេវទត្តឃើញពួកអ្នកហើយធ្វើដូចម្តេច ព្រះថេរៈក៏ក្រាបទូលថា បពិត្រព្រះអង្គ ទេវទត្តនោះ កាលធ្វើត្រាប់តាមព្រះអង្គ ឲ្យផ្ចិតក្នុងដៃខ្ញុំព្រះអង្គហើយសិង ។ ពេលនោះកោកាលិកភិក្ខុក៏យកជង្គង់ប្រហារទេវទត្តនោះត្រង់ទ្រូង ទេវទត្តនោះ ធ្វើត្រាប់តាមព្រះអង្គ បានសោយទុក្ខបែបនេះ ។ ព្រះសាស្តាទ្រង់ស្តាប់ដូច្នោះទើបត្រាស់ថា ម្នាលសារីបុត្ត ទេវទត្តធ្វើតាមកិរិយារបស់តថាគតសោយនូវសេចក្តីទុក្ខមិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បានសោយទុក្ខមកហើយដូចគ្នា កាលព្រះថេរៈទូលអារាធនាទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ យោនយកកំណើតជារាជសីហ៍ នៅក្នុងគុហានាហិមវន្តប្បទេស ។ ថ្ងៃមួយសម្លាប់ក្របីហើយបរិភោគ ផឹកទឹក ហើយត្រឡប់មកគុហា ចចកមួយជួបរាជសីហ៍នោះ ចាល់ប្រេកមិនអាចរត់គេចបានទើបក្រាបចុះ កាលរាជសីហ៍ពោលថា តើមានរឿងអ្វី ចចកក៏ពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងឧបដ្ឋាក

លោកម្ចាស់ រាជសីហ៍ពោលថា បើយ៉ាងនោះឯងចូរមក ហើយនាំចចកទៅកាន់លំនៅរបស់ខ្លួន ហើយនាំសាច់មកឲ្យរាល់ៗថ្ងៃ ។ ចចកនោះមានរាងកាយធាត់ ព្រោះបានស៊ីរំពារបស់រាជសីហ៍ ។ ថ្ងៃមួយក៏កើតមានះឡើងមក ទើបចូលទៅរករាជសីហ៍ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំអំពល់លោកម្ចាស់មកយូរហើយ លោកម្ចាស់នាំសាច់ឲ្យមកខ្ញុំជានិច្ច ថ្ងៃនេះសូមលោកម្ចាស់នៅទីនេះឯង ខ្ញុំនឹងចាប់ដំរីមួយស៊ី ហើយនាំមកដើម្បីលោកម្ចាស់ផង រាជសីហ៍ពោលថា នែចចក អ្នកកុំពេញចិត្តក្នុងរឿងសម្លាប់ដំរីនេះឡើយ ព្រោះអ្នកមិនមែនកើតក្នុងកំណើតសត្វ ដែលសម្លាប់ដំរីបរិភោគសាច់ យើងនឹងសម្លាប់ដំរីឲ្យដល់ឯង ធម្មតាដំរីទាំងឡាយមានខ្លួនធំ រាងកាយខ្ពស់ ឯងកុំចេញមុខចាប់ឡើយ ចូរឯងធ្វើតាមពាក្យរបស់យើង ហើយពោលគាថាទី ១ ថា

នែចចក ដំរីនោះធំណាស់ មានកាយក៏ខ្ពស់ មានភ្លុកក៏វែង
ពួកសត្វកើតក្នុងត្រកូលរាជសីហ៍ណា រមែងចាប់ដំរីបាន អ្នក
ឯងមិនមែនកើតក្នុងត្រកូលរាជសីហ៍នោះទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្រហា** ប្រែថា ធំ ។ បទថា **បវឌ្ឍកាយោ** បានដល់ មានរាងកាយខ្ពស់សម្បើម ។ បទថា **ទីឃទាឋោ** សេចក្តីថា ដំរីនោះមានភ្លុកវែង វានឹងយកភ្លុកប្រហារបុគ្គលដូចអ្នក ឲ្យដល់នូវការអស់ជីវិត ។ បទថា **យត្ថ** សេចក្តីថា ឯងមិនមែនកើតក្នុងត្រកូលរាជសីហ៍ ដែលអាចចាប់ដំរីចុះប្រេងដ៏ប្រសើរ អធិប្បាយថា ឯងកើតក្នុងត្រកូលចចក ។

ចចកកាលរាជសីហ៍ឃាត់ ក៏ចចេសចេញអំពីគុហា បន្លឺសិង្ហាលនាទ ៣

ជនថា ពុក្កុ: ពុក្កា កាលបន្ទឹសំឡេងហើយ ក៏ឈរលើកំពូលភ្នំ សម្លឹងមើល មកជើងភ្នំឃើញដំរីខ្មៅមួយកំពុងដើរតាមជើងភ្នំ ទើបលោតទៅ បំណងថាឲ្យធ្លាក់លើក្បាលដំរីនោះ តែភ្លាត់ធ្លាក់ទៅត្រង់ជើង ដំរីយកជើងមុខ ជាន់លើអំបែងក្បាល របស់ចចកនោះ ក្បាលក៏បែកខ្ទេចជាលម្អិតតូចធំ ចចកនោះដេកស្លាប់ក្នុងទីនោះឯង ។ ដំរីបន្លឺកោញ្ចនាទរំពង ហើយចៀសចេញទៅ ។ ព្រះពោធិសត្វ ឈរលើកំពូលភ្នំ ឃើញចចកនោះ ដល់នូវសេចក្ដីវិនាស ទើបពោលថា ចចកបានទទួលសេចក្ដីវិនាស ព្រោះអាស្រ័យមានះរបស់ខ្លួន ហើយពោលគាថា ៣ ថា

សត្វណា មិនមែនជារាជសីហ៍ ក្លែងខ្លួនដោយមានះថាអញជារាជសីហ៍ សត្វនោះរមែងដេកថ្ងូរលើផែនដី ដូចជាចចកមកកាន់ដំរី ( ត្រូវដំរីជាន់ ) ។

ចចកនេះ មិនដឹងកម្លាំងកាយ កម្លាំងប្រាជ្ញា និងកំណើតរបស់សីហៈដែលជាសត្វមានយស ជាសត្វឧត្តម ជាសត្វមានខ្លួនមាំមួន ជាសត្វមានកម្លាំងខ្លាំងសោះ ទើបត្រូវដំរីជាន់ស្លាប់ ។

ក្នុងលោកនេះ បុគ្គលណា បានពិចារណាឲ្យដឹងច្បាស់នូវកម្លាំងកាយនិងកម្លាំងប្រាជ្ញា ក្នុងខ្លួន ជាអ្នកកំណត់ដោយការស្វាធ្យាយដោយការប្រឹក្សា ដោយសុភាសិត ( ជាមុន ) ទើបធ្វើការងារ បុគ្គលនោះឈ្មោះថា ឈ្នះនូវប្រយោជន៍ធំ គឺមិនសាបសូន្យប្រយោជន៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិកុព្វតិ** បានដល់ រមែងញុំាងខ្លួនឲ្យផ្លាស់ប្ដូរទៅ ។ បទថា **កោត្ថុវ** បានដល់ ដូចចចក ។ បទថា **អនុត្ថុនំ** បានដល់ ដេកថ្ងូរ ។ លោកពោលពាក្យអធិប្បាយទុកថា ចចកបានទទួលទុក្ខវេទនាដ៏ខ្លាំងក្លា ដេកថ្ងូរលើផែនដីយ៉ាងណា សូម្បីជនដទៃដែលថមថយកម្លាំង ធ្វើនូវការឈ្លោះជាមួយអ្នកមានកម្លាំងក៏យ៉ាងនោះ រមែងដូចចចកនោះឯង ។ បទថា **យសស្សិនោ** បានដល់ ដែលមានភាពជាធំ ។ បទថា **ឧត្តមបុគ្គលស្ស** បានដល់បុគ្គលដែលឧត្តមដោយកម្លាំងកាយនិងកម្លាំងញាណ ។ បទថា **សញ្ញា-តខន្ធស្ស** បានដល់ មានខ្លួនមាំមួនតាំងនៅរៀបរយល្អ ។ បទថា **មហាព្វលស្ស** បានដល់ មានកម្លាំងច្រើន ។ បទថា **ថាមពលូបបត្តឹ** សេចក្ដីថា មិនដឹងកម្លាំង គឺសម្ទុះ និងការកើតឡើង និងឧបបត្តិ គឺជាតិកំណើតជារាជសីហ៍របស់រាជសីហ៍បែបនេះ ។ អត្ថនេះមានដូច្នេះថា ចចកមិនដឹងកម្លាំងកាយកម្លាំងប្រាជ្ញា និងការកើតជារាជសីហ៍ ។ បទថា **ស សេតិ** សេចក្ដីថា ចចកនេះ សម្គាល់ខ្លួនថា ដូចរាជសីហ៍នោះ ទើបត្រូវដំរីព្រេចដេកស្លាប់ ។ បទថា **បមាយ** បានដល់ ជញ្ជឹងគិត គឺពិចារណា ។ បាលីថា **បមាណា** ដូច្នេះក៏មាន អធិប្បាយថា បុគ្គលណាកាន់យកប្រមាណរបស់ខ្លួន ហើយធ្វើដោយប្រមាណរបស់ខ្លួន ។ បទថា **ថាមពលំ** បានដល់ កម្លាំង គឺថាមពល អធិប្បាយថា កម្លាំងកាយនិងកម្លាំងបញ្ញាដូច្នេះក៏បាន ។ បទថា **ជប្បេន** បានដល់ ដោយការរៀនសូត្រ គឺការសិក្សា ។ បទថា **មន្តេន** បានដល់ ដោយការប្រឹក្សាជាមួយបណ្ឌិតទាំងឡាយដទៃ ហើយទើបធ្វើ ។ បទថា **សុភាសិ-**

**តេន** *បានដល់ ដោយវាចាដែលមិនមានទោស ប្រកបដោយគុណមានសច្ចៈជាដើម ។ បទថា* **បរិក្ខវា** *បានដល់ ដល់ព្រមដោយការកំណត់ ។ បទថា* **សោ វិបុលំ ជិនាតិ** *សេចក្តីថា អ្នកណាជាបុគ្គលបែបនោះ គឺជាអ្នកធ្វើការងារឯណានីមួយ ដឹងនូវកម្លាំងកាយ និងកម្លាំងប្រាជ្ញារបស់ខ្លួន ហើយកំណត់ដោយអំណាចការសិក្សាសូត្ររៀន និងការប្រឹក្សាសាកសួរ ពោលតែពាក្យជាសុភាសិតទើបធ្វើ បុគ្គលនោះរមែងឈ្នះ គឺរមែងមិនសាបសូន្យប្រយោជន៍ដែលបរិបូណ៌ផង ច្រើនផង ។ ព្រះពោធិសត្វ ពោលកម្មដែលគួរធ្វើក្នុងលោកនេះដោយគាថា ៣ ដូច្នេះឯង ។*

*ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាទេវទត្ត ក្នុងកាលឥឡូវនេះ ចំណែករាជសីហ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។*

**អដ្ឋកថា ជម្ពុកជាតក ចប់**

# ព្រហាឆត្តជាតក

[ ៦៤២ ] ( អាមាត្យពោធិសត្វទូលថា ) ព្រះអង្គត្រាស់ថាស្មៅៗ ដូច្នេះ តើនរណាហ្ន៎ លួចយកស្មៅរបស់ព្រះអង្គទៅ ហេតុដូចម្ដេច បានជាព្រះអង្គមានកិច្ច ដោយស្មៅ ទើបត្រាស់រកតែស្មៅប៉ុណ្ណោះ ។

[ ៦៤៣ ] ( ព្រះបាទពារាណសីត្រាស់ថា ) តាបសឈ្មោះឆត្តៈ មានរាងកាយដ៏ខ្ពស់ ជាព្រហ្មចារីបុគ្គល ជាពហូសូត បានមកក្នុងទីនេះ លោកបានប្រមូលទ្រព្យរបស់យើងទាំងអស់ រួចដាក់ស្មៅ ( ក្នុងពាងទាំងឡាយ ) ហើយទៅបាត់ ។

[ ៦៤៤ ] ( ព្រះពោធិសត្វពោលថា ) ការកាន់យកទ្រព្យទាំងអស់របស់ខ្លួនក្ដី ការមិនកាន់យកស្មៅ ( ដែលមិនគួរយកទៅ ) នេះក្ដី ជាកិច្ចដែលអ្នកប្រាថ្នានូវទ្រព្យដ៏ច្រើន ដោយយកស្មៅបន្តិចបន្តួច ( ជាលេស ) គប្បីធ្វើយ៉ាងនេះឯង ( ព្រោះហេតុនោះ ) ឆត្តតាបស ដាក់ស្មៅក្នុងពាងទាំងឡាយហើយទៅបាត់ ចុះការខ្សឹកខ្សួលធ្វើអ្វីក្នុងរបស់នោះ ។

[ ៦៤៥ ] ( ព្រះបាទពារាណសីត្រាស់ថា ) ពួកលោកអ្នកមានសីលធម៌មិនធ្វើបែបនេះទេ ចំណែកមនុស្សពាល ទើបធ្វើសីលធម៌ទាំងឡាយរបស់ខ្លួន ( ឲ្យអាក្រក់ ) ភាពជាបណ្ឌិត នឹងធ្វើខ្លួនឲ្យជាបុគ្គលអ្នកទ្រុស្តសីល មានសីលមិនខ្ជាប់ខ្ជួន ដូចម្ដេចកើត ។

**ចប់ ព្រហាឆត្តជាតកទី ៦ ។**

# អដ្ឋកថា

# ព្រហាឆត្តជាតក

[ ៦៤២-៦៤៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តិណំ តិណន្តិ លបសិ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន បានពោលទុកហើយដូចគ្នា ។ ចំណែករឿងក្នុងអតីតៈមានសេចក្តីដូចតទៅនេះ ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបានជាអាមាត្យ អ្នកទូន្មានអត្ថនិងធម៌របស់ព្រះរាជាអង្គនោះ ។ ព្រះបាទពារាណសី ទ្រង់លើកកងទ័ពធំទៅច្បាំងជាមួយព្រះបាទកោសល ទ្រង់យាងដល់នគរសាវត្ថី ហើយចូលនគរចាប់ព្រះបាទកោសលបានដោយការធ្វើចម្បាំង ។ មានព្រះរាជឱរសព្រះនាមថាឆត្តកុមារ ។ ឆត្តកុមារនោះក្លែងភេទគេចចេញទៅកាន់នគរតក្កសិលា រៀនទូវត្រៃវេទនិងសិល្បសាស្ត្រ ១៨ ប្រការ ហើយចេញអំពីនគរតក្កសិលា ត្រាច់សិក្សាសិប្បៈគ្រប់លទ្ធិ រហូតដល់បច្ចន្តគ្រាមមួយ ។ មានតាបស ៥០០ រូបអាស្រ័យនៅក្នុងបច្ចន្តគ្រាមនោះ នាបណ្ណសាលាក្នុងព្រៃ ។ ព្រះរាជកុមារចូលទៅរកតាបសទាំងនោះ ហើយគិតថានឹងសិក្សាអ្វីមួយ ក្នុងសម្នាក់របស់តាបសទាំងនេះ ទើបបួស ហើយរៀនយកលទ្ធិទាំងអស់ដែលតាបសទាំងនោះចេះ ។ ក្នុងកាលតមក ព្រះរាជកុមារបានជាសាស្តាក្នុងគណៈ ថ្ងៃមួយហៅពួកឥសីមកហើយសួរថា លោកនិទ្ទុក្ខ

ទាំងឡាយ ព្រោះហេតុអ្វីទើបពួកលោកមិនទៅកាន់មជ្ឈិមប្រទេស ពួកឥសីពោលថា លោកនិទ្ទុក្ខ ឈ្មោះថាមនុស្សទាំងឡាយក្នុងមជ្ឈិមប្រទេស ជាបណ្ឌិត គេសួរបញ្ហា ឲ្យធ្វើអនុមោទនា ឲ្យពោលមង្គល រមែងតិះដៀលអ្នកមិនមានសមត្ថភាព យើងទាំងឡាយមិនទៅព្រោះ ការខ្លាចនោះ ។ ធត្តតាបសពោលថា លោកទាំងឡាយកុំខ្លាចឡើយ ខ្ញុំនឹងធ្វើកិច្ចទាំងអស់នោះ ។ ពួកតាបសពោលថា បើយ៉ាងនោះពួកយើងនឹងទៅ ។ តាបសទាំងពួងកាន់យកអម្រែកបរិក្ខាររៀងៗខ្លួន ដល់ក្រុងពារាណសីដោយលំដាប់ ។

ចំណែកព្រះបាទពារាណសី ទ្រង់ធ្វើរាជសម្បត្តិរបស់ព្រះបាទកោសលឲ្យធ្លាក់នៅក្នុងកណ្ដាប់ដៃរបស់ទ្រង់ហើយ ទ្រង់តាំងបុគ្គលដែលគួរដល់ព្រះរាជាទុកក្នុងនគរនោះ ចំណែកទ្រង់នាំយកទ្រព្យដែលមានក្នុងនគរនោះទៅកាន់នគរពារាណសី ឲ្យដាក់ពេញពាងលោហៈ ហើយកប់ទុកក្នុងព្រះរាជឧទ្យាន ក្នុងសម័យនោះ ប្រថាប់នៅក្នុងនគរពារាណសីនោះឯង ។ កាលណោះឥសីទាំងនោះ នៅក្នុងព្រះរាជឧទ្យានអស់រាត្រី លុះថ្ងៃស្អែកឡើងទើបចូលទៅភិក្ខាចារក្នុងព្រះនគរ បានទៅកាន់ទ្វារព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងឥរិយាបថរបស់ឥសីទាំងនោះ ទើបនិមន្តមកហើយឲ្យអង្គុយក្នុងផ្ទៃប្រាសាទ ប្រគេនបបរនិងរបស់ទំពា ហើយត្រាស់សួរបញ្ហានោះៗ រហូតដល់ពេលភត្តាហារ ។ ធត្តតាបស កាលនឹងធ្វើព្រះរាជហឫទ័យរបស់ព្រះរាជាឲ្យត្រេកអរ ទើបឆ្លើយបញ្ហាទាំងពួង ក្នុងពេលស្រេចភត្តកិច្ច បានធ្វើអនុមោទនាដ៏វិចិត្រ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្រៃលែងទ្រង់ទទួលប្ដេជ្ញាឲ្យឥសីទាំងអស់នោះនៅក្នុងព្រះរាជឧទ្យាន។

ធុត្តឥសីដឹងមន្តសម្រាប់មើលកំណប់ទ្រព្យ កាលនៅក្នុងព្រះរាជឧទ្យាននោះ គិតថា ព្រះបាទពារាណសីនេះ កប់ទ្រព្យដែលជារបស់បិតាអញទុកក្នុងទីណាហ្ន៎ ទើបរាយមន្តហើយពិនិត្យមើល ដឹងថាកប់ក្នុងព្រះរាជឧទ្យាន ទើបគិតថា នឹងកាន់យកទ្រព្យក្នុងទីនេះ ហើយទៅដណ្តើមយករាជសម្បត្តិមកវិញ ទើបហៅតាបសទាំងឡាយមក ហើយពោលថា លោកនិទ្ទុក្ខទាំងឡាយ ខ្ញុំជាឱរសរបស់ព្រះបាទកោសល ព្រះបាទពារាណសី ដណ្តើមយករាជសម្បត្តិរបស់ខ្ញុំមក ទើបខ្ញុំក្លែងភេទចេញមកដើម្បីរក្សាជីវិត អស់កាលមានប្រមាណប៉ុណ្ណេះ ឥឡូវនេះ ខ្ញុំបានទ្រព្យដែលជារបស់ត្រកូលហើយ ខ្ញុំនឹងកាន់យកទៅដណ្តើមរាជសម្បត្តិរបស់ខ្លួន លោកទាំងឡាយនឹងធ្វើដូចម្តេច ។ ឥសីទាំងឡាយពោលថា ខ្ញុំទាំងឡាយនឹងទៅជាមួយលោកដូចគ្នា ។ ធុត្តឥសីនោះទទួលពាក្យថា សាធុ ហើយឲ្យធ្វើសម្ពាយស្បែកធំៗក្នុងកណ្តាលយប់ ក៏ជីកដីលើកពាងទ្រព្យឡើងមក ដាក់ទ្រព្យក្នុងសម្ពាយទាំងឡាយ ហើយញាត់ស្មៅឲ្យពេញពាងជំនួសទ្រព្យ ឲ្យឥសី ៥០០ និងជនដទៃៗកាន់យកទ្រព្យ គេចទៅកាន់នគរសាវត្ថី ឲ្យចាប់ព្រះរាជានោះ ដណ្តើមយករាជសម្បត្តិវិញ ទើបឲ្យជួសជុលកំពែងនិងប៉មជាដើម ធ្វើនគរនោះ ឲ្យជានគរដែលព្រះរាជាជាសត្រូវដណ្តើមមិនបានដោយការច្បាំងបន្តទៅទៀត ហើយទ្រង់គ្រប់គ្រងព្រះនគរ ។ ចំណែកព្រះបាទ ពារាណសី កាលពួករាជបុរសក្រាបទូលថា តាបសទាំងឡាយកាន់យកទ្រព្យអំពីព្រះរាជឧទ្យាន គេចទៅហើយ ទើបទ្រង់យាងទៅកាន់ព្រះរាជឧទ្យានត្រាស់ឲ្យបើកពាងទ្រព្យមើល ទ្រង់ឃើញតែស្មៅប៉ុណ្ណោះ ។ ព្រះរាជា

ទ្រង់កើតនូវការសោកស្តាយជាខ្លាំង ព្រោះអាស្រ័យទ្រព្យជាហេតុ ។ ទើបយាងទៅកាន់ព្រះនគរ រវើរវាយថា ស្មៅៗ ។ អ្នកដទៃមិនអាចធ្វើនូវសេចក្តីសោករបស់ព្រះរាជានោះឲ្យស្ងប់បាន ។ ព្រះពោធិសត្វគិតថា សេចក្តីសោករបស់ព្រះរាជាធំពេកណាស់ ទ្រង់ត្រាច់រវើរវាយ វៀរអាត្មាអញហើយ អ្នកដទៃមិនអាចបន្ទោបង់សេចក្តីសោករបស់ទ្រង់បានឡើយ អញនឹងធ្វើទ្រង់ ឲ្យអស់សេចក្តីសោក ។ ថ្ងៃមួយ ព្រះពោធិសត្វនោះ អង្គុយជាសុខ ជាមួយព្រះរាជានោះ ក្នុងកាលដែលព្រះរាជាទ្រង់រវើរវាយ ទើបពោលគាថាទី ១ ថា

ព្រះអង្គត្រាស់ថា ស្មៅៗ ដូច្នេះ តើនរណាហ្ន៎ លួចយកស្មៅ
របស់ព្រះអង្គទៅ ហេតុដូចម្តេចបានជាព្រះអង្គមានកិច្ចដោយ
ស្មៅ ទើបត្រាស់រកតែស្មៅប៉ុណ្ណោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិន្នុ តេ តិណាកិច្ចត្ថិ** សេចក្តីថា កិច្ចដែលគប្បីធ្វើដោយស្មៅ មានដល់ទ្រង់ឬហ្ន៎ ។ បទថា **តិណមេវ បភាសសិ** សេចក្តីថា ទ្រង់ត្រាស់ដល់តែស្មៅតែម្យ៉ាងថា ស្មៅៗ មិនត្រាស់ថាស្មៅឈ្មោះនោះឡើយ សូមទ្រង់ត្រាស់ឈ្មោះរបស់ស្មៅនោះមុនថា ស្មៅឈ្មោះនោះ ទូលបង្គំទាំងឡាយនឹងនាំមកថ្វាយទ្រង់ ស្មៅមិនមានប្រយោជន៍អ្វីដល់ទ្រង់ទេ សូមព្រះអង្គ កុំត្រាស់រវើរវាយរកស្មៅដោយឥតហេតុឡើយ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់គាថាទី ២ ថា

តាបសឈ្មោះឆត្តៈ មានរាងកាយដ៏ខ្ពស់ ជាព្រហ្មចារីបុគ្គល
ជាពហុសូត បានមកក្នុងទីនេះ លោកបានប្រមូលទ្រព្យរបស់

យើងទាំងអស់ រួបដាក់ស្មៅ ( ក្នុងពាងទាំងឡាយ ) ហើយ
ទៅបាត់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ព្រហា** ប្រែថា ខ្ពស់ ។ ពាក្យថា **ធត្តោ** ជាឈ្មោះរបស់ឥសីនោះ ។ បទថា **សព្វំ សមាទាយ** បានដល់ កាន់យកទ្រព្យទាំងអស់ ។ ដោយបទថា **តិណាំ និក្ខិប្ប គច្ឆតិ** នេះ ព្រះបាទពារាណសីកាលនឹងសម្ដែងថា ធត្តឥសីដាក់ស្មៅក្នុងពាង ហើយចៀសចេញទៅ ទើបត្រាស់យ៉ាងនេះ ។

ព្រះពោធិសត្វបានស្ដាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

ការកាន់យកទ្រព្យទាំងអស់របស់ខ្លួនក្ដី ការមិនកាន់យកស្មៅ
( ដែលមិនគួរយកទៅ ) នេះក្ដី ជាកិច្ចដែលអ្នកប្រាថ្នានូវទ្រព្យ
ដ៏ច្រើនដោយយកស្មៅបន្តិចបន្តួច ( ជាលេស ) គប្បីធ្វើ
យ៉ាងនេះឯង ( ព្រោះហេតុនោះ ) ធត្តតាបស ដាក់ស្មៅក្នុង
ពាងទាំងឡាយហើយទៅបាត់ ចុះការខ្សឹកខ្សួលធ្វើអ្វីក្នុងរបស់
នោះ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថដូច្នេះថា ការកាន់យកទ្រព្យដែលជារបស់ព្រះរាជបិតាទៅទាំងអស់ និងការមិនកាន់យកស្មៅដែលមិនគួរនឹងយកទៅនោះ ជាកិច្ចដែលអ្នកប្រាថ្នាទ្រព្យដ៏ច្រើនគប្បីធ្វើយ៉ាងនោះជាលេសដោយស្មៅបន្តិចបន្តួច បពិត្រមហារាជ ហេតុនោះទើបធត្តឥសីអ្នកមានរាងកាយខ្ពស់នោះ កាន់យកទ្រព្យដែលជារបស់បិតាខ្លួន ដែលគួរកាន់យក ហើយដាក់ស្មៅ

ដែលមិនគួរកាន់យកក្នុងពានទាំងឡាយ ហើយទៅបាត់ ចុះការខ្សឹកខ្សួលធ្វើអ្វីក្នុងរបស់នោះ ។ ព្រះរាជាស្តាប់ដូច្នោះ ទើបត្រាស់គាថាទី ៤ ថា

ពួកលោកអ្នកមានសីលធម៌មិនធ្វើបែបនេះទេ ចំណែកមនុស្ស
ពាល ទើបធ្វើសីលធម៌ទាំងឡាយរបស់ខ្លួន ( ឲ្យអាក្រក់ )
ភាពជាបណ្ឌិត នឹងធ្វើខ្លួនឲ្យជាបុគ្គលអ្នកទ្រុស្តសីល មាន
សីលមិនខ្ជាប់ខ្ជួន ដូចម្តេចកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលវន្តោ** សេចក្តីថា បុគ្គលដែលសម្បូរដោយសីល ប្រព្រឹត្តព្រហ្មចរិយៈ រមែងមិនធ្វើកម្មបែបនោះ ។ បទថា **ពាលោ សីលានិ កុព្វតិ** សេចក្តីថា ចំណែកបុគ្គលពាល មានអាចារៈមិនល្អ រមែងធ្វើប្រក្រតី ពោលគឺធ្វើអនាចាររបស់ខ្លួនបែបនេះបាន ។ បទថា **អនិច្ចសីលំ** បានដល់ ដែលប្រកបដោយសីលមិនឋិតថេរ គឺមិនប្រព្រឹត្តទៅអស់កាលយូរ ។ បទថា **ទុស្សីល្យំ** បានដល់ បុគ្គលទ្រុស្តសីល ។ បទថា **កឹ បណ្ឌិច្ចំ ករិស្សតិ** សេចក្តីថា ភាពជាបណ្ឌិត ដែលអប់រំមកដោយភាពជាពហុស្សូតនឹងធ្វើបុគ្គលបែបនេះឲ្យទៅជាដូចម្តេច គឺនឹងឲ្យបុគ្គលនោះដល់ព្រមដូចម្តេច គឺនឹងនាំវិបត្តិដល់បុគ្គលនោះ ប៉ុណ្ណោះ ។

ព្រះបាទពារាណសីនោះ កាលតិះដៀលធត្តឥសីនោះហើយ ជាអ្នកអស់សេចក្តីសោក ព្រោះកថារបស់ព្រះពោធិសត្វនោះ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើប

ទ្រង់ប្រជុំជាតកថា ព្រហាឆត្តឥសីក្នុងកាលនោះ បានជាភិក្ខុកុហក ក្នុងកាលឥឡូវនេះ ចំណែកអាមាត្យជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ព្រហាឆត្តជាតក ចប់

# ពីឋជាតក

[ ៦៤៦ ] ( ពារាណសីសេដ្ឋីពោលថា ) យើងខ្ញុំទាំងឡាយមិនបាន ប្រគេនតាំង មិនបានប្រគេនទឹក ទាំងមិនបានប្រគេនភោជនាហារដល់លោក សូមលោកជាព្រហ្មចារីអត់ទោសដល់ខ្ញុំ ខ្ញុំឃើញទោសនុ៎ះហើយ ។

[ ៦៤៧ ] ( ពោធិសត្វពោលថា ) អាត្មាមិនជាប់ចំពាក់ផង មិនខឹងផង ទាំងវត្ថុតិចតួចដែលមិនជាទីស្រឡាញ់របស់អាត្មា ក៏មិនមានឡើយ មួយទៀត អាត្មាមានសេចក្តីត្រិះរិះក្នុងចិត្តថា ធម្មតានៃត្រកូលប្រាកដដូច្នេះ ដោយពិត ។

[ ៦៤៨ ] ( សេដ្ឋីពោលថា ) យើងខ្ញុំបានប្រគេនអាសនៈ ប្រគេនទឹក ប្រគេនប្រេងសម្រាប់លាងជើងទាំងអស់នេះ នេះជាធម្មតារបស់ឪពុកនិងជីតា ក្នុងត្រកូលរបស់យើងខ្ញុំសព្វៗកាល ។

[ ៦៤៩ ] យើងខ្ញុំនឹងបម្រើ ( សមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ល្អ ) ដូចជាញាតិជាន់ខ្ពស់ ដោយសេចក្តីគោរព នេះជាធម្មតារបស់ឪពុកនិងជីតា ក្នុងត្រកូលរបស់យើងខ្ញុំសព្វៗកាល ។

**ចប់ ពីឋជាតកទី ៧ ។**

# អដ្ឋកថា

# បីឋជាតក

[ ៦៤៦-៦៤៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឆ តេ បីឋ-មទាយិម្ហា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះចេញអំពីជនបទ ទៅកាន់វត្តជេតពន ទុកដាក់បាត្រនិងចីវរ ថ្វាយបង្គំព្រះសាស្ដា ហើយសួរសាមណេរក្មេងៗថា អាវុសោ ក្នុងនគរសាវត្ថី អ្នកណាធ្វើឧបការៈដល់ភិក្ខុអាគន្តុកៈទាំងឡាយ ពួកសាមណេរក្មេងៗបានពោលថា លោកម្ចាស់ ជនទាំងនេះគឺ អនាថបិណ្ឌិកមហាសេដ្ឋីនិងវិសាខាមហាឧបាសិកា ជាអ្នកឧបការៈភិក្ខុសង្ឃ តាំងនៅក្នុងឋានៈជាមាតាបិតា ភិក្ខុនោះទទួលពាក្យថា សាធុ ស្អែកឡើងបានទៅកាន់ទ្វារផ្ទះរបស់សេដ្ឋីឈ្មោះអនាថបិណ្ឌិកៈអំពីព្រលឹម ក្នុងពេលដែលភិក្ខុសូម្បីមួយរូបមិនទាន់បានចូលទៅ ព្រោះភិក្ខុនោះទៅមិនទាន់ដល់ពេល បុគ្គលណាមួយក៏មិនឃើញ ភិក្ខុនោះ ក៏មិនបានរបស់អ្វីមួយអំពីទីនោះ ទើបទៅកាន់ទ្វារផ្ទះរបស់នាងវិសាខាមហាឧបាសិកា ត្រង់ផ្ទះរបស់នាងវិសាខាមហាឧបាសិកានោះ លោកក៏មិនបានរបស់ណាមួយ ព្រោះទៅព្រឹកពេក ។ ភិក្ខុនោះត្រាច់ទៅក្នុងទីនោះៗ ហើយបានត្រឡប់មកជាថ្មី ក្នុងពេលគេអង្គាសបបរស្រេចហើយ ត្រាច់ទៅក្នុងទីនោះៗទៀត កាលគេអង្គាសភត្តាហារស្រេចហើយ ទើបទៅដល់ ។ ភិក្ខុនោះត្រឡប់ទៅកាន់វិហារ បានត្រាច់ពោលមើលងាយត្រកូលទាំងនោះថា ត្រកូលទាំងពីរមិនមានសទ្ធា មិនមានការជ្រះថ្លាឡើយ តែភិក្ខុទាំងនេះប្រាប់ថា មាន

សទ្ធា មានសេចក្ដីជ្រះថ្លា ។ ថ្ងៃមួយភិក្ខុទាំងឡាយ អង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ភិក្ខុអ្នកជនបទរូបនោះ ទៅកាន់ទ្វារផ្ទះរបស់ត្រកូលខុសពេលវេលា កាលមិនបានភិក្ខា ទើបដើរមើលងាយត្រកូលទាំងឡាយ ។ ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដោយកថាឈ្មោះនេះ ទើបទ្រង់ឲ្យហៅភិក្ខុនោះមកត្រាស់សួរថា ម្នាលភិក្ខុ រឿងនេះពិតឬ កាលភិក្ខុនោះទូលថា ករុណាពិតព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ព្រោះហេតុអ្វីទើបអ្នកក្រោធ ក្នុងកាលមុន កាលដែលព្រះពុទ្ធមិនទាន់កើតឡើង សូម្បីតាបសទាំងឡាយ ទៅកាន់ទ្វារត្រកូល មិនបានភិក្ខា ក៏មិនក្រោធឡើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយ បានរៀនសិប្បៈគ្រប់យ៉ាងក្នុងនគរតក្កសិលា ។ ក្នុងកាលតមកបានបួសជាតាបស ក្នុងហិមវន្តប្បទេសអស់កាលយូរ កាលត្រូវការបរិភោគរសជូរប្រៃទើបទៅដល់នគរពារាណសី នៅក្នុងរាជឧទ្យាននោះឯង ។ ស្អែកឡើងក៏ចូលទៅបិណ្ឌបាតក្នុងព្រះនគរ ។ ក្នុងកាលណោះ ពារាណសីសេដ្ឋី ជាអ្នកមានសទ្ធានិងសេចក្ដីជ្រះថ្លា ។ ព្រះពោធិសត្វសួរថា ផ្ទះរបស់ត្រកូលណាមានសទ្ធា បានដំណឹងថា ផ្ទះរបស់សេដ្ឋី ទើបទៅកាន់ទ្វារផ្ទះរបស់សេដ្ឋី ។ ខណៈនោះសេដ្ឋីទៅ

គាល់ព្រះរាជាហើយ ចំណែកមនុស្សទាំងឡាយក៏មិនឃើញព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វក៏បានត្រឡប់ទៅ ។ លំដាប់នោះ សេដ្ឋីនោះកំពុងចេញអំពីរាជត្រកូល បានឃើញព្រះពោធិសត្វនោះទើបថ្វាយបង្គំ ហើយទទួលយកភាជនភិក្ខានាំទៅកាន់ផ្ទះ និមន្តឲ្យគង់ ឲ្យផ្អែតស្អប់ស្អល់ដោយការលាងជើង ការលាបប្រេង បបរនិងរបស់ទំពាជាដើម ក្នុងរវាងភត្ត មិនសួរហេតុណាមួយ លុះព្រះពោធិសត្វធ្វើភត្តកិច្ចហើយ ទើបថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ហើយពោលថា បពិត្រលោកម្ចាស់ យាចកឬសមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ ឈ្មោះថាមកកាន់ទ្វារផ្ទះរបស់ខ្ញុំហើយ មិនធ្លាប់បានសក្ការៈ ការរាប់អានហើយទៅវិញទទេរមែងមិនមាន តែថ្ងៃនេះលោកម្ចាស់មិនបានទីអង្គុយ ទឹកផឹក ការលាងជើង ឬបបរនិងភត្ត ហើយចេញទៅ ព្រោះក្មេងៗរបស់ខ្ញុំមិនឃើញលោកម្ចាស់ នេះជាទោសរបស់ខ្ញុំ សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំ ហើយពោលគាថាទី ១ ថា

យើងខ្ញុំទាំងឡាយមិនបានប្រគេនតាំង មិនបានប្រគេនទឹក ទាំង
មិនបានប្រគេនភោជនាហារដល់លោក សូមលោកជាព្រហ្មចារី
អត់ទោសដល់ខ្ញុំ ខ្ញុំឃើញទោសនុ៎ះហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន តេ បីឋមទាយិម្ហា** សេចក្ដីថា ខ្ញុំមិនបានឲ្យសូម្បីតាំងដល់លោកម្ចាស់ ។ ព្រះពោធិសត្វស្ដាប់ពាក្យនោះ ទើបពោលគាថាទី ២ ថា

អាត្មាមិនជាប់ចំពាក់ផង មិនខឹងផង ទាំងវត្ថុតិចតួចដែលមិន

ជាទីស្រឡាញ់របស់អាត្មា ក៏មិនមានឡើយ មួយទៀត អាត្មា មានសេចក្តីត្រិះរិះក្នុងចិត្តថា ធម្មតានៃត្រកូល ប្រាកដដូច្នេះ ដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នេវាភិសជ្ជាមិ** សេចក្តីថា អាត្មាមិនបាន ជាប់ចំពាក់ឡើយ ។ បទថា **ឯតាទិសោ** សេចក្តីថា អាត្មាកើតនូវវិតក្កក្នុងចិត្ត យ៉ាងនេះថា ធម្មតារបស់ត្រកូលនេះ បែបនេះពិត គឺនឹងជាវង្សរបស់អ្នកមិន ឲ្យ ។ សេដ្ឋីបានស្តាប់ដូច្នេះ ក៏ពោលគាថា ២ ក្រៅនេះថា

យើងខ្ញុំ បានប្រគេនអាសនៈ ប្រគេនទឹក ប្រគេនប្រេង សម្រាប់លាងជើងទាំងអស់នេះ នេះជាធម្មតា របស់ឪពុកនិង ជីតាក្នុងត្រកូលរបស់យើងខ្ញុំសព្វៗកាល ។

យើងនឹងខ្ញុំបម្រើ ( សមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ល្អ ) ដូច ជាញាតិជាន់ខ្ពស់ដោយសេចក្តីគោរព នេះជាធម្មតា របស់ឪពុក និងជីតាក្នុងត្រកូលរបស់យើងខ្ញុំសព្វៗកាល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ** បានដល់ សភាវៈ ។ បទថា **បិតុ-បិតាមហោ** សេចក្តីថា ជារបស់មាននៃមាតាបិតានិងជីដូនជីតា ។ បទថា **ឧទកំ** បានដល់ ទឹកសម្រាប់លាងជើង ។ បទថា **មជ្ជំ** បានដល់ ប្រេង សម្រាប់លាបជើង ។ បទថា **សព្វេតំ** កាត់បទជា **សព្វំ ឯតំ** ។ **និ** អក្ខរៈ និង **ប** អក្ខរៈ ក្នុងបទថា **និបទាមសេ** នេះ ជាឧបសគ្គ អធិប្បាយថា ឲ្យ ។ លោកអធិប្បាយថា ខ្ញុំរមែងឲ្យ ។ ដោយបទថា **និបទាមសេ** នេះ លោក

សម្តែងសេចក្តីថា វង្សរបស់ខ្ញុំ ជាវង្សរបស់បុគ្គលអ្នកឲ្យបន្តគ្នាមកអស់ ៧ តំណ ។ បទថា **ឧត្តមំ វិយ ញាតកំ** សេចក្តីថា ខ្ញុំឃើញសមណៈឬព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌រមែងទំនុកបម្រុងដោយការគោរព គឺដោយដៃរបស់ខ្លួន ដូចទំនុកបម្រុងមាតានិងបិតាដូច្នោះ ។

ព្រះពោធិសត្វនៅក្នុងទីនោះ សម្តែងធម៌ដល់ពារាណសីសេដ្ឋី ពីរបីថ្ងៃ ហើយត្រឡប់ទៅកាន់ហិមវន្តប្បទេសវិញ បានធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ពារាណសីសេដ្ឋីក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ពីឋជាតក ចប់

# ថុសជាតក

[ ៦៥០ ] ( ព្រះរាជាទ្រង់ត្រាស់ថា ) កណ្តុរទាំងឡាយស្គាល់ច្បាស់នូវអង្កាម ស្គាល់ច្បាស់នូវអង្ករ កណ្តុរទាំងឡាយវៀរបង់នូវអង្កាម ស៊ីតែអង្ករ ។

[ ៦៥១ ] ការប្រឹក្សាគ្នាណាក្នុងព្រៃ ការខ្សឹបណាក្នុងស្រុក ទាំងការគិត ( ប្រុងប្រហារ ) ណា រឿងទាំងនេះអញដឹងច្បាស់ហើយ ។

[ ៦៥២ ] ឮថាទំនៀមស្វាជាឪពុក តែងយកធ្មេញទៅខាំផ្តាច់នូវអង្គជាតិរបស់កូនតូច ដែលកើតហើយ ។

[ ៦៥៣ ] អ្នកឯងលូនវារ ដូចជាពពែខ្វាក់ ក្នុងចម្ការស្ពៃ បុគ្គលណាដេកខាងក្រោមទីដេក អំពើរបស់បុគ្គលនោះ យើងដឹងច្បាស់ហើយ ។

**ចប់ ថុសជាតកទី ៨ ។**

## អដ្ឋកថា

## ថុសជាតក

[ ៦៥០-៦៥៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះបាទអជាតសត្តុ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វិទិតំ ថុសំ** ដូច្នេះជាដើម ។

បានឮថា កាលព្រះបាទអជាតសត្តុនោះ នៅក្នុងព្រះឧទររបស់ព្រះមាតា ព្រះមាតារបស់ទ្រង់ ជាព្រះរាជធីតារបស់ព្រះបាទ ( មហា ) កោសល កើតបាញ់ព្រះគភ៌ ចង់ផឹកព្រះលោហិតព្រះជានុខាងស្តាំ របស់ព្រះបាទពិម្ពិសារ

ដោយអាការៈខ្វាំងក្លា ។ ព្រះនាងត្រូវស្រីស្នំអ្នកបម្រើទូលសួរទើបប្រាប់សេចក្តីនោះដល់ស្នំទាំងនោះ ចំណែកព្រះរាជាទ្រង់បានស្តាប់ហើយ ត្រាស់ឲ្យហៅហោរាអ្នកទាយនិមិត្តមកត្រាស់សួរថា បានឮថា ព្រះទេវីទ្រង់កើតការចាញ់ផ្ទៃបែបនេះ ការសម្រេចរបស់ព្រះនាងដូចម្តេច ពួកហោរាអ្នកទាយនិមិត្តក្រាបទូលថា សត្វដែលកើតក្នុងព្រះឧទរ របស់ព្រះទេវីនឹងផ្តាច់ព្រះជន្មរបស់ព្រះអង្គហើយដណ្តើមរាជសម្បត្តិ ។ ព្រះរាជាត្រាស់ថា បើបុត្តរបស់យើងសម្លាប់យើងហើយដណ្តើមរាជសម្បត្តិ សេចក្តីនោះនឹងមានទោសដូចម្តេច ហើយទ្រង់ចូតព្រះជានុខាងស្តាំដោយកាំបិតដ៏មុត យកចានមាសត្រងព្រះលោហិត ហើយឲ្យដល់ព្រះទេវី ។ ព្រះទេវីទ្រង់ព្រះតម្រិះថា បើឱរសដែលកើតក្នុងព្រះឧទររបស់អញផ្តាច់ព្រះជន្មបិតាសោត ប្រយោជន៍អ្វីដោយព្រះឱរសនោះ ទើបព្រះនាងប្រចបាច់ផ្ទៃពោះដើម្បីឲ្យព្រះគភ៌ធ្លាក់ទៅ ។ ព្រះរាជាទ្រង់ជ្រាបទើបឲ្យហៅព្រះទេវីនោះមក ហើយត្រាស់ថា នែនាងដ៏ចម្រើន បានឮថា បុត្តរបស់យើងសម្លាប់យើងហើយដណ្តើមរាជសម្បត្តិ ឯយើងមិនចាស់ មិនស្លាប់ក៏មិនមែនចូរនាងឲ្យយើងឃើញមុខកូនចុះ តាំងអំពីនេះទៅ ចូរនាងកុំធ្វើកម្មបែបនេះ ។ ចាប់តាំងអំពីនោះ ព្រះទេវីយាងទៅព្រះរាជឧទ្យាន ហើយឲ្យប្រចបាច់ព្រះគភ៌ព្រះរាជាទ្រង់បានជ្រាប ទើបទ្រង់ហាមការយាងទៅព្រះរាជឧទ្យាន ចាប់តាំងអំពីកាលនោះព្រះទេវីមានព្រះគភ៌បរិបូណ៌ ហើយប្រសូតព្រះឱរស ។ ក្នុងថ្ងៃថ្វាយព្រះនាមព្រះឱរសនោះ បានថ្វាយព្រះនាមថា អជាតសត្តុកុមារ ព្រោះជាសត្រូវចំពោះបិតា តាំងអំពីមិនទាន់ប្រសូត ។ កាលអជាតសត្តុកុមារនោះ

ចម្រើនធំធាត់ដោយកុមារបរិហារ ។ ថ្ងៃមួយ ព្រះសាស្ដាចោមរោមដោយភិក្ខុ ៥០០ រូប យាងទៅកាន់ព្រះរាជនិវេសន៍របស់ព្រះរាជា ហើយគង់ ព្រះរាជាអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយរបស់ទំពា និងរបស់ឆាន់ដ៏ប្រណីត ទ្រង់នមស្ការហើយប្រថាប់គង់ស្ដាប់ធម៌ ។ ខណៈនោះ ភីលៀងបង្ហាញព្រះរាជកុមារ ហើយបានថ្វាយដល់ព្រះរាជា ព្រះរាជាទ្រង់ទទួលព្រះរាជឱរសដោយសេចក្ដីស្នេហាជាកម្លាំង ឲ្យអង្គុយលើភ្លៅ ទ្រង់ឱបក្រសោបចំពោះព្រះឱរសដោយសេចក្ដីស្រឡាញ់ក្នុងព្រះឱរសមិនបានស្ដាប់ធម៌ ។ ព្រះសាស្ដាទ្រង់ជ្រាបការប្រមាទរបស់ព្រះរាជា ទើបត្រាស់ថា មហាបពិត្រ ព្រះរាជាទាំងឡាយក្នុងកាលមុន រង្កៀសក្នុងព្រះឱរសទាំងឡាយ ធ្វើឲ្យនៅក្នុងទីដែលបិទបាំង ( ឃុំខាំង ) ហើយត្រាស់ទុកថា អំណឹះឥតអំពីយើងទៅហើយ អ្នកទាំងឡាយ ចូរនាំមកឲ្យនៅក្នុងរាជសម្បត្តិ ។ កាលព្រះរាជាទូលអារាធនាហើយទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វជាអាចារ្យទិសាបាមោក្ខ ក្នុងនគរតក្កសិលា បង្រៀនសិល្បសាស្ត្រពួករាជកុមារនិងព្រាហ្មណកុមារជាច្រើន ។ រាជឱរសរបស់ព្រះរាជាក្នុងនគរពារាណសី យាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះ ក្នុងកាលទ្រង់មានព្រះជន្មាយុ ១៦ វស្សារៀនចប់ត្រៃវេទ ចេះសិល្បសាស្ត្រគ្រប់យ៉ាង ជាអ្នកមានសិប្បៈគ្រប់បរិបូណ៌ហើយ ទើបត្រាស់លាអាចារ្យ ។ អាចារ្យមើលលក្ខណៈរាជកុមារនោះ ដោយវិជ្ជាមើលអវយវៈហើយគិតថា អន្តរាយព្រោះអាស្រ័យ

ព្រះឱរសនឹងប្រាកដដល់ព្រះរាជកុមារនេះ អញនឹងបញ្ចៀសអន្តរាយនោះដោយអានុភាពរបស់អញ ទើបចងគាថា ៤ ថ្វាយដល់ព្រះរាជកុមារ កាលឲ្យគាថាទើបបញ្ជាក់ព្រះរាជកុមារនោះថា នែបា បាតាំងនៅក្នុងរាជសម្បត្តិហើយ ក្នុងកាលឱរសរបស់បាមានអាយុ ១៦ ឆ្នាំ កាលសោយព្រះក្រយាហារ គប្បីពោលគាថាទី ១ ក្នុងពេលមានពិធីបម្រើធំគប្បីពោលគាថាទី ២ ក្នុងកាលឡើងជណ្តើរប្រាសាទ ឈរជាន់លើជណ្តើរខាងលើ គប្បីពោលគាថាទី ៣ ក្នុងកាលយាងចូលបន្ទប់ដ៏មានសិរី ប្រថាប់ឈរត្រង់ធរណីទ្វារ គប្បីពោលគាថាទី ៤ ។ ព្រះរាជកុមារនោះ ទទួលពាក្យហើយ ទើបថ្វាយបង្គំលាអាចារ្យទៅតាំងនៅក្នុងតំណែងឧបរាជ អំណឹះតតអំពីបិតាទៅក៏តាំងនៅក្នុងរាជសម្បត្តិ ។ ព្រះឱរសរបស់ទ្រង់ក្នុងកាលមានព្រះជន្ម ១៦ វស្សាបានឃើញសិរីសម្បត្តិរបស់ព្រះរាជាដែលយាងចេញដើម្បីប្រយោជន៍ដល់កិច្ច មានកីឡាក្នុងព្រះរាជឧទ្យានជាដើម មានបំណងនឹងផ្តាច់ព្រះជន្មបិតា ហើយដណ្តើមរាជសម្បត្តិទើបត្រាស់នឹងពួកអ្នកបម្រើរបស់ព្រះអង្គ ។ ពួកអ្នកបម្រើទាំងនោះនាំគ្នាទូលថា សាធុ ប្រយោជន៍អ្វីដោយភាពជាធំដែលបានក្នុងពេលចាស់ គួរផ្តាច់ព្រះជន្មព្រះរាជាចោល ដោយឧបាយឯណានីមួយ ហើយដណ្តើមរាជសម្បត្តិ ។ ព្រះរាជកុមារគិតថា អញនឹងឲ្យព្រះរាជបិតាសោយថ្នាំពិស សោយទិវង្គតកាលនឹងសោយព្រះក្រយាហារល្ងាចជាមួយព្រះបិតា ទើបកាន់ថ្នាំពិសប្រថាប់គង់ ។ កាលព្រះក្រយាហារក្នុងភាជនៈ មិនទាន់មានអ្នកណាប៉ះពាល់ ព្រះរាជាត្រាស់គាថាទី ១ ថា

កណ្តុរទាំងឡាយស្គាល់ច្បាស់នូវអង្កាម ស្គាល់ច្បាស់នូវអង្ករ
កណ្តុរទាំងឡាយ វៀរបង់នូវអង្កាម ស៊ីតែអង្ករ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិធិតំ** សេចក្តីថា ក្នុងទីងងឹត សូម្បីមានភ្លៀង អង្កាម ក៏ប្រាកដដោយភាពជាអង្កាម អង្ករក៏ប្រាកដដោយភាពជាអង្ករ ដល់កណ្តុរទាំងឡាយ ។ តែក្នុងទីនេះ លោកពោលដោយលិង្គវិបល្លាសថា **ថុសំ តណ្ឌុលំ** ដូច្នេះ ។ បទថា **ខាទរេ** សេចក្តីថា កណ្តុរទាំងឡាយ វៀរនូវអង្កាម ស៊ីតែអង្ករប៉ុណ្ណោះ ។ លោកពោលអធិប្បាយតទៅថា លំដាប់នោះ ព្រះរាជកុមារគិតថា សូម្បីក្នុងទីងងឹត អង្កាម ក៏ប្រាកដដោយភាពជាអង្កាម អង្ករប្រាកដដោយភាពជាអង្ករដល់កណ្តុរទាំងឡាយ ពួកកណ្តុរវៀរអង្កាម ស៊ីតែអង្ករយ៉ាងណាការដែលអញអង្គុយក្តាប់ថ្នាំពិសក៏ប្រាកដយ៉ាងនោះដូចគ្នា ។

ព្រះរាជកុមារត្រិះរិះថា បិតាអញដឹងហើយ ទើបខ្លាចមិនអាចដាក់ថ្នាំពិសក្នុងព្រះក្រយាហារ ក្រោកឡើងថ្វាយបង្គំព្រះរាជាហើយយាងទៅ ។ ព្រះរាជកុមារក៏ប្រាប់រឿងនោះដល់ពួកអ្នកបម្រើរបស់ទ្រង់ ហើយត្រាស់សួរថា ថ្ងៃនេះព្រះរាជបិតាយើងដឹងមុន ឥឡូវនេះ ពួកយើងនឹងផ្តាច់ព្រះជន្មទ្រង់ដូចម្តេច តាំងអំពីនោះពួកអ្នកបម្រើទាំងនោះ ពួនក្នុងព្រះរាជឧទ្យាន ប្រឹក្សាគ្នាដោយសម្ងាត់ សម្រេចថា មានឧបាយមួយទើបកំណត់ថា ក្នុងពេលដែលទ្រង់ទៅកាន់ទីបម្រើធំៗ ត្រូវសៀតដាវចូលទៅ ប្រថាប់ឈរក្នុងរវាងពួកអាមាត្យ លុះដឹងថាព្រះរាជាធ្វេសប្រហែស សឹមដកដាវផ្តាច់ព្រះជន្មរមែងគួរ ព្រះរាជកុមារទទួលថា សាធុ ស៊កដាវក្នុងស្រោម ហើយយាងទៅ រង់ចាំឱកាសប្រហារ

ព្រះរាជាដោយដាវនោះ ។ ខណៈនោះព្រះរាជាត្រាស់គាថាទី ២ ថា

ការប្រឹក្សាគ្នាណាក្នុងព្រៃ ការខ្សឹបណាក្នុងស្រុក ទាំងការគិត
( ប្រុងប្រហារ ) ណា រឿងទាំងនេះ អញដឹងច្បាស់ហើយ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អរញ្ញស្មឹ** បានដល់ ក្នុងព្រះរាជឧទ្យាន ។ បទថា **និកណ្ណិកា** បានដល់ ប្រឹក្សាគ្នាដោយខ្សឹបក្បែរៗត្រចៀក ។ បទថា **យញ្ចេតំ ឥតិ ចីតិ ច** បានដល់ ការស្វែងរកឱកាសសម្លាប់យើង ក្នុងកាលឥឡូវនេះក្ដី លោកពោលអធិប្បាយទុកថា ម្នាលរាជកុមារ ការដែលឯងខ្សឹបប្រឹក្សាគ្នាទាំងក្នុងឧទ្យាននិងក្នុងស្រុកនិងហេតុនៃការគិតថាត្រូវការសម្លាប់យើងក្នុងកាលឥឡូវនេះក្ដី យើងដឹងអស់ហើយ ។

ព្រះរាជកុមារគិតថា បិតាដឹងថាអញជាសត្រូវ ទើបគេចទៅ ប្រាប់ដល់អ្នកបម្រើ ធ្វើកាលវេលាឲ្យកន្លងផុត ៧-៨ ថ្ងៃ ទើបទូលថា បពិត្រព្រះរាជកុមារ បិតារមែងមិនដឹងថាទ្រង់ជាសត្រូវ ព្រះរាជាបានសម្គាល់យ៉ាងនោះព្រោះការគិតស្មាន សូមទ្រង់ផ្ដាច់ព្រះជន្មព្រះបិតានោះចុះ ។ ថ្ងៃមួយ ព្រះរាជកុមារនោះកាន់ដាវហើយបានឈរត្រង់ទ្វារបន្ទប់ក្បែរមាត់ជណ្ដើរ កាលណោះព្រះរាជាប្រថាប់ឈរត្រង់ក្បាលជណ្ដើរ ពោលគាថាទី ៣ ថា

ឮថាទំនៀមស្វាជាឪពុក តែងយកធ្មេញទៅខាំផ្ដាច់នូវអង្គជាតិ
របស់កូនតូច ដែលកើតហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មេន** បានដល់ តាមសភាវៈ ។ បទថា

**បិតា បុត្តស្ស មញ្ញជោ** បានដល់ ស្វាដែលជាបារបស់កូន ។ លោកពោលពាក្យអធិប្បាយនេះទុកថា ស្វាដែលកើតក្នុងព្រៃ រង្កៀសក្នុងការរក្សាហ្វូងរបស់ខ្លួន យកធ្មេញខាំផ្តាច់អង្គជាតិរបស់កូនស្វា ដែលជិតជំទង់ ធ្វើភាពឈ្មោលឲ្យវិនាសទៅយ៉ាងណា យើងនឹងដកពូជជាដើមរបស់ឯងដែលប្រាថ្នារាជសម្បត្តិ ធ្វើបុរសភាវៈឲ្យវិនាសទៅដូច្នោះ ។

ព្រះរាជកុមារគិតថា បិតាបំណងឲ្យចាប់អញ ទើបកិតភ័យខ្លាច ហើយគេចទៅ ប្រាប់ដល់អ្នកបម្រើថា បិតាទ្រង់គំរាមយើង មនុស្សទាំងនោះ លុះកន្លងទៅកន្លះខែទើបទូលថា បពិត្រព្រះរាជកុមារ បើព្រះរាជាគប្បីជ្រាបហេតុនោះទ្រង់មិនអត់ធន់ អស់កាលមានប្រមាណប៉ុណ្ណេះឡើយ ព្រះរាជាត្រាស់ដោយគិតស្មានប៉ុណ្ណោះ សូមទ្រង់ផ្តាច់ព្រះជន្មព្រះរាជានោះចុះ ។ ថ្ងៃមួយព្រះរាជកុមារនោះ កាន់ដាវយាងចូលទៅកាន់ព្រះសិរីសេយ្យាសនៈ ក្នុងប្រាសាទជាន់លើ ហើយដេកក្រោមបល្ល័ង្កដោយបំណងថា នឹងប្រហារព្រះបិតាដែលមកដល់ភ្លាម ។ ព្រះរាជាទ្រង់ សោយព្រះក្រយាហារល្ងាចហើយបញ្ជូនបរិវារត្រឡប់ទៅ ទ្រង់ត្រិះរិះថានឹងផ្ទំ ទើបយាងចូលទៅកាន់បន្ទប់សម្រាប់ផ្ទំដែលប្រកបដោយសិរី ប្រថាប់ឈរត្រង់ធរណីទ្វារ ហើយត្រាស់គាថាទី ៤ ថា

អ្នកឯងលូនវារ ដូចជាពពែខ្វាក់ក្នុងចម្ការស្ពៃ បុគ្គលណាដេក
ខាងក្រោមទីដេក អំពើរបស់បុគ្គលនោះយើងដឹងច្បាស់ហើយ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិសប្បសិ** បានដល់ បាននៅក្នុងទីនោះ

ក្នុងទីនេះព្រោះខ្លាច ។ បទថា **សាសបេ** បានដល់ ក្នុងចង្ការស្ពៃ ។ បទថា **យោធាយំ** កាត់បទជា **យោធិ អយំ** លោកពោលអធិប្បាយទុកថា ឯងលួនវារទៅខាងនោះខាងនេះ ព្រោះការភ័យខ្លាច ដូចពពែខ្វាក់ ចូលទៅកាន់ចង្ការស្ពៃ គឺលើកទី ១ ឯងកាន់ថ្នាំពិសមក លើកទី ២ បំណងប្រហារដោយដាវទើបមក លើកទី ៣ បានកាន់ព្រះខ័នមកឈរត្រង់ក្បាលដំណេក ឥឡូវនេះឯងគិតថានឹងសម្លាប់យើង ដូច្នេះហើយ ទើបមកដេកក្រោមដំណេក រឿងទាំងអស់នោះយើងដឹង ឥឡូវនេះមិនលះបង់ឯង នឹងចាប់ដាក់រាជអាជ្ញា ព្រះរាជានោះ ទោះបីទ្រង់មិនជ្រាបយ៉ាងនោះ តែគាថានោះៗ ក៏ធ្លុះបញ្ចាំងសេចក្តីនោះៗ ។

ព្រះរាជកុមារគិតថា ព្រះបិតាទ្រង់ជ្រាបអញហើយ ឥឡូវនេះ ទ្រង់នឹងធ្វើអញឲ្យវិនាស ទើបតក់ស្លុតកិតភ័យ ចេញមកពីក្រោមទីបន្ទំ បោះព្រះខ័នក្នុងទីទៀបព្រះបាទាព្រះរាជានោះឯង ក្រាបចុះទៀបបាទមូល ក្រាបទូលសូមខមាទោសថា បពិត្រព្រះសម្មតិទេព សូមព្រះបិតាអត់នូវទោសដល់ទូលបង្គំចុះ ព្រះរាជាទ្រង់សម្លុតព្រះកុមារនោះថា ឯងគិតថា អ្នកណាៗ មិនដឹងនូវការធ្វើរបស់ឯង ហើយត្រាស់ឲ្យចងដោយគ្រឿងចង គឺច្រវាក់ហើយបញ្ជូនទៅកាន់ទីឃុំខាំងរក្សាទុក ។ ក្នុងកាលណោះ ព្រះរាជារឭកបាន ដល់គុណរបស់ព្រះពោធិសត្វ តមកព្រះរាជានោះទ្រង់សោយទិវង្គត ពួកសេវកាមាត្យបានធ្វើពិធីថ្វាយព្រះភ្លើងរបស់ទ្រង់ ហើយទើបនាំ ព្រះរាជកុមារ ចេញអំពីទីឃុំខាំង ឲ្យតាំងនៅក្នុងរាជសម្បត្តិ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ត្រាស់ហេតុនេះថា មហាបពិត្រ ព្រះរាជាក្នុងកាលមុនទ្រង់វៀរហេតុដែលគួរវៀរយ៉ាងនេះ សូម្បីព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះរាជាក៏ទ្រង់កំណត់មិនបាន ។ ព្រះសាស្តាទ្រង់ប្រជុំជាតកថា អាចារ្យទិសាបាមោក្ខក្នុងនគរតក្កសិលាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ថុសជាតក ចប់

## ពាវេរុជាតក

[ ៦៥៤ ] ( ព្រះសាស្តាត្រាស់ថា ) ជនទាំងឡាយបានយកសាច់នឹងផ្លែឈើ បូជាក្អែកក្នុងដែននោះ ព្រោះមិនទាន់ឃើញសត្វក្ងោក ជាសត្វមានសិរី មានសំឡេងពីរោះ ។

[ ៦៥៥ ] ក្ងោកជាសត្វបរិបូណ៌ដោយសំឡេងពីរោះ បានមកដល់ដែនពាវេរុ ក្នុងកាលណា លាភនិងសក្ការៈរបស់ក្អែកក៏សាបសូន្យក្នុងកាលនោះ ។

[ ៦៥៦ ] ព្រះពុទ្ធជាធម្មរាជទ្រង់ធ្វើនូវពន្លឺ មិនទាន់កើតឡើងដរាបណា ពួកជនឯទៀត បានបូជាសមណព្រាហ្មណ៍ដ៏ច្រើនដរាបនោះ ។

[ ៦៥៧ ] ព្រះពុទ្ធព្រះអង្គបរិបូណ៌ដោយសំឡេង បានសម្តែងនូវព្រះធម៌ ក្នុងកាលណា លាភនិងសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏សាបសូន្យអស់ក្នុងកាលនោះ ។

**ចប់ ពាវេរុជាតកទី ៩ ។**

## អដ្ឋកថា

## ពាវេរុជាតក

[ ៦៥៤-៦៥៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធតិរ្ថិយទាំងឡាយ ដែលវិនាសសាបសូន្យលាភសក្ការៈ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អទស្សនេន មោរស្ស** ដូច្នេះ ជាដើម ។

បានឮថា ពួកតិរ្ថិយទាំងឡាយ កាលព្រះពុទ្ធមិនទាន់កើតឡើង ជាអ្នកមាន

លាភច្រើន តែកាលព្រះពុទ្ធកើតឡើងហើយ ជាអ្នកសាបសូន្យលាភសក្ការៈ ដូចជាអំពិលអំពែកក្នុងកាលដែលព្រះអាទិត្យរះឡើងដូច្នោះ ។ ភិក្ខុទាំងឡាយប្រារព្ធរឿងនោះរបស់តិរ្ថិយទាំងនោះ ទើបប្រជុំសន្ទនាគ្នាក្នុងធម្មសភា ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ពួកបុគ្គលអ្នកឥតគុណ បានដល់នូវភាពប្រសើរដោយលាភ និងយសដរាបណាដែលអ្នកមានគុណមិនទាន់កើតឡើង កាលបុគ្គលប្រកបដោយគុណទាំងឡាយ កើតឡើងហើយ ពួកបុគ្គលដែលមិនមានគុណ ក៏ត្រូវសាបសូន្យលាភសក្ការៈទៅ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ យោនយកកំណើតជាសត្វក្ងោក អាស្រ័យនូវការចម្រើនធំធាត់ ដល់នូវភាពជាសត្វប្រសើរដោយលម្អ ត្រាច់ទៅក្នុងព្រៃ ។ ក្នុងកាលណោះ ឈ្មួញមួយពួកនាំក្អែកសម្រាប់ប្រាប់ទិស ទៅកាន់ពាវេរុរដ្ឋដោយផ្លូវទឹក បានឮថាក្នុងកាលនោះ ឈ្មោះថាបក្សីទាំងឡាយរមែងមិនមានក្នុងពាវេរុរដ្ឋ ។ ពួកអ្នកដែនដើរធ្វេងទៅធ្វេងមកឃើញក្អែកនោះដែលទំក្នុងទ្រុង ទើបសរសើរក្អែកនោះឯងថា ចូរមើលពណ៌សម្បុររបស់បក្សីនេះ ចំពុះសមនឹងដងក ក្អែកដូចដុំកែវមណី ហើយពោលនឹងឈ្មួញទាំងនោះថា នែអ្នក សូមអ្នកឲ្យនូវបក្សី

នេះដល់ពួកយើង ពួកយើង ក៏មានសេចក្ដីត្រូវការដោយបក្សីនេះ អ្នកទាំងឡាយនឹងបានបក្សីដទៃក្នុងដែនរបស់ខ្លួន ពួកឈ្មួញពោលថា បើយ៉ាងនោះ ពួកអ្នកទាំងឡាយ ចូរកាន់យកដោយតម្លៃ ។ អ្នកដែនពាវេរុរដ្ឋពោលថា ពួកអ្នកចូរកាន់យកកហាបណៈ ហើយឲ្យបក្សីនេះដល់យើង ពួកឈ្មួញប្រាប់ថា មិនបាន កាលពួកអ្នកពាវេរុរដ្ឋបន្ថែមតម្លៃឡើងដោយលំដាប់ ពោលថា សូមលក់ឲ្យខ្ញុំក្នុងតម្លៃមួយរយចុះ ពួកឈ្មួញក៏ពោលថា បក្សីនេះមានឧបការៈច្រើនដល់ពួកយើង តែដោយមេត្រីភាពជាមួយពួកអ្នក ទើបកាន់យកកហាបណៈមួយរយ ហើយឲ្យបក្សីទៅ ។ ពួកអ្នកពាវេរុរដ្ឋទាំងនោះ នាំក្អែកនោះទៅដាក់ក្នុងទ្រុងមាស ប្រណិប័តន៍ដោយត្រី សាច់និងផ្លែឈើតូចធំ មានប្រការផ្សេង ៗ ។ ក្នុងទីដែលមិនមានបក្សីដទៃ ៗ ក្អែកដែលប្រកបដោយអសទ្ធម្ម ១០ ប្រការ បានជាសត្វដែលប្រសើរដោយលាភសក្ការៈ ។ គ្រាមួយ ឈ្មួញទាំងនោះ ចាប់ស្ដេចក្ងោកបានមួយ បង្ហាត់ឲ្យយំដោយការផ្ទាត់ម្រាមដៃ ឲ្យរាំដោយការទះដៃ ឲ្យសិក្សាហើយ បាននាំទៅកាន់ពាវេរុរដ្ឋ ។ ស្ដេចក្ងោកនោះ កាលមហាជនប្រជុំគ្នា ទើបឈរត្រង់ក្បាលទូក បើកស្លាបបន្លឺសំឡេងដ៏ពីរោះហើយរាំ ។ មនុស្សទាំងឡាយឃើញដូច្នោះកើតនូវសោមនស្សពោលថា នែអ្នកអ្នកទាំងឡាយចូរឲ្យស្ដេចក្ងោកនេះ ដែលដល់ព្រមដោយលម្អដ៏លើស ដែលបង្ហឹកមកល្អហើយដល់ពួកខ្ញុំចុះ ពួកឈ្មួញឆ្លើយថា ដំបូងពួកយើងនាំក្អែកមក អ្នកទាំងឡាយក៏យកក្អែកនោះទៅ ឥឡូវនេះយើងនាំស្ដេចក្ងោកមក ក៏សូមស្ដេចក្ងោកនេះទៀត ឈ្មោះថាបក្សីក្នុងដែនរបស់អ្នក

ទាំងឡាយ ពួកយើងមិនអាចចាប់យកមក ។ អ្នកពាវេរុរដ្ឋពោលថា ណ្ហើយចុះ អ្នកទាំងឡាយនឹងបានបក្សីដទៃក្នុងដែនរបស់ខ្លួន ចូរឲ្យក្អែកនេះដល់ពួកយើងចុះ ហើយប្រមូលតម្លៃទិញយកដោយឲ្យទ្រព្យមួយពាន់ ។ ពេលនោះ អ្នកពាវេរុរដ្ឋ ក៏ឲ្យក្អែកនោះនៅក្នុងទ្រុងដែលវិចិត្រដោយរតនៈ ៧ ប្រការ ប្រណិប័តន៍ដោយត្រី សាច់ ផ្លែឈើតូចធំនិងលាជលាយដោយទឹកឃ្មុំ ឲ្យផឹកទឹកដែលលាយដោយស្ករ ស្តេចក្អែកដល់នូវភាពប្រសើរដោយលាភនិងយសៗ ចាប់តាំងពីកាលស្តេចក្អែកនោះមកហើយ លាភនិងសក្ការៈរបស់ក្អែក ក៏សាបសូន្យទៅ បុគ្គលណាមួយក៏មិនប្រាថ្នានឹងមើលក្អែក ។ ក្អែកកាលមិនបានខាទនីយ ភោជនីយាហារ ទើបស្រែកថា ខ្វក ខ្វក ហើរទៅត្រង់គំនរសំរាម ។

ព្រះសាស្តាកាលទ្រង់បន្តរឿងទាំងពីរជាប់គ្នាហើយ ទ្រង់ត្រាស់ដឹងឯងបានត្រាស់គាថាទាំងនេះថា

ជនទាំងឡាយបានយកសាច់នឹងផ្លែឈើ បូជាក្អែកក្នុងដែននោះ ព្រោះមិនទាន់ឃើញសត្វក្ងោក ជាសត្វមានសិរ្ស មានសំឡេងពីរោះ ។

ក្ងោកជាសត្វបរិបូណ៌ ដោយសំឡេងពីរោះ បានមកដល់ដែនពាវេរុក្នុងកាលណា លាភនិងសក្ការៈរបស់ក្អែក ក៏សាបសូន្យក្នុងកាលនោះ ។

ព្រះពុទ្ធជាធម្មរាជ ទ្រង់ធ្វើនូវពន្លឺ មិនទាន់កើតឡើងដរាបណា ពួកជនឯទៀត បានបូជាសមណព្រាហ្មណ៍ដ៏ច្រើនដរាប

នោះ ។

ព្រះពុទ្ធព្រះអង្គបរិបូណ៌ដោយសំឡេង បានសម្ដែងនូវព្រះធម៌ក្នុងកាលណា លោកនិងសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏សាបសូន្យអស់ក្នុងកាលនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សិខិនោ** បានដល់ ប្រកបដោយសិរ្ស ។ បទថា **មញ្ជុភាណកោ** បានដល់ ជាអ្នកមានសំឡេងពីរោះ ។ បទថា **អបូជេសុំ** ប្រែថា បានបូជាហើយ ។ បទថា **ផលេន ច** បានដល់ ផ្លែឈើតូចធំមានប្រការផ្សេងៗ ។ បទថា **ពាវេរុមាគមា** ប្រែថា មកកាន់ពាវេរុរដ្ឋ បាលីថា **ភាវេរុ** ដូច្នេះក៏មាន ។ បទថា **អហាយថ** បានដល់ វិនាសទៅហើយ ។ បទថា **ធម្មរាជា** សេចក្ដីថា ឈ្មោះថា ធម្មរាជា ព្រោះញុំាងបរិស័ទឲ្យត្រេកអរដោយលោកុត្តរធម៌ ៩ ។ បទថា **បភង្ករោ** សេចក្ដីថា ឈ្មោះថាជាធ្វើនូវពន្លឺ ព្រោះបញ្ចេញពន្លឺទៅក្នុងសត្វលោក ឱកាសលោក និងសង្ខារលោក ។ បទថា **សរសម្បន្នោ** បានដល់ ដែលប្រកបដោយសំឡេងដូចសំឡេងព្រហ្ម ។ បទថា **ធម្មំ អទេសយិ** បានដល់ ទ្រង់ប្រកាសសច្ចធម៌ទាំង ៤ ។

ព្រះសាស្ដាកាលត្រាស់គាថា ៤ នេះដោយប្រការដូច្នេះហើយ ទើបទ្រង់ប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានមកជានិគន្ថនាដបុត្តក្នុងកាលឥឡូវនេះ ស្ដេចក្ងោកក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ពាវេរុជាតក ចប់**

# វិសយ្ហជាតក

[ ៦៥៨ ] ( សក្កទេវរាជត្រាស់ថា ) នែវិសយ្ហសេដ្ឋី ក្នុងកាលមុនអ្នក បានឲ្យទានទាំងឡាយហើយ កាលអ្នកចេះតែឲ្យ សភាវៈអស់ទៅនៃភោគៈ ទាំងឡាយ បានកើតមានហើយ ខាងមុខអំពីនេះទៅ បើអ្នកមិនឲ្យទានទេ ភោគសម្បត្តិទាំងឡាយរបស់អ្នកដែលឈប់ឲ្យ ទើបគង់នៅ ។

[ ៦៥៩ ] ( វិសយ្ហសេដ្ឋីពោលថា ) នែសហស្សនេត្ត ព្រះអរិយៈ ទាំងឡាយ បានពោលថា អំពើដ៏លាមក អរិយជនសូម្បីជាអ្នកកម្សត់ ក៏មិន គប្បីធ្វើដែរ នែជនិន្ទ្រ យើងលះបង់ហើយនូវសេចក្តីជឿក្នុងទាន ព្រោះហេតុ តែទ្រព្យណា ទ្រព្យនោះពុំមានដល់យើងឡើយ ។

[ ៦៦០ ] រថមួយបរទៅតាមផ្លូវណា រថឯទៀតក៏បរទៅតាមផ្លូវនោះដែរ នែវាសវៈ កិច្ចវត្តដែលយើងបំពេញមកក្នុងកាលមុន ចូរប្រព្រឹត្តទៅចុះ ។

[ ៦៦១ ] បើទ្រព្យមាន យើងនឹងឲ្យបាយ កាលបើទ្រព្យមិនមាន យើងនឹងឲ្យដូចម្តេចកើត ថ្វីបើយើងជាអ្នក ( ប្រូតស្មៅលក់ ) យើងនៅតែ ឲ្យទាន យើងមិនប្រហែសក្នុងទានទេ ។

**ចប់ វិសយ្ហជាតកទី ១០ ។**

**ចប់ កោកិលវគ្គទី ៤ ។**

### ឧទ្ទាននៃកោកិលវគ្គនោះគឺ

និយាយអំពីបុគ្គលនិយាយហួសប្រមាណ ១ បុគ្គលផ្ចាញ់ខ្លួន
ឯង ១ ព្រះរាជាប្រសើរក្នុងរថកណ្តាលព្រៃ ១ គោដើររៀច

១ ឆ្កែចចក ១ ស្ដេចត្រាស់ថាស្មៅ ១ ជើងតាំងជាអាសនៈដ៏ប្រសើរ ១ អង្ករ ១ សត្វក្ងោក ១ វិសយ្ហសេដ្ឋី ១ ត្រូវជា ១០ ។

# អដ្ឋកថា

# វិសយ្ហជាតក

[ ៦៥៨-៦៦១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អទាសិ ទានានិ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន បានឲ្យពិស្តារហើយក្នុងខទិរង្គារជាតក ខាងដើមនោះឯង ចំណែកក្នុងជាតកនេះ ព្រះសាស្តា ត្រាស់ហៅអនាថបិណ្ឌិកសេដ្ឋីមកហើយ ត្រាស់ថា ម្នាលគហបតី បុរាណកបណ្ឌិតទាំងឡាយ ឃាត់សក្កទេវរាជដែលប្រថាប់ឈរក្នុងអាកាស ដែលឃាត់ថា អ្នកកុំឲ្យទាន ក៏នៅតែឲ្យទានដូចមុននោះឯង កាលអនាថបិណ្ឌិកសេដ្ឋីនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ បានជាសេដ្ឋីឈ្មោះវិសយ្ហ មានទ្រព្យសម្បត្តិ ៨០ កោដិ ជាអ្នកប្រកបដោយសីល ៥ មានអធ្យាស្រ័យក្នុងទាន ត្រេកអរក្រៃលែងក្នុងទាន ។ ព្រះពោធិសត្វនោះ ឲ្យសាងសាលាទានក្នុងទី ៦ កន្លែង គឺត្រង់ទ្វារនគរទាំង ៤ កណ្តាលព្រះនគរ ១ ត្រង់ទ្វារនិវេសន៍របស់ខ្លួន ១ ហើយញ៉ាំងការឲ្យទានឲ្យប្រព្រឹត្តទៅ បរិច្ចាគទ្រព្យមួយថ្ងៃ ៦ សែនរាល់ថ្ងៃ ។ ព្រះពោធិសត្វនិងវនិព្វកៈទាំងឡាយ រមែងមានភត្តាហារដូចគ្នា ។ កាលព្រះពោធិសត្វនោះឲ្យទាន ធ្វើជម្ពូទ្វីបទាំងមូល ឲ្យមាននង្គ័លលើកឡើងហើយ ( មិនចាំបាច់ឲ្យភ្ជួរស្រែ ) ភពរបស់សក្កទេវរាជ ក៏កម្រើកញាប់ញ័រដោយ

អានុភាពនៃការឲ្យទានបណ្ដុកម្ពលសិលាអាសនៈរបស់សក្កទេវរាជ សម្ដែងអាការៈក្ដៅ ។ សក្កទេវរាជទ្រង់ព្រះតម្រិះថា អ្នកណាហ្ន៎ បំណាងនឹងឲ្យអញឃ្លាតចាកទី ទ្រង់ក៏ពិចារណា ទ្រង់ឃើញមហាសេដ្ឋីទើបព្រះតម្រិះថា វិសយ្ហសេដ្ឋីនេះ ផ្សាយទៅទូលំទូលាយពន់ពេក ឲ្យទាន ធ្វើជម្ពូទ្វីបទាំងមូលឲ្យមានន័ង្គលលើកឡើងហើយ ប្រហែលជាឲ្យអញឃ្លាតចាកទី ហើយធ្វើជាសក្កៈខ្លួនឯងដោយទាននេះ អញនឹងធ្វើទ្រព្យរបស់សេដ្ឋីនេះឲ្យវិនាស ធ្វើគេឲ្យជាមនុស្សក្រីក្រកុំឲ្យទានបាន ទើបបណ្ដាលទ្រព្យទាំងពួង តាំងអំពីស្រូវ ប្រេងទឹកឃ្មុំនិងស្ករអំពៅជាដើម ដោយហោចសូម្បីតែទាសៈនិងកម្មករឲ្យអន្តរធានទៅ ។ ពួកអ្នកចាត់ចែងទានមកប្រាប់លោកសេដ្ឋីថា បពិត្រលោកម្ចាស់ រោងទានបាត់ទៅ ពួកខ្ញុំមិនឃើញអ្វីមួយក្នុងទីដែលរក្សាទុក ។ លោកសេដ្ឋីពោលថា ចូរអ្នកនាំទ្រព្យសម្រាប់ចាយអំពីទីនេះ កុំផ្ដាច់ទានចោលឡើយ ហើយហៅភរិយាមកពោលថា នែនាង ចូរនាងឲ្យទានប្រព្រឹត្តទៅ ។ ភរិយានោះរកមើលពេញផ្ទះមិនឃើញសូម្បីត្រឹមតែកន្ទះមាសកៈ ទើបពោលថា បពិត្រអ្នក ខ្ញុំមិនឃើញមានអ្វីដទៃ វៀរលែងតែសំពត់ដែលយើងទាំងឡាយស្លៀកដណ្ដប់ក្នុងផ្ទះទទេទាំងអស់ ។ សេដ្ឋីឲ្យបើកទ្វារបន្ទប់ដែលដាក់រតនៈ ៧ ប្រការ ក៏មិនឃើញមានអ្វី សូម្បីទាសៈនិងកម្មករដទៃៗ ក៏មិនប្រាកដ វៀរលែងតែសេដ្ឋីនិងភរិយា ។ មហាសត្វហៅភរិយាមកទៀតហើយពោលថា នែនាង យើងមិនអាចកាត់ផ្ដាច់នូវការឲ្យទាន ចូរនាងរកឲ្យសព្វក្នុងនិវេសន៍ ពិចារណាមើលរបស់ណាមួយ ។ ខណៈនោះ អ្នករែកស្មៅម្នាក់ចោល កណ្ដៀវ ដងរែក

និងខ្សែចងស្មៅ ទុកក្នុងរោងទ្វារហើយចៀសចេញទៅ ។ ភរិយារបស់សេដ្ឋី ឃើញដូច្នោះទើបនាំមកឲ្យ ដោយពោលថា បពិត្រអ្នក វៀរតែរបស់នេះ ខ្ញុំមិនឃើញរបស់ដទៃឡើយ ។ ព្រះមហាសត្វពោលថា នែនាង ជម្មតាស្មៅ យើងមិនធ្លាប់ប្រមូលអស់កាលមានប្រមាណប៉ុណ្ណោះ តែថ្ងៃនេះ យើងនឹងប្រមូលស្មៅនាំមកលក់ ហើយឲ្យទានតាមសមគួរ ព្រោះខ្វាចដាច់ក្នុងការឲ្យទានទើបកាន់យកកណ្តៀវ ជងរែកនិងខ្សែ ចេញអំពីព្រះនគរទៅកាន់ទីមានស្មៅហើយប្រមូលស្មៅគិតថា ស្មៅមួយបាច់ជារបស់ពួកយើង នឹងឲ្យទានដោយស្មៅមួយបាច់ ទើបចងស្មៅពីរបាច់ ស៊កត្រង់ជងរែក រែកយកទៅលក់ត្រង់ទ្វារក្រុង បានមាសកៈមកហើយ បានឲ្យចំណែកមួយដល់យាចក តែពួកយាចកមានច្រើនគ្នា កាលពួកគេសូមថា ឲ្យខ្ញុំផង ទើបឲ្យចំណែកក្រៅអំពីនេះទៅទៀត ថ្ងៃនោះទើបមិនមានអាហារ មួយអន្លើដោយភរិយា ឲ្យពេលវេលាកន្លងទៅដោយទំនងនេះអស់ ៦ ថ្ងៃ ។ ថ្ងៃទី ៧ កាលសេដ្ឋីនោះកំពុងនាំស្មៅមក ជាអ្នកអត់អាហារ ៧ ថ្ងៃហើយ សេដ្ឋីជាសុខមាលជាតិ កាលពន្លឺព្រះអាទិត្យចាំងចំថ្ងាស ភ្នែកទាំងសងខាងក៏ស្រវាំង សេដ្ឋីមិនអាចតម្កល់សតិបាន ទើបដួលសន្លត់លើស្មៅ ។ សក្កទេវរាជបានត្រាច់មើលកិរិយាអាការៈរបស់សេដ្ឋីនោះ ។ រំពេចនោះ ទ្រង់មកប្រថាប់ឈរលើអាកាស ត្រាស់គាថាទី ១ ថា

នែ វិសយ្ហសេដ្ឋី ក្នុងកាលមុនអ្នកបានឲ្យទានទាំងឡាយហើយ
កាលអ្នកចេះតែឲ្យ សភាវៈអស់ទៅនៃភោគៈទាំងឡាយ បាន
កើតមានហើយ ខាងមុខអំពីនេះទៅ បើអ្នកមិនឲ្យទានទេភោគ

សម្បត្តិទាំងឡាយរបស់អ្នកដែលឈប់ឲ្យទើបគង់នៅ ដូច្នេះ ។

អធិប្បាយពាក្យដែលជាគាថានោះថា វិសយ្ហដ៏ចម្រើន កាលមុនអំពីនេះ កាលទ្រព្យក្នុងផ្ទះរបស់អ្នកនៅមាន អ្នកបានឲ្យទាន ធ្វើសកលជម្ពូទ្វីបឲ្យមាននន្ទ័លលើកឡើងហើយ បើអ្នកឲ្យទានយ៉ាងនេះ ធម៌គឺការខូចខាត បានដល់ភាវៈ គឺការវិនាសភោគៈនឹងមានឡើង គឺទ្រព្យទាំងមូលនឹងអស់ទៅ ខាងមុខអំពីនេះ អ្នកមិនឲ្យទានសោត គឺមិនឲ្យអ្វីដល់បុគ្គលណា កាលបើអ្នកសំចៃ គឺមិនឲ្យ ភោគៈទាំងឡាយគប្បីតាំងនៅដូចដើម ចូរអ្នកប្ដេជ្ញាថា តាំងអំពីនេះទៅនឹងមិនឲ្យទាន យើងនឹងឲ្យភោគៈទាំងឡាយដល់អ្នក ។

ព្រះមហាសត្វបានស្ដាប់ព្រះតម្រាស់របស់សក្កៈនោះហើយ ទើបសួរថា លោកជាអ្នកណា សក្កទេវរាជត្រាស់ថា យើងជាសក្កៈ ។ ព្រះមហាសត្វបានពោលថា ធម្មតាសក្កៈខ្លួនលោកក៏ឲ្យទាន សមាទានសីល រក្សាឧបោសថបំពេញវត្តបទ ៧ ប្រការ ទើបបានជាសក្កទេវរាជ តែទ្រង់ឃាត់ការឲ្យទានដែលជាហេតុនៃភាពជាធំ របស់ទ្រង់ខ្លួនឯង ទ្រង់ធ្វើចរិយាវត្តដែលមិនមែនរបស់អរិយជន ហើយបានពោលគាថា ៣ ថា

នៃសហស្សនេត្តព្រះអរិយៈទាំងឡាយបានពោលថា អំពើដ៏លាមក អរិយជនសូម្បីជាអ្នកកម្សត់ ក៏មិនគប្បីធ្វើដែរ នៃជនិន្ទ្រ យើងលះបង់ហើយនូវសេចក្ដីជឿក្នុងទាន ព្រោះហេតុតែទ្រព្យណា ទ្រព្យនោះពុំមានដល់យើងឡើយ ។

រថមួយបរទៅតាមផ្លូវណា រថឯទៀតក៏បរទៅតាមផ្លូវនោះ

ដែរ នៃវាសវៈ កិច្ចវត្តដែលយើងបំពេញមកក្នុងកាលមុន ចូរប្រព្រឹត្តទៅចុះ ។

បើទ្រព្យមាន យើងនឹងឲ្យបាយ កាលបើទ្រព្យមិនមាន
យើងនឹងឲ្យដូចម្តេចកើត ថ្វីបើយើងជាអ្នក ( ប្រូតស្មៅលក់ )
យើងនៅតែឲ្យទាន យើងមិនប្រហែសក្នុងទានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនរិយំ** បានដល់ បាបកម្មដ៏លាមក ។ បទថា **អរិយេន** បានដល់ អរិយជន មានអាចារបរិសុទ្ធ ។ បទថា **សុទុគ្គតេនាបិ** បានដល់ ដល់នូវភាពក្រីក្រ ។ បទថា **អកិច្ចមាហុ** សេចក្តីថា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមពោលទុកថា មិនគប្បីធ្វើទេ អធិប្បាយថា ទ្រង់ត្រាស់ប្រាប់ផ្លូវ ដែលមិនប្រសើរដល់ខ្ញុំ ។ សព្ទថា **វោ** ត្រឹមតែជានិបាត ។ ដោយបទថា **យំ ភោគហេតុ** នេះ លោកសម្តែងសេចក្តីថា ខ្ញុំលះបង់នូវសទ្ធាក្នុងការឲ្យទាន ព្រោះការបរិភោគទ្រព្យណាជាហេតុ ទ្រព្យនោះឯងកុំបីមាន គឺយើងមិនត្រូវការទ្រព្យនោះ ។ បទថា **រថោ** បានដល់ យានឯណាមួយ ។ លោក អធិប្បាយថា រថមួយគ្រៀងស្ទុះទៅផ្លូវណាសូម្បីរថដទៃក៏ស្ទុះទៅដោយផ្លូវនោះ ដោយយល់ថា នេះជាផ្លូវរបស់រថ ។ បទថា **បោរាណំ និហតំ វត្តំ** សេចក្តីថា វត្តដែលយើងធ្លាប់បំពេញមកក្នុងកាលមុននោះឯង កាលយើងនៅមានជីវិត ចូរប្រព្រឹត្តទៅចុះ គឺកុំឈប់ឡើយ ។ បទថា **ឃរំ ភុញ្ជាបិ** សេចក្តីថា ខ្ញុំទោះជាអ្នករែកស្មៅយ៉ាងនេះ ក៏នៅតែឲ្យទានដរាបណានៅមានជីវិត ព្រោះហេតុអ្វី ព្រោះខ្ញុំមិនប្រមាណក្នុងការឲ្យទាន ។

លោកសម្តែងសេចក្តីថា ព្រោះបុគ្គលមិនឲ្យរមែងឈ្មោះថាប្រមាណ គឺមិនរឭកដល់ មិនកំណត់ដល់ការឲ្យទាន ចំណែកខ្ញុំកាលជីវិតនៅមានរមែងមិនប្រាថ្នាបំភ្លេចក្នុងការឲ្យទាន ព្រោះដូច្នោះខ្ញុំនឹងឲ្យទានដូចដើម ។

សក្កទេវរាជកាលមិនអាចឃាត់វិសយ្ហសេដ្ឋីនោះ ទើបត្រាស់សួរថា អ្នកឲ្យទានដើម្បីប្រយោជន៍អ្វី វិសយ្ហសេដ្ឋីទូលថា ខ្ញុំមិនបានប្រាថ្នាភាពជាសក្កៈ ឬភាពជាព្រហ្ម តែខ្ញុំប្រាថ្នាភាពជាសព្វញ្ញុតញ្ញាណទើបឲ្យទាន ។ សក្កទេវរាជបានស្តាប់ពាក្យរបស់វិសយ្ហនោះហើយ សប្បាយព្រះហឫទ័យ យកព្រះហស្តស្ទាបខ្នង ។ កាលព្រះពោធិសត្វ ត្រូវសក្កៈស្ទាបខ្នង ខណៈនោះឯងសរីរៈទាំងមូល ក៏ពេញបរិបូណ៌ និងដោយអានុភាពរបស់សក្កៈ កំណត់ដែនទ្រព្យសម្បត្តិទាំងអស់របស់ព្រះពោធិសត្វនោះ ក៏ត្រឡប់ទៅតាមប្រក្រតីដូចដើម ។ សក្កៈត្រាស់ថា លោកសេដ្ឋី ចាប់តាំងអំពីនេះទៅ សូមលោកលះទ្រព្យ ១២ សែន ឲ្យទានរាល់ថ្ងៃចុះ ហើយប្រទានទ្រព្យប្រមាណមិនបាន ទុកក្នុងផ្ទះរបស់ព្រះពោធិសត្វ ទ្រង់ជូនព្រះពោធិសត្វទៅហើយ យាងទៅកាន់ទេវស្ថានរបស់ទ្រង់វិញ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ភរិយារបស់សេដ្ឋីក្នុងកាលនោះ បានមកជារាហុលមាតាក្នុងកាលឥឡូវនេះ ចំណែកវិសយ្ហសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វិសយ្ហជាតក ចប់**

**កោកិលវគ្គ ចប់**

# ចុល្លកុណាលវគ្គ

## កុណ្ឌលិកជាតក

[ ៦៦២ ] ( ព្រះអង្គត្រាស់ថា ) ស្ត្រីទាំងឡាយអ្នកធ្វើនូវសេចក្តីត្រេកអរចំពោះបុរសទាំងឡាយ ជាស្ត្រីមានចិត្តច្រើនផង ផ្ញៀផ្ញាល់មិនបានផង ប្រសិនបើស្ត្រីទាំងអស់ធ្វើនូវសេចក្តីពេញចិត្ត ( ចំពោះបុរស ) ដោយខ្លួនឯងក៏ដោយ បុរសមិនគប្បីទុកចិត្តទេ ព្រោះថាស្រីទាំងឡាយ ស្មើដោយកំពង់ទឹក ។

[ ៦៦៣ ] ហេតុនៃសេចក្តីធុញទ្រាន់ណា នៃព្រះរាជាទ្រង់ព្រះនាមកិន្នរៈនឹងនាងទេវីទ្រង់ព្រះនាមកិន្នរី ( ហេតុនៃសេចក្តីធុញទ្រាន់នោះ ) បុគ្គលឃើញហើយ ( គប្បីដឹងចុះ ) ស្រីទាំងពួង រមែងមិនត្រេកអរ ( នឹងស្វាមី ) ក្នុងផ្ទះរបស់ខ្លួន នាងកិន្នរីទេវី ជាកិរិយាលះបង់នូវព្រះរាជាកិន្នរៈនោះ ជាស្វាមីប្រាកដ ដូច្នោះ ព្រោះតែឃើញបុរសខ្វិនដទៃ ។

[ ៦៦៤ ] នាងបញ្ចបាបី ជាកិរិយារបស់ព្រះបាទពកៈផង របស់ព្រះបាទពាវរិកៈផង ដែលលុះក្នុងកាមដ៏ជ្រុលពេក ក៏បានប្រព្រឹត្តបទមិនគួរជាមួយនឹងបុរសអ្នកបម្រើ ធ្វើម្តេចហ្ន៎ ស្ត្រីមិនប្រព្រឹត្តបទមិនគួរនឹងបុរសដទៃនោះ ។

[ ៦៦៥ ] អគ្គមហេសីឈ្មោះនាងបិយង្គានី ជាទីគាប់ព្រះហឫទ័យរបស់ព្រះបាទព្រហ្មទត្ត ជាធំក្នុងលោកទាំងមូល បានប្រព្រឹត្តបទមិនគួរជាមួយនឹងបុរសអ្នកឃ្វាលសេះមង្គល ជាអ្នកបម្រើនៃអគ្គមហេសីនោះ ជាស្រីប្រាថ្នាកាម ក៏មិនបាននូវបុរសអ្នកឃ្វាលសេះនោះផង ( នូវទីជាអគ្គមហេសីផង ) ។

**ចប់ កុណ្ឌលិកជាតកទី ១ ។**

# ចូឡកុណាលវគ្គ

## អដ្ឋកថា កណ្ឌលិកជាតក

*[ ៦៦២-៦៦៥ ] រឿងពិស្តាររបស់ជាតកនេះ មានពាក្យផ្ដើមថា* **ឆិកានមាកាមករាសុ** *ដូច្នេះជាដើម ។ ផ្ទៃរឿងមានជាក់ច្បាស់ក្នុងកុណាល ជាតក នោះឯង ។*

*អដ្ឋកថា កណ្ឌរីជាតក ចប់*

## វានរជាតក

[ ៦៦៦ ] ( ពានរពោធិសត្វពោលថា ) នែសត្វទឹកក្រពើ អញអាច រើខ្លួនអំពីទឹកមកលើគោកហើយ ឥឡូវនេះ អញមិនលុះអំណាចនៃអ្នកឯង ទៀតទេ ។

[ ៦៦៧ ] ផ្លែឈើទាំងឡាយណា ដែលយើងគប្បីទៅកាន់ត្រើយនៃ សមុទ្ទ ហើយស៊ីផ្លែឈើទាំងឡាយនោះ គឺផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ មិន គួរដល់យើងឡើយ ឯផ្លែល្វារបស់យើងទើបប្រសើរជាង ។

[ ៦៦៨ ] បុគ្គលណា មិនដឹងហេតុដែលកើតឡើងភ្លាមៗទេ បុគ្គល នោះ គង់លុះក្នុងអំណាចសត្រូវផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ផង ។

[ ៦៦៩ ] បុគ្គលណា ដឹងនូវហេតុដែលកើតឡើងភ្លាម បុគ្គលនោះគង់ រួចចាកសេចក្តីចង្អៀត គឺសត្រូវផង មិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ ផង ។

**ចប់ វានរជាតកទី ២ ។**

## អដ្ឋកថា

## វានរជាតក

[ ៦៦៦-៦៦៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធ ទេវទត្តដែលព្យាយាមសម្លាប់ព្រះអង្គ ទើបត្រាស់រឿងនេះ មានពាក្យផ្តើម

ថា **អសក្ខិ វត អត្តានំ** ដូច្នេះជាដើម ។ រឿងបច្ចុប្បន្ន បានឲ្យពិស្តារទុកហើយនោះឯង ។

ចំណែករឿងក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតស្វា ក្នុងហិមវន្តប្បទេស លុះចម្រើនវ័យហើយ នៅត្រង់ឆ្នេរស្ទឹងគង្គា ។ គ្រានោះក្រពើញីមួយ ក្នុងស្ទឹងគង្គា កើតចាញ់ផ្ទៃចង់បរិភោគសាច់បេះដូងរបស់ព្រះពោធិសត្វ ទើបប្រាប់ដល់ក្រពើជាស្វាមី ។ ក្រពើជាស្វាមីគិតថា អញនឹងឲ្យស្វានោះ លិចចុះក្នុងទឹកហើយសម្លាប់យកសាច់បេះដូងឲ្យក្រពើញីដែលជាភរិយា ទើបពោលជាមួយព្រះពោធិសត្វថា មកសម្លាញ់ ពួកយើងទៅស៊ីផ្លែឈើតូចធំត្រង់កោះជាមួយគ្នា ។ មហាសត្វពោលថា យើងនឹងទៅបានដូចម្តេច ក្រពើពោលថា ខ្ញុំនឹងឲ្យឯងអង្គុយលើខ្នងខ្ញុំនាំទៅ ព្រះមហាសត្វមិនដឹងគំនិតរបស់ក្រពើនោះ ទើបលោតទៅអង្គុយលើខ្នង ។ ក្រពើទៅបានបន្តិច ក៏ពន្លិចខ្លួន លំដាប់នោះទើបពានរពោលនឹងក្រពើថា នែអ្នក អ្នកឲ្យយើងលិចចុះក្នុងទឹកធ្វើអ្វី ក្រពើពោលថា យើងនឹងសម្លាប់ឯង ហើយឲ្យសាច់បេះដូងដល់ភរិយារបស់យើង ។ ពានរពោលថា នែ ក្រពើល្ងង់ ឯងយល់ថាសាច់បេះដូងរបស់យើងនៅត្រង់ទ្រូងឬ ក្រពើពោលថា កាលបើដូច្នោះ បេះដូងរបស់ឯងនៅឯណា ពានរពោលថា ឯងមិនឃើញសាច់បេះដូងនោះដែលសំយុងនៅត្រង់ដើមល្វាទេឬ ក្រពើពោលថា ឃើញ ឯងឲ្យដល់យើងឬ ពានរពោលថា អើយើងនឹងឲ្យ ។ ព្រោះភាពល្ងង់ខ្លៅ ក្រពើក៏នាំពានរនោះទៅកាន់គល់ល្វានៅក្បែរមាត់ទឹក ។ ព្រះពោធិ

សត្វក៏លោតអំពីខ្នងក្រពើនោះទៅអង្គុយលើដើមល្វា ហើយបានពោលគាថាទាំងនេះថា

នែសត្វទឹកក្រពើ អញអាចរើខ្លួនអំពីទឹកមកលើគោកហើយ ឥឡូវនេះ អញមិនលុះអំណាចនៃអ្នកឯងទៀតទេ ។

ផ្លែឈើទាំងឡាយណា ដែលយើងគប្បីទៅកាន់ត្រើយនៃសមុទ្ទហើយស៊ីផ្លែឈើទាំងឡាយនោះ គឺផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ មិនគួរដល់យើងឡើយឯផ្លែល្វារបស់យើងទើបប្រសើរជាង ។

បុគ្គលណា មិនដឹងហេតុដែលកើតឡើងភ្លាមៗទេ បុគ្គលនោះ គង់លុះក្នុងអំណាចសត្រូវផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយផង ។

បុគ្គលណា ដឹងនូវហេតុដែលកើតឡើងភ្លាម បុគ្គលនោះគង់រួចចាកសេចក្តីបង្អៀត គឺសត្រូវផង មិនក្តៅក្រហាយក្នុងកាលជាខាងក្រោយផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសក្ខិ វត** សេចក្តីថា បានជាអ្នកអាចហ្ន៎ ។ បទថា **ឧទ្ធាតុំ** បានដល់ ដើម្បីលើកឡើង ។ ពានរហៅក្រពើថា **វារិជ** ។ បទថា **យានិ ចារំ សមុទ្ទស្ស** សេចក្តីថា ពានរកាលហៅស្ទឹងគង្គាដោយឈ្មោះថាសមុទ្រ ទើបពោលថា ផ្លែឈើទាំងឡាយណា ដែលយើងត្រូវឆ្លងត្រើយសមុទ្ទទៅបរិភោគ ផ្លែឈើទាំងឡាយនោះ មិនគួរដល់យើងឡើយ ។

បទថា **បច្ឆា ច អនុតប្បតិ** សេចក្តីថា បុគ្គលដែលមិនដឹងរឿងដែលកើតឡើងដោយឆាប់រួសរាន់រមែងទៅកាន់អំណាចរបស់សត្រូវ និងរមែងត្រូវក្តៅក្រហាយក្នុងកាលជាក្រោយ ។

ពានរពោលហេតុ ដែលជាគ្រឿងឲ្យសម្រេចកិច្ចបែបលោកិយៈ ដោយគាថាទាំង ៤ ដោយប្រការដូច្នេះហើយ ក៏ទៅកាន់ព្រៃនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះ មកសម្តែងហើយទើបទ្រង់ប្រជុំជាតកថា ក្រពើក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកពានរក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វានរជាតក ចប់**

# កុណ្ឌិនីជាតក

[ ៦៧០ ] ( មេក្រៀលទូលស្តេចថា ) ខ្ញុំនៅអាស្រ័យក្នុងព្រះរាជដំណាក់ របស់ព្រះអង្គ ៗ ធ្វើសក្ការៈបូជាជានិច្ច ឥឡូវនេះ ព្រះអង្គបានធ្វើ ( នូវហេតុឲ្យខ្ញុំចេញទៅ ) បពិត្រមហារាជ បើដូច្នោះ ខ្ញុំព្រះអង្គនឹងទៅ ។

[ ៦៧១ ] ( ព្រះរាជាពោធិសត្វត្រាស់ថា ) បុគ្គលណា ( ដឹង ) អំពើអាក្រក់ ដែលអ្នកដទៃធ្វើហើយចំពោះខ្លួន ( ដឹង ) អំពើអាក្រក់តប ដែលខ្លួនធ្វើតបតវិញ ពៀររបស់បុគ្គលនោះរមែងស្ងប់រម្ងាប់ដោយអាការយ៉ាងនេះ នែនាងក្រៀល ចូរនាងនៅចុះ កុំទៅឡើយ ។

[ ៦៧២ ] ( មេក្រៀលនិយាយថា ) មិត្តភាពនៃបុគ្គលដែលត្រូវគេធ្វើ និងបុគ្គលអ្នកធ្វើ ( តប ) រមែងមិនតគ្នាទៀតបានឡើយ ចិត្តរបស់ខ្ញុំ មិនយល់តាមទេ បពិត្រព្រះអង្គប្រសើរក្នុងរថ ខ្ញុំនឹងទៅមិនខាន ។

[ ៦៧៣ ] ( ព្រះរាជាត្រាស់ថា ) មិត្តភាពរបស់បុគ្គលដែលត្រូវគេធ្វើ នឹងបុគ្គលអ្នកធ្វើ ( តប ) រមែងតគ្នាទៀតបាន ចំពោះពួកជន ជាអ្នកប្រាជ្ញ មិនចំពោះពួកជនពាលទេ ម្នាលនាងក្រៀលនាងចូរនៅចុះ នាងកុំទៅឡើយ ។

**ចប់ កុន្តិនីជាតកទី ៣ ។**

# អដ្ឋកថា

# កុន្តិនីជាតក

[ ៦៧០-៦៧៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធក្រៀលញីដែលអាស្រ័យនៅក្នុងព្រះរាជវាំង របស់ព្រះបាទកោសល ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អវសិម្ហ តវាំ ឃរេ** ដូច្នេះជាដើម ។

បានឮថា ក្រៀលញីនោះជាអ្នកនាំព្រះរាជសាសន៍របស់ព្រះរាជា ក្រៀលញីនោះមានកូនពីរ ។ ព្រះរាជាទ្រង់ឲ្យក្រៀលញីនោះនាំព្រះរាជសាសន៍ទៅថ្វាយដល់ស្តេចមួយអង្គ ក្នុងពេលដែលក្រៀលញីនោះទៅហើយ ពួកទារកក្នុងរាជត្រកូល នាំគ្នាយកដៃច្របាច់កូនក្រៀលនោះរហូតស្លាប់ទៅ ។ ក្រៀលញីនោះត្រឡប់មកហើយ ឃើញកូនទាំងនោះស្លាប់ទើបសួរថា អ្នកណាសម្លាប់កូនខ្ញុំ ពួកមនុស្សប្រាប់ថា កុមារឈ្មោះនោះ និងកុមារឈ្មោះនោះ ។ ក្នុងកាលនោះ ក្នុងរាជត្រកូលមានខ្លាធំមួយដែលចិញ្ចឹមទុក ជាសត្វកាច ខ្លានោះនៅបានដោយការចងទុក ។ ក្នុងពេលដែលពួកក្មេងទាំងនោះ ទៅមើលខ្លានោះ ក្រៀលញីនោះក៏បានទៅជាមួយក្មេងទាំងនោះ គិតថា អញនឹងធ្វើក្មេងទាំងនោះឲ្យដូចវាសម្លាប់កូនអញ ទើបនាំក្មេងទាំងនោះទៅ ធ្វើឲ្យដួលក្បែរជើងខ្លា ខ្លាទំពាស៊ីក្មេងទាំងនោះ ។ ក្រៀលញីគិតថា ឥឡូវនេះ មនោរថរបស់អញបរិបូណ៌ហើយ ទើបហើរទៅកាន់ហិមវន្តប្បទេស ។ ភិក្ខុទាំងឡាយបានស្តាប់ហេតុនោះហើយទើបសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ក្រៀលញីក្នុងរាជត្រកូល ប្រាសពួកក្មេងដែលសម្លាប់កូនខ្លួន ឲ្យដួល

ក្នុងទីជិតជើងខ្លា ហើយហើរទៅកាន់ហិមវន្តប្បទេសនោះឯង ។ ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក្រៀលញីនេះ ក៏ប្រាសពួកក្មេង ដែលសម្លាប់កូនរបស់ខ្លួនឲ្យដួលចុះជិតជើងខ្លាធំ ហើយទៅកាន់ព្រៃហិមពាន្តដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះពោធិសត្វសោយរាជសម្បត្តិ ក្នុងនគរពារាណសី ដោយធម៌ដ៏ស្មើ ។ ក្នុងព្រះរាជនិវេសន៍ មានក្រៀលមួយ ជាអ្នកនាំព្រះរាជសាសន៍ ។ សេចក្តីទាំងអស់ ដូចគ្នាតាមដែលពោលមកហើយនោះឯង ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះថា ក្រៀលញីនោះ ឲ្យខ្លាធំសម្លាប់ក្មេងទាំងឡាយហើយគិតថា ឥឡូវនេះ អញមិនអាចនៅក្នុងទីនេះ អញត្រូវទៅ តែកាលទៅ មិនទាន់ក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាបជាមុននឹងមិនទៅ អញក្រាបទូលព្រះរាជាហើយសឹមទៅ ក្រៀលញីនោះក៏ចូលទៅគាល់ព្រះរាជា ថ្វាយបង្គំហើយ ឈរក្នុងទីបំផុតនាចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះអង្គ ពួកក្មេងសម្លាប់កូនរបស់ខ្ញុំ ព្រោះការប្រហែសធ្វេសរបស់ទ្រង់ ខ្ញុំជាអ្នកធ្លាក់ក្នុងអំណាចនៃសេចក្តីក្រោធ ទើបសម្លាប់ក្មេងទាំងនោះវិញ ឥឡូវនេះ ខ្ញុំមិនអាចនៅក្នុងទីនេះ ហើយពោលគាថាទី ១ ថា

ខ្ញុំនៅអាស្រ័យក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ៗ ធ្វើសក្ការៈ

បូជាជានិច្ច ឥឡូវនេះ ព្រះអង្គបានធ្វើ ( នូវហេតុឲ្យខ្ញុំចេញ
ទៅ ) បពិត្រមហារាជ បើដូច្នោះ ខ្ញុំព្រះអង្គនឹងទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ត្វមេវធានិមការិ** សេចក្ដីថា ទ្រង់នោះឯងឲ្យខ្ញុំកាន់ព្រះរាជសាសន៍បញ្ជូនទៅ ទ្រង់មិនថែរក្សាកូនជាទីស្រឡាញ់ទាំងឡាយរបស់ខ្ញុំ ព្រោះការប្រមាទរបស់ទ្រង់ ឈ្មោះថាទ្រង់ញ៉ាំងហេតុឲ្យខ្ញុំនេះ ទៅក្នុងឥឡូវនេះ ។ សព្ទថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថនៃឧបសគ្គ ។ ក្រៀលញីហៅព្រះពោធិសត្វថា **រាជ** ។ បទថា **វជាមហំ** សេចក្ដីថា ខ្ញុំទៅកាន់ហិមវន្តប្បទេស ។ ព្រះរាជាទ្រង់ស្ដាប់ដូច្នោះ ក៏ពោលគាថាទី ២ ថា

បុគ្គលណា ( ដឹង ) អំពើអាក្រក់ ដែលអ្នកដទៃធ្វើហើយ
ចំពោះខ្លួន ( ដឹង ) អំពើអាក្រក់តប ដែលខ្លួនធ្វើតបតវិញ
ពៀររបស់បុគ្គលនោះរមែងស្ងប់រម្ងាប់ ដោយអាការយ៉ាងនេះ
នែ នាងក្រៀល ចូរនាងនៅចុះ កុំទៅឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា បុគ្គលណា កាលអ្នកដទៃធ្វើកម្មគ្រោតគ្រាត គឺធ្វើកម្មដ៏ទារុណ មានសម្លាប់កូនជាដើមរបស់ខ្លួន កាលខ្លួនធ្វើតបនូវកម្មគ្រោតគ្រាតចំពោះបុគ្គលនោះបាន រមែងដឹងថា អញសងសឹកបានហើយ ពៀររបស់បុគ្គលនោះ រមែងស្ងប់រម្ងាប់ទៅដោយអាការៈយ៉ាងនេះ គឺពៀរនោះរមែងស្ងប់ ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រោះហេតុនោះ នែក្រៀលញី ចូរនាងនៅចុះកុំទៅណាឡើយ ។ សត្វក្រៀលបានស្ដាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

មិត្តភាពនៃបុគ្គលដែលត្រូវគេធ្វើ នឹងបុគ្គលអ្នកធ្វើ ( តប )
រមែងមិនតគ្នាទៀតបានឡើយ ចិត្តរបស់ខ្ញុំ មិនយល់តាមទេ
បពិត្រព្រះអង្គប្រសើរក្នុងរថ ខ្ញុំនឹងទៅមិនខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆ កតស្ស ច កត្តា ច** សេចក្តីថា ឈ្មោះថាមិត្តភាពរបស់បុគ្គលពីរពួកនេះ គឺបុគ្គលដែលត្រូវគេធ្វើការបៀតបៀន និងគំរាមកំហែង និងបុគ្គលដែលធ្វើឲ្យប្រែប្រួលទៅដោយការបែកខ្ញែកក្នុងឥឡូវនេះរមែងផ្សាភ្ជាប់មិនបាន គឺតគ្នាមិនបានវិញ ។ បទថា **ហទយំ ឆានុជានាតិ** សេចក្តីថា ព្រោះហេតុនោះ ចិត្តរបស់ខ្ញុំក៏មិនអនុញ្ញាតការនៅក្នុងទីនេះ ។ បទថា **គច្ឆញ្ញេវ រថេសភ** សេចក្តីថា បពិត្រមហារាជ ព្រោះដូច្នោះ ខ្ញុំសូមទៅតែម្យ៉ាង ។ ព្រះរាជាទ្រង់ស្តាប់ដូច្នោះទើបត្រាស់គាថាទី ៤ ថា

មិត្តភាពរបស់បុគ្គលដែលត្រូវគេធ្វើនិងបុគ្គលអ្នកធ្វើ ( តប )
រមែងតគ្នាទៀតបាន ចំពោះពួកជនជាអ្នកប្រាជ្ញ មិនចំពោះពួក
ជនពាលទេ ម្នាលនាងក្រៀលនាងចូរនៅចុះ នាងកុំទៅឡើយ
ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា មេត្រីភាពរបស់បុគ្គលដែលត្រូវធ្វើការបៀតបៀនមុន បុគ្គលដែលសងសឹកតប រមែងជាប់គ្នាបានទៀត តែមេត្រីភាពនោះរមែងភ្ជាប់គ្នាបានសម្រាប់ពួកអ្នកប្រាជ្ញ តែសម្រាប់បុគ្គលពាលរមែងភ្ជាប់គ្នាមិនបាន ព្រោះថាមេត្រីភាពរបស់អ្នកប្រាជ្ញទាំងឡាយ ទោះបីបែកទៅហើយក៏ត្រឡប់តជាប់គ្នាបាន ចំណែកមេត្រីរបស់បុគ្គលពាល បែកគ្នាតែម្តង

រមែងបែករហូត ព្រោះដូច្នោះ នៃក្រៀលញី ចូរនាងនៅចុះកុំទៅឡើយ ។

កាលព្រះរាជាឃាត់យ៉ាងនោះ ក្រៀលញីក៏នៅតែទូលថា បពិត្រព្រះអង្គ ខ្ញុំមិនអាចនៅក្នុងទីនេះបាន ទើបថ្វាយបង្គំព្រះរាជា ហើយហើរទៅកាន់ហិមវន្តប្បទេសនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ក្រៀលញីក្នុងកាលនោះ បានមកជាក្រៀលញី ក្នុងកាលឥឡូវនេះ ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កុន្តិនីជាតក ចប់**

## អម្ពជាតក

[ ៦៧៤ ] ( សេដ្ឋីធីតាទី ១ ពោលថា ) ស្រ្តីណាលួចស្វាយរបស់លោកម្ចាស់ ស្រ្តីនោះចូរលុះក្នុងអំណាចនៃបុរស ដែលប្រដាប់ដោយវត្ថុសម្រាប់ធ្វើសក់ឲ្យខ្មៅ លំបាកដោយសណ្ឋាសចុះ ( បានប្តីចាស់ ) ។

[ ៦៧៥ ] ( សេដ្ឋីធីតាទី ២ ពោលថា ) ស្រ្តីណាលួចស្វាយរបស់លោកម្ចាស់ ស្រ្តីបែបនោះ ទោះបីអាយុដល់ ២០ ឆ្នាំ ឬ ២៥ ឆ្នាំ ឬក៏ថយពី ៣០ ឆ្នាំ ក៏កុំឲ្យបានប្តីឡើយ ។

[ ៦៧៦ ] ( សេដ្ឋីធីតាទី ៣ ពោលថា ) ស្រ្តីណាលួចស្វាយរបស់លោកម្ចាស់ ស្រ្តីនោះតែម្នាក់ឯងពឹងផ្អែកតែនឹងប្តី ហើយដើរទៅកាន់ផ្លូវឆ្ងាយ កុំឲ្យជួបនឹងប្តីក្នុងទីដែលសន្យាគ្នាឡើយ ។

[ ៦៧៧ ] ( សេដ្ឋីធីតាទី ៤ ពោលថា ) ស្រ្តីណាលួចស្វាយរបស់លោកម្ចាស់ ស្រ្តីនោះមានខ្លួនប្រដាប់ហើយ មានសម្លៀកបំពាក់ដ៏ស្អាត ទ្រទ្រង់កម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ ចូរដេកនៅលើទីដេកតែម្នាក់ឯងចុះ ។

**ចប់ អម្ពជាតកទី ៤ ។**

## អដ្ឋកថា

## អម្ពជាតក

[ ៦៧៤-៦៧៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈអ្នកយាមស្វាយមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យ

ផ្ដើមថា **យោ នីលិយំ មណ្ឌយតិ** ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈនោះបួសឯចាស់ សាងបណ្ណសាលានៅក្នុងចម្ការស្វាយខាងចុងវត្តជេតពនមើលថែស្វាយ ទំពាស៊ីស្វាយទុំដែលជ្រុះ រមែងឲ្យចំពោះបុគ្គលដែលជាប់ទាក់ទងនឹងខ្លួនប៉ុណ្ណោះ ។ កាលព្រះថេរៈនោះ ចូលទៅបិណ្ឌបាត អ្នកលួចស្វាយធ្វើផ្លែស្វាយឲ្យជ្រុះហើយទំពាស៊ីកាន់យកទៅ ។ ខណៈនោះ ធីតារបស់សេដ្ឋី ៤ នាក់ ងូតទឹកក្នុងស្ទឹងអចិរវតី ហើយត្រាច់ទៅ ចូលទៅកាន់ចម្ការស្វាយនោះ ព្រះថេរៈមកឃើញសេដ្ឋីធីតាទាំងនោះ ក៏ពោលថា នាងស៊ីស្វាយរបស់យើង សេដ្ឋីធីតាទាំងនោះបានពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំទើបតែមក មិនបានទំពាស៊ីស្វាយរបស់លោកម្ចាស់ទេ ព្រះថេរៈចាស់ពោលថា បើយ៉ាងនោះចូរពួកនាងស្បថ ។ ធីតាសេដ្ឋីទាំងនោះទទួលពាក្យថា សាធុ ហើយធ្វើការស្បថ ។ ព្រះថេរៈចាស់ឲ្យធីតាសេដ្ឋីទាំងនោះធ្វើការស្បថ ឲ្យដល់នូវការខ្មាសហើយទើបឲ្យទៅ ។ ភិក្ខុទាំងឡាយបានស្ដាប់ការធ្វើរបស់ព្រះថេរៈចាស់រូបនោះ ទើបសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ព្រះថេរៈចាស់រូបនោះ ឲ្យធីតាសេដ្ឋីដែលបានចូលទៅកាន់ចម្ការស្វាយដែលជាលំនៅរបស់ខ្លួនធ្វើការស្បថ ធ្វើឲ្យនាងខ្មាសគេហើយលែងទៅ ។ ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន

ភិក្ខុចាស់នេះ បានជាអ្នកយាមស្វាយ ញ៉ាំងធីតាសេដ្ឋីទាំងនេះឲ្យធ្វើការស្បថ ធ្វើឲ្យខ្មាសហើយលែងទៅ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិជាសក្កទេវរាជ ។ ក្នុងកាលនោះ ជដិលកោងម្នាក់ចូលទៅអាស្រ័យនគរពារាណសី សាងបណ្ណសាលាក្នុងចម្ការស្វាយ ក្នុងទីជិតស្ទឹង រក្សាស្វាយបរិភោគផ្លែស្វាយដែលទុំជ្រុះ ឲ្យចំពោះបុគ្គលដែលទាក់ទងនឹងខ្លួន ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ មានប្រការផ្សេងៗ ។ ក្នុងកាលនោះ សក្កទេវរាជទ្រង់ព្រះតម្រិះថា ក្នុងលោកអ្នកណាហ្ន៎ ទំនុកបម្រុងមាតាបិតា អ្នកណាហ្ន៎ ប្រព្រឹត្តឱនលំទោនចំពោះអ្នកចម្រើនក្នុងត្រកូល ( រៀមច្បង ) អ្នកណាឲ្យទានរក្សាសីល ធ្វើឧបោសថកម្ម អ្នកណាបួសហើយខ្វល់ខ្វាយក្នុងសមណធម៌ អ្នកណាប្រព្រឹត្តអនាចារ ទើបទ្រង់ប្រមើលមើលសត្វលោក ឃើញជដិលកោងយាមស្វាយ មិនមានអាចារៈ ទើបត្រិះរិះថា ជដិលកោងនេះ លះបង់សមណធម៌របស់ខ្លួន មានការបរិកម្មកសិណជាដើម រក្សាចម្ការស្វាយ អញនឹងធ្វើឲ្យជដិលនេះសង្វេគ ក្នុងពេលដែលជដិលកោងនោះចូលទៅរកភិក្ខាក្នុងស្រុក ទើបបានបណ្តាលឲ្យស្វាយទាំងឡាយជ្រុះចុះដោយអានុភាពរបស់ទ្រង់ ហើយធ្វើឲ្យដូចជាទីដែលត្រូវចោរប្លន់ ។ គ្រានោះ ធីតាសេដ្ឋី ៤ នាក់ចេញអំពីនគរពារាណសី ចូលទៅកាន់ចម្ការស្វាយនោះ ។ ជដិលកោងឃើញធីតាសេដ្ឋីនោះ ទើបយកលេសថា ពួកនាងបរិភោគស្វាយរបស់យើង សេដ្ឋីធីតា

ទាំងនោះពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំទើបតែមកអំបាញ់មិញនេះឯងពួកខ្ញុំមិនបានស៊ីផ្លែស្វាយរបស់លោកទេ ជដិលកោងពោលថា បើយ៉ាងនោះពួកនាងចូរស្បថ ។ ធីតាសេដ្ឋីទាំងនោះសួរថា ពួកខ្ញុំស្បថហើយនឹងទៅបានឬ ជដិលកោងពោលថា អើ ស្បថហើយនឹងទៅបាន ធីតាសេដ្ឋីទាំងនោះនាំគ្នាទទួលពាក្យថា សាធុ កាលធីតាសេដ្ឋីច្បងស្បថក៏ពោលគាថាទី ១ ថា

ស្ត្រីណា លួចស្វាយរបស់លោកម្ចាស់ ស្ត្រីនោះ ចូរលុះក្នុង
អំណាចនៃបុរស ដែលប្រដាប់ដោយវត្ថុសម្រាប់ធ្វើសក់ឲ្យខ្មៅ
លំបាកដោយសណ្ឋាសចុះ ( បានប្តីចាស់ ) ដូច្នេះ ។

ពាក្យជាគាថានោះ មានអត្ថថា បុរសណាធ្វើឲ្យសក់ខ្មៅ ដោយយកផ្លែឈើពណ៌ខៀវជាដើម មកប្រកបធ្វើ ដើម្បីធ្វើសក់ស្កូវឲ្យមានពណ៌ខ្មៅ និងដកសក់ស្កូវដែលនៅជាមួយសក់ខ្មៅ ឈ្មោះថាក្តៅក្រហាយ គឺលំបាកព្រោះសណ្ឋាស ស្រីដែលលួចស្វាយរបស់លោកម្ចាស់ ចូរធ្លាក់ក្នុងចំណោចរបស់បុរសចាស់បែបនោះ គឺចូរបានប្តីបែបនោះ ។

តាបសពោលថា ចូរនាងឈរក្នុងចំណែកម្ខាង ហើយឲ្យធីតាសេដ្ឋីទីពីរធ្វើការស្បថ ធីតាសេដ្ឋីទីពីរកាលនឹងស្បថ ក៏ពោលគាថាទី ២ ថា

ស្ត្រីណា លួចស្វាយរបស់លោកម្ចាស់ ស្ត្រីបែបនោះ ទោះបី
អាយុដល់ ២០ ឆ្នាំ ឬ ២៥ ឆ្នាំ ឬក៏ថយពី ៣០ ឆ្នាំ ក៏
កុំឲ្យបានប្តីឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា ធម្មតានារីទាំងឡាយ រមែងជាទី

ស្រឡាញ់របស់ពួកបុរស ក្នុងគ្រាមានអាយុប្រមាណ ១៥-១៦ ឆ្នាំ តែស្រី ដែលល្អចស្វាយរបស់លោក កុំបានប្តីក្នុងកាលជាក្រមុំបែបនោះ លុះដល់អាយុ ២០ ឬ ២៥ ឆ្នាំ ឬឈ្មោះថា ៣០ ឆ្នាំ ខ្វះ ១ ខ្វះ ២ ( ២៨-២៩ ឆ្នាំ ) ដោយជាតិកំណើត ទោះបីជាបែបនោះ គឺជាអ្នកមានវ័យចាស់ហើយ ក៏ចូរកុំបានប្តីឡើយ ។

កាលធីតាសេដ្ឋីទី ២ ស្បថហើយ ឈរក្នុងចំណែកម្ខាង ធីតាសេដ្ឋីទី ៣ ក៏ពោលគាថាទី ៣ ថា

ស្ត្រីណាល្អចស្វាយរបស់លោកម្ចាស់ ស្ត្រីនោះតែម្នាក់ឯង ពឹង
ផ្អែកតែនឹងប្តី ហើយដើរទៅកាន់ផ្លូវឆ្ងាយ កុំឲ្យជួបនឹងប្តីក្នុងទី
ដែលសន្យាគ្នាឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា ស្រីណាល្អចស្វាយរបស់លោកម្ចាស់ ស្រីនោះកាលប្រាថ្នាប្តី ឈ្មោះថា ជាអ្នកអន្ទះអន្ទែង ព្រោះសោប់សល់ក្នុងសម្នាក់របស់ប្តីនោះតែម្នាក់ឯង គឺមិនមានសម្លាញ់ដើរផ្លូវដ៏ឆ្ងាយប្រមាណ ១ គាវុត ២ គាវុត ទោះបីទៅដល់ហើយធ្វើនូវការណាត់គ្នាថា អ្នកគប្បីមកក្នុងទីឈ្មោះនោះ ក៏កុំបានជួបប្តីនោះឡើយ ។

កាលធីតាសេដ្ឋីទី ៣ ស្បថហើយឈរក្នុងចំណែកម្ខាង ធីតាសេដ្ឋីទី ៤ ក៏ពោលគាថាទី ៤ ថា

ស្ត្រីណាល្អចស្វាយរបស់លោកម្ចាស់ ស្ត្រីនោះមានខ្លួនប្រដាប់
ហើយ មានសម្លៀកបំពាក់ដ៏ស្អាត ទ្រទ្រង់កម្រងផ្កា ប្រោះព្រំ

ដោយខ្ញីមចន្ទន៍ ចូរដេកនៅលើទីដេកតែម្នាក់ឯងចុះ ដូច្នេះ ។

ពាក្យដែលជាគាថានេះ មានអត្ថងាយយល់ទាំងអស់ហើយ ។ តាបសកោងពោលថា នាងទាំងឡាយធ្វើការស្បថខ្លាំងក្លាពេក មុខជាជនដទៃស៊ីផ្លែស្វាយរបស់យើង ឥឡូវនេះ ពួកនាងទៅបាន ហើយបញ្ជូនធីតាសេដ្ឋីនោះទៅ ។ សក្កទេវរាជទ្រង់សម្តែងរូបារម្មណ៍ដែលគួរខ្លាច ធ្វើឲ្យតាបសកោងគេចទៅអំពីទីនោះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ជដិលកោងក្នុងកាលនោះ បានមកជាភិក្ខុចាស់អ្នកយាមស្វាយក្នុងកាលឥឡូវនេះ ធីតាសេដ្ឋីទាំង ៤ នាក់ក្នុងកាលនោះ បានមកជាធីតាសេដ្ឋីទាំងនេះ ចំណែកសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អម្ពជាតក ចប់

# គជកុម្ភជាតក

[ ៦៧៨ ] ( អាមាត្យពោធិសត្វពោលថា ) កាលណាភ្លើងឆេះព្រៃ ម្នាលបចលកៈ អ្នកនឹងធ្វើដូចម្តេច បើអ្នកមានសេចក្តីព្យាយាមយឺតយូរយ៉ាងនេះ ។

[ ៦៧៩ ] ( គជកុម្ភ ( ខ្យងសោក ) ពោលថា ) ប្រហោងឈើ ក្រហែងដីមានច្រើន បើយើងទៅមិនដល់ទីទាំងនោះទេ យើងទៀងតែស្លាប់ ។

[ ៦៨០ ] ( ពោធិសត្វពោលថា ) បុគ្គលណា រហ័សរហួន ក្នុងកាលដែលខ្លួនត្រូវធ្វើការងារយឺតយូរផង យឺតយូរក្នុងការងារ ដែលគេត្រូវធ្វើឲ្យរហ័សរហួនផង បុគ្គលនោះឈ្មោះថា បំបាក់នូវប្រយោជន៍របស់ខ្លួនចោល ដូចជាបុរសដើរជាន់ស្លឹកត្នោតស្ងួត ឲ្យខ្ទេចខ្ទីដូច្នោះ ។

[ ៦៨១ ] បុគ្គលណា យឺតយូរក្នុងការងារដែលខ្លួនត្រូវធ្វើឲ្យយឺតយូរផង រហ័សរហួនក្នុងការងារដែលខ្លួនត្រូវធ្វើឲ្យរហ័សផង ប្រយោជន៍របស់បុរសនោះ តែងពេញគ្រប់គ្រាន់ ដូចជាព្រះចន្ទវេលារាត្រី ( ឲ្យលេចពន្លឺធំម្តងបន្តិចៗ ) ។

**ចប់ គជកុម្ភជាតកទី ៩ ។**

# អដ្ឋកថា

# គជកុម្ភជាតក

[ ៦៧៨-៦៨១ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុខ្ជិលច្រអូសមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វនំ យទគ្គិ ទហាតិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ ជាកុលបុត្តអ្នកក្រុងសាវត្ថី បួសឧទ្ទិសខ្លួនក្នុងព្រះសាសនា បានជាអ្នកខ្ជិលច្រអូសឆ្ងាយអំពីឧទ្ទេស ការរៀនព្រះបាលី ( ព្រះត្រៃបិដក ) ការសាកសួរ ការធ្វើយោនិសោមនសិការៈក្នុងកម្មដ្ឋាននិងវត្តបដិបត្តិ មានកិច្ចវត្តជាដើម ជាបុគ្គលដែលត្រូវនីវរណៈគ្របសង្កត់ ជាអ្នកនៅយ៉ាងនោះគ្រប់ឥរិយាបថ មានការអង្គុយនិងការឈរជាដើម ។ ភិក្ខុទាំងឡាយសន្ទនាគ្នាប្រារព្ធដល់ការខ្ជិលច្រអូសរបស់ភិក្ខុនោះក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុឈ្មោះនោះ បួសក្នុងព្រះសាសនាដែលជានេយ្យានិកៈជាគ្រឿងនាំចេញចាកទុក្ខបែបនោះ គង់ខ្ជិលច្រអូស ត្រូវនីវរណៈគ្របសង្កត់ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ជាអ្នកខ្ជិលច្រអូសដូចគ្នា ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វ បានជាអាមាត្យរតន៍របស់ព្រះរាជាអង្គនោះ ។ ព្រះបាទពារា

ណសីនោះ មានព្រះអជ្ឈាស្រ័យខ្ជិលច្រអូស ព្រះពោធិសត្វគិតថា អញនឹងឲ្យព្រះរាជាទ្រង់ភ្ញាក់រឭក ដូច្នេះហើយ ទើបពិចារណារកឧបមាមួយ ។ ថ្ងៃមួយ ព្រះរាជាយាងទៅព្រះរាជឧទ្យាន កាលពួកអាមាត្យចោមរោម ទ្រង់យាងទៅក្នុងព្រះរាជឧទ្យាននោះ ទ្រង់ទតឃើញខ្យងសោកមួយ ជាសត្វខ្ជិលច្រអូស យឺតយ៉ាវ បានឮថា សត្វនោះជាសត្វយឺត ទោះបីដើរមួយថ្ងៃបានប្រមាណ ១ ធ្នាប់ ឬ ២ ធ្នាប់នោះឯង ។ ព្រះរាជា ឃើញដូច្នោះ ត្រាស់សួរព្រះពោធិសត្វថា សត្វនេះឈ្មោះអ្វី មហាសត្វក្រាបទូលថា បពិត្រមហារាជ សត្វនេះឈ្មោះថា រាជកុក្កុះ ហើយក្រាបទូលថា សត្វបែបនេះ ខ្ជិលច្រអូស ដើរទៅមួយថ្ងៃបានត្រឹមតែ ១ ធ្នាប់ ឬ ២ ធ្នាប់ប៉ុណ្ណោះ កាលចរចាជាមួយខ្យងសោកនោះ ទើបពោលថា នែរាជកុក្កុះ ពួកអ្នកដើរយឺត កាលភ្លើងព្រៃកើតឡើងក្នុងព្រៃនេះ ពួកអ្នកធ្វើដូចម្តេច ហើយពោលគាថាទី ១ ថា

កាលណាភ្លើងឆេះព្រៃ ម្នាលបចលកៈ អ្នកនឹងធ្វើដូចម្តេច បើ
អ្នកមានសេចក្តីព្យាយាមយឺតយូរយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទគ្គិ** កាត់បទជា **យទា អគ្គិ** ។ បទថា **ទាវកោ កណ្ហវត្តនី** ជាឈ្មោះរបស់ភ្លើង ។ ព្រះពោធិសត្វហៅរាជកុក្កុះនោះថា បចលកៈ ( សត្វដែលដើរឃ្លោង ) ។ ព្រោះរាជកុក្កុះនោះ ដើរដោយយោលខ្លួន ឬយោកខ្លួនជានិច្ច ព្រោះដូច្នោះទើបហៅថា បចលកៈ ។ បទថា **ធន្ធបរក្កមោ** បានដល់ មានសេចក្តីព្យាយាមធូរថយ ។ រាជកុក្កុះបានស្តាប់ដូច្នោះ ទើបពោលគាថា ទី ២ ថា

ប្រហោងឈើ ក្រហែងដី មានច្រើន បើយើងទៅមិនដល់ទី
ទាំងនោះទេ យើងទៀតតែស្លាប់ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា បពិត្រអ្នកបណ្ឌិត ឈ្មោះថាការទៅដែលក្រៃលែងជាងនេះរបស់ខ្ញុំមិនមាន ។ ក្នុងព្រៃនេះ ព្រង់ឈើនិងក្រហែងដីមានច្រើន បើពួកខ្ញុំទៅមិនទាន់ដល់ព្រង់ឈើ ឬក្រហែងដីទាំងនោះ ពួកខ្ញុំក៏ត្រូវស្លាប់ គឺសេចក្តីស្លាប់ប៉ុណ្ណោះមានដល់ពួកខ្ញុំ ។ ព្រះពោធិសត្វបានស្តាប់ដូច្នោះ ក៏ពោលគាថា ២ ក្រោអំពីនេះថា

បុគ្គលណា រហ័សរហួន ក្នុងកាលដែលខ្លួនត្រូវធ្វើការងារ
យឺតយូរផង យឺតយូរក្នុងការងារដែលគេត្រូវធ្វើឲ្យរហ័សរហួន
ផង បុគ្គលនោះឈ្មោះថា បំបាក់នូវប្រយោជន៍របស់ខ្លួនចោល
ដូចជាបុរសដើរជាន់ស្លឹកត្នោតស្ងួតឲ្យខ្ទេចដូច្នោះ ។

បុគ្គលណា យឺតយូរក្នុងការងារដែលខ្លួនត្រូវធ្វើឲ្យយឺតយូរ
ផង រហ័សរហួនក្នុងការងារដែលខ្លួនត្រូវធ្វើឲ្យរហ័សផង ប្រ-
យោជន៍របស់បុរសនោះ តែងពេញគ្រប់គ្រាន់ ដូចជាព្រះចន្ទ
វេករាត្រី ( ឲ្យលេចពន្លឺជំម្លងបន្តិចៗ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧទ្ធកាលេ** សេចក្តីថា ក្នុងពេលដែលត្រូវធ្វើការងារនោះសន្សឹមៗ ។ បទថា **តរតិ** សេចក្តីថា ក៏ប្រញាប់ធ្វើការងារនោះៗដោយរហ័ស ។ បទថា **សុក្ខបណ្ណំវ** សេចក្តីថា បុគ្គលនោះ រមែងកាច់បំបាក់សេចក្តីចម្រើននៃប្រយោជន៍របស់ខ្លួន ដូចបុរសមានកម្លាំង ជាន់នូវ

ស្ងឹកគ្លោតស្ងួតព្រោះខ្យល់និងកម្តៅថ្ងៃ គឺធ្វើឲ្យបែកខ្ទេចខ្ទីក្នុងទីនោះឯង ។ បទថា **ឧឆ្ចុតិ** សេចក្តីថា រមែងយឺតយូរ គឺការងារដែលត្រូវធ្វើយឺតៗ ក៏ធ្វើឲ្យយឺត ។ បទថា **តារយិ** សេចក្តីថា ការងារដែលត្រូវប្រញាប់ ក៏ធ្វើដោយប្រញាប់ ។ បទថា **សសីវ រត្តឹ វិភជំ** នេះ លោកអធិប្បាយថា ប្រយោជន៍របស់បុរសនោះពេញបរិបូណ៌ ដូចព្រះចន្ទធ្វើរាត្រីខាងរនោចឲ្យភ្លឺស្វាង ឈ្មោះថាកម្ចាត់រាត្រីខាងរនោច ឲ្យពេញវង់រាល់ៗថ្ងៃ ដូច្នោះ ។

ព្រះរាជា បានស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ តាំងអំពីនោះមកក៏ទ្រង់មិនមានសេចក្តីខិលប្រអូស ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ខ្សែសោកក្នុងកាលនោះ បានមកជាភិក្ខុខិលប្រអូសក្នុងកាលឥឡូវនេះ ចំណែកបណ្ឌិតអមាត្យក្នុងកាលនោះ គឺ តថាគតនេះឯង ។

## អដ្ឋកថា គជកុម្ភជាតក ចប់

# កេសវជាតក

[ ៦៨២ ] ( នារទាមាត្យទូលសួរកេសវតាបសថា ) កេសវតាបសមានព្រះភាគ ( របស់យើងខ្ញុំ ) នេះ លះបង់ព្រះបាទពារាណសីជាធំជាងមនុស្ស អ្នកឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយក្នុងអាស្រមរបស់កូនសិស្សឈ្មោះកប្បកៈ តើដោយឧបាយដូចម្តេច ។

[ ៦៨៣ ] ( កេសវតាបសនិយាយថា ) ម្នាលអាមាត្យ រសទាំងឡាយដ៏ឆ្ងាញ់ គួររីករាយក៏មាន ដើមឈើទាំងឡាយជាទីរីករាយចិត្តក៏មានពាក្យជាសុភាសិតទាំងឡាយរបស់កប្បកៈតែងធ្វើឲ្យអាត្មាត្រេកអរបាន ។

[ ៦៨៤ ] ( នារទាមាត្យពោលថា ) លោកម្ចាស់ ឆាន់ចង្ហាន់ស្រូវសាលីដែលលាយដោយសាច់ដ៏ស្អាត ហេតុដូចម្តេច បានជាស្រងែនិងស្មៅគែលលកដែលមិនមានរសប្រៃសោះ ធ្វើឲ្យលោកម្ចាស់ត្រេកអរបាន ។

[ ៦៨៥ ] ( កេសវតាបសនិយាយតបថា ) បុគ្គលមានសេចក្តីស្និទ្ធស្នាលបរិភោគភោជន ទោះបីឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តី តិចក្តី ច្រើនក្តី ក្នុងកន្លែងណា ភោជន ( ណាមួយដែលបុគ្គលបរិភោគហើយក្នុងទីកន្លែងនោះជាភោជនប្រសើរ ) ព្រោះរសមានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង ។

**ចប់ កេសវជាតកទី ៦ ។**

# អដ្ឋកថា

## កេសវជាតក

[ ៦៨២-៦៨៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភោជននៃបុគ្គលស្និទ្ធស្នាលគ្នា ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **មនុស្សិន្ទំ ជហិត្វាន** ដូច្នេះជាដើម ។

បានឮថា ក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី មានភត្តាហារទុកប្រគេនភិក្ខុ ៥០០ រូបជាប្រចាំ ទើបផ្ទះរបស់សេដ្ឋីដូចជាអណ្តូងទឹកដែលកើតហើយរបស់ភិក្ខុសង្ឃជានិច្ចកាល ។ ផ្ទះរបស់គាត់ ដេរដាសដោយសំពត់កាសាវពស្ត្រច្រើនដោយពួកឥសីអ្នកស្វែងរកបុណ្យ ។ ថ្ងៃមួយព្រះរាជាទ្រង់ធ្វើប្រទក្សិណព្រះនគរ បានទតឃើញភិក្ខុសង្ឃក្នុងនិវេសន៍របស់សេដ្ឋី ទ្រង់ត្រិះរិះថា អញនឹងថ្វាយភិក្ខាជាប្រចាំ ដល់ព្រះអរិយសង្ឃដូច្នេះ ទើបទៅកាន់វិហារទ្រង់នមស្ការព្រះសាស្តា ហើយទ្រង់តម្កល់ភិក្ខាហារដល់ភិក្ខុ ៥០០ រូប ជាប្រចាំ តាំងអំពីនោះមកទ្រង់ក៏ថ្វាយភិក្ខាហារក្នុងព្រះរាជនិវេសន៍ជាប្រចាំ ។ ភោជននៃស្រូវសាលីមានក្លិនក្រអូបដែលរក្សាទុកអស់ ៣ ឆ្នាំ ជារបស់ប្រណីត ។ បុគ្គលប្រគេនដោយដៃរបស់ខ្លួនក្តី ដោយភាពស្និទ្ធស្នាលក្តី ដោយសេចក្តីស្រឡាញ់ក្តី មិនមាន ។ ពួកខ្ញុំរាជការប៉ុណ្ណោះរមែងចាត់ចែង ។ ភិក្ខុទាំងឡាយ មិនប្រាថ្នានឹងអង្គុយឆាន់ ទទួលយកភត្តាហារមានរសប្រសើរផ្សេងៗ ហើយទៅកាន់ត្រកូលឧបដ្ឋាករៀងៗខ្លួន ឲ្យភត្តាហារដល់ពួកឧបដ្ឋាកទាំងនោះ ហើយនាំគ្នាឆាន់ភត្តាហារ ដែលឧបដ្ឋាកទាំងនោះប្រគេន ទោះជាសៅហ្មងឬ

ប្រណីត ។ ថ្ងៃមួយ មនុស្សទាំងឡាយនាំយកផលាផលជាច្រើនទៅថ្វាយព្រះរាជា ។ ព្រះរាជាត្រាស់ថា ពួកអ្នក ចូរប្រគេនដល់ភិក្ខុសង្ឃ ទើបមនុស្សទាំងឡាយនាំគ្នាទៅកាន់រោងភត្តាហារ មិនឃើញភិក្ខុត្រឹមតែមួយរូប ទើបក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ សូម្បីភិក្ខុមួយរូបក៏មិនមាន ។ ព្រះរាជាត្រាស់ថា មិនទាន់ដល់ពេលទេដឹង មនុស្សទាំងឡាយក្រាបទូលថា ដល់ពេលហើយព្រះអង្គ តែភិក្ខុទាំងឡាយទទួលភត្តាហារក្នុងវាំងរបស់ទ្រង់ហើយទៅក្នុងផ្ទះនៃឧបដ្ឋាកដែលស្និទ្ធស្នាលរៀងៗខ្លួន ឲ្យភត្តាហារនោះដល់ឧបដ្ឋាកប៉ុណ្ណោះ ហើយឆាន់ភត្តាហារដែលឧបដ្ឋាកទាំងនោះប្រគេន ទោះជាសៅហ្មងឬប្រណីតក៏ដោយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ភត្តាហាររបស់យើងប្រណីតព្រោះហេតុអ្វីហ្ន៎ ទើបភិក្ខុទាំងឡាយមិនឆាន់ភត្តាហារនោះ នាំគ្នាឆាន់ភត្តាហារដទៃ អញនឹងទូលសួរព្រះសាស្តា ទើបយាងទៅកាន់វិហារ ទ្រង់ថ្វាយបង្គំហើយ ទើបទូលសួរ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ធម្មតាការបរិភោគភោជន មានការស្និទ្ធស្នាលសំខាន់ជាង ព្រោះក្នុងរាជវាំងរបស់ទ្រង់មិនមានអ្នកចូលទៅតាំងនូវការស្និទ្ធស្នាល ហើយឲ្យដោយសេចក្តីស្និទ្ធស្នាល ភិក្ខុទាំងឡាយក៏ទទួលភត្តាហារ ហើយឆាន់ក្នុងទីនៃបុគ្គលដែលមានភាព ស្និទ្ធស្នាលដល់ខ្លួន មហាបពិត្រ ឈ្មោះថារសដទៃដូចគ្នានឹងការស្និទ្ធស្នាលរមែងមិនមាន សូម្បីមធុរស ៤ យ៉ាង ដែលជនមិនស្និទ្ធស្នាលឲ្យ រមែងមិនដល់ចំណែកដែលបុគ្គលស្និទ្ធស្នាលឲ្យឡើយ បុរាណកបណ្ឌិតទាំងឡាយ កាលរោគកើតឡើង កាលព្រះរាជាទ្រង់នាំគ្រូពេទ្យទាំង ៥ ត្រកូលមកឲ្យផ្សំថ្នាំ កាល

រោគមិនស្ងប់ បានទៅកាន់សម្នាក់របស់បុគ្គលដែលស្និទ្ធស្នាល បរិភោគយាគូ ដែលធ្វើដោយស្រងែនិងស្ពួយដែលមិនមានរសប្រៃនិងបន្លែដែលស្រុសដោយទឹកទទេ មិនមានរសប្រៃ ក៏ជារោគបាន កាលព្រះរាជាទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាសិករដ្ឋ មាតាបិតាដាក់ឈ្មោះកុមារនោះថា កប្បកុមារ ។ កប្បកុមារនោះចម្រើនវ័យហើយ បានរៀនសិប្បៈគ្រប់យ៉ាងក្នុងនគរតក្កសិលា ខាងក្រោយមកបានបួសជាឥសី ។ កាលនោះកេសវតាបស ចោមរោមដោយតាបស ៥០០ រូប ជាគ្រូនៃគណៈ នៅក្នុងហិមវន្តប្បទេស ។ ព្រះពោធិសត្វបានទៅកាន់សម្នាក់នៃកេសវតាបសនោះ បានជាអន្តេវាសិកច្បងក្នុងអន្តេវាសិក ៥០០ រូប ។ មែនពិត អធ្យាស្រ័យរបស់ព្រះពោធិសត្វនោះ មានសេចក្តីស្និទ្ធស្នាលចំពោះកេសវតាបស ។ តាបសទាំងនោះ បានជាអ្នកស្និទ្ធស្នាលដល់គ្នានឹងគ្នាក្រៃលែង ។ ចំណេរ កាលតមក កេវសតាបសបាននាំតាបសទាំងនោះទៅកាន់ដែនដីមនុស្ស ដើម្បីសេពរសជូរប្រៃ ដល់នគរពារាណសីហើយ សម្រាកក្នុងព្រះរាជឧទ្យាន ។ ស្អែកឡើង ចូលទៅកាន់នគរដើម្បីភិក្ខាចារ បានទៅដល់ទ្វារព្រះរាជវាំង ។ ព្រះរាជាទ្រង់ឃើញពួកឥសីទើបឲ្យទៅនិមន្តមកហើយ ឲ្យឆាន់ខាងក្នុងព្រះរាជនិវេសន៍ ទ្រង់កាន់យកប្តេជ្ញាហើយ ឲ្យស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ លុះកន្លងរដូវភ្លៀងហើយ កេសវតាបសបានទូលលាព្រះរាជា ។ ព្រះរាជាត្រាស់

ថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយចាស់ជរា សូមអាស្រ័យខ្ញុំនៅចុះ បញ្ជូនតែតាបសកំលោះៗ ទៅកាន់ហិមវន្តប្បទេសចុះ ។ កេសវតាបសទទួលថា សាធុ ហើយបានបញ្ជូនតាបសទាំងនោះ មួយអន្លើដោយអន្តេវាសិកប្បន ទៅកាន់ហិមវន្តប្បទេស ខ្លួនឯងប៉ុណ្ណោះអាស្រ័យនៅ ។

ចំណែកកប្បតាបស ក៏ទៅកាន់ហិមវន្តប្បទេសជាមួយតាបសទាំងឡាយ កេសវតាបសកាលនៅឆ្ងាយអំពីកប្បតាបសក៏អផ្សុក ជាអ្នកប្រាថ្នាឃើញកប្បតាបសនោះ ជាអ្នកមិនបានសិងលក់ ។ កាលកេសវតាបសនោះ សិងមិនលក់ អាហារក៏មិនរលួយដោយល្អ រោគចុះលោហិតក៏ប្រាកដឡើង ទុក្ខវេទនាប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ។ ព្រះរាជា ទ្រង់នាំគ្រូពេទ្យ ៥ ត្រកូល មកប្រតិបត្តិតាបស រោគក៏មិនស្ងប់ ។ កេសវតាបសទូលព្រះរាជាថា មហាបពិត្រទ្រង់ប្រាថ្នាឲ្យអាត្មាភាពស្លាប់ឬប្រាថ្នាឲ្យជាសះស្បើយ ។ ព្រះរាជាត្រាស់ថា ប្រាថ្នាឲ្យជាសះស្បើយរោគ ។ កេសវតាបសទូលថា បើយ៉ាងនោះសូមទ្រង់បញ្ជូនអាត្មាទៅកាន់ហិមវន្តប្បទេសចុះ ។ ព្រះរាជាត្រាស់ថា សាធុ ហើយទ្រង់ឲ្យហៅនារទអាមាត្យមកត្រាស់ថា ចូរអ្នកនាំលោកម្ចាស់ទៅកាន់ព្រៃហិមពាន្តមួយអន្លើដោយពួកព្រានព្រៃ ហើយទ្រង់បញ្ជូនទៅ ។ នារទអាមាត្យនាំកេសវតាបសនោះទៅកាន់ព្រៃហិមពាន្តហើយត្រឡប់មក ។ ចំណែកកេសវតាបស កាលបានឃើញកប្បតាបសប៉ុណ្ណោះ រោគផ្លូវចិត្ត ក៏ស្ងប់ ការអផ្សុកក៏ស្ងប់ទៅ ។ លំដាប់នោះ កប្បតាបសបានឲ្យយាគូដែលចម្អិនដោយស្លែនិងស្លឹកព្រមទាំងបន្លែដែលស្រុសដោយទឹកទទេដែលមិនប្រៃ មិនបាន

អប់ ដល់កេសវតាបសនោះ រោគចុះលោហិតរបស់កេសវតាបស ក៏ស្ងប់រម្ងាប់ក្នុងខណៈនោះឯង ។ ព្រះរាជា ទ្រង់បញ្ជូននារទអាមាត្យនោះទៅទៀត ដោយត្រាស់ថា ចូរអ្នកទៅ ចូរដឹងការប្រព្រឹត្តទៅរបស់កេសវតាបសនោះ ។ នារទអាមាត្យនោះទៅហើយ បានឃើញតាបសជាសះស្បើយរោគទើបពោលថា បពិត្រលោកម្ចាស់ ព្រះបាទពារាណសីទ្រង់នាំពេទ្យ ៥ ត្រកូលមកប្រតិបត្តិ ក៏មិនអាចធ្វើលោកម្ចាស់ឲ្យជាសះស្បើយ កប្បតាបសប្រតិបត្តិលោកម្ចាស់ដូចម្តេច ហើយពោលគាថាទី ១ ថា

កេសវតាបសមានព្រះភាគ ( របស់យើងខ្ញុំ ) នេះ លះបង់
ព្រះបាទពារាណសី ជាធំជាងមនុស្ស អ្នកឲ្យសម្រេចសេចក្តី
ប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយក្នុង អាស្រមរបស់កូន
សិស្សឈ្មោះកប្បកៈ តើដោយឧបាយដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មនុស្សិន្ទំ** បានដល់ ព្រះបាទពារាណសីដែលជាកំពូលនៃមនុស្ស ។ បទថា **កថំ នុ ភគវា កេសិ** សេចក្តីថា ព្រោះឧបាយដូចម្តេចហ្ន៎ ទើបកេសវតាបសដ៏មានជោគរបស់ពួកយើងរូបនេះ ត្រេកអរក្នុងអាស្រមរបស់កប្បតាបស ។ នារទអាមាត្យ ធ្វើហាក់ដូចជាចរចានឹងអ្នកដទៃ សួរដល់ហេតុក្នុងការត្រេកអរក្រៃលែងរបស់កេសវតាបសដោយប្រការយ៉ាងនេះ ។ កេសវតាបសបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ២ ថា

ម្នាលអាមាត្យ រសទាំងឡាយដ៏ឆ្ងាញ់ គួររីករាយក៏មាន ដើម
ឈើទាំងឡាយជាទីរីករាយចិត្ត ក៏មាន ពាក្យជាសុភាសិត

ទាំងឡាយរបស់កប្បកៈ តែងធ្វើឲ្យអាត្មាត្រេកអរបានដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វក្ខា** បានដល់ ដើមឈើទាំងឡាយ ។ តែក្នុងបាលីសរសេរទុកថា **រុក្ខា** ។ បទថា **សុភាសិតានិ** សេចក្ដីថា ពាក្យសុភាសិតដែលកប្បតាបសពោលរមែងធ្វើយើងឲ្យត្រេកអរ ។

កាលកេសវតាបសនោះពោលយ៉ាងនេះហើយ ក៏ពោល ( បន្ត ) ថា កប្បតាបស ធ្វើយើងឲ្យត្រេកអរយ៉ាងនេះ ទើបឲ្យយើងបរិភោគបបរដែលចម្អិនដោយស្រងែនិងស្លួយ លាយដោយបន្លែដែលស្រុសដោយទឹកមិនប្រៃនិងមិនបានអប់ក្លិន ព្យាធិក្នុងរាងកាយរបស់យើង ស្ងប់រម្ងាប់ព្រោះបបរនោះយើងជាសះស្បើយរោគហើយ ។ នារទអាមាត្យបានស្ដាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

លោកម្ចាស់ ឆាន់ចង្ហាន់ស្រូវសាលី ដែលលាយដោយសាច់
ដ៏ស្អាត ហេតុដូចម្ដេច បានជាស្រងែនិងស្មៅគេលលកដែល
មិនមានរសប្រៃសោះ ធ្វើឲ្យលោកម្ចាស់ត្រេកអរបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភុញ្ជេ** បានដល់ បរិភោគហើយ ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនោះដូចគ្នា ។ បទថា **ឆាទយន្តិ** បានដល់ ឲ្យត្រេកអរ គឺឲ្យឆ្អែត ឲ្យគាប់ចិត្ត ។ ដើម្បីងាយស្រួលក្នុងការចងគាថា ទើបលោកចុះនិគ្គហិត ។ លោកពោលពាក្យអធិប្បាយទុកថា ហេតុអ្វីទើបស្រងែនិងស្លួយដែលមិនមានរសប្រៃនេះ ធ្វើលោកម្ចាស់ដែលបរិភោគកត្តនៃស្រូវសាលី ដែលចម្អិនដោយសាច់ដ៏ស្អាត សមគួរដល់ព្រះរាជាក្នុងរាជត្រកូល ឲ្យឆ្អែតត្រេកអរ

បាន គឺហេតុអ្វីទើបលោកម្ចាស់គាប់ចិត្តយ៉ាងនេះ ។ កេសវតាបសបានស្តាប់ដូច្នោះ ក៏ពោលគាថាទី ៤ ថា

បុគ្គលមានសេចក្តីស្និទ្ធស្នាល បរិភោគភោជន ទោះបីឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តី តិចក្តី ច្រើនក្តី ក្នុងកន្លែងណា ភោជន ( ណាមួយ ដែលបុគ្គលបរិភោគហើយក្នុងទីកន្លែងនោះ ជាភោជនប្រសើរ ) ព្រោះរស មានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែងដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យទិវាសាធុំ** កាត់បទជា **យទិវា អសាធុំ** ប្រែថា មិនល្អក្តី ។ បទថា **វិស្សដ្ឋោ** សេចក្តីថា ជាអ្នកប្រាសចាកសេចក្តីរង្កៀស ដល់នូវភាពជាអ្នកស្និទ្ធស្នាលគ្នា ។ បទថា **យត្ថ ភុញ្ជេយ្យ** សេចក្តីថា គប្បីបរិភោគយ៉ាងនេះក្នុងនិវេសន៍ណា ភោជនប្រភេទណាមួយ ដែលបរិភោគហើយយ៉ាងនោះក្នុងនិវេសន៍នោះល្អទាំងអស់ ព្រោះហេតុអ្វី ព្រោះរសទាំងឡាយ មានការស្និទ្ធស្នាលជាកំពូល អធិប្បាយថា រសទាំងឡាយឈ្មោះថាមានសេចក្តីស្និទ្ធស្នាលជាកំពូល ព្រោះការស្និទ្ធស្នាល ជាកំពូលក្រៃលែង គឺឧត្តមនៃរសទាំងឡាយនោះ ។ ព្រោះឈ្មោះថារស ស្មើដោយរសនៃការស្និទ្ធស្នាលរមែងមិនមាន ហេតុនោះភោជនាហារ សូម្បីមានរសឆ្ងាញ់ ៤ យ៉ាង ដែលបុគ្គលមិនស្និទ្ធស្នាលរៀបចំឲ្យ រមែងមិនស្មើទឹកជ្រក់ និងទឹកបាយដែលបុគ្គលស្និទ្ធស្នាលរៀបចំឲ្យឡើយ ។

នារទអាមាត្យបានស្តាប់ពាក្យរបស់កេសវតាបសនោះហើយ ទើបទៅកាន់

រាជសម្នាក់ក្រាបទូលថា កេសវតាបសពោលពាក្យឈ្មោះនេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ នារទអាមាត្យក្នុងកាលនោះ បានមកជាសារីបុត្ត កេសវតាបសក្នុងកាលនោះ បានមកជាពកព្រហ្ម ចំណែកកប្បតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កេសវជាតក ចប់

## អយក្ខូដជាតក

[ ៦៨៦ ] ( ពោធិសត្វពោលថា ) អ្នកណា ឈរកាន់ញញួរដែកទាំងមូល ធំហួសប្រមាណ លើអាកាស អ្នកនោះមកស្ថិតនៅដើម្បីរក្សាអញ ( ក្នុងថ្ងៃនេះ ) ឬព្យាយាម ដើម្បីសម្លាប់អញ ។

[ ៦៨៧ ] ( យក្សពោលថា ) បពិត្រមហារាជ ខ្ញុំព្រះអង្គជាទូតរបស់អារក្សទឹក ខ្ញុំព្រះអង្គត្រូវពួកអារក្សទឹកប្រើមកក្នុងទីនេះ ដើម្បីសម្លាប់ព្រះអង្គ តែថា ព្រះឥន្ទ្រជាស្តេចទេវតារក្សាព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គនឹងបំបែកព្រះសិរ្សរបស់ព្រះអង្គមិនបានទេ ។

[ ៦៨៨ ] ( ពោធិសត្វពោលថា ) បើទេវរាជ ទេវានមិន្ទ មឃវៈ សុជម្បតិ រក្សានូវអញ ម្នាលបិសាច អារក្សទាំងអស់ ចូរបន្ទឺឡើងតាមសេចក្តីប្រាថ្នាចុះ យ៉ាងអញមិនតក់ស្លុត ចំពោះពួកអារក្សទឹកទេ ។

[ ៦៨៩ ] ពួកកុម្ភណ្ឌនិងពួកបិសាច នៅលើគំនរសំរាមទាំងអស់ ចូរកម្លាត់តាមសេចក្តីប្រាថ្នាចុះ នៃបិសាច ពួកបិសាចទាំងអស់មិនអាចដើម្បីច្បាំងនឹងអញបានទេ ការបន្ទាចគួរឲ្យខ្លាចនោះធំណាស់ ( តែអញមិនខ្លាចឯងទេ ) ។

**ចប់ អយកូដជាតកទី ៧ ។**

# អដ្ឋកថា

# អយក្ខូដជាតក

[ ៦៨៦-៦៨៩ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការប្រព្រឹត្តប្រយោជន៍ដល់សត្វលោក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សព្វាយសំ ក្ខូដំ** ដូច្នេះជាដើម ។ រឿងបច្ចុប្បន្ន មានជាក់ច្បាស់ក្នុងមហាកណ្ហជាតក ចំណែករឿងក្នុងអតីតៈ មានដូចតទៅនេះ ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទព្រហ្មទត្តនោះ ។ លុះចម្រើនវ័យហើយ រៀនសិល្បសាស្ត្រចប់ហើយ កាលព្រះរាជបិតាសោយទិវង្គតទៅ បានតាំងនៅក្នុងរាជសម្បត្តិ ទ្រង់គ្រងរាជដោយធម៌ ។ ក្នុងកាលណោះ មនុស្សទាំងឡាយគោរពទេវតាជាមង្គល សម្លាប់ពពែជាដើមសន្ទឹកសន្ធាប់ធ្វើពលីកម្មដល់ទេវតាទាំងឡាយ ។ ព្រះពោធិសត្វឲ្យវាយស្គរប្រកាសថា មិនត្រូវសម្លាប់សត្វមានជីវិត ។ យក្ខទាំងឡាយកាលមិនបានពលីកម្ម ទើបក្រោធនឹងព្រះពោធិសត្វ បានទៅកាន់សមាគមយក្ខ ក្នុងហិមវន្តប្បទេស បញ្ជូនយក្ខម្នាក់ដែលកាចឃោរឃៅទៅ ដើម្បីសម្លាប់ព្រះពោធិសត្វ ។ យក្ខនោះ កាន់ញញួរដែកដែលមានកម្ដៅ ដ៏ធំ ប្រមាណប៉ុនហោជាង ដោយតាំងចិត្តថានឹងប្រហារព្រះពោធិសត្វ ដោយញញួរដែកនេះឲ្យស្លាប់ ទើបឈរត្រង់ក្បាលដំណេកព្រះពោធិសត្វ ក្នុងវេលាមជ្ឈិមយាម ។ ខណៈនោះ អាសនៈរបស់សក្កទេវរាជសម្ដែងអាការៈក្ដៅ ទើបទ្រង់រំពឹងមើល ទ្រង់បានជ្រាបហេតុនោះ ទ្រង់ក៏កាន់វជិរាវុធយាងមក ហើយបានប្រឋាប់ឈរ ខាងលើយក្ខ ។

ព្រះពោធិសត្វបានឃើញយក្ខហើយគិតថា យក្ខនេះឈររក្សាអាត្មាអញ ឬឈរបំណាំងនឹងសម្លាប់អញ កាលចរចានឹងយក្ខនោះ ទើបពោលគាថាទី ១ ថា

អ្នកណា ឈរកាន់ញញួរដែកទាំងមូលធំហួសប្រមាណ លើអាកាស អ្នកនោះមកស្ថិតនៅដើម្បីរក្សាអញ ( ក្នុងថ្ងៃនេះ ) ឬព្យាយាមដើម្បីសម្លាប់អញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិហិតោនុសជ្ជ** កាត់បទជា **វិហិតោនុសិ អជ្ជ** ។ ព្រះពោធិសត្វ ឃើញយក្ខប៉ុណ្ណោះមិនឃើញសក្កទេវរាជ ។ យក្ខមិនអាចប្រហារព្រះពោធិសត្វ ព្រោះខ្លាចសក្កទេវរាជ យក្ខនោះបានស្តាប់ពាក្យរបស់ព្រះពោធិសត្វទើបពោលថា បពិត្រមហារាជ ខ្ញុំមិនបានឈររក្សាទ្រង់ តែខ្ញុំមកដោយបំណងថានឹងយកញញួរដែកដែលឆេះសន្ធោសន្ធៅនេះ ប្រហារធ្វើឲ្យស្លាប់ ខ្ញុំមិនអាចប្រហារព្រោះខ្លាចសក្កៈ កាលសម្តែងសេចក្តីនេះ ទើបពោលគាថាទី ២ ថា

បពិត្រមហារាជ ខ្ញុំព្រះអង្គជាទូតរបស់អារក្សទឹក ខ្ញុំព្រះអង្គត្រូវពួកអារក្សទឹកប្រើមកក្នុងទីនេះដើម្បីសម្លាប់ព្រះអង្គ តែថាព្រះឥន្ទ្រជាស្តេចទេវតារក្សាព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គនឹងបំបែកព្រះសិរ្សរបស់ព្រះអង្គមិនបានទេ ដូច្នេះ ។

ព្រះពោធិសត្វបានស្តាប់ពាក្យនោះទើបពោលគាថា ២ ក្រៅអំពីនេះថា

បើទេវរាជ ទេវានមិន្ទ មឃវៈ សុជម្បតិ រក្សានូវអញ

ម្នាលបិសាច អារក្សទាំងអស់ ចូរបន្ទឺឡើងតាមសេចក្ដីប្រាថ្នា
ចុះ យ៉ាងអញមិនតក់ស្លុតចំពោះពួកអារក្សទឹកទេ ។

ពួកកុម្ភណ្ឌនិងពួកបិសាច នៅលើគំនរសំរាមទាំងអស់ ចូរ
កម្ចាត់តាមសេចក្ដីប្រាថ្នាចុះ នៃបិសាច ពួកបិសាចទាំងអស់
មិនអាចដើម្បីច្បាំងនឹងអញបានទេ ការបន្ទាច គួរឲ្យខ្លាចនោះ
ធំណាស់ ( តែអញមិនខ្លាចឯងទេ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រក្ខសិយា បជាយ** សេចក្ដីថា ពួកសត្វគឺអារក្សទឹក បានដល់ ពួកសត្វដែលជាអារក្សទឹក ។ បទថា **កុម្ភណ្ឌា** បានដល់ ពួកយក្ខដែលមានពោះធំ មានអណ្ឌជប៉ុនក្អម ។ បទថា **បំសុបិសាចកា** បានដល់ ពួកបិសាចក្នុងទីចោលសំរាម ។ បទថា **នាលំ** សេចក្ដីថា ឈ្មោះថា ពួកបិសាចមិនអាចច្បាំងជាមួយអញ ។ បទថា **មហាតី សា វិភេសិកា** សេចក្ដីថា យក្ខទាំងនេះប្រជុំគ្នាសម្ដែងកិរិយាគួរខ្លាចផ្សេងៗយ៉ាងណា កិរិយាដែលគួរខ្លាចផ្សេងៗនោះ ទោះបីច្រើនក៏ត្រឹមតែសម្ដែងអាការៈគួរខ្លាចដល់អញប៉ុណ្ណោះ តែអញមិនខ្លាចឡើយ ។

សក្កទេវរាជដេញយក្ខនោះឲ្យគេចទៅ ទូន្មានព្រះមហាសត្វហើយត្រាស់ថា បពិត្រមហារាជ ទ្រង់កុំខ្លាចឡើយ ចាប់តាំងអំពីនេះទៅការគ្រប់គ្រងទ្រង់ជានាទីរបស់ខ្ញុំ ហើយយាងទៅកាន់ឋានរបស់ព្រះអង្គនោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា សក្កទេវរាជក្នុងកាលនោះបានមកជាអនុរុទ្ធក្នុងកាលឥឡូវ

នេះ ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អយកូដជាតក ចប់

# អរញ្ញជាតក

[ ៦៩០ ] ( តាបសកុមារនិយាយប្រាប់បិតាថា ) បពិត្របិតា ខ្ញុំបាទចេញអំពីព្រៃ មករកស្រុកវិញ គួរសេពគប់នឹងបុរសមានមារយាទដូចម្តេច មានវត្តប្រតិបត្តិដូចម្តេច ខ្ញុំបាទសួរហើយ សូមបិតាប្រាប់ហេតុនោះ ( ដល់ខ្ញុំ ) ឲ្យទាន ។

[ ៦៩១ ] ( តាបសពោធិសត្វជាបិតាប្រាប់ថា ) ម្នាលកូន បុរសណាគប្បីស្និទ្ធស្នាលនឹងអ្នក គប្បីអត់ទ្រាំនូវសេចក្តីស្និទ្ធស្នាលរបស់អ្នក ជាអ្នកចង់ស្តាប់ពាក្យរបស់អ្នក អត់ទោសដល់អ្នក អ្នកទៅអំពីព្រៃនេះទៅ ចូរសេពគប់នឹងបុរសនោះចុះ ។

[ ៦៩២ ] បុរសណា មិនមានអំពើអាក្រក់ដោយកាយវាចាចិត្តបើអ្នកចេញអំពីព្រៃនេះទៅ អ្នកចូរសេពគប់បុរសនេះចុះ ធ្វើដូចជាកូនដែលតាំងនៅព្ទដ៏ទ្រូង ។

[ ៦៩៣ ] បើផ្ទៃជម្ពូទ្វីបនេះ គ្មានមនុស្សអ្នកវៀរចាកកាយទុច្ចរិតជាដើមទេ ម្នាលកូន អ្នកកុំសេពគប់នឹងបុរសដែលមានចិត្តដូចទឹកល្មៀតជាគ្រឿងជ្រលក់ ( មានចិត្តមិនបានខ្ជាប់ខ្ជួន ) មានចិត្តដូចជាអាការនៃស្វា ជួនត្រេកអរ ជួនមិនត្រេកអរ ( ប្រែប្រួលភ្លាមៗ ) ប្រាកដដូច្នោះឡើយ ។

**ចប់ អរញ្ញជាតកទី ៨ ។**

# អដ្ឋកថា

## អរញ្ញជាតក

[ ៦៩០-៦៩៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារិកាម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អរញ្ញា គាមមាគម្ម** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានច្បាស់ក្នុងចុល្លនារទកស្សបជាតក ។ ចំណែករឿងក្នុងអតីត: មានដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយរៀនសិល្បសាស្ត្រក្នុងនគរតក្កសិលា កាលភរិយាអនិច្ចកម្មហើយ បាននាំកូនទៅបួសជាឥសីក្នុងហិមវន្តប្បទេស ឲ្យកូននៅក្នុងអាស្រមបទ ។ ចំណែកខ្លួនចេញទៅរកផ្លែឈើ ។ កាលណោះ ពួកចោរប្លន់បច្ចន្តគាម ហើយនាំពួកឈ្លើយទៅ កុមារិកាម្នាក់គេចទៅដល់អាស្រមបទនោះ លួងលោមតាបសកុមារ ឲ្យដល់នូវការវិនាសសីល ហើយពោលថា មកពួកយើងនាំគ្នាទៅ តាបសពោលថា ចូរ បង្អង់ឲ្យបិតារបស់យើងមកសិន យើងជួបបិតាហើយនឹងទៅ កុមារិកានោះពោលថា បើយ៉ាងនោះ លោកជួបបិតាហើយចូរមក ហើយចេញទៅអង្គុយត្រង់រវាងផ្លូវ ។ កាលបិតាមកហើយ តាបសកុមារ ក៏ពោលគាថាទី ១ ថា

បពិត្របិតា ខ្ញុំបាទចេញអំពីព្រៃ មករកស្រុកវិញ គួរសេព
គប់នឹងបុរស មានមារយាទដូចម្តេច មានវត្តប្រតិបត្តិដូចម្តេច

ខ្ញុំបាទសួរហើយ សូមបិតាប្រាប់ហេតុនោះ ( ដល់ខ្ញុំ ) ឲ្យទាន
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរញ្ញា គាមមាគម្ម** សេចក្តីថា បពិត្រលោកឪពុក ខ្ញុំនឹងចេញអំពីព្រៃនេះ ទៅកាន់ដែនដីមនុស្សដើម្បីរស់នៅ ដល់ទីលំនៅហើយនឹងធ្វើដូចម្តេច ។ លំដាប់នោះ បិតាកាលនឹងឲ្យឱវាទដល់បុត្តនោះ ទើបពោលគាថា ៣ ថា

ម្នាលកូន បុរសណាគប្បីស្និទ្ធស្នាលនឹងអ្នក គប្បីអត់ទ្រាំ
នូវសេចក្តីស្និទ្ធស្នាល របស់អ្នក ជាអ្នកចង់ស្តាប់ពាក្យរបស់
អ្នក អត់ទោសដល់អ្នក អ្នកទៅអំពីព្រៃនេះទៅ ចូរសេពគប់
នឹងបុរសនោះចុះ ។

បុរសណា មិនមានអំពើអាក្រក់ដោយកាយវាចាចិត្ត បើ
អ្នកចេញអំពីព្រៃនេះទៅ អ្នកចូរសេពគប់បុរសនេះចុះ ធ្វើដូច
ជាកូនដែលតាំងនៅក្នុងដ៏ទ្រូង ។

បើផែ្ទជម្ពូទ្វីបនេះ គ្មានមនុស្សអ្នកវៀរចាកកាយទុច្ចរិតជា
ដើមទេ ម្នាលកូន អ្នកកុំសេពគប់នឹងបុរសដែលមានចិត្តដូច
ទឹកល្មៀត ជាគ្រឿងជ្រលក់ ( មានចិត្តមិនបានខ្ជាប់ខ្ជួន )
មានចិត្តដូចជាអាការនៃស្វា ជួនត្រេកអរ ជួនមិនត្រេកអរ ( ប្រែ
ប្រួលក្លាមៗ ) ប្រាកដដូច្នោះឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ តំ វិស្សាសយេ** សេចក្តីថា បុរស

ណាគប្បីស្និទ្ធស្នាល គឺមិនរង្កៀសជាមួយឯង ។ បទថា **វិស្សាសញ្ច ខមេយ្យ តេ** សេចក្តីថា ម្យ៉ាងទៀត បុគ្គលណាគប្បីជាអ្នកមានការស្និទ្ធស្នាល ដែលធ្វើទុកក្នុងខ្លួនអ្នក មិនរង្កៀស គប្បីអត់ធន់នឹងបុគ្គលនោះដែលធ្វើនូវសេចក្តីស្និទ្ធស្នាលនោះដល់ខ្លួន ។ បទថា **សុស្សូសី** សេចក្តីថា ម្យ៉ាងទៀត បុគ្គលណាត្រូវការស្តាប់វាចាដោយការស្និទ្ធស្នាលរបស់ឯង ។ បទថា **តិតិក្ខី** សេចក្តីថា ម្យ៉ាងទៀត បុគ្គលណា អត់ធន់នូវកំហុសដែលឯងធ្វើបាន ។ បទថា **តំ ភជេហិ** សេចក្តីថា ឯងគប្បីសេពគប់ គឺគប្បីចូលទៅអង្គុយជិតបុរសនោះ ។ បទថា **ឱរសីវ បតិដ្ឋាយ** សេចក្តីថា បុត្តកើតអំពីទ្រូង ចម្រើនធំធាត់ ក្នុងទ្រូងរបស់បុគ្គលនោះ យ៉ាងណា ឯងគប្បីដូចបុត្តដែលតាំងនៅក្នុងទ្រូងបែបនោះ គប្បីសេពគប់បុរសបែបនោះ ដូច្នោះ ។ បទថា **ហលិទ្ទរាគំ** បានដល់ ដែលមានចិត្តមិនមាំទាំ ដូចជ្រលក់ដោយល្មៀត ។ បទថា **កបិចិត្តំ** បានដល់ ឈ្មោះថា **កបិចិត្តំ** ព្រោះប្រែប្រួលរហ័ស ។ បទថា **រាគវិរាគិនំ** បានដល់ មានសភាពស្រឡាញ់និងនឿយណាយមួយរំពេចប៉ុណ្ណោះ ។ បទថា **និម្មនុស្សម្បិ ចេ សិយា** សេចក្តីថា ជម្ពូទ្វីបទាំងមូល ឈ្មោះថាគប្បីប្រាសចាកមនុស្ស ព្រោះមិនមានមនុស្សដែលវៀរចាកកាយទុច្ចរិតជាដើម ទោះបីដូច្នោះ ឯងកុំសេពគប់មនុស្សដែលមានចិត្តស្រាលដូច្នោះឡើយ ចូរឯងពិនិត្យមើលក្នុងដែនដីមនុស្សទូទៅ ហើយសេពគប់បុគ្គល ដែលសម្បូរដោយគុណដូចពោលខាងដើមចុះ ។

តាបសកុមារបានស្តាប់ដូច្នោះ ទើបពោលថា បពិត្របិតា ខ្ញុំនឹងបាននូវ

បុរសដែលប្រកបដោយគុណទាំងនេះក្នុងទីណា ខ្ញុំនឹងមិនទៅ នឹងនៅក្នុងសម្នាក់របស់បិតាប៉ុណ្ណោះ កាលពេលហើយក៏ត្រឡប់មក ។ លំដាប់នោះបិតាក៏បានប្រាប់កសិណបរិកម្មដល់តាបសកុមារនោះ តាបសទាំងពីរមានឈានមិនសាបសូន្យ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា បុត្តនិងកុមារិកាក្នុងកាលនោះ បានមកជាជនទាំងនេះក្នុងកាលឥឡូវនេះ ចំណែកតាបសជាបិតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អរញ្ញជាតក ចប់

# សន្ធិភេទជាតក

[ ៦៩៤ ] ( ព្រះរាជាមានព្រះឱង្ការនឹងសារថីថា ) ម្នាលសារថី សេចក្តីស្មើគ្នា ( របស់សត្វទាំង ២ ) ក្នុងសត្វញីទាំងឡាយមិនមាន ក្នុងចំណីអាហារទាំងឡាយក៏មិនមានដែរ អ្នកចូរមើលគំនិតរបស់ចចក អ្នកបំបែកនូវតំណនៃមិត្តនោះ គិតមើលឲ្យល្អចុះ ។

[ ៦៩៥ ] ពួកម្រឹគអធម៌ ( ចចក ) ស៊ីគោផង ស៊ីសីហៈផង ព្រោះសេចក្តីញុះញង់ណា សេចក្តីញុះញង់នោះ រមែងប្រែប្រួល ដូចជាដាវមុតក្នុងសាច់ ។

[ ៦៩៦ ] ម្នាលសារថី អ្នកឃើញកិរិយាដេកស្លាប់ ( នៃសត្វទាំង ២ ) នេះ បុគ្គលណាជឿពាក្យរបស់បុគ្គលអ្នកញុះញង់បំបែកនូវតំណនៃមិត្ត បុគ្គលនោះរមែងដេកស្លាប់យ៉ាងនេះ ( ពុំខាន ) ។

[ ៦៩៧ ] ម្នាលសារថី ពួកជនណាមិនជឿពាក្យញុះញង់របស់អ្នកបំបែកនូវតំណនៃមិត្ត ពួកជននោះតែងបាននូវសេចក្តីសុខ ដូចជាពួកនរជនអ្នកទៅកើតក្នុងឋានសួគ៌ដូច្នោះ ។

**ចប់ សន្ធិភេទជាតកទី ៩ ។**

# អដ្ឋកថា

# សន្ធិភេទជាតក

[ ៦៩៤-៦៩៧ ] ព្រះសាស្តាកាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធបេសុញ្ញសិក្ខាបទ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នេវ ឥត្ថីសុ សាមញ្ញំ** ដូច្នេះជាដើម ។

បានឮថា សម័យមួយ ព្រះសាស្តាទ្រង់បានឮថាឆព្វគ្គិយភិក្ខុនាំនូវការញុះញង់ចូលទៅឲ្យ ទើបត្រាស់ឲ្យហៅឆព្វគ្គិយភិក្ខុទាំងនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកនាំនូវការញុះញង់ ចូលទៅឲ្យដល់ពួកភិក្ខុដែលទាស់ទែងគ្នា វិវាទគ្នាពិតឬ ព្រោះហេតុនោះ ជម្លោះដែលមិនទាន់កើតឡើង ក៏កើតឡើង និងជម្លោះដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើនក្រៃលែងឡើងទៀត កាលពួកឆព្វគ្គិយភិក្ខុ ទទួលថាពិតហើយព្រះអង្គ ទើបទ្រង់តិះដៀលភិក្ខុទាំងនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាវាចាញុះញង់ ខ្លាំងក្លាដូចប្រហារដោយសស្ត្រា ទោះបីភាពស្និទ្ធស្នាលដែលជាប់ស្អិត ក៏គង់បែកធ្លាយទៅ ដោយឆាប់រហ័សព្រោះវាចាញុះញង់នោះ កាលបុគ្គលកាន់យកវាចាស៊កសៀតនោះ ហើយទម្លាយនូវមេត្រីរបស់ខ្លួនចោល រមែងដូចគ្នានឹងរាជសីហ៍និងគោបានោះឯង ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វជាឱរស របស់ព្រះបាទពារាណសីនោះ ចម្រើនវ័យហើយរៀនសិប្បៈក្នុងនគរតក្កសិលាចប់ហើយ កាលព្រះបិតាសោយទិវង្គត បានគ្រង

រាជសម្បត្តិដោយធម៌ ។ កាលនោះនាយគោបាលម្នាក់ ចិញ្ចឹមគោទាំងឡាយ ក្នុងត្រកូលទាំងឡាយ កាលនឹងមកអំពីព្រៃ ក៏ទុកចោលមេមួយដែលផើម ព្រោះមិនបានចាប់ភ្លឹក ហើយទៅ មេគោនោះ កើតសេចក្តីស្និទ្ធស្នាល ជាមួយមេរាជសីហ៍មួយ ។ មេគោនិងមេរាជសីហ៍ទាំងនោះ ជាមិត្តយ៉ាងមាំត្រាច់ទៅជាមួយគ្នា ។ ចំណេរកាលតមក មេគោក៏កើតកូនគោ មេរាជសីហ៍ក៏កើតកូនរាជសីហ៍ កូនគោនិងកូនរាជសីហ៍ទាំងពីរនោះ ក៏បានជាមិត្តនឹងគ្នាយ៉ាងជិតស្និទ្ធ ព្រោះមេត្រីដែលមានមកដោយត្រកូល ទើបត្រាច់ទៅជាមួយគ្នា ។ គ្រានោះព្រានព្រៃម្នាក់ចូលព្រៃឃើញសត្វទាំងពីរនោះស្និទ្ធស្នាលគ្នា ទើបកាន់យករបស់ដែលកើតក្នុងព្រៃ ហើយទៅក្រុងពារាណសី ថ្វាយដល់ព្រះរាជា កាលព្រះរាជាត្រាស់សួរថា នែសម្លាញ់ អ្នកធ្លាប់ឃើញសេចក្តីអស្ចារ្យណាមួយក្នុងព្រៃដែរឬទេ ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនបានឃើញអ្វីដទៃឡើយ តែបានឃើញរាជសីហ៍មួយ និងគោឈ្មោលមួយ ស្និទ្ធស្នាលនឹងគ្នា ត្រាច់ទៅជាមួយគ្នា ។ ព្រះរាជាត្រាស់ថា កាលសត្វទី ៣ កើតឡើងដល់សត្វទាំងពីរនោះភ័យនឹងកើតមាន កាលណាអ្នកឃើញសត្វទី ៣ បន្ថែមឡើងដល់សត្វទាំងពីរនោះ កាលណោះ អ្នកគប្បីប្រាប់យើង ។ នាយព្រានព្រៃនោះទូលទទួលថា ករុណាថ្លៃវិសេស ។ កាលព្រានព្រៃទៅនគរពារាណសីហើយ មានចចកមួយចូលទៅបម្រើរាជសីហ៍និងគោ ។ ព្រានព្រៃទៅព្រៃបានឃើញចចកនោះគិតថា នឹងក្រាបទូលភាពដែលសត្វទី ៣ កើតឡើងហើយដល់ព្រះរាជា ទើបបានទៅកាន់នគរពារាណសី ។ ចចកគិតថា

វៀរសាច់រាជសីហ៍និងសាច់គោចេញហើយ ឈ្មោះថាសាច់ដទៃដែលអញមិនធ្លាប់ស៊ីមិនមាន អញនឹងញុះញង់សត្វទាំងពីរនោះហើយស៊ីសាច់ ។ ទើបចចកនោះបំបែកបំបាក់សត្វទាំងពីរនោះឲ្យបែកគ្នានឹងគ្នាដោយពោលថា បុគ្គលនេះពោលយ៉ាងនេះនឹងអ្នក បុគ្គលនេះពោលយ៉ាងនេះនឹងអ្នក មិនយូរប៉ុន្មាន ក៏ធ្វើឲ្យដល់នូវការស្លាប់ព្រោះឈ្លោះគ្នា ។ ព្រានព្រៃមកដល់ហើយក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព សត្វទី ៣ កើតឡើងហើយដល់រាជសីហ៍និងគោទាំងនោះ ព្រះរាជាត្រាស់សួរថា សត្វទី ៣ នោះគឺអ្វី ព្រានព្រៃក្រាបទូលថា បពិត្រព្រះអង្គ គឺឆ្កែចចក ។ ព្រះរាជាត្រាស់ថា ចចកនឹងញុះញង់បំបែកសត្វទាំងពីរនោះឲ្យស្លាប់ ពួកយើងនឹងទៅឲ្យទាន់ក្នុងពេលសត្វទាំងពីរនោះស្លាប់ ទើបទ្រង់ឡើងរាជរថ ទៅតាមផ្លូវដែលព្រានព្រៃចង្អុលបង្ហាញព្រះរាជាទៅទាន់ក្នុងកាលសត្វទាំងពីរនោះ ធ្វើនូវការឈ្លោះគ្នា ហើយដល់នូវការអស់ជីវិត ។ ចចកមានចិត្តត្រេកអរស៊ីសាច់រាជសីហ៍ម្តង ស៊ីសាច់គោម្តង ។ ព្រះរាជាឃើញសត្វទាំងពីរនោះដល់នូវការអស់ជីវិត ទ្រង់ប្រថាប់ឈរលើរថនោះឯង កាលចរចានឹងនាយសារថី ទើបត្រាស់គាថាទាំងនេះថា

ម្នាលសារថី សេចក្តីស្នេហ៍គ្នា ( របស់សត្វទាំង ២ ) ក្នុងសត្វញីទាំងឡាយមិនមាន ក្នុងចំណីអាហារទាំងឡាយ ក៏មិនមានដែរ អ្នកចូរមើលគំនិតរបស់ចចក អ្នកបំបែកនូវតំណនៃមិត្តនោះ គិតមើលឲ្យល្អចុះ ។

ពួកម្រឹគអធម៌ ( ចចក ) ស៊ីគោផង ស៊ីសីហៈផង ព្រោះ

សេចក្តីញុះញង់ណា សេចក្តីញុះញង់នោះ រមែងប្រែប្រួលដូច ជាដាវមុតក្នុងសាច់ ។

ម្នាលសារថី អ្នកឃើញកិរិយាដេកស្លាប់ ( នៃសត្វទាំង ២ ) នេះ បុគ្គលណា ជឿពាក្យរបស់បុគ្គលអ្នកញុះញង់ បំបែកនូវ តំណនៃមិត្ត បុគ្គលនោះរមែងដេកស្លាប់យ៉ាងនេះ ( ពុំខាន ) ។

ម្នាលសារថី ពួកជនណា មិនជឿពាក្យញុះញង់របស់អ្នក បំបែកនូវតំណនៃមិត្ត ពួកជននោះតែងបាននូវសេចក្តីសុខដូច ជាពួកនរជនអ្នកទៅកើតក្នុងឋានសួគ៌ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **នេវ ឥត្ថីសុ** សេចក្តីថា នៃសារថីសម្លាញ់ សត្វទាំងពីរនេះ មិនមានការស្មើគ្នាក្នុងញី និងក្នុងអាហារ ព្រោះរាជសីហ៍រមែង សេពញីដោយឡែក គោសេពញីដោយឡែក គឺម្នាក់ម្យ៉ាង ម្យ៉ាងទៀតរាជសីហ៍ រមែងបរិភោគកិច្ចាហារម្យ៉ាង គោរមែងបរិភោគកិច្ចាហារម្យ៉ាង មិនដូចគ្នា ។ ក្នុងបទថា **អថស្ស** នេះ មានអធិប្បាយថា កាលហេតុដែលធ្វើឲ្យឈ្មោះគ្នា សូម្បីមិនមានយ៉ាងនេះ ក្រោយមកចចកជាតិអាក្រក់នេះ ទម្លាយនូវសេចក្តី ស្និទ្ធស្នាលជាមិត្ត គិតថានឹងស៊ីសាច់របស់សត្វទាំងពីរ ទើបសម្លាប់សត្វ ទាំងពីរនេះ អ្នកចូរឃើញដូចដែលយើងគិតទុកល្អហើយ ។ ក្នុងបទថា **យត្ថ** នេះ លោកសម្តែងសេចក្តីថា កាលការញុះញង់ណាប្រព្រឹត្តទៅ ពួកក្អែចចក ដែលសម្លាប់ម្រឹគរមែងទំពាស៊ីគោនិងរាជសីហ៍ ការញុះញង់នោះរមែងកាត់មិត្ត ភាព ដូចដាវដែលមុតក្នុងសាច់ដូច្នោះ ។ ដោយបទថា **យមិមំ បស្សសិ** នេះ

លោកសម្តែងថា នៃសារបីសម្លាញ់ ចូរអ្នកមើលនូវការដេកស្លាប់របស់សត្វទាំងពីរនេះបុគ្គលដទៃណាជឿហើយ កាន់យកវាចាញុះញង់របស់អ្នកញុះញង់ដែលទម្លាយនូវការស្និទ្ធស្នាល បុគ្គលនោះរមែងដេកដូច្នេះ គឺស្លាប់យ៉ាងនេះឯង ។ បទថា **សុខមេធន្តិ** សេចក្តីថា រមែងជួប គឺបាននូវសេចក្តីសុខ ។ បទថា **នរា សគ្គគតារិវ** សេចក្តីថា ជនទាំងនោះរមែងជួបនូវសុខ ដូចនរជនដែលទៅកាន់ឋានសួគ៌ ដល់ព្រមដោយភោគៈដែលជាទិព្វដូច្នោះ ។ បទថា **នាវពោធន្តិ** សេចក្តីថា រមែងសង្រួមរវាំងចាកវត្ថុដែលមិនមែនសារៈ គឺបានស្តាប់ពាក្យបែបនេះហើយ ក៏ធ្វើឲ្យសិក្សា មិនទម្លាយមេត្រី តាំងនៅតាមប្រក្រតីដើម ។

ព្រះរាជាត្រាស់គាថានេះហើយ ទើបឲ្យកាន់យក កេសរ ស្បែក ក្រចក និងចង្កូមរបស់កេសរសីហរាជ ហើយយាងទៅកាន់ព្រះនគរនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សន្ធិភេទជាតក ចប់

# ទេវតាបញ្ហជាតក

[ ៦៩៨ ] ( ទេវតាសួរថា ) បុគ្គលណា ប្រហារដោយដៃទាំង ២ ផង ដោយជើងទាំង ២ ផង ប្រហារនូវមាត់ផង បពិត្រមហារាជ បុគ្គលនោះជាទីស្រឡាញ់នៃគេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

[ ៦៩៩ ] បុគ្គលណា ជេរប្រទេច តាមសេចក្ដីប្រាថ្នា តែមិនប្រាថ្នានូវការមកដល់បុគ្គលនោះ បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

[ ៧០០ ] បុគ្គលណា ពោលបង្កាច់ដោយពាក្យមិនពិត ប្រកាសប្រាប់ឲ្យព្រួដោយពាក្យឡូឡា បពិត្រមហារាជ បុគ្គលនោះជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

[ ៧០១ ] ពួកអ្នកនាំយកទៅ បាននាំយកបាយផង ទឹកផង សំពត់និងសេនាសនៈទាំងឡាយផង ដោយពិត បពិត្រមហារាជ ពួកអ្នកនាំយកទៅនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

**ចប់ ទេវតាបញ្ហជាតកទី ១០ ។**

**ចប់ ចុល្លកុណាលវគ្គទី ៥ ។**

### ឧទ្ទាននៃចុល្លកុណាលវគ្គនោះគឺ

និយាយអំពីស្រីធ្វើសេចក្ដីត្រេកអរ ដល់ពួកបុរស ១ ព្រះពោធិសត្វបានរើខ្លួន ១ មេក្រៀលនៅក្នុងសំណាក់ស្ដេច ១ វត្ថុធ្វើសក់ឲ្យខ្មៅ ១ ភ្លើងដ៏ប្រសើរ ១ រសទាំងឡាយ ១

ញញួរដែកដ៏ប្រសើរ ១ ការចេញអំពីព្រៃ ១ នាយសារថី ១ ប្រហារដោយដៃ ១ ត្រូវជា ១០ ។

**ឧទ្ទាននៃវគ្គក្នុងចតុក្កនិបាតនោះគឺ**

កាលិង្គវគ្គ ១ បុចិមន្ទវគ្គ ១ កុដិទូសកវគ្គ ១ កោកិលវគ្គ ១ ចុល្លកុណាលវគ្គគម្រប់ជា ៥ លោកសម្ដែងល្អហើយ ។

**ចប់ ចតុក្កនិបាត ។**

# អដ្ឋកថា

## ទេវតាបញ្ហជាតក

[ ៦៩៨-៧០១ ] ការបុច្ឆារបស់ទេវតានេះ មានពាក្យផ្ដើមថា **ហន្តិ ហត្ថេហិ បាទេហិ** ដូច្នេះជាដើម នឹងមានជាក់ច្បាស់ក្នុង មហាឧម្មង្គជាតក ( មហោសធជាតក ) ដូច្នេះ ។

*ទេវតាបញ្ហជាតក ចប់*

*ចុល្លកុណាលវគ្គ ចប់*

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ជាតក

# អដ្ឋមភាគ

# បញ្ចកនិបាតជាតក

# មណិកុណ្ឌលវគ្គ

## មណិកុណ្ឌលជាតក

[ ១ ] ( ព្រះរាជាកោសលពោលថា ) ព្រះអង្គសាបសូន្យចាកដែនសេះ កែវមណីនិងកុណ្ឌល សាបសូន្យចាកបុត្តនិងកិរិយាដូច្នោះដែរ កាលបើភោគទាំងអស់ មិនមានសេសសល់ទេ តើហេតុអ្វី ទើបព្រះអង្គមិនក្តៅក្រហាយក្នុងកាលដែលគួរសោកស្តាយ ។

[ ២ ] ( ព្រះរាជាពោធិសត្វពោលថា ) ភោគៈទាំងឡាយ លះបង់សត្វមុនក៏មាន សត្វលះបង់ភោគៈទាំងនោះមុនក៏មាន បពិត្រព្រះអង្គទ្រង់ប្រាថ្នាកាម ជនអ្នកមានភោគៈទាំងឡាយមិនទៀងទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។

[ ៣ ] ព្រះចន្ទរមែងរះឡើងពេញវង់រួចអស់ទៅ ព្រះអាទិត្យ ក៏អស្តង្គតទៅដូចគ្នា បពិត្រស្តេចជាសត្រូវ ពួកលោកធម៌ខ្ញុំឈ្នះហើយ ព្រោះហេតុនោះទើបខ្ញុំមិនសោកស្តាយក្នុងកាលដែលគួរសោកស្តាយ ។

[ ៤ ] គ្រហស្ថអ្នកបរិភោគកាមជាអ្នកខ្ជិលច្រអូសមិនល្អ បព្វជិតមិន

សង្រ្គមមិនល្អ ព្រះរាជាមិនបានពិចារណាមុនហើយធ្វើមិនល្អ បណ្ឌិតអ្នកច្រើន ក្រោធមិនល្អទេ ។

[ ៥ ] បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រគប្បីពិចារណា ហើយសឹមធ្វើ មិនគប្បីធ្វើទាំងមិនបានពិចារណាទេ យសក្តី កិត្តិគុណក្តី រមែងចម្រើនដល់ព្រះរាជាដែលពិចារណាហើយទើបធ្វើ ។

## ចប់ មណិកុណ្ឌលជាតកទី ១ ។

# បញ្ចកនិបាត ជាតក

## មណិកុណ្ឌលវគ្គ

### អដ្ឋកថា មណិកុណ្ឌលជាតក

[ ១-៥ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាមាត្យអាក្រក់ដែលសម្រេចប្រយោជន៍ទាំងពួង ខាងក្នុងព្រះរាជវាំង របស់ព្រះបាទកោសល ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ជិណ្ណោ រដ្ឋស្ស-មណិកុណ្ឌលេ ច** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នបានឲ្យពិស្តារទុកហើយខាងដើមនោះឯង ។ ចំណែកក្នុងជាតកនេះ ព្រះពោធិសត្វបានជាព្រះបាទពារាណសី ។ អាមាត្យអាក្រក់ នាំព្រះបាទកោសលមកដណ្តើមយកកាសិករដ្ឋ ចាប់ព្រះបាទពារាណសីដាក់ក្នុងគុក ព្រះបាទពារាណសីធ្វើឈានឲ្យកើតឡើងហើយ អង្គុយពត់ភ្នែនក្នុងអាកាស ។ ការក្តៅក្រហាយកើតឡើងក្នុងរាងកាយរបស់ចោររាជ ។ ចោររាជនោះចូលទៅរកព្រះបាទពារាណសី ហើយពោលគាថាទី ១ ថា

> ព្រះអង្គសាបសូន្យចាកដែន សេះ កែវមណីនិងកុណ្ឌល សាប
> សូន្យចាកបុត្តនិងភរិយាដូច្នោះដែរ កាលបើភោគទាំងអស់មិន
> មានសេសសល់ទេ តើហេតុអ្វីទើបព្រះអង្គមិនក្តៅក្រហាយក្នុង
> កាលដែលគួរសោកស្តាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជីនោ រថស្សំ មណិកុណ្ឌលេ ច** សេចក្តីថា បពិត្រមហារាជ ទ្រង់លះបង់នូវរថ សេះនិងកុណ្ឌលកែវមណីទាំងឡាយ ។

បាលីថា **ជីនោ រដ្ឋស្ស ច មណិកុណ្ឌលេ ច** ដូច្នេះក៏មាន ។ បទថា **អ-សេសកេសុ** បានដល់ មិនសេសសល់ឡើយ ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះទើបពោលគាថា ២ ថា

*ភោគៈទាំងឡាយលះបង់សត្វមុនក៏មាន សត្វលះបង់ភោគៈទាំងនោះមុនក៏មាន បពិត្រព្រះអង្គទ្រង់ប្រាថ្នាកាម ជនអ្នកមានភោគៈទាំងឡាយមិនទៀងទេ ព្រោះហេតុនោះទើបខ្ញុំមិនសោកស្តាយក្នុងកាលដែលគួរសោកស្តាយ ។*

*ព្រះចន្ទរមែងរះឡើងពេញវង់ រួចអស់ទៅ ព្រះអាទិត្យក៏អស្តង្គតទៅដូចគ្នា បពិត្រស្តេចជាសត្រូវ ពួកលោកធម៌ ខ្ញុំឈ្នះហើយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយក្នុងកាលដែលគួរសោកស្តាយ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **បុព្វេ មច្ចំ** សេចក្តីថា ភោគៈទាំងឡាយរមែងលះបង់សត្វទៅក្នុងខាងដើម គឺមុនខ្លះ សត្វរមែងលះបង់ភោគៈទាំងនោះទៅមុនខ្លះ ។ ព្រះពោធិសត្វហៅចោររាជថា **កាមកាមិ** អធិប្បាយថា ទ្រង់ជាអ្នកប្រាថ្នាកាមទាំងឡាយ ឈ្មោះថា **កាមកាមិ** ធម្មតា បុគ្គលដែលមានភោគៈជាអ្នកមិនទៀងទាត់ក្នុងលោក គឺកាលភោគៈទាំងឡាយវិនាសទៅហើយ ទោះបីមានជីវិត ក៏ជាអ្នកមិនមានភោគៈ ឬបុគ្គលលះបង់ភោគៈទៅឯង ព្រោះហេតុនោះ ទើបខ្ញុំមិនសោយសោក ក្នុងកាលមហាជនសោយសោក ។ ព្រះពោធិសត្វហៅចោររាជដោយពាក្យថា បពិត្រស្តេចជាសត្រូវ ពួកលោកធម៌

ខ្ញុំឈ្នះហើយ ដូច្នេះ អធិប្បាយថា បពិត្រព្រះអង្គជាសត្រូវ លោកធម៌ទាំងឡាយដូចជា មានលាភ វិនាសលាភ មានយស វិនាសយស ខ្ញុំឈ្នះហើយ ដូចព្រះចន្ទរះឡើងពេញវង់ ហើយត្រឡប់អស់ទៅយ៉ាងណា និងដូចព្រះអាទិត្យកម្ចាត់នូវងងឹត ធ្វើភូមិភាគរបស់លោកសន្និវាសដ៏ធំឲ្យក្តៅ ហើយក៏តាំងនៅមិនបាន គឺអស្តង្គត មិនប្រាកដក្នុងពេលល្ងាចយ៉ាងណា ភោគសម្បត្តិទាំងឡាយ ក៏យ៉ាងនេះដូចគ្នា រមែងកើតឡើង និងរមែងវិនាសទៅ ប្រយោជន៍អ្វីដោយសេចក្តីសោកក្នុងរឿងនោះ ព្រោះដូច្នោះ ទើបខ្ញុំមិន សោយសោក ។ ព្រះមហាសត្វសម្តែងធម៌ដល់ចោររាជយ៉ាងនោះហើយ ឥឡូវនេះកាលនឹងតិះដៀលចោររាជនោះ ទើបពោលថា

គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូសមិនល្អ បព្វជិត
មិនសង្រួមមិនល្អ ព្រះរាជាមិនបានពិចារណាមុនហើយធ្វើមិន
ល្អ បណ្ឌិតអ្នកច្រើនក្រោធមិនល្អទេ ។

បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រគប្បីពិចារណាហើយ
សឹមធ្វើ មិនគប្បីធ្វើទាំងមិនបានពិចារណាទេ យសក្តី កិត្តិ
គុណក្តី រមែងចម្រើនដល់ព្រះរាជា ដែលពិចារណាហើយទើប
ធ្វើ ដូច្នេះ ។

គាថាទាំង ២ នេះ បានពណ៌នាឲ្យពិស្តារខាងដើមហើយ ។

ចោររាជសូមខមាទោសព្រះពោធិសត្វហើយ ប្រគល់រាជសម្បត្តិឲ្យវិញ យាងទៅកាន់ជនបទរបស់ទ្រង់នោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបាទកោសលក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកព្រះបាទពារាណសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មណិកុណ្ឌលជាតក ចប់

# សុជាតជាតក

[ ៦ ] ( បិតារបស់ពោធិសត្វពោលថា ) អ្នករលះរលាំងទៅប្រូតស្មៅស្រស់ ហើយនិយាយនឹងគោចាស់ដែលមានជីវិតបាត់បង់ទៅ ហើយថា ឯងស៊ីទៅ ឯងស៊ីទៅ ដូចម្ដេចកើត គោស្លាប់ហើយមិនគប្បីក្រោកឡើងបាន ព្រោះគ្រឿងស៊ីនិងគ្រឿងផឹកទេ អ្នករវើរវាយទទេ ដូចជាមនុស្សល្ងង់ខ្លៅ ។

[ ៧ ] ( សុជាតមាណពជាបុត្តពោលថា ) ក្បាលក៏តាំងនៅដដែល ដៃ ជើង កន្ទុយនិងត្រចៀកក៏តាំងនៅដដែលដែរ ខ្ញុំសម្គាល់ថា គោនៅក្រោកឡើងបាន ត្រង់ក្បាល ដៃ ជើង របស់ជីតាមិនប្រាកដទេ ឪពុកយំទួញជិតស្តូបដែលធ្វើដោយដីស្អិត មិនមែនជាអ្នកល្ងង់ខ្លៅទេឬ ។

[ ៨ ] ( បិតាពោលថា ) អ្នកបានស្រោចស្រពនូវខ្ញុំដែលក្ដៅគឺសេចក្ដីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្ដីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលស្រោចភ្លើងដែលឆេះឆ្នាំងខ្លាញ់ដោយទឹក សរគឺសេចក្ដីសោក ដែលអាស្រ័យនូវហឫទ័យរបស់យើង អ្នកដកចេញហើយ អ្នកបានបន្ទោបង់នូវសេចក្ដីសោកក្នុងបិតានៃយើង ដែលមានសេចក្ដីសោកបៀតបៀនហើយ ។

[ ៩ ] ខ្ញុំនោះមានសរដកចេញហើយ ជាអ្នកប្រាសចាកសេចក្ដីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោក លែងយំ ព្រោះបានស្តាប់ពាក្យរបស់អ្នក ។

[ ១០ ] ពួកជនណាប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ ( ដោះទុក្ខ ) រមែងធ្វើយ៉ាងនេះ រមែងដោះ ( បុគ្គលដទៃ ) ចេញចាកសេចក្ដីសោក ដូចសុជាតមាណព ដោះបិតាចាកសេចក្ដីទុក្ខសោក ។

**ចប់ សុជាតជាតកទី ២ ។**

# អដ្ឋកថា

# សុជាតជាតក

[ ៦-១០ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈដែលបិតាស្លាប់ ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្ដើមថា **កិន្នុ សន្តរមានោវ** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈនោះកាលបិតាស្លាប់ហើយ ត្រាច់បរិទេវនាការ មិនអាចបន្ទោបង់សេចក្ដីសោកបាន ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ឃើញឧបនិស្ស័យសោតាបត្តិផលរបស់កុដុម្ពិកៈនោះ ទ្រង់នាំបច្ឆាសមណៈយាងទៅបិណ្ឌបាតក្នុងនគរសាវត្ថី យាងទៅដល់ផ្ទះរបស់កុដុម្ពិកៈនោះ គង់លើអាសនៈដែលគេក្រាលទុក ទើបត្រាស់នឹងកុដុម្ពិកៈនោះដែលនមស្ការហើយ អង្គុយក្នុងទីសមគួរថា ឧបាសក អ្នកសោយសោកឬ កុដុម្ពិកៈក្រាបទូលថា ករុណាព្រះអង្គ ទើបព្រះសាស្ដាត្រាស់ថា អាវុសោ បោរាណកបណ្ឌិតទាំងឡាយ ស្ដាប់ពាក្យរបស់បណ្ឌិតទាំងឡាយហើយ កាលបិតាស្លាប់ មិនសោយសោកឡើយ ។ កាលកុដុម្ពិកៈទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទះរបស់កុដុម្ពិកៈ ញាតិទាំងឡាយបានដាក់ឈ្មោះរបស់ព្រះពោធិសត្វថា សុជាតកុមារ ។ កាលសុជាតកុមារនោះចម្រើនវ័យហើយ ជីតាបានធ្វើកាលកិរិយាទៅ ។ លំដាប់នោះ ឪពុករបស់សុជាតកុមារនោះក៏

ចម្រើនដោយសេចក្តីសោក ចាប់តាំងពីកាលបិតាធ្វើកាលកិរិយា ទើបទៅកាន់ព្រៃខ្មោចនាំឆ្អឹងមកអំពីព្រៃ សាងស្តូបដីទុកក្នុងចម្ការរបស់ខ្លួន ហើយកប់ឆ្អឹងទាំងនោះក្នុងចម្ការនោះ ឲ្យពេលវេលាកន្លងទៅ បានបូជាស្តូបដោយផ្កាទាំងឡាយ ដើរធ្វេលចេតិយយំរៀបរាប់ មិនងូតទឹក មិនលាបស្រឡាប មិនបរិភោគ មិនចាត់ចែងការងារទាំងពួង ។ ព្រះពោធិសត្វឃើញដូច្នោះ ទើបគិតថា បិតារបស់អញ តាំងពីកាលជីតាស្លាប់ទៅហើយ ត្រូវសេចក្តីសោកគ្របសង្កត់មិនមានទីបំផុត វៀរអាត្មាអញហើយ អ្នកដទៃមិនអាចធ្វើបិតានេះឲ្យដឹងខ្លួនបាន អញនឹងធ្វើបិតានោះឲ្យអស់សេចក្តីសោក ដោយឧបាយឯណាមួយ បានឃើញគោងាប់មួយខាងក្រៅស្រុក ទើបនាំស្មៅនិងទឹកផឹកមកទុកខាងមុខគោងាប់នោះ ហើយពោលថា ចូរស៊ី ចូរស៊ី ចូរផឹក ចូរផឹក ។ ពួកជនដែលឆ្លងទៅមកបានឃើញដូច្នោះ នាំគ្នាពោលថា សុជាតសម្លាញ់ អ្នកឆ្កួតទៅហើយឬ ទើបអ្នកឲ្យស្មៅនិងទឹកដល់គោងាប់ ។ សុជាតកុមារនោះមិនបានពោលជាមួយអ្នកណាឡើយ ។ លំដាប់នោះ ជនទាំងឡាយ ក៏ទៅកាន់សម្នាក់បិតា របស់សុជាតកុមារនោះ ហើយពោលថា បុត្តរបស់អ្នកឆ្កួតទៅហើយ ឲ្យស្មៅនិងទឹកដល់គោងាប់ ។ ព្រោះបានស្តាប់ពាក្យរបស់ជនទាំងឡាយនោះ សេចក្តីសោកព្រោះឪពុករបស់កុដុម្ពិកៈ ក៏បាត់ទៅ សេចក្តីសោកព្រោះបុត្តត្រឡប់តាំងនៅ ទើបកុដុម្ពិកៈនោះ ប្រញាប់មកពោលថា បាសុជាតបាជាបណ្ឌិតមិនមែនឬ ព្រោះហេតុអ្វី ទើបឲ្យស្មៅនិងទឹកដល់គោងាប់ ហើយពោលគាថា ២ ថា

អ្នករលះរលាំង ទៅប្រូតស្មៅស្រស់ហើយនិយាយនឹងគោ
ចាស់ដែលមានជីវិតបាត់បង់ទៅហើយថា ឯងស៊ីទៅ ឯងស៊ី
ទៅ ដូចម្ដេចកើត គោស្លាប់ហើយមិនគប្បីក្រោកឡើងបាន
ព្រោះគ្រឿងស៊ី និងគ្រឿងផឹកទេ អ្នករវើរវាយទទេ ដូចជា
មនុស្សល្ងង់ខ្លៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សន្តរមានោវ** សេចក្ដីថា ដូចជាប្រញាប់ប្រញាល ។ បទថា **លាយិត្វា** បានដល់ ប្រូតហើយ ។ បទថា **លបសិ** បានដល់ រវើរវាយហើយ ។ បទថា **គតសត្តំ ជរគ្គវំ** បានដល់ គោចាស់ដែលប្រាសចាកជីវិត ។ បទថា **តំ** ក្នុងបទថា **យថាតំ** ត្រឹមតែជានិបាត ។ អធិប្បាយថា បុគ្គលដែលមិនមានការគិត គឺមានបញ្ញាតិច គប្បីរវើរវាយផ្ដេសផ្ដាសយ៉ាងណា ឯងក៏រវើរវាយទទេៗ គឺមិនពិតដូច្នោះ ។ លំដាប់នោះ ព្រះពោធិសត្វបានពោលគាថា ២ ថា

ក្បាលក៏តាំងនៅដដែល ដៃ ជើង កន្ទុយនិងត្រចៀកក៏តាំង
នៅដដែលដែរ ខ្ញុំសម្គាល់ថា គោនៅក្រោកឡើងបាន ត្រង់
ក្បាល ដៃ ជើង របស់ជីតាមិនប្រាកដទេ ឪពុកយំទួញជិត
ស្តូបដែលធ្វើដោយដីស្អិត មិនមែនជាអ្នកល្ងង់ខ្លៅទេឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តថេវ** សេចក្ដីថា នៅតាំងនៅដូចកាលមុន ។ បទថា **មញ្ញេ** សេចក្ដីថា ខ្ញុំសម្គាល់ថា គោនេះនឹងក្រោកឡើង ព្រោះអវយវៈមានក្បាលជាដើម តាំងនៅដូចដើមយ៉ាងនោះ ។ បទថា **នេវយ្យកស្ស សីសំ**

សេចក្តីថា ចំណែកក្បាល ដៃ និងជើងរបស់ជីតាមិនប្រាកដ ។ បាលីថា **បិដ្ឋិចាធា ន ធិស្សរេ** ដូច្នេះក៏មាន ។ បទថា **ឆន្ទុ ត្វញ្ញោវ ឧម្មតិ** សេចក្តីថា ខាងដើម ខ្ញុំឃើញក្បាលជាដើម ទើបធ្វើយ៉ាងនោះ ចំណែកលោកឪពុកមិនឃើញអ្វីសោះ បាននាំធ្នឹងអំពីឈាបនដ្ឋានសាងស្តូបដី ( ផ្នូរ ) យំរៀបរាប់បើប្រៀបធៀបនឹងខ្ញុំ លោកឪពុកនោះឯង ជាអ្នកគ្មានការគិត មួយរយដងមួយពាន់ដង មួយសែនដង មិនមែនឬ ព្រោះហេតុនោះ សង្ខារទាំងឡាយឈ្មោះថាមានការបែកធ្លាយទៅជាធម្មតា រមែងបែកធ្លាយទៅ ចាំបាច់កន្ទក់កន្ទេញថ្វីក្នុងសេចក្តីនោះ ។

បិតារបស់ព្រះពោធិសត្វ បានស្តាប់ដូច្នោះ ទើបគិតថា បុត្តរបស់យើងជាបណ្ឌិត ដឹងកិច្ចក្នុងលោកនេះនិងលោកខាងមុខ បានធ្វើកម្មនេះ ដើម្បីឲ្យអាត្មាអញដឹងបានឯង ទើបពោលថា សុជាតបណ្ឌិត អាពុកដឹងហើយថាសង្ខារទាំងពួងមិនទៀង បន្ទាប់អំពីនេះទៅពុកមិនសោយសោក ឈ្មោះថាកូននាំសេចក្តីសោករបស់បិតាចេញទៅបាន គប្បីជាបុគ្គលដូចរូបអ្នក កាលធ្វើនូវការសរសើរបុត្តក៏ពោលគាថាថា

> អ្នកបានស្រោចស្រពនូវខ្ញុំ ដែលភ្លើងគឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ ក្រវាយទាំងអស់ឲ្យរលត់ដូចបុគ្គលស្រោចភ្លើងដែលឆេះឆ្នាំងខ្លាញ់ដោយទឹក សរគឺសេចក្តីសោកដែលអាស្រ័យនូវហឫទ័យរបស់យើង អ្នកដកចេញហើយ អ្នកបានបន្ទោបង់នូវសេចក្តីសោកក្នុងបិតានៃយើង

ដែលមានសេចក្ដីសោកបៀតបៀនហើយ ។

ខ្ញុំនោះ មានសរដកចេញហើយ ជាអ្នកប្រាសចាកសេចក្ដីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោក លែងយំ ព្រោះបានស្ដាប់ពាក្យរបស់អ្នក ។

ពួកជនណាប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ ( ដោះទុក្ខ ) រមែងធ្វើយ៉ាងនេះ រមែងដោះ ( បុគ្គលដទៃ ) ចេញចាកសេចក្ដីសោក ដូចសុជាតមាណពដោះបិតាចាកសេចក្ដីទុក្ខសោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និព្វាបយេ** បានដល់ ឲ្យរលត់ហើយ ។ បទថា **ទរំ** បានដល់ សេចក្ដីក្រវល់ក្រវាយ ព្រោះសេចក្ដីសោក ។ បទថា **សុជាតោ បិតរំ យថា** សេចក្ដីថា សុជាតបុត្តរបស់យើងធ្វើយើងជាបិតាឲ្យផុតចាកសេចក្ដីសោក ព្រោះភាពដែលខ្លួនជាអ្នកមានបញ្ញាយ៉ាងណា សូម្បីអ្នកដទៃដែលមានបញ្ញា ក៏រមែងធ្វើអ្នកដទៃ ឲ្យផុតចាកសេចក្ដីសោកយ៉ាងនោះ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈតាំងនៅក្នុងសោតាបត្តិផលហើយទ្រង់ប្រជុំជាតកថា សុជាតកុមារក្នុងកាលនោះគឺតថាគតនេះឯង ។

**អដ្ឋកថាសុជាតជាតក ចប់**

# វេឡសាខជាតក

[ ១១ ] ( *អាចារ្យទិសាបាមោក្ខពោធិសត្វពោលថា* ) ម្នាលព្រហ្មទត្តកុមារ សេចក្តីក្រេមក្សាន្តក្តី កិច្ចាដ៏សម្បូរក្តី សេចក្តីសុខក្នុងកាយក្តី នេះមិនគប្បីមានជានិច្ចទេ ( កាលបើឥស្សរភាពវិនាស ) ក្នុងកាលជាទីកន្ទងនៃប្រយោជន៍ អ្នកកុំវង្វេងជ្រប់ដូចបុគ្គលដែលបែកធ្លាយនាវាក្នុងកណ្តាលសាគរ ។

[ ១២ ] បុរសធ្វើនូវអំពើទាំងឡាយ រមែងឃើញនូវអំពើរនោះ ចំពោះខ្លួនវិញ បុរសអ្នកធ្វើល្អរមែងបានផលល្អ អ្នកធ្វើអាក្រក់ រមែងបានផលអាក្រក់ បុរសអ្នកសាបព្រោះពូជបែបណា ផលបែបនោះក៏រមែងដុះឡើង ។

[ ១៣ ] ( *ស្តេចព្រហ្មទត្តពោលថា* ) អាចារ្យបារាចរិយគោត្តបានពោលនូវពាក្យណា នេះជាពាក្យរបស់អាចារ្យនោះថា បាបណាដែលអ្នកធ្វើហើយគប្បីក្តៅក្រហាយក្នុងកាលជាខាងក្រោយ អ្នកកុំធ្វើបាបនោះឡើយ ។

[ ១៤ ] ខ្ញុំនិងបិង្គិយបុរោហិត សម្លាប់នូវពួកក្សត្រិយ៍មួយពាន់នាក់ដែលប្រដាប់លាបដោយខ្លឹមចន្ទន៍ ទៀបដើមឈើណា ដើមឈើនេះឯងជាដើមជ្រៃមានមែកត្រសាយត្រសុំ ( មិនអាចជួយអញបាន ) សេចក្តីទុក្ខនោះឯងត្រឡប់មកត្រូវខ្ញុំវិញ ។

[ ១៥ ] ( *អគ្គមហេសីរបស់ខ្ញុំ* ) ឈ្មោះនាងឧព្វរី មានខ្លួនលាបដោយខ្លឹមចន្ទន៍ មានសម្បុរដូចមាស ស្រលូតស្រឡៅដូចជាលំពង់ឈើម្រុមត្រូវខ្យល់បក់ល្អ ខ្ញុំមិនបានឃើញនាងឧព្វរីនឹងធ្វើមរណកាល ការមិនបានឃើញនាងឧព្វរីនោះជាទុក្ខដ៏លើសលុបដល់ខ្ញុំ ជាងទុក្ខព្រោះសេចក្តីស្លាប់នេះទៅទៀត ។

**ចប់ វេទសាខជាតកទី ៣ ។**

# អដ្ឋកថា

## វេឍសាខជាតក

[ ១១-១៥ ] ព្រះសាស្តា កាលគង់នៅក្នុងភគ្គជនបទសុំសុមារគិរីនគរ គង់នៅក្នុងភេសកឡាវ័ន ទ្រង់ប្រារព្ធពោធិរាជកុមារទើបត្រាស់ព្រះធម្មទេសនា នេះមានពាក្យផ្តើមថា **ឆយិធំ ឆិទ្ធំ ភវិតព្វំ** ដូច្នេះ ជាដើម ។

កាលណោះ ព្រះឱរសរបស់ព្រះបាទឧទេន ព្រះនាមថាពោធិរាជកុមារ ប្រថាប់នៅក្នុងសុំសុមារគិរី ត្រាស់ឲ្យហៅជាងឈើដែលជំនាញក្នុងសិប្បៈម្នាក់មក ឲ្យសាងប្រាសាទឈ្មោះកោកនុទៈ ដោយសាងមិនឲ្យដូចព្រះរាជាដទៃៗ កាលទ្រង់សាងស្រេចហើយ មានព្រះហឫទ័យកំណាញ់ថា ជាងឈើនេះគប្បីសាងប្រាសាទបែបនេះដល់ព្រះរាជាអង្គណាមួយ ទើបឲ្យខ្វេះភ្នែកជាងឈើនោះចោល ព្រោះហេតុនោះ ភាពដែលពោធិរាជកុមារឲ្យខ្វេះភ្នែកជាងឈើនោះក៏បានកើតប្រាកដក្នុងពួកភិក្ខុសង្ឃ ។ ព្រោះដូច្នោះ ភិក្ខុទាំងឡាយ ក៏អង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ពោធិរាជកុមារត្រាស់ឲ្យខ្វេះភ្នែកទាំងពីររបស់ជាងឈើបែបនេះ ឱព្រះរាជា កាចអាក្រក់ឃោរឃៅហ្ន៎ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ពោធិរាជកុមារនេះក៏ជាបុគ្គលកាចអាក្រក់ឃោរឃៅដូចគ្នា ឥឡូវនេះ មិនជាអស្ចារ្យឡើយ ក្នុងកាលមុនពោធិរាជកុមារ ក៏ឲ្យខ្វេះព្រះនេត្រស្តេចមួយពាន់អង្គ ឲ្យផ្តាច់ព្រះ

ជន្ទុក្សត្រមួយពាន់អង្គនោះ យកសាច់ធ្វើពលីកម្ម ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ ជាអាចារ្យទិសាបាមោក្ខក្នុងនគរតក្កសិលា ។ ខត្តិយមាណព និងព្រាហ្មណមាណពក្នុងជម្ពូទ្វីប នាំគ្នារៀនសិប្បៈក្នុងសម្នាក់របស់ព្រះពោធិសត្វនោះឯង ព្រះឱរសរបស់ព្រះបាទពារាណសីព្រះនាមថាព្រហ្មទត្តកុមារបានរៀនវេទទាំង ៣ ក្នុងសម្នាក់របស់ព្រះពោធិសត្វនោះ តែតាមប្រក្រតីព្រហ្មទត្តកុមារនោះជាមនុស្សរឹងត្អឹងគ្រោតគ្រាតឃោរឃៅ ។ ព្រះពោធិសត្វដឹងថាព្រហ្មទត្តកុមារនោះជាមនុស្សកាច អាក្រក់ ឃោរឃៅ ដោយអំណាចវិជ្ជាមើលអវយវៈ បានពោលទូន្មានថា នែបា អ្នកជាមនុស្ស រឹងត្អឹង គ្រោតគ្រាត ឃោរឃៅ ភាពជាធំដែលបានដោយភាពគ្រោតគ្រាតរមែងមិនតាំងនៅបានយូរកាល បើភាពជាធំវិនាសទៅ បុគ្គលដែលគ្រោតគ្រាតនោះរមែងមិនបានទីពឹង ដូចបុគ្គលដែលបែកនាវា មិនបាននូវទីពឹងពំនាក់ក្នុងសមុទ្រដូច្នោះ ព្រោះដូច្នោះ អ្នកកុំបីជាបុគ្គលបែបនោះ ដូច្នេះ ទើបពោលគាថា ២ ថា

ម្នាលព្រហ្មទត្តកុមារ សេចក្តីក្សេមក្សាន្តក្តី ភិក្ខាដ៏សម្បូរក្តី
សេចក្តីសុខក្នុងកាយក្តី នេះមិនគប្បីមានជានិច្ចទេ ( កាលបើឥស្សរភាពវិនាស ) ក្នុងកាលជាទីកន្ទង់នៃប្រយោជន៍ អ្នកកុំ
វង្វេងជ្រប់ ដូចបុគ្គលដែលបែកធ្លាយនាវាក្នុងកណ្តាលសាគរ ។
បុរសធ្វើនូវអំពើទាំងឡាយរមែងឃើញនូវអំពើរនោះចំពោះ

ខ្លួនវិញ បុរសអ្នកធ្វើល្អរមែងបានផលល្អ អ្នកធ្វើអាក្រក់រមែង
បានផលអាក្រក់ បុរសអ្នកសាបព្រោះពូជបែបណា ផលបែប
នោះ ក៏រមែងដុះឡើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុខតា ច កាយេ** សេចក្ដីថា នៃព្រហ្មទត្ត សេចក្ដីសុខក្ដី កិច្ចការកបានងាយក្ដី សេចក្ដីសុខកាយក្ដី ទាំងអស់នេះមិនមានជានិច្ច គឺអស់កាលទាំងពួងដល់សត្វទាំងឡាយ ការក្សេមជាដើមនេះ រមែងមិនទៀង មានការមិនមានជាធម្មតា ។ បទថា **អត្ថច្ចយេ** សេចក្ដីថា អ្នកក្នុងកាលដែលភាពជាធំប្រាសទៅដោយភាពជារបស់មិនទៀងព្រោះប្រយោជន៍របស់ខ្លួនកន្លងទៅ កុំបីជាអ្នកលិចចុះ ដូចបុគ្គលដែលមានសំពៅបែកធ្លាយ មិនបាននូវទីពឹងកណ្ដាលសាគរ រមែងជាអ្នកលិចចុះ អ្នកកុំជាអ្នកលិចចុះយ៉ាងនេះឡើយដូច្នេះ ។ បទថា **តានិ អត្តនិ បស្សតិ** សេចក្ដីថា បុគ្គលដែលជួបនូវផលរបស់កម្មទាំងនោះ ឈ្មោះថា ឃើញកម្មក្នុងខ្លួន ។

ព្រហ្មទត្តកុមារនោះ ថ្វាយបង្គំអាចារ្យហើយ ទៅដល់នគរពារាណសី សម្ដែងសិប្បៈដល់បិតា ហើយតាំងនៅក្នុងតំណែងឧបរាជ កាលព្រះបិតាសោយទិវង្គតហើយ ក៏បានគ្រងរាជសម្បត្តិ ។ ព្រះរាជាមានបុរោហិតឈ្មោះបិង្គិយ ជាបុគ្គល រឹងរូស គ្រោតគ្រាត ឃោរឃៅ ព្រោះល្មោភក្នុងយស ទើបគិតថា បើដូច្នោះអញនឹងញុះញង់ឲ្យព្រះរាជាចាប់ស្ដេចទាំងអស់ ក្នុងជម្ពូទ្វីបទាំងមូល កាលបើយ៉ាងនេះ ព្រះរាជានេះនឹងជាព្រះរាជាតែមួយអង្គ អញក៏បានជាបុរោហិតតែមួយ ។ បុរោហិតនោះធ្វើឲ្យព្រះរាជាជឿនូវពាក្យរបស់ខ្លួន

ព្រះរាជាលើកកងទ័ពធំចេញទៅ ព័ទ្ធនគរព្រះរាជាមួយអង្គ ហើយចាប់ព្រះរាជាអង្គនោះ ។ ព្រះរាជានោះ ដណ្តើមយករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូលដោយឧបាយនេះឯង ចោមរោមដោយព្រះរាជាមួយពាន់អង្គ បានទៅដោយបំណងថានឹងដណ្តើមរាជសម្បត្តិ ក្នុងនគរតក្កសិលា ព្រះពោធិសត្វជួសជុលព្រះនគរ ធ្វើឲ្យជានគរដែលអ្នកដទៃកម្ចាត់មិនបាន ចំណែកស្តេចពារាណសីឲ្យបាំងរាំងនន ត្រង់គល់ជ្រៃធំ ក្បែរឆ្នេរស្ទឹងគង្គា ហើយឲ្យធ្វើពិដានខាងលើក្រាលទីបន្ទំហើយសម្រាក ។ សូម្បីទ្រង់នាំព្រះរាជាមួយពាន់អង្គ ក្នុងជម្ពូទ្វីបចេញច្បាំង ក៏មិនអាចដណ្តើមយកនគរតក្កសិលាបាន ទើបត្រាស់សួរបុរោហិតថា លោកអាចារ្យ ពួកយើង និងព្រះរាជាទាំងនេះមិនអាចដណ្តើមនគរតក្កសិលាបានគួរធ្វើយ៉ាងណាល្អ ។ បុរោហិតក្រាលទូលថា បពិត្រមហារាជយើងទាំងឡាយ ចូរខ្វេះភ្នែករបស់ព្រះរាជាមួយពាន់អង្គ ហើយផ្តាច់ព្រះជន្ទចោល វះយកសាច់ដែលធ្លាញ់ ៥ ប្រភេទ ធ្វើពលីកម្មដល់ទេវតា ដែលអាស្រ័យនៅត្រង់ដើមជ្រៃនេះ ហើយព័ទ្ធជុំវិញដើមជ្រៃ ដោយរមូរពោះវៀនធំហើយធ្វើការប្រោះព្រំដោយឈាម ជ័យជម្នះនឹងមានដល់ពួកយើង យ៉ាងឆាប់រហ័សនោះឯង ដោយឧបាយយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា សាធុ ហើយដាក់មនុស្សអ្នកចំបាប់ដែលមានកម្លាំងខ្លាំង ខាងក្នុងរាំងនន ឲ្យហៅព្រះរាជាមកម្តងមួយអង្គ ធ្វើឲ្យសន្លប់ដោយការច្របាច់ ហើយខ្វេះយកភ្នែកសម្លាប់ឲ្យស្លាប់យកតែសាច់បណ្តែតសាកសពទៅក្នុងស្ទឹងគង្គា ហើយធ្វើពលីកម្ម មានប្រការដូចពោលហើយ ឲ្យវាយស្គរបួងសួងហើយយាងទៅច្បាំង ។ កាល

ពេលនោះយក្សម្នាក់ឈ្មោះអដ្ឋាលកត: មកខ្វេះភ្នែកខាងស្តាំរបស់ព្រះបាទពារាណសីនោះហើយក៏ទៅ វេទនាដ៏ធំកើតឡើងហើយ ទ្រង់បានទទួលទុក្ខវេទនាទើបយាងទៅផ្ទំផ្ងារលើអាសនៈដែលគេក្រាលទុកត្រង់គល់ជ្រៃ ។ ខណៈនោះ ត្មាតមួយពាំយកឆ្អឹងដែលមានចុងស្រួច មកទំលើដើមឈើ ស៊ីសាច់អស់ហើយក៏ទម្លាក់ឆ្អឹងចុះមក ចុងឆ្អឹងធ្លាក់ចំភ្នែកខាងឆ្វេងរបស់ព្រះរាជា ធ្វើព្រះនេត្រឲ្យបែកទៅដូចលំពែងដែកចាក់ដូច្នោះ ។ ខណៈនោះ ព្រះរាជាកំណត់ដល់ពាក្យរបស់ព្រះពោធិសត្វ ទ្រង់កំណត់ទុកថា អាចារ្យរបស់យើង ពោលទុកថា សត្វទាំងឡាយ រមែងសោយវិបាកដែលសមគួរដល់កម្ម ដូចបុគ្គលសោយផលដែលសមគួរដល់ពូជដូច្នោះ លោកឃើញហេតុនេះទើបពោលទុក ហើយពោលគាថា ២ ថា

> អាចារ្យបារាចរិយគោត្ត បានពោលនូវពាក្យណា នេះជាពាក្យរបស់អាចារ្យនោះថា បាបណាដែលអ្នកធ្វើហើយ គប្បីក្តៅក្រហាយក្នុងកាលជាខាងក្រោយ អ្នកកុំធ្វើបាបនោះឡើយ ។
>
> ខ្ញុំនិងបិង្គិយបុរោហិត សម្លាប់នូវពួកក្សត្រិយ៍មួយពាន់នាក់ ដែលប្រដាប់ លាបដោយខ្លឹមចន្ទន៍ ទៀបដើមឈើណា ដើមឈើនេះឯង ជាដើមជ្រៃមានមែកត្រសាយត្រសុំ ( មិនអាចជួយអញបាន ) សេចក្តីទុក្ខនោះឯង ត្រឡប់មកត្រូវខ្ញុំវិញដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទំ តទាចរិយវចោ** សេចក្តីថា ពាក្យ

នោះជាពាក្យរបស់អាចារ្យ ។ ព្រះបាទពារាណសី ត្រាស់ហៅអាចារ្យនោះដោយគោត្តថា **ធាកាសរិយ** ។ បទថា **បច្ឆា កតំ** សេចក្ដីថា អាចារ្យបានឲ្យឱវាទថា បាបណាដែលអ្នកធ្វើទុក បាបនោះនឹងធ្វើឲ្យអ្នកក្ដៅក្រហាយលំបាកក្នុងកាលខាងក្រោយ អ្នកកុំធ្វើបាបនោះឡើយដូច្នេះ តែខ្ញុំមិនបានធ្វើតាមពាក្យរបស់អាចារ្យនោះ ។ ព្រះរាជាវេវរវាយសម្ដែងដើមជ្រៃថា **អយមេវ** ប្រែថា ដើមឈើនេះឯង ។ បទថា **វេឆសោភោ** បានដល់ មានមែកត្រសាយត្រសុំ ។ បទថា **យម្ហិ ឃាតយឹ** សេចក្ដីថា ឲ្យផ្ដាច់ព្រះជន្ទុក្សត្រ មួយពាន់អង្គត្រង់ដើមឈើណា ។ បទថា **អលង្កតេ ចន្ទនសារលិត្តេ** នេះ លោកសម្ដែងថា យើងឲ្យសម្លាប់ក្សត្រទាំងនោះ ដែលប្រដាប់ដោយរាជអលង្ការលាបស្រឡាបដោយចន្ទន៍ក្រហមត្រង់ដើមឈើណាដើមឈើនោះ គឺដើមនេះ ឥឡូវនេះ មិនអាចធ្វើនូវទីពឹងអ្វីដល់យើង ។ បទថា **តមេវ ទុក្ខំ** សេចក្ដីថា ព្រះបាទពារាណសីយំរៀបរាប់ថា ទុក្ខដែលកើតអំពីការខ្វះភ្នែករបស់អ្នកដទៃ ឯណា ដែលខ្ញុំធ្វើហើយ ទុក្ខនេះត្រឡប់មកដល់ខ្ញុំយ៉ាងនោះឯង ឥឡូវនេះ ពាក្យអាចារ្យរបស់ខ្ញុំដល់ទីបំផុតហើយ ។ ព្រះរាជាកាលទ្រង់កន្ទក់កន្ទេញនោះឯង ទ្រង់រឭកដល់អគ្គមហេសី ទើបពោលគាថាដូច្នេះថា

( អគ្គមហេសីរបស់ខ្ញុំ ) ឈ្មោះនាងឧព្វរី មានខ្លួនលាបដោយខ្លឹមចន្ទន៍ មានសម្បុរដូចមាស ស្រលូតស្រឡៅដូចជាលំពង់ឈើម្រុមត្រូវខ្យល់បក់ល្អ ខ្ញុំមិនបានឃើញនាងឧព្វរី នឹងធ្វើមរណកាល ការមិនបានឃើញនាងឧព្វរីនោះ ជាទុក្ខដ៏លើស

លុះបដល់ខ្ញុំ ជាងទុក្ខព្រោះសេចក្តីស្លាប់នេះទៅទៀត ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា ព្រះនាងឧព្វរី អគ្គមហេសីយើង មានធរីវណ្ណល្អដូចមាស កាលធ្វើឥត្ថីវិលាសរបស់ស្រីរមែងស្អាត ដូចមែកម្រុម ក្នុងកាលដែលត្រូវខ្យល់បក់ផាត់រយោនរយាន ។ ឥឡូវនេះ យើងមិនបានឃើញនាងឧព្វរីនោះ ព្រោះក្អែកទាំងពីរបែកហើយនឹងត្រូវស្លាប់ ការដែលខ្ញុំមើលមិនឃើញនាងឧព្វរីនោះ ជាទុក្ខក្រៃលែងជាងមរណទុក្ខនេះ ។

ព្រះបាទពារាណសីនោះ ទ្រង់កន្ទក់កន្ទេញយ៉ាងនេះ ស្លាប់ហើយកើតក្នុងនរក ។ បុរោហិតចង់បានភាពជាធំ មិនអាចធ្វើទីពឹងដល់ព្រះបាទពារាណសីនោះតិចតួច មិនអាចធ្វើភាពជាធំដល់ខ្លួន ។ កាលព្រះបាទពារាណសីសោយទិវង្គតប៉ុណ្ណោះ ពលនិកាយក៏បែកគ្នាខ្ចាត់ខ្ចាយទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាពោធិរាជកុមារក្នុងកាលឥឡូវនេះ បិង្គិយបុរោហិតក្នុងកាលនោះ បានមកជាទេវទត្ត អាចារ្យទិសាបាមោក្ខក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វេនសាខជាតក ចប់**

# ឧរគជាតក

[ ១៦ ] ( ព្រាហ្មណ៍ពោធិសត្វពោលថា ) កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់លះបង់នូវសំណាកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយាទៅកាន់លោកខាងមុខយ៉ាងនេះ រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយ ព្រោះហេតុនោះទើបខ្ញុំមិនសោកស្តាយចំពោះកូនទុំះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

[ ១៧ ] ( នាងព្រាហ្មណីពោលថា ) កូន ( របស់ខ្ញុំ ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអង្វរ គេទៅអំពីលោកនេះ ក៏ខ្ញុំមិនអនុញ្ញាត គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃញាតិទាំងឡាយទេព្រោះហេតុនោះទើបខ្ញុំមិនសោកនឹងកូនទុំះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

[ ១៨ ] ( នាងព្រាហ្មណីជាប្អូនពោលថា ) បើខ្ញុំយំទួញ ខ្ញុំនឹងស្គាំងស្គម កាលខ្ញុំនោះយំទួញ នឹងមានផលដូចម្តេច សេចក្តីមិនត្រេកអររបស់ពួកញាតិមិត្តនិងសម្លាញ់របស់យើងគប្បីមានដោយក្រៃលែង រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះទើបខ្ញុំមិនសោកនឹងបងនោះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

[ ១៩ ] ( ភរិយាពោលថា ) ទារកយំទាមព្រះចន្ទដែលកំពុងចរទៅយ៉ាងណា បុគ្គលដែលសោករកអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបធៀប យ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវ

សេចក្តីខ្សឹកខ្សួលនៃពួកញាតិទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងប្តីនុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

[ ២០ ] ( ទាសីពោលថា ) ក្អមទឹកដែលបែកធ្លាយតវិញមិនជាប់យ៉ាងណា បុគ្គលសោកស្តាយនឹងអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបធៀប ក៏យ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់នុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

**ចប់ ឧរគជាតកទី ៤ ។**

# អដ្ឋកថា

## ឧរគជាតក

[ ១៦-២០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពិកៈម្នាក់ ដែលមានកូនស្លាប់ហើយ ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ឧរគោវ តចំ ជិណ្ណំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នដូចគ្នានឹងរឿងកុដុម្ពិកៈដែលមានកិរិយាស្លាប់ និងមានបិតាស្លាប់ហើយនោះឯង ។ សូម្បីក្នុងជាតកនេះ ព្រះសាស្តាយាងទៅកាន់និវេសន៍របស់កុដុម្ពិកៈនោះ យ៉ាងនោះដូចគ្នា ហើយត្រាស់សួរកុដុម្ពិកៈនោះ ដែលមកថ្វាយបង្គំហើយអង្គុយថា អាវុសោ អ្នកសោយសោកឬ កាលកុដុម្ពិកៈនោះ

ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គសោយសោកតាំងអំពីកូនរបស់ខ្ញុំព្រះអង្គស្លាប់ទៅហើយ ទើបព្រះសាស្តាត្រាស់ថា អាវុសោ ឈ្មោះថា វត្ថុដែលមានការបែកធ្លាយជាធម្មតារមែងបែកធ្លាយទៅ ឈ្មោះថា វត្ថុដែលមានការវិនាសទៅជាធម្មតារមែងវិនាសទៅយ៉ាងនេះ ឯវត្ថុដែលមានការបែកធ្លាយ និងការវិនាសទៅនោះនឹងមានដល់ត្រកូលមួយប៉ុណ្ណោះ ក៏មិនមែន នឹងមានក្នុងស្រុកមួយប៉ុណ្ណោះ ក៏មិនមែន ឈ្មោះថាជាសភាវធម៌ គឺការមិនស្លាប់រមែងមិនមានក្នុងភពទាំង ៣ និងក្នុងចក្កវាឡប្រមាណមិនបាន សង្ខារឯណាទីមួយដែលអាចតាំងនៅដោយភាវៈនោះប៉ុណ្ណោះ ឈ្មោះថា ទៀងឋិតថេររមែងមិនមាន សត្វទាំងពួងមានការស្លាប់ជាធម្មតា សង្ខារទាំងឡាយមានការ បែកធ្លាយជាធម្មតា សូម្បីបុរាណកបណ្ឌិតទាំងឡាយ កាលបុត្តស្លាប់ហើយគិតថាវត្ថុដែលមានការស្លាប់ជាធម្មតា បានស្លាប់ទៅហើយ វត្ថុដែលមានការវិនាសទៅជាធម្មតា ក៏វិនាសទៅហើយទើបមិនគួរសោយសោក កាលកុដុម្ពិកៈនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ត្រង់ទ្វារស្រុកក្នុងនគរពារាណសីនោះ សន្សំទ្រព្យសម្បត្តិទុកចិញ្ចឹមជីវិតដោយកសិកម្ម ។ ព្រះពោធិសត្វនោះ មានទារក ២ នាក់ គឺបុត្ត ១ ធីតា ១ ។ ព្រះពោធិសត្វនោះ កាលបុត្តចម្រើនវ័យហើយ បាននាំនាងកុមារិកាមកអំពីត្រកូលស្មើគ្នា ឲ្យដល់បុត្តរបស់ខ្លួន ។ ដូច្នោះជនទាំងនោះបានជា ៦ នាក់ មួយអន្លើដោយនាងទាសី គឺព្រះពោធិ

សត្វ ១ ភរិយា ១ បុត្ត ១ ធីតា ១ កូនប្រសាស្រី ១ និងទាសី ១ ។ ជនទាំងនោះ បានជាអ្នកស្ម័គ្រស្មាគមត្រេកអរដោយសេចក្តីស្រឡាញ់ ។ ព្រះពោធិសត្វបានឲ្យឱវាទដល់ជនទាំង ៥ ដ៏សេស យ៉ាងនេះថា អ្នកទាំងឡាយចូរឲ្យទានដោយនិយាមតាមទំនងដែលរកបានប៉ុណ្ណោះ ចូររក្សាសីលធ្វើឧបោសថកម្មចម្រើនមរណស្សតិ ចូរកំណត់ដល់ភាវៈ គឺការស្លាប់របស់អ្នកទាំងឡាយ ព្រោះការស្លាប់របស់សត្វទាំងនេះ ជារបស់ទៀង ជីវិតមិនទៀងទាត់ សង្ខារទាំងពួងមិនទៀង មានការអស់ទៅជាធម្មតានោះឯង អ្នកទាំងឡាយចូរជាអ្នកមិនប្រមាទទាំងក្នុងពេលយប់និងពេលថ្ងៃចុះ ។ ជនទាំង ៥ នោះទទួលឱវាទថា សាធុ ហើយជាអ្នកមិនប្រមាទ ចម្រើនមរណស្សតិ ។ ថ្ងៃមួយព្រះពោធិសត្វទៅភ្ជួរស្រែ មួយអន្លើដោយកូនប្រុស កូនប្រុសអូសសំរាមមកដុត ។ ក្នុងទីមិនឆ្ងាយអំពីបុត្តនោះ មានអាសិរពិសនៅក្នុងជំពូកមួយកន្លែង កាលផ្សែងប៉ះភ្នែករបស់ខ្លួនខឹងក្រោធលូនចេញមកគិតថា ភ័យកើតដល់អញព្រោះតែអាស្រ័យបុរសនេះ ទើបខាំបុរសនោះដោយចង្កូមទាំង ៤ ។ បុត្តនោះដួលចុះស្លាប់មួយរំពេច ។ ព្រះពោធិសត្វក្រឡេកមកឃើញកូនប្រុសនោះដួលចុះទើបបញ្ឈប់គោហើយចូលមករក ដឹងថាកូនប្រុសនោះស្លាប់ហើយ ទើបយកកូននោះទៅដាក់ឲ្យដេកត្រង់គល់ឈើមួយកន្លែងគ្របសំពត់ទុក មិនយំ មិនបរិទេវនាការអ្វីឡើយ ភ្ជួរស្រែបណ្តើរកំណត់ដល់អនិច្ចំថា វត្ថុដែលមានការបែកជាធម្មតា បែកទៅហើយ វត្ថុដែលមានការស្លាប់ជាធម្មតា ស្លាប់ទៅហើយ សង្ខារទាំងពួងមិនទៀង សម្រេចដោយការស្លាប់ ។ ព្រះពោធិសត្វនោះឃើញ

បុរសដែលស្និទ្ធស្នាលម្នាក់ដើរតាមផ្លូវក្បែរស្រែ ទើបសួរថា តើអ្នកទៅផ្ទះឬ កាលបុរសនោះពោលថា អើខ្ញុំទៅ ទើបពោលថា បើយ៉ាងនោះ អ្នកគប្បី ចៀងចូលទៅកាន់ផ្ទះរបស់ពួកយើងប្រាប់នាងព្រាហ្មណីថា ថ្ងៃនេះមិនចាំបាច់ យកភត្តាហារមកដើម្បីមនុស្សពីរនាក់ដូចពេលមុនឡើយ គប្បីនាំអាហារមក សម្រាប់មនុស្សម្នាក់ប៉ុណ្ណោះ ។ ក្នុងកាលមុន ទាសីម្នាក់ប៉ុណ្ណោះនាំអាហារ មក តែថ្ងៃនេះជនទាំង ៤ គប្បីស្លៀកដណ្តប់សំពត់ពណ៌ស កាន់គ្រឿងក្រអូប និងផ្កាមក បុរសនោះទទួលពាក្យថា សាធុ ហើយទៅប្រាប់ដល់នាងព្រាហ្មណី យ៉ាងនោះ ។ ព្រាហ្មណី សួរថា នែបា ដំណឹងនេះអ្នកណាឲ្យនាំមក បុរស នោះឆ្លើយថា ព្រាហ្មណ៍ផ្តាំមក ព្រាហ្មណីនោះដឹងថាកូនរបស់ខ្លួនស្លាប់ហើយ ។ ការរំភើបញាប់ញ័រសូម្បីត្រឹមតែរន្ធត់ចិត្ត ក៏មិនមានដល់ព្រាហ្មណីនោះ នាងមានចិត្ត អប់រំទុកល្អហើយយ៉ាងនេះ ស្លៀកដណ្តប់សំពត់ស កាន់គ្រឿងក្រអូបនិងផ្កា ឲ្យ ( ទាសី ) កាន់អាហារហើយ បានទៅស្រែជាមួយមនុស្សដ៏សេស ។ មនុស្សសូម្បីតែម្នាក់ ក៏មិនបានយំឬកន្ទក់កន្ទេញ ។ ព្រះពោធិសត្វ អង្គុយ ត្រង់ម្លប់ដែលកូនប្រុសដេកនោះឯង បរិភោគអាហារ លុះបរិភោគស្រេច មនុស្សទាំងអស់ក៏ជញ្ជូនឧសមក លើកកូនប្រុសឡើងកាន់ជើងថ្ករ បូជាដោយ គ្រឿងក្រអូបនិងផ្កាហើយដុត ។ ទឹកភ្នែកត្រឹមមួយតំណក់ ក៏មិនមាន ដល់ បុគ្គលណាមួយ ជនទាំងអស់ ចម្រើនមរណស្សតិទុកល្អហើយ ។ ដោយ តេជះនៃសីលរបស់ជនទាំងនោះ អាសនៈរបស់សក្កទេវរាជ ក៏បានសម្តែង អាការៈក្តៅ សក្កទេវរាជទ្រង់ពិចារណាថា អ្នកណាហ្ន៎ បំណងឲ្យអញឃ្លាត

បាកទី ទ្រង់ជ្រាបថាអាសនៈក្តៅព្រោះតេជៈនៃគុណរបស់ជនទាំងនោះ ជាអ្នកមានចិត្តជ្រះថ្លា ទ្រង់ត្រិះរិះថា អញនឹងទៅកាន់សម្នាក់ជនទាំងនេះ ឲ្យជនទាំងនេះបន្លឺសីហនាទ ក្នុងកាលចប់ការបន្លឺសីហនាទ អញនឹងធ្វើនិវេសន៍របស់ជនទាំងនោះឲ្យពេញដោយរតនៈទាំង ៧ ហើយសឹមត្រឡប់មកវិញគួរ ទើបយាងទៅទីនោះដោយរហ័ស ហើយប្រថាប់ឈរក្នុងព្រៃត្រាស់ថា នែបា ពួកអ្នកធ្វើអ្វី ជនទាំងនោះពោលថា ពួកខ្ញុំដុតមនុស្សម្នាក់ ។ សក្កទេវរាជត្រាស់ថា ពួកអ្នកមិនមែនដុតមនុស្ស ប្រហែលជាសម្លាប់ម្រឹគមួយហើយចម្អិន ។ ជនទាំងនោះពោលថា នែអ្នក មិនមែនដូច្នោះទេពួកយើងដុតមនុស្សប៉ុណ្ណោះ ។ សក្កទេវរាជត្រាស់ថា បើយ៉ាងនោះ គង់ជាមនុស្សដែលមានពៀរជាមួយពួកអ្នក លំដាប់នោះ ព្រះពោធិសត្វពោលនឹងសក្កទេវរាជនោះថា នែអ្នក បុរសនេះជាកូនប្រុសដែលកើតអំពីទ្រូងរបស់ពួកយើង មិនមែនអ្នកមានពៀរនឹងគ្នាទេ ។ សក្កទេវរាជត្រាស់ថា បើយ៉ាងនោះ គេប្រហែលជាបុត្តដែលមិនជាទីស្រឡាញ់របស់អ្នក ព្រះពោធិសត្វពោលថា នែអ្នក គេជាបុត្តជាទីស្រឡាញ់ក្រៃលែងរបស់ខ្ញុំ សក្កៈត្រាស់ថា បើយ៉ាងនោះ ហេតុអ្វីទើបពួកអ្នកមិនយំ ព្រះពោធិសត្វ កាលប្រាប់ដល់ហេតុដែលមិនយំ ទើបពោលគាថាទី ១ ថា

កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់ លះបង់
នូវសំណាកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាល
កិរិយា ទៅកាន់លោកខាងមុខយ៉ាងនេះ រាងកាយ កាលត្រូវ
គេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយ

ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយចំពោះកូនទុំះ គតិណា
ជារបស់គេ គេក៏ទៅកាន់គតិនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សំតនុំ** បានដល់ រាងកាយរបស់ខ្លួន ។ បទថា **និព្ភោគេ** សេចក្តីថា ឈ្មោះថាប្រើប្រាស់មិនបាន ព្រោះមិនមានជីវិតិន្ទ្រិយ គឺភាពជាធំនៃជីវិត ។ បទថា **បេតេ** បានដល់ ត្រឡប់ទៅកាន់ បរលោក ។ បទថា **កាលកតេ** បានដល់ ធ្វើកាលកិរិយាហើយ អធិប្បាយថា ស្លាប់ហើយ ។ លោកពោលពាក្យអធិប្បាយនេះទុកថា នៃអ្នក បុត្តរបស់ខ្ញុំលះបង់រាងកាយរបស់ខ្លួនទៅ ដូចពស់សកសំណកចាស់ មិនអាឡោះអាល័យមិនក្រឡេកមើល មិនសម្លឹងមើលលះបង់ទៅដូច្នោះ កាលរាងកាយនៃបុត្តរបស់យើងនោះ ដាច់ចាកជីវិតិន្ទ្រិយប្រើការមិនបានយ៉ាងនេះ កាលបុត្តរបស់យើងនោះលះ ( លោក ) ទៅហើយ គឺវិលត្រឡប់ទៅហើយ ធ្វើមរណកាលហើយ ប្រយោជន៍អ្វីដោយការខ្សឹកខ្សួលឬកន្ទក់កន្ទេញ ព្រោះបុត្តរបស់យើងនេះ រមែងមិនដឹងសូម្បីការយំរបស់ញាតិ ដូចយកឈើស្ងួលចាក់ហើយដុតរមែងមិនដឹងសុខនិងទុក្ខដូច្នោះ ព្រោះហេតុនោះ ទើបខ្ញុំមិនសោយសោក គេទៅតាមគតិនៃខ្លួនរបស់គេហើយ ។

សក្កទេវរាជ បានស្តាប់ពាក្យរបស់ព្រះពោធិសត្វ ទើបត្រាស់សួរនាងព្រាហ្មណីថា នៃនាង អ្នកស្លាប់ជាអ្វីនឹងនាង ព្រាហ្មណីឆ្លើយថា គេជាកូនរបស់ខ្ញុំ ខ្ញុំបរិហារគភ៌ ១០ ខែ ឲ្យបៅដោះហើយចិញ្ចឹមឲ្យចម្រើនធំធាត់ ។ សក្កៈត្រាស់ថា នៃនាង បិតាមិនយំព្រោះជាបុរស ក៏ស្នេះទុកចុះ ចំណែកហទយៈ

មាតាទោវទន់ ព្រោះហេតុអ្វីទើបនាងមិនយំ ព្រាហ្មណីនោះកាលប្រាប់ហេតុដែលមិនយំ ទើបពោលគាថា ២ ថា

កូន ( របស់ខ្ញុំ ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអង្វរ
គេទៅអំពីលោកនេះ ក៏ខ្ញុំមិនអនុញ្ញាត គេមកយ៉ាងណា គេក៏
ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ រាង
កាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃ
ញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូន
នុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនព្ភិតោ** សេចក្តីថា នែអ្នក កូនរបស់ខ្ញុំនេះ ខ្ញុំមិនបានអញ្ជើញ គឺមិនបានសំណូមពរឲ្យមកអំពីបរលោក ។ បទថា **អាគា** សេចក្តីថា មកកាន់ផ្ទះរបស់ខ្ញុំហើយ ។ បទថា **ឥតោ** សេចក្តីថា កាលទៅអំពីមនុស្សលោកនេះ ខ្ញុំមិនបានអនុញ្ញាតឡើយ បានទៅហើយ ។ បទថា **យថាគតោ** សេចក្តីថា កាលនឹងមក ក៏មកតាមគាប់ចិត្តរបស់ខ្លួនយ៉ាងណា កាលនឹងទៅ ក៏ទៅយ៉ាងនោះឯង ។ បទថា **តត្ថ** សេចក្តីថា នឹងអំពល់បរិទេវនាការធ្វើអ្វីក្នុងការដែលគេទៅអំពីមនុស្សលោកនេះនុ៎ះ ។ បទថា **ឧយ្ហមានោ** ដូច្នេះ គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

លំដាប់នោះ សក្កទេវរាជបានស្តាប់ពាក្យ របស់ព្រាហ្មណីហើយ ទើបត្រាស់សួរប្អូនស្រីថា នែនាង នាងជាអ្វីនឹងអ្នកស្លាប់នេះ ប្អូនស្រីពោលថា គេជាបងប្រុសរបស់ខ្ញុំ សក្កទេវរាជត្រាស់ថា នែនាង ធម្មតាប្អូនស្រីទាំងឡាយ

រមែងមានសេចក្តីស្នេហាក្នុងបងប្រុស ព្រោះហេតុអ្វីទើបនាងមិនយំ ចំណែក ប្អូនស្រីនោះកាលប្រាប់ហេតុដែលមិនយំដល់សក្កៈនោះទើបពោលគាថា ២ ថា

បើខ្ញុំយំទួញខ្ញុំនឹងស្គាំងស្គម កាលខ្ញុំនោះយំទួញនឹងមានផល
ដូចម្តេច សេចក្តីមិនត្រេកអររបស់ពួកញាតិមិត្ត និងសម្លាញ់
របស់យើង គប្បីមានដោយក្រៃលែង រាងកាយកាលត្រូវគេ
ដុត រមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ
ព្រោះហេតុនោះទើបខ្ញុំមិនសោកនឹងបងនោះ គតិណាជារបស់
គេ គេក៏ទៅកាន់គតិនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សចេ** នេះ លោកសម្តែងថា កាលបងប្រុស ស្លាប់ បើខ្ញុំយំសោត ខ្ញុំនឹងជាអ្នកមានរាងកាយស្គាំងស្គម ម្យ៉ាងទៀត ឈ្មោះ ជាសេចក្តីចម្រើនដែលមានការយំនោះជាបច្ច័យ ក៏មិនមានដល់បងប្រុសរបស់ ខ្ញុំ ។ ដោយបទថា **តស្សា មេ** នេះ លោកសម្តែងថា កាលខ្ញុំនោះយំ ផល អ្វី គឺអានិសង្សអ្វីគប្បីមាន តែការមិនចម្រើនរបស់ខ្ញុំនឹងប្រាកដ ។ បទថា **ញាតិមិត្តសុហជ្ជានំ** បានដល់ ញាតិមិត្តនិងសម្លាញ់ ។ ម្យ៉ាងទៀត បាលី ក៏យ៉ាងនេះដូចគ្នា ។ បទថា **ភិយ្យោ នោ** សេចក្តីថា សេចក្តីមិនត្រេកអរ យ៉ាងក្រៃលែងនឹងមានដល់ញាតិមិត្តនិងសម្លាញ់ទាំងនោះរបស់ខ្ញុំ ។

កាលសក្កៈ បានស្តាប់ពាក្យរបស់ស្ត្រីជាប្អូនស្រីហើយ ទើបត្រាស់សួរ ភរិយាបុរសដែលស្លាប់នោះថា នៃនាង បុរសនេះជាអ្វីនឹងនាង ភរិយាឆ្លើយថា ជាប្តីរបស់ខ្ញុំ សក្កទេវរាជត្រាស់ថា ធម្មតាស្ត្រីទាំងឡាយកាលប្តីស្លាប់ទៅរមែង

ជាស្រីមេម៉ាយមិនមានទីពឹង ព្រោះហេតុអ្វីទើបនាងមិនយំ ។ ចំណែកកិរិយានោះ កាលនឹងប្រាប់ហេតុដែលមិនយំដល់សក្កៈនោះ ទើបពោលគាថា ២ ថា

ទារកយំទារព្រះចន្ទ ដែលកំពុងចរទៅយ៉ាងណា បុគ្គលដែលសោករកអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបធៀបយ៉ាងនោះដែរ រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃពួកញាតិទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងប្តីនុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា ទារកតូចដែលមិនដឹងវត្ថុគួរនិងមិនគួរ វត្ថុដែលគួរបាននិងមិនគួរបានក្នុងទីឯណាមួយ អង្គុយលើភ្លៅរបស់ម្តាយឃើញព្រះចន្ទពេញវង់ ក្នុងថ្ងៃពេញបូណ៌មីអណ្តែតនៅក្នុងអាកាស រមែងយំហើយយំទៀតថា សូមម៉ែឲ្យព្រះចន្ទខ្ញុំ សូមម៉ែឲ្យព្រះចន្ទខ្ញុំ ដូច្នេះយ៉ាងណាការដល់ព្រមដោយឧបមេយ្យ ក៏យ៉ាងនោះដូចគ្នា គឺការយំរបស់បុគ្គលដែលសោយសោក ដល់អ្នកដែលស្លាប់ទៅ គឺស្លាប់ទៅហើយនោះ សម្រេចការឧបមេយ្យដូច្នោះដូចគ្នា មិនជាប្រយោជន៍ក្រៃលែងជាងពាលទារក ដែលយំចង់បានព្រះចន្ទនេះទៅទៀត ព្រោះហេតុអ្វី ព្រោះពាលទារកនោះ យំទារព្រះចន្ទដែលមាន ចំណែកប្តីរបស់ខ្ញុំស្លាប់ហើយ ឥឡូវនេះ មិនប្រាជក សូម្បីគេយកឈើសូលចាក់ដុតក៏មិនដឹងអ្វី ។

សក្កទេវរាជ ទ្រង់បានស្តាប់ពាក្យរបស់កិរិយាហើយ ត្រាស់សួរទាសីថា

នៃនាង នាងជាអ្វីនឹងបុរសនេះ ទាសីឆ្លើយថា គាត់ជាចៅហ្វាយខ្ញុំ សក្កៈត្រាស់ថា នាងត្រូវបុរសនេះបៀតបៀនវាយតប់ ហើយប្រើពិត ព្រោះដូច្នោះទើបមិនយំព្រោះគិតថា បុរសនេះផុតទៅល្អហើយ ។ ទាសីពោលថា អ្នកកុំពោលយ៉ាងនោះឡើយ ពាក្យដែលអ្នកពោលនេះមិនសមគួរដល់ខ្ញុំ អយ្យបុត្តរបស់ខ្ញុំដល់ព្រមដោយខន្តិ មេត្តា និងការអាណិតអាសូរ ដូចបុត្តដែលខ្ញុំឲ្យចម្រើនក្នុងទ្រូង ។ សក្កទេវរាជត្រាស់ថា បើយ៉ាងនោះព្រោះហេតុអ្វីទើបនាងមិនយំ ចំណែកទាសី កាលប្រាប់ហេតុដែលមិនយំដល់សក្កៈនោះ ទើបពោលគាថា ២ ថា

ក្អមទឹកដែលបែកធ្លាយ តវិញមិនជាប់យ៉ាងណា បុគ្គលសោកស្តាយនឹងអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបធៀប ក៏យ៉ាងនោះដែរ រាងកាយកាលត្រូវគេដុតរមែងមិនដឹងនូវសេចក្តីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់ទុំ គតិណា ជារបស់គេ គេក៏ទៅកាន់គតិនោះ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា ក្អមទឹកដែលគេលើកឡើងរអិលធ្លាក់បែកជា ៧ ចំរៀក មិនអាចតម្រៀបអំបែងទាំងនោះ ហើយធ្វើឲ្យត្រឡប់ជាប្រក្រតីបានយ៉ាងណា សេចក្តីសោករបស់បុគ្គលអ្នកសោក ដល់មនុស្សដែលស្លាប់ទៅហើយនោះ ក៏សម្រេចដោយការឧបមេយ្យ ដូចគ្នាយ៉ាងនោះ ព្រោះមិនអាចធ្វើមនុស្សដែលស្លាប់ឲ្យរស់មកវិញបាន ម្យ៉ាងទៀត បុគ្គលអ្នក

មានឫទ្ធិ មិនអាចតផ្ទាំងដែលបែកហើយ ឲ្យពេញដោយទឹកដោយអានុភាពនៃឫទ្ធិយ៉ាងណា បុគ្គលដែលស្លាប់ហើយ បុគ្គលណាមួយ ក៏មិនអាចធ្វើឲ្យត្រឡប់ជាប្រក្រតីដូចដើមដោយកម្លាំងឫទ្ធិបានដូច្នោះ ។ គាថាក្រៅអំពីនេះមានអត្ថដូចពោលទុកហើយក្នុងគាថាមុននោះឯង ។

សក្កទេវរាជទ្រង់ស្តាប់ធម្មកថារបស់មនុស្សទាំងអស់ហើយ ទ្រង់ជ្រះថ្លាត្រាស់ថា អ្នកទាំងឡាយជាអ្នកមិនប្រមាទ ចម្រើនមរណស្សតិ ចាប់តាំងអំពីនេះទៅ អ្នកទាំងឡាយមិនចាំបាច់ធ្វើការងារដោយដៃរបស់ខ្លួន យើងជាសក្កទេវរាជ យើងនឹងធ្វើរតនៈ ៧ ដែលមិនមានប្រមាណទុកក្នុងផ្ទះរបស់ពួកអ្នក អ្នកទាំងឡាយ ចូរឲ្យទាន រក្សាសីល ធ្វើឧបោសថ ចូរជាអ្នកមិនប្រមាទចុះ ។ កាលឲ្យឱវាទដល់ជនទាំងនោះហើយ ទ្រង់ធ្វើផ្ទះឲ្យមានទ្រព្យ ប្រមាណមិនបាន ហើយជៀសចេញទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ កុដុម្ពិកៈតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ទាសីក្នុងកាលនោះ បានមកជានាងខុជ្ជុត្តរា ក្នុងកាលឥឡូវនេះ កូនស្រីក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណា កូនប្រុសក្នុងកាលនោះបានមកជារាហុល មាតាក្នុងកាលនោះបានមកជានាងខេមា ចំណែកព្រាហ្មណ៍ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ឧរគជាតក ចប់**

# ធជ្ជជាតក

[ ២១ ] ( ស្តេចធជ្ជ:សួរព្រះរាជាពោធិសត្វថា ) ពួកជនឯទៀតតែង សោកយំទួញ ពួកជនឯទៀត មានមុខជោកដោយទឹកភ្នែក ម្នាលយុវកុមារ អ្នកមានសម្បុរមុខស្រស់បស់ អ្នកមិនសោកសៅ ព្រោះហេតុអ្វី ។

[ ២២ ] ( ព្រះពោធិសត្វឆ្លើយថា ) សេចក្តីសោកនាំមកនូវសេចក្តី សុខដែលកន្លងទៅហើយមិនបានទេ នាំមកនូវសេចក្តីសុខ ដែលមិនទាន់មក មិនបានទេ បពិត្រស្តេចធជ្ជ: ព្រោះហេតុនោះទើបខ្ញុំមិនសោក ភាពជាសម្លាញ់ ក្នុងសេចក្តីសោកមិនមានទេ ។

[ ២៣ ] បុគ្គលកាលសោក រមែងជាអ្នកមានរោគលឿង ស្គាំងស្គម ទាំងបាយរមែងមិនពេញចិត្តដល់បុគ្គលនោះ បុគ្គលដែលត្រូវសរ គឺសេចក្តី សោកមុតហើយ ក៏ទុក្ខព្រួយ ពួកជនជាសត្រូវរមែងមានចិត្តត្រេកអរ ។

[ ២៤ ] សេចក្តីវិនាសនឹងមករកខ្ញុំដែលឋិតនៅក្នុងស្រុកឬក្នុងព្រៃ ក្នុង ទីទាបឬទីទួលមិនបានទេ ( ព្រោះ ) ខ្ញុំឃើញច្បាស់ផ្លូវធម៌យ៉ាងនេះហើយ ។

[ ២៥ ] បុគ្គលណាមានខ្លួនតែមួយ មិនអាចជាអ្នកនាំយកនូវរសនៃ សេចក្តីប្រាថ្នា គឺសុខក្នុងឈានទាំងពួងបាន សូម្បីផែនដីទាំងមូល ក៏មិនអាច នាំមកនូវសេចក្តីសុខដល់បុគ្គលនោះបាន ។

**ចប់ ធជ្ជជាតកទី ៥**

# អដ្ឋកថា

# ចណ្ឌជាតក

[ ២១-២៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាមាត្យរបស់ព្រះបាទកោសល ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អញ្ញោ សោចន្តិ រោទន្តិ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នដូចគ្នានឹងរឿងដែលពោលហើយខាងដើមនោះឯង ចំណែកក្នុងជាតកនេះ ព្រះរាជាទ្រង់ប្រទានយសធំដល់អាមាត្យ ដែលឧបការៈទ្រង់ក្រោយមក ទ្រង់ជឿពាក្យញុះញង់ ទើបទ្រង់ចងអាមាត្យនោះ ហើយឲ្យឃុំឃាំងក្នុងគុក ។ អាមាត្យនោះអង្គុយក្នុងគុកនោះឯង ធ្វើសោតាបត្តិមគ្គឲ្យកើតហើយ ព្រះរាជាទ្រង់កំណត់ដល់គុណរបស់អាមាត្យនោះ ទើបឲ្យដោះលែងពីគុក ។ អាមាត្យនោះ ទើបកាន់យកគ្រឿងក្រអូបនិងផ្កាកម្រងទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរអាមាត្យនោះថា បានឮថា វត្ថុមិនមែនជាប្រយោជន៍ កើតឡើងដល់អ្នកឬ អាមាត្យនោះក្រាបទូលថា ករុណាព្រះអង្គ ប្រយោជន៍ក៏មកដល់ខ្ញុំព្រះអង្គ ដោយវត្ថុដែលមិនជាប្រយោជន៍ គឺសោតាបត្តិមគ្គកើតឡើងហើយ ។ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលឧបាសក មិនមែនតែអ្នកប៉ុណ្ណោះទេដែលនាំយកប្រយោជន៍ ដោយវត្ថុដែលមិនមែនជាប្រយោជន៍ សូម្បីបុរាណកបណ្ឌិតទាំងឡាយ ក៏នាំមកហើយ កាលអាមាត្យនោះទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ បានបដិសន្ធិក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទព្រហ្មទត្ត អង្គនោះ ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមព្រះពោធិសត្វថា យជកុមារ ។ សម័យតមក យជកុមារនោះ រៀនសិប្បៈក្នុងនគរតក្កសិលា ហើយគ្រងរាជសម្បត្តិដោយធម៌ ។ អាមាត្យម្នាក់នៅខាងក្នុងព្រះរាជវាំងរបស់ព្រះរាជានោះ គិតប្រទុស្តព្រះរាជានោះ ទ្រង់ជ្រាបដោយជាក់ច្បាស់ ទើបបណ្តេញអាមាត្យនោះចេញអំពីដែន ។ គ្រានោះ ព្រះបាទធង្កៈ គ្រងរាជសម្បត្តិក្នុងនគរសាវត្ថី ។ អាមាត្យនោះបានទៅកាន់រាជសម្នាក់របស់ព្រះបាទធង្កៈនោះ ឧបដ្ឋាកឲ្យកាន់យកពាក្យរបស់ខ្លួនដោយន័យដូចពោលហើយខាងដើមនោះឯង ហើយឲ្យដណ្តើមយករាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះបាទធង្កៈនោះ ដណ្តើមរាជសម្បត្តិបានហើយ ឲ្យយកច្រវាក់ចងព្រះពោធិសត្វ ហើយបញ្ចូលទៅក្នុងពន្ធនាគារ ។ ព្រះពោធិសត្វធ្វើឈានឲ្យកើតឡើង ហើយអង្គុយពត់ភ្នែនក្នុងអាកាស ។ ការក្តៅក្រហាយតាំងឡើងក្នុងសរីរៈរបស់ព្រះបាទធង្កៈទើបទ្រង់យាងទៅមើល ឃើញព្រះពោធិសត្វ ស្អាតដូចកញ្ចក់មាស និងផ្កាឈូករីកកាលនឹងសួរទើបត្រាស់គាថាទី ១ ថា

ពួកជនឯទៀតតែងសោកយំទួញ ពួកជនឯទៀតមានមុខជោក
ដោយទឹកភ្នែក ម្នាលយជកុមារអ្នកមានសម្បុរមុខស្រស់បស់
អ្នកមិនសោកសៅ ព្រោះហេតុអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អញ្ញេ** សំដៅដល់មនុស្សដ៏សេស វៀរព្រះ

ពោធិសត្វនោះ ។

លំដាប់នោះ ព្រះពោធិសត្វកាលប្រាប់ហេតុដែលមិនសោយសោកដល់ព្រះបាទធនុ្ក:នោះ ទើបពោលគាថា ៤ ថា

សេចក្តីសោកនាំមកនូវសេចក្តីសុខ ដែលកន្លងទៅហើយ មិនបានទេ នាំមកនូវសេចក្តីសុខដែលមិនទាន់មក មិនបានទេ បពិត្រស្តេចធនុ្ក: ព្រោះហេតុនោះ ទើបខ្ញុំមិនសោក ភាពជាសម្លាញ់ក្នុងសេចក្តីសោក មិនមានទេ ។

បុគ្គលកាលសោក រមែងជាអ្នកមានរោគលឿង ស្គាំងស្គម ទាំងបាយរមែងមិនពេញចិត្តដល់បុគ្គលនោះ បុគ្គលដែលត្រូវសរ គឺសេចក្តីសោកមុតហើយ ក៏ទុក្ខព្រួយ ពួកជនជាសត្រូវរមែងមានចិត្តត្រេកអរ ។

សេចក្តីវិនាសនឹងមករកខ្ញុំដែលឋិតនៅក្នុងស្រុក ឬក្នុងព្រៃ ក្នុងទីទាប ឬទីទួលមិនបានទេ ( ព្រោះ ) ខ្ញុំឃើញច្បាស់ផ្លូវធម៌យ៉ាងនេះហើយ ។

បុគ្គលណាមានខ្លួនតែមួយ មិនអាចជាអ្នកនាំយកនូវរសនៃសេចក្តីប្រាថ្នា គឺសុខក្នុងឈានទាំងពួងបាន សូម្បីផែនដីទាំងមូលក៏មិនអាចនាំមកនូវសេចក្តីសុខដល់បុគ្គលនោះបានដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាត្តតីតមាហោ** បានដល់ នាំវត្ថុដែលកន្លងទៅហើយមកមិនបាន ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនោះដូចគ្នា ។ ឈ្មោះថា

សេចក្តីសោករមែងនាំយកសេចក្តីសុខ ដែលជាអតីត ដែលកន្លងទៅហើយ ដែលរលាយរលត់ទៅហើយមកវិញមិនបានទេ ។ បទថា **ទុតិយតា** បាន ដល់ ភាពជាសម្លាញ់ ។ ព្រះពោធិសត្វពោលថា ឈ្មោះថា សេចក្តីសោក រមែងមិនជាសម្លាញ់របស់បុគ្គលណាមួយ ក្នុងការដែលនាំយកអតីតៈមក ឬ ក្នុងការនាំយកអនាគតមក ដោយហេតុនោះ ទើបខ្ញុំមិនសោយសោក ។ បទ ថា **សោចំ** បានដល់ សោយសោក ។ បទថា **សល្លវិទ្ធស្ស រុប្បតោ** សេចក្តីថា កាលបុគ្គលត្រូវសរ គឺសេចក្តីសោកមុត ត្រូវសរ គឺសេចក្តីសោក ប៉ះខ្ទប់ សត្រូវទាំងឡាយរមែងត្រេកអរថា ពួកយើងឃើញខ្នងសត្រូវហើយ ។ បទថា **ឋិតំ មំ នាគមិស្សតិ** សេចក្តីថា នៃសម្លាញ់ធម្ម: សេចក្តីវិនាស ដែលមានសោកជាមូល ដែលមានសភាវៈជាអ្នកស្តមល្បើងជាដើម នឹងមិន មកដល់យើងដែលឋិតនៅក្នុងទីណាមួយ ក្នុងបណ្តាស្រុកជាដើមនេះ ។ បទ ថា **ឃរំ ឱដ្ឋបនោ** សេចក្តីថា ខ្ញុំបានឃើញ ឈានបទដោយប្រការដែល សេចក្តីវិនាសនោះ មិនទាន់មកដល់ ។ អាចារ្យពួកខ្លះពោលថា **អដ្ឋលោក ធម្មបទំ** បទគឺលោកធម៌ ៨ ដូច្នេះ ក៏មាន ។ តែក្នុងបាលីរចនាថា **ន មត្តំ នាគមិស្សតិ** សេចក្តីស្លាប់នឹងមិនមកដល់ ។ ពាក្យដែលរចនាទុកនោះមិន មានក្នុងអដ្ឋកថាទាំងឡាយ ។

ក្នុងគាថាចុងក្រោយ មានវិនិច្ឆ័យដូចតទៅនេះថា ខ្ទនដែលឈ្មោះថានាំ មកនូវកាមរសទាំងពួង ព្រោះនាំមកនូវសព្វកាមរស ពោលគឺឈានសុខ ព្រោះអត្ថថា គួរចង់បាន គួរប្រាថ្នា ។ លោកបានពោលពាក្យអធិប្បាយនេះ

ទុកថា ព្រះរាជាអង្គណា ព្រះអង្គឯងតែមួយអង្គ វៀរនូវសម្លាញ់ដទៃៗចោល មិនអាចនាំកាមរសទាំងពួងមក គឺមិនអាចនាំមកនូវកាមរសទាំងពួង ពោលគឺសេចក្តីសុខក្នុងឈានទាំងពួង ទ្រព្យសម្បត្តិក្នុងផែនដីទាំងមូល ក៏មិននាំសេចក្តីសុខមកឲ្យដល់ព្រះរាជានោះ ព្រោះធម្មតាសេចក្តីសុខ រមែងមិនមានដល់បុគ្គលដែលក្តៅក្រហាយព្រោះកាម ចំណែកព្រះរាជាណា ដែលអាចនាំមកនូវសេចក្តីសុខក្នុងឈានដែលវៀរចាកសេចក្តីក្រវល់ក្រវាយព្រោះកិលេស ព្រះរាជានោះរមែងជាអ្នកមានសេចក្តីសុខ ។ ចំណែកអត្ថរបស់បាលីក្នុងគាថានេះថា **យស្សេត្ថា ឆាលមេកោ** ដូច្នេះក៏មាននោះ មិនប្រាកដ ។

ព្រះបាទចន្ទៈបានស្តាប់គាថាទាំង ៤ ដោយប្រការដូច្នេះហើយ ទើបសូមខមាទោសព្រះពោធិសត្វ ហើយប្រគល់រាជសម្បត្តិសងវិញ បានចៀសចេញទៅហើយ ។ ចំណែកព្រះមហាសត្វ ប្រគល់រាជសម្បត្តិដល់អាមាត្យទាំងឡាយ ហើយទៅកាន់ហិមវន្តប្បទេសបួសជាឥសី មានឈានមិនសាបសូន្យ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបាទចន្ទៈក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកព្រះបាទយជៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ចន្ទជាតក ចប់

# ការន្ទិយជាតក

[ ២៦ ] ( អាចារ្យសួរថា ) អ្នកតែម្នាក់ឯង រលះរលាំងលើកដុំថ្មធំៗ បោះទៅក្នុងជ្រោះភ្នំក្នុងព្រៃរឿយៗ ម្នាលការន្ទិយៈ អ្នកមានប្រយោជន៍ដូចម្តេចក្នុងជ្រោះនេះ ។

[ ២៧ ] ( ពោធិសត្វឆ្លើយថា ) ខ្ញុំនឹងធ្វើនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យស្មើដូចជាផ្ទៃបាតដៃ ព្រោះហេតុនោះ បានជាខ្ញុំពង្រាបភ្នំដីនិងភ្នំថ្ម ហើយបោះថ្មទៅក្នុងជ្រោះ ។

[ ២៨ ] ( អាចារ្យពោលថា ) បុគ្គលម្នាក់ មិនគួរដើម្បីធ្វើផែនដីធំនេះឲ្យរាបស្មើដូចបាតដៃបានទេ ម្នាលការន្ទិយៈ ខ្ញុំសម្គាល់នូវអ្នកដែលស្វែងរកថ្មភ្នំនេះឯង ( ដើម្បីបំពេញជ្រោះ ) អ្នកនឹងលះបង់នូវជីវលោក ( ស្លាប់ខ្លួន ) ។

[ ២៩ ] ( ពោធិសត្វពោលថា ) បើមនុស្សម្នាក់នេះមិនអាចដើម្បីធ្វើនូវផែនដីធំនេះ ឲ្យរាបស្មើបានទេយ៉ាងណា ម្នាលព្រាហ្មណ៍ អ្នកនឹងដឹកនាំពួកមនុស្សទាំងនេះ ដែលមានទិដ្ឋិផ្សេងៗគ្នាមិនបាន ក៏យ៉ាងនោះដែរ ។

៣០ ] ( អាចារ្យពោលថា ) ម្នាលការន្ទិយៈ អ្នកដ៏ចម្រើនពោលនូវពាក្យនេះដោយសង្ខេប ជាពាក្យមានប្រយោជន៍ដល់ខ្ញុំយ៉ាងនេះ ផែនដីនេះគេមិនអាចធ្វើឲ្យរាបស្មើយ៉ាងណា ពួកមនុស្ស ក៏មនុស្សមិនអាចធ្វើបានយ៉ាងនោះដែរ ។

**ចប់ ការន្ទិយជាតកទី ៦**

# អដ្ឋកថា

## ការន្ទិយជាតក

[ ២៦-៣០ ] ព្រះសាស្តាកាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មសេនាបតី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯកោ អរញ្ញេ** ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈឲ្យសីលដល់បុគ្គលទ្រុស្តសីលទាំងឡាយ មានព្រានម្រឹគនិងអ្នកចាប់ត្រីជាដើមដែលធ្លងមកដែលលោកបានឃើញប៉ុណ្ណោះថា អ្នកទាំងឡាយចូរកាន់សីល អ្នកទាំងឡាយចូរកាន់សីល ។ ជនទាំងនោះមានសេចក្តីគោរពក្នុងព្រះថេរៈ មិនអាចទម្លាយពាក្យរបស់ព្រះថេរៈនោះ ទើបនាំគ្នាទទួលសីល កាលទទួលហើយក៏មិនរក្សា នៅតែធ្វើការងាររបស់ខ្លួននោះឯង ព្រះថេរៈហៅសទ្ធិវិហារិកទាំងឡាយរបស់ខ្លួនមកហើយពោលថា អាវុសោទាំងឡាយ មនុស្សទាំងនេះទទួលសីលក្នុងសម្នាក់របស់ខ្ញុំ កាលទទួលហើយក៏មិនរក្សា ។ សទ្ធិវិហារិកទាំងឡាយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ឲ្យសីលដោយការមិនពេញចិត្តរបស់ជនទាំងនោះ ពួកគេមិនអាចជំទាស់ពាក្យរបស់លោកម្ចាស់បាន ទើបទទួលយក ចាប់អំពីនេះទៅ សូមលោកម្ចាស់កុំឲ្យសីលដល់ជនទាំងឡាយបែបនេះ ។ ព្រះថេរៈមានចិត្តមិនជារបស់ខ្លួន ( មិនពេញចិត្តនឹងពាក្យរបស់សទ្ធិវិហារិក ) ។ ភិក្ខុទាំងឡាយបានស្តាប់រឿងនោះហើយក៏សន្ទនាគ្នាឡើងក្នុងធម្មសភាថា អាវុសោទាំងឡាយ បានឮថា ព្រះសារីបុត្ត ឲ្យសីលដល់មនុស្សដែលលោកបានជួបនោះឯង ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នក

អន្តុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន សារីបុត្តក៏ឲ្យសីលដល់មនុស្សដែលខ្លួនបានជួប បានឃើញ ដែលមិនសូមសីលឡើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ លុះចម្រើនវ័យហើយ បានជាអន្តេវាសិកច្បងនៃអាចារ្យទិសាបាមោក្ខក្នុងនគរតក្កសិលាមានឈ្មោះថា គោរណ្ឌិយៈ កាលណោះ អាចារ្យនោះឲ្យសីលដល់មនុស្សដែលខ្លួនបានជួប បានឃើញ មានអ្នកប្រមង់ជាដើម ដែលមិនសូមសីលដោយពោលថា អ្នកទាំងឡាយចូរទទួលសីល អ្នកទាំងឡាយចូរទទួលសីល ដូច្នេះ ។ ជនទាំងនោះសូម្បីទទួលយកហើយ ក៏មិនរក្សា ។ អាចារ្យក៏ប្រាប់សេចក្តីនោះ ដល់អន្តេវាសិកទាំងឡាយ អន្តេវាសិកទាំងឡាយក៏នាំគ្នាពោលថា បពិត្រលោកអាចារ្យ លោកឲ្យសីលដោយការមិនគាប់ចិត្តរបស់មនុស្សទាំងនោះ ព្រោះដូច្នោះ ទើបពួកគេទម្លាយចោល ចាប់អំពីថ្ងៃនេះទៅ លោកអាចារ្យគប្បីឲ្យចំពោះ ដល់បុគ្គលដែលសូមប៉ុណ្ណោះ កុំឲ្យដល់បុគ្គលដែលមិនសូម ។ អាចារ្យនោះ បានជាអ្នកមានវិប្បដិសារៈក្តៅក្រហាយចិត្ត កាលបើយ៉ាងនោះ ក៏នៅតែឲ្យសីលដល់បុគ្គលដែលខ្លួនជួបនោះឯង ។ ថ្ងៃមួយ មនុស្សទាំងឡាយ មកអំពីស្រុកមួយអញ្ជើញអាចារ្យទៅដើម្បីត្រូវការសូត្យមន្តរបស់ព្រាហ្មណ៍ អាចារ្យនោះហៅ

កោរណ្ឌិយមាណពមកហើយពោលថា នែបា យើងមិនទៅ ចូរអ្នកនាំមាណព ៥០០ ទៅក្នុងទីនោះ ទទួលនូវការសូត្យ ហើយចូរនាំយកចំណែកដែលគេឲ្យដល់យើងមក ដូច្នេះ ហើយទើបបញ្ជូនទៅ ។ កោរណ្ឌិយមាណពនោះទៅហើយត្រឡប់មក ក្នុងរវាងផ្លូវឃើញញកភ្នំមួយកន្លែងគិតថា អាចារ្យរបស់ពួកយើងឲ្យសីលដល់មនុស្សដែលបានជួប ដែលមិនសូមសីលឡើយ ចាប់តាំងអំពីនេះទៅ យើងនឹងធ្វើអាចារ្យនោះ ឲ្យជាអ្នកឲ្យសីលចំពោះបុគ្គលដែលសូមប៉ុណ្ណោះ កាលពួកមាណពនោះកំពុងអង្គុយសប្បាយ មាណពក្រោកឡើងទៅយកថ្មដុំធំបោះទៅក្នុងជ្រោះ បោះហើយបោះទៀតនោះឯង ។ លំដាប់នោះមាណពទាំងនោះ ក៏ក្រោកឡើងនិយាយនឹង កោរណ្ឌិយមាណពនោះថា នែអាចារ្យអ្នកធ្វើអ្វី កោរណ្ឌិយមាណពនោះ មិនពោលពាក្យណាមួយ ។ មាណពទាំងនោះ ទើបប្រញាប់ទៅប្រាប់អាចារ្យ អាចារ្យមកហើយ កាលនឹងចរចាជាមួយ កោរណ្ឌិយមាណពនោះ ទើបពោលគាថាទី ១ ថា

អ្នកតែម្នាក់ឯង រលះរលាំងលើកដុំថ្មធំៗ បោះទៅក្នុងជ្រោះភ្នំ
ក្នុងព្រៃរឿយៗ ម្នាលការន្ទិយៈ អ្នកមានប្រយោជន៍ដូចម្តេច
ក្នុងជ្រោះនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ នុ តវ៎យិធត្ថោ** សេចក្តីថា ប្រយោជន៍អ្វីហ្ន៎ ដែលឯងទម្លាក់ដុំថ្មចុះក្នុងជ្រោះនេះ ។

កោរណ្ឌិយមាណពនោះ បានស្តាប់ពាក្យរបស់អាចារ្យនោះហើយបំណងនឹងទូន្មានអាចារ្យ ទើបពោលគាថាទី ២ ថា

ខ្ញុំនឹងធ្វើនូវផែនដីនេះដែលមានសាគរជាទីបំផុត ឲ្យស្មើដូចជាផ្ទៃបាតដៃ ព្រោះហេតុនោះបានជាខ្ញុំពង្រាបភ្នំដីនិងភ្នំថ្ម ហើយបោះថ្មទៅក្នុងជ្រោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អហាញ្ញិមំ** សេចក្ដីថា ខ្ញុំយកដុំថ្មតូចធំទម្លាក់ចុះនឹងធ្វើមហាប្រឹថពីឲ្យរាបស្មើ ។ បទថា **សាគរសេវិតន្តំ** បានដល់ ដែលសាគរនិងសមុទ្រព័ទ្ធហើយ មានមហាសមុទ្រទាំង ៤ ជាទីបំផុត ។ បទថា **យថាបិ ចាណិ** សេចក្ដីថា ខ្ញុំនឹងធ្វើឲ្យរាបស្មើដូចបាតដៃ ។ បទថា **វិកិរិយ** បានដល់ ពង្រាបហើយ ។ បទថា **សានូនិ ច បព្វតានិ** បានដល់ ភ្នំដីនិងភ្នំថ្ម ។

ព្រាហ្មណ៍បានស្ដាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

បុគ្គលម្នាក់ មិនគួរដើម្បីធ្វើផែនដីធំនេះឲ្យរាបស្មើ ដូចបាតដៃបានទេ ម្នាលការទ្ធិយៈ ខ្ញុំសម្គាល់នូវអ្នកដែលស្វែងរកថ្មភ្នំនេះឯង (ដើម្បីបំពេញជ្រោះ) អ្នកនឹងលះបង់នូវជីវលោក (ស្លាប់ខ្លួន) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ករណាយមេកោ** នេះ លោកសម្ដែងថា បុគ្គលម្នាក់ មិនអាចធ្វើបាន គឺមិនអាចនឹងធ្វើបាន ។ បទថា **មញ្ញាមិមញ្ញេវ ធរឹ ឯតិសំ** សេចក្ដីថា ខ្ញុំរមែងសម្គាល់ថា ផែនដីនេះស្ទេះទុកសិនចុះ ញកភ្នំមួយនេះប៉ុណ្ណោះ អ្នកព្យាយាមដើម្បីធ្វើឲ្យពេញ ស្វែងរកដុំថ្មទាំងឡាយមកគិតត្រិះរិះរកឧបាយនោះឯង នឹងលះជីវលោកនេះទៅ អធិប្បាយថា នឹងស្លាប់

ទេវ ។

មាណពបានស្តាប់ពាក្យនោះ ទើបពោលគាថាទី ៤ ថា

បើមនុស្សម្នាក់នេះ មិនអាចដើម្បីធ្វើនូវផែនដីធំនេះ ឲ្យរាបស្មើ
បានទេយ៉ាងណា ម្នាលព្រាហ្មណ៍ អ្នកនឹងដឹកនាំពួកមនុស្សទាំង
នេះ ដែលមានទិដ្ឋិផ្សេងៗគ្នាមិនបាន ក៏យ៉ាងនោះដែរ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអត្ថថា បើមនុស្សម្នាក់នេះមិនអាច គឺមិនអាចធ្វើផែនដី គឺប្រឹថពីធំនេះឲ្យរាបស្មើបានយ៉ាងណា បពិត្រព្រាហ្មណ៍ លោកអាចារ្យក៏នឹងធ្វើមនុស្សទ្រុស្តសីល មានទិដ្ឋិផ្សេងៗគ្នាមិនបានក៏យ៉ាងនោះ ដូចគ្នា គឺលោកពោលនឹងមនុស្សទាំងនោះថា ពួកអ្នកចូរទទួលសីល ពួកអ្នកចូរទទួលសីល នឹងនាំមកកាន់អំណាចរបស់ខ្លួនមិនបានយ៉ាងនោះព្រោះថាមនុស្សដែលជាបណ្ឌិតប៉ុណ្ណោះរមែងតិះដៀលបាណាតិបាត ថាជាអកុសល ចំណែកបុគ្គលពាលមិនជៀសវាងព្រោះ ជាអ្នកមានការសម្គាល់ ក្នុងសេចក្តីនោះថាជាកុសល លោកនឹងនាំមនុស្សទាំងនោះមកបានដូចម្តេច ព្រោះដូច្នោះ លោកកុំឲ្យសីលដល់មនុស្សដែលបានជួប ចូរឲ្យដល់មនុស្សដែលសូមប៉ុណ្ណោះ ។

អាចារ្យបានស្តាប់ដូច្នោះគិតថា កោរណ្ឌិយៈនិយាយត្រូវ ឥឡូវនេះ អញនឹងមិនធ្វើយ៉ាងនោះ កាលដឹងថាខ្លួនខុសហើយ ទើបពោលគាថាទី ៥ ថា

ម្នាលការន្ទិយៈ អ្នកដ៏ចម្រើនពោលនូវពាក្យនេះដោយសង្ខេប
ជាពាក្យមានប្រយោជន៍ដល់ខ្ញុំយ៉ាងនេះ ផែនដីនេះគេមិនអាច
ធ្វើឲ្យរាបស្មើយ៉ាងណា ពួកមនុស្ស ក៏មនុស្សមិនអាចធ្វើបាន

យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមាយំ** កាត់បទជា **សមា អយំ** ។ អាចារ្យបានធ្វើការសរសើរមោណពយ៉ាងនេះ ។ ចំណែកមាណពនោះ ដាស់តឿនអាចារ្យនោះហើយ ក៏នាំអាចារ្យទៅកាន់ផ្ទះ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាសារីបុត្តក្នុងកាលឥឡូវនេះ ចំណែក កោរណ្ឌិយបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កោរណ្ឌិយជាតក ចប់

# លដុកិកជាតក

[ ៣១ ] ( ចាបចៀបកប្បាសពោលនឹងដំរីពោធិសត្វថា ) ខ្ញុំសូមថ្វាយបង្គំលោកជាដំរីមានកម្លាំងខ្សោយក្នុងកាលមានអាយុ ៦០ ជាអ្នកនៅក្នុងព្រៃជាម្ចាស់ហ្វូង មានយស ខ្ញុំសូមធ្វើនូវអញ្ជលិកម្មចំពោះលោក ដោយស្លាបទាំងឡាយ សូមកុំឲ្យលោកសម្លាប់កូនរបស់ខ្ញុំជាសត្វមានកម្លាំងខ្សោយ ។

[ ៣២ ] ( ចាបចៀបកប្បាសពោលនឹងដំរីទេវទត្តថា ) ខ្ញុំសូមថ្វាយបង្គំលោកជាដំរីត្រាច់ទៅតែម្នាក់ឯង ជាអ្នកនៅក្នុងព្រៃ ដើរទៅតាមញកភ្នំ ខ្ញុំសូមធ្វើអញ្ជលិកម្មដោយស្លាបទាំងឡាយ សូមលោកកុំសម្លាប់កូនខ្ញុំ ជាសត្វមានកម្លាំងខ្សោយ ។

[ ៣៣ ] ( ដំរីទេវទត្តពោលថា ) នែមេចាបចៀបកប្បាស អញនឹងសម្លាប់នូវកូននាង នាងជាសត្វមានកម្លាំងខ្សោយនឹងធ្វើអ្វីដល់អញ អញនឹងជាន់នូវចាបសូម្បីមួយសែនប្រហែលនឹងនាងឯង ដោយជើងឆ្វេង ។

[ ៣៤ ] ( ចាបចៀបកប្បាសពោលថា ) កិច្ចដោយកម្លាំងកាយ មិនមែនប្រើបានគ្រប់កន្លែងទេ ព្រោះកម្លាំងកាយសម្លាប់បានតែអ្នកល្ងង់ទេ នែស្តេចដំរី អ្នកណាសម្លាប់កូនរបស់ខ្ញុំជាសត្វមានកម្លាំងខ្សោយ ខ្ញុំនឹងធ្វើសេចក្តីវិនាសដល់អ្នកនោះវិញ ។

[ ៣៥ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) អ្នកចូរមើលនូវក្អែក ចាបចៀបកប្បាស កន្កែបទិងរុយខៀវ សត្វទាំងនុ៎ះ សម្លាប់នូវដំរីបាន អ្នកចូរមើល ( នូវគតិ ) នៃពៀររបស់ពួកសត្វមានពៀរ ព្រោះហេតុនោះ អ្នកទាំងឡាយកុំធ្វើនូវពៀរនឹងជនណាមួយ សូម្បីមិនជាទីស្រឡាញ់ឡើយ ។

**ចប់ លដុកិកជាតកទី ៧**

# អដ្ឋកថា
# លដុកិកជាតក

[ ៣១-៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វន្ទាមិ តំ កុញ្ជរំ សដ្ឋិ-ហាយនំ** ដូច្នេះជាដើម ។

បានឮថា ថ្ងៃមួយភិក្ខុទាំងឡាយ ប្រជុំសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តជាមនុស្សរឹងត្អឹង គ្រោតគ្រាត ឃោរឃៅ ទេវទត្តនោះមិនមានសូម្បីតែករុណាក្នុងពួកសត្វ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេសូម្បីក្នុងកាលមុន ទេវទត្តនេះ ក៏ជាអ្នកមិនមានសេចក្តីករុណាដូចគ្នា ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតដំរី ចម្រើនវ័យហើយ មានរាងកាយធំគួរជ្រះថ្លា ជាមេហ្វូង មានដំរី ៨ ម៉ឺនជាបរិវារ នៅក្នុងហិមវន្តប្បទេស ។ គ្រានោះ ចាបចៀបកប្បាសមួយ កាច់សម្បុកពងក្នុងទីមួយកន្លែង ដែលជាទីត្រាច់ទៅរបស់ពួកដំរី ។ កូនបក្សីទាំងឡាយញាស់ចេញមក កាលកូនបក្សីទាំងនោះស្វាបមិនទាន់អាចហើរទៅបាន ព្រះមហាសត្វដែលដំរី ៨ ម៉ឺន ចោមរោម

ដើររកអាហារទៅដល់កន្លែងនោះ ចាបចៀបកប្បាសឃើញដូច្នោះ គិតថា ស្តេចដំរីនេះនឹងជាន់កូនទាំងឡាយរបស់អញស្លាប់ ណ្ហើយចុះ អញនឹងសូមនូវការរក្សាដែលប្រកបដោយធម៌ជាមួយស្តេចដំរីនេះ ដើម្បីការពារនូវកូនតូចទាំងឡាយរបស់អញ ។ កាលគិតហើយ ចាបនោះក៏ផ្គងស្លាបទាំងពីរចូលគ្នា ហើយឈរខាងមុខស្តេចដំរីនោះ ពោលគាថាទី ១ ថា

ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីមានកម្លាំងខ្សោយក្នុងកាលមាន
អាយុ ៦០ ជាអ្នកនៅក្នុងព្រៃ ជាម្ចាស់ហ្វូង មានយស ខ្ញុំ
សូមធ្វើនូវអញ្ជលិកម្មចំពោះលោកដោយស្លាបទាំងឡាយ សូម
កុំឲ្យលោកសម្លាប់កូនរបស់ខ្ញុំជាសត្វមានកម្លាំងខ្សោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សដ្ឋិហាយនំ** បានដល់ មានកម្លាំងខ្សោយក្នុងកាលមានអាយុ ៦០ ឆ្នាំ ។ បទថា **យសស្សឹ** បានដល់ ដល់ព្រមដោយបរិវារ ។ បទថា **បក្ខេហិ តំ អញ្ជលិកំ ករោមិ** សេចក្តីថា ខ្ញុំសូមធ្វើអញ្ជលីលោក ដោយស្លាបទាំងពីរ ។

ព្រះមហាសត្វពោលថា ម្នាលចាបចៀបកប្បាស ចូរនាងកុំទោមនស្សឡើយ យើងនឹងរក្សាកូនតូចរបស់នាង ហើយទើបឈរក្រុងអំពីខាងលើកូនបក្សីទាំងឡាយ កាលដំរី ៨ ម៉ឺនដើរចេញទៅហើយ ទើបហៅមេចាបមកពោលថា នែនាង មានដំរីមួយ មានប្រក្រតីត្រាច់ទៅតែឯកឯង នឹងមកខាងក្រោយពួកយើង ដំរីនោះនឹងមិនធ្វើតាមពាក្យរបស់យើងទាំងឡាយ កាលដំរីនោះមកដល់ នាងគប្បីអង្វរដំរីនោះធ្វើនូវសួស្តីដល់កូនតូចទាំងឡាយដូច្នេះហើយ

ក៏ចៀសចេញទៅ ។ ចំណែកចាបចៀបកប្បាសនោះ ធ្វើការទទួលដំរីនោះ ដោយស្លាបទាំងពីរ ធ្វើអញ្ជលី ហើយពោលគាថាទី ២ ថា

ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីត្រាច់ទៅតែម្នាក់ឯង ជាអ្នកនៅ
ក្នុងព្រៃ ដើរទៅតាមញកភ្នំ ខ្ញុំសូមធ្វើអញ្ជលិកម្មដោយស្លាប
ទាំងឡាយ សូមលោកកុំសម្លាប់កូនខ្ញុំជាសត្វមានកម្លាំងខ្សោយ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បព្វតសានុគោចរំ** សេចក្ដីថា ជាអ្នករក អាហារត្រង់ក្អំថ្មនិងក្អំដី ។

ស្ដេចដំរីនោះ បានស្ដាប់ពាក្យរបស់ចាបចៀបកប្បាសនោះហើយ បាន ពោលគាថាទី ៣ ថា

នែមេចាបចៀបកប្បាស អញនឹងសម្លាប់នូវកូននាង នាងជា
សត្វមានកម្លាំងខ្សោយ នឹងធ្វើអ្វីដល់អញ អញនឹងជាន់នូវចាប
សូម្បីមួយសែនប្រហែលនឹងនាងឯងដោយជើងឆ្វេង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វធិស្សាមិ តេ** សេចក្ដីថា ស្ដេចដំរីពោលថា ព្រោះហេតុអ្វី ទើបនាងដាក់កូនតូចទាំងឡាយក្នុងផ្លូវដែលជាទីទៅរបស់យើង ព្រោះហេតុអ្វីទើបនាងដាក់ទុកដូច្នោះ យើងនឹងសម្លាប់កូនខ្ចីទាំងឡាយ របស់ នាង ។ បទថា **កឹ មេ ត្វំ ការិស្សសិ** សេចក្ដីថា នាងជាសត្វទុព្វល នឹងធ្វើអ្វី ដល់អញដែលមានកម្លាំងច្រើន ។ បទថា **បប្បោថយេយ្យំ** សេចក្ដីថា យើង គប្បីធ្វើចាបចៀបកប្បាសដូចនាង ១ សែន ឲ្យបែកល្អិតដោយជើងឆ្វេង នឹង

ពោលថ្វីដល់ជើងស្តាំ ។

កាលដំរីនោះពោលយ៉ាងនេះហើយ ក៏ធ្វើកូនតូចទាំងឡាយ របស់ចាប ចៀបកប្បាសនោះ ឲ្យបែកខ្ទេចខ្ទីដោយជើង ហើយធ្វើឲ្យអណ្តែតទៅដោយ ទឹកមូត្រ បន្លឺសំឡេងហើយក៏ចៀសចេញទៅ ។ ចាបចៀបកប្បាស ទំត្រង់ មែកឈើ ពោលថា នែដំរី អំបាញ់មិញនេះឯងស្រែសិនចុះ កន្លងទៅ ២-៣ ថ្ងៃទៀត ឯងនឹងឃើញការធ្វើរបស់អញ ឯងរមែងមិនដឹងថាកម្លាំងប្រាជ្ញាធំ ក្រៃលែងជាងកម្លាំងកាយ សេចក្តីនោះចូរលើកទុក អញនឹងធ្វើឯង ឲ្យដឹងនូវ កម្លាំងប្រាជ្ញានោះ កាលគំរាមដំរីនោះទើបពោលគាថាទី ៤ ថា

> កិច្ចដោយកម្លាំងកាយ មិនមែនប្រើបានគ្រប់កន្លែងទេ ព្រោះ
> កម្លាំងកាយសម្លាប់បានតែអ្នកល្ងង់ទេ នែស្តេចដំរី អ្នកណា
> សម្លាប់កូនរបស់ខ្ញុំ ជាសត្វមានកម្លាំងខ្សោយ ខ្ញុំនឹងធ្វើសេច
> ក្តីវិនាសដល់អ្នកនោះវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពលេន** បានដល់ កម្លាំងកាយ ។ បទថា **អនត្ថំ** បានដល់ សេចក្តីមិនចម្រើន ។ បទថា **យោ មេ** សេចក្តីថា បុគ្គល ណាសម្លាប់ គឺពិឃាដកូនតូចដែលមានកម្លាំងទុព្វលរបស់ខ្ញុំ ។

មេចាបចៀបកប្បាសនោះ ពោលយ៉ាងនោះហើយ ទើបទៅបម្រើក្អែក មួយ បាន ២-៣ ថ្ងៃ ក្អែកនោះត្រេកអរហើយពោលថា យើងនឹងធ្វើអ្វីឲ្យ ដល់នាង ទើបពោលថា នែអ្នក កិច្ចដទៃដែលអ្នកគប្បីធ្វើដល់ខ្ញុំមិនមាន តែ ខ្ញុំចង់ឲ្យអ្នកយកចំពុះប្រហារក្អែកទាំងពីររបស់ដំរី ដែលមានប្រក្រតីត្រាច់ទៅ

តែម្នាក់ឯងឲ្យបែក ។ មេចាបចៀបកប្បាសនោះ កាលក្អែកនោះទទួលពាក្យថា សាធុ ទើបទៅឧបដ្ឋាករុយខៀវមួយ កាលរុយខៀវនោះពោលថា ខ្ញុំនឹងធ្វើអ្វីឲ្យដល់នាង ទើបពោលថា កាលក្អែកទាំងពីររបស់ដំរី មានប្រក្រតីដើរទៅតែឯងបែក ព្រោះក្អែកនេះហើយ ខ្ញុំប្រាថ្នាឲ្យនាងពងក្នុងក្អែកទាំងពីរនោះ កាលរុយខៀវនោះពោលថា សាធុ ទើបទៅឧបដ្ឋាកកង្កែបមួយ កាលកង្កែបនោះពោលថា ខ្ញុំគប្បីធ្វើអ្វីឲ្យដល់នាង ទើបពោលថា ក្នុងកាលណា ដំរីមួយមានប្រក្រតីដើរតែឯង ក្លាយជាដំរីខ្វាក់ហើយ ត្រាច់ស្វែងរកទឹកផឹក ក្នុងកាលនោះអ្នកគប្បីឡើងទៅលើកំពូលភ្នំ ហើយបន្លឺសំឡេងយំ កាលដំរីនោះឡើងលើកំពូលភ្នំ គប្បីចុះមកយំក្នុងជ្រោះ ខ្ញុំប្រាថ្នានូវការធ្វើមានប្រមាណប៉ុណ្ណោះអំពីសម្នាក់របស់អ្នក ។ កង្កែបនោះ បានស្តាប់ពាក្យរបស់ចាបចៀបកប្បាសនោះហើយ ទើបទទួលថា សាធុ ។ ថ្ងៃមួយក្អែកយកចំពុះចឹកក្អែកទាំងសង-ខាងរបស់ដំរីបែកហើយ រុយក៏ពងដាក់ក្នុងក្អែកនោះ ដំរីត្រូវដង្កូវទាំងឡាយរុកបានទទួលនូវទុក្ខវេទនា ត្រូវការស្រេកទឹកគ្របសង្កត់ ទើបត្រាច់ស្វែងរកទឹកផឹក ។ ក្នុងកាលណោះ កង្កែបទំនៅលើកំពូលភ្នំ បញ្ចេញសំឡេងយំ ដំរីគិតថា ទឹកផឹកនឹងមានក្នុងទីនោះ ទើបឡើងទៅកាន់ភ្នំ ។ លំដាប់នោះកង្កែបចុះមកត្រង់បាតជ្រោះបន្លឺសំឡេង ដំរីគិតថា ទឹកផឹកនឹងមាន ទើបបែរមុខទៅរកជ្រោះ បានរអិលជើងធ្លាក់ទៅកាន់ជ្រោះដល់នូវការអស់ជីវិត ។ មេចាបចៀបកប្បាសដឹងថាដំរីនោះស្លាប់ហើយ ទើបត្រេកអរថា អញឃើញខ្នងបច្ចាមិត្តហើយ ទើបដើរទៅដើរមកលើសរីរៈដំរីនោះ ហើយទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាពៀរមិនគួរធ្វើជាមួយបុគ្គលណាមួយឡើយ សត្វទាំង ៤ នេះរួមគ្នាហើយ ធ្វើដំរីដែលដល់ព្រមដោយកម្លាំងឲ្យអស់ជីវិតបាន ហើយត្រាស់អភិសម្ពុទ្ធគាថាដូច្នេះថា

អ្នកចូរមើលនូវក្អែក ចាបចៀបកប្បាស កង្កែបនិងរុយខៀវ សត្វទាំងនុ៎ះ សម្លាប់នូវដំរីបាន អ្នកចូរមើល ( នូវគតិ ) នៃពៀររបស់ពួកសត្វមានពៀរ ព្រោះហេតុនោះ អ្នកទាំងឡាយ កុំធ្វើនូវពៀរ នឹងជនណាមួយ សូម្បីមិនជាទីស្រឡាញ់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បស្ស** នេះ ជាពាក្យហៅដែលមិនកំណត់ពិតប្រាកដ តែព្រោះត្រាស់សំដៅយកភិក្ខុទាំងឡាយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើល ។ បទថា **ឃតេ** បានដល់ សត្វទាំង ៤ នេះ បានរួមគ្នា ។ បទថា **អឃាតេសុំ** បានដល់ សម្លាប់ដំរីនោះ ។ បទថា **បស្ស វេរស្ស វេរិនំ** សេចក្តីថា អ្នកទាំងឡាយចូរមើលគតិនៃពៀររបស់បុគ្គលដែលមានពៀរ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ដំរីមានប្រក្រតីត្រាច់ទៅតែម្នាក់ឯងក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកដំរីមេហ្វូងក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា លដុកិកជាតក ចប់**

# ចុល្លធម្មបាលជាតក

[ ៣៦ ] ( ព្រះនាងចន្ទាទេវីពោលថា ) ខ្ញុំម្ចាស់ជាស្រីប្រទូស្តជាអ្នកបំផ្លាញនូវសេចក្តីចម្រើនដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមលែងនូវធម្មបាល ( ជាកូនខ្ញុំ ) នេះចេញ សូមកាត់នូវដៃទាំងឡាយរបស់ខ្ញុំម្ចាស់វិញចុះ ។

[ ៣៧ ] ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្តីចម្រើន ដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវជើងទាំងឡាយរបស់ខ្ញុំវិញចុះ ។

[ ៣៨ ] ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្តីចម្រើន ដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវក្បាលរបស់ខ្ញុំម្ចាស់វិញចុះ ។

[ ៣៩ ] ពួកមិត្តអាមាត្យ និងជនអ្នកមានហឫទ័យល្អរបស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំសម្លាប់បុត្តជាឱរស ។

[ ៤០ ] ពួកមិត្ត ញាតិ និងជនអ្នកមានហឫទ័យល្អរបស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំសម្លាប់បុត្តដែលកើតអំពីខ្លួន ។

[ ៤១ ] ដើមដៃទាំងឡាយដែលលាបដោយខ្លឹមចន្ទន៍របស់ធម្មបាល អ្នកជាទាយាទផែនដីដាច់ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងរលត់ ។

**ចប់ ចុល្លធម្មបាលជាតកទី ៨**

# អដ្ឋកថា

# ចុល្លធម្មបាលជាតក

[ ៣៦-៤១ ] ព្រះសាស្ដាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេចក្ដីព្យាយាមរបស់ទេវទត្ត ដើម្បីផ្ដាច់ព្រះជន្មព្រះអង្គ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អហមេវ ទូសិយា ភូនហតា** ដូច្នេះជាដើម ។

ក្នុងជាតកដទៃៗ ទេវទត្តមិនអាចធ្វើសូម្បីត្រឹមតែការតក់ស្លុតឲ្យដល់ព្រះពោធិសត្វ ចំណែកក្នុងចុល្លធម្មបាលជាតកនេះ ទេវទត្តឲ្យកាត់ដៃជើង និងសីសៈ ហើយឲ្យធ្វើកម្មករណៈឈ្មោះអសិមាលកៈ ក្នុងពេលដែលព្រះពោធិសត្វមានអាយុ ៧ ខែ ក្នុងទទ្ទរជាតក ទេវទត្តមួលកឲ្យស្លាប់ អាំងលើរងើកភ្លើងបរិភោគ ។ ក្នុងខន្តិវាទិជាតក ទេវទត្តឲ្យយកផ្ដៅពីរដើម វាយមួយពាន់ដង ឲ្យកាត់ដៃ ជើង ត្រចៀក និងច្រមុះ ហើយចាប់ ត្រង់ផ្នួងសក់ទាញមកឲ្យដេកផ្ងារ ជាក់ត្រង់ដើមទ្រូងហើយទៅ ។ ព្រះពោធិសត្វដល់នូវការអស់ជីវិតក្នុងថ្ងៃនោះឯង ក្នុងចុល្លនន្ទិកជាតកក្ដី មហាកបិជាតកក្ដី ទេវទត្តបានត្រឹមតែសម្លាប់ឲ្យស្លាប់ប៉ុណ្ណោះ ទេវទត្តនេះ ព្យាយាមផ្ដាច់ព្រះជន្មអស់កាលយូរដោយប្រការយ៉ាងនេះ ក្នុងពុទ្ធកាលបានព្យាយាមដូចគ្នា ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តធ្វើឧបាយដើម្បីផ្ដាច់ព្រះជន្មព្រះពុទ្ធប៉ុណ្ណោះ ទេវទត្តគិតថា នឹងផ្ដាច់ព្រះជន្មព្រះសម្មាសម្ពុទ្ធ ទើបប្រកបនាយខ្មាន់ធ្នូ ប្រមៀលថ្មនិងឲ្យលែងដំរីនាឡាគិរី ។ ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នា ដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា

បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមសម្លាប់តថាគតដូចគ្នា តែក្នុងឥឡូវនេះ ទេវទត្តមិនអាចធ្វើត្រឹមតែការតក់ស្លុត តែក្នុងកាលមុន ក្នុងកាលដែលតថាគតជាចូឡធម្មបាលកុមារ ទេវទត្តធ្វើតថាគតដែលជាកូនរបស់ខ្លួន ឲ្យដល់នូវការអស់ជីវិត ហើយធ្វើកម្មករណៈឈ្មោះអសិមាលកៈ ( គឺបោះឡើងលើហើយយកដាវទ្រ ) កាលត្រាស់ហើយ ទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមហាបតាបៈ គ្រងរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងព្រះឧទររបស់ព្រះនាងចន្ទាទេវី អគ្គមហេសីរបស់ព្រះបាទមហាបតាបៈនោះ ព្រះញាតិទាំងឡាយ ថ្វាយព្រះនាមព្រះពោធិសត្វថា ធម្មបាល ។ ក្នុងពេលធម្មបាលកុមារមានអាយុ ៧ ខែ ព្រះមាតាស្រពស្រង់ធម្មបាលកុមារនោះដោយទឹកដែលផ្សំដោយគ្រឿងក្រអូប តែងព្រះកាយហើយដាក់ឲ្យអង្គុយលេង ។ ព្រះរាជាទ្រង់យាងមកកាន់កន្លែងព្រះទេវីនោះប្រថាប់នៅ ព្រះទេវីឲ្យព្រះឱរសលេង ជាអ្នកពោរពេញដោយសេចក្តីស្នេហាក្នុងបុត្តទោះបីឃើញព្រះរាជាក៏មិនក្រោកទទួល ព្រះរាជាទ្រង់ព្រះតម្រិះថា ឥឡូវនេះនាងចន្ទានេះធ្វើនូវមានះព្រោះអាស្រ័យកូន មិនសម្គាល់អញក្នុងរឿងអ្វីសោះ កាលកូនធំឡើង នាងមិនធ្វើសេចក្តីសម្គាល់ក្នុងអញ ថាជាមនុស្សក៏ថាបាន អញនឹងសម្លាប់ក្មេងនេះ ក្នុងកាលឥឡូវនេះឯង ។ ព្រះរាជាយាងទៅប្រថាប់គង់លើព្រះរាជអាសនៈ ត្រាស់ឲ្យហៅពេជ្ឈឃាដមក ដោយព្រះរាជឱង្ការថា

ពេជ្ឈឃាដចូរមកដោយទំនៀបរបស់ខ្លួន ។ ពេជ្ឈឃាដនោះទើបស្លៀកជណ្តប់ សំពត់ជ្រលក់ដោយទឹកម្ចត់ ពាក់កម្រងផ្កាពណ៌ក្រហម ស្ពាយពូថៅ កាន់កំណាត់ឈើសម្រាប់ពាក់ដៃនិងជើង មានជ្រញ់សម្រាប់ទ្រ មកថ្វាយបង្គំព្រះរាជា ក្រាបទូលថា បពិត្រទេវៈ ទូលបង្គំនឹងធ្វើអ្វី កាលក្រាបទូលហើយ បានឈរង់ចាំព្រះរាជបញ្ជា ។ ព្រះរាជាត្រាស់ថា ចូរចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះទេវី ហើយនាំធម្មបាលកុមារមក ចំណែកព្រះទេវីជ្រាបថា ព្រះរាជាទ្រង់ពិរោធ ហើយត្រឡប់ទៅ ទើបឲ្យព្រះពោធិសត្វដេកផ្ទឹបនឹងព្រះឱរៈប្រថាប់គង់ព្រះកន្ទ្រេង ។ ពេជ្ឈឃាដមកដល់ យកដៃទះខ្នងព្រះទេវីនោះហើយកញ្ឆក់យកព្រះរាជកុមារអំពីព្រះហស្ត នាំមកកាន់សម្នាក់ព្រះរាជាហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងធ្វើអ្វី ព្រះរាជាត្រាស់ឲ្យនាំយកបន្ទះក្តារមួយមកហើយឲ្យដាក់ខាងមុខ ហើយត្រាស់ថា ចូរឲ្យកុមារនោះដេកលើបន្ទះក្តារនោះ ។ ពេជ្ឈឃាដនោះ បានធ្វើតាមព្រះរាជបញ្ជាយ៉ាងនោះ ។ ព្រះនាងចន្ទាទេវីបរិទេវនាការខាងក្រោយព្រះរាជឱរសនោះឯង ។ ពេជ្ឈឃាដក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងធ្វើដូចម្តេចទៀត ។ ព្រះរាជាត្រាស់ថា ចូរកាត់ដៃទាំងពីររបស់ធម្មបាលកុមារ ។ ព្រះនាងចន្ទាទេវីក្រាបទូលថា បពិត្រមហារាជ បុត្តរបស់ខ្ញុំម្ចាស់មានអាយុត្រឹមតែ ៧ ខែ នៅទន់ខ្ចីមិនដឹងអ្វីឡើយ បុត្តរបស់ខ្ញុំម្ចាស់នោះ មិនមានទោសកំហុស ទោសកំហុសដែលធំក្រៃលែងគួរនឹងមានចំពោះខ្ញុំម្ចាស់ ព្រោះដូច្នោះ សូមទ្រង់ឲ្យគេកាត់ដៃទាំងពីររបស់ខ្ញុំម្ចាស់ចុះ កាលព្រះនាងប្រកាសសេចក្តីនេះទើបពោល

គាថាទី ១ ថា

ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្ដីចម្រើន ដល់ស្ដេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមលែងនូវធម្មបាល ( ជាកូនខ្ញុំ ) នេះចេញ សូមកាត់នូវដៃទាំងឡាយរបស់ខ្ញុំម្ចាស់វិញចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទូសិយា** បានដល់ ដែលធ្វើឲ្យវិនាស អធិប្បាយថា ឃើញទ្រង់ហើយ មិនក្រោកឡើងទទួល ឈ្មោះថាជាអ្នកធ្វើខុស បាលីថា **ទូសិកា** ដូច្នេះក៏មាន ឯសេចក្ដីក៏យ៉ាងនេះដូចគ្នា ។ បទថា **ភូនហា–តា** បានដល់ កម្ចាត់នូវសេចក្ដីចម្រើន អធិប្បាយថា កម្ចាត់នូវភាពចម្រើន ។ បទថា **រញ្ញោ** គប្បីប្រកបជាមួយបទថា **ទូសិយា** ។ ក្នុងសេចក្ដីនេះ មានអធិប្បាយដូច្នេះថា ខ្ញុំម្ចាស់ធ្វើខុសចំពោះព្រះបាទមហាបតាបៈ មិនមែនកុមារនេះឡើយ ព្រោះដូច្នោះ សូមទ្រង់ដោះលែងនូវធម្មបាលដែលនៅតូចខ្ចី មិនមានកំហុសនេះចុះ បើទ្រង់បំណងនឹងកាត់ដៃទាំងពីរ បពិត្រព្រះសម្មតិទេព សូមទ្រង់កាត់ដៃទាំងពីររបស់ខ្ញុំដែលជាអ្នកខុស ។

ព្រះរាជាទ្រង់មើលពេជ្ឈឃាដ ទើបពេជ្ឈឃាដក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងធ្វើដូចម្ដេច ។ ព្រះរាជាត្រាស់ថា ចូរកុំយឺតយូរ ចូរកាត់ដៃទាំងពីរភ្លាម ។ ខណៈនោះ ពេជ្ឈឃាដឆាពូថៅដ៏មុត កាត់ដៃទាំងពីររបស់ព្រះរាជកុមារ ដូចគេកាត់នូវទំពាំងខ្ចីដូច្នោះ ។ កាលពេជ្ឈឃាដកាត់ដៃទាំងគូ ធម្មបាលកុមារនោះមិនយំ មិនកន្ទក់កន្ទេញ ធ្វើនូវខន្តិនិងមេត្តា ឲ្យ

ជាបុរេចារិក អត់សង្កត់ ។ ចំណែកព្រះនាងចន្ទាទេវី រើសយកចុងដៃដែលដាច់ដាក់ក្នុងថ្នក់ដែលមានលោហិតកំពុងហូរ ព្រះនាងត្រាច់បរិទេវនាការ ។ នាយពេជ្ឈឃាដទូលសួរទៀតថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងធ្វើអ្វីទៀត ព្រះរាជាត្រាស់ថា ចូរកាត់ជើងទាំងពីរ ។ ព្រះនាងចន្ទាទេវីបានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្តីចម្រើន ដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវជើងទាំងឡាយរបស់ខ្ញុំវិញចុះ ដូច្នេះ ។

អធិប្បាយក្នុងគាថាទី ២ នេះ គប្បីជ្រាបដោយន័យគាថាដំបូងនោះឯង ។ ចំណែកព្រះរាជា ទ្រង់បញ្ជាពេជ្ឈឃាដនោះទៀត ។ ពេជ្ឈឃាដបានកាត់ជើងទាំងពីរ ។ ព្រះនាងចន្ទាទេវី រើសយកចុងជើងដាក់ក្នុងថ្នក់ មានព្រះលោហិតជោកព្រះកាយ ទ្រង់ព្រះកន្សែងក្រាបទូលថា បពិត្រព្រះបាទមហាបតាបៈដ៏ជាព្រះស្វាមី ទារកដែលមានដៃនិងជើងដែលទ្រង់ឲ្យកាត់ហើយ ដែលមាតាចាំបាច់ចិញ្ចឹមមិនមែនឬ ខ្ញុំម្ចាស់នឹងស៊ីឈ្នួលចិញ្ចឹមបុត្ររបស់ខ្ញុំម្ចាស់ សូមទ្រង់ព្រះរាជទានបុត្តនោះដល់ខ្ញុំចុះ នាយពេជ្ឈឃាដ ក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ទូលបង្គំធ្វើតាមព្រះរាជអាជ្ញាហើយ កិច្ចរបស់ទូលបង្គំចប់ហើយឬ ព្រះរាជាត្រាស់ថា មិនទាន់ស្រេចទេ ពេជ្ឈឃាដក្រាបទូលថា បើយ៉ាងនោះទូលបង្គំនឹងធ្វើអ្វីទៀត ព្រះរាជាត្រាស់ថា ចូរកាត់ក្បាលធម្មបាល

កុមារនេះ ។ លំដាប់នោះ ព្រះនាងចន្ទាទេវីក៏ត្រាស់គាថាទី ៣ ថា

ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្ដីចម្រើន ដល់ស្ដេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវក្បាលរបស់ខ្ញុំម្ចាស់វិញចុះ ដូច្នេះ ។

កាលត្រាស់ហើយ ព្រះនាងបង្អោនសិរសាចូលទៅ ។ ពេជ្ឈឃាដបានក្រាបទូលសួរព្រះរាជាទៀតថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងធ្វើដូចម្ដេចទៀត ព្រះរាជាត្រាស់ថា ចូរកាត់ក្បាល របស់ធម្មបាលកុមារនោះ ។ ពេជ្ឈឃាដនោះ កាលកាត់ក្បាលហើយក៏ក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ទូលបង្គំធ្វើតាមព្រះរាជអាជ្ញាហើយឬ ព្រះរាជាត្រាស់ថា មិនទាន់បានធ្វើសព្វគ្រប់នៅឡើយ ។ ពេជ្ឈឃាដក្រាបទូលថា បពិត្រព្រះសម្មតិទេពកាលបើដូច្នោះទូលបង្គំនឹងធ្វើដូចម្ដេចទៀត ព្រះរាជាត្រាស់ថា ចូរឯងយកចុងដាវទទួលសរីរៈធម្មបាលកុមារនោះ ធ្វើកម្មករណៈឈ្មោះអសិមាលកៈ ។ ពេជ្ឈឃាដនោះ ក៏បោះរាងកាយរបស់ធម្មបាលកុមារនោះឡើងទៅក្នុងអាកាសហើយ យកចុងដាវទទួលសរីរៈរបស់ធម្មបាលកុមារនោះ ធ្វើកម្មករណៈឈ្មោះអសិមាលកៈ ហើយបោះទម្លាក់អំពីផ្ទៃប្រាសាទ ។ ព្រះនាងចន្ទាទេវី ក៏យកសាច់របស់ព្រះពោធិសត្វដាក់ក្នុងថ្នក់ ព្រះនាងយំខ្សឹកខ្សួលពោលគាថា ២ ថា

ពួកមិត្តអាមាត្យ និងជនអ្នកមានហឫទ័យល្អ របស់ស្ដេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្ដេចថា សូមព្រះ

អង្គ កុំសម្លាប់បុត្តជាឱរសៈ ។

ពួកមិត្ត ញាតិ និងជនអ្នកមានហឫទ័យល្អរបស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំ សម្លាប់បុត្តដែលកើតអំពីខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិត្តាមច្ចា ច វិជ្ជរេ សុហទា** សេចក្តីថា បុគ្គលណាមួយដែលជាមិត្តស្និទ្ធស្នាលរបស់ព្រះរាជានេះ ឬអាមាត្យដែលរួមក្នុងកិច្ចទាំងពួង ឬដែលឈ្មោះថាមានចិត្តល្អ ព្រោះមានហទយៈទន់ភ្លន់ នឹងមិនមានពិតប្រាកដ ។ បទថា **យេ ន វទន្តិ** សេចក្តីថា ជនទាំងឡាយ ណាមកទាន់ពេល មិនពោល មិនឃាត់ព្រះរាជានេះថា កុំផ្តាច់ព្រះជន្មព្រះបិយោ-រសរបស់ទ្រង់ ជនទាំងនោះ ខ្ញុំយល់ថាមិនមានឡើយ ។ បទថា **ញាតី** ក្នុងគាថាទី ២ បានដល់ ញាតិច្រើននាក់ ។

ព្រះនាងចន្ទាទេវី កាលពោលគាថា ២ នេះហើយ ទើបរើសសាច់បេះដូងដោយដៃទាំងទ្វេ ហើយពោលគាថាចុងក្រោយថា

ដើមដៃទាំងឡាយ ដែលលាបដោយខ្លឹមចន្ទន៍ របស់ធម្មបាល អ្នកជាទាយាទផែនដីដាច់ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំ ម្ចាស់នឹងរលត់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទាយាទស្ស បថព្យា** សេចក្តីថា ព្រះនាងចន្ទាទេវី រៀបរាប់ពាក្យជាដើមយ៉ាងនេះថា ដៃរបស់ទាយាទនៃផែនដី ដែលមានមហាសមុទ្រទាំង ៤ ជាព្រំប្រទល់ ដែលជារបស់ព្រះបិតា លាបដោយ

ខ្ទឹមចន្ទន៍ក្រហមដាច់ទៅ ជើងក៏ដាច់ ក្បាលក៏ដាច់ ហើយត្រូវដាក់កម្មករណៈឈ្មោះអសិមាលកៈ ឥឡូវនេះ ទ្រង់បានកាត់នូវវង្សរបស់ខ្លួនឯងដូច្នេះ ទើបត្រាស់យ៉ាងនេះ ។ បទថា **ទាណា មេ តេវ រុជ្ឈន្តិ** សេចក្តីថា បពិត្រព្រះសម្មតិទេព កាលខ្ញុំមិនអាចអត់សង្កត់នូវសេចក្តីសោកនេះបាន ជីវិតគង់នឹងរលត់ទៅ ។

កាលព្រះនាងយំរៀបរាប់យ៉ាងនោះ ព្រះហឫទ័យក៏បែក ដូចឫស្សីត្រូវភ្លើងឆេះយ៉ាងនោះដូច្នេះ ព្រះនាងបានដល់នូវការអស់ព្រះជន្មក្នុងទីនោះឯង ។ ចំណែកព្រះរាជា មិនអាចតាំងនៅលើបល្ល័ង្កបាន ក៏ធ្លាក់ទៅក្នុងផ្ទៃប្រាសាទ ផែនដីដែលរាបស្មើញែកជាពីរភាគ ព្រះបាទមហាបតាបៈនោះ ធ្លាក់អំពីផ្ទៃរាបនោះដល់ផែនដី បន្ទាប់អំពីនោះ ផែនដីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ មិនអាចទ្រទ្រង់នូវទោសកំហុសរបស់ព្រះរាជានោះបាន ទើបញែកជា ២ ឲ្យឱកាស អណ្តាតភ្លើងផុសឡើងអំពីអវីចិមហានរក ស្រោបយកព្រះបាទមហាបតាបៈ ទៅទម្លាក់ក្នុងអវីចិមហានរក ដូចដណ្តប់ដោយសំពត់កម្ពលដែលត្រកូលប្រគល់ឲ្យដូច្នោះ ។ ចំណែកព្រះនាងចន្ទាទេវីនិងព្រះពោធិសត្វ អាមាត្យទាំងឡាយបានបូជាព្រះសពឲ្យហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ព្រះនាងចន្ទាទេវីក្នុងកាលនោះ បានមកជាព្រះនាងមហាបជាបតិគោតមី ចំណែកធម្មបាលកុមារក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ចុល្លធម្មបាលជាតក ចប់**

# សុវណ្ណមិគជាតក

[ ៤២ ] ( ម្រឹគញីជាប្រពន្ធពោលថា ) បពិត្រមហាម្រឹគ អ្នកចូរខំប្រឹង បពិត្រម្រឹគមានជើងដូចមាស អ្នកចូរខំប្រឹង ចូរកាត់នូវអន្ទាក់ដែលធ្វើដោយព្រ័ត្រ ខ្ញុំជាម្រឹគញីម្នាក់ឯង មិនអាចត្រេកអរក្នុងព្រៃបានទេ ។

[ ៤៣ ] ( ម្រឹគពោធិសត្វជាប្តីពោលថា ) អញខំប្រឹងមិនរួចទេ អញនឹងកកាយផែនដីដោយកម្លាំង អន្ទាក់ដែលគេធ្វើដោយព្រ័ត្រជាប់មាំមួន រឹតក្តួតជើងរបស់អញ ។

[ ៤៤ ] ( ម្រឹគញីពោលថា ) បពិត្រអ្នកព្រាន អ្នកចូរក្រាលនូវស្លឹកឈើ អ្នកចូរហូតដាវ ( អំពីស្រោម ) អ្នកសម្លាប់ខ្ញុំមុន ហើយសឹមសម្លាប់មហាម្រឹគជាខាងក្រោយ ។

[ ៤៥ ] ( ព្រានពោលថា ) អញមិនដែលឮ ឬឃើញមេម្រឹគចេះនិយាយភាសាមនុស្សទេ ម្នាលមេម្រឹគដ៏ចម្រើន នាងឯងចូរនៅជាសុខចុះ ទាំងមហាម្រឹគនុ៎ះ ក៏សូមឲ្យនៅជាសុខចុះ ។

[ ៤៦ ] ( ម្រឹគញីពោលថា ) បពិត្រអ្នកព្រាន ខ្ញុំត្រេកអរព្រោះឃើញនូវមហាម្រឹគដែលរួច ( ចាកអន្ទាក់ ) ក្នុងថ្ងៃនេះ យ៉ាងណា សូមអ្នកត្រេកអរ ជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះដែរ ។

**ចប់ សុវណ្ណមិគជាតក ទី ៩ ។**

# អដ្ឋកថា

# សុវណ្ណមិគជាតក

[ ៤២-៤៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុលធីតាម្នាក់ក្នុងក្រុងសាវត្ថី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វិក្កម រេ មហាមិគ** ដូច្នេះជាដើម ។

បានឮថា ស្រីនោះជាធីតារបស់ត្រកូលឧបដ្ឋាក នៃព្រះអគ្គសាវកទាំងពីរក្នុងក្រុងសាវត្ថី ជាអ្នកមានសទ្ធាជ្រះថ្លា រាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សម្បូរដោយមារយាទ ជាអ្នកឈ្លាស ត្រេកអរក្រៃលែងក្នុងបុណ្យ មានទានជាដើម ។ ត្រកូលមិច្ឆាទិដ្ឋិដទៃមានជាតិស្មើគ្នា ក្នុងនគរសាវត្ថីនោះឯង បានមកសូមធីតានោះ ។ លំដាប់នោះ មាតាបិតារបស់នាងពោលថា ធីតារបស់យើងមានសទ្ធាជ្រះថ្លា រាប់អានព្រះរតនត្រ័យត្រេកអរក្រៃលែងក្នុងបុណ្យ មានទានជាដើម អ្នកទាំងឡាយជាមិច្ឆាទិដ្ឋិ នឹងមិនឲ្យកូនស្រីរបស់ខ្ញុំនេះ ឲ្យនូវទាន ស្តាប់ធម៌ ទៅវិហាររក្សាសីល ឬធ្វើឧបោសថកម្មតាមគាប់ចិត្ត ខ្ញុំនឹងមិនឲ្យដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរសូមកុមារិកាក្នុងត្រកូលមិច្ឆាទិដ្ឋិដូចគ្នាចុះ ។ ជនដែលមកសូមទាំងនោះ ត្រូវមាតាបិតារបស់កុមារិកានោះប្រាប់ហើយ ទើបពោលថា ធីតារបស់អ្នកទាំងឡាយ ទៅផ្ទះរបស់ពួកខ្ញុំហើយ ចូរធ្វើកិច្ចទាំងពួងតាមបំណងចុះ ពួកយើងមិនហាមឃាត់ ចូរពួកលោកឲ្យធីតានោះដល់ពួកយើងចុះ កាលមាតាបិតារបស់នាងពោលថា បើយ៉ាងនោះអ្នកទាំងឡាយចូរយកទៅចុះ កាលដល់ឫក្សល្អ ទើបធ្វើមង្គលពិធី ហើយនាំនាងទៅកាន់ផ្ទះរបស់ខ្លួន ។ នាងកុលធីតានោះ បានជាអ្នកដល់ព្រមដោយការប្រព្រឹត្ត និង

មារយាទ មានស្វាមីដូចទេវតា ។ វត្តបដិបត្តិចំពោះឪពុកក្មេក ម្តាយក្មេក និងស្វាមីរមែងធ្វើហើយយ៉ាងល្អ ។ ថ្ងៃមួយនាងពោលនឹងស្វាមីថា បពិត្រអយ្យបុត្ត ខ្ញុំប្រាថ្នានឹងឲ្យទានដល់ព្រះថេរៈទាំងឡាយប្រចាំត្រកូល របស់ពួកយើង ស្វាមីពោលថា សាធុ នាងដ៏ចម្រើន ចូរនាងឲ្យទានតាមអធ្យាស្រ័យចុះ ។ នាងក៏ឲ្យនិមន្តព្រះថេរៈទាំងឡាយមកហើយ ធ្វើសក្ការៈធំ ឲ្យឆាន់នូវភោជនដ៏ប្រណីត ហើយអង្គុយក្នុងចំណែកម្ខាងពោលថា បពិត្រលោកម្ចាស់ត្រកូលនេះជាមិច្ឆាទិដ្ឋិ មិនមានសទ្ធា មិនដឹងគុណរបស់ព្រះរតនត្រ័យ សូមលោកម្ចាស់ទាំងឡាយ ទទួលកិច្ចាក្នុងទីនេះឯង ទម្រាំត្រកូលនេះស្គាល់គុណរបស់ព្រះរតនត្រ័យ ។ ព្រះថេរៈទាំងឡាយទទួលនិមន្តន៍ហើយ ឆាន់ជាប្រចាំក្នុងត្រកូលនោះ ។ នាងពោលនឹងស្វាមីទៀតថា បពិត្រអយ្យបុត្ត ព្រះថេរៈទាំងឡាយមកជាប្រចាំក្នុងត្រកូលនេះ ព្រោះហេតុអ្វីទើបអ្នកមិនមកមើលព្រះថេរៈ ។ ស្វាមីពោលថា យើងនឹងទៅមើល ។ ស្អែកឡើង ទើបនាងប្រាប់ដល់ស្វាមីនោះ ក្នុងពេលព្រះថេរៈទាំងឡាយធ្វើកត្តកិច្ចស្រេចហើយ ស្វាមីរបស់នាងចូលទៅរកហើយធ្វើនូវបដិសណ្ឋារៈជាមួយព្រះថេរៈ ហើយអង្គុយក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះធម្មសេនាបតីក៏ពោលធម្មកថាដល់ស្វាមីរបស់ធីតានោះ បុរសនោះជ្រះថ្លាក្នុងធម្មកថានិងឥរិយាបថរបស់ព្រះថេរៈ តាំងអំពីនោះទើបឲ្យក្រាលអាសនៈដើម្បីព្រះថេរៈទាំងឡាយ ត្រងទឹកផឹក ស្តាប់ធម្មកថាក្នុងរវាងភត្ត ។ ក្នុងកាលតមកមិច្ឆាទិដ្ឋិរបស់បុរសនោះ ក៏ត្រូវទម្លាយទៅ ។ ថ្ងៃមួយព្រះថេរៈកាលពោលធម្មកថាដល់ស្វាមីភរិយាទាំងពីរនោះ ទើប

ប្រកាសសច្ចៈ ៤ ក្នុងកាលចប់សច្ចៈ ស្វាមីភរិយាទាំងពីរតាំងនៅក្នុងសោតាបត្តិផល ។ ចាប់តាំងពីកាលនោះមកជនទាំងអស់ មានមាតាបិតា ជាដើមដោយហោចសូម្បីតែទាសៈនិងកម្មករ បានទម្លាយនូវមិច្ឆាទិដ្ឋិ ក្លាយជាអ្នករាប់អានព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ ថ្ងៃមួយទារិកានោះ ពោលនឹងស្វាមីថា បពិត្រអយ្យបុត្ត ខ្ញុំនេះ ប្រយោជន៍អ្វីដោយការគ្រប់គ្រងផ្ទះ ខ្ញុំប្រាថ្នានឹងបួស ស្វាមីនោះពោលថា សាធុ នាងដ៏ចម្រើន សូម្បីខ្ញុំក៏នឹងបួសដែរ ហើយនាំភរិយានោះ ទៅកាន់សម្នាក់ភិក្ខុនីដោយបរិវារច្រើន ឲ្យបួសហើយ ចំណែកខ្លួនឯង ចូលទៅគាល់ព្រះសាស្តា ទូលសូមបព្វជ្ជា ។ ព្រះសាស្តាឲ្យបព្វជ្ជាឧបសម្បទាហើយ លោកទាំងពីរចម្រើនវិបស្សនា មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។ ថ្ងៃមួយភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុនីឈ្មោះនោះ បានជាបច្ច័យដល់ខ្លួននិងដល់ប្តី បួសហើយសម្រេចអរហត្តទៀត ឲ្យប្តីនោះសម្រេចផង ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនេះ បានដោះស្វាមីចាកអន្ទាក់ គឺរាគៈតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនភិក្ខុនីនេះក៏បានដោះបុរាណកបណ្ឌិតទាំងឡាយអំពីអន្ទាក់ គឺមរណៈ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី

ព្រះពោធិសត្វកើតក្នុងកំណើតម្រឹគ ចម្រើនវ័យហើយ ជាសត្វមានរូបស្អាត គួរស្រឡាញ់ គួរមើល មានពណ៌សម្បុរដូចមាស ប្រកបដោយជើងមុខ និងជើងក្រោយដូចធ្វើបរិកម្មដោយទឹកល័ក្ត ស្នែងដូចកម្រងប្រាក់ ភ្នែកទាំងពីរមានចំណែកប្រៀបដូចដុំកែវមណី កន្ទុយដូចសំពត់កម្ពលក្រហម ចំណែកម្រឹគញីជាម្រឹគដែលមានរូបគួរស្រឡាញ់ ម្រឹគទាំងពីរនោះ នៅរួមគ្នាដោយការព្រមព្រៀង មានម្រឹគដែលស្អាត ៨ ម៉ឺនចាំឧបដ្ឋាកបម្រើព្រះពោធិសត្វ ។ ក្នុងកាលនោះពួកព្រាន សម្លាប់ម្រឹគទាំងឡាយផង ដាក់អន្ទាក់ផង ។ ថ្ងៃមួយព្រះពោធិសត្វ ដើរទៅខាងមុខម្រឹគទាំងឡាយ ជើងជាប់អន្ទាក់ ទើបទាញជើងមកដោយគិតថា អញនឹងធ្វើអន្ទាក់នេះឲ្យដាច់ ស្បែកក៏ដាច់ កាលទាញម្តងទៀត សាច់ក៏ដាច់ សរសៃក៏ដាច់ ខ្សែអន្ទាក់បានលះរហូតដល់ឆ្អឹង ។ ព្រះពោធិសត្វ មិនអាចធ្វើអន្ទាក់ឲ្យដាច់ក៏តក់ស្លុតចំពោះមរណភ័យ ទើបស្រែកប្រាប់ឲ្យដឹងថាខ្លួនជាប់អន្ទាក់ ។ ពួកម្រឹគបានស្តាប់ដូច្នោះ ក៏តក់ស្លុតនាំគ្នារត់គេចទៅ ។ ចំណែកម្រឹគញីនោះ គេចទៅហើយ សម្លឹងមើលក្នុងរវាងពួកម្រឹគមិនឃើញព្រះពោធិសត្វគិតថា ភ័យនេះគង់នឹងកើតដល់ប្តីជាទីស្រឡាញ់របស់អញ ដូច្នេះហើយ ទើបប្រញាប់ទៅកាន់សម្នាក់របស់ព្រះពោធិសត្វនោះ មានមុខជោកដោយទឹកភ្នែក ទួញយំពោលថា បពិត្រស្វាមី លោកជាអ្នកមានកម្លាំងច្រើន លោកមិនអាចតតាំងនឹងអន្ទាក់នេះឬ ចូរលោកប្រមូលកម្លាំងធ្វើអន្ទាក់នេះឲ្យដាច់ កាលនឹងញុំាងឧស្សាហៈឲ្យកើតដល់ព្រះពោធិសត្វនោះ ទើបពោលគាថាទី ១ ថា

បពិត្រមហាម្រឹគ អ្នកចូរខំប្រឹង បពិត្រម្រឹគមានជើងដូចមាស
អ្នកចូរខំប្រឹង ចូរកាត់នូវអន្ទាក់ដែលធ្វើដោយព្រ័ត្រ ខ្ញុំជាម្រឹគ
ញី ម្នាក់ឯង មិនអាចត្រេកអរក្នុងព្រៃបានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិក្កម** បានដល់ ចូរព្យាយាម អធិប្បាយថា ចូរទាញ ។ សព្ទថា **រេ** ជានិបាតប្រើក្នុងអត្ថថា ហៅ ។ បទថា **ហរីបទ** បានដល់ ជាអ្នកមានជើងដូចមាស ។ ក្នុងសរីរៈទាំងមូលរបស់ព្រះពោធិសត្វនោះ មានពណ៌ដូចមាស ។ តែម្រឹគញីនេះពោលយ៉ាងនោះ ដោយអំណាចរាគៈ ។ បទថា **ឆាហំ ឯកា** នេះ សម្ដែងថា ខ្ញុំវៀរអ្នកហើយ នៅម្នាក់ឯងនឹងមិនត្រេកអរក្នុងព្រៃ ខ្ញុំនឹងមិនបរិភោគស្មៅនិងទឹក ស្ដាំងស្គមស្លាប់ ។ ស្ដេចម្រឹគបានស្ដាប់ ដូច្នោះ ទើបពោលគាថាទី ២ ថា

អញខំប្រឹងមិនរួចទេ អញនឹងកកាយផែនដីដោយកម្លាំង អន្ទាក់
ដែលគេធ្វើដោយព្រ័ត្រ ជាប់មាំមួន រឹតកួតជើងរបស់អញ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិក្កមាមិ** សេចក្ដីថា នែនាង អញធ្វើនូវសេចក្ដីព្យាយាមដើម្បីនាង ។ បទថា **ន ចារេមិ** សេចក្ដីថា តែអញមិនអាចធ្វើអន្ទាក់ឲ្យដាច់ ។ បទថា **ភូមឹ សុម្ភាមិ** សេចក្ដីថា អញយកជើងកកាយផែនដីត្រង់អន្ទាក់ដោយបំណងថា អន្ទាក់នឹងដាច់ ។ បទថា **វេគសា** បានដល់ ដោយពេញកម្លាំង ។ បទថា **បរិកន្តតិ** សេចក្ដីថា អន្ទាក់ស្បែកជាដើមលះសាច់ដោយជុំវិញ ។

លំដាប់នោះ ម្រឹគញីក៏ពោលនឹងម្រឹគនោះថា បពិត្រអ្នកជាស្វាមី អ្នកកុំខ្លាចឡើយ ខ្ញុំនឹងអង្វរព្រាហ្មណ៍តាមកម្លាំងរបស់ខ្លួន នឹងនាំជីវិតមកដើម្បីអ្នក បើខ្ញុំអង្វរមិនបានសោត ខ្ញុំនឹងឲ្យជីវិតរបស់ខ្ញុំ ហើយនាំយកជីវិតមកដើម្បីអ្នក ហើយលួងលោមព្រះមហាសត្វឲ្យធូរស្រាលចិត្ត ឈរក្បែរព្រះពោធិសត្វដែលមានខ្លួនជោកដោយឈាម ។ ចំណែកព្រានកាន់ដាវនិងលំពែងដើរមក ដូចភ្លើងឆេះកប្ប ម្រឹគញីឃើញព្រាននោះហើយ លួងលោមព្រះពោធិសត្វថា បពិត្រអ្នកជាស្វាមី នាយព្រានម្រឹគកំពុងមក ខ្ញុំនឹងធ្វើតាមកម្លាំងរបស់ខ្លួន អ្នកកុំខ្លាច ហើយដើរទៅរកព្រាន ឈរក្នុងចំណែកម្ខាង ថ្វាយបង្គំព្រាននោះហើយ ពោលគុណសម្បត្តិ របស់ព្រះពោធិសត្វថា បពិត្រលោកស្វាមីរបស់ខ្ញុំ មានពណ៌ដូចមាស សម្បូរដោយសីលនិងមារយាទ ជាស្តេចនៃពួកម្រឹគ ៨ ម៉ឺន កាលស្តេចម្រឹគកំពុងឈរនោះឯង កាលសំណូមពរឲ្យសម្លាប់ខ្លួន ទើបពោលគាថាទី ៣ ថា

បពិត្រអ្នកព្រាន អ្នកចូរក្រាលនូវស្លឹកឈើ អ្នកចូរហូតដាវ
( អំពីស្រោម ) អ្នកសម្លាប់ខ្ញុំមុន ហើយសឹមសម្លាប់មហាម្រឹគ
ជាខាងក្រោយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បលាសានិ** សេចក្តីថា ចូរអ្នកក្រាលស្លឹកឈើទាំងឡាយ ដើម្បីបានដាក់សាច់ ។ បទថា **អសឹ និព្វាហ** សេចក្តីថា អ្នកចូរដកដាវអំពីស្រោម ។

ព្រានបានស្តាប់ដូច្នោះហើយគិតថា បុគ្គលដែលជាមនុស្ស មិនឲ្យជីវិត

ខ្លួនដើម្បីប្រយោជន៍ដល់ប្ដីបានឡើយ ម្រឹគញីនេះជាសត្វតិរច្ឆាន បរិច្ចាគជីវិតបានផង ពោលភាសាមនុស្ស ដោយសំឡេងដ៏ពីរោះផង ថ្ងៃនេះអញនឹងឲ្យជីវិតរបស់ប្ដីនៃម្រឹគញីនេះផង ជីវិតរបស់ម្រឹគញីនេះផង កាលគិតដូច្នេះហើយ ក៏មានចិត្តជ្រះថ្លា ទើបពោលគាថាទី ៤ ថា

អញមិនដែលឮ ឬឃើញមេម្រឹគ ចេះនិយាយភាសាមនុស្ស
ទេ ម្នាលមេម្រឹគដ៏ចម្រើន នាងឯងចូរនៅជាសុខចុះ ទាំងមហាម្រឹគនុ៎ះ ក៏សូមឲ្យនៅជាសុខចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុតំ វា ទិដ្ឋំ វា** សេចក្ដីថា ក្នុងកាលមុនអំពីនេះ វត្ថុដែលអញបានឃើញ ឬបានស្ដាប់មកបែបនេះរមែងមិនមាន ។ បទថា **ភាសន្តឹ មានុសឹ មិគឹ** សេចក្ដីថា ព្រោះក្នុងកាលមុនអំពីនេះ អញមិនដែលបានឃើញ មិនដែលបានឮម្រឹគពោលវាចាមនុស្សបានឡើយ ។ បាលីថា **ន ច មេ សុតា វា ទិដ្ឋា វា ភាសន្តី មានុសី មិគី** ប្រែថា ម្រឹគនិយាយភាសាមនុស្ស អញមិនធ្លាប់បានឮ ឬបានស្ដាប់ បានឃើញមកឡើយដូច្នេះក៏មាន អត្ថរបស់បាលីទាំងនោះរមែងប្រាកដតាមបាលីនោះឯង ។ ព្រានដែលជាបណ្ឌិតឈ្លាសក្នុងឧបាយហៅម្រឹគញីនោះថា **ភទ្ទេ** ប្រែថា នៃនាងដ៏ចម្រើន ដោយប្រការដូច្នេះហើយ លួងលោមម្រឹគញីនោះទៀតថា អ្នកទាំងពីរ គឺនាងនិងស្ដេចម្រឹគនេះ ចូរមានសេចក្ដីសុខ ប្រាសចាកទុក្ខចុះហើយ បានទៅកាន់សម្នាក់របស់ព្រះពោធិសត្វ យកកាំបិតកាត់អន្ទាក់ជ្មមៗ នាំអន្ទាក់ដែលជាប់ជើងចេញ ហើយយកសរសៃភ្ជាប់សរសៃ យកសាច់បិទសាច់ យក

ស្បែកបិទស្បែក ហើយយកដៃប្រេបាច់ជើង ។ ដោយអានុភាព បារមីដែលព្រះពោធិសត្វបានបំពេញមក ដោយអានុភាពនៃមេត្តាចិត្តរបស់ព្រាន ដោយអានុភាពនៃមិត្តធម៌របស់មេម្រឹគ បណ្ដាលឲ្យសរសៃ សាច់និងស្បែក ជាប់ជាមួយសរសៃ សាច់និងស្បែក ក្នុងខណៈនោះមួយរំពេច ។ ចំណែកព្រះពោធិសត្វ មានសេចក្ដីសុខ ប្រាសចាកទុក្ខហើយឈរ ។ ម្រឹគញីឃើញព្រះពោធិសត្វមានសេចក្ដីសុខសប្បាយទើបកើតសោមនស្ស កាលនឹងធ្វើអនុមោទនាដល់ព្រាន ទើបពោលគាថាទី ៥ ថា

បពិត្រអ្នកព្រាន ខ្ញុំត្រេកអរ ព្រោះឃើញនូវមហាម្រឹគ ដែល
រួច ( ចាកអន្ទាក់ ) ក្នុងថ្ងៃនេះ យ៉ាងណា សូមអ្នកត្រេកអរ
ជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ ដូច្នេះ ។

ដោយបទថា **លុទ្ទក** នេះ ក្នុងគាថានោះ ម្រឹគញីហៅដោយអំណាចឈ្មោះដែលបានដោយអំណាចការធ្វើកម្មដែលឃោរឃៅ ។

ព្រះពោធិសត្វគិតថា ព្រាននេះជាទីពឹងអាស្រ័យរបស់អញ សូម្បីអញក៏គួរជាទីពឹងអាស្រ័យរបស់ព្រាននេះខ្លះ ទើបប្រគល់កែវមណីមួយដុំឲ្យដល់ព្រាន ដែលខ្លួនបានឃើញក្នុងទីស្វែងរកស៊ី ហើយឲ្យឱវាទដល់ព្រាននោះថា នែសម្លាញ់ ចាប់តាំងអំពីនេះទៅ អ្នកកុំធ្វើបាប មានបាណាតិបាតជាដើម ចូរប្រមូលទ្រព្យសម្បត្តិចិញ្ចឹមកូនប្រពន្ធ ធ្វើបុណ្យមានទាននិងសីលជាដើមដោយដុំកែវមណីនេះចុះ ហើយក៏ចូលទៅក្នុងព្រៃ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើប

ទ្រង់ប្រជុំជាតកថា ព្រានក្នុងកាលនោះ បានមកជាឆន្នភិក្ខុក្នុងកាលឥឡូវនេះ ម្រឹគញីក្នុងកាលនោះ បានមកជាភិក្ខុនីនោះ ចំណែកស្តេចម្រឹគក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាសុវណ្ណមិគជាតក ចប់

# សុសន្ធិជាតក

[ ៤៧ ] ( អ្នករបាំឈ្មោះអគ្គៈពោលថា ) ក្លិននៃផ្កាតិមិរព្រឹក្ស រមែងផ្សាយទៅ សមុទ្រដែលពេញដោយទឹកមានសំឡេងគឹកកង បពិត្រស្តេចតម្ពៈ ព្រោះថានាងសុសន្ធី ( នៅ ) ក្នុងទីឆ្ងាយពីនគរនេះ កាមទាំងឡាយតែងចាក់ដោតខ្ញុំ ។

[ ៤៨ ] ( ស្តេចគ្រុឌពោលថា ) អ្នកឆ្លងសមុទ្របានដោយប្រការដូចម្តេច អ្នកឃើញកោះឈ្មោះសេរុមដោយប្រការដូចម្តេច ម្នាលអគ្គៈ ការជួបប្រសព្វនាងសុសន្ធីនឹងអ្នកបានមានមកដោយប្រការដូចម្តេច ។

[ ៤៩ ] ( អ្នករបាំឈ្មោះអគ្គៈពោលថា ) នាវារបស់ពួកឈ្មួញ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ករុកច្ឆា បែកធ្លាយដោយមង្គរ ខ្ញុំក៏ឆ្លងសមុទ្រដោយផែនក្តារ ។

[ ៥០ ] នាងសុសន្ធីនោះ ជាស្ត្រីមានវាចាទន់ពីរោះ មានក្លិនដូចខ្លឹមចន្ទន៍អស់កាលជានិច្ច ជាស្ត្រីចម្រើន ស្រង់ខ្ញុំដោយអវយវៈ ដូចមាតាត្រកងនូវបុត្តដែលកើតអំពីទ្រូង ។

[ ៥១ ] នាងជាស្ត្រីមានភ្នែកទន់ បានផ្គត់ផ្គង់ខ្ញុំដោយបាយ ទឹក សំពត់ និងទីដេកព្រមទាំងខ្លួន បពិត្រស្តេចតម្ពៈ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។

**ចប់ សុសន្ធីជាតកទី ១០**

**ចប់ មណិកុណ្ឌលវគ្គទី ១**

## ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីដែន និងកែវមណីដ៏ប្រសើរដែលសាបសូន្យ ១ អ្នកប្រួតស្មៅយកស្មៅខ្ចី ( ឲ្យគោស្លាប់ ) ១ បុគ្គលវង្វេង ដូចបុគ្គលធ្លាយសំពៅ ១ បុគ្គលលះបង់សរីរៈ ដូចពស់លះបង់សំណាក ១ ព្រះរាជាឈ្មោះយជកុមារ ១ ជ្រោះភ្នំ ១ កុញ្ជរ ១ មហេសីអ្នកបំផ្លាញនូវសេចក្តីចម្រើន ១ ម្រឹគ ១ ការត្រេកអរនូវកូន ១ រួមជា ១០ ។

# អដ្ឋកថា
# សុសន្ធីជាតក

[ ៤៧-៥១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វាតិ គន្ធោ តិមិរានំ** ដូច្នេះជាដើម ។

បានឮថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះទទួលថា ករុណាពិតព្រះអង្គ ទើបត្រាស់ថា ព្រោះហេតុអ្វី កាលភិក្ខុនោះក្រាបទូលថា ព្រោះឃើញមាតុគ្រាមប្រដាប់តាក់តែងខ្លួន ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ធម្មតាមាតុគ្រាមនេះ មិនអាចរក្សាទុកបាន សូម្បីបោរាណកបណ្ឌិត រក្សាទុកក្នុងសុបណ្ណពិភព ក៏មិនអាចរក្សាទុកបាន កាលភិក្ខុនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមថាតម្ពរាជ សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះអគ្គមហេសីរបស់ព្រះបាទតម្ពរាជនោះ ព្រះនាមថាសុយោនន្ទី មានរូបឆោមល្អក្រៃលែង ។ គ្រានោះព្រះពោធិសត្វកើតក្នុងកំណើតគ្រុឌ ក្នុងកាលណោះ មានកោះនាគឈ្មោះសេរុមៈ ។ ព្រះពោធិសត្វនៅក្នុងសុបណ្ណពិភពនាកោះនោះ ។ ព្រះពោធិសត្វចេញអំពីសុបណ្ណពិភព ទៅកាន់នគរពារាណសី កាឡាខ្លួនជាមាណព លេងបាស្កាជាមួយព្រះបាទតម្ពរាជ ស្រីដែលជាបរិចារិកា ឃើញរូបសម្បត្តិរបស់មាណពនោះ ទើបទូលដល់ព្រះនាងសុ-យោនន្ទីថា មាណពឈ្មោះនេះលេងបាស្កាជាមួយព្រះរាជានៃយើងទាំងឡាយ ។

ព្រះនាងសុយោនទ្ធីនោះបានស្ដាប់ដូច្នោះ ប្រាថ្នានឹងឃើញមាណពនោះ ។ ថ្ងៃមួយតាក់តែងព្រះកាយហើយ ចេញមកកាន់ទីលានលេងបាស្កា ប្រថាប់ឈរក្នុងរវាងបរិចារិកា មើលមាណពនោះ ។ ចំណែកមាណព ក៏មើលព្រះទេវីជនទាំងពីរ មានចិត្តប្រតិព័ទ្ធគ្នានឹងគ្នា ។ ស្ដេចគ្រុឌធ្វើខ្យល់ឲ្យតាំងឡើងក្នុងនគរដោយអានុភាពរបស់ខ្លួន មនុស្សទាំងឡាយ នាំគ្នាចេញអំពីព្រះរាជនិវេសន៍ ព្រោះខ្លាចផ្ទះបាក់ ។ ស្ដេចសុបណ្ណនោះ ធ្វើនូវភាពងងឹតដោយអានុភាពរបស់ខ្លួនហើយ នាំព្រះទេវីទៅតាមអាកាស ទៅទុកក្នុងភពរបស់ខ្លួននានាគទ្វីបនោះ ។ ឈ្មោះថាបុគ្គលដែលដឹងទីកន្លែង ដែលព្រះនាងសុយោនទ្ធីយាងទៅមិនមានឡើយ ។ ស្ដេចគ្រុឌនោះអភិរម្យជាមួយព្រះនាងសុយោនទ្ធីនោះហើយទៅលេងបាស្កាជាមួយព្រះរាជា ។ ឯព្រះរាជានោះមានគន្ធព្វឈ្មោះថាសគ្គៈ ។ ព្រះរាជាមិនជ្រាបទីដែលព្រះទេវីយាងទៅ ទើបត្រាស់ហៅគន្ធព្វនោះមក ហើយបញ្ជូនទៅដោយព្រះតម្រាស់ថា នែបាគន្ធព្វ ចូរអ្នកទៅ ចូរត្រាច់ទៅតាមផ្លូវគោក និងផ្លូវទឹករហូតដល់ដឹងទីកន្លែងដែលព្រះទេវីទៅ ។ គន្ធព្វនោះកាន់យកស្បៀងធ្វើដំណើររកមើលតាំងអំពីទ្វារស្រុក រហូតដល់កំពង់កុរុកច្ឆៈ ។ គ្រានោះឈ្មួញអ្នកកុរុកច្ឆៈ ចេញសំពៅទៅកាន់សុវណ្ណភូមិ ។ ទើបគន្ធព្វនោះ ចូលទៅរកឈ្មួញទាំងនោះហើយពោលថា ខ្ញុំជាគន្ធព្វអ្នកតន្ត្រីនឹងធ្វើការប្រៀងឲ្យដល់ពួកលោកផាត់ថ្លៃសំពៅ សូមលោកទាំងឡាយ នាំខ្ញុំទៅផង ឈ្មួញទាំងនោះទទួលថា សាធុ ហើយឲ្យឡើងសំពៅចេញ ដំណើរទៅ ។ កាលសំពៅសោត់ទៅហើយ ឈ្មួញទាំងនោះ ក៏ហៅគន្ធព្វនោះមក

ពោលថា ចូរធ្វើនូវការច្រៀងឲ្យដល់ពួកយើង គន្ធព្វពោលថា បើខ្ញុំច្រៀង សោត កាលខ្ញុំកំពុងច្រៀង ពួកត្រីទាំងឡាយនឹងរំជើបរំជួល កាលបើដូច្នោះ សំពៅរបស់អ្នកទាំងឡាយនឹងបែកធ្លាយ ។ ពួកឈ្មួញពោលថា បើអ្នកត្រឹម តែជាមនុស្ស ឈ្មោះថាពួកត្រីរំជើបរំជួលរមែងមិនមាន ចូរអ្នកច្រៀងចុះ ។ ទើបគន្ធព្វពោលថា បើយ៉ាងនោះអ្នកទាំងឡាយកុំក្រោធនឹងខ្ញុំ ។ ហើយស្រាយ ពិណាចេញធ្វើនូវការច្រៀង ឲ្យសំឡេងពិណានិងសំឡេងច្រៀងចូលគ្នាតែមួយ ។ ត្រីទាំងឡាយរំជើបរំជួលព្រោះសំឡេងនោះ ទើបនាំគ្នាច្រួលច្របល់ កាល ណោះ មករមួយលោតចូលទៅក្នុងសំពៅ ក៏ធ្វើឲ្យសំពៅធ្លាយ ។ នាយសគ្គៈ នោះដេកលើបន្ទះក្តារ អណ្តែតទៅតាមខ្យល់ រហូតដល់ដើមជ្រៃដែលជាសុ- បណ្ណពិភពនានាគទ្វីបនោះ ។ ចំណែកព្រះនាងសុយោនន្ទីទេវី ក្នុងកាលដែល ស្តេចគ្រុឌទៅលេងបាស្កាជាមួយព្រះរាជា ក៏ចុះអំពីវិមាន ដើរតាមមាត់ច្រាំង ឃើញគន្ធព្វឈ្មោះសគ្គៈនោះ ព្រះនាងចាំបានទើបសួរថា ឯងមកបានដូចម្តេច គន្ធព្វនោះក៏ក្រាបទូលរឿងទាំងអស់ ព្រះនាងសុយោនន្ទីលួងលោមគន្ធព្វនោះ ថា បើយ៉ាងនោះឯងកុំខ្លាចឡើយ ហើយយកដៃទាំងពីរ ត្រកងឡើងទៅកាន់ វិមាន ឲ្យដេកលើទីដេក ក្នុងកាលដែលនាយសគ្គៈមានកម្លាំងហើយ ក៏ឲ្យ ភោជនាហារទិព្វ ឲ្យងូតទឹកក្រអូបទិព្វ ឲ្យស្លៀកសំពត់ទិព្វ ប្រដាប់ដោយគ្រឿង ក្រអូបនិងផ្កាទិព្វ ហើយឲ្យដេកលើសេយ្យាសនទិព្វទៀត ។ ព្រះនាងបដិបត្តិ គន្ធព្វនោះដោយប្រការយ៉ាងនេះ ពេលស្តេចគ្រុឌមកក៏លាក់ទុក ពេលស្តេច គ្រុឌទៅ ក៏អភិរម្យដោយអំណាចកិលេស ជាមួយគន្ធព្វនោះអស់មួយថ្ងៃ ។

បន្ទាប់អំពីនោះ កន្ទុងទៅបានកន្លះខែ ឈ្មួញអ្នកនគរពារាណសីមកដល់គល់ជ្រៃក្នុងកោះនោះ ដើម្បីត្រូវការឧសនិងទឹក នាយសគ្គៈនោះ ក៏ឡើងសំពៅទៅកាន់នគរពារាណសីជាមួយពួកអ្នកសំពៅនោះ បានគាល់ព្រះរាជាស្រួលបួលហើយ ក្នុងកាលស្តេចគ្រុឌនោះមកលេងបាស្កា ទើបកាន់ពិណាច្រៀងថ្វាយព្រះរាជាដោយគាថាទី ១ ថា

ក្លិននៃផ្កាតិមិរព្រឹក្ស រមែងផ្សាយទៅ សមុទ្ទដែលពេញដោយទឹកមានសំឡេងគឹកកង បពិត្រស្តេចតម្ពៈ ព្រោះថា នាងសុសន្ទី ( នៅ ) ក្នុងទីឆ្ងាយពីនគរនេះ កាមទាំងឡាយតែងចាក់ដោតខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តិមិរានំ** បានដល់ ផ្ការបស់ដើមតិមិរៈ ។ បានឮថា ដើមតិមិរៈដុះជុំវិញដើមជ្រៃនោះ ។ សគ្គគន្ធព្វ ពោលយ៉ាងនោះសំដៅយកដើមតិមិរៈទាំងនោះ ។ បទថា **កុសមុទ្ទោ** បានដល់ ទឹកសមុទ្ទ ។ បទថា **ឃោសវា** បានដល់ មានសំឡេងលាន់ឮ ។ សគ្គគន្ធព្វពោលយ៉ាងនេះ សំដៅយកសមុទ្ទក្បែរៗដើមជ្រៃនោះប៉ុណ្ណោះ ។ បទថា **ឥតោ ហិ** បានដល់ ក្រៅនគរនេះ ។ សគ្គគន្ធព្វហៅព្រះរាជាថា **តម្ព** ។ ម្យ៉ាងទៀត ដោយបទថា **តម្ពកាមា** នេះ លោកសម្តែងថា កាមដែលព្រះបាទតម្ពរាជប្រាថ្នាឈ្មោះថាតម្ពកាម កាមនោះចាក់ដោតហទយៈរបស់ទូលព្រះបង្គំ ។ ស្តេចគ្រុឌបានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

អ្នកឆ្លងសមុទ្ទបានដោយប្រការដូចម្តេច អ្នកឃើញកោះឈ្មោះ

សេរុមដោយប្រការដូចម្តេច ម្នាលអគ្គៈ ការជួបប្រសព្វនាង
សុសន្ទីនឹងអ្នក បានមានមកដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សេរុមំ** បានដល់ កោះឈ្មោះសេរុមៈ ។ លំដាប់នោះ សគ្គគន្ធព្វបានពោលគាថា ៣ ថា

នាវារបស់ពួកឈ្មួញអ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់
ភរុកច្ឆា បែកធ្លាយដោយមង្គរ ខ្ញុំក៏ធ្វងសមុទ្រដោយផែនក្តារ ។

នាងសុសន្ទីនោះ ជាស្រ្តីមានវាចាទន់ពីរោះ មានក្លិនដូច
ខ្លឹមចន្ទន៍អស់កាលជានិច្ច ជាស្រ្តីចម្រើន ស្រង់ខ្ញុំដោយអវ-
យវៈ ដូចមាតាត្រកងនូវបុត្តដែលកើតអំពីទ្រូង ។

នាងជាស្រ្តីមានភ្នែកទន់ បានផ្គត់ផ្គង់ខ្ញុំដោយបាយទឹកសំពត់
និងទីដេកព្រមទាំងខ្លួន បពិត្រស្តេចតម្ពៈ សូមព្រះអង្គជ្រាប
យ៉ាងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សា មំ សណ្ហេន មុទុនា** សេចក្តីថា ព្រះនាងត្រាច់ទៅត្រង់ច្រាំងសមុទ្រ ឃើញទូលព្រះបង្គំ ដេកលើបន្ទះក្តារយ៉ាងនេះហើយ ព្រះនាងលួងលោមដោយវាចាដ៏ពីរោះថា អ្នកកុំខ្លាចឡើយ ។ បទថា **អង្កេន** នេះ ដើមដៃទាំងគូ លោកហៅថា **អង្កេន** ក្នុងទីនេះ ។ បទថា **ភទ្ទា** បានដល់ គួរមើល គួរជ្រះថ្លា ។ បទថា **សា មំ អន្នេន** សេចក្តីថា ព្រះនាងបម្រើទូលព្រះបង្គំឲ្យឆ្អែតស្កប់ស្កល់ដោយបាយជាដើម ។ បទថា **អត្ត-មនាបិ ច** នេះ លោកសម្តែងថា មិនមែនតែបាយជាដើម តែប៉ុណ្ណោះ

ឡើយ សូម្បីខ្លួនព្រះនាង ក៏ព្រះនាងបម្រើទូលព្រះបង្គំឲ្យឆ្អែតស្កប់ស្កល់ក្នុងការអភិរម្យ ។ បទថា **មន្ទក្ខី** បានដល់ មានភ្នែកស្រទន់ លោកអធិប្បាយថា មានប្រក្រតីមើលដោយអាការៈទន់ភ្លន់ ។ បាលីថា **មត្តក្ខី** ដូច្នេះក៏មាន ។ អធិប្បាយថា ប្រកបដោយកែវភ្នែកហាក់ដូចស្រវឹងល្មមប្រមាណ គឺមានកែវភ្នែកស្រទន់ ។ បទថា **ឯវំ តម្ពូ** សេចក្តីថា បពិត្រព្រះបាទតម្ពរាជ សូមទ្រង់ជ្រាបយ៉ាងនេះ ។

កាលគន្ធព្វនោះឯងកំពុងពោល ស្តេចគ្រុឌមានការទោមនស្សគិតថា សូម្បីអញនៅក្នុងសុបណ្ណពិភព ក៏មិនអាចរក្សាស្រីនេះបាន ប្រយោជន៍អ្វីដោយស្រីទ្រុស្តសីល ទើបនាំព្រះនាងមកថ្វាយព្រះរាជា ហើយចៀសចេញទៅ តាំងអំពីនោះមក ស្តេចគ្រុឌលែងមកទៀតហើយ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ទើបទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ស្តេចគ្រុឌក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សុសន្ធីជាតក ចប់**

**មណិកុណ្ឌលវគ្គ ចប់**

# វណ្ណារោហវគ្គ

## វណ្ណារោហជាតក

[ ៥២ ] ( ខ្លាឈ្មោះសុពាហុពោលថា ) អ្នកឈ្មោះសុទាឋៈនិយាយថា ខ្លាឈ្មោះសុពាហុមិនប្រសើរជាងអញដោយទំហំ កម្ពស់ ជាតិ កម្លាំងកាយនិងសេចក្តីព្យាយាម ដូច្នេះឬទេ ។

[ ៥៣ ] ( សីហៈឈ្មោះសុទាឋៈពោលថា ) អ្នកឈ្មោះសុពាហុនិយាយថា សីហៈឈ្មោះសុទាឋៈ មិនប្រសើរជាងអញដោយទំហំ កម្ពស់ ជាតិ កម្លាំងកាយនិងសេចក្តីព្យាយាមដូច្នេះឬទេ ។

[ ៥៤ ] ម្នាលសុពាហុសម្លាញ់ បើអ្នកប្រទូស្តចំពោះខ្ញុំ ដែលកំពុងនៅយ៉ាងនេះ ឥឡូវនេះខ្ញុំមិនពេញចិត្តចំពោះការនៅរួមជាមួយអ្នកទេ ។

[ ៥៥ ] អ្នកណាជឿនូវពាក្យនៃជនដទៃដ៏ផ្តេសផ្តាស អ្នកនោះគប្បីបែកធ្លាយចាកមិត្តឆាប់រហ័ស ទាំងបាននូវពៀរជាច្រើន ។

[ ៥៦ ] មិត្តណាជាអ្នកប្រយ័ត្ន រង្កៀសក្នុងការបែកធ្លាយ ( ចំពោះមិត្ត ) ឃើញតែទោសសព្វកាល អ្នកនោះមិនឈ្មោះថាមិត្តឡើយ មួយទៀតបុគ្គលណាដែលពួកជនដទៃបំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះឯងទើបឈ្មោះថាមិត្ត ។

**ចប់ វណ្ណារោហជាតកទី ១ ។**

# វណ្ណារោហវគ្គ

## អដ្ឋកថា វណ្ណារោហជាតក

[ ៥២-៥៦ ] ព្រះសាស្ដា កាលអាស្រ័យនគរសាវត្ថី គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈដែលជាអគ្គសាវកទាំងពីរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **វណ្ណារោហេន** ដូច្នេះជាដើម ។

បានឮថា សម័យមួយព្រះមហាថេរទាំងពីរគិតគ្នាថា ពួកយើងនឹងនៅក្នុងផ្ទះស្ងាត់អស់កាលខាងក្នុងវស្សានេះ ទើបទូលលាព្រះសាស្ដា ហើយលះពួកគណៈ កាន់បាត្រចីវរដោយខ្លួនឯងចេញអំពីវត្តជេតពន អាស្រ័យបច្ចន្តគ្រាមមួយកន្លែងនៅក្នុងព្រៃ ។ បុរសអ្នកស៊ីដែលម្នាក់ ធ្វើការឧបដ្ឋាកព្រះថេរៈទាំងពីរក្នុងចំណែកម្ខាងក្នុងព្រៃនោះឯង ។ បុរសនោះ ឃើញការនៅព្រមព្រៀងរបស់ព្រះថេរៈទាំងពីរទើបគិតថា ព្រះថេរៈទាំងពីរនេះ នៅព្រមព្រៀងគ្នានឹងគ្នាពន់ពេក អញអាចបំបែកព្រះថេរៈទាំងនេះ ឲ្យបែកគ្នាបានឬទេហ្ន៎ ទើបចូលទៅរកព្រះសារីបុត្តត្ថេរហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មានពៀរណាមួយជាមួយព្រះមោគ្គល្លានត្ថេរដែរឬហ្ន៎ ព្រះសារីបុត្តត្ថេរសួរថា ពៀរអ្វីអាវុសោ បុរសនោះពោលថា បពិត្រលោកម្ចាស់ ក្នុងពេលដែលខ្ញុំមក ព្រះមហាមោគ្គល្លានត្ថេរ ពោលតែទោសរបស់លោកម្ចាស់ប៉ុណ្ណោះថា ឈ្មោះថាសារីបុត្ត ធ្វើម្ដេចល្មមជាមួយយើងដោយជាតិ គោត្ត ត្រកូល ប្រទេស សុតៈគន្ថៈ បដិវេធ និងឫទ្ធិជាដើមព្រះថេរៈធ្វើការញញឹមហើយពោលថា អាវុសោ ចូរអ្នកទៅចុះ ។ ក្នុងថ្ងៃដទៃបុរសនោះចូលទៅរកព្រះមោគ្គល្លានត្ថេរ ហើយ

ពោលយ៉ាងនោះឯង ។ ចំណែកព្រះមហាមោគ្គល្លានត្ថេរ ក៏ធ្វើការញញឹម ហើយពោលនឹងបុរសនោះថា អាវុសោ ចូរអ្នកទៅចុះ ។ ហើយទើបចូលទៅរកព្រះសារីបុត្តសួរថា អាវុសោ បុរសស៊ីដែលនោះ ពោលអ្វីក្នុងសម្នាក់របស់លោក ព្រះសារីបុត្តពោលថា អាវុសោ គេពោលនឹងខ្ញុំ យើងគួរនាំបុរសអ្នកស៊ីដែលនោះចេញទៅ ព្រះមោគ្គល្លានត្ថេរពោលថា សាធុអាវុសោ ចូរលោកនាំចេញទៅចុះ ព្រះថេរៈក៏ផ្ទាត់ម្រាមដៃដែលជាហេតុឲ្យដឹងថា អ្នកកុំនៅក្នុងទីនេះហើយនាំបុរសនោះចេញទៅ ព្រះថេរៈនៅដោយសាមគ្គីគ្នា ហើយបានទៅកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ។ ព្រះសាស្ដាធ្វើបដិសណ្ឋារៈ ហើយត្រាស់សួរថា អ្នកទាំងពីរនៅអស់វស្សាដោយសុខឬ កាលព្រះថេរៈទាំងពីរក្រាបទូលថា បពិត្រព្រះអង្គ បុរសស៊ីដែលម្នាក់បំណងនឹងបំបែកពួកខ្ញុំ កាលមិនអាចបំបែក ក៏គេចទៅ ។ ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ ដែលបុរសនេះមិនអាចបំបែក សូម្បីក្នុងកាលមុន បុរសស៊ីដែលនេះ ក៏គិតថានឹងបំបែកពួកអ្នក កាលមិនអាចបំបែកក៏គេចទៅហើយ ព្រះថេរៈទាំងពីរនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតានៅក្នុងព្រៃ ។ កាលណោះ រាជសីហ៍និងខ្លាធំរស់នៅជាមួយគ្នាក្នុងគុហាភ្នំ ។ ចចកមួយឧបដ្ឋាកសត្វទាំងពីរនោះ ជាអ្នកស៊ីដែលរបស់សត្វទាំងពីរនោះ រហូតមានរាងកាយធំធាត់ ថ្ងៃមួយគិតថា អញ

មិនធ្លាប់ស៊ីសាច់របស់រាជសីហ៍និងខ្លាធំ អញគួរធ្វើសត្វទាំងពីរនេះឲ្យបែកគ្នា បន្ទាប់អំពីនោះអញនឹងស៊ីសាច់របស់សត្វទាំងពីរ ដែលស្លាប់ព្រោះការឈ្លោះគ្នា ។ ចចកនោះក៏ចូលទៅរករាជសីហ៍ហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មានពៀរអ្វីជាមួយខ្លាធំឬ រាជសីហ៍ពោលថា ពៀរអ្វីសម្លាញ់ ចចកពោលថា បពិត្រលោកម្ចាស់ ខាងដើមកាលខ្ញុំមក ខ្លាធំនោះពោលតែទោសរបស់លោកប៉ុណ្ណោះឯងថា រាជសីហ៍នោះ រមែងមិនដល់យើង ដោយចំណែកនៃចម្រៀក ដោយពណ៌សម្បុរនៃសរីរៈក្តី កម្ពស់និងទំហំក្តី ជាតិនិងកម្លាំងកាយក្តី សេចក្តីព្យាយាមក្តី ។ រាជសីហ៍ពោលថា ចូរអ្នកទៅចុះ ខ្លានោះនឹងមិនពោលយ៉ាងនោះ ។ សូម្បីខ្លាកាលចចកចូលទៅរក ក៏ពោលដោយឧបាយនោះឯង ។ ខ្លាបានស្តាប់ដូច្នោះ ទើបចូលទៅរករាជសីហ៍ ហើយពោលថា នៃសម្លាញ់ បានឮថា អ្នកពោលយ៉ាងនេះនិងយ៉ាងនេះ កាលនឹងសួរទើបពោលគាថាទី ១ ថា

> អ្នកឈ្មោះសុទាឋៈនិយាយថា ខ្លាឈ្មោះសុពាហុ មិនប្រសើរ
> ជាងអញដោយទំហំ កម្ពស់ ជាតិ កម្លាំងកាយ និងសេចក្តី
> ព្យាយាម ដូច្នេះឬទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពលនិក្កមេន ច** សេចក្តីថា មានកម្លាំងកាយនិងកម្លាំងព្យាយាម ។ បទថា **សុពាហុ ន មយា សេយ្យោ** សេចក្តីថា បានឮថា ស្តេចម្រឹគដែលប្រកបដោយចង្កូមទាំងឡាយស្អាត ឈ្មោះថាជាអ្នកមានចង្កូមស្អាតពោលយ៉ាងនេះថា ខ្លាធំឈ្មោះថាសុពាហុនេះ មិនប្រហែល គឺ

មិនប្រសើរជាងអញដោយហេតុទាំងនេះពិតឬ ។

រាជសីហ៍បានស្តាប់ពាក្យនោះ ទើបពោលគាថា ៤ ដ៏សេសថា

អ្នកឈ្មោះសុពាហុនិយាយថា សីហៈឈ្មោះ សុទាឋៈ មិន ប្រសើរជាងអញដោយទំហំ កម្ពស់ ជាតិ កម្លាំងកាយ និង សេចក្តីព្យាយាមដូច្នេះឬទេ ។

ម្នាលសុពាហុសម្លាញ់ បើអ្នកប្រទូស្តចំពោះខ្ញុំដែលកំពុង នៅយ៉ាងនេះ ឥឡូវនេះខ្ញុំមិនពេញចិត្តចំពោះការនៅរួមជាមួយ អ្នកទេ ។

អ្នកណាជឿនូវពាក្យនៃជនដទៃដ៏ផ្តេសផ្តាស អ្នកនោះគប្បី បែកធ្លាយចាកមិត្តឆាប់រហ័ស ទាំងបាននូវពៀរជាច្រើន ។

មិត្តណាជាអ្នកប្រយ័ត្ន រង្កៀសក្នុងការបែកធ្លាយ ( ចំពោះ មិត្ត ) ឃើញតែទោសសព្វកាល អ្នកនោះមិនឈ្មោះថាមិត្ត ឡើយ មួយទៀត បុគ្គលណាដែលពួកជនដទៃបំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះឯង ទើបឈ្មោះថាមិត្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្ម** បានដល់ នៃសម្លាញ់ ។ បទថា **ទុព្ភសិ** សេចក្តីថា បើអ្នកជឿពាក្យរបស់ចចកហើយ ប្រទូស្ត គឺប្រាថ្នានឹងសម្លាប់ខ្ញុំ ដែលនៅដោយសេចក្តីព្រមព្រៀងជាមួយអ្នកយ៉ាងនេះសោត ចាប់តាំងអំពីនេះ ទៅខ្ញុំមិនគប្បីត្រេកអរនៅជាមួយអ្នក ។ បទថា **យថាតថំ** សេចក្តីថា គប្បី

ជឿពាក្យអារ្យជនដែលមិនពោលឲ្យឃ្លៀងឃ្លាត ពោលតាមសេចក្ដីពិត គឺតាមសេចក្ដីពិត យ៉ាងណា អធិប្បាយថា បុគ្គលណា គប្បីជឿពាក្យរបស់អ្នកដទៃណាមួយ ក៏យ៉ាងនោះដែរ ។ បទថា **យោ សទា អប្បមត្តោ** សេចក្ដីថា បុគ្គលណាមិនប្រមាទជានិច្ច មិនឲ្យការស្និទ្ធស្នាលដល់មិត្ត បុគ្គលនោះមិនឈ្មោះថាមិត្ត ។ បទថា **ភេទាសង្កី** សេចក្ដីថា រមែងរង្កៀសតែការប្រេះឆារបស់មិត្តយ៉ាងនេះថា នឹងបែកគ្នាថ្ងៃនេះ នឹងបែកគ្នាថ្ងៃស្អែក ។ បទថា **រន្ធមេវានុបស្សី** បានដល់ សម្លឹងឃើញតែកំហុសត្រង់ប៉ុណ្ណោះ ។ បទថា **ឧរសីវ បុត្តោ** សេចក្ដីថា បុគ្គលដែលមិនរង្កៀសក្នុងមិត្ត ជាអ្នកផុតភ័យ ដេកដូចបុត្ត ដេកត្រង់ទ្រូងរបស់មាតាដូច្នោះ ។ កាលរាជសីហ៍ពោលគុណរបស់មិត្តដោយគាថាទាំង ៤ នេះ ដោយប្រការដូច្នេះ ខ្លាពោលថា ទោសកំហុសរបស់ខ្ញុំ ហើយសូមខមាទោសរាជសីហ៍ ។ សត្វទាំងពីរនោះ បាននៅព្រមព្រៀងគ្នាដូចមុន ចំណែកចចកបានគេចទៅកាន់ទីដទៃនោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាអ្នកស៊ីដែលក្នុងកាលឥឡូវនេះ រាជសីហ៍ក្នុងកាលនោះ បានមកជាសារីបុត្ត ខ្លាធំក្នុងកាលនោះ បានមកជាមោគ្គល្លាន ចំណែករុក្ខទេវតាដែលស្ថិតនៅក្នុងព្រៃនោះឃើញហេតុការណ៍នោះដោយប្រចក្សក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា វណ្ណារោហជាតក ចប់**

# សីលវីមំសជាតក

[ ៥៧ ] ( ព្រាហ្មណ៍ពោធិសត្វពោលថា ) ខ្ញុំមានសេចក្ដីសង្ស័យថា សីលជារបស់ប្រសើរ ឬសុតៈជារបស់ប្រសើរ សីល ( មារយាទ ) ជារបស់ប្រសើរជាងសុតៈ ( ការចេះដឹង ) ខ្ញុំមិនមានសេចក្ដីសង្ស័យដូច្នោះឡើយ ។

[ ៥៨ ] ជាតិនិងវណ្ណៈឥតអំពើ សីលហ្នឹងឯងទើបឧត្ដម បុគ្គលកាលបើប្រាសចាកសីលហើយ ប្រយោជន៍ដោយសុតៈមិនមានទេ ។

[ ៥៩ ] ក្សត្រិយ៍មិនឋិតនៅក្នុងធម៌ ( ច្បាប់ ) វេស្សៈមិនអាស្រ័យធម៌ ពួកជនទាំងនោះ រមែងលះបង់លោកទាំងពីរទៅកាន់ទុគ្គតិ ។

[ ៦០ ] ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាលនិងបុក្កុសជនប្រព្រឹត្តធម៌ក្នុងលោកនេះ រមែងស្មើគ្នាក្នុងទេវលោក ។

[ ៦១ ] វេទក៏មិនមែនឲ្យសុខក្នុងបរលោក ជាតិក៏មិនមែនឲ្យសុខក្នុងបរលោក ផៅពង្សក៏មិនមែនឲ្យសុខក្នុងបរលោក មានតែសីលដ៏បរិសុទ្ធរបស់ខ្លួន ទើបនាំមកនូវសេចក្ដីសុខក្នុងបរលោក ។

**ចប់ សីលវីមំសជាតកទី ២ ។**

# អដ្ឋកថា
# សីលវីមំសជាតក

[ ៥៧-៦១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍សាកល្បងសីលម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សីលំ សេយ្យោ** ដូច្នេះជាដើម ។

បានឮថា ព្រះរាជាឃើញព្រាហ្មណ៍នោះថា ព្រាហ្មណ៍នេះជាអ្នកដល់ព្រមដោយសីល ទើបទ្រង់តែងតាំងដំណែងឲ្យក្រៃលែងជាងព្រាហ្មណ៍ទាំងឡាយ ។ ព្រាហ្មណ៍នោះគិតថា ព្រះរាជាទ្រង់ធ្វើនូវការគោរពរាប់អានអញ ទ្រង់ឃើញអញថាជាអ្នកមានសីល ឬថាទ្រង់ឃើញអញជាអ្នកប្រកបដោយការទ្រទ្រង់សុតៈ អញនឹងសាកល្បងមើលថា សីលនិងសុតៈណាមួយសំខាន់ជាង ។ ថ្ងៃមួយព្រាហ្មណ៍នោះ ចាប់យកកហាបណៈអំពីបន្ទះក្តារសម្រាប់រាប់ប្រាក់របស់ហិរញ្ញិក ។ ហិរញ្ញិកក៏មិនថាអ្វីព្រោះសេចក្តីគោរព ក្នុងថ្ងៃទី ២ ក៏មិនពោលអ្វី តែក្នុងថ្ងៃទី ៣ ហិរញ្ញិក ពោលចោទថា ជាចោរប្លន់ប្រាក់ ហើយឲ្យចាប់ព្រាហ្មណ៍នោះមកថ្វាយព្រះរាជា កាលព្រះរាជាត្រាស់ថា ព្រាហ្មណ៍នេះធ្វើអ្វី ទើបក្រាបទូលថា បពិត្រព្រះអង្គ ព្រាហ្មណ៍នេះប្លន់ទ្រព្យ ។ ព្រះរាជាត្រាស់សួរថា គេថានុ៎ះពិតឬព្រាហ្មណ៍ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជទូលព្រះបង្គំមិនបានប្លន់ទ្រព្យ តែទូលព្រះបង្គំរង្កៀសសង្ស័យថា សីលជាធំឬសុតៈជាធំ ទើបទូលព្រះបង្គំសាកល្បងថា បណ្តាសីលនិងសុតៈនោះ មួយណាជាធំហ្ន៎ ទើបកាន់យកកហាបណៈ ៣ ដង ទើបហិរញ្ញិកឲ្យចាប់ទូលព្រះបង្គំនាំមកថ្វាយទ្រង់ ឥឡូវនេះទូលព្រះបង្គំជ្រាបហើយថា សីលធំជាងសុតៈ

ទូលព្រះបង្គំមិនត្រូវការនៅគ្រប់គ្រងផ្ទះ ទូលព្រះបង្គំនឹងបួស ។ ហើយសូមអនុញ្ញាតការបួស មិនសម្លឹងមើលទ្វារផ្ទះ ទៅកាន់វត្តជេតពន ទូលសូមបព្វជ្ជានឹងព្រះសាស្តា ព្រះសាស្តាទ្រង់ឲ្យបព្វជ្ជានិងឧបសម្បទា ដល់ព្រាហ្មណ៍នោះ ។ លោកឧបសម្បទាមិនយូរប៉ុន្មាន ចម្រើនវិបស្សនាបានតាំងនៅក្នុងអរហត្តផល ។

ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រាហ្មណ៍ឈ្មោះនោះ សាកល្បងសីលរបស់ខ្លួនហើយបួសចម្រើនវិបស្សនាបានសម្រេចអរហត្តហើយ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នេះប៉ុណ្ណោះសាកល្បងសីលហើយបព្វជ្ជាសម្រេចអរហត្តក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនបណ្ឌិតទាំងឡាយ សាកល្បងសីលហើយបព្វជ្ជា បានធ្វើទីពឹងដល់ខ្លួនហើយដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយរៀនសិល្បសាស្ត្រគ្រប់យ៉ាងក្នុងនគរតក្កសិលា សម្រេចហើយ ត្រឡប់ទៅកាន់នគរពារាណសីសម្តែងសិប្បៈឲ្យព្រះរាជាទត ។ ព្រះរាជាបានប្រទានតំណែងជាបុរោហិតដល់ព្រះពោធិសត្វនោះ ព្រះពោធិសត្វនោះរក្សាសីល ៥ ។ ចំណែកព្រះរាជាក៏ទ្រង់គោរពព្រះពោធិសត្វនោះ ព្រោះឃើញថាជាអ្នកមានសីល ។ ព្រះពោធិ

សត្វគិតថា ព្រះរាជាទ្រង់គោរពអញថាជាអ្នកមានសីលឬទ្រង់ឃើញថា អញជាអ្នកទ្រទ្រង់សុតៈ ។ រឿងទាំងពួងដូចគ្នានឹងរឿងបច្ចុប្បន្ននោះឯង តែក្នុងទីនេះ ព្រាហ្មណ៍នោះពោលថា ឥឡូវនេះអញដឹងហើយថា សីលជាធំជាងសុតៈ ទើបពោលគាថា ៥ ដូច្នេះថា

ខ្ញុំមានសេចក្តីសង្ស័យថា សីលជារបស់ប្រសើរឬសុតៈជារបស់ប្រសើរ សីល ( មារយាទ ) ជារបស់ប្រសើរជាងសុតៈ ( ការចេះដឹង ) ខ្ញុំមិនមានសេចក្តីសង្ស័យដូច្នោះឡើយ ។

ជាតិនិងវណ្ណៈឥតអំពើ សីលហ្នឹងឯងទើបឧត្តម បុគ្គលកាលបើប្រាសចាកសីលហើយប្រយោជន៍ដោយសុតៈមិនមានទេ ។

ក្សត្រិយ៍មិនឋិតនៅក្នុងធម៌ ( ច្បាប់ ) វេស្សៈមិនអាស្រ័យធម៌ ពួកជនទាំងនោះរមែងលះបង់លោកទាំងពីរទៅកាន់ទុគ្គតិ ។

ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល និងបុក្កុសជន ប្រព្រឹត្តធម៌ក្នុងលោកនេះរមែងស្មើគ្នាក្នុងទេវលោក ។

វេទក៏មិនមែនឲ្យសុខក្នុងបរលោក ជាតិក៏មិនមែនឲ្យសុខក្នុងបរលោក ផៅពង្សក៏មិនមែនឲ្យសុខក្នុងបរលោក មានតែសីលដ៏បរិសុទ្ធរបស់ខ្លួនទើបនាំមកនូវសេចក្តីសុខក្នុងបរលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលមេវ សុតា សេយ្យោ** សេចក្តីថា សីលប៉ុណ្ណោះក្រៃលែងជាងបរិយត្តិ គឺសុតៈ រាប់រយដង រាប់ពាន់ដង ។ កាល

ពោលយ៉ាងនេះហើយ ទើបតាំងមាតិកាថា ឈ្មោះថាសីលនេះ មានតែម្យ៉ាង ដោយអំណាចសំវរសីល មាន ២ យ៉ាងដោយអំណាចចារិត្តសីលនិងវារិត្តសីល មាន ៣ យ៉ាងដោយអំណាចកាយសីល វាចាសីល និងចិត្តសីល មាន ៤ យ៉ាងដោយអំណាចបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ។ គប្បីពោលគុណរបស់សីលឲ្យពិស្តារ ។ បទថា **មោឃា** បានដល់ ឥតផល គឺជារបស់ទទេ ។ បទថា **ជាតិ** បានដល់ ការកើតក្នុងខត្តិយត្រកូលជាដើម ។ បទថា **វណ្ណោ** បានដល់ ពណ៌សម្បុរនៃរាងកាយ គឺភាពជាអ្នកមានរូបស្អាត ។ ព្រោះហេតុដែលដល់ព្រមដោយជាតិក្តី ដល់ព្រមដោយពណ៌សម្បុរក្តី រមែងមិនអាចឲ្យសេចក្តីសុខក្នុងឋានសួគ៌ ដល់បុគ្គលដែលប្រាសចាកសីល ដូច្នោះទើបពោលការដល់ព្រមដោយជាតិ និងពណ៌សម្បុរទាំងពីរនោះថាជាមោឃៈ ។ ដោយបទថា **សីលមេវ កិរ** នេះ លោកពោលតាមដែលបានឮ បានស្តាប់មក តែមិនបានដឹងដោយខ្លួនឯង ។ បទថា **អនុបេតស្ស** បានដល់ ជាអ្នកមិន ប្រកបហើយ ។ បទថា **សុតេនត្ថោ ន វិជ្ជតិ** សេចក្តីថា បុគ្គលដែលវៀរចាកសីល រមែងមិនមានសេចក្តីចម្រើនណាមួយក្នុងលោកនេះ ឬលោកខាងមុខ ព្រោះត្រឹមតែបរិយត្តិ គឺសុតៈ បន្ទាប់អំពីនោះបានពោលគាថា ២ ខាងមុខតទៅ ដើម្បីសម្តែងដល់ភាពដែលជាតិជារបស់ទទេ ។ បណ្តាបទទាំងនោះ បទថា **តេ បរិច្ចជ្ជុភោ លោកេ** សេចក្តីថា បុគ្គលមិនមានសីលទាំងនោះ លះលោកទាំងពីរគឺទេវលោកនិងមនុស្សលោករមែងចូលដល់ទុគ្គតិ ។ បទថា **ចណ្ឌាល–**

**បុក្កុសា** បានដល់ មនុស្សចណ្ឌាលអ្នកចោលសាកសព និងបុគ្គលមានជាតិជាបុក្កុសៈជាអ្នកចោលផ្កា ( សំរាម ) ។ បទថា **ភវន្តិ តិទិវេ សមា** សេចក្តីថា ជនទាំងអស់នោះ កើតក្នុងទេវលោកដោយអានុភាពនៃសីល ឈ្មោះថាជាអ្នកស្មើគ្នា គឺមិនវិសេសជាងគ្នា ដល់នូវការរាប់ថាជាទេវតាដូចគ្នា ។ លោកពោលគាថាទី ៥ ដើម្បីសម្តែងថា សុតៈ ជាដើម ជារបស់ទទេ ។ អត្ថរបស់គាថាទី ៥ នោះថា បពិត្រមហារាជ វេទជាដើមនេះ វៀរការឲ្យត្រឹមតែយសក្នុងលោកនេះចេញ រមែងមិនអាចនឹងឲ្យយស ឬសុខក្នុងលោកខាងមុខ គឺក្នុងភពទី ២ ឬភពទី ៣ បានឡើយ ចំណែកសីលរបស់ខ្លួនប៉ុណ្ណោះជារបស់បរិសុទ្ធ រមែងឲ្យយស ឬសុខនោះបាន ។

ព្រះមហាសត្វ ពោលសរសើរគុណរបស់សីលយ៉ាងនេះហើយ ទើបសូមអនុញ្ញាតអំពីព្រះរាជាដើម្បីបួស ហើយចូលទៅកាន់ព្រៃហិមពាន្តក្នុងថ្ងៃនោះឯង បួសជាឥសីធ្វើអភិញ្ញា និងសមាបត្តិឲ្យកើតហើយ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ពិសោធសីលហើយបួសជាឥសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សីលវីមំសជាតក ចប់

# ហិរិជាតក

[ ៦២ ] ( ពារាណសីសេដ្ឋីពោលថា ) បណ្ឌិតគប្បីដឹងច្បាស់ នូវបុគ្គលដែលលះបង់នូវសេចក្ដីខ្មាស គួរខ្ពើមរអើម ( ដោយមេត្តាភាវនា ) ដែលគ្រាន់តែពោលថា ខ្ញុំ ( ជាមិត្ត ) របស់អ្នក តែមិនកាន់យកនូវអំពើដ៏ប្រសើរ ថា អ្នកនុ៎ះមិនមែនជាមិត្តរបស់អញ ។

[ ៦៣ ] ពិតណាស់ បុគ្គលធ្វើនូវអំពើណា គួរនិយាយចំពោះអំពើនោះ បុគ្គលមិនធ្វើនូវអំពើណា មិនគួរនិយាយចំពោះអំពើនោះ ពួកបណ្ឌិតតែងស្គាល់ច្បាស់នូវបុគ្គលដែលមិនធ្វើ គ្រាន់តែនិយាយ ។

[ ៦៤ ] បុគ្គលណាជាអ្នកប្រយ័ត្នក្នុងកាលទាំងពួង រង្កៀសក្នុងការបែកធ្លាយ ( ចំពោះមិត្ត ) សម្លឹងរំពៃរកទោសតែម្យ៉ាង អស់កាលជានិច្ច អ្នកនោះមិនឈ្មោះថាមិត្តឡើយ មួយទៀត បុគ្គលណាដែលពួកជនដទៃបំបែកមិនបាន រមែងដេកនៅរួមដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះទើបឈ្មោះថាមិត្តដោយពិត ។

[ ៦៥ ] កុលបុត្តអ្នកមានផលានិសង្ស កាលនាំទៅនូវធុរៈជារបស់បុរស រមែងចម្រើននូវហេតុជាគ្រឿងធ្វើនូវបាមោជ្ជៈ ជាគ្រឿងនាំមកនូវសេចក្ដីសរសើរជាសុខ ។

[ ៦៦ ] បុគ្គលផឹកនូវរសនៃវិវេកធម៌ផង នូវរសនៃសេចក្ដីស្ងប់រម្ងាប់ផង ផឹកនូវរសនៃធម្មបីតិផង ទើបជាអ្នកមិនមានកង្វល់មិនមានបាប ។

**ចប់ ហិរិជាតកទី ៣**

# អដ្ឋកថា

# ហិរិជាតក

[ ៦២-៦៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីអ្នកបច្ចន្តគាម ដែលជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ហិរិន្តរន្តំ** ដូច្នេះជាដើម ។

រឿងទាំងពីរ គឺរឿងបច្ចុប្បន្ននិងរឿងអតីតៈ មានពិស្តារហើយក្នុងជាតកខាងដើមនៃនវមវគ្គ ឯកនិបាត តែក្នុងជាតកនេះ កាលមនុស្សមកប្រាប់ដល់ពារាណសីសេដ្ឋីថា មនុស្សរបស់សេដ្ឋីអ្នកបច្ចន្តគាមត្រូវដណ្តើមទ្រព្យសម្បត្តិមិនជាម្ចាស់នៃទ្រព្យជារបស់ខ្លួននាំគ្នារត់ទៅហើយ ទើបពារាណសីសេដ្ឋីពោលថា ធម្មតាបុគ្គលដែលមិនធ្វើកិច្ចដែលគប្បីធ្វើដល់បុគ្គលដែលមកកាន់សម្នាក់របស់ខ្លួន រមែងមិនបានបុគ្គលដែលធ្វើតបស្នងដូចគ្នា ហើយពោលគាថាទាំងនេះថា

បណ្ឌិតគប្បីដឹងច្បាស់នូវបុគ្គលដែលលះបង់នូវសេចក្តីខ្មាស
គួរខ្ពើមរអើម ( ដោយមេត្តាភាវនា ) ដែលគ្រាន់តែពោលថា
ខ្ញុំ ( ជាមិត្ត ) របស់អ្នក តែមិនកាន់យកនូវអំពើដ៏ប្រសើរ
ថា អ្នកនុ៎ះមិនមែនជាមិត្តរបស់អញ ។

ពិតណាស់ បុគ្គលធ្វើនូវអំពើណា គួរនិយាយចំពោះអំពើ
នោះ បុគ្គលមិនធ្វើនូវអំពើណា មិនគួរនិយាយចំពោះអំពើនោះ
ពួកបណ្ឌិត តែងស្គាល់ច្បាស់នូវបុគ្គលដែលមិនធ្វើ គ្រាន់តែ
និយាយ ។

បុគ្គលណាជាអ្នកប្រយ័ត្នក្នុងកាលទាំងពួង រង្កៀសក្នុងការបែកធ្លាយ ( ចំពោះមិត្ត ) សម្លឹងរំពៃរកទោសតែម្យ៉ាងអស់កាលជានិច្ច អ្នកនោះមិនឈ្មោះថាមិត្តឡើយ មួយទៀត បុគ្គលណាដែលពួកជនដទៃ បំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះ ទើបឈ្មោះថាមិត្តដោយពិត ។

កុលបុត្តអ្នកមានផលានិសង្ស កាលនាំទៅនូវធុរៈជារបស់បុរស រមែងចម្រើននូវហេតុជាគ្រឿងធ្វើនូវបាមោជ្ជៈ ជាគ្រឿងនាំមកនូវសេចក្តីសរសើរជាសុខ ។

បុគ្គលផឹកនូវរសនៃវិវេកធម៌ផងនូវរសនៃសេចក្តីស្ងប់រម្ងាប់ផង ផឹកនូវរសនៃធម្មបីតិផង ទើបជាអ្នកមិនមានកង្វល់ មិនមានបាប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហិរិន្តរន្តំ** បានដល់ ឈានកន្លងនូវការខ្មាស ។ បទថា **វិជិគុច្ឆមានំ** បានដល់ ដែលខ្ពើមក្នុងការចម្រើនមេត្តា ។ បទថា **តវាហមស្មិ** សេចក្តីថា ពោលតែពាក្យតែម្យ៉ាងប៉ុណ្ណោះថា ខ្ញុំជាមិត្តរបស់អ្នក ។ បទថា **សេយ្យានិ កម្មានិ** សេចក្តីថា ដែលមិនអើពើ គឺមិនធ្វើកម្មដ៏ឧត្តមដែលសមគួរដល់វាចាថា នឹងឲ្យ នឹងធ្វើ ។ បទថា **អានិយន្តំ** បានដល់ មិនធ្វើ ។ បទថា **នេសោ មមំ** សេចក្តីថា គប្បីដឹងច្បាស់បុគ្គលបែបនោះថា នុ៎ះមិនមែនជាមិត្តរបស់យើង ។ បទថា **ចាមោជ្ជករណំ ឋានំ** បានដល់ ទាន

សីល ភាវនា និងភាពជាមិត្តជាមួយបណ្ឌិតដែលជាកល្យាណមិត្ត ។ តែក្នុងទីនេះ លោកពោលសំដៅយកចំពោះភាពជាមិត្ត ដែលមានប្រការដូចពោលហើយ ។ មែនពិត ភាពជាមិត្តជាមួយបណ្ឌិតដែលជាកល្យាណមិត្ត រមែងនាំមកនូវបាមោជ្ជៈផង នាំមកនូវសេចក្តីសរសើរផង លោកហៅថាសេចក្តីសុខដូច្នេះក៏មាន ព្រោះជាហេតុនៃសេចក្តីសុខផ្លូវកាយនិងផ្លូវចិត្តក្នុងលោកនេះនិងលោកខាងមុខ ។ ព្រោះហេតុនោះ កុលបុត្តដែលឃើញផល និងអានិសង្សឈ្មោះថាជាអ្នកមានផលអានិសង្ស កាលនាំធុរៈរបស់បុរស ៤ យ៉ាង គឺទានសីល ភាវនា និងមិត្តភាពដែលបុរសទាំងឡាយគប្បីនាំ រមែងញ៉ាំងហេតុជាគ្រឿងធ្វើនូវបាមោជ្ជៈ ពោលគឺមិត្តភាពនេះ និងសុខដែលជាហេតុនាំសេចក្តីសរសើរឲ្យកើត គឺឲ្យចម្រើន លោកសម្តែងថា មិនទម្លាយមិត្តភាព ឲ្យបែកចាកបណ្ឌិតទាំងឡាយ ។ បទថា **បវិវេករសំ** បានដល់ រសនៃកាយវិវេក ចិត្តវិវេកនិងឧបធិវិវេក គឺរសនៃសោមនស្សដែលអាស្រ័យវិវេកទាំងនោះកើតឡើង ។ បទថា **ឧបសមស្ស ច** បានដល់ សោមនស្សដែលបានហើយព្រោះការស្ងប់រម្ងាប់កិលេស ។ បទថា **និទ្ទរោ ហោតិ និប្បាបោ** សេចក្តីថា ឈ្មោះថា ជាអ្នកមិនមានកង្វល់ ព្រោះមិនមានសេចក្តីក្រវល់ក្រវាយដោយអំណាចនៃកិលេសទាំងពួង ឈ្មោះថាជាអ្នកមិនមានបាប ព្រោះជាអ្នកមិនមានកិលេស ។ បទថា **ធម្មប្បីតិរសំ** សេចក្តីថា ផឹកនូវរស ពោលគឺធម្មបីតិ បានដល់ បីតិដែលកើតអំពីវិមុត្តិ ។

ព្រះមហាសត្វក៏យខ្លាចរង្កៀសនឹងបាបមិត្ត ទើបកាន់យកកំពូលនៃទេសនា

ដោយឲ្យដល់អមតមហានិព្វាន ដោយសេចក្តីវិវេកដោយប្រការដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា សេដ្ឋីអ្នកបច្ចន្តគាមក្នុងកាលនោះ បានមកជាសេដ្ឋីអ្នកបច្ចន្តគាមក្នុងកាលឥឡូវនេះ ពារាណសីសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ហិរិជាតក ចប់

# ខជ្ជោបនកជាតក

[ ៦៧ ] ( ទេវតាពោលថា ) នរណាហ្ន៎ កាលបើពន្លឺមាន ត្រាច់ទៅស្វែងរកភ្លើង បានឃើញនូវអំពិលអំពែកក្នុងវេលាយប់ ក៏សម្គាល់ថាភ្លើង ។

[ ៦៨ ] បុរសនោះ ក៏ប្រុបាច់ឈ្ងើនូវលម្អិតនៃអាចម៍គោនិងស្មៅដោយសេចក្តីសម្គាល់ខុស មិនអាចនឹងបង្កាត់ភ្លើងឲ្យឆេះឡើងបានទេ ។

[ ៦៩ ] បុគ្គលកាលរូតទឹកដោះមេគោអំពីស្នែង រមែងមិនបាន នូវទឹកដោះ យ៉ាងណា បុគ្គលអន្ធពាល ក៏មិនបាននូវប្រយោជន៍ដោយហេតុមិនមែនឧបាយ យ៉ាងនោះដែរ ។

[ ៧០ ] ជនទាំងឡាយតែងបាននូវប្រយោជន៍ ដោយឧបាយទាំងឡាយផ្សេងៗ គឺការផ្ចាញ់ផ្ចាល់សត្រូវទាំងឡាយផង គឺការទំនុកបម្រុងចំពោះមិត្តទាំងឡាយផង ។

[ ៧១ ] ពួកអ្នករក្សាផែនដី រមែងគ្រប់គ្រងនូវផែនដីដែលទ្រទ្រង់នូវទ្រព្យសម្បត្តិ ដោយការបំពេញបំបាន ចំពោះសេនាជាប្រធានផង ដោយការណែនាំរបស់ពួកមន្ត្រីដែលជាអ្នកស្និទ្ធស្នាលផង ។

**ចប់ ខជ្ជោបនកជាតកទី ៤**

# អដ្ឋកថា

## ខជ្ជោបនកជាតក

[ ៦៧-៧១ ] *បញ្ហាពោលអំពីអំពិលអំពែកនេះ មានពាក្យផ្តើមថា* **កោនុ សន្តម្ហិ បជ្ជោតេ** *ដូច្នេះជាដើម ។ ផ្ទៃរឿងនឹងមានដោយពិស្តារ ក្នុងមហាឧម្មង្គជាតក ( មហោសធជាតក ) នោះឯង ។*

*អដ្ឋកថា ខជ្ជោបនកជាតក ចប់*

# អហិតុណ្ឌិកជាតក

[ ៧២ ] ( អហិតុណ្ឌិកបុរសអ្នកចាប់ពស់និយាយនឹងស្វាថា ) ម្នាលសម្លាញ់មានមុខល្អ ខ្ញុំជាអ្នកលេងល្បែងចាញ់ហើយ ដោយល្បែងភ្នាល់ អ្នកចូរទម្លាក់នូវផ្លែស្វាយទុំ យើងស៊ីដោយសារសេចក្ដីព្យាយាមរបស់អ្នក ។

[ ៧៣ ] ( ស្វានិយាយថា ) ម្នាលសម្លាញ់ ពាក្យនេះពេញជាកុហក អ្នកសរសើរខ្ញុំដោយពាក្យមិនពិត ស្វាណាឈ្មោះថាមានមុខល្អ ដែលអ្នកធ្លាប់ឮ ឬធ្លាប់ឃើញ ។

[ ៧៤ ] ម្នាលអហិតុណ្ឌិកៈ អ្នក ( ធ្វើ ) នូវអំពើណាចំពោះខ្ញុំ អំពើនោះ ( មាន ) ក្នុងចិត្តអញក្នុងថ្ងៃនេះឯង អ្នកចូលទៅឯផ្សារលក់ស្រូវ ជាអ្នកស្រវឹងហើយវាយខ្ញុំដែលកំពុងស្រេកឃ្លាន ។

[ ៧៥ ] ខ្ញុំកាលនឹកឃើញហេតុនោះ ដេកជាទុក្ខ ទោះបីអ្នកឲ្យខ្ញុំសោយរាជ្យ ហើយអ្នកសុំស្វាយខ្ញុំ ខ្ញុំក៏មិនឲ្យ ព្រោះខ្ញុំត្រូវភ័យគំរាមហើយ ។

[ ៧៦ ] អ្នកប្រាជ្ញស្គាល់នូវបុគ្គលណា ដែលកើតក្នុងត្រកូល ជាអ្នកឆ្អែតស្កប់ស្កល់ក្នុងគភ៌ ជាអ្នកមិនកំណាញ់ គួរចងសម្លាញ់ ចងមិត្តនឹងបុគ្គលនោះ ។

**ចប់ អហិតុណ្ឌិកជាតកទី ៥**

## អដ្ឋកថា

## អបរិតុណ្ឌិកជាតក

[ ៧២-៧៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់មួយរូបទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ធុត្តោម្ហិ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នបានឲ្យពិស្តារហើយ ក្នុងសាលកជាតកខាងដើម ។ ក្នុងជាតកនេះ ភិក្ខុចាស់នោះបានឲ្យក្មេងអ្នកស្រុកម្នាក់បួស ហើយជេរនឹងវាយ ។ ក្មេងនោះក៏សឹករត់ទៅ ក្នុងលើកទី ២ បានឲ្យក្មេងនោះបួសហើយ ក៏បានធ្វើដូចមុន ។ ក្នុងលើកទី ២ ក្មេងនោះក៏សឹក កាលភិក្ខុចាស់នោះលួងលោមទៀត ក៏មិនប្រាថ្នាសូម្បីសម្លឹងមើល ។ ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុចាស់ឈ្មោះនោះ មិនអាចប្រព្រឹត្តទៅដើម្បីរួម ឬព្រាត់ប្រាសអំពីសាមណេររបស់ខ្លួន ចំណែកសាមណេរ ឃើញទោសរបស់ព្រះថេរៈចាស់នោះ មិនប្រាថ្នាដើម្បីនឹងមើលទៀត សាមណេរនោះជាក្មេងចិត្តល្អ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន សាមណេរនេះ ក៏ជាបុគ្គលចិត្តល្អពិត ឃើញទោសតែម្តង មិនប្រាថ្នានឹងក្រឡេកមើលទៀត ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលឈ្មួញជួញស្រូវ ចម្រើនវ័យហើយ ទើបចិញ្ចឹមជីវិតដោយការជួញស្រូវ ។ កាលនោះ មានអាលម្ពាយម្នាក់ ចាប់ស្វាមកបង្ហឹកឲ្យលេងជាគូនឹងពស់ កាលគេឃោសនាការលេងមហោស្រព ក្នុងនគរពារាណសី ទើបដឹកស្វានោះមកទុកក្នុងសម្នាក់របស់ពាណិជ ហើយទៅញុំាងពស់ឲ្យលេងអស់ ៧ ថ្ងៃ ។ ឈ្មួញនោះបានឲ្យរបស់ទំពា របស់ បរិភោគដល់ស្វាក្នុងថ្ងៃទី ៧ គ្រូពស់ឈប់លេងមហោស្រពត្រឡប់មក បានយកមែកឫស្សីវាយស្វា ៣ ដង ហើយនាំស្វានោះទៅកាន់ឧទ្យាន ចងទុកហើយក៏ដេកលក់ទៅ ។ ស្វាស្រាយចំណងចេញហើយ ឡើងទៅកាន់ដើមស្វាយ អង្គុយស៊ីផ្លែស្វាយ ។ គ្រូពស់នោះភ្ញាក់ឡើងហើយ ក្រឡេកឃើញស្វានៅលើដើមឈើគិតថា អញគួរបញ្ឆោតចាប់ស្វានេះ ទើបចរចាជាមួយស្វានោះដោយគាថាទី ១ ថា

> ម្នាលសម្លាញ់មានមុខល្អ ខ្ញុំជាអ្នកលេងល្បែងចាញ់ហើយដោយ
> ល្បែងគ្នាល់ អ្នកចូរទម្លាក់នូវផ្លែស្វាយទុំ យើងស៊ីដោយសារ
> សេចក្តីព្យាយាមរបស់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អក្ខបរាជិតោ** បានដល់ ចាញ់ព្រោះល្បែងគ្នាល់ទាំងឡាយ ។ បទថា **ហារេហិ** សេចក្តីថា ចូរឲ្យធ្លាក់ចុះមក ។ បាលីក៏យ៉ាងនោះដូចគ្នា ។ ស្វាបានស្តាប់ដូច្នោះហើយ ក៏ពោលគាថាទាំងឡាយដ៏សេសថា

ម្នាលសម្លាញ់ ពាក្យនេះពេញជាកុហក អ្នកសរសើរខ្ញុំដោយពាក្យមិនពិត ស្វាណាឈ្មោះថាមានមុខល្អ ដែលអ្នកធ្លាប់ឮ ឬធ្លាប់ឃើញ ។

ម្នាលអហិតុណ្ឌិកៈ អ្នក ( ធ្វើ ) នូវអំពើណាចំពោះខ្ញុំ អំពើនោះ ( មាន ) ក្នុងចិត្តអញក្នុងថ្ងៃនេះឯង អ្នកចូលទៅឯផ្សារលក់ស្រូវ ជាអ្នកស្រវឹងហើយវាយខ្ញុំដែលកំពុងស្រេកឃ្លាន ។

ខ្ញុំកាលនឹកឃើញហេតុនោះ ដេកជាទុក្ខ ទោះបីអ្នកឲ្យខ្ញុំសោយរាជ្យ ហើយអ្នកសុំស្វាយខ្ញុំ ខ្ញុំក៏មិនឲ្យ ព្រោះខ្ញុំត្រូវភ័យគំរាមហើយ ។

អ្នកប្រាជ្ញស្គាល់នូវបុគ្គលណាដែលកើតក្នុងត្រកូល ជាអ្នកឆ្អែតស្កប់ស្កល់ក្នុងគភ៌ ជាអ្នកមិនកំណាញ់ គួរចងសម្លាញ់ ចងមិត្តនឹងបុគ្គលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលិកំ វត** បានដល់ កុហកហ្ន៎ ។ បទថា **អភូតេន** បានដល់ មិនមាន ។ បទថា **កោ តេ** កែជា **កោ តយា** ។ បទថា **សុមុខោ** បានដល់ ដែលមានមុខល្អ ។ ស្វាហៅអាលម្ពាយនោះថា **អហិតុណ្ឌិក** ។ បាលីថា **អហិកោណ្ឌិក** ដូច្នេះក៏មាន ។ បទថា **ជាតំ** បានដល់ត្រូវសេចក្តីឃ្លានគ្របសង្កត់ គឺទុព្វល កំព្រា ។ បទថា **ហាឆាសិ** បានដល់វាយដោយមែកឫស្សី ៣ រំពាត់ ។ បទថា **តាហំ** កាត់បទថា **តំ អហំ** ។ បទថា **សរំ** ប្រែថា រឭកដល់ ។ បទថា **ទុក្ខសេយ្យំ** បានដល់ ដេកជាទុក្ខ

ត្រង់ផ្កាវនោះ ។ បទថា **អបិ រជ្ជម្បិ ការយេ** សេចក្តីថា បើលោកយកនូវរាជសម្បត្តិក្នុងនគរពារាណសីឲ្យខ្ញុំ ហើយឲ្យខ្ញុំសោយរាជសម្បត្តិសោត ទោះជាយ៉ាងនោះ ខ្ញុំកាលអ្នកអង្វរសូម ក៏មិនឲ្យស្វាយនោះ គឺខ្ញុំត្រូវអ្នកសូមក៏មិនឲ្យស្វាយទុំនោះ សូម្បីតែមួយផ្លែ ព្រោះហេតុអ្វី ព្រោះត្រូវលោកគំរាមឲ្យភ័យខ្លាចហើយ អធិប្បាយថា ពិតយ៉ាងនោះ ខ្ញុំត្រូវលោកគំរាមដោយការខ្លាច ។ បទថា **គព្ភេ តិត្តំ** សេចក្តីថា ដែលឆ្អែត ដោយភោជនដែលមានរសល្អក្នុងផ្ទៃមាតា ឬក្នុងបន្ទប់ដេកដែលប្រដាប់តាក់តែងហើយ ឈ្មោះថាមិនក្រព្រោះសន្សំមបាននូវភោគទ្រព្យ ។ បទថា **សខិត្វា មិត្តតា** សេចក្តីថា បណ្ឌិតគួរភ្ជាប់ គឺភ្ជាប់ចំពោះភាពជាសម្លាញ់និងភាពជាមិត្តជាមួយបុគ្គលបែបនេះដែលកើតក្នុងត្រកូលអ្នកឆ្អែត មិនក្រីក្រ មិនមានសេចក្តីកំណាញ់ បុគ្គលណានឹងភ្ជាប់តនូវភាពជាមិត្តជាមួយលោកដែលជាគ្រូពស់ក្រីក្រ ។ កាលពានរពោលយ៉ាងនេះហើយ ក៏រវៀសរវៃចូលទៅកាន់ព្រៃបាត់ទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា អាយលម្ពាយក្នុងកាលនោះ បានមកជាព្រះថេរៈចាស់ក្នុងកាលឥឡូវនេះ ស្វាក្នុងកាលនោះ បានមកជាសាមណេរ ចំណែកឈ្មួញអ្នកជួញស្រូវក្នុងកាលនោះ គឺតថាគតនេះឯង ។

### អដ្ឋកថា អហិតុណ្ឌិកជាតក ចប់

# គុម្ពិយជាតក

[ ៧៧ ] ( ព្រះសម្ពុទ្ធទ្រង់ពោលថា ) ថ្នាំពិសមានពណ៌ល្អ មានរសឆ្ងាញ់ មានក្លិនក្រអូប យក្ខឈ្មោះគុម្ពិយៈ ស្វែងរកអាហារបានដាក់ថ្នាំពិស ( ទុកនៅ ) ក្នុងព្រៃ ។

[ ៧៨ ] ជនទាំងឡាយណា សម្គាល់ថ្នាំពិសថាជាវត្ថុផ្អែម ក៏លិទ្ធភក្ស នូវថ្នាំពិសនោះ ជនទាំងឡាយនោះ ក៏ពុលដល់នូវសេចក្តីស្លាប់ ដោយថ្នាំពិសនោះ ។

[ ៧៩ ] ជនទាំងឡាយណា ពិចារណាឃើញច្បាស់ថាជាថ្នាំពិសហើយវៀរចេញ ជនទាំងឡាយនោះដល់នូវសេចក្តីសុខក្នុងពួកជនកំពុងក្តៅក្រហាយ ជាអ្នកត្រជាក់ចិត្តក្នុងពួកជនកំពុងក្តៅរោលរាល ។

[ ៨០ ] ថ្នាំពិសតែងប្រជុំចុះទៀបផ្លូវធំ យ៉ាងណាមិញ កាមទាំងឡាយដូចជាពិស តែងប្រជុំចុះក្នុងពួកមនុស្ស ក៏យ៉ាងនោះដែរ កាមគុណនេះជានុយជាចំណង ជាអំណាចនៃមច្ចុ ជាគុហា ជាទីអាស្រ័យនៅនៃមច្ចុ ។

[ ៨១ ] ជនទាំងឡាយជាអ្នកក្តៅក្រហាយ លះវៀរនូវកាមទាំងនេះដែលជាគ្រឿងប្រើប្រាស់ អស់កាលទាំងពួង ជនទាំងឡាយនោះ ក៏រមែងកន្លងនូវកិលេសជាគ្រឿងជាប់ក្នុងលោកបាន ។

**ចប់ គុម្ពិយជាតកទី ៦ ។**

# អដ្ឋកថា

# គុម្ពិយជាតក

[ ៧៧-៨១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុក ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មធុវណ្ណំ មធុរសំ** ដូច្នេះជាដើម ។

បានឮថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គពិតមែន ទើបត្រាស់សួរថា ព្រោះឃើញអ្វី កាលភិក្ខុនោះក្រាបទូលថា ព្រោះឃើញមាតុគ្រាមដែលប្រដាប់តាក់តែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុ ឈ្មោះថា បញ្ចកាមគុណនោះ ប្រៀបដូចដុំទឹកឃ្មុំដែលយក្សឈ្មោះគុម្ពិយៈមួយរូប ដាក់ទឹកឃ្មុំទុកត្រង់ផ្លូវ កាលភិក្ខុនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសត្ថវាហៈ ( ឈ្មួញរទេះ ) ។ លុះចម្រើនវ័យហើយ ទើបយករទេះ ៥០០ ផ្ទុកទំនិញ ចេញអំពីក្រុងពារាណសី ទៅដើម្បីលក់ដូរ លុះដល់មាត់ព្រៃឈ្មោះ មហាវត្តនិ ទើបឲ្យពួករទេះប្រជុំគ្នាហើយឲ្យឱវាទថា អ្នកដ៏ចម្រើនទាំងឡាយ ក្នុងផ្លូវនេះមានស្លឹកឈើ ផ្កានិងផ្លែឈើជាដើមដែលមានជាតិពុល អ្នកទាំងឡាយ កាលនឹងស៊ីអ្វីមួយដែលមិនធ្លាប់ស៊ី បើមិនទាន់បានសួរខ្ញុំ កុំបរិភោគ សូម្បីពួកអមនុស្សអាចដាក់ថ្នាំពិសដាក់កញ្ចប់កត្ត ដុំទឹកឃ្មុំ និងផ្លែឈើទាំងឡាយទុកក្នុងផ្លូវ ពួកអ្នកបើមិនទាន់

បានសួរខ្ញុំ កុំបរិភោគកត្តជាដើមនោះ ដូច្នេះហើយ ក៏ធ្វើដំណើរទៅ ។ កាល នោះ យក្សមួយឈ្មោះថាគុម្ពិយៈ លាតស្លឹកឈើដាក់ជុំទឹកឃ្មុំ ផ្សំថ្នាំពិសដ៏ខ្លាំង ពន្លឹកទុកក្នុងរវាងផ្លូវត្រង់កណ្តាលព្រៃ ចំណែកខ្លួនឯងដើរគោះដើមឈើក្នុងទី ជិតធ្វើហាក់បីដូចជាអ្នករកឃ្មុំ ។ ពួកមនុស្សដែលមិនដឹងគិតថា គេគង់ទុក ដើម្បីត្រូវការបុណ្យ ទើបបរិភោគចូលទៅ ហើយក៏ដល់នូវការអស់ជីវិត ។ ពួក អមនុស្សក៏នាំគ្នាស៊ីមនុស្សទាំងនោះ សូម្បីអ្នករទេះរបស់ព្រះពោធិសត្វឃើញ របស់ទាំងនោះ អ្នកខ្លះមានសន្តានចិត្តល្មោភ មិនអាចអត់ធន់បានក៏លេបចូល ទៅ ។ ពួកជនដែលមានជាតិជាអ្នកឈ្លាសវៃ គិតថា នឹងសួរព្រះពោធិសត្វ ជាមុនសឹមបរិភោគ ទើបកាន់យកទៅហើយឈរ ។ ព្រះពោធិសត្វឃើញ ជនទាំងនោះហើយ ទើបឲ្យចោលរបស់ដែលមានក្នុងដៃ ជនណាស៊ីចូលទៅ ហើយ ជននោះក៏ស្លាប់ទៅ ជនណាស៊ីបានបន្តិច ព្រះពោធិសត្វឲ្យថ្នាំក្អួតចេញ មកដល់បុគ្គលទាំងនោះ ហើយឲ្យបរិភោគមធុរស ៤ យ៉ាង ក្នុងពេលដែល ក្អួតចេញហើយ ដូច្នោះ ជនទាំងនោះ ក៏បានរួចផុតជីវិតដោយអានុភាពរបស់ ព្រះពោធិសត្វនោះ ។ ព្រះពោធិសត្វ ទៅដល់ទីប្រាថ្នាដោយសួស្តី ហើយ ចំណាយទ្រព្យបានចំណេញ ត្រឡប់មកកាន់ផ្ទះរបស់ខ្លួនវិញ ។

ព្រះសាស្តាកាលត្រាស់អត្ថនោះ ទើបត្រាស់អភិសម្ពុទ្ធគាថា គឺគាថាដែល ត្រាស់ក្នុងពេលដែលត្រាស់ដឹងហើយថា

ថ្នាំពិសមានពណ៌ល្អ មានរសឆ្ងាញ់ មានក្លិនក្រអូប យក្ខ
ឈ្មោះគុម្ពិយៈ ស្វែងរកអាហារ បានដាក់ថ្នាំពិស ( ទុកនៅ )

ក្នុងព្រៃ ។

ជនទាំងឡាយណា សម្គាល់ថ្នាំពិសថាជាវត្ថុផ្អែម ក៏លិទ្ធ ភក្សនូវថ្នាំពិសនោះ ជនទាំងឡាយនោះ ក៏ពុលដល់នូវសេចក្តីស្លាប់ដោយថ្នាំពិសនោះ ។

ជនទាំងឡាយណា ពិចារណាឃើញច្បាស់ ថាជាថ្នាំពិសហើយ វៀរចេញ ជនទាំងឡាយនោះ ដល់នូវសេចក្តីសុខក្នុងពួកជនកំពុងក្តៅក្រហាយ ជាអ្នកត្រជាក់ចិត្ត ក្នុងពួកជនកំពុងក្តៅរោលរាល ។

ថ្នាំពិសតែងប្រជុំចុះទៀបផ្លូវធំ យ៉ាងណាមិញ កាមទាំងឡាយ ដូចជាពិសតែងប្រជុំចុះក្នុងពួកមនុស្ស ក៏យ៉ាងនោះដែរ កាមគុណនេះ ជានុយ ជាចំណង ជាអំណាចនៃមច្ចុ ជាគុហា ជាទីអាស្រ័យនៅនៃមច្ចុ ។

ជនទាំងឡាយជាអ្នកក្តៅក្រហាយ លះវៀរនូវកាមទាំងនេះ ដែលជាគ្រឿងប្រើប្រាស់ អស់កាលទាំងពួង ជនទាំងឡាយនោះ ក៏រមែងកន្លងនូវកិលេស ជាគ្រឿងជាប់ក្នុងលោកបានដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គុម្ពិយោ** បានដល់ យក្សមានឈ្មោះយ៉ាងនោះ ព្រោះត្រាច់ទៅក្នុងគុម្ពឈើក្នុងព្រៃនោះ ។ បទថា **ឃាសមេសានោ** បានដល់ អ្នកស្វែងរកចំណីរបស់ខ្លួនយ៉ាងនេះថា យើងនឹងស៊ីមនុស្សដែល

បរិភោគថ្នាំពិសនេះស្លាប់ ។ បទថា **ឱទហី** សេចក្តីថា ដាក់ថ្នាំពិសនោះដែលមានពណ៌ ក្លិន និងរសដូចទឹកឃ្មុំ ។ បទថា **កដុកំ អាសិ** សេចក្តីថា ជាថ្នាំពិសដ៏ពន្លឹក ។ បទថា **មរណំ តេនុបាគមុំ** សេចក្តីថា សត្វទាំងនោះ ចូលដល់សេចក្តីស្លាប់ ព្រោះថ្នាំពិសនោះ ។ បទថា **អាតុរេសុ** បានដល់ បុគ្គលជិតនឹងស្លាប់ ព្រោះកម្លាំងថ្នាំពិស ។ បទថា **ឧយ្យមានេសុ** បានដល់ ដែលគេជះ របស់ថ្នាំពិសនោះឯងដុតរោល ។ បទថា **វិសកាមា សមោហិតា** សេចក្តីថា ក្នុងជំពូកមនុស្ស វត្ថុកាម ៥ មានរូបជាដើមនោះឯង កប់ គឺដាក់នៅក្នុងទីនោះៗ វត្ថុកាម ៥ នោះ គប្បីជ្រាបថាជាថ្នាំពិស ដូចថ្នាំពិសដែលយក្សបង្កប់ គឺទុកក្នុងផ្លូវធំក្នុងព្រៃឈ្មោះវត្តនិដ្ឋូរេច្ចោះ ។ បទថា **អាមិសំ ពន្ធនញ្ចេតំ** សេចក្តីថា ធម្មតាកាមគុណ ៥ នេះ ឈ្មោះថាជាចំណីដែលនាយព្រានសន្ទូច គឺមារដាក់បញ្ឆោតសត្វលោក ដែលជាសត្វត្រូវស្លាប់ជាធម្មតានេះ និងឈ្មោះថាជាគ្រឿងចង មានប្រការផ្សេងៗ មានខ្នោះជាដើម ព្រោះមិនព្រមឲ្យចេញទៅអំពីភពតូចនិងភពធំដោយប្រការយ៉ាងនេះ ។ បទថា **មច្ចុ–វសោ គុហាសយោ** សេចក្តីថា ការស្លាប់ឈ្មោះថា មច្ចុវសៈ ព្រោះមានគុហា គឺរាងកាយជាលំនៅ ។ បទថា **ឯវមេវ ឥមេ កាមេ** បានដល់ កាមទាំងនេះដែលកប់នៅក្នុងរាងកាយនោះ ៗ ដូចថ្នាំពិសដែលយក្សដាក់ក្នុងផ្លូវធំក្នុងព្រៃឈ្មោះវត្តនិដ្ឋូរេច្ចោះ ។ បទថា **អាតុរា** សេចក្តីថា បុរសដែលជាបណ្ឌិតជិតនឹងស្លាប់ ដែលក្តៅក្រហាយ រសាប់រសល់ ព្រោះធម្មតាសត្វទាំងឡាយតែងមានការស្លាប់ដោយចំណែកមួយ ។ បទថា **បរិចារិកេ** បានដល់ បម្រើ

កិលេស គឺត្រូវកិលេសចងទុក ។ បទថា **យេ សទា បរិវជ្ជន្តិ** សេចក្តីថា បុរសដែលជាបណ្ឌិតពួកណាដែលមានប្រការដូចពោលហើយ វៀរនូវកាមទាំងឡាយបែបនោះបានជានិច្ច ។ បទថា **សង្គំ លោកេ** បានដល់ កិលេសជាតិប្រភេទរាគៈជាដើម ដែលបានឈ្មោះថា **សង្គំ** ព្រោះអត្ថថា ជាគ្រឿងជាប់ចំពាក់ក្នុងលោក ។ បទថា **ឧបច្ចគុំ** សេចក្តីថា បណ្ឌិតទាំងនោះគប្បីជ្រាបថា ឈ្មោះថា ជាអ្នកកន្លងទៅបានហើយ ម្យ៉ាងទៀត អធិប្បាយថា រមែងឈានកន្លងទៅ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ឈ្មួញរទេះក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គុម្ពិយជាតក ចប់

# សាលិយជាតក

[ ៨២ ] ( ពោធិសត្វពោលថា ) បុរសណាឲ្យគេចាប់នូវពស់វែក ដោយបញ្ឆោតថាកូនសាលិកា បុរសអ្នកបង្រៀនប្រដៅអាក្រក់នេះ ត្រូវពស់នោះចឹកស្លាប់ហើយ ។

[ ៨៣ ] ជនណាប្រាថ្នាដើម្បីសម្លាប់នូវបុគ្គល ប៉ុន្តែមិនបានប្រហារ មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ ។

[ ៨៤ ] ជនណាប្រាថ្នាដើម្បីសម្លាប់នូវបុគ្គលអ្នកមិនបានបៀតបៀន មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ ។

[ ៨៥ ] បុរសអ្នកក្ដាប់នូវអាចម៍ដី បាចទៅកាន់ទីច្រាសខ្យល់ ធូលីនោះរមែងវិលមកប៉ះបុរសនោះវិញ ដូចជាបុរសដែលស្លាប់នេះ ។

[ ៨៦ ] បុគ្គលពាលណាប្រទូស្តចំពោះជនដែលមិនបានប្រទូស្តតបវិញ ជាបុគ្គលបរិសុទ្ធ មិនមានទីទួលគឺកិលេស បាបរមែងវិលត្រឡប់មករកបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិតដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។

**ចប់ សាលិយជាតកទី ៧ ៗ**

# អដ្ឋកថា
# សាលិយជាតក

[ ៨២-៨៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធពាក្យថា អាវុសោទាំងឡាយ ទេវទត្តមិនអាចធ្វើនូវការតក់ស្លុត ឲ្យដល់ព្រះសម្ពុទ្ធបានឡើយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យ្វាយំ សាលិយច្ឆាតោ** ដូច្នេះជាដើម ។

មែនពិត ក្នុងកាលនោះព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តនេះ ក៏មិនអាចធ្វើនូវការតក់ស្លុតឲ្យដល់តថាគតបាន ទើបទ្រង់នាំយកអតីតនិទាន មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលកុដុម្ពិក: ក្នុងស្រុកមួយ ក្នុងកាលមានអាយុតិចលេងត្រង់គល់ជ្រៃ ក្បែរទ្វារស្រុកជាមួយពួកក្មេងៗដែលលេងធូលីដូចគ្នា ។ កាលនោះ មានគ្រូពស់ទុព្វលម្នាក់ មិនបានការងារណាមួយក្នុងស្រុក ទើបចេញទៅដល់ទីនោះ ឃើញពស់មួយដេកលក់ អើតក្បាលចេញមករវាងប្រគាបឈើ គិតថា អញមិនបានអ្វីក្នុងស្រុក អញនឹងបញ្ឆោតក្មេងទាំងនេះឲ្យពស់ចឹក ហើយព្យាបាល គង់នឹងបានរបស់ឯណានីមួយ ទើបពោលនឹងព្រះពោធិសត្វថា បើពួកឯងឃើញកូនសាលិកា តើចាប់ដែរឬទេ ព្រះពោធិសត្វពោលថា ខ្ញុំនឹងចាប់ ។ គ្រូពស់ពោលថា ចូរមើល នុ៎ះកូនសាលិកា វាដេកក្នុងរវាងប្រគាបឈើ ។ ព្រះពោធិសត្វនោះ មិនដឹងថា នុ៎ះជាពស់ ទើប

ឡើងដើមឈើ ចាប់ត្រង់កពស់ លុះដឹងថាជាពស់ មិនឲ្យវាលិបចូល ចាប់ទុកយ៉ាងណែន ហើយប្រញាប់បោះទៅ ។ ពស់នោះសោត់ទៅធ្លាក់ចុះត្រង់កអាលម្ពាយ រុំត្រង់កខាំលាន់ឮសូរក្រុប ធ្វើឲ្យគ្រូពស់នោះដួលចុះក្នុងទីនោះហើយ ក៏លូនគេចទៅ ។ មនុស្សទាំងឡាយនាំគ្នាបោមរោម ។ ព្រះមហាសត្វកាលសម្តែងធម៌ដល់បរិស័ទដែលប្រជុំព្រមគ្នា ទើបពោលគាថាទាំងនេះថា

បុរសណា ឲ្យគេចាប់នូវពស់វែក ដោយបញ្ឆោតថាកូនសាលិកា បុរសអ្នកប្រៀនប្រដៅអាក្រក់នេះ ត្រូវពស់នោះចឹកស្លាប់ហើយ ។

ជនណាប្រាថ្នាដើម្បីសម្លាប់នូវបុគ្គល ប៉ុន្តែមិនបានប្រហារ មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ ។

ជនណា ប្រាថ្នាដើម្បីសម្លាប់នូវបុគ្គលអ្នកមិនបានបៀតបៀន មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ ។

បុរសអ្នកក្តាប់នូវអាចម៍ដី បាចទៅកាន់ទីច្រាសខ្យល់ ធូលីនោះរមែងវិលមក ប៉ះបុរសនោះវិញ ដូចជាបុរសដែលស្លាប់នេះ ។

បុគ្គលពាលណាប្រទូស្តចំពោះជនដែលមិនបានប្រទូស្តតប

វិញ ជាបុគ្គលបរិសុទ្ធ មិនមានទីទួលគឺកិលេស បាបរមែង
វិលត្រឡប់មករកបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិតដែល
បុគ្គលបាចទៅកាន់ទីប្រាសខ្យល់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យ្វាយំ** កាត់បទជា **យោ អយំ** ។ម្យ៉ាង ទៀត បាលីក៏យ៉ាងនោះដូចគ្នា ។ បទថា **សបេ្បនយំ** សេចក្ដីថា បុគ្គលនេះ ត្រូវពស់នោះចឹកហើយ ។ បទថា **ចាចានុសាសកោ** បានដល់ អ្នកប្រៀន ប្រដៅវត្ថុដែលអាក្រក់ ។ បទថា **អហាន្តារំ** បានដល់ ដែលមិនសម្លាប់ឯង ។ បទថា **អហាន្តារំ** បានដល់ មិនបានឲ្យអ្នកដទៃសម្លាប់ ។ បទថា **សេតិ** បាន ដល់ រមែងដេកស្លាប់ ។ បទថា **អឃាតេន្តំ** ប្រែថា មិនប្រើឲ្យអ្នកដទៃ សម្លាប់ ។ បទថា **សុទ្ធស្ស** បានដល់ ដែលមិនមានកំហុស ។ បទថា **ចោសស្ស** បានដល់ របស់សត្វ ។ សូម្បីពាក្យនេះថា **អនង្គណស្ស** លោក ពោលសំដៅយកការមិនមានកំហុសដូចគ្នា ។ បទថា **បច្ចេតិ** សេចក្ដីថា រមែងត្រឡប់ដល់ ជាវត្ថុដែលឃើញសមគ្នានឹងកម្ម ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើប ទ្រង់ប្រជុំជាតកថា គ្រូពស់ទុច្ចលក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាល ឥឡូវនេះ ចំណែកកុមារដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សាលិយជាតក ចប់

# តចសារជាតក

[ ៨៧ ] ( ស្តេចព្រហ្មទត្តសួរថា ) អ្នកទាំងឡាយនៅក្នុងកណ្តាប់ដៃសត្រូវ ជាប់ដោយឃ្នងឫស្សី តែនៅមានមុខស្រស់បស់ ព្រោះហេតុអ្វីទើបអ្នកទាំងឡាយមិនសោយសោក ។

[ ៨៨ ] ( ពោធិសត្វទូលតបថា ) សេចក្តីចម្រើនសូម្បីមានប្រមាណតិច ក៏គេមិនដែលបាន ព្រោះសេចក្តីសោកខ្សឹកខ្សួលទេ ជនជាសត្រូវទាំងឡាយដឹងច្បាស់នូវបុរសនេះដែលកំពុងសោកដល់នូវទុក្ខហើយ រមែងជាអ្នកមានចិត្តត្រេកអរ ។

[ ៨៩ ] កាលណាបណ្ឌិតអ្នកឈ្លាសក្នុងការវិនិច្ឆ័យនូវប្រយោជន៍ មិនញាប់ញ័រក្នុងអន្តរាយទាំងឡាយ កាលនោះ បុគ្គលជាសត្រូវជាទុក្ខ ព្រោះឃើញនូវមុខរបស់បណ្ឌិតនោះ មិនប្រែប្រួលនៅដូចអំពីដើម ។

[ ៩០ ] បុគ្គលបាននូវប្រយោជន៍ ព្រោះការរាយមន្តក្តី ការប្រឹក្សាក្តី ពោលពាក្យពីរោះក្តី ការឲ្យសំណូកក្តី ប្រវេណីក្តី ក្នុងទីណា យ៉ាងណាៗ ត្រូវប្រឹងប្រែងក្នុងទីនោះ យ៉ាងនោះៗ ។

[ ៩១ ] កាលណាបុគ្គលដឹងថាប្រយោជន៍នុ៎ះ ទោះបីអញ ឬបុគ្គលដទៃមិនគប្បីបាន បណ្ឌិតមិនសោកស្តាយ ត្រូវអត់ធន់ ដោយគិតថា កម្មមានកម្លាំងមាំ ឥឡូវនេះ អាត្មាអញនឹងធ្វើដូចម្តេច ។

**ចប់ តចសារជាតកទី ៨ ។**

# អដ្ឋកថា

## តចសារជាតក

[ ៨៧-៩១ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមីទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អមិត្តហត្ថត្ត-គតា** ដូច្នេះជាដើម ។

មែនពិត ក្នុងកាលនោះព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញា ជាអ្នកឈ្លាសក្នុងឧបាយដូចគ្នា កាលភិក្ខុទាំងនោះទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទាន មកសាធកៈដូចតទៅនេះថា

រឿងក្នុងអតីតៈទាំងពួងមានពាក្យផ្ដើមថា ក្នុងអតីតកាល ព្រះបាទព្រហ្ម-ទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលកុ-ដុម្ពិកៈក្នុងស្រុកមួយ ដូច្នេះ គប្បីពោលតាមទំនងជាតកមុននោះឯង ។ ក្នុងជាតកនេះ កាលអាលម្ដាយស្លាប់ហើយ អ្នកស្រុកពោលថា កុមារទាំងនោះជាអ្នកសម្លាប់មនុស្ស ទើបចងកុមារនោះដោយឃ្នាងឫស្សី ហើយនាំទៅកាន់នគរពារាណសី ដោយបំណងថានឹងថ្វាយព្រះរាជាទត ក្នុងរវាងផ្លូវនោះឯងព្រះពោធិសត្វបានឲ្យឱវាទដល់ពួកកុមារដ៏សេសថា អ្នកទាំងឡាយកុំខ្លាច អ្នកទាំងឡាយគាល់ព្រះរាជាហើយក៏កុំខ្លាច គប្បីជាអ្នកមានឥន្ទ្រិយក្សៀវក្លា ព្រះរាជានឹងត្រាស់ជាមួយពួកយើងមុន ចាប់តាំងអំពីនោះយើងនឹងដឹង ។ ពួកក្មេងទាំងនោះទទួលពាក្យថា សាធុ ហើយទើបធ្វើយ៉ាងនោះ ។ ព្រះរាជាទ្រង់ឃើញក្មេងទាំងនោះមិនខ្លាច មានឥន្ទ្រិយក្សៀវក្លា ទ្រង់ព្រះតម្រិះថា កុមារ

ទាំងនេះ ត្រូវចោទថាជាអ្នកសម្លាប់មនុស្ស ត្រូវចងដោយឃ្នាងឫស្សីនាំមក ទោះបីដល់នូវសេចក្តីទុក្ខបែបនេះ ក៏មិនខ្វាច មានឥន្ទ្រិយក្លៀវក្លានោះឯង អ្វី ហ្ន៎ជាហេតុមិនសោយសោក របស់កុមារពួកនេះ អញនឹងសួរពួកគេលមើល កាលនឹងសួរ ទើបត្រាស់គាថាទី ១ ថា

អ្នកទាំងឡាយនៅក្នុងកណ្តាប់ដៃសត្រូវ ជាប់ដោយឃ្នាងឫស្សី
តែនៅមានមុខស្រស់បស់ ព្រោះហេតុអ្វីទើបអ្នកទាំងឡាយមិន
សោយសោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អមិត្តហត្ថត្តគតា** សេចក្តីថា នៅក្នុង កណ្តាប់ដៃរបស់ពួកអមិត្ត ដែលយកឃ្នាងជាក់ត្រង់កហើយនាំមក ។ បទថា **តចសារសមប្បិតា** សេចក្តីថា ព្រះរាជាត្រាស់យ៉ាងនេះ ព្រោះក្មេងទាំង នោះត្រូវចងដោយឃ្នាងឫស្សី ។ បទថា **កស្មា** សេចក្តីថា ព្រះរាជាត្រាស់ សួរថា ពួកអ្នកបានទទួលសេចក្តីវិនាសបែបនេះ ហេតុអ្វី ទើបមិនសោយ សោក ។ ព្រះពោធិសត្វបានស្តាប់ពាក្យនោះ ទើបពោលគាថាដ៏សេសថា

សេចក្តីចម្រើន សូម្បីមានប្រមាណតិច ក៏គេមិនដែលបាន
ព្រោះសេចក្តីសោកខ្សឹកខ្សួលទេ ជនជាសត្រូវទាំងឡាយ ដឹង
ច្បាស់នូវបុរសនេះដែលកំពុងសោក ដល់នូវទុក្ខហើយ រមែង
ជាអ្នកមានចិត្តត្រេកអរ ។

កាលណា បណ្ឌិតអ្នកឈ្លាស ក្នុងការវិនិច្ឆ័យនូវប្រយោជន៍
មិនញាប់ញ័រ ក្នុងអន្តរាយទាំងឡាយ កាលនោះ បុគ្គលជា

សត្រូវជាទុក្ខ ព្រោះឃើញនូវមុខរបស់បណ្ឌិតនោះ មិនប្រែប្រួល នៅដូចអំពីដើម ។

បុគ្គលបាននូវប្រយោជន៍ ព្រោះការរាយមន្តក្តី ការប្រឹក្សាក្តី ពោលពាក្យពីរោះក្តី ការឲ្យសំណូកក្តី ប្រវេណីក្តី ក្នុងទីណាយ៉ាងណាៗ ត្រូវប្រឹងប្រែងក្នុងទីនោះ យ៉ាងនោះៗ ។

កាលណា បុគ្គលដឹងថា ប្រយោជន៍នុ៎ះទោះបីអញ ឬបុគ្គលដទៃមិនគប្បីបាន បណ្ឌិតមិនសោកស្តាយ ត្រូវអត់ធន់ ដោយគិតថា កម្មមានកម្លាំងមាំ ឥឡូវនេះ អាត្មាអញនឹងធ្វើដូចម្តេចដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថោ** បានដល់ សេចក្តីចម្រើន ។ ដោយបទថា **បច្ចត្ថិកា អត្តមនា** នេះ លោកសម្តែងថា ពួកបច្ចាមិត្តដឹងថាបុរសនោះសោយសោក មានទុក្ខ រមែងត្រេកអរ បណ្ឌិតមិនគួរធ្វើនូវហេតុនៃសេចក្តីត្រេកអររបស់ពួកបច្ចាមិត្តនោះ ។ បទថា **យតោ** បានដល់ ក្នុងកាលណា ។ បទថា **ន វេធតិ** សេចក្តីថា រមែងមិនញាប់ញ័រព្រោះការខ្លាចដែលកើតអំពីការតក់ស្លុតនៃចិត្ត ។ បទថា **អត្ថវិនិច្ឆយញ្ញូ** បានដល់ បុគ្គលដែលឈ្លាសវិនិច្ឆ័យអត្ថក្តីនោះៗ ។ បទថា **ជប្បេន** បានដល់ ដោយការរាយមន្ត ។ បទថា **មន្តេន** បានដល់ ដោយការកាន់យកនូវការប្រឹក្សាជាមួយបណ្ឌិតទាំងឡាយ ។ បទថា **សុភាសិតេន** បានដល់ ដោយពាក្យជាទីស្រឡាញ់ ។ បទថា **អនុប្បទានេន** បានដល់ ដោយការឲ្យសំណូក ។ បទថា **បវេណិយា**

បានដល់ ដោយវង្សត្រកូល ។ លោកពោលពាក្យអធិប្បាយនេះទុកថា បពិត្រមហារាជ ធម្មតាបណ្ឌិត កាលអន្តរាយកើតឡើង មិនគួរសោយសោក មិនគួរលំបាកចិត្ត បុគ្គលគប្បីឈ្នះពួកបច្ចាមិត្តបានដោយអំណាចហេតុឯណានីមួយក្នុងហេតុ ៥ ប្រការនេះ ពិតណាស់ បើអាចធ្វើបានសោត គប្បីវាយមន្តចងមាត់ទុកមិនឲ្យនិយាយ ក៏នឹងឈ្នះពួកបច្ចាមិត្តនោះបាន ១ បើមិនអាចធ្វើយ៉ាងនេះ ត្រូវប្រឹក្សាជាមួយពួកបណ្ឌិតរិះរកឧបាយមួយគប្បីឈ្នះបច្ចាមិត្តបាន ១ បើអាចនិយាយពីរោះ ត្រូវនិយាយពាក្យពីរោះនោះ ក៏គប្បីឈ្នះបច្ចាមិត្តបាន ១ កាលមិនអាចធ្វើយ៉ាងនោះ គប្បីឲ្យសំណូកដល់ពួកអាមាត្យអ្នកកាត់ក្តី ក៏គប្បីឈ្នះបាន ១ កាលមិនអាចធ្វើយ៉ាងនោះ គប្បីពោលដល់វង្សត្រកូលនិងលំដាប់ញាតិដែលមានយ៉ាងនេះថា ពួកខ្ញុំមកអំពីវង្សឈ្មោះនោះ និងបុព្វបុរសរបស់ពួកខ្ញុំក៏តែមួយ ក៏គប្បីឈ្នះបានដូចគ្នា ១ ។ បទថា **យថា យថា** សេចក្តីថា បុគ្គលគប្បីបាននូវសេចក្តីចម្រើននៃខ្លួន ក្នុងទីណា ដោយហេតុឯណានីមួយ បណ្តាហេតុ ៥ ប្រការនេះ ។ បទថា **តថា តថា** សេចក្តីថា គប្បីព្យាយាមក្នុងទីនោះ ៗ ដោយហេតុនោះ ៗ ។ អធិប្បាយថា គប្បីធ្វើសេចក្តីព្យាយាមរហូតឈ្នះសត្រូវ ។ បទថា **យតោ ច ជានេយ្យ** សេចក្តីថា ក្នុងកាលណា បណ្ឌិតគប្បីដឹងថា ប្រយោជន៍នេះដែលយើងឬអ្នកដទៃមិនគួរបានសូម្បីព្យាយាមដោយប្រការផ្សេងៗក៏មិនអាចបាន ក្នុងកាលនោះ បុរសដែលជាបណ្ឌិតក៏មិនទោមនស្ស មិនលំបាកចិត្ត គប្បីអត់សង្កត់ដោយគិតថា កម្មដែលអញធ្វើទុកក្នុងកាលមុន មានកម្លាំង មិនអាចហាមបាន ឥឡូវនេះ អញ

អាចធ្វើអ្វីបាន ។

ព្រះរាជា បានស្តាប់ធម្មកថារបស់ព្រះពោធិសត្វហើយ ទ្រង់ដោះនូវការធ្វើដោយព្រះអង្គឯង ទ្រង់ជ្រាបថាពួកក្មេងមិនមានទោសកំហុស ទើបត្រាស់ឲ្យនាំឃ្នាងចេញ ហើយទ្រង់ព្រះរាជទានយសធំក្រៃលែងដល់មហាសត្វ ហើយទ្រង់បានឲ្យធ្វើជាអាមាត្យរតន៍ ជាអ្នកបង្រៀនអត្ថ និងធម៌ដល់ទ្រង់ សូម្បីទារកដ៏សេស ក៏ត្រូវប្រទានយសនិងឋានន្តរៈ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះបាទពារាណសីក្នុងកាលនោះ បានមកជាអានន្ទ ក្នុងកាលឥឡូវនេះ ពួកក្មេងៗក្នុងកាលនោះ បានជាព្រះថេរានុថេរៈ ចំណែកកុមារដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តចសារជាតក ចប់

# មិត្តវិន្ទុកជាតក

[ ៩២ ] ( មិត្តវិន្ទុកៈពោលថា ) ខ្ញុំបានធ្វើអំពើដូចម្តេច ដល់ពួកទេវតា ខ្ញុំបានធ្វើបាបដូចម្តេច ទើបចក្កសង្កត់លើក្បាល វិលកិនអំបែងក្បាលរបស់ខ្ញុំ ដោយបាបណា ( បាបនោះដូចម្តេចខ្លះ ) ។

[ ៩៣ ] ( ទេវបុត្តពោធិសត្វពោលថា ) អ្នកឯងកន្លងផុតនូវប្រាសាទកែវផលិក ប្រាសាទប្រាក់ ប្រាសាទកែវមណី ប្រាសាទមាស ហើយមកក្នុងទីនេះដោយហេតុអ្វី ។

[ ៩៤ ] ( មិត្តវិន្ទុកៈពោលថា ) អ្នកចូរមើលខ្ញុំ ដល់នូវសេចក្តីវិនាស ដោយសេចក្តីសម្គាល់នេះថា កោគៈទាំងឡាយច្រើនជាង កោគៈទាំងឡាយក្នុងទីនេះប្រហែលជានឹងមានក្នុងទីនោះ ។

[ ៩៥ ] ( ពោធិសត្វពោលថាអ្នកចេញ ) អំពីវេមានិកប្រេត ៤ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៨ នាក់ ( ចេញ ) អំពីវេមានិកប្រេត ៨ នាក់ទៅ ក៏បាននូវវេមានិកប្រេត ១៦ នាក់ ( ចេញ ) អំពីវេមានិកប្រេត ១៦ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៣២ នាក់ អ្នកកាលប្រាថ្នាខ្លាំងពេក ទើបមកប្រទះនឹងចក្ក ចំណែកខាងចក្ក ក៏វិលកិនអំបែងក្បាលរបស់សត្វដែលត្រូវសេចក្តីប្រណែនបៀតបៀន ។

[ ៩៦ ] តណ្ហាជាធម្មជាតិដ៏ទូលាយក្នុងខាងលើ ដែលសត្វបំពេញបានដោយក្រ ជាដំណើរដ៏វេះវាំមដោយអំណាចនៃសេចក្តីប្រាថ្នា ពួកជនណាជាប់ចំពាក់ដោយតណ្ហានោះ ពួកជននោះរមែងទ្រទ្រង់នូវចក្ក ។

**ចប់ មិត្តវិន្ទុកជាតកទី ៩ ។**

# អដ្ឋកថា

# មិត្តវិន្ទុកជាតក

[ ៩២-៩៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ក្យាហំ ទេវានមករំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានជាក់ច្បាស់ក្នុងមហាមិត្តវិន្ទុកជាតក ( ចតុទ្វារជាតក ) ។ នាយមិត្តវិន្ទុកនេះ ត្រូវគេបោះក្នុងសមុទ្ទ ( ហើយបានជួបនឹងនាងវេមានិកប្រេត ៤ នាក់ បន្ទាប់មក ៨ នាក់ បន្ទាប់មក ១៦ នាក់ បន្ទាប់មក ៣២ នាក់ ) ក៏នៅតែជាអ្នកប្រាថ្នាក្រៃលែងមិនគ្រប់គ្រាន់ ទើបធ្វើដំណើរទៅខាងមុខ បានជួបឧស្សទនរកដែលជាទីសោយវិបាករបស់ពួកសត្វនរក ទើបចូលទៅដោយសម្គាល់ថាជានគរមួយ ឃើញខុរចក្កវិលលើអំបែងក្បាលសត្វនរក ក៏សម្គាល់ថាជាគ្រឿងប្រដាប់ ទើបត្រេកអរ ។ គ្រានោះ ព្រះពោធិសត្វជាទេវបុត្តចារិកទៅក្នុងឧស្សទនរក នាយមិត្តវិន្ទុកៈនោះឃើញព្រះពោធិសត្វនោះហើយ កាលនឹងសួរ ទើបពោលគាថាទី ១ ថា

> ខ្ញុំបានធ្វើអំពើដូចម្តេចដល់ពួកទេវតា ខ្ញុំបានធ្វើបាបដូចម្តេច
> ទើបចក្កសង្កត់លើក្បាល វិលកិនអំបែងក្បាលរបស់ខ្ញុំ ដោយ
> បាបណា ( បាបនោះដូចម្តេចខ្លះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ក្យាហំ ទេវានមករំ** សេចក្តីថា បពិត្រទេវបុត្តជាម្ចាស់ ខ្ញុំបានធ្វើកម្មឈ្មោះអ្វីដល់ពួកទេវតាទាំងពួង ពួកទេវតាបៀតបៀនខ្ញុំធ្វើអ្វី ។ បទថា **កឹ ចាបំ បកតំ មយា** សេចក្តីថា មិត្តវិន្ទុកៈបាន

ទទួលទុក្ខវេទនា កំណត់បាបដែលខ្លួនធ្វើទុកមិនបាន ព្រោះមានទុក្ខច្រើនទើបបានពោលយ៉ាងនោះ ។ បទថា **យំ មេ** សេចក្តីថា ខុរចក្កនេះ វិល គឺវិខអំបែងក្បាលរបស់ខ្ញុំ ហើយវិលលើអំបែងក្បាលរបស់ខ្ញុំ ព្រោះបាបណា បាបនោះឈ្មោះអ្វី ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះ ទើបពោលគាថាទី ២ ថា

> អ្នកឯងកន្លងផុតនូវប្រាសាទកែវផលិក ប្រាសាទប្រាក់ ប្រាសាទកែវមណី ប្រាសាទមាស ហើយមកក្នុងទីនេះ ដោយហេតុអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រមណកំ** បានដល់ ប្រាសាទកែវផលិក ។ បទថា **សទាមត្តំ** បានដល់ ប្រាសាទប្រាក់ ។ បទថា **ទូភកំ** បានដល់ ប្រាសាទកែវមណី ។ បទថា **ព្រហ្មត្តរញ្ច បាសាទំ** បានដល់ ប្រាសាទមាស ។ បទថា **កេនត្ថេន** សេចក្តីថា អ្នកលះបង់នូវទេពធីតាទាំងនេះ គឺទេពធីតា ៤ នាក់ ៨ នាក់ ១៦ នាក់ ៣២ នាក់ក្នុងប្រាសាទកែវផលិកជាដើមនោះ ហើយឈានកន្លងប្រាសាទទាំងនោះមកទីនេះព្រោះហេតុអ្វី លំដាប់នោះ មិត្តវិន្ទកៈពោលគាថាទី ៣ ថា

> អ្នកចូរមើលខ្ញុំ ដល់នូវសេចក្តីវិនាស ដោយសេចក្តីសម្គាល់នេះថា ភោគៈទាំងឡាយច្រើនជាងភោគៈទាំងឡាយក្នុងទីនេះប្រហែលជានឹងមានក្នុងទីនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតោ ពហុតរា** សេចក្តីថា នឹងមានច្រើន

ជាងភោគសម្បត្តិក្នុងប្រាសាទទាំង ៤ នេះ ។ លំដាប់នោះ ព្រះពោធិសត្វបាន ពោលគាថាដែលសល់ថា

( អ្នកចេញ ) អំពីវេមានិកប្រេត ៤ នាក់ទៅ ក៏បាននូវ វេមានិកប្រេត ៨ នាក់ ( ចេញ ) អំពីវេមានិកប្រេត ៨ នាក់ទៅ ក៏បាននូវវេមានិកប្រេត ១៦ នាក់ ( ចេញ ) អំពី វេមានិកប្រេត ១៦ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៣២ នាក់ អ្នកកាលប្រាថ្នាខ្លាំងពេក ទើបមកប្រទះនឹងចក្រ ចំណែក ខាងចក្រ ក៏វិលកិនអំបែងក្បាល របស់សត្វដែលត្រូវសេចក្ដី ប្រណែនបៀតបៀន ។

តណ្ហាជាធម្មជាតិ ដ៏ទូលាយក្នុងខាងលើដែលសត្វបំពេញ បានដោយក្រ ជាដំណើរដ៏រេះរោម ដោយអំណាចនៃសេចក្ដី ប្រាថ្នា ពួកជនណា ជាប់ចំពាក់ដោយតណ្ហានោះ ពួកជននោះ រមែងទ្រទ្រង់នូវចក្រ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧបរិ វិសាលា** សេចក្ដីថា នៃមិត្តវិន្ទក: ឈ្មោះថា តណ្ហានេះ កាលបុគ្គលសេព រមែងជារបស់ធំវិសាលខាងលើ គឺ ជារបស់ផ្សាយទៅ ធម្មតាតណ្ហាបំពេញបានដោយកម្រ ដូចមហាសមុទ្ទ មាន ប្រក្រតីទៅតាមអំណាចការចង់បាន គឺសេចក្ដីប្រាថ្នាចង់បានក្នុងអារម្មណ៍នោះៗ ក្នុងរូបារម្មណ៍ជាដើម ព្រោះហេតុនោះ បុគ្គលណា ត្រេកអរក្នុងតណ្ហានោះ គឺបែបនោះ ជាអ្នកចង់បានហើយចង់បានទៀត ហើយកាន់យក ។ បទថា

**តេ ហោន្តិ ចក្កធារិនោ** សេចក្តីថា ជនទាំងនោះ រមែងទ្រទ្រង់ គឺទូលនូវកងចក្កនោះទុក ។

នាយមិត្តវិន្ទុកៈកំពុងពោលនោះឯង ចក្កនោះក៏សង្កត់ចុះទៅ ដោយហេតុនោះ ទើបមិនអាចពោលតទៅទៀតបាន ទេវបុត្តក៏ទៅកាន់ស្ថានរបស់ខ្លួននោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា មិត្តវិន្ទុកៈក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកទេវបុត្តក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មិត្តវិន្ទុកជាតក ចប់**

# បលាសជាតក

[ ៩៧ ] ( ព្រះសម្មាសម្ពុទ្ធសម្តែងថា ) ស្តេចហង្ស បាននិយាយនឹងបលាសទេវតា ( ថា ) ម្នាលសម្លាញ់ ដើមជ្រៃដុះ ដើមជ្រៃនោះដូចសត្រូវអង្គុយលើក្លៀវរបស់អ្នក នឹងកាត់បង់នូវជីវិតសង្ខាររបស់អ្នក ។

[ ៩៨ ] ( បលាសទេវតានិយាយថា ) ខ្ញុំជាទីពឹងរបស់ដើមជ្រៃនុ៎ះ ដូចជាមាតាបិតា ដើមជ្រៃនុ៎ះនឹងជាទីពឹង ( របស់ខ្ញុំ ) ក្នុងកាលដែលវាចម្រើនឡើង យ៉ាងនោះដែរ ។

[ ៩៩ ] ( ស្តេចហង្សនិយាយថា ) អ្នកបណ្តុះនូវឈើមានជ័រដូចទឹកដោះ ជ្រៃដែលគួរខ្លាចដូចសត្រូវនៅលើក្លៀវដោយ ហេតុណា ហេតុនោះទើបយើងប្រាប់អ្នកហើយនឹងទៅ ការចម្រើនឡើងនៃដើមជ្រៃនោះ មិនពេញចិត្ត ( ខ្ញុំ ) ទេ ។

[ ១០០ ] ( បលាសទេវតានិយាយថា ) ឥឡូវនេះដើមជ្រៃញុំាងអញឲ្យភ័យ ភ័យដ៏ធំមកដល់អញ ព្រោះមិនយល់ពាក្យនៃស្តេចហង្ស ជាពាក្យដូចជាភ្នំសិនេរុដ៏ធំ ។

[ ១០១ ] ( ព្រះសម្មាសម្ពុទ្ធសម្តែងថា ) អន្តរាយណាកាលចម្រើនឡើងរមែងបំផ្លាញនូវទីពឹង សេចក្តីចម្រើននៃអន្តរាយនោះ ជនអ្នកឈ្លាសវៃមិនសរសើរឡើយ អ្នកប្រាជ្ញកាលរង្កៀសនឹងសេចក្តីវិនាស រមែងព្យាយាមដើម្បីសម្លាប់នូវមូលហេតុនៃសេចក្តីអន្តរាយនោះ ។

**ចប់ បលាសជាតកទី ១០**

**ចប់ វណ្ណារោហវគ្គទី ២**

# អដ្ឋកថា

# បលាសជាតក

[ ៩៧-១០១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសង្កត់កិលេស ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ហំសោ បលាសមវច** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានជាក់ច្បាស់ក្នុងបញ្ញាសជាតក ។ ក្នុងជាតកនេះ ព្រះសាស្តាហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាកិលេសគួរវៀរសពិត កិលេសទោះមានប្រមាណតិច ក៏ធ្វើឲ្យដល់នូវការវិនាសបាន ដូចដើមជ្រៃដូច្នោះ ។ បោរាណកបណ្ឌិតទាំងឡាយ ក៏វៀរសវត្ថុដែលគួរវៀរសមកហើយដូចគ្នា កាលត្រាស់ហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសុវណ្ណហង្ស ចម្រើនវ័យហើយ នៅក្នុងគុហាមាសនាភ្នំចិត្តកូដ ស៊ីស្រូវសាលីដែលកើតឯងក្នុងជាតស្រះនាហិមវន្តប្បទេសហើយត្រឡប់មក ។ ក្នុងផ្លូវដែលព្រះពោធិសត្វនោះទៅនិងមក មានដើមរលួសផ្អុងធំមួយដើម ។ ព្រះពោធិសត្វកាលទៅ ក៏សម្រាកត្រង់ដើមរលួសផ្អុងនោះ ហើយក៏ទៅ កាលត្រឡប់មក ក៏សម្រាកត្រង់ដើមរលួសផ្អុងនោះទើបមក ។ កាលណោះ ព្រះពោធិសត្វមានសេចក្តីស្និទ្ធស្នាលនឹងទេវតាដែលកើតត្រង់ដើមរលួសផ្អុងនោះ ។ ក្នុងកាលតមក ចាបញីមួយស៊ីផ្លែជ្រៃទុំត្រង់ដើមជ្រៃមួយដើម ហើយហើរទៅទំត្រង់ដើមរលួសផ្អុងនោះ បន្ទោបង់ឧច្ចារៈ

ក្នុងវាងប្រគាប ។ បន្ទាប់អំពីនោះ ពន្លកជ្រៃក៏ដុះឡើង ។ ក្នុងពេលដែលមានទំហំ ៤ ធ្នាប់ ដើមរលួសផ្អុងស្អាត ព្រោះជាដើមរលួសផ្អុងដែលមានត្រួយក្រហម និងស្លឹកខៀវ ស្តេចហង្សឃើញដូច្នោះហើយ ទើបហៅរុក្ខទេវតាមកពោលថា នែបលាសទេវតាសម្លាញ់ ធម្មតាដើមជ្រៃកើតឡើងត្រង់ដើមឈើណា កាលធំឡើង រមែងធ្វើដើមឈើនោះឲ្យវិនាស ចូរអ្នកកុំឲ្យដើមឈើនេះធំចម្រើនឡើយ វានឹងធ្វើវិមានរបស់អ្នកឲ្យវិនាស ចូរអ្នកដកវាចោលមុននោះឯង ឈ្មោះថាវត្ថុដែលគួររង្កៀសក៏គួររង្កៀស កាលប្រឹក្សានឹងបលាសទេវតាទើបពោលគាថាទី ១ ថា

ស្តេចហង្ស បាននិយាយនឹងបលាសទេវតា ( ថា ) ម្នាលសម្លាញ់ ដើមជ្រៃដុះ ដើមជ្រៃនោះដូចសត្រូវអង្គុយលើក្លៅរបស់អ្នក នឹងកាត់បង់នូវជីវិតសង្ខាររបស់អ្នក ដូច្នេះ ។

បាទទី ១ ក្នុងគាថានេះ ព្រះសាស្តាទ្រង់ជាអ្នកត្រាស់ដឹងព្រមចំពោះហើយ ទើបត្រាស់ទុក ។ បទថា **បលាសំ** បានដល់ បលាសទេវតា ។ បទថា **សម្ម** បានដល់ សម្លាញ់ ។ បទថា **អង្កស្មិំ** បានដល់ ត្រង់ប្រគាប[១]។ បទថា **សោ តេ មម្មានិ ឆេច្ឆតិ** សេចក្តីថា ដើមជ្រៃនោះចម្រើនធំជាត់ត្រង់ប្រគាបនោះហើយ នឹងកាត់ជីវិតដូចសត្រូវ ដូច្នោះ ។ មែនពិត សង្ខារដែលមានជីវិត លោកហៅថា **មម្ម** ក្នុងទីនេះ ។

បលាសទេវតា បានស្តាប់ដូច្នោះ មិនជឿពាក្យរបស់ព្រះពោធិសត្វនោះ

១-បិដកខ្មែរ ជាក្លៅ ។

ទើបពោលគាថាទី ២ ថា

ខ្ញុំជាទីពឹងរបស់ដើមជ្រៃនុ៎ះ ដូចជាមាតាបិតា ដើមជ្រៃនុ៎ះនឹង
ជាទីពឹង ( របស់ខ្ញុំ ) ក្នុងកាលដែលវាចម្រើនឡើង យ៉ាង
នោះដែរ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានសេចក្តីថា នែសម្លាញ់ អ្នកមិនដឹង ដើមជ្រៃនេះនឹងជាទីពឹងរបស់ខ្ញុំក្នុងកាលដែលវាធំនោះឯង ខ្ញុំនឹងជាទីពឹងរបស់ដើមជ្រៃនេះ ដូចមាតាបិតា ជាទីពឹងរបស់បុត្តក្នុងកាលដែលកុមារនៅតូចដូច្នោះ ។ ម្យ៉ាងទៀត ដើមជ្រៃនេះនឹងជាទីពឹងរបស់ខ្ញុំក្នុងកាលដែលខ្លួនចាស់ ដូចបុត្តធំឡើង រមែងជាទីពឹងរបស់មាតាបិតាក្នុងកាលដែលខ្លួនចាស់ ដូច្នោះ ។ លំដាប់នោះទើបស្តេចហង្សពោលគាថាទី ៣ ថា

អ្នកបណ្តុះនូវឈើមានជ័រ ដូចទឹកដោះ ជ្រៃដែលគួរខ្លាចដូច
សត្រូវនៅលើក្អៀងដោយហេតុណា ហេតុនោះ ទើបយើងប្រាប់
អ្នក ហើយនឹងទៅ ការចម្រើនឡើងនៃដើមជ្រៃនោះ មិនពេញ
ចិត្ត ( ខ្ញុំ ) ទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ ត្វំ** សេចក្តីថា ព្រោះហេតុដែលអ្នកឲ្យនូវទឹកដោះ ( ឲ្យឈើដទៃស្រូបនូវជីវជាតិរបស់ខ្លួន ) នេះឈ្មោះថា គួរខ្លាច ព្រោះជាបុគ្គលឲ្យនូវភាពគួរខ្លាច ដូចសត្រូវដែលចម្រើនត្រង់ក្អៀង ។ បទថា **អាមន្ត ខោ តំ** សេចក្តីថា ព្រោះហេតុនោះទើបខ្ញុំហៅអ្នកមកប្រឹក្សាឲ្យដឹងហើយនឹងទៅ ។ បទថា **វុឌ្ឍិមស្ស** សេចក្តីថា សេចក្តីចម្រើនរបស់ដើម

ជ្រៃនោះ មិនគាប់ចិត្តខ្ញុំឡើយ ។

ស្តេចហង្សក្រាលពោលយ៉ាងនេះហើយ ក៏ទទះស្លាបហើរទៅកាន់ភ្នំចិត្តកូដនោះឯង តាំងអំពីនោះមកស្តេចហង្សនោះក៏មិនបានមកទៀតឡើយ ។ ចំណេរកាលតមក ដើមជ្រៃក៏ចម្រើនឡើង ។ មានរុក្ខទេវតាមួយទៀត កើតឡើងត្រង់ដើមជ្រៃនោះ ដើមជ្រៃនោះចម្រើនឡើង កាច់បំបាក់នូវដើមរលួសផ្អុង ។ វិមានរបស់ទេវតាព្រមទាំងមែកទាំងឡាយក៏បាក់ជ្រុះទៅ ។ ក្នុងកាលនោះទើបទេវតានោះ កំណត់ពាក្យរបស់ស្តេចហង្សបាន កន្ទក់កន្ទេញថា ស្តេចហង្សឃើញភ័យក្នុងអនាគត ទើបពោលទុក ចំណែកអញមិនធ្វើតាមពាក្យរបស់ស្តេចហង្ស ហើយពោលគាថាទី ៤ ថា

ឥឡូវនេះដើមជ្រៃ ញុំាងអញឲ្យភ័យ ភ័យដ៏ធំមកដល់អញ
ព្រោះមិនយល់ពាក្យនៃស្តេចហង្ស ជាពាក្យដូចជាភ្នំសិនេរុដ៏ធំ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទានិ ខោ មំ ភាយតិ** សេចក្តីថា ដើមជ្រៃនេះធ្វើឲ្យអញត្រេកអរ ក្នុងកាលដែលនៅតូច ឥឡូវនេះ ធ្វើឲ្យអញតក់ស្លុត ។ បទថា **មហានេរុនិទស្សនំ** សេចក្តីថា ព្រោះបានស្តាប់ពាក្យរបស់ស្តេចហង្ស ដែលធំដូចជាស្តេចភ្នំសិនេរុ តែមិនចាប់ភ្លឹក ទើបមិនបានដកដើមជ្រៃនេះចោលក្នុងកាលនៅតូចនោះឯង ។ ដោយបទថា **មហា មេ ភយ-មាគតំ** នេះ ទេវតាកន្ទក់កន្ទេញថា ឥឡូវនេះ ភ័យធំមកដល់អញហើយ ។

ចំណែកដើមជ្រៃ ក៏ចម្រើនឡើង កាច់បំបាក់នូវដើមរលួសផ្អុងទាំងមូល ធ្វើឲ្យសល់តែជន្ទត់ប៉ុណ្ណោះ វិមានរបស់ទេវតាក៏អន្តរធានទៅ ។

ព្រះសាស្តាកាលទ្រង់ត្រាស់ដឹងហើយទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថាថា

អន្តរាយណាកាលចម្រើនឡើងរមែងបំផ្លាញនូវទីពឹង សេចក្តី
ចម្រើននៃអន្តរាយនោះ ជនអ្នកឈ្លាសវៃ មិនសរសើរឡើយ
អ្នកប្រាជ្ញកាលវៀសនឹងសេចក្តីវិនាស រមែងព្យាយាមដើម្បី
សម្លាប់នូវមូលហេតុនៃសេចក្តីអន្តរាយនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុសលប្បសត្ថា** សេចក្តីថា ដែលលោកអ្នកឈ្លាសទាំងឡាយ សរសើរហើយ ។ បទថា **ឃសតេ** បានដល់ រមែងស៊ី អធិប្បាយថា ធ្វើឲ្យវិនាស ។ បទថា **បតារយិ** បានដល់ រមែងប្រឹង-ប្រែង គឺរមែងព្យាយាម ។ ព្រះសាស្តាអធិប្បាយទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាចម្រើន ធ្វើនូវទីពឹងអាស្រ័យរបស់ខ្លួនឲ្យវិនាស ការចម្រើនរបស់បុគ្គលនោះ បណ្ឌិតមិនសរសើរ ចំណែកអ្នកប្រាជ្ញ គឺលោកអ្នកដែលបរិបូណ៌ដោយប្រាជ្ញា វៀសនូវឧបសគ្គ គឺសេចក្តីវិនាសយ៉ាងនេះថា ឧបសគ្គនឹងមានដល់អញ ព្រោះអាស្រ័យអន្តរាយនេះរមែង ព្យាយាមដើម្បីកាត់នូវឫសគល់របស់អន្តរាយទាំងខាងក្នុងឬខាងក្រៅនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុ ៥០០ រូប បានសម្រេចអរហត្ត ហើយទ្រង់ប្រជុំជាតកថា សុវណ្ណហង្សក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា បលាសជាតក ចប់**

**វណ្ណារោហវគ្គ ចប់**

# អឌ្ឍវគ្គ

## ទីឃីតិកោសលជាតក

[ ១០២ ] ( ទីឃាវុកុមារពោលថា ) បពិត្រព្រះរាជា ព្រះអង្គធ្លាក់មកក្នុងអំណាចរបស់ខ្ញុំយ៉ាងនេះ បរិយាយណា ញុំាងព្រះអង្គឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ មានដែរឬ ។

[ ១០៣ ] ( ព្រះរាជាពោលថា ) ម្នាលអ្នក ខ្ញុំធ្លាក់មកក្នុងអំណាចរបស់អ្នកប្រាកដយ៉ាងនេះ បរិយាយណាញុំាងខ្ញុំឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ របស់យើងមិនមានទេ ។

[ ១០៤ ] ( ទីឃាវុកុមារពោលថា ) បពិត្រព្រះរាជា គុណជាតដទៃអំពីសុចរិត ទីពឹងមិនបានទេ បពិត្រព្រះរាជា គុណជាតដទៃអំពីសុភាសិត ទីពឹងមិនបានទេ ទ្រព្យក្រៅពីនេះក៏យ៉ាងនោះដែរ ។

[ ១០៥ ] បុគ្គលទាំងឡាយណា ចងនូវពៀរនោះ ( ដោយគិតថា ) អ្នកឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនេះ រមែងមិនរម្ងាប់ទេ លុះតែបុគ្គលទាំងឡាយណា មិនចងនូវពៀរនោះ ( ដោយគិតថា ) អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនោះ ទើបរម្ងាប់បាន ។

[ ១០៦ ] តាំងពីកាលណាមក ពៀរទាំងឡាយក្នុងលោកនេះ រមែងមិនរម្ងាប់ដោយពៀរទេ ពៀរទាំងឡាយរមែងរម្ងាប់បាន ដោយមិនមានពៀរ នេះ

ជាបុរាណធម៌ ។

ចប់ ទីឃីតិកោសលជាតកទី ១ ។

# អឌ្ឍវគ្គ

## អដ្ឋកថា ទីឃីតិកោសលជាតក

[ ១០២-១០៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកក្រុងកោសម្ពីដែលធ្វើនូវការឈ្លោះប្រកែកគ្នា ទើបត្រាស់ ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឯវំ ភូតស្ស តេ រាជ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលដែលភិក្ខុទាំងនោះ មកកាន់វត្តជេតពន សូមឲ្យព្រះសាស្តាទ្រង់អត់នូវទោស ព្រះសាស្តាត្រាស់ហៅភិក្ខុទាំងនោះមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយជាឱរសរបស់យើង ឈ្មោះថា ជាបុត្តដែលកើតអំពីមាត់ បុត្តទាំងឡាយមិនគួរទម្លាយឱវាទដែលបិតាទុកឲ្យ អ្នកទាំងឡាយមិនធ្វើតាមឱវាទរបស់តថាគត បោរាណកបណ្ឌិតទាំងឡាយ ក៏មិនសម្លាប់ចោរ ដែលសម្លាប់មាតាបិតារបស់ខ្លួនហើយដណ្តើមយករាជសម្បត្តិធ្លាក់នៅក្នុងកណ្តាប់ដៃក្នុងព្រៃ ដោយគិតថា អញមិនទម្លាយឱវាទដែលមាតាបិតាទុកឲ្យដូច្នេះ ទើបទ្រង់នាំយកអតីតនិទានមកសាធក: ។

ក្នុងជាតកនេះ រឿងទាំងពីរ គឺរឿងបច្ចុប្បន្ននិងរឿងក្នុងអតីត: មានជាក់ច្បាស់ដោយពិស្តារក្នុងសង្ឃភេទក្ខន្ធក: ។ ទីឃាវុកុមារនោះ ចាប់ផ្នួងសក់

របស់ព្រះបាទពារាណសី ដែលផ្ដួលកក់កើយក្ដៅរបស់ខ្លួនក្នុងព្រៃ ងាជាវឡើង ដោយបំណងថា ឥឡូវនេះ អញនឹងសម្លាប់ចោរដែលប្រហារមាតាបិតាអញ ឲ្យជាកំណាត់តូចកំណាត់ធំ ខណៈនោះ នឹកឃើញដល់ឱវាទដែលមាតាបិតាឲ្យ គិតថា ទោះបីអញលះបង់ជីវិត ក៏មិនទម្លាយឱវាទរបស់លោក អញនឹងគំរាមស្ដេចពារាណសីនេះតែម្យ៉ាង ទើបពោលគាថាទី ១ ថា

បពិត្រព្រះរាជា ព្រះអង្គធ្លាក់មកក្នុងអំណាចរបស់ខ្ញុំយ៉ាងនេះ
បរិយាយណា ញ៉ាំងព្រះអង្គឲ្យរួចចាកទុក្ខ បរិយាយណាមួយ
នោះ មានដែរឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វសេ មមំ** បានដល់ មកកាន់អំណាចរបស់ខ្ញុំ ។ បទថា **បរិយាយោ** បានដល់ ហេតុ ។ លំដាប់នោះ ព្រះរាជាត្រាស់គាថាទី ២ ថា

ម្នាលអ្នក ខ្ញុំធ្លាក់មកក្នុងអំណាចរបស់អ្នក ប្រាកដយ៉ាងនេះ
បរិយាយណា ញ៉ាំងខ្ញុំឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ
របស់យើងមិនមានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នោ** ត្រឹមតែជានិបាត អធិប្បាយថា ហេតុណាមួយដែលធ្វើឲ្យយើងផុតចាកទុក្ខនោះ មិនមានទេ ។ លំដាប់នោះ ព្រះពោធិសត្វ បានពោលគាថាដ៏សេសថា

បពិត្រព្រះរាជា គុណជាតដទៃអំពីសុចរិត ទីពឹងមិនបាន
ទេ បពិត្រព្រះរាជា គុណជាតដទៃអំពីសុភាសិតទីពឹងមិនបាន

ទេ ទ្រព្យក្រៅពីនេះ ក៏យ៉ាងនោះដែរ ។

បុគ្គលទាំងឡាយណា ចងនូវពៀរនោះ ( ដោយគិតថា ) អ្នកឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនេះរមែងមិនរម្ងាប់ទេ លុះតែបុគ្គលទាំងឡាយណាមិនចងនូវពៀរនោះ ( ដោយគិតថា ) អ្នកឯណោះបានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក ( ទ្រព្យ ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនោះ ទើបរម្ងាប់បាន ។

តាំងពីកាលណាមក ពៀរទាំងឡាយក្នុងលោកនេះ រមែងមិនរម្ងាប់ដោយពៀរទេ ពៀរទាំងឡាយរមែងរម្ងាប់បានដោយមិនមានពៀរ នេះជាបុរាណធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នាញ្ញំ សុចរិតំ** កែជា **នាញ្ញំ សុចរិតា** ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះឯង អធិប្បាយថា វៀរសុចរិតចេញ ខ្ញុំមិនឃើញអ្វីដទៃឡើយ ។ ក្នុងគាថានេះព្រះពោធិសត្វពោលថា សុចរិតខ្លះ សុភាសិតខ្លះ ក៏សំដៅយកឱវាទដែលមាតាបិតាឲ្យប៉ុណ្ណោះ ។ បទថា **ឯវមេវ** បានដល់មិនមានប្រយោជន៍ឡើយ ។ លោកអធិប្បាយទុកថា បពិត្រមហារាជ វៀរចាកសុចរិត និងវាចាសុភាសិត ពោលគឺការពោលប្រៀនប្រដៅ និងឱវាទ អ្វីដទៃដែលអាចរារាំងការពារក្នុងពេលដែលត្រូវស្លាប់នេះមិនមាន ទ្រព្យក្រៅពីនេះក៏ដូចគ្នា គឺមិនមានប្រយោជន៍ឡើយ ឥឡូវនេះ ទោះទ្រង់ឲ្យទ្រព្យរាប់សែន

កោជិដល់ទូលព្រះបង្គំ ក៏មិនបានជីវិត ព្រោះហេតុនោះ សេចក្ដីនេះ គប្បីជ្រាបថា សុចរិតនិងពាក្យជាសុភាសិតប៉ុណ្ណោះ ក្រៃលែងជាងទ្រព្យ ។

គាថាដ៏សេស មានសេចក្ដីសង្ខេបដូចតទៅនេះថា បពិត្រមហារាជ បុគ្គលពួកណាចូលទៅចងពៀរ គឺតម្កល់ពៀរទុកក្នុងហទយៈ ដូចចងទុកយ៉ាងនេះថា បុគ្គលនេះជេរអញ បុគ្គលនេះប្រហារអញ បុគ្គលនេះបានឈ្នះអញ បុគ្គលនេះលួចរបស់អញ ពៀររបស់បុគ្គលនោះមិនស្ងប់ ចំណែកបុគ្គលណាមិនចូលទៅចង គឺមិនតាំងពៀរនោះទុកក្នុងហទយៈ ពៀររបស់បុគ្គលនោះរមែងស្ងប់ ព្រោះក្នុងកាលណាមួយ ពៀរទាំងឡាយរមែងមិនរម្ងាប់ដោយពៀរ តែរម្ងាប់ដោយការមិនមានពៀរ ធម៌នោះជារបស់មានមកតាំងអំពីបុរាណ អធិប្បាយថា ជាបុរាណធម៌ គឺសភាវៈដែលប្រព្រឹត្តទៅអស់កាលយូរ ។

កាលព្រះពោធិសត្វពោលយ៉ាងនេះហើយ ទើបក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំមិនប្រទូស្តព្រះអង្គ សូមទ្រង់សម្លាប់ទូលព្រះបង្គំចុះ ហើយហុចដាវដាក់ក្នុងព្រះហស្តព្រះរាជានោះ ចំណែកព្រះរាជាក៏ទ្រង់ស្បថថា យើងមិនប្រទូស្តអ្នក ហើយយាងទៅកាន់នគរជាមួយព្រះពោធិសត្វនោះ ។ ទ្រង់បង្ហាញព្រះពោធិសត្វដល់អាមាត្យទាំងឡាយហើយត្រាស់ថា នែអ្នកទាំងឡាយ បុរសនេះជាទីឃាវុកុមារ ជាបុត្ររបស់ព្រះបាទកោសល បុរសនេះឲ្យជីវិតដល់យើង យើងក៏មិនបានធ្វើអ្វីដល់បុរសនេះ កាលត្រាស់ហើយ បានប្រទានព្រះរាជធីតារបស់ទ្រង់ ហើយឲ្យតាំងនៅក្នុងរាជសម្បត្តិ ដែលជារបស់បិតា ។ តាំងអំពីនោះមក ក្សត្រទាំងពីរអង្គសាមគ្គីត្រេកអរ គ្រងនូវរាជសម្បត្តិ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា មាតាបិតាក្នុងកាលនោះ បានមកជាត្រកូលមហារាជ ក្នុងកាលឥឡូវនេះ ចំណែកទីឃាវុកុមារ ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទីឃីតិកោសលជាតក ចប់

# មិគបោតកជាតក

[ ១០៧ ] ( ព្រះឥន្ទ្រពោលថា ) លោកចេញចាកផ្ទះ ជាបុគ្គលមិនមានផ្ទះ ជាសមណៈ លោកសោកស្តាយចំពោះសត្វដែលទៅកាន់លោកខាងមុខណា សេចក្តីសោកស្តាយនោះមិនប្រពៃទេ ។

[ ១០៨ ] ( តាបសតបថា ) បពិត្រសក្កៈ សេចក្តីស្រឡាញ់ រមែងកើតឡើងក្នុងហឫទ័យ ដោយការនៅរួមរបស់មនុស្សឬរបស់ម្រឹគ ខ្ញុំមិនអាចមិនសោយសោកនឹងម្រឹគនោះបានទេ ។

[ ១០៩ ] ( សក្កទេវរាជពោលថា ) ពួកជនណាយំនឹងបុគ្គលដែលស្លាប់ទៅហើយ ឬនឹងស្លាប់ បុគ្គលនោះរមែងយំ រមែងរវើរវាយ ( ឥតឈប់ ) បពិត្រឥសី ព្រោះហេតុនោះលោកកុំយំឡើយ ព្រោះថា ពួកសប្បុរសបានពោលនូវការយំថា ជាការឥតអំពើ ។

[ ១១០ ] បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់ លះលោកនេះទៅហើយ គប្បីក្រោកឡើងបានដោយការយំ យើងទាំងអស់ ចូរប្រជុំគ្នាយំនឹងពួកញាតិនៃគ្នានឹងគ្នា ។

[ ១១១ ] ( តាបសពោលថា ) អ្នកបានស្រោចស្រពនូវខ្ញុំ ដែលភ្លើងគឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលស្រោចនូវភ្លើងដែលឆេះឆ្នាំងខ្លាញ់ដោយទឹក សរគឺសេចក្តីសោកណាដែលអាស្រ័យក្នុងហឫទ័យ សរគឺសេចក្តីសោកនោះ ខ្ញុំបានដកចេញហើយ អ្នកណាបានបន្ទោបង់សេចក្តីសោក ព្រោះបុត្តដល់ខ្ញុំដែលត្រូវសេចក្តីសោកបៀតបៀន ខ្ញុំនោះជាអ្នកមានសរគឺសេចក្តីសោកដកចេញហើយ

ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលវាសវៈ ខ្ញុំលែងសោក ស្តាយ លែងយំទួញព្រោះបានស្តាប់ពាក្យរបស់អ្នក ( នោះ ) ។

**ចប់ មិគបោតកជាតកទី ២ ។**

# អដ្ឋកថា

# មិគបោតកជាតក

[ ១០៧-១១១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ភិក្ខុចាស់មួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អគារា បច្ចុបេតស្ស** ដូច្នេះជាដើម ។

បានឮថា ភិក្ខុចាស់នោះឲ្យកុមារម្នាក់បួស សាមណេរបម្រើភិក្ខុចាស់នោះ ដោយគោរព ក្នុងកាលតមក សាមណេរបានធ្វើកាលកិរិយាដោយជំងឺណាមួយ ព្រោះការធ្វើកាលកិរិយារបស់សាមណេរនោះ ភិក្ខុចាស់នោះត្រូវសេចក្តីសោក គ្របសង្កត់ កន្ទក់កន្ទេញដោយសំឡេងខ្លាំង ភិក្ខុទាំងឡាយមិនអាចឲ្យក្រោក ខ្ទបាន ទើបសន្ទនាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុចាស់ឈ្មោះនោះ ដើរយំព្រោះការធ្វើកាលកិរិយារបស់សាមណេរ ភិក្ខុចាស់នោះ នឹងឆ្ងាយអំពី ការចម្រើនមរណស្សតិ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាល ភិក្ខុទាំងឡាយ អំបាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាល ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបទ្រង់

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុចាស់នេះ កាលសាមណេរមរណៈហើយ ក៏ដើរយំហើយដូចគ្នា ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វជាសក្កទេវរាជ ។ កាលនោះ មានព្រាហ្មណ៍អ្នកដែនកាសីម្នាក់ចូលទៅកាន់ហិមវន្តប្បទេសបួសជាឥសី ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយផ្លែឈើតូចធំ ។ ថ្ងៃមួយឥសីនោះ ឃើញកូនម្រឹគដែលមេងាប់មួយក្នុងព្រៃ ទើបនាំមកកាន់អាស្រមបទ ហើយចិញ្ចឹមទុក ។ កូនម្រឹគធំឡើង មានរូបស្អាតពន់ពេក ។ តាបសធ្វើកូនម្រឹគនោះឲ្យជាកូនរបស់ខ្លួន ។ ថ្ងៃមួយកូនម្រឹគស៊ីស្មៅច្រើនពេកក៏ស្លាប់ ព្រោះអាហារមិនរលួយ តាបសកន្ទក់កន្ទេញថាកូនខ្ញុំស្លាប់ហើយ ។ ក្នុងកាលនោះសក្កទេវរាជ ពិចារណាមើលលោកសន្និវាស ទ្រង់ឃើញតាបសនោះ ទ្រង់ត្រិះរិះថានឹងធ្វើតាបសនោះឲ្យសង្វេគ ទើបយាងមកហើយប្រថាប់ឈរនៅក្នុងអាកាស ត្រាស់គាថាទី ១ ថា

លោកចេញចាកផ្ទះ ជាបុគ្គលមិនមានផ្ទះ ជាសមណៈ លោក
សោកស្តាយចំពោះសត្វដែលទៅកាន់លោកខាងមុខណា សេច
ក្តីសោកស្តាយនោះមិនប្រពៃទេ ដូច្នេះ ។

តាបសបានស្តាប់ដូច្នោះទើបពោលគាថាទី ២ ថា

បពិត្រសក្កៈ សេចក្តីស្រឡាញ់ រមែងកើតឡើងក្នុងហឫទ័យ
ដោយការនៅរួម របស់មនុស្ស ឬរបស់ម្រឹគ ខ្ញុំមិនអាចមិន

សោយសោកនឹងម្រឹគនោះបានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆ តំ សក្កា** សេចក្ដីថា អាត្មាមិនអាចមិនសោកដល់មនុស្ស ឬសត្វតិរច្ឆាននោះ គឺអាត្មាសោយសោកដល់នោះឯង ។ លំដាប់នោះ សក្កៈបានត្រាស់គាថា ២ ថា

ពួកជនណាយំនឹងបុគ្គលដែលស្លាប់ទៅហើយ ឬនឹងស្លាប់ បុគ្គលនោះរមែងយំ រមែងរវើរវាយ ( ឥតឈប់ ) បពិត្រឥសី ព្រោះហេតុនោះលោកកុំយំឡើយ ព្រោះថា ពួកសប្បុរសបានពោលនូវការយំថា ជាការឥតអំពើ ។

បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់លះលោកនេះទៅហើយ គប្បីក្រោកឡើងបានដោយការយំ យើងទាំងអស់ចូរប្រជុំគ្នាយំនឹងពួកញាតិនៃគ្នានឹងគ្នា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មរិស្សំ** បានដល់ បុគ្គលដែលស្លាប់ក្នុងឥឡូវនេះ ។ បទថា **លបន្តិ ច** បានដល់ រវើរវាយ ។ លោកពោលពាក្យអធិប្បាយនេះទុកថា ជនទាំងឡាយណា យំឲ្យដល់អ្នកដែលស្លាប់ហើយនិងអ្នកដែលនឹងស្លាប់ក្នុងលោក ជនទាំងនោះក៏គង់នឹងយំនិងកន្ទក់កន្ទេញ ។ ឈ្មោះថា ថ្ងៃដែលស្ងួតទឹកភ្នែករបស់ជនទាំងនោះរមែងមិនមាន ព្រោះហេតុអ្វី ព្រោះអ្នកដែលស្លាប់ទៅ និងអ្នកដែលនឹងស្លាប់នៅមានជានិច្ច ។ បទថា **តស្មា តុំ ឥសិ មា រោទិ** សេចក្ដីថា នៃឥសី ព្រោះហេតុនោះ លោកកុំយំឡើយ ។ ព្រោះហេតុអ្វី ព្រោះសប្បុរសទាំងឡាយពោលការយំថា មិនមានប្រយោជន៍

អធិប្បាយថា សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម រមែងពោលការយំថា ឥតអំពើ ។ បទថា **មតោ បេតោ** សេចក្តីថា បើបុគ្គលដែលហៅថាអ្នកស្លាប់ហើយ អ្នកលះលោកទៅហើយ គប្បីក្រោកឡើង ព្រោះការយំសោត កាលបើដូច្នោះ ពួកយើងនៅព្រងើយធ្វើអ្វី ពួកយើងទាំងអស់នឹងនាំគ្នាប្រជុំយំដល់ញាតិទាំងឡាយនៃគ្នានឹងគ្នា ព្រោះហេតុដែលញាតិទាំងនោះមិនក្រោកឡើង ព្រោះហេតុនៃការយំ ព្រោះដូច្នោះ ទើបសក្កទេវរាជទ្រង់ប្រកាសការយំថា ឥតអំពើ ។

កាលសក្កទេវរាជ ត្រាស់យ៉ាងនេះ តាបសកំណត់បានថា ការយំឥតប្រយោជន៍ កាលធ្វើនូវការសរសើរសក្កទេវរាជ ទើបពោលគាថា ៣ ថា

អ្នកបានស្រោចស្រពនូវខ្ញុំ ដែលភ្លើងគឺសេចក្តីសោកកំពុងឆេះឲ្យស្ងប់រម្ងាប់ ញុំាំងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលស្រោចនូវភ្លើងដែលឆេះឆ្នាំងខ្លាញ់ដោយទឹក សរគឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរគឺសេចក្តីសោកនោះ ខ្ញុំបានដកចេញហើយ អ្នកណាបានបន្ទោបង់សេចក្តីសោកព្រោះបុត្តដល់ខ្ញុំ ដែលត្រូវសេចក្តីសោកបៀតបៀន ខ្ញុំនោះ ជាអ្នកមានសរគឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលវាសវៈ ខ្ញុំលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់ពាក្យរបស់អ្នក ( នោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យមាសិ** កាត់បទជា **យំ មេ អាសិ** ។ បទថា **ហទយស្សិតំ** បានដល់ ចាក់ដោតក្នុងហទយៈ ។ បទថា **អចានុធិ** បានដល់ នាំចេញហើយ ។ សក្កទេវរាជកាលប្រទានឱវាទដល់តាបសហើយ ក៏យាងទៅកាន់ឋានរបស់ទ្រង់វិញ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបទ្រង់ប្រជុំជាតកថា តាបសក្នុងកាលនោះ បានមកជាភិក្ខុចាស់ក្នុងកាលឥឡូវនេះ ម្រឹគក្នុងកាលនោះ បានមកជាសាមណេរ ចំណែកសក្កៈក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មិគបោតកជាតក ចប់**

# មូសិកជាតក

[ ១១២ ] ( ព្រះរាជាពោលថា ) អ្នកផងនិយាយរវើរវាយថា នាងមូសិកាទាសីទៅឯណាទៅក្នុងទីណា អញតែម្នាក់ឯងដឹងថា នាងមូសិកាទាសីត្រូវគេសម្លាប់ ( ទម្លាក់ទៅ ) ក្នុងស្រះ ។

[ ១១៣ ] ( ព្រះរាជាពោលថា ) អ្នកគិតរកនូវឱកាសនៃការប្រហារដូច្នេះ បែរនឹកផាកដូចសត្វលា ព្រោះហេតុណា ហេតុនោះអ្នកសម្លាប់នូវនាងមូសិកាទាសី ( ទម្លាក់ទៅ ) ក្នុងស្រះប្រាថ្នាដើម្បីស៊ីនូវបាយដំណើបឬ ។

[ ១១៤ ] ( ព្រះរាជាពោលតទៅទៀតថា ) ម្នាលអ្នកឥតប្រាជ្ញា អ្នកជាបុគ្គលនៅក្មេងតូច តាំងនៅក្នុងបឋមវ័យ កាន់យកនូវគ្រឿងប្រហារមានជងដ៏វែងនេះ យើងមិនឲ្យជីវិតដល់អ្នកទេ ។

[ ១១៥ ] ( ព្រះរាជាពោលគាថាដ៏ពិសេសថា ) អញមិនមែនរួច ( អំពីសេចក្តីស្លាប់ ) ព្រោះវិមានលើអាកាស ឬព្រោះបុត្តប្រាជកស្មើដោយអវយវៈបានទេ ព្រោះថាអញត្រូវកូនប្រាថ្នា ( នឹងសម្លាប់ ) បានរួចខ្លួនព្រោះគាថាទាំងឡាយ ។

[ ១១៦ ] បុគ្គលគប្បីសិក្សានូវសុតៈទាំងពួង ទោះបីថោកទាប ឧក្រិដ្ឋ ឬយ៉ាងកណ្តាល គប្បីដឹងនូវប្រយោជន៍នៃសុតៈទាំងអស់ តែមិនគប្បីប្រកបនូវសុតៈទាំងអស់ទេ សុតៈនាំមកនូវប្រយោជន៍ក្នុងកាលណា កាលប្រាកដដូច្នោះរមែងមានប្រាកដ ។

**ចប់ មូសិកជាតកទី ៣ ។**

# អដ្ឋកថា

# មូសិកជាតក

[ ១១២-១១៦ ] *ព្រះសាស្តាកាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះបាទអជាតសត្តុ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **កុហឹ គតា កត្ថ គតា** *ដូច្នេះជាដើម ។*

*រឿងបច្ចុប្បន្នបានឲ្យពិស្តារមកហើយ ក្នុងថុសជាតកខាងដើមនោះឯង ។ ចំណែកក្នុងជាតកនេះ ព្រះសាស្តាទ្រង់ឃើញព្រះរាជា លេងនូវព្រះរាជឱរសបណ្តើរ ស្តាប់ព្រះធម្មទេសនាបណ្តើរយ៉ាងនោះ ទ្រង់ជ្រាបថា ភ័យនឹងកើតឡើងដល់ព្រះរាជា ព្រោះអាស្រ័យឱរសនោះទើបត្រាស់ថា មហាបពិត្រ ព្រះរាជាទាំងឡាយក្នុងកាលមុន ទ្រង់រង្កៀសក្នុងវត្ថុដែលគួររង្កៀស ទ្រង់បានធ្វើឱរសរបស់ទ្រង់ទុកក្នុងចំណែកម្ខាង ដោយទ្រង់ព្រះតម្រិះថា ព្រះឱរសចូរគ្រងរាជសម្បត្តិក្នុងពេលដែលអញចាស់ជរា ខ្វាក់ងងឹត ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា*

*ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរតក្កសិលា បានជាអាចារ្យទិសាបាមោក្ខ ឱរសរបស់ព្រះបាទពារាណសីព្រះនាមថា យវកុមារ បានរៀនសិប្បៈគ្រប់យ៉ាងក្នុងសម្នាក់របស់ព្រះពោធិសត្វនោះ ហើយឲ្យនូវការសាកសួរគឺសាកល្បងនូវវិជ្ជាហើយ បំណងនឹងត្រឡប់មកស្រុក ហើយទើបលាអាចារ្យនោះ ។ អាចារ្យដឹងបានដោយអំណាចវិជ្ជាមើលអវយវៈថា អន្តរាយនឹងមាន*

ដល់កុមារនេះព្រោះអាស្រ័យកូនជាហេតុ គិតថា អញនឹងកម្ចាត់អន្តរាយរបស់កុមារនោះ ទើបពិចារណារកសេចក្ដីប្រៀបធៀបឯណានីមួយ ។ ក្នុងកាលនោះ សេះរបស់អាចារ្យទិសាបាមោក្ខនោះមានមួយ ថ្ងៃមួយក៏កើតដំបៅត្រង់ជើង ។ ពួកអ្នកចិញ្ចឹមសេះ ទើបឲ្យសេះនោះនៅក្នុងផ្ទះដើម្បីព្យាបាលដំបៅ ក្នុងទីមិនឆ្ងាយអំពីផ្ទះនោះ មានអណ្ដូងទឹកមួយ កាលនោះកណ្ដុរមួយចេញអំពីផ្ទះខាំដំបៅត្រង់ជើងរបស់សេះ សេះមិនអាចឃាត់កណ្ដុរបាន ។ ថ្ងៃមួយសេះនោះមិនអាចអត់ធន់នឹងទុក្ខវេទនាបាន ទើបយកជើងធាក់កណ្ដុរ ដែលមកកកេរដំបៅឲ្យស្លាប់ធ្លាក់ទៅក្នុងអណ្ដូង ។ ពួកអ្នកចិញ្ចឹមសេះមិនឃើញកណ្ដុរមកទើបពោលថា ក្នុងថ្ងៃដទៃៗកណ្ដុរមកខាំដំបៅ ឥឡូវនេះមិនប្រាកដ តើកណ្ដុរទៅណាហ្ន៎ ។ ព្រះពោធិសត្វធ្វើហេតុនោះឲ្យប្រចក្សហើយទើបពោលថា អ្នកដទៃមិនដឹងទើបពោលថាកណ្ដុរទៅឯណា តែយើងប៉ុណ្ណោះរមែងដឹងថាកណ្ដុរត្រូវសេះសម្លាប់ ហើយធាក់ឲ្យធ្លាក់ទៅក្នុងអណ្ដូងទឹក ។ ព្រះពោធិសត្វនោះ ទើបធ្វើហេតុនេះឯងឲ្យជាការប្រៀបធៀប ហើយចងជាគាថាទី ១ ប្រគល់ឲ្យដល់កុមារ ។ ព្រះពោធិសត្វនោះ ពិចារណារកគោលប្រៀបធៀបដទៃទៀត បានឃើញសេះនោះឯង មានដំបៅជាសះស្បើយហើយ ចេញទៅត្រង់ចម្ការស្រូវដំណើបមួយកន្លែង ហើយសឹកមាត់ចូលទៅក្នុងរបង ដោយបំណងថានឹងស៊ីស្រូវទើបធ្វើហេតុនោះឯងឲ្យជាការប្រៀបធៀប ហើយចងគាថាទី ២ ប្រគល់ឲ្យដល់កុមារនោះ ចំណែកគាថាទី ៣ ព្រះពោធិសត្វចងដោយកម្លាំងប្រាជ្ញារបស់ខ្លួននោះឯង ហើយប្រគល់គាថាទី ៣ នោះឲ្យដល់កុមារនោះ

ហើយពោលថា នែបា អ្នកតាំងនៅក្នុងរាជសម្បត្តិហើយ ពេលល្ងាច កាល ទៅកាន់ស្រះបោក្ខរណី សម្រាប់ស្រង់ទឹក គប្បីទន្ទេញគាថាទី ១ ទៅរហូត ដល់ជណ្តើរដែលជិត កាលទៅកាន់ប្រាសាទដែលជាកន្លែងរបស់ខ្លួន គប្បី ទន្ទេញគាថាទី ២ រហូតដល់ជើងជណ្តើរ បន្ទាប់ពីនោះទៅគប្បីទន្ទេញគាថាទី ៣ រហូតដល់ក្បាលជណ្តើរ កាលពោលហើយ ទើបបញ្ជូនកុមារទៅ ។ កុមារ នោះកាលទៅដល់ហើយក៏បានជាឧបរាជ កាលព្រះបិតាសោយទិវង្គតហើយ បានគ្រងរាជសម្បត្តិ ។ ឱរសមួយអង្គរបស់ព្រះរាជាប្រសូតហើយ ។ ព្រះ រាជឱរសនោះ ក្នុងពេលមានវស្សា ១៦ ឆ្នាំ ព្រោះល្មោភក្នុងរាជសម្បត្តិគិត ថា នឹងផ្តាច់ព្រះជន្មព្រះបិតា ព្រោះល្មោភក្នុងរាជសម្បត្តិទើបត្រាស់នឹងឧបដ្ឋាក គឺមហាតលិកទាំងឡាយថា ព្រះបិតារបស់យើងនៅក្មេង យើងរង់ចាំពេល ថ្វាយព្រះភ្លើងព្រះបិតានេះ ក៏នឹងទៅជាមនុស្សចាស់ព្រោះជរា ប្រយោជន៍អ្វី ដោយរាជសម្បត្តិ ដែលបានក្នុងកាលបែបនោះ ។ ឧបដ្ឋាកទាំងនោះទូលថា បពិត្រព្រះសម្មតិទេព ទ្រង់មិនអាចទៅកាន់ប្រទេសជាយដែន ហើយធ្វើជា ចោរ ចូរទ្រង់ផ្តាច់ព្រះជន្មព្រះបិតារបស់ទ្រង់ដោយឧបាយឯណាមួយ ហើយ ដណ្តើមរាជសម្បត្តិចុះ ។ ព្រះរាជបុត្តនោះទទួលថា សាធុ ហើយទៅកាន់ទី ជិតស្រះបោក្ខរណី សម្រាប់ស្រង់ក្នុងពេលល្ងាចរបស់ព្រះរាជាខាងក្នុងព្រះរាជ និវេសន៍ បានកាន់ព្រះខ័នឈរដោយតាំងចិត្តថា នឹងសម្លាប់ព្រះបិតានោះក្នុង ទីនេះ ។ ក្នុងពេលល្ងាច ព្រះរាជាទ្រង់ប្រាប់ទាសីឈ្មោះមូសិកា ( នាងកណ្តុរ ) ទៅដោយត្រាស់ថា ចូរនាងទៅជម្រះខ្នងស្រះបោក្ខរណីឲ្យស្អាត ហើយចូរមក

យើងនឹងផ្ទួតទឹក ទាសីនោះទៅជម្រះខ្លួនស្រះបោក្ខរណី ក៏ឃើញព្រះរាជកុមារ ទើបព្រះរាជកុមារនោះកាប់ទាសីនោះជាពីរកំណាត់ ហើយទម្លាក់ក្នុងស្រះបោក្ខរណី ព្រោះខ្លាចកម្មរបស់ខ្លួនប្រាកដ ។ ព្រះរាជាបានយាងទៅដើម្បីស្រង់ ។ ជនដទៃពោលថា ថ្ងៃនេះនាងកណ្ដុរជាទាសីមិនទាន់ត្រឡប់មក នាងកណ្ដុរទៅណា នាងកណ្ដុរទៅឯណា ។ ព្រះរាជាត្រាស់គាថាទី ១ ថា

អ្នកផងនិយាយរវើរវាយថា នាងមូសិកាទាសីទៅឯណា ទៅក្នុងទីណា អញតែម្នាក់ឯងដឹងថា នាងមូសិកាទាសី ត្រូវគេសម្លាប់ ( ទម្លាក់ទៅ ) ក្នុងស្រះ ដូច្នេះ ។

ព្រះរាជាបានយាងទៅដល់ច្រាំងស្រះបោក្ខរណី ។ បណ្ដាបទទាំងនោះ បទថា **កុហឹ គតា កត្ថ គតា** ជាពាក្យវេចនៈនៃគ្នានឹងគ្នា ។ បទថា **ឥតិ លាលប្បតី** បានដល់ រវើរវាយយ៉ាងនោះ ។ គាថានេះសម្ដែងអត្ថដល់ព្រះរាជាដែលទ្រង់មិនដឹងសោះថា ជនដែលមិនដឹងរមែងរវើរវាយថា នាងកណ្ដុរជាទាសីទៅណា អញតែម្នាក់ឯងប៉ុណ្ណោះដឹងថា នាងកណ្ដុរត្រូវរាជកុមារកាប់ជាពីរកំណាត់ ហើយបោះទៅក្នុងស្រះបោក្ខរណី ។

ព្រះរាជាបានយាងត្រាស់គាថាទៅដល់ច្រាំងស្រះបោក្ខរណី ។ ព្រះរាជកុមារគិតថា ព្រះបិតារបស់អញបានជ្រាបកម្មដែលអញធ្វើ គិតភ័យហើយរត់ទៅ ប្រាប់រឿងនោះដល់ឧបដ្ឋាក ។ កន្លងទៅ ៧-៨ ថ្ងៃឧបដ្ឋាកនោះ ក៏ទូលដល់ព្រះរាជកុមារនោះទៀតថា បពិត្រព្រះសម្មតិទេព បើព្រះរាជាទ្រង់ជ្រាបសោតគង់មិននៅស្ងៀម ពាក្យនោះគង់ជាពាក្យដែលព្រះរាជានោះត្រាស់ដោយ

គិតស្មាន សូមទ្រង់ផ្តាច់ព្រះជន្មរបស់ព្រះបិតានោះចុះ ។ ស្អែកឡើងព្រះរាជកុមារកាន់ព្រះខ័នទៅប្រថាប់ឈរក្បែរជណ្តើរ ក្នុងពេលដែលព្រះរាជាត្រឡប់មក ព្រះរាជកុមារស្វែងរកឱកាសដើម្បីប្រហារដោយជុំវិញ ។ ព្រះរាជាយាងមកស្វាធ្យាយគាថាទី ២ ថា

អ្នកគិតរកនូវឱកាសនៃការប្រហារដូច្នេះ បែរងឹកងាកដូចសត្វលា ព្រោះហេតុណា ហេតុនោះ អ្នកសម្លាប់នូវនាងមូសិកាទាសី ( ទម្លាក់ទៅ ) ក្នុងស្រះ ប្រាថ្នាដើម្បីស៊ីនូវបាយដំណើបឬ ដូច្នេះ ។

គាថានេះសម្តែងនូវអត្ថនេះ តែព្រះរាជាទ្រង់មិនជ្រាបឡើយថា ព្រោះហេតុដែលអ្នកនោះគិតយ៉ាងនេះ នឹងរកមើលឱកាសប្រហារខាងនោះខាងនេះ ហើយត្រឡប់ទៅដូចលាដូច្នោះ ព្រោះហេតុនោះ ទើបយើងស្គាល់ឯងថា ថ្ងៃមុនឯងសម្លាប់ទាសីឈ្មោះនាងកណ្តុរ ត្រង់ស្រះបោក្ខរណី ថ្ងៃនេះប្រាថ្នានឹងសម្លាប់ព្រះបាទយវរាជទៀតឬ ។

ព្រះរាជកុមារតក់ស្លុតក្នុងព្រះហឫទ័យរត់ទៅដោយគិតថា ព្រះបិតាឃើញអញហើយ ។ កុមារនោះឲ្យពេលវេលាកន្លងទៅប្រមាណកន្លះខែហើយគិតថា អញនឹងយកដំបងប្រហារព្រះរាជា ឲ្យស្លាប់ ទើបកាន់ដំបងវែងមួយសម្រាប់ប្រហារព្រះរាជាហើយឈរប្រចាំ ។ ព្រះរាជាទ្រង់ស្វាធ្យាយគាថាទី ៣ ថា

ម្នាលអ្នកឥតប្រាជ្ញា អ្នកជាបុគ្គលនៅក្មេងតូចតាំងនៅក្នុងបឋមវ័យ កាន់យកនូវគ្រឿងប្រហារ មានដងដ៏វែងនេះ យើងមិនឲ្យ

ជីវិតដល់អ្នកទេ ដូច្នេះ ។

ហើយទ្រង់យានដល់ក្បាលជណ្តើរ ។

បណ្តាបទទាំងនោះ បទថា **បឋមុប្បត្តិកោ** បានដល់ កើត គឺប្រកប ដោយបឋមវ័យ អធិប្បាយថា តាំងនៅក្នុងបឋមវ័យ ។ បទថា **សុសូ** បាន ដល់ នៅកំលោះ ។ បទថា **ឱឃំ** បានដល់ ដំបងសម្រាប់ប្រហារ មានដង វែង ។ បទថា **សមាសជ្ជ** សេចក្តីថា ឯងមកឈរប្រចត់ទុក ។ គាថានេះក៏ជា គាថាសម្មុតព្រះរាជាកុមារ សម្តែងនូវសេចក្តីនេះសម្រាប់ព្រះរាជាដែលមិនដឹង នោះឯងថា បុរសល្ងង់នឹងមិនបានប្រើប្រាស់វ័យរបស់ខ្លួន ឥឡូវនេះ យើង នឹងមិនឲ្យជីវិតដល់ឯងដែលមិនមានខ្មាស យើងនឹងសម្លាប់ កាត់ឯងជា កំណាត់តូចកំណាត់ធំ ហើយឲ្យដោតដោយលំពែងនោះឯង ។

ថ្ងៃនោះព្រះរាជកុមារនោះមិនអាចគេចរួច ទើបក្រាបទូលថា បពិត្រព្រះ សម្មតិទេព សូមទ្រង់ទុកជីវិតឲ្យដល់ខ្ញុំចុះ ហើយក្រាបចុះទៀបបាទាព្រះរាជា ។ ព្រះរាជាសម្មុតកុមារនោះហើយឲ្យចងដោយច្រវ៉ាក់ ឃុំឃាំងក្នុងគុក ទ្រង់គង់ លើរាជអាសនៈ ដែលប្រដាប់តាក់តែងខាងក្រោមស្វេតច្ឆត្រ ទ្រង់ព្រះតម្រិះ ថា អាចារ្យទិសាបាមោក្ខជាអាចារ្យរបស់អញ ឃើញអន្តរាយនេះដល់អញ ទើបចងគាថា ៣ ឲ្យអញ ដូច្នេះ ហើយត្រេកអរ កាលនឹងបន្លឺឧទាន បាន ត្រាស់នូវគាថាដ៏សេសថា

អញមិនមែនរួច ( អំពីសេចក្តីស្លាប់ ) ព្រោះវិមានលើ
អាកាស ឬព្រោះបុត្តប្រាជកស្មើដោយអវយវៈបានទេ ព្រោះ

ថា អញត្រូវកូនប្រាថ្នា ( នឹងសម្លាប់ ) បានរួចខ្លួនព្រោះគាថា
ទាំងឡាយ ។

បុគ្គលគប្បីសិក្សានូវសុតៈទាំងពួង ទោះបីថោកទាប ឧក្រិដ្ឋ
ឬយ៉ាងកណ្តាល គប្បីដឹងនូវប្រយោជន៍នៃសុតៈទាំងអស់ តែ
មិនគប្បីប្រកបនូវសុតៈទាំងអស់ទេ សុតៈនាំមកនូវប្រយោជន៍
ក្នុងកាលណា កាលប្រាកដដូច្នោះ រមែងមានប្រាកដ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាន្ទលិក្ខភវេនេន** សេចក្តីថា ទិព្វវិមានលោក
ហៅថាកពក្នុងអាកាស ថ្ងៃនេះអញមិនបានឡើងទៅកាន់កពក្នុងអាកាស ព្រោះ
ដូច្នោះទើបមិនបានផុតចាកសេចក្តីស្លាប់ក្នុងថ្ងៃនេះ ព្រោះភពក្នុងអាកាសនោះ ។
បទថា **ឆាន្ទបុត្តបិនេន វា** សេចក្តីថា ឬអញមិនបានផុតអំពីសេចក្តីស្លាប់
ព្រោះបុត្តដែលប្រាកដស្មើដោយអវយវៈ ។ បទថា **បុត្តេន ហិ បត្ថយិតោ**
សេចក្តីថា យើងកាលបុត្តរបស់ខ្លួនឯងប្រាថ្នានឹងសម្លាប់ក្នុងថ្ងៃនេះ ។ បទថា
**សិលោកេហិ បមោចិតោ** សេចក្តីថា យើងនោះ ជាបុគ្គលផុតចាកសេចក្តី
ស្លាប់ ព្រោះគាថាទាំងឡាយ ដែលអាចារ្យចងឲ្យមក ។ បទថា **សុតំ** បាន
ដល់បរិយត្តិ ។ បទថា **អធីយេថ** បានដល់ គប្បីរៀន គឺគប្បីសិក្សា ។ ដោយ
បទថា **ហីនមុក្កដ្ឋមជ្ឈិមំ** នេះ លោកសម្តែងថា វិជ្ជាដែលរៀន ទោះជាថោក
ថយ កណ្តាលឬឧត្តមក៏ដោយ បុគ្គលគួររៀនទាំងអស់ ។ បទថា **ន ច សព្វំ
បយោជយេ** សេចក្តីថា មិនគួរប្រកបប្រើមន្តជាន់ទាបឬសិប្បៈជាន់កណ្តាល
គួរប្រកបប្រើមន្តជាន់ខ្ពស់ប៉ុណ្ណោះ ។ បទថា **យត្ថ អត្ថាវហំ សុតំ** សេច

ក្តីថា សិប្បៈដែលបានសិក្សាហើយ ប្រភេទណានីមួយ ដូចជាការសូទ្ធាំង របស់មហោសថបណ្ឌិត រមែងនាំប្រយោជន៍មកឲ្យក្នុងកាលណា កាលនោះ រមែងមាននោះឯង ។

ក្នុងកាលតមក កាលព្រះបិតាសោយទិវង្គតហើយ ព្រះរាជកុមារក៏បាន តាំងនៅក្នុងរាជសម្បត្តិ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើប ទ្រង់ប្រជុំជាតកថា អាចារ្យទិសាបាមោក្ខក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មូសិកជាតក ចប់

# ចុល្លធនុគ្គហជាតក

[ ១១៧ ] ( ស្ត្រីនោះនិយាយថា ) ម្នាលព្រាហ្មណ៍ អ្នកនាំយកទ្រព្យទាំងអស់ ឆ្លងទៅកាន់ត្រើយនាយ ម្នាលអ្នកដ៏ចម្រើន អ្នកចូរត្រឡប់មកវិញយ៉ាងឆាប់រួសរាន់ សូមអ្នកចម្លងខ្ញុំឥឡូវនេះផង ។

[ ១១៨ ] ( ចោរនិយាយថា ) នាងផ្លាស់ប្តូរយកអញអ្នកមិនស្និទ្ធស្នាល ដោយប្តីដែលស្និទ្ធស្នាលអស់កាលយូរ ផ្លាស់ប្តូរយកអញដែលមិនមែនជាប្តីទៀងទាត់ដោយប្តីទៀងទាត់ នាងនឹងផ្លាស់ប្តូរយកប្រុសឯទៀតនឹងអញមិនខានអញនឹងទៅកាន់ទីឆ្ងាយជាងទីនេះ ។

[ ១១៩ ] ( ចចកនិយាយថា ) ស្ត្រីនេះជាអ្វី ទើបធ្វើនូវសំណើចយ៉ាងខ្លាំងទៀបគុម្ពរំទឹក ការរាំក្តី ច្រៀងក្តី ប្រគំក្តី ដែលគេតាំងទុកដោយល្អក្នុងទីនេះមិនមានទេ ម្នាលស្ត្រីមានត្រគាកល្អ មានរូបល្អ ហេតុដូចម្តេចទើបនាងសើចក្អាកក្អាយក្នុងកាលគួរយំ ។

[ ១២០ ] ( នាងនោះនិយាយថា ) ម្នាលចចកជម្ពុកៈពាលឥតប្រាជ្ញាឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រីនិងដុំសាច់ សញ្ជប់សញ្ជឹងដូចសត្វកំព្រា ។

[ ១២១ ] ( ចចកនិយាយថា ) ទោសរបស់ជនទាំងឡាយឯទៀតឃើញបានដោយងាយ ចំណែកខាងទោសរបស់ខ្លួនឃើញបានដោយក្រណាស់នាងឯងជាស្ត្រីសាបសូន្យចាកប្តី និងសហាយ សញ្ជប់សញ្ជឹងជាងអញទៅទៀត ។

[ ១២២ ] ( នាងនោះនិយាយថា ) ម្នាលស្តេចម្រឹគជម្ពុកៈ អ្នកនិយាយយ៉ាងណា ពាក្យនុ៎ះយ៉ាងហ្នឹងហើយ ខ្ញុំនោះទៅអំពីទីនេះ នឹងលុះអំណាចប្តីដោយពិត ។

[ ១២៣ ] ( សក្កទេវរាជពោលថា ) អ្នកណាហ៊ានលួចភាជន៍ដី អ្នកនោះគង់ហ៊ានលួចភាជន៍សំរិទ្ធទៀត បាបដែលនាងបានធ្វើរួចហើយ នាងនឹងធ្វើយ៉ាងនេះទៀតមិនលែងឡើយ ។

## ចប់ ចុល្លធនុគ្គហជាតកទី ៤ ។

# អដ្ឋកថា

# ចុល្លធនុគ្គហជាតក

[ ១១៧-១២៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលត្រូវបុរាណទុតិយិកាលួងលោម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សព្វំ ភណ្ឌំ** ដូច្នេះជាដើម ។

( ព្រះសាស្តាត្រាស់ថាម្នាលភិក្ខុអ្នកណាធ្វើឲ្យអផ្សុក ) កាលភិក្ខុនោះក្រាបទូលថា អតីតករិយារបស់ខ្ញុំព្រះអង្គធ្វើឲ្យខ្ញុំព្រះអង្គឲ្យអផ្សុក ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ស្រីនេះធ្វើនូវសេចក្តីវិនាសឲ្យដល់អ្នក ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្រីនេះត្រូវគេ

កាត់ក្បាលដោយដាវ កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វជាសក្កទេវរាជ ។ ក្នុងកាលណោះ ព្រាហ្មណ៍កំលោះអ្នកក្រុងពារាណសីម្នាក់ រៀនសិល្បសាស្ត្រទាំងពួងក្នុងនគរតក្កសិលា បានដល់នូវការសម្រេចក្នុងវិជ្ជាធ្នូ មានឈ្មោះប្រាកដថា ចូឡធនុគ្គហបណ្ឌិត ។ កាលនោះអាចារ្យរបស់ចូឡធនុគ្គហបណ្ឌិតនោះគិតថា មាណពនេះ រៀនសិល្បសាស្ត្របានដូចអញ ទើបឲ្យធីតារបស់ខ្លួន ។ ចូឡធនុគ្គហបណ្ឌិតនាំកិរិយាធ្វើដំណើរទៅដោយបំណងថានឹងទៅកាន់ក្រុងពារាណសី ។ ក្នុងរវាងផ្លូវ ដំរីមួយបានធ្វើទីមួយកន្លែងឲ្យស្ងាត់មនុស្ស អ្នកណាមួយមិនហ៊ានទៅកាន់ទីនោះ ។ ចូឡធនុគ្គហបណ្ឌិត កាលមនុស្សទាំងឡាយនាំគ្នាឃាត់ ក៏នាំកិរិយាទៅកាន់មាត់ព្រៃ ។ កាលនោះ ដំរីបានប្រាកដឡើង ដល់ចូឡធនុគ្គហបណ្ឌិតនោះក្នុងកណ្តាលព្រៃ ទើបគេដកព្រួញបាញ់ដំរីនោះត្រង់ក្បាលឲ្យធ្លុះដល់ខាងក្រោយ ដំរីដួលចុះក្នុងទីនោះឯង ។ ធនុគ្គហបណ្ឌិត បានធ្វើទីនោះឲ្យផុតភ័យ ហើយបានទៅដល់ព្រៃមួយខាងមុខទៀត ។ ក្នុងព្រៃនោះមានចោរ ៥០ នាក់ចាំប្លន់អ្នកដំណើរ ធនុគ្គហបណ្ឌិតនោះ កាលមនុស្សទាំងឡាយនាំគ្នាឃាត់ ក៏នៅតែចូលទៅកាន់ព្រៃនោះ ។ គាត់បានទៅដល់លំនៅរបស់ចោរទាំងនោះ ដែលសម្លាប់ម្រឹគហើយ កំពុងអាំងសាច់បរិភោគក្បែរផ្លូវ ។ កាលនោះចោរទាំងឡាយឃើញធនុគ្គហបណ្ឌិតនោះ មកជាមួយកិរិយាដែលតាក់តែងកាយស្អាត

ទើបធ្វើនូវឧស្សាហៈថា យើងនឹងចាប់បុរសកាន់ផ្នូនេះ ។ មេចោរជាអ្នកឈ្លាស ក្នុងលក្ខណៈរបស់បុរស ឃើញធនុគ្គហបណ្ឌិតនោះប៉ុណ្ណោះ ក៏ដឹងថា បុរស នេះជាឧត្តមបុរស ទើបមិនឲ្យចោរណាម្នាក់ក្រោកឡើង ។ ធនុគ្គហបណ្ឌិត បញ្ជូនកិរិយាទៅកាន់សម្នាក់របស់ចោរទាំងនោះ ដោយប្រាប់ថា ចូរនាងទៅ និយាយថា សូមលោកទាំងឡាយ ឲ្យសាច់អាំងមួយ ប្រទួចដល់យើងទាំង ពីរ ហើយនាំសាច់មក ។ កិរិយានោះ បានទៅពោលថា សូមលោកទាំងឡាយ ឲ្យសាច់អាំងមួយប្រទួច ។ មេចោរគិតថា បុរសនេះមានតម្លៃកាត់ថ្លៃមិនបាន ទើបឲ្យសាច់អាំង ។ ពួកចោរពោលថា ពួកយើងនឹងស៊ីសាច់ឆ្អិន ទើបឲ្យ សាច់អាំងមិនទាន់ឆ្អិនទៅ ។ ធនុគ្គហៈលើកតម្កើងខ្លួនទើបខឹងនឹងចោរពោល ថា ឯងឲ្យសាច់ឆៅដល់យើង ពួកចោរក៏ក្រោកថា អាប៉ុណ្ណោះជាកូនប្រុស ពួកយើងជាកូនស្រីឬ ទើបនាំគ្នាក្រោកឡើង ធនុគ្គហបណ្ឌិត បាញ់ចោរ ៤៩ នាក់ ដោយព្រួញ ៤៩ ឲ្យដួលចុះ ។ ព្រួញមិនមានសម្រាប់បាញ់មេចោរ បានឮថាបំពង់ព្រួញរបស់គាត់មានព្រួញ ៥០ ប៉ុណ្ណោះ បណ្ដាព្រួញទាំងនោះ គាត់បាញ់ដំរីអស់មួយ ទើបបាញ់ពួកចោរដោយព្រួញដែលសល់ ៤៩ ហើយ ធ្វើឲ្យមេចោរដួលចុះ ។ អង្គុយសង្កត់លើទ្រូងមេចោរនោះគិតថា អញនឹងកាត់ ក្បាលរបស់មេចោរទើបឲ្យកិរិយាហុចដាវមក កិរិយានោះធ្វើសេចក្ដីស្រឡាញ់ ក្នុងចោរក្នុងរំពេចនោះ ទើបដាក់ដងដាវត្រង់ដៃចោរ ដាក់ផ្លែដាវត្រង់ដៃរបស់ ប្ដី មេចោរបានចាប់ដងដាវ កាត់ក្បាលរបស់ធនុគ្គហបណ្ឌិត ។ មេចោរនោះ កាលសម្លាប់ធនុគ្គហបណ្ឌិតហើយ ទើបនាំយកស្ត្រីនោះទៅ សួរដល់ជាតិនិង

គោត្ត ។ នាងប្រាប់ថាខ្ញុំជាកូនស្រីរបស់អាចារ្យទិសាបាមោក្ខក្នុងនគរតក្កសិលា មេចោរសួរថា បុរសនេះបាននាងដោយហេតុអ្វី នាងពោលថា ឪពុកខ្ញុំត្រេកអរថា នាយធនុគ្គហៈនេះសិក្សាសិប្បៈបានដូចគាត់ទើបឲ្យខ្ញុំដល់នាយធនុគ្គហៈនេះ ខ្ញុំមានសេចក្តីស្នេហាក្នុងលោក ទើបឲ្យសម្លាប់ប្តីដែលត្រកូលទុកដាក់ឲ្យដល់ខ្ញុំចោល ។ ចោរដើរបណ្តើរគិតបណ្តើរថា ស្រីនេះ ឲ្យសម្លាប់ប្តីដែលត្រកូលទុកដាក់ កាលឃើញប្រុសដទៃក៏នឹងធ្វើយ៉ាងនោះដល់អញទៀត អញគួរចោលស្រីនេះ កាលទៅដល់ពាក់កណ្តាលផ្លូវបានឃើញស្ទឹងតូចមួយដែលរាក់មានទឹកពេញមកម្តងម្កាល ទើបពោលថា នែនាង ក្រពើក្នុងស្ទឹងនេះកាចពួកយើងនឹងធ្វើដូចម្តេច នាងពោលថា សូមអ្នកធ្វើគ្រឿងអាភរណៈ ឲ្យជាបង្វេច ខ្ចប់ដោយសំពត់ដណ្តប់របស់ខ្ញុំ នាំទៅកាន់ត្រើយនាយ ហើយសឹមត្រឡប់មកយកខ្ញុំ ។ មេចោរនោះទទួលថា សាធុ ទើបកាន់យកគ្រឿងអាភរណៈទាំងអស់ ចុះកាន់ស្ទឹង ធ្វើជាហែលឆ្លងទៅ ដល់ត្រើយនាយហើយ ក៏ទុកនាងចោលហើយទៅ ។ ស្រីនោះឃើញដូច្នោះ ទើបពោលថា ហេតុអ្វីទើបអ្នកលះបង់ខ្ញុំ ព្រោះហេតុអ្វីទើបអ្នកធ្វើយ៉ាងនេះ មកយកខ្ញុំទៅផង កាលចរចាជាមួយចោរនោះ ទើបពោលគាថាទី ១ ថា

ម្នាលព្រាហ្មណ៍ អ្នកនាំយកទ្រព្យទាំងអស់ ឆ្លងទៅកាន់ត្រើយ
នាយ ម្នាលអ្នកដ៏ចម្រើន អ្នកចូរត្រឡប់មកវិញយ៉ាងឆាប់រួស
រាន់ សូមអ្នកចម្លងខ្ញុំឥឡូវនេះផង ដូច្នេះ ។

បណ្តាបទទាំងនោះបទថា **លហុំ ឲិប្បំ** សេចក្តីថា ចូរអ្នកប្រញាប់ត្រឡប់

មក អ្នកដ៏ចម្រើន ចូរអ្នកប្រញាប់នាំខ្ញុំឆ្លងទៅឥឡូវនេះផង ។

មេចោរបានស្តាប់ដូច្នោះ ឈរនៅត្រើយម្ខាងនោះឯង ទើបពោលគាថាទី ២ ថា

នាងផ្លាស់ប្តូរយកអញ អ្នកមិនស្និទ្ធស្នាល ដោយប្តីដែលស្និទ្ធ
ស្នាលអស់កាលយូរ ផ្លាស់ប្តូរយកអញដែលមិនមែនជាប្តីទៀង
ទាត់ ដោយប្តីទៀងទាត់ នាងនឹងផ្លាស់ប្តូរយកប្រុសឯទៀតនឹង
អញមិនខាន អញនឹងទៅកាន់ទីឆ្ងាយជាងទីនេះ ដូច្នេះ ។

គាថានោះ មានអត្ថដូចពោលខាងដើមនោះឯង ។

ចំណែកមេចោរពោលថា អញនឹងទៅឲ្យឆ្ងាយចូរនាងនៅចុះ កាលស្រីនោះកំពុងស្រែកហៅនោះឯង ក៏នាំយកបង្វិចអាភរណៈគេចទៅ ។ លំដាប់នោះ ស្រីល្ងង់នោះ ដល់នូវសេចក្តីវិនាសបែបនេះ ព្រោះប្រាថ្នាច្រើន ទើបជាមនុស្សឥតទីពឹងបានចូលទៅកាន់គុម្ពរំទឹកមួយក្នុងទីមិនឆ្ងាយ អង្គុយយំ ។

ខណៈនោះ សក្កទេវរាជទ្រង់ប្រមើលមើលលោកសន្និវាស ទ្រង់ឃើញស្ត្រីនោះត្រូវសេចក្តីប្រាថ្នាច្រើនគ្របសង្កត់ ជាអ្នកវិនាសចាកប្តីនិងចោរកំពុងយំ ទ្រង់ព្រះតម្រិះថា អញនឹងផ្ចាញ់ផ្ចាល់ស្រីនេះឲ្យខ្មាស សឹមត្រឡប់មកទើបទ្រង់នាំមាតលីសារថី និងបញ្ចសិខទេវបុត្តយាងមកក្នុងទីនោះ ប្រថាប់ឈរត្រង់ឆ្នេរស្ទឹងហើយទ្រង់ប្រាប់ថា មាតលីចូរធ្វើជាត្រី បញ្ចសិខៈចូរធ្វើជាបក្សី ឯយើងនឹងធ្វើជាឆ្កែចចកពាំដុំសាច់ ទៅកាន់ទីចំពោះមុខរបស់នាង កាលយើងទៅដល់ទីនោះ ចូរឯងលោតឡើងអំពីទឹកមកត្រង់មុខយើង កាលបើ

ដូច្នោះ យើងនឹងទម្លាក់ដុំសាច់ដែលពាំចោល ហើយស្ទុះទៅចាប់ត្រី ខណៈនោះបញ្ចសិខៈដែលកាឡាខ្លួនជាបក្សី ចូរឆាបយកដុំសាច់នោះ ហើរទៅក្នុងអាកាស ឯមាតលីដែលកាឡាខ្លួនជាត្រី ចូរលោតទៅក្នុងទឹកវិញ ទេវបុត្តទាំងពីរទទួលទេវបញ្ជាថា សាធុ ។ មាតលីសារថីបានកាឡាខ្លួនជាត្រី បញ្ចសិខទេវបុត្តបានកាឡាខ្លួនជាបក្សី ។ សក្កទេវរាជកាឡាខ្លួនជាចចកពាំដុំសាច់ទៅកាន់ទីចំពោះមុខនាង ។ ត្រីលោតឡើងអំពីទឹកធ្លាក់ត្រង់មុខចចក ចចកទម្លាក់ដុំសាច់ដែលពាំហើយរត់ទៅដើម្បីចាប់ត្រី ត្រីក៏លោតចូលទៅក្នុងទឹក បក្សីក៏ឆាបយកដុំសាច់ហើរទៅក្នុងអាកាស ចចកមិនបានទាំងពីរយ៉ាងមានមុខអាក្រក់ អង្គុយមើលគុម្ពរំទឹក ។ នាងឃើញដូច្នោះគិតថា ចចកនេះ ត្រូវសេចក្តីប្រាថ្នាច្រើនគ្របសង្កត់ អស់ទាំងសាច់មិនបានទាំងត្រី ទើបសើចខ្លាំង ដូចវាយធ្នាំងឲ្យបែកដូច្នោះ ។ ចចកបានស្តាប់សំណើចនោះទើបពោលគាថាទី ៣ ថា

> ស្ត្រីនេះជាអ្វីទើបធ្វើនូវសំណើចយ៉ាងខ្លាំង ទៀបគុម្ពរំទឹក ការរាំក្តី ច្រៀងក្តី ប្រគំក្តី ដែលគេតាំងទុកដោយល្អក្នុងទីនេះ មិនមានទេ ម្នាលស្ត្រី មានត្រគាកល្អ មានរូបល្អ ហេតុដូចម្តេចទើបនាងសើចក្អាកក្អាយក្នុងកាលគួរយំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាយំ** កាត់បទជា **កា អយំ** ប្រែថា នរណានេះ ។ បទថា **ឯឡគលាគុម្ពេ** បានដល់ ត្រង់គុម្ពរំទឹក ។ ការសើចរហូតឃើញធ្មេញ លោកហៅថា **អហុហាសិយ** ។ ចចកសួរថា អ្នកណាហ្ន៎

*មកសើចរំពងក្នុងគុម្ពឈើនេះ ។ ដោយបទថា* **នយិធ នច្ចំ វា** *នេះ លោកសម្តែងថា ទីនេះការរាំរបស់បុគ្គលណាមួយ ការច្រៀងរបស់បុគ្គលណាមួយ ឬគ្រឿងតូរ្យតន្ត្រីដែលលេងដោយដៃ ដែលរៀបចំទុកល្អហើយ របស់បុគ្គលណាមួយដែលធ្វើហត្ថវិការៈដែលល្អហើយលេង ក៏មិនមាន នាងឃើញអ្វីទើបសើច ។ បទថា* **អនម្ហិកាលេ** *បានដល់ ក្នុងកាលដែលគួរយំ ។ បទថា* **សុស្សោណិ** *បានដល់ អ្នកមានត្រគាកល្អ ។ បទថា* **កិន្នុ ជគ្ឃសិ** *សេចក្តីថា ព្រោះហេតុអ្វីហ្ន៎ ទើបនាងមិនយំក្នុងកាលដែលគួរយំ បែរជាសើចខ្លាំង ។ ចចកកាលសរសើរនាងទើបពោលថា* **សោភនេ** *ប្រែថា នៃស្រីល្អ ។*

*ស្រីនោះបានស្តាប់ដូច្នោះ ទើបពោលគាថាទី ៤ ថា*

> *ម្នាលចចកជម្ពុកៈពាលឥតប្រាជ្ញា ឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រី និងដុំសាច់ សញ្ជប់សញ្ជឹងដូចសត្វកំព្រាដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **ជិណ្ណោ** *បានដល់ ជាអ្នកដល់នូវសេចក្តីវិនាស ។ បទថា* **បេសិត្វ** *បានដល់ ដុំសាច់ ។ បទថា* **កបណោ វិយ ឈាយសិ** *សេចក្តីថា ឯងសុបសៅ គឺសោយសោកទោមនស្ស ដូចបុគ្គលកំព្រាចាញ់ ( ភ្នាល់ ) ដោយកញ្ចប់ទ្រព្យមួយពាន់ដូច្នោះ ។ លំដាប់នោះទើបចចកពោលគាថាទី ៥ ថា*

> *ទោសរបស់ជនទាំងឡាយឯទៀត ឃើញបានដោយងាយ ចំ-ណែកខាងទោសរបស់ខ្លួន ឃើញបានដោយក្រណាស់ នាង*

ឯងជាស្រ្តីសាបសូន្យចាកប្តីនិងសហាយ សញ្ជប់សញ្ជឹងជាង
អញទៅទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ ដោយបទថា **ត្វញ្ចោវ ឈាយសិ** នេះ ព្រះមហាសត្វ កាលនឹងឲ្យនាងខ្មាសហើយ ដោយប្រការដែលខុស ទើបពោលយ៉ាងនេះថា នែស្រីទ្រុស្តសីល មានធម៌ដ៏លាមក អញមិនបានចំណីរបស់អញ តែនាងត្រូវសេចក្តីប្រាថ្នាច្រើនគ្របសង្កត់ មានចិត្តប្រតិព័ទ្ធក្នុងចោរដែលឃើញមួយរំពេច វិនាសចាកសហាយនោះ និងប្តីដែលត្រកូលរៀបចំឲ្យ បើប្រៀបធៀបនឹងអញហើយ នាងកំព្រាជាងអញរាប់រយរាប់ពាន់ដង សញ្ជប់សញ្ជឹង ស្គមស្គាំង ស្ងៀមស្ងាត់ ។ នាងបានស្តាប់ពាក្យរបស់ចចកនោះហើយ ទើបពោលគាថាថា

ម្នាលស្តេចម្រឹគជម្ពុកៈ អ្នកនិយាយយ៉ាងណា ពាក្យនុ៎ះយ៉ាង
ហ្នឹងហើយ ខ្ញុំនោះទៅអំពីទីនេះ នឹងលុះអំណាចប្តីដោយពិត
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆ្វេ** ត្រឹមតែជានិបាតប្រើក្នុងអត្ថថា ពិតប្រាកដ ។ ស្រីនោះពោលថា ខ្ញុំទៅអំពីនេះហើយបានប្តីដទៃទៀត នឹងនៅក្នុងអំណាច គឺប្រព្រឹត្តទៅក្នុងអំណាចរបស់ប្តីនោះដោយពិតប្រាកដនោះឯង ។

លំដាប់នោះ សក្កទេវរាជទ្រង់ស្តាប់ពាក្យរបស់ស្រីទ្រុស្តសីលគ្មានអាចារៈ ទើបត្រាស់គាថាចុងក្រោយថា

អ្នកណាហ៊ានលួចភាជន៍ដី អ្នកនោះគង់ហ៊ានលួចភាជន៍សំរឹទ្ធ

ទៀត បាបដែលនាងបានធ្វើរួចហើយ នាងនឹងធ្វើយ៉ាងនេះទៀត មិនលែងឡើយ ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអត្ថថា នៃនាងដែលឥតអាចារៈ នាងនិយាយអ្វី បុគ្គលណាលួចភាជនៈដីទៅបាន សូម្បីភាជនៈសំរឹទ្ធ ភាជនៈមាសឬភាជនៈប្រាក់ជាដើម បុគ្គលនោះក៏លួចទៅបានដូចគ្នា បាបនេះនាងធ្វើទុកនោះឯង បុគ្គលណាមួយមិនអាចលាងឲ្យដល់នាង នាងនឹងធ្វើយ៉ាងនេះទៀត ពិតប្រាកដ ។

សក្កទេវរាជនោះ កាលទ្រង់ធ្វើនាងឲ្យខ្មាសដោយប្រការចំឡែកយ៉ាងនេះហើយ បានទៅកាន់ឋានរបស់ទ្រង់នោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុអផ្សុកតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ធនុគ្គហបណ្ឌិតក្នុងកាលនោះ បានមកជាភិក្ខុអផ្សុកក្នុងកាលឥឡូវនេះ ស្រីនោះក្នុងកាលនោះ បានមកជាភរិយាចាស់ចំ-ណែកសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ចុល្លធនុគ្គហជាតក ចប់**

# កបោតកជាតក

[ ១២៤ ] ( ក្អែកនិយាយថា ) ឥឡូវនេះអញបានសុខ មិនមានរោគ មិនមានសត្រូវដូចបន្លា ( ព្រោះ ) ព្រាបហើរចេញទៅហើយ ឥឡូវនេះ អញនឹងធ្វើនូវសេចក្តីត្រេកអរនៃចិត្ត ព្រោះថា សាច់និងអន្លក់រមែងញុំាងអញឲ្យមានកម្លាំង ។

[ ១២៥ ] ( ព្រាបនិយាយចំអកថា ) នេះជាកុកអ្វី ជាសត្វមានកំប៉ោយ ជាចោរ មានពពកជាជីតា នែនាងកុកនាងចូរមកខាងអាយ ក្អែកជាសម្លាញ់របស់ខ្ញុំកាច ។

[ ១២៦ ] ( ក្អែកនិយាយថា ) អ្នកមិនគួរសើចនឹងខ្ញុំ ព្រោះឃើញខ្ញុំ ( ដល់នូវសេចក្តីទុក្ខ ) យ៉ាងនេះ ដែលត្រូវកូនអ្នកគ្រួដកស្លាប ប្រឡាក់ដោយម្សៅម៉ដ្ឋ ។

[ ១២៧ ] ( ព្រាបនិយាយថា ) អ្នកមានខ្លួនឆ្ងូតស្អាត ស្រឡាបដោយល្អ ផ្អែតស្កប់ស្កល់ដោយបាយនិងទឹក អ្នកមានកែវពៃទូរ្យព្ធដ៏ក នឹងទៅកាន់នគរកជង្គលៈឬ ។

[ ១២៨ ] ( ក្អែកនិយាយថា ) សត្វជាមិត្តឬជាសត្រូវរបស់អ្នក កុំទៅកាន់នគរកជង្គលៈឡើយ ពួកជនក្នុងនគរនោះ បានបោចរោម ហើយចងប្រឡៅត្រង់ក ។

[ ១២៩ ] ( ព្រាបនិយាយថា ) ម្នាលសម្លាញ់ អ្នកនឹងដល់នូវអំពើយ៉ាងនេះទៀត ព្រោះមារយាទរបស់អ្នកតែយ៉ាងហ្នឹង ភោគៈទាំងឡាយរបស់មនុស្ស មិនមែនសត្វស្លាបបរិភោគបានទេ ។

## ចប់ កបោតកជាតកទី ៥ ។

## ចប់ អឌ្ឍវគ្គទី ៣ ។

### ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីវណ្ណារោហជាតក ១ សីលវីមំសជាតក ១ ហិរិជាតក ១ ខជ្ជោបនកជាតកដែលបុគ្គលបានប្រយោជន៍ ១ ស្វាមានមុខល្អ ១ ( គុម្ពិយជាតក ១ ) សាលិយជាតក ១ មិត្តដ៏ប្រសើរ ១ ចក្ក ១ បលាសជាតក ១ ព្រះរាជកុមារ ( ព្រះនាមទីឃីតិ ) ១ មិគបោតកជាតក ១ បាយដំណើប ១ ចចកពាល ១ កបោតកជាតក ១ រួមជា ១៥ ជាតក ។

### ឧទ្ទានវគ្គ មានក្នុងបញ្ចកនិបាតនោះគឺ

អំពីមណិកុណ្ឌលវគ្គ ( និយាយអំពីបុគ្គលសាបសូន្យចាកដែនជាដើម ) វណ្ណារោហវគ្គ អំពីវគ្គខាងលើមិនស្មើគ្នា វគ្គទាំងឡាយ ២០ ដែលព្រះសុគត សម្តែងទុកល្អហើយ ហៅថាជាតក ព្រះសង្គីតិកាចារ្យបានសម្តែងនូវភាពនៃព្រហ្មចរិយធម៌ដ៏ប្រសើររបស់ព្រះគាថាទាំងឡាយ មានអត្ថព្រមទាំងព្យញ្ជនៈ ( បរិបូណ៌ ) ។

## ចប់ បញ្ចកនិបាត ។

## អដ្ឋកថា

## កាកោតកជាតក

[ ១២៨-១២៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុល្មោភល្មោះមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឥទានិ ខោម្ហិ** ដូច្នេះជាដើម ។

រឿងភិក្ខុល្មោភល្មោះ បានឲ្យពិស្តារហើយដោយរឿងមិនមែនតិច ។ ចំណែកក្នុងជាតកនេះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកល្មោភល្មោះពិតឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គពិតមែន ទើបត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនអ្នកក៏ល្មោភល្មោះមកហើយ ព្រោះតែការល្មោភល្មោះទើបដល់នូវការអស់ជីវិត ហើយទ្រង់នាំយកអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតព្រាបនៅក្នុងកញ្ជ្រោបី ដែលគេធ្វើជាសម្បុកសត្វក្នុងរោងចុងភៅរបស់ពារាណសីសេដ្ឋី ។ គ្រានោះ មានក្អែកមួយចង់ស៊ីត្រីទើបធ្វើមេត្រីជាមួយព្រាបនោះ បាននៅក្នុងកញ្ជ្រោបីនោះដូចគ្នា ។ ថ្ងៃមួយក្អែកឃើញសាច់និងត្រីជាច្រើនគិតថា អញនឹងស៊ីសាច់និងត្រីនេះ ទើបដេកថ្ងូរក្នុងកញ្ជ្រោបីដែលជាសម្បុកនោះឯង សូម្បីព្រាបក៏ពោលថា មកសម្លាញ់ ពួកយើងទៅរកស៊ីទាំងអស់គ្នា ក៏ពោលថា ឆ្អែតឆ្អន់ព្រោះអាហារមិនរលួយ សូមអ្នកទៅចុះ កាលព្រាបនោះទៅហើយក៏គិតថា ចម្រូងចម្រាស គឺសត្រូវ

របស់អញទៅហើយ ឥឡូវនេះ អញនឹងស៊ីត្រីនិងសាច់តាមគាប់ចិត្ត ទើបពោលគាថាទី ១ ថា

ឥឡូវនេះអញបានសុខ មិនមានរោគ មិនមានសត្រូវដូចបន្ទា
( ព្រោះ ) ព្រាបហើរចេញទៅហើយ ឥឡូវនេះ អញនឹងធ្វើ
នូវសេចក្តីត្រេកអរនៃចិត្ត ព្រោះថា សាច់និងអន្ទក់រមែងញុំាង
អញឲ្យមានកម្លាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និប្បតិតោ** បានដល់ ចេញទៅហើយ ។ បទថា **កាកោ** បានដល់ សត្វព្រាប ។ បទថា **ការហាមិទានិ** បានដល់ ឥឡូវនេះអញនឹងធ្វើ ។ បទថា **តថា ហិ មំ មំសសាកំ ពលេតិ** សេចក្តីថា ព្រោះសាច់និងបន្លែដ៏សេសរមែងធ្វើកម្លាំងឲ្យដល់អញដោយពិត ។ អធិប្បាយថា សាច់និងបន្លែរមែងធ្វើឧស្សាហៈដល់អញ ដូចជាពោលថា ចូរក្រោកឡើងបរិភោគចុះ ។

ក្អែកនោះកាលចុងភៅចៀនត្រីសាច់ ហើយចេញទៅអំពីផ្ទះបាយ ដើម្បីឲ្យស្ងួតញើសអំពីខ្លួន ទើបចេញអំពីកន្ត្រក ហើយពួនក្នុងភាជនៈដាក់គ្រឿងផ្សំអាហារឲ្យមានរស ធ្វើឲ្យកើតសំឡេងខ្លាំងគ្រឹកៗ ។ ចុងភៅស្ទុះមកចាប់ក្អែក ដករោមចេញអស់ហើយបុកខ្ញីស្រស់ ម្សៅ គ្រាប់ស្ពៃ ខ្ទឹមនិងទធិផ្អូមលាបពេញខ្លួន ហើយបោះអំបែងចងត្រង់កក្អែកនោះ បានដាក់ក្អែកទុកក្នុងកន្ត្រកនោះឯង ហើយចៀសចេញទៅ ។ ព្រាបត្រឡប់មកឃើញដូច្នោះ កាលចំអកក៏ពោលថា កុកនេះមកអំពីណាហ្ន៎ មកដេកក្នុងកន្ត្រកសម្លាញ់

របស់អញ សម្លាញ់អញកាចណាស់ ត្រឡប់មកហើយ គប្បីសម្លាប់ចោល ទើបពោលគាថា ទី ២ ថា

នេះជាកុកអ្វី ជាសត្វមានកំប៉ោយ ជាចោរ មានពពកជាជីតា

នៃនាងកុក នាងចូរមកខាងអាយ ក្អែកជាសម្លាញ់របស់ខ្ញុំកាច

ដូច្នេះ ។

គាថានោះ មានអត្ថដូចពោលហើយខាងដើមនោះឯង ។ ក្អែកបានស្តាប់ដូច្នោះ ទើបពោលគាថាទី ៣ ថា

អ្នកមិនគួរសើចនឹងខ្ញុំ ព្រោះឃើញខ្ញុំ ( ដល់នូវសេចក្តីទុក្ខ )

យ៉ាងនេះ ដែលត្រូវកូនអ្នកគ្រូដកស្លាប ប្រឡាក់ដោយម្សៅ

ម៉ដ្ឋ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អលំ** ជានិបាតប្រើក្នុងអត្ថថា បដិសេធ ។ បទថា **ជគ្ឃិតាយេ** បានដល់ សើច ។ លោកអធិប្បាយទុកថា ឥឡូវនេះ អ្នកបានឃើញខ្ញុំទទួលសេចក្តីទុក្ខបែបនេះ គឺយ៉ាងនេះ មិនគួរសើច គឺមិនគួរធ្វើនូវការសើចចំអកក្នុងកាលបែបនេះ ។

ព្រាបធ្វើការចំអកនោះឯង ទើបពោលគាថាទី ៤ ទៀតថា

អ្នកមានខ្លួនដូតស្អាតស្រឡាបដោយល្អ ក្អែតស្កប់ស្កល់ដោយ

បាយនិងទឹក អ្នកមានកែវពៃទូរ្យពួដ៏កនឹងទៅកាន់នគរកជង្គលៈ

ឬ ដូច្នេះ ។

បណ្តាបទទាំងនោះ ដោយបទថា **ការេណ្ឌ ច តេ វេឡុរិយោ** នេះ ព្រាប

សាំដោយកអំបែងនោះឯងពោលថា កែវពិទូរ្យរបស់អ្នកប្រដាប់ត្រង់ក អស់កាលមានប្រមាណប៉ុណ្ណោះ អ្នកមិនបានបង្ហាញកែវពិទូរ្យនេះដល់ខ្ញុំសោះ ។ បទថា **កជង្គលំ** នេះ នគរពារាណសីនោះឯងលោកបំណងយកថាជា កជង្គលបទេសក្នុងទីនេះ ។ ព្រាបសួរថា អ្នកចេញអំពីទីនេះ ទៅកាន់ក្រុងកជង្គលៈឬ ។ លំដាប់នោះ ក្អែកពោលគាថាទី ៥ ថា

សត្វជាមិត្តឬជាសត្រូវរបស់អ្នក កុំទៅកាន់នគរកជង្គលៈឡើយ
ពួកជនក្នុងនគរនោះ បានបោចរោម ហើយចងប្រឡៅត្រង់ក
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បិញ្ឆានិ** បានដល់ រោមស្លាបទាំងឡាយ ។ បទថា **តត្ថ លាយិត្វា** សេចក្ដីថា ក្នុងនគរពារាណសីនោះ ជនទាំងឡាយដក ។ បទថា **វដ្ដនំ** បានដល់ អំបែង ។ ព្រាបបានស្ដាប់ដូច្នោះ ក៏ពោលគាថាចុងក្រោយថា

ម្នាលសម្លាញ់ អ្នកនឹងដល់នូវអំពើយ៉ាងនេះទៀត ព្រោះមារ-
យាទរបស់អ្នកតែយ៉ាងហ្នឹង ភោគៈទាំងឡាយរបស់មនុស្សមិន
មែនសត្វស្លាបបរិភោគបានទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុន ចាបជ្ជសិ** សេចក្ដីថា អ្នកនឹងដល់នូវសភាពបែបនេះទៀត ព្រោះប្រក្រតីរបស់អ្នកបែបនេះ ។ ព្រាបនោះ ឲ្យឱវាទក្អែកនោះដោយប្រការដូច្នេះហើយ ក៏មិននៅក្នុងទីនោះ ទទះស្លាបហើរទៅកាន់ទីដទៃហើយ ។ ចំណែកក្អែកក៏ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុល្មោះល្មោភតាំងនៅក្នុងអនាគាមិផល ហើយទ្រង់ប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានមកជាភិក្ខុល្មោះល្មោភក្នុងកាលឥឡូវនេះ ចំណែកព្រាបក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា កបោតកជាតក ចប់**

**អឌ្ឍវគ្គ ចប់**

**បញ្ចកនិបាតជាតក ចប់**

# ជក្កនិបាត ជាតក

## អាចារិយវគ្គ

### អាចារិយជាតក

[ ១៣០ ] ( ព្រះពោធិសត្វទូន្មានថា ) បពិត្រម្ចាស់ផែនដី សូមព្រះអង្គកុំខ្ញាល់ បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្ញាល់ ព្រះរាជាកាលមិនខ្ញាល់តបចំពោះបុគ្គលដែលខឹង រាស្ត្រតែងបូជា អាត្មារមែងប្រៀនប្រដៅមនុស្សក្នុងទីទាំងពួង គឺក្នុងស្រុកឬក្នុងព្រៃ ទីទាបឬទីទួល បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្ញាល់ ។

[ ១៣១ ] ( ព្រះសាស្តាត្រាស់ថា ) នាយទូកក្នុងទន្លេគង្គា ឈ្មោះអាចារិយបិតា តែងចម្លងនូវជនមុន ហើយទើបសុំយកនូវថ្លៃឈ្នួលក្នុងកាលខាងក្រោយ ហេតុនោះ ការឈ្លោះប្រកែករមែងមានដល់គាត់ គាត់ក៏មិនចម្រើនដោយភោគសម្បត្តិទាំងឡាយ ។

[ ១៣២ ] ( តាបសពោធិសត្វទូន្មានថា ) ម្នាលនាយទូក ចូរអ្នកសុំយកថ្លៃចំពោះមនុស្ស ដែលមិនទាន់ឆ្លងទៅកាន់ត្រើយនាយ ឲ្យហើយសិន ព្រោះថាចិត្តមនុស្សដែលឆ្លងហើយផ្សេង ចិត្តរបស់មនុស្សអ្នកស្វែងរកត្រើយ ( ត្រូវការឆ្លង ) ផ្សេង ។

[ ១៣៣ ] អាត្មាតែងប្រៀនប្រដៅមនុស្សក្នុងទីទាំងពួង គឺក្នុងស្រុកឬក្នុងព្រៃ ទីទាបឬទីទួល ម្នាលនាយទូកចូរអ្នកកុំខឹង ។

[ ១៣៤ ] ( ព្រះសាស្តាត្រាស់ថា ) ព្រះរាជាបានប្រទានស្រុកសួយ

ដោយពាក្យប្រៀនប្រដៅណា នាយទូកក៏ទះមាត់ ( ឥសី ) ដោយពាក្យប្រៀនប្រដៅនោះដែរ ។

[ ១៣៥ ] កាជន៍បាយក៏បែក ភរិយាក៏ត្រូវខ្ទួនប្រហារ គភ៌របស់ភរិយាក៏ធ្លាក់ចុះទៅលើផែនដី មនុស្សពាលមិនញុំាងប្រយោជន៍ឲ្យចម្រើន ដោយឱវាទនោះ ដូចជាម្រឹគមិនចម្រើនដោយមាសប្រាក់ ។

## ចប់ អាចរិយជាតកទី ១

# អដ្ឋកថា ចក្កនិបាត

## អាចារិយវគ្គ

### អាចារិយជាតក

[ ១៣០-១៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធតិត្ថនាវិកអ្នកចែវទូកប្រចាំកំពង់មួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **មាសុ កុជ្ឈ ភូមិបតិ** ដូច្នេះជាដើម ។

បានឮថា បុរសអ្នកចែវទូកនោះ ជាមនុស្សល្ងង់ខ្លៅ មិនដឹងគុណរបស់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមឡើយ មិនដឹងគុណរបស់អ្នកដទៃ ព្រោះជាមនុស្សក្រោចគ្រោតគ្រាត ជាអ្នកប្រែប្រួលរហ័ស ។ ថ្ងៃមួយ ភិក្ខុជនបទមួយរូប មកដោយតាំងចិត្តថា អញនឹងធ្វើការឧបដ្ឋាកព្រះសម្ពុទ្ធ ដល់កំពង់ទឹកនាសុីងអចិរវតីក្នុងពេលល្ងាច បាននិយាយនឹងនាយតិត្ថនាវិកយ៉ាងនេះថា នែឧបាសក អាត្មាចង់ចូងត្រើយ សូមញោមឲ្យទូកអាត្មាចុះ នាយតិត្ថនាវិកឆ្លើយថា បពិត្រលោកម្ចាស់ ឥឡូវនេះ ខុសកាលហើយ សូមលោកម្ចាស់នៅត្រង់កន្លែងមួយក្នុងទីនេះចុះ ភិក្ខុពោលថា នែឧបាសក អាត្មានឹងនៅទីណាក្នុងទីនេះ ចូរបញ្ជូនអាត្មាទៅចុះ ។ បុរសនោះក្រោធ និយាយថា មកនេះសមណៈ ខ្ញុំនឹងនាំទៅ ហើយឲ្យព្រះថេរៈចុះទូក មិនអុំទៅត្រង់ បែរជាអុំទៅខាងក្រោម ធ្វើទូកឲ្យឃ្លោង បាត្រនិងចីវររបស់លោកក៏សើម ដល់ច្រាំងដោយលំបាក ឲ្យឡើងលើច្រាំងក្នុងពេលព្រលប់ ។ តមក លោកបានទៅដល់វិហារ ។ ថ្ងៃនោះមិនបានឱកាសឧបដ្ឋាកព្រះពុទ្ធ ស្អែកឡើងទើបចូលទៅ

គាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្តាធ្វើបដិសណ្ឋារៈហើយ កាលត្រូវព្រះសាស្តាត្រាស់សួរថា អ្នកមកដល់ក្នុងកាលណា ក៏ទូលថា បពិត្រព្រះអង្គក្នុងកាលម្សិលមិញនេះ កាលទ្រង់ត្រាស់សួរថា ហេតុអ្វីទើបមកកាន់ទីឧបដ្ឋាកក្នុងថ្ងៃនេះ បានក្រាបទូលសេចក្តីនោះឲ្យទ្រង់ជ្រាប ។ ព្រះសាស្តា កាលទ្រង់ស្តាប់រឿងនោះហើយទើបត្រាស់ថា ម្នាលភិក្ខុ មិនមែនត្រឹមតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន បុរសនេះក៏កាចគ្រោតគ្រាតដូចគ្នា ។ ម្យ៉ាងទៀត បុរសនោះមិនមែនធ្វើតែអ្នកឲ្យលំបាកក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្វើឲ្យបណ្ឌិតលំបាកមកហើយ ត្រូវភិក្ខុនោះទូលអារាធនាទើបទ្រង់នាំមកយករឿងក្នុងអតីតមកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ចម្រើនវ័យហើយបានរៀនសិល្បសាស្ត្រគ្រប់យ៉ាងក្នុងនគរតក្កសិលា ហើយបួសជាឥសី ចិញ្ចឹមអត្តភាពដោយផ្លែឈើតូចធំក្នុងព្រៃហិមពាន្តអស់កាលយូរ ។ ដើម្បីបរិភោគរសជូរប្រៃទើបទៅកាន់នគរពារាណសី ស្នាក់នៅត្រង់ព្រះរាជឧទ្យាន ស្អែកឡើង ទើបទៅកាន់នគរដើម្បីភិក្ខារ ។ គ្រានោះ ព្រះរាជាទតឃើញតាបសដែលមកដល់លានព្រះរាជវាំង ជ្រះថ្លាក្នុងឥរិយាបថរបស់លោក ទើបទ្រង់នាំចូលទៅខាងក្នុងនគរឲ្យឆាន់ស្រេច ទ្រង់ទទួលបដិញ្ញាហើយ ឲ្យនៅក្នុងព្រះរាជឧទ្យាន បានទៅកាន់ទីឧបដ្ឋាកមួយថ្ងៃម្តង ។ ព្រះពោធិសត្វថ្វាយឱវាទដល់ព្រះរាជានោះរាល់ថ្ងៃថា

ថ្វាយព្រះពរមហារាជ ធម្មតាព្រះរាជា គួរវៀរនូវការលុះក្នុងអំណាចអគតិ ៤ ជាអ្នកមិនប្រមាទ សម្បូរដោយខន្តីនិងមេត្តា ករុណា គ្រងរាជ្យដោយធម៌ កាលថ្វាយឱវាទរាល់ៗថ្ងៃ បានពោលគាថា ២ ថា

បពិត្រម្ចាស់ផែនដី សូមព្រះអង្គកុំខ្វាល់ បពិត្រព្រះអង្គប្រ-
សើរលើរថ សូមព្រះអង្គកុំខ្វាល់ ព្រះរាជាកាលមិនខ្វាល់តប
ចំពោះបុគ្គលដែលខឹង រាស្ត្រតែងបូជា អាត្មារមែងប្រៀនប្រដៅ
មនុស្សក្នុងទីទាំងពួង គឺក្នុងស្រុកឬក្នុងព្រៃ ទីទាបឬទីទួល
បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្វាល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រដ្ឋស្ស បូជិតោ** សេចក្តីថា ព្រះរាជាបែបនេះ ជាបុគ្គលដែលប្រជានុរាស្ត្របូជាហើយ ។ បទថា **សព្វត្ថមនុសាសាមិ** សេចក្តីថា បពិត្រមហារាជ អាត្មាកាលនៅក្នុងទីណាមួយ បណ្តាស្រុកជាដើមនេះ ក៏ថ្វាយអនុសាសន៍ព្រះអង្គដោយអនុសាសន៍នេះឯង គឺថ្វាយអនុសាសន៍ក្នុងទីណាមួយ បណ្តាស្រុកជាដើមទាំងនេះ ទោះជាផ្ទះមួយខ្នងក្តី សត្វលោកម្នាក់ក្តី ។ បទថា **មាសុ កុជ្ឈ រថេសភ** សេចក្តីថា អាត្មាថ្វាយអនុសាសន៍ទ្រង់យ៉ាងនេះឯងថា ធម្មតាព្រះរាជាមិនគួរពិរោធ ព្រោះហេតុអ្វី ព្រោះថា ធម្មតាព្រះរាជាទាំងឡាយ មានព្រះបរមរាជឱង្ការជាអាវុធ ជនជាច្រើននឹងដល់នូវការអស់ជីវិត ដោយហេតុត្រឹមតែព្រះឱង្ការរបស់ព្រះរាជាទាំងនោះដែលទ្រង់ពិរោធហើយប៉ុណ្ណោះ ។

ក្នុងថ្ងៃដែលព្រះរាជាយាងមក ព្រះពោធិសត្វ បានពោលគាថាទាំងនេះ

ថ្វាយយ៉ាងនេះ ។ ព្រះរាជាមានព្រះហឫទ័យជ្រះថ្លា បានព្រះរាជទានស្រុកមួយយ៉ាងល្អដែលមានតម្លៃសួយមួយសែនកហាបណៈដល់ព្រះមហាសត្វ ។ ព្រះមហាសត្វទូលបដិសេធ ដោយហេតុនោះ ទើបលោកនៅក្នុងទីនោះអស់កាល ១២ ឆ្នាំ ត្រិះរិះថា អញនៅទីនេះយូរហើយ អញនឹងចារិកទៅកាន់ជនបទមុន ហើយសឹមមកមិនទូលលាព្រះរាជាឡើយ ហៅអ្នកយាមឧទ្យានមកប្រាប់ថា អាត្មាចារិកទៅកាន់ជនបទ ហើយទើបមក ចូរអ្នកទូលឲ្យព្រះរាជាទ្រង់ជ្រាបផង ហើយក៏ចៀសចេញទៅដល់កំពង់ទូកត្រង់ស្ទឹងគង្គា ។ ត្រង់កំពង់នោះ មានអ្នកចម្លងទូក ឈ្មោះអាវារិយបិតា ។ គាត់ជាបុគ្គលពាល មិនស្គាល់គុណរបស់បុគ្គលដែលមានគុណ មិនស្គាល់ឧបាយដើម្បីខ្លួនឯង គាត់ជូនមនុស្សដែលត្រូវការឆ្លងស្ទឹងមុនហើយ ទើបសូមតម្លៃជាក្រោយ កាលឈ្លោះជាមួយបុគ្គលដែលមិនឲ្យតម្លៃ ក៏ប្រើវិធីជេរនិងវាយគ្នាប៉ុណ្ណោះ ទើបបានថ្លៃច្រើន ។ ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែងហើយ បានត្រាស់គាថាទី ៣ ទុក ទ្រង់សំដៅដល់អាវារិយបិតានោះ ដែលមានលាភតិចជាអន្ធពាលយ៉ាងនេះថា

> នាយទូកក្នុងទន្លេគង្គា ឈ្មោះអាវារិយបិតា តែងចម្លងនូវជន
> មុន ហើយទើបសុំយកនូវថ្លៃឈ្នួលក្នុងកាលខាងក្រោយ ហេតុ
> នោះ ការឈ្លោះប្រកែករមែងមានដល់គាត់ គាត់ក៏មិនចម្រើន
> ដោយភោគសម្បត្តិទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាវារិយបិតា** សេចក្ដីថា គាត់មានកូនស្រី

ឈ្មោះ អាភារិយា ដោយឈ្មោះរបស់ធីតានោះ ទើបគាត់បាន ឈ្មោះថា អាភារិយបិតា គឺឪពុករបស់នាងអាភារិយា ។ បទថា **តេនស្ស ភណ្ឌនំ** សេចក្ដីថា ព្រោះហេតុនោះ ទើបគាត់មានការវាយតប់គ្នា ម្យ៉ាងទៀត គាត់មានការវាយតប់គ្នាជាមួយជននោះៗ ដែលសុំថ្លៃឈ្នួលខាងក្រោយ ។

ព្រះពោធិសត្វចូលទៅរកអ្នកចែវទូកនោះហើយ ពោលថា ចូរអ្នកជូនអាត្មាឆ្លងត្រើយចុះ គាត់បានស្ដាប់ពាក្យនោះហើយ ទើបពោលថា សមណៈលោកឲ្យថ្លៃឈ្នួលទូកខ្ញុំប៉ុន្មាន ព្រះពោធិសត្វពោលថា ធម្មតា អាត្មានឹងប្រាប់ការចម្រើននៃភោគទ្រព្យ ការចម្រើននៃអត្ថ ការចម្រើននៃធម៌ឲ្យ ។

អ្នកចែវទូកនោះ បានស្ដាប់ពាក្យនោះហើយ យល់ថា សមណៈនេះនឹងឲ្យអ្វីមួយដល់អញពិត ទើបចម្លង ហើយពោលថា សូមលោកម្ចាស់ឲ្យថ្លៃទូកដល់ខ្ញុំចុះ ព្រះពោធិសត្វឆ្លើយថា សាធុ កាលប្រាប់សេចក្ដីចម្រើននៃភោគៈដល់បុរសនោះទើបពោលគាថានេះថា

ម្នាលនាយទូក ចូរអ្នកសុំយកថ្លៃចំពោះមនុស្ស ដែលមិនទាន់
ឆ្លងទៅកាន់ត្រើយនាយឲ្យហើយសិនព្រោះថាចិត្តមនុស្សដែល
ឆ្លងហើយផ្សេង ចិត្តរបស់មនុស្សអ្នកស្វែងរកត្រើយ ( ត្រូវ
ការឆ្លង ) ផ្សេង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អចារំ** សេចក្ដីថា ចូរអ្នកសុំថ្លៃឈ្នួលនឹងបុគ្គលដែលមិនទាន់ឆ្លង កំពុងឈរក្នុងត្រើយអាយប៉ុណ្ណោះ ទទួលយកថ្លៃដែលបានអំពីបុរសនោះ ទុកក្នុងទីដែលអ្នកគ្រប់គ្រងរក្សាហើយ សឹមជូនឆ្លង

ត្រើយក្នុងកាលជាក្រោយ យ៉ាងនេះ អ្នកនឹងចម្រើនដោយភោគទ្រព្យ ។ បទថា **អញ្ញោ ហិ តិណ្ណស្ស មនោ** សេចក្តីថា នៃអ្នក ព្រោះថា ចិត្តរបស់អ្នកដែលឆ្លងទៅហើយម្យ៉ាង គឺមិនចង់ឲ្យ គិតនឹងទៅតែម្យ៉ាង តែជម្នាបុគ្គលណា មិនទាន់ឆ្លង គឺនឹងឆ្លង បានដល់ បំណងនឹងទៅត្រើយនាយ បុគ្គលនោះចង់ទៅ សូម្បីលើសតម្លៃក៏ឲ្យបាន ចិត្តរបស់បុគ្គលត្រូវការឆ្លងម្យ៉ាង ដូចពោលមកនេះ ព្រោះហេតុនោះ អ្នកគួរសុំនឹងបុគ្គលដែលមិនទាន់ឆ្លងប៉ុណ្ណោះ ដូច្នេះឈ្មោះថា ការចម្រើននៃភោគទ្រព្យទាំងឡាយរបស់អ្នកដូច្នេះឯង ។

អ្នកចែវទូកបានស្តាប់ពាក្យនោះហើយ គិតថា អញនឹងទទួលឱវាទនេះមុន តែឥឡូវនេះ សមណៈនេះនឹងឲ្យអ្វីដទៃទៀតដល់អញ គ្រានោះ ព្រះពោធិសត្វ បានពោលថា នេះជាការចម្រើននៃភោគទ្រព្យរបស់អ្នក ជាបឋម ឥឡូវនេះ ចូរអ្នកស្តាប់នូវការចម្រើននៃអត្ថនិងធម៌ កាលឲ្យឱវាទ ទើបពោលគាថាដូច្នេះថា

អាត្មាតែងប្រៀនប្រដៅមនុស្សក្នុងទីទាំងពួង គឺក្នុងស្រុកឬក្នុង
ព្រៃ ទីទាបឬទីទួល ម្នាលនាយទូកចូរអ្នកកុំខឹង ដូច្នេះ ។

ព្រះពោធិសត្វ កាលប្រាប់សេចក្តីចម្រើននៃអត្ថ និងធម៌ដោយគាថានេះហើយ ទើបពោលថា នេះជាសេចក្តីចម្រើននៃអត្ថ និងសេចក្តីចម្រើននៃធម៌របស់អ្នក តែគេជាមនុស្សក្រាច មិនសម្គាល់ឱវាទនោះថាជាអ្វី ទើបពោលថានៃសមណៈ នេះឬថ្លៃទូកដែលលោកឲ្យខ្ញុំ ព្រះពោធិសត្វឆ្លើយថា ត្រូវហើយ អ្នកចែវទូកពោលថា ខ្ញុំមិនត្រូវការថ្លៃឈ្នួលបែបនេះ ចូរឲ្យថ្លៃឈ្នួលដទៃដល់

ខ្ញុំ ព្រះពោធិសត្វពោលថា ក្រៅអំពីឱវាទនេះ អាត្មាមិនមានអ្វីដទៃឡើយ ។ អ្នកថែវទូកពោលថា បើដូច្នោះ ហេតុអ្វីទើបជិះទូកខ្ញុំ ហើយច្រានតាបសឲ្យដួលត្រង់ឆ្នេរស្ទឹងគង្គា អង្គុយលើដើមទ្រូង ហើយដាល់មាត់ព្រះពោធិសត្វ ។

ព្រះសាស្តាកាលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តាបសបានឲ្យឱវាទព្រះរាជា ហើយបានទទួលព្រះរាជទានស្រុកដែលល្អ ក្នុងរាជសម្នាក់ តែបានឲ្យឱវាទនោះឯងដល់អ្នកថែវទូកអន្ធពាល បែរជាជួបនូវការដាល់មាត់ ដោយប្រការដូច្នេះ ព្រោះហេតុនោះ បុគ្គលកាលឲ្យឱវាទ គួរឲ្យដល់បុគ្គលដែលសមគួរ មិនគួរឲ្យដល់បុគ្គលដែលមិនសមគួរ ដូច្នេះហើយ កាលទ្រង់ត្រាស់ដឹងក្រៃលែងហើយ ទើបត្រាស់គាថានេះថា

ព្រះរាជាបានប្រទានស្រុកសួយ ដោយពាក្យប្រៀនប្រដៅណា
នាយទូកក៏ទះមាត់ ( ឥសី ) ដោយពាក្យប្រៀនប្រដៅនោះ
ដែរ ។

កាលអ្នកថែវទូកនោះកំពុងទះនោះឯង ភរិយាកាន់យកអាហារមក ឃើញតាបស ទើបប្រាប់ថា នៃអ្នក តាបសនេះជាជីតុនប្រចាំរាជត្រកូល អ្នកកុំវាយលោក គាត់ក្រោធហើយពោលថា បើមិនឲ្យយើងវាយតាបសកោងនេះយើងនឹងវាយនាង ហើយក្រោកឡើងវាយភរិយានោះឲ្យដួលចុះ ។ កាលបើដូច្នោះ ថាសបាយក៏ធ្លាក់បែក ។ ទារកក្នុងផ្ទៃរបស់ភរិយាដែលមានគភ៌ចាស់ បានធ្លាក់ចុះត្រង់ផែនដី កាលនោះ ទើបមនុស្សទាំងឡាយនាំគ្នាមកមើល ហើយចាប់បុរសនោះចង ដោយយល់ថាជាចោរសម្លាប់មនុស្ស ហើយនាំទៅថ្វាយ

ព្រះរាជា ។ ព្រះរាជាទ្រង់វិនិច្ឆ័យហើយ ទ្រង់ដាក់រាជអាជ្ញាដល់បុរសនោះ ។

ព្រះសាស្តា ទ្រង់ជាអ្នកត្រាស់ដឹងក្រៃលែងហើយ កាលទ្រង់ប្រកាសសេចក្តីនេះ ទើបត្រាស់ព្រះគាថាចុងក្រោយថា

កាជន៍បាយក៏បែក ភរិយាក៏ត្រូវខ្ញុំប្រហារ គក៌របស់ភរិយាក៏ធ្លាក់ចុះទៅលើផែនដី មនុស្សពាល មិនញ៉ាំងប្រយោជន៍ឲ្យចម្រើនដោយឱវាទនោះដូចជាម្រឹគមិនចម្រើនដោយមាសប្រាក់ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភត្តំ ភិន្នំ** សេចក្តីថា ថាសបាយក៏បែកហើយ ។ បទថា **ហតា** បានដល់ ទះហើយ ។ បទថា **ឆមា** បានដល់ ត្រង់ផែនដី ។ បទថា **មិគោវ ជាតរូបេន** អធិប្បាយថា ម្រឹគជាន់មាស ប្រាក់ កែវមុក្តា ឬកែវមណីជាដើមខ្លះ ដេកសន្តត់ខ្លះ មិនអាចប្រើមាសនោះឲ្យចម្រើន គឺឲ្យកើតប្រយោជន៍ដល់ខ្លួនបាន យ៉ាងណា មនុស្សពន្ធពាលនោះ ក៏យ៉ាងនោះដូចគ្នា ទោះបីស្តាប់ឱវាទដែលបណ្ឌិតឲ្យហើយ ក៏មិនអាចកពូន គឺឲ្យកើតជាប្រយោជន៍ដល់ខ្លួនបាន ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ កាលចប់សច្ចៈ ភិក្ខុនោះតាំងនៅហើយក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា អ្នកចៃវទូកក្នុងកាលនោះ បានមកជាអ្នកចៃវទូកក្នុងកាលឥឡូវនេះឯង ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯតាបសក្នុងកាលនោះ គឺតថាគត ដូច្នេះឯង ។

**អដ្ឋកថា អាវារិយជាតក ចប់**

# សេតកេតុជាតក

[ ១៣៦ ] ( អាចារ្យទិសាបាមោក្ខទូន្មានសេតកេតុព្រាហ្មណ៍ថា ) ម្នាលអ្នក ចូរអ្នកកុំខឹង ព្រោះថាការខឹងជាការមិនល្អទេ អ្នកមិនដែលឃើញ មិនដែលឮនូវទិសជាច្រើនទេ ម្នាលអ្នកឈ្មោះសេតកេតុ មាតាបិតាទុកជាទិស ( ខាងដើម អ្នកប្រាជ្ញទាំងឡាយ ) ពោលថា អាចារ្យទុកជា ( ទិសខាងស្តាំ ) ប្រសើរជាងទិសទាំងឡាយ ។

[ ១៣៧ ] ពួកជនជាគ្រហស្ថ ជាអ្នកឲ្យបាយទឹកនិងសំពត់ ជាអ្នកហៅរក ( នូវអ្នកទទួលទាន ) ណា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ពោលនូវបុគ្គលនោះថាជាទិស ( ខាងលើ ) ម្នាលសេតកេតុ បុគ្គលមានទុក្ខ ត្រឡប់ជាបានសេចក្តីសុខវិញ ព្រោះដល់នូវទិស ( និព្វាន ) ណា ទិសនុ៎ះ ជាទិសដ៏ប្រសើរ ។

[ ១៣៨ ] ( ព្រះរាជាសួរបុរោហិតថា ) ជដិលទាំងឡាយណា ទ្រទ្រង់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រកបដោយមន្ទិល មានសភាពដ៏សៅហ្មង តែងស្វាធ្យាយនូវមន្តទាំងឡាយ ជដិលទាំងនោះ ( ឋិតនៅ ) ក្នុងសេចក្តីព្យាយាមជារបស់មនុស្ស ដឹងច្បាស់នូវលោកនេះ បានរួចចាកអបាយឬទេ ។

[ ១៣៩ ] ( បុរោហិតទូលតបថា ) បពិត្រព្រះរាជា បុគ្គលជាពហុស្សូតធ្វើបាបកម្មទាំងឡាយ មិនប្រព្រឹត្តធម៌ សូម្បីចេះដឹងច្រើន ហើយអាស្រ័យការចេះដឹងនោះ មិនបានដល់នូវការប្រព្រឹត្ត ក៏រមែងមិនបានរួចចាកទុក្ខឡើយ ។

[ ១៤០ ] ( ព្រះរាជាពោលថា ) បុគ្គលអ្នកចេះច្រើន អាស្រ័យនូវការចេះដឹងនោះតែមិនបានដល់នូវការប្រព្រឹត្តក៏រមែងមិនរួចចាកទុក្ខខ្ញុំសម្គាល់

ជាការរេះដឹងមិនមានផលទេ ការប្រព្រឹត្ត ព្រមទាំងការសង្រួមទៀងទាត់ទើបមានផល ។

[ ១៤១ ] ( បុរោហិតទូលថា ) ការរេះដឹងមិនមែនឥតផលទេ ការប្រព្រឹត្ត ព្រមទាំងការសង្រួមនោះឯង ក៏មិនទៀងទាត់ដែរ បុគ្គលដល់នូវកិត្តិសព្ទព្រោះអាស្រ័យការរេះដឹង បុគ្គលមានខ្លួនទូន្មានបានហើយ ដល់នូវព្រះនិព្វានព្រោះការប្រព្រឹត្ត ។

**ចប់ សេតកេតុជាតកទី ២ ។**

## អដ្ឋកថា

## សេតកេតុជាតក

[ ១៣៦-១៤១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហក ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **មា តាត កុជ្ឈិ ន ហិ សាធុ កោធោ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានច្បាស់ក្នុងកុទ្ទាលជាតក ។

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វជាអាចារ្យទិសាបាមោក្ខ ក្នុងនគរពារាណសី បង្រៀនមន្តមាណព ៥០០ នាក់ ប្រធានមាណពទាំងនោះឈ្មោះថាសេតកេតុ ជាមាណពកើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ មានមានះច្រើន ព្រោះអាស្រ័យជាតិត្រកូល ថ្ងៃមួយគាត់ចេញអំពីនគរទៅមួយអន្លើដោយមាណពដទៃៗ បានឃើញចណ្ឌាលម្នាក់

កំពុងចូលព្រះនគរ ទើបសួរថា អ្នកជានរណា កាលចណ្ឌាលឆ្លើយថា ជាចណ្ឌាល ទើបពោលថា វិនាសហ្ន៎ អាចណ្ឌាលកាឡកណ្ណី ឯងចូរទៅខាងក្រោមខ្យល់ ព្រោះខ្លាចខ្យល់ដែលបក់ផាត់ពីខ្លួនរបស់ចណ្ឌាល មកប៉ះពាល់កាយខ្លួន ហើយបានទៅខាងលើខ្យល់ដោយរហ័ស តែចណ្ឌាលដើរលឿនជាង ទើបទៅឈរលើខ្យល់ កាលមានហេតុយ៉ាងនោះ មាណពនោះក៏បានជេរផ្ដាសាយ៉ាងធ្ងន់ថា វិនាសចុះ អាថោកទាប កាឡកណ្ណី ។ មនុស្សចណ្ឌាលកាលបានស្ដាប់ដូច្នោះហើយ ទើបសួរថា លោកជានរណា សេតកេតុពោលថា យើងជាព្រាហ្មណមាណព បុរសចណ្ឌាលសួរថា បើជាព្រាហ្មណ៍ លោកអាចឆ្លើយបញ្ហាដែលខ្ញុំសួរបានដែរឬទេ ព្រាហ្មណ៍ពោលថា អើបាន ចណ្ឌាលពោលថា បើមិនអាចឆ្លើយសោត ខ្ញុំនឹងឲ្យលោក ចូលក្រោមជើងខ្ញុំ មាណពត្រិះរិះឯងហើយពោលថា ឯងសួរមកចុះ ។ កូនចណ្ឌាលឲ្យបរិស័ទ គឺសម្លាញ់របស់មាណពនោះ កាន់យកពាក្យប្ដេជ្ញានោះហើយ សួរបញ្ហាថា បពិត្រមាណព ធម្មតាទិសមានប៉ុន្មាន ព្រាហ្មណ៍ពោលថា ធម្មតាទិសមាន ៤ មានទិសខាងកើតជាដើម ។ ចណ្ឌាលពោលថា ខ្ញុំមិនបានសួរដល់ទិសនោះទេ គ្រាន់តែប៉ុណ្ណេះលោកក៏មិនដឹង មករង្កៀសខ្យល់ដែលបក់ខ្លួនខ្ញុំ ហើយចាប់កបោះមកត្រង់រវាងជើងរបស់ខ្លួន ។ មាណពទាំងឡាយ បានប្រាប់ព្រឹត្តិ ការណ៍នោះដល់អាចារ្យ ។ អាចារ្យបានស្ដាប់ពាក្យនោះហើយ ទើបសួរថា នែបាសេតកេតុ រឿងនេះពិតឬ បានឮថា អ្នកត្រូវចណ្ឌាលឲ្យចូលក្រោមជើង ។

មាណពឆ្លើយថា ពិតហើយលោកអាចារ្យ កូនរបស់ទាសីចណ្ឌាលនោះ

ពោលថា សូម្បីត្រឹមតែទិសក៏មិនដឹង ហើយឲ្យខ្ញុំចូលក្រោមជើងខ្លួន នេះ ខ្ញុំឃើញវាហើយ ខ្ញុំនឹងសងសឹកវា ក្រោធហើយ ជេរប្រទេសកូនចណ្ឌាល នោះ កាលនោះ អាចារ្យកាលឲ្យឱវាទ ក៏ឲ្យឱវាទថា នៃសេតកេតុ អ្នក កុំក្រោធ កូនចណ្ឌាលជាបណ្ឌិត គេមិនបានសួរដល់ទិសនោះ តែសួរដល់ ទិសដទៃ ទិសដែលគេមិនទាន់ឃើញ មិនបានឮ និងមិនបានដឹងនោះឯង មាន ច្រើនជាងទិសដែលគេបានឃើញបានឮ និងបានដឹងមកហើយ ទើបពោល គាថា ២ ថា

ម្នាលអ្នក ចូរអ្នកកុំខឹងព្រោះថាការខឹងជាការមិនល្អទេ អ្នក មិនដែលឃើញមិនដែលឮនូវទិសជាច្រើនទេ ម្នាលអ្នកឈ្មោះ សេតកេតុ មាតាបិតាទុកជាទិស ( ខាងដើម អ្នកប្រាជ្ញទាំង ឡាយ ) ពោលថា អាចារ្យទុកជា ( ទិសខាងស្ដាំ ) ប្រសើរ ជាងទិសទាំងឡាយ ។

ពួកជនជាគ្រហស្ថ ជាអ្នកឲ្យបាយ ទឹក និងសំពត់ ជាអ្នក ហៅរក ( នូវអ្នកទទួលទាន ) ណា អ្នកប្រាជ្ញទាំងឡាយ មាន ព្រះពុទ្ធជាដើម ពោលនូវបុគ្គលនោះថាជាទិស ( ខាងលើ ) ម្នាលសេតកេតុ បុគ្គលមានទុក្ខ ត្រឡប់ជាបានសេចក្ដីសុខវិញ ព្រោះដល់នូវទិស ( និព្វាន ) ណា ទិសនុ៎ះជាទិស ដ៏ប្រសើរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ហិ សាធុ កោធោ** សេចក្ដីថា ធម្មតា

សេចក្តីក្រោធ កាលកើតឡើង រមែងមិនឲ្យដឹងពាក្យជាសុភាសិត និងទុព្ភាសិត ប្រយោជន៍និងមិនមែនប្រយោជន៍ ការឧបការៈនិងមិនឧបការៈ ព្រោះដូច្នោះ សេចក្តីក្រោធមិនល្អឡើយ ។ បទថា **ពហុម្បិ តេ អទិដ្ឋំ** សេចក្តីថា អាចារ្យពោលថា ទិសដែលមិនឃើញដោយភ្នែក និងមិនឮដោយត្រចៀក មានច្រើន ជាងទិសនោះ គឺមាតាបិតាឈ្មោះថា ជាទិសខាងមុខ គឺទិសខាងកើត ព្រោះកើតមុនបុត្តទាំងឡាយ ។ បទថា **អាចរិយមាហុ ទិសតំ បសត្ថា** សេចក្តីថា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមពោលហើយ គឺប្រាប់ បានដល់ សម្តែង ឬពោលថា បពិត្រអាចារ្យទាំងឡាយ បុគ្គលត្រូវសរសើរថា ជាទិសមួយ គឺជាទិសខាងស្តាំ ព្រោះជាបុគ្គលគួរដល់ទក្ខិណា គឺការគោរព ។ បទថា **អគារិនោ** បានដល់ អ្នកគ្រប់គ្រងផ្ទះនោះឯង ។ បទថា **អន្នទាន-វត្ថទា** បានដល់ ជាអ្នកឲ្យបាយ ជាអ្នកឲ្យទឹក និងឲ្យសំពត់ស្លៀកដណ្តប់ ។ បទថា **អវ្ហាយិកា** បានដល់ ជាអ្នកស្រែកនិមន្តថា សូមនិមន្តមកចុះ និមន្តទទួលទេយ្យធម៌ ។ បទថា **តម្បិ ទិសំ វទន្តិ** សេចក្តីថា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ហៅបុរសនោះថា ជាទិសមួយ ។ ដោយបទនេះ អាចារ្យសម្តែងថា គ្រហស្ថទាំងឡាយដែលថ្វាយបច្ច័យ ៤ ឈ្មោះថា ជាទិសនោះ ព្រោះជាទីដែលសមណព្រាហ្មណ៍ទាំងឡាយទ្រទ្រង់ធម៌ និងត្រូវចូលទៅរកដោយទទួលបច្ច័យ ៤ ។ ម្យ៉ាងទៀត សមណៈនិងព្រាហ្មណ៍ទាំងឡាយ ដែលទ្រទ្រង់ធម៌ គឺអវ្ហាយិក ( អ្នកនាំមក ) ព្រោះហៅដោយគុណខ្ពស់ឡើងមក ដោយបំណងថាជាអ្នកឲ្យនូវសគ្គសម្បត្តិក្នុងកាមាវចរដល់គ្រហស្ថ

ទាំងឡាយនោះដែលប្រគេនបាយ ទឹកនិងសំពត់ដណ្តប់ ។ ដោយបទថា **តម្បិ ធិសំ វទន្តិ** លោកអាចារ្យសម្តែងថា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ហៅសមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌នោះថា ជាទិសខាងលើ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា

> មាតាបិតាជាទិសខាងកើត អាចារ្យជាទិសខាងត្បូង កូនប្រពន្ធជាទិសខាងលិច មិត្តអាមាត្យជាទិសខាងជើង ទាសៈនិងកម្មករជាទិសខាងក្រោម សមណព្រាហ្មណ៍ជាទិសខាងលើ គ្រហស្ថក្នុងត្រកូលដែលអាចគ្រប់គ្រងផ្ទះគប្បីនមស្ការទិស ទាំងឡាយនុ៎ះ ដូច្នេះ ។

ពាក្យថា **ឯសា ធិសា** នេះ អាចារ្យសំដៅយកព្រះនិព្វាន ព្រោះថាសត្វទាំងឡាយជាទុក្ខ ព្រោះទុក្ខច្រើនប្រការ មានការកើតជាដើម សម្រេចព្រះនិព្វាននោះហើយ នឹងអស់ទុក្ខ គឺជាអ្នកមានសេចក្តីសុខ ។ ទិសនោះឯង គឺព្រះនិព្វាន ទើបឈ្មោះថាជាទិសដែលសត្វទាំងឡាយមិនធ្លាប់ទៅឡើយ ម្យ៉ាងទៀត ដោយពាក្យថា **ឯសា ធិសា** នោះឯង ទើបអាចារ្យពោលដល់ព្រះនិព្វានថា ជាទិសដ៏កំពូល សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងតេលបត្តជាតកឯកនិបាត ) ថា

> បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្តាប់មាត់មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ ( ព្រះយោគាវចរ ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវ

ចិត្តរបស់ខ្លួន ( ដោយសតិ ) យ៉ាងនោះដែរ ដូច្នេះ ។

ព្រះមហាសត្វប្រាប់ទិសទាំងឡាយដល់មាណព ដោយអាការយ៉ាងនេះ តែមាណពគិតថា អញត្រូវចណ្ឌាលឲ្យចូលក្រោមជើង និងខ្មាសសម្លាញ់ ទើបមិននៅក្នុងទីនោះ ទៅកាន់នគរតក្កសិលា រៀនសិប្បៈគ្រប់យ៉ាង ក្នុងសម្នាក់របស់អាចារ្យទិសាបាមោក្ខ ចប់ហើយ អាចារ្យអនុញ្ញាតឲ្យទៅ ទើបចេញចាកនគរតក្កសិលា រករៀនសិប្បៈគ្រប់លទ្ធិ ទៅដល់ស្រុកជាយដែនមួយ អាស្រ័យស្រុកនោះ ឃើញតាបស ៥០០ ទើបបួសក្នុងសម្នាក់របស់លោក ហើយរៀនសិប្បៈខ្លះ មន្តខ្លះ ចរណៈខ្លះ ឲ្យលោកទាំងនោះដឹង បានជាប្រធានគណៈ មានតាបសទាំងនោះចោមរោម ទៅកាន់នគរពារាណសី ស្អែកឡើង ត្រាច់ភិក្ខាចារ បានទៅដល់លានព្រះរាជវាំង ព្រះរាជាទ្រង់ជ្រះថ្លាក្នុងឥរិយាបថរបស់តាបសទាំងឡាយ និមន្តឲ្យឆាន់ក្នុងព្រះរាជវាំង ហើយទ្រង់ឲ្យតាបសទាំងនោះស្នាក់នៅក្នុងព្រះរាជឧទ្យានរបស់ទ្រង់ ។ ថ្ងៃមួយ ទ្រង់អង្គាសតាបសទាំងឡាយហើយ ត្រាស់ថា ថ្ងៃនេះ ជាពេលល្ងាច ញោមនឹងទៅព្រះរាជឧទ្យានថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ។ សេតកេតុតាបសទៅកាន់ព្រះរាជឧទ្យាន ហើយប្រជុំតាបសពោលថា នែសម្លាញ់រួមជីវិតទាំងឡាយ ថ្ងៃនេះ ព្រះរាជានឹងយាងមក លោកចន្លលបង្ហាញថា ធម្មតាព្រះរាជាទាំងឡាយ ទ្រង់ប្រោសប្រាណម្តង ក៏អាចឲ្យបុគ្គលតាំងជីវិតនៅបានដរាបដល់អស់ជីវិត ថ្ងៃនេះ សូមឲ្យពួកយើង ដើរជាក្រុមៗទៅ ពួកខ្លះដេកលើបន្លា ពួកខ្លះបំពេញតបៈ ៥ យ៉ាង ពួកខ្លះប្រកបព្យាយាមអង្គុយប្រហោង ពួកខ្លះចុះទឹក ពួកខ្លះស្វាធ្យាយ

មន្ត ដូច្នេះហើយ ខ្ជននអ្នកអង្គុយលើតាំងដែលមិនមានបង្អែក ត្រង់ទ្វារបណ្ណសាលា ដាក់គម្ពីរមួយដែលរុំរឿងដោយវត្ថុដែលមានពណ៌ ៥ ទុកលើជើងអាធារ ហើយឆ្លើយបញ្ហាដែលមាណព ៤-៥ នាក់សាកសួរ ។ ខណៈនោះព្រះរាជាយាងមក ទតឃើញតាបសទាំងនោះ បំពេញមិច្ឆាតបៈ គឺតបៈខុសព្រះរាជហឫទ័យ ទើបយាងទៅរកសេតកេតុតាបស ទ្រង់ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង កាលទ្រង់ប្រាស្រ័យជាមួយបុរោហិតទើបត្រាស់គាថាទី ៣ ថា

> ជដិលទាំងឡាយណា ទ្រទ្រង់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រកបដោយមន្ទិលមានសភាពដ៏សៅហ្មងតែងស្វាធ្យាយនូវមន្តទាំងឡាយ ជដិលទាំងនោះ ( ឋិតនៅ ) ក្នុងសេចក្តីព្យាយាមជារបស់មនុស្ស ដឹងច្បាស់នូវលោកនេះបានរួចចាកអបាយឬទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខរាជិនា** បានដល់ ដែលស្លៀកដណ្តប់សំពត់ស្បែកសត្វមានក្រចក ។ បទថា **បង្កទន្តា** បានដល់ មានធ្មេញប្រកបដោយមន្ទិល ព្រោះធ្មេញមិនស្អាត ។ បទថា **ទុមុក្ខរូបា** បានដល់ មានសំពត់ដណ្តប់សៅហ្មង មិនបានបោកគក់ មិនបានតាក់តែង គឺវៀរចាកកម្រងផ្កានិងគ្រឿងលាប ។ មានអធិប្បាយថា បានដល់ មានរូបមិនស្អាត ។ បទថា **យេមេ ជបន្តិ** សេចក្តីថា ជដិលទាំងនេះបានរាយមន្ត ។ បទថា **មានុសិកេ បយោគេ** សេចក្តីថា តាំងនៅហើយក្នុងព្យាយាមដែលមនុស្សទាំង

ឡាយត្រូវធ្វើ ។ បទថា **ឥធំ វិទូ បរិមុត្តា អបាយា** សេចក្ដីថា សួរថា ឥសីទាំងនោះ កាលតាំងនៅក្នុងសេចក្ដីព្យាយាម ដឹងនូវលោកនេះហើយ គឺ ធ្វើឲ្យប្រាកដហើយ នឹងផុតចាកអបាយទាំង ៤ បានឬហ្ន៎ ។

បុរោហិតស្ដាប់ព្រះតម្រាស់នោះហើយ បានទូលគាថាទី ៤ ថា

បពិត្រព្រះរាជា បុគ្គលជាពហុស្សូត ធ្វើបាបកម្មទាំងឡាយ មិនប្រព្រឹត្តធម៌ សូម្បីចេះដឹងច្រើន ហើយអាស្រ័យការចេះដឹង នោះ មិនបានដល់នូវការប្រព្រឹត្ត ក៏រមែងមិនបានរួចចាកទុក្ខ ឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ករិត្វា** បានដល់ **កត្វា** ប្រែថា ធ្វើហើយ បទថា **ចរណំ** បានដល់ សមាបត្តិ ៨ មួយអន្លើដោយសីល ។ មានពាក្យ អធិប្បាយថា បពិត្រមហារាជ បុគ្គលណាសម្គាល់ថា យើងជាពហូសូត មាន ការចេះដឹងរាប់ពាន់ តែមិនប្រព្រឹត្តសុចរិត ៣ យ៉ាង ធ្វើបាបតែម្យ៉ាង បុគ្គល នោះកាលធ្វើបាបកម្មទាំងនោះហើយ អាស្រ័យភាពជាពហូសូតនោះ តែមិន សម្រេចចរណៈ ពោលគឺសីលនិងសមាបត្តិ ក៏គង់មិនផុតទុក្ខ គឺមិនផុតចាក អបាយទុក្ខបានឡើយ ។

ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ ទ្រង់ប្រាសចាកនូវសេចក្ដីជ្រះថ្លាក្នុង តាបសទាំងឡាយ លំដាប់នោះ ទើបសេតកេតុតាបសគិតថា ព្រះរាជានេះ បានកើតសេចក្ដីជ្រះថ្លាក្នុងតាបសទាំងឡាយហើយ ។ តែបុរោហិតនេះ ដក នូវការជ្រះថ្លានេះ ដូចយកកាំបិតកាត់ អញគួរទូលព្រះរាជានោះ កាលទូល

ព្រះរាជា បានថ្វាយគាថាទី ៥ ថា

បុគ្គលអ្នកចេះច្រើន អាស្រ័យនូវការចេះដឹងនោះ តែមិនបាន ដល់នូវការប្រព្រឹត្ត ក៏រមែងមិនរួចចាកទុក្ខ ខ្ញុំសម្គាល់ថា ការចេះដឹងមិនមានផលទេ ការប្រព្រឹត្តព្រម ទាំងការសង្រួមទៀងទាត់ ទើបមានផល ដូច្នេះ ។

គាថានោះ មានអត្ថដូចតទៅនេះថា សូម្បីបុគ្គលមានមន្ត គឺវេទរាប់ពាន់បទ អាស្រ័យភាពជាពហុស្សូតនោះ តែមិនទាន់សម្រេចចរណៈ ក៏ដោះខ្លួនចេញចាកទុក្ខមិនបាន កាលបើដូច្នោះ ទើបអាត្មាយល់ថា វេទ ៣ ជាវត្ថុដែលឥតផល ចរណៈដែលមានសីល អាស្រ័យសមាបត្តិ ៨ ប៉ុណ្ណោះ ជារបស់ពិត ។

បុរោហិតបានស្តាប់ពាក្យនោះហើយ ទើបពោលគាថាទី ៦ ថា

ការចេះដឹងមិនមែនឥតផលទេការប្រព្រឹត្តព្រមទាំងការសង្រួមនោះឯង ក៏មិនទៀងទាត់ដែរ បុគ្គលដល់នូវកិត្តិសព្ទព្រោះអាស្រ័យការចេះដឹង បុគ្គលមានខ្លួនទូន្មានបានហើយ ដល់នូវព្រះនិព្វានព្រោះការប្រព្រឹត្ត ដូច្នេះ ។

គាថានោះ មានអត្ថដូចតទៅនេះ គឺមិនមែនវេទ ៣ មិនមានផល មិនចំពោះចរណៈមួយអន្លើការសង្រួមវាំងប៉ុណ្ណោះជារបស់ពិត គឺល្អជាង បានដល់ ឧត្តម សេចក្តីថា ប្រសើរ ព្រោះហេតុអ្វី ព្រោះបុគ្គលអាស្រ័យវេទរមែងបានទទួលកិត្តិយស គឺអាស្រ័យវេទ ៣ យ៉ាង បានទទួលត្រឹមតែ

កិត្តិយស ត្រឹមតែលាភប៉ុណ្ណោះ មិនមានជទៃជាងនេះទេ ព្រោះហេតុនោះ ទើបវេទទាំងនោះ ឈ្មោះថា មិនមានផល ។ បទថា **សន្តឹ បុណោតិ ចរណេន ឧន្តោ** សេចក្តីថា បុគ្គលតាំងនៅក្នុងសីល ហើយឲ្យសមាបត្តិកើតឡើង ចម្រើនវិបស្សនាមានសមាបត្តិជាបទដ្ឋានរមែងសម្រេចរមែងស្ងប់ដោយចំណែកមួយ គឺធម៌ដ៏កំពូលដែលមានឈ្មោះថាព្រះនិព្វាន ។

បុរោហិត កាច់បំបាក់នូវពាក្យរបស់សេតកេតុតាបសយ៉ាងនេះហើយបានធ្វើតាបសទាំងនោះឲ្យជាគ្រហស្ថ គឺឲ្យសឹក ឲ្យកាន់ខែលនិងអាវុធ ឲ្យជាការកជន ( ទាហាន ) មួយក្រុមធំ ឲ្យធ្វើការបម្រើព្រះរាជា បានឮថា នេះគឺវង្សរបស់ការកជនក្រុមធំ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សេតកេតុតាបសក្នុងកាលនោះ បានមកជាភិក្ខុកុហក ក្នុងកាលឥឡូវនេះ បុត្តរបស់ចណ្ឌាលក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកបុរោហិត[១]ក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សេតកេតុជាតក ចប់

---

១-សេចក្តីខាងដើមថា ព្រះពោធិសត្វជាអាចារ្យទិសាបាមោក្ខ តែបាលីអដ្ឋកថាលោករៀបរៀងទុកយ៉ាងនេះ ទើបយើងរក្សាទុក ។

# ធីរមុខជាតក

[ ១៤២ ] ( ព្រះបច្ចេកពុទ្ធទីរមុខឲ្យឱវាទដល់ព្រះរាជាព្រហ្មទត្តថា ) កាមទាំងឡាយដូចភក់ផង កាមទាំងឡាយដូចគ្រឿងស្អិតផង នេះជាភ័យមានឫសគល់ ៣ យ៉ាង ដែលព្រះសម្ពុទ្ធពោលទុកហើយ កាមទាំងឡាយ ដូចធូលីផង ដូចផ្សែងផង ដែលអាត្មាប្រកាសហើយ បពិត្រព្រះរាជាព្រហ្មទត្ត សូមព្រះអង្គលះបង់ ( កាមទាំងនោះ ) ហើយបួសចុះ ។

[ ១៤៣ ] ( ព្រះរាជាព្រហ្មទត្តពោលថា ) បពិត្រព្រាហ្មណ៍ ខ្ញុំជាអ្នកជាប់ជំពាក់ ត្រេកអរជ្រុលជ្រប់ក្នុងកាមទាំងឡាយ ជាអ្នកត្រូវការដោយជីវិតមិនអាចដើម្បីលះនូវកាម មានសភាពគួរខ្លាចនោះបានទេ ខ្ញុំនឹងធ្វើបុណ្យទាំងឡាយច្រើន ។

[ ១៤៤ ] ( ព្រះបច្ចេកពុទ្ធពោលថា ) បុគ្គលណា កាលគេប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ប្រៀនប្រដៅ តែមិនធ្វើតាមពាក្យប្រៀនប្រដៅ សម្គាល់ថានេះឯងប្រសើរ ជាមនុស្សល្ងង់ខ្លៅ រមែងចូលទៅកាន់គភ៌ញយៗ ។

[ ១៤៥ ] បុគ្គលល្ងង់ខ្លៅនោះ រមែងចូលទៅកាន់នរក មានសភាពដ៏ពន្លឹក ជាទីមិនស្អាតដល់ពួកកុលបុត្តអ្នកស្អាត ពេញដោយមូត្រនិងករីសសត្វទាំងឡាយណា ជាអ្នកមិនទាន់ប្រាសចាករាគៈ ជាប់ចំពាក់ក្នុងកាមទាំងឡាយសត្វទាំងឡាយនោះរមែងមិនលះបង់នូវសកាយ ( ការនៅក្នុងគភ៌ ) ។

[ ១៤៦ ] សត្វទាំងឡាយប្រសូត ( ចាកគភ៌នៃមាតា ) រមែងជាប់ដោយលាមក ប្រឡាក់ដោយឈាម ជាប់ដោយរំអិល ប៉ះពាល់នូវទ្វារជាទី

ប្រសូតិណាៗដោយកាយ ក្នុងខណៈនោះ ទ្វារទាំងអស់នោះជារបស់មិនស្អាត សុទ្ធតែជាទុក្ខទាំងអស់ ។

[ ១៤៧ ] អាត្មាឃើញទើបពោល មិនមែនស្តាប់អំពីបុគ្គលដទៃទេ អាត្មាវព្រកឃើញនូវបុព្វេនិវាសច្រើន ។ ( ព្រះសម្មាសម្ពុទ្ធត្រាស់ថា ) ព្រះបច្ចេកពុទ្ធ ព្រះនាមទរីមុខៈ ពន្យល់ស្តេចព្រហ្មទត្តមានប្រាជ្ញាល្អ ដោយគាថាទាំងឡាយដ៏វិចិត្រដែលសម្តែងហើយដោយល្អ ។

**ចប់ ទរីមុខជាតកទី ៣ ។**

## អដ្ឋកថា

## ទរីមុខជាតក

[ ១៤២-១៤៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាភិនេស្រ្កមណ៍ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **បង្កោ ច កាមា** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្នបានពោលទុកហើយខាងដើម ។

ក្នុងអតីតកាល ព្រះរាជាព្រះនាមថា មគធរាជ សោយរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ កាលនោះ ព្រះពោធិសត្វកាន់យកកំណើត ក្នុងព្រះឧទរនៃអគ្គមហេសីរបស់ព្រះអង្គ ព្រះញាតិទាំងឡាយ បានថ្វាយព្រះនាម ព្រះអង្គថា ព្រហ្មទត្តកុមារ ។ ក្នុងថ្ងៃដែលព្រះរាជកុមារប្រសូតនោះឯង ឯបុត្តរបស់

បុរោហិតក៏កើត ។ ទឹកមុខរបស់កុមារនោះស្អាតពន់ពេក ព្រោះហេតុនោះទើបញាតិរបស់កុមារឲ្យឈ្មោះថា ទរីមុខ ។

កុមារទាំង ២ នោះ ចម្រើនវ័យហើយក្នុងរាជត្រកូលនោះឯង ។ កុមារទាំងពីរជាសម្លាញ់នឹងគ្នា លុះមានអាយុ ១៦ វស្សា បានទៅកាន់នគរតក្កសិលា រៀនសិល្បសាស្រ្តគ្រប់យ៉ាង ហើយនាំគ្នាត្រាច់ទៅក្នុងគាមនិគម ជាដើម ដោយតាំងចិត្តថា នឹងនាំគ្នាសិក្សាគ្រប់លទ្ធិ និងស្គាល់ចរិតរបស់ទឹកដី ដល់នគរពារាណសី ស្នាក់នៅត្រង់ទេវស្ថាន ។ ស្អែកឡើង នាំគ្នាចូលទៅកាន់នគរពារាណសីដើម្បីភិក្ខា ។ មនុស្សក្នុងត្រកូលនីមួយៗ ក្នុងនគរពារាណសីនោះតាំងចិត្តថា ពួកយើងនឹងអង្គាសព្រាហ្មណ៍ ហើយថ្វាយគ្រឿងបូជា ទើបចម្អិនបាយាស ហើយក្រាលអាសនៈទុក ។ មនុស្សទាំងឡាយឃើញជនទាំង ២ នោះកំពុងត្រាច់ភិក្ខាចារ យល់ថា ព្រាហ្មណ៍មកហើយ ទើបឲ្យចូលទៅក្នុងផ្ទះ ក្រាលសំពត់សទុកសម្រាប់ព្រះមហាសត្វ ក្រាលសំពត់ក្រហមទុកសម្រាប់ទរីមុខកុមារ ។ ទរីមុខកុមារ ឃើញនិមិត្តនោះហើយ ដឹងច្បាស់ថា ថ្ងៃនេះ សម្លាញ់របស់អញនឹងបានជាព្រះបាទពារាណសី ឯអញនឹងបានជាសេនាបតី ។ ជនទាំង ២ បរិភោគក្នុងទីនោះ ហើយទទួលយកគ្រឿងបូជាពោលមង្គលហើយចេញទៅ បាននាំគ្នាទៅដល់ព្រះរាជឧទ្យាននោះ ។ ក្នុងជនទាំង ២ នោះ មហាសត្វផ្ទំហើយលើផ្ទាំងសិលាមង្គល ចំណែកទរីមុខកុមារអង្គុយច្របាច់បាតជើងរបស់ព្រះមហាសត្វនោះ ។ ថ្ងៃនោះ ជាថ្ងៃទី ៧ នៃការសោយទិវង្គត របស់ព្រះបាទពារាណសី បុរោហិតថ្វាយព្រះភ្លើងព្រះ

សព ហើយបានផ្សងបុស្សរថក្នុងថ្ងៃទី ៧ ព្រោះរាជសម្បត្តិ មិនមានវជ្ជទាយាទ កិច្ចដែលទាក់ទងដោយការផ្សងបុស្សរថនឹងមានជាក់ច្បាស់ក្នុង មហាជនកជាតក ។ បុស្សរាជរថចេញពីព្រះនគរទៅ មានចតុរង្គសេនាចោមរោមមួយអន្លើដោយតូរ្យតន្ត្រីច្រើនរយប្រគំ ដល់ទ្វារព្រះរាជឧទ្យាន ។ គ្រានោះទរីមុខកុមារបានឮសំឡេងតូរ្យតន្ត្រីហើយ គិតថាបុស្សរាជរថមកហើយដើម្បីសម្លាញ់របស់អញ ថ្ងៃនេះ សម្លាញ់របស់អញនឹងបានជាព្រះរាជា ហើយនឹងប្រទានតំណែងសេនាបតីដល់អញ ប្រយោជន៍អ្វីរបស់អញ ដោយការគ្រប់គ្រងផ្ទះ អញនឹងចេញបួស ដូច្នេះហើយ ទើបមិនលាព្រះពោធិសត្វ ទៅកាន់ទីសមគួរម្ខាង ហើយបានឈរក្នុងទីកំបាំង ។ បុរោហិតបញ្ឈប់រថ ត្រង់ទ្វារព្រះរាជឧទ្យាន ហើយចូលទៅកាន់ព្រះរាជឧទ្យាន ឃើញព្រះពោធិសត្វផ្ទំលើសិលាមង្គល ត្រួតមើលលក្ខណៈត្រង់ផ្ទៃព្រះបាទ ហើយដឹងថា សត្វនេះជាអ្នកមានបុណ្យ អាចគ្រងរាជសម្បត្តិសម្រាប់មហាទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារបាន តែបញ្ញារបស់បុគ្គលនេះដូចម្តេចហ្ន៎ ទើបឲ្យប្រគំតូរ្យតន្ត្រីទាំងអស់ ។ ព្រះពោធិសត្វ ភ្ញាក់ពីផ្ទំហើយ ទ្រង់នាំសំពត់សាដកចេញអំពីព្រះភក្ត្រ ទ្រង់ទតឃើញមហាជន ហើយទ្រង់យកសំពត់សាដកបិទព្រះភក្ត្រវិញ ផ្ទំបន្តិច រម្ងាប់សេចក្តីក្រវល់ក្រវាយ ហើយក្រោកឡើង ប្រថាប់គង់ពត់ភ្នែនលើផ្ទាំងសិលា ។ បុរោហិតលុតជង្គង់ ហើយទូលថា បពិត្រព្រះសម្មតិទេព រាជសម្បត្តិកំពុងធ្លាក់ដល់ព្រះអង្គ ព្រះពោធិសត្វសួរថា រាជសម្បត្តិមិនមានវជ្ជទាយាទទេឬ បុរោហិតទូលថា មិនមានទេព្រះអង្គ ព្រះ

ពោធិសត្វពោលថា សាធុ បើដូច្នោះ យើងនឹងទទួល ។

មហាជនទាំងនោះ បាននាំគ្នាធ្វើអភិសេកព្រះពោធិសត្វនោះត្រង់ព្រះរាជឧទ្យាននោះឯង ទ្រង់មិនបានរឭកដល់ទរីមុខកុមារ ព្រោះភាពមានយសច្រើន ។ ទ្រង់ឡើងរាជរថ មានបរិវារចោមរោមចូលទៅកាន់ព្រះនគរ ទ្រង់ធ្វើប្រទក្សិណ ហើយប្រថាប់ឈរត្រង់ព្រះរាជនិវេសន៍នោះឯង ទ្រង់ពិចារណាដល់ឋានន្តរៈរបស់អាមាត្យទាំងឡាយ ហើយឡើងកាន់ប្រាសាទ ។ ខណៈនោះ ទរីមុខកុមារគិតថា ឥឡូវនេះ ព្រះរាជឧទ្យានទំនេរហើយ ទើបមកអង្គុយត្រង់សិលាមង្គល ។ លំដាប់នោះស្លឹកឈើទុំបានជ្រុះមកខាងមុខទរីមុខកុមារ ។ កុមារផ្ដើមតាំងនូវការអស់ទៅសូន្យទៅក្នុងស្លឹកឈើទុំនោះឯង ពិចារណាត្រៃលក្ខណ៍ ឲ្យផែនដីកម្រើក ដល់ព្រមដោយបច្ចេកពោធិញ្ញាណកើតឡើងហើយ ខណៈនោះឯងយាវាសភេទក៏អន្តរធានទៅ បាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ ក៏ធ្លាក់ចុះមកអំពីអាកាសស្រោបសរីរៈរបស់លោក ។ រំពេចនោះឯងលោកក៏ជាបុគ្គលទ្រទ្រង់នូវបរិក្ខារ ៨ សម្បូរដោយឥរិយាបថ ដូចព្រះថេរៈមានវស្សា ១០០ ហោះទៅក្នុងអាកាសដោយឫទ្ធិ បានទៅកាន់ញកភ្នំ នន្ទមូលក ទឹកដីព្រៃហិមពាន្ត ។ ឯព្រះពោធិសត្វក៏សោយរាជសម្បត្តិដោយធម៌ តែព្រោះភាពជាអ្នកមានយសច្រើន ទើបទ្រង់ស្រវឹងដោយយស មិននឹកនាដល់ទរីមុខអស់ ៤០ ឆ្នាំ ។ លុះកន្លងទៅ ៤០ ឆ្នាំ ទ្រង់រឭកបានហើយ ទើបត្រាស់ថា ខ្ញុំមានសម្លាញ់ម្នាក់ឈ្មោះថា ទរីមុខ គេនៅឯណាហ្ន៎ ដូច្នេះហើយមានព្រះរាជបំណងនឹងជួបសម្លាញ់នោះ ចាប់តាំងអំពីនោះមក ទ្រង់ក៏ត្រាស់

សួររកខាងក្នុងនគរខ្លះ កណ្តាលបរិស័ទខ្លះថា ទរីមុខកុមារសម្លាញ់របស់ខ្ញុំនៅឯណា អ្នកណាប្រាប់លំនៅរបស់សម្លាញ់នោះដល់ខ្ញុំ ខ្ញុំនឹងឲ្យយសខ្ពង់ខ្ពស់ដល់បុគ្គលនោះ ។ កាលទ្រង់រឭកដល់រឿយៗយ៉ាងនេះ ទើបឆ្នាំដទៃកន្លងទៅទៀតអស់ ១០ ឆ្នាំ ក្នុងកាលកន្លងទៅ ៥០ ឆ្នាំ ព្រះបច្ចេកពុទ្ធព្រះនាមថាទរីមុខ រឭកដល់ ក៏ជ្រាបថា សម្លាញ់នឹកដល់អាត្មាអញ ហើយត្រិះរិះថាឥឡូវនេះ ព្រះពោធិសត្វនោះទ្រង់ព្រះជរា ចម្រើនដោយព្រះរាជឱរសនិងព្រះរាជធីតា អាត្មាអញនឹងទៅសម្តែងធម៌ថ្វាយឲ្យទ្រង់បួស ដូច្នេះហើយ ទើបនិមន្តទៅតាមអាកាសដោយឫទ្ធិ ចុះត្រង់ព្រះរាជឧទ្យាន អង្គុយលើផ្ទាំងថ្ម ដូចបដិមាមាស អ្នករក្សាព្រះរាជឧទ្យានឃើញលោកហើយចូលគាល់ទូលសួរថាបពិត្រលោកម្ចាស់ លោកម្ចាស់និមន្តមកអំពីទីណា ព្រះបច្ចេកពុទ្ធត្រាស់តបថា មកអំពីញកភ្នំនន្ទមូលកៈ អ្នកយាមឧទ្យានសួរថា លោកម្ចាស់ជានរណាព្រះបច្ចេកពុទ្ធពោលថា អាត្មាភាពគឺព្រះបច្ចេកពុទ្ធឈ្មោះថាទរីមុខ អ្នកយាមឧទ្យានពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ស្គាល់ព្រះរាជារបស់ខ្ញុំដែរឬទេ ព្រះបច្ចេកពុទ្ធពោលថា អាត្មាស្គាល់ កាលជាគ្រហស្ថ ទ្រង់ជាសម្លាញ់របស់អាត្មា អ្នកយាមឧទ្យានពោលថា បពិត្រលោកម្ចាស់ ព្រះរាជាមានបំណងចង់ជួបលោកម្ចាស់ ខ្ញុំនឹងទូលឲ្យទ្រង់យាងមក ព្រះបច្ចេកពុទ្ធពោលថា ចូរអ្នកទៅទូលចុះ អ្នកយាមឧទ្យានទទួលថា សាធុ ហើយរួតរះទៅនោះឯង ទូលដល់ព្រះរាជាអំពីដំណើររបស់ព្រះទរីមុខបច្ចេកពុទ្ធដែលគង់នៅត្រង់ផ្ទាំងថ្មហើយ ។

ព្រះរាជាត្រាស់ថា បាទព្ទថា សម្លាញ់របស់យើងមកហើយ យើងនឹងទៅសួរសុខទុក្ខលោក ហើយយាងឡើងរថ មកកាន់ព្រះរាជឧទ្យានមួយអន្លើ ដោយព្រះរាជបរិវារដ៏ច្រើន ថ្វាយបង្គំព្រះបច្ចេកពុទ្ធ ធ្វើបដិសណ្ឋារៈហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ កាលនោះ ព្រះបច្ចេកពុទ្ធធ្វើបដិសណ្ឋារៈជាមួយទ្រង់ ទ្រង់ទូលពាក្យជាដើមថា សូមថ្វាយព្រះពរព្រហ្មទត្ត ទ្រង់សោយរាជសម្បត្តិដោយធម៌ឬ ទ្រង់មិនលុះក្នុងអំណាចអគតិទេឬ ទ្រង់មិនបៀតបៀនមហាជនដើម្បីទ្រព្យទេឬ ទ្រង់បំពេញបុណ្យ មានទានជាដើមឬ ដូច្នេះហើយ ទូលបន្តថា សូមថ្វាយព្រះពរព្រហ្មទត្ត ទ្រង់ជរាភាពហើយ ឥឡូវនេះ ជាសម័យរបស់ព្រះអង្គដែលទ្រង់លះនូវកាមចេញបួសហើយ កាលសម្តែងធម៌ថ្វាយ ទើបទូលគាថាដំបូងថា

កាមទាំងឡាយដូចភក់ផង កាមទាំងឡាយដូចគ្រឿងស្អិតផង
នេះជាភ័យមានឫសគល់ ៣ យ៉ាង ដែលព្រះសម្ពុទ្ធពោលទុក
ហើយ កាមទាំងឡាយដូចធូលីផង ដូចផ្សែងផង ដែលអាត្មា
ប្រកាសហើយ បពិត្រព្រះរាជាព្រហ្មទត្ត សូមព្រះអង្គលះបង់
( កាមទាំងនោះ ) ហើយបួសចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បង្កោ** ព្រះបច្ចេកពុទ្ធពោលសំដៅដល់ ពួជទាំងឡាយ មានស្មៅ សារាយ បបុស និងគុម្ពស្មៅជាដើម ដែលកើតឡើងក្នុងទឹក ឧបមាដូចពួជទាំងនោះ រមែងញ៉ាំងបុគ្គលដែលឆ្លងទឹក ឲ្យទើសទាក់យ៉ាងណា បញ្ចកាមគុណទាំងឡាយរមែងញ៉ាំងព្រះយោគាវចរដែលឆ្លងសា-

គរ គឺសង្វារឲ្យជាប់ក៏យ៉ាងនោះ ឬថាវត្ថុកាមនិងកិលេសកាមទាំងពួងឈ្មោះ ថាជាភក់ដោយអំណាចញុំាងសត្វឲ្យជាប់ ព្រោះថា ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានទាំងឡាយក្តី ដែលជាប់ជំពាក់ហើយ ជាប់ហើយក្នុងភក់នោះ នឹងលំបាក ទ្រហោយំខ្សឹកខ្សួល ។ បទថា **បលិបោ ច កាមា** ភក់មានច្រើនដែលហៅថា បលិបៈ ព្រោះសត្វទាំងឡាយ មានជ្រូកក្តី ម្រឹគក្តី សីហៈក្តី ដំរីក្តី ដែលជាប់ហើយ មិនអាចរើខ្លួនឡើងហើយទៅបាន ។ វត្ថុកាមនិងកិលេសកាមទាំងឡាយ លោកហៅថា បលិបៈ ព្រោះដូចគ្នានឹងគ្រឿងស្អិតនោះ ។ ព្រោះថា សត្វទាំងឡាយ ទោះមានបញ្ញា រាប់តាំងអំពីពេលដែលជាប់មួងហើយក្នុងកាមទាំងឡាយនោះ ក៏មិនអាចទម្លាយកាមទាំងនោះ រើខ្លួនឡើងហើយចូលទៅកាន់បព្វជ្ជាដែលមិនមានកង្វល់ មិនបលិពោធ ជាទីត្រេកអរបាន ។ បទថា **ភយញ្ច មេតំ** បានដល់ **ភយញ្ច ឯតំ** ។ **ម** អក្ខរៈ លោកពោលទុកដោយអំណាចនៃការភ្ជាប់បទដោយព្យញ្ជនៈ ។ បទថា **តិមូលំ** សេចក្តីថា មិនញាប់ញ័រ ដូចតាំងមាំដោយឫស ៣ ពាក្យនេះជាឈ្មោះរបស់ភ័យដែលមានកម្លាំង ។ បទថា **បវុត្តំ** សេចក្តីថា បពិត្រមហារាជ ឈ្មោះថាកាមទាំងនេះ ព្រះពុទ្ធក្តី ព្រះបច្ចេកពុទ្ធក្តី សាវកទាំងឡាយក្តី ព្រះពោធិសត្វក្តី ដែលជាសព្វញ្ញូទាំងឡាយត្រាស់ហើយ គឺទ្រង់ប្រាប់ហើយ អធិប្បាយថា ទ្រង់សម្តែងទុកហើយថា ឈ្មោះថាជាភ័យមានកម្លាំង ព្រោះសំដៅសេចក្តីថា ជាបច្ច័យនៃភ័យ ដែលមានក្នុងបច្ចុប្បន្ននិងសម្បរាយិកភព មានភ័យគឺការតិះដៀលខ្លួនឯងជាដើម ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃកម្ម-

ករណៈ ៣២ ប្រការ និងរោគ ៩៨ ប្រភេទ ។ ម្យ៉ាងទៀត បទថា **ភយញ្ច មេតំ** សេចក្ដីថា អាត្មាបានទូលនូវភ័យនេះទុកថា មានមូល ៣ គប្បីជ្រាប សេចក្ដីក្នុងបទនេះ ដូចពណ៌នាមកនេះឯង ។ បទថា **រជោ ច ធូមោ ច** សេចក្ដីថា កាមទាំងឡាយ អាត្មាប្រកាសទុកហើយថា ជាធូលីផង ជាផ្សែងផង ព្រោះដូចគ្នាដោយធូលីនិងផ្សែង ឧបមាដូចរាងកាយរបស់បុរសដែលងូតស្អាតហើយ លាប និងតាក់តែងល្អហើយ តែមានធូលីដ៏ល្អិត ធ្លាក់ចុះត្រង់រាងកាយនឹងមានពណ៌ស្រអាប់ ប្រាសចាកភាពល្អ ធ្វើឲ្យសៅហ្មង យ៉ាងណា ព្រះយោគាវចរទាំងឡាយក៏យ៉ាងនោះដូចគ្នា សូម្បីមកហើយដោយផ្លូវអាកាសបានដោយកម្លាំងឫទ្ធិ ប្រាកដហើយក្នុងលោក ដូចព្រះចន្ទ និងព្រះអាទិត្យដែលមានពណ៌សៅហ្មង ប្រាសចាកលម្អ ជាអ្នកសៅហ្មងហើយតាំងអំពីគ្រាដែលធូលី គឺកាមធ្លាក់ចុះទៅខាងក្នុងត្រឹមតែម្ដង ព្រោះគុណ គឺសេចក្ដីល្អ គុណ គឺការស្អាត គុណគឺភាពល្អបរិសុទ្ធិ ត្រូវកម្ចាត់ហើយ ។ ម្យ៉ាងទៀត ជញ្ជាំងផ្ទះ សូម្បីស្អាតល្អហើយ ក៏នឹងមានពណ៌ខ្មៅ តាំងអំពីផ្សែងរុំ យ៉ាងណា ព្រះយោគាវចរទាំងឡាយ ក៏យ៉ាងនោះដូចគ្នា សូម្បីមានញាណបរិសុទ្ធពន់ពេក ក៏ប្រាកដដូចមនុស្សមានពណ៌សម្បុរខ្មៅ កណ្ដាលមហាជននោះឯង ព្រោះដល់នូវការវិនាសនៃគុណ តាំងអំពីកាលដែលត្រូវផ្សែង គឺកាម បោមរោម ដូច្នោះ ទើបកាមទាំងនេះ អាត្មាប្រកាសដល់មហាបពិត្រថា ជាធូលី ជាផ្សែង ព្រោះដូចគ្នានឹងធូលីនិងផ្សែង ព្រោះហេតុនោះ មហាបពិត្រ សូមទ្រង់លះកាមទាំងនេះបួសចុះ ។ ព្រះបច្ចេកពុទ្ធ ទ្រង់ឲ្យព្រះរាជាកើតនូវឧ-

ស្សាហៈក្នុងការចេញបួសដោយប្រការដូច្នេះ ។

ព្រះរាជាកាលទ្រង់ស្តាប់ពាក្យនោះហើយ កាលត្រាស់ប្រាប់ភាពដែលទ្រង់ជាប់ដោយកិលេសទាំងឡាយ ទើបត្រាស់គាថាទីពីរថា

បពិត្រព្រាហ្មណ៍ ខ្ញុំជាអ្នកជាប់ជំពាក់ ត្រេកអរជ្រុលជ្រប់ក្នុងកាមទាំងឡាយ ជាអ្នកត្រូវការដោយជីវិត មិនអាចដើម្បីលះនូវកាមមានសភាពគួរខ្លាច នោះបានទេ ខ្ញុំនឹងធ្វើបុណ្យទាំងឡាយច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គធិតោ** បានដល់ ត្រូវកាយគន្ថៈ គឺអភិជ្ឈាចងទុក ។ បទថា **រត្តោ** បានដល់ ត្រូវរាគៈជ្រលក់ចិត្តហើយ ដោយការធ្វើឲ្យលះប្រក្រតី ។ បទថា **អធិមុច្ឆិតោ** បានដល់ ងប់ជ្រប់ច្រើនពន់ពេក ។ បទថា **កាមេស្វាហំ** សេចក្តីថា ខ្ញុំជាប់ក្នុងកាមទាំង ២ ។ ព្រះរាជាត្រាស់ហៅទីមុខបច្ចេកពុទ្ធថា ព្រាហ្មណ៍ ។ បទថា **ភឹសរូបំ** បានដល់ មានរូបមានកម្លាំង ។ បទថា **តំ ន ុស្សហោ** សេចក្តីថា ខ្ញុំមិនអាច គឺមិនអាចលះកាមទាំង ២ យ៉ាងនោះបាន ។ ដោយពាក្យថា **ជីវិកត្ថោ បហាតុំ** នេះ ព្រះរាជាត្រាស់ថា ខ្ញុំត្រូវការរស់នៅយ៉ាងនេះ ទើបមិនអាចលះកាមនោះបាន ។ បទថា **កាហាមិ បុញ្ញានិ** សេចក្តីថា ខ្ញុំនឹងធ្វើបុណ្យ ធ្វើទាន រក្សាសីល និងឧបោសថកម្មមិនមែនតិច គឺច្រើន ។ ឈ្មោះថា កិលេសកាមយ៉ាងនេះ ដែលបុគ្គលមិនអាចនាំចេញទៅអំពីចិត្តបាន ផ្តើមតាំងពីកាលដែលជាប់ជំពាក់ម្តង មហាបុរសមានចិត្តសៅហ្មងហើយ កាលព្រះបច្ចេកពុទ្ធទូលដល់គុណនៃ

បព្វជ្ជាហើយ ក៏នៅតែត្រាស់ថា ខ្ញុំមិនអាចបួសបាន ។ ព្រះបាទព្រហ្មទត្តអង្គណា កាលទ្រង់ពារកពុទ្ធការកធម៌ ដោយញាណដែលកើតឡើងក្នុងព្រះអង្គក្រោបទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមថាទីបង្ករ ទ្រង់ឃើញនេក្ខម្មៈទី ៣ ហើយ ទើបទ្រង់សរសើរគុណក្នុងនេក្ខម្មៈយ៉ាងនេះ ( ក្នុងពុទ្ធវំសៈ ) ថា

កាលនោះតថាគតកំពុងជ្រើសរើសរក ក៏បានឃើញ នេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេពធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថាម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនេក្ខម្មបារមីទី ៣ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មដើម្បីរួចចាកភពយ៉ាងនោះដែរ ដូច្នេះ ។

ព្រះបាទព្រហ្មទត្តនោះ សូម្បីជាបុគ្គលដែលព្រះបច្ចេកពុទ្ធត្រាស់សរសើរបព្វជ្ជា ហើយថ្វាយព្រះពរថា សូមមហាបពិត្រទ្រង់លះបង់កិលេសទាំងឡាយហើយទ្រង់ជាសមណៈចុះ ក៏នៅតែត្រាស់ថា ខ្ញុំមិនអាចដើម្បីលះនូវកាមមានសភាពគួរខ្ពើមនោះបានទេ ។

បានឮថា មនុស្សឆ្កួតក្នុងលោកនេះមាន ៨ ពួក ព្រោះហេតុនោះទើប

បុរាណាចារ្យ ពោលទុកថា បុគ្គលដែលបានសញ្ញាថាឆ្កួតមាន ៨ ពួក គឺ **កាមុម្មត្តកោ** ឆ្កួតព្រោះកាម គឺធ្លាក់នៅក្នុងអំណាចរបស់ចិត្ត ធ្លាក់នៅក្នុងអំណាចសេចក្ដីលោភ ១ **កោធុម្មត្តកោ** ឆ្កួតព្រោះក្រោធ គឺធ្លាក់ ក្រោមអំណាចវិបដិសារ បៀតបៀនអ្នកដទៃ ១ **ទិដ្ឋុម្មត្តកោ** ឆ្កួតព្រោះទិដ្ឋិ ឆ្កួតព្រោះទ្រឹស្ដី ឬឆ្កួតព្រោះលទ្ធិ គឺធ្លាក់ក្នុងអំណាចការយល់ខុស ១ **មោហុម្មត្តកោ** ឆ្កួតព្រោះវង្វេង គឺធ្លាក់ក្នុងអំណាចការមិនដឹង ១ **យក្ខុម្មត្តកោ** ឆ្កួតព្រោះយក្ខចូល គឺធ្លាក់ក្នុងអំណាចយក្ខ ១ **បិត្តុម្មត្តកោ** ឆ្កួតព្រោះប្រមាត់កម្រើក គឺធ្លាក់ក្នុងអំណាចរបស់ប្រមាត់ ១ **សុរុម្មត្តកោ** ឆ្កួតព្រោះសុរា គឺធ្លាក់ក្នុងអំណាចរបស់សុរា ១ **ព្យសនុម្មត្តកោ** ឆ្កួតព្រោះវិនាស គឺធ្លាក់នៅក្នុងអំណាចរបស់សេចក្ដីសោក ១ ។

ក្នុងឆ្កួត ៨ ពួកនេះ ព្រះមហាសត្វ ក្នុងជាតកនេះ ឆ្កួតព្រោះធ្លាក់ក្នុងកាម ធ្លាក់ក្រោមអំណាចសេចក្ដីលោភទើបមិនដឹងគុណរបស់បព្វជ្ជា សួរថា សេចក្ដីលោភនេះ ធ្វើវត្ថុដែលមិនជាប្រយោជន៍ ទម្លាយគុណ ដោយប្រការដែលពោលមកហើយនេះ តែហេតុអ្វីសត្វទាំងឡាយមិនអាចរួចផុតបាន ។ ឆ្លើយថា ព្រោះការលោភនោះចម្រើនមកហើយ ដោយរួមគ្នាច្រើនសែនកោដិកប្ប ក្នុងសង្សារដែលមិនដឹងខាងដើមនិងទីបំផុត កាលបើដូច្នេះ ទើបបណ្ឌិតទាំងឡាយលះដោយអំណាចការពិចារណាច្រើនយ៉ាងដូចជា កាមទាំងឡាយមានសេចក្ដីត្រេកអរតិចជាដើម ។

កាលព្រះមហាសត្វអង្គុយនោះឯង ត្រាស់ថា ខ្ញុំមិនអាចបួសបាន ព្រះ

ទីមុខបច្ចេកពុទ្ធទ្រង់ក៏មិនដាក់ធុរៈ កាលនឹងថ្វាយព្រះឱវាទឲ្យក្រៃលែង ទើបពោលគាថា ២ ថា

បុគ្គលណាកាលគេប្រាប់ថាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ប្រៀនប្រដៅតែមិនធ្វើតាមពាក្យប្រៀនប្រដៅសម្គាល់ថានេះឯងប្រសើរ ជាមនុស្សល្ងង់ខ្លៅ រមែងចូលទៅកាន់គភ៌ញយៗ ។

បុគ្គលល្ងង់ខ្លៅនោះ រមែងចូលទៅកាន់នរក មានសភាពដ៏ពន្លឹក ជាទីមិនស្អាតដល់ពួកកុលបុត្តអ្នកស្អាត ពេញដោយមូត្រនិងករីស សត្វទាំងឡាយណា ជាអ្នកមិនទាន់ប្រាសចាករាគៈ ជាប់ចំពាក់ក្នុងកាមទាំងឡាយ សត្វទាំងឡាយនោះរមែងមិនលះបង់នូវសកាយ ( ការនៅក្នុងគភ៌ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្ថកាមស្ស** សេចក្តីថា ជាអ្នកប្រាប់ថានូវសេចក្តីចម្រើន ។ បទថា **ហិតានុកម្បិនោ** សេចក្តីថា ជាអ្នកអនុគ្រោះដោយប្រយោជន៍ គឺដោយចិត្តទន់ភ្លន់ ។ បទថា **ឱវជ្ជមានោ** បានដល់ ត្រូវពោលដាស់តឿន ។ បទថា **ឥទមេវ សេយ្យោ** សេចក្តីថា សម្គាល់វត្ថុដែលខ្លួនប្រកាន់ជាវត្ថុមិនប្រសើរជាងផង មិនឧត្តមផងថា វត្ថុនេះប៉ុណ្ណោះ ប្រសើរជាងវត្ថុដទៃ ។ បទថា **មន្ទោ** សេចក្តីថា បុគ្គលនោះ ជាអ្នកមិនមានការដើរនិងឈានកន្លងការនៅក្នុងផ្ទៃ របស់មាតាទៅបាន អធិប្បាយថា ចូលដល់គភ៌ដដែលហើយដដែលទៀតនោះឯង ។ បទថា **សោ ឃោររូបំ** សេចក្តីថា សូម

ថ្វាយព្រះពរមហាបពិត្រ បុគ្គលល្ងង់នោះ កាលចូលដល់ផ្ទៃមាតានោះ ឈ្មោះថាចូលដល់នរកដែលកាចសាហាវ គឺទារុណដោយកំណើត អធិប្បាយថា ផ្ទៃនៃមាតា ព្រះបច្ចេកពុទ្ធហៅថានរក គឺហៅថា ចតុកុដ្ដិកនរក គឺទីចង្អៀត ៤ ទិស ។ ក្នុងព្រះគាថានេះ ព្រោះអត្ថថា អស់នូវការត្រេកអរ ។ កាលសួរថា ធម្មតា ចតុកុដ្ដិកនរក ជានរកដូចម្ដេច គួរប្រាប់ថា គឺផ្ទៃ មាតានោះឯង ព្រោះថា សត្វដែលកើតហើយក្នុងអវិចីមហានរក មានការរត់ស្ទុះស្ទាដោយជុំវិញទៅមកបាននោះឯង ព្រោះដូច្នោះ អវិចីមហានរកនោះ នឹងហៅថា ចតុកុដ្ដិកនរកមិនបាន ។ តែក្នុងផ្ទៃមាតា សត្វដែលកើតក្នុងផ្ទៃមិនអាចរត់ទៅក្នុងទីទាំង ៤ ទិសខាងនោះខាងនេះបាន អស់កាល ៩ ឬ ១០ ខែ ចាំបាច់អង្គុញខ្លួនក្នុងទិសទាំង ៤ ដែលជាឱកាសចង្អៀត ព្រោះដូច្នោះ ទើបហៅថា ចតុកុដ្ដិកនរក ។ បទថា **សុភាសុភំ** បានដល់ ទីមិនស្អាតសម្រាប់ព្រះយោគាវចរដែលស្អាតទាំងឡាយ អធិប្បាយថា ផ្ទៃមាតា សន្មតថា ជាទីមិនស្អាតដោយចំណែកមួយ សម្រាប់អ្នកស្អាតទាំងឡាយ គឺព្រះយោគាវចរកុលបុត្តទាំងឡាយដែលខ្ពាចសង្សារ ។ ដោយហេតុនោះ ទើបលោកពោលទុក ( ក្នុងកាយនិព្វិន្ទជាតក ) ថា

( រាងកាយនេះ ) មិនជាទីគាប់ចិត្ត តែជនពាលពោលថាជាទីគាប់ចិត្ត មិនស្អាតទេ តែជនពាលសន្មតថាជារបស់ស្អាត រាងកាយដ៏ពេញប្រៀបដោយសាកសពផ្សេង ៗ មានសភាពជាទីគាប់ចិត្តនៃជនពាល ។

យើងគួរតិះដៀលនូវកាយស្អុយនេះ ជារបស់ឈឺជានិច្ច គួរខ្ពើមរអើម មិនស្អាត មានព្យាធិជាធម្មតា ដែលពួកសត្វប្រមាទ ជ្រប់ជាប់ ញុំាងផ្លូវនៃសុគតិកពឲ្យវិនាសសាបសូន្យ ដូច្នេះ ។

បទថា **សត្តា** បានដល់ អ្នកជាប់ជំពាក់ គឺឈមទៅរក ដោយអត្ថថា ជាប់ អធិប្បាយថា ជាប់ជំពាក់ហើយ ។ បទថា **សកាយេ ន ជហន្តិ** សេចក្តីថា មិនលះចោលផ្ទៃមាតានោះ ។ បទថា **គិទ្ធា** បានដល់ ត្រេកត្រអាលហើយនោះឯង ។ បទថា **យេ ហោន្តិ** សេចក្តីថា ពួកជនមិនប្រាសចាករាគៈក្នុងកាមទាំងឡាយនឹងមិនលះការនៅក្នុងផ្ទៃមាតានោះទៅ ។

ព្រះទីមុខបច្ចេកពុទ្ធ កាលសម្តែងទុក្ខ ដែលមានការចុះកាន់គភ៌ជាមូលផង មានការបរិហារជាមូលផង ឥឡូវនេះ កាលសម្តែងដល់ទុក្ខ មានការចេញចាកគភ៌ជាមូល ទើបពោលគាថាមួយគាថាកន្លះថា

សត្វទាំងឡាយប្រសូត ( ចាកគភ៌នៃមាតា ) រមែងជាប់ដោយលាមក ប្រឡាក់ដោយឈាម ជាប់ដោយរំអិល ប៉ះពាល់នូវទ្វារជាទីប្រសូតិណាៗ ដោយកាយ ក្នុងខណៈនោះទ្វារទាំងអស់នោះជារបស់មិនស្អាត សុទ្ធតែជាទុក្ខទាំងអស់ ។
អាត្មាឃើញ ទើបពោល មិនមែនស្តាប់អំពីបុគ្គលដទៃទេ អាត្មារឭកឃើញនូវបុព្វេនិវាសច្រើន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មីឡ្ហេន លិត្តា** សេចក្តីថា ថ្វាយព្រះពរមហាបពិត្រ សត្វទាំងឡាយនេះ កាលកើតអំពីផ្ទៃមាតា មិនបានលាបដោយ

គន្ធជាតិទាំង ៤ មិនបានប្រដាប់ដោយផ្កា ដោយគ្រឿងក្រអូបចេញមកទេ ជាអ្នកប្រឡាក់ គឺជាប់ដោយអាហារចាស់ ស្អុយចេញមក ។ បទថា **រុហិរេន មក្ខិតា** សេចក្ដីថា មិនមែនលាបដោយចន្ទន៍ក្រហមចេញមក តែប្រឡាក់ដោយឈាមក្រហមចេញមក ។ បទថា **សេម្ហេន លិត្តា** សេចក្ដីថា មិនមែនលាបដោយចន្ទន៍សចេញមក តែប្រឡាក់ស្លេស្មក្រាស់ៗចេញមក ព្រោះក្នុងពេលស្រីទាំងឡាយប្រសូត របស់មិនស្អាតទាំងឡាយចេញមក ។ បទថា **តាវទេ** បានដល់ ក្នុងសម័យនោះ មានអធិប្បាយថា សូមថ្វាយព្រះពរមហាបពិត្រ សត្វទាំងនេះ ក្នុងកាលដែលចេញចាកផ្ទៃមាតានោះ ប្រឡាក់លាមកជាដើមចេញមកយ៉ាងនេះ ប៉ះទ្វារប្រសូតិឬដៃរមែងឈ្មោះថា ប៉ះសម្ផស្សទុក្ខទាំងអស់សុទ្ធៗ គឺលាយដោយរបស់មិនស្អាត មិនជាទីត្រេកអរ គឺមិនគួរសរសើរ ឈ្មោះថាសេចក្ដីសុខ មិនមានដល់សត្វទាំងនោះក្នុងសម័យនោះ ។ បទថា **ទិស្វា វទាមិ ន ហិ អញ្ញតោ សវំ** សេចក្ដីថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាកាលទូលថ្វាយប៉ុណ្ណេះ មិនបានស្ដាប់មកពីទីដទៃ គឺមិនបានស្ដាប់ពាក្យនោះអំពីសមណៈឬព្រាហ្មណ៍ដទៃ ហើយទូលថ្វាយទេ តែអាត្មាឃើញហើយ គឺត្រាស់ដឹងហើយ បានដល់ ធ្វើឲ្យប្រចក្សហើយ ដោយបច្ចេកពោធិញ្ញាណរបស់ខ្លួន ហើយទើបទូលថ្វាយ ។ បទថា **បុព្វេនិវាសំ ពហុកំ** សេចក្ដីថា ព្រះបច្ចេកពុទ្ធ កាលសម្ដែងដល់អានុភាពរបស់ខ្លួន ទើបទូលថ្វាយពាក្យនេះ មានអធិប្បាយថា សូមថ្វាយព្រះពរមហាបពិត្រ ចំណែកអាត្មារឭកដល់ខន្ធដែលធ្លាប់នៅ អាស្រ័យមក ពោលគឺខន្ធដែលនៅអាស្រ័យ

មកតាមលំដាប់ ក្នុងជាតិមុនសន្ទឹកសន្ទាប់ គឺរឭកបានដល់ទៅពីរអសង្ខេយ្យ និងមួយសែនកប្ប ។

ឥឡូវនេះ ព្រះសាស្តាទ្រង់ត្រាស់ដឹងក្រៃលែង កាលត្រាស់ថា ព្រះបច្ចេកពុទ្ធនោះ ទ្រង់សង្គ្រោះព្រះរាជា ដោយព្រះគាថាជាសុភាសិតយ៉ាងនេះហើយ បានត្រាស់កន្លះគាថាទុកខាងចុងថា

ព្រះបច្ចេកពុទ្ធព្រះនាមទរីមុខៈពន្យល់ស្តេចព្រហ្មទត្តមានប្រាជ្ញា
ល្អ ដោយគាថាទាំងឡាយដ៏វិចិត្រ ដែលសម្តែងហើយដោយ
ល្អ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចិត្រាហិ** សេចក្តីថា អាស្រ័យអត្ថដ៏វិចិត្រ ។ បទថា **សុភាសិតាហិ** បានដល់ ដែលត្រាស់ទុកល្អហើយ ។ បទថា **ទរីមុខោ និជ្ឈាបយី សុមេធំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះទរីមុខបច្ចេកពុទ្ធនោះ ឲ្យព្រះរាជានោះ ដែលទ្រទ្រង់នូវបញ្ញា គឺទ្រង់មានបញ្ញាល្អ បានដល់អាចដឹងហេតុនិងមិនមែនហេតុ ឲ្យស្គាល់ព្រះអង្គ គឺឲ្យទ្រង់រឭកបាន អធិប្បាយថា ឲ្យទ្រង់ធ្វើតាមពាក្យរបស់ខ្លួន ។

ព្រះបច្ចេកពុទ្ធ កាលសម្តែងទោសក្នុងកាមទាំងឡាយ ញុំាងព្រះរាជាឲ្យទ្រង់កាន់យកពាក្យរបស់ខ្លួនយ៉ាងនេះហើយ ទើបពោលថា សូមថ្វាយព្រះពរទមហាបពិត្រ ឥឡូវនេះ ទ្រង់បួសឬទ្រង់មិនបួស ក៏តាមព្រះទ័យចុះ តែអាត្មាបានសម្តែងទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងការបួស ថ្វាយមហាបពិត្រហើយ សូមទ្រង់កុំប្រមាទ ដូច្នេះហើយ បានហោះទៅ ក្នុងអា-

កាស ជាន់ពពក និមន្តទៅកាន់ញកក្នុំនទូមូលកៈនោះឯង ដូចស្តេចហង្សមាស ដូច្នោះ ។ ព្រះមហាសត្វទ្រង់ផ្គងអញ្ជលីដ៏រុងរឿងដោយម្រាម ១០ ដាក់លើ សិរសានមស្ការ កាលព្រះបច្ចេកពុទ្ធផុតកន្ទុយភ្នែកហើយ ទើបត្រាស់ឲ្យហៅ ព្រះរាជបុត្តច្បងមកគាល់ ទ្រង់ប្រគល់រាជសម្បត្តិ កាលមហាជនកំពុងយំទ្រង់ លះកាមទាំងឡាយ ទៅកាន់ព្រៃហិមពាន្ត សាងបណ្ណសាលា បួសជាឥសី មិនយូរប៉ុន្មាន ក៏បានញុំាងអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ក្នុងកាលអស់ព្រះ ជន្មាយុ ក៏បានទៅកាន់ព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមក ប្រកាសសច្ចធម៌ ទាំងឡាយ ក្នុងកាលចប់សច្ចធម៌ ជនទាំងឡាយបានជាព្រះសោតាបន្ន ជា ដើមសន្ទឹកសន្ធាប់ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ គឺតថា គតនេះឯង ។

**អដ្ឋកថា ទរីមុខជាតក ចប់**

## នេរុជាតក

[ ១៤៨ ] ( សុវណ្ណហង្សជាប្អូននិយាយថា ) ហ្វូងក្អែកព្រៃ ក្អែកស្រុក និងយើងជាសត្វប្រសើរជាងពួកសត្វស្លាប មកដល់ភ្នំនេះមានសម្បុរប្រហែលគ្នាទាំងអស់ ។

[ ១៤៩ ] ពួកសីហៈ ខ្លាធំ សត្វស្លាប ម្រឹគថោកទាបក្នុងទីនេះ មានសម្បុរប្រហែលគ្នាទាំងអស់ តើភ្នំនេះឈ្មោះអ្វី ។

[ ១៥០ ] ( សុវណ្ណហង្សពោធិសត្វពោលថា ) មនុស្ស ទាំងឡាយដឹងថា ភ្នំដ៏ឧត្តមនេះឈ្មោះនេរុ សព្វសត្វទាំងឡាយនៅក្នុងទីនេះ ជាសត្វបរិបូណ៌ដោយពណ៌សម្បុរ ។

[ ១៥១ ] ( សុវណ្ណហង្សជាប្អូនពោលថា ) ការមិនរាប់អាន ឬការមើលងាយនូវពួកសប្បុរស ឬក៏ការរាប់អានបុគ្គលថោកទាប មានក្នុងទីណា បុគ្គលមិនគប្បីនៅក្នុងទីនោះទេ ។

[ ១៥២ ] មនុស្សខ្ជិលនិងមនុស្សឧស្សាហ៍ មនុស្សក្លៀវក្លា និងមនុស្សខ្លាច គេបូជាស្មើគ្នាក្នុងទីណា សប្បុរសទាំងឡាយរមែងមិននៅក្នុងទីនោះ ជាភ្នំមិនធ្វើឲ្យប្លែកបាន ។

[ ១៥៣ ] ភ្នំនេរុនេះ មិនចែកនូវសត្វឲ្យថោកទាប ឲ្យខ្ពង់ខ្ពស់ ឲ្យជាកណ្ដាល ភ្នំនេរុមិនធ្វើឲ្យប្លែកគ្នាបាន បើដូច្នោះយើងទាំងឡាយ លះបង់នូវភ្នំនេរុចោល ។

**ចប់ នេរុជាតកទី ៤ ។**

# អដ្ឋកថា

## ឆេរុជាតក

[ ១៤៨-១៥៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កាកោលា កាកសង្ឃា** ច ដូច្នេះជាដើម ។

បានឮថា ភិក្ខុរូបនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា បានទៅកាន់តំបន់មួយ ។ មនុស្សទាំងឡាយជ្រះថ្លាក្នុងឥរិយាបថរបស់លោក ឲ្យលោកឆាន់ហើយ ទទួលប្តេជ្ញា សាងបណ្ណសាលាក្នុងព្រៃ ឲ្យលោកនៅក្នុងសាលាស្ទឹកនោះ នាំគ្នាថ្វាយសក្ការៈដោយអើពើ ។ កាលនោះ អ្នកបួសដទៃដែលជាពួកសស្សតវាទបានមកក្នុងទីនោះ ។ មនុស្សទាំងនោះ បានស្តាប់ពាក្យរបស់អ្នកបួសទាំងនោះហើយ នាំគ្នាលះបង់ថេរវាទចោល កាន់យកសស្សតវាទ ថ្វាយសក្ការៈដល់លោកទាំងនោះប៉ុណ្ណោះ ។ បន្ទាប់មកពួកឧច្ឆេទវាទក៏មកដល់ ពួកអ្នកស្រុកក៏នាំគ្នាលះសស្សតវាទចោល កាន់យកឧច្ឆេទវាទ ។ តមកពួកដទៃដែលជា អចេលកវាទមក ក៏នាំគ្នាលះឧច្ឆេទវាទចោល កាន់យកអចេលកវាទ ។ ភិក្ខុនោះនៅដោយមិនសប្បាយក្នុងសម្នាក់របស់មនុស្សទាំងនោះដែលមិនស្គាល់គុណនិងមិនមែនគុណ ចេញវស្សាបវារណាហើយ ទើបទៅកាន់សម្នាក់របស់ព្រះសាស្តា ជាភិក្ខុដែលព្រះសាស្តាធ្វើបដិសណ្ឋារៈហើយ កាលទ្រង់ត្រាស់សួរថា អ្នកចាំវស្សាក្នុងទីណា ក៏ទូលថា បពិត្រព្រះអង្គដ៏ចម្រើន នៅអាស្រ័យត្រង់ស្រុកជាយដែន ព្រះសាស្តាត្រាស់សួរថា អ្នកនៅសប្បាយឬ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ

នៅជាទុក្ខក្នុងសម្នាក់របស់ជនដែលមិនដឹងគុណ និងទោស ។ ព្រះសាស្តា ត្រាស់សួរថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងសម័យមុន សូម្បីកើតក្នុងកំណើតតិរច្ឆាន ត្រឹមតែមួយថ្ងៃក៏មិន នៅជាមួយជនទាំងឡាយដែលមិនដឹងគុណនិងទោស ហេតុអ្វីទើបអ្នកនៅក្នុងសម្នាក់របស់មនុស្សដែលមិនដឹងគុណ និងទោស ។ កាលភិក្ខុនោះទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាហង្សមាស មួយអន្ទើនឹងបងប្អូនទាំងឡាយ ហង្សទាំងនោះនៅអាស្រ័យត្រង់ភ្នំចិត្តកូដ បរិភោគស្រូវសាលីដែលកើតឯងក្នុងព្រៃហិមពាន្ត ។ ថ្ងៃមួយ ពួកហង្សទាំងនោះ នាំគ្នាត្រាច់ទៅត្រង់ព្រៃហិមពាន្តនោះ ហើយកំពុងត្រឡប់មកកាន់ភ្នំចិត្តកូដ ឃើញភ្នំមាសមួយឈ្មោះថានេរុក្នុងរវាងផ្លូវ ទើបនាំគ្នាទំត្រង់កំពូលភ្នំនោះ ។ សត្វដែលអាស្រ័យភ្នំនោះ មានទាំងបក្សី ទន្សាយ សត្វជើង ៤ គ្រប់ប្រភេទរកស៊ី ។ តាំងពីសត្វទាំងនោះចូលទៅកាន់ភ្នំ ក៏មានពណ៌លឿងដូចមាស ដោយពន្លឺភ្នំនោះ ប្អូនពៅរបស់ព្រះពោធិ សត្វឃើញយ៉ាងនោះហើយមិនដឹងហេតុនោះ សង្ស័យថា នុ៎ះជាអ្វីហ្ន៎ កាលសន្ទនាជាមួយបងប្រុស ទើបពោលគាថា ២ ថា

ហ្វូងក្អែកព្រៃ ក្អែកស្រុកនិងយើង ជាសត្វប្រសើរជាងពួក
សត្វស្លាប មកដល់ភ្នំនេះ មានសម្បុរប្រហែលគ្នាទាំងអស់ ។
ពួកសីហ: ខ្លាធំ សត្វស្លាប ម្រឹគថោកទាបក្នុងទីនេះ មាន

សម្បុរប្រហែលគ្នាទាំងអស់ តើភ្នំនេះឈ្មោះអ្វី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាកោលា** បានដល់ ក្អែកព្រៃនិងតាវៅ ។ បទថា **កាកសង្ឃា** បានដល់ ហ្វូងក្អែកប្រក្រតី ។ បទថា **បតតំ វរា** សេចក្ដីថា ប្រសើរបំផុតជាងបក្សីទាំងឡាយ ។ បទថា **សទិសា ហោម** សេចក្ដីថា ជាអ្នកមានពណ៌ដូចគ្នា ។

ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយ បានពោលគាថាទី ៣ ថា

មនុស្សទាំងឡាយដឹងថា ភ្នំដ៏ឧត្ដមនេះឈ្មោះនេរុ សព្វសត្វទាំងឡាយ នៅក្នុងទីនេះ ជាសត្វបរិបូណ៌ដោយពណ៌សម្បុរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធ វណ្ណាធ** បានដល់ សត្វទាំងឡាយក្នុងនេរុបព៌តនេះជាអ្នកមានពណ៌សម្បុរស្អាត ព្រោះស្រមោលភ្នំ ។

ប្អូនប្រុសឮពាក្យនោះហើយ បានពោលគាថាដ៏សេសថា

ការមិនរាប់អាន ឬការមើលងាយនូវពួកសប្បុរស ឬក៏ការរាប់អានបុគ្គលថោកទាប មានក្នុងទីណា បុគ្គលមិនគប្បីនៅក្នុងទីនោះទេ ។

មនុស្សខ្ជិលនិងមនុស្សឧស្សាហ៍ មនុស្សក្លៀវក្លានិងមនុស្សខ្លាច គេបូជាស្មើគ្នាក្នុងទីណា សប្បុរសទាំងឡាយរមែងមិននៅក្នុងទីនោះ ជាភ្នំមិនធ្វើឲ្យប្លែកបាន ។

ភ្នំនេរុនេះ មិនចែកនូវសត្វឲ្យថោកទាប ឲ្យខ្ពង់ខ្ពស់ ឲ្យជា

កណ្តាល ភ្នំនេរុមិនធ្វើឲ្យប្លែកគ្នាបាន បើដូច្នោះយើងទាំងឡាយ
លះបង់នូវភ្នំនេរុចោល ដូច្នេះ ។

បណ្តាបទទាំងនោះ គាថាជំបូង មានអត្ថថា ក្នុងទីណាមានការមិនរាប់អានផង ការមើលងាយផង ឬការប្រាសចាកការរាប់អានដោយអំណាចការមើលងាយ ព្រោះមិនមានការរាប់អានសប្បុរស គឺបណ្ឌិតដែលសម្បូរដោយសីល ឬមានការរាប់អានមនុស្សអាក្រក់ ឬមនុស្សទ្រុស្តសីល ក្នុងទីនោះ បុគ្គលមិនគួររស់នៅ គឺមិនគួរអាស្រ័យ ។ បទថា **បូជិយា** សេចក្តីថា មនុស្សទាំងនេះជាបុគ្គលដែលគេបូជាហើយដោយការបូជាដែលដូចគ្នា គឺបានសក្ការៈស្មើគ្នាក្នុងទីនោះ ។ បទថា **ហីនមុក្កដ្ឋមជ្ឈិមេ** សេចក្តីថា ភ្នំនេះមិនបែងចែកមនុស្សអាក្រក់ មនុស្សកណ្តាល និងមនុស្សជាន់ខ្ពស់ ដោយជាតិគោត្ត ត្រកូល ទឹកដី សីល អាចារ និងញាណជាដើម ។ សព្ទថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថនៃឧបសគ្គ បទថា **ជហាមសេ** បានដល់ ចូរលោះចោល ។

ហង្សទាំង ២ នោះ កាលពោលយ៉ាងនេះហើយ បាននាំគ្នាទៅកាន់ភ្នំចិត្តកូដនោះឯង ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតសច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ហង្សប្អូនក្នុងកាលនោះ បានជាអានន្ទក្នុងកាលឥឡូវនេះ ឯហង្សបង គឺតថាគតនេះឯង ។

## អដ្ឋកថា នេរុជាតក

# អាសង្កជាតក

[ ១៥៤ ] ( នាងអាសង្កាកុមារិកាពោលថា ) វល្លិ៍ឈ្មោះ អាសាវតីកើតក្នុងឧទ្យានឈ្មោះចិត្តលតាវន វល្លិ៍នោះក្នុងមួយពាន់ឆ្នាំ ទើបកើតផ្លែ ១ ។

[ ១៥៥ ] ទោះបីផ្លែមាននៅក្នុងទីឆ្ងាយដល់ម្លោះ ពួកទេវតានៅតែចូលទៅរកវល្លិ៍នោះ បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្ដីប្រាថ្នារមែងមានផល នាំមកនូវសេចក្ដីសុខ ។

[ ១៥៦ ] អម្បាលសត្វស្លាបនោះ ( កុក ) នៅប្រាថ្នាបាន អម្បាលសត្វមានកំណើតពីរ គង់ប្រាថ្នាបាន ថ្វីបើទន្លេមាននៅក្នុងទីឆ្ងាយ សេចក្ដីប្រាថ្នារបស់កុកនោះ គង់សម្រេចមិនខាន បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្ដីប្រាថ្នារមែងមានផលជាសុខ ។

[ ១៥៧ ] ( ព្រះរាជាព្រហ្មទត្តពោលថា ) នាងបានញ៉ាំងខ្ញុំ ឲ្យឆ្អែតដោយវាចា មិនឆ្អែតដោយការងារ ដូចជាផ្កាកម្រងនៃឈើសោរេយ្យកៈ មានតែពណ៌មិនមានក្លិន ។

[ ១៥៨ ] បុគ្គលណាមិនឲ្យ មិនលះបង់ភោគៈ គ្រាន់តែធ្វើនូវវាចាដ៏ពីរោះ ជាវាចាឥតផលចំពោះមិត្តទាំងឡាយ តំណ ( នៃសេចក្ដីស្និទ្ធស្នាល ) របស់បុគ្គលនោះរមែងសាបសូន្យទៅដោយហេតុនោះឯង ។

[ ១៥៩ ] ពិតណាស់ បុគ្គលធ្វើនូវអំពើណា គប្បីនិយាយនូវអំពើនោះ មិនធ្វើនូវអំពើណា មិនគប្បីនិយាយនូវអំពើនោះ បណ្ឌិតទាំងឡាយរមែងកំណត់ដឹងនូវបុគ្គលអ្នកមិនធ្វើ គ្រាន់តែនិយាយ ។

[ ១៦០ ] ពលរបស់ខ្ញុំអស់ហើយ ទាំងស្បៀងអាហារក៏មិនមាន ខ្ញុំ

វង្វៀសចំពោះការវិនាសនៃជីវិត បើដូច្នោះខ្ញុំនឹងទៅឥឡូវនេះ ។

[ ១៦១ ] ( នាងអាសង្កាទូលថា ) បពិត្រព្រះអង្គទ្រង់ប្រសើរលើវថ ពាក្យណាដែលមាននៅក្នុងឈ្មោះ ពាក្យនុ៎ះឯងជាឈ្មោះរបស់ខ្ញុំព្រះអង្គបពិត្រមហារាជ សូមព្រះអង្គរង់ចាំចុះ ខ្ញុំព្រះអង្គនឹងអញ្ជើញបិតាសិន ។

**ចប់ អាសង្កជាតកទី ៥ ។**

## អដ្ឋកថា

## អាសង្កជាតក

[ ១៥៤-១៦១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់បុរាណទុតិយិកា ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អាសាវតី ឆាម លតា** ដូច្នេះជាដើម ។ រឿងនេះនឹងមានជាក់ច្បាស់ក្នុងឥន្ទ្រិយជាតកខាងមុខ ។

ក្នុងទីនេះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកពិតឬ ភិក្ខុនោះទូលថា ព្រះករុណាព្រះអង្គ ពិតមែន ព្រះសាស្តាត្រាស់ថា អ្វីធ្វើឲ្យអ្នកអផ្សុក ភិក្ខុនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន គឺភរិយាចាស់ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ស្រីនេះធ្វើសេចក្តីវិនាស ធ្វើឲ្យអ្នកលំបាក មិនមែនក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកអាស្រ័យ

ស្រីនេះ លះបង់នូវចតុរង្គសេនា សោយទុក្ខដ៏ធ្ងន់ក្នុងទ្រង់ព្រៃហិមពាន្ត អស់កាល ៣ ឆ្នាំ ហើយទ្រង់នាំយក រឿងក្នុងអតីតមកសាធក: ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ត្រង់ស្រុកកាសិក: ចម្រើនវ័យហើយ ទទួលការសិក្សាក្នុងនគរតក្កសិលា បួសជាឥសី មានជំឡូង និងផ្លែឈើក្នុងព្រៃជាអាហារ ធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតឡើងហើយ នៅក្នុងព្រៃហិមពាន្ត ។ ពេលនោះ សត្វមួយដល់ព្រមដោយបុណ្យ ចុតិអំពីតាវត្តិង្សពិភព បដិសន្ធិជាទារិកាក្នុងផ្កាឈូកនាស្រះនោះ ។ កាលឈូកដទៃរុះរោយទៅ ផ្កាឈូកនោះនៅក្រពុំនោះឯង តាបសមកកាន់ស្រះនោះ ដើម្បីងូតទឹក ឃើញផ្កាឈូកនោះ គិតថា កាលឈូកដទៃៗរោយទៅហើយ តែឈូកនេះមិនរុះរោយ នៅក្រពុំដដែល មានហេតុអ្វីហ្ន៎ ហើយផ្លាស់សំពត់ងូតទឹកចុះទៅហែកផ្កាឈូកនោះ ឃើញទារិកានោះហើយ កើតការសម្គាល់ថា ជាកូនស្រី នាំមកកាន់បណ្ណសាលាចិញ្ចឹមទុក ។ តមក មានអាយុ ១៦ ឆ្នាំ មានរូបឆោមលោមពណ៌ ល្អលើសមនុស្ស តែក្រោមទេវតា ។ កាលនោះ សក្កទេវរាជបានមកកាន់ទីឧបដ្ឋាកព្រះពោធិសត្វ ។ សក្កទេវរាជទតឃើញទារិកា ទើបត្រាស់សួរថា ស្រីនេះ មកអំពីណា ទ្រង់ស្តាប់ពាក្យតាបសហើយ សួរថា គួរបានអ្វីសម្រាប់ស្រីនេះ តាបសទូលថា បពិត្រព្រះរាជសម្ភារ ទ្រង់គួរនិម្មិតប្រាសាទកែវផលិក ដើម្បីជាលំនៅ និងសេយ្យាសនៈដែលជាទិព្វ គ្រឿងប្រដាប់ វត្ថាភរណៈ និងភោជនដែលជាទិព្វឲ្យ ។ សក្កទេវរាជទ្រង់ស្តាប់ពាក្យ

នោះហើយ ត្រាស់ថា សាធុ ហើយទ្រង់និម្មិតប្រាសាទកែវផលិកឲ្យជាលំនៅ របស់នាង ស្រេចហើយ ទ្រង់និម្មិតទីដេកដែលជាទិព្វ គ្រឿងប្រដាប់ វត្ថាភរណៈនិងបាយទឹកដែលជាទិព្វឲ្យ ។

ប្រាសាទនោះ កាលនាងឡើងក៏ស្រុតចុះមកស្ថិតនៅត្រង់ផែនដី តែកាល នាងចុះហើយ ក៏លូតឡើងទៅលើអាកាស ។ នាងធ្វើវត្ត បដិបត្ត ព្រះពោធិសត្វនៅក្នុងប្រាសាទ ។ ព្រានព្រៃម្នាក់ឃើញនាង ទើបសាកសួរថា បពិត្រ លោកម្ចាស់ ស្រីនេះជាអ្វីរបស់លោក បានឮថា ជាកូនស្រី ទើបទៅកាន់ នគរពារាណសី ទូលព្រះរាជាថា បពិត្រព្រះករុណាជីវិតតម្កល់លើត្បូង ទូល បង្គំបានឃើញធីតារបស់តាបសមួយរូប មានរូបយ៉ាងនេះ គឺស្អាតល្អក្នុងទ្វីប ព្រៃហិមពាន្ត ។ ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ដាក់ព្រះទ័យ ព្រោះ ជាប់ជំពាក់នឹងការបានដំណឹងនោះ ទើបឲ្យព្រានព្រៃនាំផ្លូវ យាងទៅកាន់ទី នោះដោយចតុរង្គសេនា ទ្រង់បោះជំរំទុកហើយ ទ្រង់នាំព្រានព្រៃទៅ មានពួក អាមាត្យចោមរោម យាងទៅកាន់អាស្រមបទ ទ្រង់ថ្វាយបង្គំមហាសត្វហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង ត្រាស់ថា បពិត្រលោកម្ចាស់ ស្រីឈ្មោះថាជា មន្ទិលរបស់ព្រហ្មចរិយៈ ខ្ញុំនឹងចិញ្ចឹមធីតារបស់លោកម្ចាស់ ។

ឯព្រះពោធិសត្វ បានដាក់ឈ្មោះកុមារិកានោះថា អាសង្កាកុមារី ព្រោះ លោកសង្ស័យថា អ្វីហ្ន៎ក្នុងផ្កាឈូកនេះ ហើយទើបចុះទឹកទៅយកមក ។

ព្រះពោធិសត្វ មិនទូលព្រះរាជាត្រង់ៗថា សូមមហាបពិត្រយកនាងទៅ ចុះ តែទូលថា មហាបពិត្រ បើទ្រង់ជ្រាបឈ្មោះរបស់កុមារិកានេះហើយសូម

ទ្រង់ទទួលយកចុះ ។ ព្រះរាជាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ប្រាប់ខ្ញុំ ខ្ញុំនឹងស្គាល់ ។

ព្រះពោធិសត្វទូលថា អាត្មាមិនប្រាប់មហាបពិត្រទេ សូមមហាបពិត្រទ្រង់ជ្រាបនាមដោយកម្លាំងបញ្ញារបស់ទ្រង់ឯង ហើយទទួលយកចុះ ។

ព្រះរាជាទទួលពាក្យហើយ ចាប់តាំងអំពីនោះមក ទើបទ្រង់ពិចារណាមើលឈ្មោះរបស់នាង មួយអន្លើដោយអាមាត្យទាំងឡាយថា ស្រីនេះឈ្មោះអ្វីហ្ន៎ ព្រះរាជាទ្រង់កំណត់ឈ្មោះទុកជាច្រើន ដែលគេដឹងបានដោយលំបាក រួចត្រាស់ប្រាប់ដល់ព្រះពោធិសត្វថា នាងឈ្មោះនោះៗ ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ក៏បដិសេធថា មិនមែនឈ្មោះយ៉ាងនេះទេ ។ លំដាប់នោះ កាលព្រះរាជាទ្រង់ពិចារណាឈ្មោះនោះឯង ពេលវេលាកន្លងទៅមួយឆ្នាំហើយ ។ គ្រានោះ សត្វសាហាវទាំងឡាយ មានសីហៈជាដើម ចាប់ដំរី សេះ និងមនុស្សទាំងឡាយស៊ីជាអាហារ អន្តរាយអំពីសត្វលូន សត្វវារក៏មាន អន្តរាយអំពីបេបមក៏មាន ។ មនុស្សទាំងឡាយលំបាក ព្រោះរង៉ោ ក៏ស្លាប់ជាច្រើន ទើបព្រះរាជាទ្រង់ក្រោធ ហើយគិតថា អញត្រូវការអ្វីដោយស្រីនេះ ត្រាស់ប្រាប់ព្រះពោធិសត្វហើយ ក៏យាងទៅ ។ ថ្ងៃនោះ អាសង្កាកុមារិកាបើកបង្អួចកែវផលិក ហើយបានឈរបង្ហាញខ្លួន ព្រះរាជាទតឃើញហើយ ត្រាស់ថា ខ្ញុំមិនអាចស្គាល់ឈ្មោះរបស់នាងបានទេ ចូរនាងនៅត្រង់ព្រៃហិមពាន្តចុះ ខ្ញុំនឹងទៅ កុមារិកាទូលថាបពិត្រមហារាជ ទ្រង់ទៅទីណាដែលបានស្រីប្រហែលខ្ញុំ សូមទ្រង់ស្តាប់ពាក្យរបស់ខ្ញុំ វល្លិឈ្មោះអាសាវតីមានក្នុង ចិត្តលតាវន

មានក្នុងទេវលោកជាន់តាវត្តិង្ស ទឹកទិព្វកើតខាងក្នុងផ្លែរបស់វា ទេវតាទាំងឡាយផឹកទឹកនោះតែម្តង ដេកស្រវឹងលើសយនាទិព្វអស់ ៤ ខែ តែវល្លិអាសាវតីនោះ ១០០០ ឆ្នាំ ទើបផ្លែម្តង ពួកទេវបុត្តដែលញៀនសុរា គិតថា ពួកយើងនឹងបានផ្លែអំពីវល្លិអាសាវតីនេះ ទើបឃាត់នូវការស្រេកក្នុងទឹកទិព្វនោះ នាំគ្នាទៅមើលវល្លិនោះរឿយៗ អស់ ១០០០ ឆ្នាំថា មិនទាន់ផុតក័យទេឬ ចំណែកទ្រង់គ្រាន់តែ ១ ឆ្នាំ ក៏រារែកព្រះទ័យហើយ ធម្មតាការប្រាថ្នាដែលមានផល គឺការសម្រេចបំណង ជាហេតុឲ្យកើតសុខ សូមទ្រង់កុំរួញរាព្រះទ័យឡើយ ដូច្នេះហើយ ពោលគាថា ៣ ថា

វល្លិ៍ឈ្មោះអាសាវតី កើតក្នុងឧទ្យានឈ្មោះ ចិត្តលតាវន
វល្លិ៍នោះក្នុងមួយពាន់ឆ្នាំ ទើបកើតផ្លែ ១ ។

ទោះបីផ្លែមាននៅក្នុងទីឆ្ងាយដល់ម្លោះ ពួកទេវតា នៅតែ
ចូលទៅរកវល្លិ៍នោះ បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ
សេចក្តីប្រាថ្នារមែងមានផលនាំមកនូវសេចក្តីសុខ ។

អម្បាលសត្វស្លាបនោះ ( កុក ) នៅប្រាថ្នាបាន អម្បាល
សត្វមានកំណើតពីរគង់ប្រាថ្នាបាន ថ្វីបើទន្លេមាននៅក្នុងទីឆ្ងាយ
សេចក្តីប្រាថ្នារបស់កុកនោះ គង់សម្រេចមិនខាន បពិត្រព្រះ
រាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្តីប្រាថ្នារមែងមានផល ជា
សុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាសាវតី** បានដល់ វល្លិដែលមានឈ្មោះ

យ៉ាងនេះ អធិប្បាយថា វល្លិនោះបានឈ្មោះយ៉ាងនេះ ព្រោះទេវតាកើតសេចក្តីសង្ឃឹមក្នុងផ្លែរបស់វា ។

បទថា **ចិត្តលតាវនេ** សេចក្តីថា ក្នុងសួនដែលមានឈ្មោះយ៉ាងនេះ ។ បានឮថា ក្នុងសួននោះ រស្មីរបស់ដើមឈើនិងវល្លិ មានពណ៌ដូចរាងកាយទេវតាទាំងឡាយដែលចូលទៅក្នុងសួននោះ ឲ្យវិចិត្រស្រស់ស្អាត ដោយហេតុនោះ ទើបសួននោះកើតឈ្មោះថា ចិត្តលតាវន ។ បទថា **បយិរុបាសន្តិ** បានដល់ ចូលទៅទន្ទឹងមើលរឿយ ៗ ។ បទថា **អាសីសេវ** បានដល់ សូមទ្រង់ទន្ទឹងចុះ គឺទ្រង់ប្រាថ្នានោះឯង បានដល់ កុំធ្វើកម្ម គឺកាត់នូវការសង្ឃឹមចោល ។ ព្រះរាជាទ្រង់ដាក់ព្រះទ័យក្នុងពាក្យរបស់នាង ទើបទ្រង់ប្រជុំអាមាត្យទាំងឡាយ ទ្រង់ស្វែងរកឈ្មោះរបស់នាងដោយតាំងឈ្មោះ ១០ បាននៅប្រថាប់ ១ ឆ្នាំទៀត ក្នុងឈ្មោះ ១០ នោះ មិនមានឈ្មោះរបស់នាង កាលព្រះរាជាត្រាស់ថា ឈ្មោះនេះ ព្រះពោធិសត្វបដិសេធដូចគ្នា ។ ទើបព្រះរាជាទ្រង់មកទៀតដោយត្រិះរិះថា អញត្រូវការអ្វីដោយស្រីនេះ ។ ចំណែកនាងក៏ឈរត្រង់មាត់បង្អួចបង្ហាញខ្លួនឲ្យឃើញទៀត ព្រះរាជាទ្រង់ឃើញនាងហើយបានត្រាស់ថា ពួកយើងមិនអាចស្គាល់ឈ្មោះនាង ចូរនាងនៅត្រង់ព្រៃហិមពាន្តចុះ ពួកយើងនឹងត្រឡប់ នាងពោលថា បពិត្រមហារាជ ហេតុអ្វីទើបទ្រង់ទៅ ព្រះរាជាត្រាស់ថា ខ្ញុំមិនអាចស្គាល់ឈ្មោះរបស់នាង នាងទូលថា បពិត្រមហារាជ ហេតុអ្វីទ្រង់មិនស្គាល់ឈ្មោះ ធម្មតាសេចក្តីសង្ឃឹមដែលមិនឲ្យសម្រេចតាមបំណងមិនមាន សូមទ្រង់ស្តាប់ពាក្យរបស់ខ្ញុំសិន បានឮថា

កុកមួយទំលើកំពូលភ្នំ តែក៏បានទទួលវត្ថុដែលខ្លួនប្រាថ្នា ហេតុអ្វីទើបទ្រង់មិនបានទទួល បពិត្រមហារាជ សូមទ្រង់បន្អង់សិនចុះ បានឮថា កុកមួយហើរទៅពាំចំណីត្រង់ស្រះឈូកមួយ ហើយត្រឡប់មក ទំលើកំពូលភ្នំ កុកនៅទីនោះឯង អស់ថ្ងៃនោះ ស្អែកឡើងទើបគិតថា អញបានទំយ៉ាងសប្បាយលើភ្នំនេះ បើអញមិនឃ្លាតទៅអំពីទីនេះ ទំត្រង់ទីនេះប៉ុណ្ណោះ ពាំយកចំណី ផឹកទឹកហើយ នៅអស់ថ្ងៃនេះគង់ចម្រើនហ្ន៎ ។ ក្នុងថ្ងៃនោះឯង សក្កទេវរាជទ្រង់ធ្វើការញាំញីពួកអសុរ បាននូវភាពជាធំក្នុងទេវលោកក្នុងតាវត្តិង្សពិភពហើយទ្រង់ត្រិះរិះថា ជាបឋម មនោរថ គឺសេចក្តីត្រូវការរបស់អញបានដល់ទីបំផុតអ្នកដទៃ មានមនោរថមិនទាន់ដល់ទីបំផុតមានឬមិនមាន ។ សក្កទេវរាជទ្រង់ពិចារណាឃើញកុកនោះ ទើបត្រិះរិះថា អញនឹងឲ្យ មនោរថរបស់កុកដល់ទីបំផុត ។ ហើយទ្រង់បណ្តាលឲ្យស្ទឹងមួយខ្សែ ដែលនៅមិនឆ្ងាយអំពីកុកនោះពេញទៅដោយជំនន់ទឹក ហើយបញ្ជូនទឹកទៅលើកំពូលភ្នំ ។ កុកទំលើកំពូលភ្នំនោះឯង ស៊ីត្រី ផឹកទឹកហើយក្នុងទីនោះឯង អស់ថ្ងៃនោះ ក្រោយមក ទឹកក៏រីងស្ងួតទៅ ។ បពិត្រមហារាជ កុកមិនទាន់បានទទួលផលព្រោះការសង្ឃឹមរបស់ខ្លួនយ៉ាងនេះមុន ហេតុអ្វី ទ្រង់មិនបានទទួល ដូច្នេះហើយបានពោលគាថាថា **អាសីសេថេវ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អាសីសេថេវ** បានដល់ ចូរសង្ឃឹមចុះ គឺចូរប្រាថ្នាចុះ ។ បទថា **បក្ខី** បានដល់ បក្សី ឈ្មោះថា **បក្ខី** ព្រោះប្រកបដោយស្លាប ។ ឈ្មោះថា **ទិជោ** ព្រោះកើត ២ ដង ។ បទថា **តាវទ្ធរ-**

**គតា សតិ** សេចក្តីថា សូមទ្រង់មើលចុះ ភាពដែលត្រីនិងទឹកមាននៅក្នុងទីឆ្ងាយពីកំពូលភ្នំ តែការទទឹងរបស់កុកនោះ មានក្នុងរយៈឆ្ងាយយ៉ាងនេះគង់ពេញបានដូចគ្នា ដោយអានុភាពរបស់សក្កៈ ។

កាលនោះ ព្រះរាជាបានស្តាប់ពាក្យរបស់នាងហើយ ទ្រង់ជាប់ចិត្តក្នុងរូប ទ្រង់ជាប់ចិត្តក្នុងសំឡេងរបស់នាង មិនអាចយាងទៅ ទ្រង់ប្រជុំអាមាត្យទាំងឡាយ តាំងឈ្មោះ ១០០ កាលទ្រង់ស្វែងរកឈ្មោះ ១០០ ក៏កន្លងទៅមួយឆ្នាំទៀត ព្រះរាជាចូលទៅរកព្រះពោធិសត្វ ដោយកាលកន្លងទៅ ៣ ឆ្នាំ ត្រាស់សួរតាមអំណាចរបស់ឈ្មោះ ១០០ ថា បពិត្រលោកម្ចាស់ នាងមានឈ្មោះនេះ មានឈ្មោះនេះ ។ ព្រះពោធិសត្វទូលថា សូមថ្វាយព្រះពរមហាបពិត្រ ទ្រង់មិនស្គាល់ឈ្មោះរបស់នាង ។ ព្រះរាជាត្រាស់ថា ឥឡូវនេះ ពួកខ្ញុំនឹងលាទៅ ទ្រង់ថ្វាយបង្គំព្រះពោធិសត្វយាងចេញទៅ ។ អាសង្កាកុមារិកាក៏បានឈរផ្អែកទ្វារបង្អួចកែវផលិកទៀតនោះឯង ។ ព្រះរាជាទតឃើញហើយត្រាស់ថា ចូរនាងនៅចុះ ខ្ញុំនឹងទៅ នាងទូលថា បពិត្រមហារាជ ហេតុអ្វីទើបទ្រង់ទៅ ព្រះរាជាត្រាស់ថា នាងឲ្យយើងត្រេកអរដោយពាក្យតែម្យ៉ាង តែមិនឲ្យត្រេកអរក្នុងកាម ៣ ឆ្នាំបានកន្លងទៅហើយ សម្រាប់ខ្ញុំដែលជាប់ចិត្តក្នុងពាក្យផ្អែមរបស់នាង ឥឡូវនេះ ខ្ញុំនឹងទៅ ហើយបានត្រាស់គាថាទាំងនេះថា

នាងបានញ៉ាំងខ្ញុំឲ្យឆ្អែតដោយវាចា មិនឆ្អែតដោយការងារ
ដូចជាផ្កាកម្រងនៃឈើសោរេយ្យកៈ មានតែពណ៌ មិនមាន

ក្លិន ។

បុគ្គលណាមិនឲ្យ មិនលះបង់ភោគៈ គ្រាន់តែធ្វើនូវវាចាដ៏ពីរោះ ជាវាចាឥតផលចំពោះមិត្តទាំងឡាយ តំណ ( នៃសេចក្តីស្និទ្ធស្នាល ) របស់បុគ្គលនោះរមែងសាបសូន្យ ទៅដោយហេតុនោះឯង ។

ពិតណាស់ បុគ្គលធ្វើនូវអំពើណាគប្បីនិយាយនូវអំពើនោះ មិនធ្វើនូវអំពើណា មិនគប្បីនិយាយនូវអំពើនោះ បណ្ឌិតទាំងឡាយរមែងកំណត់ដឹងនូវបុគ្គលអ្នកមិនធ្វើ គ្រាន់តែនិយាយ ។

ពលរបស់ខ្ញុំអស់ហើយ ទាំងស្បៀងអាហារក៏មិនមាន ខ្ញុំរង្កៀសចំពោះការវិនាសនៃជីវិត បើដូច្នោះខ្ញុំនឹងទៅឥឡូវនេះ ។

បណ្តាបទទាំងនោះ បទថា **សមេ្មសិ** បានដល់ ឲ្យឆ្អែត គឺឲ្យឆ្អែតស្កប់ស្កល់ ។ ពាក្យថា **មាលា សោរេយ្យកស្សេវ** បានដល់ ផ្កាដកគាំ ពាក្យនេះត្រឹមតែជាមាតិកានៃទេសនា ។ តែព្រះរាជាត្រាស់សំដៅដល់ផ្កាដទៃៗ គ្រប់យ៉ាងនោះឯងដែលមានពណ៌ស្អាត តែមិនមានក្លិន ដូចជាផ្កាដកគាំ ផ្កាកន្ទុយដំរី និងផ្កាច្បាជាដើម ។ បទថា **វណ្ណវន្តា អគន្ធិកា** ព្រះរាជាទ្រង់សម្តែងថា ផ្ការបស់ដើមសេមាន់ជាដើម ឲ្យអ្នកដទៃឆ្អែតដោយការមើល ព្រោះមានពណ៌ស្អាត តែមិនឆ្អែតដោយក្លិន ព្រោះមិនមានក្លិន យ៉ាងណា នាងក៏យ៉ាងនោះ ឲ្យយើងឆ្អែតដោយការទស្សនានិងពាក្យជាទីស្រឡាញ់ តែមិនឲ្យឆ្អែតដោយវត្ថុដែលគួរធ្វើ ។ បទថា **អធនំ** សេចក្តីថា នៃនាងតូច បុគ្គលណា

ពោលដោយពាក្យផ្អែមថា ខ្ញុំនឹងឲ្យគោគទ្រព្យឈ្មោះនេះដល់អ្នក តែមិនឲ្យ មិនលះបង់គោគៈនោះ ឈ្មោះថាសាងនូវពាក្យផ្អែមតែម្យ៉ាងប៉ុណ្ណោះមិត្តសម្ពន្ធ របស់បុគ្គលនោះនឹងវិនាសទ្រុឌទ្រោម គឺមិនជាប់ដោយមិត្តសន្ថវៈ ។ បទថា **ចាជយ្យញ្ញុ** សេចក្ដីថា នែនាង កាលខ្ញុំជាប់ចិត្តនឹងពាក្យផ្អែមរបស់នាង នៅទីនេះប៉ុណ្ណោះ អស់កាល ៣ ឆ្នាំ មួយអន្លើដោយកម្លាំងពល ពោលគឺ ដំរី សេះ រថ និងពលថ្មើរជើង លះបង់នូវស្បៀង ពោលគឺអាហារ និងបៀ-វត្ស អ្នកទាំងនោះក៏មិនមាន ។ បទថា **សន្តេ ចាណ្ហាបកោដាយ** សេចក្ដីថា យើងនោះ ( អាសង្កា ) សង្ស័យ គឺដល់នូវសេចក្ដីវិនាសនៃជីវិតរបស់ខ្លួន ក្នុងទីនេះឯង អញ្ជើញចុះ ខ្ញុំនឹងទៅឥឡូវនេះឯង ដូច្នេះ ។

អាសង្កាកុមារិកាបានស្ដាប់ព្រះរាជតម្រាស់ហើយ កាលនឹងទូលប្រាស្រ័យ ជាមួយព្រះរាជាថា បពិត្រមហារាជ សូមទ្រង់ជ្រាបឈ្មោះរបស់ខ្ញុំចុះ ឈ្មោះ របស់ខ្ញុំទ្រង់ត្រាស់ហើយនោះឯង សូមទ្រង់លើកឈ្មោះនេះ ដល់បិតារបស់ខ្ញុំ ហើយទទួលយកខ្ញុំចុះ ដូច្នេះហើយ បានទូលថា

បពិត្រព្រះអង្គទ្រង់ប្រសើរលើរថ ពាក្យណាដែលមាននៅក្នុង
ឈ្មោះ ពាក្យនុ៎ះឯងជាឈ្មោះរបស់ខ្ញុំព្រះអង្គ បពិត្រមហារាជ
សូមព្រះអង្គរង់ចាំចុះ ខ្ញុំព្រះអង្គនឹងអញ្ជើញបិតាសិន ដូច្នេះ ។

គាថានោះមានអត្ថថា ព្រះរាជាត្រាស់ពាក្យណានឹងខ្ញុំ ពាក្យថា **អាសង្កា** នោះឯង ជាឈ្មោះរបស់ខ្ញុំ ។

ព្រះរាជាកាលទ្រង់ស្ដាប់ពាក្យនោះហើយ ទើបយាងទៅកាន់សម្នាក់របស់តា

បស ទ្រង់ថ្វាយបង្គំហើយ ត្រាស់ថា បពិត្រលោកម្ចាស់ ធីតារបស់លោកម្ចាស់ឈ្មោះអាសង្កា ។ ព្រះមហាសត្វបានស្តាប់ពាក្យនោះហើយ ទើបទូលថា សូមថ្វាយព្រះពរមហាបពិត្រ តាំងអំពីកាលដែលមហាបពិត្រទ្រង់ស្គាល់ឈ្មោះហើយ សូមមហាបពិត្រទ្រង់ទទួលនាងចុះ ។ ទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ថ្វាយបង្គំព្រះមហាសត្វ យាងមកកាន់វិមានកែវផលិក ត្រាស់ថា នែនាង ថ្ងៃនេះ បិតាបានឲ្យនាងដល់ខ្ញុំហើយ មកយើងនឹងទៅឥឡូវនេះ ។ នាងបានស្តាប់ពាក្យនោះហើយ ទើបទូលថា បពិត្រមហារាជ សូមទ្រង់បង្អង់សិន ខ្ញុំនឹងប្រាប់បិតាសិន ហើយចុះអំពីប្រាសាទ ថ្វាយបង្គំព្រះមហាសត្វ យំ ខមាទោស ហើយបានទៅកាន់រាជសម្នាក់ ។ ព្រះរាជាទ្រង់នាំនាងទៅកាន់នគរពារាណសី ប្រថាប់នៅគ្រប់គ្រងដោយសេចក្តីស្រឡាញ់ ព្រះនាងចម្រើនដោយព្រះរាជឱរសនិងព្រះរាជធីតា ។ ព្រះពោធិសត្វមិនវិនាសបាកឈាន មរណភាពហើយ កើតក្នុងព្រហ្មលោក ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយក្នុងកាលចប់សច្ចធម៌ ភិក្ខុអផ្សុក តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំ ជាតកថា អាសង្កាកុមារិកាក្នុងកាលនោះ បានជាភរិយាចាស់ក្នុងកាលបច្ចុប្បន្ននេះ ព្រះរាជាក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា អាសង្កជាតក ចប់**

# មិគលោបជាតក

[ ១៦២ ] ( ត្មាតពោធិសត្វនិយាយនឹងកូនថា ) ម្នាលមិគលោបៈ ដំណើររបស់អ្នកប្រាកដដូច្នោះ មិនពេញចិត្តអញទេ ម្នាលកូនត្បិតអ្នកហើរទៅខ្ពស់ពេក ម្នាលកូនអ្នកសេពគប់នូវទីមិនមែនផែនដី ។

[ ១៦៣ ] ផែនដីប្រាកដដល់អ្នក ដូចជាស្រែមានជ្រុង ៤ ម្នាលកូន ចូរអ្នកត្រឡប់អំពីទីនោះមកវិញ កុំទៅហួសអំពីទីនេះឡើយ ។

[ ១៦៤ ] ពួកសកុណជាតិឯទៀត មានស្លាបជាយាន ទៅកាន់អាកាស ពួកសត្វទាំងនោះសម្គាល់ខ្លួនថាស្មើដោយវត្ថុដ៏ទៀងទាត់ ត្រូវកម្លាំងខ្យល់បក់បោកវិនាស ។

[ ១៦៥ ] ( ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា ) មិគលោបៈ មិនធ្វើតាមពាក្យប្រដៅរបស់បិតាចាស់ ឈ្មោះអបរណ្ណៈ ហើរកន្លងនូវខ្យល់វេរម្ភកាល បានទៅដល់អំណាចនៃខ្យល់ព្យុះ ។

[ ១៦៦ ] កូនក្តីប្រពន្ធក្តីឬសត្វឯទៀតជាអ្នកចិញ្ចឹមជីវិតតាម មិគលោបៈនោះ ពួកសត្វស្លាបទាំងអស់ ក៏ដល់នូវសេចក្តីវិនាស ព្រោះទិជជាតិ ( មិគលោបៈ ) មិនធ្វើតាមឱវាទ ។

[ ១៦៧ ] បុគ្គលណាមិនយល់នូវពាក្យរបស់បុគ្គលចាស់ទុំ ក្នុងលោកនេះ បុគ្គលនោះ ( ដល់នូវសេចក្តីវិនាស ) ដូចជាត្មាតកន្លងពាក្យប្រៀនប្រដៅ ជាសត្វភ្លើតភ្លើនត្រាច់ទៅកាន់ទីហួសដែន ជនទាំងអស់ដល់នូវសេចក្តីវិនាស ព្រោះមិនធ្វើតាមពាក្យប្រដៅរបស់ព្រះពុទ្ធ ។

**ចប់ មិគលោបជាតកទី ៦ ។**

# អដ្ឋកថា

# មិគាលោបជាតក

[ ១៦២-១៦៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **ន មេ រុចិ** ដូច្នេះជាដើម ។

ក្នុងកាលនោះ ព្រះសាស្ដាបានហៅភិក្ខុនោះមក ហើយត្រាស់សួរថា ពិតឬភិក្ខុ បានឮថា អ្នកជាមនុស្សប្រដៅក្រ កាលលោកទូលថា ករុណា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលប្រដៅក្រដូចគ្នា ព្រោះអាស្រ័យភាពជាអ្នកប្រដៅក្រ អ្នកមិនជឿពាក្យរបស់បណ្ឌិតទាំងឡាយ ទើបដល់នូវសេចក្ដីវិនាសក្នុងរវាងផ្លូវរបស់ខ្យល់វេរម្ភៈ ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យ នៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាសត្វត្មាត មានឈ្មោះថា អបរណ្ណ មានពួកត្មាតចោមរោម អាស្រ័យនៅលើភ្នំគិជ្ឈកូដ ។ ឯកូនរបស់ត្មាត ឈ្មោះមិគាលោបៈ ជាសត្វសម្បូរដោយកម្លាំង ត្មាតនោះហើរខ្ពស់ហួសដែនរបស់ត្មាតដទៃៗ ត្មាតទាំងឡាយប្រាប់ដល់ស្ដេចត្មាតថា កូនរបស់លោកហើរឆ្ងាយពន់ពេក ។ ត្មាតអបរណ្ណបានស្ដាប់ដូច្នោះហើយ ហៅកូនមកសួរថា នែកូនបានឮថា ឯងហើរខ្ពស់ណាស់ ឯងហើរខ្ពស់នឹងដល់នូវការអស់ជីវិត ហើយពោលគាថា ៣ ថា

ម្នាលមិគលោបៈ ដំណើររបស់អ្នកប្រាកដដូច្នោះ មិនពេញចិត្តអញទេ ម្នាលកូនត្បិតអ្នកហើរទៅខ្ពស់ពេក ម្នាលកូនអ្នកសេពគប់នូវទីមិនមែនផែនដី ។

ផែនដីប្រាកដដល់អ្នកដូចជាស្រែមានជ្រុង ៤ ម្នាលកូនចូរអ្នកត្រឡប់អំពីទីនោះមកវិញ កុំទៅហួសអំពីទីនេះឡើយ ។

ពួកសកុណជាតិឯទៀត មានស្លាបជាយានទៅកាន់អាកាស ពួកសត្វទាំងនោះសម្គាល់ខ្លួនថាស្មើដោយវត្ថុដ៏ទៀងទាត់ ត្រូវកម្លាំងខ្យល់បក់បោកវិនាស ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះថា ត្វាតជាឪពុក ហៅកូនដោយឈ្មោះថា មិគាលោបៈ ។ បទថា **អតុច្ចំ តាត គច្ឆសិ** សេចក្តីថា នែកូន អ្នកកុំហើរខ្ពស់ហួសដែនរបស់ត្មាតដទៃ ត្មាតជាឪពុកប្រាប់ដែនដល់កូនដោយពាក្យនេះថា **ចតុក្កណ្ណំវ កេទារំ** គឺដូចស្រែ ៤ ជ្រុង ។ មានអធិប្បាយថា នែកូន កាលផែនដីនេះដូចស្រែ ៤ ជ្រុងសម្រាប់អ្នក គឺប្រាកដជាទំហំតូចយ៉ាងនេះ កាលនោះអ្នកគួរត្រឡប់អំពីទីប្រមាណប៉ុណ្ណេះ កុំទៅហួសនោះឡើយ ។ បទថា **សន្តិ អញ្ញេបិ** ជាដើម សេចក្តីថា ត្មាតជាឪពុកសម្តែងថា មិនមែនអ្នកតែម្នាក់ប៉ុណ្ណោះ សូម្បីត្មាតដទៃៗ ក៏ធ្វើយ៉ាងនេះមកហើយ ។ បទថា **ឧក្ខិត្តា** សេចក្តីថា សូម្បីពួកគេហើរហួសដែនរបស់ពួកយើងទៅ ត្រូវកម្លាំងខ្យល់វាយឲ្យវិនាសទៅហើយ ។ បទថា **សស្សតីសមា** អធិប្បាយថា ពួកវាសម្គាល់ខ្លួនថា ជាអ្នកស្មើដោយផែនដី និងភ្នំទាំងឡាយ ដែលស្ថិតស្ថេរ

សូម្បីអាយុរបស់ខ្លួនមានប្រមាណ ១០០០ ឆ្នាំ មិនទាន់ពេញបរិបូណ៌ ក៏វិនាសទៅហើយក្នុងចន្លោះ ។

ឯមិគាលោបៈមិនធ្វើតាមឱវាទ មិនស្តាប់ពាក្យរបស់បា រឹងរឹតតែហោះខ្ពស់ឡើង ឃើញដែនតាមដែលបាប្រាប់ហើយ ក៏ហើរំលងដែននោះទៅ ដល់ខ្យល់កាលវាត ហើរហួសខ្យល់កាលវាត រសាត់ចូលដល់គន្លងខ្យល់វេរម្ភវាត ទើបត្រូវខ្យល់វេរម្ភវាតបក់បោកត្មាតនោះ បែកខ្ទេចខ្ទីជាចម្រៀកតូចធំអន្តរធានក្នុងអាកាសនោះឯង ដោយហេតុនោះ ទើបលោកពោលទុកថា

មិគលោបៈ មិនធ្វើតាមពាក្យប្រដៅរបស់បិតាចាស់ ឈ្មោះអបរណ្ណៈ ហើរកន្លងនូវខ្យល់រដូវកាល បានទៅដល់ អំណាចនៃខ្យល់ព្យុះ ។

កូនក្តីប្រពន្ធក្តីឬសត្វឯទៀតជាអ្នកចិញ្ចឹមជីវិតតាមមិគលោ-បៈនោះ ពួកសត្វស្លាបទាំងអស់ ក៏ដល់នូវសេចក្តីវិនាស ព្រោះទិជជាតិ ( មិគលោបៈ ) មិនធ្វើតាមឱវាទ ។

បុគ្គលណាមិនយល់នូវពាក្យរបស់បុគ្គលចាស់ទុំ ក្នុងលោកនេះ បុគ្គលនោះ ( ដល់នូវសេចក្តីវិនាស ) ដូចជាត្មាតកន្លងពាក្យប្រៀនប្រដៅ ជាសត្វក្អឺតក្អឺនត្រាច់ទៅកាន់ទីហួសដែន ជនទាំងអស់ដល់នូវសេចក្តីវិនាសព្រោះមិនធ្វើតាមពាក្យប្រដៅរបស់ព្រះពុទ្ធ ដូច្នេះ ។

គាថា ៣ នេះ ជាអភិសម្ពុទ្ធគាថា ។

បណ្ដាបទទាំងនោះ បទថា **អនុជីវិនោ** បានដល់ ត្មាតទាំងឡាយដែលអាស្រ័យត្មាតមិគាលោបៈនោះចិញ្ចឹមជីវិត ។ បទថា **អនោវាទករេ ទិជេ** សេចក្ដីថា កាលត្មាតមិគាលោបៈនោះ មិនធ្វើតាមឱវាទ ត្មាតទាំងនោះ ហើរទៅជាមួយត្មាតមិគលោបៈនោះ ហួសដែនទៅ ដល់នូវសេចក្ដីវិនាសទាំងអស់ ។ បទថា **ឯវម្បិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ត្មាតនោះដល់នូវសេចក្ដីវិនាសហើយយ៉ាងណា សូម្បីបុគ្គលដទៃ ទោះជាគ្រហស្ថក្ដី ជាបព្វជិតក្ដី ក៏យ៉ាងនោះដូចគ្នា មិនជឿព្រះតម្រាស់របស់អ្នកត្រាស់ដឹងទាំងឡាយដែលជាអ្នកអនុគ្រោះដោយប្រយោជន៍ បុគ្គលនោះក៏ដល់នូវសេចក្ដីវិនាស ដូចត្មាតនេះ ដែលត្រាច់ទៅហួសដែន ជាអ្នកក្ដៅក្រហាយ គឺលំបាកហើយ ដូច្នោះ ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមក ទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតកថា ត្មាតឈ្មោះមិគាលោបៈក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ឯត្មាតអបរណ្ណក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មិគលោបជាតក ចប់

# សិរិកាឡកណ្ណិជាតក

[ ១៦៨ ] ( សុចិបរិវារសេដ្ឋីពោធិសត្វសួរនាងទេវធីតាឈ្មោះកាឡកណ្ណី ថា ) នាងជាអ្វី មានវណ្ណៈខ្មៅ ទាំងមិនមានគ្រឿងមើលជាទីស្រឡាញ់ នាងជាអ្វី ឬជាធីតារបស់អ្នកណា យើងស្គាល់នាងដូចម្តេចបាន ។

[ ១៦៩ ] ( នាងកាឡកណ្ណីឆ្លើយថា ) ខ្ញុំឈ្មោះចណ្ឌិយា ជាធីតានៃមហារាជឈ្មោះវិរូបក្ខៈ ខ្ញុំមានសម្បុរខ្មៅ ជាស្ត្រីឥតបុណ្យ ពួកទេវតារមែងស្គាល់ខ្ញុំថាជាកាឡកណ្ណី អ្នកកាលបើខ្ញុំសូមឱកាស សូមឲ្យយើងនឹងនៅក្នុងសម្នាក់នៃអ្នក ។

[ ១៧០ ] ( សេដ្ឋីពោធិសត្វសួរថា ) នាងតម្កល់ចិត្តចំពោះបុរសមានសីលធម៌ដូចម្តេច មានសមាចារដូចម្តេច ម្នាលនាងកាឡី នាងខ្ញុំសួរហើយ ក៏ចូរប្រាប់មក យើងនឹងស្គាល់នាងដូចម្តេចបាន ។

[ ១៧១ ] ( នាងកាឡកណ្ណី ឆ្លើយប្រាប់ថា ) បុរសណាជាអ្នកលុបគុណ ប្រឡូងវាសនា ប្រណាំងប្រជែង ច្រណែន កំណាញ់ ជាអ្នកអួតអាង បានទ្រព្យហើយបំផ្លាញទៅវិញ បុរសនោះជាទីត្រេកអររបស់ខ្ញុំ ។

[ ១៧២ ] បុរសណាច្រើនក្រោធ ចងសេចក្តីក្រោធទុក ញុះញង់បំបែកមិត្ត ពោលពាក្យចាក់ដោតដូចបន្លា ពោលពាក្យទ្រគោះ បុរសនោះជាទីត្រេកអរក្រៃលែងរបស់ខ្ញុំជាងនោះទៅទៀត ។

[ ១៧៣ ] បុរសមិនយល់ប្រយោជន៍របស់ខ្លួនថា ( កិច្ចនេះត្រូវធ្វើ ) ក្នុងថ្ងៃនេះឬក្នុងថ្ងៃស្អែកកាលបើគេទូន្មានក៏ខឹងតបមើលងាយនូវបុគ្គលប្រសើរ ។

[ ១៧៤ ] បុរសណាជាប់ចិត្តក្នុងល្បែង គឺកាមគុណ រមែងឃ្លាតចាក

មិត្តទាំងពួង បុរសនោះជាទីគ្រេកអររបស់ខ្ញុំ ទាំងខ្ញុំ ក៏មិនមានមោះមៃចំពោះបុរសនោះទេ ។

[ ១៧៥ ] ( ពោធិសត្វតិះដៀលថា ) ម្នាលនាងកាឡី នាងចូរជៀសចេញអំពីទីនេះទៅ អំពើអាក្រក់នេះ មិនមានក្នុងយើងទាំងឡាយទេ នាងចូរទៅកាន់ជនបទ ឬនិគមរាជធានីដទៃចុះ ។

[ ១៧៦ ] ( នាងកាឡកណ្ណីពោលថា ) ខ្ញុំក៏បានដឹងហេតុនោះដែរ អំពើនោះមិនមានក្នុងអ្នកទេ ពួកជនជាអ្នកឥតបុណ្យក្នុងលោក រមែងប្រមូលនូវទ្រព្យច្រើន ខ្ញុំនឹងទេវតាជាបងរបស់ខ្ញុំទាំងពីរនាក់តែងបំផ្លាញនូវទ្រព្យនុ៎ះ ។

[ ១៧៧ ] ( ពោធិសត្វសួរថា ) នាងជាអ្វី មានវណ្ណៈជាទិព្វ មកឋិតលើផែនដី នាងជាអ្វី ឬជាធីតារបស់នរណា យើងនឹង ស្គាល់នាងដូចម្តេចបាន ។

[ ១៧៨ ] ( នាងសិរីទេវធីតាពោលថា ) ខ្ញុំជាធីតានៃមហារាជឈ្មោះធតរដ្ឋដ៏មានសិរី ខ្ញុំជាស្ត្រីឈ្មោះសិរីផង លក្ខីផង ពួកទេវតារមែងស្គាល់ខ្ញុំថាជាស្ត្រីមានប្រាជ្ញាដូចផែនដី លោកខ្ញុំសូមឱកាសហើយ សូមឲ្យយើងនឹងសូមនៅក្នុងសម្នាក់លោក ។

[ ១៧៩ ] ( ពោធិសត្វសួរថា ) នាងនឹងតម្កល់ចិត្តចំពោះបុរសមានសីលធម៌ដូចម្តេច មានសមាចារៈដូចម្តេច ម្នាលលក្ខី ខ្ញុំសួរហើយ នាងចូរប្រាប់ យើងស្គាល់នាងដូចម្តេច ។

[ ១៨០ ] ( នាងសិរីទេវធីតាពោលថា ) បុរសណាគ្របសង្កត់នូវ

ត្រជាក់ក្តី ក្តៅក្តី ខ្យល់និងកម្តៅថ្ងៃក្តី រពោម ពស់តូច ពស់ធំក្តី ឃ្លានក្តី ស្រេកក្តីទាំងអស់ ហើយប្រកបព្យាយាម រឿយៗក្នុងវេលាយប់និងថ្ងៃ រមែងមិនញុំាងប្រយោជន៍ដែលតាំងនៅក្នុងកាលគួរឲ្យវិនាស បុរសនោះជាទីពេញចិត្តរបស់ខ្ញុំ ខ្ញុំគប្បីស៊ប់ចិត្តក្នុងបុរសនោះឯង ។

[ ១៨១ ] បុរសណាជាអ្នកមិនក្រោធ មានកល្យាណមិត្ត មានការបរិច្ចាគ ជាអ្នកបរិបូណ៌ដោយសីល មិនមែនជាអ្នកលេងបោកប្រាស់ ជាអ្នកត្រង់ ជាអ្នកមានសង្គហធម៌ មានវាចាទន់ភ្លន់ មានវាចាពីរោះ សូម្បីដល់នូវភាពជាអ្នកធំ ក៏ប្រព្រឹត្តឱនលំទោន ខ្ញុំជាអ្នកមានចិត្តធំទូលាយចំពោះបុរសនោះ ដូចជារលក ( ប្រាកដជារបស់ធំទូលាយដល់បុគ្គលដែលសម្លឹងមើល ) នូវពណ៌របស់សមុទ្ទ ។

[ ១៨២ ] បុគ្គលណា ប្រព្រឹត្តនូវសេចក្តីសង្គ្រោះ ក្នុងចំពោះមុខ កំបាំងមុខ ចំពោះមិត្តក្តី សត្រូវក្តី បុគ្គលប្រសើរក្តី ស្មើគ្នាក្តី ថោកទាបក្តី បុគ្គលអ្នកប្រព្រឹត្តនូវប្រយោជន៍ក្តី មិនមែនជាប្រយោជន៍ក្តី មិនពោលពាក្យអាក្រក់ក្នុងកាលណាមួង ខ្ញុំជាអ្នកគប់រកចំពោះបុរសនោះ ទោះបីស្លាប់ក្តីរស់ក្តី ។

[ ១៨៣ ] បណ្តាគុណទាំងនោះ បុរសណាមួយ ជាអ្នកគ្មានបញ្ញា បាននូវសិរី ជាទីត្រេកអរណាមួយ ហើយស្រវឹង ខ្ញុំវៀរនូវបុរសនោះ អ្នកប្រព្រឹត្តមិនស្មើ មានសភាពដ៏ក្តៅក្រហាយ ដូចជាបុគ្គលវៀរបង់នូវរណ្តៅលាមក ។

[ ១៨៤ ] បុគ្គលធ្វើនូវគុណសម្បត្តិ គឺបុណ្យដោយខ្លួនឯង ធ្វើនូវអំពើមិនមែនជាបុណ្យ ក៏ដោយខ្លួនឯង ព្រោះថាបុគ្គលដទៃ ធ្វើនូវគុណសម្បត្តិ

គឺបុណ្យក្តី មិនមែនបុណ្យក្តីដល់បុគ្គលឯទៀតមិនបានទេ ។

**ចប់ សិរីកាឡកណ្ណិជាតកទី ៧ ។**

# អដ្ឋកថា
# សិរីកាឡកណ្ណិជាតក

[ ១៦៨-១៨៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កាឡុ កាឡេឡុ វណ្ណេន** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា អនាថបិណ្ឌិកសេដ្ឋីនោះ ចាប់តាំងពីបានសម្រេចសោតាបត្តិផលហើយ រក្សាសីល ៥ មិនដាច់ ទាំងភរិយា ទាំងបុត្ត ធីតា និងទាសកម្មករ អ្នកស៊ីឈ្នួលរបស់លោក ក៏នាំគ្នារក្សាសីលដូចគ្នាទាំងអស់ ថ្ងៃមួយ ភិក្ខុទាំងឡាយតាំងជារឿងឡើងក្នុងធម្មសភាថា អាវុសោ អនាថបិណ្ឌិកសេដ្ឋី ខ្លួនឯងក៏ស្អាត បរិវារក៏ស្អាត ប្រព្រឹត្តធម៌ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន បុរាណកបណ្ឌិតទាំងឡាយក៏បានជាអ្នកស្អាតឯងផង ជាអ្នកមានបរិវារស្អាតផង ដូច្នេះហើយ ភិក្ខុទាំងនោះនាំគ្នាទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសាធក: ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វជាសេដ្ឋី បានថ្វាយទាន រក្សាសីល រក្សាឧបោសថ ឯភរិយារបស់លោកក៏រក្សាសីល ៥ កូនប្រុសនិងកូនស្រី ទាសកម្មករ និងបុរសទាំងឡាយក៏នាំគ្នារក្សា ។ ទើបលោកប្រាកដជា សេដ្ឋីដែលមានបរិវារស្អាតនោះឯង ។ ថ្ងៃមួយ សេដ្ឋីគិតថា បើនរណាមានបរិវារស្អាតជាប្រក្រតីនឹងមករកសោត អញមិនគួរឲ្យទែនសម្រាប់អង្គុយឬទីដេកសម្រាប់ដេករបស់អញដល់បុគ្គលនោះ អញគួរឲ្យទីអង្គុយទីដេកដែលមិនប្រឡាក់ប្រឡូសដែលមិនទាន់បានប្រើដល់បុគ្គលនោះ ។ កាលបើដូច្នោះ ទើបលោកឲ្យគេក្រាលទីអង្គុយនិងទីដេកដែលមិនទាន់បានប្រើប្រាស់ទុកម្ខាងក្នុងទីសម្រាប់ប្រណិប័តន៍ខ្ទួន ។ សម័យនោះ ធីតា ២ រូប គឺធីតារបស់ស្តេចវិរូបក្ខមហារាជ ឈ្មោះកាឡកណ្ណី ១ ធីតារបស់ស្តេចធតរដ្ឋមហារាជឈ្មោះសិរី ១ ក្នុងទេវលោកជាន់ចាតុម្មហារាជិកា កាន់គ្រឿងក្រអូប និងផ្កាកម្រងជាច្រើន នាំគ្នាទៅកាន់កំពង់ទឹក អនោតត្តស្រះដោយបំណងថា ពួកយើងនឹងលេងទឹកក្នុងអនោតត្តស្រះ ។

ក្នុងអនោតត្តស្រះនោះ មានកំពង់ទឹកជាច្រើន ក្នុងចំនួនកំពង់ទឹកទាំងនោះ កំពង់សម្រាប់ព្រះពុទ្ធទាំងឡាយព្រះពុទ្ធប៉ុណ្ណោះទ្រង់ស្រពស្រង់កំពង់សម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ទ្រង់ស្រពស្រង់ កំពង់សម្រាប់ភិក្ខុទាំងឡាយក៏ចំពោះភិក្ខុទាំងឡាយនាំគ្នាស្រង់ កំពង់សម្រាប់តាបសទាំងឡាយសម្រាប់តាបសទាំងឡាយស្រង់ កំពង់សម្រាប់ទេវបុត្តទាំងឡាយក្នុងសួគ៌ ៦ ជាន់ មានជាន់ចាតុម្មហារាជិកាជាដើម ទេវបុត្តទាំងឡាយ

ប៉ុណ្ណោះស្រេច កំពង់សម្រាប់ទេពធីតាទាំងឡាយ ចំពោះទេពធីតាប៉ុណ្ណោះស្រេច ។

ក្នុងចំនួនទេពធីតាទាំងនោះ ទេពធីតា ២ រូបនេះឈ្លោះគ្នាដោយត្រូវការកំពង់ទឹកថា ខ្ញុំនឹងងូតមុន ខ្ញុំនឹងងូតមុន ដូច្នេះ ។ កាឡកណ្ណីទេពធីតាពោលថា ខ្ញុំរក្សាលោកសន្និវាស ត្រាច់ចរពិនិត្យមើលលោកសន្និវាស ព្រោះដូច្នោះ ខ្ញុំគួរងូតមុន ឯសិរីទេពធីតាពោលថា ខ្ញុំតាំងនៅក្នុងបដិបទាប្រពៃដែលនឹងឲ្យឥស្សរិយយសដល់មហារាជ ព្រោះដូច្នោះ ខ្ញុំគួរងូតមុន ។ ជនទាំង ២ យល់ថា មហារាជទាំង ៤ នឹងដឹងថា ក្នុងយើងទាំង ២ នេះ អ្នកណាគួរងូតមុន ឬមិនសមគួរ ។ ទើបនាំគ្នាទៅកាន់សម្នាក់របស់មហារាជទាំងនោះ ហើយក្រាបទូលថា បណ្តាខ្ញុំទាំង ២ អ្នកណាសមគួរងូតទឹកក្នុងអនោតត្តស្រះមុន ព្រះបាទធតរដ្ឋនិងព្រះបាទវិរូបក្ខៈប្រាប់ថា យើងមិនអាចវិនិច្ឆ័យបានទេ ទើបឲ្យជាភារៈរបស់ព្រះបាទវិរុឡ្ហកៈនិងព្រះបាទវេស្សវ័ណ ។ ទេវរាជទាំង ២ នោះប្រាប់ថា សូម្បីពួកយើងក៏មិនអាចវិនិច្ឆ័យបាននឹងបញ្ជូនទៅទៀបបាទមូលរបស់សក្កទេវរាជ ហើយបានបញ្ជូនជនទាំង ២ ទៅកាន់សម្នាក់សក្កទេវរាជ សក្កទេវរាជ ទ្រង់ស្តាប់ពាក្យរបស់អ្នកទាំង ២ ហើយ ទ្រង់ព្រះតម្រិះថាទេពធីតាទាំង ២ នេះ ក៏ជាកូនស្រីរបស់បរិស័ទអញដូចគ្នា អញមិនអាចវិនិច្ឆ័យក្តីនេះបានទេ ។ គ្រានោះ សក្កទេវរាជបានត្រាស់ថា ក្នុងនគរពារាណសី មានសេដ្ឋីឈ្មោះសុចិបរិវារ ក្នុងផ្ទះរបស់គាត់ក្រាលអាសនៈដែលមិនប្រឡាក់ និងទីដេកដែលមិនប្រឡាក់ទុក ទេពធីតាណាបានអង្គុយ ឬបានដេកលើទីអង្គុយ

ទីដេកនោះ ទេពធីតានោះគួរបានផ្ទូតទឹកមុន ។ កាឡកណ្ណីទេពធីតាបានស្តាប់ទេវឱង្ការហើយ គ្រានោះឯង បានស្លៀកដណ្តប់សំពត់ពណ៌ខៀវ លាបនូវគ្រឿងលាបពណ៌ខៀវ ប្រដាប់ដោយកែវមណីពណ៌ខៀវ ចុះពីទេវលោក ដូចថ្មយន្ត បានបញ្ចេញរស្មីអណ្តែតនៅលើអាកាសក្នុងទីមិនឆ្ងាយអំពីទីដេកក្បែរទ្វារដែលជាទីប្រណិប័តន៍នៃប្រាសាទរបស់សេដ្ឋី ក្នុងវេលាមជ្ឈិមយាមនោះឯង សេដ្ឋីបានឃើញទេពធីតា ព្រមនឹងការឃើញនោះឯង ទេពធីតាមិនបានជាទីស្រឡាញ់ មិនបានជាទីពេញចិត្តរបស់សេដ្ឋីនោះឡើយ កាលចរចាជាមួយទេពធីតាទើបពោលគាថាដំបូងថា

នាងជាអ្វី មានវណ្ណៈខ្មៅទាំងមិនមានគ្រឿងមើលជាទីស្រឡាញ់
នាងជាអ្វី ឬជាធីតារបស់អ្នកណា យើងស្គាល់នាងដូចម្តេចបាន
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាឡេន** បានដល់ ពណ៌ខៀវ ។ បទថា **វណ្ណេន** សេចក្តីថា ដោយពណ៌របស់រាងកាយ និងពណ៌របស់សំពត់អាករណៈ ។ ដោយបទថា **ន ចាសិ បិយទស្សនា** ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយរមែងត្រូវគ្នាដោយធាតុ ទេពធីតានេះ មិនមានមារយាទ គឺអាចារ ជាអ្នកទ្រុស្តសីល ព្រោះដូច្នោះ ទើបមិនជាទីស្រឡាញ់របស់លោកសេដ្ឋីដំណាលគ្នានឹងការឃើញនោះឯង ដោយហេតុនោះ ទើបលោកពោលថា នាងជានរណា ម្យ៉ាងទៀត សព្វថា **កា ច ត្វំ** បានដល់ នាងជានរណា នេះឯងជាបាឋៈដើម ។

កាឡកណ្ណីទេពធីតាបានឮពាក្យនោះហើយ ទើបពោលគាថាទីពីរថា

ខ្ញុំឈ្មោះចណ្ឌិយា ជាធីតានៃមហារាជឈ្មោះវិរូបក្ខៈ ខ្ញុំមាន
សម្បុរខ្មៅ ជាស្ត្រីឥតបុណ្យ ពួកទេវតារមែងស្គាល់ខ្ញុំថាជា
កាឡកណ្ណី អ្នកកាលបើខ្ញុំសូមឱកាស សូមឲ្យយើងនឹងនៅក្នុង
សម្នាក់នៃអ្នក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចណ្ឌិយា** គឺច្រើនដោយសេចក្ដីក្រោធ អធិប្បាយថា មនុស្សទាំងឡាយដាក់ឈ្មោះខ្ញុំថា ចណ្ឌី ព្រោះជាអ្នកច្រើនទៅដោយសេចក្ដីក្រោធ ។ បទថា **អលក្ខិកា** បានដល់ មិនមានបញ្ញា ។ បទថា **មំ វិទូ** សេចក្ដីថា ទេវតាទាំងឡាយក្នុងទេវលោកជាន់ចាតុម្មហារាជិកាស្គាល់ខ្ញុំដោយប្រការយ៉ាងនេះ ។ បទថា **វសេមុ** សេចក្ដីថា ថ្ងៃនេះខ្ញុំសូមនៅក្នុងសម្នាក់របស់អ្នកមួយយប់ ចូរអ្នកឲ្យឱកាសដល់ខ្ញុំក្នុងការអង្គុយ និងដេកលើទីមិនប្រឡាក់មួយកន្លែងចុះ ព្រះពោធិសត្វកាលបានឮពាក្យនោះហើយ ទើបពោលគាថាទី ៣ ថា

នាងតម្កល់ចិត្តចំពោះបុរសមានសីលធម៌ដូចម្ដេច មានសមាចារដូចម្ដេច ម្នាលនាងកាឡី នាងខ្ញុំសួរហើយ ក៏ចូរប្រាប់មក
យើងនឹងស្គាល់នាងដូចម្ដេចបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និវិសសេ** សេចក្ដីថា តាំងចុះ គឺប្រតិស្ឋានក្នុងចិត្តរបស់នាង ។

គ្រានោះ កាលនាងពោលដល់គុណរបស់ខ្លួន ទើបពោលគាថាទី ៤ ថា

បុរសណាជាអ្នកលុបគុណ ប្រឡងវាសនា ប្រណាំងប្រជែង
ប្រណែន កំណាញ់ ជាអ្នកអួតអាង បានទ្រព្យហើយបំផ្លាញ
ទៅវិញ បុរសនោះជាទីត្រេកអររបស់ខ្ញុំ ដូច្នេះ ។

គាថានោះមានអត្ថថា បុរសណា មិនស្គាល់គុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន ជាអ្នកលុបគុណ កាលគេពោលដល់ហេតុណារបស់ខ្លួន ក៏ប្រកាន់ជាគូប្រណាំងប្រជែងថា ខ្ញុំមិនស្គាល់វត្ថុនោះ ឬឃើញអ្វីដែលជនដទៃធ្វើហើយ ក៏ធ្វើហេតុឲ្យខ្ពស់ឡើងជាង ដោយអំណាចនៃការប្រណាំងប្រជែង កាលអ្នកដទៃបានលាភ ក៏មិនត្រេកអរផង ប្រាថ្នាថា អ្នកដទៃកុំមានភាពជាធំជាងអញ សូមភាពជាធំជារបស់អញតែម្យ៉ាង ហួងហែងសម្បត្តិរបស់ខ្លួន មិនឲ្យដល់អ្នកដទៃ សូម្បីតំណក់ប្រេងដែលជ្រលក់ដោយចុងស្បូវ ជាអ្នកប្រកបដោយលក្ខណៈនៃបុគ្គលកេ្អងក្អាង មិនឲ្យទ្រព្យខ្លួនដល់អ្នកដទៃ ស៊ីរបស់អ្នកដទៃតែម្យ៉ាង ដោយឧបាយនោះៗ ។ ទ្រព្យឬស្រូវដែលបុរសណាបានមកហើយរមែងវិនាសទៅ មិនគង់វង់គឺបុរសណាជាអ្នកលេងសុរាខ្លះ ជាអ្នកលេងល្បែងភ្នាល់ខ្លះ ជាអ្នកលេងស្រីខ្លះ ញុំាងទ្រព្យដែលបានមកហើយ ឲ្យវិនាសទៅតែម្យ៉ាង បុរសនេះដែលប្រកបដោយគុណទាំងនេះ ជាទីប្រាថ្នា ជាទីស្រឡាញ់បានដល់ ជាទីគាប់ចិត្តខ្ញុំ ខ្ញុំឲ្យបុរសបែបនេះ តាំងនៅក្នុងហទយៈរបស់ខ្ញុំ ។

លំដាប់នោះ ទើបនាងពោលគាថាទី ៥-៦-៧ ដោយខ្លួននោះឯងថា

បុរសណា ច្រើនក្រោធ ចងសេចក្តីក្រោធទុក ញុះញង់
បំបែកមិត្ត ពោលពាក្យចាក់ដោតដូចបន្លា ពោលពាក្យទ្រគោះ

បុរសនោះជាទីត្រេកអរក្រៃលែង របស់ខ្ញុំជាងនោះទៅទៀត ។

បុរសមិនយល់ប្រយោជន៍របស់ខ្លួនថា ( កិច្ចនេះត្រូវធ្វើ ) ក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក កាលបើគេទូន្មានក៏ខឹងតប មើលងាយនូវបុគ្គលប្រសើរ ។

បុរសណាជាប់ចិត្តក្នុងល្បែង គឺកាមគុណ រមែងឃ្លាតចាកមិត្តទាំងពួង បុរសនោះជាទីត្រេកអររបស់ខ្ញុំ ទាំងខ្ញុំក៏មិនមានមោះមៃចំពោះបុរសនោះទេ ដូច្នេះ ។

គាថាទាំងនោះគួរឲ្យពិស្ដារដោយន័យនេះចុះ ។ តែក្នុងទីនេះ គប្បីជ្រាបអត្ថដោយសង្ខេប ។ បទថា **កោធនោ** បានដល់ ជាអ្នកក្រោធ ដោយហេតុត្រឹមតិចតួច ។ បទថា **ឧបនាហី** បានដល់ រក្សានូវកំហុសរបស់អ្នកដទៃទុកក្នុងចិត្តហើយ ធ្វើនូវសេចក្ដីវិនាស ឲ្យដល់បុគ្គលនោះ អស់កាលដ៏យូរ ។ បទថា **បិសុណោ** បានដល់ ជាអ្នកមានវាចាញុះញង់ ។ បទថា **វិភេទកោ** បានដល់ ជាអ្នកទម្លាយមិត្តដោយហេតុត្រឹមតែតិចតួច ។ បទថា **កណ្ឌកវាចោ** បានដល់ ជាអ្នកមានវាចាប្រព្រឹត្តទៅដោយទោស ។ បទថា **ផរុសោ** បានដល់ ជាអ្នកមានវាចាគ្រោតគ្រាត ។ បទថា **កន្តតរោ** សេចក្ដីថា បុរសនោះជាទីប្រាថ្នា គឺជាទីស្រឡាញ់របស់ខ្ញុំច្រើនជាងបុរសមុនទៅទៀត ។ បទថា **អត្ថំ សុវេ** សេចក្ដីថា បុរសណាមិនយល់ គឺមិនស្គាល់ប្រយោជន៍របស់ខ្លួន គឺកិច្ចការរបស់ខ្លួនយ៉ាងនេះថា កិច្ចការនេះគួរធ្វើក្នុងថ្ងៃនេះ កិច្ចការនេះគួរធ្វើក្នុងថ្ងៃស្អែក កិច្ចការនេះគួរធ្វើក្នុងថ្ងៃទី ៣ គឺក្នុងថ្ងៃខានស្អែកជាដើម ។ បទ

ថា **ឱរជ្ជមានោ** បានដល់ ត្រូវពោលជាស់តឿន ។ បទថា **សេយ្យសោ អតិមញ្ញតិ** បានដល់ មើលងាយបុគ្គលដែលក្រៃលែងជាង គឺបុគ្គលដែលឧត្តមដោយជាតិ គោត្ត ត្រកូល ទីលំនៅ និងគុណ គឺសីល និងអាចារថា ឯងល្មមនឹងដៃអញឬ ។ បទថា **ឆវប្បលុទ្ធោ** បានដល់ ត្រូវសេចក្តីថ្នាំថ្នង មិនដាច់រយៈក្នុងកាមគុណទាំងឡាយ មានរូបជាដើមលួងលោមហើយគឺគ្រប សង្កត់ហើយ បានដល់ ធ្លាក់នៅក្នុងអំណាចកាមគុណហើយ ។ បទថា **ធំសតិ** បានដល់ បុគ្គលនោះពោលថា ឯងនឹងធ្វើអ្វីអញ ដូច្នេះជាដើម ហើយព្រាត់ប្រាសចាកមិត្តទាំងអស់នោះឯង ។ បទថា **អណាមយា** បានដល់ ខ្ញុំគិតថា បុគ្គលដែលប្រកបដោយគុណទាំងនោះ ជាអ្នកមិនមានទុក្ខ មិនមានសោក បានបុរសនោះហើយ នឹងអស់អាល័យក្នុងអ្នកដទៃ ដូច្នេះ ។

លំដាប់នោះ ព្រះមហាសត្វកាលនឹងតិះដៀល ទើបពោលគាថាទី ៨ ថា

ម្នាលនាងកាឡី នាងចូរជៀសចេញអំពីទីនេះទៅ អំពើអាក្រក់
នេះ មិនមានក្នុងយើងទាំងឡាយទេ នាងចូរទៅកាន់ជនបទ
ឬនិគមរាជធានីដទៃចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបេហិ** បានដល់ ចូរចៀសចេញទៅ ។ បទថា **នេតំ អម្ហេសុ** បានដល់ ការលុបគុណជាដើមនោះ ជាគ្រឿងធ្វើឲ្យជាទីស្រឡាញ់របស់នាង មិនមានក្នុងពួកយើងឡើយ គឺមិនមាន ។ ដោយបទថា **និគមេ រាជធានិយោ** ព្រះមហាសត្វសម្តែងថា នាងចូរទៅកាន់និគមដទៃខ្លះ រាជធានីដទៃខ្លះក្នុងទីដទៃ គឺចូរទៅក្នុងទីដែលខ្ញុំមិនឃើញនាង ។

នាងកាឡកណ្ណីបានស្តាប់ដូច្នោះហើយ ឆ្លងពាក្យនោះទៅ ( បានទទួលទុក្ខ ) ទើបពោលគាថាជាប់គ្នាថា

ខ្ញុំក៏បានដឹងហេតុនោះដែរ អំពើនោះមិនមានក្នុងអ្នកទេ ពួកជន
ជាអ្នកឥតបុណ្យក្នុងលោក រមែងប្រមូលនូវទ្រព្យច្រើន ខ្ញុំនឹង
ទេវតាជាបងរបស់ខ្ញុំទាំងពីរនាក់តែងបំផ្លាញនូវទ្រព្យនុ៎ះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯតំ តុម្ហេសុ** សេចក្តីថា ខ្ញុំក៏ដឹងសេចក្តីនេះថា ការលុបគុណជាដើម ដែលជាគ្រឿងធ្វើឲ្យខ្ញុំស្រឡាញ់ឯណា ខ្ញុំ ប្រកបដោយ ការលុបគុណជាដើមឯណា ដោយខ្លួនឯង ការលុបគុណ ជាដើមនោះមិនមានក្នុងអ្នកទាំងឡាយ ។ បទថា **សន្តិ លោកេ អលក្ខិកា** បានដល់តែបុគ្គលដទៃដែលជាបុគ្គលល្ងង់ ជាអ្នកមិនមានសីល មិនមានបញ្ញា មាននៅក្នុងលោក ។ បទថា **សម្ភរន្តិ** បានដល់ មនុស្សទាំងនោះជាអ្នកមិនមានសីលសូម្បីបញ្ញាក៏មិនមានរួបរួមទ្រព្យទុកជាច្រើន គឺរក្សាទុកជាគំនរ ដោយហេតុទាំងនេះ មានការលុបគុណជាដើម ។ បទថា **ឧភោ ធំ** សេចក្តីថា តែយើងទាំង ២ នាក់ គឺទាំងខ្លួនខ្ញុំនិងទេវបុត្តដែលជាបងប្រុសនោះឯង រួមគ្នាបំផ្លាញទ្រព្យនោះដែលមនុស្សទាំងនោះប្រមូលរក្សាទុក ។ ម្យ៉ាងទៀត ទេពធីតានោះពោលថា ក្នុងទេវលោកពួកខ្ញុំក៏មានគ្រឿងបរិភោគដែលជាទិព្វច្រើនអ្នកនឹងឲ្យទីដេកជាទិព្វឬមិនឲ្យអ្នកនឹងមានប្រយោជន៍អ្វីសម្រាប់ខ្ញុំដូច្នេះហើយក៏ចៀសចេញទៅ ។

ក្នុងពេលកាឡកណ្ណីទេពធីតាចៀសចេញទៅហើយ សិរីទេពធីតាមានគ្រឿង

ក្រអូបនិងគ្រឿងលាបស្បែកមានពណ៌ដូចមាស មានគ្រឿងតាក់តែងជាមាស មកហើយ បញ្ចេញរស្មីពណ៌លឿងត្រង់ទ្វារដែលស្ថិតនៅក្បែរទីបម្រើ បានឈរយកជើងដាក់ជិតគ្នាលើផែនដីដែលស្មើគ្នា បានឈរដោយគោរព ។ ព្រះមហាសត្វកាលឃើញនាងហើយ ទើបពោលគាថាទី ១ ថា

នាងជាអ្វី មានវណ្ណៈជាទិព្វ មកឋិតលើផែនដី នាងជាអ្វី ឬជាធីតារបស់នរណា យើងនឹងស្គាល់នាងដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱព្វេន** សេចក្តីថា ប្រសើរ គឺឧត្តម ។ សិរីទេពធីតាបានស្តាប់ដូច្នោះហើយ ទើបពោលគាថាទី ២ ថា

ខ្ញុំជាធីតានៃមហារាជឈ្មោះ ធតរដ្ឋ ដ៏មានសិរី ខ្ញុំជាស្ត្រីឈ្មោះសិរីផង លក្ខីផង ពួកទេវតារមែងស្គាល់ខ្ញុំថា ជាស្ត្រីមានប្រាជ្ញាដូចផែនដី លោកខ្ញុំសូមឱកាសហើយសូមឲ្យ យើងនឹងសូមនៅក្នុងសម្នាក់លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិរី ច លក្ខី ច** សេចក្តីថា ខ្ញុំមានឈ្មោះយ៉ាងនេះគឺសិរីនិងលក្ខី មិនមែនអ្នកដទៃ ។ បទថា **ភូរិបញ្ញាតិ មំ វិទូ** សេចក្តីថា ទេវតាទាំងឡាយ ស្គាល់ខ្ញុំក្នុងទេវលោកជាន់ចាតុម្មហារាជិកាថា ជាអ្នកប្រកបដោយបញ្ញាបរិបូណ៌ ស្មើដោយផែនដី ។ បទថា **វសេមុ តវ សន្តិកេ** សេចក្តីថា ខ្ញុំអាស្រ័យយប់មួយលើទីអង្គុយដែលមិនប្រឡាក់ និងទីដេកដែលមិនប្រឡាក់ សូមអ្នកឲ្យឱកាសដល់ខ្ញុំ ។ បន្ទាប់អំពីនោះ ទើបព្រះពោធិសត្វពោលគាថាថា

នាងនឹងតម្កល់ចិត្តចំពោះបុរសមានសីលធម៌ដូចម្តេច មានសមាចារៈដូចម្តេច ម្នាលលក្ខី ខ្ញុំសួរហើយ នាងចូរប្រាប់ យើងស្គាល់នាងដូចម្តេច ។

បុរសណា គ្របសង្កត់នូវត្រជាក់ក្តី ក្តៅក្តី ខ្យល់និងកម្តៅថ្ងៃក្តី របោម ពស់តូច ពស់ធំក្តី ឃ្លានក្តី ស្រេកក្តី ទាំងអស់ហើយប្រកបព្យាយាមរឿយៗ ក្នុងវេលាយប់និងថ្ងៃ រមែងមិនញុំាងប្រយោជន៍ដែលតាំងនៅក្នុងកាលគួរឲ្យវិនាសបុរសនោះជាទីពេញចិត្តរបស់ខ្ញុំ ខ្ញុំគប្បីស៊ប់ចិត្តក្នុងបុរសនោះឯង ។

បុរសណា ជាអ្នកមិនក្រោធ មានកល្យាណមិត្ត មានការបរិច្ចាគ ជាអ្នកបរិបូណ៌ដោយសីល មិនមែនជាអ្នកលេងបោកប្រាស់ ជាអ្នកត្រង់ ជាអ្នកមានសង្គហធម៌ មានវាចាទន់ភ្លន់មានវាចាពីរោះ ស្ទួយដល់នូវភាពជាអ្នកធំ ក៏ប្រព្រឹត្តឱនលំទោន ខ្ញុំជាអ្នកមានចិត្តធំទូលាយចំពោះបុរសនោះដូចជារលក ( ប្រាកដជារបស់ធំទូលាយដល់បុគ្គលដែលសម្លឹងមើល ) នូវពណ៌របស់សមុទ្ទ ។

បុគ្គលណា ប្រព្រឹត្តនូវសេចក្តីសង្គ្រោះក្នុងចំពោះមុខកំបាំងមុខ ចំពោះមិត្តក្តី សត្រូវក្តី បុគ្គលប្រសើរក្តី ស្មើគ្នាក្តី ថោកទាបក្តីបុគ្គលអ្នកប្រព្រឹត្តនូវប្រយោជន៍ក្តី មិនមែនជាប្រយោជន៍ក្តី មិនពោលពាក្យអាក្រក់ក្នុងកាលណាមួយ ខ្ញុំជាអ្នកគប់រកចំ

ពោះបុរសនោះ ទោះបីស្លាប់ក្តី រស់ក្តី ។

បណ្តាគុណទាំងនោះ បុរសណាមួយ ជាអ្នកគ្មានបញ្ញាបាន នូវសិរី ជាទីត្រេកអរណាមួយ ហើយស្រវឹង ខ្ញុំវៀរនូវបុរស នោះ អ្នកប្រព្រឹត្តមិនស្មើ មានសភាពដ៏ក្តៅក្រហាយ ដូចជា បុគ្គលវៀរបង់នូវរណ្តៅលាមក ។

បុគ្គលធ្វើនូវគុណសម្បត្តិ គឺបុណ្យដោយខ្លួនឯង ធ្វើនូវអំពើ មិនមែនជាបុណ្យក៏ដោយខ្លួនឯង ព្រោះថា បុគ្គលដទៃធ្វើនូវ គុណសម្បត្តិគឺបុណ្យក្តី មិនមែនបុណ្យក្តីដល់បុគ្គលឯទៀតមិន បានទេ ដូច្នេះ ។

ពាក្យសួរជារបស់សេដ្ឋី ចម្លើយជាពាក្យរបស់សិរីទេពធីតា ។

បណ្តាបទទាំងនោះ ក្នុងបទថា **ឱសសិរីសបេ ច** សត្វល្អិតក្អែកលឿងហៅ ថា **ឱស** ( របោម ) ម្យ៉ាងទៀត កំណើតសត្វល្អិតគ្រប់ប្រភេទទេពធីតាសំដៅ យក ឱសៈ ក្នុងទីនេះ ។ កំណើតសត្វលូនវារហៅថា **សិរីសបា** ទាំងរបោម ទាំងសត្វលូនវារឈ្មោះថា **ឱសសិរីសបា** ។ ក្នុងរបោមនិងសត្វលូនវារនោះ ដែលមាន ។ មានពាក្យអធិប្បាយទុកថា បុរសមហាសេដ្ឋីណា កាលមាន សេចក្តីរងា ការក្តៅ ខ្យល់ កម្តៅថ្ងៃ របោមនិងសត្វលូនវារ ទោះត្រូវអន្ត- រាយទាំងនេះ មានសេចក្តីរងាជាដើមបៀតបៀនក៏គ្របសង្កត់គឺញាំញីអន្តរាយ ទាំងអស់នោះ គឺអន្តរាយទាំងនោះ មានរងាជាដើម និងការស្រេកជាច្រើន ទុកបាន បានដល់ មិនទឹកដល់អន្តរាយនេះ ដូចស្មៅ ហើយប្រកប គឺប្រកប

ខ្លួនប្រព្រឹត្តទៅក្នុងកម្មរបស់ខ្លួនរឿយៗ មានកសិកម្មនិងពាណិជ្ជកម្មជាដើមក្នុងទាននិងសីលជាដើមទាំងយប់ទាំងថ្ងៃ ។ បទថា **កាលាគតញ្ញូ** សេចក្តីថា មិនឲ្យកិច្ចទាំងឡាយមានកសិកម្មជាដើមសាបសូន្យទៅ ក្នុងពេលធ្វើកសិកម្មជាដើម នឹងមិនឲ្យសាបសូន្យចាកប្រយោជន៍ដែលនឹងនាំសេចក្តីសុខមកឲ្យក្នុងបច្ចុប្បន្ននិងចំណែកខាងមុខ ចែកប្រភេទជាការបរិច្ចាគទ្រព្យជាដើមក្នុងកាលទាំងឡាយ មានការបរិច្ចាគទ្រព្យ ការរក្សាសីល និងការស្តាប់ធម៌ជាដើម គឺធ្វើការងារក្នុងកាលដែលគួរធ្វើនោះឯង ។ បុរសសេដ្ឋីនោះ ជាទីពេញចិត្តរបស់ខ្ញុំ ហើយខ្ញុំនឹងនៅប្រចាំជាមួយបុរសនោះ ។ បទថា **អក្កោធនោ** បានដល់ ដែលប្រកបដោយអធិវាសនខន្តី គឺការអត់ធន់ ដែលបញ្ឈប់អារម្មណ៍ទុកបាន ។ បទថា **មិត្តវា** បានដល់ ដែលប្រកបដោយកល្យាណមិត្ត ។ បទថា **ចាគវា** បានដល់ ជាអ្នកប្រកបដោយការបរិច្ចាគទ្រព្យ ។ បទថា **សង្គាហកោ** បានដល់ ធ្វើការសង្គ្រោះមិត្ត សង្គ្រោះដោយអាមិសនិងសង្គ្រោះដោយធម៌ ។ បទថា **សខិលោ** បានដល់ ជាអ្នកមានវាចាទន់ភ្លន់ ។ បទថា **សណ្ហវាចោ** បានដល់ ជាអ្នកមានពាក្យពីរោះ ។ បទថា **មហត្តបត្តោបិ និវាតវុត្តិ** សេចក្តីថា សូម្បីតាំងនៅក្នុងតំណែងធំ គឺឥស្សរិយយសដែលទូលំទូលាយ តែក៏មិនតម្កើងខ្លួនដោយយស ជាអ្នកបន្ទាបខ្លួន ធ្វើតាមឱវាទរបស់បណ្ឌិត ។ បទថា **តស្មឹហំ ចោសេ** បានដល់ ខ្ញុំជាបុគ្គលទូលំទូលាយសម្រាប់បុរសនោះ ។ បទថា **វិបុលា ភវាមិ** បានដល់ ខ្ញុំមិនមែនបុគ្គលតូចតាច ព្រោះថា បុរសនោះជាបាទនៃសិរីដ៏ធំ ។ បទថា **ឧម្មី សមុទ្ទស្ស យថាបិ វណ្ណំ**

ទេពធីតាសម្តែងថា ឧបមាដូចរលកដែលប្រដេញគ្នាមកប្រាកដដល់បុគ្គលដែលសម្លឹងមើលពណ៌របស់មហាសមុទ្រ ហាក់ដូចជាធំ យ៉ាងណា ខ្ញុំក៏យ៉ាងនោះ ហាក់ដូចជាធំ ព្រោះបុគ្គលនោះៗ ។ បទថា **អាវី រហោ** សេចក្តីថា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ។ បទថា **សង្គហាមេវ វត្តេ** សេចក្តីថា បុគ្គលនោះឲ្យសង្គហធម៌ទាំង ៤ យ៉ាងនោះឯងប្រព្រឹត្តទៅ គឺទូទៅក្នុងបុគ្គលនោះ ចែកប្រភេទជាមិត្តជាដើម ។ បទថា **ឆ វជ្ជា** សេចក្តីថា បុគ្គលណា គ្រាណា គឺក្នុងកាលណា មិនគប្បីពោលពាក្យគ្រោតគ្រាត គឺជាអ្នកមានពាក្យពីរោះប៉ុណ្ណោះ ។ បទថា **មតស្ស ជីវស្ស** សេចក្តីថា បុគ្គលនោះ ស្លាប់ហើយក្តីមានជីវិតនៅក្តី ខ្ញុំក៏មានកក្តីចំពោះ ។ សិរីទេពធីតាសម្តែងថា ខ្ញុំគប់រកបុគ្គលបែបនោះ ទាំងក្នុងលោកនេះនិងលោកខាងមុខ ។ បទថា **ឯតេស យោ** សេចក្តីថា បុគ្គលណា បាននូវគុណសូម្បីតែមួយក្នុងគុណទាំងនេះដែលបានពោលទុកហើយខាងដើម មានការគ្របសង្កត់នូវរង្វាបានជាដើម ហើយប្រមាទភ្លេចស្មារតី អធិប្បាយថា មិនព្យាយាមប្រកបរឿយៗនូវគុណនោះ ។ បទថា **សិរិ** មានបាឋៈ ៣ យ៉ាង គឺកន្តាសិរី ១ កន្តសិរិ ១ កន្តំសិរី ១ ប្រែថា សិរីដែលគួរប្រាថ្នា ។ ដោយអំណាចបាឋៈទាំង ៣ នោះ មានការប្រកបអត្ថដូចតទៅនេះថា បុគ្គលណាបាននូវសិរីហើយគិតថា សិរីរបស់អញដែលគួរប្រាថ្នាតាំងនៅហើយតាមឋានៈ រមែងប្រមាទ គឺភ្លេចគុណណាមួយ បណ្តាគុណទាំងនេះ ។ ម្យ៉ាងទៀត បុគ្គលណា ប្រាថ្នាសិរីដូចបុគ្គលដែលមានសិរី ដែលគួរប្រាថ្នា បាននូវគុណណាមួយ បណ្តាគុណទាំងនេះ ហើយទើបប្រមាទ ។ ម្យ៉ាង

ទៀត បុគ្គលណា បានទូវសិរីគួរប្រាថ្នា គួរពេញចិត្តហើយ ទើបប្រមាទគុណ គឺសេចក្តីល្អណាមួយបណ្តាគុណទាំងនេះ ។ បទថា **អប្បបញ្ញោ** បានដល់ មិនមានបញ្ញា ។ បទថា **តំ ធិត្ថុរូបំ វិសមំ ចរន្តំ** សេចក្តីថា ខ្ញុំវៀរបុគ្គល ដែលមានសភាពក្តៅក្រហាយ ប្រព្រឹត្តមិនស្មើ មានកាយទុច្ចរិតជាដើម ជា សភាវៈដូចមនុស្សឬបុគ្គលដែលមានការស្អាតដោយកំណើត វៀររណ្តៅលា-មក អំពីចម្ងាយដូច្នោះ ។ បទថា **អញ្ញោ អញ្ញស្ស ការកោ** សេចក្តីថា ហេតុនេះ បុរសដែលឈ្មោះថា សាងជោគ សាងគ្រោះ ឲ្យអ្នកដទៃមិនមាន បុគ្គលណាមួយរមែងសាងជោគឬគ្រោះឲ្យដល់ខ្លួនឯង ដូច្នេះ ។

ព្រះមហាសត្វកាលពោលសួរយ៉ាងនេះ និងបានស្តាប់ពាក្យឆ្លើយរបស់ សិរីទេពធីតាហើយសរសើរ ទើបពោលថា ទីដេកនេះសមគួរសម្រាប់នាង ទីអង្គុយក៏សមគួរសម្រាប់នាងនោះឯង ព្រោះហេតុនោះ សូមនាងអង្គុយលើ ទីអង្គុយនិងដេកលើទីដេកចុះ ។ ទេពធីតានៅក្នុងទីនោះហើយ ស្អែកឡើង ក៏ ចេញទៅកាន់ទេវលោកជាន់ចាតុម្មហារាជិកា បានងូតទឹកក្នុងអនោតត្តស្រះមុន ។ ទើបទីដេកកន្លែងនោះមានឈ្មោះថា សិរិសយនៈ ព្រោះថា នាងសិរីទេពធីតា ដេកមុនអ្នកដទៃ ។ នេះគឺប្រវត្តិវង្សរបស់សិរិសយនៈ គឺទីដេកដែលជាមង្គល ហេតុនោះ ទើបគេតែងហៅថា សិរិសយនៈ ទីដេកដែលជាមង្គល ដរាបដល់ សព្វថ្ងៃនេះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ថា សិរីទេពធីតាក្នុងកាលនោះ បានមកជាឧប្បលវណ្ណាក្នុងកាលឥឡូវនេះ ឯ

សុបិនបរិវារសេដ្ឋីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថាសិរិកាឡកណ្ណិជាតក ចប់

## កុក្កុដជាតក

[ ១៨៥ ] ( សំពោចញីនិយាយថា ) នែអ្នកមានខ្លួនបិទបាំងដោយស្លាបដ៏វិចិត្រល្អ ជាសត្វមានសិរ្សក្រហម ទៅកាន់អាកាសបាន ចូរអ្នកចុះអំពីមែកឈើមក ខ្ញុំនឹងជាប្រពន្ធរបស់អ្នកដោយទទេ ។

[ ១៨៦ ] ( មាន់ពោធិសត្វឆ្លើយថា ) ម្នាលនាងដ៏ល្អ ជាទី ត្រេកអរនៃចិត្ត នាងជាសត្វជើងបួន ខ្ញុំជាសត្វជើងពីរ ពួកម្រឹគនិងសត្វបក្សី មិនសមគ្នាទេ នាងចូរស្វែងរកសត្វឯទៀតធ្វើជាស្វាមីចុះ ។

[ ១៨៧ ] ( សំពោចញីនិយាយថា ) ខ្ញុំនៅជាកុមារី ជាស្ត្រីនិយាយពីរោះ ពោលពាក្យជាទីស្រឡាញ់ នឹងបានជា ( ប្រពន្ធ ) របស់អ្នក អ្នកចូរបាននូវខ្ញុំ ជាស្ត្រីល្អ ជាព្រហ្មចារិនី ដោយការបានដ៏ប្រសើរ ។

[ ១៨៨ ] ( មាន់ពោធិសត្វតិះដៀលថា ) នែនាង ជាសត្វស៊ីនូវសាកសព ផឹកនូវឈាម ជាចោរ បៀតបៀននូវមាន់ នាងឯង មិនមែនចង់បាននូវអញធ្វើជាប្តីដោយការបានប្រសើរទេ ។

[ ១៨៩ ] ( ព្រះសម្ពុទ្ធសម្តែងថា ) នារីទាំងឡាយដែលមានការវាងវៃ ឃើញនូវបុរសដ៏ប្រសើរហើយ រមែងដឹកនាំដោយវាចាដ៏ពីរោះ យ៉ាងនេះឯង ដូចជាសំពោចញីប្រលោមនូវមាន់ឈ្មោល ( មកធ្វើជាប្តីរបស់ខ្លួន ) ។

[ ១៩០ ] បុគ្គលណាមិនចាប់យល់នូវប្រយោជន៍ដែលកើតឡើង បុគ្គលនោះរមែងលុះអំណាចនៃសត្រូវផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយផង ។

[ ១៩១ ] លុះតែបុគ្គលណា ចាប់យល់ច្បាស់នូវប្រយោជន៍ ដែលកើត

ឡើង បុគ្គលនោះរមែងរួចចាកការបៀតបៀនអំពីសត្រូវ ដូចមាន់ឈ្មោលរួចអំពីសំពោចញី ។

**ចប់ កុក្កុដជាតកទី ៨ ។**

## អដ្ឋកថា

## កុក្កុដជាតក

[ ១៨៥-១៩១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ត្រាស់រឿងនេះ មានពាក្យផ្តើមថា **សុចិត្ត បត្តច្ឆាទន** ដូច្នេះ ជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាកាលត្រាស់សួរភិក្ខុនោះថា ហេតុអ្វីទើបអ្នកអផ្សុក កាលភិក្ខុនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញស្រីម្នាក់ដែលប្រដាប់តាក់តែងហើយទើបអផ្សុកដោយអំណាចកិលេស ដូច្នេះហើយត្រាស់ថា ធម្មតាស្រីតែងបោកប្រាស់បុរសឲ្យវង្វេងហើយ ក្នុងវេលាដែលបុរសធ្លាក់ក្នុងអំណាចរបស់ខ្លួនហើយ រមែងធ្វើឲ្យវិនាស ដូចឆ្មា[១]ខិលខូច ហើយទ្រង់ស្ងៀមនៅ ។ កាលភិក្ខុនោះទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណ

---

១-សព្ទថា វិឡារ បិដកខ្មែរប្រែថាសំពោច ។

សី ព្រះពោធិសត្វយោនយកក្នុងកំណើតជាមាន់ព្រៃ មានមាន់ច្រើនរយជាបរិ-វារ នៅក្នុងព្រៃ ។ ឯមេឆ្មាមួយ នៅអាស្រ័យក្នុងទីមិនឆ្ងាយអំពីទីដែលព្រះពោធិសត្វនោះនៅ ។ ឆ្មាប្រើឧបាយបោកបញ្ឆោតមាន់ដ៏សេស វៀរតែមាន់ព្រះពោធិសត្វ ។ ព្រះពោធិសត្វមិនទៅកាន់ព្រៃស្ដុកដែលជាដែនដីរបស់ឆ្មា ។ ឆ្មាគិតថា មាន់នេះក្អេងក្អាងពន់ពេក មិនដឹងថាអញជាអ្នកអួតអាងនិងជាអ្នកឈ្លាសក្នុងឧបាយ អញគួរលួងលោមមាន់នេះថាជាភរិយារបស់វា ហើយស៊ីវាក្នុងពេលដែលវាធ្លាក់ក្នុងអំណាចរបស់អញ ។ ទើបឆ្មាញីទៅកាន់គល់ឈើដែលមាន់ទំ កាលនឹងហៅមាន់នោះដោយវាចាសរសើរទឹកមុខដោយសុភាសិតបានពោលគាថាដំបូងថា

នែអ្នកមានខ្លួនបិទបាំងដោយស្លាបដ៏វិចិត្រល្អ ជាសត្វមានសិរ្សក្រហម ទៅកាន់អាកាសបាន ចូរអ្នកចុះអំពីមែកឈើមក ខ្ញុំនឹងជាប្រពន្ធរបស់អ្នកដោយទទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុចិត្តបត្តច្ឆាទន** បានដល់ ជាអ្នកមានគ្រឿងដណ្ដប់ដែលធ្វើដោយរោមដ៏វិចិត្រ ។ បទថា **មុធា** បានដល់ ខ្ញុំនឹងជាភរិយារបស់អ្នកដោយប្រាសចាកតម្លៃ គឺដោយមិនទទួលអ្វីសោះ ។

ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយ គិតថា ឆ្មានេះស៊ីញាតិរបស់អញអស់ហើយ ឥឡូវនេះ ចង់បោកបញ្ឆោតស៊ីអញ អញនឹងបណ្ដេញឆ្មានេះទៅ ទើបពោលគាថាទីពីរថា

ម្នាលនាងដ៏ល្អ ជាទីត្រេកអរនៃចិត្ត នាងជាសត្វជើងបួន ខ្ញុំ

ជាសត្វជើងពីរ ពួកម្រឹគនិងសត្វបក្សី មិនសមគ្នាទេ នាងចូរ

ស្វែងរកសត្វឯទៀតធ្វើជាស្វាមីចុះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះថា ព្រះពោធិសត្វពោលថា **មិគី** សំដៅយកឆ្មា ។ ដោយបទថា **អសំយុត្តា** នេះ ព្រះពោធិសត្វសម្តែងថា ឆ្មានិងមាន់ប្រកបរួមគ្នាមិនបានដើម្បីជាប្តីប្រពន្ធ សត្វជើង ២ ទាំងនោះ មិនមានការសមគួរបែបនេះ ។

លំដាប់នោះ ឆ្មាញីបានស្តាប់ពាក្យនោះហើយ ទើបគិតថា មាន់នេះក្អេងក្អាងពន់ពេក អញនឹងប្រើឧបាយណាមួយស៊ីវាឲ្យបាន ហើយពោលគាថាទី ៣ ថា

ខ្ញុំនៅជាកុមារី ជាស្ត្រីនិយាយពីរោះពោលពាក្យជាទីស្រឡាញ់

នឹងបានជា ( ប្រពន្ធ ) របស់អ្នក អ្នកចូរបាននូវខ្ញុំជាស្ត្រីល្អ

ជាព្រហ្មចារិនី ដោយការបានដ៏ប្រសើរ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះថា ដោយបទថា **កោមារិកា** នេះ ឆ្មាញីពោលថា ខ្ញុំមិនស្គាល់បុរសដទៃអស់កាលត្រឹមនេះ ខ្ញុំនឹងជាកិរិយាព្រហ្មចារីរបស់អ្នក ។ បទថា **មញ្ជុកា បិយភាណិនី** សេចក្តីថា ខ្ញុំនឹងជាអ្នកមានពាក្យពីរោះ ពោលពាក្យគួរស្រឡាញ់ជាប្រក្រតីចំពោះអ្នកនោះឯង ។ បទថា **វិន្ទ មំ** បានដល់ អ្នកនឹងបានខ្ញុំ ។ បទថា **អរិយេន វេទេន** បានដល់ដោយការបានសមបំណងយ៉ាងល្អ ។ ឆ្មាញីពោលថា ព្រោះថា ខ្ញុំតាំងពីដើមមក មិនស្គាល់សម្ផស្សប្រុសឈ្មោល សូម្បីអ្នកក៏មិនស្គាល់សម្ផស្សញី

ដូច្នោះ អ្នកនឹងបានខ្ញុំជាព្រហ្មចារិនីតាមប្រក្រតី ដោយការបានដែលមិនមានទោស បើអ្នកត្រូវការខ្ញុំ បើមិនជឿពាក្យរបស់ខ្ញុំទេ សូមឲ្យវាយស្គរប្រកាសក្នុងនគរពារាណសី ដែលមានទំហំ ១២ យោជន៍ឲ្យមនុស្សដឹងថា ថ្នានេះជាទាសៈរបស់ខ្ញុំ សូមអ្នកទទួលខ្ញុំជាទាសៈចុះ ។

ព្រះពោធិសត្វបានឮពាក្យនោះហើយ បន្ទាប់អំពីនោះទៅ គិតថា អញនឹងសម្លុតថ្នានេះឲ្យគេចទៅ ហើយពោលគាថាទី ៤ ថា

នែនាងជាសត្វស៊ីនូវសាកសព ផឹកនូវឈាម ជាចោរ បៀតបៀននូវមាន់ នាងឯងមិនមែនចង់បាននូវអញធ្វើជាប្តី ដោយការបានប្រសើរទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន តំ អរិយេន** សេចក្តីថា ព្រះពោធិសត្វពោលថា នាងមិនបំណងឲ្យអញធ្វើជាប្តីដោយការបានដ៏ប្រសើរ គឺការនៅប្រព្រឹត្តដូចព្រហ្ម តែនាងត្រូវការបោកស៊ីអញ ។ នែនាងដ៏លាមក ចូរនាងវិនាស ដូច្នេះហើយ ឲ្យថ្នានោះគេចទៅហើយ ។

ឯថ្នានោះគេចទៅហើយ មិនអាចសម្លឹងមើលទៀត ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា

នារីទាំងឡាយ ដែលមានការវាងវៃ ឃើញនូវបុរសដ៏ប្រសើរហើយ រមែងដឹកនាំដោយវាចាដ៏ពីរោះ យ៉ាងនេះឯងដូចជាសំពោចញីប្រលោមនូវមាន់ឈ្មោល ( មកធ្វើជាប្តីរបស់ខ្លួន ) ។

បុគ្គលណាមិនឆាប់យល់នូវប្រយោជន៍ដែលកើតឡើងបុគ្គល

នោះរមែងលុះអំណាចនៃសត្រូវផង រមែងក្តៅក្រហាយ ក្នុងកាលជាខាងក្រោយផង ។

លុះតែបុគ្គលណា ឆាប់យល់ច្បាស់នូវប្រយោជន៍ ដែលកើតឡើង បុគ្គលនោះរមែងរួចចាកការបៀតបៀន អំពីសត្រូវ ដូចមាន់ឈ្មោលរួចអំពីសំពោចញី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចតុប្បា** បានដល់ ស្រីដែលប្រកបដោយវាចាមានអង្គ ៤ ។ បទថា **នារី** បានដល់ ស្រីទាំងឡាយ ។ បទថា **នេន្តិ** បានដល់ នាំចូលទៅកាន់អំណាចរបស់ខ្លួន ។ បទថា **វិឡារី វិយ** បានដល់ ឆ្មាញីនោះព្យាយាមប្រលោមមាន់នោះ យ៉ាងណា ស្រីដទៃក៏នឹងប្រលោមភិក្ខុនោះ យ៉ាងនោះ ដូចគ្នា ។ បទថា **ឧប្បតិតំ អត្ថំ** សេចក្តីថា ហេតុការណ៍ណាមួយនោះឯងដែលកើតឡើងហើយ ។ បទថា **ន ពុជ្ឈតិ** បានដល់ មិនដឹងតាមសភាវៈពិត ព្រោះក្តៅក្រហាយក្នុងកាលខាងក្រោយ ។ បទថា **កុក្កុ-ដោវ** មានអត្ថថា ភិក្ខុនោះផុតចាកការបៀតបៀនពីសត្រូវ ដូចមាន់ដែលដល់ព្រមដោយបញ្ញា ផុតចាកក្រញាំឆ្មា ដូច្នោះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយក្នុងទីបំផុតនៃសច្ចៈ ភិក្ខុអផ្សុកតាំងនៅហើយ ក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ស្តេចមាន់ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាកុក្កុដជាតក ចប់**

# ធម្មទ្ធជជាតក

[ ១៩២ ] ( ក្អែកនិយាយនឹងពួកសត្វស្លាបថា ) ម្នាលញាតិ ទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តធម៌ អ្នកទាំងឡាយចូរប្រព្រឹត្តធម៌ សេចក្តីចម្រើន ( នឹងមាន ) ដល់អ្នកទាំងឡាយ អ្នកប្រព្រឹត្តធម៌រមែងដេកជាសុខក្នុងលោក នេះនិងលោកខាងមុខ ។

[ ១៩៣ ] ( ពួកសត្វស្លាបសរសើរថា ) សត្វស្លាបមានកំណើតពីរនេះ ប្រសើរណាស់តើ ជាអ្នកប្រកបដោយធម៌ដ៏ក្រៃលែង ឈរតែជើងម្ខាងប្រៀនប្រដៅតែធម៌ ។

[ ១៩៤ ] ( បក្សីពោធិសត្វពោលថា ) អ្នកទាំងឡាយមិនស្គាល់ច្បាស់នូវមារយាទនៃក្អែកនោះទេ អ្នកទាំងឡាយសរសើរព្រោះមិនដឹង ( ចំណែកខាងក្អែកអាក្រក់ ) ស៊ីទាំងពងទាំងកូន ( របស់ពួកយើង ) ហើយពោលថាធម៌ៗ ដូច្នេះ ។

[ ១៩៥ ] បុគ្គលអាក្រក់ និយាយដោយវាចាផ្សេង ធ្វើដោយកាយផ្សេង វាប្រព្រឹត្តធម៌តែសម្តីមិនមែនទាំងកាយផងទេ មិនតម្កល់ខ្លួនទុកក្នុងធម៌នោះ ។

[ ១៩៦ ] បុគ្គលអ្នកទន់ភ្លន់ដោយវាចា តែគេស្គាល់ចិត្តបាន ដោយក្រ ដូចជាពស់វែកបិទបាំងខ្លួន អាស្រ័យនៅក្នុងរូង បុគ្គលមានធម៌ជាទង់ជ័យ គេសន្មតថាល្អក្នុងស្រុកនិងនិគមទាំងឡាយ បុគ្គលបែបនេះ បុរសអ្នកល្ងង់ខ្លៅស្គាល់បានដោយក្រ ។

[ ១៩៧ ] អ្នកទាំងឡាយចូរបៀតបៀនក្អែកនេះ ដោយចំពុះផងចូរបៀតបៀនក្អែកនេះដោយជើងផង ចូរញ៉ាំងក្អែកលាមកនេះឲ្យវិនាសទៅ ក្អែកនេះ

មិនគួរឲ្យនៅជាមួយទេ ។

**ចប់ ធម្មទ្ធជជាតកទី ៩ ។**

## អដ្ឋកថា

## ធម្មទ្ធជជាតក

[ ១៩២-១៩៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុកុហកមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **ធម្មំ ចរថ ញាតយោ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា ក្នុងកាលនោះ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមិនមែនកុហកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏កុហកដូចគ្នាហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតបក្សី ចម្រើនធំធាត់ហើយ មានហ្វូងបក្សីចោមរោម អាស្រ័យនៅត្រង់កោះកណ្ដាលសមុទ្រ ។ កាលនោះ ឈ្មួញអ្នកកាសិករដ្ឋមួយក្រុម នាំគ្នាចេញសំពៅទៅកាន់សមុទ្រ ដោយយកក្អែកប្រាប់ទិសទៅផង ។ សំពៅបែកធ្លាយកណ្ដាលសមុទ្រ ។ ក្អែកប្រាប់ទិសនោះ ទៅដល់កោះនោះហើយគិតថា ហ្វូងបក្សីនេះជាហ្វូងធំ អញគួរធ្វើការកុហក ហើយស៊ីស៊ុតនិងកូនខ្ចីបក្សីទាំងនេះឲ្យឆ្អែត ។ ក្អែកហើរចុះហើយ ឈរជើងម្ខាងហាមាត់ត្រង់ផែនដី កណ្ដាលហ្វូងបក្សី ។ ក្អែកនោះ ត្រូវបក្សីទាំងឡាយសួរ

ថា អ្នកជានរណា ក៏ប្រាប់ថា ខ្ញុំជាអ្នកប្រព្រឹត្តធម៌ បក្សីសួរថា ហេតុអ្វីទើប អ្នកឈរជើងមួយ ក្អែកឆ្លើយថា បើខ្ញុំឈរជើងពីរ ផែនដីមិនអាច ទ្រទ្រង់ បានទេ បក្សីពោលថា បើដូច្នោះ ហេតុអ្វីទើបឈរហាមាត់ ក្អែកពោលថា ខ្ញុំ មិនបរិភោគអាហារដទៃ បរិភោគតែខ្យល់ប៉ុណ្ណោះ ។

កាលក្អែកឆ្លើយយ៉ាងនេះហើយ ទើបហៅបក្សីទាំងនោះមកជាស់តឿនថា ខ្ញុំនឹងឲ្យឱវាទដល់អ្នកទាំងឡាយ ចូរអ្នកមកស្តាប់ឱវាទនោះ បានពោលគាថា ទី ១ ជាការឲ្យឱវាទដល់បក្សីទាំងនោះថា

ម្នាលញាតិទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តធម៌ អ្នកទាំង
ឡាយចូរប្រព្រឹត្តធម៌ សេចក្តីចម្រើន ( នឹងមាន ) ដល់អ្នក
ទាំងឡាយ អ្នកប្រព្រឹត្តធម៌រមែងដេកជាសុខក្នុងលោកនេះនិង
លោកខាងមុខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មំ ចរថ** សេចក្តីថា អ្នកទាំងឡាយ ចូរ នាំគ្នាប្រព្រឹត្តធម៌ដោយប្រភេទជាកាយសុចរិតជាដើម ។ ក្អែកប្រាប់ទិស ហៅ បក្សីទាំងនោះថា ញាតិទាំងឡាយ ។ បទថា **ធម្មំ ចរថ ភទ្ទំ វោ** សេចក្តីថា អ្នកទាំងឡាយកាលប្រព្រឹត្តមួងហើយ កុំនាំគ្នារួញរា ចូរប្រព្រឹត្តធម៌រឿយ ៗ ចុះ សេចក្តីចម្រើននឹងមានដល់អ្នកទាំងឡាយ ។ ពាក្យថា **សុខំ សេតិ** នេះ ត្រឹមតែជាមាតិកាទេសនា ។ ក្អែកនោះ សម្តែងថា អ្នកប្រព្រឹត្តធម៌ ឈរ អង្គុយ ដើរ ដេក ក៏ជាសុខយ៉ាងក្រៃលែង គឺជាសុខគ្រប់ឥរិយាបថ ។

បក្សីទាំងឡាយមិនដឹងថា ក្អែកនេះពោលយ៉ាងនេះ ដើម្បីកុហកស៊ីស៊ុត

បក្សី ។ កាលសរសើរក្អែកទ្រុស្តសីលនោះ បានពោលគាថាទី ២ ថា

សត្វស្លាបមានកំណើតពីរនេះ ប្រសើរណាស់តើ ជាអ្នកប្រកប ដោយធម៌ដ៏ក្រៃលែង ឈរតែជើងម្ខាង ប្រៀនប្រដៅតែធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មមេវ** បានដល់ សភាវធម៌នោះឯង ។ បទថា **អនុសាសតិ** បានដល់ ទូន្មាន ។ បក្សីទាំងឡាយស្ដាប់ក្អែកទ្រុស្តសីលនោះហើយប្រាប់ថា បពិត្រលោកម្ចាស់ បានឮថា លោកមិនរកចំណីដទៃទទួលទានតែខ្យល់ប៉ុណ្ណោះ បើដូច្នោះ សូមលោកជួយមើលស៊ុតនិងកូនខ្ចីរបស់ពួកខ្ញុំផង ហើយនាំគ្នាចេញទៅរកចំណី ។ ក្អែកលាមកនោះ កាលបក្សីទាំងនោះទៅហើយ ក៏ចឹកស៊ុត និងកូនតូចរបស់បក្សីទាំងនោះលេបពេញពោះ កាលបក្សីទាំងនោះត្រឡប់មក ក៏ស្ងប់ស្ងៀម ឈរជើងមួយ ហាមាត់ ។ បក្សីទាំងឡាយមកហើយមិនឃើញកូនរបស់ខ្លួន ក៏យំទ្រហឹងថា នរណាហ្ន៎ ស៊ីកូនអញ មិនធ្វើសេចក្ដីសង្ស័យក្នុងក្អែកនោះ ព្រោះគិតថា ក្អែកនេះប្រព្រឹត្តធម៌ ។ ថ្ងៃមួយព្រះមហាសត្វគិតថា មុនអំពីនេះ មិនមានអន្តរាយអ្វីឡើយ ចាប់តាំងអំពីក្អែកនេះមកហើយ ទើបកើតអន្តរាយ អញគួរចាំមើលក្អែកនេះ ។ ព្រះមហាសត្វ ធ្វើដូចជាទៅរកចំណី ជាមួយបក្សីទាំងឡាយ តែក៏ត្រឡប់មកទំក្នុងទីកំបាំង ឯក្អែកយល់ថា បក្សីទាំងឡាយទៅហើយ មិនមានការសង្ស័យ ក្រោកទៅរកស៊ីស៊ុតបក្សីនិងកូនខ្ចី ហើយត្រឡប់មកឈរជើងមួយហាមាត់ ។ ស្ដេចបក្សីកាល បក្សីទាំងឡាយមកហើយ ទើបហៅឲ្យហ្វូងបក្សីទាំងអស់មក

ប្រជុំគ្នា ដាស់តឿនហ្វូងបក្សីថា ថ្ងៃនេះ ខ្ញុំឃ្លាំចាំមើលអន្តរាយ កូនចៅទាំងឡាយ បានឃើញក្អែកលាមកនេះ ស៊ីកូនតូច មកចុះអ្នកទាំងឡាយ ពួកយើងនឹងចាប់វាទុក រួចឲ្យព័ទ្ធក្អែកនោះ ប្រាប់ថា បើក្អែកនេះគេចទៅសោត អ្នកទាំងឡាយចូរចាប់វាហើយពោលគាថាដ៏សេសថា

អ្នកទាំងឡាយ មិនស្គាល់ច្បាស់នូវមារយាទ នៃក្អែកនោះទេ
អ្នកទាំងឡាយសរសើរព្រោះមិនដឹង ( ចំណែកខាងក្អែកអា-
ក្រក់ ) ស៊ីទាំងពងទាំងកូន ( របស់ពួកយើង ) ហើយពោល
ថាធម៌ៗ ដូច្នេះ ។

បុគ្គលអាក្រក់ និយាយដោយវាចាផ្សេង ធ្វើដោយកាយ
ផ្សេង វាប្រព្រឹត្តធម៌តែសម្តី មិនមែនទាំងកាយផងទេ មិន
តម្កល់ខ្លួនទុកក្នុងធម៌នោះ ។

បុគ្គលអ្នកទន់ភ្លន់ដោយវាចា តែគេស្គាល់ចិត្តបានដោយក្រ
ដូចជាពស់វែកបិទបាំងខ្លួន អាស្រ័យនៅក្នុងរូង បុគ្គលមានធម៌
ជាទង់ជ័យ គេសន្មតថាល្អក្នុងស្រុកនិងនិគមទាំងឡាយបុគ្គល
បែបនេះ បុរសអ្នកល្ងង់ខ្លៅ ស្គាល់បានដោយក្រ ។

អ្នកទាំងឡាយ ចូរបៀតបៀនក្អែកនេះ ដោយចំពុះផង ចូរ
បៀតបៀនក្អែកនេះដោយជើងផង ចូរញ៉ាំងក្អែកលាមកនេះ ឲ្យ
វិនាសទៅ ក្អែកនេះមិនគួរឲ្យនៅជាមួយទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាស្ស សីលំ** បានដល់ ក្អែកនេះមិនមាន

សីល ។ បទថា **អនញ្ញាយ** បានដល់ មិនដឹង ។ បទថា **ភុត្វា** បានដល់ ចឹកស៊ី ។ បទថា **វាចាយ នោ ច កាយេន** បានដល់ ព្រោះថា ក្អែកនេះ ប្រព្រឹត្តធម៌ដោយវាចាប៉ុណ្ណោះ តែមិនធ្វើដោយកាយឡើយ ។ បទថា **ន តំ ធម្មំ អធិដ្ឋិតោ** បានដល់ ព្រោះហេតុនោះ គួរជ្រាបក្អែកនេះទុកថា ក្អែកនេះ ពោលធម៌យ៉ាងណា មិនអធិដ្ឋានធម៌យ៉ាងនោះគឺមិនតាំងនៅក្នុងធម៌នោះទេ ។ បទថា **វាចាយ សខិលោ** បានដល់ ជាអ្នកទន់ភ្លន់ដោយវាចា ។ បទថា **មនោបវិទុគ្គោ** បានដល់ អាក្រក់ផ្លូវចិត្ត អ្នកដទៃដឹងបានដោយកម្រ ។ បទថា **បដិច្ឆន្នោ** បានដល់ ក្អែកដេកក្នុងរន្ធណា ត្រូវរន្ធនោះបិទបាំង ។ បទថា **ក្វបស្សយោ** បានដល់ មានរន្ធជាទីនៅអាស្រ័យ ។ បទថា **ធម្មទ្ធជោ** បានដល់ ឈ្មោះថា ធម្មទ្ធជ ព្រោះធ្វើសុចរិតធម៌ឲ្យជាទង់ត្រាច់ទៅ ។ បទថា **គាមនិគមាសុ សាធុ** បានដល់ ជាសប្បុរសទាំងក្នុងស្រុក ទាំងក្នុងនិគមទាំងឡាយ ។ បទថា **សម្មតោ** បានដល់ ត្រូវលើកតម្កើងថា ជាអ្នកចម្រើន ។ បទថា **ទុជ្ជានោ** បានដល់ បុគ្គលបែបនេះ ជាអ្នកទ្រុស្តសីល មានការងារបិទបាំង បុគ្គលល្ងង់ គឺបុគ្គលមិនដឹង មិនអាចដឹងបាន ។ បទថា **បាទា ចិមំ** សេចក្តីថា ចឹកខ្ទាំក្អែកនេះដោយជើងរបស់ខ្លួន ។ បទថា **វិហេឋថ** បានដល់ ចូរវាយ ។ បទថា **ជវំ** បានដល់ លាមក ( អាក្រក់ ) ។ បទថា **នាយំ** ជាដើម បានដល់ ក្អែកនេះ មិនគួរនៅរួមជាមួយយើង ដូច្នេះ ។

កាលប្រធានបក្សីពោលយ៉ាងនេះហើយ ខ្លួនឯងក៏លោតឡើង ប្រើចំពុះចឹកក្បាលក្អែកនោះ ។ បក្សីដ៏សេសក៏នាំគ្នាប្រើចំពុះខ្លះ ក្រចកខ្លះ ជើងខ្លះ

ស្លាបខ្ទះ ចឹក និងវាយ ។ ក្អែកនោះ ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ក្អែកកុហកក្នុងកាលនោះ បានមកជាភិក្ខុកុហកក្នុងកាលឥឡូវនេះ ឯស្តេចបក្សីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ធម្មទ្ធជជាតក ចប់

# ឆន្ទិយមិគរាជជាតក

[ ១៩៨ ] ( ម្រឹគមាតាបិតានិយាយផ្តាំថា ) ម្នាលព្រាហ្មណ៍ បើអ្នកទៅកាន់ឧទ្យានឈ្មោះអញ្ជន ក្នុងក្រុងសាកេត និយាយប្រាប់កូនឈ្មោះនន្ទិយៈជាឱរសរបស់ខ្ញុំថា មាតាបិតាទាំងឡាយរបស់អ្នកចាស់ហើយ គាត់ចង់ឃើញអ្នក ។

[ ១៩៩ ] ( នន្ទិយម្រឹគនិយាយថា ) បពិត្រទាំងឡាយ ទឹកនិងគោជនរបស់ព្រះរាជាខ្ញុំបានបរិភោគហើយ ម្នាលព្រាហ្មណ៍ ខ្ញុំមិនអាចបរិភោគទទេនូវដុំគោជនជាអំណោយរបស់ព្រះរាជានោះទេ ។

[ ២០០ ] ខ្ញុំនឹងបែរនូវចំហៀងខ្លួនដល់ព្រះរាជា មានសរក្នុងដៃ ក្នុងកាលណោះ ខ្ញុំក៏ដល់នូវសេចក្តីសុខ រួចចាក ( មរណៈ ) ហើយ ប្រហែលនឹងបានឃើញនូវមាតា ។

[ ២០១ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) កាលពីដើម តថាគត ជាសត្វជើងបួន មានរូបល្អ ជាស្តេចម្រឹគឈ្មោះនន្ទិយៈ ដោយឈ្មោះនៅក្នុងលំនៅនៃស្តេចកោសល ។

[ ២០២ ] ព្រះរាជាកោសល ផ្ចាប់ព្រួញយឹតធ្នូមកដើម្បីសម្លាប់នូវតថាគតនោះ ក្នុងឧទ្យានឈ្មោះអញ្ជនជាទីដែលពួកជនថ្វាយ ។

[ ២០៣ ] តថាគត ក៏បែរនូវចំហៀងខ្លួនដល់ព្រះរាជានោះដែលមានកូនសរក្នុងដៃក្នុងកាលណោះ តថាគត ក៏ដល់នូវសេចក្តីសុខរួចចាក ( មរណៈ ) ហើយបានមកឃើញមាតា ។

**ចប់ នន្ទិយមិគរាជជាតក ទី ១០**

## ចប់ អាភិរិយវគ្គទី ១

## ឧទ្ទាននៃអាភិរិយវគ្គនោះគឺ

( អំពីអាភិរិយជាតក ) មានពាក្យថា បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្វាល់ ១ សេតកេតុជាតកដ៏ប្រសើរ ១ ទរីមុខជាតក ១ នេរុជាតក ១ ( អាសង្កជាតក ) ១ ទៀតការមិនត្រេកអរ ១ សិរីទេវធីតា ១ មាន់មានស្លាបដ៏ប្រសើរវិចិត្រ ១ ក្អែកសម្តែងធម៌ ១ ម្រឹគឈ្មោះនន្ទិយៈ ១ ត្រូវជា ១០ ។

# អដ្ឋកថា

# នន្ទិយមិគរាជជាតក

[ ១៩៨-២០៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតា ត្រាស់រឿងនេះ មានពាក្យផ្តើមថា **សចេ ព្រាហ្មណា គច្ឆសិ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ពិតឬភិក្ខុ បានឮថា អ្នកចិញ្ចឹមគ្រហស្ថ កាលភិក្ខុនោះក្រាបទូលថា ករុណាពិតព្រះអង្គ ទើបទ្រង់ត្រាស់សួរថា គ្រហស្ថនោះជាអ្វីនឹងអ្នក កាលភិក្ខុនោះទូលថា ជាមាតាបិតារបស់ខ្ញុំព្រះអង្គ ទើបត្រាស់ថា ប្រពៃហើយភិក្ខុ អ្នករក្សាវង្សរបស់បុរាណកបណ្ឌិតទាំងឡាយទុក ព្រោះថា បុរាណកបណ្ឌិតទាំងឡាយ សូម្បីកើតក្នុងកំណើតតិរច្ឆាន ក៏បានឲ្យជីវិតដល់មាតាបិតាទាំងឡាយ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទកោសលសោយរាជសម្បត្តិ នៅក្នុងនគរសាកេតដែនកោសល ព្រះពោធិសត្វកើតក្នុងកំណើតម្រឹគ ធំចម្រើនហើយ មានឈ្មោះថា នន្ទិយម្រឹគ ដល់ព្រមដោយសីលនិងអាចារ ចិញ្ចឹមមាតាបិតា ។ កាលនោះព្រះបាទកោសលបានជាក្សត្រ ចូលចិត្តក្នុងការបរបាញ់ម្រឹគប៉ុណ្ណោះ ទ្រង់មិនឲ្យមនុស្សទាំងឡាយធ្វើកសិកម្មជាដើម ទ្រង់មានបរិវារច្រើន យាងទៅប្រមាញ់ម្រឹគរាល់ថ្ងៃ ។ ទើបមនុស្សទាំងឡាយប្រជុំប្រឹក្សាគ្នាថា នែអ្នក ព្រះរាជាអង្គនេះរំខានការងាររបស់ពួកយើង សូម្បីការគ្រប់គ្រងផ្ទះ ក៏នឹងលិចចុះបើដូច្នោះ ពួកយើងគួរព័ទ្ធឧទ្យានអញ្ជើញ ធ្វើទ្វារ ជីកស្រះបោក្ខរណី ដាំដើម

ឈើ ហើយកាន់ញញួរនិងជំបងជាដើម ចូលព្រៃវាយគុម្ពឈើ កៀងម្រឹគឲ្យចូលក្នុងក្រោល គឺឧទ្យាន ដូចសត្វគោ ហើយបិទទ្វារ ហើយក្រាបទូលព្រះរាជាឲ្យទ្រង់ធ្វើការងាររបស់ទ្រង់ ។ បុគ្គលគ្រប់គ្នាមានធនុះតែមួយថា នុ៎ះជាឧបាយដែលល្អក្នុងរឿងនេះ ។ នាំគ្នារៀបចំឧទ្យាន ហើយចូលព្រៃ ព័ទ្ធទីប្រមាណមួយយោជន៍ ។ ខណៈនោះ ម្រឹគឈ្មោះនន្ទិយៈ នាំមេបាទៅដេកត្រង់ផែនដីក្នុងព្រៃដែលមានទួលតូចៗមួយកន្លែង ។ មនុស្សទាំងឡាយកាន់ខែលនិងអាវុធជាដើម នាំគ្នាព័ទ្ធទួលនោះដោយយកដៃថ្កក់នឹងដៃ គឺចាប់ដៃគ្នា ។ កាលនោះ បានឃើញម្រឹគមួយហ្វូង ទើបនាំគ្នាចូលទៅកាន់ទីទួលនោះ ។ ម្រឹគនន្ទិយៈឃើញពួកមនុស្សគិតថា ថ្ងៃនេះ អញគួរលះបង់ជីវិតឲ្យជាទានដើម្បីមេបា ហើយក្រោកឡើង ថ្វាយបង្គំមេបា សូមខមាទោសថា បពិត្រ មេបា បើមនុស្សទាំងនេះ ចូលមកកាន់ទួលនេះហើយ នឹងឃើញពួកយើងទាំង ៣ សូមលោកទាំង ២ នៅដោយឧបាយណាមួយ ការបានទូវជីវិតរបស់លោកជារបស់ប្រសើរ ខ្ញុំនឹងឲ្យទានជីវិតដើម្បីមេនិងបា លុះមនុស្សទាំងឡាយឈរត្រង់ជាយទួលប៉ុណ្ណោះ ក៏ចេញទៅ គ្រានោះ ពួកមនុស្សយល់ថា ទួលនេះតូចគង់មានម្រឹគមួយប៉ុណ្ណោះ មិននាំគ្នាចូលទៅ សូមពុកនិងម៉ែកុំប្រមាទដូច្នេះហើយ ជាអ្នកត្រៀមខ្លួនទៅឈរហើយ លុះមនុស្សទាំងឡាយឈរត្រង់ទីទួលស្រែកហ៊ោកញ្ជៀវ ហើយវាយគុម្ពឈើប៉ុណ្ណោះ ព្រះពោធិសត្វក៏ចេញអំពីទួលនោះទៅ ។ មនុស្សទាំងនោះយល់ថា ក្នុងទួលនេះ គង់មានម្រឹគតែមួយប៉ុណ្ណោះឯង ទើបមិននាំគ្នាចូលទៅមើល ។ កាលនោះ នន្ទិយៈ បានចូលទៅ

ក្នុងចំណោមម្រឹគទាំងឡាយ ។ មនុស្សទាំងឡាយ បាននាំគ្នាកៀងម្រឹគទាំងអស់ចូលឧទ្យានហើយបិទទ្វារទុក ទូលឲ្យព្រះរាជាទ្រង់ជ្រាប ហើយទៅកាន់លំនៅរៀងៗខ្លួន ។ បន្ទាប់អំពីនោះមក ព្រះរាជាក៏យាងដោយទំនើងព្រះអង្គឯងឬទ្រង់បញ្ជូនអាមាត្យម្នាក់ទៅនាំយកម្រឹគមក ដោយព្រះតម្រាស់ថា ចូរឯងទៅបាញ់ម្រឹគមួយ ហើយនាំយកមក ដូច្នេះ ។ ទើបម្រឹគទាំងឡាយនាំគ្នាតាំងវារៈទុក ម្រឹគដែលដល់វារៈ នឹងឈរក្នុងទីសមគួរនាចំណែកម្ខាង មនុស្សទាំងឡាយនឹងបាញ់ម្រឹគនោះហើយយកមក ឯនន្ទិយៈ ក៏ផឹកទឹកក្នុងស្រះបោក្ខរណី និងស៊ីស្មៅក្នុងឧទ្យាននោះ អស់កាលវារៈរបស់គេមិនទាន់មកដល់ ។ កាលនោះ ដោយកាលវេលាកន្លងទៅច្រើនថ្ងៃ បានិងមេរបស់ម្រឹគចង់ជួបនន្ទិយៈ គិតថា នន្ទិយមិគរាជកូនរបស់អញមានកម្លាំងដូចដំរី សម្បូរដោយកម្លាំង បើនៅមានជីវិតគង់នឹងលោតច្រូងរបងមកជួបពួកយើងពិត យើងទាំងឡាយនឹងបញ្ជូនដំណឹងទៅ រួចឈរត្រង់ក្បែរផ្លូវ ឃើញព្រាហ្មណ៍ម្នាក់ ទើបសួរព្រាហ្មណ៍ដោយភាសាមនុស្សថា នែអ្នក អ្នកនឹងទៅណា កាលព្រាហ្មណ៍ឆ្លើយថា ទៅនគរសាកេត ដូច្នេះហើយ កាលបញ្ជូនដំណឹងទៅរកកូន ទើបពោលគាថាទី ១ ថា

ម្នាលព្រាហ្មណ៍ បើអ្នកទៅកាន់ឧទ្យានឈ្មោះអញ្ជន ក្នុងក្រុងសាកេត និយាយប្រាប់កូនឈ្មោះ នន្ទិយៈ ជាឱរសរបស់ខ្ញុំថា មាតាបិតាទាំងឡាយរបស់អ្នកចាស់ហើយ គាត់ចង់ឃើញអ្នក ដូច្នេះ ។

គាថានោះមានសេចក្ដីថា ម្នាលព្រាហ្មណ៍ បើអ្នកទៅនគរសាកេតសោត ក្នុងនគរសាកេត មានឧទ្យានឈ្មោះថាអញ្ជនវ័ន ក្នុងឧទ្យាននោះ មានម្រឹគឈ្មោះថា នន្ទិយៈ ជាកូនរបស់ខ្ញុំ លោកគប្បីប្រាប់ថា មាតាបិតារបស់អ្នកចាស់ហើយចង់ជួបអ្នកមុនស្លាប់ ។

ព្រាហ្មណ៍ទទួលពាក្យថា សាធុ ទៅដល់នគរសាកេត ស្អែកឡើង ក៏ចូលក្នុងឧទ្យានសួរថា សត្វណាឈ្មោះនន្ទិយម្រឹគ ម្រឹគមកហើយ ឈរក្បែរព្រាហ្មណ៍នោះប្រាប់ថា ខ្ញុំ ។

ព្រាហ្មណ៍ប្រាប់រឿងនោះឲ្យជ្រាប ។ នន្ទិយៈបានឮពាក្យនោះហើយកាលប្រកាសសេចក្ដីនេះថា បពិត្រព្រាហ្មណ៍ ខ្ញុំត្រូវទៅ តែមិនលោតកន្ទងរបងទៅ ព្រោះខ្ញុំស៊ីចំណី ផឹកទឹក និងស្មៅដែលជារបស់ព្រះរាជាហើយ ចំណីជាដើមនោះ តាំងនៅក្នុងឋានៈជាបំណុលសម្រាប់ខ្ញុំ ទាំងខ្ញុំក៏នៅក្នុងកណ្ដាលពួកម្រឹគទាំងនេះមកយូរហើយ ។ ឈ្មោះថា ការទៅដោយមិនបានបង្ហាញកម្លាំងរបស់ខ្លួន មិនធ្វើសួស្ដីឲ្យព្រះរាជានោះនិងម្រឹគទាំងឡាយនោះ មិនសមគួរដល់ខ្ញុំ តែកាលដល់វារៈរបស់ខ្លួនហើយ ខ្ញុំនឹងនាំសួស្ដីដល់អ្នកទាំងនោះឲ្យនៅជាសុខ ហើយសឹមមក ដូច្នេះ ទើបពោលគាថា ២ ថា

បន្ទែទាំងឡាយ ទឹកនិងភោជនរបស់ព្រះរាជា ខ្ញុំបានបរិ-
ភោគហើយ ម្នាលព្រាហ្មណ៍ ខ្ញុំមិនអាចបរិភោគទទេនូវដុំភោ-
ជនជាអំណោយរបស់ព្រះរាជានោះទេ ។
ខ្ញុំនឹងបែរនូវចំហៀងខ្លួនដល់ព្រះរាជា មានសរក្នុងដៃ ក្នុង

កាលណោះ ខ្ញុំក៏ដល់នូវសេចក្តីសុខ រួចចាក ( មរណៈ )
ហើយ ប្រហែលនឹងបានឃើញនូវមាតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆិវាថានិ** បានដល់ ចំណីដែលព័ន្ធទុកក្នុងទីនោះៗ ។ បទថា **ថានភោជនំ** បានដល់ ទឹកនិងស្មៅដ៏សេស ។ បទថា **តំ រាជបិណ្ឌំ** សេចក្តីថា ទឹកនិងស្មៅ ឈ្មោះថា បិណ្ឌ ព្រោះអត្ថថា យករបស់ព្រះរាជាមករួមទុក ។ បទថា **អវភោត្តុំ** បានដល់ ដើម្បីស៊ីទទេៗ អធិប្បាយថា ម្រឹគនន្ទិយៈពោលថា អ្នកស៊ីហើយ កាលមិនទាន់ញុំាងរាជកិច្ចឲ្យសម្រេច ឈ្មោះថា ស៊ីចំណីនោះទទេៗ ខ្ញុំមិនព្យាយាមស៊ីឲ្យខូចទទេយ៉ាងនោះ ។ បទថា **ព្រាហ្មណា** ក្នុងបទថា **ព្រាហ្មណាមុស្សហោ** ជាពាក្យហៅ ចំណែក ម អក្ខរៈ ពោលទុកដោយអំណាចបទសន្ធិគឺការភ្ជាប់បទ ។ បទថា **ឱធហិស្សាមហំ បស្សំ ខុរប្បាណិស្ស រាជិនោ** សេចក្តីថា បពិត្រព្រាហ្មណ៍ កាលដល់វារៈរបស់ខ្លួនហើយ ខ្ញុំនឹងចេញចាកហ្វូងម្រឹគ មកឈរក្នុងទីសមគួរមួយកន្លែង ក្រាបទូលព្រះរាជា ដែលទ្រង់ផ្ទាប់ព្រួញហើយយាងមកថា បពិត្រមហារាជ សូមទ្រង់បាញ់ខ្ញុំ ហើយបង្ហាញចំហៀងត្រង់ចំណែកធំ ឲ្យជាកន្លែងសម្រាប់បាញ់ ។ បទថា **សុខិតោ មុត្តោ** សេចក្តីថា កាលនោះ ខ្ញុំនឹងជាអ្នករួចហើយចាកភ័យ គឺសេចក្តីស្លាប់ មានសេចក្តីសុខ មិនមានទុក្ខ ព្រះរាជាទ្រង់អនុញ្ញាតហើយ គង់ឃើញមេមិនខាន ។

ព្រាហ្មណ៍បានស្តាប់ពាក្យនោះហើយ ក៏ចៀសចេញទៅ ក្នុងកាលតមកក្នុងថ្ងៃដែលជាវារៈនៃម្រឹគនន្ទិយៈ ព្រះរាជាបានយាងមកកាន់ឧទ្យាន មួយ

អន្ទីដោយរាជបរិវារជាច្រើន ។ ឯមហាសត្វ បានឈរក្នុងទីសមគួរមួយកន្លែង ព្រះរាជាទ្រង់យឹតធ្នូដោយបំណងថា អញនឹងបាញ់ម្រឹគ មហាសត្វមិនគេចទៅដូចសត្វទាំងឡាយដែលត្រូវមរណភ័យគំរាមហើយគេចទៅ ធ្វើដូចមិនមានភ័យ ធ្វើមេត្តាឲ្យជាបុរេចារិកហើយ បានឈរត្រង់ចំហៀងដែលធំ ធ្វើឲ្យជាទីសម្រាប់បាញ់ មិនគេចឡើយ ។ ព្រះរាជាមិនអាចលែងព្រួញ ចេញទៅបាន ដោយអំណាចមេត្តានោះ ។ ទើបព្រះមហាសត្វទូលថា បពិត្រមហារាជទ្រង់លែងសរមិនចេញឬ សូមទ្រង់លែងចុះ ព្រះរាជាត្រាស់ថា ម្នាលមិគរាជយើងមិនអាចលែងចេញទៅបានទេ មហាសត្វទូលថា បពិត្រមហារាជ បើដូច្នោះ ទ្រង់ក៏ដឹងគុណធម៌របស់អ្នកមានគុណធម៌ កាលនោះ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងព្រះពោធិសត្វ ទ្រង់ដាក់ធ្នូហើយ ត្រាស់ថា សូម្បីកំណាត់ឈើនេះមិនមានចិត្ត ក៏គង់ដឹងគុណរបស់អ្នក ឯយើងជាមនុស្សមានចិត្ត តែមិនដឹងចូរឲ្យអភ័យដល់យើង យើងនឹងឲ្យអភ័យដល់អ្នក ។

ព្រះពោធិសត្វពោលថា បពិត្រមហារាជ ទ្រង់ព្រះរាជទានអភ័យដល់ខ្ញុំជាបឋម ចុះហ្វូងម្រឹគក្នុងឧទ្យាននេះនឹងធ្វើដូចម្ដេច ។ ព្រះរាជាត្រាស់ថា សត្វទាំងនេះ យើងក៏ឲ្យអភ័យ ។

ព្រះពោធិសត្វ កាលឲ្យព្រះរាជាព្រះរាជទានអភ័យដល់ម្រឹគក្នុងព្រៃ បក្សីដែលហើរក្នុងអាកាស ត្រីដែលហែលក្នុងទឹក ដោយន័យដែលពោលហើយក្នុងនិគ្រោធមិគជាតកនោះឯង យ៉ាងនេះហើយ បានឲ្យព្រះរាជាទ្រង់ប្រតិស្ឋានក្នុងសីល ៥ ហើយទូលថា បពិត្រមហារាជ ធម្មតាព្រះរាជាគួរទ្រង់លះការ

លុះដោយអំណាចអគតិ ទ្រង់កុំញុំាងទសពិធរាជធម៌ឲ្យកម្រើកគ្រងរាជ្យដោយធម៌ ដោយធម៌ស្មើ ដូច្នេះ ។ ព្រះមហាសត្វ បានសម្តែងរាជធម៌ដែលពោលទុកយ៉ាងនេះ ដោយចងជាគាថាទុក ( ក្នុងមហាហំសជាតក ) ថា

( ធម៌ ១០ ប្រការគឺ ) ទាន ១ សីល ១ បរិច្ចាគ ១ ភាពនៃចិត្តត្រង់ ១ ភាពនៃចិត្តទន់ ១ តបគឺឧបោសថសីល ១ ការមិនក្រោធ ១ ការមិនបៀតបៀន ១ ខន្តិ ១ កិរិយាមិនភ្លាត់ ១ ។ យើងឃើញនូវកុសលធម៌ទាំងនេះ ឋិតនៅក្នុងខ្លួន លំដាប់នោះ បីតិនិងសោមនស្សជាច្រើនកើតឡើងដល់យើង ដោយប្រការដូច្នេះ ។

ហើយស្នាក់នៅក្នុងរាជសម្នាក់ ២-៣ ថ្ងៃ ទើបទូលថា បពិត្រមហារាជ សូមទ្រង់ប្រោសឲ្យរាជបុរស វាយសុវណ្ណភេរី ដើរប្រកាសការព្រះរាជទានអភ័យ ដល់សព្វសត្វក្នុងព្រះនគរ ទ្រង់កុំប្រមាទ ដូច្នេះហើយ ទើបទៅសួរសុខទុក្ខមេបា ។ គាថាតទៅនេះ ជាអភិសម្ពុទ្ធគាថា ដូច្នេះថា

កាលពីដើម តថាគតជាសត្វជើងបួន មានរូបល្អ ជាស្តេចម្រឹគឈ្មោះនន្ទិយៈ ដោយឈ្មោះនៅក្នុងលំនៅ នៃស្តេចកោសល ។

ព្រះរាជាកោសល ផ្ចាប់ព្រួញយឹតធ្នូមកដើម្បីសម្លាប់នូវតថាគតនោះ ក្នុងឧទ្យានឈ្មោះអញ្ជន ជាទីដែលពួកជនថ្វាយ ។

តថាគត ក៏បែរនូវចំហៀងខ្លួនដល់ព្រះរាជានោះ ដែលមានកូនសរក្នុងដៃ ក្នុងកាលណោះ តថាគតក៏ដល់នូវសេចក្តីសុខ

រូបចាក ( មរណៈ ) ហើយបានមកឃើញមាតា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោសលស្ស និកេតវេ** សេចក្ដីថា ជិតរាជសម្នាក់ គឺទីប្រថាប់របស់ព្រះបាទកោសល អធិប្បាយថា ក្នុងព្រៃក្បែររាជសម្នាក់នោះ ។ បទថា **ធាយស្មិំ** បានដល់ ក្នុងឧទ្យានដែលព្រះរាជទានដើម្បីជាប្រយោជន៍ឲ្យជាទីនៅរបស់ម្រឹគទាំងឡាយ ។ បទថា **អារជ្ជ កត្វាន** មានអត្ថថា លើកឡើងរួមចូលគ្នាជាមួយខ្សែ គឺឃឹតធ្នូ ។ បទថា **សន្ធាយ** សេចក្ដីថា ទ្រង់ផ្ទាប់ គឺប្រកបនូវព្រួញ ។ បទថា **ឱធហឹ** សេចក្ដីថា បែរឲ្យ គឺធ្វើឲ្យជាទីសម្រាប់បាញ់ ។ បទថា **មាតរំ ឧដ្ឋុមាគតោ** នេះ ត្រឹមតែជាមាតិកានៃទេសនា អធិប្បាយថា ខ្ញុំកាលសម្ដែងធម៌ថ្វាយព្រះរាជា ហើយបានទូលព្រះរាជាឲ្យវាយស្គរណ្ណភេរីប្រកាស ដើម្បីព្រះរាជទានអភ័យ ដល់ពួកសត្វហើយ ទើបបានមករកមេបា ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុដែលចិញ្ចឹមមាតាបិតា តាំងនៅហើយក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា មេនិងបានៃស្ដេចម្រឹគក្នុងកាលនោះ បានមកជាត្រកូលមហារាជ ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាសារីបុត្ត ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯនន្ទិយមិគរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា នន្ទិយមិគរាជជាតក ចប់**

**អាភិរិយវគ្គ ចប់**

# ខុរបុត្តវគ្គ

## ខុរបុត្តជាតក

[ ២០៤ ] ( សេះសិន្ធវៈនិយាយថា ) ឮថាបណ្ឌិតទាំងឡាយ បាន ពោលនូវសត្វពពែថាជាសត្វពាលដោយពិត អ្នកចូរមើលចុះ សត្វពាលមិន ដឹងនូវអំពើដែលគួរធ្វើក្នុងទីកំបាំង ទៅធ្វើក្នុងទីវាល ។

[ ២០៥ ] ( ពពែនិយាយថា ) ម្នាលសម្លាញ់ អ្នកទេឬជាសត្វពាល ម្នាលខុរបុត្ត អ្នកចូរដឹងចុះ អ្នកជាសត្វដែលត្រូវគេរួបរឹតដោយខ្សែ មានបបូរ មាត់វៀច មានមុខឱនចុះ ។

[ ២០៦ ] ម្នាលសម្លាញ់ អ្នកណាបានរួចចេញ ( អំពីរថ ) មិនរត់ទៅ អ្នកនោះពេញជាពាលទៅទៀត ម្នាលសម្លាញ់ អ្នកនាំនូវស្តេចសេនកៈណា ស្តេចសេនកៈនោះ ចាត់ជាមនុស្សពាលបំផុត ។

[ ២០៧ ] ( សេះសិន្ធវៈនិយាយថា ) ម្នាលសម្លាញ់ បើខ្ញុំជាសត្វពាល ដោយហេតុណា ម្នាលអជរាជ អ្នកចូរដឹងនូវហេតុនោះចុះ តែថាស្តេចសេនកៈ ជាមនុស្សពាលដោយហេតុដូចម្តេច អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់ហេតុនោះ ។

[ ២០៨ ] ( ពពែប្រាប់ថា ) បុគ្គលណាបាននូវមន្ត ជាប្រយោជន៍ដ៏ឧត្តម ហើយប្រគល់ឲ្យប្រពន្ធ ( បុគ្គលនោះ ) នឹងលះបង់នូវខ្លួន ដោយការឲ្យមន្ត នោះ ទាំងប្រពន្ធនោះនឹងមិនមានដល់បុគ្គលនោះឡើយ ។

[ ២០៩ ] ( ពពែពោលថា ) បពិត្រព្រះអង្គជាធំជាងជន បុគ្គលបែប នោះ លះបង់ចោលនូវខ្លួន មិនសេពគប់នូវវត្ថុជាទីស្រឡាញ់ ដោយគិតថា ( វត្ថុនេះ ) ជាទីស្រឡាញ់របស់អញ ខ្លួនឯងតើប្រសើរជាងរបស់ដែលប្រ-

សើរទៅទៀត ព្រោះបុរសដែលមានខ្លួនអប់រំហើយ គប្បីបាននូវផលជាទីស្រឡាញ់ក្នុងកាលជាខាងក្រោយ ។

**ចប់ ខុរប្បជាតកទី ១ ។**

# ខុរប្បវគ្គ

## អដ្ឋកថា ខុរប្បជាតក

[ ២០៤-២០៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលត្រូវកិរិយាចាស់លួងលោម ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សច្ចំ កិរេវ មាហំសុ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុបានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះទូលថា ករុណាព្រះអង្គ ពិតមែន កាលត្រូវត្រាស់សួរទៀតថា អ្នកអផ្សុកព្រោះហេតុអ្វី ទើបក្រាបទូលថា ព្រោះអតីតភរិយារបស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ស្រីនេះធ្វើវត្ថុដែលមិនជាប្រយោជន៍ដល់អ្នក មិនចំពោះក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកលោតចូលភ្លើងស្លាប់ ព្រោះអាស្រ័យស្រីនេះ តែអាស្រ័យបណ្ឌិត ទើបបានជីវិត ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមថាសេនកៈ សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបាននូវតំណែងជាសក្កទេវរាជ ។ កាលនោះ

ព្រះបាទសេនកៈទ្រង់មានសេចក្តីស្និទ្ធស្នាលជាមួយនាគរាជមួយ ។ បានឮថា នាគរាជនោះ ចេញអំពីនាគពិភព ដើររកចាប់ចំណីលើគោក គ្រានោះ ក្មេងអ្នកស្រុកឃើញហើយ នាំគ្នាស្រែកថា នេះពស់ ហើយនាំគ្នាយកដុំដី និងដំបងជាដើមវាយ ។ ព្រះរាជាទ្រង់ក្រសាលឧទ្យាន ទ្រង់ឃើញហើយត្រាស់សួរថា ក្មេងទាំងនោះធ្វើអ្វី ទ្រង់ជ្រាបថា នាំគ្នាវាយពស់ ទើបត្រាស់ថា ពួកឯងកុំសម្លាប់ ចូរឲ្យពស់នោះគេចទៅ ទ្រង់ឲ្យនាគរាជគេចទៅហើយ ។ នាគរាជមានជីវិតហើយ បានទៅកាន់នាគពិភព កាន់យករតនៈជាច្រើន ក្នុងពេលកណ្តាលយប់ ទៅកាន់ទីផ្ទំរបស់ព្រះរាជា ថ្វាយនូវរតនៈទាំងនោះ ហើយទូលថា ទូលបង្គំអាស្រ័យទ្រង់ទើបបានជីវិត ហើយបានធ្វើមិត្តភាពជាមួយព្រះរាជា ទើបចូលគាល់ព្រះរាជារឿយៗ ។ នាគរាជនោះបានឲ្យនាគមាណវិកាមួយដែលមិនឆ្អែតក្នុងកាមគុណ បណ្តានាគមាណវិកាទាំងឡាយរបស់ខ្លួន ទុកប្រចាំរាជសម្នាក់ ដើម្បីជាប្រយោជន៍ដល់ការរក្សា ។ នាគរាជនោះទូលថា កាលណាទ្រង់មិនឃើញនាគមាណវិកានោះ កាលនោះ ទ្រង់គប្បីរាយមន្តនេះ ហើយបានថ្វាយមន្តមួយបទ ។ ថ្ងៃមួយ ព្រះរាជាទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់លេងទឹកក្នុងស្រះបោក្ខរណីជាមួយនាគមាណវិកា ។ នាគមាណវិកាឃើញពស់ទឹកមួយ ទើបកាឡាអត្តភាពជាពស់ សេពអសទ្ធម្មជាមួយពស់នោះ ព្រះរាជាកាលមិនឃើញនាគមាណវិកា ទ្រង់សង្ស័យថា នាងទៅណាហ្ន៎ ទើបរាយមន្ត ហើយទ្រង់ឃើញនាងកំពុងធ្វើអនាចារ ទើបទ្រង់វាយដោយបន្ទះឫស្សី នាគមាណវិកាក្រោធ ទើបចេញពីព្រះរាជឧទ្យាន ទៅកាន់

នាគពិភព ។ ត្រូវនាគរាជសួរថា ហេតុអ្វីទើបនាងមក ក៏ទូលថា សម្លាញ់របស់ទ្រង់វាយខ្នងខ្ញុំនឹងបន្ទះឫស្សី នាគរាជមិនជឿ ទើបបង្ហាញស្នាមវាយឲ្យមើល ។ នាគរាជ មិនដឹងតាមការពិត ទើបហៅនាគមាណព ៤ មក បញ្ជូនទៅដោយព្រះតម្រាស់ថា បាទាំងឡាយចូរទៅ ចូរនាំគ្នាចូលទៅកាន់ទីបន្ទំរបស់ព្រះបាទសេនកៈ ហើយទម្លាយព្រះទែននោះឲ្យក្លាយជាអង្កាម ដោយខ្យល់ពិសដែលចេញពីច្រមុះនោះឯង ។ នាគមាណពទាំងនោះ នាំគ្នាទៅហើយបានចូលទៅកាន់បន្ទប់ក្នុងពេលដែលព្រះរាជាទ្រង់ផ្ទំលើទីបន្ទំដ៏ស្អាត ក្នុងពេលដែលនាគមាណពទាំងនោះ ចូលទៅនោះឯង ព្រះរាជាបានត្រាស់សួរព្រះរាជទេវីថា នែនាងដ៏ចម្រើន នាងដឹងទេ នាងនាគមាណវិកាទៅណា ព្រះរាជទេវីទូលថា ខ្ញុំម្ចាស់មិនដឹងទេ ។ ព្រះរាជាត្រាស់ថា ថ្ងៃនេះ នាងនាគមាណវិកានោះ បានលះអត្តភាពរបស់ខ្លួន ហើយធ្វើអនាចារជាមួយពស់ទឹកមួយក្នុងកាលទៅលេងទឹកក្នុងស្រះបោក្ខរណីរបស់យើង កាលបើដូច្នោះ ទើបខ្ញុំយកបន្ទះឫស្សីវាយដើម្បីឲ្យសិក្សាថា កុំធ្វើយ៉ាងនេះ ។ នាងទៅកាន់ នាគពិភព គង់ប្រាប់រឿងដទៃណាមួយ ដល់សម្លាញ់របស់យើង ហើយទម្លាយមិត្តភាពភ័យនឹងកើតឡើងដល់យើង ។ នាគមាណពទាំងឡាយ បានស្តាប់ដូច្នោះហើយទើបនាំគ្នាត្រឡប់ទៅនាគពិភព ទូលសេចក្តីនោះដល់នាគរាជ ។ ខណៈនោះឯងស្តេចនាគដល់នូវសេចក្តីសង្វេគ ហើយយាងមកកាន់ទីបន្ទំរបស់ព្រះរាជាទូលឲ្យដឹងសេចក្តីនោះ សូមខមាទោសហើយបានថ្វាយមន្តឈ្មោះថា សព្វរុតជននៈ គឺមន្តដឹងសំឡេងរបស់សត្វគ្រប់ប្រភេទ ដោយបំណងថា នេះជាទណ្ឌ

កម្មរបស់ខ្ញុំ ហើយទូលថា បពិត្រមហារាជ មន្តនេះមានតម្លៃកាត់ថ្លៃមិនបាន បើទ្រង់បានប្រទានមន្តនេះដល់អ្នកដទៃសោត កាលទ្រង់ប្រទានហើយ ត្រូវលោតចូលភ្លើង សោយទិវង្គត ព្រះរាជាទ្រង់ទទួលថា សាធុ ។ បន្ទាប់អំពីនោះមក សូម្បីសំឡេងស្រមោចក៏ទ្រង់ជ្រាប ។ ថ្ងៃមួយ កាលព្រះរាជាប្រថាប់គង់ត្រង់ល្វែងប្រាសាទ សោយរបស់ទំពាជ្រលក់ទឹកឃ្មុំ ទឹកអំពៅ ទឹកឃ្មុំ ទឹកអំពៅ មួយតំណក់និងនំមួយដុំធ្លាក់ចុះត្រង់ផែនដី ស្រមោចក្រហមមួយឃើញតំណក់ទឹកឃ្មុំជាដើមនោះ ដើរស្រែកប្រាប់គ្នាថា ថាសទឹកឃ្មុំរបស់ព្រះរាជាបែកត្រង់ផ្ទៃប្រាសាទ ក្អមទឹកអំពៅ ធ្នាំងនំក៏ផ្កាប់ អ្នកទាំងឡាយចូរបរិភោគទឹកឃ្មុំ ទឹកអំពៅ និងនំ ។ ព្រះរាជាទ្រង់ស្តាប់សំឡេងស្រែកប្រាប់របស់ស្រមោចភ្លើងហើយ ទ្រង់អស់ព្រះសំណើច ។ ព្រះរាជទេវីប្រថាប់ក្បែរព្រះរាជាត្រិះរិះថា ព្រះរាជាទ្រង់ឃើញអ្វីហ្ន៎ ទើបទ្រង់សើច កាលព្រះរាជាសោយរបស់ទំពា ទ្រង់ស្រង់ទឹកហើយ ប្រថាប់គង់លើព្រះរាជបល្ល័ង្ក រុយឈ្មោលមួយនិយាយនិងរុយញីមួយថា មកចុះនាង ពួកយើងនឹងអភិរម្យដោយសេចក្តីត្រេកអរក្នុងកិលេស ។ លំដាប់នោះ រុយញីនិយាយនឹងរុយឈ្មោលថា រង់ចាំសិនបង ឥឡូវនេះ រាជបុរសនឹងនាំគ្រឿងក្រអូបមកថ្វាយព្រះរាជា លុះទ្រង់លាបគ្រឿងក្រអូប លម្អិតក្រអូបនឹងធ្លាក់ទៀបបាទមូល ខ្ញុំនឹងចូលទៅលាបក្នុងទីនោះហើយនឹងមានក្លិនក្រអូប បន្ទាប់អំពីនោះ យើងនឹងដេកអភិរម្យលើខ្នងរបស់ព្រះរាជា ព្រះរាជាទ្រង់ស្តាប់សំឡេងនោះហើយក៏ទ្រង់ព្រះសំណើច ។ ឯព្រះទេវីទ្រង់ព្រះតម្រិះថា ព្រះរាជាទ្រង់ឃើញអ្វីហ្ន៎ ទើបទ្រង់សើច កាល

ព្រះរាជាទ្រង់សោយព្រះក្រយាហារល្វាចទៀត កត្តពិសេសមួយជុំជ្រះត្រង់ជី ស្រមោចទាំងឡាយស្រែកប្រាប់គ្នាថា ឆ្នាំងព្រះក្រយាហារក្នុងព្រះរាជត្រកូលបែកហើយ ពួកអ្នកទាំងឡាយចូរនាំគ្នាទទួលទានកត្តាហារចុះ ។ ព្រះរាជាកាលបានស្តាប់ពាក្យនោះហើយ ទ្រង់អស់ព្រះសំណើចទៀត ឯព្រះទេវីកាន់យកស្លាបព្រាមាសអង្គាសព្រះរាជា ទើបព្រះនាងវិតក្កថា ព្រះរាជាទ្រង់ឃើញអ្វីហ្ន៎ ទើបទ្រង់សើច ក្នុងកាលឡើងទែនព្រះបន្ទំជាមួយព្រះរាជា ព្រះនាងទូលសួរថា បពិត្រព្រះសម្មតិទេព ទ្រង់សើចព្រោះហេតុអ្វី ព្រះរាជាត្រាស់ថា មានប្រយោជន៍អ្វីសម្រាប់នាង ព្រោះហេតុដែលខ្ញុំសើច ត្រូវព្រះនាងរំអុករឿយៗ ទើបត្រាស់ប្រាប់ បន្ទាប់អំពីនោះ ព្រះទេវីក៏ទូលថា សូមទ្រង់ប្រទានមន្តដែលធ្វើឲ្យដឹងសំឡេងសត្វរបស់ទ្រង់ដល់ខ្ញុំម្ចាស់ សូម្បីព្រះរាជាទ្រង់ឃាត់ថាយើងមិនអាចឲ្យបានទេ ក៏ព្រះនាងនៅតែរំអុករឿយៗ ។ ទើបព្រះរាជាត្រាស់ថាបើយើងឲ្យមន្តនេះដល់នាងសោត យើងក៏នឹងស្លាប់ ។ ព្រះនាងទូលថា បពិត្រព្រះសម្មតិទេព ទោះបីទ្រង់អស់ព្រះជន្មក៏សូមប្រទានដល់ខ្ញុំម្ចាស់ ព្រះរាជាជាបុគ្គលឈ្មោះថា ធ្លាក់នៅក្នុងអំណាចមាតុគ្រាម ទើបទ្រង់ទទួលថា សាធុហើយទ្រង់កាត់ព្រះទ័យថា អញនឹងឲ្យមន្តដល់ព្រះទេវី ហើយសឹមចូលគំនរភ្លើង ដូច្នេះ ហើយបានយាងចូលទៅកាន់ព្រះរាជឧទ្យាន ដោយរាជរថ ។ ខណៈនោះសក្កទេវរាជទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញហេតុការណ៍នេះហើយ ទ្រង់ត្រិះរិះថា ព្រះរាជាល្ងង់ខ្លៅអង្គនេះ អាស្រ័យមាតុគ្រាមយាងទៅដោយបំណងថា នឹងចូលគំនរភ្លើង អញនឹងឲ្យជីវិតដល់ព្រះរាជា ហើយ

ទ្រង់នាំអសុរកញ្ញាឈ្មោះសុជាតា មកកាន់ក្រុងពារាណសី ហើយទ្រង់ឲ្យនាង សុជាតាធ្វើជាពពែញី ទ្រង់ធ្វើជាពពែឈ្មោល ហើយទ្រង់អធិដ្ឋានថា ចូរមហាជនកុំឃើញ ហើយបានទៅនៅខាងមុខរាជរថ ។ ព្រះរាជាបានទតឃើញពពែនោះ ។ ឯសេះដែលទឹមរថក៏ឃើញដែរ តែអ្នកដទៃមិនឃើញ ។ ពពែឈ្មោលធ្វើអាកប្បកិរិយាសេពមេថុនធម្មជាមួយពពែញីខាងមុខរាជរថ ដើម្បីនឹងសាងរឿងឡើង ។ សេះទឹមរថមួយឃើញពពែនោះ ទើបពោលថា នែពពែ កាលមុនពួកយើងបានឮគេពោលថា ពួកពពែល្ងង់ មិនមានការខ្មាស និងមិនឃើញរឿងនោះ តែឯងធ្វើអនាចារដែលត្រូវធ្វើក្នុងទីកំបាំងដែលជាទីបិទបាំង ចំពោះមុខពួកយើង មានចំនួនប៉ុណ្ណោះដែលកំពុងមើលនោះឯង ឯងមិនខ្មាសពាក្យដែលពួកយើងបានឮមក អំពីមុននោះ សមនឹងហេតុការណ៍ដែលបានឃើញនេះ ហើយបានពោលគាថាទី ១ ថា

ឮថាបណ្ឌិតទាំងឡាយ បានពោលនូវសត្វពពែថាជាសត្វពាល
ដោយពិតអ្នកចូរមើលចុះ សត្វពាល មិនដឹងនូវអំពើដែលគួរ
ធ្វើក្នុងទីកំបាំងទៅធ្វើក្នុងទីវាល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាលកំ** បានដល់ ពពែ ។ បទថា **បណ្ឌិតា** សេចក្ដីថា ជាអ្នកសម្បូរដោយញាណ ពោលដល់ពពែនោះថាល្ងង់ បានដឹងថាជាពាក្យពិត ។ បទថា **បស្ស** ជាពាក្យតឿន សេចក្ដីថា ចូរមើលចុះ ។ បទថា **ន ពិជ្ឈតិ** សេចក្ដីថា មិនដឹងការធ្វើនោះ មិនគួរ ។ ពពែបានស្ដាប់ដូច្នេះហើយ បានពោលគាថា ២ ថា

ម្នាលសម្លាញ់ អ្នកទេឬជាសត្វពាល ម្នាលខុរបុត្ត អ្នកចូរ ដើរចុះ អ្នកជាសត្វដែលត្រូវគេរួបរឹតដោយខ្សែ មានបបូរមាត់ វៀច មានមុខឱនចុះ ។

ម្នាលសម្លាញ់ អ្នកណាបានរួចចេញ ( អំពីរថ ) មិន រត់ទៅ អ្នកនោះ ពេញជាពាលទៅទៀត ម្នាលសម្លាញ់ អ្នក នាំនូវស្តេចសេនកៈណា ស្តេចសេនកៈនោះ ចាត់ជាមនុស្ស ពាលបំផុត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ត្វំ នុ ខោ សម្ម** បានដល់ នែសិន្ធពសម្លាញ់ ឯងល្ងង់ជាងខ្ញុំច្រើនណាស់ ។ បទថា **ខុរបុត្ត** បានដល់ បានឮថា សេះ នោះជាពូជពង្សរបស់លា ព្រោះហេតុនោះ ទើបពពែពោលនឹងសេះនោះយ៉ាង នេះ ។ បទថា **វិជានហិ** បានដល់ ឯងចូរដើរចុះថា អ្នកនោះឯងល្ងង់ ។ បទថា **បរិក្ខិត្តោ** បានដល់ ឯងត្រូវគេយកខ្សែទាក់កក្ដាប់នឹងនឹម ។ បទថា **វង្កោដ្ឋោ** បានដល់ មានមាត់វៀច ។ បទថា **ឱហិតោមុខោ** បានដល់ មាន មាត់ត្រូវខ្សែចងទុក ។ បទថា **មុត្តោ ន បលាយសិ** សេចក្ដីថា កាល ដែលឯងផុតចាករថហើយ មិនរត់ចូលព្រៃ ក្នុងពេលដែលផុតហើយមិនរត់ ទៅ ជាសត្វល្ងង់មួយបែបទៀត ។ បទថា **សោ ច ពាលតរោ** បានដល់ ព្រះបាទសេនកៈដែលឯងអូសទៅនោះល្ងង់ជាងឯងទៅទៀត ។

ព្រះរាជាទ្រង់យល់ពាក្យរបស់សត្វទាំង ២ នោះ ព្រោះហេតុនោះ កាល ទ្រង់ស្ដាប់ពាក្យនោះ ទើបទ្រង់ឲ្យបររថទៅយឺតៗ ឯសេះសិន្ធព បានស្ដាប់

ពាក្យពពែហើយ បានពោលគាថាទី ៤ ថា

ម្នាលសម្លាញ់ បើខ្ញុំជាសត្វពាលដោយហេតុណា ម្នាលអជរាជអ្នកចូរដឹងនូវហេតុនោះចុះ តែថាស្តេចសេនកៈ ជាមនុស្សពាលដោយហេតុដូចម្តេច អ្នកដែលខ្ញុំសួរហើយចូរប្រាប់ហេតុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ** ជាបឋមាវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។ បទថា **នុ** ជានិបាត ប្រើក្នុងអត្ថថា ស្តាប់មក ។ មានពាក្យអធិប្បាយទុកថា នែអជរាជសម្លាញ់ ជាបឋម ខ្ញុំល្ងង់ ព្រោះភាពជាសត្វតិរច្ឆានណា ឯងដឹងហេតុនោះ សេចក្តីនេះឯងអាចដឹងបាន ព្រោះថា ខ្ញុំជាសត្វល្ងង់ខ្លៅ ព្រោះជាសត្វតិរច្ឆាននោះឯង ព្រោះហេតុនោះ ឯងពោលថា កូនលា ( ខុរបុត្ត ) ជាដើម ក៏ឈ្មោះថា ពោលត្រឹមត្រូវ តែព្រះបាទសេនកៈនេះល្ងង់ព្រោះហេតុអ្វី ឯងត្រូវខ្ញុំសួរហើយ ចូរប្រាប់សេចក្តីនោះដល់ខ្ញុំចុះ ។

ពពែកាលប្រាប់ហេតុនោះ ទើបពោលគាថាទី ៥ ថា

បុគ្គលណាបាននូវមន្ត ជាប្រយោជន៍ដ៏ឧត្តមហើយ ប្រគល់ឲ្យប្រពន្ធ ( បុគ្គលនោះ ) នឹងលះបង់នូវខ្លួនដោយការឲ្យមន្តនោះ ទាំងប្រពន្ធនោះនឹងមិនមានដល់បុគ្គលនោះឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧត្តមត្ថំ** បានដល់ មន្តជាហេតុដឹងនូវសំឡេងរបស់សត្វគ្រប់ប្រភេទ ។ បទថា **តេន** សេចក្តីថា ព្រោះហេតុ ពោលគឺការឲ្យមន្តដល់កិរិយានោះ កាលឲ្យមន្តនោះហើយ ក៏ត្រូវលះបង់ខ្លួន លោតចូល

គំនរភ្លើង បុរសនោះនឹងមិនមានកិរិយានោះឡើយ ព្រោះហេតុនោះ បុរសនោះ គឺព្រះបាទសេនកៈ ដែលមិនអាចរក្សាយសដែលបានហើយទុកបាន ទើបជាបុគ្គលល្ងង់ជាងឯង ដូច្នេះ ។

ព្រះរាជាកាលទ្រង់ស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា នែអជរាជ ឯងកាលធ្វើសួស្តីដល់អញ នឹងធ្វើវត្ថុនោះជាបឋម ចូរឯងប្រាប់វត្ថុដែលគួរធ្វើដល់អញ ។ គ្រានោះ ទើបអជរាជទូលនឹងព្រះរាជានោះថា បពិត្រមហារាជ មិនមានអ្នកដទៃដែលឈ្មោះថា ជាទីស្រឡាញ់របស់សត្វទាំងឡាយដទៃ ក្រៃលែងជាងខ្លួន បុគ្គលមិនគួរឲ្យខ្លួនវិនាស មិនគួរលះបោលនូវយសដែលបានហើយព្រោះអាស្រ័យរបស់ជាទីស្រឡាញ់តែម្យ៉ាង ដូច្នេះហើយ បានពោលគាថាទី ៦ ថា

> បពិត្រព្រះអង្គជាធំជាងជន បុគ្គលបែបនោះ លះបង់បោលនូវខ្លួន មិនសេពគប់នូវវត្ថុជាទីស្រឡាញ់ ដោយគិតថា ( វត្ថុនេះ ) ជាទីស្រឡាញ់របស់អញ ខ្លួនឯង តើប្រសើរជាងរបស់ដែលប្រសើរទៅទៀត ព្រោះបុរសដែលមានខ្លួនអប់រំហើយ គប្បីបាននូវជនជាទីស្រឡាញ់ក្នុងកាលជាខាងក្រោយ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះថា បទថា **បិយម្មេ** កាត់បទជា **បិយំ មេ** គឺជាទីស្រឡាញ់របស់ខ្ញុំ បាឋៈយ៉ាងនេះក៏មាន មានពាក្យអធិប្បាយថា បពិត្រព្រះអង្គជាធំជាងជន បុគ្គលដែលតាំងនៅក្នុងភាពជាធំដូចព្រះអង្គ ដកនូវអាល័យក្នុងខ្លួន គឺបោះបង់ខ្លួន ដោយគិតថា វត្ថុនេះជាទីស្រឡាញ់របស់

អញ ព្រោះអាស្រ័យស្រីដែលជាកណ្ហៈ ជាទីស្រឡាញ់ម្នាក់ រមែងមិនជួប របស់ស្រឡាញ់ទាំងនោះឡើយ ព្រោះហេតុអ្វី ព្រោះខ្លួនឯងប្រសើរជាងបុគ្គល ដែលប្រសើរដ៏កំពូល អធិប្បាយថា ព្រោះហេតុដែលខ្លួនឯងប្រសើរគឺប្រសើរ លើស បានដល់ ឧត្តមជាងវត្ថុដែលប្រសើរយ៉ាងក្រៃលែង គឺជាកណ្ហៈជាទី ស្រឡាញ់ជាងរបស់ដទៃ គឺកំពូលឧត្តម ដោយការគុណនឹង ១០០ គុណនឹង ១០០០ ។ ពិតហើយ **វ** អក្ខរៈ ក្នុងបទថា **បរមាវ** នេះ គប្បីឃើញថា ត្រឹមតែជានិបាត ប្រើក្នុងអត្ថថាហេតុ ។ បទថា **លទ្ធា បិយា ឱចិតត្ថេន បច្ឆា** សេចក្តីថា ព្រោះធម្មតាបុរសដែលមានប្រយោជន៍សន្សំទុកហើយ គឺ មានប្រយោជន៍ ចម្រើនហើយ អាចបានស្រីដែលស្រឡាញ់ ក្នុងកាលជា ក្រោយ បុគ្គលមិនគួរឲ្យខ្លួនវិនាសទៅ ព្រោះហេតុនៃស្រីជាទីស្រឡាញ់នោះ ដូច្នេះ ។

ព្រះមហាសត្វបានថ្វាយឱវាទដល់ព្រះរាជា ដោយប្រការដូច្នេះ ។ ព្រះ រាជាទ្រង់ពេញព្រះហឫទ័យ ហើយត្រាស់សួរថា ម្នាលអជរាជ ឯងមកអំពី ណា សក្កទេវរាជឆ្លើយថា បពិត្រមហារាជ យើងគឺសក្កទេវរាជ មកដោយ អនុគ្រោះទ្រង់ ដើម្បីដោះទ្រង់ឲ្យផុតអំពីសេចក្តីស្លាប់ ព្រះរាជាត្រាស់ថា បពិត្រ ទេវរាជ ខ្ញុំបានលាន់វាចាចេញទៅហើយថា ខ្ញុំនឹងឲ្យមន្តដល់ព្រះទេវី ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច សក្កទេវរាជពោលថា បពិត្រមហារាជ ភាវកិច្ច ដោយសេចក្តីវិនាសមិនមានដល់អ្នកទាំង ២ បើអ្នកពោលថា ឧបចារៈនៃ សិប្បៈមាន ហើយឲ្យមនុស្សវាយព្រះទេវី ២-៣ ដង ដោយឧបាយនេះ នាង

នឹងមិនរៀន ។ ព្រះរាជាទ្រង់ទទួលទេវតម្រាស់ថា សាធុ ។ ព្រះមហាសត្វថ្វាយ ឱវាទដល់ព្រះរាជាហើយ បានយាងទៅកាន់លំនៅរបស់ទ្រង់នោះឯង ។ ព្រះរាជាយាងទៅដល់ព្រះរាជឧទ្យានហើយ ត្រាស់ឲ្យហៅព្រះទេវីមក សួរថា នែនាង នាងនឹងរៀនមន្តឬ ព្រះនាងទូលថា ព្រះមេខ្ញុំម្ចាស់ ព្រះរាជាត្រាស់ថា បើដូច្នោះ យើងនឹងធ្វើឧបចារៈនៃសិប្បៈ ព្រះទេវីទូលថា ឧបចារៈនោះដូចម្តេច ព្រះរាជាត្រាស់ថា មន្តនេះ មុននឹងរៀនត្រូវវាយ ១០០ ដង ហើយមិនត្រូវស្រែកយំ ។ ព្រះនាងទទួលព្រះរាជតម្រាស់ថា សាធុ ព្រោះចង់បានមន្ត ។ ព្រះរាជាត្រាស់ឲ្យហៅអ្នកសម្លាប់ចោរ ឲ្យយកផ្តៅមកវាយទាំងសងខាង ។ ព្រះនាងទ្រង់អត់ធន់នឹងការវាយ ២-៣ ដងបាន បន្ទាប់អំពីនោះទៅក៏ស្រែកថា ខ្ញុំម្ចាស់លែងត្រូវការមន្តហើយ ។ កាលនោះ ព្រះរាជាត្រាស់នឹងព្រះនាងថា នាងបំណងរៀនមន្តដោយឲ្យអញស្លាប់ ហើយទ្រង់ឲ្យបកស្បែកខ្នងហើយលែងទៅ ។ ចាប់តាំងពីនោះ ព្រះនាងលែងហ៊ានក្រាបទូលទៀត ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុអ្នកអផ្សុកបានតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាភិក្ខុអផ្សុកក្នុងកាលឥឡូវនេះ ព្រះរាជទេវីក្នុងកាលនោះ បានមកជាភរិយាចាស់នៃភិក្ខុនោះ សេះក្នុងកាលនោះ បានមកជាសារីបុត្ត ឯសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ខុរប្បុត្តជាតក ចប់

# សុចិជាតក

[ ២១០ ] ( កុមារបុត្តពោធិសត្វពោលថា ) នរណាចង់ទិញម្សុល ( របស់ខ្ញុំ ) ជាម្សុលមិនគ្រោតគ្រាត មិនអាក្រក់ ដែលសំលៀងដោយថ្ម មានច្បោះដ៏ល្អ មានចុងដ៏ស្រួចច្នារ ។

[ ២១១ ] នរណាចង់ទិញម្សុល ជាម្សុលដែលដុសខាត់ល្អ មានច្បោះល្អ ដែលប្រព្រឹត្តទៅដោយល្អតាមលំដាប់ ( វៀវតូច ) ចាក់ទម្លុះនូវរបស់ក្រាស់បាន ។

[ ២១២ ] ( នាងកុមារីពោលថា ) ម្សុលនិងសន្ទូចតែងចេញអំពីស្រុកនេះ ក្នុងកាលឥឡូវនេះ ចុះបុរសនេះជាអ្វី ចង់លក់ម្សុលក្នុងស្រុករបស់ជាង ។

[ ២១៣ ] គ្រឿងសស្ត្រានិងការងារផ្សេងៗជាច្រើន តែងចេញទៅអំពីស្រុកនេះ ចុះបុរសនេះជាអ្វី ក៏មកលក់ម្សុលក្នុងស្រុកជាងលោហៈ ។

[ ២១៤ ] ( ពោធិសត្វពោលថា ) ជនអ្នកចេះដឹង ត្រូវលក់ម្សុល ក្នុងស្រុកជាងលោហៈ អាចារ្យទាំងឡាយរមែងដឹងច្បាស់នូវការងារ ដែលគេធ្វើល្អនិងអាក្រក់ ។

[ ២១៥ ] ម្នាលនាង បើបិតារបស់នាងស្គាល់នូវម្សុលដែលខ្ញុំធ្វើហើយនេះ គាត់នឹងអញ្ជើញ ( ផ្សំផ្គុំ ) ខ្ញុំជាមួយនាង ព្រមទាំងទ្រព្យដទៃដែលមាននៅក្នុងផ្ទះ ។

**ចប់ សុចិជាតកទី ២ ។**

# អដ្ឋកថា

# សុបិជាតក

[ ២១០-១១៥ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមី ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **អកក្ខសំ** ដូច្នេះ ជាដើម ។

រឿងមានច្បាស់ក្នុងមហាឧម្មគ្គជាតក ។

ក្នុងកាលនោះ ព្រះសាស្ដា ត្រាស់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនចំពោះតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ជាអ្នកមានបញ្ញា ជាអ្នកឈ្លាសក្នុងឧបាយនោះឯង ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលជាងដែកក្នុងដែនកាសី ធំចម្រើនវ័យហើយបានជាអ្នកសម្រេចក្នុងសិប្បៈ ។ តែមាតាបិតារបស់លោកជាអ្នកក្រីក្រ ។ ក្នុងទីមិនឆ្ងាយអំពីស្រុករបស់មាតាបិតារបស់លោកនោះ មានស្រុកជាងដែកដទៃដែលមានផ្ទះ ១០០០ ខ្នង ផ្ទះជាងដែកដែលជាប្រធាននៃជាងដែក ១០០០ គ្រួសារក្នុងស្រុកនោះ ជារាជវល្លភ ដែលស្ដុកស្ដម្ភដោយទ្រព្យច្រើន គាត់មានកូនស្រីម្នាក់ មានរូបល្អលើសលុប ប្រៀបដូចស្រីសួគ៌ ប្រកបដោយលក្ខណៈនៃជនបទកល្យាណី ។ ជនទាំងឡាយក្នុងស្រុកដោយជុំវិញ នាំគ្នាមកដល់ស្រុកនោះ ដើម្បីទិញកាំបិត ពូថៅ និងសូផាលក្អួរស្រែដោយច្រើន ក៏ឃើញនារីនោះ ពួកគេត្រឡប់ទៅផ្ទះរៀងៗខ្លួន ហើយសរសើររូបឆោមលោមពណ៌របស់នាងក្នុងទីអង្គុយ និងទីឈរជាដើម ព្រះពោធិសត្វបានឮពាក្យសរ

សើរនោះហើយជាប់ចិត្ត ព្រោះជាប់ជំពាក់ក្នុងការបានឮ ទើបគិតថា អញនឹងយកកុមារិកានោះមកជាបាទបរិចារិកាឲ្យបាន ។ ហើយបានយកដែកដែលល្អបំផុត ធ្វើជាម្ជុលមួយដើម ចោះច្បោះហើយពន្លិចទុកក្នុងទឹក ធ្វើក្លាក់ម្ជុលនោះរាងដូចម្ជុលនោះឯង ។ ម្យ៉ាងទៀត ចោះច្បោះទុក បានធ្វើក្លាក់ម្ជុលនោះដោយទំនងនេះ ៧ ជាន់ ។ មិនគួរពោលថា ធ្វើបានដូចម្តេច ព្រោះថាហេតុការណ៍សម្រេចបាន ព្រោះព្រះពោធិសត្វមានបញ្ញាច្រើន ។ ព្រះពោធិសត្វនោះ ស៊កម្ជុលនោះដាក់ក្នុងជន្ទាប់ ទុកក្នុងថង់ ហើយទៅកាន់ស្រុកនោះសួរដល់ផ្លូវដែលជាលំនៅរបស់ប្រធានជាងដែក ទៅដល់ទីនោះហើយ ឈរត្រង់ទ្វារពោលថា អ្នកណាត្រូវការទិញម្ជុល ដែលមានរូបរាងយ៉ាងនេះ អំពីដៃរបស់ខ្ញុំដោយតម្លៃ ដូច្នេះ ។ កាលពណ៌នាដល់ម្ជុល ទើបបានឈរក្បែរទ្វារផ្ទះប្រធានជាងដែក ហើយពោលគាថាទី ១ ថា

នរណាចង់ទិញម្ជុល ( របស់ខ្ញុំ ) ជាម្ជុលមិនគ្រោតគ្រាត
មិនអាក្រក់ ដែលសំលៀងដោយថ្ម មានច្បោះដ៏ល្អ មានចុង
ដ៏ស្រួចឆ្មារ ដូច្នេះ ។

គាថានោះមានអត្ថថា អ្នកណាត្រូវការទិញម្ជុលរបស់ខ្ញុំ ដែលឈ្មោះថា **អកក្កសំ** ព្រោះមិនមានពក មិនផត ឬស្នាមប្រេះ ។

ឈ្មោះថា **អផរុសំ** ព្រោះរលោង ។ ឈ្មោះថា **ខរធោតំ** ព្រោះខាត់ហើយដោយរបស់រឹង គឺរបស់ដែលខ្ទឹម បានដល់ថ្ម ។ ឈ្មោះថា **សុបាសិ-យំ** ព្រោះប្រកបដោយច្បោះ គឺរន្ធល្អប្រពៃ គឺបរិសុទ្ធិល្អ ។ ឈ្មោះថា

**សុខុមំ** ព្រោះល្អិត ឈ្មោះថា **តិក្ខិណគ្គំ** ព្រោះមុតត្រង់ចុង ។ អ្នកណាត្រូវការទិញម្ជុលអំពីដៃរបស់ខ្ញុំ ដោយឲ្យតម្លៃ ។

កាលពោលយ៉ាងនេះហើយ ដើម្បីពណ៌នាដល់ម្ជុលនោះទៀតទើបពោលគាថាទី ២ ថា

នរណាចង់ទិញម្ជុល ជាម្ជុលដែលដុសខាត់ល្អ មានច្បោះល្អ ដែលប្រព្រឹត្តទៅដោយល្អតាមលំដាប់ ( រៀវតូច ) ចាក់ទម្លុះនូវរបស់ក្រាស់បាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុមជ្ជំ** សេចក្ដីថា ដែលខាត់ហើយដោយល្អ ដោយលម្អិតដែលបានអំពីដែនកុរុ ។ បទថា **សុបាសំ** សេចក្ដីថា ឈ្មោះថា មានច្បោះ គឺមានរន្ធល្អ ព្រោះចោះដោយដែកចោះដែលល្អិត ។ បទថា **យថានុបុព្វំ** បានដល់ ម្ជុលដែលត្រូវវាយរមែងទម្លុះចូលទៅតាមលំដាប់នេះហៅថា **យថានុបុព្វំ** អធិប្បាយថា មានសភាពយ៉ាងនោះ ។ បទថា **បដិត្ថទ្ធំ** បានដល់ រឹង គឺមិនទន់ ។ ខណៈនោះ កុមារិកានោះកំពុងបក់បិតាដោយផ្ចិតដែលទទួលទានអាហារព្រឹកហើយ ដេកលើគ្រែតូច ដើម្បីរម្ងាប់ការមិនសប្បាយ បានឮសំឡេងដ៏ពីរោះរបស់ព្រះពោធិសត្វ ដូចយកដុំសាច់ស្រស់ពាសត្រង់បេះដូង និងដូចត្រូវរំលត់នូវកម្ដៅដោយទឹក ១០០០ ក្អម កើតសេចក្ដីសង្ស័យថា នុ៎ះនរណាហ្ន៎ ប្រកាសលក់ម្ជុលត្រង់ស្រុកដែលជាលំនៅរបស់ជាងដែក ដោយសំឡេងដ៏ពីរោះពន់ពេក បុរសនេះមកដោយកិច្ចអ្វីអញនឹងស្គាល់បុរសនេះ ហើយដាក់ផ្ចិតចុះ ចេញអំពីផ្ទះ ទៅឈរត្រង់ជ្រុងខាង

ក្រៅ ចរបាជាមួយព្រះពោធិសត្វនោះ ។ តាមធម្មតា សេចក្ដីប្រាថ្នារមែងសម្រេចដល់ព្រះពោធិសត្វទាំងឡាយ ។ ព្រោះថា លោកមកស្រុកនោះ ក៏ដើម្បីកញ្ញានោះឯង ។ ស្រីនោះកាលនិយាយនឹងព្រះពោធិសត្វនោះ ទើបពោលថា នៃមាណព អ្នកដែនទូទៅ មកកាន់ស្រុកនេះ ដើម្បីត្រូវការម្ជុលជាដើម តែអ្នកមកដើម្បីលក់ម្ជុលក្នុងស្រុកជាងដែក ព្រោះភាពល្ងង់ ទោះបីអ្នកពោលសរសើរម្ជុលអស់មួយថ្ងៃសោត ក៏មិនមាននរណាទទួលយកម្ជុលនោះអំពីដៃរបស់អ្នក បើអ្នកចង់បានប្រាក់សោត ក៏ចូរទៅស្រុកដទៃ ហើយបានពោលគាថា ២ ថា

ម្ជុលនិងសន្ទូច តែងចេញអំពីស្រុកនេះ ក្នុងកាលឥឡូវនេះ
ចុះបុរសនេះជាអ្វី ចង់លក់ម្ជុលក្នុងស្រុករបស់ជាង ។
គ្រឿងសស្ត្រានិងការងារផ្សេង ៗ ជាច្រើន តែងចេញទៅអំពី
ស្រុកនេះ ចុះបុរសនេះជាអ្វីក៏មកលក់ម្ជុលក្នុងស្រុកជាងលោហៈ ។

បណ្ដាបទទាំងនោះ បទថា **ឥតោ ធានិ** សេចក្ដីថា ម្ជុល សន្ទូច និងគ្រឿងឧបករណ៍ដទៃ ៗ ក្នុងរដ្ឋនេះក្នុងខណៈនេះ ចេញទៅអំពីស្រុកជាងដែកនេះ ។ បទថា **បតាយន្តិ** បានដល់ ចេញទៅ គឺចែកចាយទៅ អស់ថ្ងៃនោះ ៗ ។ បទថា **កោយំ** សេចក្ដីថា កាលបើដូច្នេះ អ្នកណាត្រូវការលក់ម្ជុលត្រង់ស្រុកជាងដែកនេះ ។ បទថា **សត្ថានិ** បានដល់ សស្ត្រាច្រើនប្រភេទដែលមកកាន់នគរពារាណសី ក៏ទៅអំពីស្រុកនេះឯង ។ បទថា **វិវិធានិ** **បុថុ** សេចក្ដីថា ការងារច្រើនប្រការ សន្ទឹកសន្ទាប់ ប្រព្រឹត្តទៅដោយគ្រឿង

ឧបករណ៍ទាំងឡាយ ដែលនៅក្នុងរដ្ឋទាំងមូល យកអំពីស្រុកនេះឯង ។

ព្រះពោធិសត្វ បានឮពាក្យរបស់នាងហើយ ទើបពោលថា នែនាង នាងមិនដឹង ព្រោះមិនដឹងទើបពោលយ៉ាងនេះ ហើយពោលគាថា ២ ថា

ជនអ្នកចេះដឹង ត្រូវលក់ម្ជុលក្នុងស្រុកជាងលោហៈ អាចារ្យ
ទាំងឡាយរមែងដឹងច្បាស់នូវការងារដែលគេធ្វើល្អនិងអាក្រក់ ។

ម្នាលនាង បើបិតារបស់នាងស្គាល់នូវម្ជុលដែលខ្ញុំធ្វើហើយ
នេះ គាត់នឹងអញ្ជើញ ( ផ្សំផ្គុំ ) ខ្ញុំជាមួយនាង ព្រមទាំងទ្រព្យ
ដទៃដែលមាននៅក្នុងផ្ទះ ដូច្នេះ ។

សព្ទថា **សូចឹ** ក្នុងគាថានោះ លោកធ្វើវិភត្តិវិបល្លាស គឺពោលបឋមាវិភត្តិជាទុតិយាវិភត្តិ មានពាក្យអធិប្បាយថា ឈ្មោះថាម្ជុល ត្រូវតែជាបុគ្គលឈ្លាស គឺជាបណ្ឌិត ទើបនឹងលក់ក្នុងស្រុកជាងដែកបាននោះឯង ។ ព្រោះហេតុអ្វី ព្រោះអាចារ្យដែលជាមេជាងទាំងឡាយ ទើបយល់ការងារនោះថាធ្វើល្អឬមិនល្អ ។ បទថា **អាចរិយា បជានន្តិ កម្មំ សុកតទុក្កដំ** សេចក្តីថា អាចារ្យដែលជាជាងសិប្បៈប្រភេទនោះ ទើបដឹងការងារដែលធ្វើល្អ ឬមិនល្អក្នុងសិប្បៈប្រភេទនោះៗ បើខ្ញុំទៅស្រុកគហបតីទាំងឡាយ បុគ្គលមិនដឹងការងាររបស់ជាងដែក នឹងឲ្យគេដឹងបានដូចម្តេចថា ខ្ញុំធ្វើម្ជុលល្អ ឬមិនល្អ តែក្នុងស្រុកនេះ ខ្ញុំនឹងឲ្យជាងទាំងឡាយដឹងកម្លាំងរបស់ខ្ញុំ ។ ព្រះពោធិសត្វពណ៌នាកម្លាំងរបស់ខ្លួន ដោយគាថានេះយ៉ាងនេះ ។ បទថា **តយា ច មំ និមន្តេយ្យ** សេចក្តីថា នែនាង បើបិតារបស់នាងគប្បីដឹងម្ជុលនេះ ដែលខ្ញុំ

ធ្វើនេះថា ម្ជុលប្រភេទនេះ ឬដើមនេះ ប្រាកដយ៉ាងនេះហើយសោត គាត់គង់អញ្ជើញខ្ញុំដោយខ្លួនឯងយ៉ាងនេះថា ខ្ញុំនឹងឲ្យធីតានេះ ជាបាទបរិចារិការបស់អ្នក ចូរអ្នកទទួលយកនាងផងដូច្នេះ ។ បទថា **យញ្ចត្ថញ្ចាំ យរេ ធនំ** សេចក្តីថា ទ្រព្យដទៃឯណាមិនមានវិញ្ញាណក្តី មានក្នុងផ្ទះ បិតារបស់នាង គង់អញ្ជើញខ្ញុំដោយទ្រព្យនោះផង ។ បាឋៈថា **យញ្ចស្សញ្ញាំ** ដូច្នេះក៏មាន សេចក្តីថា ទ្រព្យដទៃក្នុងផ្ទះរបស់បុគ្គលនោះមាន ។

ប្រធានរបស់ជាងដែក បានឮពាក្យរបស់ជនទាំង ២ នោះហើយ ទើបហៅធីតាថា នែនាង នាងចរចាជាមួយនរណា នាងឆ្លើយថា បពិត្រលោកឪពុក ខ្ញុំចរចាជាមួយបុរសម្នាក់ដែលលក់ម្ជុល ។ ឪពុកពោលថា ចូរនាងហៅបុរសនោះមក ទើបនាងហៅមក ។ ព្រះពោធិសត្វនោះ ចូលទៅខាងក្នុងផ្ទះសំពះប្រធានជាងដែកហើយឈរ ។ លំដាប់នោះ ទើបជាងដែកនោះសួរថា នែបា បាជាអ្នកស្រុកណា ព្រះពោធិសត្វឆ្លើយថា ខ្ញុំជាអ្នកស្រុកនោះ ជាកូនរបស់ជាងដែកឈ្មោះនោះ បុរសនោះពោលថា ហេតុអ្វី ទើបអ្នកមកទីនេះ ព្រះពោធិសត្វពោលថា ខ្ញុំមកដើម្បីលក់ម្ជុល បុរសនោះពោលថា យើងសូមមើលម្ជុលរបស់អ្នក ។

ព្រះពោធិសត្វត្រូវការប្រកាសគុណរបស់ខ្លួន ក្នុងកណ្តាលជាងទាំងនោះ ទើបសួរថា ការមើលក្នុងចំណោមជាងទាំងអស់ ល្អជាងមើលម្នាក់ឯង មិនមែនឬ ប្រធានជាងដែកឆ្លើយថា សាធុ ទើបឲ្យហៅជាងដែកទាំងអស់មកប្រជុំគ្នា មានជាងទាំងនោះចោមរោមហើយ ទើបពោលថា ចូរអ្នកយកចេញមក

ចុះ ពួកខ្ញុំនឹងមើលម្ជុលរបស់អ្នក ។ ព្រះពោធិសត្វសំណូមពរថា សូមលោក អាចារ្យនាំកំណល់ដែកមកមួយ និងថាសសំរឹទ្ធិ ដែលមានទឹកពេញមកមួយ ទើបឲ្យមនុស្សនាំមកឲ្យ ព្រះពោធិសត្វនាំដន្ទាប់ចេញពីថ្នក់ ហើយប្រគល់ឲ្យ ទៅ ។ ប្រធានជាងដែក នាំម្ជុលចេញអំពីដន្ទាប់នោះហើយ សួរថា នែបា នេះឬម្ជុល ព្រះពោធិសត្វឆ្លើយថា នេះមិនមែនម្ជុល នេះជាក្លាក់ម្ជុល ។ បុរស នោះពិចារណាមើលហើយ មិនឃើញគល់ មិនឃើញចុងម្ជុលឡើយ ។ ទើប ព្រះពោធិសត្វនាំមក ហើយយកក្រចកគ្កឹះក្លាក់ចេញ បង្ហាញមហាជនឲ្យឃើញ ថា នេះម្ជុល នេះក្លាក់ម្ជុល ហើយដាក់ម្ជុលត្រង់ដៃរបស់អាចារ្យ ដាក់ក្លាក់ ក្បែរជើងអាចារ្យ ។ ត្រូវអាចារ្យនោះសួរថា នេះជាម្ជុលឬ ព្រះពោធិសត្វឆ្លើយ ថា នេះមិនមែនម្ជុល នេះជាក្លាក់ម្ជុលដូចគ្នា ហើយយកក្រចកគ្កឹះចេញ ដាក់ ក្លាក់ម្ជុល ៦ ក្លាក់ទុកទៀបជើងជាងដែក តាមលំដាប់ហើយ ទើបដាក់ម្ជុល លើដៃ ដោយប្រាប់ថា នេះម្ជុល ។ ជាងដែក ១០០០ ផ្ទាត់ម្រាមដៃនិងទះ ដៃ ការលើកសំពត់ប្រព្រឹត្តទៅហើយ គឺគ្រវីសំពត់ ។ លំដាប់នោះ ទើប ប្រធានជាងដែកសួរព្រះពោធិសត្វថា ម្ជុលនេះមានកម្លាំងដូចម្តេច ព្រះពោធិ សត្វពោលថា បពិត្រលោកអាចារ្យ សូមលោកឲ្យបុរសមានកម្លាំង លើក កំណល់ដែកឡើងដាក់លើថាសទឹក ហើយដាក់ថាសទឹកទុកពីក្រោមកំណល់ ដែក ហើយដំម្ជុលនេះត្រង់កណ្តាលកំណល់ដែកចុះ បុរសនោះឲ្យធ្វើយ៉ាងនោះ ហើយ ដំចុងម្ជុលចោះត្រង់កណ្តាលកំណល់ដែក ម្ជុលនោះធ្លុះកំណល់ដែកទៅ ទៅតម្កល់នៅលើផ្ទៃទឹក មិនខ្ពស់មិនទាប ( មិនល្អៀង ) សូម្បីប៉ុនចម្រៀក

សក់ ជាងដែកទាំងអស់ ពោលថា អស់រយៈកាលប៉ុណ្ណេះ ពួកយើងមិនធ្លាប់បានឮ មិនធ្លាប់បានស្តាប់ថា ឈ្មោះថាជាងដែកទាំងឡាយបែបនេះមានហើយនាំគ្នាទះដៃគ្រវីសំពត់ឡើងរាប់ពាន់ ។ ប្រធានជាងដែក ហៅធីតាមកប្រកាសកណ្តាលបរិស័ទថា កុមារិកានេះសមគួរដល់បុរសនេះប៉ុណ្ណោះ ហើយបានប្រួចទឹកលើដៃប្រគល់ឲ្យ ។ ក្នុងកាលតមក ព្រះពោធិសត្វនោះ បានជាប្រធានជាងដែកក្នុងស្រុកនោះ ក្នុងកាលដែលប្រធានជាងដែក អនិច្ចកម្មទៅហើយ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតកថា ធីតារបស់ប្រធានជាងដែកក្នុងកាលនោះ បានជារាហុលមាតាក្នុងកាលឥឡូវនេះ បុត្តជាងដែកដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុចិជាតក ចប់

# តុណ្ឌិលជាតក

[ ២១៦ ] ( ចូឡតុណ្ឌិលសុករៈពោលថា ) ម្ចាស់យើងធ្លាប់ឲ្យ ( បបរកុណ្ឌកនិងបាយក្តាំង ) ឥឡូវនេះគាត់ឲ្យបន្លែស្រស់វិញ ស្នូកនេះពេញ ( ដោយបាយសស្អាត ) ស្ត្រីជាម្ចាស់យើង ក៏ឈរនៅ ( ជិតស្នូកនោះដែរ ) អ្នកផងច្រើនគ្នា មានដៃកាន់អន្ទាក់ ខ្ញុំមិនចង់ស៊ីទេ ។

[ ២១៧ ] ( មហាតុណ្ឌិលៈពោលថា ) អ្នកតក់ស្លុតស្ទន់ស្ទោ ប្រាថ្នារកទីពឹងពួន អ្នកឥតទីពឹងទេ អ្នកនឹងទៅក្នុងទីណា ម្នាលតុណ្ឌិលៈ អ្នកចូរមានសេចក្តីខ្វល់ខ្វាយបរិភោគចុះ យើងដែលគេចិញ្ចឹម ដើម្បីប្រយោជន៍តែសាច់ ( ប៉ុណ្ណោះ ) ។

[ ២១៨ ] ( បើអ្នកខ្លាចសេចក្តីស្លាប់ ) អ្នកចូរចុះទៅកាន់ស្រះ ដែលមិនមានកក់ អ្នកចូរជម្រះនូវញើសនិងក្អែលទាំងអស់ចេញ ក្លិននៃគ្រឿងលាបណា មិនដាច់ក្នុងកាលណាមួយ អ្នកចូរកាន់យកនូវគ្រឿងលាបដ៏ថ្មីនោះចុះ ។

[ ២១៩ ] ( ចូឡតុណ្ឌិលៈសួរថា ) ស្រះមិនមានកក់តើដូចម្តេច អ្វីហ្ន៎ដែលលោកហៅថាញើសនិងក្អែល មួយទៀតគ្រឿងលាបដ៏ថ្មីតើដូចម្តេច ទាំងក្លិនរបស់វា ក៏មិនដាច់ក្នុងកាលណាមួយ ។

[ ២២០ ] ( មហាតុណ្ឌិលៈឆ្លើយថា ) ធម៌ទុកជាស្រះមិនមានកក់ បាបលោកពោលថាញើសនិងក្អែល សីលទុកជាគ្រឿងលាបដ៏ថ្មី ទាំងក្លិនរបស់សីលនោះ មិនដាច់ក្នុងកាលណាម្តង ។

[ ២២១ ] ពួកជនអ្នកសម្លាប់នូវសរីរៈ ( នៃសត្វទាំងឡាយ ) រមែងត្រេកអរ ចំណែកខាងពួកសត្វអ្នកទ្រទ្រង់នូវសរីរៈ រមែងមិនត្រេកអរឡើយ

ពួកសត្វទាំងឡាយ ( ប្រាកដដូចជាយើង ) រមែងត្រេកអរលះបង់នូវជីវិតក្នុងខែពេញ មានព្រះចន្ទពេញវង់ ។

**ចប់ តុណ្ឌិលជាតកទី ៣ ។**

# អដ្ឋកថា

# តុណ្ឌិលជាតក

[ ២១៦-២២១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុខាចស្លាប់មួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **នវច្ឆន្ទកេ** ដូច្នេះជាដើម ។

បានឮថា កុលបុត្តអ្នកក្រុងសាវត្ថីនោះ បួសក្នុងព្រះសាសនា តែបានជាអ្នកខាចស្លាប់ ។ លោកបានឮសំឡេងមែកឈើធ្លាក់ ក៏មានខ្លួនញាប់ញ័រចំប្រប់ ឬស្នូរជើងសត្វត្រឹមតែតូចតាច គឺស្រោលៗ ឬសំឡេងដទៃបែបនោះក៏ជាអ្នកត្រូវភ័យ គឺសេចក្តីស្លាប់គ្របសង្កត់ មានខ្លួនញ័រចំប្រប់ដើរទៅ ដូចទន្សាយត្រូវចាក់ត្រង់ពោះ ដូច្នោះ ។ ភិក្ខុទាំងឡាយនាំគ្នាតាំងកថា ក្នុងធម្មសភាថា នែអាវុសោ ភិក្ខុឈ្មោះនោះខាចស្លាប់ បានឮសំឡេង ត្រឹមតែតិចតួចក៏ស្រែក ស្ទុះគេចទៅ លោកគួរមនសិការថា សេចក្តីស្លាប់របស់សត្វទាំងឡាយប៉ុណ្ណោះជារបស់ទៀង តែជីវិតមិនទៀង ដូច្នេះ ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយ

សន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ទើបត្រាស់ឲ្យហៅភិក្ខុនោះមក ទ្រង់សួរថា ម្នាលភិក្ខុ បានឮថា អ្នកខ្លាចស្លាប់ពិតឬ កាលភិក្ខុនោះទូលថា ករុណាពិតព្រះអង្គដូច្នេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនចំពោះក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ខ្លាចស្លាប់ដូចគ្នា ហើយទ្រង់បាននាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតក្នុងផ្ទៃរបស់មេជ្រូក ។ មេជ្រូកគ្រប់ខែហើយ កើតបានកូន ២ ។ ថ្ងៃមួយ ជ្រូកនោះនាំកូន ២ នោះទៅដេកត្រង់រណ្តៅមួយ ។ កាលនោះ ស្រីចាស់ម្នាក់មានប្រក្រតីនៅក្បែរទ្វារនគរពារាណសី បេះកប្បាសពេញល្អីអំពីចម្ការកប្បាស កាន់ឈើច្រត់ដើរមក ។ មេជ្រូកបានឮសំឡេងនោះហើយ បោលកូនជ្រូកគេចទៅ ព្រោះខ្លាចស្លាប់ ។ ស្រីជរាឃើញកូនជ្រូក បាននូវសេចក្តីស្រឡាញ់ដូចជាកូន ទើបចាប់ដាក់ល្អីយកទៅផ្ទះ ដាក់ឈ្មោះជ្រូកបងថា មហាតុណ្ឌិល ជ្រូកប្អូនថា ចូឡតុណ្ឌិល ចិញ្ចឹមដូចកូន ។ ក្នុងកាលតមក ជ្រូកនោះក៏ធំចម្រើនឡើង មានរាងកាយធាត់ ។ ស្រីជរាត្រូវគេសួរថា ចូរលក់ជ្រូកនេះឲ្យខ្ញុំចុះ ក៏ប្រាប់ថា កូនរបស់ខ្ញុំ ហើយមិនឲ្យដល់អ្នកណា ។ ក្រោយមក ក្នុងថ្ងៃមហោស្រព ពួកអ្នកលេងសុរា កាលសាច់អស់ ក៏ប្រឹក្សាគ្នាថា ពួកយើងបានសាច់អំពីណាហ្ន៎ បានឮថា ត្រង់ផ្ទះរបស់ស្រីជរាមានជ្រូក ទើបនាំគ្នាកាន់យកស្រាទៅទីនោះ ពោល

ថា លោកយាយ សូមទទួលយកតម្លៃ ហើយឲ្យជ្រូកមួយដល់ខ្ញុំចុះ ស្រីជរា ទោះបដិសេធថា នែចៅ អ្នកកុំធ្វើយ៉ាងនេះ ជ្រូកនោះជាកូនរបស់យាយទេ ធម្មតាមនុស្សដែលឲ្យកូនដល់អ្នកដទៃ ដើម្បីស៊ីសាច់មិនមានឡើយ ។ ពួកអ្នកលេងអង្វរហើយអង្វរទៀតថា ឈ្មោះថា ជ្រូកជាកូនរបស់មនុស្សមិនមាន សូមឲ្យជ្រូកនោះដល់ខ្ញុំចុះ ក៏មិនបានជ្រូក ទើបឲ្យស្រីជរាផឹកស្រា កាលគាត់ស្រវឹងហើយ ក៏ពោលថា យាយនឹងធ្វើអ្វីដោយជ្រូក សូមយកតម្លៃនេះទុកចាយវាយចុះ ។ ហើយដាក់កហាបណៈទុកក្នុងដៃស្រីជរា ស្រីជរាទទួលយកកហាបណៈ ពោលថា នែចៅ អញមិនអាចឲ្យជ្រូកឈ្មោះមហាតុណ្ឌិលបានទេ ចូរឯងនាំគ្នាចាប់យកចូឡតុណ្ឌិលចុះ អ្នកលេងសួរថា ជ្រូកនោះនៅឯណា ដូនចាស់ឆ្លើយថា ត្រង់គុម្ពឈើនោះ អ្នកលេងពោលថា សូមយាយប្រើសំឡេងហៅជ្រូកមកចុះ ស្រីជរាឆ្លើយថា អញមិនឃើញអាហារ ទើបអ្នកលេងឲ្យថ្លៃអាហារ ទៅនាំបាយមួយថាសមក ។ ស្រីជរាទទួលយកថ្លៃអាហារនោះ រៀបចំទិញបាយចាក់ពេញស្នូកទុកក្បែរទ្វារ ហើយបានឈរនៅជិតស្នូក ។ អ្នកលេងប្រមាណ ៣០ នាក់ មានអន្ទាក់ក្នុងដៃ បានឈរក្នុងទីនោះឯង ។ ស្រីជរាបានធ្វើសំឡេងហៅជ្រូកថា ចូឡតុណ្ឌិលមកវ៉ើយ មហាតុណ្ឌិល ឮសំឡេងនោះហើយដឹងថា អស់កាលមានប្រមាណប៉ុណ្ណេះ ម៉ែយើង មិនធ្លាប់ហៅចូឡតុណ្ឌិល បន្លឺសំឡេងហៅអញមុនប៉ុណ្ណោះ ថ្ងៃនេះភ័យនឹងកើតឡើងដល់ពួកយើងពិត ។ ទើបមហាតុណ្ឌិល ហៅចូឡតុណ្ឌិលមកប្រាប់ថា នែប្អូន ម៉ែរបស់យើងហៅឯង ចូរឯងទៅឲ្យដឹងរឿងសិន ។ ចូឡតុណ្ឌិល ក៏ចេញអំពី

 ៦២៩

គុម្ពឈើ ឃើញអ្នកលេងទាំងនោះ ឈរក្បែរស្នូកបាយ ក៏ដឹងថា ថ្ងៃនេះការស្លាប់នឹងកើតឡើងដល់អញហើយ ត្រូវមរណភ័យគំរាម ទើបរត់ត្រឡប់មានខ្លួនញ័រចំប្រប់ទៅរកបងប្រុស មិនអាចឈរបាន មានខ្លួនញ័រ វិលទៅជុំវិញ ។ មហាតុណ្ឌិលឃើញហើយ ទើបសួរថា នែប្អូន ថ្ងៃនេះឯងញ័រជើង សម្លឹងមើលទីដែលចូលទៅហើយ ឯងធ្វើអ្វីនោះ ។ ចូឡតុណ្ឌិល កាលប្រាប់ហេតុដែលខ្លួនបានឃើញ ទើបពោលគាថាទី ១ ថា

ម្ចាស់យើងធ្លាប់ឲ្យ ( បបរកុណ្ឌកនិងបាយក្តាំង ) ឥឡូវនេះ
គាត់ឲ្យបន្ទែស្រស់វិញ ស្នូកនេះពេញ ( ដោយបាយស
ស្អាត ) ស្ត្រីជាម្ចាស់យើង ក៏ឈរនៅ ( ជិតស្នូកនោះដែរ )
អ្នកផងច្រើនគ្នា មានដៃកាន់អន្ទាក់ ខ្ញុំមិនចង់ស៊ីទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នវច្ឆន្នកេ ទានិ ទិយ្យតិ** សេចក្តីថា កាលមុន ម៉ែឲ្យបបរដែលផ្សំដោយកុណ្ឌក ឬបាយក្តាំងដល់ពួកយើង តែថ្ងៃនេះ ឲ្យអាហារថ្មី គឺមានអាហារថ្មី ។ បទថា **បុណ្ណាយំ ទោណិ** បានដល់ ស្នូកអាហាររបស់ពួកយើងពេញទៅដោយបាយសុទ្ធៗ ។ បទថា **សុវាមិនី ឋិតា** សេចក្តីថា ឯម៉ែរបស់ពួកយើង ក៏បានឈរក្បែរៗស្នូកអាហារនោះ ។ បទថា **ពហុកោ ជនោ** សេចក្តីថា មិនមែនតែម៉ែម្យ៉ាងប៉ុណ្ណោះទេ សូម្បីអ្នកដទៃច្រើននាក់ទៀត បានឈរ មានដៃកាន់អន្ទាក់ ។ បទថា **នោ ច ខោ មេ បដិភាតិ** សេចក្តីថា សូម្បីការៈដែលមនុស្សទាំងនេះឈរហើយយ៉ាងនេះ មិនជាក់ច្បាស់សម្រាប់ខ្ញុំ អធិប្បាយថា ខ្ញុំមិនគាប់ចិត្តនឹងស៊ីបាយនេះទេ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះហើយ ពោលថា ចូរឡុតុណ្ឌិលប្អូន បាន ឮថា ធម្មតាម៉ែរបស់យើង កាលចិញ្ចឹមជ្រូកទុកក្នុងទីនេះឯង រមែងចិញ្ចឹម ដើម្បីជាប្រយោជន៍ណា ប្រយោជន៍នោះ របស់គាត់ដល់ទីបំផុតហើយក្នុងថ្ងៃ នេះសូមប្អូនកុំគិតថ្វីឡើយ កាលនឹងសម្តែងធម៌ដោយពុទ្ធលីលា ដោយសំឡេង ដ៏ពីរោះ បានពោលគាថា ២ ថា

អ្នកតក់ស្លុតស្ទន់ស្ទោ ប្រាថ្នារកទីពឹងពួន អ្នកឥតទីពឹងទេ អ្នកនឹងទៅក្នុងទីណា ម្នាលតុណ្ឌិលៈ អ្នកចូរមានសេចក្តីខ្វល់ ខ្វាយបរិភោគចុះ យើងដែលគេចិញ្ចឹមដើម្បីប្រយោជន៍តែសាច់ ( ប៉ុណ្ណោះ ) ។

អ្នកចូរចុះទៅកាន់ស្រះ ដែលមិនមានភក់ អ្នកចូរជម្រះនូវ ញើសនិងភ្លែលទាំងអស់ចេញ ក្លិននៃគ្រឿងលាបណាមិនដាច់ ក្នុងកាលណាមួយ អ្នកចូរកាន់យកនូវគ្រឿងលាបដ៏ថ្មីនោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តសសិ ភមសិ** សេចក្តីថា តក់ស្លុតព្រោះ ខ្លាចស្លាប់ ការលំបាកដោយការតក់ស្លុត ព្រោះការខ្លាចស្លាប់នោះឯង ទើប ជ្រួកវិលក្បាល ។ បទថា **លេណមិច្ឆសិ** បានដល់ សម្លឹងមើលរកទីពឹង ។ បទថា **អតាណោសិ** សេចក្តីថា នែប្អូន កាលមុន ម្តាយរបស់យើងជាទី ពឹងទីរឭកបាន តែថ្ងៃនេះ គាត់អស់អាល័យ បោះបង់យើងហើយ ឥឡូវនេះ យើងនឹងទៅណា ។

បទថា **ឱគហ** បានដល់ សូមចុះទៅ ។ម្យ៉ាងទៀត បាឋៈថា **ឱគាហ** យ៉ាងនេះក៏មានន័យដូចគ្នា ។ បទថា **បវាហយ** បានដល់ ឲ្យញើសក្អែលទាំងអស់អណ្តែតទៅ ។ បទថា **ន ជិជ្ឈតិ** បានដល់ មិនបាត់ទៅ ។ មានអធិប្បាយថា បើឯងខ្លាចស្លាប់សោត ចូរចុះកាន់ស្រះបោក្ខរណីដែលមិនមានកក់ ជម្រះលាងញើសនិងក្អែលទាំងអស់ក្នុងខ្លួនរបស់ឯង ហើយលាបដោយគ្រឿងក្រអូបដែលក្រអូបជានិច្ច ។

កាលតុណ្ឌិលមហាសត្វនោះ រឭកដល់បារមីទាំង ១០ ហើយធ្វើមេត្តាបារមីឲ្យជាបុរេចារិក លើកបទដំបូងមកជានិទស្សនៈនោះឯង សំឡេងបានលាន់ឮ ពេញនគរពារាណសីដែលមានទំហំ ១២ យោជន៍ ។ ក្នុងខណៈដែលមនុស្សទាំងឡាយបានឮហើយ អ្នកនគរពារាណសី ចាប់តាំងពីព្រះរាជា និងឧបរាជជាដើម បាននាំគ្នាមកតាមសំឡេង ។ ចំណែកបុគ្គលមិនបានមក នៅត្រង់ផ្ទះនោះឯងក៏បានឮ ។ រាជបុរសទាំងឡាយនាំគ្នាគ្គារគុម្ពឈើ ពង្រាបផ្ទៃដីឲ្យស្មើហើយរោយខ្សាច់ ។ អ្នកឲ្យស្មុរាជល់អ្នកលេងទាំងឡាយ ក៏លែងឲ្យ ពួកអ្នកលេងនាំគ្នាបោះអន្ទាក់ចោល ហើយឈរស្តាប់ធម៌ទាំងអស់ ។ ឯស្រីជរាក៏ស្វាងស្រា ។ មហាសត្វបានពោលប្រារព្ធទេសនាដល់ចូឡតុណ្ឌិលនៅកណ្តាលមហាជន ។

ចូឡតុណ្ឌិលបានស្តាប់ពាក្យនោះហើយគិតថា បងប្រុសរបស់អញពោលយ៉ាងនេះ វង្សរបស់ពួកយើង មិនមានការចុះកាន់ស្រះបោក្ខរណី ហើយងូតទឹក មិនមានការជម្រះលាងញើសក្អែលចេញអំពីរាងកាយ មិនមានការនាំយក

គ្រឿងលាបចាស់ចេញទៅ ហើយយកគ្រឿងលាបថ្មីដែលមានក្លិនក្រអូបលាប ក្នុងកាលណាឡើយ បងប្រុសរបស់អញពោលយ៉ាងនេះសំដៅដល់អ្វីហ្ន៎ ដូច្នេះ ហើយកាលនឹងសួរ ទើបពោលគាថាទី ៤ ថា

ស្រះមិនមានភក់ តើដូចម្តេច អ្វីហ្ន៎ដែលលោកហៅថាញើស និងក្អែល មួយទៀតគ្រឿងលាបដ៏ថ្មីតើដូចម្តេច ទាំងក្លិនរបស់ វាក៏មិនដាច់ក្នុងកាលណាមួយ ដូច្នេះ ។

មហាសត្វបានឮពាក្យសួរនោះហើយ ទើបពោលថា បើដូច្នោះ ចូរអ្នក ផ្ទៀងសោតស្តាប់ កាលនឹងសម្តែងធម៌ដោយពុទ្ធលីលា បានពោលគាថាទាំង នេះថា

ធម៌ទុកជាស្រះមិនមានភក់ បាបលោកពោលថាញើសនិង ក្អែល សីលទុកជាគ្រឿងលាបដ៏ថ្មីទាំងក្លិនរបស់សីលនោះ មិន ដាច់ក្នុងកាលណាម្តង ។

ពួកជនអ្នកសម្លាប់នូវសរីរៈ ( នៃសត្វទាំងឡាយ ) រមែង ត្រេកអរ ចំណែកខាងពួកសត្វអ្នកទ្រទ្រង់នូវសរីរៈ រមែងមិន ត្រេកអរឡើយ ពួកសត្វទាំងឡាយ ( ប្រាកដដូចជាយើង ) រមែងត្រេកអរលះបង់នូវជីវិតក្នុងខែពេញ មានព្រះចន្ទពេញវង់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ** សេចក្តីថា ធម៌ទាំងអស់នេះគឺសីល ៥ សីល ១០ សុចរិត ៣ ពោធិបក្ខិយធម៌ ៣៧ និងអមតមហានិព្វាន ឈ្មោះ

ជាធម៌ ។ បទថា **អកក្ខរោ** សេចក្ដីថា ឈ្មោះថា មិនមានកក់ ព្រោះមិនមានកក់ គឺកិលេស បានដល់រាគៈ ទោសៈ មោហៈ មានះ និងទិដ្ឋិ ។ ដោយបទនេះ មហាតុណ្ឌិលរៀរធម៌ដ៏សេសទុក សម្ដែងព្រះនិព្វានប៉ុណ្ណោះ សមដូចព្រះសាស្ដាត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានជាសង្ខតធម៌ក្ដី អសង្ខតធម៌ក្ដី វិរាគធម៌ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ព្រោះថា វិរាគធម៌នេះ ជាធម៌សម្រាប់បន្ទោបង់នូវសេចក្ដីស្រវឹង ជាធម៌កម្ចាត់បង់នូវសេចក្ដីស្រេកឃ្លាន ជាធម៌អាចដកនូវសេចក្ដីអាល័យ ជាធម៌ផ្ដាច់បង់នូវវដ្ដៈ ជាធម៌អស់ទៅនៃតណ្ហា ជាធម៌ប្រាសចាកតម្រេក ជាធម៌រលត់ ជាធម៌មិនមានគ្រឿងចាក់ស្រេះ ដូច្នេះ ។

បានឮថា ព្រះពោធិសត្វកាលសម្ដែងព្រះនិព្វាននោះឯង ទើបពោលយ៉ាងនេះ ដោយអំណាចឧបនិស្សយប្បច្ច័យថា នែចូឡតុណ្ឌិល បងហៅស្រះគឺព្រះនិព្វានថា អន្លង់ទឹក ព្រោះក្នុងព្រះនិព្វាននោះឯង មិនមានជាតិ ជរា ព្យាធិ និងមរណទុក្ខជាដើម បើអ្នកមានបំណងនឹងផុតចាកមរណៈ ក៏ចូររៀនបដិបទាដែលឲ្យដល់នូវព្រះនិព្វាន ។ បទថា **ចាបំ សេទមលំ** សេចក្ដីថា នែចូឡតុណ្ឌិលប្អូន បណ្ឌិតក្នុងកាលមុន ហៅបាបថាជាញើស ក្អែល ព្រោះដូចគ្នានឹងញើសក្អែល ។ បាបនេះមាន ១ គឺកិលេសជាគ្រឿងប្រទូស្ដចិត្ត បាបមាន ២ យ៉ាង គឺសីលដែលថោកទាប និងទិដ្ឋិដែលថោកទាប ។ បាបមាន ៣ យ៉ាង

គឺទុច្ចរិត ៣ បាបមាន ៤ យ៉ាង គឺការលុះអំណាចអគតិ ៤ ។ បាបមាន ៥ យ៉ាង គឺចេតោខិលៈ ៥ ។ បាបមាន ៦ យ៉ាង គឺអគារវៈ ៦ ។ បាបមាន ៧ យ៉ាង គឺអសទ្ធម្ម ៧ ។ បាបមាន ៨ យ៉ាង គឺមិច្ឆត្តៈ ៨ ។ បាបមាន ៩ យ៉ាង គឺអាឃាតវត្ថុ ៩ ។ បាបមាន ១០ យ៉ាង គឺអកុសលកម្មបថ ១០ ។ បាបមានច្រើនយ៉ាង គឺអកុសលធម៌ទាំងឡាយដែលទ្រង់ចែកចេញជាធម៌ពួក ១ ពួក ២ និងពួក ៣ ជាដើមយ៉ាងនេះគឺ រាគៈ ទោសៈ មោហៈ បាបទាំងអស់នេះ បណ្ឌិតពោលថា ជាញើសក្អែល ដែលនៅក្នុងសរីរៈ ដូចពណ៌នាមកនេះ ។ បទថា **សីលំ** បានដល់ សីល ៥ សីល ១០ និងបារិសុទ្ធិសីល ៤ ។ នៃបួន បណ្ឌិតទាំងឡាយ ហៅសីលនេះថា ដូចជាគ្រឿងលាបថ្មី ៤ ប្រភេទ ។ បទថា **តស្ស** សេចក្តីថា ក្លិនរបស់សីលនោះ តាំងអំពីកាលណាមក មិនបាត់បង់ទៅក្នុងវ័យទាំង ៣ គឺផ្សាយទៅពេញលោកសន្និវាស ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី
ក្លិនខ្លឹម ក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិន
បាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅ
ច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបាន គ្រប់
ទិស ។

ក្លិននៃសីល ជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិទាំងនេះ
គឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។

ក្លិនក្រស្នានិងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណ

តិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើសលុប ផ្សាយទៅក្នុងទេវលោក និងមនុស្ស លោកបាន ដូច្នេះ[១] ។

បទថា **ឆន្ទន្តិ សរីរយាតិនោ** សេចក្តីថា ចូឡតុណ្ឌិលប្អូន មនុស្ស ដែលមិនមានប្រាជ្ញាទាំងឡាយនេះ កាលធ្វើបាណាតិបាត និងភ្លើតភ្លើន គឺពេញ ចិត្តថា ពួកយើងនឹងស៊ីសាច់ធ្លាញ់ខ្លះ និងឲ្យកូនប្រពន្ធស៊ីខ្លះ គឺមិនដឹងទោស នៃបាណាតិបាតជាដើមថា បាណាតិបាត ដែលប្រព្រឹត្តអប់រំធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីឲ្យកើត ក្នុងនរក និងប្រព្រឹត្តទៅដើម្បីឲ្យកើត ក្នុងកំណើត តិរច្ឆាន ។បេ។ និងប្រព្រឹត្តទៅដើម្បីឲ្យកើត ក្នុងបិត្តិវិស័យ វិបាកនៃបាណា តិបាតដែលស្រាលជាងវិបាកទាំងអស់ បើកើតជាមនុស្សនឹងមានអាយុខ្លីដូច្នេះ កាលមិនដឹងជាអ្នកសម្គាល់បាបថាជាទឹកឃ្មុំ តាមព្រះពុទ្ធភាសិត ( ក្នុងខុទ្ទក និកាយធម្មបទ ) ថា

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសម្គាល់នូវបាប នោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាលទើប ប្រទះនូវសេចក្តីទុក្ខក្នុងកាលណោះ ដូច្នេះ ។

មិនដឹងហេតុមានប្រមាណប៉ុណ្ណោះថា

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើ កម្មលាមកដែលជាអំពើមានផលក្តៅក្រហាយ ។

---

១-ខុទ្ទនិកាយ ធម្មបទ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថាជាកម្មមិនល្អឡើយ ដូច្នេះ ។

បទថា **ឆ ច ឆន្ទន្តិ សិរីរជារិនោ** សេចក្តីថា នែប្អូនចូឡតុណ្ឌិល សត្វទាំងនេះ ដែលរក្សាជីវិត សត្វទាំងនោះ តាំងអំពីព្រះពោធិសត្វទៅ វៀរតែរាជសីហ៍ ដំរីអាជានេយ្យ សេះអាជានេយ្យ និងព្រះខីណាស្រព កាលសេចក្តីស្លាប់មកដល់ខ្លួន ឈ្មោះថា មិនខ្លាចមិនមាន ។ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងធម្មបទ ) ថា

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា ( ព្រោះថា ) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ដូច្នេះ ។

បទថា **បុណ្ណាយ** បានដល់ ពេញវង់ ។ បទថា **បុណ្ណមាសិយា** បានដល់ កាលខែប្រកបដោយព្រះចន្ទពេញវង់ស្ថិតនៅហើយ ។ បានឮថា កាលនោះ ជាថ្ងៃឧបោសថដែលមានព្រះចន្ទពេញវង់ ។ បទថា **រមមានាវ ជហាន្តិ ជីវិតំ** សេចក្តីថា នែប្អូនតុណ្ឌិល ប្អូនកុំសោយសោក កុំយំ ឈ្មោះថា សេចក្តីស្លាប់ មិនមែនចំពោះយើងប៉ុណ្ណោះទេ សូម្បីសត្វដ៏សេសទាំងឡាយ ក៏មានសេចក្តីស្លាប់ សត្វដែលមិនមានគុណ មិនមានសីលជាដើមនៅខាងក្នុងរមែងខ្លាច តែពួកយើងសម្បូរដោយសីល និងអាចារ ជាអ្នកមានបុណ្យ គឺមិនខ្លាច

ព្រោះហេតុនោះ សត្វដូចយើងនឹងត្រេកអរលះជីវិតនោះឯង ។

មហាសត្វ សម្តែងធម៌ដោយសំឡេងដ៏ពីរោះ ដោយពុទ្ធលីលាយ៉ាងនេះហើយ មហាជនមានការទះដៃ និងការគ្រវីសំពត់រាប់សែនប្រព្រឹត្តទៅហើយ លម្ហអាកាសពេញទៅដោយសំឡេងសាធុការ ។ ព្រះបាទពារាណសី ទ្រង់បូជាព្រះពោធិសត្វដោយរាជសម្បត្តិ ប្រទានយសដល់ស្រីជរា ទ្រង់ទទួលយកជ្រូកទាំង ២ ទុក ទ្រង់ឲ្យងូតដោយទឹកក្រអូប ឲ្យដណ្តប់សំពត់ ឲ្យលាបដោយគ្រឿងប្រអប់ជាដើម ឲ្យប្រដាប់ដោយកែវមណីត្រង់ក ហើយទ្រង់នាំចូលទៅកាន់ព្រះនគរ ស្ថាបនាទុកក្នុងតំណែងរាជបុត្ត ទ្រង់ផ្គត់ផ្គង់ដោយបរិវារច្រើន ។ ព្រះពោធិសត្វបានឲ្យសីល ៥ ដល់រាជបរិវារ ។ អ្នកនគរពារាណសីនិងអ្នកកាសិករដ្ឋ នាំគ្នារក្សាសីល ៥ សីល ១០ គ្រប់គ្នា ។ ឯមហាសត្វបានសម្តែងធម៌ដល់ជនទាំងនោះរាល់បក្ខ អង្គុយក្នុងទីវិនិច្ឆ័យក្តី កាលមហាសត្វនៅមានជីវិត ឈ្មោះថា អយុត្តិធម៌មិនមានឡើយ ។ ក្នុងកាលតមកព្រះរាជា ក៏សោយទិវង្គត ។ ឯមហាសត្វឲ្យប្រជានុរាស្ត្រថ្វាយព្រះភ្លើងព្រះសរីរៈរបស់ព្រះរាជា ហើយឲ្យចារឹកគម្ពីរវិនិច្ឆ័យក្តីទុក ហើយប្រាប់ថា អ្នកទាំងឡាយត្រូវមើលគម្ពីរនេះ ហើយពិចារណាក្តី ហើយសម្តែងធម៌ដល់មហាជនទូន្មានដោយសេចក្តីមិនប្រមាទ ហើយចូលព្រៃជាមួយចូឡតុណ្ឌិល ទាំងដែលមនុស្សទាំងអស់កំពុងយំនោះឯង ។ ឱវាទរបស់ព្រះពោធិសត្វក្នុងកាលនោះប្រព្រឹត្តទៅអស់ ៦ ម៉ឺនឆ្នាំ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់

ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុដែលខ្វាចស្លាប់នោះតាំងនៅហើយក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានជាអានន្ទក្នុងកាលឥឡូវនេះ ចូឡតុណ្ឌិលក្នុងកាលនោះ បានមកជាភិក្ខុខ្វាចស្លាប់ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯមហាតុណ្ឌិលក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា តុណ្ឌិលជាតក ចប់

# សុវណ្ណកក្កដកជាតក

[ ២២២ ] ( ក្អែកពោលថា ) ម្រឹគមានពណ៌ដូចមាស ( ក្តាម ) មានភ្នែកលៀន មានស្បែកដូចឆ្អឹង អាស្រ័យនៅក្នុងទឹក ជាសត្វមិនមានរោម ខ្ញុំត្រូវក្តាមនោះគ្របសង្កត់ទើបយំ កំព្រា ( តែម្នាក់ឯង ) ម្នាលសម្លាញ់អើយ ហេតុអ្វីទើបអ្នកបោះបង់ខ្ញុំចោល ។

[ ២២៣ ] ពស់នោះ កាលជួយ ( ក្អែកនោះ ) បើកពពារដ៏ធំ លូនចូលទៅជិតក្តាម យកអាសា ការពារសម្លាញ់ដ៏ស្និទ្ធស្នាល ក្តាមក៏ចាប់ពស់ទៀត ។

[ ២២៤ ] ( ពស់ពោលថា ) ចំណែកខាងក្តាម ជាសត្វត្រូវការដោយចំណី មិនគួរចាប់ក្អែក មិនគួរចាប់ពស់ទេ ម្នាលអ្នកមានភ្នែកលៀន ខ្ញុំសូមសួរអ្នក ហេតុអ្វីក៏អ្នក មកចាប់យើងទាំងពីរនាក់ ។

[ ២២៥ ] ( ក្តាមនិយាយថា ) បុរសនេះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ អ្នកណាចាប់ខ្ញុំនាំទៅក្នុងទឹក កាលបើអ្នកនោះស្លាប់ ខ្ញុំ ( នឹងមាន ) សេចក្តីទុក្ខច្រើន ( ព្រោះ ) ខ្ញុំនិងបុរសនេះទាំងពីរនាក់ នឹងមិននៅជាមួយគ្នា ។

[ ២២៦ ] ឯអ្នកផង ឃើញខ្ញុំមានកាយចម្រើន ( ធំ ) គប្បីប្រាថ្នាដើម្បីបៀតបៀនតែប៉ុណ្ណោះ សូម្បីពួកក្អែកបានឃើញខ្ញុំ មានសាច់ឆ្ងាញ់ ក្រាស់ ទន់ ក៏គប្បីបៀតបៀនដែរ ។

[ ២២៧ ] ( ពស់ពោលថា ) បើអ្នកចាប់យើងទាំងពីរនាក់ ព្រោះហេតុតែបុរសនោះ បុរសចូរក្រោកឡើង ខ្ញុំនឹងស្រូបយកពិសចេញ អ្នកចូរ

លែងខ្ញុំនិងក្អែកឲ្យធាប់ ព្រោះកាលពីដើមពិសដ៏ក្លៀវក្លាជ្រាបចូលក្នុងសត្វ ។

[ ២២៨ ] ( ក្តាមនិយាយថា ) អញលែងពស់ តែមិនលែងក្អែកទេ ព្រោះថា ក្អែកទុកជាអ្នកជានាសិន អញលុះឃើញនូវបុរសមានសេចក្តីសុខ មិនមានរោគទើបលែងក្អែកដូចយ៉ាងពស់ដែរ ។

[ ២២៩ ] ក្អែកក្នុងកាលណោះ បានមកជាទេវទត្ត ចំណែកខាងពស់វែក បានមកជាជីរ ក្តាមបានមកជាអានន្ទដ៏ចម្រើន ព្រាហ្មណ៍ក្នុងកាលណោះ បានមកជាតថាគត ជាសាស្តា ។

**ចប់ សុវណ្ណកក្កដកជាតក ទី ៤ ។**

## អដ្ឋកថា

## សុវណ្ណកក្កដកជាតក

[ ២២២-២២៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការលះបង់ជីវិតរបស់ព្រះអានន្ទដើម្បីព្រះអង្គ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សិង្គី មិគោ** ដូច្នេះជាដើម ។

រឿងអំពីខាងដើម របួតដល់ការជួលខ្មាន់ធ្នូឲ្យសម្លាប់ព្រះសាស្តា បានពោលទុកហើយក្នុង កណ្ឌហាលជាតក ការលែងដំរីធនបាលបានពោលទុកហើយក្នុងចូឡហំសជាតក ។

សេចក្តីសង្ខេបថា ក្នុងកាលនោះ ភិក្ខុទាំងឡាយតាំងរឿងសន្ទនាគ្នាឡើងក្នុងធម្មសភាថា ព្រះអានន្ទត្ថេរជាឃ្លាំងធម៌ ជាអ្នកសម្រេចសេក្ខប្បដិបទាកាល

ដំរីធនបាលកំពុងរត់មក ក៏បានលះបង់ជីវិតថ្វាយព្រះសម្មាសម្ពុទ្ធ ព្រះសាស្ដា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទក៏លះបង់ជីវិតដើម្បីតថាគតដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងទិសឦសាននៃក្រុងរាជគ្រឹះ មានស្រុកព្រាហ្មណ៍មួយឈ្មោះថា ហលិទ្ទិយៈ ។

គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលកសិកព្រាហ្មណ៍ ក្នុងស្រុកនោះ ធំចម្រើនវ័យហើយ តាំងទ្រព្យសម្បត្តិទុក ឲ្យមនុស្សធ្វើកសិកម្មប្រមាណ ៨ ម៉ឺន ក្នុងស្រែមគធៈមួយកន្លែង ក្នុងទិសឦសាននៃស្រុកនោះ ។ ថ្ងៃមួយគាត់ទៅស្រែ មួយអន្លើដោយមនុស្សទាំងឡាយដែលជាបរិវារ ប្រាប់កម្មករទាំងឡាយថា ពួកអ្នកទាំងឡាយចូរធ្វើការងារចុះ ហើយចូលទៅកាន់ជង្ហុកខាងចុងស្រែ ដើម្បីលុបមុខ ។ ក្នុងអូរនោះ មានក្ដាមមួយ ពណ៌ដូចមាស មានរូបស្អាតគួរជ្រះថ្លានៅអាស្រ័យ ។ ព្រះពោធិសត្វទំពាឈើស្ទន់ហើយ ទើបចុះកាន់អូរនោះ ក្នុងកាលព្រះពោធិសត្វលុបមុខ ក្ដាមបានមកជិតព្រះពោធិសត្វ ។ កាលនោះ ព្រះពោធិសត្វបានលើកក្ដាមឡើង ចាប់ឲ្យដេកក្នុងវាំងសំពត់ដណ្ដប់របស់ខ្លួន កាលទៅធ្វើកិច្ចដែលខ្លួនត្រូវធ្វើក្នុងស្រែ ទើបដាក់ក្ដាមទៅក្នុងអូរនោះ ហើយត្រឡប់ទៅផ្ទះ ។ បន្ទាប់អំពីនោះមក ព្រះពោធិសត្វ

កាលមកដល់ស្រែ តែងទៅកាន់អូរនោះជាមុន ឲ្យក្តាមដេកក្នុងរវាងសំពត់ដណ្តប់ហើយ ទើបមកមើលការងារជាក្រោយ ដោយប្រការដូច្នេះ ការស្និទ្ធស្នាលគ្នារវាងព្រះពោធិសត្វនិងក្តាមនោះក៏មាំទាំ ។ ព្រះពោធិសត្វក៏មកស្រែជានិច្ច ។ បសាទក្នុងភ្នែករបស់ព្រះពោធិសត្វប្រាកដជាវង្វង់មូល ៣ ជាន់ ភ្លឺថ្លា ។ កាលនោះ ក្អែកញីធ្វើសំបុកលើដើមត្នោតមួយដើម ខាងចុងស្រែរបស់ព្រះពោធិសត្វ ឃើញភ្នែករបស់ព្រះពោធិសត្វហើយ ចង់ស៊ី ទើបប្រាប់ក្អែកឈ្មោលថា នែអ្នក ខ្ញុំចាញ់ផ្ទៃហើយ ក្អែកឈ្មោលពោលថា ឈ្មោះថាការចាញ់ផ្ទៃដូចម្តេច ក្អែកញីពោលថា ខ្ញុំចង់ស៊ីភ្នែករបស់ ព្រាហ្មណ៍នោះ ក្អែកឈ្មោលពោលថា នាងកើតចាញ់ផ្ទៃអាក្រក់ នរណាអាចនាំភ្នែកទាំងនោះមកបាន ក្អែកញីពោលថា អ្នកមិនអាចឬ ក្អែកឈ្មោលពោលថា អញមិនអាចទេ ក្អែកញីពោលថា ខ្ញុំដឹងរឿងនេះ ត្រង់ជំបូកនោះ ក្នុងទីមិនឆ្ងាយមានពស់វែកនៅអាស្រ័យ សូមអ្នកប្រណិប័តន៍ពស់វែកនោះ ព្រាហ្មណ៍នោះត្រូវពស់វែកចឹកហើយក៏នឹងស្លាប់ កាលបើដូច្នោះ អ្នកនឹងយកភ្នែករបស់គេមកបាន ក្អែកឈ្មោលទទួលថា សាធុ ចាប់តាំងអំពីនោះមក ក៏ប្រណិប័តន៍ពស់វែក ។ ក្នុងពេលដែលសន្ទូងរបស់ព្រះពោធិសត្វផើម ក្តាមក៏បានធំចម្រើនឡើង ។ ថ្ងៃមួយ ពស់ពោលនឹងក្អែកថា នែសម្លាញ់ ឯងប្រណិប័តន៍ខ្ញុំជានិច្ច ព្រោះហេតុអ្វី ខ្ញុំនឹងធ្វើអ្វីឲ្យឯងបាន ។ ក្អែកប្រាប់ថា នែអ្នក ទាសីរបស់អ្នក គឺភរិយារបស់ខ្ញុំ កើតនូវការចាញ់ផ្ទៃ ចង់ស៊ីភ្នែករបស់ម្ចាស់ស្រែ ខ្ញុំនឹងបានភ្នែករបស់ម្ចាស់ស្រែនោះ ដោយអានុភាពរបស់អ្នក ព្រោះហេតុនោះ ទើបប្រណិប័តន៍

អ្នក ។ ពស់ប្រាប់ឲ្យក្អែកនោះចូរស្ងៀយថា រឿងនេះលើកទុកចុះ មិនមែនជារឿងធ្ងន់ទេ ឯងនឹងបានពិត ។ ស្អែកឡើង ទើបអាស្រ័យក្បីស្រែក្នុងផ្លូវដែលព្រាហ្មណ៍មក លាក់ខ្លួនក្នុងស្មៅ ដេកទន្ទឹងការមករបស់ព្រះពោធិសត្វ ។

ព្រះពោធិសត្វកាលមក ចុះទៅក្នុងអូរលុបមុខ ទើបញុំាងសេចក្ដីស្នេហាឲ្យកើតឡើង ឱបក្ដាមមាសឲ្យដេកក្នុងវាំងសំពត់ដណ្ដប់ ហើយទើបចូលទៅស្រែ ។ ពស់ឃើញព្រះពោធិសត្វកំពុងមក ក៏លូនទៅដោយរហ័ស ចឹកត្រង់កំភួនជើងឲ្យដួលចុះក្នុងទីនោះឯង ហើយទើបគេចទៅកាន់ដំបូកខាងចុងផ្លូវ ។ ការដួលចុះរបស់ព្រះពោធិសត្វក្ដី ការលោតចុះអំពីសំពត់សាដក របស់ក្ដាមក្ដី ការដែលក្អែកមកទំត្រង់ទ្រូងព្រះពោធិសត្វក្ដី មានមិនមុនមិនក្រោយគ្នា ។ ក្អែកទំហើយ យកចំពុះចឹកភ្នែក ។ ក្ដាមគិតថា ភ័យកើតឡើងដល់សម្លាញ់របស់អញហើយ ព្រោះអាស្រ័យក្អែកនេះ បើអញចាប់ក្អែកនេះបាន ពស់ក៏នឹងត្រឡប់មក ទើបប្រើតង្កៀបកៀបកក្អែកយ៉ាងណែន ដូចយកដង្កាប់កៀបទុក ធ្វើឲ្យទុព្វលហើយបន្ធូរបន្ដិចគឺលាដង្កៀបបន្ដិច ក្អែកក៏ហៅពស់ថា នែសម្លាញ់ សម្លាញ់បោះបង់ខ្ញុំទៅដើម្បីប្រយោជន៍អ្វី ក្ដាមនេះកៀបខ្ញុំ ចូរប្រញាប់មកមុនខ្ញុំស្លាប់ ហើយពោលគាថាទី ១ ថា

> ម្រឹគមានពណ៌ដូចមាស ( ក្ដាម ) មានភ្នែកលៀន មានស្បែកដូចឆ្អឹង អាស្រ័យនៅក្នុងទឹក ជាសត្វមិនមានរោម ខ្ញុំត្រូវក្ដាមនោះគ្របសង្កត់ ទើបយំ កំព្រា ( តែម្នាក់ឯង ) ម្នាលសម្លាញ់អើយ ហេតុអ្វីទើបអ្នកបោះបង់ខ្ញុំចោល ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថានោះដូចតទៅនេះថា ក្តាមហៅថា **សិង្គី មិគោ** ព្រោះមានពណ៌ដូចមាសសិង្គី ឬព្រោះមានស្នែង គឺតង្កៀប ។ បទថា **អា-យតចក្ខុនេត្តោ** បានដល់ ប្រកបដោយភ្នែក ពោលគឺចក្ខុវែង ។ ស្បែកគឺឆ្អឹងនៃក្តាមនោះមាន ព្រោះហេតុនោះ ទើបក្តាមនោះ ឈ្មោះថា **អដ្ឋិត្តចោ** គឺមានស្បែកដូចឆ្អឹង ។ បទថា **ហារេ សខា** ជាពាក្យហៅ ដោយអត្ថថា នៃសម្លាញ់ដ៏ចម្រើន ។

ពស់បានស្តាប់ពាក្យនោះហើយ បានបើកពពារលួងលោមក្អែកឲ្យត្រេកអរហើយចូលទៅរក ។

ព្រះសាស្តា កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់អភិសម្ពុទ្ធគាថាទី ២ ថា

ពស់នោះ កាលជួយ ( ក្អែកនោះ ) បើកពពារដ៏ធំ លូន
ចូលទៅជិតក្តាម យកអាសា ការពារសម្លាញ់ដ៏ស្និទ្ធស្នាល
ក្តាមក៏ចាប់ពស់ទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កក្កដ កដ្ឋុបគន្តោ** បានដល់ ដល់ទីជិតក្តាម ។ បទថា **សខា សខារំ** បានដល់ ជាសម្លាញ់ការពារសម្លាញ់របស់ខ្លួន ។ បាឋៈថា **សកខារំ** ដូច្នេះក៏មាន ដោយអត្ថថា សម្លាញ់របស់ខ្លួន ។ បទថា **បរិតាយមានោ** បានដល់ ដើម្បីនឹងរក្សា ។ បទថា **អគ្គហេសិ** បានដល់ ក្តាមយកតង្កៀបទី ២ កៀបកពស់យ៉ាងណែន ក្រោយមកបន្ធូរបន្តិច គឺលាតង្កៀបបន្តិច ។

លំដាប់នោះ ពស់គិតថា ធម្មតាក្អាមនឹងមិនស៊ីសាច់ឆ្កែកនិងមិនស៊ីសាច់ពស់ឡើយ ព្រោះហេតុអ្វីហ្ន៎ ទើបក្អាមនេះកៀបពួកយើង កាលសួរក្អាមនោះ ទើបពោលគាថាទី ៣ ថា

ចំណែកខាងក្អាម ជាសត្វត្រូវការដោយចំណី មិនគួរចាប់ក្អែក មិនគួរចាប់ពស់ទេ ម្នាលអ្នកមានក្អែកលៀន ខ្ញុំសូមសួរអ្នក ហេតុអ្វីក៏អ្នកមកចាប់យើងទាំងពីរនាក់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឃាសត្ថិកោ** បានដល់ ជាអ្នកត្រូវការអាហារ ។ បទថា **អនេយ្យ** បានដល់ កៀបទុក អធិប្បាយថា កៀបទុកធ្វើជាអាហារក៏មិនមែន ។

ក្អាមបានស្ដាប់ពាក្យនោះហើយ កាលនឹងប្រាប់ដល់ហេតុដែលកៀប ក៏ពោលគាថា ២ ថា

បុរសនេះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ អ្នកណាចាប់ខ្ញុំនាំទៅក្នុងទឹក កាលបើអ្នកនោះស្លាប់ ខ្ញុំ ( នឹងមាន ) សេចក្ដីទុក្ខច្រើន ( ព្រោះ ) ខ្ញុំនិងបុរសនេះ ទាំងពីរនាក់នឹងមិននៅជាមួយគ្នា ។

ឯអ្នកផង ឃើញខ្ញុំមានកាយចម្រើន ( ធំ ) គប្បីប្រាថ្នាដើម្បីបៀតបៀនតែប៉ុណ្ណោះសូម្បីពួកក្អែកបានឃើញខ្ញុំមានសាច់ធ្លាញ់ ក្រាស់ ទន់ ក៏គប្បីបៀតបៀនដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អយំ** សំដៅដល់ ព្រះពោធិសត្វ ។ បទ

ថា **អត្ថកាមោ** ដោយអត្ថថា បំណងនូវប្រយោជន៍ ។ ដោយបទថា **ឧទ-កាយ នេតិ** ក្តាមសម្តែងថា បុគ្គលណាស្រឡាញ់ខ្ញុំ យកសំពត់ដណ្តប់ខ្ញុំទៅត្រង់ទឹក គឺឲ្យខ្ញុំដល់លំនៅរបស់ខ្លួន ។ បទថា **តស្មឹ មតេ** ក្តាមសម្តែងថា បើបុរសនេះស្លាប់ក្នុងទីនេះសោត បើមនុស្សនេះស្លាប់ហើយ ខ្ញុំនឹងដល់នូវសេចក្តីទុក្ខដោយកាយនិងទុក្ខដោយចិត្តច្រើន ។ បទថា **ឧភោ ន ហោម** បានដល់ យើងទាំងពីរក៏នឹងមិនមាន ។ គាថាថា **មមញ្ច ធិស្វាន** មានអត្ថដូចតទៅនេះថា សេចក្តីនេះជាហេតុ សេចក្តីដទៃក៏ជាហេតុ គឺកាលមនុស្សនេះស្លាប់ហើយ អ្នករាល់គ្នាឃើញខ្ញុំអស់ទីពឹង មិនមានបច្ច័យ តែមានរាងកាយធំធាត់ហើយ គង់នឹងត្រូវសម្លាប់ខ្ញុំ ដោយឃើញថា សាច់របស់ក្តាមនេះ ឆ្ងាញ់ផងក្រាស់ផង មិនមែនតែមនុស្សប៉ុណ្ណោះដែលត្រូវការសូម្បីក្អែកទាំងឡាយដែលជាសត្វតិរច្ឆាន ឃើញខ្ញុំ ក៏គង់នឹងបៀតបៀន គឺគង់នឹងសម្លាប់ឲ្យស្លាប់ ។

ពស់បានស្តាប់ពាក្យនោះហើយ ទើបគិតថា អញនឹងបោកក្តាមនេះដោយឧបាយមួយ ហើយឲ្យលែងទាំងក្អែកទាំងអញ ។ លំដាប់នោះ ពស់កាលនឹងបោកក្អាមនោះ បានពោលគាថាទី ៦ ថា

បើអ្នកចាប់យើងទាំងពីរនាក់ ព្រោះហេតុតែបុរសនោះ បុរស
ចូរក្រោកឡើង ខ្ញុំនឹងស្រូបយកពិសចេញ អ្នកចូរលែងខ្ញុំនិង
ក្អែកឲ្យឆាប់ ព្រោះកាលពីដើម[១]ពិសដ៏ក្លៀវក្លាជ្រាបចូលក្នុង

---

១-បាលីថា បុរេ វិសំ គាឡ្ហមុបេតិ មច្ចំ គួរប្រែថា មុនពិសដ៏ក្លៀវក្លាជ្រាបចូលក្នុងសត្វ ទើបត្រូវតាមន័យរបស់អដ្ឋកថា ។

សត្វ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សចេ តស្ស ហេតុ** បានដល់ បើព្រោះហេតុនៃបុរសនេះសោត ។ បទថា **ឧដ្ឋាតុ** បានដល់ ចូរជាអ្នកប្រាសចាកពិស ។ បទថា **វិសមាវមាមិ** បានដល់ ខ្ញុំនឹងដកពិសរបស់បុរសនោះចេញ និងធ្វើឲ្យបុរសនេះជាអ្នកមិនមានពិសទៀត ។ បទថា **បុរេ វិសំ គាឡ្ហមុបេតិ មជ្ជំ** សេចក្ដីថា ព្រោះថា ពិសដែលមិនទាន់បឺតត្រឡប់ ជាពិសមានកម្លាំងខ្លាំងក្លាគប្បីចូលទៅកាន់បុរសនេះ ដរាបណាពិសនោះមិនទាន់ចូលទៅ ដរាបនោះឯង ចូរអ្នកលែងយើងទាំង ២ ។

ក្អាមបានស្ដាប់ដូច្នោះហើយ ទើបគិតថា ពស់នេះប្រើឧបាយណាមួយ ឲ្យអញលែងទាំង ២ ហើយគេចទៅ ពស់នេះមិនដឹងការឈ្លាសវៃក្នុងឧបាយរបស់អញ ។ ឥឡូវនេះ អញនឹងធ្វើតង្កៀបរបស់អញឲ្យធូរ ល្មមឲ្យពស់អាចលូនទៅបាន កាលគិតយ៉ាងនេះហើយ បានពោលគាថាទី ៧ ថា

អញលែងពស់ តែមិនលែងក្អែកទេ ព្រោះថា ក្អែកទុកជាអ្នក
ជានាសិន អញលុះឃើញនូវបុរសមានសេចក្ដីសុខ មិនមាន
រោគ ទើបលែងក្អែក ដូចយ៉ាងពស់ដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិពទ្ធកោ** បានដល់ ជាអ្នកជានា ។ បទថា **យថេវ សប្បំ** សេចក្ដីថា អញលែងពស់ដ៏ចម្រើនយ៉ាងណា ទោះក្អែកអញក៏លែងយ៉ាងនោះ ឯងចូរបឺតពិសអំពីរាងកាយរបស់ព្រាហ្មណ៍នេះ ឲ្យអស់ដោយរហ័ស ។

ឯក្អាមកាលពោលយ៉ាងនេះហើយ បានលាតង្កៀប ឲ្យពស់នោះលូនទៅ

ដោយស្រួល ពស់បឺតពិសចេញហើយ បានធ្វើរាងកាយរបស់មហាសត្វឲ្យអស់ពិស ។ ព្រះមហាសត្វនោះមិនមានទុក្ខ ទើបក្រោកឡើងឈរ ដោយរាងកាយប្រក្រតីនោះឯង ក្អាមគិតថា បើសត្វទាំង ២ នេះផុតភ័យសោតឈ្មោះថា សេចក្តីចម្រើននឹងមិនមានដល់សម្លាញ់របស់អញ អញនឹងឲ្យវាវិនាសទៅ ដូច្នេះហើយ បានយកតង្កៀបកៀបកសត្វទាំងពីរ ដូចយកឈើប្រត់សង្កត់ត្របកឈូក ឲ្យដល់នូវការអស់ជីវិត ។ ឯក្អែកញីក៏បានគេចទៅអំពីទីនោះ ។ ព្រះពោធិសត្វ យកកំណាត់ឈើរុំសរីរៈពស់ ហើយបោះទៅលើដំបូក លែងក្អាមមាសត្រង់អួរហើយ ទៅស្រុកហលិទ្ទិយៈនោះឯង ។ តាំងអំពីនោះមក ការស្និទ្ធស្នាលរវាងព្រះពោធិសត្វនិងក្អាមមានជាងមុន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ មហាជនជនបានជាព្រះសោតាបន្នជាដើម ហើយទ្រង់ត្រាស់គាថាចុងក្រោយប្រជុំជាតកថា

ក្អែកក្នុងកាលណោះ បានមកជាទេវទត្ត ចំណែកខាងពស់វែក
បានមកជាដីរ[១]ក្អាមបានមកជា អានន្ទដ៏ចម្រើន ព្រាហ្មណ៍ក្នុង
កាលណោះ បានមកជាតថាគត ជាសាស្តា ដូច្នេះ ។

ឯក្អែកញីមិនបានត្រាស់ទុកក្នុងគាថា ។ ក្អែកញីនោះ បានមកជានាងចិញ្ចមាណវិកា ។

## អដ្ឋកថា សុវណ្ណកក្កដកជាតក ចប់

---

១-ដីរនាឡាគីរី ។

# មយ្ហកសកុណជាតក

[ ២៣០ ] ( តាបសពោធិសត្វពោលថា ) សត្វស្លាបឈ្មោះ មយ្ហកៈ ហើរទៅតាមញកនិងច្រកភ្នំ ទៅទំដើមលៀបដែលមានផ្លែទុំ យំកន្ទក់កន្ទេញ ថា របស់អញៗដូច្នេះ ។

[ ២៣១ ] កាលសត្វមយ្ហកៈនោះ ស្រែកយំការពារយ៉ាងនេះ ពួកសត្វទិជជាតិ ក៏មកប្រជុំគ្នា ស៊ីផ្លែលៀបហើយហើរទៅ សត្វនោះ ក៏នៅតែស្រែកយំការពារ ។

[ ២៣២ ] ដូចយ៉ាងជនពួកខ្លះក្នុងលោកនេះ ប្រមូលមកនូវទ្រព្យមានប្រមាណច្រើន ហើយមិនចាត់ចែងនូវទ្រព្យ ឲ្យសមគួរដល់ចំណែកដើម្បីខ្លួន មិនទំនុកបម្រុងដល់ញាតិទាំងឡាយ ។

[ ២៣៣ ] បុគ្គលនោះ រមែងមិនបានប្រើប្រាស់នូវគ្រឿងស្លៀកពាក់និងបាយ មិនបានទ្រទ្រង់នូវកម្រងផ្កា មិនបានលាបនូវគ្រឿងលាប ( ដ៏ល្អទេ ) មិនបានប្រើប្រាស់នូវវត្ថុណាមួយជារបស់ខ្លួនទេ ទាំងមិនបានសង្គ្រោះនូវញាតិទាំងឡាយឡើយ ។

[ ២៣៤ ] កាលបើបុគ្គលនោះ ពោលរៀបរាប់ហួងហែងថា របស់អញៗ យ៉ាងនេះ ស្រាប់តែពួកព្រះរាជាឬពួកចោរ និងពួកជនអ្នកត្រូវទទួលមត៌កមិនជាទីស្រឡាញ់ នាំយកទ្រព្យនោះទៅ បុគ្គលនោះ ក៏នៅតែនិយាយរៀបរាប់ ។

[ ២៣៥ ] ឯអ្នកប្រាជ្ញ បាននូវភោគៈហើយ រមែងសង្គ្រោះញាតិទាំងឡាយ អ្នកប្រាជ្ញនោះរមែងបាននូវសេចក្តីសរសើរដោយ ការសង្គ្រោះញាតិ

នោះ លុះលះលោកនេះទៅហើយ រមែងវិករាយក្នុងឋានសួគ៌ ។

**ចប់ មយ្ហកសកុណជាតកទី ៥ ។**

## អដ្ឋកថា

## មយ្ហកសកុណជាតក

[ ២៣០-២៣៥ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាគន្តុកសេដ្ឋី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **សកុណោ មយ្ហកោ នាម** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ត្រង់នគរសាវត្ថី មានសេដ្ឋីម្នាក់ ឈ្មោះអាគន្តុកៈ ជាអ្នកស្តុកស្តម្ភដោយទ្រព្យ តែគាត់មិនបានប្រើភោគទ្រព្យដោយខ្លួនឯងឡើយ និងមិនបានឲ្យអ្នកដទៃ ។ កាលមនុស្សនាំភោជនដែលប្រណីត មានរសឆ្ងាញ់ផ្សេងៗមកឲ្យ គាត់ក៏មិនបរិភោគភោជននោះ បរិភោគតែចុងអង្ករ មានម្ជូរគឺទឹកជ្រក់ជាគម្រប់ ២ ប៉ុណ្ណោះ ។ កាលគេនាំសំពត់ពីដែនកាសី ដែលគេក្ងួតហើយដោយល្អអប់ឲ្យក្រអូបហើយមកឲ្យ ក៏ឲ្យមនុស្សនាំចេញទៅ ស្លៀកដណ្តប់សំពត់សាច់រឹងគ្រោតគ្រាត កាលគេនាំរថដែលរំលេចដោយកែវ និងមាស ទឹមដោយសេះមកឲ្យ ក៏ឲ្យនាំរថនោះចេញ ហើយទៅដោយរថតូចដែលធ្វើដោយឈើធម្មតា កាលគេបាំងឆត្រមាសឲ្យ ក៏ឲ្យគេនាំឆត្រមាសនោះចេញទៅ បាំងដោយឆត្រ ដែលធ្វើដោយស្លឹកឈើ ។ មួយជីវិត គាត់មិនបានធ្វើបុណ្យសូម្បីតែម្តង ក្នុងបុណ្យទាំងឡាយ មានទានជាដើមឡើយ អនិច្ចកម្ម

ហើយ ទៅកើតក្នុងរោរុវនរក ។ ព្រះរាជា ទ្រង់ឲ្យដឹកនាំសម្បត្តិដែលមិនមាន កូនទទួលមត៌ករបស់សេដ្ឋីនោះចូលទៅក្នុងរាជត្រកូលអស់កាល ៧ ថ្ងៃ ។ កាលឲ្យដឹកនាំសម្បត្តិនោះស្រេចហើយ ព្រះរាជាទ្រង់សោយព្រះក្រយាហារព្រឹកហើយ បានយាងទៅព្រះវិហារជេតពន ទ្រង់ថ្វាយបង្គំព្រះសាស្តា ហើយប្រថាប់គង់ កាលព្រះសាស្តាត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ទ្រង់មិនយាងមកព្រោះហេតុអ្វី ទើបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីឈ្មោះអាគន្តុកៈក្នុងនគរសាវត្ថី អនិច្ចកម្មហើយ កាលឲ្យមនុស្សដឹកនាំទ្រព្យ ដែលមិនមានម្ចាស់ របស់សេដ្ឋីនោះមកកាន់ព្រះរាជវាំងនោះឯង ទើបពេលវេលាកន្លងទៅអស់ ៧ ថ្ងៃ ។ សេដ្ឋីនោះសូម្បីមានទ្រព្យប្រមាណប៉ុណ្ណោះ ក៏មិនបានប្រើប្រាស់ដោយខ្លួនឯង មិនបានឲ្យដល់អ្នកដទៃ ទ្រព្យរបស់គាត់ ដូចស្រះបោក្ខរណីដែលអារក្ខទឹកហ៊ុំហែង រសភោជនដ៏បណីតជាដើម សូម្បីតែមួយថ្ងៃ គាត់ក៏មិនបានបរិភោគ ទល់គ្មានីងចូលកាន់មាត់មច្ចុរាជ អ្នកមិនមានបុណ្យ មានសេចក្តីកំណាញ់យ៉ាងនេះ ធ្វើកម្មអ្វីទុក ទើបបានទទួលទ្រព្យប្រមាណប៉ុណ្ណោះ និងដោយហេតុអ្វីទើបចិត្តរបស់គាត់មិនត្រេកអរក្នុងភោគទ្រព្យ ( ក្នុងការប្រើប្រាស់ ) ព្រះសាស្តាត្រាស់ថា សូមថ្វាយព្រះពរមហាបពិត្រ សេដ្ឋីនោះធ្វើហេតុដែលឲ្យបានទ្រព្យ ១ ការៈ ដែលបានទ្រព្យហើយមិនប្រើប្រាស់ ១ ដូច្នេះហើយ ជាបុគ្គលដែលព្រះរាជាទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណ

សី មានសេដ្ឋីក្រុងពារាណសីម្នាក់មិនមានសទ្ធា មានសេចក្ដីកំណាញ់ មិនឲ្យទ្រព្យដល់បុគ្គលណាមួយឡើយ មិនសង្គ្រោះបុគ្គលណាឡើយ ។ ថ្ងៃមួយគាត់កំពុងដើរទៅគាល់ព្រះរាជា ឃើញព្រះបច្ចេកពុទ្ធ ព្រះនាមថាតគរសិខី កំពុងនិមន្តបិណ្ឌបាត ថ្វាយបង្គំហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានកិច្ចាហើយឬ កាលព្រះបច្ចេកពុទ្ធត្រាស់ថា មហាសេដ្ឋី អាត្មាកំពុងដើរទៅរឿយៗមិនមែនឬ ទើបប្រាប់បុរសម្នាក់ថា ទៅចុះ ឯងចូរនាំព្រះបច្ចេកពុទ្ធទៅផ្ទះរបស់ពួកយើង ឲ្យលោកគង់លើបល្ល័ង្ករបស់យើង ហើយដាក់កត្តាហារដែលត្រៀមទុកសម្រាប់យើងឲ្យពេញបាត្រ ហើយប្រគេនទៅ ។ បុរសនោះនាំព្រះបច្ចេកពុទ្ធទៅផ្ទះ ហើយឲ្យគង់ ប្រាប់ឲ្យភរិយាសេដ្ឋីដឹង ឲ្យដាក់កត្តា-ហារដែលមានរសដ៏ប្រសើរ ច្រើនប្រភេទពេញបាត្រ ហើយបានប្រគេនព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធទទួលកត្តាហើយ បាននិមន្តចេញអំពីនិវេសន៍របស់សេដ្ឋីកាត់តាមវិថី ។ សេដ្ឋីមកអំពីព្រះរាជវាំង ឃើញលោកហើយថ្វាយបង្គំទូលសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានកត្តាហារហើយឬ ព្រះបច្ចេកពុទ្ធតបថា បានហើយលោកសេដ្ឋី ។ សេដ្ឋីនោះមើលក្នុងបាត្រហើយ មិនអាចឲ្យចិត្តជ្រះថ្លាបាន គិតថា កត្តាហាររបស់អញនេះ ទាសៈឬកម្មករទាំងឡាយបរិភោគហើយគង់ធ្វើការងារដែលធ្វើបានលំបាក គួរឲ្យស្ដាយហ្ន៎ អញមានសេចក្ដីវិនាសទ្រព្យអស់ហើយ ដូច្នេះ មិនអាចធ្វើអបរចេតនាឲ្យបរិបូណ៌បាន ។ ធម្មតាទាន លុះណាបុគ្គលអាចធ្វើចេតនាទាំង ៣ ឲ្យបរិបូណ៌ប៉ុណ្ណោះ ទើបមានផលច្រើន ។ ( សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ទុកក្នុងមហាធម្ម

បាលជាតក និងក្នុងអង្គុត្តរនិកាយឆក្កនិបាតថា )

ពួកយើងមានចិត្តល្អក្នុងកាលមុនឲ្យ កាលកំពុងឲ្យក៏មាន ចិត្តត្រេកអរ លុះឲ្យហើយមិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង ( ក្នុងត្រកូល ) របស់ពួកយើងមិនស្លាប់ ។

ទាយកមានចិត្តរីករាយក្នុងវេលាមុនអំពីកាលឲ្យ កំពុងឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយ ក៏មានចិត្តត្រេកអរ ( តាមក្រោយ ) នេះជាសេចក្តីបរិបូណ៌របស់ទាន ដូច្នេះ ។

សូមថ្វាយព្រះពរមហាបពិត្រ អាគន្តុកសេដ្ឋី បានទ្រព្យច្រើនព្រោះបច្ច័យដែលបានប្រគេនដល់ព្រះតគរសិខីបច្ចេកពុទ្ធ តែមិនអាចប្រើប្រាស់ភោគទ្រព្យបាន ព្រោះមិនអាចធ្វើអបរចេតនា គឺចេតនាត្រេកអរតាមក្រោយឲ្យប្រណីតបាន ដោយប្រការដូច្នេះ ។

ព្រះរាជាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វី ទើបគាត់មិនមានបុត្ត ព្រះសាស្តាត្រាស់ឆ្លើយថា ថ្វាយព្រះពរមហាបពិត្រ ហេតុនៃការមិនមានបុត្ត សេដ្ឋីនោះក៏ធ្វើទុកដូចគ្នា ព្រះរាជាអារាធនាហើយ ក៏ទ្រង់នាំយក រឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេដ្ឋី មានសម្បត្តិ ៨០ កោដិ ធំចម្រើនវ័យហើយ កាលមាតាបិតាអនិច្ចកម្មទៅគ្រប់គ្រងសម្បត្តិ ២ នាក់ ប្អូនប្រុស

កាលសម្លឹងមើលសម្បត្តិហើយទើបឲ្យសាងរោងទានទុកត្រង់ទ្វារផ្ទះ បំពេញនូវមហាទានគ្រប់គ្រងផ្ទះ ។ តមកកូនរបស់ព្រះពោធិសត្វម្នាក់ក៏ប្រសូត ក្នុងកាលកូននោះដើរបាន ព្រះពោធិសត្វ ឃើញទោសក្នុងកាមទាំងឡាយឃើញអានិសង្សក្នុងការបួស ទើបប្រគល់សម្បត្តិក្នុងផ្ទះទាំងអស់ឲ្យប្អូនប្រុស មួយអន្លើដោយកូននិងប្រពន្ធ ឲ្យឱវាទថា ចូរកុំប្រមាទ ឲ្យទានជាដើមចុះ ហើយបួសជាឥសី ញុំាងឈាននិងអភិញ្ញាឲ្យកើតឡើង អាស្រ័យនៅក្នុងទ្រូងព្រៃហិមពាន្ត ។ ឯប្អូនប្រុសរបស់ព្រះពោធិសត្វ ក៏បានកូនម្នាក់ គាត់ឃើញកុមារនោះចម្រើនវ័យឡើងទើបគិតថា បើកូនប្រុសរបស់បងប្រុសអញនៅមានជីវិត សម្បត្តិនឹងត្រូវចែកជា ២ ចំណែក អញនឹងសម្លាប់កូនបងប្រុសចោល ។ ថ្ងៃមួយ គាត់បានសម្លាប់ក្មេងនោះត្រង់អន្លង់ទឹក ។ ករិយារបស់បងប្រុសសួរដល់កូនដែលងូតទឹក ជាមួយឪពុកមាដែលមកហើយថា កូនរបស់ខ្ញុំទៅណា បុរសនោះឆ្លើយថា វាលេងទឹកក្នុងស្ទឹង លុះនាងរកមិនជួបទើបទ្រហោយំ ។ ព្រះពោធិសត្វដឹងហេតុនោះគិតថា អញនឹងធ្វើកិច្ចនេះឲ្យប្រាកដ ទើបមកតាមអាកាស ចុះត្រង់នគរពារាណសី ស្លៀកដណ្តប់រៀបរយហើយឈរត្រង់ទ្វារផ្ទះរបស់ប្អូនប្រុសនោះ មិនឃើញរោងទានទើបគិតថា សូម្បីតែរោងទាន ក៏អសប្បុរសនេះធ្វើឲ្យវិនាសទៅហើយ ។ ឯប្អូនប្រុសរបស់ព្រះពោធិសត្វ បានដឹងថា ព្រះពោធិសត្វមកហើយ ក៏មកថ្វាយបង្គំ ហើយឲ្យឡើងកាន់ប្រាសាទឲ្យឆាន់បណីតភោជន ។ ក្នុងទីបំផុតនៃភត្តកិច្ច ព្រះពោធិសត្វអង្គុយដោយផាសុក សួរថា កុមារមិនប្រាកដ តើគេទៅណា ប្អូនប្រុសឆ្លើយថា ស្លាប់ហើយ

លោកម្ចាស់ ព្រះពោធិសត្វសួរថា ស្លាប់ដោយហេតុអ្វី ប្អូនប្រុសឆ្លើយថា ខ្ញុំមិនជ្រាបថាដោយអ្វីឡើយ ក្នុងទីដែលលេងទឹក ព្រះពោធិសត្វពោលថា នែអសប្បុរស ឯងមិនដឹងថាកិច្ចដែលឯងធ្វើហើយប្រាកដដល់អញ ឯងសម្លាប់ក្មេងនោះដោយហេតុអាក្រក់នេះមិនមែនឬ ឯងអាចរក្សាទ្រព្យដែលកំពុងសូន្យទៅដោយអំណាចព្រះរាជាជាដើម បានឬទេ សត្វមយ្ហកៈនិងឯង មានអ្វីខុសគ្នា ។ លំដាប់នោះមហាសត្វកាលនឹងសម្តែងធម៌ដល់ប្អូនដោយពុទ្ធលីលាទើបពោលគាថាទាំងនេះថា

សត្វស្លាបឈ្មោះមយ្ហកៈ ហើរទៅតាមញកនិងច្រកភ្នំ ទៅទំដើមល្វាដែលមានផ្លែទុំ យំកន្ទក់កន្ទេញថា របស់អញ ៗ ដូច្នេះ ។

កាលសត្វមយ្ហកៈនោះ ស្រែកយំការពារយ៉ាងនេះ ពួកសត្វទិជជាតិ ក៏មកប្រជុំគ្នាស៊ីផ្លែល្វាហើយហើរទៅ សត្វនោះក៏នៅតែស្រែកយំការពារ ។

ដូចយ៉ាងជនពួកខ្លះក្នុងលោកនេះ ប្រមូលមកនូវទ្រព្យមានប្រមាណច្រើន ហើយមិនចាត់ចែងនូវទ្រព្យ ឲ្យសមគួរដល់ចំណែកដើម្បីខ្លួន មិនទំនុកបម្រុងដល់ញាតិទាំងឡាយ ។

បុគ្គលនោះ រមែងមិនបានប្រើប្រាស់នូវគ្រឿងស្លៀកពាក់និងបាយ មិនបានទ្រទ្រង់នូវកម្រងផ្កា មិនបានលាបនូវគ្រឿងលាប ( ដ៏ល្អទេ ) មិនបានប្រើប្រាស់នូវវត្ថុណាមួយជារបស់ខ្លួនទេ

ទាំងមិនបានសង្គ្រោះនូវញាតិទាំងឡាយឡើយ ។

កាលបើបុគ្គលនោះ ពោលរៀបរាប់ ហួងហែងថា របស់អញៗ យ៉ាងនេះ ស្រាប់តែពួកព្រះរាជាឬពួកចោរនិងពួកជនអ្នកត្រូវទទួលមត៌ក មិនជាទីស្រឡាញ់ នាំយកទ្រព្យនោះទៅ បុគ្គលនោះ ក៏នៅតែនិយាយរៀបរាប់ ។

ឯអ្នកប្រាជ្ញ បាននូវភោគៈហើយ រមែងសង្គ្រោះញាតិទាំងឡាយ អ្នកប្រាជ្ញនោះរមែងបាននូវសេចក្តីសរសើរដោយ ការសង្គ្រោះញាតិនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មយ្ហកោ** សេចក្តីថា ដែលបានឈ្មោះយ៉ាងនេះ ព្រោះអំណាចការយំថា របស់អញៗ ។ បទថា **គិរិសានុទរីចរោ** សេចក្តីថា សត្វនោះដែលឈ្មោះថា **គិរិសានុទរីចរោ** ព្រោះហើរទៅត្រង់ជង្គភ្នំនិងញកភ្នំ ។ បទថា **បក្កំ បិប្ផលឹ** បានដល់ ដើមល្វៀបមួយដើមមានផ្លែសន្ទឹកសន្ធាប់ ក្នុងផែនដីនៃព្រៃហិមពាន្ត ។ បទថា **កន្ទតិ** បានដល់ សត្វនោះហើរយំឃាត់ហ្វូងបក្សី ដែលចោមរោមដើមឈើនោះ ស៊ីផ្លែដែលទុំ ។ បទថា **តស្សេវំ វិលបន្តស្ស** បានដល់ កាលមយ្ហកៈយំយ៉ាងនោះឯង ។ បទថា **កុលាន បិប្ផលឹ យន្តិ** សេចក្តីថា បក្សីដទៃ នាំគ្នាស៊ីផ្លែល្វៀបនោះ ហើយហើរទៅដើមដទៃដែលមានផ្លែសម្បូរ ។ បទថា **វិលបតេវ** បានដល់ ចំណែកបក្សីនោះ ក៏នៅតែយំនោះឯង ។ បទថា **យថោធី** បានដល់ តាមចំណែក

អធិប្បាយថា មិនបាន ចំណែកដែលត្រូវបាន ដោយអំណាចគ្រឿងឧបភោគ និងគ្រឿងបរិភោគដល់មាតាបិតា បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី និងបុត្តធីតាជាដើម ។ បទថា **សកំ** បានដល់ មិនបានប្រើប្រាស់ សូម្បីតែម្តងអធិប្បាយថា មិនបានប្រើប្រាស់ខ្លួនឯង ។ បទថា **ន សង្គណ្ហាតិ** បានដល់ មិនបានសង្គ្រោះដោយអំណាចការឲ្យភត្តាហារ គ្រឿងស្លៀកដណ្តប់ ពូជនិងនង្គ័លជាដើម ។ បទថា **វិលបតេវ សោ ឆកោ** សេចក្តីថា កាលព្រះរាជាជាដើមនោះយកទ្រព្យទៅ បុគ្គលនោះ ក៏នៅកន្ទក់កន្ទេញនោះឯង ។ បទថា **ធីរោ** បានដល់ បណ្ឌិត ។ បទថា **សង្គណ្ហាតិ** បានដល់ រមែងសង្គ្រោះញាតិទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខ ដែលមកកាន់សម្នាក់របស់ខ្លួន ដោយការឲ្យភត្តាហារ គ្រឿងស្លៀកដណ្តប់ ពូជនិងនង្គ័លជាដើម ។ បទថា **តេន** សេចក្តីថា សប្បុរសនោះនឹងបានទទួលកិត្តិយសនិងការសរសើរក្នុងកណ្តាលបរិស័ទ ៤ កាលលះលោកនេះទៅហើយ នឹងត្រេកអរក្នុងទេវនគរ ដោយការសង្គ្រោះញាតិនោះ ។ ព្រះមហាសត្វ កាលសម្តែងធម៌ដល់ប្អូនប្រុសយ៉ាងនេះហើយ ក៏ទៅកាន់រោងទានដែលគេឈប់ធ្វើហើយ ឲ្យប្រព្រឹត្តទៅតាមប្រក្រតី ទើបទៅកាន់ព្រៃហិមពាន្ត មានឈានមិនវិនាស អនិច្ចកម្មហើយ បានចូលដល់ព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយទើបត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ អាគន្តុកសេដ្ឋី មិនមានកូនប្រុស កូនស្រី ព្រោះសម្លាប់កូនបងប្រុស ដោយហេតុនេះឯង ហើយទ្រង់ប្រជុំជាតកថា ប្អូនប្រុស

ក្នុងកាលនោះបានមកជាអាគន្តុកសេដ្ឋីក្នុងកាលឥឡូវនេះ ឯបងប្រុសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មយ្ហកសកុណជាតក ចប់

# បញ្ជិតរិហោបកជាតក

[ ២៣៦ ] ( ព្រះរាជាពារាណសីត្រាស់ថា ) អ្នកមានពណ៌ទ្រង់ទ្រាយដ៏ល្អ ផ្គងអញ្ជលីនមស្ការ តម្កល់នូវបុគ្គលមានរូបអាក្រក់អំពីខាងមុខ តើបុរសនោះ ប្រសើរជាងអ្នកឬប្រហែលគ្នា អ្នកចូរប្រាប់នូវឈ្មោះនៃអ្នកឯទៀតផង នៃខ្លួនផង ។

[ ២៣៧ ] ( ព្រះឥន្ទ្រពោលថា ) បពិត្រព្រះរាជា ទេវតាទាំងឡាយមិនកាន់យកនូវនាមនិងគោត្តព្រះខីណាស្រព អ្នកដល់នូវការស្ងប់ ទាំងប្រព្រឹត្តតាមផ្លូវត្រង់ ប៉ុន្តែខ្ញុំនឹងសូមប្រាប់ឈ្មោះ ( ខ្លួនខ្ញុំ ) ដល់ព្រះអង្គ ខ្ញុំជាសក្កៈជាធំជាងទេវតាជាន់តាវត្តិង្ស ។

[ ២៣៨ ] ( ព្រះរាជាសួរថា ) បុគ្គលណា ឃើញនូវភិក្ខុអ្នកបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បពិត្រទេវរាជ ខ្ញុំសូមសួរនូវដំណើរនុ៎ះ ចំពោះព្រះអង្គ បុគ្គលនោះ លុះច្យុតចាកលោកនេះទៅ រមែងបានសេចក្ដីសុខដូចម្ដេច ។

[ ២៣៩ ] ( ព្រះឥន្ទ្រឆ្លើយថា ) បុគ្គលណា ឃើញនូវភិក្ខុដែលបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បុគ្គលនោះរមែងបាននូវសេចក្ដីសរសើរក្នុងបច្ចុប្បន្ន លុះបុគ្គលនោះបែកធ្លាយសរីរកាយរមែងទៅកាន់ឋានសួគ៌ ។

[ ២៤០ ] ( ព្រះរាជាត្រាស់ថា ) ឱហ្ន៎ សិរីរបស់អញកើតឡើងក្នុងថ្ងៃនេះ ព្រោះអញបានឃើញនូវវាសវៈ ជាម្ចាស់នៃភូត បពិត្រសក្កៈ ខ្ញុំនឹងធ្វើនូវបុណ្យជាច្រើន ព្រោះបានឃើញនូវភិក្ខុផង ព្រះអង្គផង ។

[ ២៨១ ] ( ព្រះឥន្ទពោលថា ) បុគ្គលណាប្រកបដោយបញ្ញា ជាពហុស្សុត អាចគិតឃើញនូវហេតុជាច្រើន ( ព្រះអង្គ ) គប្បីសេពគប់ ( បុគ្គលនោះ ) ដោយពិត បពិត្រព្រះរាជា ព្រោះព្រះអង្គបានឃើញភិក្ខុនិងខ្ញុំ សូមធ្វើបុណ្យជាច្រើនចុះ ។

[ ២៨២ ] ( ព្រះរាជាត្រាស់ថា ) បពិត្រព្រះអង្គជាធំជាងទេវតា ខ្ញុំនឹងជាអ្នកមិនមានសេចក្តីក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកគួរដល់អ្នកដំណើរនិងស្នូមទាំងអស់ សង្កត់សង្កិននូវមានះ ថ្វាយបង្គំ ព្រោះបានស្តាប់នូវសុភាសិត ( របស់ព្រះអង្គ ) ។

**ចប់ បញ្ជិតវិហោឋកជាតកទី ៦ ។**

## អដ្ឋកថា

## បញ្ជិតវិហោឋកជាតក

[ ២៣៦-២៨២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោកត្ថចរិយា ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ឧព្វណ្ណរូបំ** ដូច្នេះជាដើម ។

រឿងនេះមានច្បាស់ក្នុងកណ្ហជាតក ។

កាលនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បំពេញប្រយោជន៍ដល់លោកដូចគ្នា ហើយទ្រង់នាំអតីតនិទាន មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិជាសក្កទេវរាជ កាលនោះ វិទ្យាធរម្នាក់ រាយមន្ត ហើយចូលទៅកាន់បន្ទប់ដ៏មានសិរី ក្នុងពេលរាត្រី ប្រព្រឹត្តកន្ទង់ក្នុងអគ្គមហេសីនៃព្រះបាទពារាណសី ។ ឯទាសីរបស់ព្រះនាងបាន ក្រាបទូលដល់ព្រះរាជា ។ ទើបព្រះនាងចូលគាល់ព្រះរាជាឯង ទូលថា បពិត្រព្រះសម្មតិទេព បុរសម្នាក់ ចូលមកក្នុងបន្ទប់ដ៏មានសិរីកណ្ដាលរាត្រី បំពានលើខ្ញុំម្ចាស់ ព្រះរាជាត្រាស់ថា នាងអាចធ្វើគ្រឿងសម្គាល់ គឺសញ្ញាណាមួយទុកលើបុរសនោះបានដែរឬទេ អគ្គមហេសីទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់អាច ។

ព្រះនាងឲ្យដាក់ទឹកល័ខក្នុងថាស គឺជាតិហិង្គុលមកឲ្យ កាលបុរសនោះមកក្នុងពេលរាត្រី រួមអភិរមហើយ ព្រះនាងប្រថាប់ម្រាមទាំង ៥ ត្រង់ខ្នងបានក្រាបទូលព្រះរាជាអំពីព្រលឹម ។ ព្រះរាជាបញ្ជាដល់មនុស្សទាំងឡាយថា អ្នកទាំងឡាយចូរទៅ ចូរនាំគ្នាពិនិត្យគ្រប់ទិស ហើយចាប់បុរសដែលមានស្នាមល័ខនៅលើខ្នង ។ចំណែកវិទ្យាធរ កាលធ្វើអនាចារក្នុងពេលយប់ហើយ ពេលថ្ងៃ ក៏ឈរជើងមួយ នមស្ការព្រះអាទិត្យត្រង់ទីរហោស្ថាន ។ រាជបុរសឃើញបុរសនោះហើយ ទើបនាំគ្នាព័ទ្ធ ។ បុរសនោះដឹងថា កម្មរបស់អញប្រាកដហើយ ទើបរាយវេទហោះទៅក្នុងអាកាស ។ ព្រះរាជា ទ្រង់ឃើញបុរសនោះហើយ ទើបត្រាស់សួររាជបុរសដែលមកហើយថា អ្នកទាំងឡាយបានឃើញដែរឬទេ រាជបុរសក្រាបទូលថា បានឃើញព្រះអង្គ ព្រះរាជាត្រាស់សួរថា គេនោះជានរណា ។ រាជបុរសទូលថា បពិត្រព្រះអង្គ ជាបព្វជិត ។

បានឮថា ពេលយប់បុរសនោះធ្វើអនាចារ តែពេលថ្ងៃ បុរសនោះនៅដោយភេទបព្វជិត ។ ព្រះរាជាទ្រង់ខ្ញាល់នឹងបព្វជិតទាំងឡាយថា បព្វជិតទាំងនេះ ពេលថ្ងៃប្រព្រឹត្តភេទសមណៈ ពេលយប់ធ្វើអនាចារ ហើយទ្រង់យល់ខុស ទើបទ្រង់ឲ្យវាយស្គរប្រកាសថា អ្នកទាំងឡាយត្រូវស្តាប់ព្រះរាជឱង្ការក្នុងទីដែលខ្លួនបានឃើញហើយថា បព្វជិតទាំងអស់ ចូរចៀសចេញអំពីអាណាចក្ររបស់យើង ទើបបព្វជិតទាំងអស់ គេចចេញអំពីដែនកាសីដែលមានទំហំ ៣០០ យោជន៍ បាននាំគ្នាទៅកាន់រាជធានីដទៃៗ ។ សមណ ព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ សូម្បីតែម្នាក់ដែលឲ្យឱវាទដល់មនុស្សទាំងឡាយ ក្នុងដែនកាសីមិនមាន ។ មនុស្សទាំងឡាយដែលមិនបានទទួលឱវាទ បានជាបុគ្គលពាលគ្រោតគ្រាត ។ មនុស្សទាំងឡាយ លះបង់ទាននិងសីលជាដើម ស្លាប់ហើយ ដោយច្រើនកើតក្នុងអបាយ ។ ឈ្មោះថា កើតក្នុងស្ថានសួគ៌មិនមាន ។ សក្កទេវរាជ កាលមិនឃើញ ទេវបុត្តថ្មីៗកើតឡើង ទើបប្រមើលមើលថា មានហេតុអ្វីហ្ន៎ ទ្រង់ជ្រាបថា ព្រះបាទពារាណសីទ្រង់ពិរោធ ព្រោះអាស្រ័យវិទ្យាធរ ទ្រង់បណ្តេញបព្វជិតចេញអំពីដែន ព្រោះទ្រង់យល់ខុស ទើបត្រិះរិះថា អ្នកដទៃក្រៅអំពីអញ ដែលអាចទម្លាយនូវការប្រកាន់ខុសនៃព្រះរាជាអង្គនេះមិនមាន អញនឹងជាទីពឹងរបស់ប្រជារាស្ត្រទាំងឡាយ ហើយបានយាងទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធទាំងឡាយ ត្រង់ញកភ្នំនន្ទមូលកៈ ទ្រង់ថ្វាយបង្គំហើយទូលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយឲ្យព្រះបច្ចេកពុទ្ធចាស់ជរាមួយអង្គដល់ខ្ញុំ ខ្ញុំនឹងឲ្យមហាជនក្នុងដែនកាសីជ្រះថ្លា ។ សក្កទេវរាជ

បានព្រះសង្ឃត្ថេរនោះឯង ។ ទើបទ្រង់ទទួលយកបាត្រនិងចីវររបស់ព្រះបច្ចេក ពុទ្ធនោះ ឲ្យលោកនៅអំពីខាងមុខ ទ្រង់នៅអំពីខាងក្រោយ ទ្រង់កាន់ឡាកេទ ជាមាណពដែលមានរូបឧត្តម ផ្គងអញ្ជលីលើសិរសា នមស្ការព្រះបច្ចេកពុទ្ធ បានហោះលើព្រះនគរទាំងមូល ៣ ជុំ មកដល់ទ្វារព្រះរាជវាំង បានប្រថាប់ ឈរលើអាកាស ។ អាមាត្យទាំងឡាយបានក្រាបទូលព្រះរាជាថា បពិត្រព្រះ សម្មតិទេព មាណពរូបស្អាតម្នាក់នាំសមណៈមួយរូប មកឈរលើអាកាស ត្រង់ទ្វារព្រះរាជវាំង ។ ទើបព្រះរាជាក្រោកចាកអាសនៈ ប្រថាប់ឈរត្រង់ បង្អួច ទ្រង់ចរចាជាមួយសក្កៈនោះថា នៃមាណព អ្នកមានរូបស្អាត ហេតុអ្វី ទើបឈរកាន់បាត្រនិងចីវររបស់សមណៈដែលមានរូបអាក្រក់ ហើយនមស្ការ ទៀត ដូច្នេះ ទើបត្រាស់ព្រះគាថាទី ១ ថា

> អ្នកមានពណ៌ទ្រង់ទ្រាយដ៏ល្អ ផ្គងអញ្ជលីនមស្ការ តម្កល់នូវ
> បុគ្គលមានរូបអាក្រក់អំពីខាងមុខ តើបុរសនោះ ប្រសើរជាង
> អ្នក ឬប្រហែលគ្នា អ្នកចូរប្រាប់នូវឈ្មោះនៃអ្នកឯទៀតផងនៃ
> ខ្លួនផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភិរូបវណ្ណី** បានដល់រូបស្អាត ។ បទថា **សេយ្យោ នុ តេ សោ** សេចក្តីថា បព្វជិតរូបអាក្រក់នោះ ល្អក្រៃលែងជាង អ្នកឬស្មើជាមួយអ្នក ។ បទថា **បរស្សត្តនោ ច** សេចក្តីថា ព្រះរាជាត្រាស់ សួរថា ចូរអ្នកប្រាប់ឈ្មោះរបស់អ្នកដទៃនោះនិងរបស់ខ្លួនចុះ ។

លំដាប់នោះ ទើបសក្កទេវរាជត្រាស់នឹងព្រះរាជានោះថា បពិត្រមហារាជ

ឈ្មោះថា សមណៈទាំងឡាយ រមែងជាបុគ្គលគួរគោរព ព្រោះហេតុនោះ ទើបខ្ញុំមិនបានហៅឈ្មោះរបស់លោក តែខ្ញុំនឹងប្រាប់ឈ្មោះរបស់ខ្ញុំដល់ទ្រង់ ហើយបានត្រាស់គាថាទី ២ ថា

បពិត្រព្រះរាជា ទេវតាទាំងឡាយមិនកាន់យកនូវនាមនិងគោត្ត
ព្រះខីណាស្រពអ្នកដល់នូវការស្ងប់ ទាំងប្រព្រឹត្តតាមផ្លូវត្រង់
ប៉ុន្តែខ្ញុំនឹងសូមប្រាប់ឈ្មោះ ( ខ្លួនខ្ញុំ ) ដល់ព្រះអង្គ ខ្ញុំជាសក្កៈ
ជាធំជាងទេវតាជាន់តាវត្តិង្ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមគ្គតានុជ្ជុគតាន ទេវា** សេចក្តីថា ឧបបត្តិទេពទាំងឡាយ នឹងមិនពាល់ត្រូវនូវឈ្មោះនិងគោត្តរបស់ព្រះខីណាស្រពទាំងឡាយ ដែលឈ្មោះថាសម្រេចនូវអគ្គផល ព្រោះពិចារណាសង្ខារទាំងឡាយដោយអំណាចនៃកិច្ចតាមសេចក្តីពិតហើយ សម្រេចអរហត្តផល ដែលជាផលដ៏ប្រសើរ ជាបុគ្គលទៅត្រង់ហើយ ព្រោះទៅកាន់ព្រះនិព្វាន ដោយមគ្គមានអង្គ ៨ ជាវិសុទ្ធិទេពដ៏កំពូលជាងឧបបត្តិទេពទាំងឡាយ ។

បទថា **អហញ្ច តេ នាមធេយ្យំ** បានដល់ តែខ្ញុំនឹងប្រាប់ឈ្មោះរបស់ខ្ញុំដល់ទ្រង់ ។

ព្រះរាជាស្តាប់ពាក្យនោះហើយ បានទូលដល់អានិសង្សនៃបុគ្គលនមស្ការភិក្ខុដោយគាថាទី ៣ ថា

បុគ្គលណា ឃើញនូវភិក្ខុអ្នកបរិបូណ៌ដោយចរណៈ ហើយ
ផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បពិត្រទេវរាជ ខ្ញុំ

សូមសួរនូវដំណើរនុ៎ះ ចំពោះព្រះអង្គ បុគ្គលនោះ លុះច្យុតចាក
លោកនេះទៅរមែងបានសេចក្តីសុខដូចម្តេច ដូច្នេះ ។

សក្កទេវរាជត្រាស់ឆ្លើយដោយគាថាទី ៤ ថា

បុគ្គលណា ឃើញនូវភិក្ខុដែលបរិបូណ៌ដោយចរណៈ ហើយ
ផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បុគ្គលនោះរមែង
បាននូវសេចក្តីសរសើរក្នុងបច្ចុប្បន្ន លុះបុគ្គលនោះបែកធ្លាយ
សរីរកាយ រមែងទៅកាន់ឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិក្ខុំ** បានដល់ បុគ្គលដែលបរិសុទ្ធ ព្រោះ
ទម្លាយកិលេសបានហើយ ។ បទថា **ចរណូបបន្នំ** បានដល់ ចូលដល់សីល
និងចរណៈ ។ បទថា **ឩិដ្ឋេវ ធម្មេ** បានដល់ មិនមែនចុតិអំពីលោកនេះតែ
ម្យ៉ាងប៉ុណ្ណោះ ទើបទៅកាន់ស្ថានសួគ៌ ទោះបីក្នុងអត្តភាពនេះ ក៏នឹងបានទទួល
ការសរសើរ គឺជួបនូវសេចក្តីសុខអំពីការសរសើរ ។

ព្រះរាជាទ្រង់ស្តាប់ទេវគាថារបស់សក្កៈហើយ កម្ចាត់បង់នូវការប្រកាន់
ខុសបាន ពេញព្រះរាជហឫទ័យ បានត្រាស់គាថាទី ៥ ថា

ឱហ្ន៎ សិរីរបស់អញកើតឡើងក្នុងថ្ងៃនេះ ព្រោះអញបានឃើញ
នូវវាសវៈ ជាម្ចាស់នៃភូត បពិត្រសក្កៈ ខ្ញុំនឹងធ្វើនូវបុណ្យជា
ច្រើន ព្រោះបានឃើញនូវភិក្ខុផង ព្រះអង្គផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លក្ខី** គឺបុណ្យ បានដល់សិរី មានពាក្យ
អធិប្បាយទុកថា ថ្ងៃនេះ បញ្ញាដែលដឹងវិបាករបស់កុសលនិងអកុសលកើត

ឡើងហើយដល់ខ្ញុំ ដែលបានស្តាប់ព្រះតម្រាស់របស់ទ្រង់នោះឯង ។ បទថា **យំ** ត្រឹមតែជានិបាត ។ បទថា **ភូតបតិទ្ទស្សាម** សេចក្តីថា ខ្ញុំបានឃើញលោកជាម្ចាស់នៃភូត ។

សក្កទេវរាជទ្រង់ស្តាប់ពាក្យនោះហើយ កាលទ្រង់ត្រេកអរនឹងបណ្ឌិតទើបត្រាស់គាថាទី ៦ ថា

បុគ្គលណាប្រកបដោយបញ្ញា ជាពហុស្សូត អាចគិតឃើញ
នូវហេតុជាច្រើន ( ព្រះអង្គ ) គប្បីសេពគប់ ( បុគ្គលនោះ )
ដោយពិត បពិត្រព្រះរាជា ព្រោះព្រះអង្គបាន ឃើញភិក្ខុនិង
ខ្ញុំ សូមធ្វើបុណ្យជាច្រើនចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុឋានចិន្តិនោ** សេចក្តីថា ដែលអាចគិតដល់ហេតុការណ៍បានសន្ទឹកសន្ធាប់ ។

ព្រះរាជាស្តាប់ព្រះតម្រាស់នោះហើយ ទើបត្រាស់គាថាចុងក្រោយថា

បពិត្រព្រះអង្គ ជាធំជាងទេវតា ខ្ញុំនឹងជាអ្នកមិនមានសេចក្តី
ក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកគួរដល់អ្នកដំណើរនិងស្មូម
ទាំងអស់ សង្កត់សង្កិននូវមានះ ថ្វាយបង្គំ ព្រោះបានស្តាប់នូវ
សុភាសិត ( របស់ព្រះអង្គ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សព្វាតិថីយាចយោគោ ភវិត្វា** សេចក្តីថា បណ្តាភ្ញៀវទាំងឡាយ គឺអាគន្តុកៈទាំងឡាយដែលមកហើយទាំងអស់ មនុស្សទាំងនោះ សូមនូវវត្ថុណា បុគ្គលនោះ ក៏ជាអ្នកសមគួរ គឺសមគួរដល់វត្ថុ

នោះៗ អធិប្បាយថា ឲ្យវត្ថុទាំងអស់ដល់ជនដែលសូមហើយ ។ បទថា **សុត្វាន គាថា សុភាសិតានិ** សេចក្ដីថា ព្រះរាជាទូលថា ខ្ញុំស្ដាប់សុភាសិតរបស់ទ្រង់ហើយ នឹងជាបុគ្គលបែបនេះ ។

ព្រះរាជាកាលត្រាស់យ៉ាងនេះ ក៏ចុះអំពីប្រាសាទ ថ្វាយបង្គំព្រះបច្ចេកពុទ្ធ ហើយបានប្រជាប់ឈរក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះបច្ចេកពុទ្ធអង្គុយពត់ភ្នែនក្នុងអាកាសហើយទូន្មានព្រះរាជាថា ថ្វាយព្រះពរមហាបពិត្រ វិទ្យាធរនោះ មិនមែនជាសមណៈ ចាប់ពីពេលនេះទៅ សូមទ្រង់ជ្រាបទុកថា លោកសន្និវាសមិនទទេឡើយ គង់មានសមណព្រាហ្មណ៍ដែលទ្រទ្រង់សីល ហើយសូមទ្រង់ឲ្យទាន រក្សាសីល ធ្វើឧបោសថកម្មចុះ ឯសក្កៈប្រថាប់ ឈរត្រង់អាកាសដោយអានុភាពរបស់សក្កៈ ប្រទានឱវាទដល់អ្នកនគរថា តាំងអំពីនេះទៅ អ្នកទាំងឡាយ ចូរកុំប្រមាទ ហើយទ្រង់ឲ្យវាយស្គរប្រកាសថា សមណព្រាហ្មណ៍ទាំងឡាយដែលគេចទៅហើយ សូមត្រឡប់មក ។ ជនទាំង ២ គឺសក្កទេវរាជនិងព្រះបច្ចេកពុទ្ធបានយាងទៅកាន់លំនៅរបស់ខ្លួន ព្រះរាជាតាំងនៅក្នុងឱវាទរបស់សក្កៈនោះហើយបានធ្វើបុណ្យទាំងឡាយមានទានជាដើម ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានទៅហើយ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា បញ្ជិតវិហេឋកជាតក ចប់**

# ឧបសិង្ឃបុប្ផជាតក

[ ២៤៣ ] ( នាងទេពធីតាពោលថា ) បពិត្រលោក លោកស្រូបក្លិនផ្កាកើតអំពីទឹក ( ផ្កាឈូក ) ដែលគេមិនបានឲ្យ នុ៎ះជាចំណែកមួយនៃការលួច លោកជាអ្នកលួចក្លិន ។

[ ២៤៤ ] ( តាបសពោធិសត្វពោលថា ) អាត្មាមិនលួចទេ មិនកាច់យកទេ អាត្មាគ្រាន់តែស្រូបក្លិនផ្កាឈូកអំពីចម្ងាយ កាលបើដូច្នេះ ហេតុអ្វីទើបអ្នកពោលថា លោកជាអ្នកលួចក្លិន ។

[ ២៤៥ ] បុរសណាជីកយកក្រអៅឈូក កាច់យកផ្កាឈូកស បុរសនោះ ដែលមានការងារអាក្រក់យ៉ាងនេះ ព្រោះហេតុអ្វី ក៏អ្នកមិនថា ។

[ ២៤៦ ] ( នាងទេពធីតាពោលថា ) ពាក្យសម្ដីរបស់ខ្ញុំ មិនមានចំពោះបុរស ដែលជាអ្នកល្មោភអាក្រក់ ប្រឡាក់ ( ដោយបាបធម៌ ) ដូចជាសំពត់មេនំទេ ខ្ញុំគួរនិយាយតែនឹងលោក ។

[ ២៤៧ ] បាបរបស់បុរសអ្នកមិនមានទីទួលគឺកិលេស អ្នកស្វែងរកនូវអំពើដ៏ស្អាតជានិច្ច ប្រមាណប៉ុនចុងនៃរោមកន្ទុយសត្វ រមែងប្រាកដដូចប៉ុនមេឃ ។

[ ២៤៨ ] ( តាបសពោធិសត្វពោលថា ) ម្នាលយក្ខ នាងស្គាល់នូវអាត្មាដោយពិត មួយទៀត នាងឈ្មោះថាអនុគ្រោះនូវអាត្មា ម្នាលយក្ខ បើនាងឃើញទោសនេះ ក្នុងកាលណា នាងគប្បីប្រាប់ ( ដល់អាត្មា ) ទៀតក្នុងកាលនោះ ។

[ ២៤៩ ] ( នាងទេពធីតាពោលថា ) ខ្ញុំមិនមែនរស់នៅព្រោះអា-

ស្រ័យលោកទេ ទាំងមិនមែនជាអ្នកធ្វើការឈ្នួលរបស់លោកទេ បពិត្រភិក្ខុ លោកទៅកាន់សុគតិ ដោយអំពើណា លោកគប្បីដឹង ( នូវអំពើនោះចុះ ) ។

**ចប់ ឧបសិង្ឃបុប្ផជាតកទី ៧ ។**

## អដ្ឋកថា

## ឧបសិង្ឃបុប្ផជាតក

[ ២៨៣-២៨៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **យមេតំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុរូបនោះ កាលចេញអំពីព្រះវិហារជេតពនទៅ អាស្រ័យនៅក្នុងព្រៃមួយកន្លែង ក្នុងកោសលរដ្ឋ ។ ថ្ងៃមួយ ចុះកាន់ស្រះឈូក ឃើញផ្កាឈូករីកល្អ ទើបឈរហិតផ្កាក្នុងទីក្រោមខ្យល់ ។ លំដាប់នោះ ទេវតាដែលអាស្រ័យនៅក្នុងដងព្រៃនោះ ឃើញភិក្ខុនោះ ក៏សង្វេគ ពោលថា បពិត្រលោកម្ចាស់អ្នកនិទ្រិក្ខ លោកម្ចាស់ឈ្មោះថាជាអ្នកលួចក្លិន នេះជាអង្គប្រកបមួយនៃការលួចរបស់លោក ។ ភិក្ខុនោះ កាលទេវតានោះធ្វើឲ្យសង្វេគហើយ ទើបមកកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា ហើយអង្គុយនាចំណែកម្ខាង ត្រូវព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ អ្នកនៅក្នុងទីណា ភិក្ខុនោះក្រាបទូលថា នៅត្រង់ដងព្រៃឈ្មោះនោះ ទេវតាត្រង់ដងព្រៃនោះឯង ឲ្យខ្ញុំព្រះអង្គសង្វេគយ៉ាងនេះ ។ កាលនោះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ មិនមែនតែអ្នកប៉ុណ្ណោះ ដែលហិតក្លិនផ្កា ត្រូវទេវតាធ្វើឲ្យសង្វេគ សូម្បីបណ្ឌិតក្នុង

កាលមុន ទេវតាក៏ធ្លាប់ធ្វើឲ្យសង្វេគមកហើយដូចគ្នា កាលភិក្ខុនោះអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីត មកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ត្រង់ស្រុកមួយ ក្នុងដែនកាសី ធំចម្រើនវ័យហើយ រៀនសិប្បៈក្នុងនគរតក្កសិលា តមក បានបួសជាឥសី ចូលទៅអាស្រ័យស្រះឈូកមួយ ។ ថ្ងៃមួយ បានចុះកាន់ស្រះនោះ បានឈរហិតផ្កាឈូកដែលរីកល្អ ។ កាលនោះ ទេពធីតាមួយរូបស្ថិតនៅត្រង់ដើមឈើមួយដើម កាលនឹងឲ្យតាបសសង្វេគ បានពោលគាថាទី ១ ថា

បពិត្រលោក លោកស្រង់ក្លិនផ្កាកើតអំពីទឹក ( ផ្កាឈូក )
ដែលគេមិនបានឲ្យ នុ៎ះជាចំណែកមួយនៃការលួច លោកជា
អ្នកលួចក្លិន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯកង្គមេតំ** បានដល់ នុ៎ះជាចំណែកមួយ ។ លំដាប់នោះទើបព្រះពោធិសត្វពោលគាថាទី ២ ថា

អាត្មាមិនលួចទេ មិនកាច់យកទេ អាត្មាគ្រាន់តែស្រង់ក្លិនផ្កាឈូក
អំពីចម្ងាយ កាលបើដូច្នេះ ហេតុអ្វីទើបអ្នកពោលថា លោក
ជាអ្នកលួចក្លិន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អារា សិង្ឃាមិ** បានដល់ ខ្ញុំឈរហិតក្នុងទីឆ្ងាយ ។ បទថា **វណ្ណេន** បានដល់ ហេតុ ។

ខណៈនោះ បុរសម្នាក់ជកក្រអៅឈូក និងកាច់ផ្កាបុណ្ឌរិកក្នុងស្រះនោះ

ព្រះពោធិសត្វឃើញហើយ ក៏ចរចាជាមួយទេពធីតានោះថា នាងពោលមករកខ្ញុំដែលឈរហិតក្នុងទីឆ្ងាយថាជាចោរ តែហេតុអ្វី មិនស្តីថាបុរសនោះ ទើបពោលគាថាទី ៣ ថា

បុរសណាជីកយកក្រអៅឈូក កាច់យកផ្កាឈូកស បុរសនោះ ដែលមានការងារអាក្រក់យ៉ាងនេះ ព្រោះហេតុអ្វី ក៏អ្នកមិនថា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាកិណ្ណកម្មន្តោ** បានដល់ មានការងារគ្រោតគ្រាត គឺមានការងារថោកថយ ។

លំដាប់នោះ ទេវតាកាលនឹងប្រាប់ហេតុនៃការពោលដល់ព្រះពោធិសត្វនោះ បានពោលគាថាទី ៤ និងទី ៥ ថា

ពាក្យសម្តីរបស់ខ្ញុំ មិនមានចំពោះបុរសដែលជាអ្នកល្មោភអាក្រក់ ប្រឡាក់ ( ដោយបាបធម៌ ) ដូចជាសំពត់មេទំទេ ខ្ញុំគួរនិយាយតែនឹងលោក ។

បាបរបស់បុរស អ្នកមិនមានទីទួលគឺកិលេស អ្នកស្វែងរកនូវអំពើដ៏ស្អាតជានិច្ច ប្រមាណប៉ុនចុងនៃរោមកន្ទុយសត្វ រមែងប្រាកដដូចប៉ុនមេឃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធាតិចោលំវ** សេចក្តីថា បុគ្គលនេះ ជាអ្នកប្រឡាក់ទៅដោយបាប ដូចគ្នានឹងសំពត់កីលៀងប្រឡាក់ទឹកមាត់ ទឹកសំបោរ មូត្រ និងលាមក ព្រោះហេតុនោះ ទើបខ្ញុំមិនថាអ្វីក្នុងរឿងនោះ ។ បទថា

**តញ្ចារហាមិ** សេចក្តីថា តែសមណៈទាំងឡាយ ជាអ្នកមានសីលជាទីស្រឡាញ់ ជាអ្នកប្រាថ្នាចំពោះឱវាទ បពិត្រសមណៈ ព្រោះដូច្នោះ ទើបខ្ញុំគួរពោលនឹងបុគ្គលដែលធ្វើវត្តមិនសមគួរមានប្រមាណតិច ។ បទថា **អនង្គ-ណស្ស** បានដល់ បុគ្គលដូចអ្នកដែលមិនមានទោស ។ បទថា **អព្ភាមត្តំវ ខាយតិ** សេចក្តីថា បាបនឹងប្រាកដជារបស់មានប្រមាណប៉ុនមហាមេឃ ។ ឥឡូវនេះ ហេតុអ្វីទើបអ្នកធ្វើទោសបែបនេះឲ្យជាអញ្ចោហារិក ដូចជាមិនមានទោស ។

ចំណែកព្រះពោធិសត្វ ត្រូវទេវតាឲ្យសង្វេគ បានដល់នូវសេចក្តីសង្វេគ ហើយបានពោលគាថាទី ៦ ថា

ម្នាលយក្ខ នាងស្គាល់នូវអាត្មាដោយពិត មួយទៀត នាង
ឈ្មោះថាអនុគ្រោះនូវអាត្មា ម្នាលយក្ខ បើនាងឃើញទោស
នេះក្នុងកាលណា នាងគប្បីប្រាប់ ( ដល់អាត្មា ) ទៀតក្នុង
កាលនោះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅនេះថា ព្រះពោធិសត្វហៅទេវតាថាជាយក្ខ ។ បទថា **វជ្ជាសិ** បានដល់ នាងគប្បីពោល ។ បទថា **យថា បស្សសិ ឯទិសំ** សេចក្តីថា ព្រះពោធិសត្វពោលថា កាលណា នាងឃើញទោសបែបនេះរបស់ខ្ញុំ កាលនោះ នាងគប្បីពោលយ៉ាងនេះឯង ។

លំដាប់នោះ ទេពធីតាពោលគាថាទី ៧ ដល់ព្រះពោធិសត្វថា

ខ្ញុំមិនមែនរស់នៅព្រោះអាស្រ័យលោកទេ ទាំងមិនមែនជាអ្នក

ធ្វើការឈ្នួលរបស់លោកទេ បពិត្រភិក្ខុ លោកទៅកាន់សុគតិ
ដោយអំពើណា លោកគប្បីដឹង ( នូវអំពើនោះចុះ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភតិកម្មាសេ** សេចក្តីថា ទេពធីតាសម្តែងថា ខ្ញុំមិនមែនជាកូនឈ្នួលរបស់លោក គឺមិនជាអ្នកធ្វើការងារដើម្បីស៊ីឈ្នួលរបស់លោក ខ្ញុំនឹងត្រាច់រក្សាលោកគ្រប់កាលដោយហេតុអ្វី ។ បទថា **យេន គច្ឆេយ្យ** សេចក្តីថា បពិត្រភិក្ខុ លោកគប្បីទៅកាន់សុគតិដោយកម្មឯណា លោកនោះឯងគប្បីដឹង ( ឯង ) ។

ទេវតា កាលឲ្យឱវាទដល់ព្រះពោធិសត្វយ៉ាងនេះហើយ ក៏ត្រឡប់ចូលកាន់វិមានរបស់ខ្លួន ។ ឯព្រះពោធិសត្វ ញ៉ាំងឈានឲ្យកើតហើយ បានជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចធម៌ទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ទេពធីតាក្នុងកាលនោះ បានមកជានាងឧប្បលវណ្ណាថេរីក្នុងកាលឥឡូវនេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ឧបសិង្ឃបុប្ផជាតក ចប់

# វិឃាសាទជាតក

[ ២៥០ ] ( ព្រះឥន្ទ្រក្លែងខ្លួនជាសេកនិយាយថា ) ពួកជនណា ជាអ្នកស៊ីវត្ថុសល់ដែល ជននោះ រមែងរស់នៅជាសុខស្រួល សេចក្ដីសរសើរក្នុងបច្ចុប្បន្ននិងសុគតិក្នុងបរលោក រមែងមាន ។

[ ២៥១ ] ( ឥសីមួយរូបពោលថា ) អ្នកទាំងឡាយជាបណ្ឌិត ចូរកុំផ្ទៀងស្ដាប់ ( នូវសម្ដី ) របស់សេកនិយាយ ម្នាលអ្នកមានពោះដ៏ស្មើទាំងឡាយ ពួកអ្នកចូរស្ដាប់ពាក្យខ្ញុំនេះវិញ សេកនេះបញ្ឆោរនូវពួកយើងទេ ។

[ ២៥២ ] ( សេកនិយាយថា ) ខ្ញុំមិនបញ្ឆោរលោកទាំងឡាយទេ បពិត្រលោកអ្នកបរិភោគនូវសាកសព លោកទាំងឡាយចូរស្ដាប់ខ្ញុំ លោកទាំងឡាយ ជាអ្នកបរិភោគនូវភោជនសល់ លោកទាំងឡាយមិនមែនជាអ្នកបរិភោគនូវវត្ថុសល់ដែលទេ ។

[ ២៥៣ ] ( ពួកឥសីនិយាយថា ) យើងទាំងឡាយបួសបានវស្សា ៧ ហើយ ជាអ្នកមានកំប៉ោយសក់ នៅក្នុងកណ្ដាលព្រៃ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយវត្ថុដ៏សល់ប៉ុណ្ណោះ បើពួកយើងត្រូវអ្នកដ៏ចម្រើនតិះដៀលហើយ តើពួកជនណា គួរជាទីសរសើររបស់លោកដ៏ចម្រើន ។

[ ២៥៤ ] ( សេកពោធិសត្វពោលថា ) លោកទាំងឡាយ បរិភោគនូវភោជនសល់របស់សត្វសាហាវ គឺសីហៈនិងខ្លា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយរបស់សល់ ទើបគេសម្គាល់ថាជាអ្នកបរិភោគរបស់សល់ដែល ។

[ ២៥៥ ] ពួកជនណាឲ្យដល់ព្រាហ្មណ៍ សមណៈ និងអ្នកសូមឯទៀត ហើយទើបបរិភោគនូវភោជនដ៏សេសសល់ ពួកជននោះហៅថាជាអ្នកបរិភោគ

នូវវត្ថុសល់ដែល ។

**ចប់ វិឃាសាទជាតកទី ៨ ។**

## អដ្ឋកថា

## វិឃាសាទជាតក

[ ២៥០-២៥៥ ] ព្រះសាស្តា កាលគង់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធភិក្ខុដែលមានសីលគួរចំអក ហើយត្រាស់រឿងនេះ មានពាក្យផ្តើមថា **សុសុខំ វត ជីវន្តិ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា កាលព្រះមហាមោគ្គល្លានត្ថេរ ញុំាំងប្រាសាទឲ្យញាប់ញ័រ ហើយឲ្យភិក្ខុទាំងនោះសង្វេគ ភិក្ខុទាំងឡាយនាំគ្នាអង្គុយ ពោលទោសដែលមិនមែនជាគុណរបស់ភិក្ខុទាំងនោះ ក្នុងធម្មសភា ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះ ក៏ជាអ្នកមានសីលជាទីចំអក ( មាននិស្ស័យឡេះឡោះ ) ដូចគ្នា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិជាសក្កទេវរាជ ក្នុងកាលនោះ បងប្អូន ៧ នាក់ ក្នុងកា-

សិកគ្រាម ឃើញទោសក្នុងកាមទាំងឡាយ នាំគ្នាបួសជាឥសីក្នុងព្រៃ មិនធ្វើសេចក្តីព្យាយាមក្នុងយោគៈ ជាអ្នកច្រើនទៅ ដោយការធ្វើពងកាយឲ្យរឹងមាំ ត្រាច់លេងកីឡាច្រើនប្រការ សក្កទេវរាជ ទ្រង់ព្រះតម្រិះថា អញនឹងឲ្យភិក្ខុទាំងនេះសង្វេគ ហើយទ្រង់កាឡាខ្លួនជាសត្វសេក យាងមកដល់លំនៅរបស់ភិក្ខុទាំងនោះ ពួនត្រង់ដើមឈើមួយ កាលឲ្យភិក្ខុទាំងនោះសង្វេគ ទើបពោលគាថា ទី ១ ថា

ពួកជនណា ជាអ្នកស៊ីវត្ថុសល់ដែល ជននោះរមែងរស់នៅ
ជាសុខស្រួល សេចក្តីសរសើរក្នុងបច្ចុប្បន្ន និងសុគតិ ក្នុងបរ-
លោករមែងមាន ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះថា បទថា **វិឃាសាទិនោ** សត្វសេក ពោលសំដៅដល់ពួកអ្នកស៊ីអាហារដែលសល់ពីអ្នកដទៃស៊ីហើយ ។ បទថា **ទិដ្ឋេវ ធម្មេ** សេចក្តីថា ជនបែបនេះក្នុងបច្ចុប្បន្ននេះ ក៏គួរសរសើរនោះឯង ក្នុងសម្បរាយភព អ្នកទាំងនោះ ក៏មានសុគតិ គឺសេកពោលដោយអធិប្បាយថា ពួកជនទាំងនោះ កើតក្នុងស្ថានសួគ៌ ។

លំដាប់នោះ បណ្តាឥសីទាំងនោះ ឥសីម្នាក់បានឮពាក្យរបស់សេកនោះហើយ ទើបហៅឥសីដ៏សេស ពោលគាថាទី ២ ថា

អ្នកទាំងឡាយជាបណ្ឌិត ចូរកុំផ្ទៀងស្តាប់ ( នូវសម្តី ) របស់
សេកនិយាយ ម្នាលអ្នកមានពោះដ៏ស្មើទាំងឡាយ ពួកអ្នកចូរ
ស្តាប់ពាក្យខ្ញុំនេះវិញ សេកនេះបញ្ឆោរនូវពួកយើងទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភាសមានស្ស** សេចក្ដីថា កាលសត្វសេកពោលដោយពាក្យរបស់មនុស្ស ។ បទថា **ន និសាមេថ** បានដល់ មិនស្ដាប់ ។ បទថា **ឥធំ សុណាថ** សេចក្ដីថា សូមអ្នកទាំងឡាយស្ដាប់ពាក្យនេះរបស់សេកនោះ ។ តាបសហៅអ្នកទាំងនោះថា **សោទរិយា** គឺបងប្អូនរួមឧទរព្រោះភាពជាអ្នកនៅហើយក្នុងឧទរស្មើគ្នា ។

កាលនោះ សត្វសេកហាមអ្នកទាំងនោះ ទើបពោលគាថាទី ៣ ថា

ខ្ញុំមិនបញ្ឆោរលោកទាំងឡាយទេ បពិត្រលោកអ្នកបរិភោគនូវសាកសព លោកទាំងឡាយ ចូរស្ដាប់ខ្ញុំ លោកទាំងឡាយជាអ្នកបរិភោគនូវភោជនសល់ លោកទាំងឡាយ មិនមែនជាអ្នកបរិភោគនូវវត្ថុសល់ដែលទេ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅនេះថា សត្វសេកហៅមនុស្សទាំងនោះថា **កុណបខាទា** សេចក្ដីថា ជាអ្នកស៊ីសាកសព ។

មនុស្សទាំងនោះ បានស្ដាប់ពាក្យនោះហើយ បាននាំគ្នាពោលគាថាទី ៤ ថា

យើងទាំងឡាយ បួសបានវស្សា ៧ ហើយ ជាអ្នកមានកំប៉ោយសក់ នៅក្នុងកណ្ដាលព្រៃ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដ៏សល់ប៉ុណ្ណោះ បើពួកយើង ត្រូវអ្នកដ៏ចម្រើនតិះដៀលហើយ តើពួកជនណា គួរជាទីសរសើររបស់លោកដ៏ចម្រើន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សិខណ្ឌិនោ** បានដល់ ប្រកបដោយផ្នួងសក់ ។ បទថា **វិឃាសេនេវ** សេចក្ដីថា ពួកយើងកាលចិញ្ចឹមជីវិតដោយអាហារដែលជាសំណល់របស់រាជសីហ៍និងខ្លាធំតែម្យ៉ាងអស់ ៧ ឆ្នាំ អស់កាលប៉ុណ្ណេះ បើជាបុគ្គលដែលអ្នកគប្បីតិះដៀលសោត អ្នកណាវិញ ជាបុគ្គលដែលអ្នកគួរសរសើរ ។

ព្រះមហាសត្វ កាលឲ្យឥសីទាំងនោះសង្វេគ ទើបពោលគាថាទី ៥ ថា

លោកទាំងឡាយ បរិភោគនូវភោជនសល់របស់សត្វសាហាវ
គឺសីហៈនិងខ្លា ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយរបស់សល់
ទើបគេសម្គាល់ថា ជាអ្នកបរិភោគរបស់សល់ដែល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វាឡានញ្ចាវសិដ្ឋកំ** បានដល់របស់ដ៏សេសគឺភោជនដែលសល់របស់សត្វសាហាវទាំងឡាយផង ។

តាបសទាំងឡាយ បានស្ដាប់ពាក្យនោះហើយ ទើបពោលថា បើពួកយើងមិនជាអ្នកស៊ីដែលសោត បើយ៉ាងនេះ អ្នកតិះដៀលនរណា នរណាជាអ្នកស៊ីដែល ។

លំដាប់នោះ ព្រះមហាសត្វ កាលនឹងប្រាប់សេចក្ដីនោះដល់តាបស បានពោលគាថាទី ៦ ថា

ពួកជនណាឲ្យដល់ព្រាហ្មណ៍ សមណៈ និងអ្នកសូមឯទៀត
ហើយទើបបរិភោគនូវភោជនដ៏សេសសល់ ពួកជននោះ ហៅ
ថា ជាអ្នកបរិភោគនូវវត្ថុសល់ដែល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វណិព្វិតោ** បានដល់ អ្នកសូមរបស់នោះៗ ព្រះពោធិសត្វ កាលឲ្យតាបសទាំងនោះសង្រ្គោះហើយ ទើបទៅលំនៅរបស់ខ្លួននោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា បងប្អូនប្រុស ៧ នាក់ក្នុងកាលនោះ បានមកជា ភិក្ខុទាំងឡាយដែលមានសីលគួរចំអកទាំងនេះ ក្នុងកាលឥឡូវនេះ ឯសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វិឃាសាទជាតក ចប់

## វដ្ដកជាតក

[ ២៥៦ ] ( ចាបពោធិសត្វសួរថា ) បពិត្រឪពុកធំ លោកបរិភោគនូវបាយ ទឹកដោះរាវ និងប្រេងដ៏ប្រណីត បពិត្រក្អែក កាលបើដូច្នេះ ហេតុអ្វីបានជាអ្នកស្គាំងស្គមម្ល៉េះ ។

[ ២៥៧ ] ( ក្អែកឆ្លើយថា ) បណ្ដាពួកក្អែកទាំងនោះ សត្វក្អែកនៅក្នុងកណ្ដាលសត្រូវ ស្វែងរកចំណី មានសេចក្ដីតក់ស្លុតជានិច្ច តើនឹងមានសេចក្ដីមាំមួនអំពីណាកើត ។

[ ២៥៨ ] ពួកក្អែក ជាសត្វមានពុតត្បុត តក់ស្លុតអស់កាលជានិច្ច បានដុំបាយដោយអំពើអាក្រក់ មិនដែលឆ្អែតស្កប់ស្កល់ទេ ម្នាលសត្វចាប ព្រោះហេតុនោះ ទើបខ្ញុំស្គាំងស្គម ។

[ ២៥៩ ] ម្នាលចាប អ្នកបរិភោគនូវពូជស្មៅដ៏សៅហ្មង មានឱជារសតិច កាលបើដូច្នេះ ហេតុអ្វីទើបអ្នកមានសរីរៈធាត់ម្ល៉េះ ។

[ ២៦០ ] ( ចាបពោធិសត្វពោលថា ) ម្នាលក្អែក ខ្ញុំញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលខ្ញុំបាន និងមិនបាន ព្រោះខ្ញុំជាអ្នកប្រាថ្នាតិច គិតតិច ទាំងត្រាច់ទៅកាន់ទីមិនឆ្ងាយ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកមានសរីរៈធាត់ ។

[ ២៦១ ] សេចក្ដីពិតថា ការប្រព្រឹត្តចិញ្ចឹមជីវិតរបស់បុគ្គលអ្នកប្រាថ្នាតិចផង មានសេចក្ដីសុខព្រោះការគិតតិចផង ដឹងប្រមាណក្នុងអាហារដែលខ្លួនកាន់យកដោយល្អផង រមែងប្រព្រឹត្តទៅបានដោយស្រួល ។

**ចប់ វដ្ដកជាតកទី ៩ ។**

# អដ្ឋកថា

## វដ្តកជាតក

[ ២៥៦-២៦១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុល្មោភល្មោះមួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **បណីតំ** ដូច្នេះជាដើម ។

ព្រះសាស្តាត្រាស់សួរថា បានឮថា អ្នកជាបុគ្គលល្មោភល្មោះពិតឬ កាលភិក្ខុនោះក្រាបទូលថា ពិតហើយព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលល្មោភល្មោះដូចគ្នា ព្រោះភាពជាអ្នកល្មោភល្មោះនោះឯង អ្នកមិនឆ្អែតក្នុងសាកសពដំរីសាកសពគោ សាកសពសេះ និងសាកសពមនុស្សទាំងឡាយក្នុងនគរពារាណសី ទើបចូលទៅកាន់ព្រៃដោយគិតថា អញនឹងបានក្រៃលែងឡើងៗ ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតចាប មានស្មៅ និងធញ្ញជាតិដែលគ្រោតគ្រាតជាអាហារ អាស្រ័យនៅក្នុងព្រៃ ។ កាលនោះក្នុងក្រុងពារាណសី មានក្អែកល្មោភល្មោះមួយ មិនឆ្អែតដោយសាកសព មានសពដំរីជាដើមគិតថា អញនឹងបានទទួលអាហារច្រើនក្រៃលែងជាងនេះទើបចូលទៅកាន់ព្រៃ ស៊ីផ្លែឈើតូចធំ ឃើញព្រះពោធិសត្វ គិតថា ចាបនេះ មានរាងកាយធាត់ពន់ពេកប្រហែលជាស៊ីចំណីឆ្ងាញ់ អញនឹងសួរដល់ចំណីរបស់ចាបនេះ ស៊ីចំណីនោះហើយ នឹងបានធាត់ ទំត្រង់មែកឈើខាងលើព្រះពោធិសត្វ ហើយសួរព្រះ

ពោធិសត្វថា នែចាបដ៏ចម្រើន អ្នកស៊ីអាហារប្រណីតឬ ទើបមានរាងកាយធាត់ ព្រះពោធិសត្វត្រូវក្អែកឡេះឡោះសួរ កាលធ្វើបដិសណ្ឋារៈជាមួយក្អែកនោះ ទើបពោលគាថាទី ១ ថា

បពិត្រឪពុកធំ លោកបរិភោគនូវបាយ ទឹកដោះរាវ និងប្រេង
ដ៏ប្រណីត បពិត្រក្អែក កាលបើដូច្នេះ ហេតុអ្វីបានជាអ្នកស្គាំង
ស្គមម៉្លេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភត្តំ** បានដល់ ភត្តដែលគេត្រៀមទុកតាមទំនងកោជនរបស់មនុស្សទាំងឡាយ ។ ព្រះពោធិសត្វហៅក្អែកនោះថា **មាតុល** គឺហៅដោយសេចក្តីស្រឡាញ់ ។ បទថា **កិសោ** បានដល់ មានសាច់និងឈាមតិច ។ ក្អែកបានស្តាប់ពាក្យរបស់ចាបនោះហើយ ទើបពោលគាថា ៣ ថា

បណ្តាពួកក្អែកទាំងនោះ សត្វក្អែក នៅក្នុងកណ្តាលសត្រូវ
ស្វែងរកចំណី មានសេចក្តីតក់ស្លុតជានិច្ចតើនឹងមានសេចក្តីមាំ
មួន អំពីណាកើត ។

ពួកក្អែក ជាសត្វមានពុតត្បុត តក់ស្លុតអស់កាលជានិច្ច
បានដុំបាយ ដោយអំពើអាក្រក់ មិនដែលឆ្អែតស្កប់ស្កល់ទេ
ម្នាលសត្វចាប ព្រោះហេតុនោះ ទើបខ្ញុំស្គាំងស្គម ។

ម្នាលចាប អ្នកបរិភោគនូវពូជស្មៅដ៏សៅហ្មង មានឱជារស
តិច កាលបើដូច្នេះ ហេតុអ្វីទើបអ្នកមានសរីរៈធាត់ម៉្លេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទ្ធិយំ** សេចក្ដីថា សម្រាប់ខ្ញុំដែលជាក្អែកនឹងមានសេចក្ដីមាំទាំមកអំពីណា អធិប្បាយថា នឹងធាត់មកអំពីណា ។ បទថា **ឧត្តិគ្គិណោ** បានដល់ តក់ស្លុត ។ បទថា **ធង្ក** បានដល់ ជាឈ្មោះរបស់ក្អែកទាំងឡាយនោះឯង ។ បទថា **ធាបេន កម្មុនា លទ្ធោ** សេចក្ដីថា ដុំបាយដែលក្អែកបានមកដោយកម្មដ៏លាមក គឺដណ្ដើមយករបស់អ្នកដទៃមក ។ បទថា **ន បីណេតិ** សេចក្ដីថា មិនឆ្អែត ។ បទថា **តេនស្មិ** សេចក្ដីថា ព្រោះហេតុនោះទើបខ្ញុំស្គម ។ បទថា **អប្បស្នេហានិ** សេចក្ដីថា មានខ្លាញ់តិចតួច ។ ក្អែកជាអ្នកសម្គាល់ថា ចាបស៊ីចំណីប្រណីត កាលនឹងសួរដល់ចំណីតាមប្រក្រតីរបស់ចាបទាំងឡាយជាមួយព្រះពោធិសត្វ ទើបពោលពាក្យនេះ ។

ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយ កាលប្រាប់ហេតុដែលខ្លួនធាត់ ទើបពោលគាថាទាំងនេះថា

> ម្នាលក្អែក ខ្ញុំញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលខ្ញុំបាន និងមិនបាន ព្រោះខ្ញុំជាអ្នកប្រាថ្នាតិច គិតតិច ទាំងត្រាច់ទៅកាន់ទីមិនឆ្ងាយ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកមានសរីរៈធាត់ ។
>
> សេចក្ដីពិតថា ការប្រព្រឹត្តចិញ្ចឹមជីវិតរបស់បុគ្គលអ្នកប្រាថ្នាតិចផង មានសេចក្ដីសុខព្រោះការគិតតិចផង ដឹងប្រមាណក្នុងអាហារ ដែលខ្លួនកាន់យកដោយល្អផង រមែងប្រព្រឹត្តទៅបានដោយស្រួល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អប្បិច្ឆា** សេចក្តីថា ព្រោះមានការប្រាថ្នាតិចក្នុងអាហារទាំងឡាយ គឺព្រោះមានតណ្ហា ម្យ៉ាងទៀត អធិប្បាយថា ព្រោះត្រូវការអាហារ ដោយញុំាងអត្តភាពឲ្យប្រព្រឹត្តទៅតែម្យ៉ាង ។ បទថា **អប្បចិន្តាយ** បានដល់ ព្រោះមិនមានការគិតដល់អាហារយ៉ាងនេះថា ថ្ងៃនេះអញនឹងបានអាហារក្នុងទីណា ស្អែកនេះក្នុងទីណា ។ បទថា **អទិទូរគមនេន ច** បានដល់ ព្រោះមិនមានការទៅក្នុងទីមិនឆ្ងាយ ដោយគិតថា អញនឹងបានអាហារឆ្ងាញ់ក្នុងទីឈ្មោះនោះ ។ បទថា **លទ្ធាលទ្ធេន** បានដល់ ដោយអាហារដែលបានហើយនោះឯង ទោះអាក្រក់ឬប្រណីត ក៏មិនជាថ្វី ។ បទថា **ថូលោ តេនស្មិ** សេចក្តីថា ខ្ញុំធាត់ដោយហេតុ ៤ យ៉ាងនោះ ។ ព្រះពោធិសត្វហៅក្អែកថា **វាយស** ( អ៊ើក្អែក ) ។ បទថា **អប្បចិន្តី** មានវិគ្គហៈថា សេចក្តីសុខរបស់ព្រះអរិយៈទាំងឡាយ ដែលវៀរចាកការគិតច្រើនក្នុងអាហារ គឺជាអ្នកមានការគិតតិច មានដល់បុគ្គលនោះ ហេតុនោះទើបឈ្មោះថា មានសេចក្តីសុខបែបព្រះអរិយៈដែលគិតតិច ។ របស់បុគ្គលដែលប្រកបដោយសេចក្តីសុខបែបនោះ ។ បទថា **សុសង្គ ហិតប្បមាណស្ស** សេចក្តីថា បុគ្គលមានប្រមាណនៃអាហារដែលទទួលទុកដោយល្អហើយយ៉ាងនេះថា អញបរិភោគហើយនឹងអាចរល្ងួយបានអស់កាលមានប្រមាណប៉ុណ្ណេះ ។ បទថា **វុត្តិ សុសមុទានិយា** សេចក្តីថា ការប្រព្រឹត្តទៅនៃជីវិតរបស់បុគ្គលនេះ អាចដំណើរទៅ គឺប្រព្រឹត្តទៅបានដោយល្អនោះឯង ដោយអត្ថថា ដើម្បីកើតឡើងដោយងាយ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចធម៌ទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុដែលខ្ជិលច្រអូស តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានមកជាភិក្ខុខ្ជិលច្រអូសក្នុងកាលឥឡូវនេះ ឯចាបក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា វដ្ដកជាតក ចប់

# មណិជាតក

[ ២៦២ ] ( ព្រាហ្មណ៍ពោធិសត្វនិយាយថា ) យូរណាស់ហើយតើ ខ្ញុំទើបឃើញសម្លាញ់ពាក់នូវកម្រងកែវមណី សម្លាញ់របស់ខ្ញុំល្អមែន ព្រោះល្អដោយការលេងពុកមាត់ ។

[ ២៦៣ ] ( ក្អែកនិយាយតបថា ) ខ្ញុំមានការខ្វល់ខ្វាយច្រើនក្នុងការងារ មានក្រចកនិងរោមក្លៀកដុះទ្រុបទ្រុលយូរណាស់ហើយ គេទើបតែនឹងបោចរោមអាក្រក់ចេញក្នុងថ្ងៃនេះ ព្រោះបានជាងកោរកាត់ ។

[ ២៦៤ ] ( ព្រាហ្មណ៍ពោធិសត្វនិយាយថា ) អ្នកបានឲ្យជាងកោរកាត់ដែលគេរកបានដោយក្រ ឲ្យបោចនូវរោមណាមែនឬ ម្នាលសម្លាញ់ កាលបើដូច្នេះ រោមបន្តិចបន្តួចត្រង់ករបស់អ្នក ( នោះ ) បិទទុកនៅវែងអន្លាយធ្វើអ្វី ។

[ ២៦៥ ] ( ក្អែកនិយាយតបថា ) កែវមណីតែងសំយុងចុះព្ធដ៏កនៃមនុស្សស្រុខុមាលជាតិ ខ្ញុំយកតម្រាប់តាមពួកមនុស្សទាំងនោះ អ្នកកុំសម្គាល់ថា ( ខ្ញុំ ) ធ្វើដោយល្បែងឡើយ ។

[ ២៦៦ ] បើអ្នកពេញចិត្តនឹងការលេងពុកមាត់ ដែលឲ្យនាយជាងធ្វើយ៉ាងល្អនេះ ម្នាលសម្លាញ់ ខ្ញុំនឹងឲ្យជាងធ្វើដល់អ្នកផង ឲ្យនូវកែវមណីដល់អ្នកផង ។

[ ២៦៧ ] ( ព្រាហ្មណ៍ពោធិសត្វនិយាយថា ) អ្នកឯងយកកែវមណីផងយកពុកមាត់ដែលគេធ្វើឲ្យល្អផង មកបិទបាំង ទើបខ្ញុំហៅអ្នកមកហើយនឹងទៅ ការបានជួបប្រទះនឹងអ្នករមែងជាទីពេញចិត្តរបស់ខ្ញុំ ។

**ចប់ មណិជាតកទី ១០ ។**

**ចប់ ខុរបុត្តវគ្គទី ២ ។**

## ឧទ្ទាននៃឧរុបុត្តវគ្គនោះគឺ

និយាយអំពីអ្នកចូរមើលចុះ ( ជាដើម ) ១ ព្រមទាំងម្ហូល ១ តុណ្ឌិលជាតក ១ ម្រឹគក្ដាម ១ សត្វស្វាបដ៏ប្រសើរឈ្មោះមយ្ហកៈជាគម្រប់ ៥ ផ្គងអញ្ជលី ១ ផ្កាឈូក ១ កណ្ដាលព្រៃ ១ សត្វចាប ១ ព្រាបដ៏ប្រសើរ ១ រួមជា ១០ ។

## ឧទ្ទាននៃវគ្គក្នុងឆក្កនិបាតនោះគឺ

ខ្ញុំនឹងសម្ដែងនូវវគ្គក្នុងឆក្កនិបាតដ៏ប្រសើរថ្លៃថ្លា វគ្គទាំងពីរ គឺអាវារិយវគ្គ និងឧរុបុត្តវគ្គ មានពាក្យថាសូចិជាតក មានព្យញ្ជនៈដ៏ល្អ ដែលព្រះដ៏មានព្រះភាគសម្ដែងហើយ ។

**ចប់ ឆក្កនិបាត ។**

# អដ្ឋកថា

# មណិជាតក

[ ២៦២-២៦៧ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឡេះឡោះ ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **ចិរស្សំ វត បស្សាមិ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នមានន័យដូចពោលទុកហើយខាងដើមនោះឯង ទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាសត្វព្រាប អាស្រ័យនៅត្រង់សំបុកដែលធ្វើដោយកំប្រោងត្រង់រោងបាយរបស់សេដ្ឋីក្រុងពារាណសី ។ ឯក្អែកធ្វើការស្និទស្នាលនឹងសត្វព្រាបនោះហើយ នៅក្នុងទីនោះដូចគ្នា ព្រោះហេតុនោះរឿងទាំងអស់គួរឲ្យពិស្ដារចុះ ។ ចុងភៅដករោមស្លាបរបស់ក្អែកចេញហើយយកម្សៅលាបស្លាប ចោះអំបែងមួយពាក់ត្រង់ក ហើយដាក់ក្នុងកំប្រោង ព្រះពោធិសត្វមកអំពីព្រៃ ឃើញក្អែកហើយ កាលនឹងធ្វើការចំអក ទើបពោលគាថាទី ១ ថា

យូរណាស់ហើយតើ ខ្ញុំទើបឃើញសម្លាញ់ពាក់នូវកម្រងកែវ
មណី សម្លាញ់របស់ខ្ញុំល្អមែន ព្រោះល្អដោយការលេងពុក
មាត់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មស្សុកុត្តិយា** បានដល់ ព្រោះការតាក់តែងរោមនេះ ។

ក្អែកស្ដាប់ពាក្យនោះហើយ ទើបពោលគាថាទី ២ ថា

ខ្ញុំមានការខ្វល់ខ្វាយច្រើនក្នុងការងារ មានក្រចកនិងរោមក្លៀក
ដុះទ្រុបទ្រុលយូរណាស់ហើយ គេទើបតែនឹងបោចរោមអាក្រក់
ចេញក្នុងថ្ងៃនេះ ព្រោះបានជាងកោរកាត់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាម្មេ សុព្យាវដោ** សេចក្ដីថា ក្អែកពោលថា នែសម្លាញ់ ខ្ញុំជាអ្នកខ្វល់ខ្វាយក្នុងការងាររាជការទាំងឡាយ កាលមិនបានឱកាសដករោម ទើបមានស្លាប ក្រចក និងរោមដុះឡើង ។ បទថា **អហារយិ** បានដល់ ថ្ងៃនេះ ខ្ញុំបានឲ្យជាងដករោមចេញហើយ ។

លំដាប់នោះ ទើបព្រះពោធិសត្វពោលគាថាទី ៣ ថា

អ្នកបានឲ្យជាងកោរកាត់ ដែលគេរកបានដោយក្រ ឲ្យបោច
នូវរោមណាមែនឬ ម្នាលសម្លាញ់ កាលបើដូច្នេះ រោមបន្ទិច
បន្តួចត្រង់ករបស់អ្នក[១]( នោះ ) បិទទុកនៅវែងអន្លាយធ្វើអ្វី
ដូច្នេះ ។

គាថានោះមានសេចក្ដីថា ឯងបានជាងកោរកាត់ដែលរកបានលំបាកហើយ បានឲ្យគេដករោមចេញដោយវិធីណា ឯងគាប់ចិត្តក្នុងវិធីនោះ ខ្ញុំនឹងឲ្យគេធ្វើការតាក់តែងរោមពុកមាត់ឲ្យ ឯងចូរឲ្យគេដករោមនោះចេញចុះ នែ សម្លាញ់ អ្វីសំយុងវែងអន្លាយត្រង់ករបស់អ្នក ។

លំដាប់នោះ ក្អែកបានពោលគាថា ២ ថា

---

១-គួរប្រែថា អ្វីសំយុងវែងអន្លាយត្រង់ករបស់អ្នក ព្រោះព្រាបសួរសំដៅដល់ខ្សែរក្រដែលចងអំបែង។

កែវមណីតែងសំយុងចុះ ពួជ័កនៃមនុស្សសុខុមាលជាតិ ខ្ញុំយកតម្រាប់តាមពួកមនុស្សទាំងនោះ អ្នកកុំសម្គាល់ថា ( ខ្ញុំ ) ធ្វើដោយល្បែងឡើយ ។

បើអ្នកពេញចិត្តនឹងការលេងពុកមាត់ ដែលឲ្យនាយជាងធ្វើយ៉ាងល្អនេះ ម្នាលសម្លាញ់ ខ្ញុំនឹងឲ្យជាងធ្វើដល់អ្នកផង ឲ្យនូវកែវមណីដល់អ្នកផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មណិ** សេចក្ដីថា រតនមណីមួយសំយុងត្រង់ករបស់មនុស្សទាំងឡាយបែបនោះ ។ បទថា **តេសាហំ** កាត់បទជា **តេសំ អហំ** ។ បទថា **មា ត្វំ មញ្ញិ** បានដល់ តែឯងកុំសម្គាល់ថា របស់នេះខ្ញុំធ្វើលេង ។ បទថា **បិហាយសិ** បានដល់ បើឯងត្រូវការបែបបទរោមដែលខ្ញុំតាក់តែងល្អហើយសោត ។

ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយ ទើបពោលគាថាទី ៦ ថា

អ្នកឯងយកកែវមណីផង យកពុកមាត់ ដែលគេធ្វើឲ្យល្អផង មកបិទបាំង[១]ទើបខ្ញុំហៅអ្នកមកហើយនឹងទៅ ការបានជួបប្រទះនឹងអ្នក រមែងជាទីពេញចិត្តរបស់ខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **មណិនា** សេចក្ដីថា សម្រាប់កែវមណី ។

---

១-បាលីថា ឆន្ទោ ប្រែថា បិតបាំង ក៏បាន ប្រែថា សមគួរ ក៏បាន ក្នុងទីនេះគួរប្រែថា សមគួរ សេចក្ដីថា អ្នកឯងសមនឹងកែវមណីផង សមនឹងពុកមាត់ដែលគេធ្វើឲ្យល្អ ផង ។

បាឋៈជា **មណិនោ** យ៉ាងនេះក៏មាន ។ មានពាក្យអធិប្បាយទុកថា នែសម្លាញ់ ឯងប៉ុណ្ណោះសមនឹងកែវមណីនេះ និងរោមដែលតាក់តែងហើយនេះ តែការឃើញឯងនោះជាទីស្រឡាញ់របស់ខ្ញុំ ព្រោះហេតុនោះ ខ្ញុំប្រាប់អ្នកហើយ ក៏នឹងទៅ ។ សត្វព្រាបនោះកាលពោលយ៉ាងនោះហើយ ក៏ហើយទៅព្រៃ ឯក្អែកក៏ស្លាប់ក្នុងទីនោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុឡេះឡោះ តាំងនៅក្នុងអនាគាមិផល ហើយទ្រង់ប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានមកជាភិក្ខុឡេះឡោះក្នុងកាលឥឡូវនេះ ឯព្រាបក្នុងកាលនោះ គឺតថាគតនេះឯង ។

អដ្ឋកថា មណិជាតក ចប់

ខុរប្បុត្តវគ្គ ចប់

# សត្តកនិបាត ជាតក

## កុក្កុវគ្គ

### កុក្កុជាតក

[ ២៦៨ ] ( ព្រះរាជាព្រហ្មទត្តសួរអាមាត្យពោធិសត្វថា ) កំពូល (ជហ្វា) មួយហត្ថកន្លះ រនង់ជុំវិញកំពូលនោះ ៨ ចំអាម កំពូលនោះជាឈើធ្ងន់ខ្ទឹមសុទ្ធ ឥតមានស្រោយ ឋិតនៅលើអ្វីហ្ន៎ បានជាមិនជ្រុះអំពីខាងលើមក ។

[ ២៦៩ ] ( ពោធិសត្វពោលតបថា ) បង្កង់ទាំងឡាយណា ចំនួន ៣០ ខ្ទឹមសុទ្ធឥតមានស្រោយ ឋិតនៅតំរៀបគ្នាជុំវិញ ( កំពូលនោះ ) បង្កង់ទាំងឡាយនោះទល់ទ្រផង គាបដោយកម្លាំងផង ឋិតនៅស្មើភាគគ្នា ទើបមិនធ្លាក់របូតអំពីខាងលើមក ។

[ ២៧០ ] បណ្ឌិតបានពួកមិត្តដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យចាកសិរី ដូចជាកំពូល ( ជហ្វា ) ដែលបង្កង់នាំទៅនូវភារៈ យ៉ាងនេះឯង ។

[ ២៧១ ] បុគ្គលដែលមានកាំបិតក្នុងដៃ កាលបើមិនចិតផ្លែក្រូចឆ្មារដែលមានសម្បករឹងចេញទេ រមែងធ្វើ ( ផ្លែនេះ ) ឲ្យមានរសល្វីង បពិត្រម្ចាស់ផែនដី បុគ្គលកាលនាំយក ( សម្បកក្រៅចេញ ) រមែងធ្វើឲ្យមានរសឆ្ងាញ់ កាលបើចិតសម្បកស៊ើៗទេ រមែងធ្វើឲ្យមានរសមិនឆ្ងាញ់ មានឧបមាយ៉ាងណាមិញ ។

[ ២៧២ ] ព្រះរាជាជាបណ្ឌិត វៀរមិនលុះអំណាចកម្មដ៏ក្លៀវក្លា វៀរ

( អគតិ ) ក្នុងពួកអ្នកស្រុក អ្នកនិគម ប្រមូលមកនូវទ្រព្យទាំងឡាយ ជាអ្នកប្រព្រឹត្តប្រតិបត្តិតាមធម៌ មិនបៀតបៀនបុគ្គលដទៃ គប្បីធ្វើឲ្យសម្រេចបាន ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

[ ២៧៣ ] ផ្កាឈូកជាអម្ពុជជាតិ មានឫសស កើតក្នុងទឹកដ៏ស្អាត ក្នុងស្រះបោក្ខរណី រីកស្គុះស្គាយដោយសារព្រះអាទិត្យ មិនជាប់ដោយភក់ មិនជាប់ដោយធូលី មិនជាប់ដោយទឹក មាន ឧបមាយ៉ាងណាមិញ ។

[ ២៧៤ ] កម្មក្កិលេសប្រាកដដូច្នោះ មិនប្រឡាក់ ( ចំពោះស្តេច ) ដែលមានវោហារ ( សម្រាប់វិនិច្ឆ័យ ) ដ៏ស្អាត មិនមានកម្មជាសាហ័ស មានការងារដ៏ស្អាត មានបាបកម្មប្រាសចេញហើយ ដូចជាផ្កាឈូកដែលដុះក្នុងស្រះបោក្ខរណី ក៏មានឧបមេយ្យ យ៉ាងនោះដែរ ។

**ចប់ កុក្កុជាតកទី ១ ។**

# សត្តកនិបាត ជាតក

## កុក្កុវគ្គ

### អដ្ឋកថា កុក្កុជាតក

[ ២៦៨-២៧៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធរាជោវាទ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ទិយឌ្ឍកុក្កុ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្ន មានជាក់ច្បាស់ក្នុងតេសកុណជាតក ( ចត្តាឡីសនិបាត ) ។

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជាអាមាត្យ ជាអ្នកថ្វាយអត្ថនិងធម៌ ដល់ព្រះរាជាអង្គនោះ ព្រះរាជាទ្រង់តាំងនៅក្នុងអំណាចអគតិ ទ្រង់គ្រងរាជ្យមិនប្រកបដោយធម៌ ទារពន្ធដារក្នុងជនបទ យកទ្រព្យតែម្យ៉ាង ។ ព្រះពោធិសត្វបំណងនឹងថ្វាយព្រះឱវាទដល់ព្រះរាជា ពិចារណារកឧបាយឯណានីមួយ ។ ម្យ៉ាងទៀត ក្នុងព្រះរាជឧទ្យាន មានព្រះដំណាក់ជាទីប្រថាប់បណ្តោះអាសន្ន ប្រក់មិនទាន់សម្រេច គ្រាន់តែលើកជហ្វាឡើង ហើយយកបង្កង់តម្រៀប ។ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ដើម្បីក្រសាលកីឡា ទ្រង់យាងទៅគ្រប់កន្លែង ក្នុងព្រះរាជឧទ្យាននោះ ហើយយាងចូលព្រះដំណាក់នោះ កាលទតឃើញកំពូលជហ្វា ទើបយាងចេញមកប្រថាប់ខាងក្រៅ ព្រោះទ្រង់ខ្លាចធ្លាក់លើទ្រង់ ហើយទ្រង់ពិនិត្យមើលទៀត ទ្រង់ព្រះតម្រិះថា ជហ្វាតាំងនៅបាន ព្រោះអាស្រ័យអ្វីហ្ន៎ បង្កង់តាំងនៅបាន ព្រោះអាស្រ័យអ្វីហ្ន៎ កាលត្រាស់សួរព្រះពោធិសត្វ ទើប

ពោលគាថាទី ១ ថា

កំពូល ( ជហ្វា ) មួយហត្ថកន្លះ វង្វង់ជុំវិញកំពូលនោះ ៨ ចំអាម កំពូលនោះជាឈើផ្ចង់ខ្ចឹមសុទ្ធឥតមានស្រោយ ឋិតនៅលើអ្វីហ្ន៎ បានជាមិនជ្រុះអំពីខាងលើមក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទិយឌ្ឍកុក្កូ** បានដល់ មួយហត្ថកន្លះ ។ បទថា **ឧច្ចយេន** បានដល់ ដោយចំណែកកម្ពស់ ។ បទថា **បរិក្ខិបន្តិ ធំ** សេចក្ដីថា វង្វង់ជុំវិញកំពូលនោះ ៨ អធិប្បាយថា ដោយជុំវិញមានប្រមាណ ៨ ចំអាម ។ បទថា **កុហឹ ឋិតា** បានដល់ ជារបស់តាំងនៅដោយអ្វី ។ បទថា **ន ធំសតិ** បានដល់ មិនធ្លាក់ចុះមក ។

ព្រះពោធិសត្វបានស្ដាប់រាជតម្រាស់នោះហើយគិតថា ឥឡូវនេះ អញបានឧបាយដើម្បីថ្វាយព្រះឱវាទដល់ព្រះរាជាហើយ បានពោលគាថាទាំងនេះថ្វាយថា

បង្កង់ទាំងឡាយណាចំនួន ៣០ ខ្ចឹមសុទ្ធឥតមានស្រោយ ឋិតនៅតំរៀបគ្នាជុំវិញ ( កំពូលនោះ ) បង្កង់ទាំងឡាយនោះទល់ទ្រផង គាបដោយកម្លាំងផង ឋិតនៅស្មើភាគគ្នា ទើបមិនធ្លាក់របូតអំពីខាងលើមក ។

បណ្ឌិតបានពួកមិត្តដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យ ចាកសិរី ដូចជាកំពូល ( ជហ្វា ) ដែលបង្កង់នាំទៅនូវភារៈ យ៉ាង

នេះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យា តឹសតិ សារមយា** សេចក្ដីថា បង្កង់ ៣០ ណា ធ្វើដោយឈើខ្លឹម ។ បទថា **បរិកិរិយា** បានដល់ ព័ទ្ធជុំវិញ ។ បទថា **សមដ្ឋិតា** បានដល់ ដាក់តម្រៀបទុកស្មើៗគ្នា ។ បទថា **ពលសា ច បីឡិតា** សេចក្ដីថា បង្កង់នោះៗ និងកម្លាំងរបស់វាទាញទុកយ៉ាងល្អ គឺជាប់គ្នាតែមួយ ។ បទថា **បណ្ឌិតោ** បានដល់ ព្រះរាជាដែលទ្រទ្រង់នូវបដិភាណ ។ បទថា **សុចីហិ** បានដល់ ដែលកល្យាណមិត្តទាំងឡាយ អ្នកមានការប្រព្រឹត្តស្អាត ។ បទថា **មន្តិភិ** បានដល់ អ្នកឈ្លាស ព្រោះការដឹង ។ បទថា **គោបាណសីការវិហារ កណ្ណិកា** សេចក្ដីថា កំពូលជហ្វាដែលបង្កង់ទាំងឡាយទ្រទម្ងន់ទុក រមែងមិនធ្លាប់យ៉ាងណា សូម្បីព្រះរាជា ក៏យ៉ាងនោះ ជាបុគ្គលដែលមន្ត្រីទាំងឡាយ មានប្រការដូចពោលហើយ មានចិត្តមិនបែកខ្ញែកទ្រទ្រង់ទុក រមែងមិនភ្លាំងភ្លាត់ គឺមិនធ្លាក់ទៅ បានដល់ មិនសាបសូន្យបាកសិរី ។

ព្រះរាជា កាលព្រះពោធិសត្វពោលនោះឯង ទ្រង់កំណត់មើលព្រះរាជកិរិយារបស់ព្រះអង្គហើយ ទើបទ្រង់ជ្រាបថា កាលជហ្វាមិនមានបង្កង់ទាំងឡាយ ក៏ដាក់មិនបាន ជហ្វាដែលបង្កង់មិនទ្រទ្រង់ទុក ក៏តាំងនៅមិនបាន កាលបង្កង់បែកគ្នា ជហ្វាក៏ធ្លាក់ចុះ យ៉ាងណា ព្រះរាជាដែលមិនទ្រទ្រង់ធម៌ ក៏យ៉ាងនោះដូចគ្នា កាលទ្រង់មិនយកចិត្តទុកដាក់ក្នុងមិត្តអាមាត្យ កម្លាំងពលរបស់ខ្លួន និងព្រាហ្មណ៍គហបតីទាំងឡាយទេ កាលអ្នកទាំងនោះបែកខ្ញែកគ្នា

មិននាំគ្នាធ្វើឧបការៈ ព្រះរាជាក៏នឹងវិនាសចាកឥស្សរិយយស ធម្មតាព្រះរាជាគួរជាអ្នកទ្រទ្រង់ធម៌ ។ ក្នុងខណៈនោះ មនុស្សទាំងឡាយ នាំយកផ្លែក្រូចព្រៃ⁽¹⁾មក ដើម្បីជាបណ្ណាការ ថ្វាយដល់ព្រះរាជា ។ ទើបព្រះរាជាត្រាស់នឹងព្រះពោធិសត្វថា នែសម្លាញ់ ចូរអ្នកទទួលទានផ្លែក្រូចព្រៃនេះចុះ ។ ព្រះពោធិសត្វទទួលផ្លែក្រូចព្រៃនោះហើយ ក៏ទូលសម្តែងឧបាយរូបរួមទ្រព្យ គឺការប្រមូលភាសុីថ្វាយព្រះរាជាដោយឧបមានេះថា បពិត្រមហារាជ មនុស្សទាំងឡាយមិនដឹងនូវការបរិភោគផ្លែក្រូចព្រៃនេះ នឹងធ្វើឲ្យមានតែរសល្វីង ឯអ្នកឈ្លាស ដឹងនូវរសជូរ នាំតែរសល្វីងចេញទៅ មិននាំរសជូរចេញ មិនឲ្យរសក្រូចព្រៃខូច ហើយទទួលទានជាខាងក្រោយ ដូច្នេះហើយ ពោល ២ គាថាដោយសេចក្តីថា

បុគ្គលដែលមានកាំបិតក្នុងដៃ កាលបើមិនចិតផ្លែក្រូចធ្នារ ដែលមានសម្បករឹងចេញទេ រមែងធ្វើ ( ផ្លែនេះ ) ឲ្យមានរសល្វីង បពិត្រម្ចាស់ផែនដី បុគ្គលកាលនាំយក ( សម្បកក្រៅចេញ ) រមែងធ្វើឲ្យមានរសឆ្ងាញ់ កាលបើចិត សម្បកសើៗទេ រមែងធ្វើឲ្យមានរសមិនឆ្ងាញ់ មានឧបមាយ៉ាងណាមិញ ។

ព្រះរាជាជាបណ្ឌិត វៀរមិនលុះអំណាចកម្មដ៏គៀវក្លា វៀរ ( អគតិ ) ក្នុងពួកអ្នកស្រុក អ្នកនិគម ប្រមូលមកនូវទ្រព្យ

---

១-បិដកខ្មែរជាក្រូចធ្នារ ។

ទាំងឡាយ ជាអ្នកប្រព្រឹត្តប្រតិបត្តិតាមធម៌ មិនបៀតបៀន
បុគ្គល ដទៃគប្បីធ្វើឲ្យសម្រេចបាន ក៏មានឧបមេយ្យយ៉ាងនោះ
ដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខរត្តចំ** បានដល់ មានសម្បករឹង ។ បទថា **ពេលុវំ** បានដល់ ផ្លែក្រូចព្រៃ បាឋៈថា **ពាលំ** ក៏មាន ។ អត្ថក៏យ៉ាងនេះដូចគ្នា ។ បទថា **សត្ថវា** បានដល់ ជាអ្នកមានសស្ត្រាតូច ។ បទថា **អផាម-សន្តោ** បានដល់ កាលមិនបកសម្បកខាងក្រៅឲ្យស្តើង រមែងធ្វើផ្លែនោះឲ្យល្វីង ។ បទថា **សមាហរំ** សេចក្តីថា កាលបកសម្បក គឺចិតសម្បកខាងក្រៅចេញ និងមិននាំរសជូរចេញទៅ រមែងធ្វើឲ្យមានរសឆ្ងាញ់ ។ ព្រះពោធិសត្វ ហៅព្រះរាជាថា **បត្ថវា** ។ បទថា **តន្ទុពន្ធមុទ្ធរំ** សេចក្តីថា តែបើចិតតែសម្បកស្តើងៗចេញ គង់មិនធ្វើឲ្យរសក្រូចព្រៃនោះឆ្ងាញ់បានឡើយ ព្រោះមិនបាននាំរសល្វីងចេញទៅឲ្យអស់ ។ បទថា **ឯវំ** សេចក្តីថា ចំណែកព្រះរាជាដែលទ្រទ្រង់បដិភាណអង្គនោះ ក៏យ៉ាងនោះ ទ្រង់មិនតឹងតែង គឺមិនលុះអំណាចតណ្ហា មិនរួសរាន់ ទ្រង់លះនូវការលុះក្នុងអំណាចអគតិ ទ្រង់មិនបៀតបៀនប្រជារាស្ត្រ ទ្រង់រក្សាប្រាក់កាស៊ីដោយទំនងកណ្តៀរទាំងឡាយ គឺរមែងធ្វើនូវដំបូក និងដោយទំនងឃ្មុំទាំងឡាយ ដែលក្រេបយកកេសរមកធ្វើទឹកឃ្មុំ ជាអ្នកបដិបត្តិអនុលោមតាមធម៌ ដោយការអនុលោមតាមរាជធម៌ ១០ ប្រការ គឺទាន ១ សីល ១ ចាគៈ ១ អជ្ជវៈ ( ស្មោះត្រង់ ) ១ មទ្ទវៈ ( ទន់ភ្លន់ ) ១ តបៈ ១ អក្កោធៈ ១ អវិហិង្សា ១ ខន្តិ ១ អវិរោធនៈ ( មិនខុស )

១ ។ ទ្រង់គួរធ្វើនូវផាសុក គឺសេចក្ដីចម្រើនឲ្យខ្លួនឯង និងអ្នកដទៃ មិនបៀតបៀនអ្នកដទៃ ។

ព្រះរាជាទ្រង់ប្រឹក្សាជាមួយព្រះពោធិសត្វបណ្ដើរ យាងទៅបណ្ដើរ ដល់ប្រាំងស្រះបោក្ខរណី ទតឃើញផ្កាឈូកដែលរីកក្នុងស្រះនោះ តែមិនសើមដោយទឹក មានពណ៌ដូចអរុណ ទើបត្រាស់ថា នែសម្លាញ់ ផ្កាឈូកនេះកើតក្នុងទឹកនោះឯង តែមិនសើមដោយទឹក ។ លំដាប់នោះ ព្រះពោធិសត្វ ក៏ថ្វាយឱវាទព្រះរាជានោះថា សូមព្រះរាជាក៏គួរតែបែបនេះដូចគ្នា ទើបបានទូលគាថាថា

ផ្កាឈូកជាអម្ពុជជាតិ មានឫសស កើតក្នុងទឹកដ៏ស្អាតក្នុងស្រះបោក្ខរណី រីកស្គុសស្គាយដោយសារព្រះអាទិត្យ មិនជាប់ដោយភក់ មិនជាប់ដោយធូលី មិនជាប់ដោយទឹក មានឧបមាយ៉ាងណាមិញ ។

កម្មក្កិលេសប្រាកដដូច្នោះ មិនប្រឡាក់ ( ចំពោះស្ដេច ) ដែលមានវោហារ ( សម្រាប់វិនិច្ឆ័យ ) ដ៏ស្អាត មិនមានកម្មជាសាហ័ស មានការងារដ៏ស្អាត មានបាបកម្មប្រាសចេញហើយ ដូចជាផ្កាឈូកដែលដុះក្នុងស្រះបោក្ខរណី ក៏មានឧបមេយ្យ យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱទាតមូលំ** បានដល់ មានឫសស ។ ពាក្យថា **អម្ពុជ** ជាវេវចនៈរបស់បទថា **បទុម** នោះឯង ។ បទថា **អគ្គិនិភាសិ-**

**ជាលិមំ** សេចក្តីថា រីកហើយ អធិប្បាយថា រីកហើយ ព្រោះព្រះអាទិត្យមានពន្លឺដូចភ្លើង ។ បទថា **ន កទ្ទមោ ន រជោ ន វារិ លិម្បតិ** សេចក្តីថា ភក់ក៏មិនប្រឡាក់ ធូលីក៏មិនប្រឡាក់ ទឹកក៏មិនសើម អធិប្បាយថា មិនប្រឡាក់ប្រឡូស ។ បាឋៈថា **លិប្បតិ** ដូច្នេះក៏មាន ។ ម្យ៉ាងទៀត បទទាំងនោះ ជាបឋមាវិភត្តិ ប្រើក្នុងអត្ថសត្តមីវិភត្តិ ។ ដោយអត្ថថា មិនប្រឡាក់ប្រឡូស គឺមិនជាប់ក្នុងភក់ជាដើមនោះ ។ បទថា **វោហារសុចឹ** សេចក្តីថា ទ្រង់ជាអ្នកស្អាត ក្នុងការកាត់ក្តីតាមច្បាប់ដែលបុរាណរាជាទាំងឡាយចងក្រងទុក អធិប្បាយថា ទ្រង់មិនលុះក្នុងអំណាចអគតិ ធ្វើការវិនិច្ឆ័យដោយធម៌ ។ បទថា **អសាហសំ** សេចក្តីថា ឈ្មោះថា ទ្រង់វៀរចាកព្រះរាជកិរិយាដែលឆាប់រូសរាន់ ព្រោះទ្រង់តាំង នៅក្នុងព្រះរាជវិនិច្ឆ័យដែលប្រព្រឹត្តតាមធម៌នោះឯង ។ បទថា **វិសុទ្ធកម្មំ** សេចក្តីថា ឈ្មោះថា ទ្រង់មានរាជកិច្ចបរិសុទ្ធ គឺមានប្រក្រតីត្រាស់ពាក្យពិត បានដល់ ទ្រង់មិនពិរោធ ដោយអត្ថថា ទ្រង់ជាកណ្តាល ទ្រង់ដូចជាជញ្ជីង ព្រោះទ្រង់មិនប្រញាប់រូសរាន់នោះឯង ។ បទថា **អបេតបាបកំ** បានដល់ ទ្រង់ប្រាសចាកបាបកម្ម ។ បទថា **ន លិម្បតិ កម្មកិលេស** សេចក្តីថា កម្មកិលេសនេះ គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ មិនប្រឡាក់ប្រឡូសព្រះរាជានោះ ។ ព្រោះហេតុអ្វី ព្រោះព្រះរាជានោះ ក៏ដូចគ្នានឹងផ្កាឈូកដែលកើតហើយក្នុងស្រះបោក្ខរណី អធិប្បាយថា បពិត្រមហារាជ ព្រះរាជាបែបនោះ ទ្រង់ជាបុគ្គលឈ្មោះថា មិនមានអ្វីប្រឡាក់ហើយ ដូចផ្កាឈូកដែលកើតហើយក្នុងព្រះបោក្ខរណី

ដែលអ្វីប្រឡាក់មិនបាន ដូច្នោះ ។ ព្រះរាជាទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វហើយ តាំងអំពីនោះមក ក៏ទ្រង់គ្រងរាជសម្បត្តិដោយធម៌ ទ្រង់បំពេញកុសល មានទានជាដើម ហើយទ្រង់មានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ឯអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កុក្កុជាតក ចប់

## មនោជជាតក

[ ២៧៥ ] ( ចចកឮសំឡេងសីហៈនិងសំឡេងបន្ទោះធ្នូហើយក៏ពោលគាថាពីរនេះថា ) ធ្នូទន់ខ្ទបទៅផង បន្ទោះលាន់ឮផង ដោយហេតុណា មិគ-រាជឈ្មោះមនោជៈជាសម្លាញ់របស់អញត្រូវ គេសម្លាប់ដោយពិត ( ដោយហេតុនោះ ) ។

[ ២៧៦ ] បើដូច្នោះមានតែអញនឹងជៀសចេញទៅកាន់ព្រៃជាទីពឹងតាមសេចក្ដីសប្បាយក្នុងពេលឥឡូវនេះ សត្វស្លាប់បែបនេះនឹងយកធ្វើជាសម្លាញ់មិនកើត កាលបើអញរស់នៅ គង់បានសម្លាញ់ទៀត ។

[ ២៧៧ ] ( មាតាបិតាបងប្អូនស្រីប្រពន្ធពោលគាថាទាំង ៤ នេះថា ) បុគ្គលដែលសេពគប់ជាមួយនឹងជនបាប មិនបានសេចក្ដីសុខដ៏ទៀងទាត់ឡើយ អ្នកចូរមើលសីហៈឈ្មោះមនោជៈកំពុងដេក ( ស្លាប់នេះព្រោះតែជឿតាម ) ពាក្យប្រៀនប្រដៅរបស់ចចកឈ្មោះគិរិយៈ ។

[ ២៧៨ ] មាតាមិនបានរីករាយជាមួយនឹងកូន ព្រោះតែគប់រកសម្លាញ់អាក្រក់ អ្នកចូរមើលសីហៈឈ្មោះមនោជៈ ដេកត្រាំនៅក្នុងឈាមរបស់ខ្លួន ។

[ ២៧៩ ] សត្វណាមិនធ្វើតាមពាក្យនៃជនទាំងឡាយអ្នកប្រាថ្នានូវសេចក្ដីចម្រើន អ្នកឃើញនូវប្រយោជន៍ ( ទៅក្នុងអនាគត ) សត្វនោះរមែងដល់ ( នូវសេចក្ដីទុក្ខ ) យ៉ាងនេះផង តែងជួប ប្រទះនូវទោសដ៏លាមកក្រៃលែងផង ។

[ ២៨០ ] បុគ្គលដ៏ឧត្ដមណាសេពគប់នឹងអធម្មជន ( ជនដ៏លាមក ) បុគ្គលនោះអាក្រក់ក្រៃលែងជាងអធម្មជននោះទៅទៀតយ៉ាងនេះ អ្នកចូរមើល

នូវស្តេចនៃម្រឹគដ៏ឧត្តម ដែលសេពគប់នឹងអធម្មជន ត្រូវកម្លាំងនៃព្រួញដ៏ប្រសើរមុតហើយ ។

[ ២៨១ ] ( ព្រះសាស្តាទ្រង់ត្រាស់នូវអភិសម្ពុទ្ធគាថាក្រោយបំផុតថា ) បុរសអ្នកគប់រកនូវជនថោកទាប រមែងសាបសូន្យ បុគ្គលគប់រកនូវជនស្មើៗគ្នា រមែងមិនសាបសូន្យ ក្នុងកាលណាឡើយ គប់រកនូវជនដែលប្រសើរជាង រមែងចម្រើនឆាប់រួសរាន់ ព្រោះហេតុនោះបុគ្គលគួរតែគប់រកនូវបុគ្គលដែលប្រសើរជាងខ្លួន ។

**ចប់ មនោជជាតកទី ២ ។**

## អដ្ឋកថា

## មនោជជាតក

[ ២៧៥-២៨១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវន ទ្រង់ប្រារព្ធភិក្ខុសេពគប់ខុស ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **យថា ចាបោ និន្នមតិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារមានក្នុងមហិឡាមុខជាតកខាងដើម ។ តែក្នុងកាលនោះព្រះសាស្តាត្រាស់ថា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនភិក្ខុនោះ ក៏ជាអ្នកសេពគប់ខុសដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វយោនយកកំណើតជាសីហៈ អាស្រ័យនៅជាមួយសីហៈញី បាន កូន ២ គឺ កូនឈ្មោល ១ កូនញី ១ កូនឈ្មោលឈ្មោះថា មនោជៈ ។ កូនរាជសីហ៍នោះធំហើយ ទទួលយកកូនសីហៈមួយទៀតមកជាភរិយា ។ តាំង អំពីនោះ ទើបសីហៈទាំងនោះមានសមាជិក ៥ រូប ។ សីហមនោជៈ បាន សម្លាប់ក្របីជាដើមក្នុងព្រៃ នាំសាច់មកចិញ្ចឹមមេបា ប្អូនស្រី និងប្រពន្ធ ។ ថ្ងៃមួយ រាជសីហ៍ឃើញចចកមួយ ឈ្មោះគិរិយៈ ត្រង់ទីកន្ទែងរកចំណីដែល គេចមិនទាន់ បានក្រាបចុះ ទើបសីហៈសួរថា មានរឿងអ្វីសម្លាញ់ កាលចចក ប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំបំណងនឹងប្រណិប័តន៍លោកម្ចាស់ ទើបរាជ សីហ៍ទទួល ហើយនាំមកកាន់គុហាដែលជាលំនៅរបស់ខ្លួន ព្រះពោធិសត្វ ឃើញព្រឹត្តិការណ៍នោះហើយឃាត់ថា នែបាមនោជៈ ធម្មតាចចកទាំងឡាយ ជាសត្វទ្រុស្តសីល មានបាបធម៌ ប្រកបវត្តដែលមិនមែនជាកិច្ច ឯងកុំយក ចចកនោះទុកក្នុងសម្នាក់របស់ខ្លួនដូច្នោះឡើយ ក៏មិនអាចឃាត់បាន ។ ថ្ងៃ មួយ ចចកចង់ចង់ស៊ីសាច់សេះ ទើបពោលនឹងមនោជៈថា បពិត្រលោកម្ចាស់ ឈ្មោះថា ម្រឹគដទៃ វៀរតែសាច់សេះ ដែលពួកយើងមិនធ្លាប់ស៊ីមិនមានពួក យើងនឹងសង្គ្រុបសេះចុះ ។ មនោជៈសួរថា សេះមានក្នុងទីណា ទើបចចក ឆ្លើយថា ត្រង់ប្រាំងស្ទឹងនគរពារាណសី ។ មនោជៈទទួលពាក្យចចក ហើយ ទៅជាមួយចចក ក្នុងកាលដែលសេះទាំងឡាយនាំគ្នាងូតទឹកក្នុងស្ទឹង សីហៈ ចាប់សេះបានមួយ លើកឡើងដាក់លើខ្នង មកដល់គុហារបស់ខ្លួននោះឯង

ដោយកម្លាំងសីហៈ ។ លំដាប់នោះ បារបស់សីហៈ ទំពាសាច់សេះហើយទើប ពោលថា ធម្មតាសេះជាជំនិះរបស់ព្រះរាជា ។ ព្រះរាជាទាំងឡាយទ្រង់មាន មាយាច្រើន ត្រាស់បញ្ជាឲ្យពួកខ្មាន់ធ្នូដែលឈ្លាសចាំបាញ់ ។ ឈ្មោះថាសីហៈ ដែលស៊ីសាច់សេះហើយ មានអាយុវែងមិនមានទេ បន្ទាប់អំពីនេះទៅ ឯងកុំ ចាប់សេះបរិភោគឡើយ ។ មនោជៈមិនធ្វើតាមពាក្យរបស់បា នៅតែចាប់សេះ នោះឯង ។ ព្រះរាជាទ្រង់បានឮថា សីហៈចាប់សេះស៊ី ទើបទ្រង់ឲ្យសាងស្រះ បោក្ខរណីសម្រាប់សេះទុកក្នុងព្រះនគរនោះឯង ។ សូម្បីស្រះបោក្ខរណីនោះ សីហៈក៏នៅតែមកចាប់យកដូចគ្នា ។ ទើបព្រះរាជាឲ្យធ្វើក្រោលសេះ ហើយ ឲ្យស្មៅនិងទឹកដល់សេះខាងក្នុងរោងនោះឯង ។ សីហៈក៏ផ្លោះរំលងកំពែងចាប់ យកក្នុងក្រោលនោះឯង ។ ព្រះរាជាត្រាស់ឲ្យខ្មាន់ធ្នូដែលបាញ់រហ័ស គឺបាញ់ ឲ្យព្រួញជាប់តគ្នាម្នាក់មក ហើយត្រាស់ថា នែបា ឯងអាចបាញ់សីហៈបានទេ ខ្មាន់ធ្នូទូលថា ទូលព្រះបង្គំអាច ហើយបានឲ្យមនុស្សធ្វើប៉មដែលបិតជិតក្បែរ កំពែងត្រង់ផ្លូវដែលសីហៈមក ហើយឈរលើនោះ ។ សីហៈមកហើយ ឲ្យ ចចកឈរខាងក្រៅ ត្រង់ព្រៃខ្មោច ហើយផ្លោះចូលព្រះនគរដើម្បីចាប់សេះ ។ ចំណែកខ្មាន់ធ្នូ កាលឃើញសីហៈមកគិតថាសីហៈនេះមានសម្ទុះរហ័សណាស់ ទើបមិនបាញ់ រង់ចាំពេលសីហៈចាប់សេះបានហើយដើរទៅ ក៏បាញ់សីហៈ ដែលថយសម្ទុះហើយព្រោះលីធ្ងន់ ដោយព្រួញមួយដ៏មុតត្រង់ខ្នង ។ ព្រួញ ធ្លុះទៅមុខ ហើយហើរទៅលើអាកាស ។ សីហៈស្រែកថា ខ្ញុំត្រូវបាញ់ហើយ ។ ខ្មាន់ធ្នូបាញ់សីហៈនោះ ខ្សែធ្នូលាន់ដូចរន្ទះ ចចកបានឮសំឡេងសីហៈ និង

សំឡេងខ្សែធ្នូហើយគិតថា សម្លាញ់របស់អញ ត្រូវខ្មាន់ធ្នូបាញ់ស្លាប់ហើយ ធម្មតាការស្និទ្ធស្នាលនឹងសត្វទាំងឡាយ ដែលស្លាប់ហើយមិនមាន ឥឡូវនេះ អញនឹងនៅតាមប្រក្រតីនោះឯង ។ កាលចរចាជាមួយខ្លួនឯង ទើបពោល គាថា ២ ថា

ធ្នូទន់ខ្ទបទៅផង បន្ទោះលាន់ឮផង ដោយហេតុណា មិគរាជឈ្មោះមនោជៈជាសម្លាញ់របស់អញ ត្រូវគេសម្លាប់ដោយពិត ( ដោយហេតុនោះ ) ។

បើដូច្នោះ មានតែអញនឹងជៀសចេញទៅកាន់ព្រៃជាទីពឹងតាមសេចក្តីសប្បាយ ក្នុងពេលឥឡូវនេះ សត្វស្លាប់បែបនេះនឹងយកធ្វើជាសម្លាញ់មិនកើត កាលបើអញរស់នៅ គង់បានសម្លាញ់ទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថា** បានដល់ ធ្នូដែលទន់ខ្ទបព្រោះហេតុណា ។ បទថា **ហញ្ញតេ ធុវំ** បានដល់ ត្រូវសម្លាប់ពិត ។ បទថា **ឆេកា-និសា** បានដល់ ធម្មតាសម្លាញ់បែបនេះ គឺដែលស្លាប់ហើយនឹងមិនមាន ។ បទថា **លព្ភា** បានដល់ ធម្មតាសម្លាញ់ បើអញនៅមានជីវិត អាចរកបានទៀត ។

ឯសីហៈ ស្ទុះទៅដោយសម្ទុះដ៏រហ័សនោះឯង ទម្លាក់សេះចុះត្រង់ទ្វារគុហា ខ្លួនឯងក៏ដួលស្លាប់ ក្រោយមក ញាតិរបស់សីហៈចេញមកមើល បានឃើញខ្លួនសីហៈប្រឡាក់ដោយឈាម មានឈាមហូរចេញពីមុខរបួសដែល

ត្រូវបាញ់ដល់នូវការអស់ជីវិត ព្រោះគប់រកសត្វអាក្រក់ ។ បា មេ ប្អូនស្រី និង កិរិយារបស់សីហៈ ឃើញហេតុការណ៍នោះ បាននាំគ្នាពោលគាថា ៤ តាមលំដាប់ថា

បុគ្គលដែលសេពគប់ជាមួយនឹងជនបាប មិនបានសេចក្តីសុខដ៏ទៀងទាត់ឡើយ អ្នកចូរមើលសីហៈឈ្មោះមនោជៈកំពុងដេក ( ស្លាប់នេះព្រោះតែជឿតាម ) ពាក្យប្រៀនប្រដៅរបស់ចចកឈ្មោះគិរិយៈ ។

មាតាមិនបានរីករាយជាមួយនឹងកូន ព្រោះតែគប់រកសម្លាញ់អាក្រក់ អ្នកចូរមើលសីហៈឈ្មោះមនោជៈដេកត្រាំនៅក្នុងឈាមរបស់ខ្លួន ។

សត្វណា មិនធ្វើតាមពាក្យនៃជនទាំងឡាយអ្នកប្រាថ្នា នូវសេចក្តីចម្រើនអ្នកឃើញនូវប្រយោជន៍ ( ទៅក្នុងអនាគត ) សត្វនោះ រមែងដល់ ( នូវសេចក្តីទុក្ខ ) យ៉ាងនេះផង តែងជួប ប្រទះនូវទោសដ៏លាមកក្រៃលែងផង ។

បុគ្គលដ៏ឧត្តមណាសេពគប់នឹងអធម្មជន ( ជនដ៏លាមក ) បុគ្គលនោះអាក្រក់ក្រៃលែងជាងអធម្មជននោះទៅទៀត យ៉ាងនេះ អ្នកចូរមើលនូវស្តេចនៃម្រឹគដ៏ឧត្តម ដែលសេពគប់នឹងអធម្មជន ត្រូវកម្លាំងនៃព្រួញដ៏ប្រសើរមុតហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ចន្តំ សុខមេធតិ** សេចក្តីថា មិនបាននូវ

សេចក្តីសុខអស់កាលយូរ ។ បទថា **តិរិយស្សានុសាសនី** សេចក្តីថា ព្រះពោធិសត្វដែលជាបិតាពោលតិះដៀលថា នេះជាអនុសាសនីរបស់ចចកឈ្មោះតិរិយៈ ដែលមានសភាពបែបនេះ ។ បទថា **ទាបសម្បវឌ្ឍន** សេចក្តីថា មានសម្លាញ់ដែលអាក្រក់ ។ បទថា **អជ្ជន្តំ** បានដល់ លិចចុះ ។ បទថា **ទាបិយោ ច និគច្ឆតិ** បានដល់ ជួបនូវវត្ថុដែលអាក្រក់ ។ បទថា **ហិតាន** បានដល់ ដែលប្រាថ្នាប្រយោជន៍ ។ បទថា **អត្ថទស្សិនំ** បានដល់ បុគ្គលណែនាំនូវប្រយោជន៍អនាគត ។ បទថា **ទាបិយោ** បានដល់ អាក្រក់ជាង ។ បទថា **អធម្មជន្ទូបសេវី** បានដល់ គប់រកបុគ្គលអាក្រក់ ។ បទថា **ឧត្តមំ** បានដល់ ដែលចម្រើនបំផុតដោយកម្លាំងរាងកាយ ។

ព្រះសាស្តាបានត្រាស់អភិសម្ពុទ្ធគាថាចុងក្រោយថា

បុរសអ្នកគប់រកនូវជនថោកទាប រមែងសាបសូន្យ បុគ្គលគប់រកនូវជនស្មើៗគ្នា រមែងមិនសាបសូន្យក្នុងកាលណាឡើយ គប់រកនូវជនដែលប្រសើរជាងរមែងចម្រើនឆាប់រួសរាន់ ព្រោះហេតុនោះបុគ្គលគួរតែគប់រកនូវបុគ្គលដែលប្រសើរជាងខ្លួន ។

បណ្តាបទទាំងនោះ បទថា **និហីយតិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ធម្មតាអ្នកសេពគប់បុគ្គលអាក្រក់ រមែងវិនាសទៅ គឺដល់នូវសេចក្តីវិនាស បានដល់ ដល់នូវសេចក្តីវិនាស ដូចសីហឈ្មោះមនោជៈ ។ បទថា **តុល្យសេវី** សេចក្តីថា គប់រកបុគ្គលស្មើខ្លួន ដោយគុណទាំងឡាយ មានសីលគុណជាដើម នឹងមិនវិនាស តែបុគ្គលនោះ នឹងមានសេចក្តីចម្រើនតែម្យ៉ាង ។

បទថា **សេដ្ឋមុបគម្ម** សេចក្ដីថា កាលចូលទៅរកបុគ្គលដែលខ្ពស់ជាងខ្លួន ដោយគុណ មានសីលជាដើមនោះឯង ។ បទថា **ឧទេតិ ចិរប្បំ** បានដល់ ចូលដល់ដោយគុណ មានសីលជាដើម ដោយឆាប់រហ័ស ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាស សច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចៈ ភិក្ខុសេពគប់ខុស តាំងនៅក្នុងសោតា បត្តិផល ហើយទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាទេវទត្តក្នុង កាលឥឡូវនេះ មនោជៈក្នុងកាលនោះ បានមកជាភិក្ខុសេពគប់ខុស ប្អូនស្រី ក្នុងកាលនោះ បានមកជាឧប្បលវណ្ណាថេរី ប្រពន្ធក្នុងកាលនោះ បានមកជា ខេមាភិក្ខុនី មេក្នុងកាលនោះ បានមកជារាហុលមាតា ឯបាក្នុងកាលនោះ គឺ តថាគតនេះឯង ។

## អដ្ឋកថា មនោជជាតក ចប់

# សុតនជាតក

[ ២៨២ ] ( ពោធិសត្វពោលថា ) ស្តេចបានបញ្ជូនភត្តដែល លាយដោយសាច់ដ៏ស្អាតមកឲ្យអ្នក ម្នាលទេវតាអ្នកអាស្រ័យនៅលើដើមជ្រៃគ្រីម អ្នកចូរចេញមកបរិភោគចុះ ។

[ ២៨៣ ] ( យក្ខពោលថា ) នែមាណពអ្នកចូរមក ចូរអ្នកយកបាយព្រមទាំងសម្លដាក់ចុះមក ម្នាលមាណពអ្នកនឹងបានជាចំណី ( នៃយើង ) អ្នកទាំងពីរនឹងបានជាចំណី ។

[ ២៨៤ ] ( ពោធិសត្វពោលថា ) ម្នាលយក្ខ អ្នកនឹងលះបង់នូវប្រយោជន៍ធំ ព្រោះតែហេតុបន្តិចបន្តួច ពួកជនអ្នករន្ធៀសនឹងសេចក្តីស្លាប់ នឹងលែងយកអាហារមកឲ្យអ្នកទៀតហើយ ។

[ ២៨៥ ] ម្នាលយក្ខ អ្នកនឹងបាននូវនិច្ចភត្តដ៏ស្អាតថ្លៃថ្លា ប្រកបដោយរសដ៏ឧត្តម កាលបើអ្នកទំពាស៊ីយើងហើយ ជនអ្នកនាំយកអាហារមកឲ្យអ្នក មុខជាមិនងាយនឹងរកបានក្នុងទីនេះទៀតឡើយ ។

[ ២៨៦ ] ( យក្ខមានចិត្តជ្រះថ្លាហើយបានពោលថា ) ម្នាលសុតនមាណព អ្នកនិយាយ ( បែបនេះ ) ជាប្រយោជន៍ដល់ខ្ញុំមែនហើយ ខ្ញុំព្រមបើកលែងអ្នកទៅហើយ ចូរអ្នកជួបនឹងមាតាដោយសួស្តីចុះ ។

[ ២៨៧ ] ម្នាលមាណព ចូរអ្នកកាន់យកព្រះខ័ន ឆត្រ និងភាជន៍ទៅចុះ សូមឲ្យមាតារបស់អ្នកឃើញអ្នកដោយសួស្តី អ្នកសោតក៏ចូរទៅជួបនឹងមាតាចុះ ។

[ ២៨៨ ] ( ពោធិសត្វពោលថា ) ម្នាលយក្ខ កាលបើយ៉ាងនេះ សូម

ឲ្យអ្នកបានសេចក្ដីសុខ ព្រមទាំងពួកញាតិទាំងអស់ ទ្រព្យក៏ខ្ញុំបានហើយ ទាំងព្រះឱង្ការរបស់ព្រះរាជា ខ្ញុំបានធ្វើរួចហើយ ។

**ចប់ សុតនជាតកទី ៣ ។**

## អដ្ឋកថា

## សុតនជាតក

[ ២៨២-២៨៨ ] ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតា ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **រាជា តេ ភត្តំ** ដូច្នេះជាដើម ។

រឿងនឹងមានច្បាស់ក្នុង ៣ ជាតក ។ តែក្នុងរឿងនេះមានដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលគហបតីក្រីក្រម្នាក់ ។ ញាតិទាំងឡាយបានឲ្យឈ្មោះថាសុតនុ ។ លុះចម្រើនវ័យហើយ បានស៊ីឈ្នួលចិញ្ចឹមមាតាបិតាកាលបិតាអនិច្ចកម្មហើយ ក៏ចិញ្ចឹមមាតា ។ តែក្នុងពេលនោះ ព្រះបាទពារាណសីទ្រង់ជាអ្នកមានព្រះហឫទ័យជាប់ជំពាក់ក្នុងការ បរបាញ់ម្រឹគ ។ ថ្ងៃមួយទ្រង់ចេញទៅព្រៃឆ្ងាយប្រមាណមួយយោជន៍ មួយអន្លើដោយបរិវារជាច្រើនត្រាស់ប្រាប់មនុស្សគ្រប់គ្នាថា បើម្រឹគចេញតាមមុខអ្នកណា អ្នកនោះ ត្រូវពិន័យយ៉ាងនេះ ។ អាមាត្យទាំងឡាយបាននាំគ្នាព័ទ្ធថ្វាយព្រះរាជាក្នុងទីដែលជាផ្លូវ

ដើរជាប្រចាំ ។ ពួកមនុស្សព័ទ្ធត្រង់លំនៅរបស់ម្រឹគហើយ ដេញឲ្យក្រោក ឡើងដោយដុំដីនិងអន្ទត់ខស រមាំងមួយរត់ទៅត្រង់មុខព្រះរាជា ។ ព្រះរាជា គិតថា អញនឹងបាញ់ ហើយបាញ់ព្រួញទៅ តែម្រឹគបានសិក្សាមាយាមកហើយ ដឹងព្រួញដែលបែរមុខមក គេចផុតយ៉ាងសប្បាយ តែធ្វើដូចជាត្រូវព្រួញហើយ ដួលចុះ ។ ព្រះរាជាទ្រង់យល់ថា ម្រឹគត្រូវអញបាញ់ហើយ ទើបទ្រង់ស្ទុះ ទៅដើម្បីចាប់ តែម្រឹគក្រោករត់ទៅដោយរហ័សដូចខ្យល់ ។ ពួកអាមាត្យជា ដើមបាននាំគ្នាចំអកព្រះរាជា ។ ទើបព្រះរាជាដេញតាមទៅ ទាន់ហើយក្នុង កាលដែលម្រឹគអស់កម្លាំង ។ ទ្រង់ដកព្រះខ័នកាប់ជា ២ កំណាត់ ពាក់ទុក ត្រង់កំណាត់ឈើមួយ ដូចដងរែក ហើយរែកមក ទ្រង់គេចចូលទៅកាន់ដើម ជ្រៃដែលនៅឆ្ងាយអំពីផ្លូវ ដោយព្រះតម្រិះថា អញនឹងសម្រាកបន្តិច រួចទ្រង់ ផ្ទំលក់ទៅ ។ យក្ខឈ្មោះមឃទេព កើតត្រង់ដើមជ្រៃនោះ បាននូវសិទ្ធិអាច ស៊ីសត្វដែលចូលទៅក្រោមដើមឈើនោះអំពីព្រះបាទវេស្សវ័ណ យក្ខចាប់ព្រះ ហស្តព្រះរាជាដែលក្រោកឡើង បំណងនឹងយាងទៅ សម្មតថា ឈប់ ឈប់ អ្នកជាភក្ខារបស់យើងហើយ ព្រះរាជាត្រាស់សួរថា ឯងជានរណា យក្ខពោល ថា យើងជាយក្ខកើតក្នុងទីនេះ បានសិទ្ធិស៊ីមនុស្ស និងសត្វដែលចូលមកក្នុង ទីនេះ ព្រះរាជាទ្រង់តាំងសតិ ហើយត្រាស់ថា ឯងនឹងស៊ីចំពោះថ្ងៃនេះឬ ឬ នឹងស៊ីជាប្រចាំ យក្ខឆ្លើយថា បើបាននឹងស៊ីជាប្រចាំ ។ ព្រះរាជាត្រាស់ថា ថ្ងៃនេះ ចូរឯងស៊ីសាច់នេះ ហើយលែងយើងទៅ ចាប់ពីស្អែកនេះទៅ យើង នឹងបញ្ជូនមនុស្ស មកឲ្យម្នាក់មួយថ្ងៃ មួយអន្លើដោយអាហារមួយសម្រាប់ ។

បើយ៉ាងនោះអ្នកកុំភ្លេច ក្នុងថ្ងៃដែលអ្នកមិនបញ្ជូនមនុស្សមក យើងនឹងស៊ីខ្លួនអ្នក ។ ព្រះរាជាត្រាស់ថា យើងជាព្រះរាជាក្រុងពារាណសី ឈ្មោះថារបស់មិនមានសម្រាប់យើងមិនមាន ។

យក្ខទទួលប្តេជ្ញា ហើយបានលែងព្រះរាជាទៅ ។ ព្រះរាជាយាងចូលទៅកាន់ព្រះនគរ ហើយប្រាប់សេចក្តីនោះដល់អាមាត្យជាទីប្រឹក្សាម្នាក់ ហើយត្រាស់សួរថា ឥឡូវនេះ យើងគួរធ្វើដូចម្តេច អាមាត្យទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ធ្វើការកំណត់ថ្ងៃដែរឬទេ ព្រះរាជាត្រាស់ថា មិនបានធ្វើឡើយ អាមាត្យទូលថា ទ្រង់ធ្វើវត្ថុដែលមិនគួរ កាលបើដូច្នោះ សូមទ្រង់កុំគិតថ្វីឡើយ មនុស្សក្នុងគុកមានច្រើន ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរឯងធ្វើការងារនោះរក្សាជីវិតយើង អាមាត្យទទួលថា សាធុ ហើយបើកគុក ឲ្យអ្នកទោសរែកបាយបញ្ជូនទៅឲ្យយក្ខរាល់ថ្ងៃ ដោយមិនឲ្យដឹងរឿងអ្វីឡើយ ។ យក្ខស៊ីកត្តាហារផង ស៊ីមនុស្សផង ។ សម័យក្រោយមក មនុស្សទាំងឡាយក៏អស់ពីគុក គឺអ្នកទោសមិនមាន ។ ព្រះរាជាកាលមិនបានមនុស្សសម្រាប់ជាចំណីយក្ខ ក៏ទ្រង់តក់ស្លុតខ្លាចសេចក្តីស្លាប់ ។ លំដាប់នោះ អាមាត្យកាលនឹងលួងលោមព្រះហឫទ័យទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព បុគ្គលមានចំណង់ក្នុងទ្រព្យ មានច្រើនជាងមនុស្សដែលបំណងក្នុងជីវិត ទូលព្រះបង្គំ នឹងឲ្យដាក់កញ្ចប់ប្រាក់ ១០០០ កហាបណៈ លើកដំរី ហើយឲ្យវាយស្គរប្រកាសថា អ្នកណាទទួលយកទ្រព្យនេះ ហើយកាន់យកកត្តាហារទៅឲ្យយក្ខ ហើយក៏ឲ្យធ្វើយ៉ាងនោះ ។ គ្រានោះ ព្រះពោធិសត្វបានឮពាក្យនោះហើយគិតថា អញ

សន្សំថ្លៃឈ្នួលបានមួយមាសកន្លះ កន្លះមាសកន្លះ ចិញ្ចឹមមាតាដោយលំបាក អញនឹងទទួលយកទ្រព្យនេះឲ្យមាតា ហើយនឹងទៅកាន់សម្នាក់របស់យក្ខ បើអញអាចទូន្មានយក្ខបានសោត ការនេះជាកុសល តែបើមិនអាច មាតារបស់អញក៏គង់មានជីវិតយ៉ាងសប្បាយ ។ ព្រះពោធិសត្វធ្វើការសម្រេចចិត្តហើយ ទើបប្រាប់សេចក្តីនោះឲ្យមាតាជ្រាប ត្រូវមាតាហាមអស់វារៈ ២ ដងថា នែកូន កុំឡើយ ម៉ែមិនត្រូវការទ្រព្យ លើកទី ៣ មិនប្រាប់មាតាឡើយ ប្រាប់អាមាត្យថា នែលោក នាំទ្រព្យ ១០០០ មកចុះ ខ្ញុំនឹងនាំភត្តាហារទៅឲ្យយក្ខ ឲ្យទ្រព្យដល់មាតាហើយ ពោលថា សូមម៉ែកុំគិតថ្វី ខ្ញុំនឹងទូន្មានយក្ខ ធ្វើនូវសួស្តីដល់មហាជន ហើយនឹងត្រឡប់មក ឲ្យផ្ទៃមុខរបស់មាតា ដែលជោកដោយទឹកភ្នែកញញឹមក្នុងថ្ងៃនេះឯង ថ្វាយបង្គំលួងលោមមាតា ឲ្យធូរស្រាលចិត្ត ហើយទៅកាន់រាជសម្នាក់ជាមួយរាជបុរស ថ្វាយបង្គំហើយឈរ ។ បន្ទាប់អំពីនោះ កាលព្រះរាជាត្រាស់ថា នែបា ឯងឬដែលនាំភត្តាហារទៅ ទើបក្រាបទូលថាករុណាថ្លៃវិសេស ព្រះរាជាត្រាស់ថា ឯងគួរបានអ្វី ព្រះពោធិសត្វពោលថា បពិត្រព្រះសម្មតិទេព បាទុកាមាសរបស់ទ្រង់ ព្រះរាជាសួរថាព្រោះហេតុអ្វី ព្រះពោធិសត្វពោលថា បពិត្រព្រះសម្មតិទេព យក្ខនោះ បានស៊ីចំពោះមនុស្សដែលឈរលើផែនដី ត្រង់ក្រោមដើមឈើរបស់ខ្លួន ទូលព្រះបង្គំមិនឈរផ្ទាល់ដីដែលជារបស់យក្ខនោះ តែនឹងឈរលើទ្រនាប់ជើង ព្រះរាជាសួរថា ឯងត្រូវការអ្វីទៀត ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គ ទូលព្រះបង្គំត្រូវការឆត្រ ព្រះរាជាត្រាស់ថា ឆត្រនេះមានប្រយោជន៍ដូចម្តេច ព្រះ

ពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព យក្ខនោះស៊ីមនុស្សដែលឈរក្រោមម្លប់ឈើរបស់ខ្លួន ទូលព្រះបង្គំមិនឈរក្រោមម្លប់ឈើ តែឈរក្រោមម្លប់ឆត្រ ព្រះរាជាត្រាស់ថា ឯងត្រូវការអ្វីទៀត ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព គឺព្រះខ័នរបស់ទ្រង់ ព្រះរាជាត្រាស់ថា ព្រះខ័ននេះមានប្រយោជន៍ដូចម្តេច ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព យក្ខទាំងឡាយខ្លាចព្រះខ័ន សូម្បីមនុស្សទាំងឡាយក៏ខ្លាចដូចគ្នា ព្រះរាជាត្រាស់ថា ឯងត្រូវការអ្វីទៀត ព្រះពោធិសត្វក្រាបទូលថា គ្រឿងភោជនពេញសុវណ្ណភាជន៍របស់ទ្រង់ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រោះថា ធម្មតាការនាំភោជនីយាហារដែលអាក្រក់ៗ ដាក់ក្នុងថាសដី គឺអំបែងទៅ រមែងមិនគួរដល់បុរសជាតិបណ្ឌិតដូចទូលបង្គំ ។ ព្រះរាជាត្រាស់ថា សាធុ ទ្រង់ប្រទានគ្រប់យ៉ាង ហើយទ្រង់ឲ្យអ្នកបម្រើព្រះពោធិសត្វម្នាក់ទៅ ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់កុំខ្លាច ថ្ងៃនេះទូលព្រះបង្គំនឹងទូន្មានយក្ខ ធ្វើនូវសួស្តីដល់ទ្រង់ ហើយនឹងមក ។ ថ្វាយបង្គំព្រះរាជា ហើយឲ្យមនុស្សកាន់គ្រឿងឧបករណ៍ទៅក្នុងទីនោះ ឲ្យមនុស្សទាំងឡាយឈរមិនឆ្ងាយអំពីដើមឈើ ពាក់ទ្រនាប់ជើងមាស សៀតព្រះខ័ន បាំងឆត្រលើក្បាល កាន់ថាសមាសដាក់អាហារទៅកាន់សម្នាក់របស់យក្ខ ។ យក្ខចាំមើលផ្លូវ ឃើញព្រះពោធិសត្វនោះ ទើបគិតថា បុរសនេះ មិនមកដោយទំនងការមកក្នុងថ្ងៃដទៃៗ នឹងមានហេតុអ្វីហ្ន៎ ព្រះពោធិសត្វទៅក្បែរដើមឈើ យកចុងដាវរុញថាសភត្តចូលទៅខាងក្រោមម្លប់ឈើ

ខ្ជួនឯងឈរផុតម្លប់ឈើនោះឯង ពោលគាថាទី ១ ថា

ស្តេចបានបញ្ជូនកត្ត ដែលលាយដោយសាច់ដ៏ស្អាតមកឲ្យអ្នក ម្នាលទេវតាអ្នកអាស្រ័យនៅលើដើមជ្រៃក្រឹម អ្នកចូរចេញមកបរិភោគចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាហាសិ** សេចក្តីថា ទ្រង់បញ្ជូនមក ។ បទថា **មយគោវស្មឹ អធិវត្ថេ** សេចក្តីថា ដើមជ្រៃ[១]ហៅថា មយទេព ។ ព្រះពោធិសត្វហៅទេវតាថា អ្នកដែលអាស្រ័យនៅត្រង់ដើមជ្រៃនោះ ។

យក្ខបានស្តាប់ពាក្យនោះហើយ គិតថា អញនឹងបោកបុរសនេះឲ្យចូលមកក្រោមម្លប់ឈើ ហើយនឹងស៊ី ដូច្នេះហើយ បានពោលគាថាទី ២ ថា

នែមាណពអ្នកចូរមក ចូរអ្នកយកបាយព្រមទាំងសម្ល ដាក់ចុះមក ម្នាលមាណពអ្នកនឹងបានជាចំណី ( នៃយើង ) អ្នកទាំងពីរនឹងបានជាចំណី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភិក្ខំ** បានដល់ កត្តាហារប្រចាំ ។ បទថា **សូបិតំ** សេចក្តីថា ដល់ព្រមដោយម្ហូប ។

បន្ទាប់ពីនោះ ព្រះពោធិសត្វពោលគាថា ២ ថា

ម្នាលយក្ខ អ្នកនឹងលះបង់នូវប្រយោជន៍ធំ ព្រោះតែហេតុបន្តិចបន្តួច ពួកជនអ្នករន្ធៀសនឹងសេចក្តីស្លាប់ នឹងលែងយកអាហារមកឲ្យអ្នកទៀតហើយ ។

---

១-បិដកខ្មែរជាដើមជ្រៃក្រឹម ។

ម្នាលយក្ខ អ្នកនឹងបាននូវនិច្ចភត្តដ៏ស្អាតថ្លៃថ្លា ប្រកបដោយ
រសដ៏ឧត្តម កាលបើអ្នកទំពាស៊ីយើងហើយ ជនអ្នកនាំយក
អាហារមកឲ្យអ្នក មុខជាមិនងាយនឹងរកបាន ក្នុងទីនេះទៀត
ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជហិស្សមត្ថំ** សេចក្តីថា ព្រះពោធិសត្វសម្តែងថា អ្នកនឹងលះប្រយោជន៍ជាច្រើន ព្រោះហេតុប្រមាណតិចតួច ។ បទថា **ឆាហារិស្សន្តិ** សេចក្តីថា ចាប់តាំងអំពីនេះទៅ មនុស្សទាំងឡាយដែលតក់ស្លុតក្នុងសេចក្តីស្លាប់ នឹងមិននាំភត្តាមកឲ្យ កាលបើដូច្នោះ អ្នកនឹងជាបុគ្គលមិនមានអាហារ មានកម្លាំងតិចតួច ដូចដើមឈើដែលមានមែកក្រៀមស្វិតដូច្នោះ ។ បទថា **លទ្ធាយំ** សេចក្តីថា ដែលបាននេះ គឺបានមក មានអធិប្បាយថា សម្លាញ់យក្ខ ថ្ងៃនេះ ខ្ញុំនាំភិក្ខាហារមក ភិក្ខាហារដែលខ្ញុំនាំមកនេះ ជាភិក្ខាហារប្រចាំរបស់អ្នក ជារបស់ស្អាតប្រណីត ប្រកបដោយរសដ៏ប្រសើរ ជារបស់ដែលមកល្អ គឺនឹងមករកអ្នករាល់ថ្ងៃ ។ បទថា **អាហារិយោ** បានដល់ ជាអ្នកនាំមក មានអធិប្បាយថា បើអ្នកស៊ីខ្ញុំ បុគ្គលដែលកាន់អាហារនេះមកឲ្យខាងក្រោយ កាលខ្ញុំត្រូវស៊ីយ៉ាងនេះ អ្នកដទៃដែលនាំភិក្ខាមកឲ្យនឹងរកបានដោយលំបាកក្នុងទីនេះ ។ ព្រោះហេតុអ្វី ព្រោះអ្នកដទៃដែលជាអ្នកឈ្លាសដូចខ្ញុំ ក្នុងនគរពារាណសីមិនមាន ។ តែកាលខ្ញុំត្រូវស៊ីហើយ មនុស្សទាំងឡាយក៏នឹងពោលថា យក្ខស៊ីបុរសឈ្មោះសុតនុ យក្ខមិនខ្លាសចំពោះបុគ្គលដទៃឡើយ អ្នកក៏នឹងមិនបានមនុស្សនាំភត្តាហារមកឲ្យ ។

កាលបើដូច្នោះ ចាប់ពីពេលនេះទៅ ភោជនីយាហារ នឹងជារបស់រកលំបាក សម្រាប់អ្នក ។ ចំណែកអ្នកក៏ចាប់ព្រះរាជារបស់ខ្ញុំមិនបាន ព្រោះហេតុអ្វី ព្រោះការឈរខាងក្រៅដើមឈើ តែបើអ្នកទទួលទានកត្តាហារនេះហើយ បញ្ជូនខ្ញុំទៅសោត ខ្ញុំក៏នឹងក្រាបទូលព្រះរាជាឲ្យទ្រង់បញ្ជូនកត្តាហារជាប្រចាំ ដល់អ្នក ។ សូម្បីខ្ញុំខ្លួនឯង ក៏នឹងមិនឲ្យអ្នកស៊ី ព្រោះថាខ្ញុំមិនឈរក្នុងសម្នាក់របស់អ្នក ឈរលើទ្រនាប់ជើង និងមិនត្រេកអរក្នុងម្លប់ឈើរបស់អ្នក ។ ខ្ញុំឈរក្រោមឆត្ររបស់ខ្លួនប៉ុណ្ណោះ ។ តែបើអ្នកចង់ច្បាំងជាមួយខ្ញុំ ខ្ញុំនឹងប្រើព្រះខ័នកាប់អ្នកឲ្យដាច់ជា ២ កំណាត់ ព្រោះថ្ងៃនេះ ខ្ញុំត្រៀមខ្លួនហើយទើបមកដើម្បីប្រយោជន៍នេះប៉ុណ្ណោះ ។ បានឮថា ព្រះមហាសត្វសម្លុតយក្ខនោះ យ៉ាងនោះ ។ យក្ខសង្កេតឃើញថា មាណពពោលត្រឹមត្រូវ មានចិត្តជ្រះថ្លា បានពោលគាថា ២ ថា

ម្នាល សុតនមាណព អ្នកនិយាយ ( បែបនេះ ) ជាប្រយោជន៍ដល់ខ្ញុំមែនហើយ ខ្ញុំព្រមបើកលែងអ្នកទៅហើយ ចូរអ្នកជួបនឹងមាតា ដោយសួស្តីចុះ ។

ម្នាលមាណព ចូរអ្នកកាន់យកព្រះខ័ន ឆត្រ និង ភាជន៍ទៅចុះ សូមឲ្យមាតារបស់អ្នក ឃើញអ្នកដោយសួស្តី អ្នកសោត ក៏ចូរទៅជួបនឹងមាតាចុះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគាថានោះដូច្នេះថា យក្ខហៅព្រះពោធិសត្វថា សុតនៈ ។ បទថា **យថា ភាសសិ** សេចក្តីថា ប្រយោជន៍របស់ខ្ញុំនោះឯង

តាមដែលអ្នកពោលដល់ រមែងចម្រើនដល់ខ្ញុំនោះឯង ។

ព្រះពោធិសត្វ បានឮពាក្យរបស់យក្ខនោះហើយ ត្រេកអរថា ការងាររបស់អញសម្រេចហើយ យក្ខអញទូន្មានបានហើយ អញបានទ្រព្យជាច្រើន បានទាំងបដិបត្តិតាមព្រះរាជតម្រាស់ហើយ កាលនឹងធ្វើការអនុមោទនា ទើបពោលគាថាចុងក្រោយថា

ម្នាលយក្ខ កាលបើយ៉ាងនេះ សូមឲ្យអ្នកបានសេចក្ដីសុខព្រម
ទាំងពួកញាតិទាំងអស់ ទ្រព្យក៏ខ្ញុំបានហើយ ទាំងព្រះឱង្ការ
របស់ព្រះរាជា ខ្ញុំបានធ្វើរួចហើយ ដូច្នេះ ។

កាលព្រះពោធិសត្វពោលគាថាហើយ ក៏ហៅយក្ខមក ហើយប្រាប់អានិសង្សសីលនិងទោសនៃការទ្រុស្តសីលថា នែសម្លាញ់ កាលមុនអ្នកធ្វើអកុសលកម្មទុក ទើបកើតជាបុគ្គលរឹងត្អឹងគ្រោតគ្រាត មានសាច់ឈាមអ្នកដទៃជាភិក្ខាហារ តែបន្ទាប់ពីនេះទៅ អ្នកកុំធ្វើអកុសលកម្មគឺបាណាតិបាតជាដើម ហើយឲ្យយក្ខតាំងនៅក្នុងសីល ៥ ពោលថា អ្នកនឹងមានប្រយោជន៍អ្វីដោយការនៅព្រៃ មកខ្ញុំនឹងឲ្យអ្នកអង្គុយត្រង់ទ្វារនគរ ហើយធ្វើឲ្យមានលាភ មានកត្តាហារដ៏ប្រសើរជាដើម ហើយចេញទៅជាមួយយក្ខ ឲ្យយក្ខនោះឯងកាន់ព្រះខ័នជាដើមទៅកាន់នគរពារាណសី អាមាត្យទាំងឡាយនាំគ្នាក្រាបទូលព្រះរាជាថា សុតនុមាណពបាននាំយក្ខមក ។ ព្រះរាជាមានពួកអាមាត្យចោមរោមធ្វើការទទួលព្រះពោធិសត្វ ឲ្យយក្ខអង្គុយត្រង់ទ្វារនគរ ធ្វើឲ្យយក្ខបាននូវលាភមានកត្តាហារដ៏ប្រសើរជាដើម ហើយយាងចូលព្រះនគរ ។ ទ្រង់ឲ្យវាយស្គរ

ប្រកាសឲ្យអ្នកនគរប្រជុំគ្នា ត្រាស់ប្រាប់គុណរបស់ព្រះពោធិសត្វ រួចព្រះរាជទានតំណែងជាសេនាបតីដល់ព្រះពោធិសត្វ ហើយទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យទាំងឡាយមានទានជាដើម ហើយមានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសំដែងហើយទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចៈ ភិក្ខុអ្នកចិញ្ចឹមមាតា តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា យក្ខក្នុងកាលនោះ បានមកជាអង្គុលិមាលក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែកមាណពក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា សុតនជាតក ចប់

# មាតុបោសកគិជ្ឈជាតក

[ ២៨៩ ] ( ត្មាតពោធិសត្វពោលថា ) មាតាបិតាទាំងនោះចាស់ អាស្រ័យនៅព្លដ៏ប្រកនៃភ្នំ នឹងធ្វើដូចម្ដេចហ្ន៎ អាត្មាអញជាប់អន្ទាក់ លុះអំណាចនេសាទបុត្ត ឈ្មោះនិលិយៈហើយ ។

[ ២៩០ ] ( នេសាទបុត្តពោលថា ) ម្នាលត្មាតហេតុដូចម្ដេច ក៏បានជាអ្នកខ្សឹកខ្សួល ការខ្សឹកខ្សួលរបស់អ្នកដូចម្ដេចហ្ន៎ បក្សីចេះនិយាយសម្ដីមនុស្ស យើងមិនដែលឮ មិនដែលឃើញសោះឡើយ ។

[ ២៩១ ] ( ពោធិសត្វពោលថា ) យើងចិញ្ចឹមមាតាបិតាចាស់ អាស្រ័យនៅព្លដ៏ប្រកនៃភ្នំ យើងលុះក្នុងអំណាចអ្នកហើយ មាតាបិតាទាំងនោះនឹងធ្វើដូចម្ដេចហ្ន៎ ។

[ ២៩២ ] ( នេសាទបុត្តពោលថា ) ក្រែងត្មាតរមែងមើលឃើញសាកសពចម្ងាយ ១០០ យោជន៍បានឬ ចុះហេតុអ្វីបានជាអ្នកមកជាប់លប់និងអន្ទាក់ ក៏មិនភ្ញាក់ខ្លួនសោះ ។

[ ២៩៣ ] ( ពោធិសត្វពោលថា ) ពេលណាដែលមានសេចក្ដីវិនាស ( មកដល់ ) ពេលនោះសត្វដែលនឹងអស់ជីវិត បើទុកជាមកជាប់លប់និងអន្ទាក់ ក៏គង់មិនអាចភ្ញាក់ខ្លួនបាន ។

[ ២៩៤ ] ( នេសាទបុត្តពោលថា ) អ្នកចូរទៅចិញ្ចឹមមាតា បិតាចាស់ជរា ដែលអាស្រ័យនៅព្លដ៏ប្រកនៃភ្នំចុះ យើងបានបើកលែងអ្នកហើយ ចូរអ្នកទៅជួបនឹងញាតិសន្ដានដោយសួស្ដីចុះ ។

[ ២៩៥ ] ( ពោធិសត្វពោលថា ) ម្នាលព្រាន អ្នកចូររីករាយជាមួយ

នឹងពួកញាតិទាំងអស់យ៉ាងនេះចុះ យើងនឹងចិញ្ចឹមមាតាបិតាចាស់ ដែលអាស្រ័យនៅព្លដ៏ប្រកនៃភ្នំ ។

ចប់ មាតុបោសកគិជ្ឈជាតកទី ៤ ។

# អដ្ឋកថា

## មាតុបោសកគិជ្ឈជាតក

[២៨៩-២៩៥] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមមាតា ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **តេ កថំ នុ ករិស្សន្តិ** ដូច្នេះជាដើម ។

រឿងនឹងមានជាក់ច្បាស់ក្នុងសាមជាតក ។

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតត្មាត ធំចម្រើនហើយ ឲ្យមេបាដែលចាស់ជរាមានភ្នែកទុព្វលហើយ ស្ថិតនៅត្រង់គុហានាភ្នំគិជ្ឈកូដ នាំសាច់គោជាដើមមកចិញ្ចឹម ។ ពេលនោះ ក្នុងក្រុងពារាណសី ព្រានម្នាក់ដាក់អន្ទាក់ត្មាតដោយមិនកំណត់កាលក្នុងព្រៃខ្មោច ។ ថ្ងៃមួយ ព្រះពោធិសត្វកាលស្វែងរកសាច់គោ ចូលទៅកាន់ព្រៃខ្មោច ក៏ជាប់អន្ទាក់ តែមិនគិតដល់ខ្លួន រឭកដល់មេបាដែលចាស់ជរា ហើយយំរៀបរាប់ថា មេបារបស់អញនឹងនៅបានដូចម្តេចហ្ន៎ មិនដឹងថាអញជាប់អន្ទាក់ឡើយ អស់នូវទីពឹង ដាច់នូវអាហារ លោកប្រហែលជាស្គមស្លាប់ក្នុងគុហា ភ្នំនោះឯង ដូច្នេះ ពោលគាថាទី ១ ថា

មាតាបិតាទាំងនោះចាស់ អាស្រ័យនៅព្នដ៏ប្រកនៃភ្នំ នឹងធ្វើដូចម្ដេចហ្ន៎ អាត្មាអញជាប់អន្ទាក់ លុះអំណាចនេសាទបុត្តឈ្មោះនិលិយៈហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និលិយស្ស** បានដល់ បុត្តរបស់នាយព្រានដែលមានឈ្មោះយ៉ាងនេះ ។ បុត្តរបស់នាយព្រាន បានឮពាក្យកន្ទក់កន្ទេញរបស់ត្មាតនោះហើយ ទើបពោលថា

ម្នាលត្មាតហេតុដូចម្ដេច ក៏បានជាអ្នកខ្សឹកខ្សួល ការខ្សឹកខ្សួលរបស់អ្នកដូចម្ដេចហ្ន៎ បក្សីចេះនិយាយសម្ដីមនុស្ស យើងមិនដែលឮ មិនដែលឃើញសោះឡើយ ដូច្នេះ ។

ត្មាតពោធិសត្វពោលថា

យើងចិញ្ចឹមមាតាបិតាចាស់ អាស្រ័យនៅព្នដ៏ប្រកនៃភ្នំ យើងលុះក្នុងអំណាចអ្នកហើយ មាតាបិតាទាំងនោះនឹងធ្វើដូចម្ដេចហ្ន៎ ដូច្នេះ ។

នាយព្រានពោលថា

ក្រែងត្មាតរមែងមើលឃើញសាកសពចម្ងាយ ១០០ យោជន៍បានឬ ចុះហេតុអ្វីបានជាអ្នកមកជាប់លប់និងអន្ទាក់ ក៏មិនភ្ញាក់ខ្លួនសោះ ដូច្នេះ ។

ត្មាតពោធិសត្វពោលថា

ពេលណាដែលមានសេចក្ដីវិនាស ( មកដល់ ) ពេលនោះ

សត្វដែលនឹងអស់ជីវិត បើទុកជាមកជាប់លប់និងអន្ទាក់ ក៏គង់
មិនអាចភ្ញាក់ខ្លួនបាន ដូច្នេះ ។

នាយព្រានពោលថា

អ្នកចូរទៅចិញ្ចឹមមាតាបិតាចាស់ជរា ដែលអាស្រ័យនៅ ត្នូដ៏
ប្រកនៃភ្នំចុះ យើងបានបើកលែងអ្នកហើយ ចូរអ្នកទៅជួបនឹង
ញាតិសន្តានដោយសួស្តីចុះ ។

ត្មាតពោធិសត្វពោលថា

ម្នាលព្រាន អ្នកចូររីករាយជាមួយនឹងពួកញាតិទាំងអស់យ៉ាង
នេះចុះ យើងនឹងចិញ្ចឹមមាតាបិតាចាស់ដែល អាស្រ័យនៅត្នូ
ដ៏ប្រកនៃភ្នំ ។

គាថាទាំងនេះ គាថាទី ២ នាយព្រានជាអ្នកពោលថា គាថាទី ៣ ព្រះពោធិសត្វជាអ្នកពោលតាមលំដាប់ ។

បណ្តាបទទាំងនោះ បទថា **យន្នុ** សេចក្តីថា សត្វលោកពោលពាក្យនេះទុក ។ បទថា **គិជ្ឈោ យោជនសតំ កុណបានិ អវេក្ខតិ** សេចក្តីថា ត្មាតមើលឃើញសាកសពឆ្ងាយជាង ១០០ យោជន៍ បើសត្វលោកពោលពាក្យនោះសោត កាលបើដូច្នោះ ព្រោះហេតុអ្វីទើបត្មាតចូលទៅជិតជង់និងអន្ទាក់ក៏នៅតែមិនដឹងខ្លួន គឺសូម្បីដល់ហើយ ក៏មិនដឹងខ្លួន ។ បទថា **បរាភវោ** បានដល់ សេចក្តីវិនាស ។ បទថា **ភរស្សុ** សេចក្តីថា ព្រាននោះ កាលបានស្តាប់ធម្មកថា របស់ព្រះពោធិសត្វនោះហើយ គិតថា ស្តេចត្មាតអ្នកឈ្លាស

កាលកន្ទក់កន្ទេញ ក៏មិនកន្ទក់កន្ទេញដើម្បីខ្លួន តែកន្ទក់កន្ទេញដើម្បីមេទិងបា ស្តេចត្មាតនេះ មិនគួរស្លាប់ ហើយបានពោលដោយសេចក្តីត្រេកអរចំពោះ ព្រះពោធិសត្វនោះ កាលពោលហើយ ក៏ស្រាយអន្ទាក់ចេញ ដោយចិត្តទន់ ភ្លន់ ។

លំដាប់នោះ ព្រះពោធិសត្វផុតចាកមរណទុក្ខ មានសុខក្នុងចិត្ត កាល នឹងធ្វើអនុមោទនាដល់ព្រានទោះ ទើបពោលថាចុងក្រោយ ហើយពាំយក សាច់ពេញមាត់ ទៅរកបាទិងមេ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើប ប្រកាសសច្ចៈធម៌ទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុអ្នកចិញ្ចឹមមាតាបាន តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា កូនព្រានក្នុងកាលនោះ បានមកជាឆន្នត្ថេរក្នុងកាលឥឡូវនេះ បាទិងមេក្នុងកាលនោះ បានមកជាត្រ- កូលមហារាជ ចំណែកស្តេចត្មាតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា មាតុបោសកគិជ្ឈជាតក ចប់

# ធម្មទុព្ពុប្ផជាតក

[ ២៩៦ ] ( ភេដែលត្រាច់ទៅក្នុងទឹកជ្រៅពោលថា ) ម្នាលសម្លាញ់ អ្នកត្រាច់ទៅតាមឆ្នេរដ៏ចម្រើន សូមអ្នកស្ទុះមកជួយខ្ញុំ ខ្ញុំចាប់បានត្រីធំ វានាំខ្ញុំទៅដោយកម្លាំងដ៏ខ្លាំង ។

[ ២៩៧ ] ( ភេត្រាច់ទៅតាមឆ្នេរក្រៅនេះពោលថា ) ម្នាលអ្នកត្រាច់ទៅក្នុងទឹកជ្រៅដ៏ចម្រើន អ្នកចូរចាប់ដោយកម្លាំងយ៉ាងមាំ ខ្ញុំនឹងជួយយោងយកត្រីនោះ ដូចគ្រុឌដែលស្រង់ឡើងនូវពស់ ។

[ ២៩៨ ] ( ភេទាំងពីរឃើញចចកហើយពោលថា ) ម្នាលចចកទព្វបុប្ផៈ ចូរអ្នកស្តាប់ពាក្យយើង វិវាទកើតដល់យើងហើយ ម្នាលសម្លាញ់ អ្នកចូររម្ងាប់នូវជម្លោះ ឲ្យវិវាទ ( របស់យើង ) ស្ងប់រម្ងាប់ទៅ ។

[ ២៩៩ ] ( ចចកពោលថា ) កាលពីដើមយើងជាអ្នកឋិតនៅក្នុងតំណែងជម្រះក្តី បានកាត់ក្តីឲ្យគេជាច្រើនមកហើយ ម្នាលសម្លាញ់ យើងនឹងរម្ងាប់នូវជម្លោះ ( របស់អ្នកទាំងឡាយ ) សូមឲ្យវិវាទ ( របស់អ្នកទាំងឡាយ ) ស្ងប់រម្ងាប់ទៅ ។

[ ៣០០ ] ម្នាលភេអ្នកត្រាច់ទៅតាមឆ្នេរ ( អ្នកត្រូវបាន ) កន្ទុយ ភេដែលត្រាច់ទៅក្នុងទឹកជ្រៅ ( ត្រូវបាន ) ក្បាល ដុំជាកណ្តាលក្រៅអំពីចំណែកពីរនេះ ត្រូវបាន ( យើង ) អ្នកឋិតនៅក្នុងតំណែងជម្រះក្តី ។

[ ៣០១ ] ( ភេទាំងពីរត្អូញថា ) ប្រសិនបើយើងកុំទាស់គ្នា ( ត្រីនេះ ) នឹងបានជាអាហារអស់កាលដ៏យូរ ចចកពាំយកត្រីគ្មានឥតក្បាលឥតកន្ទុយទៅព្រងើយ ។

[ ៣០២ ] ( មេចចកពោលថា ) ខត្តិយរាជ បានទូវរាជសម្បត្តិ ហើយរីករាយយ៉ាងណាមិញ ក្នុងថ្ងៃនេះខ្ញុំឃើញប្តីដែលមានមុខរីកហើយ ក៏មានចិត្តរីករាយយ៉ាងនោះដែរ ។

[ ៣០៣ ] អ្នកជាសត្វកើតលើគោកទេ ម្តេចក៏ចាប់ត្រីក្នុងទឹកបាន ម្នាលសម្លាញ់ ខ្ញុំសួរហើយសូមអ្នកប្រាប់ អ្នកចាប់ ( ត្រី ) បានដោយហេតុដូចម្តេច ។

[ ៣០៤ ] ( ចចកពោលថា ) សត្វទាំងឡាយស្គាំងស្គមព្រោះតែការទាស់ទែងគ្នា ការអស់ទ្រព្យសម្បត្តិ ក៏ព្រោះតែទាស់ទែងគ្នាដែរ ភេ ( ទាំងពីរ ) សាបសូន្យ ( ចាកត្រី ) ព្រោះតែទាស់ទែងគ្នា នែនាងមាយាវី នាងចូរបរិភោគនូវត្រីឆ្ពិនចុះ ។

[ ៣០៥ ] ( អភិសម្ពុទ្ធគាថា ) ក្នុងទីណាវិវាទកើតឡើង ក្នុងពួកមនុស្ស ( មនុស្សទាំងឡាយ ) រមែងស្ទុះស្ទារទៅពឹងចៅក្រមអ្នកកាត់ក្តី ត្បិតចៅក្រមនោះជាអ្នកដឹកនាំមនុស្សទាំងនោះ មនុស្សទាំងនោះ រមែងសាបសូន្យចាកទ្រព្យ ( របស់ខ្លួន ) ក្នុងទីនោះ ឃ្លាំងរបស់ព្រះរាជារមែងចម្រើនក៏យ៉ាងនោះដែរ ។

**ចប់ ទព្វបុប្ផជាតកទី ៥ ។**

# អដ្ឋកថា

## ឧព្ភបុប្ផជាតក

[ ២៩៦-៣០៦ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧបនន្ទសក្យបុត្ត ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អនុតីរចារី ភទ្ទន្តេ** ដូច្នេះជាដើម ។

មានសេចក្តីសង្ខេបថា ព្រះឧបនន្ទសក្យបុត្ត លោកបួសក្នុងព្រះសាសនាហើយ លះគុណធម៌ មានការប្រាថ្នាតិចជាដើម បានជាអ្នកល្មោភច្រើន ក្នុងថ្ងៃចូលវស្សា លោកគ្រប់គ្រងវត្តពីរបីវត្ត គឺផ្ញើធត្រឬស្បែកជើងទុកត្រង់វត្តមួយ ឈើច្រត់ឬបំពង់ទឹកទុកក្នុងវត្តមួយ ខ្លួនឯងក៏នៅក្នុងវត្តមួយ ។ លោកចាំវស្សាក្នុងវត្តជនបទមួយ បង្រៀនបដិបទាដែលជាអរិយវង្ស ដែលសម្តែងដល់ការសន្តោសក្នុងបច្ច័យដល់ភិក្ខុទាំងឡាយ ជាក់ច្បាស់ ដូចលើកព្រះចន្ទឡើងដាក់ក្នុងអាកាសពោលថា ធម្មតាភិក្ខុ គួរជាអ្នកប្រាថ្នាតិច ជាដើម ។ ភិក្ខុទាំងឡាយបានស្តាប់ពាក្យនោះហើយ នាំគ្នាចោលបាត្រ និងចីវរដែលគាប់ចិត្ត ទទួលយកបាត្រដីនិងសំពត់បង្សុកូល ។ លោកឲ្យភិក្ខុទាំងឡាយទុករបស់ទាំងនោះក្នុងលំនៅរបស់លោក ចេញវស្សាបវារណាហើយ ដាក់ពេញរទេះតូចទៅកាន់វត្តជេតពនមហាវិហារ ត្រូវវល្លិទាក់ជើងត្រង់វត្តមួយកន្លែងក្នុងរវាងផ្លូវយល់ថា នឹងត្រូវមានរបស់អ្វីដែលអញគួរបានក្នុងវត្តនេះ ពិតប្រាកដហើយ ទើបចៀងចូលវត្តនោះ ។ ក្នុងវត្តនោះ មានភិក្ខុចាស់ ២ រូបចាំវស្សា ។ លោកបានសំពត់សាដកសាច់គ្រោតគ្រាត ២ ផ្ទាំង និងសំពត់កម្ពលសាច់ម៉ដ្តមួយផ្ទាំង មិនអាចចែកគ្នាបាន ឃើញព្រះឧបនន្ទមក ក្រោកអរថា ព្រះថេរៈនឹង

ចែកឲ្យពួកយើងបានពិត ទើបនាំគ្នាប្រាប់ថា អាវុសោ ពួកខ្ញុំមិនអាចចែកសំពត់ចំណាំវស្សានេះបាន ពួកខ្ញុំវិវាទគ្នា ព្រោះសំពត់ចាំវស្សានេះ ចូរអាវុសោចែកសំពត់នេះដល់ពួកខ្ញុំ ។ ព្រះថេរៈទទួលថា សាធុ ខ្ញុំនឹងចែកឲ្យ ហើយបានចែកសំពត់សាដកសាច់គ្រោតគ្រាតឲ្យភិក្ខុ ២ រូបនោះ ប្រាប់ថា សំពត់នេះ គឺសំពត់កម្ពល ត្រូវធ្លាក់ដល់ខ្ញុំជាវិនយធរ ហើយកាន់យកសំពត់កម្ពលចៀសចេញទៅ ។ ព្រះថេរៈទាំងនោះ នៅមានសេចក្តីអាល័យ ក្នុងសំពត់កម្ពល ទើបនាំគ្នាទៅកាន់វត្តជេតពនមហាវិហារ មួយអន្លើដោយព្រះឧបនន្ទនោះឯង បានប្រាប់សេចក្តីនោះដល់ភិក្ខុទាំងឡាយ ដែលជាព្រះវិនយធរ ហើយពោលថា បពិត្រលោកម្ចាស់ មានឬហ្ន៎ ការដែលវិនយធរទាំងឡាយប្រើប្រាស់វត្ថុដែលជណ្តើមមកយ៉ាងនេះ ។ ភិក្ខុទាំងឡាយឃើញគំនរបាត្រ និងចីវរដែលព្រះឧបនន្ទនាំមកហើយ ពោលថា អាវុសោ លោកមានបុណ្យច្រើនឬ ទើបបានបាត្រនិងចីវរច្រើន ។ លោកប្រាប់គ្រប់យ៉ាងថា អាវុសោ ខ្ញុំមានបុណ្យអំពីណា បាត្រ និងចីវរនេះ ខ្ញុំបានមកដោយឧបាយនេះ ។ ភិក្ខុទាំងឡាយនាំគ្នាលើករឿងនេះឡើងក្នុងធម្មសភាថា នែអាវុសោ ឧបនន្ទសក្យបុត្រមានសេចក្តីប្រាថ្នាច្រើន មានសេចក្តីល្មោភច្រើន ។ ព្រះសាស្តាយាងមកដល់ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះអ្នកទាំងឡាយ អង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទ មិនធ្វើវត្តុដែលសមគួរដល់បដិបទា ធម្មតាភិក្ខុ កាលនឹងប្រាប់បដិបទា

ដល់អ្នកដទៃ គួរធ្វើឲ្យសមគួរដល់ខ្លួនជាមុន ហើយសឹមឲ្យឱវាទដល់អ្នកដទៃក្នុងកាលជាក្រោយ ហើយទ្រង់សម្តែងធម៌ដោយគាថាក្នុងធម្មបទនេះថា

បណ្ឌិតគួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយ
សឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ ( ធ្វើយ៉ាងនេះ ) នឹង
មិនលំបាកឡើយ ដូច្នេះ ។

ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទមិនមែនលោភច្រើនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ឧបនន្ទក៏មានសេចក្តីលោភច្រើនដូចគ្នា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ឧបនន្ទក៏ដណ្តើមយកដូចគ្នា ហើយទ្រង់បាននាំយករឿងក្នុងអតីត មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតជារុក្ខទេវតា ត្រង់ច្រាំងស្ទឹង ។ កាលនោះ ចចកមួយនាំចចកញីឈ្មោះមាយាវី ទៅកាន់ទីមួយកន្លែងក្បែរឆ្នេរស្ទឹង ។ ថ្ងៃមួយ ចចកញីពោលនឹងចចកឈ្មោលថា ខ្ញុំចាញ់ផ្ទៃហើយ ខ្ញុំចង់ស៊ីត្រីក្ដិនស្រស់ ។ ចចកឈ្មោលប្រាប់ថា នាងកុំព្រួយ អញនឹងនាំមកឲ្យបាន ទើបដើរទៅត្រង់ឆ្នេរស្ទឹង ត្រូវវល្លិទាក់ជើង ទើបដើរទៅតាមឆ្នេរស្ទឹងនោះឯង គ្រានោះភេ ២ ភេមួយរកស៊ីទឹកជ្រៅជាប្រក្រតី ឯភេមួយរកស៊ីទឹករាក់ជាប្រក្រតី កំពុងស្វែងរកត្រី បានឃើញត្រីរង្គធំ ។ បណ្តាភេ ២ នោះ ភេមួយរកស៊ីទឹកជ្រៅ ឃើញត្រីក្ដិនធំមួយ ទើបមុជទឹកទៅ ដោយរហ័ស ខាំត្រង់កន្ទុយត្រីបាន តែត្រីមាន

កម្លាំងខ្លាំង ក៏ទាញកេទៅ ។ ទើបកេដែលរកស៊ីទឹកជ្រៅចរចាជាមួយកេមួយទៀតថា ត្រីនេះធំល្មមយើង ២ នាក់ស៊ីបាន ណ្ហើយចុះសម្លាញ់ ចូរអ្នកសហការជាមួយយើង ហើយពោលគាថាទី ១ ថា

ម្នាលសម្លាញ់ អ្នកត្រាច់ទៅតាមច្រាំងដ៏ចម្រើន សូមអ្នកស្ទុះមក
ជួយខ្ញុំ ខ្ញុំចាប់បានត្រីធំ វានាំខ្ញុំទៅដោយកម្លាំងដ៏ខ្លាំង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សហាយមនុធាវ មំ** កាត់បទជា **សហាយ អនុធាវ មំ** សេចក្ដីថា នែសម្លាញ់ ចូរតាមខ្ញុំមក ។ **ម** អក្ខរៈ លោកពោលទុកដោយអំណាចសន្ធិ ។ មានពាក្យអធិប្បាយថា សូមសម្លាញ់តាមខ្ញុំ មកចាប់កន្ទុយដោយភាពដែលខ្ញុំមិនត្រូវត្រីនេះអូសទៅ ដូច្នោះ ។

កេមួយទៀត បានឮពាក្យនោះហើយ ទើបពោលគាថាទី ២ ថា

ម្នាល អ្នកត្រាច់ទៅក្នុងទឹកជ្រៅដ៏ចម្រើន អ្នកចូរចាប់ដោយ
កម្លាំងយ៉ាងមាំ ខ្ញុំនឹងជួយយោងយកត្រីនោះដូចគ្រុឌដែលស្រង់
ឡើងនូវពស់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ថាមសា** សេចក្ដីថា ដោយកម្លាំង ។ បទថា **ឧទ្ធរិស្សាមិ** សេចក្ដីថា នឹងនាំចេញទៅ ។ បទថា **សុបណ្ណោ ឧរគម្មិវ** សេចក្ដីថា ដូចគ្រុឌលើកពស់ឡើង ដូច្នោះ ។

លំដាប់នោះ កេទាំង ២ នោះរួមគ្នានាំត្រីផ្ទិនពណ៌ក្រហមមកបាន ដាក់ឲ្យស្លាប់នៅលើគោក កើតនូវការឈ្លោះគ្នាថា ឯងចែកគ្នាចុះ ឯងចែកគ្នាចុះ ក៏មិនអាចចែកគ្នាបាន ទើបឈប់ហើយនាំគ្នាអង្គុយ ។ ខណៈនោះ ចចកនោះ

ចូលមកដល់ទីនោះ ភេទាំងនោះឃើញហើយ ទើបនាំគ្នាស្វាគមន៍ ហើយក៏ពោលថា នែសម្លាញ់ ទព្ភបុប្ផៈ ត្រីនេះពួកខ្ញុំចាប់បានរួមគ្នា កាលពួកខ្ញុំមិនអាចចែកគ្នាបាន ទើបកើតនូវជម្លោះឡើង សូមអ្នកជួយចែកត្រីឲ្យពួកខ្ញុំស្មើៗគ្នាផងចុះ ហើយពោលគាថាទី ៣ ថា

ម្នាលចចកទព្ភបុប្ផៈ ចូរអ្នកស្តាប់ពាក្យយើង វិវាទកើតដល់
យើងហើយ ម្នាលសម្លាញ់ អ្នកចូររម្ងាប់នូវជម្លោះ ឲ្យវិវាទ
( របស់យើង ) ស្ងប់រម្ងាប់ទៅ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ភេហៅចចកថា ទព្ភបុប្ផៈ ព្រោះចចកមានពណ៌ដូចផ្កាស្បូវក្លាំង ។ បទថា **មេធគំ** បានដល់ ឈ្លោះគ្នា ។

ចចកបានឮពាក្យរបស់ភេនោះហើយ កាលនឹងសម្តែងដល់បដិភាណរបស់ខ្លួន ទើបពោលគាថានេះថា

កាលពីដើមយើងជាអ្នកឋិតនៅក្នុងតំណែងជម្រះក្តី បានកាត់ក្តី
ឲ្យគេជាច្រើនមកហើយ ម្នាលសម្លាញ់យើងនឹងរម្ងាប់នូវជម្លោះ
( របស់អ្នកទាំងឡាយ ) សូមឲ្យវិវាទ ( របស់អ្នកទាំងឡាយ )
ស្ងប់រម្ងាប់ទៅ ដូច្នេះ ។

ចចកកាលពោលគាថានេះហើយ កាលនឹងចែកត្រី ទើបពោលគាថានេះថា

ម្នាលភេ អ្នកត្រាច់ទៅតាមឆ្នេរ ( អ្នកត្រូវបាន ) កន្ទុយ ភេ
ដែលត្រាច់ទៅក្នុងទឹកជ្រៅ ( ត្រូវបាន ) ក្បាល ដុំជាកណ្តាល

ក្រៅអំពីចំណែកពីរនេះត្រូវបាន ( យើង ) អ្នកឋិតនៅក្នុង

តំណែងជម្រះក្តី ដូច្នេះ ។

បណ្តាគាថាទាំង ២ នោះ គាថាទី ១ មានអត្ថដូច្នេះថា ខ្ញុំធ្លាប់ជាចៅក្រមរបស់ព្រះរាជាទាំងឡាយក្នុងកាលមុន ខ្ញុំនេះឯងអង្គុយក្នុងសាលាពិចា-រណាក្តីសន្ទឹកសន្ទាប់ គឺក្តីជាច្រើនរបស់ព្រាហ្មណ៍និងគហបតីទាំងឡាយនោះ ខ្ញុំពិចារណា គឺវិនិច្ឆ័យមកហើយ ខ្ញុំមិនអាចពិចារណាក្តីរបស់សត្វជើង ៤ ទាំងឡាយ ដែលមានជាតិស្មើគ្នាដូចអ្នកទាំងឡាយបានដូចម្តេច ខ្ញុំនឹងរម្ងាប់អធិ-ករណ៍ទាំងឡាយ នៃសម្លាញ់ ជម្លោះទាស់ទែង ចូរស្ងប់រម្ងាប់ទៅ ព្រោះអាស្រ័យខ្ញុំ ។ កាលពោលយ៉ាងនេះហើយ ចចកក៏ចែកត្រីជា ៣ ចំណែក ហើយប្រាប់ថា កេមួយរកស៊ីទឹករាក់ ចូរពាំយកត្រង់កន្ទុយ ខាងក្បាលចូរជារបស់កេដែលរកស៊ីទឹកជ្រៅ ។ បទថា **អថាយំ មជ្ឈិមោ ខណ្ឌោ** សេចក្តីថា ចំណែកដុំកណ្តាលនេះ ។ម្យ៉ាងទៀត បទថា **អថ** សេចក្តីថា ហួសទៅ គឺដុំដែលហួសអំពីចំណែកទាំង ២ នេះទៅ បានដល់ ដុំកណ្តាលនេះ ជារបស់ចៅក្រម គឺអ្នកវិនិច្ឆ័យក្តី ។

ចចកកាលចែកត្រីយ៉ាងនេះហើយ ក៏ប្រាប់ថា អ្នកទាំងឡាយ កុំឈ្លោះគ្នា ហើយនាំគ្នាស៊ីកន្ទុយនិងក្បាលចុះ ហើយយកមាត់ពាំយកដុំកណ្តាលចៀសចេញទៅទាំងកេពីរនោះកំពុងឃើញនោះឯង ។ កេពីរនោះអង្គុយដូចចាញ់ល្បែងក្នាល់រាប់ពាន់ហើយពោលគាថាទី ៦ ថា

ប្រសិនបើ យើងកុំទាស់គ្នា ( ត្រីនេះ ) នឹងបានជាអាហារ

អស់កាលដ៏យូរ ចចកពាំយកត្រីឆ្ពិន ឥតក្បាលឥតកន្ទុយទៅ
ព្រងើយ ដូច្នេះ ។

ក្នុងគាថានោះ បទថា **ចិរំបិ** គេពោលសំដៅយកកាលពីរបីថ្ងៃ ។ ចំណែកចចកត្រេកអរថា ថ្ងៃនេះអញនឹងឲ្យកិរិយាស៊ីត្រីឆ្ពិនក្រហម ហើយបានមកកាន់សម្នាក់របស់កិរិយានោះ ។ ចចកញី ឃើញចចកឈ្មោលកំពុងមក ក៏ត្រេកអរយ៉ាងក្រៃលែង ទើបពោលគាថានេះថា

ខត្តិយរាជ បានទូវរាជសម្បត្តិ ហើយរីករាយ យ៉ាងណាមិញ
ក្នុងថ្ងៃនេះខ្ញុំឃើញប្តីដែលមានមុខរីកហើយ ក៏មានចិត្តរីករាយ
យ៉ាងនោះដែរ ដូច្នេះ ។

លុះពោលគាថានេះហើយ កាលសួរដល់ឧបាយដែលបានអាហារមកទើបពោលគាថានេះថា

អ្នកជាសត្វកើតលើគោកទេ ម្តេចក៏ចាប់ត្រីក្នុងទឹកបាន ម្នាល
សម្លាញ់ ខ្ញុំសួរហើយសូមអ្នកប្រាប់ អ្នកចាប់ ( ត្រី ) បាន
ដោយហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កថន្នុ** សេចក្តីថា កាលចចកឈ្មោលប្រាប់ថា ចូរនាងបរិភោគចុះ ហើយដាក់ត្រីទុកខាងមុខ ទើបចចកញីសួរថា អ្នកជាសត្វកើតលើគោក តើចាប់ត្រីក្នុងទឹកបានមកដូចម្តេច ។

ចចកឈ្មោល កាលនឹងប្រាប់ឧបាយដែលបានត្រីនោះមក ទើបពោលគាថាបន្តថា

សត្វទាំងឡាយស្គាំងស្គម ព្រោះតែការទាស់ទែងគ្នា ការអស់
ទ្រព្យសម្បត្តិ ក៏ព្រោះតែទាស់ទែងគ្នាដែរ ភេ ( ទាំងពីរ )
សាបសូន្យ ( ចាកគ្រី ) ព្រោះតែទាស់ទែងគ្នា នែនាងមា-
យាវី នាងចូរបរិភោគនូវត្រីធ្លិនចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិវាទេន កិសា ហោន្តិ** សេចក្ដីថា នែនាងដ៏ចម្រើន សត្វទាំងនេះ កាលធ្វើវិវាទគ្នា អាស្រ័យវិវាទទើបស្គម គឺមានសាច់និងឈាមតិច ។ បទថា **វិវាទេន ធនក្ខយា** សេចក្ដីថា ការអស់ទ្រព្យទាំងឡាយ មានប្រាក់និងមាសជាដើម ក៏មានព្រោះវិវាទគ្នានោះឯង ។ កាលមនុស្សទាំង ២ វិវាទគ្នា បុគ្គលម្នាក់ចាញ់ ព្រោះចាញ់ ទើបដល់នូវការអស់ទ្រព្យ អ្នកឈ្នះក៏អស់ទ្រព្យ ព្រោះឲ្យចំណែកនៃការឈ្នះដល់ចៅក្រម ។ បទថា **ជិនា ឧទ្ទា** សេចក្ដីថា ភេពីរបាត់បង់ដុំសាច់នោះទៅ ព្រោះវិវាទគ្នានោះឯង ព្រោះហេតុនោះ នាងកុំបាច់សួរដល់ហេតុនៃដុំត្រីនេះ ដែលអញនាំមកហើយ នែនាង ចូរនាងបរិភោគត្រីធ្លិនក្រហមនេះតែម្យ៉ាង ។

គាថានេះ ជាគាថារបស់ព្រះមានព្រះភាគដែលត្រាស់ដឹងក្រៃលែងហើយដូច្នេះថា

ក្នុងទីណាវិវាទកើតឡើងក្នុងពួកមនុស្ស ( មនុស្សទាំងឡាយ )
រមែងស្ទុះស្ទារទៅពឹងចៅក្រមអ្នកកាត់ក្ដី ត្បិតចៅក្រមនោះជា
អ្នកដឹកនាំមនុស្សទាំងនោះ មនុស្សទាំងនោះ រមែងសាបសូន្យ
ចាកទ្រព្យ ( របស់ខ្លួន ) ក្នុងទីនោះ ឃ្លាំងរបស់ព្រះរាជារមែង

ចម្រើនក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯវមេវ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភេ ២ នោះ ក្លាំងក្លាត់ទៅហើយយ៉ាងណា សូម្បីក្នុងពួកមនុស្ស ក៏យ៉ាងនោះដូចគ្នា ក្នុងទីណាកើតការវិវាទគ្នាឡើង ក្នុងទីនោះ មនុស្សទាំងឡាយ រត់មករកចៅក្រម គឺចូលទៅរកអ្នកកាត់ក្តី ។ ព្រោះហេតុអ្វី ព្រោះថា ជននោះជាអ្នកដឹកនាំពួកគេ អធិប្បាយថា ជាអ្នករម្ងាប់វិវាទរបស់ជនទាំងនោះដែលទាស់ទែងគ្នាឲ្យស្ងប់បាន ។ បទថា **ធនាបិ តត្ថ** សេចក្តីថា ជនទាំងនោះ វិវាទគ្នានឹងវិនាសចាកទ្រព្យក្នុងទីនោះ អធិប្បាយថា នឹងវិនាសចាករបស់ដែលមានរបស់ខ្លួន តែឃ្លាំងរបស់ព្រះរាជានឹងចម្រើន ព្រោះសំណូក និងព្រោះទទួលចំណែកដែលចែកអំពីជ័យជម្នះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាឧបនន្ទក្នុងកាលឥឡូវនេះ ភេពីរក្នុងកាលនោះ បានមកជាភិក្ខុចាស់ ២ រូប ឯរុក្ខទេវតាដែលឃើញហេតុការណ៍នោះច្បាស់ក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ទព្ភបុប្ផជាតក ចប់**

# ទសណ្ណកជាតក

[ ៣០៦ ] ( ព្រះរាជាទ្រង់សួរអាមាត្យឈ្មោះអាយុរៈថា ) បុរសលេបដាវមានមុខដ៏មុត ដែលកើតក្នុងដែនឈ្មោះទសណ្ណកៈ ជាដាវផឹកឈាមខ្មែតហើយ ក្នុងកណ្តាលបរិស័ទ ចុះអំពើអ្វី ដែលគេធ្វើបានដោយកម្រជាងកិរិយាលេបនូវដាវនោះទៅទៀត ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃដែលគេធ្វើបានដោយកម្រនោះ ។

[ ៣០៧ ] ( អាយុរាមាត្យពោលថា ) បុរសលេបដាវដែលផឹកឈាមខ្មែតហើយ ព្រោះតែលោភៈ បើបុគ្គលណាពោលថា យើងនឹងឲ្យ ( នូវវត្ថុនោះដល់អ្នក ) ដូច្នេះ ពាក្យរបស់បុគ្គលនោះ ពិបាកធ្វើក្រៃលែងជាងការលេបដាវនោះទៅទៀត បពិត្រព្រះមាគធរាជ ហេតុដទៃទាំងអស់ ( ក្រៅអំពីពាក្យនេះ ) គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ។

[ ៣០៨ ] ( ព្រះរាជាទ្រង់ចរចាជាមួយនិងបុក្កុសាមាត្យថា ) អាយុរបណ្ឌិតជាអ្នកឈ្លាសវៃក្នុងធម៌ បានដោះស្រាយនូវសេចក្តីនៃប្រស្នា ឥឡូវនេះយើងនឹងសាកសួរចំពោះបុក្កុសបណ្ឌិតវិញ អំពើអ្វី ដែលបុគ្គលធ្វើបានដោយកម្រជាងពាក្យនោះទៅទៀត យើងសួរហើយ ចូរអ្នកប្រាប់នូវហេតុដទៃដែលបុគ្គលធ្វើបានដោយកម្រនោះ ( ដល់យើង ) ។

[ ៣០៩ ] ( បុក្កុសបណ្ឌិតពោលថា ) ពួកមនុស្សរស់នៅ ( ព្រោះអាស្រ័យ ) នូវវាចាឥតផល ជាសម្តីដែលគេពោលឥតអន្លឹមានឡើយបុគ្គលណាបានឲ្យ ( ពាក្យបេ្តជ្ញា ) ហើយក៏បានកាត់ផ្តាច់ចោល ( នូវលោភៈ ) ពាក្យបេ្តជ្ញានោះ ជាការធ្វើដោយលំបាកជាងការលេបដាវ និងពាក្យនោះទៅ

ទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំងអស់គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ។

[ ៣១០ ] ( ព្រះរាជាទ្រង់សួរសេនកបណ្ឌិតថា ) បុក្កុសបណ្ឌិត ជាអ្នកឈ្លាសវៃក្នុងធម៌ បានឆ្លើយនូវសេចក្តីនៃប្រស្នារួចហើយ ឥឡូវនេះយើងនឹងសួរចំពោះសេនកបណ្ឌិត អ្វីអេះដែលបុគ្គលធ្វើបានដោយលំបាក ជាងពាក្យប្តេជ្ញានោះទៅទៀត យើងសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃដែលបុគ្គលធ្វើបានដោយលំបាកនោះ ( ដល់យើង ) ។

[ ៣១១ ] ( សេនកបណ្ឌិតពោលថា ) បុរសគួរឲ្យនូវទាន ទោះបីតិចក្តីច្រើនក្តី បើបុគ្គលណាបានឲ្យហើយមិនក្តៅក្រហាយស្តាយក្រោយ អំពើនោះជាការធ្វើបានដោយលំបាក ជាងការលេបដាវជាដើមនោះទៅទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំងអស់ គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ។

[ ៣១២ ] ( ព្រះរាជាសរសើរពោធិសត្វហើយពោលគាថាទីបំផុតថា ) អាយុរបណ្ឌិត បានឆ្លើយប្រស្នារួចហើយ ទាំងបុក្កុសបុរសក៏ដូចគ្នា សេនកបណ្ឌិតនិយាយដោះស្រាយប្រស្នាទាំងអស់តាមសមគួរ ។

## ចប់ ទសណ្ណកជាតកទី ៦

## អដ្ឋកថា

## ឧសណ្ហកជាតក

[ ៣០៦-៣១២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោម របស់ភរិយាចាស់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **បណ្ណកំ តិខិណធារំ** ដូច្នេះជាដើម ។

រឿងនេះមានសេចក្តីសង្ខេបថា ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា បានឮថា អ្នកអផ្សុកពិតឬ កាលភិក្ខុនោះទូលថា ករុណាព្រះអង្គពិតមែន ទើបត្រាស់សួរថា អ្នកណាល្បួងឲ្យអ្នកអផ្សុក កាលភិក្ខុនោះក្រាបទូលថា ភរិយាចាស់របស់ខ្ញុំព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្រីនេះ ធ្វើវត្ថុមិនជាប្រយោជន៍ឲ្យដល់អ្នក មិនចំពោះតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្រីនេះ កំពុងស្លាប់ព្រោះរោគផ្លូវចិត្ត បានអាស្រ័យបណ្ឌិត ទើបបាននូវជីវិត ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមទ្ទវៈសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ញាតិទាំងឡាយ បានដាក់ឈ្មោះថា សេនកកុមារ លុះធំចម្រើនវ័យហើយ បានរៀនសិប្បៈ គ្រប់ប្រភេទក្នុងនគរតក្កសិលាចប់ហើយ ក៏ត្រឡប់មកនគរពារាណសី បានជាអាមាត្យថ្វាយអត្ថ និងធម៌ដល់ព្រះបាទមទ្ទវៈ ។ លោកត្រូវមនុស្សទាំងឡាយហៅថា សេនកបណ្ឌិត រុងរឿងក្នុងផ្ទៃនគរដូចព្រះចន្ទនិងព្រះអាទិត្យ ។ គ្រានោះ បុត្តរបស់បុរោហិតមកគាល់ព្រះរាជា ឃើញអគ្គមហេសីរបស់ព្រះរាជា មានព្រះរូបឆោមលោម

ពេលរំលងដ៏ត្រកាល ទ្រង់ទ្រង់នូវគ្រឿងអាភរណៈសព្វយ៉ាង មានចិត្តប្រតិព័ទ្ធ ទៅផ្ទះហើយដេកអត់អាហារ ត្រូវមិត្តសម្លាញ់សួរក៏ប្រាប់សេចក្តីនោះ ។ ព្រះរាជាត្រាស់សួរថា មិនឃើញបុត្តរបស់បុរោហិត តើគេទៅណា ទ្រង់ជ្រាបសេចក្តីនោះហើយឲ្យចូលគាល់ហើយត្រាស់ថា ខ្ញុំប្រគល់ឲ្យអ្នក ៧ ថ្ងៃ ចូរយកអគ្គមហេសីនេះទៅទុកឯផ្ទះ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ សឹមនាំមក ។ បុត្តបុរោហិតទទួលព្រះរាជឱង្ការហើយ នាំអគ្គមហេសីទៅផ្ទះ រួមអភិរមហើយ បុត្តបុរោហិតនិងអគ្គមហេសីនោះ ក៏មានចិត្តប្រតិព័ទ្ធគ្នានឹងគ្នា គេចទៅតាមទ្វារនគរនោះឯងដោយមិនឲ្យអ្នកណាដឹង បានទៅកាន់ដែនរបស់ព្រះរាជាដទៃ បុគ្គលណាម្នាក់ ក៏មិនដឹងទីដែលជនទាំង ២ ទៅហើយ មិនមានតម្រុយ ដូចផ្លូវដែលទូកទៅហើយ ដូច្នោះ ។ ព្រះរាជាទ្រង់ឲ្យវាយស្គរប្រកាស ពេញព្រះនគរ រកមើលដោយប្រការផ្សេងៗ ក៏មិនដឹងទីដែលជនទាំងនោះទៅ ។ តមកទ្រង់មានសេចក្តីសោកជាកម្លាំង ព្រោះអាស្រ័យព្រះនាង ព្រះហឫទ័យក្តៅ ព្រះលោហិតក៏ហូរចេញ មាននូវព្យាធិជាទម្ងន់ ។ រាជពេទ្យជាច្រើនក៏មិនអាចព្យាបាលបាន ។ ព្រះពោធិសត្វដឹងថា ព្រះរាជានេះ មិនមានព្យាធិណាមួយ តែទ្រង់មិនឃើញព្រះមហេសីទើបត្រូវរោគចិត្តបៀតបៀន អញនឹងប្រើឧបាយជួយព្រះអង្គ ហើយទើបហៅអាមាត្យដែលជារាជបណ្ឌិត ២ នាក់ គឺអាយុរអាមាត្យម្នាក់ បុក្កុសអាមាត្យម្នាក់មកហើយប្រាប់ថា ព្រះរាជាទ្រង់មិនមានព្រះរោគដទៃ ក្រៅអំពីរោគចិត្តឡើយ ព្រោះទ្រង់មិនឃើញព្រះរាជទេវី ព្រះរាជាទ្រង់មានព្រះឧបការៈដល់យើងច្រើន ព្រោះហេតុនោះ ពួកយើងប្រើ

ឧបាយជួយទ្រង់ គឺឲ្យមនុស្សលេងនូវកីឡាត្រង់លានព្រះរាជវាំង ហើយឲ្យអ្នកចេះលេបដាវ លេបដាវថ្វាយព្រះរាជាទត ។ ព្រះរាជាឈរទតកីឡា ក្បែរមាត់បង្អួច ។ ព្រះរាជាទតអ្នកលេបដាវហើយ ក៏នឹងត្រាស់សួរបញ្ហាថា មានរបស់អ្វីដទៃដែលធ្វើបានលំបាកជាងនេះដែរឬទេ នៃសម្លាញ់អាយុរៈ អ្នកគួរក្រាបទូលបញ្ហានោះថា ការពោលថា យើងនឹងឲ្យរបស់ឈ្មោះនេះ ជារបស់ដែលធ្វើលំបាកជាងនេះទៀត ឯបុក្កុសៈបន្ទាប់អំពីនោះទ្រង់នឹងត្រាស់សួរអ្នក អ្នកគួរក្រាបទូលព្រះរាជាថា កាលបុគ្គលពោលថាឲ្យ តែមិនឲ្យ វាចានោះឥតផល បុគ្គលពួកខ្លះ មិនតម្កល់ជីវិត មិនទំពាស៊ី មិនផឹក អាស្រ័យវាចាប្រភេទនោះ ចំណែកបុគ្គលណា ធ្វើឲ្យសមគួរដល់ពាក្យនោះ រមែងឲ្យនូវប្រយោជន៍តាមដែលប្តេជ្ញាទុកនោះឯង ការឲ្យរបស់បុគ្គលនោះ ធ្វើបានលំ-បាកជាងការពោលថានឹងឲ្យ បន្ទាប់អំពីនោះ ខ្ញុំក៏ដឹងកិច្ចដែលត្រូវធ្វើ ដូច្នេះហើយ បានឲ្យសម្តែងនូវការលេង ។ លំដាប់នោះ បណ្ឌិតទាំង ៣ នាំគ្នាទៅកាន់រាជសម្នាក់ក្រាបទូលថា បពិត្រព្រះអង្គ ត្រង់លានព្រះរាជវាំង មានកីឡាកំពុងសម្តែង មនុស្សទាំងឡាយកំពុងមើលការលេងនោះ ។ ទោះបីជាទុក្ខឬមិនជាទុក្ខ សូមទ្រង់យាងចុះ ទូលព្រះបង្គំទាំងឡាយនឹងទៅមើល ហើយបាននាំព្រះរាជាទៅ បើកបង្អួចឲ្យទ្រង់ទតការលេង ។ មនុស្សជាច្រើននាំគ្នាសម្តែងសិប្បៈដែលខ្លួនចេះរៀង ៗ ខ្លួន ។ បុរសម្នាក់លេបដាវរតនៈដែលមានមុខដ៏មុតប្រវែង ៣៣ ធ្នាប់ ។ ព្រះរាជាទតបុរសនោះហើយ ទ្រង់ព្រះតម្រិះថា បុរសនេះលេបដាវយ៉ាងនេះ អញនឹងសួរបណ្ឌិតទាំងនេះថា មានឬ

ការលេងជទៃដែលធ្វើបានលំបាកជាងនេះ កាលត្រាស់សួរអាយុរបណ្ឌិតទើបពោលគាថាទី ១ ថា

បុរសលេបដាវមានមុខដ៏មុត ដែលកើតក្នុងដែនឈ្មោះទសណ្ណកៈ ជាដាវផឹកឈាមឆ្អែតហើយ ក្នុងកណ្តាលបរិស័ទ ចុះអំពើអ្វី ដែលគេធ្វើបានដោយកម្រជាងកិរិយាលេបនូវដាវនោះទៅទៀត ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលគេធ្វើបានដោយក្រមនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បណ្ណកំ** សេចក្តីថា កើតឡើងត្រង់ដែនបណ្ណកៈ ។ បទថា **សម្បន្នធាយិនំ** សេចក្តីថា ដែលផឹកឈាមអ្នកដទៃគឺដាវនេះប្រហារអ្នកដទៃហើយ ។ បទថា **បរិសាយំ** សេចក្តីថា បុរសនេះលេបដាវកណ្តាលបរិស័ទ ព្រោះចង់បានទ្រព្យ ។ បទថា **យទញ្ញំ** សេចក្តីថា វត្ថុដទៃណា គឺហេតុដទៃណាដែលធ្វើបានលំបាកជាងការលេបដាវនេះមានអ្នកត្រូវខ្ញុំសួរហើយ ចូរប្រាប់ហេតុនោះដល់ខ្ញុំ ។

លំដាប់នោះ អាយុរបណ្ឌិត កាលទូលប្រាប់ព្រះរាជា ទើបពោលគាថាទី ២ ថា

បុរសលេបដាវ ដែលផឹកឈាមឆ្អែតហើយ ព្រោះតែលោភៈ បើបុគ្គលណាពោលថា យើងនឹងឲ្យ ( នូវវត្ថុនោះដល់អ្នក ) ដូច្នេះ ពាក្យរបស់បុគ្គលនោះ ពិបាកធ្វើក្រៃលែងជាងការលេបដាវនោះទៅទៀត បពិត្រព្រះមាគធរាជ ហេតុដទៃទាំងអស់

( ក្រៅអំពីពាក្យនេះ ) គេធ្វើបានដោយងាយទេសូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វជ្ជា** សេចក្ដីថា គប្បីពោល ។ បទថា **តំ ទុក្ករតរំ** សេចក្ដីថា ការពោលថា ខ្ញុំនឹងឲ្យ នេះជាវត្ថុធ្វើបានលំបាកជាងនោះ គឺជាងការលេបដាវ ។ បទថា **សព្វញ្ញំ** សេចក្ដីថា ហេតុដទៃ គ្រប់យ៉ាង វៀរតែការពោលថា ខ្ញុំនឹងឲ្យរបស់នេះ ដល់អ្នក ជាវត្ថុដែលធ្វើបានងាយ ។ អាយុរបណ្ឌិតហៅព្រះរាជាដោយគោត្តថា ព្រះបាទមគធៈ ។

កាលព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់អាយុរបណ្ឌិតហើយ ទ្រង់ពិចារណាពាក្យនោះឯងថា បានឮថា ការពោលថា ខ្ញុំនឹងឲ្យរបស់ឈ្មោះនេះ ជាវត្ថុធ្វើបានលំបាកជាងការលេបដាវ ឯយើងក៏បានពោលចេញទៅហើយថា យើងនឹងឲ្យព្រះរាជទេវីដល់បុត្តបុរោហិត យើងធ្វើកម្មដែលធ្វើបានលំបាកហើយហ្ន៎ ការសោយសោកក្នុងព្រះរាជហឫទ័យ ក៏បានធូរស្រាលបន្តិចហើយ ទ្រង់ព្រះតម្រិះថា កម្មដទៃដែលធ្វើបានលំបាកជាងការពោលថា យើងនឹងឲ្យរបស់នេះដល់អ្នកដទៃនោះនៅមានឬហ្ន៎ កាលទ្រង់ប្រាស្រ័យជាមួយបុក្កុសបណ្ឌិត បានត្រាស់គាថាទី ៣ ថា

អាយុរបណ្ឌិត ជាអ្នកឈ្លាសវៃក្នុងធម៌ បានដោះស្រាយនូវ
សេចក្ដីនៃប្រស្នា ឥឡូវនេះ យើងនឹងសាកសួរចំពោះបុក្កុស
បណ្ឌិតវិញ អំពើអ្វីដែលបុគ្គលធ្វើបានដោយកម្រ ជាងពាក្យ
នោះទៅទៀត យើងសួរហើយ ចូរអ្នកប្រាប់នូវហេតុដទៃដែល

បុគ្គលធ្វើបានដោយកម្រនោះ ( ដល់យើង ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បញ្ហំ អត្ថំ** មានពាក្យអធិប្បាយថា ពោល ដោះ គឺស្រាយនូវបញ្ហាហើយ ។ បទថា **ធម្មស្ស កោវិទោ** បានដល់ អ្នកឈ្លាសក្នុងអត្ថដែលសបញ្ជាក់ដល់សេចក្ដីរបស់ធម៌នោះ ។ បទថា **តតោ** សេចក្ដីថា វត្ថុដែលធ្វើបានលំបាកជាងការពោលនោះមានឬ ។

គ្រានោះ បុក្កុសបណ្ឌិតកាលនឹងទូលស្រាយបញ្ហាថ្វាយព្រះរាជា ទើបពោលគាថាទី ៤ ថា

ពួកមនុស្សរស់នៅ ( ព្រោះអាស្រ័យ ) នូវវាចាឥតផល ជាសម្ដីដែលគេពោល ឥតអង្គឹមានឡើយ បុគ្គលណា បានឲ្យ
( ពាក្យប្ដេជ្ញា ) ហើយក៏បានកាត់ផ្ដាច់ចោល ( នូវលោភៈ )
ពាក្យប្ដេជ្ញានោះ ជាការធ្វើដោយលំបាកជាងការលេបដាវ និង
ពាក្យនោះទៅទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំង
អស់គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះ
ចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទត្វា** សេចក្ដីថា ឲ្យនូវប្ដេជ្ញាទុកថា ខ្ញុំនឹងឲ្យវត្ថុឈ្មោះនោះ ។ បទថា **អវាកយិរា** មានពាក្យអធិប្បាយទុកថា បុគ្គលកាលឲ្យប្រយោជន៍ដែលបានប្ដេជ្ញាទុកហើយនោះ ដកគឺទម្លាយសេចក្ដីលោភចោលព្រោះប្ដេជ្ញានោះ នឹងគប្បីឲ្យវត្ថុនោះ ។ បទថា **តតោ** សេចក្ដីថា ការដក គឺការឲ្យវត្ថុនោះឯង ធ្វើបានលំបាកជាងការលេបដាវនេះ និងការពោល

ថា នឹងឲ្យរបស់ឈ្មោះនោះដល់បុគ្គលនោះ ។

កាលព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់បរិវិតក្កថា ពីមុនអញពោល ហើយថា អញនឹងឲ្យព្រះទេវីដល់បុត្តបុរោហិត ក៏បានឲ្យព្រះទេវី ធ្វើឲ្យសម គួរ ដល់ការពោលហើយ អញបានធ្វើកម្មដែលគេធ្វើបានលំបាកហ្ន៎ សេចក្តី សោក ក៏ធូរស្រាលជាងមុន ។ លំដាប់នោះ ព្រះរាជាមានបរិវិតក្កថា អ្នក ដទៃដែលឈ្មោះថា ជាអ្នកឈ្លាសជាងសេនកបណ្ឌិតមិនមាន អញនឹងសួរ បញ្ហានេះនឹងសេនកបណ្ឌិតនោះ ។ លំដាប់នោះ កាលទ្រង់សួរបញ្ហា បាន ត្រាស់គាថាទី ៥ ថា

បុក្កុសបណ្ឌិត ជាអ្នកឈ្លាសវៃក្នុងធម៌ បានឆ្លើយនូវសេចក្តីនៃ
ប្រស្នារួចហើយ ឥឡូវនេះ យើងនឹងសួរចំពោះសេនកបណ្ឌិត
អ្វីអេះ ដែលបុគ្គលធ្វើបានដោយលំបាក ជាងពាក្យប្តេជ្ញានោះ
ទៅទៀត យើងសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែល
បុគ្គលធ្វើបានដោយលំបាកនោះ ( ដល់យើង ) ដូច្នេះ ។

សេនកបណ្ឌិតកាលទូលស្រាយបញ្ហាថ្វាយព្រះរាជា ក៏ពោលគាថាទី ៦ ថា

បុរសគួរឲ្យនូវទាន ទោះបីតិចក្តីច្រើនក្តី បើបុគ្គលណាបាន
ឲ្យហើយ មិនក្តៅក្រហាយស្តាយក្រោយ អំពើនោះជាការធ្វើ
បានដោយលំបាកជាងការលេបដាវជាដើមនោះទៅទៀតបពិត្រ
ព្រះបាទមាគធរាជ ហេតុដទៃទាំងអស់ គេធ្វើបានដោយងាយ

ទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាទុតប្បេ** សេចក្តីថា បុគ្គលណាកាលឲ្យរបស់ជាទីស្រឡាញ់ដែលខ្លួនស្រឡាញ់ ដែលខ្លួនគាប់ចិត្តយ៉ាងក្រៃលែងដល់អ្នកដទៃហើយ មិនប្រារព្ធដល់របស់ជាទីស្រឡាញ់នោះ ក្តៅក្រហាយចិត្តក្នុងកាលជាក្រោយ គឺមិនសោយសោកយ៉ាងនេះថា អញឲ្យរបស់ឈ្មោះនេះដើម្បីអ្វី ការមិនក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយនេះ ជារបស់ដែលធ្វើបានលំបាក ជាងការលេបដាវ ជាងការពោលថា យើងនឹងឲ្យរបស់ឈ្មោះនេះនិងជាងការឲ្យរបស់នោះ ។ ព្រះមហាសត្វក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាបដោយប្រការដូច្នេះ ។ ពិតហើយ អបរចេតនា ( ចេតនាក្រោយអំពីឲ្យ ) របស់បុគ្គលដែលឲ្យទានហើយ ជាវត្ថុដែលធ្វើឲ្យជ្រះថ្លាបានលំបាក ការធ្វើអបរចេតនាឲ្យជ្រះថ្លា ជារបស់ធ្វើបានដោយក្រ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកក្នុងវេស្សន្តរជាតកថា

អញនឹងកាន់យកធ្នូ ស្តាយព្រះខាន់លើស្មាខាងឆ្វេង ហើយនាំយកកូនទាំងពីររបស់ខ្លួនមកវិញឬ ព្រោះថា ការដែលគេវាយដំកូនទាំងពីរ នាំមកនូវសេចក្តីទុក្ខ ។ កុមារទាំងពីរគប្បីលំបាកដោយហេតុណា ហេតុនុ៎ះ មិនមែនជាទីតាំងមានសភាពជាទុក្ខទេ នរណាយល់ធម៌របស់ពួកសប្បុរសហើយឲ្យទាន រមែងក្តៅក្រហាយរឿយៗ ដូច្នេះ ។

ឯព្រះរាជា កាលទ្រង់ស្តាប់ពាក្យរបស់មហាសត្វហើយ ទ្រង់កំណត់ថា

អញឲ្យព្រះរាជទេវីដល់បុត្តបុរោហិត ដោយចិត្តរបស់ខ្លួននោះឯង តែមិនអាចទ្រទ្រង់ទុកនូវចិត្តរបស់ខ្លួនបាន ជាអ្នកក្តៅក្រហាយចិត្ត លំបាកចិត្ត សេចក្តីនេះមិនសមគួរដល់អញ បើព្រះរាជទេវីនោះ មានសេចក្តីស្នេហាក្នុងអញ សោត នាងគង់មិនលះបង់នូវឥស្សរិយយសនេះគេចទៅ តែព្រោះនាង មិនស្នេហាក្នុងអញ ទើបគេចទៅហើយ អញនឹងមានប្រយោជន៍អ្វី ។ កាលទ្រង់ត្រិះរិះដល់សេចក្តីនេះ ការសោយសោកទាំងអស់ ក៏ប្រាសទៅ ដូចតំណក់ទឹកដែលធ្លាក់អំពីស្លឹកឈូក ដូច្នោះ ។ រំពេចនោះ ព្រះនាភីរបស់ទ្រង់ក៏ឈប់ស្បៀម ទ្រង់ប្រាសចាកព្រះរោគ ដល់នូវការក្សេម កាលទ្រង់សរសើរព្រះពោធិសត្វបានត្រាស់គាថាចុងក្រោយថា

អាយុរបណ្ឌិតបានឆ្លើយប្រស្នារួចហើយ ទាំងបុក្កុសបុរសក៏ដូច
គ្នាសេនកបណ្ឌិតនិយាយដោះស្រាយប្រស្នាទាំងអស់តាមសម
គួរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថា ភាសតិ** សេចក្តីថា ធម្មតាទាននោះបុគ្គលឲ្យហើយ មិនគួរក្តៅក្រហាយក្នុងកាលខាងក្រោយ ដូចសេនកបណ្ឌិតពោលនោះឯង ។

ព្រះរាជាកាលទ្រង់សរសើរហើយ ទ្រង់ពេញព្រះរាជហឫទ័យ បានព្រះរាជទានទ្រព្យជាច្រើនដល់សេនកបណ្ឌិតនោះ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុអផ្សុកនោះតាំងនៅក្នុងសោតាបត្តិ

ផល ហើយទ្រង់ប្រជុំជាតកថា អគ្គមហេសីក្នុងកាលនោះ បានមកជាភរិយា ចាស់ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាភិក្ខុអផ្សុក អាយុរបណ្ឌិតក្នុងកាលនោះ បានមកជាមោគ្គល្លាន បុក្កុសបណ្ឌិតក្នុងកាល នោះបានមកជាសារីបុត្ត ឯសេនកបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទសណ្ណកជាតក ចប់

# សេនកជាតក

[ ៣១៣ ] ( សេនកបណ្ឌិតពោធិសត្វពោលថា ) អ្នកមានចិត្តក្រឡុក មានចក្ខុន្ទ្រិយកម្រើក ដំណក់ទឹកហូរចេញអំពីភ្នែករបស់អ្នក ម្នាលព្រាហ្មណ៍ អ្នកបាត់របស់អ្វី ឬក៏អ្នកប្រាថ្នាចង់បានរបស់អ្វី បានជាមកក្នុងទីនេះ ចូរអ្នកប្រាប់មកមើល ។

[ ៣១៤ ] ( ព្រាហ្មណ៍ពោលថា ) យក្ខពោលថា កាលបើខ្ញុំទៅដល់ ( ផ្ទះ ) ក្នុងថ្ងៃនេះ ប្រពន្ធ ( របស់ខ្ញុំ ) នឹងស្លាប់ កាលបើខ្ញុំទៅមិនដល់ ( ផ្ទះ ) ទេ ខ្ញុំនឹងស្លាប់ ដោយសេចក្តីទុក្ខនេះ បានជាខ្ញុំរន្ធត់ចិត្ត បពិត្រសេនកៈ សូមលោកប្រាប់សេចក្តីនេះដល់ខ្ញុំ ។

[ ៣១៥ ] ( ពោធិសត្វពោលថា ) យើងរិះគិតនូវហេតុច្រើនយ៉ាង បណ្តាហេតុទាំងនោះ យើងនឹងប្រាប់ហេតុណាមួយ ហេតុនោះឯងជារបស់ពិត ម្នាលព្រាហ្មណ៍យើងយល់ថា អ្នកមិនបានដឹងទេ មានពស់វែកលូនចូលក្នុងថៃសដូវ ។

[ ៣១៦ ] ( ពោធិសត្វពោលថា ) អ្នកចូរយកដំបងគោះថៃ មើល អ្នកចូរមើលពស់ដែលមានអណ្តាតពីរ ហៀរទឹកមាត់ចេញមក អ្នកចូរកាត់បង់នូវសេចក្តីសង្ស័យផង នូវសេចក្តីងឿងឆ្ងល់ផង ក្នុងថ្ងៃនេះ អ្នកចូរមើលពស់ អ្នកចូរទម្លាក់ថៃចោលទៅ ។

[ ៣១៧ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ព្រាហ្មណ៍នោះមានសភាពតក់ស្លុត ក្នុងកណ្តាលបរិស័ទ ហើយក៏បោះថៃថៃសដូវចោល ទើបពស់ជាសត្វអាសីពិស លូនទៅដោយទ្រូងមានតេជៈក្លាក៏បើកពពារលូនចេញមក ។

[ ៣១៨ ] ( ព្រាហ្មណ៍ពោលថា ) ព្រះរាជាជនកៈអង្គណា បានជួប នឹងសេនកបណ្ឌិតអ្នកមានប្រាជ្ញាធ្មេត ព្រះរាជាជនកៈ ( អង្គនោះ ) ឈ្មោះថាមានលាភបានហើយដោយប្រពៃ ( ព្រាហ្មណ៍លុះសរសើរព្រះរាជាហើយ ក៏សរសើរពោធិសត្វថា ) បពិត្រព្រាហ្មណ៍ អ្នកមានធម៌កំបាំង ( ញៀមធម៌ ) បើកហើយ ជាអ្នកឃើញនូវធម៌ទាំងអស់ឬ បានជាញាណរបស់អ្នកគួរស្ញប់ស្ញែងម្លេះ ខ្ញុំមានកហាបណៈប្រាំពីររយនេះ សូមអ្នកយកទាំងអស់ចុះ ខ្ញុំជូនអ្នក ត្បិតខ្ញុំបានជីវិតក្នុងថ្ងៃនេះដោយសារអ្នក មិនតែប៉ុណ្ណោះសោត ថែមទាំងអ្នកបានធ្វើសួស្តីដល់ភរិយា ( របស់ខ្ញុំ ) ទៀតផង ។

[ ៣១៩ ] ( ពោធិសត្វពោលថា ) បណ្ឌិតទាំងឡាយ មិនបានទទួលយករង្វាន់ដោយពោលគាថាទាំងឡាយដ៏វិចិត្រទេ ម្នាលព្រាហ្មណ៍ ( ជនទាំងឡាយ ) ឲ្យទ្រព្យអំពីបាទមូលរបស់យើងនេះដល់អ្នក អ្នកចូរយក ហើយចូរទៅកាន់លំនៅរបស់ខ្លួនចុះ ។

**ចប់ សេនកជាតកទី ៧**

# អដ្ឋកថា

## សេនកជាតក

[ ៣១៣-៣១៩ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមីរបស់ព្រះអង្គ ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **វិព្ភន្តចិត្តោ** ដូច្នេះជាដើម ។ រឿងបច្ចុប្បន្ននឹងមានច្បាស់ក្នុងឧម្មង្គជាតក ។

ក្នុងអតីតកាល ព្រះរាជាព្រះនាមជនក សោយរាជសម្បត្តិនៅក្នុងនគរពារាណសី ។ សម័យនោះ ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ពួកញាតិបានឲ្យឈ្មោះថា សេនកៈកុមារ ។ លុះចម្រើនវ័យហើយ រៀនសិប្បៈគ្រប់យ៉ាងឯនគរតក្កសិលា ហើយត្រឡប់មកគាល់ព្រះរាជា ឯនគរពារាណសី ។ ព្រះរាជាទ្រង់ស្ថាបនាទុកក្នុងតំណែងអាមាត្យ ហើយទ្រង់ប្រទានយសធំដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វជាអ្នកថ្វាយអត្ថនិងធម៌ដល់ព្រះរាជារឿយៗ ។ ជាអ្នកទូន្មានធម៌ដោយវាចាដ៏ពីរោះ ឲ្យព្រះរាជាតាំងនៅក្នុងបញ្ចសីល ហើយឲ្យតាំងនៅក្នុងបដិបទាដ៏ល្អនេះ គឺក្នុងទាន ក្នុងឧបោសថកម្មនិងក្នុងកុសលកម្មបថ ១០ ។ សម័យនោះ ហាក់ដូចពេលដែលព្រះសម្ពុទ្ធកើតឡើងក្នុងសកលរដ្ឋ ។ ព្រះរាជានិងឧបរាជទាំងអស់ប្រជុំគ្នាហើយ ឲ្យរាជបុរសតាក់តែងធម្មសភាក្នុងបក្ខទាំងឡាយ ព្រះមហាសត្វទៅកាន់ទីព្រះទែន ដែលអប់ទៅដោយគ្រឿងក្រអូបក្នុងសភា ដែលគេត្រៀមទុកហើយ សម្ដែងធម៌ដោយពុទ្ធលីលា ។ ធម្មកថារបស់មហាសត្វ ដូចគ្នានឹងធម្មកថា របស់ព្រះពុទ្ធទាំងឡាយ ។ គ្រានោះ ព្រាហ្មណ៍ជរាម្នាក់ ដើរសុំប្រាក់ បានប្រាក់ ១០០០ កហាបណៈ ផ្ញើក្នុងត្រកូលព្រាហ្មណ៍ម្នាក់ ហើយគិតថា អញនឹងដើរសូមទៀត

ដូច្នេះហើយ ក៏ទៅ ។ ក្នុងកាលព្រាហ្មណ៍នោះទៅហើយ ត្រកូលនោះក៏ចាយកហាបណៈអស់ ព្រាហ្មណ៍នោះត្រឡប់មក ហើយទារកហាបណៈ ព្រាហ្មណ៍មិនអាចរកកហាបណៈសងបាន ទើបឲ្យកូនស្រីរបស់ខ្លួនឲ្យជាបាទបរិចារិកា គឺជាប្រពន្ធរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នាំនាងទៅរកស៊ីត្រង់តំបន់មួយមិនឆ្ងាយអំពីនគរពារាណសី ។ គ្រានោះ កិរិយារបស់បុរសនោះ មិនឆ្អែតក្នុងកាម ព្រោះនៅក្មេង ទើបប្រព្រឹត្តមិច្ឆាចារជាមួយព្រាហ្មណ៍កំលោះម្នាក់ ។ ពិតហើយឈ្មោះថារបស់ដែលមិនឆ្អែតមាន ១៦ យ៉ាង ១៦ យ៉ាង ដូចម្តេច គឺមហាសមុទ្ទមិនឆ្អែតដោយទឹកដែលហូរមកគ្រប់ទិស ១ ភ្លើងមិនឆ្អែតដោយឧស ១ ព្រះរាជាមិនឆ្អែតដោយរាជសម្បត្តិ ១ បុគ្គលពាលមិនឆ្អែតដោយបាប ១ ស្រីមិនឆ្អែតដោយរបស់ ៣ យ៉ាង គឺមេថុនធម្ម គ្រឿងអលង្ការនិងការប្រសូតបុត្ត ១ ព្រាហ្មណ៍មិនឆ្អែតដោយមន្ត ១ អ្នកបានឈានមិនឆ្អែតដោយវិហារសមាបត្តិគឺការចូលឈាន ១ ព្រះសេក្ខបុគ្គលមិនឆ្អែតក្នុងការឲ្យទាន ១ អ្នកប្រាថ្នាតិចមិនឆ្អែតដោយធុតង្គគុណ ១ អ្នកផ្តើមព្យាយាមមិនឆ្អែតដោយការប្រារព្ធព្យាយាម ១ អ្នកសម្តែងធម៌មិនឆ្អែតដោយការសន្ទនាធម៌ ១ អ្នកក្លាហានមិនឆ្អែតដោយបរិស័ទ ១ អ្នកមានសទ្ធាមិនឆ្អែតដោយឧបដ្ឋាកសង្ឃ ១ ទាយកមិនឆ្អែតដោយការឲ្យទាន ១ បណ្ឌិតមិនឆ្អែតដោយការស្តាប់ធម៌ ១ បរិស័ទបួនមិនឆ្អែតដោយការចូលគាល់ព្រះសម្ពុទ្ធ ១ ។ ព្រាហ្មណីនោះ ក៏មិនឆ្អែតដោយមេថុនធម្ម ត្រូវការនៅឆ្ងាយអំពីព្រាហ្មណ៍ ធ្វើព្រាហ្មណ៍នោះឲ្យចេញទៅ ហើយធ្វើបាបកម្ម ។ ថ្ងៃមួយ ដេកធ្វើលំបាកចិត្ត

កាលព្រាហ្មណ៍សួរថា នែនាង តើមានរឿងអ្វី ទើបពោលថា នែព្រាហ្មណ៍ ខ្ញុំមិនអាចធ្វើការងារក្នុងផ្ទះរបស់លោក គឺធ្វើមិនបាន សូមលោកនាំយកទាសៈ និងទាសីមក ព្រាហ្មណ៍ពោលថា នែនាង ទ្រព្យរបស់យើងមិនមាន ខ្ញុំនឹងឲ្យអ្វីគេ ទើបនាំទាសៈទាសីមកបាន ព្រាហ្មណីពោលថា ដើរស្វែងរកទ្រព្យ ហើយនាំមកចុះ ។ ព្រាហ្មណ៍ពោលថា អើនាង បើយ៉ាងនោះ នាងត្រៀមស្បៀងឲ្យខ្ញុំ ។

នាងត្រៀមសដូវជុំ សដូវផង់ ដាក់ពេញថៃស្បែក ហើយប្រគល់ឲ្យព្រាហ្មណ៍ ។ ឯព្រាហ្មណ៍ កាលត្រាច់ទៅក្នុងស្រុកនិគមនិងរាជធានីទាំង-ឡាយ បានប្រាក់ ៧០០ កហាបណៈ ឃើញថា ល្មមហើយ ប្រាក់ប៉ុណ្ណោះសម្រាប់ជួលទាសៈទាសី ហើយក៏ត្រឡប់មកផ្ទះរបស់ខ្លួន លុះមកដល់ទីមួយជាទីដែលមានទឹកសប្បាយ ទើបស្រាយថៃ បរិភោគសដូវ ហើយមិនបានចងមាត់ថៃ ចុះទៅផឹកទឹក ។ ពស់វែកមួយនៅត្រង់ព្រង់ឈើបានក្លិនសដូវ ទើបលូនចូលទៅ ព័ន្ធរង្វេល ស៊ីសដូវនោះ ។ ព្រាហ្មណ៍មកហើយ មិនបានសម្លឹងមើល ចងថៃហើយ លើកឡើងដាក់លើស្មា ធ្វើដំណើរទៅ ។ រុក្ខទេវតាមួយរូបនៅក្នុងរវាងផ្លូវ ឈរលើប្រគាបឈើពោលថា នែ ព្រាហ្មណ៍ បើអ្នកឈប់ក្នុងរវាងផ្លូវអ្នកនឹងស្លាប់ឯង បើថ្ងៃនេះ អ្នកទៅដល់ផ្ទះ ភរិយារបស់អ្នកនឹងស្លាប់ ប្រាប់ហើយក៏អន្តរធានទៅ ។ ព្រាហ្មណ៍សម្លឹងមើលមិនឃើញទេវតា ត្រូវមរណភ័យគំរាម ទើបដើរយំ ដល់ទ្វារនគរពារាណសី ។ ថ្ងៃនោះជាថ្ងៃឧបោសថ ជាថ្ងៃ ១៥ ព្រះពោធិសត្វអង្គុយសម្តែងធម៌លើធម្មា

សនៈដែលគេតាក់តែងហើយ មហាជននាំគ្នាកាន់ផ្កាកម្រង និងគ្រឿងក្រអូប ដើរទៅស្តាប់ធម្មកថា ជាក្រុមៗ ព្រាហ្មណ៍ឃើញជនទាំងនោះទើបសួរថា អ្នកទាំងឡាយទៅណា កាលគេប្រាប់ថា នែព្រាហ្មណ៍ ថ្ងៃនេះ សេនកបណ្ឌិតសម្តែងធម៌ដោយសំឡេងដ៏ពីរោះ តាមពុទ្ធលីលា អ្នកមិនដឹងទេឬ ទើបគិតថា បានឮថាធម្មកថិកជាបណ្ឌិត ឯអញត្រូវមរណភ័យគំរាម ឯបណ្ឌិតអាចជួយបន្ទោបង់សេចក្តីសោកជាច្រើនបាន អញគួរចូលទៅស្តាប់ធម៌ក្នុងទីនោះ ទើបទៅក្នុងទីនោះជាមួយមហាជន ខ្លាចនូវសេចក្តីស្លាប់ បានឈរយំខាងចុងបរិស័ទ ដែលមានព្រះរាជាគង់ចោមរោមព្រះមហាសត្វ មិនឆ្ងាយអំពីធម្មាសនៈ ទាំងដែលទៃពាក់នៅលើក ។ ព្រះមហាសត្វសម្តែងធម៌ ដូចធ្វើទឹកភ្លៀងឲ្យធ្លាក់ចុះ និងដូចធ្វើភ្លៀងអមតៈឲ្យធ្លាក់ចុះ ។ មហាជនកើតនូវសោមនស្ស ឲ្យនូវសាធុការ ស្តាប់ធម៌ហើយ ។ ធម្មតាបណ្ឌិតទាំងឡាយ ជាអ្នកសម្លឹងមើលទិសផ្សេងៗ ក្នុងខណៈនោះ ព្រះមហាសត្វបើកភ្នែក ដែលមានបសាទ ទាំង ៥ ផូរផង់ មើលបរិស័ទដោយជុំវិញ ឃើញព្រាហ្មណ៍នោះ ទើបគិតថា បរិស័ទចំនួនប៉ុណ្ណេះ កើតនូវសោមនស្ស ឲ្យនូវសាធុការ ស្តាប់ធម៌ តែព្រាហ្មណ៍នេះដល់នូវទោមនស្ស ស្រែកយំ ព្រាហ្មណ៍នោះ មានសេចក្តីសោកនៅខាងក្នុង ដែលអាចឲ្យទឹកភ្នែកកើតឡើង អញនឹងសម្តែងធម៌ធ្វើឲ្យបុរសនេះ មិនមានសេចក្តីសោក ឲ្យពេញចិត្តក្នុងទីនេះឯង ដូចដេញមន្ទិលមាស ដោយរបស់ជូរនិងដូចរលាស់ តំណក់ទឹកចេញអំពីស្លឹកឈូក ដូច្នោះ ។ លោកបានហៅព្រាហ្មណ៍នោះមក កាលចរចាជាមួយព្រាហ្មណ៍នោះថា នែ

ព្រាហ្មណ៍ ខ្ញុំឈ្មោះថាសេនកបណ្ឌិត ខ្ញុំនឹងធ្វើឲ្យអ្នកមិនមានសេចក្ដីសោក សូមអ្នកទុកចិត្ត ហើយប្រាប់មកចុះ បានពោលគាថាទី ១ ថា

អ្នកមានចិត្តក្រឡុក មានចក្ខុន្ទ្រិយកម្រើក ដំណក់ទឹកហូរចេញ
អំពីភ្នែករបស់អ្នក ម្នាលព្រាហ្មណ៍អ្នកបាត់របស់អ្វី ឬក៏អ្នក
ប្រាថ្នាចង់បានរបស់អ្វី បានជាមកក្នុងទីនេះ ចូរអ្នកប្រាប់មក
មើល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កុបិតិន្ទ្រិយោសិ** សេចក្ដីថា ព្រះមហាសត្វពោលថា អ្នកមានឥន្ទ្រិយកម្រើកហើយ សំដៅដល់ចក្ខុន្ទ្រិយនោះឯង ។ បទថា **វារិគណា** បានដល់ តំណក់ទឹកភ្នែក ។ បទថា **កឹន្នុ** ត្រឹមតែជានិបាតប្រើក្នុងអត្ថជាសំតឿន ។ ពិតហើយ ព្រះមហាសត្វ កាលនឹងជាស់តឿនព្រាហ្មណ៍នោះ ទើបពោលយ៉ាងនេះថា នែព្រាហ្មណ៍ ធម្មតាសត្វទាំងឡាយសោយសោកកន្ទក់កន្ទេញព្រោះហេតុ ២ យ៉ាង គឺសាបសូន្យចាកញាតិជាទីស្រឡាញ់ណាមួយ ក្នុងបណ្ដាសត្វ និងសង្ខារទាំងឡាយនោះឯង ឬប្រាថ្នាញាតិដែលស្រឡាញ់នោះឯង តែមិនបានដូចប្រាថ្នា ។ ក្នុងចំនួន ២ យ៉ាងនោះ អ្នកសាបសូន្យចាកឥដ្ឋផលមួយណា អ្នកប្រាថ្នាអ្វីទើបមកទីនេះ ចូរប្រាប់រឿងនេះដល់ខ្ញុំដោយឆាប់ចុះ ។ លំដាប់នោះ ព្រាហ្មណ៍កាលនឹងប្រាប់ហេតុនៃសេចក្ដីសោករបស់ខ្លួនដល់ព្រះមហាសត្វ ក៏ពោលគាថាទី ២ ថា

យក្ខពោលថា កាលបើខ្ញុំទៅដល់ ( ផ្ទះ ) ក្នុងថ្ងៃនេះ ប្រពន្ធ
( របស់ខ្ញុំ ) នឹងស្លាប់ កាលបើខ្ញុំទៅមិនដល់ ( ផ្ទះ ) ទេ

ខ្ញុំនឹងស្លាប់ ដោយសេចក្តីទុក្ខនេះ បានជាខ្ញុំរន្ធត់ចិត្ត បពិត្រ សេនកៈ សូមលោកប្រាប់សេចក្តីនេះដល់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វជតោ** សេចក្តីថា ទៅដល់ផ្ទះ ។ បទថា **អគច្ឆតោ** សេចក្តីថា កាលទៅមិនដល់ ។ បទថា **យក្ខោ** សេចក្តីថា ព្រាហ្មណ៍ពោលថា រុក្ខទេវតាមួយរូបក្នុងវវាងផ្លូវពោលយ៉ាងនេះ ។ បានឮថា ទេវតានោះគួរប្រាប់ថា នែព្រាហ្មណ៍ ក្នុងថៃរបស់អ្នកមានពស់វែក តែមិនប្រាប់ ដើម្បីប្រកាសអានុភាពញាណរបស់ព្រះពោធិសត្វ ។ បទថា **ឃតេន ទុក្ខេន** សេចក្តីថា ខ្ញុំស្លុតរន្ធត់ អន្ទះអន្ទែង ញាប់ញ័រ ព្រោះហេតុនោះ គឺព្រោះទុក្ខកើតអំពីសេចក្តីស្លាប់របស់ភរិយា ក្នុងកាលដែលទៅដល់ផ្ទះ និងទុក្ខគឺការស្លាប់របស់ខ្ញុំក្នុងកាលទៅមិនដល់ផ្ទះ ។ បទថា **ឯតមត្ថំ** មានអធិប្បាយថា សូមលោកជួយប្រាប់ខ្ញុំដល់ហេតុនោះ គឺហេតុដែលឲ្យភរិយារបស់ខ្ញុំស្លាប់ គ្រាខ្ញុំទៅដល់ផ្ទះ និងហេតុធ្វើឲ្យខ្ញុំស្លាប់ បើទៅមិនដល់ផ្ទះ ។

ព្រះពោធិសត្វ បានស្តាប់ពាក្យរបស់ព្រាហ្មណ៍ ទើបផ្សាយសំណាញ់ញាណទៅ ដូចបង់សំណាញ់ចូលក្នុងសមុទ្រ គិតហើយថា ហេតុនៃការស្លាប់របស់សត្វទាំងនេះមានច្រើន គឺលិចក្នុងសមុទ្រខ្លះ ត្រូវត្រីកាចក្នុងសមុទ្រពាំទៅខ្លះ ធ្លាក់ចូលក្នុងទឹកខ្លះ ត្រូវក្រពើក្នុងទឹកពាំទៅខ្លះ ធ្លាក់ពីលើដើមឈើខ្លះត្រូវបន្លាជង់ខ្លះ ត្រូវប្រហារដោយអាវុធផ្សេងៗខ្លះ ស៊ីថ្នាំពិសខ្លះ ឡើងភ្នំហើយធ្លាក់ទៅក្នុងជ្រោះខ្លះ ឬត្រូវរោគមានប្រការផ្សេងៗមានរោគខ្លាំងជាដើម បៀតបៀនខ្លះ ក៏ស្លាប់ដូចគ្នាទាំងអស់ ។ កាលហេតុនៃការស្លាប់មានច្រើន យ៉ាង

នេះឯង ដោយហេតុអ្វីហ្ន៎ ថ្ងៃនេះ ព្រាហ្មណ៍នោះ កាលនៅក្នុងរវាងផ្លូវនឹងស្លាប់ឯង តែបើទៅដល់ផ្ទះ ភរិយារបស់គាត់នឹងស្លាប់ កាលកំពុងគិត បានមើលទៃក្នុងករបស់ព្រាហ្មណ៍ ក៏ដឹងបានដោយញាណ គឺការឈ្លាសដោយឧបាយថា ក្នុងថៃនេះមានពស់មួយលូនចូលទៅខាងក្នុង កាលលូនទៅព្រោះក្លិនសដូវក្នុងកាលព្រាហ្មណ៍នេះបរិភោគសដូវក្នុងពេលព្រឹក មិនបានចងមាត់ថៃទុកហើយទៅផឹកទឹក ព្រាហ្មណ៍ផឹកទឹកហើយមក មិនដឹងថាពស់ចូលទៅខាងក្នុងថៃ គង់ចងមាត់ថៃហើយពុនយកទៅ ។ ព្រាហ្មណ៍នេះ លុះស្នាក់នៅក្នុងរវាងផ្លូវ ក៏នឹងស្រាយថៃលូកដៃចូលទៅ ដោយតាំងចិត្តថា នឹងបរិភោគសដូវក្នុងទីដែលសម្រាកពេលល្ងាច កាលបើដូច្នោះ ពស់ក៏នឹងចឹកដៃព្រាហ្មណ៍ឲ្យដល់នូវការអស់ជីវិត នេះគឺហេតុនៃការស្លាប់របស់ព្រាហ្មណ៍ ដែលស្នាក់នៅក្នុងរវាងផ្លូវ ។ បើព្រាហ្មណ៍នោះទៅដល់ផ្ទះសោត ថៃនឹងធ្លាក់ដល់ដៃភរិយានាងក៏នឹងស្រាយថៃ យកដៃលូកដោយតាំងចិត្តថា នឹងមើលរបស់ខាងក្នុងកាលបើដូច្នោះ ពស់ក៏នឹងចឹកនាងឲ្យដល់នូវការអស់ជីវិត នេះគឺហេតុនៃការស្លាប់របស់ភរិយារបស់ព្រាហ្មណ៍ដែលទៅដល់ផ្ទះក្នុងថ្ងៃនេះ ។ លំដាប់នោះព្រះមហាសត្វមានសេចក្តីត្រិះរិះថា ពស់វែកនេះក្លាហាន មិនខ្លាចភ័យ ព្រោះថា ពស់នេះ សូម្បីប៉ះធ្មឹងជំនីររបស់ព្រាហ្មណ៍ ក៏មិនកម្រើក ឬបម្រះនទៀលទោះបីក្នុងកណ្តាលបរិស័ទបែបនេះក៏មិនសម្តែងការមានរបស់ខ្លួន ព្រោះហេតុនោះ ពស់វែកនេះក្លាហាន មិនខ្លាចភ័យ ។ សូម្បីហេតុការណ៍ ដូចពោលមកនេះ ព្រះមហាសត្វក៏ដឹងដោយញាណ គឺភាពជាអ្នកឈ្លាសក្នុងឧបាយនោះ

ឯង ដូចឃើញដោយទិព្វចក្ខុ កាលបើដូច្នេះ ព្រះមហាសត្វ កំណត់ដោយញាណ គឺភាពជាអ្នកឈ្លាសក្នុងឧបាយនោះឯង ដូចបុគ្គលឈរមើលពស់ដែលកំពុងលូនចូលទៅក្នុងថង់ កណ្តាលបរិស័ទដែលមានព្រះរាជាគង់នៅកាលនឹងដោះស្រាយបញ្ហារបស់ព្រាហ្មណ៍ ទើបពោលគាថាទី ៣ ថា

យើងរិះគិតនូវហេតុច្រើនយ៉ាង បណ្តាហេតុទាំងនោះ យើងនឹងប្រាប់ហេតុណាមួយ ហេតុនោះឯង ជារបស់ពិត ម្នាលព្រាហ្មណ៍ យើងយល់ថា អ្នកមិនបានដឹងទេ មានពស់វែកលូនចូលក្នុងថង់សង្កូវ ដូច្នេះ ។

បណ្តាបទទាំងនោះបទថា **ពហូនិ ឋានានិ** បានដល់ ហេតុច្រើនយ៉ាង ។ បទថា **វិចិន្តយិត្វា** សេចក្តីថា ដូចសម្រេចបដិវេធដោយអំណាចនៃការចាក់ធ្លុះ ។ បទថា **យមេត្ថ វក្ខាមិ** សេចក្តីថា បណ្តាហេតុទាំងនោះ យើងនឹងប្រាប់ហេតុឯណាមួយដល់អ្នក ។ ដោយបទថា **តទេវ សច្ចំ** ព្រះមហាសត្វសម្តែងថា ហេតុនោះឯងជារឿងពិត គឺដូចគ្នានឹងរឿងដែលឃើញដោយទិព្វចក្ខុ ហើយទើបប្រាប់ ។ បទថា **មញ្ញាមិ** បានដល់ កំណត់ ។ បទថា **សត្តុភស្តំ** បានដល់ ថង់សង្កូវ ។ បទថា **អជានតោ** សេចក្តីថា ខ្ញុំយល់ថាកាលអ្នកមិនដឹងនោះឯង ពស់វែកមួយលូនចូលទៅហើយ ។

ព្រះមហាសត្វ កាលពោលយ៉ាងនេះហើយ ទើបសួរថា នែព្រាហ្មណ៍ក្នុងថង់របស់អ្នកមានសង្កូវដែរឬទេ ព្រាហ្មណ៍ប្រាប់ថា បពិត្របណ្ឌិត មានមហាសត្វពោលថា ថ្ងៃនេះ ពេលព្រឹក អ្នកអង្គុយបរិភោគសង្កូវ ពិតឬ

ព្រាហ្មណ៍ពោលថា បពិត្របណ្ឌិត ពិតហើយ មហាសត្វសួរថា អ្នកអង្គុយក្នុងទីណា ព្រាហ្មណ៍ពោលថា ត្រង់គល់ឈើក្នុងព្រៃ មហាសត្វពោលថា អ្នកបរិភោគសដូវហើយ កាលទៅផឹកទឹកមិនចងមាត់ថង់ទេមែនឬ ព្រាហ្មណ៍ពោលថា បពិត្របណ្ឌិត មិនបានចងទេ មហាសត្វពោលថា អ្នកផឹកទឹកហើយមកមិនបានពិនិត្យមើលថង់ទេមែនឬ ព្រាហ្មណ៍ពោលថា បពិត្របណ្ឌិត ខ្ញុំមិនបានមើលឡើយ មហាសត្វពោលថា នែព្រាហ្មណ៍ ខ្ញុំយល់ថា ក្នុងពេលអ្នកទៅផឹកទឹក ពស់ចូលទៅក្នុងថង់ហើយ ព្រោះបានក្លិនសដូវរបស់អ្នក អ្នកមិនដឹងខ្លួនឡើយ អ្នកបានមកទីនេះយ៉ាងនេះហើយ ព្រោះហេតុនោះ ចូរដាក់ថង់ចុះត្រង់កណ្ដាលបរិស័ទ ស្រាយមាត់ថង់ចេញ ហើយគេចទៅឈរឲ្យឆ្ងាយល្មមសមគួរ កាន់ឈើមួយកំណាត់គោះថង់មើល បន្ទាប់អំពីនោះ ក៏នឹងឃើញពស់វែកបើកពពារបញ្ចេញសំឡេង សុ សុ លូនចេញមក នឹងអស់សង្ស័យ ដូច្នេះទើបពោលគាថាទី ៤ ថា

អ្នកចូរយកដំបងគោះថង់មើល អ្នកចូរមើលពស់ ដែលមានអណ្ដាតពីរ ហៀរទឹកមាត់ចេញមក អ្នកចូរកាត់បង់នូវសេចក្ដីសង្ស័យផង នូវសេចក្ដីងឿងឆ្ងល់ផង ក្នុងថ្ងៃនេះ អ្នកចូរមើលពស់ អ្នកចូរទម្លាក់ថង់ចោលទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បរិសុម្ភ** សេចក្ដីថា ចូរគោះ ។ បទថា **បស្សេលមូគំ** សេចក្ដីថា អ្នកនឹងឃើញពស់មានអណ្ដាត ២ ផ្ទំពិសតាមមាត់មានទឹកមាត់ហូរចេញមក ។ បទថា **ឆិន្ទជ្ជ កង្ខំ វិចិកិច្ឆិតានិ** សេចក្ដីថា

ថ្ងៃនេះ អ្នកនឹងកាត់ការសន្ទិះ និងការសង្ស័យដែលកើតឡើងរឿយៗថា ក្នុងទៃមានពស់ ឬមិនមានហ្ន៎ ជឿខ្ញុំចុះ ព្រោះពាក្យព្យាការណ៍របស់ខ្ញុំ មិនខុសភ្លាំងភ្លាត់ អ្នកនឹងឃើញពស់លូនចេញមកឥឡូវនេះឯង ចូរស្រាយថៃចុះ ។

ព្រាហ្មណ៍ បានស្តាប់ពាក្យរបស់មហាសត្វហើយ ភិតភ័យ ដល់នូវការតក់ស្លុត បានធ្វើតាមនោះ ។ ឯពស់ត្រូវឈើគោះចំរង្វេល ក៏លូនចេញមកពីមាត់ថៃ ឃើញមនុស្សជាច្រើន ទើបនៅស្ងៀម ។

ព្រះសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះ ទើបពោលគាថាទី ៥ ថា

ព្រាហ្មណ៍នោះមានសភាពតក់ស្លុតក្នុងកណ្តាលបរិស័ទ ហើយ
ក៏បោះថៃនៃសជូវចោល ទើបពស់ជាសត្វអាសីពិស លូនទៅ
ដោយទ្រូង មានតេជះក្លា ក៏បើកពពារលូនចេញមក ដូច្នេះ ។

ក្នុងកាលពស់បើកពពារចេញមក ពាក្យព្យាករណ៍របស់មហាសត្វ បានដូចជាពាក្យព្យាករណ៍របស់ព្រះសព្វញ្ញុពុទ្ធ ។ មហាជន នាំគ្នាលើកសំពត់គ្រវីរាប់ពាន់ លើកម្រាមដៃឡើងគ្រវីទៅជុំវិញរាប់ពាន់ដង ។ ភ្លៀងកែវ ៧ ប្រការធ្លាក់ចុះមក ដូចព្រិលធ្លាក់ ។ សាធុការប្រព្រឹត្តទៅរាប់ពាន់ សំឡេងហាក់ដូចមហាប្រឹថពីស្រុត ។ ធម្មតាការស្រាយបញ្ហាបែបនេះ ដោយពុទ្ធលីលានេះ មិនមែនជាកម្លាំងរបស់វណ្ណៈ មិនមែនជាកម្លាំងរបស់គោត្ត មិនមែនជាកម្លាំងរបស់ត្រកូល មិនមែនជាកម្លាំងរបស់ប្រទេស មិនមែនជាកម្លាំងរបស់យសនិងកម្លាំងនៃទ្រព្យទាំងឡាយ មិនមែនជាកម្លាំងរបស់អ្វីឡើយ គឺកម្លាំងរបស់បញ្ញាប៉ុណ្ណោះ ដ្បិតថា បុគ្គលមានកម្លាំងវិបស្សនាហើយ នឹងបើកទ្វារ

អរិយមគ្គចូលទៅកាន់អមត មហានិព្វានបាន សម្រេចសាវកបារមីខ្លះ បច្ចេកពោធិញ្ញាណខ្លះ សម្មាសម្ពោធិញ្ញាណខ្លះ ព្រោះថា បណ្ដាធម៌ទាំងឡាយដែលឲ្យសម្រេចអមតមហានិព្វាន បញ្ញាប៉ុណ្ណោះប្រសើរបំផុត ធម៌ទាំងឡាយដ៏សេស ត្រឹមតែជាបរិវាររបស់បញ្ញាប៉ុណ្ណោះ ព្រោះហេតុនោះទើបទ្រង់ត្រាស់ទុក ( ក្នុងសរភង្គជាតក ) ថា

អ្នកឈ្លាសវៃទាំងឡាយ ពោលថា ប្រាជ្ញាជាគុណជាតិដ៏ប្រសើរបំផុត ដូចស្ដេចនៃផ្កាយ ( ព្រះចន្ទ ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ ទុកជាសីលក្ដី សិរីក្ដី ធម៌របស់សប្បុរសក្ដីក៏ប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា ដូច្នេះ ។

កាលព្រះមហាសត្វពោលស្រាយបញ្ហាយ៉ាងនេះហើយ អាលម្ពាយម្នាក់ក៏ចងមាត់ពស់ ហើយចាប់ពស់ទៅលែងក្នុងព្រៃ ព្រាហ្មណ៍ចូលទៅគាល់ព្រះរាជា ថ្វាយព្រះពរឲ្យទ្រង់មានជ័យជម្នះ ហើយផ្គងអញ្ជលី កាលសរសើរព្រះរាជា ទើបពោលកន្លះគាថាថា

ព្រះរាជាជនកៈអង្គណា បានជួបនឹងសេនកបណ្ឌិត អ្នកមានប្រាជ្ញាចេះ ព្រះរាជាជនកៈ ( អង្គនោះ ) ឈ្មោះថាមានលាភបានហើយដោយប្រពៃ ដូច្នេះ ។

ក្នុងគាថានោះ មានអធិប្បាយថា ព្រះជនកអង្គណា ទ្រង់បើកព្រះនេត្រហើយបានឃើញសេនកបណ្ឌិត អ្នកមានបញ្ញាល្អ គឺមានបញ្ញាឧត្ដម ដោយព្រះនេត្រដែលជាទីស្រឡាញ់ គ្រប់ខណៈ ដែលទ្រង់បំណងទាំងនោះ របស់

ព្រះបាទជនកៈនោះ ជាលោកដែលទ្រង់បានហើយដោយប្រពៃពិត គឺបណ្ដាលោកទាំងអស់ដែលព្រះបាទជនកនោះទ្រង់បានហើយ លោកទាំងនោះប៉ុណ្ណោះ ឈ្មោះថា ជាលោកដែលទ្រង់បានមកល្អហើយ ។

កាលសរសើរព្រះរាជាហើយ ព្រាហ្មណ៍បានទាញយកប្រាក់ ៧០០ កហាបណៈ ចេញអំពីថៃបំណងនឹងសរសើរព្រះមហាសត្វ ឲ្យនូវការសរសើរទើបពោលគាថាមួយគាថាកន្លះថា

បពិត្រព្រាហ្មណ៍ អ្នកមានធម៌កំបាំង ( ញេយ្យធម៌ ) បើកហើយ ជាអ្នកឃើញនូវធម៌ទាំងអស់ឬ បានជាញាណរបស់អ្នក គួរស្ញប់ស្ញែងម្ល៉េះ ខ្ញុំមានកហាបណៈប្រាំពីររយនេះ សូមអ្នកយកទាំងអស់ចុះ ខ្ញុំជូនអ្នក ត្បិតខ្ញុំបានជីវិតក្នុងថ្ងៃនេះដោយសារអ្នក មិនតែប៉ុណ្ណោះសោត ថែមទាំងអ្នកបានធ្វើសួស្ដីដល់កិរិយា ( របស់ខ្ញុំ ) ទៀតផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិវដ្ដច្ឆទោ នុ សិ សព្វទស្សី** សេចក្ដីថា ព្រាហ្មណ៍សួរដោយអំណាចការសរសើរថា លោកជាសព្វញ្ញុពុទ្ធ បើកនូវគ្រឿងបិទបាំងក្នុងអាការរបស់ធម៌គ្រប់យ៉ាង គឺលោកជាអ្នកមានធម៌ដែលគួរដឹងបើកហើយ ឬដូចម្ដេច ។ បទថា **ញាណំ នុ តេ ព្រាហ្មណ ភឹសរូបំ** សេចក្ដីថា បពិត្រព្រាហ្មណ៍ កាលលោកជាអ្នកដឹងសព្វយ៉ាង ញាណរបស់លោកជាញាណដែលគួរស្ញប់ស្ញែងពន់ពេក គឺមានកម្លាំងដូចសព្វញ្ញុតញ្ញាណ ។ បទថា **តយា ហិ មេ** សេចក្ដីថា ថ្ងៃនេះ ខ្ញុំបានជីវិតមក ព្រោះលោកឲ្យ ។

បទថា **អជោបិ ភរិយាយមកាសិ សោត្ថឹ** សេចក្តីថា ម្យ៉ាងទៀត លោកក៏បានធ្វើនូវសួស្តីដល់ភរិយារបស់ខ្ញុំ ។ ព្រាហ្មណ៍នោះ កាលពោលយ៉ាងនេះហើយ ក៏អង្វរព្រះពោធិសត្វហើយអង្វរទៀតថា បើមានទ្រព្យមួយសែនសោត ខ្ញុំក៏ត្រូវឲ្យនោះឯង ។ តែទ្រព្យរបស់ខ្ញុំមានត្រឹមតែប៉ុណ្ណេះប៉ុណ្ណោះសូមលោកទទួលទ្រព្យ ៧០០ កហាបណៈនេះចុះ ព្រះពោធិសត្វកាលបានឮពាក្យនោះហើយ ទើបពោលគាថាទី ៨ ថា

បណ្ឌិតទាំងឡាយ មិនបានទទួលយករង្វាន់ដោយពោលគាថា
ទាំងឡាយដ៏វិចិត្រទេ ម្នាលព្រាហ្មណ៍ ( ជនទាំងឡាយ ) ឲ្យ
ទ្រព្យអំពីបាទមូលរបស់យើងនេះដល់អ្នក អ្នកចូរយក ហើយ
ចូរទៅកាន់លំនៅរបស់ខ្លួនចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេត្តនំ** បានដល់ ថ្លៃរង្វាន់ ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **ឥតោបិ តេ ព្រាហ្មណ** សេចក្តីថា នែព្រាហ្មណ៍ ជនទាំងឡាយចូរឲ្យទ្រព្យដល់អ្នកទៀបបាតជើងរបស់ខ្ញុំ ។ បទថា **វិត្តំ អាទាយ ត្វំ គច្ឆ** អធិប្បាយថា ចូរកាន់យកទ្រព្យចំនួនដទៃទៀត ៣០០ កហាបណៈអំពីទីនេះរួមជា ១០០០ កហាបណៈ ហើយទៅកាន់លំនៅរបស់ខ្លួនចុះ ។

កាលព្រះមហាសត្វពោលយ៉ាងនេះហើយ ក៏ឲ្យកហាបណៈដល់ព្រាហ្មណ៍គម្រប់ ១០០០ ហើយសួរថា នែព្រាហ្មណ៍ អ្នកណាបញ្ជូនអ្នកមករកទ្រព្យ ព្រាហ្មណ៍ប្រាប់ថា បពិត្របណ្ឌិត ភរិយារបស់ខ្ញុំ មហាសត្វសួរថា ភរិយា

របស់អ្នកចាស់ឬក្មេង ព្រាហ្មណ៍ប្រាប់ថា បពិត្របណ្ឌិតក្មេង ។ ព្រះពោធិសត្វពោលថា បើដូច្នោះ នាងគង់នឹងប្រព្រឹត្តអនាចារជាមួយបុរសដទៃទើបបញ្ជូនអ្នកទៅ ដោយបំណងថា ងាយស្រួលនឹងប្រព្រឹត្តអនាចារ ។ មហាសត្វប្រាប់បន្តទៀតថា បើអ្នកនាំកហាបណៈទាំងនោះទៅដល់ផ្ទះហើយសោត នាងនឹងឲ្យកហាបណៈ ដែលអ្នករកបានមកដោយលំបាក ដល់សហាយរបស់ខ្លួន ។ ព្រោះហេតុនោះ អ្នកកុំតម្រង់ទៅផ្ទះតែម្តង គួរលាក់កហាបណៈទុកត្រង់គល់ឈើឬត្រង់ទីឯណានីមួយខាងក្រៅផ្ទះ ហើយសឹមចូលទៅ ដូច្នេះហើយ ក៏បញ្ជូនព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍នោះបានទៅជិតផ្ទះហើយ ក៏ទុកកហាបណៈត្រង់គល់ឈើមួយដើម ទើបចូលផ្ទះក្នុងពេលល្ងាច ។ សម័យនោះ ភរិយារបស់គាត់ បានអង្គុយជាមួយសហាយ ព្រាហ្មណ៍ឈរត្រង់ទ្វារ ពោលថា អើនាង នាងចាំសំឡេងព្រាហ្មណ៍បាន ក៏ពន្លត់ភ្លើងបិទទ្វារ កាលព្រាហ្មណ៍ចូលខាងក្នុង ទើបនាំសហាយចេញទៅ ឲ្យឈរត្រង់មាត់ទ្វារ ហើយក៏ចូលផ្ទះមិនឃើញមានអ្វីក្នុងដៃ ទើបសួរថា នែព្រាហ្មណ៍ លោកត្រាច់ទៅសូមបានអ្វីមក ព្រាហ្មណ៍ពោលថា បានកហាបណៈ ១០០០ ភរិយាពោលថា លោកទុកឯណា ព្រាហ្មណ៍ពោលថា ទុកក្នុងទីឈ្មោះនោះ ចាំព្រឹកសឹមយកមក នាងកុំគិតថ្វីឡើយ នាងទៅប្រាប់សហាយ ទើបសហាយចេញទៅយកដូចរបស់ដែលខ្លួនកប់ទុកឯង ។ ស្អែកឡើង ព្រាហ្មណ៍ទៅ ក៏មិនឃើញកហាបណៈ ទើបទៅរកព្រះពោធិសត្វ កាលព្រះពោធិសត្វសួរថា តើមានរឿងអ្វី ទើបប្រាប់ថា ខ្ញុំបាត់កហាបណៈ ព្រះមហាសត្វពោលថា អ្នកប្រាប់ភរិយារបស់អ្នកឬ ព្រា-

ហ្មណ៍ពោលថា បពិត្របណ្ឌិត មែនហើយ ។

ព្រះមហាសត្វក៏ដឹងថា ស្រីនោះប្រាប់សហាយ ទើបសួរថា នែព្រាហ្មណ៍ កិរិយារបស់អ្នក មានព្រាហ្មណ៍ប្រចាំត្រកូលដែរឬទេ ព្រាហ្មណ៍ពោលថា បពិត្របណ្ឌិត មាន ព្រះមហាពោធិសត្វពោលថា ចុះព្រាហ្មណ៍ប្រចាំត្រកូលរបស់អ្នកមានដែរឬទេ ព្រាហ្មណ៍ពោលថា បពិត្របណ្ឌិត មាន ។

ព្រះមហាសត្វ បានឲ្យស្បៀងអាហារ ល្មមធ្វើបុណ្យបាន ៧ ថ្ងៃ ដល់ព្រាហ្មណ៍ហើយប្រាប់ថា ទៅចុះអ្នក ថ្ងៃដំបូង ចូរអញ្ជើញព្រាហ្មណ៍ ១៤ នាក់ គឺខាងអ្នក ៧ ខាងកិរិយា ៧ តាំងអំពីស្អែកឡើងជាដើមទៅ ត្រូវបន្ថយមួយថ្ងៃម្នាក់ ក្នុងថ្ងៃទី ៧ ទើបអញ្ជើញព្រាហ្មណ៍ ២ នាក់ គឺខាងអ្នកម្នាក់ ខាងកិរិយារបស់អ្នកម្នាក់ កាលដឹងថា ព្រាហ្មណ៍ជាមនុស្សដែលកិរិយារបស់អ្នកអញ្ជើញមក ៧ ថ្ងៃជាប្រចាំ ហើយចូរប្រាប់ដល់ខ្ញុំ ។ ព្រាហ្មណ៍បានធ្វើតាមនោះ ហើយទើបមកប្រាប់ព្រះមហាសត្វថា បពិត្របណ្ឌិត ខ្ញុំកំណត់ព្រាហ្មណ៍ដែលមកទទួលទានជានិច្ចទុកហើយ ។ ព្រះពោធិសត្វបញ្ជូន បុរសទៅជាមួយព្រាហ្មណ៍នោះ ឲ្យនាំព្រាហ្មណ៍នោះមក ហើយសួរថា ឯងយកកហាបណៈ ១០០០ ដែលជារបស់ព្រាហ្មណ៍នេះ អំពីគល់ឈើនោះឬ ព្រាហ្មណ៍នោះបដិសេធថា ខ្ញុំមិនបានយកទេ ព្រះពោធិសត្វប្រាប់ថា ឯងមិនស្គាល់យើងថាជាសេនកបណ្ឌិតទេឬ យើងនឹងឲ្យអ្នកនាំកហាបណៈមកសង បុរសនោះខ្លាចទើបទទួលថា ខ្ញុំយក មហាសត្វសួរថា ឯងយកទៅទុកឯណា ព្រាហ្មណ៍នោះពោលថា ទុកក្នុងទីនោះៗឯង ។

ព្រះពោធិសត្វសួរព្រាហ្មណ៍ដែលជាប្ដីថា នែព្រាហ្មណ៍ ស្រីនោះឯងជាកិរិយារបស់អ្នកឬ ឬនឹងទទួលយកអ្នកដទៃ ព្រាហ្មណ៍ពោលថា នាងនោះឯងជាកិរិយារបស់ខ្ញុំ ។ ព្រះពោធិសត្វបញ្ជូនមនុស្សទៅ ឲ្យនាំកហាបណៈរបស់ព្រាហ្មណ៍ និងព្រាហ្មណីមក ហើយឲ្យមនុស្សទទួលកហាបណៈអំពីដៃរបស់ព្រាហ្មណ៍ដែលជាចោរ មកឲ្យដល់ព្រាហ្មណ៍ ឲ្យដាក់រាជអាជ្ញាដល់ព្រាហ្មណ៍ដែលជាចោរ និរទេសចេញអំពីព្រះនគរ ហើយឲ្យដាក់អាជ្ញាដល់ព្រាហ្មណី ឲ្យនូវយសធំដល់ព្រាហ្មណ៍ ហើយឲ្យនៅក្នុងសម្នាក់របស់ខ្លួននោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ មនុស្សជាច្រើនបានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ រុក្ខទេវតាក្នុងកាលនោះ បានមកជាសារីបុត្ត បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ឯសេនកបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សេនកជាតក ចប់**

# អដ្ឋិសេនជាតក

[ ៣២០ ] ( ព្រះបាទពារាណសីសួរពោធិសត្វថា ) បពិត្រ តាបស ព្រះនាមអដ្ឋិសេន ខ្ញុំមិនដែលស្គាល់ពួកស្មូមណា ពួកស្មូមនោះ ប្រជុំគ្នាមករកខ្ញុំ ហើយសូម ( នូវវត្ថុដែលខ្លួនត្រូវការ ) ហេតុអ្វីក៏លោកមិនសូមខ្ញុំ ។

[ ៣២១ ] ( តាបសពោធិសត្វពោលថា ) បុគ្គលអ្នកសូម រមែងមិនជាទីស្រឡាញ់ ( នៃអ្នកឲ្យ ) បុគ្គលអ្នកមិនឲ្យនូវរបស់ដែលគេសូម រមែងមិនជាទីស្រឡាញ់ ( នៃស្មូម ) ព្រោះហេតុនោះ បានជាអាត្មាមិនសូមមហារាជ កុំឲ្យមហារាជស្អប់អាត្មាឡើយ ។

[ ៣២២ ] ( ព្រះរាជាត្រាស់ថា ) សមណព្រាហ្មណ៍ណារស់ដោយការសូមតែមិនសូមវត្ថុដែលខ្លួនត្រូវសូមក្នុងកាលគួរ ( សមណព្រាហ្មណ៍នោះ ) ឈ្មោះថាញុំាងបុគ្គលដទៃឲ្យខូចបុណ្យផង ឈ្មោះថាមិនបានរស់ស្រួលដោយខ្លួនឯងផង ។

[ ៣២៣ ] សមណព្រាហ្មណ៍ណារស់ដោយការសូម ហើយសូមនូវវត្ថុដែលខ្លួនត្រូវការសូមក្នុងកាលគួរ ( សមណព្រាហ្មណ៍នោះ ) ឈ្មោះថាញុំាងបុគ្គលដទៃឲ្យបានបុណ្យផង ឈ្មោះថារស់នៅស្រួលដោយខ្លួនឯងផង ។

[ ៣២៤ ] បុគ្គលមានប្រាជ្ញាទាំងឡាយ ឃើញពួកស្មូមមកដល់ហើយមិនដែលប្រទូស្ត លោកជាព្រហ្មចារីបុគ្គល ជាទីស្រឡាញ់នៃខ្ញុំ លោកប្រាថ្នារបស់ណាដែលត្រូវនិយាយសូម លោកចូរសូមចុះ ។

[ ៣២៥ ] ( ពោធិសត្វពោលថា ) បុគ្គលមានប្រាជ្ញាទាំងឡាយ មិនដែលសូមទេ ស្រេចតែនឹង ( ឧបដ្ឋាក ) អ្នកមានប្រាជ្ញាគួរដឹង ( ខ្លួនឯងចុះ )

ពួកអរិយៈគ្រាន់តែឈរឧទ្ទិសស្ងៀមៗប៉ុណ្ណោះ ទុំះជាការសូមរបស់ពួកអរិយៈ ។

[ ៣២៦ ] ( ព្រះរាជាពោលថា ) បពិត្រព្រាហ្មណ៍ ខ្ញុំសូមប្រគេនមេគោមានសម្បុរក្រហម ១ ពាន់ ព្រមទាំងគោឈ្មោលដល់លោកម្ចាស់ ដ្បិតជាបុគ្គលមានមារយាទដ៏ប្រសើរ បានស្តាប់គាថារបស់លោកដែលប្រកបដោយធម៌ហើយ មិនឲ្យដល់បុគ្គលមានអាចារៈដ៏ប្រសើរ ( ដូចគ្នា ) ដូចម្តេចបាន ។

**ចប់ អដ្ឋិសេនជាតកទី ៨ ។**

## អដ្ឋកថា

## អដ្ឋិសេនជាតក

[ ៣២០-៣២៦ ] ព្រះសាស្តា ទ្រង់អាស្រ័យក្រុងអាឡវី គង់នៅត្រង់អគ្គាឡវចេតិយ ទ្រង់ប្រារព្ធកុដិការសិក្ខាបទ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **យេ មេ អហំ ន ជានាមិ** ដូច្នេះជាដើម ។ រឿងបច្ចុប្បន្នដូចគ្នាដែលពោលមកហើយក្នុងមណិកណ្ឋជាតកខាងដើមនោះឯង ។

ព្រះសាស្តាហៅភិក្ខុទាំងនោះមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយក្នុងសម័យមុន កាលព្រះពុទ្ធមិនទាន់កើតឡើង បុរាណកបណ្ឌិត បានបួសក្នុងពាហិរកលទ្ធិ ព្រះរាជាទ្រង់បវារណាហើយ ក៏មិនទូលសូមរបស់ណាមួយដោយគិតថា ឈ្មោះថា ការសូមរបស់ស្រឡាញ់រមែងមិនជាទីស្រឡាញ់មិនជាទីពេញចិត្តនៃជនដទៃ ដូច្នេះហើយ ទ្រង់បាននាំយករឿងក្នុងអតីតមកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ នានិគមមួយ ។ ពួកញាតិបានដាក់ឈ្មោះថា អគ្គិសេនកុមារ ។ កុមារនោះចម្រើនវ័យហើយ បានរៀនសិល្បសាស្ត្រគ្រប់យ៉ាងក្នុងនគរតក្កសិលា ។ សម័យក្រោយមក ឃើញទោសក្នុងកាមទាំងឡាយ ហើយបានចេញចាកឃរាវាស បួសជាឥសី ឲ្យឈានសមាបត្តិនិងអភិញ្ញាសមាបត្តិកើតឡើងហើយ នៅត្រង់ទឹកដីនៃព្រៃហិមពាន្ត អស់កាលយូរ ។ ក្រោយមក បានមកកាន់ទឹកដីមនុស្ស ដើម្បីបរិភោគរសជូរប្រៃ ដល់នគរពារាណសីដោយលំដាប់ ស្នាក់នៅក្នុងព្រះរាជឧទ្យាន ព្រឹកឡើងបានត្រាច់ភិក្ខាចារ ដល់លានព្រះរាជវាំង ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងអាចារ និងវិហារធម៌របស់ព្រះពោធិសត្វ ទើបឲ្យរាជបុរសនិមន្តព្រះពោធិសត្វមក ឲ្យគង់លើប្រាសាទ ឆាន់នូវបណីតភោជន ទ្រង់ស្តាប់អនុមោទនាកថា ក្នុងកាលស្រេចភត្តកិច្ច ទ្រង់ជ្រះថ្លាទើបទ្រង់ឲ្យព្រះមហាសត្វទទួលបដិញ្ញា ដើម្បីស្នាក់នៅត្រង់ព្រះរាជឧទ្យាន ហើយបានយាងទៅឧបដ្ឋាកមួយថ្ងៃ ២-៣ ដង ។ ថ្ងៃមួយព្រះរាជាទ្រង់ជ្រះថ្លាក្នុងធម្មកថា ទើបទ្រង់បវារណាថា លោកម្ចាស់ត្រូវការរបស់ណា តាំងពីរាជសម្បត្តិឡើងទៅ សូមលោកម្ចាស់ប្រាប់របស់នោះចុះ ។ ព្រះពោធិសត្វមិនថ្វាយព្រះពរថា សូមទ្រង់ព្រះរាជទានវត្ថុនេះដល់អាត្មា សូមទ្រង់ព្រះរាជទានវត្ថុនេះដល់អាត្មា ស្មូមដទៃទូលសូមវត្ថុដែលខ្លួនត្រូវការថា សូមទ្រង់ព្រះរាជទានរបស់នេះ សូមទ្រង់ព្រះរាជទានរបស់នេះ ។ ព្រះរាជាព្រះរាជទានមិនទើសទាក់ ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា យាចកនិងវនិព្វកដទៃ

សូមនឹងអញថា សូមទ្រង់ព្រះរាជទានរបស់នេះផង របស់នេះផង ដល់ទូលព្រះបង្គំទាំងឡាយ តែលោកម្ចាស់អដ្ឋិសេននេះ តាំងពីអញបវារណាហើយ មិនសូមអ្វីសោះ លោកម្ចាស់អង្គនេះជាអ្នកមានបញ្ញាពិត ជាអ្នកឈ្លាសក្នុងឧបាយ អញនឹងសាកសួរលោក ថ្ងៃមួយ ទ្រង់សោយព្រះក្រយាហារព្រឹកហើយ បានយាងទៅឧបដ្ឋាកឥសី ទ្រង់ថ្វាយបង្គំហើយ គង់ប្រថាប់ក្នុងទីសមគួរ កាលនឹងត្រាស់សួរដល់ហេតុនៃការសូមរបស់យាចកដទៃ និងហេតុនៃការមិនសូមរបស់ព្រះពោធិសត្វ ក៏បានត្រាស់គាថាទី ១ ថា

> បពិត្រតាបសព្រះនាម អដ្ឋិសេន ខ្ញុំមិនដែលស្គាល់ពួកស្មូមណា ពួកស្មូមនោះប្រជុំគ្នាមករកខ្ញុំហើយសូម ( នូវវត្ថុដែលខ្ញុំត្រូវការ ) ហេតុអ្វី ក៏លោកមិនសូមខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វនិព្វកេ** បានដល់ អ្នកសូម ។ បទថា **សង្គម្ម** សេចក្តីថា នាំគ្នាមករក ។ មានពាក្យអធិប្បាយថា បពិត្រលោកម្ចាស់អដ្ឋិសេន វនិព្វកពួកណា ខ្ញុំមិនស្គាល់ថា ជនទាំងនេះឈ្មោះនេះ ដោយឈ្មោះ ជាតិ គោត្ត ត្រកូល និងប្រទេស វនិព្វកទាំងនោះនាំគ្នាមករក ហើយសូមវត្ថុដែលខ្ញុំត្រូវការអំពីហេតុណា ហេតុអ្វីទើបលោកម្ចាស់មិនសូមអ្វីនឹងខ្ញុំ ។ ព្រះពោធិសត្វបានស្តាប់ដូច្នេះហើយ បានពោលគាថាទី ២ ថា

> បុគ្គលអ្នកសូមរមែងមិនជាទីស្រឡាញ់ ( នៃអ្នកឲ្យ ) បុគ្គលអ្នកមិនឲ្យនូវរបស់ដែលគេសូម រមែងមិនជាទីស្រឡាញ់ ( នៃស្មូម ) ព្រោះហេតុនោះ បានជាអាត្មាមិនសូមមហារាជ កុំឲ្យ

មហារាជស្អប់អាត្មាឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យាចកោ អប្បិយោ ហោតិ** សេចក្ដីថា សូមថ្វាយព្រះពរមហាបពិត្រ បុគ្គលដែលសូមថា សូមទ្រង់ឲ្យវត្ថុនេះដល់ខ្ញុំ សូមទ្រង់ឲ្យវត្ថុនេះដល់ខ្ញុំ រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់មាតាបិតាខ្លះ របស់មិត្តនិងអាមាត្យជាដើមខ្លះ ការដែលបុគ្គលនោះមិនជាទីស្រឡាញ់គួរសម្ដែងដោយមណិកណ្ឋកជាតក ។ បទថា **យាចំ** បានដល់ របស់ដែលគេសូម ។ បទថា **អទទំ** បានដល់ មិនឲ្យ អធិប្បាយថា ចំណែកបុគ្គលដែលមិនឲ្យ រាប់អំពីមាតាបិតាជាដើមទៅ មិនឲ្យវត្ថុដែលគេសូមរមែងមិនជាទីស្រឡាញ់របស់អ្នកសូម ។ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុអ្នកសូម ក៏មិនជាទីស្រឡាញ់របស់អ្នកឲ្យ ទាំងអ្នកឲ្យកាលមិនឲ្យរបស់ដែលគេសូម ក៏មិនជាទីស្រឡាញ់របស់អ្នកសូម ហេតុនោះទើបអាត្មាមិនសូមរបស់អ្វីមួយនឹងមហាបពិត្រ ។ បទថា **មា មេ វិទ្ទេស្សនា អហុ** សេចក្ដីថា បើអាត្មាគប្បីសូមទ្រង់សោត មហាបពិត្រ ក៏គង់ព្រះរាជទានវត្ថុនោះដល់អាត្មា តែគង់អាក់អន់ព្រះហឫទ័យដល់មហាបពិត្រ ការអាក់អន់ចិត្តដែលកើតឡើងអំពីសម្នាក់មហាបពិត្រនោះ ក៏នឹងមានដល់អាត្មា បើមហាបពិត្រមិនព្រះរាជទានសោត មហាបពិត្រគង់ជាទីអាក់អន់របស់អាត្មា អាត្មាក៏នឹងមានការអាក់អន់ចិត្តក្នុងមហាបពិត្រ កាលបើដូច្នោះ អាត្មាកុំបីមានការអាក់អន់ក្នុងទីគ្រប់អន្លើ គឺមេត្រីរវាងមហាបពិត្រនិងអាត្មាទាំងពីរកុំបីបែកគ្នាឡើយ អាត្មាកាលសម្លឹងឃើញប្រយោជន៍នេះ ទើបមិនសូមអ្វីនឹងមហាបពិត្រ ។

លំដាប់នោះ ព្រះរាជាកាលស្តាប់ពាក្យនោះហើយ ទើបត្រាស់គាថា ៣ ថា

សមណព្រាហ្មណ៍ណារស់ដោយការសូម តែមិនសូមវត្ថុ ដែលខ្លួនត្រូវសូម ក្នុងកាលគួរ ( សមណព្រាហ្មណ៍នោះ ) ឈ្មោះថា ញុំាងបុគ្គលដទៃឲ្យខូចបុណ្យផង ឈ្មោះថា មិនបាន រស់ស្រួលដោយខ្លួនឯងផង ។

សមណព្រាហ្មណ៍ណា រស់ដោយការសូម ហើយសូមនូវ វត្ថុដែលខ្លួនត្រូវការ សូមក្នុងកាលគួរ ( សមណព្រាហ្មណ៍ នោះ ) ឈ្មោះថា ញុំាងបុគ្គលដទៃឲ្យបានបុណ្យផង ឈ្មោះ ថារស់នៅស្រួលដោយខ្លួនឯងផង ។

បុគ្គលមានប្រាជ្ញាទាំងឡាយ ឃើញពួកស្មូមមកដល់ហើយ មិនដែលប្រទូស្ត លោកជាព្រហ្មចារីបុគ្គល ជាទីស្រឡាញ់ នៃខ្ញុំ លោកប្រាថ្នារបស់ណាដែលត្រូវនិយាយសូម លោកចូរ សូមចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាចនជីវានោ** បានដល់ អ្នកមានជីវិត ដោយការសូម ។ ម្យ៉ាងទៀត បាឋៈថា **យាចនជីវមានោ** នេះក៏មានន័យ ដូចគ្នា ។ មានពាក្យអធិប្បាយថា បពិត្រលោកម្ចាស់អដ្ឋិសេន បុគ្គលណា ប្រព្រឹត្តតាំងជីវិតនៅដោយការសូម ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី មិន សូមវត្ថុណាមួយដែលគួរសូមក្នុងពេលដែលសមគួរ បុគ្គលនោះរមែងកម្ចាត់

អ្នកដទៃដែលជាអ្នកឲ្យ គឺធ្វើបុគ្គលនោះឲ្យវិនាសទៅចាកបុណ្យផង ទាំងខ្លួនឯងក៏មានជីវិតរស់នៅមិនសុខផង ។ បទថា **បុញ្ញំ លភេតិ** សេចក្ដីថា តែកាលសូមវត្ថុដែលគួរសូម ក្នុងពេលដែលគួរសូម ធ្វើអ្នកដទៃឲ្យបានបុណ្យផង ខ្លួនឯងក៏មានជីវិតរស់នៅជាសុខផង ។ បទថា **ន វេ ទុស្សន្តិ** ព្រះរាជាសម្ដែងថា លោកម្ចាស់ពោលពាក្យណាថា សូមការអាក់អន់ចិត្តកុំបីមានដល់អាត្មាភាពឡើយ ហេតុអ្វីទើបលោកម្ចាស់ពោលពាក្យនោះ ព្រោះថា បុគ្គលមានប្រាជ្ញាទាំងឡាយ គឺពួកបណ្ឌិតអ្នកដឹងទាំងទាននិងផលនៃទាន ឃើញយាចកមកហើយមិនចង្អៀតចង្អល់ មិនក្រោធ តែជាអ្នកត្រេកអរដោយពិត ។ **ម** អក្ខរៈ ក្នុងពាក្យថា **យាចកមាគតេ** លោកពោលទុកដោយអំណាចព្យញ្ជនៈសន្ធិ មានអត្ថថា **យាចកេ អាគតេ** យាចកមកហើយ ។ បទថា **ព្រហ្មចារី បិយោ មេសិ** សេចក្ដីថា បពិត្រលោកម្ចាស់អដ្ឋិសេន អ្នកប្រព្រឹត្តបរិសុទ្ធិ ដែលមានបញ្ញាច្រើន លោកម្ចាស់ ជាទីស្រឡាញ់របស់ខ្ញុំពន់ពេក ព្រោះហេតុនោះ សូមលោកម្ចាស់ប្រាប់ គឺសូមពរនិងខ្ញុំនោះឯង ។ បទថា **ភញ្ញិតមិច្ឆសិ** សេចក្ដីថា លោកម្ចាស់ប្រាថ្នាវត្ថុណាមួយដែលគួរពោលសូមខ្ញុំនឹងប្រគេនគ្រប់យ៉ាងនោះឯង សូម្បីតែរាជសម្បត្តិ ។

ព្រះរាជាទ្រង់បវារណាដោយរាជសម្បត្តិយ៉ាងនេះ ព្រះពោធិសត្វ ក៏មិនសូមរបស់ណាឡើយ ។

កាលព្រះរាជា ត្រាស់សួរដល់អធ្យាស្រ័យរបស់ខ្លួនយ៉ាងនេះហើយ ឯព្រះមហាសត្វដើម្បីសម្ដែងដល់បដិបទារបស់អ្នកបួសថ្វាយ ក៏សម្ដែងថា សូម

ថ្វាយព្រះពរមហាបពិត្រ ឈ្មោះថា ការសូមនេះ ជារបស់ដែលពួកគ្រហស្ថ បរិភោគកាមប្រព្រឹត្តថ្មីកមកហើយ មិនមែនពួកបព្វជិត ឯបព្វជិត តាំងអំពីពេលបួសហើយ គួរជាអ្នកមានអាជីវៈបរិសុទ្ធ ដោយសង្រួមក្នុងទ្វារទាំង ៣ កាលសំដែងដល់បដិបទារបស់បព្វជិត ទើបពោលគាថាទី ៦ ថា

បុគ្គលមានប្រាជ្ញាទាំងឡាយ មិនដែលសូមទេ ស្រេចតែនឹង ( ឧបដ្ឋាក ) អ្នកមានប្រាជ្ញា គួរដឹង ( ខ្លួនឯងចុះ ) ពួកអរិយៈគ្រាន់តែឈរឧទ្ទិសស្ងៀម ៗ ប៉ុណ្ណោះ ទុំះជាការសូមរបស់ពួកអរិយៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សប្បញ្ញា** ជាដើម សេចក្ដីថា ព្រះពុទ្ធទាំងឡាយក្ដី ពុទ្ធសាវកទាំងឡាយក្ដី ព្រះពោធិសត្វទាំងឡាយដែលបួសជាឥសីបដិបត្តិដើម្បីពោធិញ្ញាណក្ដី ទាំងអស់ ឈ្មោះថា ជាអ្នកមានបញ្ញាផង ជាអ្នកមានសីលផង លោកទាំងនោះ ជាអ្នកមានបញ្ញាបែបនេះ នឹងមិនសូមថា ចូរអ្នកទាំងឡាយឲ្យនូវវត្ថុនេះនិងវត្ថុនេះដល់អាត្មាទាំងឡាយ ។ បទថា **ធីរោ វេទិតុមរហតិ** សេចក្ដីថា ឯធីរជន គឺបណ្ឌិត អ្នកឧបដ្ឋាក គួរដឹង គឺជ្រាបសេចក្ដីត្រូវការគ្រប់យ៉ាងរបស់លោកដោយខ្លួនឯង ទាំងក្នុងពេលអាពាធ និងក្នុងពេលមិនអាពាធ ។ បទថា **ឧទ្ទិស្ស អរិយា តិដ្ឋន្តិ** សេចក្ដីថា ចំណែកព្រះអរិយៈទាំងឡាយ មានសេចក្ដីត្រូវការវត្ថុណា មិនបន្លឺវាចាសូម គ្រាន់តែឈរចំពោះក្នុងទីនោះ ដោយកិរិយាបវត្តតែម្យ៉ាងប៉ុណ្ណោះ មិនឲ្យអង្គ គឺកាយនិងអង្គ គឺវាចាកម្រើក ព្រោះថា កាលសំដែងកាយវិការធ្វើនូវគ្រឿងសម្គាល់

ឲ្យដឹង ក៏ឈ្មោះថាឲ្យអង្គគឺកាយកម្រើក កាលធ្វើនូវការបន្ទឹវាចាក៏ឈ្មោះថា ឲ្យអង្គគឺវាចាកម្រើក ព្រះអរិយៈទាំងឡាយមានព្រះពុទ្ធជាដើម មិនធ្វើទាំង ២ យ៉ាងនោះ ឈរព្រងើយៗ ។ បទថា **ឯសា អរិយាន យាចនា** សេចក្ដីថា ការមិនឲ្យអង្គគឺវាចាកម្រើក ឈរដើម្បីភិក្ខានេះឈ្មោះថា ជាការសូមរបស់ព្រះអរិយៈទាំងឡាយ ។

ព្រះរាជា ទ្រង់ស្ដាប់ពាក្យ របស់ព្រះពោធិសត្វហើយ កាលត្រាស់ថា បពិត្រលោកម្ចាស់ បើឧបដ្ឋាកអ្នកមានបញ្ញាដឹងដោយខ្លួនឯងហើយសោត ក៏នឹងឲ្យវត្ថុដែលគួរឲ្យដល់កុលបុត្ត ឯខ្ញុំក៏នឹងប្រគេនវត្ថុនេះនិងវត្ថុនេះដល់លោកម្ចាស់ទាំងឡាយ ដូច្នេះ ទើបត្រាស់គាថាទី ៧ ថា

> បពិត្រព្រាហ្មណ៍ ខ្ញុំសូមប្រគេនមេគោមានសម្បុរក្រហម ១ ពាន់ ព្រមទាំងគោឈ្មោលដល់លោកម្ចាស់ ដ្បិតថាបុគ្គលមានមារយាទដ៏ប្រសើរបានស្ដាប់គាថារបស់លោកដែលប្រកបដោយធម៌ហើយ មិនឲ្យដល់បុគ្គលមានអាចារៈដ៏ប្រសើរ ( ដូចគ្នា ) ដូចម្ដេចបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រោហិណីនំ** សេចក្ដីថា មានពណ៌ក្រហម ។ បទថា **គវំ សហស្សំ** សេចក្ដីថា ខ្ញុំនឹងប្រគេនគោប្រភេទនេះ ១០០០ ដល់លោកម្ចាស់ ដើម្បីជាប្រយោជន៍ដល់ការផឹករសទឹកដោះស្រស់និងទឹកដោះជូរជាដើម សូមលោកម្ចាស់ទទួលគោនោះរបស់ខ្ញុំ ។ បទថា **អរិយោ** បានដល់ដែលមានមារយាទប្រសើរ ។ បទថា **អរិយស្ស** សេចក្ដីថា ដល់លោកម្ចាស់

ដែលមានមារយាទប្រសើរ ។ បទថា **កច្ចំ ន ទជ្ជា** សេចក្តីថា ហេតុអ្វីទើប មិនប្រគេន ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ព្រះពោធិសត្វ ក៏ទូលបដិសេធថា មហាបពិត្រ ធម្មតាបព្វជិតមិនមានសេចក្តីកង្វល់ណាមួយ អាត្មាមិនមានសេចក្តីត្រូវការដោយមេគោទាំងឡាយឡើយ ។ ព្រះរាជាតាំងនៅហើយក្នុងឱវាទរបស់ព្រះពោធិសត្វនោះ ទ្រង់បំពេញកុសលមានទានជាដើម ជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ឯព្រះពោធិសត្វមានឈានមិនវិនាស កើតឡើងហើយក្នុងព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ មហាជនសម្រេចសោតាបត្តិផលជាដើម ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកអដ្ឋិសេនឥសីក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា អដ្ឋិសេនជាតក ចប់

# កបិជាតក

[ ៣២៧ ] ( ពានរពោធិសត្វពោលថា ) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា បណ្ឌិតមិនគប្បីនៅក្នុងទីនោះទេ ( ព្រោះ ) នៅក្នុងពួកបុគ្គលមានពៀរ មួយយប់ក្តីពីរយប់ក្តីជាទុក្ខ ។

[ ៣២៨ ] បុគ្គលអ្នកមានចិត្តស្រាល គប្បីជាសត្រូវដល់សត្វអ្នកប្រព្រឹត្តតាម សេចក្តីមិនចម្រើនដែលព្រាហ្មណ៍ធ្វើហើយដល់ហ្វូងស្វា ព្រោះហេតុតែស្វាមួយ ។

[ ៣២៩ ] បុគ្គលល្ងង់តែប្រកាន់ខ្លួនឯងថាជាបណ្ឌិត ហើយរក្សាពួកក្រុមជាអ្នកលុះអំណាចចិត្តរបស់ខ្លួន រមែងដេក ( ស្លាប់ ) ដូចស្វានេះឯង ។

[ ៣៣០ ] បុគ្គលល្ងង់មានកម្លាំងជាអ្នករក្សាពួកក្រុមមិនប្រពៃទេ មិនមានសេចក្តីចម្រើនដល់ពួកញាតិ ដូចទទាធ្នាក់មិនជាប្រយោជន៍ដល់ពួកសត្វស្លាប ( ដែលជាញាតិ ) ។

[ ៣៣១ ] ឯបុគ្គលមានប្រាជ្ញា មានកម្លាំងរក្សាពួកក្រុមវិញទើបប្រពៃ រមែងចម្រើនដល់ពួកញាតិ ដូចជាវាសវៈទេវរាជ ( ជាប្រយោជន៍ ) ដល់ពួកទេវតាក្នុងឋានត្រៃត្រិង្ស ។

[ ៣៣២ ] បុគ្គលណាមួយឃើញថា ខ្លួនឯងមានសីលផង មានបញ្ញាផង មានសុតៈផង ( បុគ្គលនោះ ) តែងប្រព្រឹត្តប្រយោជន៍ដើម្បីខ្លួននិងអ្នកដទៃទាំងពីរ ។ ព្រោះហេតុនោះអ្នកប្រាជ្ញកាលបើគ្នេរគ្នាន់មើលខ្លួនមានសីល មានបញ្ញានិងសុតៈហើយ គប្បីថែរក្សាពួកក្រុមក៏បាន គប្បីប្រព្រឹត្តនៅតែម្នាក់ឯងក៏បាន ។

**ចប់ កបិជាតកទី ៩ ។**

# អដ្ឋកថា

## កបិជាតក

[ ៣២៧-៣៣២ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធរឿងផែនដីស្រូបទេវទត្តហើយ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **យត្ថ វេរី និវសតិ** ដូច្នេះជាដើម ។

មានរឿងពោលដោយសង្ខេបថា កាលទេវទត្តចូលទៅកាន់ផែនដីហើយ ភិក្ខុទាំងឡាយ តាំងរឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា ទេវទត្តវិនាសហើយមួយអន្លើដោយបរិស័ទ ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្ត មួយអន្លើដោយបរិស័ទ មិនមែនវិនាសតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏វិនាសដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតស្វា មានស្វា ៥០០ ជាបរិវារ អាស្រ័យនៅត្រង់ព្រះរាជឧទ្យាន ។ ឯទេវទត្តកើតក្នុងកំណើតស្វា មានស្វា ៥០០ ជាបរិវារ អាស្រ័យនៅក្នុងព្រះរាជឧទ្យានដូចគ្នា ។ ថ្ងៃមួយ កាលបុរោហិតទៅកាន់ឧទ្យាន ងូតទឹកតែងខ្លួនហើយចេញទៅ ស្វាឡេះឡោះមួយ ដើរទៅមុនអង្គុយលើសសរខ្លោងទ្វារឧទ្យាន បន្ទោបង់ឧច្ចារៈដាក់ក្បាលបុរោហិត កាលបុរោហិតសម្លឹងមើលខាងលើ ក៏បន្ទោបង់ដាក់មុខទៀត ។ បុរោហិតបែរមក

សម្មុតពួកស្វាថា ផ្ញើទុកសិនចុះ អញនឹងសងពួកឯង ក្នុងកាលខាងក្រោយ ហើយផ្ទួតទឹកជាថ្មីចៀសចេញទៅ ។ ពួកស្វាបានប្រាប់ព្រះពោធិសត្វដល់ការដែលបុរោហិតនោះចងពៀរហើយគំរាមពួកស្វា ។ ព្រះពោធិសត្វបានប្រាប់ឲ្យស្វាទាំងមួយពាន់ដឹងថា ឈ្មោះថាការនៅក្នុងលំនៅរបស់អ្នកមានពៀរមិនគួរហ្វូងស្វាទាំងអស់ ចូរនាំគ្នាគេចទៅទីដទៃចុះ ឯស្វាប្រដៅក្រ នាំស្វាដែលជាបរិវាររបស់ខ្លួនទៅ មិនគេចចេញដោយគិតថា ខាងក្រោយអញនឹងដឹងឯងទើបទៅ ។ ព្រះពោធិសត្វនាំបរិវាររបស់ខ្លួនចូលទៅកាន់ព្រៃ ។ ថ្ងៃមួយពាំងមួយស៊ីស្រូវដែលទាសីម្នាក់ហាលទុក ត្រូវគេវៃដោយអង្កត់ឧសដែលមានភ្លើង ឆេះត្រង់ខ្លួន រត់គេចទៅត្រដុសខ្លួនត្រង់ខ្ទមស្បូវមួយ ក្បែររោងដំរី ភ្លើងនោះឆេះខ្ទមស្មៅ រាលពីខ្ទមស្មៅ ឆេះរោងដំរីទៀត ។ កាលរោងដំរីឆេះ ខ្នងដំរីក៏រលាក គ្រូពេទ្យព្យាបាលដំរី ក៏រក្សាព្យាបាលដំរី ចំណែកបុរោហិតកំពុងពិចារណារកឧបាយចាប់ពានរ កាលព្រះរាជាត្រាស់សួរបុរោហិត ដែលមកគាល់ថា លោកអាចារ្យដំរីរបស់យើង មានដំបៅជាច្រើន គ្រូពេទ្យមិនចេះព្យាបាល អាចារ្យដឹងថ្នាំអ្វីខ្លះដែរឬ បុរោហិតទូលថា បពិត្រមហារាជ ទូលព្រះបង្គំដឹង ព្រះរាជាត្រាស់ថា តើជាអ្វី បុរោហិតក្រាបទូលថា បពិត្រមហារាជថ្នាំនោះគឺខ្លាញ់ស្វា ព្រះរាជាត្រាស់ថា តើយើងនឹងបានក្នុងទីណា បុរោហិតក្រាបទូលថា ត្រង់ព្រះរាជឧទ្យាន មានពានរច្រើនមិនមែនឬ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយចូរសម្លាប់ពានរត្រង់ព្រះរាជឧទ្យាន នាំយកខ្លាញ់មក ។ ខ្មាន់ធ្នូនាំគ្នាទៅបាញ់ស្វាទាំង ៥០០ ឲ្យស្លាប់អស់ សល់តែពានរជាប្រធាន

មួយ គេចទៅបានទាំងជាប់ព្រួញ លុះទៅដល់លំនៅរបស់ព្រះពោធិសត្វហើយ ទើបដួលស្លាប់ ។ ពួកពានរប្រាប់ព្រះពោធិសត្វដល់ស្វានោះ ដែលត្រូវបាញ់ដោយព្រួញថា ប្រធានពានរមកដល់លំនៅរបស់ពួកយើង ហើយក៏ស្លាប់ ។ ព្រះពោធិសត្វ មកអង្គុយត្រង់កណ្តាលហ្វូងពានរពោលថា ធម្មតាអ្នកមិនជឿឱវាទនៃបណ្ឌិតទាំងឡាយ នៅក្នុងលំនៅរបស់អ្នកមានពៀរនឹងវិនាសយ៉ាងនេះ ហើយបានពោលគាថាទាំងនេះដាស់តឿនហ្វូងស្វាថា

បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា បណ្ឌិតមិនគប្បីនៅក្នុងទីនោះទេ ( ព្រោះ ) នៅក្នុងពួកបុគ្គលមានពៀរមួយយប់ក្តី ពីរយប់ក្តីជាទុក្ខ ។

បុគ្គលអ្នកមានចិត្តស្រាល គប្បីជាសត្រូវដល់សត្វអ្នកប្រព្រឹត្តតាម សេចក្តីមិនចម្រើនដែលព្រាហ្មណ៍ធ្វើហើយដល់ហ្វូងស្វា ព្រោះហេតុតែស្វាមួយ ។

បុគ្គលល្ងង់ តែប្រកាន់ខ្លួនឯងថាជាបណ្ឌិត ហើយរក្សាពួកក្រុម ជាអ្នកលុះអំណាចចិត្តរបស់ខ្លួន រមែងដេក ( ស្លាប់ ) ដូចស្វានេះឯង ។

បុគ្គលល្ងង់មានកម្លាំង ជាអ្នករក្សាពួកក្រុមមិនប្រពៃទេ មិនមានសេចក្តីចម្រើនដល់ពួកញាតិ ដូចទទាធ្លាក់មិនជាប្រយោជន៍ដល់ពួកសត្វស្លាប ( ដែលជាញាតិ ) ។

ឯបុគ្គលមានប្រាជ្ញា មានកម្លាំងរក្សាពួកក្រុមវិញ ទើបប្រពៃ

រមែងចម្រើនដល់ពួកញាតិ ដូចជាវាសវៈទេវរាជ ( ជាប្រយោជន៍ ) ដល់ពួកទេវតាក្នុងឋានត្រៃត្រិង្ស ។

បុគ្គលណាមួយឃើញថា ខ្លួនឯងមានសីលផង មានបញ្ញាផង មានសុតៈផង ( បុគ្គលនោះ ) តែងប្រព្រឹត្តប្រយោជន៍ដើម្បីខ្លួននឹងអ្នកដទៃទាំងពីរ ។ ព្រោះហេតុនោះអ្នកប្រាជ្ញកាលបើគ្រវគ្រាន់មើលខ្លួនមានសីល មានបញ្ញានិងសុតៈហើយគប្បីថែរក្សាពួកក្រុមក៏បាន គប្បីប្រព្រឹត្តនៅតែម្នាក់ឯងក៏បានដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លហុចិត្តស្ស** កាត់បទថា **លហុចិត្តោ អស្ស** សេចក្តីថា គប្បីជាអ្នកមានចិត្តស្រាល មានពាក្យអធិប្បាយថា បុគ្គលណាបណ្តោយតាមគឺអនុវត្តតាមមិត្តឬញាតិដែលមានចិត្តស្រាល ព្រោះអនុលោមតាមបុគ្គលនោះ បុគ្គលនោះក៏នឹងជាប្រធានចិត្តស្រាល ធ្វើកិច្ចនៃបុគ្គលមានពៀរ ។ បទថា **ឯកស្ស កបិនោ** សេចក្តីថា អ្នកទាំងឡាយ ចូរមើលចុះព្រោះស្វាចិត្តស្រាល គឺស្វាអន្ធពាលមួយ ដែលជាមេហ្វូងវិរូស បានធ្វើនូវសេចក្តីលំបាក គឺការមិនចម្រើន បានដល់នូវសេចក្តីវិនាសធំកន្លង ដល់ស្វាទាំងហ្វូង ។ បទថា **បណ្ឌិតមានី** មានអត្ថថា បុគ្គល ណាដឹងខ្លួនឯងជាអ្នកល្ងង់តែសម្គាល់ថា យើងជាអ្នកឈ្លាស មិនធ្វើតាមឱវាទលោកអ្នកឈ្លាសធ្លាក់ក្នុងអំណាចការគិតរបស់ខ្លួន បុគ្គលនោះនឹងលុះក្នុងអំណាចការគិតរបស់ខ្លួនហើយ គង់ដេកស្លាប់ដូចស្វាចេសនេះឯង ។ បទថា **ន សាធុ** សេចក្តីថា ធម្មតាបុគ្គលល្ងង់ តែមានកម្លាំងព្រម បរិហារពួកគណៈ រមែងមិនល្អ

គឺមិនផុតភ័យ ព្រោះហេតុអ្វី ព្រោះបុគ្គលនោះ មិនមានប្រយោជន៍សម្រាប់ពួកញាតិ គឺនាំសេចក្តីវិនាសមកឲ្យតែម្យ៉ាង ។ បទថា **សកុណឃាតំវ ចេតកោ** សេចក្តីថា ឧបមាដូចបណ្តាសត្វទទាទាំងឡាយ សត្វទទាធ្លាក់រងាវអស់មួយថ្ងៃ ក៏មិនធ្វើឲ្យសត្វប្រភេទដទៃស្លាប់ ធ្វើពួកញាតិនៃខ្លួនប៉ុណ្ណោះឲ្យស្លាប់យ៉ាងណា បុគ្គលល្ងង់ ក៏មិនមានប្រយោជន៍ដល់ពួកគណៈទាំងនោះឡើយ ក៏យ៉ាងនោះ ។ បទថា **ហិតោ ភវតិ** សេចក្តីថា ធីរជនជាអ្នកធ្វើប្រយោជន៍ដល់ពួកញាតិនោះឯង ដោយកាយខ្លះ ដោយវាចាខ្លះ ដោយចិត្តខ្លះ ។ បទថា **ឧភិន្នមត្ថំ ចរតិ** សេចក្តីថា បុគ្គលក្នុងលោកនេះ ជាអ្នកមើលឃើញគុណទាំងនោះ មានសីលជាដើមក្នុងខ្លួន ដឹងថាអាចារនិងសីលរបស់អញក៏មាន បញ្ញាក៏មាន សុតៈក៏មាន ជ្រាបតាមសេចក្តីពិតហើយ បរិហារពួកគណៈឈ្មោះថា ប្រព្រឹត្តប្រយោជន៍តែម្យ៉ាងដល់ជនទាំង ២ ចំណែក គឺដល់ខ្លួនផង ដល់អ្នកដទៃផង បានដល់ ពួកញាតិដែលចោមរោមខ្លួន ។ បទថា **តុលេយ្យមត្តានំ** កាត់បទជា **តុលេយ្យ អត្តានំ** គឺថ្លឹងមើលនូវចិត្តខ្លួនឯងហើយ ។ បទថា **តុលេយ្យ** កែជា **តុលេត្វា** ។ បទថា **សីលំ បញ្ញំ សុតំបិវ** សេចក្តីថា ដូចថ្លឹងចិត្តមើលសីលជាដើមទាំងនោះ ។ មានពាក្យអធិប្បាយថា ព្រោះធីរជនពិចារណាមើលគុណទាំងឡាយ មានសីលជាដើមក្នុងខ្លួន ឈ្មោះថា ប្រព្រឹត្តប្រយោជន៍ដល់ជនទាំង ២ ចំណែក ដូច្នោះ ធីរជនគួរថ្លឹងមើលចិត្តខ្លួនឯង ដូចបណ្ឌិតថ្លឹងមើលគុណ មានសីលជាដើមនោះ គឺពិចារណាមើលថា អញតាំងនៅក្នុងសីល ក្នុងបញ្ញា ក្នុងសុតៈហើយឬ ធ្វើនូវការយល់ឲ្យជាក់

ច្បាស់ថា ខ្លួនតាំងនៅក្នុងគុណទាំងនោះដែរឬទេ សឹមថែរក្សាពួកគណៈខ្លះ មិនពួនសម្ងំ គឺត្រាច់ទៅតែម្នាក់ឯងក្នុងឥរិយាបថ ៤ ខ្លះ ព្រោះថាបុគ្គលឲ្យបរិស័ទបម្រើក្តី ប្រព្រឹត្តវិវេកក្តី គួរប្រកបដោយគុណ ៣ យ៉ាងនេះឯង ។

ព្រះមហាសត្វ គឺស្តេចពានរប្រាប់កិច្ចទាក់ទងនឹងវិន័យ និងសុតៈដូច្នេះ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ស្វាប្រជៅក្រក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកបរិវាររបស់ស្វាប្រជៅក្រក្នុងកាលនោះ បានមកជាបរិវាររបស់ទេវទត្ត ឯស្តេចស្វាអ្នកឈ្លាសក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កបិជាតក ចប់

## ពកព្រហ្មជាតក

[ ៣៣៣ ] ( ពកព្រហ្មពោលថា ) បពិត្រព្រះគោតម ពួកយើង ៧២ រូប មានអំពើជាបុណ្យ ជាអ្នកមានអំណាចប្រព្រឹត្តទៅកន្លង ផុតជាតិនិងជរាបាន នេះជាការដល់នូវវេទ ជាកំណើតដ៏ប្រសើរ មានក្នុងទីបំផុត ( របស់ពួកយើង ) ពួកជនច្រើនរូបតែងប្រាថ្នាទីនេះ ។

[ ៣៣៤ ] ( ព្រះសាស្តាត្រាស់ថា ) នៃពកៈ អ្នកសម្គាល់ថាអាយុណាជាធម្មជាតវែងអាយុនុ៎ះខ្លីទេ មិនមែនវែងឡើយ ម្នាលព្រហ្ម តថាគតដឹងអាយុរបស់អ្នក មួយសែននិរព្វុទៈ ( ប៉ុណ្ណោះឯង ) ។

[ ៣៣៥ ] ( ពកព្រហ្មពោលថា ) បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះបន្ទូលថា តថាគតជាអ្នកឃើញមិនមានទីបំផុត កន្លងផុតស្រឡះនូវជាតិនិងជរាផង នូវសេចក្តីសោកផង តើវត្តនិងសីលវត្តរបស់ខ្ញុំពីដើមដូចម្តេចខ្លះ សូមព្រះអង្គប្រាប់នូវវត្តនិងសីលវត្តដែលខ្ញុំគួរដឹងនុ៎ះដល់ខ្ញុំ ។

[ ៣៣៦ ] ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ) អ្នកបានញ៉ាំងពួកមនុស្សច្រើនដែលស្រេកទឹក លំបាកដោយកម្តៅថ្ងៃ ឲ្យផឹកហើយ នោះឯងជាវត្តសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

[ ៣៣៧ ] អ្នកបានដោះលែងនូវពួកជនឈ្លើយ ដែលចោរចាប់នាំយកទៅទៀបឆ្នេរនៃស្ទឹងឈ្មោះឯណី នោះឯងជាវត្តសមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគតរលឹកឃើញដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

[ ៣៣៨ ] អ្នកបានគំរាមដោយកម្លាំងហើយដោះលែងនូវទូក ដែលនាគ

រាជអាក្រក់បម្រុងនឹងពន្ទិចចោលក្នុងខ្សែនៃទឹកស្ទឹង ព្រោះវាចង់ធ្វើមនុស្សឲ្យវិនាស នោះឯងជាវត្តសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

[ ៣៣៩ ] តថាគតឈ្មោះកប្បៈ ធ្លាប់ជាកូនសិស្សរបស់អ្នក តថាគតបានសម្គាល់ថាអ្នកជាបុគ្គលមានប្រាជ្ញា មានវត្តប្រតិបត្តិ នោះឯងជាវត្តសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

[ ៣៤០ ] ( ពកព្រហ្មពោលថា ) ព្រះអង្គជ្រាបច្បាស់នូវអាយុរបស់ខ្ញុំនុ៎ះដោយពិតផង ជ្រាបច្បាស់នូវហេតុដទៃផង ព្រះអង្គជាព្រះពុទ្ធមែន នេះជាអានុភាពដ៏រុងរឿងរបស់ព្រះអង្គដែលញ៉ាំងព្រហ្មលោកឲ្យភ្លឺរុងរឿង ។

**ចប់ ពកព្រហ្មជាតកទី ១០ ។**

**ចប់ កុក្កុវគ្គទី ១ ។**

## ឧទ្ទាននៃជាតកក្នុងកុក្កុវគ្គនោះគឺ

និយាយអំពីកំពូលដ៏ប្រសើរ ១ បំពង់ព្រួញដ៏ប្រសើរ ១ សុតនជាតក ១ ត្មាត ១ ត្រីឆ្ពិន ១ ដាវកើតក្នុងស្រុកទសណ្ណកៈ ១ សេនកបណ្ឌិត ១ យាចក ១ បុគ្គលមានពៀរ ១ ពកព្រហ្ម ១ រួមត្រូវជា ១០ ។

# អដ្ឋកថា

## ពកព្រហ្មជាតក

[ ៣៣៣-៣៤០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនទ្រង់ប្រារព្ធពកព្រហ្ម ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ទ្វាសត្តតិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ពកព្រហ្មកើតនូវទិដ្ឋិឡើងយ៉ាងនេះថា វត្ថុនេះទៀង មាំទាំ ស្ថិតស្ថេរ មិនមានចុតិជាធម្មតា បណ្តាវត្ថុដទៃក្រៅអំពីនេះ ដែលឈ្មោះថា ជាព្រះនិព្វាន ជាទីចេញទៅរបស់សត្វលោកមិនមាន ។ បានឮថា ព្រហ្មអង្គនេះកើតក្នុងព្រហ្មលោកជាន់ទាប កាលមុនបំពេញឈាន ហើយបានកើតក្នុងជាន់វេហប្ផលា ។ ព្រហ្មនេះឲ្យអាយុប្រមាណ ៥០០ កប្ប អស់ទៅក្នុងជាន់វេហប្ផលានោះហើយ ទើបកើតក្នុងជាន់សុភកិណ្ហាអស់ ៦៤ កប្ប ចុតិអំពីនោះ មកកើតក្នុងជាន់អាភស្សរា មានអាយុ ៨ កប្ប ក្នុងជាន់អាភស្សរានោះព្រហ្មនោះមានទិដ្ឋិយ៉ាងនេះ ព្រោះរឮកដល់ចុតិអំពីព្រហ្មលោកជាន់ខ្ពស់មិនបាន រឮកដល់ការកើតឡើងក្នុងព្រហ្មលោកជាន់នោះក៏មិនបាន កាលមិនឃើញទាំង ២ យ៉ាង ទើបមានទិដ្ឋិយ៉ាងនេះ ។ ព្រះសាស្តាទ្រង់ជ្រាបការគិតរបស់ពកព្រហ្មនោះ ដោយចេតោបរិយញ្ញាណ ហើយទើបទ្រង់បាត់អំពីវត្តជេតពន ប្រាកដកាយក្នុងព្រហ្មលោក ឧបមាដូចបុរសមានកម្លាំង បត់ដៃហើយលាដៃទៅដូច្នោះ ឬលាដៃហើយបត់ចូលមកដូច្នោះ ។ គ្រានោះ មហាព្រហ្ម ឃើញព្រះសាស្តាហើយ ទើបទូលថា មកសម្លាញ់ អ្នកមកល្អហើយ យូរណាស់ហើយ ទើបអ្នកធ្វើបរិយាយនេះ គឺការមកទីនេះ ព្រោះទីនេះជាកន្លែងទៀង ជាទីដែលមិនមានចុតិជាធម្មតា មិនកើត មិនចាស់ មិនស្លាប់

មិនចុតិមិនបដិសន្ធិ ទីដទៃដែលឈ្មោះថា ជាទីចេញទៅចាកទុក្ខក្រៃលែងជាង ទីនេះមិនមាន ។ កាលពកព្រហ្មទូលយ៉ាងនេះហើយ ព្រះមានព្រះភាគត្រាស់នឹងពកព្រហ្មថា ឱហ្ន៎ ពកព្រហ្មប្រកបដោយអវិជ្ជាហើយ ឱហ្ន៎ ពកព្រហ្មប្រកបដោយអវិជ្ជាហើយ ព្រោះថា គាត់ពោលនូវរបស់ដែលមិនទៀងថាជារបស់ទៀងវិញ ។បេ។ មួយទៀត គាត់ពោលនូវទីដទៃជាគ្រឿងរលាស់ចេញដ៏ក្រៃលែង ថាទីដទៃជាគ្រឿងរលាស់ចេញដ៏ក្រៃលែងមិនមានឡើយ ។ ព្រហ្មបានស្តាប់ពាក្យនោះហើយគិតថា ព្រះមានព្រះភាគអង្គនេះកាលពោលបញ្ជាក់ថា អ្នកពោលយ៉ាងនេះ ឈ្មោះថា រមែងចង់តថាគត ដោយប្រការដូច្នេះ ខ្លាចអនុលោមតាមព្រះមានព្រះភាគ ទំនងដូចគ្នានឹងចោរដែលថមថយកម្លាំង បានទទួលការវាយបន្តិចបន្តួច ក៏ប្រាប់មនុស្សគ្រប់គ្នាថា ខ្ញុំម្នាក់ឯងឬជាចោរ បុគ្គលនោះក៏ជាចោរ បុគ្គលនោះក៏ជាចោរ កាលប្រាប់គ្នីគ្នារបស់ខ្លួនដទៃៗក៏បានពោលគាថាទី ១ ថា

> បពិត្រព្រះគោតម ពួកយើង ៧២ រូប មានអំពើជាបុណ្យ ជាអ្នកមានអំណាចប្រព្រឹត្តទៅ កន្លងផុតជាតិនិងជរាបាន នេះជាការដល់នូវវេទ ជាកំណើតដ៏ប្រសើរ មានក្នុងទីបំផុត ( របស់ពួកយើង ) ពួកជនច្រើនរូបតែងប្រាថ្នាទីនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទ្វាសត្តតិ** សេចក្តីថា បពិត្រព្រះគោតម មិនមែនត្រឹមតែខ្ញុំម្នាក់ប៉ុណ្ណោះទេ ដោយពិត ពួកខ្ញុំ ៧២ រូប ក្នុងព្រហ្មលោកនេះ សុទ្ធតែបានធ្វើបុណ្យមកហើយ ជាអ្នកផ្សាយអំណាចទៅដោយការផ្សាយ

អំណាចរបស់ខ្លួន លើអ្នកដទៃ និងបានកន្លងនូវការកើតនិងការចាស់ហើយ ការកើតក្នុងព្រហ្មនេះ ឈ្មោះថាដល់នូវត្រើយនៃវេទ ព្រោះពួកខ្ញុំដល់ហើយនូវវេទទាំងឡាយ បពិត្រព្រះគោតម ការកើតជាព្រហ្មនេះ ជាការកើតចុងក្រោយ គឺដល់ចំណែកទីបំផុត ជាអ្នកចូលដល់ភាពជាបុគ្គលប្រសើរបំផុត ។ បទថា **អស្មាភិជប្បន្តិ ជនា អនេកា** សេចក្តីថា អ្នកដទៃជាច្រើននាំគ្នាធ្វើអញ្ជលីដល់ពួកខ្ញុំ ពោលពាក្យជាដើមថា នេះឯង គឺព្រះព្រហ្ម ព្រះមហាព្រហ្មដ៏ចម្រើន នមស្ការ គឺប្រាថ្នា បានដល់ ញញឹម អធិប្បាយថា ប្រាថ្នាថា អស្មាប្រហ្ម៌ យើងទាំងឡាយគួរជាបុគ្គលបែបនេះ ។

ព្រះសាស្តា កាលទ្រង់ស្តាប់ពាក្យរបស់ពកព្រហ្មនោះហើយ ទើបត្រាស់គាថាទី ២ ថា

> នៃពកៈ អ្នកសម្គាល់ថា អាយុណាជាធម្មជាតវែង អាយុនុ៎ះ
> ខ្លីទេ មិនមែនវែងឡើយ ម្នាលព្រហ្មតថាគតដឹងអាយុរបស់
> អ្នក មួយសែននិរព្វុទៈ ( ប៉ុណ្ណោះឯង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតំ សហស្សាន និរព្វុទានំ** សេចក្តីថា មួយសែននៃការរាប់ ពោលគឺនិរព្វុទៈ អធិប្បាយថា ដប់ឆ្នាំដប់ដងជាមួយរយ ដប់រយជាមួយពាន់ មួយរយពាន់ជាមួយសែន មួយរយសែនឈ្មោះថាជាមួយកោដិ មួយរយសែនកោដិឈ្មោះថាមួយបកោដិ មួយរយសែនបកោដិឈ្មោះថាជាមួយកោដិបកោដិ មួយរយសែនកោដិបកោដិឈ្មោះថាមួយនហុត មួយរយសែននហុតឈ្មោះថាជាមួយនិន្នហុត ។ អ្នកគណិតសាស្ត្រ ដែលឈ្លាស

អាចរាប់បានត្រឹមប៉ុណ្ណោះ ការរាប់បន្តអំពីនេះទៅ ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយ ។ បណ្ដាការរាប់ទាំងនោះ មួយរយសែននិន្នហុតជាមួយអពុទៈ ម្ភៃអពុទៈជាមួយនិរពុទៈ មួយសែននិរពុទៈឈ្មោះថាមួយអហហៈ ចំនួនប៉ុណ្ណោះជាអាយុរបស់ពកព្រហ្មដែលនៅសល់ក្នុងស្ថាននេះ ។ ព្រះសាស្ដាទ្រង់សំដៅយកអាយុនោះទើបត្រាស់យ៉ាងនេះ ។

ព្រហ្មបានស្ដាប់ពុទ្ធវចនៈនេះហើយ ទើបពោលគាថាទី ៣ ថា

បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះបន្ទូលថា តថាគតជាអ្នកឃើញមិនមានទីបំផុត កន្លងផុតស្រឡះនូវជាតិនិងជរាផងនូវសេចក្ដីសោកផង តើវត្តនិងសីលវត្តរបស់ខ្ញុំពីដើមដូចម្ដេចខ្លះ សូមព្រះអង្គប្រាប់នូវវត្តនិងសីលវត្តដែលខ្ញុំគួរដឹងនុ៎ះដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភគវា** សេចក្ដីថា បពិត្រព្រះមានព្រះភាគ កាលទ្រង់ត្រាស់ថា តថាគតដឹងអាយុរបស់អ្នកឈ្មោះថារមែងត្រាស់ថា តថាគតឃើញ មិនមានទីបំផុត ឈានកន្លងនូវជាតិ ជរា មរណៈនិងសេចក្ដីសោកបានហើយ ។ បទថា **វតសីលវត្តំ** បានដល់ ការសមាទានវត្ត ទាំងសីលវត្ត មានពាក្យអធិប្បាយទុកថា បើព្រះអង្គជាសព្វញ្ញុពុទ្ធសោត កាលបើដូច្នោះ អ្វីគឺវត្ត សីល និងបុរាណចរណៈរបស់ខ្ញុំ ខ្ញុំគួរដឹងវត្ត សីល និងចរណៈណាដែលទ្រង់ត្រាស់ប្រាប់ហើយតាមសេចក្ដីពិត សូមទ្រង់ត្រាស់ប្រាប់សេចក្ដីនោះដល់ខ្ញុំ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់នាំអតីតទាំងឡាយមកត្រាស់ប្រាប់ដល់ពកព្រហ្ម ទើបត្រាស់គាថា ៤ ថា

អ្នកបានញ៉ាំងពួកមនុស្សច្រើន ដែលស្រេកទឹក លំបាក ដោយកម្ដៅថ្ងៃឲ្យផឹកហើយ នោះឯងជាវត្តសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

អ្នកបានដោះលែងនូវពួកជនឈ្លើយដែលចោរចាប់ នាំយកទៅ ទៀបឆ្នេរនៃស្ទឹងឈ្មោះឯណី នោះឯងជាវត្តសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

អ្នកបានគំរាមដោយកម្លាំង ហើយដោះលែងនូវទូក ដែលនាគរាជអាក្រក់បម្រុងនឹងពន្លិចចោលក្នុងខ្សែនៃទឹកស្ទឹង ព្រោះវាចង់ធ្វើមនុស្សឲ្យវិនាស នោះឯងជាវត្តសមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

តថាគតឈ្មោះកប្បៈ ធ្លាប់ជាកូនសិស្សរបស់អ្នក តថាគតបានសម្គាល់ថា អ្នកជាបុគ្គលមានប្រាជ្ញា មានវត្តប្រតិបត្តិនោះឯងជាវត្តសមាទាននិងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបាយេសិ** សេចក្តីថា ឲ្យផឹកហើយ ។ បទថា **ឃម្មនិសប្បរេត** សេចក្តីថា បុគ្គលខ្វះស្វាប់ព្រោះក្តៅ គឺលំបាកព្រោះកម្តៅដែលក្តៅពន់ពេក ។ បទថា **សុត្តប្បត្តុទ្វោរ** សេចក្តីថា រឮកដល់វត្តជាដើមបានដូចដេកលក់ក្នុងពេលជិតភ្លឺ យល់សប្តិឃើញហើយភ្ញាក់ឡើងរឮកដល់យល់សប្តិនោះបានដូច្នោះ ។

បានឮថា ពកព្រហ្មនោះ ក្នុងកប្បមួយ កើតជាតាបស នៅត្រង់សមុទ្ទខ្សាច់ ដែលមិនមានទឹក បាននាំទឹកមកឲ្យមនុស្សជាច្រើន ដែលដើរតាមផ្លូវកន្តារ ។ ថ្ងៃមួយ ឈ្មួញមួយពួកធ្វើដំណើរទៅដល់សមុទ្ទខ្សាច់ ដែលមិនមានទឹក ដោយរទេះ ៥០០ មនុស្សទាំងឡាយ មិនអាចកំណត់ទិសបាន ធ្វើដំណើរទៅអស់ ៧ ថ្ងៃ អស់ឧសនិងទឹក អស់អាហារ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ គិតថា ឥឡូវនេះ ពួកយើងមិនមានជីវិតឡើយ នាំគ្នាតម្រៀបរទេះជាវង្វង់ហើយក៏ដោះគោ នាំគ្នាដេកក្រោមរទេះរៀង ៗ ខ្លួន កាលនោះតាបសប្រមើលមើល ឃើញឈ្មួញទាំងនោះហើយគិតថា ដរាបណាអញនៅឃើញ មនុស្សទាំងនោះកុំបីវិនាសឡើយ ទើបអធិដ្ឋានឲ្យក្រសែទឹកកើតឡើងគឺហូរទៅចំពោះមុខឈ្មួញ ដោយអានុភាពឫទ្ធិរបស់ខ្លួន និងបាននិម្មិតដងព្រៃមួយកន្លែងទុកក្នុងទីមិនឆ្ងាយ ពួកមនុស្សបានផឹកទឹកនិងងូតទឹក ឲ្យគោទាំងឡាយឆ្អែតស្កប់ស្កល់ហើយ នាំគ្នាទៅប្រូតស្មៅ កាប់ឧសអំពីដងព្រៃ កំណត់ទិសបានហើយ ឆ្លងផ្លូវកន្តារទៅដោយសុវត្ថិភាព ។ ព្រះមានព្រះភាគត្រាស់ពាក្យថា **យំ តុំ ។បេ។ អនុស្សរាមិ** នោះ ទ្រង់សំដៅយកតាបសនោះ ។

បទថា **ឯណិកូលស្មឹ** សេចក្តីថា ក្បែរច្រាំងស្ទឹងឈ្មោះឯណិ ។ បទថា **គយ្ហក និយ្យមានំ** សេចក្តីថា ដែលកំពុងត្រូវចាប់ជាឈ្លើយនាំមក ។

បានឮថា តាបសនោះ ក្នុងកាលក្រោយមក បានទៅអាស្រ័យនៅត្រង់ស្រុកជាយដែនមួយ សម្រាកក្នុងដងព្រៃមួយកន្លែងក្បែរឆ្នេរស្ទឹង ។ ថ្ងៃមួយពួកចោរចូលមកប្លន់ស្រុកនោះ ចាប់យកមនុស្សជាច្រើន ធ្លោះទៅកាន់ភ្នំ ដាក់អ្នកស៊ីបការក្នុងចន្លោះៗផ្លូវ ចូលទៅកាន់ញកភ្នំហើយ ឲ្យអង្គុយចម្អិនអាហារ តាបសបានឮសំឡេងយំរបស់សត្វ មានគោនិងក្របីជាដើម និងរបស់មនុស្សទាំងឡាយ មានកុមារ កុមារីជាដើម គិតថាកាលអញនៅឃើញ ចូរជនទាំងឡាយកុំបីវិនាសឡើយ ហើយទើបបាត់អត្តភាពឥសី ក្លាយជាព្រះរាជា ចោមរោមដោយចតុរង្គិនីសេនា វាយស្គរទ័ពចេញទៅក្នុងទីនោះ ។ ពួកអ្នកស៊ីបការឃើញតាបសនោះហើយ ទើបប្រាប់ដល់ពួកចោរៗគិតថា ឈ្មោះថា ការតតាំងជាមួយព្រះរាជាមិនសមគួរឡើយ ហើយនាំគ្នាបោះបង់ឈ្លើយ មិនបានបរិ-ភោគអាហាររត់ទៅ តាបសនាំមនុស្សទាំងនោះត្រឡប់ទៅផ្ទះរបស់ខ្លួនគ្រប់គ្នា ព្រះមានព្រះភាគត្រាស់ពាក្យថា **យំ ឯណិកូលស្មឹ ។បេ។ អនុស្សរាមិ** នោះទុក ទ្រង់សំដៅយកសេចក្តីនោះ ។ បទថា **គហិតង្គាវំ** បានដល់ ទូកដែលសណ្តាំងគ្នា ។ បទថា **លុទ្ទេន** សេចក្តីថា ជាសត្វគ្រោតគ្រាត ។ បទថា **មនុស្សកប្បា** សេចក្តីថា ព្រោះត្រូវការឲ្យពួកមនុស្សវិនាស ។ បទថា **ពលសា** សេចក្តីថា ដោយកម្លាំង ។ បទថា **បសយ្ហ** សេចក្តីថា សង្កត់សង្កិន ។

ក្នុងកាលតមក តាបសស្នាក់នៅក្បែរឆ្នេរស្ទឹងគង្គា កាលនោះ មនុស្ស ទាំងឡាយនាំគ្នាចងទូក ២-៣ ជាប់គ្នា ហើយធ្វើមណ្ឌបផ្កាទុកអំពីខាងលើទូក នោះ អង្គុយផឹកស៊ីក្នុងទូក បេញដំណើរទៅកាន់ឆ្នេរសមុទ្ទ ពួកមនុស្សនាំគ្នា ចាក់ស្រាដែលសល់អំពីផឹក និងចាក់បាយ ត្រី សាច់ ស្ករ ម្ហូជាដើមដែល សល់ ពីការផឹកស៊ីក្នុងស្ទឹងគង្គានោះឯង ស្តេចនាគឈ្មោះគង្គេយ្យខឹងក្រោធ គិតថា មនុស្សទាំងនេះបោះរបស់សំណល់លើអញ អញនឹងធ្វើមនុស្សទាំងនេះ ឲ្យលិចក្នុងស្ទឹងទាំងអស់ ហើយនិម្មិតអត្តភាពធំ ប្រមាណប៉ុនទូកកម្រោល ជ្រែកផ្ទៃទឹកឡើងមក បើកពពារហែលមកចំពោះមុខមនុស្សទាំងនោះ ។ ពួក មនុស្សឃើញស្តេចនាគប៉ុណ្ណោះ ត្រូវមរណភ័យគំរាម ស្រែករំពងឡើង ។ តាបសបានឮសំឡេងតក់ស្លុតរបស់អ្នកទាំងនោះ ក៏ដឹងថា ស្តេចនាគខឹងគិត ថា មនុស្សទាំងឡាយដែលអញឃើញកុំបីវិនាសឡើយ ប្រញាប់និម្មិតអត្តភាព ជាគ្រុឌបោះពួយទៅ ដោយអានុភាពរបស់ខ្លួនមួយរំពេច ។ ស្តេចនាគឃើញ គ្រុឌនោះហើយ តក់ស្លុតចំពោះសេចក្តីស្លាប់ ទើបមុជចុះទៅក្នុងទឹក ។ ពួក មនុស្សដល់នូវសួស្តី ហើយនាំគ្នាទៅ ។ ព្រះមានព្រះភាគ ត្រាស់ពាក្យថា **គង្គាយ សោតស្មឹ ។បេ។ អនុស្សរាមិ** នោះ ទ្រង់សំដៅយកសេចក្តីនោះ ។

បទថា **បត្តចរោ** បានដល់ អន្តេវាសិក ។ បទថា **សម្មុទ្ធិវត្តំ វតិ តំ អមញ្ញំ** សេចក្តីថា តថាគតស្គាល់អ្នកថាជាតាបសដែលដល់ព្រមដោយបញ្ញា ផង ដល់ព្រមដោយវត្តផង ។ ដោយបទនេះព្រះមានព្រះភាគទ្រង់សម្តែងទុក ដូចម្តេច ទ្រង់សម្តែងទុកថា នៃមហាព្រហ្ម ក្នុងអតីតកាល ក្នុងកាលដែល

អ្នកជាកេសវតាបស តថាគតជាសិស្សជិតស្និទឈ្មោះកប្បៈ បានរម្ងាប់រោគរបស់អ្នកដែលអាមាត្យឈ្មោះនារទៈនាំមកកាន់ព្រៃហិមពាន្ត អំពីនគរពារាណសី ។ លំដាប់នោះ នារទអាមាត្យសួរសុខទុក្ខអ្នកលើកទី ២ ឃើញថា ជាសះស្បើយអំពីរោគ ទើបពោលគាថានេះថា

កេសវតាបសមានព្រះភាគ ( របស់យើងខ្ញុំ ) នេះ លះបង់ព្រះបាទពារាណសី ជាធំជាងមនុស្ស អ្នកឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយក្នុងអាស្រមរបស់កូនសិស្សឈ្មោះកប្បកៈ តើដោយឧបាយដូចម្តេច ។

អ្នកបានពោលពាក្យនេះ ជាមួយនារទាមាត្យនោះថា

ម្នាលអាមាត្យ រសទាំងឡាយដ៏ត្រាញ់ គួររីករាយក៏មាន ដើមឈើទាំងឡាយជាទីរីករាយចិត្តក៏មាន ពាក្យជាសុភាសិតទាំងឡាយរបស់កប្បកៈ តែងធ្វើឲ្យអាត្មាត្រេកអរបាន ដូច្នេះ ។

អ្នកបានពោលពាក្យនេះនឹងអាមាត្យនារទៈនោះថា នែនារទៈ វត្ថុដែលល្អគួរត្រេកអរនៃចិត្តមានដើម ឈើទាំងឡាយដែលជាទីត្រេកអរនៃចិត្តក៏មាន ពាក្យដែលជាសុភាសិតរបស់កប្បៈ ឲ្យអាត្មាត្រេកអរបាន ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់រោគរបស់កេសីតាបសនេះ ជាវត្ថុដែលព្រះអង្គទ្រង់ជាអន្តេវាសិកឲ្យស្ងប់បាន ដោយប្រការយ៉ាងនេះហើយ ទើបបានត្រាស់យ៉ាងនេះ ម្យ៉ាងទៀត កាលនឹងឲ្យមហាព្រហ្មទាំងអស់កំណត់ដឹងកម្មដែលព្រហ្មនោះ ( ពកព្រហ្ម ) ធ្វើទុកក្នុងមនុស្សលោកនោះឯង ទើប

ត្រាស់ពាក្យនេះទុក ។

ពកព្រហ្មនោះ រឭកដល់កម្មដែលខ្លួនធ្វើទុកបាន តាមព្រះតម្រាស់របស់ព្រះសាស្តាហើយ កាលនឹងសរសើរព្រះតថាគត ទើបពោលថាចុងក្រោយថា

ព្រះអង្គជ្រាបច្បាស់នូវអាយុ របស់ខ្ញុំនុ៎ះដោយពិតផង ជ្រាបច្បាស់នូវហេតុដទៃផង ព្រះអង្គជាព្រះពុទ្ធមែន នេះជាអានុភាពដ៏រុងរឿងរបស់ព្រះអង្គ ដែលញុំាងព្រហ្មលោក ឲ្យភ្លឺរុងរឿង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តថា ហិ ពុទ្ធោ** សេចក្តីថា ព្រោះទ្រង់ជាព្រះពុទ្ធពិត ធម្មតាព្រះពុទ្ធទាំងឡាយ មិនមានវត្ថុដែលទ្រង់មិនដឹង ព្រោះថាទ្រង់ប៉ុណ្ណោះ ឈ្មោះថា ពុទ្ធៈ ព្រោះត្រាស់ដឹងធម៌គ្រប់យ៉ាងនោះឯង ។ បទថា **តថា ហិ តាយំ** សេចក្តីថា មួយវិញទៀត ព្រោះទ្រង់ជាពុទ្ធៈនោះឯង ព្រះរស្មីចេញអំពីព្រះសរីរៈរបស់ព្រះអង្គរុងរឿង ។ បទថា **ឱភាសយំ តិដ្ឋតិ** សេចក្តីថា ព្រះរស្មីអំពីព្រះសរីរៈនេះ ទើបបំភ្លឺព្រហ្មលោកទាំងអស់ឲ្យភ្លឺ ។

ព្រះសាស្តាទ្រង់ឲ្យពកព្រហ្មដឹងពុទ្ធគុណរបស់ទ្រង់បណ្តើរ ទ្រង់សម្តែងធម៌បណ្តើរ ទ្រង់ប្រកាសនូវសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចៈ ចិត្តរបស់ព្រហ្មប្រមាណមួយម៉ឺនអង្គ ផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រះមានព្រះភាគ កាលទ្រង់ជាទីពឹងនៃព្រហ្មទាំងឡាយ ដោយប្រការដូច្នេះ ទ្រង់បានចុះអំពីព្រហ្មលោក មកកាន់ជេតពនវិហារ ហើយទ្រង់សម្តែងព្រះធម៌ទេសនាដល់ភិក្ខុទាំងឡាយដោយទំនងដែលបានសម្តែងហើយក្នុងព្រហ្មលោក

នោះ ហើយទ្រង់ប្រជុំជាតកថា កេសវតាបសក្នុងកាលនោះ បានមកជាពកព្រហ្មក្នុងកាលឥឡូវនេះ ឯកប្បមាណពក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ពកព្រហ្មជាតក ចប់

## កុក្កុវគ្គ ចប់

# គន្ធារវគ្គ

## គន្ធារជាតក

[ ៣៨១ ] ( តាបសពោធិសត្វពោលថា ) អ្នកលះបង់នូវស្រុកចំណុះ ១ ពាន់ និងឃ្លាំង ១៦ ដ៏ពេញបរិបូណ៌ ( ដោយទ្រព្យ ) ធ្វើនូវការសន្សំក្នុងកាលឥឡូវនេះ ។

[ ៣៨២ ] ( វិទេហតាបសពោលថា ) អ្នកលះបង់នូវដែនគន្ធារៈដែលជាដែនសម្បូរដោយទ្រព្យនិងទឹក ហើយចេញផុតអំពីទីជាទីឲ្យនូវពាក្យប្រៀនប្រដៅ ( ដូចខ្ញុំដែរ ) ឥឡូវនេះ ( ហេតុអ្វីក៏មក ) ប្រៀនប្រដៅ ( យើង ) ក្នុងព្រៃនេះ ។

[ ៣៨៣ ] ( ពោធិសត្វពោលថា ) ម្នាលវិទេហៈ ខ្ញុំនិយាយចំពោះតែធម៌ សភាវៈមិនមែនជាធម៌មិនគាប់ចិត្តខ្ញុំទេ កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់បានទេ ។

[ ៣៨៤ ] ( វិទេហតាបសពោលថា ) បុគ្គលដទៃបាននូវសេចក្តីក្រោធព្រោះពាក្យណានីមួយ បណ្ឌិតមិនគប្បីពោលនូវពាក្យនោះឡើយ បើទុកជាពាក្យមានប្រយោជន៍ដ៏ធំក៏ដោយ ។

[ ៣៨៥ ] ( ពោធិសត្វពោលថា ) បុគ្គលទោះខឹងក៏ដោយ មិនខឹងក៏ដោយ ទោះរោយរាយដូចអង្កាមក៏ដោយ កាលបើខ្ញុំនិយាយធម៌ បាបមិនប្រឡាក់បានទេ ។

[ ៣៨៦ ] ប្រសិនបើប្រាជ្ញារបស់ខ្លួនក្តី វិន័យដែលសិក្សាល្អក្តី មិនមាន

ទេ ជនច្រើនគ្នាតែងប្រព្រឹត្តដូចជាក្របីខ្វាក់ក្នុងព្រៃ ។

[ ៣៤៧ ] មួយទៀត ជនពួកខ្លះក្នុងលោកនេះ បានសិក្សាល្អក្នុងអាចារប្បញ្ញត្តិ ព្រោះហេតុនោះ ( ធីរជន ) អ្នកមានវិន័យទូន្មានហើយ រមែងមានចិត្តតាំងមាំល្អ ។

## ចប់ គន្ធារជាតកទី ១

# គន្ធារវគ្គ

## អដ្ឋកថា គន្ធារជាតក

[ ៣៤១-៣៤៧ ] ព្រះសាស្តា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធ ភេសជ្ជសន្និធិការសិក្ខាបទ គឺសិក្ខាបទពោលដោយការសន្សំភេសជ្ជៈ ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **ហិត្វា គាមសហស្សានិ** ដូច្នេះជាដើម ។

រឿងនេះកើតឡើងហើយក្នុងក្រុងរាជគ្រឹះ សេចក្ដីពិស្ដារថា កាលព្រះបិលិន្ទវច្ឆៈទៅកាន់ព្រះរាជវាំង ដើម្បីដោះត្រកូលអ្នករក្សាអារាម ហើយនិម្មិតប្រាសាទថ្វាយព្រះរាជាដោយកម្លាំងឫទ្ធិ ទើបមនុស្សទាំងឡាយជ្រះថ្លា នាំគ្នាបញ្ជូននូវភេសជ្ជៈ ៥ យ៉ាងទៅប្រគេនព្រះថេរៈ ។ ព្រះថេរៈចែកចាយភេសជ្ជៈទាំងនោះដល់បរិស័ទ តែបរិស័ទរបស់លោកមានច្រើន ពួកលោកក៏ទុកដាក់របស់ដែលបានមកពេញថាំងខ្លះ ឆ្នាំងខ្លះ ស្បោកបាត្រខ្លះ មនុស្សទាំងឡាយឃើញ នាំគ្នាពោលទោសថា សមណៈទាំងនេះប្រាថ្នាច្រើន ជាអ្នករក្សាឃ្លាំងខាងក្នុង ។ ព្រះសាស្តាទ្រង់ស្ដាប់ការប្រព្រឹត្តទៅនោះហើយ ទើបទ្រង់បញ្ញត្តិសិក្ខាបទឡើងថា ភេសជ្ជៈណាមួយដែលពួកភិក្ខុមានជំងឺគប្បីឆាន់បាន ... ដូច្នេះជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតក្នុងកាលមុន កាលព្រះពុទ្ធមិនទាន់កើតឡើង បួសជាបព្វជិត ក្នុងលទ្ធិខាងក្រៅ សូម្បីរក្សាត្រឹមតែសីល ៥ ក៏មិនសន្សំដុំអំបិលទុកដើម្បីជាប្រយោជន៍ក្នុងថ្ងៃស្អែក អ្នកទាំងឡាយបួសក្នុងសាសនា ដែលនាំចេញចាកទុក្ខបែបនេះ កាលនាំគ្នាធ្វើការសន្សំនូវអាហារទុកដើម្បីជាប្រយោជន៍ដល់ថ្ងៃទី ២ ថ្ងៃទី ៣ ឈ្មោះថា ធ្វើវត្ថុដែលមិនសមគួរហើយ ទ្រង់នាំរឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះពោធិសត្វ ទ្រង់ជាឱរសរបស់ព្រះបាទគន្ធារៈ ក្នុងគន្ធាររដ្ឋ កាលព្រះរាជបិតាសោយទិវង្គតហើយ ទ្រង់ឡើងគ្រងរាជសម្បត្តិប្រកបដោយធម៌ ។ ក្នុងមជ្ឈិមប្រទេស ព្រះបាទវិទេហៈក៏ទ្រង់គ្រងរាជ្យក្នុងវិទេហរដ្ឋ ព្រះរាជា ២ អង្គនោះទ្រង់ជាសម្លាញ់មិនធ្លាប់ឃើញគ្នា តែទ្រង់រាប់អានគ្នាយ៉ាងមាំទាំ ។ មនុស្សក្នុងសម័យនោះ មានអាយុវែង រស់នៅបានដល់ទៅ ៣ ម៉ឺនឆ្នាំ ។ កាលនោះ ក្នុងថ្ងៃឧបោសថ ពាក់កណ្តាលខែ ព្រះបាទគន្ធារៈ ទ្រង់ក៏សមាទានសីលតាមកាល ហើយប្រថាប់លើបល្ល័ង្កដ៏ប្រសើរ ខាងក្នុងប្រាសាទ ត្រួតមើលលោកធាតុទិសខាងកើត តាមសីហបញ្ជរដែលបើក ប្រថាប់គង់ ត្រាស់ពាក្យដែលប្រកបដោយអត្ថ និងធម៌ដល់ពួកអាមាត្យ ខណៈនោះរាហូបានបិទបាំងដួងចន្ទដែលកំពុងពេញវង់ ដែលកំពុងអណ្តែតទៅក្នុងអាកាស ពន្លឺក៏អន្តរធានទៅ ពួកអាមាត្យមិនឃើញព្រះចន្ទទើបទូលព្រះរាជាដល់ការៈដែលព្រះចន្ទត្រូវរាហូគ្រប់គ្រង ។ ព្រះរាជាទតព្រះចន្ទទ្រង់ព្រះតម្រិះថា ព្រះចន្ទនេះសៅហ្មងអាប់ពន្លឺទៅ ព្រោះវត្ថុសៅហ្មងដែលចរមក ។ សូម្បីរាជបរិវារនេះ ក៏ជាគ្រឿងសៅហ្មងសម្រាប់អញដូចគ្នា តែការដែលអញជាអ្នកអស់នូវសិរី ដូចព្រះចន្ទដែលរាហូគ្រប់គ្រងទុកដូច្នោះមិនសមគួរដល់អញឡើយ ។ អញនឹងលះរាជសម្បត្តិចេញបួស ដូចព្រះចន្ទសញ្ចរទៅក្នុងផ្ទៃមេឃដ៏បរិសុទ្ធ ដូច្នោះ នឹងមានប្រយោជន៍អ្វីដោយអ្នកដទៃដែលអញត្រូវដាស់តឿន អញជាបុគ្គលដែលមិនជាប់ចំពាក់ដោយត្រកូលនិងពួកគណៈ ដាស់តឿនខ្លួនឯងប៉ុណ្ណោះត្រាច់ទៅ នេះជាវត្ថុដែលសមគួរសម្រាប់

អញ ហើយទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ពួកអាមាត្យ ដោយព្រះតម្រាស់ថា អ្នកទាំងឡាយចូរនាំគ្នាតែងតាំងបុគ្គលដែលអ្នកទាំងឡាយពេញចិត្ត ឲ្យធ្វើជាព្រះរាជាចុះ ។ ព្រះរាជាក្នុងគន្ធាររដ្ឋនោះ ទ្រង់លះរាជសម្បត្តិ ចេញបួសជាឥសី ញ៉ាំងឈាននិងអភិញ្ញាឲ្យកើតឡើង ទ្រង់ផ្អែតដោយការត្រេកអរក្នុងឈាន សម្រេចការនៅក្នុងដែនដីនៃព្រៃហិមពាន្ត ។ ឯព្រះបាទវិទេហៈត្រាស់សួរពួកឈ្មួញទាំងឡាយថា សម្លាញ់របស់យើងសុខសប្បាយដែរឬ ទ្រង់ជ្រាបថា ព្រះរាជាចេញបួសហើយ ទ្រង់ព្រះតម្រិះថា បើសម្លាញ់របស់អញបួសហើយ អញនឹងធ្វើអ្វីដោយរាជសម្បត្តិនេះ ហើយទើបទ្រង់លះរាជសម្បត្តិក្នុងមិថិលានគរដែលមានទំហំ ៧ យោជន៍ និងឃ្លាំងដែលពេញក្នុងស្រុក ១៦០០០ ស្រុក ក្នុងវិទេហរដ្ឋ ដែលមានទំហំ ៣០០ យោជន៍ និងស្រីរបាំ ១៦០០០ នាក់ ទ្រង់មិនគិតដល់ព្រះរាជឱរសនិងព្រះរាជធីតា យាងចូលកាន់ទឹកដីនៃព្រៃហិមពាន្ត ទ្រង់បួសហើយ សោយផ្លែឈើដែលជ្រុះឯង គង់នៅហើយត្រាច់ទៅ ។ ឥសីទាំង ២ ប្រព្រឹត្តវត្តនិងអាចារស្មើគ្នា ក្រោយមក បានមកជួបគ្នា តែមិនស្គាល់គ្នា សរសើរគ្នានឹងគ្នា ប្រព្រឹត្តវត្តនិងអាចារស្មើគ្នា ។ គ្រានោះ វិទេហតាបសធ្វើឧបដ្ឋាកគន្ធារតាបស ។ ក្នុងថ្ងៃពេញបូណ៌មីថ្ងៃមួយ កាលជនទាំង ២ នោះអង្គុយពោលកថាដែលប្រកបដោយធម៌ជាមួយគ្នា ក្នុងមណ្ឌលដើមឈើមួយដើម រាហូក៏បាំងដួងចន្ទដែលអណ្តែតក្នុងផ្ទៃមេឃ ។ វិទេហតាបសគិតថា ពន្លឺព្រះចន្ទបាត់ទៅព្រោះអ្វីហ្ន៎ សម្លឹងមើលក៏ឃើញព្រះចន្ទត្រូវរាហូគ្រប់គ្រង ទើបសាកសួរថា បពិត្រអាចារ្យ នុ៎ះអ្វីហ្ន៎ បានបិទបាំង

ដួងចន្ទធ្វើឲ្យអស់រស្មី ។ គន្ធារតាបសឆ្លើយថា នែអន្តេវាសិក នេះជារាហូ ជាគ្រឿងសៅហ្មងម្យ៉ាងនៃព្រះចន្ទ មិនឲ្យព្រះចន្ទភ្លឺថ្លា សូម្បីខ្ញុំឃើញព្រះចន្ទ ត្រូវរាហូបិទបាំងហើយគិតថា ព្រះចន្ទបរិសុទ្ធនេះ ក៏ក្លាយជាអស់ពន្លឺទៅព្រោះ គ្រឿងសៅហ្មងដែលចរមក រាជសម្បត្តិនេះក៏ជាគ្រឿងសៅហ្មងសម្រាប់អាត្មាអញ អញនឹងបួសទាន់រាជសម្បត្តិមិនទាន់ធ្វើឲ្យអញអាប់រស្មី ដូចរាហូបិទបាំង ដួងចន្ទ ហើយធ្វើដួងចន្ទដែលត្រូវរាហូបិទបាំងនោះឯងឲ្យជាអារម្មណ៍ លះបង់ រាជសម្បត្តិធំ បួសហើយ ។

វិទេហតាបសសួរថា បពិត្រលោកអាចារ្យ លោកជាព្រះបាទគន្ធារៈឬ គន្ធារតាបសប្រាប់ថា អើ ខ្ញុំជាព្រះបាទគន្ធារៈ វិទេហតាបសពោលថា បពិត្រ លោកអាចារ្យ ខ្ញុំក៏ជាព្រះបាទវិទេហៈ ក្នុងមិថិលានគរ វិទេហរដ្ឋ ពួកយើង ជាសម្លាញ់មិនធ្លាប់ឃើញគ្នាមិនមែនឬ គន្ធារតាបសពោលថា លោកមានអ្វី ជាអារម្មណ៍ទើបចេញបួស វិទេហតាបសពោលថា ខ្ញុំបានឮថា លោកចេញ បួសហើយគិតថា លោកនឹងបានឃើញគុណដ៏ធំនៃការបួសពិតប្រាកដ ទើប ធ្វើលោកនោះឯងឲ្យជាអារម្មណ៍ ហើយលះរាជសម្បត្តិចេញបួស ។

តាំងអំពីនោះមក តាបសទាំង ២ នោះ រាប់អានគ្នាពន់ពេក ជាអ្នកមាន ផ្លែឈើជ្រុះឯងជាភោជនីយាហារ ត្រាច់ទៅ ។ ជនទាំង ២ អាស្រ័យនៅជា មួយគ្នាក្នុងទីនោះអស់កាលយូរ ទើបនាំគ្នាចេញអំពីព្រៃហិមពាន ដើម្បីបរិ- ភោគរស់ជូរប្រៃ ដល់តំបន់ជាយដែនមួយ ។ ជនទាំងឡាយជ្រះថ្លាក្នុងឥរិ យាបថរបស់លោក ប្រគេនភិក្ខា ទទួលបដិញ្ញាហើយ នាំគ្នាសាងទីសម្រាក

ពេលយប់ជាដើម ឲ្យលោកនៅក្នុងព្រៃ សូម្បីក្នុងរវាងផ្លូវក៏នាំគ្នាធ្វើបណ្ណសាលាទុកក្នុងទីដែលមានទឹកស្រួល ដើម្បីឲ្យលោកធ្វើកត្តកិច្ច ឥសីទាំង ២ នាំគ្នាត្រាច់កិក្ខា ត្រង់តំបន់ជាយដែននោះហើយ អង្គុយឆាន់ត្រង់បណ្ណសាលាទើបទៅលំនៅរបស់ខ្លួន ។ ជនទាំងនោះ កាលប្រគេនអាហារ ជួនកាលក៏ប្រគេនអំបិលដាក់ក្នុងបាត្រ ជួនកាលក៏ខ្ចប់ស្លឹកចេកប្រគេន ជួនកាលក៏ប្រគេនអាហារដែលមិនមានរសប្រៃឡើយ ។ ថ្ងៃមួយ ជនទាំងនោះបានប្រគេនអំបិលជាច្រើន ដាក់ក្នុងកញ្ចប់ស្លឹកចេកដល់ឥសីទាំងនោះ ។ វិទេហតាបសកាន់យកអំបិលទៅផង ពេលភត្តកិច្ចរបស់ព្រះពោធិសត្វ ក៏ប្រគេនរហូតគ្រប់គ្រាន់ ឯខ្លួនឯងក៏កាន់យកប្រមាណសមគួរ អំបិលដែលសល់ ក៏ខ្ចប់ស្លឹកចេកទុកត្រង់គុម្ពស្មៅគិតថា នឹងប្រើក្នុងថ្ងៃដែលមិនមានអំបិល ។ ថ្ងៃមួយបាននូវអាហារសាប វិទេហតាបសប្រគេនភាជនកិក្ខាដល់គន្ធារតាបស ហើយយកអំបិលចេញអំពីគុម្ពស្មៅ ហើយពោលថា បពិត្រលោកអាចារ្យ សូមលោកម្ចាស់ទទួលអំបិល គន្ធារតាបសសួរថា ថ្ងៃនេះ មនុស្សទាំងឡាយមិនបានឲ្យអំបិល លោកបានអំបិលមកអំពីណា វិទេហតាបសពោលថា បពិត្រ លោកអាចារ្យ ក្នុងថ្ងៃមុនមនុស្សទាំងឡាយបានប្រគេនអំបិលច្រើន ទើបខ្ញុំរក្សាទុកដោយតាំងចិត្តថា នឹងប្រើប្រាស់ក្នុងថ្ងៃដែលអាហារមានរសសាប ។

ព្រះពោធិសត្វពោលនឹងវិទេហតាបសថា នែមោឃបុរស លោកលះវិទេហរដ្ឋប្រមាណ ៣០០ យោជន៍ បួសហើយដល់នូវការមិនមានកង្វល់ ឥឡូវនេះ នៅកើតចំណង់ចង់បានក្នុងដុំអំបិលទៀតឬ កាលជាស់តឿនឥសីនោះ ក៏

បានពោលគាថាទី ១ ថា

អ្នកលះបង់នូវស្រុកចំណុះ ១ ពាន់ និងឃ្លាំង ១៦ ដ៏ពេញបរិបូណ៌ ( ដោយទ្រព្យ ) ធ្វើនូវការសន្សំក្នុងកាលឥឡូវនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោដ្ឋាគារានិ** បានដល់ ឃ្លាំងមាស ឃ្លាំងប្រាក់ ឃ្លាំងកែវ មានកែវមណីនិងកែវមុក្តាជាដើម និងឃ្លាំងសំពត់ ឃ្លាំងស្រូវ ។ បទថា **ផីតានិ** បានដល់ ពេញហើយ ។ បទថា **សន្និធិំ ទានិ កុព្វសិ** បានដល់ ឥឡូវនេះ លោកនៅមកធ្វើការសន្សំត្រឹមតែអំបិល ដោយគិតថា នឹងប្រើក្នុងថ្ងៃស្អែកនេះ នឹងប្រើក្នុងថ្ងៃខានស្អែកនេះ ។ វិទេហតាបសត្រូវតិះដៀលយ៉ាងនេះ អត់ធន់នឹងពាក្យតិះដៀលមិនបាន ក៏ក្លាយជាបដិបក្ខកាលប្រកែកថា បពិត្រលោកអាចារ្យ លោកមិនឃើញទោសខ្លួនឯង ឃើញទោសខ្ញុំតែម្យ៉ាង លោកត្រិះរិះថា អញនឹងប្រយោជន៍អ្វីដោយអ្នកដទៃ ដែលត្រូវជាសត្តៀន អញនឹងជាសត្តៀនខ្លួនឯង លះរាជសម្បត្តិ ចេញបួសហើយតែថ្ងៃនេះ ហេតុអ្វី ទើបលោកទូន្មានខ្ញុំ ហើយពោលគាថាទី ២ ថា

អ្នកលះបង់នូវដែនគន្ធារៈ ដែលជាដែនសម្បូរដោយទ្រព្យនិងទឹក ហើយចេញផុតអំពីទីជាទីឲ្យនូវពាក្យប្រៀនប្រដៅ ( ដូចខ្ញុំដែរ ) ឥឡូវនេះ ( ហេតុអ្វីក៏មក ) ប្រៀនប្រដៅ ( យើង ) ក្នុងព្រៃនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បសាសនិតោ** សេចក្តីថា ចាកការឲ្យឱវាទ

និងការប្រៀនប្រដៅ ។ បទថា **ឥធ ឋានេ** សេចក្ដីថា ហេតុអ្វីឥឡូវនេះ ទើបមកជាស់តឿនខ្ញុំក្នុងទីនេះ គឺក្នុងព្រៃទៀត ។

ព្រះពោធិសត្វ បានស្ដាប់ពាក្យនោះហើយ ពោលគាថាទី ៣ ថា

ម្នាលវិទេហៈ ខ្ញុំនិយាយចំពោះតែធម៌ សភាវៈមិនមែនជាធម៌
មិនគាប់ចិត្តខ្ញុំទេ កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់បាន
ទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មំ** បានដល់ សភាវៈ គឺហេតុដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមទ្រង់ពណ៌នាសរសើរហើយ ។ បទថា **អធម្មោ មេ ន រុច្ចតិ** សេចក្ដីថា ធម្មតាអធម៌មិនមែនសភាវៈ ខ្ញុំមិនគាប់ចិត្តក្នុងទីណាឡើយ ។ បទថា **ន បាបមុបលិម្បតិ** សេចក្ដីថា កាលខ្ញុំពោលសភាវៈនោះឯង ឬហេតុនោះឯង ឈ្មោះថា បាបមិនជាប់ក្នុងចិត្តធម្មតាការឲ្យឱវាទនេះ ជាបវេណីរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវ័កនិងព្រះពោធិសត្វទាំងឡាយ ទោះបីបុគ្គលពាលមិនទទួលយកឱវាទដែលលោកទាំងនោះឲ្យហើយ តែអ្នកឲ្យឱវាទក៏មិនមានបាបឡើយ កាលនឹងសម្ដែងទៀត ក៏ពោលគាថាទាំងឡាយថា

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់
សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់
ទ្រព្យឲ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា ) កាល
បុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្ដីគាប់ប្រ-

សើរ ឥតមានទោសដ៏លាមកឡើយ ។

បណ្ឌិតគួរទូន្មានប្រៀនប្រដៅគួរហាមឃាត់នូវជនទាំងឡាយ ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ដូច្នេះ ។

វិទេហតាបស ស្ដាប់ពាក្យព្រះពោធិសត្វនោះហើយ ពោលថា បពិត្រលោកអាចារ្យ បុគ្គលកាលពោលពាក្យដែលអាស្រ័យប្រយោជន៍ ក៏មិនគួរពោលទ្រគោះអ្នកដទៃ លោកពោលពាក្យគ្រោតគ្រាតច្រើន ដូចកោរសក់ដោយកាំបិតកោរមិនមុត ហើយពោលគាថាទី ៤ ថា

បុគ្គលដទៃបាននូវសេចក្ដីក្រោធព្រោះពាក្យណានីមួយ បណ្ឌិតមិនគប្បីពោល នូវពាក្យនោះឡើយ បើទុកជាពាក្យមានប្រយោជន៍ដ៏ធំក៏ដោយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេនកេនចិ** សេចក្ដីថា ដោយហេតុសូម្បីត្រឹមតែប្រកបដោយធម៌ ។ បទថា **លភតិ រុប្បនំ** សេចក្ដីថា បានទទួលនូវការទ្រគោះ ការចង្អៀតចង្អល់ គឺការក្ដៅរោលរាល ។ បទថា **ន តំ ភាសេយ្យ** មានអត្ថថា ព្រោះដូច្នោះ បុគ្គលមិនគួរពោលវាចាសូម្បីមានប្រយោជន៍ច្រើន គឺដែលអាស្រ័យប្រយោជន៍ច្រើនដែលជាហេតុប្រទូស្តបុគ្គលដទៃនោះ ។ លំដាប់នោះ ទើបព្រះពោធិសត្វពោលគាថាទី ៥ ដល់វិទេហតាបសថា

បុគ្គលទោះខឹងក៏ដោយ មិនខឹងក៏ដោយ ទោះរោយរាយ ដូច

អង្កាមក៏ដោយ កាលបើខ្ញុំនិយាយធម៌ បាបមិនឡាក់បានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាមំ** សេចក្តីថា ដោយចំណែកមួយ ។ មានពាក្យអធិប្បាយថា បុគ្គលធ្វើកម្មមិនសមគួរ កាលត្រូវជាស់តឿនថា អ្នកធ្វើកម្មមិនសមគួរហើយ ទោះក្រោធដោយចំណែកមួយក្តី ឬមិនក្រោធក្តី ។ ម្យ៉ាងទៀត បុគ្គលនោះ ទោះផ្ទុះចោល ដូចបាចអង្កាមចោលក្តី តែកាលខ្ញុំពោលពាក្យជាធម៌ ឈ្មោះថា បាប រមែងមិនមាន ។

ព្រះពោធិសត្វ កាលពោលយ៉ាងនេះហើយ បានតាំងនៅក្នុងបដិបទាដែលសមគួរដល់ឱវាទរបស់ព្រះសុគត ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសកៈ ) នេះថា

> ម្នាលអានន្ទ ស្មូនឆ្នាំងកាន់ភាជន៍ទទឹកមិនទាន់ស្ងួត ( ជួមមិនឲ្យបែក ) យ៉ាងណា តថាគតមិនបៀតបៀនអ្នកទាំងឡាយយ៉ាងនោះដែរ ។ ម្នាលអានន្ទ តថាគតសង្កត់សង្កិនហើយប្រៀនប្រដៅរឿយៗ ម្នាលអានន្ទ តថាគតបន្សាត់បង់ បំផ្លាញបង់នូវទោសចេញហើយ ប្រៀនប្រដៅថែមទៀតដោយគិតថានឹងឲ្យអ្នកទាំងឡាយមានសារៈ គឺមគ្គផល តាំងនៅក្នុងសន្តានដូច្នេះ ។

ដើម្បីសម្តែងថា បណ្ឌិតជាស់តឿនហើយ ព្រកហើយព្រកទៀត ទើបទទួលបុគ្គលទាំងឡាយ ដែលដូចគ្នានឹងភាជនដីដែលដុតហើយ ដូចស្មូនឆ្នាំង

គោះមើលហើយគោះមើលទៀត មិនទទួលយកភាជនដីដែលឆៅ ទទួលយកភាជនដីដែលដុតឆ្អិនហើយប៉ុណ្ណោះ កាលជាស់តឿនវិទេហតាបសទៀត ទើបពោលគាថា ២ ថា

ប្រសិនបើប្រាជ្ញារបស់ខ្លួនក្ដី វិន័យដែលសិក្សាល្អក្ដី មិនមានទេ ជនច្រើនគ្នាតែងប្រព្រឹត្តដូចជាក្របីខ្វាក់ក្នុងព្រៃ ។

មួយទៀត ជនពួកខ្លះក្នុងលោកនេះ បានសិក្សាល្អក្នុងអាចារប្បញ្ញត្តិ ព្រោះហេតុនោះ ( ធីរជន ) អ្នកមានវិន័យទូន្មានហើយ រមែងមានចិត្តតាំងមាំល្អ ដូច្នេះ ។

គាថានេះមានសេចក្ដីថា ម្នាលវិទេហៈសម្លាញ់ ព្រោះថា បើសត្វទាំងនេះមិនមានបញ្ញា ឬមិនមានវិន័យ គឺអាចារប្បញ្ញត្តិដែលសិក្សាល្អហើយព្រោះអាស្រ័យពួកបណ្ឌិតដែលឲ្យឱវាទសោត កាលបើដូច្នេះ មនុស្សជាច្រើន ក៏នឹងដូចជាលោក ត្រាច់ទៅដូចក្របីខ្វាក់ មិនដឹងទីដែលជាគោចរ ឬអគោចរ មានវត្ថុដែលគួរវៀស ឬមិនមានវត្ថុដែលគួរវៀស ត្រាច់ទៅក្នុងគុម្ពស្មៅនិងវល្លិជាដើម តែព្រោះសត្វពួកខ្លះក្នុងលោកនេះ ដែលប្រាសចាកបញ្ញារបស់ខ្លួន សិក្សាល្អហើយដោយអាចារប្បញ្ញត្តិក្នុងសម្នាក់អាចារ្យ ព្រោះហេតុនោះសត្វទាំងនោះ ឈ្មោះថា មានវិន័យដែលទូន្មានហើយ ព្រោះខ្លួនជាបុគ្គលដែលអាចារ្យទូន្មានហើយដោយវិន័យដែលសមគួរដល់ខ្លួន គឺជាអ្នកមានចិត្តតាំងមាំហើយ បានដល់ ជាអ្នកមានចិត្តជាសមាធិ ត្រាច់ទៅ ដូច្នេះ ។ ដោយគាថានេះ គន្ធារតាបសសម្ដែងពាក្យនេះទុកថា ពិតហើយ បុគ្គលនេះជាគ្រហស្ថ

ក៏សិក្សាសិក្ខាដែលសមគួរដល់ត្រកូលរបស់ខ្លួន ជាបព្វជិត ក៏សិក្សាសិក្ខាដែលសមគួរដល់បព្វជិត អធិប្បាយថា ចំណែកគ្រហស្ថជា អ្នកសិក្សាល្អក្នុងកសិកម្មនិងគោរក្ខកម្មជាដើមដែលសមគួរដល់ត្រកូលរបស់ខ្លួន ក៏ជាអ្នកមានការរស់នៅសម្បូរ មានចិត្តតាំងមាំ ត្រាច់ទៅ ។ ឯបព្វជិតជាអ្នកសិក្សាក្នុងអាចារ មានការឈានទៅខាងមុខ និងការឈានថយក្រោយជាដើម និងក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខាទាំងឡាយ ដែលសមគួរដល់បព្វជិតដែលគួរជ្រះថ្លា ហើយក៏ជាបុគ្គលប្រាសចាកការរាយមាយ មានចិត្តតាំងមាំ ត្រាច់ទៅ ។ ព្រោះ ( លោកពោលទុកក្នុងមង្គលសូត្រ ) ថា

> ពាហុសច្ចៈ ១ សិល្បសាស្ត្រ ១ វិន័យដែលសិក្សាដោយ
> ប្រពៃ ១ វាចាដែលពោលត្រឹមត្រូវ ១ ( ទាំង៤ ) នេះជា
> មង្គលដ៏ឧត្តម ដូច្នេះ ។

វិទេហតាបសបានស្តាប់ដូច្នោះហើយ ថ្វាយបង្គំសូមខមាទោសចំពោះព្រះពោធិសត្វថា បពិត្រលោកអាចារ្យ តាំងអំពីនេះទៅ សូមលោកអាចារ្យជាស់តឿនប្រៀនប្រដៅខ្ញុំចុះ ខ្ញុំពោលនឹងលោក ព្រោះភាពជាអ្នកមិនមានការទប់ស្កាត់ចិត្តដោយកំណើត សូមលោកឲ្យអភ័យដល់ខ្ញុំចុះ ។ ឥសីទាំង ២ នោះសាមគ្គីគ្នាហើយ បាននាំគ្នាទៅកាន់ព្រៃហិមពាន្តទៀតនោះឯង ។ ក្នុងទីនោះព្រះពោធិសត្វបានប្រាប់កសិណបរិកម្មដល់វិទេហតាបស លោកស្តាប់ហើយញុំាងអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ។ ជនទាំង ២ មានឈានមិនវិនាសជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា វិទេហរាជក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះចំណែកព្រះបាទគន្ធារៈក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា គន្ធារជាតក ចប់

# មហាកបិជាតក

[ ៣៤៨ ] ( ព្រះរាជាពារាណសីត្រាស់សួរថា ) ម្នាលស្វាដ៏ប្រសើរ អ្នកបានធ្វើខ្លួនឲ្យជាស្ពាន ហើយចម្លង ( ពួកស្វាទាំងនេះ ) ឲ្យឆ្លងទៅដល់ទីសួស្តី តើអ្នកត្រូវជាអ្វីនឹងពួកស្វាទាំងនោះ ឯស្វាទាំងនោះត្រូវជាអ្វីនឹងអ្នក ។

[ ៣៤៩ ] ( ស្តេចស្វាពោធិសត្វទូលតបថា ) បពិត្រព្រះបាទអរិន្ទមៈ ( អ្នកបង្ក្រាបសត្រូវ ) ខ្ញុំជាស្តេចជាឥស្សរៈលើស្វាទាំងនោះ ជាអ្នកគ្រប់គ្រងហ្វូងស្វាទាំងនោះ ដែលត្រូវសេចក្តីសោកគ្របសង្កត់ ជាអ្នកខ្លាចព្រះអង្គ ។

[ ៣៥០ ] ខ្ញុំលោតខ្លួនអំពីឈើនេះ ទៅកាន់ទីប្រមាណ ១ រយ ជួរធ្នូដែលគេលើកឡើងហើយ ចងវល្លិ៍ផ្តៅដ៏មាំ ត្រង់សរីរៈជាខាងក្រោយនៃជើង ( ចង្កេះ ) ។

[ ៣៥១ ] ខ្ញុំលោតទៅកាន់ដើមឈើដោយខ្យល់ ដូចជាពពកដែលខ្យល់ផ្ចាច់ហើយខ្ញុំនោះទៅមិនដល់ ក៏លូកដៃទៅចាប់មែក ( នៃឈើ ) ឰដ៏អាកាសបប្បទេសនោះ ។

[ ៣៥២ ] ពួកស្វាលើកជើងជាន់លើខ្ញុំនោះ ដែលដេកសន្ធឹងដូចខ្សែចាប៉ី ដោយមែកឈើផង ដោយវល្លិ៍ផ្តៅផង ហើយនាំគ្នាទៅដោយសួស្តី ។

[ ៣៥៣ ] ខ្ញុំនោះមិនក្តៅក្រហាយនឹងការចង ខ្ញុំនឹងមិនក្តៅក្រហាយនឹងការសម្លាប់ឡើយ ( ព្រោះ ) ខ្ញុំសោយរាជ ( ត្រួតត្រា ) លើពួកស្វាណាសេចក្តីសុខ ខ្ញុំបាននាំមកឲ្យពួកស្វានោះហើយ ។

[ ៣៥៤ ] បពិត្រព្រះបាទអរិន្ទមៈ នេះជាសេចក្តីប្រៀបធៀបចំពោះព្រះអង្គ សូមព្រះអង្គស្តាប់នូវឧបមានោះ ខត្តិយរាជមានប្រាជ្ញា ត្រូវផ្តល់សេចក្តី

សុខដល់ពួកជនទាំងអស់ គឺអ្នកដែនផង យាន ( ពាហនៈសម្រាប់ទឹម ) ផង ពលច្មើរជើងផង អ្នកនិគមផង ។

**ចប់ មហាកបិជាតកទី ២ ។**

## អដ្ឋកថា

## មហាកបិជាតក

[ ៣៤៨-៣៥៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធញាតត្ថចរិយា គឺការបំពេញប្រយោជន៍ដើម្បីញាតិ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អត្តានំ សង្កមំ កត្វា** ដូច្នេះជាដើម ។

រឿងមានជាក់ច្បាស់ក្នុងភទ្ទសាលជាតក ។

ក្នុងកាលនោះ ភិក្ខុទាំងឡាយ តាំងរឿងសន្ទនាគ្នាឡើងក្នុងធម្មសភាថា អាវុសោទាំងឡាយ ព្រះសាស្តាទ្រង់បំពេញញាតត្ថចរិយា ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ដូច្នេះហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនចំពោះតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏បំពេញញាតត្ថ-ចរិយាដូចគ្នា ហើយទ្រង់បាននាំយករឿងក្នុងអតីតមក សាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី

ព្រះពោធិសត្វ កើតក្នុងកំណើតស្វា ចម្រើនវ័យហើយ ដល់ព្រមដោយទំហំនិងកម្ពស់ មានកម្លាំងច្រើនស្មើនឹងដំរី ៥ មានហ្វូងស្វា ៨ ម៉ឺនជាបរិវារ អាស្រ័យនៅនាដែនដីនៃព្រៃហិមពាន្ត ។ ក្នុងទីនោះ មានដើមអម្ពៈ គឺដើមស្វាយមានមែកសាខា ធំត្រកាល មានស្លឹកក្រាស់ ម្លប់ល្អ កម្ពស់ស្មើនឹងកំពូលភ្នំ ត្រង់ឆ្នេរស្ទឹងគង្គា ។ អាចារ្យពួកខ្លះពោលថា ដើមជ្រៃក៏មាន ។ ផ្លែរបស់ស្វាយនោះមានរសផ្អែម មានក្លិនក្រអូប ដូចគ្នានឹងរសនិងក្លិននៃផ្លែឈើទិព្វ ផ្លែស្វាយនោះមានទំហំធំ ប្រមាណប៉ុនក្អមធំ ។ មែកមួយ ផ្លែរបស់ស្វាយជ្រុះលើគោក មែកមួយទៀតជ្រុះក្នុងទឹកស្ទឹងគង្គា ។ ឯផ្លែរបស់មែក ២ ជ្រុះក្បែរដើម ។ ព្រះពោធិសត្វ នាំហ្វូងស្វាទៅស៊ីផ្លែឈើត្រង់ដើមស្វាយនោះគិតថា ថ្ងៃណាមួយ ភ័យនឹងកើតឡើងដល់ពួកយើង ព្រោះអាស្រ័យផ្លែឈើដែលជ្រុះក្នុងទឹកនេះ ទើបឲ្យហ្វូងស្វាស៊ីផ្លែត្រង់មែកដែលត្រូវធ្លាក់លើទឹក មិនឲ្យសេសសល់សូម្បីមួយផ្លែ តាំងអំពីពេលផ្លែនៅប៉ុនរុយឬពេលចេញផ្កា ។ កាលបើដូច្នោះ ផ្លែទុំមួយបាននៅក្នុងសម្បុកអង្រ្កង ហ្វូងពានរ ៨ ម៉ឺន មើលមិនឃើញ ក៏ជ្រុះក្នុងទឹក ជាប់ត្រង់សំណាញ់ខាងលើរបស់ព្រះបាទពារាណសី ដែលទ្រង់ឲ្យសន្ទឹងខាងលើក្តារសម្រាប់ងូត ហើយទ្រង់លេងឧទកកីឡា ។ ក្នុងកាលដែលព្រះរាជាទ្រង់លេងពេលថ្ងៃហើយ លុះវេលាល្ងាចទ្រង់ត្រឡប់ ពួកអ្នកប្រមង់នាំគ្នាសាសំណាញ់ ឃើញផ្លែនោះ មិនដឹងថា ផ្លែនេះឈ្មោះអ្វី ទើបនាំទៅថ្វាយព្រះរាជា ឲ្យទ្រង់ទត ។

ព្រះរាជាត្រាស់សួរថា នេះជាផ្លែអ្វី អ្នកប្រមង់ទូលថា ទូលព្រះបង្គំមិន

ដឹង ព្រះរាជាត្រាស់ថា អ្នកណានឹងដឹង អ្នកប្រមង់ទូលថា ព្រានព្រៃព្រះអង្គ ។

ព្រះរាជាត្រាស់ឲ្យហៅព្រានព្រៃមកហើយសួរ ទ្រង់ជ្រាបថា ជាផ្លែរបស់ស្វាយ ហើយទ្រង់យកព្រះខ័នចិតឲ្យព្រានព្រៃបរិភោគមុន ហើយទ្រង់សោយក្នុងកាលជាក្រោយ ។ ព្រះរាជទានឲ្យស្រីស្នំខ្លះ អាមាត្យខ្លះបរិភោគ រសរបស់ផ្លែស្វាយ ផ្សាយទូទៅពេញសរីរៈរបស់ព្រះរាជា ។ ព្រះរាជានោះទ្រង់ជាប់ព្រះហឫទ័យ ទ្រង់ជាប់ជំពាក់ក្នុងរស បានត្រាស់សួរពួកព្រានព្រៃដល់ទីកន្លែងរបស់ដើមឈើនោះ ។ កាលពួកព្រានក្រាបទូលថា ស្វាយនេះមានត្រង់ឆ្នេរស្ទឹងនៃដែនដីព្រៃហិមពាន្ត ក៏ត្រាស់ឲ្យមនុស្សជាច្រើន ចងទូកភ្ជាប់គ្នាហើយទ្រង់យាងច្រាស់ខ្សែទឹកឡើងទៅ តាមផ្លូវដែលព្រានព្រៃបង្ហាញ ពួកព្រានព្រៃក្រាបទូលប្រាប់កំណត់ថា អស់កាលប៉ុណ្ណេះថ្ងៃ ដល់ទីនោះតាមលំ-ដាប់ហើយ ទើបពួកព្រានព្រៃក្រាបទូលព្រះរាជាថា នេះគឺដើមឈើដ៏ប្រសើរ ។ ព្រះរាជាត្រាស់ឲ្យចតទូកទុកត្រង់ស្ទឹងហើយ មានមហាជនចោមរោម យាងទៅទីនោះដោយព្រះបាទ ទ្រង់ឲ្យក្រាលទីបន្ទំត្រង់គល់ស្វាយ សោយផ្លែស្វាយទុំហើយ សោយព្រះក្រយាហារដែលមានរសដ៏ប្រសើរច្រើនប្រភេទ ស្រេចហើយក៏ផ្ទំ ។ រាជបុរសទាំងឡាយយាមហើយ គរគំនរភ្លើងគ្រប់ទិស កាលមនុស្សទាំងឡាយដេកលក់ហើយ ព្រះមហាសត្វក៏បានទៅជាមួយបរិស័ទក្នុងពេលរាត្រី ។ ស្វា ៨ ម៉ឺននាំគ្នាស៊ីផ្លែស្វាយទុំអំពីមែកមួយទៅមែកមួយ ។ ព្រះរាជាទ្រង់តើនឡើង ឃើញហ្វូងស្វា ទើបទ្រង់ឲ្យមនុស្សទាំងឡាយភ្ញាក់ឡើង ហើយឲ្យហៅពួកខ្មាន់ធ្នូមកត្រាស់ថា ស្អែកនេះ អ្នកទាំងឡាយចូរនាំគ្នា

ព័ទ្ធបាញ់ពួកស្វាទាំងនេះ ត្រង់មែកឈើ កុំឲ្យវាគេចទៅ ។ ស្អែកនេះ យើងនឹងស៊ីផ្លែស្វាយនិងសាច់ពានរ ពួកខ្មាន់ធ្នូទូលទទួលព្រះបរមរាជឱង្ការ ហើយនាំគ្នាឈរព័ទ្ធដើមស្វាយ ត្រៀមព្រួញទុក ។ ពួកពានរបានឃើញជនទាំងនោះខ្លាចចំពោះមរណភ័យ មិនអាចគេចទៅបាន ទើបនាំគ្នាចូលទៅរកព្រះមហាសត្វ ឈរញ័រចំប្រប់សួរថា បពិត្រព្រះសម្មតិទេព ពួកខ្មាន់ធ្នូឈរព័ទ្ធដើមឈើដោយបំណងថា ពួកយើងនឹងបាញ់ស្វាដែលគេចទៅ ពួកយើងនឹងធ្វើដូចម្តេច ព្រះពោធិសត្វលួងលោម ហ្វូងស្វាថា ពួកអ្នកទាំងឡាយកុំខ្លាចយើងនឹងឲ្យជីវិតដល់ពួកអ្នក ហើយបានរត់ឡើងទៅកាន់មែកដែលត្រង់ បែរមុខទៅកាន់ស្ទឹងគង្គា លោតអំពីចុងមែកនោះ ក្នុងទីប្រមាណ ១០០ ជួរធ្នូ ធ្លាក់ត្រង់គុម្ពឈើមួយ ចុះអំពីគុម្ពឈើ នោះហើយកំណត់ចម្ងាយផ្លូវថា ទីដែលអញមកមានប្រមាណប៉ុណ្ណេះ ទើបបោចផ្តៅមួយដើមត្រង់គល់ បោចស្រទបចេញហើយស្មានរយៈ ២ ដង គឺរយៈប៉ុណ្ណេះនឹងចងដើមឈើ រយៈប៉ុណ្ណេះនឹងសន្ធឹងក្នុងអាកាស តែមិនបានស្មាន ចុងផ្តៅដែលសម្រាប់ចងនឹងចង្កេះរបស់ខ្លួន ។ ស្វាពោធិសត្វយកផ្តៅនោះចងត្រង់ដើមឈើត្រង់ត្រើយស្ទឹងម្ខាង យកចុងផ្តៅចងត្រង់ចង្កេះ លោតមកកាន់ដើមស្វាយប្រមាណ ១០០ ជួរធ្នូ រហ័សដូចពពកត្រូវខ្យល់ផាត់ទៅដូច្នោះ ព្រោះមិនបានស្មានវល្លិដែលរុំត្រង់ចង្កេះទើបមិនដល់ដើមស្វាយ ក៏យកដៃទាំងពីរទាញមែកស្វាយ នោះយ៉ាងតឹង ហើយបានឲ្យសញ្ញា ដល់ហ្វូងស្វាទាំងនោះថា ចូរពួកអ្នកជាន់ខ្នងខ្ញុំទៅដោយសួស្តីតាមផ្តៅ ដោយរហ័ស ។ ស្វា ៨ ម៉ឺនលើកដៃសំពះសូមខមាទោសព្រះពោធិ

សត្វហើយ បានទៅយ៉ាងនោះ ឯទេវទត្តកាលនោះជាស្វាក្នុងចំនួនស្វាទាំងនោះ គិតថា នេះជាពេលបានឃើញខ្នងសត្រូវរបស់អញហើយ ទើបឡើងមែកឈើខ្ពស់ លោតចុះមកដោយសម្ទុះដ៏រហ័ស ហើយធ្លាក់លើខ្នងព្រះមហាសត្វ បេះដូងរបស់មហាសត្វក៏បែក ។ វេទនាដ៏មានកម្លាំងកើតឡើងដល់ព្រះមហាសត្វ ។ ឯស្វាទេវទត្តនោះ ធ្វើព្រះមហាសត្វឲ្យបានទទួលវេទនាហើយ ក៏ចូងទៅ មហាសត្វនៅម្នាក់ឯង ។ ព្រះរាជាផ្ទំមិនទាន់លក់នៅឡើយ ទតឃើញ កិរិយាដែលពួកស្វានិងព្រះមហាសត្វធ្វើគ្រប់យ៉ាង ទ្រង់ផ្ទំបណ្តើរគិតបណ្តើរថា ស្វានេះជាសត្វតិរច្ឆាន បានធ្វើសួស្តីដល់បរិស័ទ ដោយមិនបានគិតដល់ជីវិតរបស់ខ្លួនលុះភ្លឺហើយ ទ្រង់ពេញព្រះហឫទ័យចំពោះព្រះមហាសត្វ ទ្រង់ត្រិះរិះថា អញមិនគួរឲ្យស្តេចស្វានេះវិនាសទៅ អញនឹងឲ្យយកស្តេចស្វានេះចុះមក បដិបត្តិរក្សា ហើយត្រាស់ឲ្យបតទូកខាងក្នុងស្ទឹងគង្គា ទ្រង់ឲ្យចងទ្រុងទុកលើនោះ ហើយឲ្យដាក់ស្តេចស្វាចុះមក ត្រាស់ឲ្យដណ្តប់សំពត់កាសាវពស្ត្រលើខ្នងឲ្យងូតទឹកក្នុងស្ទឹងគង្គា ឲ្យផឹកនូវទឹកអំពៅ ឲ្យយកប្រេងដែលចម្រាញ់ ១០០០ ដងលាបខ្លួន ដាក់លើដំណេកហើយ ។ ទ្រង់ឲ្យស្តេចស្វានោះដេកលើទីដេកនោះ ទ្រង់ប្រថាប់គង់លើអាសនៈទាប បានត្រាស់គាថាទី ១ ថា

ម្នាលស្វាដ៏ប្រសើរអ្នកបានធ្វើខ្លួនឲ្យជាស្ពួ ហើយចម្លង ( ពួក
ស្វាទាំងនេះ ) ឲ្យចូងទៅដល់ទីសួស្តី តើអ្នកត្រូវជាអ្វីនឹងពួក
ស្វាទាំងនោះ ឯស្វាទាំងនោះត្រូវជាអ្វីនឹងអ្នក ដូច្នេះ ។

គាថានោះមានសេចក្តីថា នែស្វាដ៏ចម្រើន អ្នកធ្វើខ្លួនឲ្យជាស្ពាន គឺលើក

ខ្លួនឲ្យជាស្ពួ ហើយលះបង់ជីវិតឲ្យហ្វូងស្វាទាំងនេះ ឆ្លងទៅដោយសួស្តី គឺឲ្យឆ្លងទៅដោយក្សេម ។ អ្នកជាអ្វីនឹងពួកស្វាទាំងនោះ ស្វាទាំងនោះជាអ្វីនឹងអ្នក ។

ព្រះមហាសត្វ បានស្តាប់ពាក្យនោះហើយ កាលនឹងជាស់តឿនព្រះរាជា បានពោលគាថាដ៏សេសថា

បពិត្រព្រះបាទអរិន្ទមៈ ( អ្នកបង្ក្រាបសត្រូវ ) ខ្ញុំជាស្តេច
ជាឥស្សរៈលើស្វាទាំងនោះ ជាអ្នកគ្រប់គ្រងហ្វូងស្វាទាំងនោះ
ដែលត្រូវសេចក្តីសោកគ្របសង្កត់ ជាអ្នកខ្លាចព្រះអង្គ ។

ខ្ញុំលោតខ្លួនអំពីឈើនេះ ទៅកាន់ទីប្រមាណ ១ រយ ជួរធ្នូ
ដែលគេលើកឡើង ហើយចងវល្លិ៍ផ្តៅដ៏មាំ ត្រង់សរីរៈជាខាង
ក្រោយនៃជើង ( ចង្កេះ ) ។

ខ្ញុំលោតទៅកាន់ដើមឈើដោយខ្យល់ ដូចជាពពក ដែល
ខ្យល់ផ្តាច់ហើយ ខ្ញុំនោះទៅមិនដល់ ក៏លូកដៃទៅចាប់មែក
( នៃឈើ ) ពួដ៏អាកាសប្បទេសនោះ ។

ពួកស្វាលើកជើងជាន់លើខ្ញុំនោះ ដែលដេកសន្ធឹងដូចខ្សែ
ចាប៉ីដោយមែកឈើផង ដោយវល្លិ៍ផ្តៅផង ហើយនាំគ្នាទៅ
ដោយសួស្តី ។

ខ្ញុំនោះមិនក្តៅក្រហាយនឹងការចង ខ្ញុំនឹងមិនក្តៅក្រហាយនឹង
ការសម្លាប់ឡើយ ( ព្រោះ ) ខ្ញុំសោយរាជ ( ត្រួតត្រា ) លើ
ពួកស្វាណា សេចក្តីសុខខ្ញុំបាននាំមកឲ្យពួកស្វានោះហើយ ។

បពិត្រព្រះបាទអរិន្ទមៈ នេះជាសេចក្ដីប្រៀបធៀប ចំពោះ
ព្រះអង្គ សូមព្រះអង្គស្ដាប់នូវឱវាទនោះ ខត្តិយរាជមានប្រាជ្ញា
ត្រូវផ្ដល់សេចក្ដីសុខដល់ពួកជនទាំងអស់ គឺអ្នកដែនផង យាន
( ពាហនៈសម្រាប់ទឹម ) ផង ពលថ្មើរជើងផង អ្នកនិគមផង
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តេសំ** បានដល់ ស្វាទាំង ៨ ម៉ឺននោះ ។ បទថា **ភីតាឆន្ត** សេចក្ដីថា ជាអ្នកខ្វាចទ្រង់ ដែលទ្រង់ប្រថាប់ឈរបញ្ជាឲ្យបាញ់ ។ ស្ដេចស្វាហៅព្រះរាជាថា អរិន្ទមៈ ។ ព្រះរាជាហៅថា អរិន្ទមៈ ព្រោះទ្រង់បង្ក្រាបសត្រូវ មានចោរជាដើម ។ បទថា **វិស្សដ្ឋធនុនោ សតំ** សេចក្ដីថា ដែលលោតទៅក្នុងអាកាសក្នុងទីប្រមាណ ១០០ ជួរដងធ្នូ ដែលលើកឡើងវាស់ ។ បទថា **តតោ** សេចក្ដីថា អំពីដើមឈើនេះ គឺអំពីទីដែលលោតទៅ ។ បទថា **អបរបាទេសុ** សេចក្ដីថា ខាងលើខ្នងជើង ។ ពាក្យថា **អបរបាទេសុ** នេះ លោកសំដៅដល់ចង្កេះ ។ ព្រោះថា ព្រះពោធិសត្វចងវល្លិនោះត្រង់ចង្កេះ យ៉ាងខ្ជាប់ហើយ ជាន់ផែនដីដោយជើង ស្ទុះទៅក្នុងអាកាស ដោយកម្លាំងដ៏រហ័សដូចខ្យល់ ។ បទថា **ឆុណ្ណា រុក្ខមុបាគមឹ** សេចក្ដីថា ខ្ញុំលោតទៅដោយខ្យល់របស់ខ្លួន ដែលឲ្យសម្រេចជាកម្លាំងដូចគ្នានឹងដុំពពកដែលខ្យល់បក់ទៅ ដូច្នោះ គឺលោតទៅ ដោយកម្លាំងរហ័សរបស់ខ្លួន ដូចពពកត្រូវខ្យល់ផ្ដាច់ទៅ ដូច្នោះ ហើយត្រឡប់មកដល់ដើមស្វាយនេះ ។ បទថា **អប្បត្វា** សេចក្ដីថា ខ្ញុំទៅមិនដល់ដើមឈើ ដែលសល់ប្រមាណមួយ

ជួរខ្លួន ទើបយកដៃចាប់មែកឈើនោះទុក ។ បទថា **វិណាយតំ** សេចក្តីថា ខ្ញុំមានរាងកាយត្រូវមែកឈើនិងផ្កាសន្ធឹងដូចខ្សែពិណ[១]ដ៏តឹង ដូច្នោះ ។ បទថា **សមនុញ្ញមត្ថា** សេចក្តីថា ពួកស្វាដែលខ្ញុំអនុញ្ញាតហើយ ខមាទោសខ្ញុំហើយ ប្រើជើងជាន់ខ្ញុំទៅដោយសួស្តី មិនមានជាប់ឡើយ ។ បទថា **តំ មំ ន តប្បតិ ពន្ធោ** សេចក្តីថា ការចងដោយវល្លិនោះក៏មិនធ្វើឲ្យ ខ្ញុំក្តៅក្រហាយឡើយ ទោះបីឥឡូវនេះសេចក្តីស្លាប់ ក៏មិនធ្វើឲ្យខ្ញុំក្តៅក្រហាយ ព្រោះហេតុអ្វី ព្រោះការស្លាប់នោះ នាំសេចក្តីសុខមកឲ្យពានរទាំងនោះ ។ បទថា **សុខ-មាហរិតំ តេសំ** សេចក្តីថា ព្រោះហេតុដែល ទូលព្រះបង្គំបាននូវភាពជាព្រះរាជារបស់ពានរពួកណា ភាពជាព្រះរាជារបស់ទូលព្រះបង្គំ រមែងនាំសុខមកឲ្យ ដល់ពានរទាំងនោះ បពិត្រមហារាជ ព្រោះហេតុដែលពានរទាំងនោះពោលថា បុរសនេះនឹងបំបាត់ទុក្ខដែលកើតឡើងដល់ពួកយើង ហើយនាំសុខឲ្យបាន ទើបនាំគ្នាតែងតាំងឲ្យខ្ញុំជាធំ ។ ឯខ្ញុំក៏ពោលដូចគ្នាថា យើងនឹងកម្ចាត់ទុក្ខដែលកើតឡើងដល់អ្នកទាំងឡាយ ហើយក៏បានក្លាយជាប្រធាន គឺជាស្តេចនៃស្វាទាំងនេះ ។ ថ្ងៃនេះ ទូលព្រះបង្គំបានកម្ចាត់មរណទុក្ខនោះ នាំសេចក្តីសុខមកឲ្យពួកស្វាទាំងនោះហើយ ដោយហេតុនោះ ការចងទើបមិនដុតរោលទូលព្រះបង្គំឲ្យក្តៅក្រហាយ ពេជ្ឈឃាត គឺមរណៈ ក៏មិនញ៉ាំងខ្ញុំឲ្យក្តៅក្រហាយ ។ បទថា **ឯសា តេ ឧបមា** សេចក្តីថា បពិត្រមហារាជ នេះគឺឧបមាការធ្វើដែលខ្ញុំបានថ្វាយដល់ទ្រង់ ។ បទថា **តំ សុណោហិ** សេចក្តីថា ព្រោះហេតុ

---

១-បិដកខ្មែរជា ខ្សែចាប៉ី ។

នោះ សូមទ្រង់ស្តាប់ពាក្យជាស់តឿនដែលខ្ញុំកំពុងថ្វាយដល់ទ្រង់ ដោយប្រៀបធៀបនឹងឧបមានេះ ។ បទថា **រញ្ញោ រដ្ឋស្ស** អធិប្បាយថា បពិត្រមហារាជ ធម្មតាព្រះរាជា មិនរឹបជាន់ប្រជានុរាស្ត្រ ដូចឃ្នាបអំពៅឡើយ សូមទ្រង់លះការលុះអំណាចអគតិ ដាក់ចិត្តដោយសង្គហធម្មវត្ថុ ៤ តាំងនៅក្នុងរាជធម៌ ១០ ហើយទ្រង់លះបង់ជីវិតរបស់ខ្លួនដូចខ្ញុំ ហើយគួរស្វែងរកសេចក្តីសុខប៉ុណ្ណោះដល់អ្នកដែនទាំងមូល ដល់យានពាហនៈដែលទឹមហើយ មានរថនិងរទេះជាដើម ដល់កងទ័ព ពោលគឺពលជើងជើង និងដល់និគម ពោលគឺនិគមនិងជនបទទាំងអស់ ដោយព្រះតម្រិះថា ធ្វើដូចម្តេចហ្ន៎រាស្ត្រទាំងឡាយរបស់អញគប្បីប្រាសចាកសេចក្តីខ្លាច រដូវក្តៅបើកទ្វារបាន ញាតិនិងមិត្តទាំងឡាយចោមរោមហើយ ដាក់កូនឲ្យរាំលើទ្រូង ឲ្យល់ត្រជាក់បក់មក បរិភោគអាហាររបស់ខ្លួនតាមគាប់ចិត្ត ជាអ្នកដល់ព្រមដោយសេចក្តីសុខកាយ សប្បាយចិត្ត ។ បទថា **ខត្តិយេន បជានតា** សេចក្តីថា ព្រះរាជានេះ ដែលបានឈ្មោះថា ជាក្សត្រ ព្រោះទ្រង់ជាម្ចាស់នៃស្រែ ទ្រង់គួរជាអ្នកមានបដិភាណ គឺទ្រង់សម្បូរដោយបញ្ញា ជាងមនុស្សដ៏សេស ។

មហាសត្វ កាលជាស់តឿននិងប្រៀនប្រដៅព្រះរាជាយ៉ាងនេះ ក៏ស្លាប់ទៅ ។ ព្រះរាជាហៅអាមាត្យមកហើយត្រាស់ថា អ្នកទាំងឡាយចូរធ្វើ សរីរកិច្ចរបស់ស្តេចស្វានេះ ឲ្យដូចសរីរកិច្ចរបស់ព្រះរាជា សូម្បីក្នុងស្រីស្នំក៏ទ្រង់ត្រាស់ថា នាងទាំងឡាយចូរនាំគ្នាស្លៀកសំពត់ពណ៌ក្រហម រំសាយសក់ មានដៃកាន់ប្រទីបមានដង ហែហមស្តេចស្វាទៅកាន់ឈាបនដ្ឋាន ។ អាមាត្យទាំង

ឡាយរៀបជើងថ្ករដោយគំនរខសប៉ុនរទេះ បូជាសពមហាសត្វ ដោយទំនង ដូចគ្នានឹងការថ្វាយព្រះភ្លើងដល់ព្រះរាជា ។ ហើយបានកាន់យកលលាដ៍សីសៈ ទៅកាន់សម្នាក់ព្រះរាជា ព្រះរាជាឲ្យសាងចេតិយទុកក្នុងឈាបនដ្ឋាន ឲ្យអុជ ប្រទីប បូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម ហើយទ្រង់ឲ្យស្រោប លលាដ៍សីសៈដោយមាស ទុកត្រង់ចុងរំពែង ដង្ហែទៅខាងមុខ ទ្រង់បូជា ដោយគ្រឿងក្រអូបនិងផ្កាជាដើម ទើបយាងទៅកាន់នគរពារាណសី ហើយ តម្កល់ទុកត្រង់ទ្វារព្រះរាជវាំង ហើយទ្រង់ឲ្យត្រៀមព្រះនគរ ធ្វើការបូជាធាតុ អស់ ៧ ថ្ងៃ ។ បន្ទាប់មក ទ្រង់ទទួលយកធាតុនោះ មកសាងចេតិយទុក បូជាដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើម ដរាបដល់អស់ព្រះជន្ម ទ្រង់តាំង នៅក្នុងឱវាទរបស់ព្រះពោធិសត្វ បំពេញបុណ្យ មានទានជាដើម គ្រងរាជ សម្បត្តិដោយធម៌ហើយមានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាស សច្ចៈទាំងឡាយ ទ្រង់ប្រជុំជាតកទុកថា ព្រះរាជាក្នុងកាលនោះ បានមកជា អានន្ទក្នុងកាលឥឡូវនេះ ស្វាអាក្រក់ក្នុងកាលនោះ បានមកជាទេវទត្ត បរិស័ទ ទាំងឡាយក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ចំណែកស្តេចស្វាក្នុងកាល នោះ គឺតថាគតនេះឯង ។

**អដ្ឋកថា មហាកបិជាតក ចប់**

## កុម្ភការជាតក

[ ៣៥៥ ] ( ព្រះបច្ចេកពុទ្ធ ៤ អង្គ ពោលគាថាមួយៗថា ) អាត្មាបានឃើញដើមស្វាយដុះលូតលាស់ ក្នុងកណ្តាលព្រៃស្វាយ មានពណ៌ខៀវ មានផ្លែ អាត្មាឃើញស្វាយនោះបាក់ខ្ទេចខ្ទីព្រោះហេតុតែផ្លែ លុះឃើញស្វាយនោះហើយ ទើបអាត្មាប្រព្រឹត្តនូវភិក្ខាចារ ( ទៅបួស ) ។

[ ៣៥៦ ] នាងនារី ( ម្នាក់ ) ពាក់កងជាវិការៈនៃកែវមណី ១ គូ ដ៏ស្អាតរលោង ដែលជនអ្នកចេះធ្វើឲ្យសម្រេចហើយ ឥតឮសូរសំឡេង ( ទង្គិចគ្នាឡើយ ) លុះដល់អាស្រ័យកមកពាក់ជាមួយគ្នានឹងកងទី ២ ក៏ ( ទង្គិចគ្នា ) ឮសូរសំឡេង អាត្មាបានឃើញនូវកងនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

[ ៣៥៧ ] ពួកបក្សីច្រើនចោមរោម ដេញចឹកបក្សី ១ កំពុងពាំដុំសាច់ ព្រោះហេតុតែអាហារ អាត្មាបានឃើញបក្សីនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

[ ៣៥៨ ] អាត្មាឃើញគោឧសភ ( មួយ ) កណ្តាលហ្វូង មានបូកជ្រួញៗ បរិបូណ៌ដោយសម្បុរនិងកម្លាំង អាត្មាបានឃើញគោឧសភនោះ ត្រូវគោឧសភដទៃបុះមុត ( ធ្លាយពោះវៀន ) ព្រោះហេតុតែកាម លុះបានឃើញគោឧសភនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

[ ៣៥៩ ] ( ពោធិសត្វពោលថា ) ព្រះរាជារបស់អ្នកដែនកលិង្គៈព្រះនាមករណ្ឌកៈ ព្រះរាជារបស់អ្នកដែនគន្ធារៈ ព្រះនាមនគ្គជិ ព្រះរាជារបស់អ្នកដែនវិទេហៈ ព្រះនាមនិមិរាជ ព្រះរាជារបស់អ្នកដែនបញ្ចាលៈ ព្រះនាមទុម្មុខៈ

ព្រះរាជាទាំង ៤ អង្គនុ៎ះ លះបង់នូវដែនទាំងឡាយ ជាអ្នកឥតកង្វល់បួស ហើយ ។

[ ៣៦០ ] ព្រះរាជាទាំងអស់អង្គនេះ ប្រហែលគ្នានឹងវិសុទ្ធិទេវតា បាន មកចួបគ្នាហើយ ព្រះរាជាទាំងនេះ ( រុងរឿងដោយគុណទាំងឡាយ មានសីល គុណជាដើម ) ដូចជាភ្លើង ដែលភ្លឺរុងរឿងដូច្នោះឯង ម្នាលនាងមានភក្រ្ត ចំណែកខាងបងក៏នឹងលះបង់នូវកាមទាំងឡាយ ជាចំណែកដែលខ្ជូនទៀយ- ណាយហើយ ប្រព្រឹត្តតែម្នាក់ឯង ។

[ ៣៦១ ] ( ភរិយានោះពោលថា ) កាលនេះជាកាលគួរ ( នឹងបួស ហើយ ) ឥតមានកាលដទៃទៀតឡើយ ( ព្រោះ ) ដល់ទៅពេលក្រោយ បុគ្គលជាអ្នកប្រៀនប្រដៅខ្ញុំមិនមានទេ បពិត្រអ្នកមានភក្រ្ត ខ្ញុំនឹងប្រព្រឹត្តតែ ម្នាក់ឯង ដូចជាមេបក្សីដែលរួចអំពីដៃនៃបុរស ។

[ ៣៦២ ] ( ព្រះមហាសត្វពោលថា ទារកទាំងឡាយនោះ ) ស្គាល់ បាយឆៅ បាយឆ្អិន ទាំងស្គាល់បាយប្រៃនិងបាយសាបហើយ លុះយើងឃើញ កិរិយារបស់ទារកនោះហើយ ទើបបួស នាងចូរប្រព្រឹត្តស្វែងរកនូវភិក្ខាចារ ចុះ យើងក៏នឹងប្រព្រឹត្តស្វែងរកនូវភិក្ខាចារដែរ ។

## ចប់ កុម្ភការជាតកទី ៣

## អដ្ឋកថា

## កុម្ភការជាតក

[ ៣៥៥-៣៦២ ] ព្រះសាស្តាកាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធការសង្កត់កិលេស ហើយត្រាស់រឿងនេះ មានពាក្យផ្តើមថា **អម្ពាហមទ្ទំ វនមន្តរស្មឹ** ដូច្នេះជាដើម ។

រឿងមានច្បាស់ក្នុងបានីយជាតក ។

ក្នុងកាលនោះ ក្នុងនគរសាវត្ថី មានសម្លាញ់ ៥០០ នាក់ បួសហើយស្នាក់នៅក្នុងកោដិសន្ថារៈ ក្នុងពេលរាត្រី បានត្រិះរិះដល់កាមវិតក្ក ។ ព្រះសាស្តាទ្រង់ប្រមើលមើលសាវករបស់ព្រះអង្គ ទាំងពេលយប់ និងពេលថ្ងៃ ចំនួន ៦ ដង គឺពេលយប់ ៣ ដង ពេលថ្ងៃ ៣ ដង ទ្រង់រក្សាដូចសត្វត្រដេវិចរក្សាស៊ុត សត្វចាមរីរក្សាកន្ទុយ ម្តាយរក្សាកូនតូចជាទីស្រឡាញ់ និងដូចមនុស្សដែលមានភ្នែកមួយចំហៀង រក្សាភ្នែកដែលសល់ ដូច្នោះ ។ ព្រោះហេតុនោះទើបទ្រង់សង្កត់កិលេសដែលកើតឡើងរបស់សាវកទាំងឡាយក្នុងខណៈនោះ ។ ថ្ងៃនោះ ក្នុងពេលយប់ ទ្រង់កំណត់មើលវត្តជេតពន ទ្រង់ដឹងវិតក្ករបស់ភិក្ខុទាំងនោះដែលកំពុងផ្សាយឡើង ទ្រង់ព្រះតម្រិះថា កិលេសនេះ កាលផ្សាយឡើងខាងក្នុងរបស់ភិក្ខុទាំងនេះ នឹងទម្លាយហេតុនៃអរហត្តផល តថាគតនឹងសង្កត់សង្កិនកិលេស ហើយឲ្យនូវអរហត្តផលដល់ភិក្ខុទាំងនោះ ក្នុងកាលឥឡូវនេះឯង ។ ហើយទ្រង់យាងចេញអំពីព្រះគន្ធកុដិ ត្រាស់ឲ្យហៅព្រះអានន្ទត្ថេរមក ឲ្យហៅភិក្ខុទាំងនោះមកប្រជុំថា ម្នាលអានន្ទ ចូរអ្នកឲ្យភិក្ខុដែលនៅក្នុងកោដិសន្ថារៈទាំងអស់ប្រជុំគ្នា ។ ទ្រង់គង់លើពុទ្ធាសនៈ

ដែលក្រាលទុក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរប្រព្រឹត្តទៅក្នុងអំណាចរបស់កិលេសដែលប្រព្រឹត្តទៅហើយខាងក្នុង ដ្បិតថា កិលេសកាលចម្រើនឡើង រមែងឲ្យដល់នូវសេចក្តីវិនាសច្រើន ដូចបច្ចាមិត្ត ។ ធម្មតាភិក្ខុគួរសង្កត់កិលេសសូម្បីមានប្រមាណតិចតួច បណ្ឌិតក្នុងកាលមុន ឃើញអារម្មណ៍ប្រមាណតិចតួច ក៏សង្កត់កិលេសដែលប្រព្រឹត្តទៅហើយ ខាងក្នុងទុក ឲ្យបច្ចេកពោធិញ្ញាណកើតឡើង ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលស្មូនឆ្នាំង ក្នុងស្រុកក្បែរទ្វារនគរពារាណសី ចម្រើនវ័យហើយ បានគ្រប់គ្រងសម្បត្តិ ល្មមគ្រប់គ្រាន់ មានកូនប្រុសមួយ កូនស្រីមួយ ចិញ្ចឹមកូនប្រពន្ធដោយការធ្វើឆ្នាំង ។ ក្នុងកាលនោះ ព្រះរាជាព្រះនាមថា ករណ្ឌក: ក្នុងទន្តបុរនគរ ដែនកលិង្គ: កាលយាងទៅកាន់ព្រះរាជឧទ្យានជាមួយរាជបរិវារធំ ទតឃើញដើមស្វាយ ក្បែរទ្វារព្រះរាជឧទ្យាន មានផ្លែគួរចង់សោយ ពេញទៅដោយផ្លែជាចង្កោមៗ ប្រថាប់លើកដំរីនោះឯង ទ្រង់លាព្រះហត្ថបេះផ្លែស្វាយមួយ ហើយយាងទៅកាន់ព្រះរាជឧទ្យានប្រថាប់គង់លើមង្គលសិលាអាសនៈ ព្រះរាជទាន ដល់មនុស្សដែលគួរព្រះរាជទានហើយ ទើបសោយផ្លែស្វាយ ។ ចាប់តាំងពីពេលដែលព្រះរាជាទ្រង់បេះផ្លែស្វាយហើយ ជាធម្មតាមនុស្សដ៏សេសទាំងឡាយ ក៏ហ៊ាននាំគ្នាបេះដូចគ្នា ហេតុនោះអាមាត្យខ្លះ ព្រាហ្មណ៍និងគហបតីខ្លះ ទើបនាំគ្នាអង្រួនផ្លែស្វាយឲ្យ

ជ្រុះហើយបរិភោគ ។ ជនដែលមកឯក្រោយ ក៏ឡើងបេះ ប្រើដំបងគ្រវែង ធ្វើឲ្យបាក់បែក ហើយបរិភោគ សូម្បីតែផ្លែខ្ចីៗក៏មិនសល់ ។ ឯព្រះរាជាទ្រង់លេងកីឡាក្នុងព្រះរាជឧទ្យានពេញមួយថ្ងៃហើយ លុះពេលល្ងាចទ្រង់ក៏ប្រថាប់គង់លើកដំរីដែលគេតាក់តែងហើយ យាងមក ទតឃើញដើមស្វាយនោះទើបចុះអំពីកដំរី ចូលទៅត្រង់គល់ស្វាយ ទ្រង់សម្លឹងមើលបណ្តើរត្រិះរិះ បណ្តើរថា ស្វាយនេះ ព្រឹកមិញពេញទៅដោយផ្លែជាចង្កោមល្អពេកណាស់ ធ្វើនូវការឆ្អែតឆ្អន់ឲ្យដល់អ្នកមើលទាំងឡាយ ឥឡូវនេះ គេបេះផ្លែអស់ហើយសល់តែមែកទទេ មិនស្អាត កាលទ្រង់មើលហើយមើលទៀត ឃើញដើមស្វាយដទៃមិនមានផ្លែ ប្រថាប់ឈរត្រង់គល់ស្វាយនោះឯង ទ្រង់ធ្វើដើមស្វាយដែលមានផ្លែឲ្យជាអារម្មណ៍ថា ដើមឈើនោះ ឈរយ៉ាងស្រស់ត្រកាល ដូចភ្នំកែវមណី ព្រោះមិនមានផ្លែ ចំណែកស្វាយនេះ ដល់នូវសេចក្តីលំបាកយ៉ាងនេះព្រោះចេញផ្លែ សូម្បីត្រង់កណ្តាលផ្ទះនេះ ក៏ដូចគ្នានឹងដើមស្វាយដែលមានផ្លែ ឯបព្វជ្ជា ដូចគ្នានឹងដើមឈើដែលមិនមានផ្លែ បុគ្គលមានទ្រព្យនោះឯង ជាអ្នកមានភ័យ ចំណែកបុគ្គលមិនមានទ្រព្យមិនមានភ័យ ឯអាត្មាអញ ក៏គួរដូចដើមឈើដែលមិនមានផ្លែ ដូច្នេះហើយ ទ្រង់កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើងហើយ ទ្រង់រំពឹកថា ឥឡូវនេះ អញទម្លាយខ្ទមគឺផ្ទៃមាតាហើយ បដិសន្ធិក្នុងភព ៣ អញផ្តាច់ ផ្តិលហើយ បង្គន់នៃឧច្ចារៈ គឺសង្សារអញលាងហើយ សមុទ្ទទឹកភ្នែក អញបាចឲ្យស្ងួតហើយ កំពែងឆ្អឹងអញទម្លាយហើយ ។ អញមិនមានបដិសន្ធិទៀត

ឡើយ ទ្រង់កំពុងទ្រទ្រង់នូវគ្រឿងអលង្ការទាំងអស់ ប្រថាប់ឈរហើយ ។ អាមាត្យទាំងឡាយបានទូលថា បពិត្រមហារាជ ទ្រង់ប្រថាប់ឈរយូរហើយ ព្រះរាជាត្រាស់ថា អាត្មាមិនមែនព្រះរាជា អាត្មាជាព្រះបច្ចេកពុទ្ធ អាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ មិនដូចទ្រង់ឡើយ ព្រះរាជាត្រាស់ថា បើដូច្នោះដូចអ្វី អាមាត្យក្រាបទូលថា ព្រះបច្ចេកពុទ្ធមិនមានសក់ មិនមានពុកមាត់ បិទបាំងរាងកាយដោយកាសាវពស្ត្រ មិនជាប់ជំពាក់ក្នុងត្រកូលនិងពួកគណៈ មានចំណែកប្រៀបដូចពពកដែលត្រូវខ្យល់បក់និងប្រៀបដូចព្រះចន្ទផុតអំពីមាត់រាហូ ស្នាក់នៅត្រង់ញកភ្នំនន្ទមូលកៈនាព្រៃហិមពាន្ត ព្រះបច្ចេកពុទ្ធទាំងឡាយក៏យ៉ាងនោះ ។

ក្នុងខណៈនោះ ព្រះរាជាលើកព្រះហត្ថាឡើងស្ទាបព្រះកេសា រំពេចនោះឯងគ្រហស្ថការៈ ក៏អន្តរធានទៅ សមណភេទក៏ប្រាកដឡើង សមណបរិក្ខារទាំងឡាយ ដែលលោកពោលដល់យ៉ាងនេះថា

> ត្រៃចីវរ បាត្រ កំបិតកោរ បំពង់ម្ជុល វត្ថពន្ធចង្កេះ និងតម្រងទឹក ៨ យ៉ាងនេះ ជាបរិក្ខាររបស់ភិក្ខុដែលប្រកបការព្យាយាម ដូច្នេះ ។

បានបិទបាំងកាយរបស់ទ្រង់មួយរំពេច ។ ព្រះបច្ចេកពុទ្ធប្រថាប់ឈរក្នុងអាកាស ឲ្យឱវាទដល់មហាជនហើយ បានទៅកាន់ញកភ្នំនន្ទមូលកៈនោះឯង ។

ចំណែកព្រះរាជាព្រះនាមថានគ្គជិ ក្នុងនគរតក្កសិលា ដែនគន្ធារៈ យាងទៅប្រថាប់លើរាជបល្ល័ង្ក ខាងលើផ្ទៃប្រាសាទ ទតឃើញស្រីម្នាក់ មានដៃ

ប្រដាប់កងកែវមណីម្ខាងមួយ អង្គុយបុកគ្រឿងក្រអូប ក្នុងទីមិនឆ្ងាយ ទ្រង់ទតបណ្តើរ ត្រិះរិះបណ្តើរថា កងកែវមណីទាំងនោះ មិនទង្គិចគ្នាមិនមានសំឡេងខ្លាំង ព្រោះនៅម្ខាង ១ គឺនៅបែកគ្នា ។ ក្រោយមក ស្រីនោះក៏ដោះពីដៃម្ខាងពាក់ត្រង់ដៃម្ខាងរួមគ្នា ហើយចាប់ផ្តើមបុកគ្រឿងក្រអូប កងដៃកែវមណីក៏ទង្គិចគ្នា មានសំឡេងឡើង ។ ព្រះរាជាទ្រង់ទតឃើញកងទាំង ២ នោះប៉ះគ្នា មានសំឡេងខ្លាំង ទើបទ្រង់ត្រិះរិះថា កងដៃនេះ កាលនៅម្ខាងមួយចំហៀង មិនទង្គិចគ្នា តែនៅម្ខាង ២ ក៏មានសំឡេងខ្លាំង យ៉ាងណា សូម្បីសត្វទាំងឡាយនេះ ក៏យ៉ាងនោះដូចគ្នា បើនៅម្នាក់ឯង មិនប៉ះទង្គិចគ្នា ក៏មិនមានសំឡេង តែលុះមាន ២-៣ នាក់ឡើងទៅ ក៏ប៉ះគ្នា ធ្វើនូវជម្លោះទាស់ទែង ។ ចំណែកអញ ថែរក្សារាស្ត្រក្នុងរាជសម្បត្តិ ២ កន្លែង គឺក្នុងដែនកស្មិរៈ ១ ដែនគន្ធារៈ ១ អញគួរដូចជាកងដៃតែម្ខាង មិនរក្សាបុគ្គលដទៃរក្សាខ្លួនឯងប៉ុណ្ណោះ ដូច្នេះហើយ ទ្រង់ធ្វើការប៉ះទង្គិចគ្នានៃកងឲ្យជាអារម្មណ៍ទាំងដែលកំពុងអង្គុយនោះឯង ទ្រង់កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនាញ៉ាំងបច្ចេកពោធិញ្ញាណឲ្យកើត ។ សេចក្តីដែលសេសសល់ ដូចគ្នានឹងន័យមុននោះឯង ។

នៅឯមិថិលានគរ ក្នុងវិទេហរដ្ឋ ព្រះបាទនិមិរាជ សោយព្រះក្រយាហារព្រឹកហើយ មានគណៈអាមាត្យហែហម បានឈរប្រថាប់ទតរវាងវិថី តាមបង្អួចដែលបើក កាលនោះ ខ្លែងមួយឆាបដុំសាច់អំពីជ្រញ់អ្នកលក់ ហើយហើរទៅក្នុងអាកាស ។ សត្វទាំងឡាយ មានត្មាតជាដើម ក៏ហើរចោមរោម

ក្អែងនោះ ខាងនោះខ្លះ ខាងនេះខ្លះ ប្រើចំពុះចឹក ប្រើស្លាបវាយ ប្រើជើងខ្ទាំ ព្រោះហេតុនៃអាហារ ។ ខ្លែងទ្រាំនឹងការឈឺចាប់មិនបាន ទើបលែងដុំសាច់នោះទៅ សត្វដទៃក៏ពាំដុំសាច់នោះ សត្វដទៃនាំគ្នាបោះបង់ខ្លែង ហើយដេញតាមសត្វនោះទៅ ។ ឯសត្វនោះលែង សត្វដទៃក៏ពាំទៅ បក្សីទាំងឡាយ ក៏ចោមរោមចឹកសត្វនោះ យ៉ាងនោះដូចគ្នា ព្រះរាជាឃើញសត្វទាំងនោះហើយ ទ្រង់ត្រិះរិះថា បក្សីណាពាំដុំសាច់ បក្សីនោះឯងដល់នូវសេចក្ដីទុក្ខ ឯបក្សីណាលែងនូវដុំសាច់នោះចោល បក្សីនោះឯង មានសេចក្ដីសុខ ។ កាមគុណ ៥ នេះ បុគ្គលណាប្រកាន់ទុក បុគ្គលនោះឯងមានសេចក្ដីទុក្ខ ឯបុគ្គលណាមិនប្រកាន់ បុគ្គលនោះឯងមានសេចក្ដីសុខ ព្រោះកាមទាំងនេះ ជារបស់សា-ធារណៈសម្រាប់មនុស្សជាច្រើន ។ ចំណែកអញ មានស្រីស្នំ ១៦០០០ នាក់ អញគួរលះកាមគុណ ៥ ហើយនៅជាសុខ ដូចខ្លែងដែលចោលដុំសាច់នេះ ទ្រង់មនសិការដោយឧបាយ ទាំងដែលកំពុងឈរនោះឯង ទ្រង់កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើង សេចក្ដីដែលសេសសល់ ដូចន័យមុននោះឯង ។

ក្នុងឧត្តរបញ្ចាលរដ្ឋ កបិលនគរ ព្រះរាជាព្រះនាមទុម្មុខៈ សោយព្រះក្រយាហារព្រឹកហើយ ទ្រង់ប្រដាប់គ្រឿងអង្ការគ្រប់យ៉ាង មានពួកអាមាត្យចោមរោម បានឈរទតលានព្រះរាជវាំង តាមសីហបញ្ជរដែលបើក ។ គ្រានោះ អ្នកចិញ្ចឹមគោទាំងឡាយ ក៏បើកក្រោលគោ ពួកគោបាចេញអំពីក្រោល ក៏ដេញតាមគោញីមួយ ដោយអំណាចកិលេស ក្នុងចំនួនគោទាំងនោះ គោ

បម្រើមាឌធំមួយមានស្នែងដ៏មុត ឃើញគោជទែកំពុងដើរមក ត្រូវសេចក្តីកំណាញ់ដោយកិលេសគ្របសង្កត់ ទើបយកស្នែងដ៏មុត ឬសត្រង់រវាងជើងពោះវៀនធំទាំងឡាយរបស់គោនោះ ក៏ចេញមកក្រៅតាមមុខរបួស ដល់នូវការអស់ជីវិតក្នុងទីនោះឯង ព្រះរាជាឃើញហេតុការណ៍នោះ ទ្រង់ព្រះតម្រិះថា សត្វលោកទាំងឡាយ តាំងពីសត្វតិរច្ឆានឡើងទៅ ដល់នូវសេចក្តីទុក្ខដោយអំណាចកិលេស គោនេះអាស្រ័យកិលេស ដល់នូវការអស់ជីវិត សត្វដទៃក៏ញាប់ញ័រព្រោះកិលេសទាំងឡាយនោះឯង អញគួរប្រហារកិលេសដែលជាហេតុឲ្យសត្វទាំងឡាយញាប់ញ័រ ។ ទ្រង់ប្រថាប់ឈរនោះឯង កំណត់ត្រៃលក្ខណ៍ ចម្រើនវិបស្សនា ហើយញ៉ាំងបច្ចេកពោធិញ្ញាណឲ្យកើតឡើង ។ អត្ថដ៏សេស ដូចគ្នានឹងរឿងមុននោះឯង ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធទាំងឡាយ ៤ អង្គនោះ កំណត់កាលកិច្ចាចារហើយ ក៏និមន្តចេញអំពីញកភ្នំនន្ទមូលកៈ ទំពានូវឈើស្ទន់ ឈ្មោះនាគលតាត្រង់អនោតត្តស្រះ ជម្រះព្រះកាយហើយ ប្រថាប់ឈរលើផ្ទាំងមនោសិលាស្លៀកស្បង់ ហើយកាន់បាត្រ និងចីវរ ហោះឡើងទៅលើអាកាសដោយឫទ្ធិជាន់ពពកដែលមានពណ៌ ៥ ទៅហើយ ចុះក្នុងទីមិនឆ្ងាយអំពីស្រុកក្បែរទ្វារនគរពារាណសី ដណ្តប់ចីវរត្រង់ទីផាសុកមួយកន្លែង កាន់បាត្រចូលទៅក្នុងស្រុកជិតទ្វារក្រុង ត្រាច់បិណ្ឌបាត ដល់ទ្វារផ្ទះព្រះពោធិសត្វ ។ ព្រះពោធិសត្វឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ត្រេកអរ និមន្តឲ្យចូលទៅក្នុងផ្ទះ ឲ្យគង់លើអាសនៈដែលក្រាលទុក ហើយថ្វាយទក្ខិណោទក អង្គាសដោយរបស់

ទំពារបស់ឆាន់ដ៏ប្រណីត អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ថ្វាយបង្គំព្រះសង្ឃត្ថេរហើយ ទូលសួរថា បពិត្រលោកម្ចាស់ បព្វជ្ជារបស់លោកម្ចាស់ទាំងឡាយ ស្អាតពន់ពេក ឥន្ទ្រិយទាំងឡាយរបស់លោកម្ចាស់ក៏ផូរផង់ ឆវីវណ្ណក៏បរិសុទ្ធ លោកម្ចាស់ឃើញអារម្មណ៍ដូចម្តេចហ្ន៎ ទើបចូលដល់បព្វជ្ជាដោយអំណាចកិច្ចាចារវត្តនេះ និងបានចូលទៅទូលសួរព្រះបច្ចេកពុទ្ធដ៏សេសដូចទូលសួរព្រះសង្ឃត្ថេរ ដូច្នោះ ព្រះបច្ចេកពុទ្ធទាំង ៤ ព្រះអង្គនោះបានត្រាស់ប្រាប់រឿងការចេញបួសរៀងៗខ្លួន ដល់ព្រះពោធិសត្វនោះ ដោយន័យជាដើមថា អាត្មាជាព្រះរាជាឈ្មោះនោះក្នុងនគរឈ្មោះនោះ ក្នុងដែនឈ្មោះនោះ ហើយបានត្រាស់គាថាមួយអង្គមួយគាថាថា

អាត្មាបានឃើញដើមស្វាយ ដុះលូតលាស់ ក្នុងកណ្តាលព្រៃស្វាយ មានពណ៌ខៀវ មានផ្លែ អាត្មាឃើញស្វាយនោះបាក់ខ្ទេចខ្ទីព្រោះហេតុតែផ្លែ លុះឃើញស្វាយនោះហើយទើបអាត្មាប្រព្រឹត្តនូវកិច្ចាចារ ( ទៅបួស ) ។

នាងនារី ( ម្នាក់ ) ពាក់កងជាវិការៈនៃកែវមណី ១ គូដ៏ស្អាតរលោង ដែលជនអ្នកចេះ ធ្វើឲ្យសម្រេចហើយ ឥតឮសូរសំឡេង ( ទង្គិចគ្នាឡើយ ) លុះដល់អាស្រ័យយកមកពាក់ជាមួយគ្នានឹងកងទី ២ ក៏ ( ទង្គិចគ្នា ) ឮសូរសំឡេង អាត្មាបានឃើញនូវកងនោះហើយ ទើបប្រព្រឹត្តនូវកិច្ចាចារ ។

ពួកបក្សីច្រើនចោមរោម ដេញចឹកបក្សី ១ កំពុងពាំដុំសាច់

ព្រោះហេតុតែអាហារ អាត្មាបានឃើញបក្សីនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ។

អាត្មាឃើញគោឧសភ ( មួយ ) កណ្តាលហ្វូង មានបូកជ្រញៗ បរិបូណ៌ដោយសម្បុរនិងកម្លាំង អាត្មាបានឃើញគោឧសភនោះ ត្រូវគោឧសភដទៃបុះមុត ( ព្រោះរឿងយពោះវៀន ) ព្រោះហេតុតែកាម លុះបានឃើញគោឧសភនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អម្ពាហមទ្ទំ** សេចក្តីថា អាត្មាបានឃើញដើមស្វាយហើយ ។ បទថា **វនមន្តរស្មឹ** សេចក្តីថា ក្នុងចន្លោះនៃព្រៃ អធិប្បាយថា កណ្តាលព្រៃស្វាយ ។ បទថា **សំវិរូឡ្ហំ** សេចក្តីថា ចម្រើនល្អហើយ ។ បទថា **តមទ្ទសំ** សេចក្តីថា កាលចេញទៅអំពីព្រះរាជឧទ្យាន អាត្មាបានឃើញស្វាយនោះម្តងទៀត ដែលបាក់ខ្ទេចខ្ទី ព្រោះផ្លែជាហេតុ ។ បទថា **តំ ទិស្វា** សេចក្តីថា កាលឃើញស្វាយនោះបាក់ខ្ទេចខ្ទី ព្រោះផ្លែជាដើមហេតុហើយ អាត្មាបាននូវសេចក្តីសង្វេគ ញ៉ាំងបច្ចេកពោធិញ្ញាណឲ្យកើតឡើង ហើយបានចូលដល់បព្វជ្ជា ដោយអំណាចភិក្ខាចារវត្តនេះ ព្រោះហេតុនោះ ទើបអាត្មាប្រព្រឹត្តភិក្ខាចារវត្ត ។ លោកប្រាប់វារៈចិត្តគ្រប់យ៉ាងនេះតាំងអំពីការឃើញដើមស្វាយទ្រុឌទ្រោមព្រោះផ្លែជាហេតុ ។ ក្នុងពាក្យឆ្លើយរបស់ព្រះបច្ចេកពុទ្ធដ៏សេសក៏ន័យនេះដូចគ្នា ។ តែក្នុងពាក្យឆ្លើយនេះ មានអដ្ឋកថាលម្អិតពាក្យដែលលំបាកដូចតទៅនេះថា បទថា **សេលំ** បានដល់ កងដៃ

កែវមណី ។ បទថា **ឆវិរធិដ្ឋិតំ** សេចក្ដីថា ដែលនរជនដ៏ប្រសើរ គឺជាន ទាំងឡាយច្នៃហើយ អធិប្បាយថា ដែលអ្នកឈ្លាសវៃទាំងឡាយធ្វើហើយ ។ បទថា **យុតំ** បានដល់ កងដៃមួយគូ ដោយធ្វើម្ខាងមួយ ។ បទថា **ធិជា ធិជំ** សេចក្ដីថា បក្សីដ៏សេស ក៏ចោមរោមចឹកបក្សីដែលពាំសាច់ទៅ ។ បទថា **កុណប មាហរន្តំ** សេចក្ដីថា នាំយកដុំសាច់ទៅ ។ បទថា **សមេច្ច** សេចក្ដីថា មករួមគ្នា គឺប្រជុំគ្នា ។ បទថា **បរិធាតយឹសុ** សេចក្ដីថា ដេញតាមចឹកវាយ ។ បទថា **ឧសភាហមទ្ទំ** សេចក្ដីថា អាត្មាបានឃើញគោឧសភ ។ បទថា **វលកត្ថុំ** បានដល់ មានបូកស្អាត ។

ព្រះពោធិសត្វ កាលបានស្ដាប់គាថានីមួយៗ បានធ្វើនូវការសរសើរព្រះបច្ចេកពុទ្ធគ្រប់ព្រះអង្គថា បពិត្រលោកម្ចាស់ ខ្ញុំសូមឱកាស អារម្មណ៍នោះឯងសមសម្រាប់ខ្ញុំដែរ ។ កាលព្រះពោធិសត្វស្ដាប់ធម្មកថា ដែលព្រះបច្ចេកពុទ្ធ ៤ អង្គនោះសម្ដែងហើយ ជាអ្នកមិនជាប់ជំពាក់ក្នុងឃរាវាស កាលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តទៅហើយ បរិភោគអាហារព្រឹកហើយ អង្គុយជាផាសុក បានហៅភរិយាមកពោលថា ព្រះបច្ចេកពុទ្ធ ៤ ព្រះអង្គនេះ លះរាជសម្បត្តិចេញបួស មិនមានកង្វល់ មិនជាប់ចំពាក់ ឲ្យកាលវេលាកន្លងទៅដោយសេចក្ដីសុខដែលកើតអំពីបព្វជ្ជា ឯខ្ញុំចិញ្ចឹមជីវិតដោយថ្ងៃឈ្នួល ប្រយោជន៍អ្វីដោយការគ្រប់គ្រងផ្ទះ ចូរនាងសង្គ្រោះ គឺចិញ្ចឹមកូនក្នុងផ្ទះចុះ ហើយពោលគាថា ២ ថា

ព្រះរាជារបស់អ្នកដែនកលិង្គៈ ព្រះនាមករណ្ឌកៈ ព្រះរាជា

របស់អ្នកដែនគន្ធារៈព្រះនាមនគ្គជិ ព្រះរាជារបស់អ្នកដែនវិ-
ទេហៈព្រះនាមនិមិរាជ ព្រះរាជារបស់អ្នកដែនបញ្ចាលៈព្រះ-
នាមទុម្មុខៈ ព្រះរាជាទាំង ៤ អង្គនុ៎ះ លះបង់នូវដែនទាំងឡាយ
ជាអ្នកឥតកង្វល់បួសហើយ ។

ព្រះរាជាទាំងអស់អង្គនេះប្រហែលគ្នានឹងវិសុទ្ធិទេវតា បាន
មកជួបគ្នាហើយ ព្រះរាជាទាំងនេះ ( រុងរឿងដោយគុណទាំង
ឡាយ មានសីលគុណជាដើម ) ដូចជាភ្លើង ដែលភ្លឺរុងរឿង
ដូច្នោះឯង ម្នាលនាងមានកត្រ្គ ចំណែកខាងបងក៏នឹងលះបង់
នូវកាមទាំងឡាយ ជាចំណែក ដែលខ្ជិនទៀយណាយហើយ
ប្រព្រឹត្តតែម្នាក់ឯង ដូច្នេះ ។

គាថានោះមានសេចក្តីថា នែនាង ព្រះបច្ចេកពុទ្ធដែលជាសង្ឃត្ថេរ ជា
ព្រះរាជានៃជនបទរបស់អ្នកដែនកលិង្គៈ ទ្រង់ព្រះនាមថាករណ្ឌកៈ ក្នុងនគរ
ឈ្មោះថាទន្តបុរៈ អង្គទី ២ ជាព្រះរាជានៃជនបទរបស់អ្នកគន្ធារៈ ទ្រង់ព្រះ
នាមថានគ្គជិ ក្នុងតក្កសិលានគរ អង្គទី ៣ ជាព្រះរាជា នៃជនបទរបស់អ្នក
វិទេហៈព្រះនាមថានិមិរាជ ក្នុងនគរមិថិលា អង្គទី ៤ ជាព្រះរាជានៃជនបទ
របស់អ្នកឧត្តរបញ្ចាលព្រះនាមទុម្មុខៈក្នុងកបិលនគរ ។ ព្រះបច្ចេកពុទ្ធទាំងនោះ
លះបង់ដែនទាំងឡាយបែបនេះហើយ ជាអ្នកមិនមានការជាប់ជំពាក់ ទ្រង់ព្រះ
ផ្នួសហើយ ។ បទថា **សព្វេបិមេ** សេចក្តីថា ព្រះបច្ចេកពុទ្ធទាំងនោះ ជាអ្នក
ស្មើដោយបច្ចេកពុទ្ធទាំងឡាយក្នុងកាលមុន ដែលជាវិសុទ្ធិទេព ទ្រង់យាង

មករួមគ្នាហើយ ។ បទថា **អគ្គិ យថា** សេចក្តីថា ភ្លើងដែលឆេះហើយរមែង រុងរឿងយ៉ាងណា ។ បទថា **តថេវិមេ** សេចក្តីថា ព្រះបច្ចេកពុទ្ធទាំងឡាយ នោះរមែងល្អរុងរឿងដោយគុណទាំងឡាយ មានសីលជាដើម យ៉ាងនោះដូច គ្នា អធិប្បាយថា សូម្បីយើងក៏នឹងបួសត្រាច់ទៅម្នាក់ឯង ដូចព្រះបច្ចេកពុទ្ធ ទាំងនោះ ។ ស្តេចថ្នាំងហៅភរិយាថា **ភគ្គវិ** ម្នាលនាងមានភក្រ្ត ។ បទថា **ហិត្វាន កាមានិ** សេចក្តីថា លះវត្ថុកាមទាំងឡាយ មានរូបជាដើម ។ បទ ថា **យថោធិកានិ** សេចក្តីថា តាំងនៅហើយដោយអំណាចនៃចំណែករបស់ ខ្លួន មានពាក្យអធិប្បាយថា សូម្បីខ្ញុំកាលលះវត្ថុកាមទាំងឡាយ តាមដែល តាំងនៅនោះឯង ដោយអំណាចនៃចំណែក មានរូបជាដើម ហើយនឹងបួស ត្រាច់ទៅម្នាក់ឯង ។ បាឋៈថា **តយោធិកានិ** ដូច្នេះក៏មាន អត្ថនៃបាឋៈនោះ ថា ចំណែកនៃកាមទាំងនោះ ដែលជនទាំងនោះវៀរហើយ គឺវៀរចាកហើយ មាន ហេតុនោះកាមទាំងនោះឈ្មោះថា មានចំណែកដែលជនទាំងនោះវៀរ ហើយ គឺមានចំណែកដែលជនទាំងនោះវៀរចាកហើយ ។ ចាប់តាំងពីពេល ដែលគិតហើយថា ខ្ញុំនឹងបួស ចំណែកមួយនៃកិលេសកាមទាំងឡាយឈ្មោះ ថា ជាវត្ថុដែលវៀរហើយ ។ ចំណែករបស់កាមដែលជាទីតាំងរបស់ជនទាំង នោះដែលរលត់ទៅហើយ ក៏ឈ្មោះថាវៀរហើយដូចគ្នា ។

ភរិយានោះ កាលបានស្តាប់ពាក្យរបស់ព្រះពោធិសត្វនោះហើយ ទើប ពោលថា នៃអ្នក តាំងពីពេលបានស្តាប់ធម្មកថារបស់ព្រះបច្ចេកពុទ្ធហើយ សូម្បីចិត្តខ្ញុំ ក៏មិនស្ថិតនៅក្នុងផ្ទះ ហើយបានពោលគាថានេះថា

កាលនេះជាកាលគួរ ( នឹងបួសហើយ ) ឥតមានកាលដទៃ
ទៀតឡើយ ( ព្រោះ ) ដល់ទៅពេលក្រោយ បុគ្គលជាអ្នក
ប្រៀនប្រដៅខ្ញុំមិនមានទេ បពិត្រអ្នកមានភក្ត្រ ខ្ញុំនឹងប្រព្រឹត្តតែ
ម្នាក់ឯងដូចជាមេបក្សីដែលរួចអំពីដៃនៃបុរស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុសាសិតោ មេ ន ភវេយ្យ បច្ឆា** សេចក្តីថា កិរិយាចង្អុលបង្ហាញថា បុគ្គលប្រៀនប្រដៅ គឺជាស់តឿនគង់មិនមាន ព្រោះបុគ្គលដែលជាស់តឿនរកបានលំបាក ព្រោះហេតុនោះពេលនេះប៉ុណ្ណោះ ជាពេលចេញបួស ពេលដទៃមិនមានឡើយ ។ បទថា **សកុណីវ មុត្តា** សេចក្តីថា កាលបក្សីញីទាំងឡាយត្រូវព្រានចាប់បាន ដាក់ក្នុងទ្រុងរបស់បក្សី បក្សីញីមួយផុតអំពីកណ្តាប់ដៃរបស់ព្រាន បក្សីញីនោះនឹងត្រាច់ទៅតាមអាកាស ទៅកាន់ទីគាប់ចិត្ត ហើយហើរទៅតាមទំនើង យ៉ាងណា សូម្បីខ្ញុំក៏យ៉ាងនោះ ផុតចាកដៃរបស់អ្នកហើយ នឹងត្រាច់ទៅម្នាក់ឯង ព្រោះហេតុនោះ នាងជាអ្នកបំណងនឹងបួសទើបបានពោលយ៉ាងនេះ ។

ព្រះពោធិសត្វ កាលបានស្តាប់ពាក្យរបស់នាងហើយ បាននៅស្ងៀម ។ ឯនាងបំណងនឹងបញ្ឆោតព្រះពោធិសត្វ ហើយបួសមុន ទើបពោលថា នែអ្នក ខ្ញុំនឹងទៅកំពង់ទឹក សូមអ្នកមើលកូន ហើយកាន់យកក្អមទឹក ធ្វើអាកប្បកិរិយាដូចជាដើរទៅកំពង់ទឹក ហើយគេចទៅ ដល់សម្នាក់របស់ពួកតាបសដែលនៅជិតនគរហើយក៏បួស ។ ព្រះពោធិសត្វជ្រាបថា នាងមិនមក ទើបចិញ្ចឹមកូនដោយខ្លួនឯង លុះក្មេងនោះធំបន្តិច ដល់នូវភាពជាអ្នកអាចដឹងនូវសេចក្តី

ចម្រើននិងសេចក្តីវិនាសរបស់ខ្លួន គឺដឹងក្តីហើយ កាលទីងល្បងក្មេងទាំងនោះ ថ្ងៃមួយ ព្រះពោធិសត្វកាលដាំបាយ បានដាំឲ្យឆៅបន្តិច ថ្ងៃមួយជ្រាយបន្តិច ថ្ងៃមួយខ្លោច ថ្ងៃមួយចម្អិនអាហារសាប ថ្ងៃមួយចម្អិនឲ្យប្រៃ ក្មេងទាំងឡាយ ពោលថា ថ្ងៃនេះបាយឆៅ ថ្ងៃនេះបាយជ្រាយ ថ្ងៃនេះបាយខ្លោច ថ្ងៃនេះសាប ថ្ងៃនេះប្រៃ ។ ព្រះពោធិសត្វពោលថា អើកូន ថ្ងៃនេះបាយឆៅ ហើយគិតថា ឥឡូវនេះ ក្មេងទាំងនេះស្គាល់ឆៅ ឆ្អិន សាបនិងប្រៃហើយ អាចចិញ្ចឹមជីវិត តាមធម្មតារបស់ខ្លួន អញគួរនឹងបួស ។ ក្រោយមក បានទុកដាក់ក្មេងនោះ ឲ្យពួកញាតិពោលថា នែអ្នក និងនាង ចូរចិញ្ចឹមក្មេងនេះឲ្យល្អចុះ កាលពួកញាតិកំពុងកុកកួលនោះឯង បានចេញអំពីព្រះនគរទៅបួសជាឥសីនៅក្បែរៗ ព្រះនគរនោះឯង ។ ថ្ងៃមួយ នាងបរិព្វាជិកា គឺកិរិយាចាស់ បានឃើញព្រះពោធិសត្វ កំពុងត្រាច់ទៅបិណ្ឌបាតក្នុងនគរពារាណសី ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ឲ្យក្មេង គឺកូនទាំងឡាយវិនាសហើយ ។ ព្រះមហាសត្វឆ្លើយថា យើងមិនបានឲ្យក្មេង គឺកូនវិនាសឡើយ ចេញបួសក្នុងពេលដែលពួកក្មេងទាំងនោះអាចដឹងសេចក្តីចម្រើន និងសេចក្តីវិនាស គឺដឹងល្អដឹងអាក្រក់របស់ខ្លួនហើយ នាងកុំគិតដល់ពួកគេឡើយ ចូរត្រេកអរក្នុងការបួសចុះ ហើយបានពោលគាថាចុងក្រោយថា

( ទារកទាំងឡាយនោះ ) ស្គាល់បាយឆៅ បាយឆ្អិន ទាំង
ស្គាល់បាយប្រៃនិងបាយសាបហើយ លុះយើងឃើញកិរិយា
របស់ទារកនោះហើយ ទើបបួស នាងចូរប្រព្រឹត្តស្វែងរកនូវ

ភិក្ខាចារចុះ យើងក៏នឹងប្រព្រឹត្តស្វែងរកនូវភិក្ខាចារដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមហំ** សេចក្តីថា ខ្ញុំឃើញកិរិយានៃទារកទាំងនោះហើយ ទើបបួស ។ បទថា **ចរេវ តុំ ចរាមិហំ** សេចក្តីថា សូម្បីនាង ក៏ចូរត្រាច់ទៅដើម្បីភិក្ខាចារចុះ ខ្ញុំនឹងត្រាច់ទៅដើម្បីភិក្ខាចារដែរ ។

ព្រះពោធិសត្វដាស់តឿនបរិព្វាជិកាដោយប្រការដូច្នេះហើយ ក៏បញ្ជូននាងទៅ ឯបរិព្វាជិកាទទួលឱវាទ ថ្វាយបង្គំព្រះមហាសត្វហើយ ទើបទៅកាន់ទីតាមគាប់ចិត្ត ។ បានឮថា ក្រោយអំពីថ្ងៃនោះហើយ ជនទាំង ២ នោះ ក៏មិនបានជួបគ្នាទៀតឡើយ ។ ព្រះពោធិសត្វ ឲ្យឈាននិងអភិញ្ញាកើតឡើងហើយ បានជាអ្នកចូលដល់ព្រហ្មលោក ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បានប្រកាសសច្ចទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុ ៥០០ រូបតាំងនៅហើយក្នុងអរហត្តផល ហើយទ្រង់ប្រជុំជាតកថា កូនស្រីក្នុងកាលនោះបានមកជាឧប្បលវណ្ណាថេរីក្នុងកាលឥឡូវនេះ កូនប្រុសក្នុងកាលនោះបានមកជារាហុល បរិព្វាជិកាក្នុងកាលនោះបានមកជារាហុលមាតា ឯបរិព្វាជកក្នុងកាលនោះគឺតថាគតនេះឯង ។

**អដ្ឋកថា កុម្ភការជាត ចប់**

# ធម្មទ្ធជជាតក

[ ៣៦៣ ] ( មេដំរីឈ្មោះឌិដ្ឋិព្យាធិបានពោលនឹងអាមាត្យពោធិសត្វថា ) ខ្ញុំកាលនាំទៅ ( នូវកិច្ច ) របស់ព្រះបាទទទ្ធធម្មៈ នាំទៅនូវសារ ( ដែលគេចង ) ត្រង់ទ្រូងហើយត្រាច់ទៅ ក្នុងទីចម្បាំងដោយសេចក្តីប្រឹងប្រែង ក៏គង់ញុំាងព្រះអង្គឲ្យសព្វព្រះរាជហឫទ័យមិនបាន ។

[ ៣៦៤ ] ព្រះរាជាមិនជ្រាបនូវសេចក្តីប្រឹងប្រែងរបស់បុរស ដែលខ្ញុំបានធ្វើដោយពិត ទាំងការនាំសំបុត្រចុះឡើងក្នុងសង្គ្រាម ក៏ខ្ញុំបានធ្វើល្អហើយ ។

[ ៣៦៥ ] ខ្ញុំនោះជាអ្នកឥតផៅពង្ស ឥតទីពុំនាក់ មុខជានឹងស្លាប់មិនខាន ព្រោះក្នុងពេលនោះ ព្រះរាជាបានទ្រង់ប្រទានខ្ញុំឲ្យជាអ្នកនាំនូវអាចម៍គោដល់សួនច្បាំង ។

[ ៣៦៦ ] ( ពោធិសត្វទូលព្រះរាជាថា ) បុរសប្រាថ្នា ( ប្រយោជន៍ ) ដរាបណារមែងគប់រក ( នឹងគេ ) ដរាបនោះ ជនទាំងឡាយរមែងលះបង់ចោលគេ ក្នុងពេលដែលគេសាបសូន្យចាកសេចក្តីចម្រើនដូចជាក្សត្រ ( លះបង់ចោល ) នូវមេដំរីឈ្មោះឌិដ្ឋិព្យាធិនោះ ។

[ ៣៦៧ ] បុគ្គលណានីកមិនឃើញនូវអំពើល្អដែលអ្នកដទៃធ្វើហើយ និងប្រយោជន៍ដែលអ្នកដទៃធ្វើហើយ ( ដល់ខ្លួន ) ក្នុងកាលមុន ប្រយោជន៍ទាំងឡាយដែលបុគ្គលនោះប្រាថ្នា រមែងសាបសូន្យ ។

[ ៣៦៨ ] បុគ្គលណានឹកឃើញនូវអំពើល្អដែលអ្នកដទៃធ្វើហើយ និងប្រយោជន៍ដែលអ្នកដទៃធ្វើហើយ ( ដល់ខ្លួន ) ក្នុងកាលមុន ប្រយោជន៍ទាំងឡាយណាដែលបុគ្គលនោះប្រាថ្នាហើយ រមែងចម្រើន ។

[ ៣៦៩ ] ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នកទាំងឡាយ សូមសេចក្តីចម្រើន ( កើតមាន ) ដល់អ្នកទាំងឡាយដែលបាន អញ្ជើញមកជួបជុំក្នុងទីនេះទាំងអម្បាលមាណ អ្នកទាំងអស់គ្នា ចូរជាអ្នកដឹងនូវឧបការៈដែលអ្នកដទៃបានធ្វើហើយ ( ដល់ខ្លួន ) អ្នកទាំងឡាយនឹងបានឋិតនៅក្នុងឋានសួគ៌អស់កាលយូរ ។

**ចប់ ទទ្ទរជាតកទី ៤ ។**

## អដ្ឋកថា

## ទទ្ទរជាតក

[ ៣៦៣-៣៦៩ ] ព្រះសាស្តា ទ្រង់ចូលទៅអាស្រ័យនគរកោសម្ពី គង់នៅក្នុងឃោសិតារាម ទ្រង់ប្រារព្ធដំរីញីឈ្មោះ ភទ្ទវតី របស់ព្រះបាទឧទេន ហើយទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អហាតុ ទទ្ទរស្ស** ដូច្នេះជាដើម ។

ចំណែកវិធីដែលព្រះបាទឧទេន ទ្រង់បានដំរីញីនេះក្តី វង្សរបស់ព្រះបាទឧទេនក្តី មានច្បាស់ក្នុងមាតង្គជាតក ។

ថ្ងៃមួយ ដំរីញីដើរចេញអំពីព្រះនគរទៅ បានឃើញព្រះមានព្រះភាគមានពួកព្រះអរិយៈចោមរោម យាងចូលទៅក្នុងព្រះនគរ ដោយពុទ្ធសិរីមិនមានអ្វីប្រៀប ដើម្បីបិណ្ឌបាតអំពីព្រលឹម ទើបក្រាបចុះទៀបបាទមូលរបស់ព្រះសម្ពុទ្ធ ទូលសូមព្រះមានព្រះភាគដោយក្តុកក្តួលថា បពិត្រព្រះដ៏មានព្រះភាគ

ដ៏ជាសព្វញ្ញូ សូមទ្រង់ជួយស្រោចស្រង់សត្វលោកទាំងមូល ព្រះបាទឧទេន ទ្រង់សព្វព្រះហឫទ័យខ្ញុំ ក្នុងកាលដែលខ្ញុំនៅក្មេង ក្នុងកាលដែលខ្ញុំអាចជួយរាជការបាន ទ្រង់ឃើញថា ខ្លួនឯងបាននូវជីវិត បាននូវរាជសម្បត្តិនិងព្រះរាជទេវីមក ដោយអាស្រ័យខ្ញុំ ទើបព្រះរាជទានការចិញ្ចឹមជាច្រើន ទ្រង់តាក់តែងទីលំនៅ ប្រដាប់ដោយគ្រឿងអលង្ការទាំងឡាយ ឲ្យគេធ្វើការប្រោះព្រំដោយគ្រឿងក្រអូប ទ្រង់បានចងពិតាន ដែលលម្អដោយផ្កាយមាសទុកខាងលើ ឲ្យបាំងរាំងននដ៏វិចិត្រទុកដោយជុំវិញ ឲ្យអុជប្រទីបដោយប្រេងលាយដោយគ្រឿងក្រអូប ដាក់ថាំងបំពក់ផ្សែង ដាក់ថាំងមាសទុកក្នុងទីសម្រាប់បន្ទោបង់ ឲ្យខ្ញុំឈរលើទែនដែលមានកម្រាលដ៏វិចិត្រ និងបានព្រះរាជទានគ្រឿងបរិភោគមានរសដ៏ប្រសើរច្រើនប្រភេទដល់ខ្ញុំ ។ ឥឡូវនេះ ជាពេលដែលខ្ញុំមិនអាចជួយរាជការបានទេ គឺពេលដែលខ្ញុំចាស់ជរា ព្រះរាជាផ្តាច់ការទំនុកបម្រុងសព្វយ៉ាង ខ្ញុំមិនមានទីពឹង ជាសត្វមិនមានបច្ច័យគ្រឿងអាស្រ័យរកស៊ីនូវស្មឹករំបេកក្នុងព្រៃចិញ្ចឹមជីវិត ខ្ញុំមិនមានទីពឹងដទៃ បពិត្រព្រះមានព្រះភាគ សូមទ្រង់ឲ្យព្រះបាទឧទេននឹកដល់គុណ គឺសេចក្តីល្អរបស់ខ្ញុំ ហើយធ្វើការទំនុកបម្រុងដូចមុនជាប្រក្រតីដល់ខ្ញុំ ។ ព្រះសាស្តាត្រាស់ថា ម្នាលដំរី អ្នកទៅចុះ តថាគតនឹងទូលព្រះរាជា ហើយនឹងតែងតាំងយសឲ្យត្រឡប់ជាប្រក្រតី ហើយបានទៅកាន់ទ្វារព្រះរាជនិវេសន៍ ។ ព្រះរាជាយាងព្រះតថាគតចូលទៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គហើយ បានថ្វាយមហាទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនាក្នុងកាល

ស្រេចកត្តកិច្ចហើយ បានត្រាស់សួរថា មហាបពិត្រ ដំរីកន្ទវតីនៅឯណាព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានដឹងទេ ។ ព្រះសាស្តាត្រាស់ដល់គុណរបស់ដំរីញីកន្ទវតីថា មហាបពិត្រ ឈ្មោះថា ការប្រទានយសដល់អ្នកមានឧបការគុណ ហើយបោះបង់ក្នុងកាលឯចាស់រមែងមិនគួរ គួរជាបុគ្គលមានកតញ្ញូកតវេទី ។ ដំរីកន្ទវតីឥឡូវនេះ ចាស់ទ្រុឌទ្រោមច្រើន ជាសត្វអនាថា ដើរស៊ីដើមរំពេកក្នុងព្រៃកំដរជីវិត ការធ្វើឲ្យដំរីនេះអស់ទីពឹងក្នុងកាលឯចាស់មិនសមគួរដល់ទ្រង់ឡើយ សូមទ្រង់ទំនុកបម្រុងដូចមុនគ្រប់យ៉ាងឲ្យជាប្រក្រតីចុះ ដូច្នេះហើយ ទើបយាងចៀសចេញទៅ ។ ព្រះរាជាទ្រង់បានធ្វើយ៉ាងនោះ សំឡេងសាធុការបានផ្សាយទៅពេញព្រះនគរថា បានឮថា ព្រះតថាគតត្រាស់ដល់គុណរបស់ដំរីកន្ទវតី ហើយទ្រង់ឲ្យព្រះរាជាតែងតាំងយសចាស់ឲ្យត្រឡប់ជាប្រក្រតី ការប្រព្រឹត្តទៅនោះ ប្រាកដហើយក្នុងជំនុំសង្ឃ ។ ភិក្ខុទាំងឡាយ នាំគ្នាសន្ទនាក្នុងធម្មសភាថា អាវុសោ បានឮថា ព្រះសាស្តាត្រាស់ដល់គុណរបស់ដំរីញីកន្ទវតី ហើយទ្រង់ឲ្យព្រះបាទឧទេនតែងតាំងយសចាស់ជាប្រក្រតីវិញ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នា ដោយរឿងអ្វីកាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ពោលដល់គុណរបស់ដំរីកន្ទវតីនេះ ឲ្យព្រះរាជាទ្រង់តែងតាំងយសតាមប្រក្រតីដូចគ្នា ហើយទ្រង់បាននាំយករឿងក្នុងអតីត មក

សាធក:ដូចតទៅនេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមថាទឡ្ហធម្ម សោយរាជសម្បត្តិក្នុងនគរពារាណសី កាលនោះព្រះពោធិសត្វកើតក្នុងត្រកូលអាមាត្យ ធំចម្រើនវ័យហើយ បានជាមហាតលិកនៃព្រះរាជាអង្គនោះ ។ ព្រះពោធិសត្វបាននូវយសធំតាំងនៅក្នុងតំណែងរតនអាមាត្យអំពីរាជសម្នាក់នោះ ។ កាលនោះ ព្រះរាជាអង្គនោះ មានដំរីញីមួយឈ្មោះឱដ្ឋិព្យាធិ ជាសត្វមានកម្លាំងច្រើន មួយថ្ងៃដើរបាន ១០០ យោជន៍ ។ មាននាទីជាទូតនាំរបស់របរដែលបញ្ជូនទៅថ្វាយព្រះរាជា គឺបញ្ជូនសួយសារអាករ ។ ក្នុងសង្គ្រាមដែលច្បាំងដោយដំរី ដំរីនេះបានធ្វើការញាំញីសត្រូវ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ដំរីនេះមានឧបការៈច្រើនដល់អញ ទើបព្រះរាជទានគ្រឿងអលង្ការ គឺអាភរណៈគ្រប់យ៉ាងដល់ដំរីញីនោះ ហើយបានព្រះរាជទាននូវការទំនុកបម្រុងសព្វយ៉ាង ដូចព្រះបាទឧទេនព្រះរាជទានដល់ដំរីញីភទ្ទវតីដូច្នោះ ។ ក្រោយមក ក្នុងកាលដំរីញីឱដ្ឋិព្យាធិនោះ ចាស់ហើយ អស់នូវកម្លាំង ទ្រង់ដកនូវយសទាំងឡាយចេញ ។ ក្រោយមក ដំរីញីក៏ក្លាយជាសត្វអនាថា រកស៊ីស្មៅនិងស្លឹកឈើក្នុងព្រៃកំដរជីវិត ។ ថ្ងៃមួយ កាលភាជនៈក្នុងរាជត្រកូល ប្រើមិនគ្រប់គ្រាន់ ទើបព្រះរាជាឲ្យហៅស្មូនឆ្នាំងចូលគាល់ ហើយត្រាស់ថា បានឮថាភាជនៈមិនគ្រប់គ្រាន់សម្រាប់ប្រើ ទើបស្មូនឆ្នាំងទូលថា បពិត្រព្រះសម្មតិទេពទូលព្រះបង្គំរកគោទឹមរទេះ ដឹកគោម័យមិនបាន ។ ព្រះរាជាទ្រង់ស្តាប់ពាក្យស្មូនឆ្នាំងហើយ ទើបត្រាស់សួរថា ដំរីញីឱដ្ឋិព្យាធិរបស់យើងនៅឯណា ទើប

អាមាត្យក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន គ្រាច់ទៅតាមជម្មតារបស់ខ្លួន ។ ព្រះរាជាបានប្រទានដំរីញីនោះ ដល់សូនធ្នាំង ដោយព្រះតម្រាស់ថា ចាប់អំពីនេះទៅ ចូរអ្នកយកដំរីញីនោះដឹកគោម័យចុះ ។ សូនធ្នាំងទទួលព្រះតម្រាស់ថា សាធុ ហើយបានធ្វើយ៉ាងនោះ ។ ថ្ងៃមួយ ដំរីចេញអំពីព្រះនគរ ជួបនឹងព្រះពោធិសត្វ កំពុងចូលព្រះនគរ ហើយក្រាបទៀបជើងរបស់លោក ក្តុកក្តួលពោលថា បពិត្រលោកម្ចាស់ ព្រះរាជាទ្រង់កំណត់ដឹងខ្ញុំថា មានឧបការៈច្រើនក្នុងកាលដែលខ្ញុំនៅក្មេង បានព្រះរាជទាននូវយស តែឥឡូវនេះ កាលខ្ញុំចាស់ ទ្រង់ដកយសគ្រប់យ៉ាង មិនធ្វើសូម្បីត្រឹមតែការគិតដល់ ខ្ញុំមិនមានទីពឹង ទើបដើរស៊ីស្មៅនិងស្លឹកឈើកំដរជីវិត ឥឡូវនេះ បានព្រះរាជទានខ្ញុំដែលធ្លាក់ខ្លួនយ៉ាងនេះឲ្យទៅសូនធ្នាំង ដើម្បីអូសយានតូច វៀរលោកហើយ អ្នកដទៃជាទីពឹងរបស់ខ្ញុំមិនមានទេ លោកដឹងឧបការៈដែលខ្ញុំធ្វើដល់ព្រះរាជាហើយ សូមលោកមេត្តាធ្វើយសរបស់ខ្ញុំដែលវិនាសទៅហើយឲ្យបានមកវិញតាមប្រក្រតីផងចុះ ហើយបានពោលគាថា ៣ ថា

ខ្ញុំកាលនាំទៅ ( នូវកិច្ច ) របស់ព្រះបាទទឡ្ហធម្មៈ នាំទៅ
នូវសរ ( ដែលគេចង ) ត្រង់ទ្រូង ហើយត្រាច់ទៅក្នុងទី
ចម្បាំងដោយសេចក្តីប្រឹងប្រែង ក៏គង់ញុំាងព្រះអង្គឲ្យសព្វព្រះ
រាជហឫទ័យមិនបាន ។

ព្រះរាជាមិនជ្រាបនូវសេចក្តីប្រឹងប្រែងរបស់បុរស ដែលខ្ញុំ
បានធ្វើដោយពិត ទាំងការនាំសំបុត្រចុះឡើងក្នុងសង្គ្រាម ក៏ខ្ញុំ

បានធ្វើល្អហើយ ។

ខ្ញុំនោះជាអ្នកឥតផៅពង្ស ឥតទីពុំនាក់ មុខជានឹងស្លាប់មិនខាន ព្រោះក្នុងពេលនោះ ព្រះរាជាបានទ្រង់ប្រទានខ្ញុំឲ្យជាអ្នកនាំនូវអាចម៍គោដល់ស្មូនឆ្នាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វហាន្តិ** សេចក្តីថា នាំ គឺជួយឲ្យសម្រេចការនាំកិច្ចទៅ គឺទម្លាយកម្លាំងសត្រូវក្នុងសង្គ្រាម បានដល់រាជកិច្ចនោះៗ ។ បទថា **ធុរន្តិ ឱរសិ សល្លំ** សេចក្តីថា នាំជាវឬលំពែងដែលចង្រត់ទ្រូងទៅញាំញីសត្រូវទាំងឡាយក្នុងពេលច្បាំង ។ បទថា **វិក្កន្តចារិនី** សេចក្តីថាដល់នូវសេចក្តីក្លាហានក្នុងការច្បាំងជាប្រក្រតី ដោយការធ្វើសេចក្តីក្លាហានហើយផ្ចាញ់កម្លាំងរបស់បរបក្ខ មានពាក្យអធិប្បាយថា បពិត្រលោកម្ចាស់ ខ្ញុំធ្វើរាជកិច្ចនេះ ក៏មិនញុំាំងព្រះរាជហឫទ័យរបស់ព្រះបាទទទ្ឋធម្មៈ ឲ្យត្រេកអរបាន គឺមិនឲ្យព្រះអង្គពេញព្រះរាជហឫទ័យហើយសោត ឥឡូវនេះ អ្នកដទៃណានឹងញុំាំងព្រះរាជហឫទ័យរបស់ទ្រង់ឲ្យត្រេកអរ ។ បទថា **មម វិក្កមពោរិសំ** បានដល់ សេចក្តីព្យាយាមរបស់បុរសដែលខ្ញុំបានធ្វើហើយ ។ បទថា **សុកតន្តានិ** សេចក្តីថា ធ្វើរៀបរយហើយ ។ ក្នុងថ្ងៃនេះ រាជកិច្ចទាំងឡាយរៀបរយហើយនោះឯង ហៅថា **សុកតន្តានិ** គឺធ្វើល្អហើយ ដូចពាក្យថា ការងារនោះឯងហៅថា **កម្មានេវ កម្មន្តានិ** និងដូចព្រៃនោះឯង ហៅថា **វនានេវ វនន្តានិ** ។ បទថា **ទូតវិប្បហិតានិ ច** សេចក្តីថា ការបញ្ជូនសាសន៍ដែលខ្ញុំជាបុគ្គលត្រូវគេចងរាជសាសន៍ត្រង់កហើយ បញ្ជូនទៅដោយប្រាប់ថា ចូរ

ថ្វាយដល់ព្រះរាជាឈ្មោះនោះ ហើយដើរទៅម្នាក់ឯងប៉ុណ្ណោះ ក្នុងមួយថ្ងៃ ១០០ រយយោជន៍ ។ បទថា **ឆ្វន រាជា ន ជានាតិ** សេចក្តីថា ព្រះរាជានោះ មិនជ្រាបរាជកិច្ចទាំងឡាយនោះ ដែលខ្ញុំធ្វើថ្វាយទ្រង់ពិតប្រាកដ ។ បទថា **អបរាយិនី** សេចក្តីថា មិនមានទីពឹងទីអាស្រ័យ ។ បទថា **តទាហិ** កែជា **តថា ហិ** ។ ម្យ៉ាងទៀត បាឋៈថា **តថាហិ** នេះ ក៏ដូចគ្នា ។ បទថា **ធិន្នា** សេចក្តីថា ព្រោះខ្ញុំជាបុគ្គលដែលព្រះរាជាព្រះរាជទាន ដល់ស្មូនឆ្នាំង ធ្វើជាអ្នកជញ្ជូនអាចម៍សត្វហើយ ។

ព្រះពោធិសត្វ ស្តាប់ពាក្យរបស់មេដំរីនោះហើយ ទើបលួងលោមថា នាងកុំសោកថ្វីឡើយ ខ្ញុំនឹងទូលព្រះរាជា ហើយឲ្យព្រះរាជទានយសតាមប្រក្រតី ហើយចូលទៅកាន់ព្រះនគរទទួលទានអាហារព្រឹកហើយ ទៅកាន់រាជសម្នាក់ លើករឿងនេះឡើងទូលសួរព្រះរាជាថា បពិត្រមហារាជ ទ្រង់មានមេដំរីឈ្មោះឱដ្ឋិព្យាធិមិនមែនឬ ដំរីនេះ ត្រូវចងលំពែងទុកត្រង់ទ្រូងហើយចូលក្នុងសង្គ្រាម ក្នុងទីឈ្មោះនោះនិងទីឈ្មោះនោះ ថ្ងៃនោះ ត្រូវចងរាជសាសន៍ គឺសារត្រង់ក ហើយបញ្ជូនទៅ បានធ្វើដំណើរទៅរាប់រយយោជន៍ ឯទ្រង់ក៏បានព្រះរាជទានយសធំដល់ដំរីនេះ ឥឡូវនេះ ដំរីនោះនៅឯណា ព្រះរាជាត្រាស់ឆ្លើយថាយើងបានឲ្យដល់ស្មូនឆ្នាំងដើម្បីដឹកគោម័យហើយ ។ លំដាប់នោះ ទើបព្រះពោធិសត្វទូលព្រះរាជាថា បពិត្រមហារាជ ការដែលព្រះអង្គព្រះរាជទានដំរីដល់ស្មូនឆ្នាំងដើម្បីឲ្យអូសរទេះ មិនសមគួរឡើយ ហើយបានពោលគាថា ៤ ថ្វាយដល់ព្រះរាជាថា

បុរសប្រាថ្នា ( ប្រយោជន៍ ) ដរាបណា រមែងគប់រក ( នឹងគេ ) ដរាបនោះ ជនទាំងឡាយរមែងលះបង់ចោលគេ ក្នុងពេលដែលគេសាបសូន្យចាកសេចក្តីចម្រើនដូចជាក្សត្រ ( លះបង់ចោល ) នូវមេដំរីឈ្មោះឱដ្ឋិព្យាធិនោះ ។

បុគ្គលណា នឹកមិនឃើញនូវអំពើល្អដែលអ្នកដទៃធ្វើហើយនិងប្រយោជន៍ដែលអ្នកដទៃធ្វើហើយ ( ដល់ខ្លួន ) ក្នុងកាលមុន ប្រយោជន៍ទាំងឡាយ ដែលបុគ្គលនោះប្រាថ្នារមែងសាបសូន្យ ។

បុគ្គលណានឹកឃើញនូវអំពើល្អ ដែលអ្នកដទៃធ្វើហើយនិងប្រយោជន៍ដែលអ្នកដទៃធ្វើហើយ ( ដល់ខ្លួន ) ក្នុងកាលមុន ប្រយោជន៍ទាំងឡាយណាដែលបុគ្គលនោះប្រាថ្នាហើយ រមែងចម្រើន ។

ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នកទាំងឡាយ សូមសេចក្តីចម្រើន ( កើតមាន ) ដល់អ្នកទាំងឡាយដែលបានអញ្ជើញមកជួបជុំក្នុងទីនេះ ទាំងអម្បាលមាណ អ្នកទាំងអស់គ្នាចូរជាអ្នកដឹងនូវឧបការៈដែលអ្នកដទៃបានធ្វើហើយ ( ដល់ខ្លួន ) អ្នកទាំងឡាយ នឹងបានឋិតនៅក្នុងឋានសួគ៌អស់កាលយូរ ដូច្នេះ ។

បណ្តាគាថាទាំងនោះ គាថាទី ១ មានអត្ថថា បុគ្គលខ្លះក្នុងលោកនេះ

ជាអ្នកមិនដឹងគុណ ប្រាថ្នាប្រយោជន៍ដរាបណា បុគ្គលនោះ ប្រាថ្នាថាបុគ្គលនេះអាចធ្វើវត្ថុនេះដល់អញ ដរាបនោះ បុគ្គលនោះ នៅគប់រកជាមួយបុគ្គលនោះ តែក្នុងវេលាណាបុគ្គលនោះ មិនមានប្រយោជន៍ហើយ គឺក្នុងពេលមិនដល់នូវសេចក្តីចម្រើនហើយ បានដល់ ពេលវិនាសហើយ បុគ្គលល្ងង់ខ្លៅពួកខ្លះ ក៏នឹងលះបង់បុគ្គលនោះ ៗ តាំងនៅហើយក្នុងកិច្ចច្រើនប្រភេទ ដូចខត្តិយរាជអង្គនេះ ទ្រង់លះបង់នូវដំរីឧឌ្ឌិព្យាធិនេះ ដូច្នោះ ។ បទថា **កត-កល្យាណោ** សេចក្តីថា ដែលមានកល្យាណធម៌ដែលអ្នកធ្វើហើយដល់ខ្លួន ។ បទថា **កតត្ថោ** សេចក្តីថា ជាអ្នកសម្រេចកិច្ចហើយ ។ បទថា **ឆាវពុជ្ឈតិ** សេចក្តីថា មិនរឭកដល់ឧបការៈនោះដែលអ្នកដទៃធ្វើហើយ ក្នុងកាលដែលដំរីនោះចាស់ហើយ គឺពេលដែលអស់សមត្ថភាព រមែងដកយស ដែលខ្លួនឲ្យហើយមកវិញ ។ បទថា **បលុជ្ជន្តិ** សេចក្តីថា សាបសូន្យទៅ គឺវិនាសទៅ ។ ដោយបទថា **យេ ហោន្តិ អភិបត្ថិតា** ព្រះពោធិសត្វ សម្តែងថា ប្រយោជន៍ខ្លះ ដែលឈ្មោះថា បុគ្គលនោះប្រាថ្នាហើយ នឹងវិនាសទាំងអស់ព្រោះថា ការប្រាថ្នានោះរបស់បុគ្គលទ្រុស្តមិត្តនឹងវិនាសទៅ ដូចពូជដែលដាក់ក្នុងភ្លើងដូច្នោះ ។ បទថា **កតត្ថោ មនុពុជ្ឈតិ** លោកប្រើ **ម** អក្ខរៈ ជាព្យញ្ជនៈសន្ធិ ។ បទថា **តំ វោ វទាមិ** សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំពោលនឹងអ្នកទាំងឡាយ ។ បទថា **ឋស្សថ** សេចក្តីថា អ្នកទាំងឡាយជាកតញ្ញូបុគ្គលនឹងសោយទិព្វសម្បត្តិស្ថិតនៅក្នុងស្ថានសួគ៌អស់កាលយូរៗព្រះមហាសត្វបានឲ្យឱវាទដល់មនុស្សទាំងអស់ តាំងអំពីព្រះរាជាដែលមកប្រជុំ

គ្នាហើយ ដោយប្រការយ៉ាងនេះ ។ ព្រះរាជាទ្រង់ស្តាប់ឱវាទនោះហើយ ទ្រង់បានតែងតាំងយសឲ្យដំរីញីឱដ្ឋិព្យាធិដូចមុន ។ ព្រះរាជា តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វហើយ ទ្រង់បំពេញបុណ្យមានទានជាដើមអស់កាលយូរ ហើយមានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រជុំជាតកថា ដំរីញីឈ្មោះឱដ្ឋិព្យាធិក្នុងកាលនោះ បានមកជាដំរីញីកទូវតីក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ឯអាមាត្យក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ទឡ្ហធម្មជាតក ចប់

# សោមទត្តជាតក

[ ៣៧០ ] ( តាបសយំទួញរកដំរីថា ) កាលពីមុនដំរីណា មកអំពីចម្ងាយទទួលអាត្មាអញក្នុងព្រៃ ( ឥឡូវនេះ ) ដំរីឈ្មោះ សោមទត្តនោះទៅក្នុងទីណា បានជាបាត់មិនឃើញមក ។

[ ៣៧១ ] ( តាបសនោះឃើញដំរីនោះដួលស្លាប់ហើយពោលថា ) ដំរីដេកស្លាប់នេះគឺដំរីនេះឯង ដំរីសោមទត្តដួលដេកលើផែនដី ដូចជាត្រួយជ្រៃដែលបុគ្គលក្តិចហើយ ដំរី ( នោះ ) មិនទាន់ស្លាប់ទេហ្ន៎ ។

[ ៣៧២ ] ( ខណៈនោះសក្កទេវរាជពោលថា ) លោកសោកស្តាយដំរីណាដែលស្លាប់បាត់ទៅហើយ ការសោកស្តាយដំរីនោះ មិនសមគួរដល់លោកដែលចូលមកកាន់ផ្នួសជាសមណៈ មានចិត្តរួចស្រឡះសោះឡើយ ។

[ ៣៧៣ ] ( តាបសពោលថា ) បពិត្រសក្កៈ សេចក្តីស្រឡាញ់រមែងកើតក្នុងហឫទ័យរបស់មនុស្សក្តី ម្រឹគក្តី ដោយសារធ្លាប់នៅជាមួយគ្នា អាត្មាមិនអាចមិនសោកស្តាយដំរីនោះបានឡើយ ។

[ ៣៧៤ ] ( សក្កទេវរាជពោលថា ) សត្វទាំងឡាយណាយំទួញរៀបរាប់ សត្វទាំងឡាយនោះតែងយំរកសត្វដែលស្លាប់បាត់ទៅហើយ ឬក៏សត្វដែលបម្រុងនឹងស្លាប់ នៃឥសីព្រោះហេតុនោះ លោកកុំយំឡើយពួកសប្បុរសពោលថាការយំជាធម្មជាតឥតអំពើទេ ។

[ ៣៧៥ ] បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់ទៅកាន់បរលោកហើយគប្បីរស់ឡើងវិញដោយការយំទួញ ពួកយើងទាំងអស់ក៏គួរប្រជុំគ្នាយំរកពួកញាតិនៃគ្នានឹងគ្នាដែរ ។

[ ៣៧៦ ] ( តាបសពោលថា ) អ្នកបានស្រោចខ្ញុំដែលត្រូវភ្លើងគឺសេចក្ដីសោកកំពុងឆេះសព្វ ឲ្យត្រជាក់ត្រជុំ រំលត់នូវក្រវល់ក្រវាយទាំងអស់បាន ដូចជាបុគ្គលយកទឹកស្រោចលត់នូវភ្លើង ដែលកំពុងឆេះនូវផ្ទាំងខ្លាញ់ ។ អ្នកបានបន្ទោបង់សេចក្ដីសោក ព្រោះកូនរបស់ខ្ញុំដែលត្រូវសេចក្ដីសោកកំពុងគ្របសង្កត់ ឈ្មោះថាបានដកចោលនូវសរ គឺសេចក្ដីសោកដែលអាស្រ័យនៅក្នុងហឫទ័យនៃខ្ញុំបាន ។ បពិត្រវាសវៈ ខ្ញុំនោះឈ្មោះថា មានសរដកចោលហើយ ប្រាសចាកសេចក្ដីសោកហើយ ឥតមានចិត្តល្អក់ ខ្ញុំលែងសោកស្ដាយលែងយំព្រោះបានស្ដាប់ ( នូវពាក្យរបស់អ្នក ) ។

**ចប់ សោមទត្តជាតកទី ៥ ។**

## អដ្ឋកថា

## សោមទត្តជាតក

[ ៣៧០-៣៧៦ ] ព្រះសាស្ដា កាលគង់នៅក្នុងវិហារជេតពន ទ្រង់ប្រារព្ធព្រះថេរៈចាស់មួយរូប ទើបត្រាស់រឿងនេះ មានពាក្យផ្ដើមថា **យោ មំ បុរេ បច្ចុេតិ** ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈចាស់នោះ បំបួសសាមណេរមួយរូប សាមណេរនោះជាអ្នកឧបដ្ឋាកលោក បានអនិច្ចធម្មដោយរោគឯណានីមួយ ។ កាលសាមណេរនោះអនិច្ចធម្ម ព្រះថេរៈចាស់យំរៀបរាប់ ដោយប្រការផ្សេងៗ ។ ភិក្ខុទាំងឡាយឃើញលោកហើយ តាំងរឿងឡើងសន្ទនាក្នុងធម្មសភាថា អាវុសោ

ព្រះថេរៈចាស់រូបនោះ ដើរយំរៀបរាប់ផ្សេងៗ ព្រោះមរណៈភាពនៃសាមណេរ លោកប្រហែលជាវៀរកម្មដ្ឋានគឺមរណានុស្សតិ ។ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនចំពោះតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន កាលសាមណេរមរណៈហើយ ភិក្ខុចាស់នេះ ក៏យំដូចគ្នា កាលភិក្ខុទាំងឡាយអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅនគរពារាណសី ព្រះពោធិសត្វសោយព្រះជាតិជាសក្កទេវរាជ ។ កាលនោះ ព្រាហ្មណមហាសាលអ្នកកាសីនិគមម្នាក់ លះបង់កាមទាំងឡាយ ចេញទៅកាន់ព្រៃហិមពាន្តបួសជាឥសី មានមើមឈើនិងផ្លែឈើក្នុងព្រៃជាអាហារ នៅដោយការប្រព្រឹត្តដោយការស្វែងរក ។ ថ្ងៃមួយ លោកទៅរកផ្លែឈើតូចធំ ឃើញកូនដំរីមួយទើបនាំមកកាន់អាស្រមរបស់ខ្លួន ឲ្យតាំងនៅក្នុងឋានៈជាកូន ដាក់ឈ្មោះថាសោមទត្ត ចិញ្ចឹមឲ្យស៊ីស្មៅនិងស្លឹកឈើ ធំចម្រើនឡើង មានរាងកាយធំសម្បើម ។ ថ្ងៃមួយ ស៊ីចំណីច្រើនពេក ក៏ខ្សោយកម្លាំង ព្រោះអាហារមិនរលាយ តាបសឲ្យដំរីនោះនៅក្បែរអាស្រម ហើយទៅរកផ្លែឈើតូចធំកាលតាបសមិនទាន់មកនោះឯង កូនដំរីនោះក៏ដួលស្លាប់ទៅ ។ តាបសកាន់យកផ្លែឈើតូចធំមក សន្សំយថា ក្នុងថ្ងៃដទៃៗកូនរបស់អញមកទទួល ថ្ងៃនេះ

មិនឃើញ ព្រោះហេតុអ្វីហ្ន៎ កាលខ្សឹកខ្សួល បានពោលគាថាទី ១ ថា

កាលពីមុន ដំរីណា មកអំពីចម្ងាយទទួលអាត្មាអញក្នុងព្រៃ ( ឥឡូវនេះ ) ដំរីឈ្មោះសោមទត្តនោះ ទៅក្នុងទីណា បានជាបាត់មិនឃើញមក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុរេ** សេចក្តីថា មុនអំពីថ្ងៃនេះ ។ បទថា **បច្ចុទេតិ** សេចក្តីថា ចេញមកទទួល ។ បទថា **អរញ្ញេ ទូរំ** សេចក្តីថា ទទួលយើងអំពីចម្ងាយដល់ក្នុងព្រៃដែលមិនមានមនុស្សនេះ ។ បទថា **អាយតោ** សេចក្តីថា ដល់ព្រមដោយទំហំ[១] ។

តាបសដើរបណ្តើរ យំបណ្តើរយ៉ាងនេះ ឃើញកូនដំរីនោះដួលត្រង់ទីចង្ក្រមហើយ កាលនឹងយំរៀបរាប់ បានពោលគាថាទី ២ ថា

ដំរីដេកស្លាប់នេះ គឺដំរីនេះឯង ដំរីសោមទត្តដួលដេកលើផែនដី ដូចជាត្រួយជ្រៃដែលបុគ្គលក្តិចហើយ ដំរី ( នោះ ) មិនទាន់ស្លាប់ទេហ្ន៎ ដូច្នេះ ។

**វា** សព្ទ ក្នុងពាក្យថា **អយំ វា** ក្នុងគាថានោះ មានអត្ថថា ធ្វើឲ្យជាក់ច្បាស់ ។ តាបសកាលឲ្យរឿងនោះជាក់ច្បាស់ថា ដំរីនេះឯង គឺដំរីសោមទត្តនោះ មិនមែនដំរីដទៃ ទើបពោលយ៉ាងនេះ ។ បទថា **អល្លុបិតំ** បានដល់ត្រួយនៃដើមជ្រៃ ។ បទថា **វិច្ឆិនោ** សេចក្តីថា កាត់ផ្តាច់ហើយ អធិប្បាយថា ដូចត្រួយជ្រៃ ដែលគេយកក្រចកផ្តិចចោលលើផ្នែកខ្សាច់ក្តៅ ក្នុងរដូវ

---

១-សេចក្តីថា ដំរីណាជាសត្វធំមកអំពីចម្ងាយ... ។ បិដកខ្មែរលោកមិនប្រែពាក្យនេះ ។

ប្រាំង ។ បទថា **ភូម្យា** បានដល់ ត្រង់ផែនដី ។ បទថា **អមរា វត** សេចក្តីថា ស្លាប់ហើយហ្ន៎ បាឋៈថា **អមរី** ក៏មាន ។

ក្នុងខណៈនោះ សក្កទេវរាជកំពុងត្រួតមើលសត្វលោក ទ្រង់ឃើញហេតុការណ៍នោះ ទ្រង់ត្រិះរិះថា តាបសនេះ លះបង់កូនប្រពន្ធទៅបួសហើយឥឡូវនេះ នៅមកសាងនូវការសម្គាល់ក្នុងកូនដំរីថាជាកូន ហើយកន្ទក់កន្ទេញអញនឹងឲ្យតាបសសង្វេគ បាននូវសតិ ដូច្នេះហើយទើបមកកាន់អាស្រមបទស្ថិតនៅឰដ៏អាកាសនោះឯង ពោលគាថាទី ៣ ថា

លោកសោកស្តាយដំរីណាដែលស្លាប់បាត់ទៅហើយការសោក
ស្តាយដំរីនោះ មិនសមគួរដល់លោកដែលចូលមកកាន់ផ្នួស
ជាសមណៈមានចិត្តរួចស្រឡះសោះឡើយ ដូច្នេះ ។

តាបសកាលស្តាប់ពាក្យនោះហើយ បានពោលគាថាទី ៤ ថា

បពិត្រសក្កៈ សេចក្តីស្រឡាញ់រមែងកើតក្នុងហឫទ័យ របស់
មនុស្សក្តី ម្រឹគក្តី ដោយសារជាប់នៅជាមួយគ្នា អាត្មាមិនអាច
មិនសោកស្តាយដំរីនោះបានឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មិគស្ស វា** ក្នុងទីនេះ លោកហៅសត្វតិរច្ឆានទាំងអស់ថាម្រឹគ ។ បទថា **តំ** បានដល់ សត្វដែលជាទីស្រឡាញ់ ។

លំដាប់នោះ សក្កទេវរាជកាលនឹងឲ្យឱវាទដល់ឥសីនោះ បានពោលគាថា ២ ថា

សត្វទាំងឡាយណាយំទួញរៀបរាប់ សត្វទាំងឡាយនោះ

តែងយំរកសត្វដែលស្លាប់បាត់ទៅហើយ ឬក៏សត្វដែលបម្រុង
នឹងស្លាប់ នៃឥសី ព្រោះហេតុនោះ លោកកុំយំឡើយ ពួក
សប្បុរសពោលថាការយំ ជាធម្មជាតឥតអំពើទេ ។

បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់ទៅកាន់បរលោក
ហើយ គប្បីរស់ឡើងវិញដោយការយំទួញ ពួកយើងទាំងអស់
ក៏គួរប្រជុំគ្នាយំរកពួកញាតិនៃគ្នានឹងគ្នាដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ រុទន្តិ លបន្តិ ច** សេចក្ដីថា បពិត្រព្រាហ្មណ៍ ពួកជនដែលយំគ្រប់គ្នា រមែងយំឲ្យដល់អ្នកដែលស្លាប់ទៅហើយនោះឯងនិងបុគ្គលដែលនឹងស្លាប់ ។ កាលពួកជនទាំងនោះ នាំគ្នាយំយ៉ាងនេះ ពេលដែលស្ងួតទឹកភ្នែកមិនមាន ព្រោះហេតុនោះ បពិត្រតាបស លោកកុំធ្វើការយំឡើយ ។ ព្រោះហេតុអ្វី ព្រោះថា ពួកសប្បុរសពោលថា ការយំជាធម្មជាតឥតអំពើទេ ។ បទថា **រោទិតំ មោឃមាហុ សន្តោ** សេចក្ដីថា បណ្ឌិតទាំងឡាយពោលថា ការយំ ជារបស់ឥតផល ។ បទថា **មតោ បេតោ** សេចក្ដីថា បើអ្នកដែលស្លាប់ហើយនោះ ដល់នូវការរាប់ថា ជាអ្នកស្លាប់ទៅហើយ គប្បីរស់ឡើងព្រោះការយំសោត ។ កាលបើដូច្នោះ ពួកយើងគ្រប់គ្នា ក៏ចូរប្រជុំយំឲ្យដល់ញាតិនៃគ្នានឹងគ្នាចុះ ពួកយើងអត់សង្កត់ធ្វើអ្វី ។

តាបសស្ដាប់ពាក្យនោះហើយ បាននូវសតិ ប្រាសចាកសេចក្ដីសោកជូតទឹកភ្នែកហើយ ពោលគាថាដ៏សេស ដោយការសរសើរសក្កទេវរាជថា

អ្នកបានស្រោចខ្ញុំដែលត្រូវភ្លើង គឺសេចក្តីសោកកំពុងឆេះ សព្វឲ្យត្រជាក់ត្រជុំ រំលត់នូវក្រវល់ក្រវាយទាំងអស់បាន ដូចជាបុគ្គលយកទឹកស្រោចលត់នូវភ្លើង ដែលកំពុងឆេះនូវថ្នាំងខ្លាញ់ ។ អ្នកបានបន្ទោបង់សេចក្តីសោក ព្រោះកូនរបស់ខ្ញុំ ដែលត្រូវសេចក្តីសោកកំពុងគ្របសង្កត់ ឈ្មោះថា បានដកចោលនូវសរ គឺសេចក្តីសោកដែលអាស្រ័យនៅក្នុងហឫទ័យនៃខ្ញុំបាន ។ បពិត្រវាសវៈ ខ្ញុំនោះឈ្មោះថា មានសរដកចោលហើយ ប្រាសចាកសេចក្តីសោកហើយ ឥតមានចិត្តល្អក់ ខ្ញុំលែងសោកស្តាយ លែងយំព្រោះបានស្តាប់ ( នូវពាក្យរបស់អ្នក ) ដូច្នេះ ។

អត្ថនៃគាថាទាំងនេះ បានពោលទុកហើយ ខាងដើមនោះឯង ។

សក្កទេវរាជកាលទូន្មានតាបសយ៉ាងនេះហើយ ក៏យាងទៅកាន់ឋានរបស់ទ្រង់នោះឯង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះ មកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈ ប្រជុំជាតកថា កូនដំរីក្នុងកាលនោះ បានមកជាសាមណេរក្នុងកាលឥឡូវនេះ តាបសក្នុងកាលនោះ បានមកជាថេរៈចាស់ ឯសក្កទេវរាជក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា សោមទត្តជាតក ចប់**

# សុសីមជាតក

[ ៣៧៧ ] ( ព្រះរាជាពោធិសត្វពោលថា ) ម្នាលសុសីមៈ កាលពីដើមសក់ទាំងឡាយខ្មៅដុះលើក្បាលជាប្រទេសដ៏សមគួរ ថ្ងៃនេះ អ្នកឃើញសក់ទាំងនោះសហើយ ចូរប្រព្រឹត្តធម៌ចុះ ( ព្រោះកាលនេះ ) ជាកាលគួរដល់ព្រហ្មចរិយធម៌ហើយ ។

[ ៣៧៨ ] ( អគ្គមហេសីពោលថា ) បពិត្រព្រះសម្មតិទេព សក់ស្កូវរបស់ខ្ញុំ មិនមែនរបស់ព្រះអង្គទេ ស្កូវក្បាលរបស់ខ្ញុំ ស្កូវត្បូងរបស់ខ្ញុំទេតើ បពិត្រព្រះរាជសេដ្ឋៈ ខ្ញុំនិយាយកុហកទេ ដោយបំណងថា អាត្មាអញនឹងធ្វើនូវសេចក្តីចម្រើន ( ដល់ខ្លួន ) សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសអភ័យទោសកំហុសម្តង ( ដល់ខ្ញុំ ) ។

[ ៣៧៩ ] បពិត្រព្រះរាជា ព្រះអង្គនៅក្មេងឋិតនៅក្នុងបឋមវ័យនៅឡើយ មុខគួរឲ្យអ្នកផងពិតពិលរមិលមើល ដូចជាទំពាំង ( ខ្ញុំមានសម្បុរដ៏ស្និទ្ធ ) សូមទ្រង់សោយរាជ្យផង សូមទ្រង់ទតខ្ញុំព្រះអង្គផង បពិត្រព្រះជនិន្ទៈ សូមព្រះអង្គកុំស្ទុះទៅតាមកាលិកៈឡើយ ។

[ ៣៨០ ] ( ពោធិសត្វពោលថា ) យើងឃើញកុមារីក្រមុំ មានសម្បុរស្បែកដ៏ផូរផង់ក្នុងខាងទាំងអស់ មានដងខ្លួនសមរម្យ ត្រង់ពាក់កណ្តាលខ្លួនសណ្ឋិតដោយល្អ ( កុមារីនោះ ) ធ្វើដំណើរញ្ញែងញ៉ងដូចជាវល្លិ៍ប្រេងមានស្ទឹកខ្ញី ( ដែលទន់ល្វន់ ) ហើយប្រលោមពួកបុរស ។

[ ៣៨១ ] លុះដល់សម័យខាងក្រោយមក យើងឃើញនារីនុ៎ះកើតបាន ៨០ ឆ្នាំ ឬ ៩០ ឆ្នាំអំពីកំណើត កាន់ឈើច្រត់ញ័រទទ្រេតត្រាច់ទៅកោងៗដូច

ជាបន្តន់ផ្ទះ ។

[ ៣៨២ ] យើងនោះត្រិះរិះឃើញនូវសេចក្តីរីករាយនិងទោសរបស់រូបនោះដេកម្នាក់ឯង ពាក់កណ្តាលនៃដំណេក ក៏ត្រិះរិះឃើញថា អាត្មាអញមុខជាយ៉ាងនោះដែរដូច្នេះហើយក៏លែងរីករាយក្នុងផ្ទះ ( កាលនេះ ) ជាកាលគួរនៃព្រហ្មចរិយៈ ។

[ ៣៨៣ ] សេចក្តីត្រេកអរ ( ក្នុងកាម ) របស់បុគ្គលអ្នកនៅ ក្នុងផ្ទះនុ៎ះ ដូចជាខ្សែសម្រាប់តោង ( របស់បុរសដែលមានជំងឺ ) អ្នកប្រាជ្ញទាំងឡាយ កាត់ផ្តាច់នូវខ្សែនុ៎ះហើយ លែងនឹកនា លះបង់ចោលនូវកាមសុខ ទៅបួស ។

**ចប់ សុសីមជាតកទី ៦ ។**

## អដ្ឋកថា

## សុសីមជាតក

[ ៣៧៧-៣៨៣ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាភិនេស្ក្រមណ៍ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កាឡានិ កេសានិ បុរេ អហេសុំ** ដូច្នេះជាដើម ។

ក្នុងសម័យនោះ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា ពណ៌នានូវការយាងចេញអភិនេស្ក្រមណ៍របស់ព្រះទសពល ។ ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាដោយ

រឿងអ្វី កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលតថាគតបំពេញបារមីមកសន្ទឹកសន្ធាប់ ច្រើនសែនកោដិកប្ប ចេញមហាភិនេស្រ្កមណ៍ ក្នុងកាលឥឡូវនេះ មិនជាការអស្ចារ្យទេ សូម្បីក្នុងកាលមុន តថាគតក៏លះបង់រាជសម្បត្តិ ក្នុងកាសិករដ្ឋដែលមានទំហំប្រមាណ ៣០០ យោជន៍ ចេញអភិនេស្រ្កមណ៍ដូចគ្នា ហើយទ្រង់បាននាំយករឿងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅនានគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃភរិយាធំរបស់បុរោហិត នៃព្រះរាជាអង្គនោះ ។ ក្នុងថ្ងៃដែលព្រះពោធិសត្វកើតនោះឯង ព្រះរាជឱរសរបស់ព្រះបាទពារាណសីក៏ប្រសូត ។ ក្នុងថ្ងៃដាក់ឈ្មោះនិងថ្វាយព្រះនាមនៃកុមារទាំងនោះ ពួកបុរោហិតបានដាក់ឈ្មោះព្រះមហាសត្វថា សុសីមកុមារ ឯព្រះរាជបុត្តថ្វាយនាមថាព្រហ្មទត្តកុមារ ។ ព្រះបាទពារាណសីទ្រង់ព្រះតម្រិះថា សុសីមកុមារកើតក្នុងថ្ងៃជាមួយគ្នានឹងបុត្តរបស់យើង ទើបមានព្រះរាជឱង្ការទៅកាន់ព្រះពោធិសត្វព្រះរាជទានភីលៀង ឲ្យចម្រើនវ័យជាមួយព្រះរាជកុមារនោះឯង ។ កុមារទាំង ២ ចម្រើនវ័យហើយ មានរូបស្រស់បស់ មានពណ៌សម្បុរដូចទេវកុមារ រៀនសិល្បសាស្រ្តគ្រប់យ៉ាងក្នុងនគរតក្កសិលា ។ សម្រេចហើយក៏ត្រឡប់មក ។ ព្រះរាជបុត្ត ទ្រង់បានជាឧបរាជ ទ្រង់សោយ ទ្រង់ផឹក ទ្រង់ប្រថាប់គង់ ទ្រង់ផ្ទុំរួមជាមួយព្រះពោធិសត្វរហូតអស់រដ្ឋកាលព្រះជនក ក៏បានសោយរាជ្យស្នងព្រះបិតា ប្រទានយសធំដល់មហាសត្វ ទ្រង់តាំងទុកក្នុងតំណែង

បុរោហិត ។ ថ្ងៃមួយ ទ្រង់ត្រាស់ឲ្យរៀបចំព្រះនគរ ហើយតែងព្រះកាយដូច សក្កទេវរាជ ប្រថាប់គង់លើកដីរ ដែលអង់អាច មានចំណែកប្រៀបដូចដីរ ឯរាវ័ណ ដែលតាក់តែងហើយ ទ្រង់ឲ្យព្រះពោធិសត្វអង្គុយខាងក្រោយ ក្នុង ទីអង្គុយខាងក្រោយ ទ្រង់ធ្វើប្រទក្សិណព្រះនគរ ។ ឯសម្តេចព្រះរាជជននី ប្រថាប់ឈរត្រង់សីហបញ្ជរ ដោយព្រះនាងព្រះតម្រិះថា អញនឹងមើលកូន ទតឃើញបុរោហិតអង្គុយខាងក្រោយ ។ ព្រះរាជាទ្រង់ធ្វើប្រទក្សិណ ព្រះ នគរ ហើយយាងមក ព្រះនាងមានព្រះហឫទ័យប្រតិព័ទ្ធ ទើបចូលក្រឡា ព្រះបន្ទំ មិនសោយព្រះក្រយាហារ ហើយព្រះនាងផ្ទំដោយតាំងព្រះហឫទ័យ ថា បើមិនបានបុរោហិតនេះ ក៏នឹងស្លាប់ក្នុងទីនោះឯង ។ ព្រះរាជា កាល ទ្រង់មិនឃើញព្រះមាតា ទើបត្រាស់សួរថា មាតារបស់យើងទៅឯណា ទ្រង់ បានឮថា ប្រឈួន ទើបយាងទៅដល់ទីប្រថាប់របស់ព្រះរាជជននី ទ្រង់ថ្វាយ បង្គំ ត្រាស់សួរថា បពិត្រព្រះមាតា ព្រះមាតា ប្រឈួនរោគអ្វី ព្រះនាងមិន ប្រាប់ ព្រោះខ្មាសអៀន ។ ព្រះរាជាយាងទៅប្រថាប់គង់លើរាជបល្ល័ង្កត្រាស់ ហៅមហេសីរបស់ទ្រង់មកបញ្ជូនទៅដោយពាក្យថា ចូរនាងទៅ ហើយចូរដឹង ការប្រឈួនរបស់ព្រះមាតា ។ ព្រះនាងយាងទៅគក់ប្រេបាច់ព្រះបិដ្ឋិបណ្តើរ សួរបណ្តើរ ។ ធម្មតាស្ត្រីទាំងឡាយមិនលាក់អាថ៌កំបាំងដល់គ្នានឹងគ្នា ។ ព្រះ រាជជននីនោះត្រាស់ប្រាប់សេចក្តីនោះ ឯព្រះរាជិនីបានស្តាប់ពាក្យនោះហើយ ទើបទូលដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា រឿងនោះស្ទេះទុកចុះ ចូរនាង ទៅចុះ ចូរឲ្យព្រះមាតាធូរស្បើយព្រះហឫទ័យ យើងនឹងតាំងបុរោហិតឲ្យជា

ព្រះរាជា ហើយតាំងព្រះមាតាឲ្យជាអគ្គមហេសី ។ ព្រះនាងក៏យាងទៅ ឲ្យព្រះរាជជននីស្បើយព្រះហឫទ័យហើយ ។ ឯព្រះរាជាត្រាស់ឲ្យបុរោហិតចូលគាល់ ហើយប្រាប់សេចក្ដីនោះថា នែសម្លាញ់ សូមសម្លាញ់ឲ្យជីវិតដល់ព្រះមាតា សូមសម្លាញ់ធ្វើជាព្រះរាជា ព្រះមាតាជាព្រះមហេសី យើងនឹងធ្វើជាឧបរាជ ។ បុរោហិតទូលជំទាស់ថា ទូលព្រះបង្គំមិនអាចធ្វើយ៉ាងនោះបានទេ តែកាលព្រះរាជាទ្រង់អង្វររឿយៗ ក៏យល់ព្រម ។ ព្រះរាជាទ្រង់បានអភិសេកបុរោហិតឲ្យឡើងជាព្រះរាជា ព្រះរាជជននីឲ្យជាអគ្គមហេសី ចំណែកទ្រង់ធ្វើជាឧបរាជ ។ ក្សត្រទាំងពីរអង្គនោះ ប្រថាប់ដោយការព្រមព្រៀងគ្នា ក្នុងកាលជាខាងក្រោយមក ព្រះពោធិសត្វទ្រង់អោក្នុងព្រះហឫទ័យ ក្នុងការគ្រប់គ្រងផ្ទះ ទ្រង់លះកាមទាំងឡាយ ហើយមានព្រះហឫទ័យបង្អោនទៅកាន់បព្វជ្ជា ទ្រង់មិនអាល័យ មិនត្រេកអរដោយ អំណាចកិលេស ប្រថាប់ឈរ ប្រថាប់គង់ ផ្ទំតាមទំនើងព្រះអង្គឯង ដូចជាត្រូវចងដាក់ក្នុងពន្ធនាគារ និងដូចមាន់ត្រូវឃុំទុកក្នុងទ្រុង ។ សម័យនោះ ព្រះមហេសីរបស់ទ្រង់ព្រះតម្រិះថា ព្រះរាជាអង្គនេះ ទ្រង់មិនអភិរម្យជាមួយអញ ប្រថាប់ឈរ ប្រថាប់គង់ និងផ្ទំតែមួយព្រះអង្គឯង តែព្រះរាជាអង្គនេះ ជាយុវវ័យ ឯអញជាមនុស្សចាស់សក់ស្កូវប្រាកដលើក្បាលរបស់អញ កាលបើដូច្នោះ អញគួរប្រឌិតរឿងឡើងថា បពិត្រព្រះសម្មតិទេព លើសីសៈរបស់ទ្រង់ ក៏មានព្រះកេសាស្កូវ ដូច្នេះ ។ ឲ្យព្រះរាជាទ្រង់ទទួលហើយ ទ្រង់នឹងអភិរម្យជាមួយអញ ដោយឧបាយនោះ ។ ថ្ងៃមួយ ព្រះនាងធ្វើជារកចៃលើសីសៈរបស់ព្រះរាជា ទូលថា បពិត្រព្រះអង្គ

ទ្រង់ព្រះជាហើយ លើសីសៈរបស់ទ្រង់មានសក់ស្កូវមួយសរសៃ ។ ព្រះរាជា ត្រាស់ថា នែនាងដ៏ចម្រើន កាលបើដូច្នោះ ចូរនាងដកសក់ស្កូវមួយសរសៃនោះ មកដាក់លើដៃរបស់យើង ។ ព្រះនាងក៏ដកព្រះកេសាមួយសរសៃអំពីសីសៈ ព្រះរាជាបោះចោលទៅ ហើយព្រះនាងយក ព្រះកេសាស្កូវមួយសរសៃអំពី សីសៈរបស់ខ្លួន ដាក់លើដៃរបស់ព្រះរាជា ទូលថា បពិត្រព្រះសម្មតិទេព នេះសក់ស្កូវរបស់ទ្រង់ ។ ព្រះសេទោហូរចេញអំពីព្រះនលាដ ដែលដូចគ្នានឹង ផែនមាសរបស់ព្រះពោធិសត្វ ទ្រង់តក់ស្លុត ព្រោះឃើញសក់ស្កូវប៉ុណ្ណោះ ហើយទ្រង់ក៏ខ្លាច ។ ព្រះរាជា កាលទ្រង់ទូន្មានខ្លួន ទ្រង់ព្រះតម្រិះថា នែ សុសីម: ឯងជាមនុស្សកំលោះ ឥឡូវនេះក្លាយជាមនុស្សចាស់ទៅហើយ ឯង លិចក្នុងភក់គឺកាម ដូចជ្រូកស្រុកលិចក្នុងភក់គឺលាមក ដូច្នោះ មិនអាចរើខ្លួន ឡើងបាន ឥឡូវនេះ ជាពេលដែលឯងលះកាមទាំងឡាយ ចូលកាន់ព្រៃហិម ពាន្តបួសហើយប្រព្រឹត្តព្រហ្មចរិយៈមិនមែនឬ ដូច្នេះហើយ បានពោលគាថាទី ១ ថា

> ម្នាលសុសីម: កាលពីដើម សក់ទាំងឡាយខ្មៅដុះលើក្បាល
> ជាប្រទេសដ៏សមគួរ ថ្ងៃនេះអ្នកឃើញសក់ទាំងនោះសហើយ
> ចូរប្រព្រឹត្តធម៌ចុះ ( ព្រោះកាលនេះ ) ជាកាលគួរដល់ព្រហ្ម
> ចរិយធម៌ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថាបទេសេ** សេចក្តីថា ព្រះពោធិសត្វ ត្រាស់ថា មុននេះ សក់ទាំងឡាយ មានពណ៌ដូចស្លាបកំកែម និងផ្កាអញ្ចន

បានកើតហើយលើក្បាលរបស់អ្នកដែលជាបទេសសមគួរដល់សក់ទាំងឡាយក្នុងទីនោះៗ ។ បទថា **ធម្មំ ចរ** សេចក្តីថា ព្រះពោធិសត្វទ្រង់ទូន្មានខ្លួនឯងថា ចូរអ្នកប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ។ បទថា **ព្រហ្មចរិយស្ស** មានអត្ថថា ជាពេលនៃមេថុនវិរតិរបស់អ្នកហើយ កាលព្រះពោធិសត្វពណ៌នាគុណ គឺការប្រព្រឹត្តព្រហ្មចរិយៈយ៉ាងនេះហើយ ព្រះរាជិនីទ្រង់តក់ស្លុតព្រះហឫទ័យ ព្រោះខ្លាចថា អញតាំងចិត្តថា នឹងធ្វើការចងព្រះហឫទ័យព្រះរាជា តែប្រែទៅជាធ្វើនូវការលះបង់ទៅវិញ ទើបព្រះនាងព្រះតម្រិះថា អញនឹងសរសើរព្រះឆវីវណ្ណនៃព្រះសរីរៈ ដើម្បីកុំឲ្យព្រះរាជាចេញបួស ទើបត្រាស់គាថា ២ ថា

បពិត្រព្រះសម្មតិទេព សក់ស្កូវរបស់ខ្ញុំ មិនមែនរបស់ព្រះអង្គទេ ស្កូវក្បាលរបស់ខ្ញុំ ស្កូវត្បូងរបស់ខ្ញុំទេតើ បពិត្រព្រះរាជសេដ្ឋៈ ខ្ញុំនិយាយកុហកទេដោយបំណងថា អាត្មាអញនឹងធ្វើនូវសេចក្តីចម្រើន ( ដល់ខ្លួន ) សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស អភ័យទោសកំហុសម្តង ( ដល់ខ្ញុំ ) ។

បពិត្រព្រះរាជា ព្រះអង្គនៅក្មេងឋិតនៅក្នុងបឋមវ័យ នៅឡើយ មុខគួរឲ្យអ្នកផងពិតពិលរមិលមើល ដូចជាទំពាំង ( ខ្ចីមានសម្បុរដ៏ស្និទ្ធ ) សូមទ្រង់សោយរាជ្យផង សូមទ្រង់ទតខ្ញុំព្រះអង្គផង បពិត្រព្រះជនិន្ទៈ សូមព្រះអង្គកុំស្ទុះទៅតាមកាលិកៈឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មមេវ សីសំ** សេចក្តីថា ព្រះរាជនីសម្តែង ថា សក់ស្កូវលើសីសៈរបស់ខ្ញុំម្ចាស់ទេតើ ។ ពាក្យថា **ឧត្តមង្គំ** ជាវេវចនៈ នៃពាក្យថា **សីសំ** នោះឯង ។ បទថា **អក្ខំ** សេចក្តីថា ខ្ញុំម្ចាស់ពោលពាក្យ កុហក ដោយបំណងថា នឹងធ្វើសេចក្តីចម្រើនដល់ខ្លួនឯង ។ បទថា **ឯកា-បរាធំ** សេចក្តីថា ទោសកំហុសឯណានីមួយរបស់ខ្ញុំម្ចាស់នេះ ។ បទថា **បឋមុគ្គតោ** សេចក្តីថា ចម្រើនឡើងដោយបឋមវ័យ ។ បទថា **ហោហិ** កែជា **ហោសិ** អធិប្បាយថា តាំងនៅហើយក្នុងបឋមវ័យ ។ បាឋៈថា **ហោសិ យេវ** ក៏មាន ។ បទថា **យថា កលីរោ** សេចក្តីថា ព្រះរាជិនីទ្រង់ ត្រាស់ថា បណ្តូលចេក[1]មានពណ៌ល្អ ត្រូវខ្យល់បក់មក រេរាំល្អ យ៉ាងណា ទ្រង់ក៏មានព្រះរូបឆោម យ៉ាងនោះ ។ បាឋៈថា **បឋមុគ្គតោ ហោសិ** ដូច្នេះ ក៏មាន ។ បាឋៈនោះមានអត្ថថា ពន្លករបស់ត្រួយឈើខ្ចី ដុះឡើងគួរទស្សនា យ៉ាងណា ទ្រង់ក៏គួរឲ្យទស្សនា យ៉ាងនេះ ។ បទថា **មមញ្ច បស្ស** សេចក្តីថា សូមទ្រង់ក្រឡេកមើលខ្ញុំម្ចាស់ផងចុះ អធិប្បាយថា សូមទ្រង់កុំធ្វើឲ្យ ខ្ញុំម្ចាស់នៅមេម៉ាយមិនមានទីពឹងឡើយ ។ បទថា **កាលិកំ** សេចក្តីថា ព្រះ នាងទូលថា ធម្មតាការប្រព្រឹត្តព្រហ្មចរិយៈ ដែលឈ្មោះថា ឲ្យផលតាមកាល ព្រោះឲ្យផលក្នុងអត្តភាពទី ២ ឬទី ៣ ឯរាជសម្បត្តិ ឈ្មោះថាឲ្យផលមិន រើសកាលវេលា ព្រោះឲ្យនូវសុខ គឺកាមគុណក្នុងអត្តភាពនេះឯង ទ្រង់កុំលះ រាជសម្បត្តិ ដែលឲ្យផលមិនរើសកាល ហើយទ្រង់ស្ទុះទៅតាមការប្រព្រឹត្ត

---

១-ពាក្យថា កលីរោ បិដកខ្មែរប្រែថា ទំពាំង ។

ព្រហ្មចរិយៈ ដែលឲ្យផលតាមកាលវេលាឡើយ ។ ព្រះពោធិសត្វ កាលទ្រង់ស្ដាប់ពាក្យនោះហើយ ត្រាស់ថា នែនាងដ៏ចម្រើន នាងពោលពាក្យនោះគួរប្រព្រឹត្តទៅបាន ព្រោះថា កាលវ័យរបស់យើងប្រែប្រួលទៅហើយ កំពុងប្រែប្រួល សក់ខ្មៅទាំងឡាយនេះ ក៏ត្រូវមានពណ៌ស ដូចសម្បកផ្ទៃទៅទាំងអស់ ។ ពិតហើយ កាលវ័យរបស់កុមារទាំងឡាយដូចគ្នានឹងកម្រងផ្កា មានផ្កាឧប្បលខៀវជាដើម និងរបស់ខត្តិយកញ្ញាជាដើម ប្រៀបដូចបដិមាមាសឧត្តមសម្បូរដោយភាពជាកំលោះក្រមុំ និងភាពស្អាត មានការប្រែប្រួលជាទីបំផុត បានប្រែប្រួលទៅហើយ យើងឃើញវត្ថុដែលគួរតិះដៀលផង ការទ្រុឌទ្រោមនៃសរីរៈរបស់ជនទាំងឡាយ ដែលដល់នូវការជរាហើយផង នែនាងដ៏ចម្រើន កាលបើដូច្នេះ លោករបស់សត្វដែលមានជីវិតនោះ ក៏មានវិបត្តិជាទីបញ្ចប់ ដូច្នេះហើយ កាលទ្រង់សម្ដែងធម៌ដោយពុទ្ធលីលា ឲ្យក្រៃលែងឡើង ទើបពោលគាថា ២ ថា

យើងឃើញកុមារីក្រមុំ មានសម្បុរស្បែកដ៏ផូរផង់ក្នុងខាងទាំងអស់ មានដងខ្លួនសមរម្យ ត្រង់ពាក់កណ្ដាលខ្លួនសណ្ឋិតដោយល្អ ( កុមារីនោះ ) ធ្វើដំណើរញែងញ៉ងដូចជាវល្លិ៍ប្រេងមានស្លឹកខ្ចី ( ដែលទន់ល្វន់ ) ហើយប្រលោមពួកបុរស ។

លុះដល់សម័យខាងក្រោយមក យើងឃើញនារីនុ៎ះកើតបាន ៨០ ឆ្នាំ ឬ ៩០ ឆ្នាំ អំពីកំណើត កាន់ឈើច្រត់ញ័រទទ្រើតត្រាច់ទៅកោងៗ ដូចជាបង្កង់ផ្ទះ ដូច្នេះ ។

*បណ្ដាបទទាំងនោះ បទថា* **វេ** *ត្រឹមតែជានិបាត ។ បទថា* **សាមដ្ឋ-បស្សំ** *សេចក្ដីថា មានពណ៌សម្បុរផូរផង់ ម្យ៉ាងទៀត បាឋៈថា* **សមដ្ឋ-បស្សំ** *ក៏មានន័យដូចគ្នានោះឯង អធិប្បាយថា មានពណ៌សម្បុររលើបរលោង តាំងអំពីដើមដៃមក ។ បទថា* **សុតនុំ** *បានដល់ មានរូបរាងស្អាត ។ បទថា* **សុមជ្ឈំ** *បានដល់ មានជង្គង់សមរម្យល្អ ។ បទថា* **កាលប្បល្លវាវ បវេល្លមានា** *សេចក្ដីថា ឧបមាដូចវល្លិប្រេងដែលឡើងល្អហើយ ស្អាតក្នុងពេលនៅតូច គឺត្រួយខ្ចីនោះឯង ត្រូវខ្យល់បក់ត្រសៀកៗ ក៏រេរាំទៅខាងនេះខាងនោះ យ៉ាងណា ទារិកានោះក៏យ៉ាងនោះ ពត់ខ្លួនទៅមក រាយនូវភាពល្វតល្វន់នៃស្រី ។ បទថា* **ឆរេសុ** *ក្នុងបទថា* **បលោភយន្តីវ ឆរេសុ គច្ឆតិ** *ជាសត្តមីវិភត្តិចុះក្នុងអត្ថថាជិត ។ ស្រីនោះ ទៅជិតសម្នាក់របស់ប្រុសទាំងឡាយ ហាក់ដូចជាទាញយកបុរសទាំងនោះដោយអំណាចកិលេស ។ បទថា* **តមេន បស្សាមិ បរេន ឆារឹ** *សេចក្ដីថា សម័យតមក យើងឃើញស្រីនោះ ដល់នូវភាពជរា គឺការស្អាតនៃរូប ក៏បាត់ទៅហើយ អស់នូវសម្រស់ ។ ព្រះពោធិសត្វពោលដល់គុណរបស់រូបដោយគាថាទី ១ ឥឡូវនេះ កាលនឹងពោលដល់ទោស ទើបបានពោលយ៉ាងនេះ ។ បទថា* **អសីតិកំ ឆាវុតិកញ្វ ជច្ចា** *សេចក្ដីថា ៨០ ឬ ៩០ ឆ្នាំអំពីកំណើត ។ បទថា* **គោបាណាសី-ភគ្គសមំ** *សេចក្ដីថា មានកាយកោងដូចបង្កង់ផ្ទះ គឺមានខ្នងកោងដូចបង្កង់ដើរញ៉ូរទេរទ្រេទ្រឹកដូចអ្នករកកាកណិកៈ ១ ដែលបាត់ទៅ ។ ឈ្មោះថាស្រីដែលព្រះពោធិសត្វឃើញកាលពីក្រមុំ ហើយបានឃើញទៀតក្នុងអាយុ ៩០ ឆ្នាំ*

មិនមានក៏ពិត តែពាក្យនេះលោកពោលសំដៅយកការៈ របស់ស្រីដែលបាន ឃើញដោយបញ្ញា ។

ព្រះមហាសត្វ កាលទ្រង់សម្តែងទោសរបស់រូបដោយគាថានេះ ដោយ ប្រការដូច្នេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសនូវការនឿយណាយរបស់ខ្លួន ក្នុងការគ្រប់គ្រងផ្ទះ ទើបត្រាស់គាថា ២ ថា

យើងនោះត្រិះរិះឃើញនូវសេចក្តីរីករាយ និងទោសរបស់ រូបនោះ ដេកម្នាក់ឯង ពាក់កណ្តាលនៃជំណេក ក៏ត្រិះរិះឃើញ ថា អាត្មាអញមុខជាយ៉ាងនោះដែរ ដូច្នេះហើយ ក៏លែងរីក រាយក្នុងផ្ទះ ( កាលនេះ ) ជាកាលគួរនៃព្រហ្មចរិយៈ ។

សេចក្តីត្រេកអរ ( ក្នុងកាម ) របស់បុគ្គលអ្នកនៅក្នុងផ្ទះ នុ៎ះដូចជាខ្សែសម្រាប់គោង ( របស់បុរសដែលមានជំងឺ ) អ្នក ប្រាជ្ញទាំងឡាយកាត់ផ្តាច់នូវខ្សែនុ៎ះហើយ លែងនឹកនា លះបង់ បោលនូវកាមសុខ ទៅបួស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោហំ** កាត់បទជា **សោ អហំ** សេចក្តីថា ខ្ញុំនោះ ។ បទថា **តមេវានុវិចិន្តយន្តោ** សេចក្តីថា ត្រិះរិះដល់គុណនិងទោស នៃរូបទាំងឡាយនោះឯង ។ បទថា **ឯវំ កិរ បេក្ខមានោ** សេចក្តីថា ពិចា រណាឃើញថា ស្រីនេះប្រែប្រួលទៅហើយ យ៉ាងណា ឯអញក៏នឹងយ៉ាង នោះ គឺនឹងដល់នូវជរា មានសរីរៈកោងទៅ ។ បទថា **គេហេ ន រមេ** សេច ក្តីថា យើងមិនត្រេកអរក្នុងផ្ទះ ។ បទថា **ព្រហ្មចរិយស្ស កាលោ** សេចក្តី

ថា ព្រះពោធិសត្វទ្រង់សម្តែងថា នែនាងដ៏ចម្រើន កាលនេះជាព្រហ្មចរិយ-កាល របស់យើង ព្រោះដូច្នោះ យើងនឹងបួស ។ ៩ អក្ខរៈ ក្នុងពាក្យថា **វដ្ដវាលមត្ថនី ចេសា** ត្រឹមតែជានិបាត អធិប្បាយថា វត្ថុនេះដូចជាចំណង ដែលចងទុក ។ វត្ថុនេះគឺអ្វី គឺសេចក្តីត្រេកអរ ( ក្នុងកាម ) របស់បុគ្គល អ្នកនៅក្នុងផ្ទះ ។ អធិប្បាយថា សេចក្តីត្រេកអរដោយអំណាចនៃកាមក្នុងអា-រម្មណ៍ទាំងឡាយ មានរូបជាដើមរបស់អ្នកនៅគ្រប់គ្រងផ្ទះណា ។ ដោយបទ នេះ ព្រះពោធិសត្វសម្តែងដល់ភាពដែលកាមទាំងឡាយមានគុណតិច ។ ក្នុង សេចក្តីនេះមានអធិប្បាយដូចតទៅនេះថា បុរសអ្នកជំងឺ មិនអាចកម្រើកខ្លួន បាន ដោយកម្លាំងរបស់ខ្លួនឯង អ្នកព្យាបាលត្រូវចងខ្សែសម្រាប់តោងដោយ ប្រាប់ថា ចូរតោងខ្សែនេះដើម្បីកម្រើកខ្លួន ។ កាលបុរសនោះតោងខ្សែនោះ កម្រើកខ្លួន ក៏គង់មានសេចក្តីសុខកាយនិងសុខចិត្តតិចតួច យ៉ាងណា កាល សត្វទាំងឡាយពេលពាលព្រោះកិលេស ក៏យ៉ាងនោះដូចគ្នា មិនអាចដកចិត្ត បានដោយអំណាចសេចក្តីសុខ ដែលកើតអំពីវិវេក ប្រារព្ធរូបារម្មណ៍ជាដើម ដែលឲ្យនូវការត្រេកអរក្នុងកាម ដែលស្ថិតនៅត្រង់កណ្តាលផ្ទះ និងប្រារព្ធនូវ ការត្រេកអរក្នុងការសេពមេថុនធម្មក្នុងកាលពួកគេក្តៅក្រហាយព្រោះកិលេស បម្រះនទៀលទៅមក សេចក្តីត្រេកអរក្នុងកាម ពោលគឺសុខកាយ សុខចិត្ត ដែលកើតឡើងមួយខណៈប៉ុណ្ណោះ ក៏មានប្រមាណតិចតួច កាមទាំងឡាយ ឈ្មោះថា មានសេចក្តីត្រេកអរតិច យ៉ាងនេះ ។ បទថា **ឯតំបិ ឆេត្វាន** សេចក្តីថា ព្រោះកាមទាំងឡាយ មានទុក្ខច្រើន មានការចង្អៀតចង្អល់ច្រើន

ក្នុងកាមនេះមានទោសច្រើន ព្រោះហេតុនោះ បណ្ឌិតទាំងឡាយឃើញទោសនោះ គប្បីកាត់នូវខ្សែនោះ មិនអាឡោះអាល័យ ដូចបុរសលិចក្នុងរណ្ដៅលាមកលះបង់រណ្ដៅលាមកទៅ ដូច្នោះ លះកាមសុខ ដែលមានប្រមាណតិច មានទុក្ខច្រើនយ៉ាងនេះហើយ គេចទៅ ។ កាលចេញទៅហើយ ក៏កាន់យកផ្នួសដែលជាទីត្រេកអរនៃចិត្ត ។

ព្រះមហាសត្វ កាលទ្រង់សម្ដែងធម៌ដោយពុទ្ធលីលា ចង្អុលឲ្យឃើញគុណនិងទោសក្នុងកាមទាំងឡាយ យ៉ាងនេះហើយ ត្រាស់ហៅសម្លាញ់មកទ្រង់ប្រគល់រាជសម្បត្តិឲ្យ កាលញាតិនិងមិត្តដែលមានចិត្តល្អទាំងឡាយកំពុងទ្រហោយំ បម្រះនទៀលទៅមកនោះឯង ទ្រង់លះបង់នូវសិរីរាជសម្បត្តិចូលកាន់ព្រៃហិមពាន្តបួសជាឥសី ញុំាងឈាន និងអភិញ្ញាឲ្យកើតឡើង ជាអ្នកចូលដល់ព្រហ្មលោក ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ មហាជនបានផឹកនូវអមតៈហើយទ្រង់ប្រជុំជាតកថា អគ្គមហេសីក្នុងកាលនោះ បានមកជារាហុលមាតាក្នុងកាលឥឡូវនេះ ព្រះរាជាជាសម្លាញ់ក្នុងកាលនោះបានមកជាអានន្ទ ឯព្រះបាទសុសីមៈក្នុងកាលនោះ គឺតថាគតនេះឯង

**អដ្ឋកថា សុសីមជាតក ចប់**

# កោដសិម្ពលិជាតក

[ ៣៨៤ ] ( ស្តេចគ្រុឌឃើញដើមរការនោះកំពុងកក្រើកញាប់ញ័រក៏សួររកហេតុថា ) យើងចាប់នាគមានប្រវែង ១ ពាន់ ព្យាម យកមក ( ក្នុងទីនេះ ) អ្នកទ្រនូវនាគនោះផង នូវយើងផង សុទ្ធតែមានកាយដ៏ធំមិនកម្រើក ។

[ ៣៨៥ ] ម្នាលកោដសិម្ពលិ លុះដល់អ្នកមកទ្របក្សីតូចនេះ ដែលមានសាច់តិចជាងយើងទេ ហេតុអ្វីក៏ភ័យញ័ររន្ធត់ ។

[ ៣៨៦ ] ( ទេវបុត្តពោលថា ) បពិត្រព្រះរាជា ព្រះអង្គមានសាច់ជាអាហារ ឯបក្សីនេះមានផ្លែឈើជាអាហារ បក្សីនេះនឹងស៊ីនូវពូជជ្រៃ ពូជលៀប ពូជល្វាទាំងឡាយ ពូជពោធិ៍បាយទាំងឡាយ ហើយមកជុះដាក់លើដើមឈើរបស់យើង ។

[ ៣៨៧ ] ឈើទាំងឡាយនោះ ដុះក្នុងទីបាំងខ្យល់ក្បែរខាងយើង លូតលាស់ល្អ ឈើទាំងឡាយនោះ មុខជានឹងរួបរឹតយើង ធ្វើយើងមិនឲ្យនៅជាដើមឈើ ។

[ ៣៨៨ ] មានឈើដទៃទៀតដែលជាឈើបរិបូណ៌ដោយឫស បរិបូណ៌ដោយដើម ត្រូវសកុណជាតិនេះពាំយកពូជមកបំផ្លាញ ហើយដែរ ។

[ ៣៨៩ ] ដ្បិត ( ឈើទាំងឡាយមានជ្រៃជាដើម ) រមែងដុះសង្កត់នូវឈើជាធំក្នុងព្រៃ សូម្បីធំចម្រើន បពិត្រព្រះរាជាព្រោះ ហេតុនោះ យើងឃើញភ័យទៅអនាគត បានជាញាប់ញ័រ ។

[ ៣៩០ ] ( សុបណ្ណរាជឮពាក្យរុក្ខទេវតាហើយពោលថា ) អ្នកប្រាជ្ញគប្បីរង្កៀសចំពោះហេតុទាំងឡាយដែលគួររង្កៀស គប្បីរក្សា ( ប្រយ័ត្ន )

នូវភ័យជាអនាគត ទើបឈ្មោះថារមិល មើលនូវលោកទាំងពីរព្រោះហេតុនៃភ័យជាអនាគត ។

## ចប់ កោដសិម្ពលិជាតកទី ៧ ។

# អដ្ឋកថា

# កោដសិម្ពលិជាតក

[ ៣៨៤-៣៩០ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសង្កត់កិលេស ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អហំ ទសសតព្យាមំ** ដូច្នេះជាដើម ។ រឿងមានច្បាស់ក្នុងបានីយជាតក ។

តែក្នុងទីនេះ ព្រះសាស្តាទ្រង់ឃើញភិក្ខុទាំងឡាយប្រមាណ ៥០០ រូប ត្រូវកាមវិតក្កគ្របសង្កត់ ក្នុងកោដិសន្ថារៈ ទើបទ្រង់ឲ្យប្រជុំសង្ឃ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា វត្ថុដែលគួររង្កៀស ក៏គួររង្កៀស ឈ្មោះថាកិលេសទាំងឡាយ កាលចម្រើនឡើង ក៏រមែងបំផ្លាញខ្លួន ដូចដើមជ្រៃជាដើមក្នុងព្រៃ កាលចម្រើនធំធាត់ឡើង ក៏កាច់បំបាក់នូវដើមឈើចាស់ ដូច្នោះដោយហេតុនោះក្នុងកាលមុន ទេវតាដែលកើតត្រង់កោដសិម្ពលិ ឃើញបក្សីមួយស៊ីផ្លែនិគ្រោធបន្ទោបង់ឧច្ចារៈដាក់មែកឈើរបស់ខ្លួន បានដួបនូវភ័យថាបន្តពីនេះទៅវិមានរបស់យើងនឹងដល់នូវការវិនាស ដូច្នេះ ។ ហើយទ្រង់បាននាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកាន់យកកំណើតជារុក្ខទេវតា ត្រង់កោដសិម្ពលិ ។ ក្រោយមក ស្តេចគ្រុឌមួយមានអត្តភាព ១៥០ យោជន៍ ទទះស្លាបបំបែកទឹកមហាសមុទ្ទ ចេញជា ២ ចំណែក ហើយចាប់យកនាគមួយនៅបាតសមុទ្ទ ដែលមាន ប្រវែង ១០០០ ព្យាម ប្រើចំពុះពាំហើរទៅរំលងព្រៃ ឆ្ពោះទៅកាន់កោដ សិម្ពលិ ។ នាគរាជ កាលសំយុងក្បាលចុះ គិតថា អញនឹងដោះខ្លួនឲ្យផុត ទើបសិករង្វេលត្រង់ដើមជ្រៃមួយ រុំដើមជ្រៃនោះទុក ដើមជ្រៃក៏សណ្តកឡើង ព្រោះកម្លាំងស្តេចគ្រុឌនិងស្តេចនាគ ។ ស្តេចនាគក៏មិនលែងដើមឈើឡើយ គ្រុឌឆាបយកនាគព្រមទាំងដើមនិគ្រោធទៅដល់កោដសិម្ពលិ ហើយដាក់នាគ លើដើមរកាចឹកពោះ បរិភោគខ្លាញ់របស់ស្តេចនាគ ហើយចោលសាកសព ដ៏សេសទៅក្នុងសមុទ្ទ ។ លើដើមនិគ្រោធនោះ មានបក្សីញីមួយ កាលស្តេច នាគទម្លាក់ដើមនិគ្រោធហើយ ក៏ហើរទៅទំត្រង់មែករបស់ដើម កោដសិម្ពលិ រុក្ខទេវតាឃើញហើយ ក៏តក់ស្លុត មានខ្លួនញ័រចំប្រប់ គិតថា ចាបញីនេះ នឹងបន្ទោបង់ឧច្ចារៈដាក់ដើមឈើរបស់អញ បន្ទាប់អំពីនោះទៅគុម្ពជ្រៃ ឬគុម្ព ឈើព្រៃនឹងដុះឡើងគ្របសង្កត់នូវដើមឈើទាំងមូល កាលបើដូច្នោះ វិមាន របស់អញក៏នឹងវិនាស ។ កាលរុក្ខទេវតាញាប់ញ័រ កោដសិម្ពលិក៏រញ្ជួយ ដល់គល់ ។ ស្តេចគ្រុឌឃើញរុក្ខទេវតាញាប់ញ័រ កាលនឹងសួរដល់ហេតុទើប ពោលគាថាទាំងឡាយថា

យើងចាប់នាគមានប្រវែង ១ ពាន់ព្យាមយកមក ( ក្នុង

ទីនេះ ) អ្នកទ្រទ្រង់នាគនោះផង នូវយើងផងសុទ្ធតែមានកាយ
ដ៏ធំ មិនកម្រើក ។

ម្នាលកោដសិម្ពលិ លុះដល់អ្នកមកទ្រទ្រង់បក្សីតូចនេះ ដែល
មានសាច់តិចជាងយើងទេ ហេតុអ្វីក៏ភ័យញ័ររន្ធត់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧសសតព្យាមំ** សេចក្ដីថា ប្រវែង ១០០០ ព្យាម ។ បទថា **ឧរគមាទាយ អាគតោ** សេចក្ដីថា យើងចាប់យកពស់ធំមកក្នុងទីនេះយ៉ាងនេះ ។ បទថា **តញ្ច មញ្ច** សេចក្ដីថា ពស់ធំផង ខ្ញុំផង ។ បទថា **ធារយំ** បានដល់ ទ្រទ្រង់ទុក ។ បទថា **ព្យថសិ** សេចក្ដីថា ញាប់ញ័រ ។ បទថា **កិមត្ថំ** សេចក្ដីថា ស្ដេចគ្រុឌសួរថា ដើម្បីប្រយោជន៍អ្វី គឺព្រោះហេតុអ្វី អធិប្បាយថា លោកឃើញនូវប្រយោជន៍អ្វី ។ ស្ដេចគ្រុឌហៅទេវបុត្តតាមឈ្មោះដើមឈើថា កោដសិម្ពលិ ។ ដើមសិម្ពលិនោះបានឈ្មោះថា កោដសិម្ពលិ ព្រោះមានដើមនិងមែកធំ សូម្បីទេវបុត្តដែលអាស្រ័យនៅលើដើមកោដសិម្ពលិនោះ ក៏មានឈ្មោះយ៉ាងនោះដូចគ្នា ។

លំដាប់នោះ ទេវបុត្តកាលពោលដល់ហេតុនៃការញាប់ញ័រនោះ បានពោលគាថា ៤ ថា

បពិត្រព្រះរាជា ព្រះអង្គមានសាច់ជាអាហារ ឯបក្សីនេះ
មានផ្លែឈើជាអាហារ បក្សីនេះនឹងស៊ីនូវពូជជ្រៃ ពូជលៀប
ពូជល្វាទាំងឡាយ ពូជពោធិ៍បាយទាំងឡាយ ហើយមកជុះ
ដាក់លើដើមឈើរបស់យើង ។

ឈើទាំងឡាយនោះ ដុះក្នុងទីបាំងខ្យល់ក្បែរខាងយើងលូតលាស់ល្អ ឈើទាំងឡាយនោះ មុខជានឹងរួបរឹតយើង ធ្វើយើងមិនឲ្យនៅជាដើមឈើ ។

មានឈើដទៃទៀត ដែលជាឈើបរិបូណ៌ដោយឫស បរិបូណ៌ដោយដើម ត្រូវសកុណជាតិនេះ នាំយកពូជមកបំផ្លាញហើយដែរ ។

ជ្រិត ( ឈើទាំងឡាយមានជ្រៃជាដើម ) រមែងដុះសង្កត់នូវឈើជាធំក្នុងព្រៃ សូម្បីធំចម្រើន បពិត្រព្រះរាជាព្រោះហេតុនោះ យើងឃើញភ័យទៅអនាគត បានជាញាប់ញ័រ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱធហិស្សតិ** សេចក្តីថា នឹងបន្ទោបង់ឧច្ចារៈដាក់ ។ បទថា **តេ រុក្ខា** សេចក្តីថា ដើមឈើទាំងឡាយ មានដើមជ្រៃជាដើមកើតឡើងហើយអំពីផ្លែទាំងនោះ ។ បទថា **សំវិរូហន្តិ** សេចក្តីថា នឹងដុះឡើង គឺនឹងចម្រើនធំឡើង ។ បទថា **មម បស្សេ** សេចក្តីថា ក្នុងរវាងមែកជាដើមរបស់ខ្ញុំ ។ បទថា **និវាតជា** សេចក្តីថា កើតហើយក្នុងទីបាំងខ្យល់ ព្រោះខ្យល់ត្រូវមែករបស់ខ្ញុំបាំងទុក ។ បទថា **បរិយោ នទ្ធិស្សន្តិ** សេចក្តីថា ដើមឈើទាំងនោះធំចម្រើនឡើងយ៉ាងនេះហើយ នឹងគ្របសង្កត់យើងទុក ។ ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **ករិស្សរេ** សេចក្តីថា ក្រោយមក កាលគ្របសង្កត់យ៉ាងនេះហើយ នឹងធ្វើយើងមិនឲ្យជាដើមឈើឡើយ គឺនឹងទម្លាយដោយប្រការទាំងពួង ។ បទថា **រុក្ខាសេ** គឺជា

រុក្ខា បានដល់ ដើមឈើ ។ បទថា **មូលិនោ ខន្ធិនោ** សេចក្តីថា មានឫស សម្បូរផង មានមែកសម្បូរផង ។ ពាក្យថា **ឧមា** ជាពាក្យវេវចនៈនៃពាក្យ ថា **រុក្ខា** នោះឯង ។ បទថា **វីជមាហរិត្វា** សេចក្តីថា នាំនូវពូជផ្លែឈើមក ហើយ ។ បទថា **ហតា** សេចក្តីថា ដើមឈើក្នុងព្រៃនេះ សូម្បីដើមដទៃៗ ដែលវិនាសហើយ មាន ។ បទថា **អជ្ឈារូហា ហិ វឌ្ឍន្តិ** សេចក្តីថា រុក្ខ ទេវបុត្តសម្តែងថា ព្រោះថា ដើមឈើទាំងឡាយ មានដើមនិគ្រោធជាដើម ជាដើមឈើដែលដុះឡើងគ្របសង្កត់គេឯង ហើយនឹងធំជាងដើមឈើមុននិង ដើមឈើដទៃ ។ ក្នុងបទថា **វនប្បតឹ** នេះ មានបាឋៈដល់ ៣ យ៉ាងនោះឯង គឺ **វនេបតិ** ១ **វនស្ស បតិ** ១ **វនប្បតិ** ១ រុក្ខទេវបុត្តហៅគ្រុឌថា រាជា ។ គ្រុឌបានស្តាប់ពាក្យរបស់រុក្ខទេវតាហើយ ទើបពោលគាថាចុងក្រោយថា

អ្នកប្រាជ្ញគប្បីវង្វៀសចំពោះហេតុទាំងឡាយ ដែលគួរវង្វៀស
គប្បីរក្សា ( ប្រយ័ត្ន ) នូវភ័យជាអនាគត ទើបឈ្មោះថា
រមិលមើលនូវលោកទាំងពីរ ព្រោះហេតុនៃភ័យ ជាអនាគត
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនាគតំ ភយំ** សេចក្តីថា ធីរជន កាល វៀរចាកបាណាតិបាតជាដើម ឈ្មោះថារក្សានូវភ័យដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នខ្លះ ដែលប្រព្រឹត្តទៅខាងមុខ គឺអនាគតខ្លះ ។ កាលមិនចូលទៅគប់រក បាបមិត្តនិងបុគ្គលដែលជា គូនៃពៀរវេរា ឈ្មោះថាវង្វៀសក្នុងភ័យដែលមិន ទាន់មកដល់ ។ គួរវាំងប្រយ័ត្នក្នុងភ័យដែលមិនទាន់មកដល់ យ៉ាងនេះ ។

បទថា **អនាគតភយា** សេចក្តីថា ព្រោះហេតុនៃភ័យក្នុងអនាគត ។ ធិរជនលុះពិចារណាឃើញភ័យនោះ ឈ្មោះថាសម្លឹងឃើញ គឺសម្លឹងឃើញទាំងលោកនេះនិងលោកខាងមុខ គ្រុឌកាលពោលយ៉ាងនេះ ទើបឲ្យបក្សីនោះគេចចេញទៅអំពីដើមឈើនោះ ដោយអានុភាពរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបត្រាស់ថា អ្នកទាំងឡាយគួររង្កៀសវត្ថុដែលគួររង្កៀស ដូច្នេះហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងទីបំផុតនៃសច្ចធម៌ ភិក្ខុប្រមាណ ៥០០ រូប តាំងនៅក្នុងអរហត្តផល ហើយទ្រង់ប្រជុំជាតកថា ស្តេចគ្រុឌក្នុងកាលនោះ បានមកជាសារីបុត្តក្នុងកាលឥឡូវនេះ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កោដសិម្ពលិជាតក ចប់

# ធូមការិជាតក

[ ៣៩១ ] ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ព្រះរាជាទ្រង់ព្រះនាម យុធិដ្ឋិល: ព្រះអង្គពេញព្រះទ័យនឹងសុចរិតធម៌ បានត្រាស់សួរវិធុរបណ្ឌិតថា ម្នាលព្រាហ្មណ៍ អ្នកដឹងឬទេ អ្នកណាតែម្នាក់ឯង សោកស្តាយច្រើន ។

[ ៣៩២ ] ( វិធុរបណ្ឌិតពោធិសត្វពោលថា ) ព្រាហ្មណ៍ជាវាសិដ្ឋគោត្ត មានរំកាច់ឧសច្រើននៅក្នុងព្រៃជាមួយនឹងហ្វូងពពែ ជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ បានបង្ហុយផ្សែង ( ដើម្បីការពារកុំឲ្យមូសខាំ ) ។

[ ៣៩៣ ] ពួកម្រឹគឈ្មោះសរភ:[១]ត្រូវមូសខាំ ជុំក្លិនផ្សែងនោះ ក៏ចូលទៅនៅក្នុងសម្នាក់នៃព្រាហ្មណ៍ ជាអ្នកធ្វើផ្សែងនោះក្នុងពេលដែលមានភ្លៀងធ្លាក់ជោកជាំ ។

[ ៣៩៤ ] ព្រាហ្មណ៍នោះចំពាក់ចិត្តនឹងពួកសរភ: លែងរវល់នឹកដល់ពួកពពែថា ( ពពែប៉ុណ្ណោះ ) មកកាន់ក្រោលហើយ ឬថា ( ពពែប៉ុណ្ណោះចេញអំពីក្រោលទៅព្រៃ ) ពួកពពែទាំងនោះរបស់គាត់ក៏វិនាសអស់ទៅ ។

[ ៣៩៥ ] លុះដល់ក្នុងសរទកាល ពួកសរភម្រឹគក៏ចូលទៅកាន់ជើងភ្នំផង កាន់ជងស្ទឹងផង ក្នុងព្រៃដែលគ្មានមូស ។

[ ៣៩៦ ] ចំណែកខាងព្រាហ្មណ៍ ក៏កើតរោគលឿង ស្គមមានសម្បុរអាក្រក់ ព្រោះឃើញពួកសរភម្រឹគទៅបាត់ផង ឃើញពួកពពែវិនាសផង ។

[ ៣៩៧ ] បុគ្គលណាលះបង់អជ្ឈត្តិកជន ( បុរាណ ) របស់ខ្លួនចោលយ៉ាងនេះ ហើយបែរជាធ្វើសេចក្តីរាប់អានចំពោះអាគន្តុកជនវិញ បុគ្គលនោះ តែម្នាក់ឯងតែងសោកស្តាយច្រើន ដូចព្រាហ្មណ៍ជាអ្នកធ្វើផ្សែង ។

**ចប់ ធូមការិជាតកទី ៨ ។**

## អដ្ឋកថា

## ធូមការិជាតក

[ ៣៩១-៣៩៧ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការសង្គ្រោះអាគន្តុកៈរបស់ព្រះបាទកោសល ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **រាជា អបុច្ឆិ វិធុរំ** ដូច្នេះជាដើម ។

បានឮថា សម័យមួយ ព្រះបាទកោសលនោះ ទ្រង់មិនបានសង្គ្រោះទាហានចាស់ដែលមកតាល់តាមបវេណី តែទ្រង់បានធ្វើសក្ការៈរាប់អានដល់ទាហានដែលមកថ្មីៗ ក្នុងនាមជាភ្ញៀវ ក្រោយមកទ្រង់យាងទៅដើម្បីបង្ក្រាបជនបទដែលបះបោរ ទាហានចាស់មិនច្បាំងដោយគិតថា ទាហានថ្មីជាភ្ញៀវបានសក្ការៈនឹងច្បាំង ឯទាហានថ្មីដែលជាភ្ញៀវក៏មិនច្បាំងដោយគិតថា ទាហានចាស់នឹងច្បាំង ចោរក៏ឈ្នះលើព្រះរាជា ។ ព្រះរាជាទ្រង់បរាជ័យហើយ ទ្រង់ជ្រាបភាពដែលខ្លួនបរាជ័យ ព្រោះទោស គឺការសង្គ្រោះទាហានថ្មី ដែលជាភ្ញៀវ ទ្រង់ត្រឡប់មកនគរសាវត្ថី ព្រះតម្រិះថា អញតែម្នាក់ឯងឬដែលធ្វើបែបនេះហើយចាញ់ ឬព្រះរាជាដទៃក៏ធ្លាប់ចាញ់យ៉ាងនេះដែរ ណ្ហើយចុះអញនឹងទូលសួរព្រះទសពល ។ ទ្រង់សោយព្រះក្រយាហារព្រឹកហើយ យាងទៅកាន់វត្តជេតពន នមស្ការព្រះសាស្តាហើយ ទើបទូលសួរសេចក្តីនោះ ។ ព្រះសាស្តាត្រាស់ឆ្លើយថា សូមថ្វាយព្រះពរមហាបពិត្រ មិនមែនតែទ្រង់ប៉ុណ្ណោះទេ សូម្បីព្រះរាជាពីបុរាណ ទ្រង់ធ្វើការសង្គ្រោះទាហានថ្មី ដែលជាអាគន្តុកៈ ហើយទ្រង់បរាជ័យក៏មានដូចគ្នា កាលព្រះរាជាទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទកោរព្យៈ ព្រះនាមធនញ្ជយៈ យុធិដ្ឋិលគោត្ត សោយរាជ្យនៅក្នុងឥន្ទបត្តនគរ ក្នុងដែនកុរុ ។ គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលបុរោហិត របស់ព្រះបាទធនញ្ជយៈនោះ ចម្រើនវ័យហើយ បានទទួលការសិក្សាសិប្បៈគ្រប់យ៉ាងក្នុងនគរតក្កសិលា ត្រឡប់មកឥន្ទបត្តនគរ ហើយទទួលតំណែងបុរោហិត ជាអ្នកថ្វាយអត្ថ និងធម៌ដល់ព្រះរាជាជំនួសបិតាដែលអនិច្ចកម្មទៅហើយ ។ មនុស្សទាំងឡាយ បានដាក់ឈ្មោះលោកថា វិធុរបណ្ឌិត ។ កាលនោះព្រះបាទធនញ្ជយៈ ទ្រង់មិននឹកនាដល់ទាហានចាស់ ទ្រង់ធ្វើការសង្គ្រោះទាហានថ្មីដែលជាអាគន្តុកៈប៉ុណ្ណោះ ។ កាលទ្រង់យាងទៅបង្ក្រាបបច្ចន្តជនបទដែលបង្ករនូវការបះបោរ ទាហានចាស់មិនច្បាំងដោយគិតថា ទាហានថ្មីជាក្មៀវនឹងដឹងកិច្ច ។ ទាហានជាក្មៀវ ក៏មិនច្បាំង ដោយគិតថា ទាហានចាស់នឹងដឹងកិច្ច សេចក្តីថា ទាហានចាស់ក្តី ថ្មីក្តី មិនច្បាំងឡើយ ។ ព្រះរាជាទ្រង់បរាជ័យហើយ យាងត្រឡប់មកឥន្ទបត្តនគរនោះឯង ទ្រង់ត្រិះរិះថា អញបរាជ័យ ព្រោះអញធ្វើការសង្គ្រោះទាហានថ្មីដែលជាអាគន្តុកៈ ។ ថ្ងៃមួយ ព្រះរាជាត្រិះរិះថា អញនឹងសួរវិធុរបណ្ឌិតថា មានតែយើងម្នាក់ឯងឬ ធ្វើការសង្គ្រោះទាហានថ្មីដែលជាអាគន្តុកៈហើយបរាជ័យ ឬព្រះរាជាអង្គដទៃៗដែលធ្លាប់បរាជ័យមកហើយក៏មាន ហើយត្រាស់សួរសេចក្តីនោះនឹងវិធុរបណ្ឌិត ដែលមកគាល់ព្រះរាជា ហើយអង្គុយ ។ ព្រះសាស្តាកាលទ្រង់លម្អិតអាការដែលត្រាស់សួររបស់ព្រះរាជាឲ្យជាក់ច្បាស់ បានត្រាស់គន្ធៈគាថាថា

ព្រះរាជាទ្រង់ព្រះនាម យុធិដ្ឋិលៈ ព្រះអង្គពេញព្រះទ័យនឹង

សុចរិតធម៌ បានត្រាស់សួរវិធុរបណ្ឌិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មកាមោ** បានដល់ ទ្រង់មានសុចរិតធម៌ជាទីស្រឡាញ់ ។ ចំណែកគាថាដ៏សេសថា

ម្នាលព្រាហ្មណ៍ អ្នកដឹងឬទេ អ្នកណាតែម្នាក់ឯង សោកស្តាយ

ច្រើន ដូច្នេះ ។

មានសេចក្តីដូចតទៅនេះថា នែព្រាហ្មណ៍ ធម្មតា អ្នកដឹងខ្លះដែរឬទេថា បុគ្គលណាម្នាក់ក្នុងលោកនេះ សោយសោកច្រើន គឺសោយសោកដោយអាការផ្សេងៗ ។

ព្រះពោធិសត្វ កាលស្តាប់ពាក្យនោះហើយ ក៏នាំឧទាហរណ៍នេះមកសម្តែងថា បពិត្រមហារាជ សេចក្តីសោករបស់ព្រះអង្គ ឈ្មោះថាជាសេចក្តីសោកឬ ក្នុងកាលមុន ព្រាហ្មណ៍ចិញ្ចឹមពពែម្នាក់ ឈ្មោះធូមការី គៀងពពែមួយហ្វូងធំទៅនោះឯង ធ្វើក្រោលទុកក្នុងព្រៃ ដាក់ពពែក្នុងក្រោលនោះ បង្កាត់ភ្លើងនិងផ្សែង បដិបត្តិហ្វូងពពែ បរិភោគទឹកដោះជាដើម ស្នាក់នៅ ។ បុរសនោះឃើញសារកៈ ( ក្តាន់ ) ទាំងឡាយដែលមកទីនោះ មានពណ៌ដូចមាស ហើយធ្វើសេចក្តីស្រឡាញ់ក្នុងសារកៈទាំងនោះ ធ្វើសក្ការៈដែលធ្លាប់ធ្វើដល់ពពែ ដល់សារកៈទាំងឡាយ ដោយមិននឹកនាដល់ពពែ កាលពួកសារកៈគេចទៅព្រៃហិមពាន្តក្នុងសារទកាល ពពែទាំងឡាយក៏បាត់ទៅ សារកៈក៏មិនឃើញ ទើបកើតរោគស្គមលឿងព្រោះសេចក្តីសោក ដល់នូវការអស់ជីវិតហើយ ។

ព្រាហ្មណ៍នេះធ្វើការសង្គ្រោះសត្វដែលជាអាគន្តុកៈ ទើបសោយសោក លំបាក ដល់នូវសេចក្តីវិនាសច្រើន ជាងទ្រទ្រង់រាប់រយដង រាប់ពាន់ដង ដូច្នេះទើបពោលគាថាទាំងនេះថា

ព្រាហ្មណ៍ជាវាសិដ្ឋគោត្ត មានរំកាច់ខសច្រើននៅក្នុងព្រៃ
ជាមួយនឹងហ្វូងពពែ ជាអ្នកមិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ
បានបង្អុយផ្សែង ( ដើម្បីការពារកុំឲ្យមូសខាំ ) ។

ពួកម្រឹគឈ្មោះសរភៈ ត្រូវមូសខាំ ជុំកិ្ខនផ្សែងនោះក៏ចូល
ទៅនៅក្នុងសម្នាក់នៃព្រាហ្មណ៍ ជាអ្នកធ្វើផ្សែងនោះ ក្នុងពេល
ដែលមានភ្លៀងធ្លាក់ជោកជាំ ។

ព្រាហ្មណ៍នោះចំពាក់ចិត្តនឹងពួកសរភៈ លែងរវល់នឹកដល់
ពួកពពែថា ( ពពែប៉ុណ្ណោះ ) មកកាន់ក្រោលហើយ ឬថា
( ពពែប៉ុណ្ណោះចេញអំពីក្រោលទៅព្រៃ ) ពួកពពែទាំងនោះ
របស់គាត់ក៏វិនាសអស់ទៅ ។

លុះដល់ក្នុងសរទកាល ពួកសរភម្រឹគក៏ចូលទៅកាន់ជើង
ភ្នំផង កាន់ដងស្ទឹងផង ក្នុងព្រៃដែលគ្មានមូស ។

ចំណែកខាងព្រាហ្មណ៍ ក៏កើតរោគលឿង ស្គមមានសម្បុរ
អាក្រក់ ព្រោះឃើញពួកសរភម្រឹគទៅបាត់ផង ឃើញពួកពពែ
វិនាសផង ។

បុគ្គលណាលះបង់អជ្ឈត្តិកជន ( បុរាណ ) របស់ខ្លួនចោល

យ៉ាងនេះ ហើយបែរជាធ្វើសេចក្តីរាប់អាន ចំពោះអាគន្តុកជន
វិញ បុគ្គលនោះតែម្នាក់ឯងតែងសោកស្តាយច្រើន ដូចព្រា-
ហ្មណ៍ ជាអ្នកធ្វើផ្សែង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ពហុតេជ្ជោ** សេចក្តីថា ជាអ្នកមានភ្លើងគ្រប់គ្រាន់ ។ បទថា **ធូមំ អកាសិ** សេចក្តីថា បានបង្កាត់ឡើងទាំងភ្លើងទាំងផ្សែង ដើម្បីជាប្រយោជន៍ដល់ការនាំទៅនូវអន្តរាយ អំពីសត្វល្អិត ។ ពាក្យថា **វាសេដ្ឋោ** ជាគោត្ត គឺជាឈ្មោះត្រកូលរបស់បុរសនោះ ។ បទថា **អតន្ទិតោ** បានដល់ ជាអ្នកមិនខ្ជិលច្រអូស ។ បទថា **តំ ធូមគន្ធេន** សេចក្តីថា ព្រោះក្លិនផ្សែងនោះ ។ បទថា **សរភា** បានដល់ សរភៈម្រឹគ គឺសត្វក្តាន់ ។ បទថា **មកសទ្ទិតា** សេចក្តីថា ពួកមូសទាំងឡាយ រុកកួន គឺបៀតបៀនហើយ ។ សូម្បីសត្វល្អិតដ៏សេស ក៏កាន់យកហើយដោយ **មកស** សព្ទនោះឯង ។ បទថា **វស្សាវាសំ** មានសេចក្តីថា នៅហើយអស់រាត្រីនៃរដូវភ្លៀងក្នុងសម្នាក់នៃព្រាហ្មណ៍នោះ ។ បទថា **មធំ កត្វា** សេចក្តីថា ឲ្យកើតសេចក្តីស្រឡាញ់ ។ បទថា **ឆាវពុជ្ឈថ** សេចក្តីថា មិនដឹងថា ពពែទាំងឡាយចេញអំពីព្រៃកំពុងមកចូលក្រោល ចេញអំពីក្រោលកំពុងចូលទៅព្រៃ និងមកហើយចំនួនប៉ុណ្ណេះ មិនទាន់មកចំនួនប៉ុណ្ណេះ ។ បទថា **តស្ស តា វិនស្សុំ** សេចក្តីថា កាលគាត់មិនបានពិនិត្យពិច័យពពែទាំងនោះយ៉ាងនេះ ពពែទាំងឡាយដែលគាត់មិនបានរក្សាចាកអន្តរាយ មានសីហៈជាដើម វិនាសទៅហើយ ព្រោះអន្តរាយមានសីហៈជាដើម គឺពពែទាំងឡាយវិនាសទៅហើយ ។ បទថា **ឆទិនំ បភវានិ**

ច សេចក្ដីថា ចូលទៅហើយកាន់ទីដែលជាទីកើតដំបូង គឺប្រកពនៃស៊ីង ទាំងឡាយ ដែលកើតអំពីក្អំផង ។ បទថា **វិភវំ** បានដល់ ការមិនមាន ។ ពពែទាំងឡាយដល់នូវសេចក្ដីវិនាសហើយ ឃើញគឺជីងហើយ ។ បទថា **កីសោ ច វិវណ្ណោ** សេចក្ដីថា ព្រាហ្មណ៍លះនូវពពែដែលឲ្យនូវទឹកដោះជា ដើម ហើយសង្គ្រោះសរកៈទាំងឡាយ កាលមិនឃើញសត្វទាំង ២ ប្រភេទ នោះ ជាអ្នកសាបសូន្យចាកសត្វទាំង ២ ពួក ត្រូវសេចក្ដីសោកគ្របសង្កត់ ហើយ ទើបបានជាអ្នកស្គាំងស្គម មានពណ៌សម្បុរស្ងេកស្ងាំង ។ បទថា **ឯវំ យោ សន្និរង្កត្វា** សេចក្ដីថា កាលបើដូច្នេះ មហាបពិត្រ បុគ្គលណា នាំមនុស្សខាងក្នុងរបស់ខ្លួនដែលជាអ្នកចាស់ចេញទៅ គឺលះបង់ហើយ ធ្វើនូវ ការស្រឡាញ់ ក្នុងមនុស្សដែលមកថ្មី ដោយមិននឹកនាដល់បុគ្គលណាម្នាក់ ឡើយ បុគ្គលនោះតែម្នាក់ដូចគ្នានឹងទ្រង់ តែងសោយសោកច្រើន ដូច ព្រាហ្មណ៍អ្នកធ្វើផ្សែងដែលទូលព្រះបង្គំទូលថ្វាយទ្រង់ហើយ ដូច្នោះ ។

ព្រះមហាសត្វទូលព្រះរាជាឲ្យទ្រង់រព្ញកយ៉ាងនេះហើយ ចំណែកព្រះរាជា ទ្រង់រព្ញកបានហើយ ទ្រង់ជ្រះថ្លាហើយ បានព្រះរាជទានទ្រព្យជាច្រើនដល់ ព្រះពោធិសត្វនោះ ។ តាំងពីនោះមក ទ្រង់ក៏ធ្វើការសង្គ្រោះមនុស្សខាងក្នុង ប៉ុណ្ណោះ ទ្រង់បំពេញបុណ្យទាំងឡាយមានទានជាដើមហើយ ជាអ្នកមានស្ថាន សួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ ប្រជុំជាតកថា ព្រះបាទកោរព្យៈក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវ

នេះ ព្រាហ្មណ៍ធូមការីក្នុងកាលនោះ បានមកជាព្រះបាទបសេនទិកោសល ឯវិធូរបណ្ឌិតក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា ធូមការិជាតក ចប់

## ជាគរជាតក

[ ៣៩៨ ] ( រុក្ខទេវតាសួរប្រស្នាថា ) កាលសត្វទាំងឡាយកំពុងភ្ញាក់ អ្នកណាជាអ្នកដេកលក់ក្នុងលោកនេះ កាលសត្វទាំងឡាយកំពុងដេកលក់អ្នកណាជាអ្នកភ្ញាក់ក្នុងលោកនេះ អ្នកណាហ្ន៎ ដឹងច្បាស់នូវប្រស្នារបស់យើងនុ៎ះបាន អ្នកណាឆ្លើយតបប្រស្នាយើងនោះបាន ។

[ ៣៩៩ ] ( តាបសពោធិសត្វពោលថា ) កាលសត្វទាំងឡាយកំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់ កាលសត្វទាំងឡាយកំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះ ខ្ញុំឆ្លើយតប ( ប្រស្នានុ៎ះ ) របស់អ្នកបាន ។

[ ៤០០ ] ( រុក្ខទេវតានោះសួរទៀតថា ) កាលសត្វទាំងឡាយកំពុងភ្ញាក់ អ្នកដេកលក់តើដូចម្តេច កាលសត្វទាំងឡាយកំពុងដេកលក់ អ្នកភ្ញាក់តើដូចម្តេច អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះដូចម្តេច អ្នកឆ្លើយតបខ្ញុំដូចម្តេច ។

[ ៤០១ ] ( ពោធិសត្វពោលថា ) សត្វទាំងឡាយណាមិនដឹងច្បាស់នូវធម៌ផង មិនដឹងថា ( នេះ ) ជាសញ្ញមៈផង ( នេះ ) ជាទមៈផង កាលបើសត្វទាំងឡាយនោះដេកលក់ទាំងសេចក្តីប្រមាទហើយ ម្នាលទេវតាខ្ញុំរមែងភ្ញាក់ ។

[ ៤០២ ] ពួកសត្វណាលះបង់នូវរាគៈ ទោសៈនិងអវិជ្ជាបាន កាលបើពួកសត្វនោះកំពុងភ្ញាក់ ម្នាលទេវតា ខ្ញុំជាអ្នកដេកលក់ ។

[ ៤០៣ ] កាលបើពួកសត្វកំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់យ៉ាងនេះ កាលបើពួកសត្វកំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់យ៉ាងនេះ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះយ៉ាងនេះ ខ្ញុំឆ្លើយតបអ្នកយ៉ាងនេះ ។

[ ៤០៤ ] ( រុក្ខទេវតាមានចិត្តត្រេកអរពោលសរសើរថា ) ត្រូវហើយ កាលបើពួកសត្វកំពុងភ្ញាក់ អ្នកជាបុគ្គលដេកលក់ត្រូវហើយ កាលបើពួកសត្វកំពុងដេកលក់ អ្នកជាបុគ្គលភ្ញាក់ត្រូវហើយ អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះអ្នកឆ្លើយតបខ្ញុំត្រូវហើយ ។

**ចប់ ជាគរជាតកទី ៩ ។**

## អដ្ឋកថា

## ជាគរជាតក

[ ៣៩៨-៤០៤ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ ប្រារព្ធឧបាសកម្នាក់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **កោធ ជាគរតំ សុត្តោ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ឧបាសកម្នាក់នោះ ជាអរិយសាវក ជាសោតាបន្នដើរផ្លូវកន្តារទៅជាមួយឈ្មួញរទេះអ្នកក្រុងសាវត្ថី ។ ប្រធានឈ្មួញរទេះ បញ្ឈប់រទេះ ៥០០ ក្នុងទីមួយកន្លែង ក្នុងទីដែលរកទឹកបានងាយ ចាត់ចែងរបស់ទំពា របស់បរិភោគ ហើយចូលទីសម្រាក ។ មនុស្សទាំងនោះ នាំគ្នាដេកក្នុងទីនោះៗហើយ ក៏លក់ទៅ ។ ឯឧបាសកតាំងចិត្តដើមចង្រ្កម ត្រង់ដើមឈើមួយដើមក្បែរៗក្រុមរទេះ ។ លំដាប់នោះ ពួកចោរ ៥០០ បំណងនឹងប្លន់ពួកឈ្មួញនោះ បាននាំគ្នាកាន់អាវុធច្រើនប្រភេទ មកឈរព័ទ្ធឈ្មួញទាំងនោះ ។ ពួកចោរឃើញឧបាសកនោះកំពុងចង្រ្កមគិតថា ពួកយើងនឹងប្លន់ក្នុងពេលឧបា-

សកនេះដេកលក់ ហើយបាននាំគ្នានៅក្នុងទីនោះៗ ។ ឯឧបាសកក៏បានចង្រ្កម អស់រាត្រីទាំង ៣ យាមនោះឯង ។ លុះពេលទៀបភ្លឺ ពួកចោរនាំគ្នាចោល ដុំថ្ម និងដំបងជាដើមដែលកាន់មក ហើយពោលថា ប្រធានរទេះដ៏ចម្រើន លោកអាស្រ័យបុរសនេះដែលជាអ្នកភ្ញាក់រឭកដោយការមិនប្រមាទ បានជីវិត ហើយ ជាម្ចាស់របស់ទ្រព្យដែលមានរបស់អ្នក អ្នកគួរធ្វើសក្ការៈបុរសនេះ ដូច្នេះហើយ ទើបចៀសចេញទៅ ។ មនុស្សទាំងឡាយក្រោកឡើងតាមកាល នោះឯង ឃើញដុំថ្ម និងដំបងជាដើមដែលពួកចោរទាំងនោះទុកចោល ទើប ពោលថា ពួកយើងបានជីវិតព្រោះអាស្រ័យឧបាសកនេះ ហើយនាំគ្នាធ្វើនូវ សក្ការៈដល់ឧបាសក ។ ឯឧបាសកទៅកាន់ទីដែលខ្លួនត្រូវការ ធ្វើកិច្ចស្រេច ហើយ ត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ទៅកាន់វិហារជេតពន បូជាព្រះមុនី នមស្ការហើយអង្គុយ កាលព្រះសាស្តាត្រាស់សួរថា ម្នាលឧបាសក អ្នក បាត់ទៅឬ ទើបក្រាបទូលសេចក្តីនោះ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក អ្នកមិនដេក បដិបត្តិ តែមិនបានគុណវិសេស ចំណែកបណ្ឌិតក្នុងកាលមុន កាលបដិបត្តិ ក៏បាននូវគុណវិសេស ដូច្នេះហើយ ត្រូវឧបាសកអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកៈដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ កើតក្នុងត្រកូលព្រាហ្មណ៍ ធំចម្រើនវ័យហើយ រៀនសិល្ប សាស្ត្រគ្រប់យ៉ាងឯនគរតក្កសិលា លុះចប់ត្រឡប់មកគ្រប់គ្រងផ្ទះ ។ ចំណោរ កាលតមក ចេញបួសជាឥសី មិនយូរប៉ុន្មាន ក៏ញុំាងឈាន និងអភិញ្ញាឲ្យ

កើតឡើង ជាអ្នកមានឥរិយាបថឈរចង្ក្រមក្នុងទឹកដីនៃព្រៃហិមពាន្ត មិនចូលដល់ការដេក ចង្ក្រមអស់រាត្រី ។ លំដាប់នោះ ទេវតាដែលកើតលើដើមឈើក្បែរទីចង្ក្រមរបស់ឥសី មានចិត្តត្រេកអរ ឈរត្រង់ប្រគាបឈើ កាលនឹងសួរបញ្ហា ទើបពោលគាថាទី ១ ថា

កាលសត្វទាំងឡាយកំពុងភ្ញាក់ អ្នកណា ជាអ្នកដេកលក់ក្នុងលោកនេះ កាលសត្វទាំងឡាយកំពុងដេកលក់ អ្នកណា ជាអ្នកភ្ញាក់ក្នុងលោកនេះ អ្នកណាហ្ន៎ ដឹងច្បាស់នូវប្រស្នារបស់យើងនុ៎ះបាន អ្នកណា ឆ្លើយតបប្រស្នាយើងនោះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោធ** កាត់បទជា **កោ ឥធ** ។ បទថា **កោ មេតំ** សេចក្ដីថា ទេវតាសួរថា អ្នកណាដឹងច្បាស់នូវបញ្ហានេះរបស់ខ្ញុំ ។ បទថា **កោ តំ បដិភណាតិ មេ** សេចក្ដីថា ទេវតាសួរថា អ្នកណានឹងឆ្លើយបញ្ហាដែលយើងសួរនោះ របស់យើងបាន គឺអ្នកណាអាចពោលឆ្លើយបញ្ហាបាន ។

ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយទើបពោលគាថានេះថា

កាលសត្វទាំងឡាយកំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់ កាលសត្វទាំងឡាយកំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះ ខ្ញុំឆ្លើយតប ( ប្រស្នានុ៎ះ ) របស់អ្នកបាន ។

កាលពោលគាថានេះហើយ ត្រូវទេវតានោះសួរគាថានេះថា

កាលសត្វទាំងឡាយកំពុងភ្ញាក់ អ្នកដេកលក់តើដូចម្ដេចកាល

សត្វទាំងឡាយកំពុងដេកលក់ អ្នកភ្ញាក់តើដូចម្តេច អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះ ដូចម្តេច អ្នកឆ្លើយតបខ្ញុំដូចម្តេចដូច្នេះ ។

កាលព្យាករសេចក្តីនោះ ទើបពោលគាថាទាំងនេះថា

សត្វទាំងឡាយណា មិនដឹងច្បាស់នូវធម៌ផង មិនដឹងថា ( នេះ ) ជាសញ្ញមៈផង ( នេះ ) ជាទមៈផង កាលបើសត្វទាំងឡាយនោះដេកលក់ទាំងសេចក្តីប្រមាទហើយ ម្នាលទេវតា ខ្ញុំរមែងភ្ញាក់ ។

ពួកសត្វណាលះបង់នូវរាគៈ ទោសៈនិងអវិជ្ជាបាន កាលបើពួកសត្វនោះកំពុងភ្ញាក់ ម្នាលទេវតា ខ្ញុំជាអ្នកដេកលក់ ។

កាលបើពួកសត្វកំពុងភ្ញាក់ខ្ញុំជាអ្នកដេកលក់យ៉ាងនេះ កាលបើពួកសត្វកំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់យ៉ាងនេះ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះយ៉ាងនេះ ខ្ញុំឆ្លើយតបអ្នកយ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **កថំ ជាគរតំ សុត្តោ** សេចក្តីថា លោកឈ្មោះថាជាអ្នកភ្ញាក់ហើយក្នុងរវាងសត្វទាំងឡាយដែលភ្ញាក់ដូចម្តេច ។ ក្នុងបទទាំងអស់ក៏មានន័យដូច្នេះ ។ បទថា **យេ ធម្មំ** សេចក្តីថា សត្វទាំងឡាយណាមិនដឹងច្បាស់នូវលោកុត្តរធម៌ទាំង ៩ យ៉ាង ។ បទថា **សញ្ញមោតិ ទមោតិ ច** សេចក្តីថា មិនដឹងនូវសីលផង ឥន្ទ្រិយសំវរៈផង ដែលមកហើយដោយមគ្គយ៉ាងនេះថា នេះសញ្ញមៈ នេះទមៈ ដូច្នេះ ។ ពិតហើយ

ឥន្ទ្រិយសំវរៈ លោកហៅថា ទមៈ ព្រោះសង្កត់នូវឥន្ទ្រិយទាំងឡាយមានចិត្តជាគម្រប់ ៦ ។ បទថា **តេសុ សុត្តប្បមាទេសុ** សេចក្តីថា កាលសត្វទាំងនោះដេកលក់ហើយដោយអំណាចកិលេស ខ្ញុំក៏ភ្ញាក់ដោយអំណាចនៃសេចក្តីមិនប្រមាទ ។ គាថាថា **យេសំ រាគោ ច** ជាដើម មានអត្ថថា កិលេសទាំងនេះគឺរាគៈ ពោលគឺសេចក្តីលោភ ១៥០០ ដែលលោកសម្តែងទុកដោយសតបទ ( បទមួយរយ ) ទោសៈដែលមានអាឃាតវត្ថុ ៩ ប្រការជាសមុដ្ឋាននិងអវិជ្ជាដែលជាការមិនដឹងក្នុងវត្ថុ ៨ ប្រការ មានទុក្ខជាដើមដែលព្រះមហាខីណាស្រពពួកណាធ្វើឲ្យប្រាសចាកហើយ គឺលះបានហើយ នៃទេវតា កាលព្រះអរិយៈទាំងនោះកំពុងភ្ញាក់ដោយអាការទាំងពួង ខ្ញុំឈ្មោះថាដេកលក់ហើយ ព្រោះប្រៀបធៀបជាមួយព្រះអរិយៈទាំងនោះ ។ បទថា **ឯវំ ជាគរតំ** សេចក្តីថា នៃទេវតា ខ្ញុំឈ្មោះថា ជាអ្នកដេកលក់ហើយ ក្នុងរវាងព្រះអរិយៈទាំងឡាយ ដែលកំពុងភ្ញាក់ ដោយហេតុយ៉ាងនេះ ។ ក្នុងបទទាំងអស់ក៏មានន័យដូច្នេះ ។

កាលព្រះមហាសត្វ ស្រាយបញ្ហាយ៉ាងនេះហើយ ទេវតាពេញចិត្ត កាលនឹងធ្វើការសរសើរព្រះមហាសត្វ ទើបពោលគាថាចុងក្រោយថា

ត្រូវហើយ កាលបើពួកសត្វកំពុងភ្ញាក់ អ្នកជាបុគ្គលដេកលក់
ត្រូវហើយ កាលបើពួកសត្វកំពុងដេកលក់ អ្នកជាបុគ្គលភ្ញាក់
ត្រូវហើយ អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះ អ្នកឆ្លើយតប
ខ្ញុំត្រូវហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាធុ** ជាដើម សេចក្ដីថា អ្នកឆ្លើយបញ្ហានេះបានល្អហើយ គឺចម្រើនហើយ សូម្បីខ្ញុំក៏ឆ្លើយបញ្ហានេះយ៉ាងនេះដូចគ្នា ។ ទេវតាកាលធ្វើការសរសើរព្រះមហាសត្វយ៉ាងនេះហើយ ក៏បានចូលទៅកាន់វិមានរបស់ខ្លួននោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ទេវតា ក្នុងកាលនោះ បានមកជាឧប្បលវណ្ណាថេរីក្នុងកាលឥឡូវនេះ ឯតាបសក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថា ជាគរជាតក ចប់**

# កុម្មាសបិណ្ឌជាតក

[ ៤០៥ ] ( ព្រះរាជាពោធិសត្វបានពោលថា ) បានឮថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយដែលលោកមានពោធិញាណមិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលសោះកក្រោះ ឥតរសប្រៃ ។ ដំរី គោ និងសេះដ៏ច្រើនទាំងនេះផង ទ្រព្យ ស្រូវ និងផែនដីទាំងអស់ផង នាងនារីទាំងឡាយ ដែលប្រៀបដូចជាស្រ្តីអប្សរទាំងនេះផង សុទ្ធតែជារបស់ខ្ញុំ អ្នកចូរមើលនូវផលនៃដុំនំកុម្មាសៈ ។

[ ៤០៦ ] ( នាងទេវីបានពោលថា ) បពិត្រព្រះរាជកុញ្ជរ មានព្រះអធ្យាស្រ័យជាកុសល ទ្រង់ញុំាងដែនឲ្យចម្រើន ព្រះអង្គត្រាស់គាថាទាំងឡាយរឿយៗ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរទ្រង់ ព្រះអង្គមានព្រះទ័យប្រកបដោយបីតិក្រៃពេក ហើយទ្រង់ត្រាស់ ( គាថាទាំងនុ៎ះ ) ។

[ ៤០៧ ] ( ព្រះមហាសត្វបានត្រាស់គាថាទាំងនេះថា ) យើងបានកើតក្នុងត្រកូលមួយក្នុងក្រុងនេះដែរ ជាអ្នកស៊ីឈ្នួលធ្វើការងាររបស់បុគ្គលដទៃ ជាអ្នកសង្រួមក្នុងសីល យើងចេញទៅធ្វើការងារ បានជួបនឹងសមណៈ ៤ អង្គ លោកបរិបូណ៌ដោយអាចារនិងសីល មានសេចក្តីត្រជាក់ ទាំងឥតមានអាសវៈឡើយ ។ យើងបានញុំាងចិត្តឲ្យជ្រះថ្លាចំពោះសមណៈទាំងនោះ បាននិមន្តលោកឲ្យគង់លើកម្រាលស្លឹកឈើ លុះយើងមានចិត្តជ្រះថ្លាហើយ បានប្រគេននំកុម្មាសៈដល់ព្រះបច្ចេកពុទ្ធទាំងឡាយដោយដៃរបស់ខ្លួន ។ ឯផលរបស់យើងប្រាកដដូច្នេះ នេះជាផលរបស់កម្មជាកុលសនោះ យើងសោយរាជ្យដ៏ស្តុកស្តម្ភប្រសើរលើធរណីនេះ ។

[ ៤០៨ ] ( នាងទេវីពោលថា ) បពិត្រព្រះអង្គមានព្រះអធ្យាស្រ័យជាកុសល សូមព្រះអង្គទ្រង់ព្រះរាជទានហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គញ៉ាំងចក្រធម៌ឲ្យប្រព្រឹត្តទៅ បពិត្រព្រះរាជាមានព្រះអធ្យាស្រ័យជាកុសល ព្រះអង្គកុំជាអ្នកមិនប្រកបដោយធម៌ សូមទ្រង់រក្សានូវអនុធម៌ ។

[ ៤០៩ ] ( ព្រះមហាសត្វទ្រង់ត្រាស់ថា ) ម្នាលនាងមានឆោមល្អ យើងនោះនឹងដើរតាមតម្រាយ ដែលព្រះអរិយៈធ្លាប់ប្រព្រឹត្តរឿយៗ មកនោះឯង ម្នាលនាងដ៏ល្អ ជាធីរបស់ព្រះបាទកោសល ការបានជួបប្រទះនូវព្រះអរហន្តទាំងឡាយ ជាទីគាប់ចិត្តរបស់យើងពន់ពេក ។

[ ៤១០ ] ( ព្រះរាជាទ្រង់សួរនាងទេវីថា ) ម្នាលនាងសុកោសលធីតា នាងប្រៀបដូចជាស្ត្រីទេពអប្សរជាទេវធីតា ( របស់សក្កទេវរាជ ) ផើតឆាយក្នុងកណ្តាលនៃពួកនាងនារី នាងបានធ្វើនូវកម្មដ៏ចម្រើនដូចម្តេច នាងមានសម្បុរល្អដោយហេតុអ្វី ។

[ ៤១១ ] ( នាងទេវីឆ្លើយថា ) បពិត្រក្សត្រិយ៍ ខ្ញុំម្ចាស់ជាទាសីបម្រើអ្នកដទៃរបស់ត្រកូលអម្ពដ្ឋៈ ជាស្ត្រីសង្រួម ចិញ្ចឹមជីវិតដោយធម៌ មានសីលធម៌មានការឃើញមិនអាក្រក់ ។ កាលនោះខ្ញុំជាស្ត្រីមានចិត្តត្រេកអរវីករាយខ្ជួនឯង បានប្រគេនភត្តដែលគេដួស ( ទុកបម្រុងខ្ញុំ ) ដល់ភិក្ខុ ( ព្រះបច្ចេកពុទ្ធ ) ដែលត្រាច់ទៅ ( ដើម្បីបិណ្ឌបាត ) ផលប្រាកដដូច្នេះនេះ គឺជាផលនៃបុញ្ញកម្មនោះ ។

**ចប់ កុម្មាសបិណ្ឌជាតកទី ១០ ។**

# អដ្ឋកថា

# កុម្មាសបិណ្ឌជាតក

[ ៤០៥-៤១១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវី ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **ន កិរត្ថិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ព្រះនាងមល្លិកានោះជាធីតារបស់នាយមាលាការម្នាក់ក្នុងនគរសាវត្ថី មានរូបឆោមលោមពណ៌ល្អក្រៃលែង មានបុណ្យច្រើន កាលព្រះនាងមានអាយុ ១៦ ឆ្នាំ ថ្ងៃមួយ ទៅកាន់សួនផ្កា មួយអន្លើដោយទារិកាទាំងឡាយ ខ្ចប់នំកុម្មាស ៣ ដុំ ដាក់ក្នុងល្អីដើរទៅ ។ កាលចេញ អំពីព្រះនគរ ឃើញព្រះមានព្រះភាគទ្រង់បញ្ចេញព្រះរស្មីនៃព្រះសរីរៈ មានភិក្ខុសង្ឃចោមរោម កំពុងចូលទៅកាន់ព្រះនគរ ទើបបង្អោនទំនុកម្មាសទាំងនោះចូលទៅថ្វាយ ។ ព្រះសាស្តាទ្រង់បង្អោនបាត្រ ដែលស្តេចចាតុម្មហារាជិកាថ្វាយដើម្បីទទួល ។ ឯនាងវន្ទាបាទារបស់ព្រះសាស្តាដោយសិរសាគឺត្បូងហើយ សរីរៈមានបីតិដែលមានពុទ្ធគុណជាអារម្មណ៍ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្តាកាលទ្រង់ទតនាងទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។ ព្រះអានន្ទទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ ជាបច្ច័យក្នុងការញញឹមរបស់ទ្រង់ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ហេតុនៃការញញឹមដល់ព្រះអានន្ទថា ម្នាលអានន្ទ កុមារិកានេះ នឹងបានជាអគ្គមហេសីរបស់ព្រះបាទកោសលក្នុងថ្ងៃនេះឯង ព្រោះផលនៃការឲ្យនំកុម្មាសទាំងនេះ ។ ឯកុមារិកាទៅសួនផ្កាហើយ ។ ថ្ងៃនោះឯង ព្រះបាទកោសលទ្រង់ច្បាំងចាញ់ព្រះ

បាទអជាតសត្តុ បរាជ័យក្នុងការច្បាំងហើយ កាលទ្រង់ជកជ័យ បានផែល សេះមួយយានមក ទ្រង់ស្តាប់សំឡេង ច្រៀងរបស់នាង មានព្រះហឫទ័យ ប្រតិព័ទ្ធ ទើបទ្រង់ញាក់សេះឲ្យបែរមុខចូលចម្ការនោះ ។ កុមារិកាជាអ្នកដល់ ព្រមដោយបុណ្យ ឃើញព្រះរាជាហើយមិនរត់ឡើយ មកចាប់បង្ហៀរសេះ ។ ព្រះរាជាប្រថាប់លើខ្នងសេះនោះឯង សួរថា នាងមានប្តីហើយឬ កាលទ្រង់ ជ្រាបថាមិនទាន់មាន ទើបចុះអំពីខ្នងសេះ ទ្រង់នឿយហត់ព្រោះខ្យល់និងកម្តៅ ថ្ងៃ ទ្រង់ផ្ទុំលក់បន្តិច លើភ្លៅរបស់នាង ហើយឲ្យនាងអង្គុយលើខ្នងសេះមាន ពលនិកាយចោមរោមចូលព្រះនគរ ។ ទ្រង់បញ្ជូននាងទៅកាន់ផ្ទះត្រកូលរបស់ នាង ក្នុងវេលាល្ងាចទ្រង់បញ្ជូនយានទៅ ឲ្យនាំនាងមកអំពីផ្ទះរបស់ត្រកូល ដោយសក្ការៈ និងការរាប់អានច្រើន ឲ្យអង្គុយលើគំនររតនៈ ធ្វើអភិសេក ហើយ តាំងនៅក្នុងតំណែងជាអគ្គមហេសី ។ តាំងពីកាលនោះមក ព្រះនាង ជាទីត្រេកអរ ជាទីពេញព្រះរាជហឫទ័យរបស់ព្រះរាជា ព្រះនាងប្រកបដោយ កល្យាណធម៌ ៥ ប្រការ មានការភ្ញាក់មុនប្តីជាដើម ព្រះនាងបម្រើព្រះស្វាមី ដូចទេវតា ជាអ្នកជិតស្និទ្ធនឹងព្រះសម្មាសម្ពុទ្ធ ។ រឿងដែលព្រះនាងថ្វាយនំ កុម្មាស ៣ ដុំ ដល់ព្រះមុនី បានជួបនូវសម្បត្តិនោះ ក៏ល្បីទូទៅពេញព្រះ នគរ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយ នាំគ្នាសន្ទនាឡើងត្រង់ធម្មសភាថា អាវុសោ ព្រះនាងមល្លិកាទេវីថ្វាយនំ ៣ ដុំ ដល់ព្រះសម្មាសម្ពុទ្ធ ដោយផលនៃការ ថ្វាយនំទាំងនោះ នាងបានអភិសេកក្នុងថ្ងៃនោះឯង ព្រះពុទ្ធទាំងឡាយជា បុគ្គលមានគុណធំក្រៃលែង គួរអស្ចារ្យពិត ។ ព្រះសាស្តាយានមកហើយ

ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនគួរអស្ចារ្យឡើយ ការដែលនាងមល្លិកាទេវីថ្វាយនំកុម្មាស ដល់ព្រះសព្វញ្ញុពុទ្ធមួយអង្គ ហើយបានទទួលភាពជាអគ្គមហេសីរបស់ព្រះបាទកោសលនោះ ព្រោះហេតុអ្វី ព្រោះព្រះពុទ្ធទាំងឡាយ ជាបុគ្គលមានគុណច្រើន ឯបណ្ឌិតក្នុងកាលមុនបានថ្វាយនំកុម្មាសសាប មិនដាក់អំបិល មិនមានប្រេង មិនដាក់ស្ករអំពៅដល់ព្រះ-បច្ចេកពុទ្ធទាំងឡាយ ហើយបានទទួលសិរីរាជសម្បត្តិ ក្នុងដែនកាសីប្រមាណ ៣០០ យោជន៍ ក្នុងអត្តភាពទី ២ ព្រោះផលនៃការថ្វាយនំនោះ ទើបគួរអស្ចារ្យពិត ដូច្នេះហើយ ទ្រង់បាននាំយករឿងក្នុងអតីតមកសាធកៈ ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលអ្នកក្រីក្រមួយ ធំចម្រើនវ័យហើយ រស់នៅអាស្រ័យសេដ្ឋីម្នាក់ ធ្វើការងារស៊ីឈ្នួលចិញ្ចឹមជីវិត ។ ថ្ងៃមួយ ព្រះពោធិសត្វកាន់នំកុម្មាស ៤ ដុំ មកអំពីផ្សារដោយគិតថា នំទាំងនេះជាអាហារព្រឹករបស់អញ កាលដើរទៅធ្វើការងារ បានឃើញព្រះបច្ចេកពុទ្ធ ៤ អង្គកំពុងនិមន្តមក បែរមុខទៅកាន់នគរពារាណសី ដើម្បីជាប្រយោជន៍ដល់ភិក្ខាចារ គិតថា ព្រះបច្ចេកពុទ្ធទាំងនេះ និមន្តទៅនគរពារាណសីដើម្បីភិក្ខាចារ អញមាននំកុម្មាស ៤ ដុំនេះ បើដូច្នោះ អញគួរប្រគេនដល់ព្រះបច្ចេកពុទ្ធទាំងនេះ

ហើយចូលទៅគាល់ពិតថា បពិត្រលោកម្ចាស់ ខ្ញុំមាននំកុម្មាសក្នុងដៃ ៤ ដុំ ខ្ញុំសូមប្រគេននំទាំងនេះ ដល់លោកម្ចាស់ទាំងឡាយ បពិត្រលោកម្ចាស់ ខ្ញុំសូមឱកាស សូមលោកម្ចាស់ទាំងឡាយទទួលចុះ កាលបើដូច្នេះ បុណ្យនេះនឹងមានដល់ខ្ញុំដើម្បីជាប្រយោជន៍និងសេចក្តីសុខអស់កាលយូរ បានដឹងការដែលលោកទទួលនិមន្តន៍ហើយ ក៏រៀបចំអាសនៈ ៤ ដោយពូនខ្សាច់ឡើងក្រាលនូវមែកឈើនិងសំពត់សម្បកឈើលើពំនូកខ្សាច់នោះ និមន្តព្រះបច្ចេកពុទ្ធឲ្យគង់តាមលំដាប់ហើយ យកកន្ទោងដងទឹកមកធ្វើជាទក្ខិណោទក ដាក់នំកុម្មាស ៤ ក្នុងបាត្រទាំង ៤ នមស្ការហើយពិតថា បពិត្រលោកម្ចាស់ដោយផលនៃការប្រគេននំកុម្មាសទាំងនោះ ឈ្មោះថា ការកើតក្នុងផ្ទះអ្នកក្រីក្រកុំបីមានឡើយ សូមការថ្វាយទាននេះ ជាបច្ច័យនៃការសម្រេចនូវសព្វញ្ញុតញ្ញាណ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ឆាន់ក្នុងវេលានោះឯង ក្នុងទីបំផុតនៃការឆាន់ ព្រះបច្ចេកពុទ្ធធ្វើអនុមោទនា ហើយហោះទៅកាន់ញកភ្នំនន្ទមូលកៈនោះឯង ។ ព្រះពោធិសត្វផ្គងអញ្ជលី ហើយកាន់យកនូវបីតិក្នុងព្រះបច្ចេកពុទ្ធជាអារម្មណ៍ លុះព្រះបច្ចេកពុទ្ធទាំងនោះលះក្រសែភ្នែកហើយ ក៏ទៅក្នុងទីធ្វើការរបស់ខ្លួន ។ លោកធ្វើកម្មមានប្រមាណប៉ុណ្ណោះ តែរឭកដល់ទាននោះដរាបដល់អស់អាយុ លុះអនិច្ចកម្មហើយ ក៏បដិសន្ធិក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទពារាណសី ។ ព្រះញាតិទាំងឡាយ បានថ្វាយនាមថាព្រហ្មទត្តកុមារ ។ ព្រះរាជកុមារចាប់តាំងអំពីទ្រង់ចេះ យាងទៅដោយព្រះបាទទ្រង់ឃើញកិរិយាអាការរបស់ខ្លួន ក្នុងជាតិមុនប្រាកដច្បាស់ ដោយការរឭក

ជាតិបានដូចការឃើញស្រមោលមុខក្នុងកញ្ចក់ដែលថ្លា គិតថា អញជាអ្នកស៊ីឈ្នួលក្នុងនគរនេះឯង កាលដើរទៅធ្វើការងារបានប្រគេននំកុម្មាស ៤ ដុំ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយ បានបដិសន្ធិក្នុងទីនេះ ព្រោះផលនៃកម្មនោះ ។ ព្រះរាជកុមារ ទ្រង់ចម្រើនវ័យហើយ យាងទៅកាន់នគរតក្កសិលា រៀនទូវសិល្បសាស្ត្រគ្រប់យ៉ាង ហើយយាងត្រឡប់មក ទ្រង់សម្តែងសិល្បសាស្ត្រដែលទ្រង់សិក្សាមកហើយដល់ព្រះរាជបិតា ព្រះរាជបិតា ទ្រង់ពេញព្រះរាជហឫទ័យស្ថាបនាទុកក្នុងតំណែងឧបរាជ ក្នុងកាលតមក អស់រជ្ជកាលរបស់ព្រះរាជបិតា ក៏បានឡើងគ្រងរាជសម្បត្តិ ។ សម័យនោះ អាមាត្យទាំងឡាយនាំគ្នានាំព្រះរាជធីតារបស់ព្រះបាទកោសល ដែលទ្រទ្រង់នូវរូបឆោមលោមពណ៌ មកថ្វាយឲ្យជាអគ្គមហេសីរបស់ព្រះរាជកុមារ ។ ក្នុងថ្ងៃធ្វើងឆត្តមង្គល មនុស្សទាំងឡាយនាំគ្នាតាក់តែងព្រះនគរ ឲ្យដូចគ្នានឹងទេវនគរ ។ ព្រះរាជាទ្រង់ប្រពាសព្រះនគរ ហើយយាងឡើងប្រាសាទ ដែលតាក់តែងល្អហើយ ឡើងកាន់ព្រះរាជបល្ល័ង្ក ដែលលើកមហាស្វេតច្ឆត្រឡើងត្រង់កណ្តាល គង់ប្រថាប់ហើយ ទតមើលពលនិករទាំងឡាយ ដែលនាំគ្នាគាល់ មួយផ្នែកជាអាមាត្យ មួយផ្នែកជាគហបតី មានព្រាហ្មណគហបតីជាដើមដែលមានសម្បត្តិផ្សេងៗគ្នា មានការរុងរឿងដោយសិរីវិលាស មួយផ្នែកជាមហាជនអ្នកក្រុងមានដៃកាន់គ្រឿងបណ្ណាការច្រើនប្រភេទ មួយផ្នែកជាគណៈស្រីរបាំ ដែលមានចំនួន ១៦០០០ នាក់ បីដូចជាស្រីទេពអប្សរដែលតាក់តែងហើយដូច្នោះ សិរីរាជសម្បត្តិនេះ ជាទីត្រេកអរនៃព្រះហឫទ័យក្រៃលែង ទ្រង់រំឭកដល់

កុសលកម្មដែលខ្ញុំបំពេញក្នុងកាលមុនហើយ ទ្រង់រំឭកដល់គុណរបស់ព្រះបច្ចេកពុទ្ធទាំងឡាយថាសិរីសម្បត្តិទាំងអស់នេះ គឺកញ្ចប់មាស ១ ផ្កាមាស ១ ស្វេតច្ឆត្រ ១ ដីរី សេះនិងរថដែលជារាជពាហនៈទាំងនេះច្រើនពាន់ ១ ឃ្លាំងដែលពេញដោយកែវមណីនិងកែវមុក្តាជាដើម ១ ផែនដីធំដែលពេញដោយធញ្ញជាតិច្រើនប្រភេទ ១ ពួកនារីដែលប្រៀបបាននឹងស្រីទេពអប្សរ ១ ជាសម្បត្តិរបស់អញ មិនមែនរបស់អ្នកដទៃ តែជារបស់ដែលអាស្រ័យការប្រគេននំកុម្មាស ៤ ដុំដល់ព្រះបច្ចេកពុទ្ធ ៤ អង្គនោះឯង សម្បត្តិរបស់អញនោះបានមកព្រោះអាស្រ័យ ព្រះបច្ចេកពុទ្ធទាំងនោះ ដូច្នេះ បានធ្វើកម្មរបស់ខ្ញុំឲ្យប្រាកដហើយ កាលទ្រង់រំឭកដល់ផលកម្មនោះហើយ ព្រះសរីរៈទាំងមូលពេញទៅដោយបីតិ ៗ ទ្រង់មានព្រះរាជហឫទ័យត្រជាក់ដោយបីតិ កាលទ្រង់ច្រៀងឧទានត្រង់ជំនុំមហាជន បានត្រាស់គាថា ២ ថា

បានឮថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយដែលលោកមាន ពោធិញាណមិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលសោះកក្រោះឥតរសប្រៃ ៗ ដីរី គោនិងសេះដ៏ច្រើនទាំងនេះផង ទ្រព្យ ស្រូវ និងផែនដីទាំងអស់ផង នាងនារីទាំងឡាយដែលប្រៀបដូចជាស្ត្រីអប្សរទាំងនេះផង សុទ្ធតែជារបស់ខ្ញុំ អ្នកចូរមើលនូវផលនៃដុំនំកុម្មាសៈ ដូច្នេះ ៗ

បណ្តាបទទាំងនោះ បទថា **អនោមទស្សិសុ** សេចក្តីថា ព្រះបច្ចេកពុទ្ធ

ទ្រង់ព្រះនាមថា អនោមទស្សី ព្រោះបានឃើញបច្ចេកពោធិញ្ញាណដែលមិនថោកថយ គឺមិនលាមក ។ ការធ្វើសាមីចិកម្ម មានការអភិវាទ ការក្រោកទទួលនិងការធ្វើអញ្ជលីជាដើមក្តី ការឃើញសម្បត្តិក្នុងបច្ចុប្បន្នហើយ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងទេយ្យធម៌ដែលជារបស់ខ្លួន ទោះតិចក្តី ច្រើនក្តី អាក្រក់ក្តី ប្រណីតក្តី ហើយកំណត់គុណរបស់បដិគ្គាហកៈ ជម្រះចេតនាទាំង ៣ ឲ្យស្អាត ជឿនូវផលនៃកម្ម ហើយបរិច្ចាគក្តី ឈ្មោះថា បារិចរិយា ។ បទថា **ពុទ្ធេសុ** សេចក្តីថា ក្នុងព្រះបច្ចេកពុទ្ធទាំងឡាយ ។ បទថា **អប្បកា** សេចក្តីថា ធម្មតាការប្រណិប័តន៍ដែលធូរថយឬតិចតួចមិនមាន ។ បទថា **សុក្ខា-យ** សេចក្តីថា មិនមានជ័រស្អិត ( សោះកក្រោះ ) ។ បទថា **អលោណិ-កាយ** សេចក្តីថា វៀរចាកស្ករអំពៅ អធិប្បាយថា ដុំកុម្មាសនោះ លោកពោលថា **អលោណិកា** គឺសាប ព្រោះធ្វើសម្រេចហើយ ដោយមិនផ្សំនឹងទឹកអំពៅ ។ បទថា **កុម្មាសបិណ្ឌិយា** សេចក្តីថា ព្រះរាជាត្រាស់យ៉ាងនេះសំដៅដល់នំកុម្មាស ដែលព្រះពោធិសត្វកាន់ទៅ ដោយរួមនំកុម្មាសទាំង ៤ ដុំចូលគ្នានោះឯង ។ ទក្ខិណាទាន ដែលទាយកកំណត់គុណ របស់សមណព្រាហ្មណ៍ទាំងឡាយដែលមានគុណ ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងចេតនាទាំង ៣ របស់បុគ្គលដែលប្រាថ្នានូវផលឲ្យផូរផង់ហើយទើបថ្វាយ ឈ្មោះថាមានផលតិចមិនមាន តែនាំមកនូវមហាសម្បត្តិក្នុងទីដែលកើតហើយប៉ុណ្ណោះ ព្រោះហេតុនោះ ទើបក្នុងសេចក្តីនេះ លោកពោលទទួលធានាទុក ( ក្នុងខុទ្ទកនិកាយវិមានវត្ថុ ) ថា

កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័ក របស់ព្រះតថាគតហើយ ទក្ខិណាទានឈ្មោះថា មានផលតិច មិនមែនឡើយ ។

កាលព្រះតថាគតឋិតនៅក្តី បរិនិព្វានទៅក្តី បើតាំងចិត្តស្មើ ផលក៏ស្មើ ដ្បិតថា សត្វទាំងឡាយមានការតម្កល់ចិត្តទុកជា ហេតុ ទើបទៅកាន់សុគតិបាន ដូច្នេះ ។

តែដើម្បីសម្តែងដល់សេចក្តីនោះ គួរនាំរឿងវិមានវត្ថុទាំងឡាយមកសាធក:យ៉ាងនេះថា

ខ្ញុំបានឲ្យនូវបាយលាយដោយទឹកដោះស្រស់ ដល់ភិក្ខុត្រាច់ ទៅបិណ្ឌបាត សូមលោកមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជា ស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរ ទាំងមួយពាន់ សូមលោករមិលមើល នូវផលនៃបុណ្យទាំង ឡាយ ។

ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស ។

ភោគ:ទាំងឡាយណាមួយជាទីពេញចិត្ត ភោគ:ទាំងនោះក៏ កើតឡើងដល់ខ្ញុំផង ដោយសារបុញ្ញកម្មនោះ ។

ខ្ញុំមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺ ច្បាស់សព្វទិស ដោយបុញ្ញកម្មនោះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធនធញ្ញា** បានដល់ ទ្រព្យ មានកែវមុក្ដាជាដើម និងធញ្ញជាតិ ៧ ប្រការ ។ បទថា **បថវី ច គោវលា** បានដល់ផែនដីធំទាំងមូលនេះ ។ ព្រះរាជាត្រាស់សំដៅថា ផែនដីទាំងមូល នៅក្នុងកណ្ដាប់ព្រះហស្តរបស់ព្រះអង្គហើយ ។ បទថា **បស្ស ផលំ កុម្មាសបិណ្ឌិយា** សេចក្ដីថា ព្រះរាជាកាលទ្រង់សម្ដែងផលទានរបស់ទ្រង់ដោយព្រះអង្គឯង ទើបត្រាស់យ៉ាងនេះ ។ បានឮថា ព្រះពោធិសត្វក្ដី ព្រះសព្វញ្ញុពុទ្ធទាំងឡាយក្ដី ទ្រង់ជ្រាបផលរបស់ទាន ព្រោះហេតុនោះឯង ព្រះសាស្ដាកាលត្រាស់ព្រះសូត្រក្នុងឥតិវុត្តកៈ ទើបត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឲ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ មួយទៀត មន្ទិលគឺសេចក្ដីកំណាញ់របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ ។ ទោះបីពំនូតបាយជាដំបូង ដុំបាយជាដំបូងឯណារបស់សត្វទាំងឡាយនោះ សត្វទាំងឡាយមិនបានរំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះមានបដិគ្គាហកបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងផលនៃការឲ្យ និងការចែករំលែកយ៉ាងណា សត្វទាំងឡាយ មិនដឹងយ៉ាងនោះទេ ព្រោះហេតុណា ហេតុនោះសត្វទាំងឡាយមិនបានឲ្យទានហើយ ទើបហ៊ានបរិភោគ មួយទៀត មន្ទិលគឺសេចក្ដីកំណាញ់ ក៏តែងគ្របសង្កត់ចិត្តសត្វទាំង

ឡាយនោះ ដូច្នេះ ។

ឯព្រះពោធិសត្វ ទ្រង់មានបីតិបាមោជ្ជកើតឡើង ក្នុងថ្ងៃធ្វងឧត្តមង្គលរបស់ខ្លួន ទើបទ្រង់បន្លឺឧទានជាចម្រៀងដោយគាថាទាំង ២ នេះ ។ ចាប់តាំងអំពីនោះមក ពួកស្រីបាំរបស់ព្រះពោធិសត្វ ក៏នាំគ្នាច្រៀងចម្រៀងនោះដោយគិតថា ជាចម្រៀងដែលព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ គឺព្រះរាជនិពន្ធ ហើយពួកគន្ធព្វដែលជាអ្នកចម្រៀងជាដើមដ៏សេសក្តី មនុស្សទាំងឡាយខាងក្នុងបុរីក្តី នៅក្នុងព្រះនគរក្តី នៅខាងក្រៅព្រះនគរក្តី នាំគ្នាច្រៀងនូវចម្រៀងនោះដូចគ្នា ត្រង់រានលក់គ្រឿងផឹកក្តី ត្រង់បរិវេណប្រជុំក្តី ដោយគិតថា ជាចម្រៀងដែលព្រះរាជារបស់ពួកយើងទ្រង់ព្រះរាជនិពន្ធ ។ ពេលវេលាកន្លងទៅអស់កាលដ៏យូរយ៉ាងនេះ ព្រះមហេសីមានព្រះរាជបំណងជ្រាបអត្ថនៃបទចម្រៀងនោះ តែមិនហ៊ានទូលសួរព្រះមហាសត្វ ។ ថ្ងៃមួយ ព្រះរាជាទ្រង់ត្រេកអរក្នុងគុណឯណានីមួយរបស់ព្រះនាងទើបត្រាស់ថា នែនាង យើងនឹងឲ្យពរដល់នាងចូរនាងទទួលពរ ។ ព្រះនាងទូលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់សូមទទួលពរ ។ ព្រះពោធិសត្វពោលថា បណ្តាដំរី សេះជាដើម យើងនឹងឲ្យដល់នាង ។ ព្រះទេវីទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់អាស្រ័យព្រះអង្គមិនមានអ្វីដែលខ្ញុំម្ចាស់មិនមាន ខ្ញុំម្ចាស់មិនមានសេចក្តីត្រូវការ ដោយវត្ថុទាំងនោះ បើទ្រង់ព្រះរាជបំណងប្រទានពរ សូមទ្រង់ត្រាស់ប្រាប់អត្ថនៃបទចម្រៀងព្រះរាជនិពន្ធដល់ខ្ញុំម្ចាស់ចុះ ព្រះរាជាត្រាស់ថា នែនាង ប្រយោជន៍អ្វីដោយពរនេះ ចូរនាងទទួលពរដទៃចុះ ព្រះទេវីទូលថា បពិត្រព្រះសម្មតិទេព

ខ្ញុំម្ចាស់មិនត្រូវការពរដទៃឡើយ ត្រូវការអត្ថនៃបទចម្រៀង ព្រះរាជនិពន្ធតែម្យ៉ាង ព្រះរាជាត្រាស់ថា សាធុ យើងនឹងប្រាប់ តែយើងមិនប្រាប់ដល់នាងតែម្នាក់ក្នុងទីស្ងាត់ឡើយ នឹងឲ្យវាយស្គរប្រកាសក្នុងនគរពារាណសីប្រមាណ ១២ យោជន៍ ឲ្យសាងរតនបល្ល័ង្កត្រង់ទ្វារព្រះរាជវាំង ឲ្យក្រាលរតនបល្ល័ង្ក ចោមរោមដោយអ្នកនគរទាំងឡាយ មានអាមាត្យនិងព្រាហ្មណ៍ជាដើម មួយអន្លើដោយស្រីរបាំ ១៦០០០ នាក់ គង់លើរតនបល្ល័ង្កកណ្ដាលជនទាំងនោះ ហើយនឹងប្រាប់ ។ ព្រះនាងទទួលថា សាធុ ។ ព្រះរាជា ទ្រង់ឲ្យធ្វើយ៉ាងនោះហើយ មានពួកមហាជនចោមរោម ដូចសក្កទេវរាជ មានពួកទេវតាហែហមដូច្នោះ ទ្រង់ប្រថាប់លើរតនវល្ល័ង្ក ឯព្រះទេវីប្រដាប់តាក់តែងដោយគ្រឿងអលង្ការគ្រប់យ៉ាង តាំងព្រះរាជអាសនៈប្រដាប់ដោយមាស ព្រះនាងផ្ទៀងព្រះនេត្រមើលទីសមគួរនាចំណែកម្ខាង ហើយគង់ប្រថាប់ ក្នុងទីសមគួរទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រាប់អត្ថនៃបទចម្រៀង មង្គលដែលទ្រង់ពេញព្រះទ័យ ហើយទ្រង់ច្រៀង ដល់ខ្ញុំម្ចាស់ឲ្យជាក់ច្បាស់ ដូចឲ្យព្រះចន្ទប្រាកដក្នុងលម្ហ ដូច្នោះ ហើយត្រាស់គាថាទី ៣ ថា

> បពិត្រព្រះរាជកុញ្ជរ មានព្រះអធ្យាស្រ័យជាកុសល ទ្រង់ញុំាងផែនឲ្យចម្រើន ព្រះអង្គត្រាស់គាថាទាំងឡាយរឿយៗ ខ្ញុំព្រះអង្គ សូមក្រាបបង្គំទូលសួរទ្រង់ ព្រះអង្គមានព្រះទ័យប្រកបដោយបីតិក្រៃពេក ហើយទ្រង់ត្រាស់ ( គាថាទាំងនុ៎ះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កោសលាធិប** សេចក្ដីថា ព្រះមហាសត្វ

នោះទ្រង់ជាធំក្នុងដែនកោសល តែទ្រង់ប្រថាប់នៅដោយទ្រង់ធ្វើភាពជាធំក្រៃលែងក្នុងកុសលធម៌ ព្រោះហេតុនោះ ព្រះរាជទេវី កាលព្រះនាងហៅព្រះរាជាទើបហៅយ៉ាងនេះ ។ ពាក្យថា **កោសលាធិប** នេះ មានពាក្យអធិប្បាយថា ទ្រង់មានព្រះអធ្យាស្រ័យជាកុសល ។ បទថា **ពាឡ្ហំ បីតិមនោ បកាសសិ** សេចក្តីថា សូមទ្រង់មានរាជហឫទ័យប្រកបដោយបីតីដ៏ខ្លាំងក្លាត្រាស់ប្រាប់ ព្រោះហេតុនោះសូមទ្រង់ប្រាប់អត្ថនៃគាថាគឺសេចក្តីរបស់ចម្រៀងនោះដល់ខ្ញុំម្ចាស់ចុះ ។ គ្រានោះ ព្រះមហាសត្វកាលធ្វើអត្ថនៃគាថាទាំងឡាយឲ្យប្រាកដដល់ព្រះនាង បានពោលគាថា ៤ ថា

យើងបានកើត ក្នុងត្រកូលមួយ ក្នុងក្រុងនេះដែរ ជាអ្នកស៊ីឈ្នួលធ្វើការងាររបស់បុគ្គលដទៃ ជាអ្នកសង្រួមក្នុងសីលយើងចេញទៅធ្វើការងារ បានជួបនឹងសមណ: ៤ អង្គ លោកបរិបូណ៌ដោយអាចារនិងសីល មានសេចក្តីត្រជាក់ ទាំងឥតមានអាសវៈឡើយ ។ យើងបានញុំាងចិត្តឲ្យជ្រះថ្លាចំពោះសមណ:ទាំងនោះ បាននិមន្តលោក ឲ្យគង់លើកម្រាលស្លឹកឈើ លុះយើងមានចិត្តជ្រះថ្លាហើយ បានប្រគេននំកុម្មាសៈដល់ព្រះបច្ចេកពុទ្ធទាំងឡាយដោយដៃរបស់ខ្លួន ។ ឯផលរបស់យើងប្រាកដដូច្នេះ នេះជាផលរបស់កម្មជាកុលសនោះ យើងសោយរាជ្យដ៏ស្តុកស្តម្ភប្រសើរលើធរណីនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុលេ អញ្ញតរេ** សេចក្តីថា ក្នុងត្រកូលមួយ

នោះឯងដែលមិនប្រាកដឈ្មោះ ឬគោត្ត ។ បទថា **អហុំ** សេចក្តីថា កើតហើយ ។ បទថា **បរកម្មករោ អាសឹ** សេចក្តីថា យើងកើតក្នុងត្រកូលនោះហើយ កាលធ្វើការងាររបស់អ្នកដទៃចិញ្ចឹមជីវិត ព្រោះជាមនុស្សក្រីក្រ បានជាកម្មកររបស់អ្នកដទៃ ។ បទថា **ភតកោ** គឺកូនឈ្នួល បានដល់ បុគ្គលដែលចិញ្ចឹមខ្លួន ដោយការស៊ីឈ្នួលរបស់អ្នកដទៃ ។ បទថា **សីលសំវុតោ** សេចក្តីថា តាំងនៅហើយក្នុងសីលសំវរៈ ៥ ប្រការ ព្រះពោធិសត្វសម្តែងថា យើងសូម្បីចិញ្ចឹមជីវិតដោយថ្លៃឈ្នួល តែក៏លះនូវការទ្រុស្តសីល ជាអ្នកដល់ព្រមដោយសីល ។ បទថា **កម្មាយ និក្ខមន្តាហំ** សេចក្តីថា ថ្ងៃនោះ យើងចេញទៅដើម្បីធ្វើការងារដែលត្រូវធ្វើ ។ បទថា **ចតុរោ សមណេទ្ទសំ** សេចក្តីថា ម្នាលប្អូនស្រី យើងចេញអំពីនគរទៅកាន់ផ្លូវធំ ដើរទៅកាន់ទីធ្វើការរបស់ខ្លួន បានឃើញបព្វជិត ៤ រូប មានបាបស្ងប់ហើយ កំពុងចូលទៅកាន់នគរពារាណសី ដើម្បីបិណ្ឌបាត ។ បទថា **អាចារសីលសម្បន្នេ** សេចក្តីថា ការចិញ្ចឹមជីវិតដោយអនេសនា ២១ យ៉ាង ឈ្មោះថា អនាចារ ជាអ្នកប្រកបព្រមដោយអាចារដែលផ្ទុយគ្នានឹងអនាចារនោះ និងសីលដែលមកហើយដោយមគ្គនិងផលទាំងឡាយ ។ បទថា **សីតិភូតេ** សេចក្តីថា ជាអ្នកដល់ហើយនូវភាពត្រជាក់ ព្រោះរម្ងាប់នូវសេចក្តីក្រវល់ក្រវាយ មានរាគៈជាដើមបាន និងលត់ភ្លើង ១១ កងបាន ។ បទថា **អនាសវេ** សេចក្តីថា ជាអ្នកវៀរចាកកាមាសវៈ ជាដើមបាន ។ បទថា **និសីទិត្វា** សេចក្តីថា ឲ្យអង្គុយលើសន្ថត់ស្លឹកឈើដែលក្រាលលើពំនូកខ្សាច់ ។ គ្រឿងកម្រាលក្នុងទី

នេះលោកពោលថា សន្តិក ។ បទថា **អទំ** សេចក្ដីថា ខ្ញុំថ្វាយទក្ខិណោទក ដល់លោកទាំងនោះហើយ ទើបបានប្រគេនទំកុម្ភាសដោយគោរព ដោយដៃរបស់ខ្លួនឯង ។ បទថា **កុសលស្ស** សេចក្ដីថា ឈ្មោះថា កុសល ព្រោះអត្ថថា មិនមានរោគផង មិនមានទោសផង ។ បទថា **ផលំ** បានដល់ ផលដែលកំពុងហូរមកអំពីហេតុ ។ បទថា **ជីតំ** សេចក្ដីថា ដែលឲ្យនូវសម្បត្តិគ្រប់យ៉ាង ។

កាលព្រះមហាសត្វប្រាប់ផលកម្មរបស់ខ្លួន ដោយពិស្ដារយ៉ាងនេះហើយ ព្រះទេវីកាលព្រះនាងស្ដាប់ហើយ មានព្រះហឫទ័យជ្រះថ្លា កាលធ្វើនូវការសរសើរព្រះពោធិសត្វ ក៏ពោលថា បពិត្រមហារាជ បើទ្រង់ជ្រាបផលទានដោយប្រចក្សយ៉ាងនេះហើយសោត តាំងអំពីឥឡូវនេះទៅ ទ្រង់បានដុំបាយមួយដុំហើយ ត្រូវប្រគេនដល់សមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌នោះឯងសឹមសោយ ដូច្នេះ ហើយបានពោលគាថានេះថា

បពិត្រព្រះអង្គមានព្រះអធ្យាស្រ័យជាកុសល សូមព្រះអង្គទ្រង់
ព្រះរាជទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ
( ក្នុងបុណ្យទាំងឡាយ ) សូមព្រះអង្គញុំាងចក្រធម៌ឲ្យប្រ-
ព្រឹត្តទៅ បពិត្រព្រះរាជាមានព្រះអធ្យាស្រ័យជាកុសល ព្រះ
អង្គកុំជាអ្នកមិនប្រកបដោយធម៌សូមទ្រង់រក្សានូវអនុធម៌ដូច្នេះ។

បណ្ដាបទទាំងនោះ បទថា **ទទំ ភុញ្ជ** សេចក្ដីថា ទ្រង់ប្រទានដល់អ្នកដទៃហើយសឹមសោយដោយព្រះអង្គឯង ។ បទថា **មា ច បមាទោ** សេច

ក្ដីថា សូមទ្រង់កុំប្រមាទក្នុងបុណ្យទាំងឡាយមានទានជាដើម ។ បទថា **ចក្កំ វត្តយ កោសលាធិប** សេចក្ដីថា បពិត្រមហារាជទ្រង់មានព្រះអធ្យាស្រ័យក្នុងកុសលធម៌ សូមទ្រង់បន្ទិលនូវចក្ក គឺព្រះធម៌ ៤ យ៉ាង មានការនៅក្នុងប្រទេសដែលសមគួរជាដើម ។ បទថា **ចក្កំ** សេចក្ដីថា រថស្មុះទៅដោយកង់ ២ ។ តែកាយនេះទៅទេវលោកដោយកង់ទាំង ៤ នេះ ដោយហេតុនោះ កង់ ៤ នោះ ឈ្មោះថា ចក្កធម៌ ។ សូមទ្រង់បន្ទិល គឺឲ្យចក្កនោះវិលទៅ ។ បទថា **អធម្មិកោ** សេចក្ដីថា មនុស្សដទៃដល់នូវការលំអៀងព្រោះស្រឡាញ់ទ្រព្យនោះឯងដូចកៀបសត្វលោកដោយគ្រឿងកៀបអំពៅ ដូច្នោះ ឈ្មោះថា ជាអ្នកមិនតាំងនៅក្នុងធម៌យ៉ាងណា សូមទ្រង់កុំជាអ្នកប្រព្រឹត្តអធម៌យ៉ាងនោះ ។ បទថា **ធម្មំ ចាលយ** សេចក្ដីថា តែសូមទ្រង់គ្រប់គ្រង គឺរក្សា បានដល់ កុំលះបង់ទសពិតរាជធម៌នេះចោល គឺទាន ១ សីល ១ ចាគៈ ១ អជ្ជវៈ ១ មទ្ទវៈ តបៈ ១ អកោធៈ ១ អវិហឹសា ១ ខន្តិ ១ អវិរោធៈ ១ ដូច្នេះ ។

ព្រះមហាសត្វ កាលទ្រង់ទទួលព្រះតម្រាស់របស់ព្រះនាង ទើបត្រាស់គាថានេះថា

> ម្នាលនាងមានឆោមល្អ យើងនោះនឹងដើរតាមតម្រាយ ដែល
> ព្រះអរិយៈធ្លាប់ប្រព្រឹត្តរឿយៗមកនោះឯង ម្នាលនាងដ៏ល្អ ជា
> ធីតារបស់ព្រះបាទកោសល ការបានជួបប្រទះនូវព្រះអរហន្ត
> ទាំងឡាយ ជាទីគាប់ចិត្តរបស់យើងពន់ពេក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វដុមំ** បានដល់ ផ្លូវ ឬតម្រាយ ។ បទថា

**អរិយាចរិតំ** សេចក្តីថា ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមប្រព្រឹត្តមកហើយ ។ បទថា **សុកោសលេ** សេចក្តីថា នៃព្រះធីតាជាបុត្តរបស់ព្រះបាទកោសលដ៏ស្អាត ។ បទថា **អរហន្តោ** បានដល់ ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលមានឈ្មោះយ៉ាងនេះ ព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយ ព្រោះជាអ្នកកាច់បំបាក់នូវកាំនៃសង្សារចក្ក ព្រោះជាអ្នកទម្លាយនូវសត្រូវទាំងឡាយ និងព្រោះជាអ្នកគួរដល់បច្ច័យទាំងឡាយ មានពាក្យអធិប្បាយទុកថា នៃធីតារបស់ព្រះបាទកោសលដ៏ចម្រើន យើងមិនធ្វើសេចក្តីផ្អែតក្នុងចិត្តថា យើងថ្វាយទានហើយ នឹងប្រព្រឹត្តតាមផ្លូវ គឺទានដែលព្រះអរិយៈទាំងឡាយប្រព្រឹត្តហើយរឿយៗនោះឯង ដ្បិតថា ព្រះអរហន្តទាំងឡាយ ជាទីគាប់ចិត្ត គឺគួរទស្សនារបស់យើង ព្រោះជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ យើងបំណងនឹងឃើញលោកទាំងនោះ ព្រោះត្រូវការថ្វាយចីវរជាដើម ។

ព្រះរាជាកាលត្រាស់ពាក្យនេះហើយ ពិនិត្យមើលសម្បត្តិរបស់ព្រះទេវីត្រាស់សួរថា នៃនាងដ៏ចម្រើន យើងប្រាប់កុសលកម្មរបស់ខ្លួនក្នុងភពមុនយ៉ាងពិស្តារដល់នាងហើយ តែក្នុងចំណោមស្រីទាំងនេះ មិនមានស្រីសូម្បីតែម្នាក់ដែលដូចជានាងដោយរូបសម្បត្តិ ដោយលីលា និងកិរិយារបស់ស្ត្រី នាងធ្វើកម្មអ្វីទុក ទើបបានទទួលសម្បត្តិនេះ ទើបត្រាស់គាថានេះថា

ម្នាលនាងសុកោសលធីតា នាងប្រៀបដូចជាស្ត្រីទេពអប្សរជា
ទេវធីតា ( របស់សក្កទេវរាជ ) ដើរឆាយក្នុងកណ្តាលនៃ
ពួកនាងនារី នាងបានធ្វើនូវកម្មដ៏ចម្រើនដូចម្តេច នាងមាន

សម្បុរល្អដោយហេតុអ្វី ដូច្នេះ ។

គាថានោះមានអត្ថថា នែនាងដ៏ចម្រើន ជាអ្នកកោសល នាងមានរូបល្អ ជាព្រះរាជធីតាល្អរបស់ព្រះបាទកោសល នាងប្រៀបដូចទេពអប្សរដោយរូបសម្បត្តិ ល្អលុះពន់ពេកក្នុងកណ្តាលពួកនារី ដូចទេពធីតារបស់សក្កទេវរាជក្នុងស្ថានសួគ៌ ក្នុងសម័យមុន នាងបានធ្វើកុសលកម្មអ្វីទុក ព្រោះហេតុអ្វី ក៏នាងមានសម្បុរល្អម៉្លេះ ។

លំដាប់នោះ ព្រះទេវីនោះ កាលប្រាប់នូវកុសលកម្មក្នុងភពមុន ដោយញាណដែលរឭកជាតិបាន ទើបត្រាស់គាថា ២ ដ៏សេសថា

បពិត្រក្សត្រិយ៍ ខ្ញុំម្ចាស់ជាទាសីបម្រើអ្នកដទៃរបស់ត្រកូលអម្ពដ្ឋៈ ជាស្ត្រីសន្ធួម ចិញ្ចឹមជីវិតដោយធម៌ មានសីលធម៌ មានការឃើញមិនអាក្រក់ ។ កាលនោះខ្ញុំជាស្ត្រីមានចិត្តត្រេកអររីករាយខ្លួនឯង បានប្រគេនភត្តដែលគេដួស ( ទុកបម្រុងខ្ញុំ ) ដល់ភិក្ខុ ( ព្រះបច្ចេកពុទ្ធ ) ដែលត្រាច់ទៅ ( ដើម្បីបិណ្ឌបាត ) ផលប្រាកដដូច្នេះ នេះគឺជាផលនៃបុញ្ញកម្មនោះដូច្នេះ ។

បានឮថា ព្រះរាជទេវីនោះ នាងក៏រឭកជាតិបានដូចគ្នា ព្រោះដូច្នោះទើបនាងទូលព្រះរាជា កំណត់ដោយព្រះញាណដែលរឭកជាតិរបស់ខ្លួនបាននោះឯង ។

បណ្តាបទទាំងនោះ បទថា **អមដ្ឋកុសលស្ស** សេចក្តីថា នៃត្រកូល

កុដុម្ពិក: ។ បទថា **ធាសយាហំ** កាត់បទជា **ធាសី អហំ** ប្រែថា ខ្ញុំជាទាសី បាឋ:ថា **ធាសាហំ** ដូច្នេះក៏មាន ។ បទថា **បរបេសិយា** សេចក្ដីថា ជាអ្នកបម្រើ គឺអ្នកបម្រើដែលត្រូវអ្នកដទៃបញ្ជូនទៅធ្វើកិច្ចនោះៗ ។ បទថា **សញ្ញតា** សេចក្ដីថា ធម្មតាទាសីជាអ្នកទ្រុស្ដសីល តែខ្ញុំជាអ្នកសង្រួមទ្វារ ៣ ដល់ព្រមហើយដោយសីល ។ បទថា **ធម្មជីវិនី** សេចក្ដីថា ជាអ្នកចិញ្ចឹមជីវិតដោយមិនបោកប្រាស់អ្នកដទៃជាដើម ហើយប្រព្រឹត្តធម៌ដោយស្មើ ។ បទថា **សីលវតី** សេចក្ដីថា ខ្ញុំជាអ្នកដល់ព្រមដោយអាចារ មានទូវគុណ ។ បទថា **អចាបធស្សនា** សេចក្ដីថា ជាអ្នកឃើញវត្ថុដែលល្អគឺមានធម៌ជាទីស្រឡាញ់ ។ បទថា **ឧទ្ធដភត្តំ** សេចក្ដីថា ភត្តចំណែកដែលខ្ញុំបាន ដោយអ្នកដទៃលើកឡើងឲ្យ ដូចជាចំណែកដែលខ្លួនត្រូវបាន ។ បទថា **ភិក្ខុនោ** សេចក្ដីថា ដល់ព្រះបច្ចេកពុទ្ធដែលលោកទម្លាយកិលេសហើយ ។ បទថា **វិត្តា សុមនា** សេចក្ដីថា ជាអ្នកត្រេកអរ គឺកើតសោមនស្ស ជឿផលនៃកម្ម ។ បទថា **តស្ស កម្មស្ស** សេចក្ដីថា នៃកម្ម គឺការថ្វាយភិក្ខានោះ ។ មានពាក្យអធិប្បាយថា បពិត្រមហារាជ កាលមុនខ្ញុំជាទាសីរបស់កុដុម្ពិក: ត្រកូលណាមួយក្នុងនគរសាវត្ថី កាន់យកភត្តាហារចំណែកខ្លួនដើរចេញទៅ ឃើញព្រះបច្ចេកពុទ្ធមួយអង្គទ្រង់កំពុងនិមន្តបិណ្ឌបាត ធ្វើតណ្ហារបស់ខ្លួនឲ្យថយចុះដល់ព្រមដោយគុណធម៌ មានការសង្រួមជាដើម ជឿផលរបស់កម្ម ទើបប្រគេនភត្តាហារនោះ ដល់ព្រះបច្ចេកពុទ្ធអង្គនោះ ។ ខ្ញុំម្ចាស់តាំងនៅដរាបដល់អស់អាយុ ស្លាប់ហើយបានបដិសន្ធិក្នុងព្រះឧទរ របស់ព្រះមហេសីនៃព្រះបាទកោ

សល ក្នុងនគរសាវត្ថីនោះ ឥឡូវនេះ កំពុងបម្រើបាទារបស់ព្រះអង្គ សោយសម្បត្តិបែបនេះ ផលកម្មរបស់ខ្ញុំម្ចាស់នោះយ៉ាងនេះឯង ។ ក្នុងរឿងនោះដើម្បីសម្តែងដល់ទានដែលបុគ្គលឲ្យហើយដល់លោកអ្នកសម្បូរដោយគុណ មានផលច្រើន គួរអាងគាថាឲ្យពិស្តារ ( ក្នុងឥតិវុត្តកៈនិងខុទ្ទកបាឋៈ ) មានពាក្យជាដើមថា

បុណ្យដ៏ប្រសើរ ក៏រមែងចម្រើន ទាំងអាយុ ពណ៌ យស កេរ្តិ៍ឈ្មោះ សេចក្តីសុខនិងកម្លាំងដ៏ប្រសើរ ក៏រមែងចម្រើន អ្នកប្រាជ្ញជាអ្នកឲ្យ ( នូវទេយ្យធម៌ ) ចំពោះវត្ថុដ៏ប្រសើរហើយ ជាអ្នកមានចិត្តតាំងមាំក្នុងធម៌ដ៏ប្រសើរ...ដូច្នេះ ។

កំណប់ទ្រព្យគឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគួរធ្វើនូវកំណប់ទ្រព្យគឺបុណ្យនោះ កំណប់ទ្រព្យគឺបុណ្យនុ៎ះឲ្យនូវសេចក្តីបាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណា ៗ ផលទាំងពួងនោះ ៗ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ដូច្នេះ ។

ព្រះរាជានិងព្រះមហេសីទាំង ២ អង្គនោះ កាលត្រាស់កម្មចាស់ដោយពិស្តារយ៉ាងនេះហើយ តាំងពីនោះមក ទ្រង់ឲ្យសាងសាលាធទាន គឺត្រង់ទ្វារនគរ ៤ កន្លែង កណ្តាលព្រះនគរ ១ ត្រង់ទ្វារព្រះរាជវាំង ១ ទ្រង់ធ្វើជម្ពូទ្វីបទាំងមូលឲ្យខ្វូរខ្វារ ញុំាងមហាទានឲ្យប្រព្រឹត្តទៅ ទ្រង់រក្សាសីល រក្សាឧបោ

សថ ក្នុងអវសាននៃព្រះជន្ម ក៏មានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា ព្រះទេវីក្នុងកាលនោះ បានមកជារាហុលមាតាក្នុងកាលឥឡូវនេះ ឯព្រះរាជាក្នុងកាលនោះ គឺតថាគតនេះឯង ។

## អដ្ឋកថា កុម្មាសបិណ្ឌជាតក ចប់

# បរន្តបជាតក

[ ៤១២ ] ( បរន្តបទាសះពោលថា ) អំពើលាមកនឹងមានមកដល់ខ្ញុំ ភ័យនឹងមានមកដល់ខ្ញុំ ដ្បិតក្នុងកាលនោះមែកឈើកម្រើក ព្រោះមនុស្ស ឬម្រឹគ ។

[ ៤១៣ ] ( បុរោហិតពោលថា ) កាមរបស់ខ្ញុំ ( កើតចំពោះនាងព្រាហ្មណី ) ជាស្ត្រីខ្លាចច្រើនដែលនៅក្នុងទីមិនឆ្ងាយ វានឹងធ្វើខ្ញុំឲ្យជាបុគ្គលស្គមលឿងដូចជាមែកឈើនោះ ( ដែលធ្វើ ) ទាសះឈ្មោះបរន្តបះ ( ឲ្យជាបុគ្គលស្គមលឿង ) ។

[ ៤១៤ ] ( ថ្ងៃក្រោយបុរោហិតនោះពោលថា ) កិរិយាជាទីពេញចិត្តកាលនៅក្នុងស្រុកឥតមានអ្នកផងតិះដៀលបាន នឹងធ្វើខ្ញុំឲ្យរីងស្ងួតនឹងធ្វើខ្ញុំឲ្យស្គមលឿង ដូចជាមែកឈើនោះ ( ដែលធ្វើ ) ទាសះឈ្មោះបរន្តបះ ( ឲ្យជាបុគ្គលស្គមលឿង ) ។

[ ៤១៥ ] ( ថ្ងៃក្រោយទៀតបុរោហិតពោលថា ) នៃភ្នែកការញញឹមញញែមឬសម្តី ( ដ៏ពីរោះ ) ដែលនាង ( ឲ្យប្រព្រឹត្តទៅហើយ ) នឹងធ្វើខ្ញុំឲ្យជាបុគ្គលស្គមលឿងដូចជាមែកឈើនោះ ( ដែលធ្វើ ) ទាសះឈ្មោះបរន្តបះ ( ឲ្យជាបុគ្គលស្គមលឿង ) ។

[ ៤១៦ ] ( បរន្តបទាសះពោលថា ) សំឡេង ( នៃមែកឈើ ) នោះប្រព្រឹត្តទៅហើយនោះ ដូចជាប្រាប់អ្នកហើយ សត្វណាញុំាងមែកឈើនោះឲ្យកម្រើក សត្វនោះប្រាប់ហេតុនោះហើយ ។

[ ៤១៧ ] គំនិតណាដែលខ្ញុំជាបុគ្គលល្ងង់គិតថា ក្នុងកាលនោះ មែក

ឈើកម្រើក ព្រោះមនុស្សឬម្រឹគ គំនិតនេះឯងមកដល់ខ្ញុំហើយ ។

[ ៤១៨ ] ( លំដាប់នោះរាជកុមារពោលថា ) អ្នកបានដឹងពិតដូច្នោះមែន ព្រោះអ្នកបានសម្លាប់នូវបិតារបស់ខ្ញុំ បិទបាំងដោយមែកឈើទាំងឡាយលាក់លៀមដោយគិតថា ( ភ័យនឹងមានមកដល់អ្នក ) ។

**ចប់ បរន្តបជាតកទី ១១ ។**

**ចប់ គន្ធារវគ្គទី ២ ។**

## ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីការលះស្រុកដ៏ប្រសើរ ១ ស្វាធំ ១ កគ្គវៈស្ទួនថ្នាំង ១ ស្តេចព្រះនាមទឡ្ហធម្មៈ ១ ដំរី ១ សក់ដ៏ប្រសើរ ១ នាគ ១ វិធូរបណ្ឌិត ១ កាលជនភ្ញាក់រព្ញក ១ ព្រះរាជាមានអាជ្ញាស្រ័យជាកុសល ១ បរន្តបទាសៈ ១ ។

ក្នុងសត្តកនិបាតនោះ មានឧទ្ទាននៃវគ្គ ( ដូច្នេះ ) កាលខ្ញុំសូមពោលនូវវគ្គក្នុងសត្តកនិបាតអ្នកចូរស្តាប់វគ្គពីរ គឺកុក្កុវគ្គ ១ គន្ធារវគ្គ ១ ដែលព្រះសម្ពុទ្ធព្រះអង្គស្វែងរកនូវគុណដ៏ធំទ្រង់ត្រាស់ទុកហើយ ។

**ចប់ សត្តកនិបាត ។**

# អដ្ឋកថា

## បរន្តបជាតក

[ ៤១២-៤១៨ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការប្រឹងប្រែងរបស់ទេវទត្តដើម្បីផ្តាច់ព្រះជន្មរបស់ទ្រង់ ទើបត្រាស់រឿងនេះ មានពាក្យផ្តើមថា **អាគមិស្សតិ មេ ចាបំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កាលនោះ ភិក្ខុទាំងឡាយផ្តើមរឿងសន្ទនាគ្នាឡើងក្នុងធម្មសភាថា អាវុសោ ទេវទត្តខ្នះខ្នែងដើម្បីផ្តាច់ព្រះជន្មព្រះតថាគត គឺប្រកបនាយខ្មាន់ធ្នូ ប្រមៀលថ្ម លែងដំរីនាឡាគិរី ធ្វើឧបាយដើម្បីឲ្យព្រះតថាគតទ្រង់វិនាស ព្រះសាស្តាយាងមកដល់ហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនព្យាយាម ដើម្បីសម្លាប់តថាគតតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ខ្នះខ្នែងដើម្បីសម្លាប់តថាគតដូចគ្នា តែមិនអាចធ្វើត្រឹមតែការតក់ស្លុត ឲ្យតថាគតបានឡើយ សោយតែទុក្ខខ្លួនឯង ហើយទ្រង់នាំយករឿងក្នុងអតីត មកសាធក:ដូចតទៅនេះថា

ក្នុងអតីតកាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ បដិសន្ធិក្នុងព្រះឧទររបស់អគ្គមហេសី នៃព្រះរាជាអង្គនោះ ចម្រើនវ័យហើយ ទ្រង់សិក្សាសិល្បសាស្ត្រគ្រប់យ៉ាងឯនគរតក្កសិលា ទ្រង់រៀនមន្តដែលធ្វើឲ្យដឹងសំឡេងគ្រប់យ៉ាង ។ ព្រះរាជកុមារទ្រង់ឲ្យនូវតម្លៃគ្រូ

ដល់អាចារ្យហើយ ទ្រង់យាងត្រឡប់មកាន់នគរពារាណសី ។ ព្រះជនកតាំងព្រះរាជកុមារទុកក្នុងតំណែងឧបរាជ តែទោះជាទ្រង់តាំងក្នុងតំណែងឧបរាជក៏ពិត ទ្រង់នៅតែមានបំណងនឹងផ្តាច់ព្រះជន្មព្រះពោធិសត្វ ( ដែលជាបុត្ត ) ទ្រង់មិនប្រាថ្នាឲ្យព្រះពោធិសត្វចូលគាល់ ។ ថ្ងៃមួយមេចចកមួយពាំកូនទី ២ ក្បាល ចូលទៅតាមលូទឹកក្នុងរាត្រីកាលដែលមនុស្សម្នាទាំងឡាយលង់លក់ហើយ ។ នៅក្បែរបន្ទប់ផ្ទំខាងលើប្រាសាទរបស់ព្រះពោធិសត្វ មានសាលាមួយខ្នង លើសាលានោះមានជនអនាថាម្នាក់ ដោះស្បែកជើងដាក់លើផែនដីក្បែរជើងហើយឡើងដេកលើបន្ទះក្តារមួយបន្ទះ តែមិនទាន់លក់ ។ កាលកូនចចកទាំង ២ របស់មេចចកឃ្លានស្រេកឃ្លាំ ទើបមេចចកពោលនឹងកូនទាំង ២ តាមភាសារបស់ខ្លួនថា កុំធ្វើមាត់ មនុស្សម្នាក់ដោះស្បែកជើងដាក់លើផែនដីដេកលើបន្ទះក្តារ តែមិនទាន់លក់ទេ មនុស្សនោះដេកលក់ មេនឹងទៅពាំយកស្បែកជើងនោះមកឲ្យឯងស៊ី ។ ព្រះពោធិសត្វទ្រង់ដឹងភាសារបស់ចចកដោយអានុភាពនៃមន្ត ទើបចេញអំពីបន្ទប់សម្រាប់ផ្ទំ បើកបង្អួច ហើយត្រាស់ថា នរណានៅទីនេះ ជនទុគ៌តពោលថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំអ្នកដើរផ្លូវឆ្ងាយ ព្រះពោធិសត្វសួរថា ស្បែកជើងរបស់ឯងនៅឯណា អ្នកក្រីក្រក្រាបទូលថា នៅខាងក្រោមព្រះអង្គ ព្រះពោធិសត្វត្រាស់ថា ចូរលើកឡើង ហើយព្យួរទុកចុះ ។

មេចចក កាលបានឮពាក្យនោះហើយ ខឹងសម្បានឹងព្រះពោធិសត្វ ។ ស្អែកឡើង ចចកនោះក៏ចូលនគរយ៉ាងនោះដូចគ្នា កាលនោះ មនុស្សម្នាក់

គិតថា នឹងផឹកទឹក កាលចុះទៅក្នុងស្រះបោក្ខរណី ក៏ធ្លាក់ទៅក្នុងទឹក លង់ទឹកស្លាប់ ។ បុរសនោះមានសំពត់សាដកសម្រាប់ស្លៀកដណ្តប់ ២ ផ្ទាំង និងចិញ្ចៀនពាក់ម្រាមដៃតម្លៃ ១០០០ កហាបណៈ ទុកត្រង់សំពត់ស្លៀក ។ គ្រានោះកូនចចកកំពុងឃ្លាំ ក៏ពោលចំពោះមេរបស់វាថា ពួកខ្ញុំឃ្លាន មេចចក ក៏ពោលនឹងកូនថា នែកូន កុំព្រួយ មនុស្សស្លាប់ត្រង់ស្រះបោក្ខរណីនេះឯង គេមានទ្រព្យឈ្មោះនេះនិងឈ្មោះនេះ តែគេស្លាប់ហើយ ក្រោមជណ្តើរនោះឯង ម៉ែនឹងឲ្យពួកឯងស៊ីមនុស្សនោះ ។ ព្រះពោធិសត្វស្តាប់ពាក្យនោះហើយ ទ្រង់បើកបង្អួចហើយត្រាស់ថា លើសាលាមានមនុស្សដែរឬទេ បុរសម្នាក់ក្រោកឡើងក្រាបទូលថា បពិត្រព្រះអង្គ គឺទូលព្រះបង្គំ ទើបព្រះពោធិសត្វត្រាស់ថា ទៅចុះ ចូរយកសំពត់សាដកនិងចិញ្ចៀនរបស់បុរសដែលស្លាប់ក្នុងស្រះបោក្ខរណីនោះ ហើយចូរសង្កត់សាកសពឲ្យលិចទៅក្នុងទឹកកុំឲ្យអណ្តែតឡើង បុរសនោះបានធ្វើយ៉ាងនេះហើយ មេចចកក៏ក្រោធខឹងម្តងទៀត ហើយសម្លុតព្រះពោធិសត្វថា ថ្ងៃមុនយើងមិនបានឲ្យកូនយើងស៊ីស្បែកជើង ថ្ងៃនេះមិនបានស៊ីសាកសព ណ្ហើយចុះ ឥឡូវនេះ បន្ទាប់អំពីនេះទៅ ក្នុងថ្ងៃទី ៣ ស្តេចជាសត្រូវមួយអង្គនឹងមកព័ទ្ធព្រះនគរ កាលនោះ ព្រះបិតានឹងបញ្ជូនឯងឲ្យទៅច្បាំង ស្តេចជាសត្រូវ នឹងកាត់ក្បាលរបស់ឯងក្នុងទីនោះ កាលបើដូច្នោះយើងនឹងផឹកឈាមក្នុងបំពង់ករបស់ឯង ឲ្យផុតពៀរ ឯងចងពៀរនឹងយើង យើងនឹងដឹង ដូច្នេះហើយ នាំកូនចេញទៅ ។

ក្នុងថ្ងៃទី ៣ ស្តេចជាសត្រូវមកព័ទ្ធព្រះនគរ ព្រះរាជាត្រាស់នឹងព្រះពោធិ

សត្វថា នែកូន ចូរអ្នកច្បាំងនឹងស្តេចជាសត្រូវនេះ ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព មានហេតុមួយដែលទូលព្រះបង្គំឃើញហើយ ទូលព្រះបង្គំមិនអាចទៅបាន ទូលព្រះបង្គំខ្លាចអន្តរាយនៃជីវិត ព្រះរាជាត្រាស់ថា ឯងខ្លាចស្លាប់ ឬមិនខ្លាចស្លាប់ នឹងមានប្រយោជន៍អ្វីសម្រាប់យើង ចូរឯងទៅចុះ ។ ព្រះមហាសត្វទទួលព្រះរាជឱង្ការហើយ នាំបរិវារទៅ មិនបានចេញតាមទ្វារដែលស្តេចជាសត្រូវទ្រង់តាំងទ័ព ទ្រង់បើកទ្វារដទៃចេញទៅ ។ កាលព្រះមហាសត្វចេញទៅ ព្រះនគរក៏ស្ងាត់ទទេ មនុស្សទាំងឡាយបានចេញទៅជាមួយព្រះមហាសត្វទាំងអស់នោះឯង ។ ព្រះមហាសត្វ ទ្រង់ឲ្យបោះព្រះពន្លាក្នុងទីសមគួរមួយកន្លែង ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឧបរាជធ្វើនគរយើងឲ្យស្ងាត់ នាំកម្លាំងគេចទៅហើយ ឯស្តេចជាសត្រូវ ក៏ព័ទ្ធព្រះនគរទុក ឥឡូវនេះ ជីវិតរបស់អញមិនមាន ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងរក្សាជីវិតទុក ហើយទ្រង់នាំព្រះរាជទេវី បុរោហិតនិងអ្នកបម្រើម្នាក់ឈ្មោះបរន្តបៈ ក្លែងភេទគេចចូលទៅកាន់ព្រៃក្នុងកណ្តាលយប់ ។ ព្រះពោធិសត្វដឹងថា ព្រះរាជាគេចទៅហើយ ទើបយាងចូលព្រះនគរទ្រង់ធ្វើការច្បាំង ដេញស្តេចជាសត្រូវឲ្យគេចទៅហើយ ទ្រង់ដណ្តើមរាជសម្បត្តិបានវិញ ។ ចំណែកព្រះរាជបិតារបស់ព្រះអង្គ ទ្រង់ឲ្យសាងបណ្ណសាលាក្បែរឆ្នេរស្ទឹងមួយកន្លែង ទ្រង់តម្កល់ជីវិតឲ្យស្ថិតនៅដោយផ្លែឈើតូចធំ ។ ព្រះរាជានិងបុរោហិតទៅរក ផ្លែឈើតូចធំ ។ នៅឯបណ្ណសាលានោះ មានតែទាសៈឈ្មោះបន្តបៈ និងព្រះរាជទេវី ។ ព្រោះអាស្រ័យព្រះរាជា ព្រះរាជទេវីទ្រង់មានព្រះគភ៌ក្នុងទីនោះ ។

ម្យ៉ាងទៀតព្រះនាងបានប្រព្រឹត្តក្រៅចិត្តព្រះរាជា ជាមួយទាសៈឈ្មោះបរន្តបៈនោះ ដោយអំណាចសេចក្តីស្និទ្ធស្នាល ។ ថ្ងៃមួយព្រះនាងត្រាស់នឹងទាសៈបរន្តបៈថា បើព្រះរាជាទ្រង់ដឹងរឿងហើយ ជីវិតរបស់ឯងនិងជីវិតរបស់យើងក៏មិនមាន ព្រោះហេតុនោះ ចូរឯងផ្តាច់ព្រះជន្មរបស់ព្រះរាជានោះចោលចុះ ។ ទាសបរន្តបៈពោលថា ទូលព្រះបង្គំនឹងផ្តាច់ដូចម្តេច ព្រះទេវីប្រាប់ថា ព្រះរាជានេះឲ្យឯងកាន់ព្រះខ័ននោះនិងព្រះកូសាសម្រាប់ស្រង់ទឹក ហើយទៅស្រង់ទឹក ចូរឯងចាំមើលការភ្លេចខ្លួនរបស់ព្រះរាជានោះ ក្នុងទីស្រង់នោះ ប្រើដាវកាត់ក្បាលហើយ ចិញ្ច្រាំព្រះសរីរៈជាកំណាត់ៗ កប់ក្នុងផែនដី ។ ទាសៈទទួលព្រះរាជសវនីយ៍ថា សាធុ ។ ថ្ងៃមួយ បុរោហិតនោះឯង ដើរទៅដើម្បីផ្លែឈើតូចធំ ឡើងដើមឈើមួយដើម ក្បែរទីដែលព្រះរាជាស្រង់ទឹក ហើយបេះផ្លែឈើតូចធំ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងងូតទឹកហើយឲ្យទាសបរន្តបៈកាន់ព្រះខ័ននិងព្រះកូសាសម្រាប់ស្រង់ ហើយទ្រង់ចុះកាន់ស្ទឹង ទាសបរន្តបៈទូលព្រះរាជាដែលទ្រង់ដល់នូវការប្រមាទ ក្នុងកាលដែលទ្រង់ស្រង់ក្នុងទីនោះថា ទូលព្រះបង្គំនឹងសម្លាប់ ហើយចាប់ព្រះសូរង ផារព្រះខ័នឡើង ព្រះរាជាទ្រង់ស្រែក ព្រោះខ្លាចសេចក្តីស្លាប់ ។ បុរោហិតបានឮសំឡេងនោះ ហើយក្រឡេកមើល ឃើញទាសៈបរន្តបៈកំពុងផ្តាច់ព្រះជន្មព្រះរាជា ក៏មានសេចក្តីតក់ស្លុត ទើបលែងមែកឈើ ហើយលោតចុះអំពីដើមឈើ ទៅអង្គុយត្រង់គុម្ពឈើមួយ ។ ទាសៈបរន្តបៈបានឮសំឡេងអង្រួនមែកឈើរបស់បុរោហិតនោះហើយ ផ្តាច់ព្រះជន្មព្រះរាជាកប់ត្រង់ផែនដី ស្រេចហើយពិចារណាមើល

ថា មានសំឡេងអង្រួនមែកឈើក្នុងទីនេះ អ្នកណាហ្ន៎នៅក្នុងទីនេះ មិនឃើញមាននរណាទើបផ្លូតទឹកហើយទៅ ។ ក្នុងកាលទាសៈបរន្តបៈទៅហើយ បុរោហិតក៏ចេញពីទីអន្ទ្វយ ដឹងថាព្រះរាជាត្រូវចិញ្ច្រាំព្រះសរីរៈជាកំណាត់ៗ ហើយកប់ក្នុងរណ្តៅ ទើបផ្លូតទឹកហើយពុតធ្វើជាខ្វាក់ភ្នែក ដើរទៅកាន់បណ្ណសាលា ព្រោះខ្លាចគេសម្លាប់ខ្លួន បរន្តបៈឃើញហើយ ពោលថា នែព្រាហ្មណ៍ អ្នកកើតអ្វី បុរោហិតធ្វើដូចជាមិនដឹង ពោលថា បពិត្រព្រះសម្មតិទេព ភ្នែកទាំង ២ របស់ទូលព្រះបង្គំខូច ទើបមកទីនេះ ទូលព្រះបង្គំបានឈរក្បែរដំបូកមួយក្នុងព្រៃមានអាសិរពិស អាសិរពិសមួយព្រួសពិសដាក់ ។ បរន្តបៈគិតថា បុរោហិតមិនស្គាល់អញ ទើបពោលថា បពិត្រព្រះសម្មតិទេព អញនឹងលួងលោមបុរោហិត ហើយបានលួងលោមថា ម្នាលព្រាហ្មណ៍ អ្នកកុំគិតថ្វីឡើយ យើងនឹងបដិបត្តិអ្នក ហើយបានឲ្យផ្លែឈើតូចធំបរិភោគស្កប់ស្កល់ ។ តាំងអំពីនោះមកទាសៈបរន្តបៈ នាំផ្លែឈើតូចធំមកឲ្យ ។ ព្រះរាជទេវីប្រសូតព្រះឱរសហើយ ។ កាលព្រះរាជឱរសចម្រើនវ័យឡើង ព្រះនាងផ្ទុំសប្បាយក្នុងព្រលប់មួយ បានត្រាស់នឹងទាសៈបរន្តបៈតិចៗថា កាលឯងផ្តាច់ព្រះជន្មព្រះរាជា មិនមានអ្នកណាឃើញទេឬ កាលបុរសនោះចរចានឹងព្រះនាង ក៏ពោលថា អ្នកណាមួយមិនបានឃើញទូលព្រះបង្គំ តែទូលព្រះបង្គំបានឮសំឡេងមែកឈើ មិនដឹងថាមែកឈើនោះ មនុស្សឬសត្វតិរច្ឆានអង្រួន បើមិនពេលណាក៏ពេលណាមួយភ័យនឹងមកដល់ទូលព្រះបង្គំ ហើយនឹងមកអំពីបុគ្គលអង្រួនមែកឈើ ដូច្នេះហើយ ពោលគាថាទី ១ ថា

អំពើលាមកនឹងមានមកដល់ខ្ញុំ ភ័យនឹងមានមកដល់ខ្ញុំ ដ្បិត
ក្នុងកាលនោះមែកឈើកម្រើក ព្រោះមនុស្សឬម្រឹគ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធាបំ** បានដល់ វត្ថុដែលលាមក គឺវត្ថុដែលមិនគួរប្រាថ្នា មិនគួរស្រឡាញ់ ។ បទថា **ភយំ** សេចក្ដីថា ភ័យ គឺការតក់ស្លុតនឹងមកដល់ទូលព្រះបង្គំ មិនមែនមិនអាចមកដល់ ។ ព្រោះហេតុអ្វីព្រោះថា មែកឈើដែលកម្រើកនោះ មិនដឹងថា ព្រោះមនុស្ស ឬម្រឹគ ព្រោះហេតុនោះ ភ័យនឹងមកដល់ទូលព្រះបង្គំអំពីមនុស្ស ឬម្រឹគនោះឯង ។ ជនទាំង ២ នោះយល់ថា បុរោហិតដេកលក់ហើយ តែបុរោហិតនោះ មិនទាន់ដេកលក់នៅឡើយ បានឮពាក្យនៃជនទាំងនោះ ។ ថ្ងៃមួយ កាលទាសៈឈ្មោះបរន្តបៈទៅរកផ្លែឈើតូចធំ បុរោហិតនឹកក្នុកដល់ព្រាហ្មណីជាភរិយារបស់ខ្លួន ទើបពោលគាថាទី ២ ថា

កាមរបស់ខ្ញុំ ( កើតចំពោះនាងព្រាហ្មណី ) ជាស្ត្រីខ្លាចច្រើន
ដែលនៅក្នុងទីមិនឆ្ងាយ វានឹងធ្វើខ្ញុំឲ្យជាបុគ្គលស្គមលឿង ដូច
ជាមែកឈើនោះ ( ដែលធ្វើ ) ទាសៈឈ្មោះបរន្តបៈ ( ឲ្យជា
បុគ្គលស្គមលឿង ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភីរុយា** សេចក្ដីថា ធម្មតាស្រីទាំងឡាយរមែងខ្លាច ព្រោះហេតុត្រឹមតែបន្តិចបន្តួច ព្រោះហេតុនោះ ស្ត្រីទើបត្រូវហៅថា ជាអ្នកខ្លាច ។ បទថា **អវិទូរេ** សេចក្ដីថា បុរោហិតសម្ដែងថា សេចក្ដីប្រាថ្នារបស់អញក្នុងនាងព្រាហ្មណី ដែលនៅក្នុងទីមិនឆ្ងាយអំពីទីនេះ គឺក្នុងទី

បំផុតរយៈ ២ ឬ ៣ យោជន៍ កើតឡើងហើយដល់អញ ។ ព្រាហ្មណីនោះនឹងធ្វើឲ្យអញស្គមលឿងពិតប្រាកដ ។ បទថា **សារំ សាខា** មានអត្ថថា ដោយពាក្យនេះ បុរោហិតសម្តែងឧបមាថា មែកឈើធ្វើឲ្យបរន្តបៈស្គមលឿងយ៉ាងណា ព្រាហ្មណីនោះក៏យ៉ាងនោះ គឺធ្វើឲ្យអញស្គមលឿង ។ ហេតុនោះទើបព្រាហ្មណ៍ពោលគាថានោះឯង តែមិនប្រាប់អត្ថ ព្រោះដូច្នោះ ទើបកិច្ចមិនប្រាកដដល់ព្រះរាជទេវីព្រោះគាថានេះ ។

សម័យនោះ ទើបព្រះរាជទេវីពោលនឹងបុរោហិតនោះថា នែព្រាហ្មណ៍អ្នកនិយាយអ្វី បុរោហិតក្រាបទូលថា ទូលបង្គំកំណត់ដឹងហើយ ក្នុងថ្ងៃស្អែកឡើង ក៏ពោលគាថាទី ៣ ថា

កិរិយាជាទីពេញចិត្ត កាលនៅក្នុងស្រុក ឥតមានអ្នកផងតិះ
ដៀលបាន នឹងធ្វើខ្ញុំឲ្យរីងស្ងួត នឹងធ្វើខ្ញុំឲ្យស្គមលឿងដូចជា
មែកឈើនោះ ( ដែលធ្វើ ) ទាសៈឈ្មោះបរន្តបៈ ( ឲ្យជា
បុគ្គលស្គមលឿង ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោចយិស្សតិ** សេចក្តីថា នឹងឲ្យស្គាំងស្គម ព្រោះកើតសេចក្តីសោក ។ បទថា **កន្តា** បានដល់ កិរិយាដែលគួរប្រាថ្នា ។ បទថា **គាមេ វសំ** មានអធិប្បាយថា នៅក្នុងនគរពារាណសី ។ បទថា **អនិន្ទិតា** សេចក្តីថា មិនមានទីដែលត្រូវតិះដៀល គឺទ្រទ្រង់នូវរូបដែលល្អប្រពៃ ។

ក្នុងថ្ងៃស្អែកបុរោហិតបានពោលគាថាទី ៤ ថា

នៃក្អែក ការញញឹមញញែម ឬសម្តី ( ដ៏ពីរោះ ) ដែលនាង ( ឲ្យប្រព្រឹត្តទៅហើយ ) នឹងធ្វើខ្ញុំឲ្យជាបុគ្គលស្គមលឿនដូចជាមែកឈើនោះ ( ដែលធ្វើ ) ទាសៈឈ្មោះបរន្តបៈ ( ឲ្យជាបុគ្គលស្គមលឿន ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តយា មំ ហសិតាបន្តី** សេចក្តីថា កន្ទុយក្អែកដែលនាងបោលមករកខ្ញុំ ។ មានពាក្យអធិប្បាយថា នៃនាងដ៏ចម្រើន កែវក្អែក ដែលនាងលាបល្អហើយ ព្រោះនាំវត្ថុស្មោកគ្រោកចេញអំពីក្អែកហើយ ដោយឈើសម្រាប់លាបថ្នាំបន្តក់ក្អែក ដែលនាងសម្លឹងមកហើយក្តី ការញញឹមតិចៗក្តី វាចាដែលនាងពោលយ៉ាងផ្អែមក្តី ធ្វើឲ្យខ្ញុំស្គមលឿន ដូចមែកឈើដែលអញអង្រួនហើយ ធ្វើឲ្យបរន្តបៈស្គមរីងស្ងួត ដូច្នោះ ។ បាឋៈថា **វន្តី** ដូច្នេះក៏មាន ដោយផ្លាស់ **ប** អក្ខរៈ ឲ្យជា **វ** អក្ខរៈនោះឯង ។

ក្នុងកាលតមក ព្រះរាជកុមារទ្រង់ចម្រើនវ័យឡើង មានព្រះជន្មាយុ ១៦ ព្រះវស្សា ពេលនោះ ព្រាហ្មណ៍ក៏បានឲ្យព្រះរាជកុមារចាប់ចុងឈើច្រត់ ដឹកទៅត្រង់កំពង់ទឹក ហើយបានបើកក្អែកសម្លឹងមើល ។ ព្រះរាជកុមារត្រាស់ថា នៃព្រាហ្មណ៍ លោកជាបុគ្គលក្អែកខ្វាក់មិនមែនឬ ព្រាហ្មណ៍ក្រាបទូលថា ទូលព្រះបង្គំមិនមែនខ្វាក់ តែប្រើឧបាយនេះដើម្បីរក្សាជីវិត ហើយកាបទូលបន្តថា តើទ្រង់ស្គាល់ព្រះបិតារបស់ទ្រង់ដែរឬទេ កាលព្រះរាជកុមារត្រាស់ថា ខ្ញុំស្គាល់បុរសនោះជាបិតារបស់ខ្ញុំ ទើបព្រាហ្មណ៍ក្រាបទូលថា បុរសនេះមិនមែនបិតារបស់ទ្រង់ទេ បិតារបស់ទ្រង់ជាព្រះបាទពារាណសី បុរសនេះជាទាសៈ គេ

បដិបត្តិខុសក្នុងមាតារបស់ទ្រង់ សម្លាប់បិតារបស់ទ្រង់កប់ក្នុងទីនេះ ហើយនាំឆ្អឹងមកឲ្យមើល ព្រះរាជកុមារបានកើតនូវសេចក្តីក្រេវក្រោធឡើងជាកម្លាំង ។ គ្រានោះ ព្រះរាជកុមារត្រាស់សួរបុរោហិតថា ឥឡូវនេះ យើងនឹងធ្វើដូចម្តេច ទើបបុរោហិតទូលថា វត្ថុណាដែលគេធ្វើដល់ព្រះរាជបិតាទ្រង់ ត្រង់កំពង់ទឹកនេះ សូមទ្រង់ធ្វើវត្ថុនោះចុះ ហើយបានប្រាប់ការប្រព្រឹត្តទៅទាំងអស់ ឲ្យរាជកុមារជ្រាប ហើយបានឲ្យព្រះរាជកុមារទ្រង់សិក្សាគុណជំបង ២-៣ ថ្ងៃ ។ ថ្ងៃមួយ ព្រះរាជកុមារទ្រង់កាន់ព្រះខ័ននិងព្រះភូសា ហើយពោលថា សូមទ្រង់ស្រង់ទឹកចុះ បន្តបៈឆ្លើយថា សាធុ ហើយក៏ទៅជាមួយព្រះរាជកុមារនោះ ។ ក្នុងគ្រាចុះងូតទឹក ព្រះរាជកុមារប្រើព្រះហស្តស្តាំកាន់ដាវ ព្រះហស្តឆ្វេងចាប់ផ្នួងសក់ ហើយត្រាស់ថា បានឮថា ឯងចាប់ព្រះចូឡារបស់បិតាយើងហើយផ្តាច់ព្រះជន្មរបស់ទ្រង់ ដែលកំពុងស្រែកត្រង់កំពង់ទឹកនេះឯង ចំណែកយើងនឹងធ្វើឯងយ៉ាងនោះដូចគ្នា បុរសនោះភ័យចំពោះមរណៈបានខ្សឹកខ្សួល ដាយពោលគាថា ២ ថា

សំឡេង ( នៃមែកឈើ ) នោះ ប្រព្រឹត្តទៅហើយនោះ
ដូចជាប្រាប់អ្នកហើយ សត្វណាញុំាងមែកឈើនោះឲ្យកម្រើក
សត្វនោះប្រាប់ហេតុនោះហើយ ។

គំនិតណា ដែលខ្ញុំជាបុគ្គលល្ងង់គិតថាក្នុងកាលនោះ មែក
ឈើកម្រើកព្រោះមនុស្សឬម្រឹគ គំនិតនេះឯងមកដល់ខ្ញុំហើយ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អគមា** សេចក្តីថា សំឡេងរបស់មែកឈើនោះបានមកដល់ គឺមកដល់ខ្លួនខ្ញុំហើយ ។ បទថា **អសំសិ ឆ្ងង សោ តវ** សេចក្តីថា សំឡេងនោះប្រហែលជាប្រាប់ហេតុដល់អ្នក ។ បទថា **អក្ខាតំ ឆ្ងង តំ តេន** សេចក្តីថា សត្វណាបានអង្រួនមែកឈើនោះក្នុងកាលនោះ សត្វនោះបានប្រាប់ហេតុនោះ ពិតប្រាកដយ៉ាងនេះថា បុរសនោះសម្លាប់បិតារបស់អ្នក ។ បទថា **សមាគម្ម** បានដល់ មកដល់ហើយ គឺមកដល់ព្រមហើយ មានពាក្យអធិប្បាយថា ការដែលយើងជាបុគ្គលល្ងង់បានគិត គឺបរិវិតក្កថា ភ័យនឹងកើតឡើងដល់អញអំពីមនុស្ស ឬម្រឹគដែលអង្រួនមែកឈើក្នុងកាលនោះ នេះបានមកប្រាកដដល់អញហើយ ។

បន្ទាប់អំពីនោះ រាជកុមារក៏បានត្រាស់គាថាចុងក្រោយថា

> អ្នកបានដឹងពិតដូច្នោះមែន ព្រោះអ្នកបានសម្លាប់នូវបិតារបស់
> ខ្ញុំ បិទបាំងដោយមែកឈើទាំងឡាយ លាក់លៀមដោយគិត
> ថា ( ភ័យនឹងមានមកដល់អ្នក ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តថេវ តុំ អវេទសិ** សេចក្តីថា អ្នកបានដឹងហើយយ៉ាងនោះដូចគ្នា ។ បទថា **អវធិ បិតរំ មម** សេចក្តីថា អ្នកលួងលោមចិត្តរបស់បិតាយើងថា ពួកយើងទៅងូតទឹក ហើយផ្តាច់ព្រះជន្មទ្រង់ដែលកំពុងស្រង់ទឹក កាប់ឲ្យជាកំណាត់តូចធំ កប់ទុកត្រង់ប្រាំងហើយ ដោយគិតថា បើនរណាដឹងសោត ភ័យបែបនេះនឹងមកដល់ខ្លួនអញ តែភ័យ គឺសេចក្តីស្លាប់នេះ ឥឡូវនេះ បានមកដល់ខ្លួនអ្នកហើយ ។

ព្រះរាជកុមារកាលត្រាស់ដូចពោលមកហើយនេះ ក៏ឲ្យទាសៈបរន្តបៈដល់នូវការអស់ជីវិតក្នុងទីនោះឯង ហើយកប់យកមែកឈើគ្របទុក ទ្រង់លាងព្រះខ័ន ទ្រង់ស្រង់ទឹកហើយ យាងទៅកាន់បណ្ណសាលា ប្រាប់បុរោហិតនោះដល់ការៈដែលខ្លួនបានសម្លាប់ហើយ ទើបទ្រង់តវ៉ានឹងព្រះមាតា ជនទាំង ៣ ប្រឹក្សាគ្នាថា ពួកយើងនៅធ្វើអ្វីក្នុងទីនេះ ហើយទើបនាំគ្នាទៅកាន់នគរពារាណសីនោះឯង ។ ព្រះពោធិសត្វទ្រង់ប្រទានតំណែងឧបរាជ ដល់ប្អូនប្រុសហើយបំពេញបុណ្យមានទានជាដើមធ្វើស្ថានសួគ៌ឲ្យពេញបរិបូណ៌ ។

ព្រះសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតកថា ព្រះរាជាដែលជាបិតាក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ បុរោហិតក្នុងកាលនោះ បានមកជាអានន្ទ ឯព្រះរាជបុត្តក្នុងកាលនោះ គឺតថាគតនេះឯង ។

**អដ្ឋកថាបរន្តបជាតក ចប់**

**គន្ធារវគ្គ ចប់**

**សត្តកនិបាត ចប់**

# ក្បាលទី ៤៧

# សុត្តន្តបិដក បាលីប្រែ -៥៨

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ចុល្លកាលិង្គជាតក | ២ |
| អដ្ឋកថា ចុល្លកាលិង្គជាតក | ៣ |
| មហាអស្សារោហជាតក | ១៦ |
| អដ្ឋកថា មហាអស្សារោហជាតក | ១៧ |
| ឯករាជជាតក | ២៦ |
| អដ្ឋកថា ឯករាជជាតក | ២៧ |
| ទទ្ទរជាតក | ៣២ |
| អដ្ឋកថា ទទ្ទរជាតក | ៣៣ |
| សីលវីមំសជាតក | ៣៨ |
| អដ្ឋកថា សីលវីមំសជាតក | ៣៩ |
| សុជាតាជាតក | ៤៥ |
| អដ្ឋកថា សុជាតាជាតក | ៤៦ |
| បលាសជាតក | ៥២ |
| អដ្ឋកថា បលាសជាតក | ៥៣ |
| ជវសកុណជាតក | ៥៨ |
| អដ្ឋកថា ជវសកុណជាតក | ៥៩ |
| ឆវជាតក | ៦២ |
| អដ្ឋកថា ឆវជាតក | ៦៣ |

សយ្ហជាតក .......... .......... .......... .......... .................. ៦៩

អដ្ឋកថា សេយ្ហជាតក .......... .......... .......... .......... ................. ៧០

## បុចិមន្ទវគ្គ

បុចិមន្ទជាតក .......... .......... .......... .......... .................. ៧៥

អដ្ឋកថា បុចិមន្ទជាតក .......... .......... .......... .......... .................. ៧៦

កស្សបមន្ទិយជាតក .......... .......... .......... .......... .................. ៨១

អដ្ឋកថា កស្សបមន្ទិយជាតក .......... .......... .......... .......... .................. ៨២

ខន្តិវាទិជាតក .......... .......... .......... .......... .................. ៨៨

អដ្ឋកថា ខន្តិវាទិជាតក .......... .......... .......... .......... .................. ៨៨

លោហកុម្ភិជាតក .......... .......... .......... .......... .................. ៩៦

អដ្ឋកថា លោហកុម្ភិជាតក .......... .......... .......... .......... .................. ៩៧

មំសជាតក .......... .......... .......... .......... .............. ១០៦

អដ្ឋកថា មំសជាតក .......... .......... .......... .......... ............. ១០៧

សសបណ្ឌិតជាតក .......... .......... .......... .......... .............. ១១២

អដ្ឋកថា សសបណ្ឌិតជាតក .......... .......... .......... .......... .............. ១១៣

មតភោទនជាតក .......... .......... .......... .......... .............. ១២១

អដ្ឋកថា មតភោទនជាតក .......... .......... .......... .......... ............. ១២២

កណវេរជាតក .......... .......... .......... .......... ............. ១២៧

អដ្ឋកថា កណវេរជាតក .......... .......... .......... .......... ............. ១២៨

តិត្តិរជាតក .......... .......... .......... .......... .............. ១៣៦

អដ្ឋកថា តិត្តិរជាតក .......... .......... .......... .......... .............. ១៣៧

សុចជជាតក .......... .......... .......... .......... .............. ១៤២

អដ្ឋកថា សុចជជាតក .......... .......... .......... .......... ................ ១៤៣

# កុដិទូសកវគ្គ


កុដិទូសកជាតក .......... .......... .......... .......... ................ ១៥១

អដ្ឋកថា កុដិទូសកជាតក .......... .......... .......... .......... ................ ១៥១

ទុទ្ទុភាយជាតក .......... .......... .......... .......... ................ ១៥៩

អដ្ឋកថា ទុទ្ទុភាយជាតក ........ .......... .......... .......... .......... ... ១៥៩

ព្រហ្មទត្តជាតក .......... .......... .......... .......... ................ ១៦៧

អដ្ឋកថា ព្រហ្មទត្តជាតក .......... .......... .......... .......... ................ ១៦៨

ចម្មសាដកជាតក .......... .......... .......... .......... ................ ១៧៤

អដ្ឋកថា ចម្មសាដកជាតក .......... .......... .......... .......... ................ ១៧៥

គោធជាតក .......... .......... .......... .......... ................. ១៧៩

អដ្ឋកថា គោធជាតក .......... .......... .......... .......... ................ ១៨០

កក្ការុជាតក .......... .......... .......... .......... ................. ១៨៤

អដ្ឋកថា កក្ការុជាតក .......... .......... .......... .......... ................ ១៨៤

កាកាតិជាតក .......... .......... .......... .......... ................. ១៩១

អដ្ឋកថា កាកាតិជាតក .......... .......... .......... .......... ............... ១៩២

អនទុសោចិយជាតក .......... .......... .......... .......... ................ ១៩៦

អដ្ឋកថា អនទុសោចិយជាតក .......... .......... .......... .......... ................ ១៩៧

កាឡពាហុជាតក .......... .......... .......... .......... ............... ២០៥

អដ្ឋកថា កាឡពាហុជាតក .......... .......... .......... .......... ............... ២០៦

សីលវីមំសជាតក .......... .......... .......... .......... ............... ២១១

អដ្ឋកថា សីលវីមំសជាតក .......... .......... .......... .......... ............... ២១៣


# កោកិលវគ្គ


កោកាលិកជាតក .......... .......... .......... .......... .......... ........... ២១៧

អដ្ឋកថា កោកាលិកជាតក ...... .......... .......... .......... .......... .......... ២១៧
វេលដ្ឋិជាតក .......... .......... .......... .......... .......... .......... ២២២
អដ្ឋកថា វេលដ្ឋិជាតក .......... .......... .......... .......... .......... ......... ២២៣
គោធជាតក .......... .......... .......... .......... .......... .......... ២២៧
អដ្ឋកថា គោធជាតក .......... .......... .......... .......... .......... ......... ២២៨
ភោជាភិទជាតក .......... .......... .......... .......... .......... ......... ២៣៤
អដ្ឋកថា ភោជាភិទជាតក .......... .......... .......... .......... .......... ......... ២៣៥
ជម្ពុកជាតក .......... .......... .......... .......... .......... .......... ២៤០
អដ្ឋកថា ជម្ពុកជាតក .......... .......... .......... .......... .......... .......... ២៤១
ព្រហាធត្តជាតក .......... .......... .......... .......... .......... .......... ២៤៦
អដ្ឋកថា ព្រហាធត្តជាតក .......... .......... .......... .......... .......... .......... ២៤៧
បីឋជាតក .......... .......... .......... .......... .......... .......... ២៥៤
អដ្ឋកថា បីឋជាតក .......... .......... .......... .......... .......... .......... ២៥៥
ថុសជាតក .......... .......... .......... .......... .......... .......... ២៦០
អដ្ឋកថា ថុសជាតក .......... .......... .......... .......... .......... .......... ២៦០
ពាវេរុជាតក .......... .......... .......... .......... .......... ............ ២៦៩
អដ្ឋកថា ពាវេរុជាតក .......... .......... .......... .......... .......... ............ ២៦៩
វិសយ្ហជាតក .......... .......... .......... .......... .......... .......... ២៧៤
អដ្ឋកថា វិសយ្ហជាតក .......... .......... .......... .......... .......... .......... ២៧៦

## ចុល្លកុណាលវគ្គ

កុណ្ឌលិកជាតក .......... .......... .......... .......... .......... .......... ២៨២
អដ្ឋកថា កណ្ឌលិជាតក .......... .......... .......... .......... .......... ......... ២៨៣
ភានរជាតក .......... .......... .......... .......... .......... ......... ២៨៤

អដ្ឋកថា វានរជាតក .......... .......... .......... .......... .......... ......... ២៨៤
កុន្តិនីជាតក .......... .......... .......... .......... .......... ........ ២៨៨
អដ្ឋកថា កុន្តិនីជាតក .......... .......... .......... .......... .......... ........ ២៨៩
អម្ពជាតក .......... .......... .......... .......... .......... ........ ២៩៤
អដ្ឋកថា អម្ពជាតក .......... .......... .......... .......... .......... ........ ២៩៤
គជកុម្ភជាតក .......... .......... .......... .......... .......... ....... ៣០០
អដ្ឋកថា គជកុម្ភជាតក .......... .......... .......... .......... .......... ....... ៣០១
កេសវជាតក .......... .......... .......... .......... .......... ........ ៣០៥
អដ្ឋកថា កេសវជាតក .......... .......... .......... .......... .......... ........ ៣០៦
អយកូដជាតក .......... .......... .......... .......... .......... ........ ៣១៤
អដ្ឋកថា អយកូដជាតក ......... .......... .......... .......... .......... ......... ៣១៥
អរញ្ញជាតក .......... .......... .......... .......... .......... ......... ៣១៩
អដ្ឋកថា អរញ្ញជាតក .......... .......... .......... .......... .......... ......... ៣២០
សន្ធិភេទជាតក .......... .......... .......... .......... .......... .......... ៣២៤
អដ្ឋកថា សន្ធិភេទជាតក .......... .......... .......... .......... .......... .......... ៣២៥
ទេវតាបញ្ហជាតក .......... .......... .......... .......... .......... ......... ៣៣០
អដ្ឋកថា ទេវតាបញ្ហជាតក .......... .......... .......... .......... .......... ........ ៣៣២

## សុត្តន្តបិដក ចាលីប្រែ -៥៩

## មណិកុណ្ឌលវគ្គ

មណិកុណ្ឌលជាតក .......... .......... .......... .......... .......... ..... ៣៣៣
អដ្ឋកថា មណិកុណ្ឌលជាតក .......... .......... .......... .......... .......... ..... ៣៣៥
សុជាតជាតក .......... .......... .......... .......... .......... ..... ៣៣៩
អដ្ឋកថា សុជាតជាតក .......... .......... .......... .......... .......... ..... ៣៤០

វេនសាខជាតក .......... .......... .......... .......... .......... ..... ៣៤៥

អដ្ឋកថា វេនសាខជាតក .......... .......... .......... .......... .......... .... ៣៤៦

ឧរគជាតក .......... .......... .......... .......... .......... ....... ៣៥៣

អដ្ឋកថា ឧរគជាតក .......... .......... .......... .......... .......... ....... ៣៥៤

ធង្កជាតក .......... .......... .......... .......... .......... ...... ៣៦៥

អដ្ឋកថា ធង្កជាតក .......... .......... .......... .......... .......... ....... ៣៦៦

ការន្ទិយជាតក .......... .......... .......... .......... .......... ...... ៣៧១

អដ្ឋកថា ការន្ទិយជាតក .......... .......... .......... .......... .......... ..... ៣៧២

លដុកិកជាតក .......... .......... .......... .......... .......... ...... ៣៧៨

អដ្ឋកថា លដុកិកជាតក .......... .......... .......... .......... .......... ..... ៣៧៩

ចុល្លធម្មបាលជាតក .......... .......... .......... .......... .......... ..... ៣៨៥

អដ្ឋកថា ចុល្លធម្មបាលជាតក ......... .......... .......... .......... .......... ..... ៣៨៦

សុវណ្ណមិគជាតក .......... .......... .......... .......... .......... ...... ៣៩៤

អដ្ឋកថា សុវណ្ណមិគជាតក .......... .......... .......... .......... .......... ...... ៣៩៥

សុសន្ធីជាតក .......... .......... .......... .......... .......... ..... ៤០៤

អដ្ឋកថា សុសន្ធីជាតក .......... .......... .......... .......... .......... .... ៤០៦


## វណ្ណារោហវគ្គ


វណ្ណារោហជាតក .......... .......... .......... .......... .......... ......... ៤១២

អដ្ឋកថា វណ្ណារោហជាតក .......... .......... .......... .......... .......... ......... ៤១៣

សីលវីមំសជាតក .......... .......... .......... .......... .......... ......... ៤១៨

អដ្ឋកថា សីលវីមំសជាតក .......... .......... .......... .......... .......... ......... ៤១៩

ហិរិជាតក .......... .......... .......... .......... .......... ......... ៤២៤

អដ្ឋកថា ហិរិជាតក .......... .......... .......... .......... .......... ......... ៤២៥

ខជ្ជោបនកជាតក .......... .......... .......... .......... .......... .......... ៤២៩

អដ្ឋកថា ខជ្ជោបនកជាតក .......... .......... .......... .......... .......... .......... ៤៣០

អហិតុណ្ឌិកជាតក .......... .......... .......... .......... .......... .......... ៤៣១

អដ្ឋកថា អហិតុណ្ឌិកជាតក .......... .......... .......... .......... .......... .......... ៤៣២

គុម្ពិយជាតក .......... .......... .......... .......... .......... .......... ៤៣៦

អដ្ឋកថា គុម្ពិយជាតក .......... .......... .......... .......... .......... .......... ៤៣៧

សាលិយជាតក .......... .......... .......... .......... .......... .......... ៤៤២

អដ្ឋកថា សាលិយជាតក .......... .......... .......... .......... .......... .......... ៤៤៣

តចសារជាតក .......... .......... .......... .......... .......... .......... ៤៤៦

អដ្ឋកថា តចសារជាតក .......... .......... .......... .......... .......... .......... ៤៤៧

មិត្តវិន្ទុកជាតក .......... .......... .......... .......... .......... .......... ៤៥២

អដ្ឋកថា មិត្តវិន្ទុកជាតក .......... .......... .......... .......... .......... .......... ៤៥៣

បលាសជាតក .......... .......... .......... .......... .......... .......... ៤៥៧

អដ្ឋកថា បលាសជាតក .......... .......... .......... .......... .......... .......... ៤៥៨

## អឌ្ឍវគ្គ

ទីឃីតិកោសលជាតក .......... .......... .......... .......... .......... .......... ៤៦៣

អដ្ឋកថា ទីឃីតិកោសលជាតក .......... .......... .......... .......... ............... ៤៦៤

មិគបោតកជាតក .......... .......... .......... .......... ............... ៤៦៩

អដ្ឋកថា មិគបោតកជាតក .......... .......... .......... .......... ............... ៤៧០

មូសិកជាតក .......... .......... .......... .......... ............... ៤៧៥

អដ្ឋកថា មូសិកជាតក .......... .......... .......... .......... ............... ៤៧៦

ចុល្លធនុគ្គហជាតក .......... .......... .......... .......... ............... ៤៨៤

អដ្ឋកថា ចុល្លធនុគ្គហជាតក .......... .......... .......... .......... ............... ៤៨៥

កបោតកជាតក .......... .......... .......... .......... ............... ៤៩៤

អដ្ឋកថា កបោតកជាតក .......... .......... .......... .......... ............... ៤៩៦

# ឆក្កនិបាត

## អាចារិយវគ្គ

អាចារិយជាតក .......... .......... .......... .......... ................. ៥០១

អដ្ឋកថា អាចារិយជាតក .......... .......... .......... .......... ................ ៥០៣

សេតកេតុជាតក .......... .......... .......... .......... ............... ៥១១

អដ្ឋកថា សេតកេតុជាតក .......... .......... .......... .......... ............... ៥១២

ទរីមុខជាតក .......... .......... .......... .......... ................ ៥២២

អដ្ឋកថា ទរីមុខជាតក .......... .......... .......... .......... ................ ៥២៣

នេរុជាតក .......... .......... .......... .......... ............... ៥៤០

អដ្ឋកថា នេរុជាតក .......... .......... .......... .......... ............... ៥៤១

អាសង្កជាតក .......... .......... .......... .......... ............... ៥៤៥

អដ្ឋកថា អាសង្កជាតក .......... .......... .......... .......... ............... ៥៤៦

មិគលោបជាតក .......... .......... .......... .......... ............... ៥៥៧

អដ្ឋកថា មិគលោបជាតក .......... .......... .......... .......... ............... ៥៥៨

សិរិកាឡកណ្ណិជាតក .......... .......... .......... .......... ............... ៥៦២

អដ្ឋកថា សិរិកាឡកណ្ណិជាតក .......... .......... .......... .......... ............... ៥៦៥

កុក្កុដជាតក .......... .......... .......... .......... ............... ៥៨១

អដ្ឋកថា កុក្កុដជាតក .......... .......... .......... .......... ............... ៥៨២

ធម្មទ្ធជជាតក .......... .......... .......... .......... ............... ៥៨៧

អដ្ឋកថា ធម្មទ្ធជជាតក .......... .......... .......... .......... ............... ៥៨៨

នន្ទិយមិគរាជជាតក .......... .......... .......... .......... ............... ៥៩៤

អដ្ឋកថា នន្ទិយមិគរាជជាតក .......... .......... .......... .......... ................ ៥៩៦

# ខុរបុត្តវគ្គ

ខុរបុត្តជាតក .......... .......... .......... .......... ................ ៦០៤
អដ្ឋកថា ខុរបុត្តជាតក .......... .......... .......... .......... ................ ៦០៥
សុចិជាតក .......... .......... .......... .......... ................ ៦១៦
អដ្ឋកថា សុចិជាតក .......... .......... .......... .......... ................ ៦១៧
តុណ្ឌិលជាតក .......... .......... .......... .......... ................ ៦២៥
អដ្ឋកថា តុណ្ឌិលជាតក .......... .......... .......... .......... ................ ៦២៦
សុវណ្ណកក្កដកជាតក .......... .......... .......... .......... ................ ៦៣៩
អដ្ឋកថា សុវណ្ណកក្កដកជាតក .......... .......... .......... .......... ................ ៦៤០
មយ្ហកសកុណជាតក .......... .......... .......... .......... ................ ៦៤៩
អដ្ឋកថា មយ្ហកសកុណជាតក ....... .......... .......... .......... ................ ៦៥០
បព្វជិតវិហេឋកជាតក .......... .......... .......... .......... ................ ៦៥៩
អដ្ឋកថា បព្វជិវិហេឋកជាតក .......... .......... .......... ................ ៦៦០
ឧបសិឡ្ហបុប្ផជាតក .......... .......... .......... .......... ............. ៦៦៨
អដ្ឋកថា ឧបសិឡ្ហបុប្ផជាតក ................ .......... .......... ............ ៦៦៩
វិឃាសាទជាតក .......... .......... .......... .......... ............. ៦៧៤
អដ្ឋកថា វិឃាសាទជាតក .......... .......... .......... .......... ............. ៦៧៥
វដ្តកជាតក .......... .......... .......... .......... ............. ៦៨០
អដ្ឋកថា វដ្តកជាតក .......... .......... .......... .......... ............. ៦៨១
មណិជាតក .......... .......... .......... .......... ............. ៦៨៦
អដ្ឋកថា មណិជាតក .......... .......... .......... .......... ............ ៦៨៨

# សត្តកនិបាត

## កុក្កុវគ្គ


កុក្កុជាតក .......... .......... .......... .......... ............. ៦៩២

អដ្ឋកថា កុក្កុជាតក .......... .......... .......... .......... .............. ៦៩៤

មនោជជាតក .......... .......... .......... .......... ............. ៧០២

អដ្ឋកថា មនោជជាតក .......... .......... .......... .......... ............. ៧០៣

សុតនជាតក .......... .......... .......... .......... ............ ៧១០

អដ្ឋកថា សុតនជាតក .......... .......... .......... .......... ............ ៧១១

មាតុបោសកគិជ្ឈជាតក .......... .......... .......... .......... ............ ៧២១

អដ្ឋកថា មាតុបោសកគិជ្ឈជាតក .......... .......... .......... .......... ............ ៧២២

ទព្វបុប្ផជាតក .......... .......... .......... .......... ............ ៧២៦

អដ្ឋកថា ទព្វបុប្ផជាតក .......... .......... .......... .......... ............ ៧២៨

ទសណ្ណកជាតក .......... .......... .......... .......... ............ ៧៣៧

អដ្ឋកថា ទសណ្ណកជាតក ...... .......... .......... .......... ........... ៧៣៩

សេនកជាតក .......... .......... .......... .......... .......... .......... ៧៤៩

អដ្ឋកថា សេនកជាតក .......... .......... .......... .......... .......... ......... ៧៥១

អដ្ឋិសេនជាតក .......... .......... .......... .......... .......... .......... ៧៦៧

អដ្ឋកថា អដ្ឋិសេនជាតក .......... .......... .......... .......... .......... .......... ៧៦៨

កបិជាតក .......... .......... .......... .......... .......... .......... ៧៧៧

អដ្ឋកថា កបិជាតក ......... .......... .......... .......... .......... .......... ៧៧៨

ពកព្រហ្មជាតក .......... .......... .......... .......... .......... .......... ៧៨៤

អដ្ឋកថា ពកព្រហ្មជាតក ............. .......... .......... .......... ........ ៧៨៦

គន្ធារជាតក .......... ......... .......... .......... .......... ........... ៧៩៧

# គន្ធារវគ្គ


អដ្ឋកថា គន្ធារជាតក .......... .......... .......... .......... .......... .......... ៧៩៩
មហាកបិជាតក .......... .......... .......... .......... .......... .......... ៨១១
អដ្ឋកថា មហាកបិជាតក .......... .......... .......... .......... .......... .......... ៨១២
កុម្ភការជាតក .......... .......... .......... .......... .......... .......... ៨២២
អដ្ឋកថា កុម្ភការជាតក .......... .......... .......... .......... .......... .......... ៨២៤
ទឡ្ហធម្មជាតក .......... .......... .......... .......... .......... ........... ៨៣៩
អដ្ឋកថា ទឡ្ហធម្មជាតក .......... .......... .......... .......... .......... ........... ៨៤០
សោមទត្តជាតក .......... .......... .......... .......... .......... ........... ៨៥០
អដ្ឋកថា សោមទត្តជាតក .......... .......... .......... .......... .......... .......... ៨៥១
សុសីមជាតក .......... .......... .......... .......... .......... .......... ៨៥៧
អដ្ឋកថា សុសីមជាតក .......... .......... .......... .......... .......... .......... ៨៥៨
កោដសិម្ពលិជាតក .......... .......... .......... .......... .......... ........... ៨៧០
អដ្ឋកថា កោដសិម្ពលិជាតក .......... .......... .......... .......... .......... ...... ៨៧១
ធូមការិជាតក .......... .......... .......... .......... .......... ....... ៨៧៧
អដ្ឋកថា ធូមការិជាតក .......... .......... .......... .......... .......... ....... ៨៧៨
ជាគរជាតក .......... .......... .......... .......... .......... ....... ៨៨៥
អដ្ឋកថា ជាគរជាតក .......... .......... .......... .......... .......... ........... ៨៨៦
កុម្មាសបិណ្ឌជាតក .......... .......... .......... .......... .......... ....... ៨៩២
អដ្ឋកថា កុម្មាសបិណ្ឌជាតក .......... .......... .......... .......... .......... ....... ៨៩៤
បរន្តបជាតក .......... .......... .......... .......... .......... ....... ៩១៤
អដ្ឋកថា បរន្តបជាតក .......... .......... .......... .......... .......... ....... ៩១៦